ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល

Supreme Court Chamber

Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Apr-2012, 14:01
CMS/CFO: Sann Rada

សំណុំរឿងលេខៈ ០០១/១៨ កក្កដា ២០០៧/អ.វ.ត.ក/អ.ជ.ត.ក

**Case File/Dossier No. 001/18-07-2007/ECCC/SC**

| | |
|---|---|
| ចំពោះមុខ | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម** Motoo NOGUCHI |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម** Agnieszka KLONOWIECKA-MILART |
| | **ចៅក្រម ស៊ិន រិទ្ធ** |
| | **ចៅក្រម** Chandra Nihal YASINGHE |
| | **ចៅក្រម យ៉ា ណារិន** |
| **ក្រឡាបញ្ជីសវនាការ** | ស៊ា ម៉ៅ |
| | **Christopher RYAN** |
| | ផន ធឿន |
| | **Paolo LOBBA** |
| **កាលបរិច្ឆេទសវនាការ** | ចាប់ផ្តើមថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ និងបញ្ចប់កិច្ចពិភាក្សាដេញដោល ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១ |
| **កាលបរិច្ឆេទប្រកាសសាលដីកា** | ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ |
| **ភាសាដើម** | ភាសាខ្មែរ/ភាសាអង់គ្លេស |
| **ចំណាត់ថ្នាក់ឯកសារ** | សាធារណៈ |

---

# សាលដីកា

---

00798307

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F28

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ *ហៅ* "**ឌុច**"

**មេធាវីការពារក្តីជនជាប់ចោទ**

ការ សាវុត្ថ

កង ឫទ្ធារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១**

ទី ស្រ៊ីនណា

Karim KHAN
Alain WERNER
Brianne McGONIGLE

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២**

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

Silke STUDZINSKY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣**

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN
Annie DELAHAIE
Philippe CANONNE
Elizabeth RABESANDRATANA
Fabienne TRUSSES-NAPROUS
Christine MARTINEAU

00798308



# មាតិកា

**១.សេចក្តីផ្តើម** ........................................ 10

១.ក.សាវតា ........................................ 10

១.ខ.ប្រវត្តិនីតិវិធី ........................................ 11

**២.បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ** ........................................ 17

**៣.កំហុសដែលបានលើកឡើងទាក់ទងទៅនឹងយុត្តាធិការលើរូបបុគ្គល (ចន្លោះករណីទី ១ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី)** ........................................ 27

៣.ក.យុត្តាធិការលើរូបបុគ្គលនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ........................................ 27

៣.ក.១.សារណារបស់ភាគី ........................................ 29

៣.ក.២.ការពិចារណា ........................................ 32

៣.ក.៣.អញ្ញត្រកម្មតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ........................................ 32

៣.ក.៤.បទដ្ឋាននៃសារណាបណ្តឹងសាទុក្ខ ........................................ 42

៣.ក.៥.យុត្តាធិការលើរូបបុគ្គល ........................................ 46

៣.ក.៥.ក.វិសាលភាពនៃពាក្យថា"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ........................................ 47

៣.ក.៥.ខ.ការវាយតម្លៃពាក្យ"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ........................................ 56

៣.ក.៥.ខ.១.កម្មាភិបាលខ្មែរក្រហម ........................................ 58

៣.ក.៥.ខ.២.អ្នកទទួលខុសត្រូវខ្ពស់បំផុត ........................................ 59

៣.ក.៥.ខ.៣.មេដឹកនាំជាន់ខ្ពស់ ........................................ 69

៣.ក.៥.ខ.៤.សេចក្តីសង្ខេបនៃសំអាងហេតុ ........................................ 71

៣.ក.៥.ខ.៥.ការពិនិត្យឡើងវិញលើឆន្ទានុសិទ្ធិនៃការស៊ើបអង្កេត និងការចោទប្រកាន់ដោយផ្អែកលើមូលដ្ឋានផ្សេងទៀត ........................................ 72

៣.ក.៥.គ.សេចក្តីសន្និដ្ឋាន ........................................ 75

**៤.កំហុសដែលបានលើកឡើងទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ទឡ្ហីករណ៍ទី ២ និងទី ៣ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា)** ....76

៤.ក.គោលការណ៍នីត្យានុកូលភាព ....79

៤.ខ.ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាឧក្រិដ្ឋកម្មអន្តរជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩....88

៤.គ.ការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ (ទឡ្ហីករណ៍ទី ៣ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា)....104

៤.គ.១.ការកំណត់និយមន័យនៃការធ្វើឱ្យទៅជាទាសកររបស់អង្គជំនុំជម្រះសាលាដំបូង....109

៤.គ.២.ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ និងអំពើធ្វើឱ្យទៅជាទាសករ....135

៤.គ.៣.សេចក្តីសន្និដ្ឋាន....139

៤.ឃ.ការរំលោភលើផ្លូវភេទ គឺជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ (ទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា) ..140

៤.ឃ.១. ការរំលោភលើផ្លូវភេទ គឺជាបទឧក្រិដ្ឋមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ....143

៤.ឃ.២.ការរំលោភលើផ្លូវភេទ គឺជាអំពើធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ...153

៤.ឃ.៣.សេចក្តីសន្និដ្ឋាន....171

៤.ង.ការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩....173

៤.ង.១.អត្ថិភាពនៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ....173

៤.ង.២.និយមន័យនៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ....182

៤.ង.២.ក.ធាតុផ្សំអត្តនោម័ត ....189

៤.ង.២.ខ.ធាតុផ្សំសត្យានុម័ត....195

៤.ង.២.ខ.១.អំពើសកម្ម ឬអកម្មដែលដកហូត ឬរំលោភទៅលើសិទ្ធិសារវន្ត ដែលមានចែងនៅក្នុងច្បាប់សន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ ....196

៤.ង.២.ខ.២.អំពើសកម្ម ឬអកម្មដែលមានការរើសអើងជាក់ស្តែង ..... 217

៤.ង.២.គ.សេចក្តីសន្និដ្ឋាន ..... 228

៤.ង.៣.ភាពអាចយល់ដឹង និងភាពអាចដឹងជាមុនថា អំពីធ្វើទុក្ខបុកម្នេញគឺជាបទល្មើសនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ..... 228

៤.ង.៤.ការយល់ឃើញអំពីអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការធ្វើទុក្ខបុកម្នេញលើអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ..... 230

៤.ច.ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ..... 233

៤.ច.១.លក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *ČELEBIĆI* ..... 236

៤.ច.២.បទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយយោងតាមលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *ČELEBIĆI* ..... 252

៤.ច.២.ក.យុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ ..... 256

៤.ច.២.ខ.ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នានៅក្នុងរឿងក្តីនេះ ..... 264

៤.ច.៣.សេចក្តីសន្និដ្ឋាន ..... 278

**៥.កំហុសដែលបានលើកឡើងទាក់ទងនៅនឹងការប្រកាសទោស (ចំណុចឧទ្ធរណ៍ ទី ២ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី និងចំណុចឧទ្ធរណ៍ទី ១ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា) ..... 280**

៥.ក.ចំណុចឧទ្ធរណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ..... 280

៥.ក.១.ច្បាប់ជាធរមានទាក់ទងទៅនឹងរបបនៃការប្រកាសទោស ..... 284

៥.ក.២.សេចក្តីសន្និដ្ឋាន ..... 288

៥.ខ.បទដ្ឋាននៃការពិនិត្យឡើងវិញស្តីពីរបបនៃការប្រកាសទោស ..... 288

៥.គ.ចំណុចឧទ្ធរណ៍ទី ១ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ..... 290

៥.គ.១.សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការប្រកាសទោស ..... 293

៥.គ.២.ការប្រកាសទោសដែលត្រូវកែប្រែដោយអង្គជំនុំជម្រះតុលាការកំពូល ..... 303

៥.គ.៣.ការដោះលែងដោយមានលក្ខខណ្ឌ ..... 314

៥.គ.៤.ការឃុំខ្លួននៅចំពោះមុខតុលាការយោធាកម្ពុជា ..... 317

៥.គ.៥.ការគិតបញ្ចូលនូវថិរវេលានៃការឃុំខ្លួនមុនដំណាក់កាលជំនុំជម្រះ ..... 324

៥.ឃ.សេចក្ដីសន្និដ្ឋាន ........................................................................327

**៦.កំហុសដែលបានលើកឡើងទាក់ទងទៅនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១, ២ និង ៣)**........................................................................328

៦.ក.ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការបង្កើតសញ្ញាណថ្មីនៃជនរងគ្រោះ ........................................................................328

៦.ក.១.សារណា ........................................................................328

៦.ក.២.សញ្ញាណនៃដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ........................................................................330

៦.ក.៣.ការកំណត់និយមន័យឡើងវិញលើដើមបណ្ដឹងរដ្ឋប្បវេណី ឬការសន្មតទុកជាមុន..........345

៦.ក.៤.ការសន្មតទុកជាមុនតាមផ្លូវច្បាប់ ឬតាមឆន្ទានុសិទ្ធិ ........................................................................349

៦.ក.៥.ការវាយតម្លៃទៅលើការសន្មតទុកជាមុនដែលអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង .....370

៦.ខ.ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការអនុវត្តបទដ្ឋាននៃការពិនិត្យឡើងវិញចំពោះភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាពីរដំណាក់កាល ........................................................................374

៦.ខ.១.សារណា ........................................................................374

៦.ខ.២.សាវតានីតិវិធី ........................................................................378

៦.ខ.៣.ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ........................................................................379

៦.ខ.៤.ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង........................................................................381

៦.ខ.៥.ច្បាប់ជាធរមាន ........................................................................387

៦.ខ.៥.ក.ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ .... 387

៦.ខ.៥.ខ.ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្របខណ្ឌ អ.វ.ត.ក .................... 390

៦.ខ.៥.គ.ការអនុវត្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ........................................................................394

៦.ខ.៦.ការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ........................................................................403

៦.គ.ថាតើអង្គជំនុំជម្រះសាលាដំបូងអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងត្រឹមត្រូវ ដែរ ឬយ៉ាងណា ក្នុងការសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម ....... 416

៦.គ.១.សារណា....... 416

៦.គ.២.សាលក្រមអង្គជំនុំជម្រះសាលាដំបូង....... 420

៦.គ.៣.ច្បាប់ដែលត្រូវយកមកអនុវត្ត....... 423

៦.គ.៣.ក.វិធានស្តីពីនីតិវិធីដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ....... 426

៦.គ.៣.ក.១.តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការ ICC") និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ ("តុលាការ STL")....... 426

៦.គ.៣.ក.២.តុលាការថ្នាក់តំបន់ស្តីពីសិទ្ធិមនុស្ស....... 431

៦.គ.៣.ក.៣.កម្មវិធីទាមទារសំណង ....... 437

៦.គ.៤.ការពិចារណា ....... 440

៦.ឃ.ការទទួលយកពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី....... 451

៦.ឃ.១.ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ **(E2/61, E2/62, E2/69, E2/73, E2/74, E2/75, E2/86, E2/88, D25/15)** ....... 453

៦.ឃ.២.ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ **(E2/32, E2/35, E2/83, E2/22, E2/64)**....... 467

៦.ឃ.៣.ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ **(E2/23, E2/33, E2/34, E2/63, E2/70, E2/71, E2/82, D25/11)**....... 478

៦.ឃ.៤.បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ ស៊ីរ៉ាត....... 494

**៧.កំហុសដែលបានលើកឡើងទាក់ទងនៅនឹងសំណើទាមទារសំណង (បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និង ៣)** ....... 497

៧.ក.សេចក្តីបង្គាប់ដែលស្នើសុំដោយម្ចាស់បណ្តឹងសាទុក្ខ ....... 497

៧.ខ.អំណះអំណាងទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី....... 498

៧.ខ.១.សារណា....... 499

៧.ខ.២.ការពិចារណា....... 501

៧.ខ.២.ក.សំណងរដ្ឋប្បវេណីនៅក្នុងក្របខណ្ឌច្បាប់ អ.វ.ត.ក ....... 501

៧.ខ.២.ខ.ថាតើ អ.វ.ត.ក អាចចេញដីកាបង្គាប់ឱ្យសងសំណងដែលការអនុវត្តដីកាបង្គាប់នេះអាចតម្រូវឱ្យមានជំនួយផ្នែករដ្ឋបាលរបស់រដ្ឋាភិបាល ដែរ ឬយ៉ាងណា ........................ 519

៧.ខ.២.គ.ថាតើភាពក្រីក្ររបស់ កាំង ហ្គេកអ៊ាវ ប៉ះពាល់ដល់អំណាចរបស់ អ.វ.ត.ក ចំពោះការសងសំណងដែលជាកាតព្វកិច្ចរបស់ កាំង ហ្គេកអ៊ាវ ដែរ ឬយ៉ាងណា ........................ 520

៧.ខ.២.ឃ.ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការដាក់សំណើទាមទារសំណងជាក្រុម ដោយមិនបានបង្ហាញច្បាស់លាស់អំពីសំអាងហេតុដល់ការបដិសេធលើសំណើនីមួយៗ ........................ 524

៧.ខ.២.ង.សំណើទាមទារសំណងជាក់លាក់របស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី. 526

៧.ខ.២.ង.១.ការចងក្រង និងផ្សព្វផ្សាយពាក្យសម្តីសុំអភ័យទោស និងការចងក្រងមតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី........................ 526

៧.ខ.២.ឃ.២.លិខិតសុំការអភ័យទោសពីរដ្ឋាភិបាល........................ 531

៧.ខ.២.ឃ.៣.ការសាងសង់បូជនីយដ្ឋាននៅទួលស្លែង និងជើងឯក និងការប្រែក្លាយព្រៃសឱ្យទៅជាកន្លែងបូជនីយដ្ឋាន........................ 534

៧.ខ.២.ឃ.៤.ការផ្តល់សោហ៊ុយដល់ដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ការធ្វើទស្សនកិច្ច នៅបូជនីយដ្ឋាននានា........................ 544

៧.ខ.២.ឃ.៥.ការផ្តល់នូវការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងសេវាចិត្តសាស្ត្រដល់ដើមបណ្តឹងរដ្ឋប្បវេណី........................ 545

៧.ខ.២.ឃ.៦.ការបង្កើត និងចែកចាយសម្ភារៈសោតទស្សន៍ស្តីពីសំណុំរឿង ០០១........................ 554

៧.ខ.២.ឃ.៧.ការយកឈ្មោះរបស់ជនរងគ្រោះចំនួន ១៧ រូប ដាក់ជាឈ្មោះអគារសាធារណៈ និងការប្រារព្ធពិធីបុណ្យផ្សេងៗដល់ជនរងគ្រោះ........................ 557

៧.ខ.២.ឃ.៨.ការសរសេរលិខិតជាចំហទៅកាន់រដ្ឋាភិបាល ដោយស្នើសុំថវិកាមួយផ្នែកដែលបានមកពីការចូលទស្សនាសារៈមន្ទីរត្រូវយកមកប្រើប្រាស់ជាការផ្តល់សំណង........ 559

៧.ខ.៣.សេចក្តីសន្និដ្ឋាន ........................ 560

**៨.ផ្នែកសម្រេចសេចក្តី**........................ 562

**៩.មតិជំទាស់រួមគ្នាលើផ្នែកខ្លះរបស់ចៅក្រម** AGNIESKA KLONOWIECKA-MILART **និងចៅក្រម** CHANDRA NIHAL JAYASINGE........................ 567

**១០.ឧបសម្ព័ន្ធ** I: **សាវតានីតិវិធីលើបណ្តឹងសាទុក្ខ** ........................ 593

ក.បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ........................ 593

ខ.បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ..................................... 594

គ.បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ..................................... 596

ឃ.បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ..................................... 598

ង.បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ..................................... 599

ច.ភស្តុតាងបន្ថែម ..................................... 599

ឆ.សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ..................................... 600

ជ.សវនាការបណ្តឹងសាទុក្ខ ..................................... 602

ឈ.ការប្រកាស និងការចេញសាលដីកា ..................................... 604

**១១.ឧបសម្ព័ន្ធ II: សន្ទានុក្រម និងតារាងអក្សរកាត់** ..................................... 605

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F28

# ១.សេចក្ដីផ្ដើម

១. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រេចចេញសាលដីការបស់ខ្លួន លើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង (សាលក្រមអង្គជំនុំជម្រះសាលាដំបូង) ដែលចេញនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ នៅក្នុងរឿងក្ដី *កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ត.ក[1]។

## ១.ក.សាវតា

២. បណ្ដឹងសាទុក្ខនេះលើកពីព្រឹត្តិការណ៍ ដែលបានកើតឡើងនៅក្នុងចន្លោះពីអំឡុង ខែ តុលា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ នៅមន្ទីរសន្ដិសុខ ស ២១ (មន្ទីរ ស ២១) ក្នុងទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា ដែលមន្ទីរសន្ដិសុខនេះទទួលបន្ទុកក្នុងការសួរចម្លើយ និងកាប់សម្លាប់ អ្នកដែលត្រូវបានសន្មតថា ប្រឆាំងនឹងបក្សកុម្មុយនីស្ដកម្ពុជា។ មន្ទីរ ស ២១ រួមមានមន្ទីរឃុំឃាំង និងបរិវេណជុំវិញ (ទួលស្លែង) ព្រមទាំងកន្លែងប្រមូលផ្ដុំសម្រាប់អប់រំ និងកាប់សម្លាប់ដែលស្ថិតនៅជាយក្រុងភ្នំពេញ ហៅថា ជើងឯក និងព្រៃ ស (ស ២៤)។ មានជនរងគ្រោះ ប្រុស ស្រី និងកុមារ មិនតិចជាង ១២.២៧២ នាក់ ដែលត្រូវបានកាប់សម្លាប់នៅមន្ទីរ ស ២១ ដែលជនរងគ្រោះភាគច្រើនទទួលរងនូវការធ្វើទារុណកម្មតាមលក្ខណៈជាប្រព័ន្ធ[2]។

៣. ជនជាប់ចោទ កាំង ហ្គេក អ៊ាវ *ហៅ* ឌុច ដែលអតីតជាគ្រូបង្រៀនគណិតវិទ្យា កើតនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ប្រទេស

---

[1]ឯកសារលេខ E188។ នៅក្នុងសវនាការសាធារណៈនៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានអាននូវសេចក្ដីសង្ខេប និងបានចុះហត្ថលេខាក្នុងផ្នែកសម្រេចសេចក្ដីនៃសាលដីការបស់ខ្លួន ហើយសាលដីកាសង្ខេបនេះត្រូវបានចេញផ្សាយនៅក្នុងថ្ងៃដដែលនេះផងដែរ។ ដូចដែលបានរៀបរាប់នៅក្នុងទំព័រ ៣៥ (ជាភាសាខ្មែរ) ក្នុងសាលដីកាសង្ខេបនេះ ថា"សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលបានចូលស្ថាពរ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២", ឯកសារលេខ F26/3។

[2]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១១១, ១១៩ និង ៥៩៧។

កម្ពុជា[3]។ ជនជាប់ចោទជាអនុលេខាមន្ទីរ ស ២១ ចាប់ពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៥ ដល់ខែ មីនា ឆ្នាំ ១៩៧៦ ហើយជាលេខាមន្ទីរ ស ២១ ចាប់ពីខែ មីនា ឆ្នាំ ១៩៧៦ រហូតដល់មានការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩[4]។

## ១.២. ប្រវត្តិនីតិវិធី

៤. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញានៃ អ.វ.ត.ក បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៥៣ នៃវិធានផ្ទៃក្នុង ដោយស្នើសុំឱ្យបើកការស៊ើបសួរលើបុគ្គលចំនួនប្រាំរូប រួមទាំងជនជាប់ចោទផងដែរ[5]។ នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ឱ្យបំបែកសំណុំរឿងរបស់ជនជាប់ចោទលើអង្គហេតុទាក់ទងនឹងមន្ទីរ ស ២១ ដែលអង្គហេតុនេះត្រូវបានស៊ើបសួរក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧ ដែលជាសំណុំរឿងក្តីមួយនេះ[6]។ នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩[7]។

---

[3]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១។

[4]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១១១, ១១៩, ១២១, ១៣០ និង ២០៣។

[5]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧, ឯកសារលេខ D3។

[6]ដីកាបំបែកសំណុំរឿងថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧, ឯកសារលេខ D18។ អង្គហេតុដទៃទៀតដែលពាក់ព័ន្ធនឹងជនជាប់ចោទ ឬជនផ្សេងទៀតដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវបានស៊ើបសួរក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧។

[7]ដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ *ហៅ*ឌុច ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨, ឯកសារលេខ D99។

៥. នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[8]។ នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានចេញសាលដីកាប្រកាសផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍នេះ[9]។ អង្គបុរេជំនុំជម្រះ ទទួលយកមួយផ្នែកនូវទឡ្ហីករណ៍ទីមួយនៃបណ្តឹងឧទ្ធរណ៍ ដោយយល់ឃើញថា ឧក្រិដ្ឋកម្មជាតិនៃការធ្វើទារុណកម្ម និងអំពើមនុស្សឃាតគិតទុកជាមុនក្រោមច្បាប់ជាតិ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ("ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦") គប្បីត្រូវបានបន្ថែមទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[10]។ អង្គបុរេជំនុំជម្រះបានបដិសេធទឡ្ហីករណ៍ទីពីរនៃបណ្តឹងឧទ្ធរណ៍ដែលលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំដោយមិនបានបញ្ចូលសហឧក្រិដ្ឋកម្មរួមដែលជាទម្រង់នៃការទទួលខុសត្រូវទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[11]។ អង្គបុរេជំនុំជម្រះបានសម្រេចបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែ ហើយដីកានេះបានលើកឡើងអំពីការចោទប្រកាន់លើអង្គហេតុទាំងឡាយសម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកាត់សេចក្តី។

៦. សវនាការបឋមចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៧ និងទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩[12]។ សវនាការលើអង្គសេចក្តីបានចាប់ផ្តើមនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩ និងបានបញ្ចប់សវនាការពិភាក្សាដេញដោលនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៩ បន្ទាប់ពីមានសវនាការអស់រយៈពេល ៧២ ថ្ងៃ[13]កន្លងមក។ ជនរងគ្រោះចំនួន ៩០ នាក់ បានតាំងខ្លួន

---

[8]បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨, ភាសាខ្មែរដាក់នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៨, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨, ឯកសារលេខ D99/3/3។

[9]សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨, ឯកសារលេខ D99/3/42 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែ")។

[10]ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែ, កថាខណ្ឌ ១០៣ ដល់ ១០៧។

[11]ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែ, កថាខណ្ឌ ១៤១។

[12]ដីកាកំណត់កាលបរិច្ឆេទសវនាការបឋម ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E8។

[13]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៩។

ជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាង ហើយត្រូវបានបែងចែកជាបួនក្រុម ("ដើមបណ្តឹងរដ្ឋប្បវេណី")[14]។ សហព្រះរាជអាជ្ញា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីការពារក្តី និងជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលបន្តបន្ទាប់គ្នានៅថ្ងៃទី ២៣ ដល់ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩[15]។

៧. អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមរបស់ខ្លួននៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទក្នុងនាមជាអនុលេខា ហើយបន្ទាប់មកជាលេខាមន្ទីរ ស ២១ បានគ្រប់គ្រង និងកែប្រែប្រព័ន្ធគ្រប់គ្រងអស់រយៈពេលជាងបីឆ្នាំ ដែលបណ្តាលឱ្យមានការសម្លាប់ជនរងគ្រោះមិនតិចជាង ១២.២៧២ នាក់ ដែលជនរងគ្រោះភាគច្រើនត្រូវបានទទួលរងនូវការធ្វើទារុណកម្មតាមលក្ខណៈជាប្រព័ន្ធ[16]។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ ៣៥ ឆ្នាំ ដោយផ្អែកលើការរកឃើញថា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ (ដោយស្រូបបញ្ចូលនូវបទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានដូចជា ការសម្លាប់រង្គាល(រួមបញ្ចូលអំពើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមបញ្ចូលការរំលោភផ្លូវភេទមួយករណី) និងអំពើអមនុស្សធម៌ផ្សេងៗទៀត) និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ រួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កឱ្យមានការឈឺចាប់ដោយចេតនា ឬឱ្យមានរបួសធ្ងន់ធ្ងរដល់រូបរាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបាននូវការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់[17]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាត់បន្ថយទោសចំនួន ៥ ឆ្នាំ ពីរយៈពេលផ្តន្ទាទោស ដោយសារការរំលោភលើសិទ្ធិរបស់ជនជាប់

[14]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៣៧ ដល់ ៦៣៨។

[15]ដីកាកំណត់កាលបរិច្ឆេទសម្រាប់ភាគីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩, ឯកសារលេខ E170។

[16]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៩៧។

[17]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧៧ និង៦៧៩។

ចោទ ក្នុងអំឡុងពេលឃុំខ្លួនខុសច្បាប់នីតិវិធី ដោយតុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧[18]។ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចផងដែរថា ជនជាប់ចោទត្រូវទទួលបានការទូទាត់នូវថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទាំងស្រុង ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ (ក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា) និងពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ រហូតដល់សាលក្រមចូលជាស្ថាពរ[19]។

៨. អង្គជំនុំជម្រះសាលាដំបូង បានផ្តល់សំណងពីរប្រភេទដល់ដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងសាលក្រមរបស់ខ្លួនថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ ពិតជាបានទទួលរងគ្រោះ ដែលជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋទាំងឡាយដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធភាព។ អង្គជំនុំជម្រះសាលាដំបូង បានយល់ព្រមធ្វើការចងក្រងពាក្យសម្តីសុំអភ័យទោសទាំងអស់ និងពាក្យសម្តីទទួលស្គាល់ការទទួលខុសត្រូវ ដែលជនជាប់ចោទ បានធ្វើនៅក្នុងអំឡុងពេលសវនាការ ហើយកម្រងពាក្យសម្តីទាំងនេះ នឹងត្រូវដាក់នៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក ក្នុងរយៈពេល ១៤ ថ្ងៃបន្ទាប់ពីសាលក្រមរបស់ខ្លួនចូលជាស្ថាពរ[20]។

៩. សហព្រះរាជអាជ្ញា ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ក្រុម ២ និងក្រុម ៣ បានធ្វើបណ្តឹងសាទុក្ខ មកអង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[21]។

---

[18]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៨០។

[19]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៨១។

[20]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៨២ ដល់ ៦៨៣។

[21]បណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ប្រឆាំងនឹងការសម្រេចដកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចេញពីសាលក្រម ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ F8 ("បណ្តឹងសាទុក្ខភ្លាមៗរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១") (ដំបូងដាក់នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០, ជាឯកសារលេខ E188/10 ប៉ុន្តែបន្ទាប់មកទៀត ដាក់សារឡើងវិញទៅជាឯកសារលេខ F8 ដោយអនុលោមតាមសេចក្តីសម្រេចស្តីពីការកំណត់ចរិតលក្ខណៈនៃបណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ចំពោះការសម្រេចដកឋានៈជាដើមបណ្តឹង

រដ្ឋប្បវេណីចេញពីសាលក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ F8/1)។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ - សេចក្តីជូនដំណឹងអំពីគោលបំណងដាក់សារណាបន្ថែមរបស់មេធាវីតំណាងដើមរដ្ឋប្បវេណីក្រុម ១ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ F12 ("សេចក្តីជូនដំណឹងអំពីគោលបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១")។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣, ភាសាខ្មែរដាក់នៅ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ E188/4 ("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣")។ បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ភាសាខ្មែរដាក់នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១០, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារលេខ F9 ("បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣")។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ E188/2។ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ F10 ("បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")។ សេចក្តីជូនដំណឹងអំពីបណ្តឹងសារទុក្ខរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និងទឡ្ហីករណ៍នៃបណ្តឹងសារទុក្ខប្រឆាំងនឹងសាលក្រម, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ E188/12 ("បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ស្តីពី ជុំ ស៊ីរ៉ាត")។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០ ឯកសារលេខ E188/6។ បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម - សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ F11 ("បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ស្តីពីភាពអាចទទួលយកបាន")។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ លើសាលក្រមទាក់ទិននឹងសំណងចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ E188/14។ បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ លើសាលក្រមទាក់ទិននឹងសំណងចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារ F13 ("បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ស្តីពីសំណង")។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ E188/8 ("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារ")។ សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារលេខ F14 ("បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី") (សារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទបានដាក់ជាភាសាខ្មែរនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០ ហើយសារណាជាភាសាអង់គ្លេសបានកែតម្រូវចុងក្រោយ ហើយដាក់នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១១។ សំណើសុំធ្វើការកែតម្រូវក្នុងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារលេខ

១០. អង្គជំនុំជម្រះតុលាការកំពូល បានបើកកិច្ចប្រជុំរៀបចំសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ ជាសម្ងាត់ ដោយមានវត្តមានរបស់មេធាវីតំណាងម្ចាស់បណ្តឹងសាទុក្ខ។ សវនាការបណ្តឹងសាទុក្ខលើអង្គសេចក្តីត្រូវបានធ្វើឡើងអស់រយៈពេល ០៣(បី)ថ្ងៃ ចាប់ពីថ្ងៃទី ២៨ ដល់ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១។

---

F14/Corr-1។ សំណើសុំធ្វើការកែតម្រូវក្នុងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ F14/Corr-2)។ សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី ឌុច ប្រឆាំងនឹងសាលក្រមសាលាដំបូងចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ភាសាខ្មែរដាក់នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១០, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ F14/2 "សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣"។ សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១០, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារលេខ F14/4 ("សារណាតបរបស់សហព្រះរាជអាជ្ញា")។ ការឆ្លើយតបរបស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" ទៅនឹងសារណាតបរបស់សហព្រះរាអាជ្ញាចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១០, ភាសាខ្មែរដាក់នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១, ឯកសារបកប្រែជាភាសាអង់គ្លេសបានដាក់នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ F14/4/2 ("ការឆ្លើយតបរបស់មេធាវីការពារក្តី")។ សេចក្តីអង្កេតរបស់សហព្រះរាជអាជ្ញាទៅលើសារណាបណ្តឹងសាទុក្ខជាភាសាអង់គ្លេសដែលបានកែតម្រូវរបស់សហមេធាវីការពារក្តី កាំង ហ្គេក អ៊ាវ *ហៅ* "ឌុច" ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F14/5។ សារណាបន្ថែមទាក់ទងនឹងសំណង នៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F25 ("សារណាបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣")។

## ២.បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខ

១១. វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងចែងថា ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខមកកាន់អង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង លើកឡើងនូវ"កំហុសអង្គច្បាប់ ដែលនាំអោយមោឃៈសាលក្រមលើអង្គសេចក្ដី (...) ឬកំហុសអង្គហេតុដែលនាំឱ្យសាលក្រមលើអង្គសេចក្ដី ឬសេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌"[22]។ ការលើកឡើងទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខទាំងនេះ បានអនុវត្តស្របទៅនឹងសេចក្ដីសម្រេចរបស់អង្គការនីតិបញ្ញត្តិ ដែលបានធ្វើឡើងនៅក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលចែងថា ការពិនិត្យឡើងវិញលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវតែធ្វើឡើងដោយតុលាការមួយថ្នាក់តែប៉ុណ្ណោះ[23]។ ជាលទ្ធផល កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មានលក្ខណៈខុសប្លែកពីបទដ្ឋាននៃការពិនិត្យឡើងវិញជាពីរថ្នាក់ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[24]។ ទោះបីជាយ៉ាងណាក៏ដោយ បទដ្ឋាននេះ បានផ្ដល់នូវគោលការណ៍ណែនាំតិចតួចដល់វិធីសាស្ត្របណ្ដឹងសាទុក្ខ

---

[22]វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិសោធនកម្មលើកទី ៨)។ លើកលែងតែមានបទប្បញ្ញត្តិចែងផ្ទុយពីនេះ រាល់ការយោងនៅក្នុងសាលដីកានេះ គឺសំដៅទៅលើវិធានផ្ទៃក្នុង("វិធានផ្ទៃក្នុង") របស់ អ.វ.ត.ក ក្នុងវិសោធនកម្មលើកទី ៣។

[23]មាត្រា ៩ ថ្មី នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដោយរួមបញ្ចូលនូវវិសោធនកម្មដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (**នស/រកម/១០០៤/០០៦**) ("ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក")។ មាត្រា ៣(២) (ខ) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ចុះហត្ថលេខា នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ (ចូលជាធរមាន នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥) ("កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ")។

[24]ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ (**នស/រកម/០៨០១/១២**) ("ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក") មាត្រា ២ (ចែងសម្រាប់ដំណាក់កាលជំនុំជម្រះ បណ្ដឹងសាទុក្ខ និងអង្គជំនុំជម្រះតុលាការកំពូល)។

របស់ អ.វ.ត.ក ក្នុងការអនុវត្តមុខងារជាក់ស្តែងរបស់ខ្លួន។

១២. យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានការបែងចែកជាពីរថ្នាក់ក្នុងការពិនិត្យឡើងវិញលើសាលក្រមរបស់តុលាការជាន់ដំបូង។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ មានសមត្ថកិច្ចដើម្បីសម្រេចអំពីបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើភស្តុតាង ដែលមាននៅចំពោះមុខតុលាការជាន់ដំបូង ហើយក្នុងករណីមួយចំនួននៅចំពោះមុខសាលាឧទ្ធរណ៍[25]។ សាលដីកាដែលចេញដោយសាលាឧទ្ធរណ៍ អាចត្រូវធ្វើការពិនិត្យឡើងវិញ ដោយតុលាការកំពូលតាមរយៈបណ្តឹងសាទុក្ខ[26]។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានរៀបរាប់នូវមូលហេតុនៃបណ្តឹងសាទុក្ខមួយចំនួន ដែលតុលាការកំពូលកម្ពុជាអាចបដិសេធសេចក្តីសម្រេច ក្នុងករណីដូចតទៅ:

-សមាសភាពមិនស្របច្បាប់នៃតុលាការ

-អសមត្ថកិច្ចនៃតុលាការ

-ការរំលោភអំណាច

-ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់

-ការបំពាន ឬភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ

-ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការ ឬភាគី កាលណាពាក្យសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់

-ការបំភ្លៃអង្គហេតុ

-គ្មានសំអាងហេតុ ឬ

-ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេច[27]។

១៣. យោងតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា អង្គជំនុំជម្រះតុលាការកំពូល

---

[25]មាត្រា ៣៧៣ ៤០៥ ដល់ ៤០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ (“ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧”)។

[26]មាត្រា ៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។

[27]មាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។

"គឺជាកន្លែងទទួលពាក្យបណ្ដឹងសាទុក្ខផង និងសម្រេចសេចក្ដីចុងក្រោយផង"[28]។ នៅពេលកំណត់ពីយុត្តាធិការបណ្ដឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូល អ.វ.ត.ក បានធ្វើការបញ្ចូលនូវដំណោះស្រាយដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ទៅក្នុងប្រព័ន្ធបណ្ដឹងសាទុក្ខដែលមានលក្ខណៈពិសេស (*sui generis*)។ ហេតុដូច្នេះ អ.វ.ត.ក ត្រូវបានអនុញ្ញាតដោយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ក្នុងការស្វែងរកសេចក្ដីណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតក្នុងកម្រិតអន្តរជាតិនូវការបកស្រាយរបស់ស្ថាប័នតុលាការអន្តរជាតិនោះ[29]។ ប្រព័ន្ធនៃបណ្ដឹងសាទុក្ខនៅក្នុងវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង អនុវត្តតាមលក្ខណៈពិសេសនៃការពិនិត្យឡើងវិញនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ក្នុងន័យថា អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក អាចពិនិត្យលើភស្ដុតាង និងអាចស្នើសុំ ឬទទួលយកភស្ដុតាងបន្ថែមដើម្បីសម្រេចអំពីបញ្ហាណាមួយ[30]។ ទទ្បីករណ៍នៃបណ្ដឹងសាទុក្ខក្នុងវិធាន ១០៤(១) ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក៏រួមបញ្ចូលទាំងមូលហេតុនៃបណ្ដឹងសាទុក្ខទៅតុលាការកំពូលកម្ពុជា។ ទន្ទឹមគ្នានេះដែរ ដើម្បីឱ្យស្របទៅតាមគោលបំណងរបស់វិធានផ្ទៃក្នុង[31] មូលហេតុទាំងនេះត្រូវបានលើកឡើងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរ

[28]មាត្រា ៩ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ។

[29]មាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ មាត្រា ៣៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។

[30]វិធាន ១០៤(១) និង ១០៨(៧) នៃវិធានផ្ទៃក្នុង។

[31]វិធានផ្ទៃក្នុង បុព្វកថា កថាខណ្ឌ ៥ ("អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុម័តវិធានផ្ទៃក្នុងដូចខាងក្រោម ដែលមានគោលបំណងធ្វើការចងក្រងនូវនីតិវិធីជាធរមានរបស់កម្ពុជា សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង (...) អនុម័តវិធានមួយចំនួនបន្ថែមទៀត នៅពេលណាដែលច្បាប់កម្ពុជាជាធរមាន ពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្ត ឬក៏ប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងនឹងភាពស្របគ្នារវាងបទប្បញ្ញត្តិនៅក្នុងច្បាប់កម្ពុជាទៅនឹងនិយាមអន្តរជាតិ")។

ជាតិ[32] ហើយពាក្យពេចន៍ដែលយកមកប្រើប្រាស់ក្នុងវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង មានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងមូលហេតុនៃបណ្តឹងសាទុក្ខ នៅក្នុងលក្ខន្តិកៈរបស់តុលាការ ICTY និង ICTR[33]។ ហេតុដូច្នេះ យុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR ត្រូវបានយកមកប្រើប្រាស់ជាប្រភពនៃសេចក្តីណែនាំនៅក្នុងការបកស្រាយវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

១៤. កំហុសអង្គច្បាប់អាចត្រូវបានលើកឡើងប្រឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាព ឬការសម្រេចឱ្យរួចខ្លួន។ នៅពេលដែលភាគីណាមួយលើកឡើងនូវទឡ្ហីករណ៍បែបនេះ អង្គជំនុំជម្រះតុលាការកំពូល ដែលជាតុលាការវិនិច្ឆ័យទៅលើអង្គច្បាប់ដែលយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក ជាគោលការណ៍ ត្រូវបានចងកាតព្វកិច្ចក្នុងការសម្រេច ថាតើកំហុសអង្គច្បាប់ត្រូវបានប្រព្រឹត្តឡើងយ៉ាងជាក់ស្តែងទៅលើបញ្ហានីតិវិធី ឬអង្គសេចក្តី ដែរ ឬយ៉ាងណា[34]។ អង្គជំនុំជម្រះតុលាការកំពូល ត្រូវពិនិត្យឡើងវិញនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហាអង្គច្បាប់ដើម្បីសម្រេច ថាតើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងត្រឹមត្រូវ ដែរ ឬយ៉ាងណា ដោយមិនគ្រាន់តែសម្រេចថា ការយល់ឃើញនេះសមហេតុផល ដែរ ឬយ៉ាងណានោះទេ[35]។ និយាមក្នុងការសម្រេចពីភាពត្រឹមត្រូវកំណត់ថា អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេច ថាតើអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមខ្លឹមសារនៃនិយាមគតិយុត្តជាធរមាន ដោយផ្អែកតាមប្រភពដ៏សមស្របនៃច្បាប់ និងតាមរយៈការអនុវត្តនូវវិធាន

---

[32]*សូមមើលឧទា. រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Galić*, សំណុំរឿងលេខ IT-98-29-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦, ("សាលដីកាក្នុង*រឿងក្តី Galić* "), កថាខណ្ឌ ៦។

[33]មាត្រា ២៥(១) នៃលក្ខន្តិកៈរបស់តុលាការ ICTY ត្រូវបានអនុម័តនៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅខែ កញ្ញា ឆ្នាំ ២០០៩, ("លក្ខន្តិកៈរបស់តុលាការ ICTY")។ លក្ខន្តិកៈរបស់តុលាការ ICTR ត្រូវបានអនុម័តនៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ហើយវិសោធនកម្មនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១០ ("លក្ខន្តិកៈរបស់តុលាការ ICTR") មាត្រា ២៤ (១)។

[34]*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Krnojelac*, សំណុំរឿងលេខ IT-97-25-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣, ("សាលដីកាក្នុង*រឿងក្តី Krnojelac*"), កថាខណ្ឌ ១០។

[35]សាលដីកានៃ*រឿងក្តី Krnojelac*, កថាខណ្ឌ ១០។

នៃការបកស្រាយទាក់ទងទៅនឹងប្រភពនៃច្បាប់ទាំងនោះ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលក៏ត្រូវធ្វើការវាយតម្លៃ ថាតើលទ្ធផលដែលសាលាដំបូងទទួលបាននោះមានលក្ខណៈច្បាស់លាស់ និងជាក់លាក់ ដែរ ឬយ៉ាងណា។

១៥. អំណាចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងដំណាក់កាលបណ្ដឹងសាទុក្ខ ត្រូវអនុវត្តក្នុងកម្រិតនៃបញ្ហា ដែលបានប្ដឹងសាទុក្ខតែប៉ុណ្ណោះ។ មេធាវីការពារក្ដី សហព្រះរាជអាជ្ញា ឬមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានលើកឡើងនូវកំហុសអង្គច្បាប់ ត្រូវបង្ហាញពីកំហុសនោះ ត្រូវមានអំណះអំណាងក្នុងការគាំទ្រដល់ការលើកឡើងនេះ ហើយត្រូវពន្យល់អំពីមូលហេតុដែលនាំឱ្យសាលក្រមមោឃៈ[36]។ ប៉ុន្តែ បន្ទុកក្នុងការបង្ហាញភស្តុតាងលើបណ្ដឹងសាទុក្ខ មិនមានលក្ខណៈដាច់ខាតនោះទេទាក់ទងនឹងកំហុសអង្គច្បាប់។ ទោះបីជាអំណះអំណាងរបស់ភាគីមិនមានលក្ខណៈគ្រប់គ្រាន់ ក្នុងការគាំទ្រដល់ការលើកឡើងអំពីកំហុសអង្គច្បាប់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលអាចស្វែងរកមូលហេតុដទៃទៀត ហើយធ្វើការសន្និដ្ឋានដូចគ្នាផងដែរថា មានកំហុសអង្គច្បាប់[37]។ ដើម្បីធ្វើការសម្រេចលើបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលក៏ត្រូវពិនិត្យឡើងវិញផងដែរ លើការយល់ឃើញផ្នែកអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ដែលជាមូលដ្ឋានចាំបាច់សម្រាប់សេចក្ដីសម្រេចដែលរងការជំទាស់នោះ។ ក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះតុលាការកំពូលអាចលើកបញ្ហាឡើងតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន (*proprio motu*)[38] ឬស្ដាប់សវនាការលើបណ្ដឹងសាទុក្ខដែលភាគីបានលើកឡើងពីបញ្ហាអង្គច្បាប់ ដែលមិនត្រឹមតែមិនធ្វើឱ្យសាលក្រមមោឃៈប៉ុណ្ណោះនោះទេ ប៉ុន្តែ

---

[36]វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។

[37]*រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង* Boškoski *និង* Tarčulovski, សំណុំរឿងលេខ IT-04-82-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០, ("សាលដីកាក្នុង*រឿងក្ដី* *Boškoski និង Tarčulovski*"), កថាខណ្ឌ ១០។ *រឿងក្ដី* Kambanda *ទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខ ICTR-97-23-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០០, ("សាលដីកាក្នុង*រឿងក្ដី Kambanda*"), កថាខណ្ឌ ៩៨។

[38]សាលដីកាក្នុង*រឿងក្ដី* *Krnojelac*, កថាខណ្ឌ ៦។ មាត្រា ៤០៥ ដល់ ៤០៦ និង ៤៤០ ដល់ ៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។

ថែមទាំងផ្តល់នូវសារៈសំខាន់ជាទូទៅសម្រាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក ទៀតផង[39]។

១៦. នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលរកឃើញថា មានកំហុសអង្គច្បាប់នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលកើតចេញពីការភ័ន្តច្រឡំក្នុងការអនុវត្តនូវបទដ្ឋានផ្លូវច្បាប់នោះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកំណត់នូវបទដ្ឋានផ្លូវច្បាប់ដ៏ត្រឹមត្រូវមួយ ហើយត្រូវពិនិត្យឡើងវិញ នូវផ្នែកសំអាងហេតុដែលពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូង។ ការធ្វើបែបនេះ អង្គជំនុំជម្រះតុលាការកំពូលមិនត្រឹមតែកែតម្រូវកំហុសអង្គច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងអនុវត្តនូវបទដ្ឋានផ្លូវច្បាប់ដោយត្រឹមត្រូវចំពោះភស្តុតាងដែលមាន នៅក្នុងកំណត់ហេតុនៃការជំនុំជម្រះ ហើយក្នុងករណីចាំបាច់ត្រូវកំណត់ ថាតើខ្លួនជឿជាក់លើបទដ្ឋានពាក់ព័ន្ធនៃការបង្ហាញភស្តុតាងទាក់ទងទៅនឹងសំអាងហេតុ ដែលត្រូវបានជំទាស់ដោយភាគីណាមួយនៅមុនពេល ដែលសំអាងហេតុនេះត្រូវបានទទួលយកនៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ ដែរ ឬយ៉ាងណា[40]។ អង្គជំនុំជម្រះតុលាការកំពូលអាចកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបាន តែក្នុងករណីដែលខ្លួនរកឃើញថា មានកំហុសអង្គច្បាប់ ដែល "នាំឱ្យសាលក្រម ឬសេចក្តីសម្រេចមោឃៈ"[41]។ ប៉ុន្តែ មិនមែនរាល់កំហុសអង្គច្បាប់សុទ្ធតែតម្រូវឱ្យមានការបដិសេធ ឬការកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ នៅពេលដែលកំហុសអង្គច្បាប់ត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញា ឬដោយដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចឱ្យរួចខ្លួន អង្គជំនុំជម្រះតុលាការកំពូល អាចត្រឹមតែធ្វើការកែប្រែលើសំអាងហេតុផ្នែកអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសនោះ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលមិនអាចធ្វើការកែប្រែផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូងបានឡើយ[42]។

---

[39]សាលដីកាក្នុង *រឿងក្តី Galić*, កថាខណ្ឌ ៦។

[40]*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Blagojević *និង* Jokić, សំណុំរឿងលេខ IT-02-60-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៧, ("សាលដីកាក្នុង *រឿងក្តី Blagojević និង Jokić*"), កថាខណ្ឌ ៨។

[41]វិធាន ១០៤(១)(ក) នៃវិធានផ្ទៃក្នុង។

[42]វិធាន ១១០(៤) នៃវិធានផ្ទៃក្នុង។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចូលជាស្ថាពរ និងបិទផ្លូវប្តឹងតវ៉ាចំពោះភាគីទាំងអស់នៅក្នុងរឿងក្តីនោះ។

១៧. ដូចគ្នាទៅនឹងកំហុសអង្គច្បាប់ដែរ កំហុសអង្គហេតុអាចត្រូវបានចោទឡើងប្រឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាព ឬសេចក្តីសម្រេចឱ្យរួចខ្លួន។ អង្គជំនុំជម្រះតុលាការកំពូល អនុវត្តបទដ្ឋាននៃភាពសមហេតុផលក្នុងការពិនិត្យឡើងវិញនូវផ្នែកសំអាងហេតុ ដែលរងការជំទាស់ ប៉ុន្តែមិនគិតថាសំអាងហេតុនោះត្រឹមត្រូវ ឬមានកំហុសនោះទេ។ ដើម្បីសម្រេច ថាតើសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ស្រប ឬមិនស្របទៅនឹងសំអាងហេតុរបស់តុលាការអង្គហេតុដែលមានលក្ខណៈសមហេតុផលណាមួយ ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះតុលាការកំពូល "មិនត្រូវប៉ះពាល់ដល់សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ"[43]។ អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយនឹងវិធីសាស្ត្រទូទៅនៃការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដូចដែលបានបង្ហាញដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ដូចខាងក្រោម:

> យោងតាមយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មនានា ការស្តាប់ ការវាយតម្លៃ និងថ្លឹងថ្លែងភស្តុតាងដែលបង្ហាញនៅពេលជំនុំជម្រះ ជាចម្បង គឺជាកិច្ចការរបស់អង្គជំនុំជម្រះសាលាដំបូង។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ត្រូវគោរពចំពោះការយល់ឃើញផ្នែកសំអាងហេតុ ដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង។ លើកលែងតែភស្តុតាង ដែលអង្គជំនុំជម្រះយកមកសំអាងនោះ មិនអាចទទួលយកបានដោយតុលាការឧក្រិដ្ឋកម្មណាមួយដែលវិនិច្ឆ័យលើភាពសមហេតុផលនៃអង្គហេតុ ឬលើកលែងតែការវាយតម្លៃលើភស្តុតាងនោះមាន"ការភ័ន្តច្រឡំទាំងស្រុង" ទើបអង្គជំនុំជម្រះតុលាការកំពូល អាចផ្លាស់ប្តូរការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបាន។
>
> (...)

[43] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Furundžija*, សំណុំរឿងលេខ IT-95-17/1, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០, ("សាលដីកាក្នុង*រឿងក្តី Furundžija*") , កថាខណ្ឌ ៣៧។

មូលហេតុបានបង្ហាញឱ្យឃើញច្បាស់លាស់ថា អង្គជំនុំជម្រះតុលាការកំពូលមិនត្រូវប៉ះពាល់ដល់ការយល់ឃើញ ផ្នែកសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ អង្គជំនុំជម្រះសាលាដំបូងមានអាទិភាពជាងក្នុងការពិនិត្យលើសាក្សីដោយផ្ទាល់ ដូច្នេះស្ថិតនៅក្នុងតួនាទីមួយដែលប្រសើរជាងអង្គជំនុំជម្រះតុលាការកំពូល ក្នុងការវាយតម្លៃលើភាពដែលគួរឱ្យជឿបាននៃភស្តុតាង។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានតួនាទីធំជាងគេក្នុងការកំណត់ថាតើសាក្សីណាមួយគួរឱ្យជឿបាន ហើយសម្រេច ថាតើខ្លួនចង់បានការផ្តល់សក្ខីកម្មរបស់សាក្សីណាខ្លះ ដោយមិនចាំបាច់បញ្ជាក់ពីដំណាក់កាលនីមួយៗនៃសំអាងហេតុ ក្នុងការសម្រេចសេចក្តីលើចំណុចទាំងនេះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ឆន្ទានុសិទ្ធិនេះត្រូវបានប្រើក្នុងកម្រិតនៃកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់នូវសំអាងហេតុ (...)[44]។

១៨. ដោយពិចារណាឃើញថា ពិរុទ្ធភាពរបស់ជនជាប់ចោទត្រូវតែបង្ហាញថា គ្មានវិមតិសង្ស័យនៅក្នុងដំណាក់កាលជំនុំជម្រះ ទើបអង្គជំនុំជម្រះតុលាការកំពូលត្រូវវាយតម្លៃចំណុចសំខាន់ៗនៃកំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ ទៅលើចំណុចដែលម្ចាស់បណ្តឹងសាទុក្ខចង់បង្ហាញ។ ដូច្នេះហើយ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចឱ្យរួចខ្លួន មានភាពខុសគ្នាពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីប្រឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាព។ បណ្តឹងសាទុក្ខប្រឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាពត្រូវបង្ហាញថា កំហុសអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង មានវិមតិសង្ស័យចំពោះការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ។ ក្នុងករណីដែលមានការលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុនោះ បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចឱ្យរួចខ្លួន ត្រូវបង្ហាញថា គ្មានវិមតិសង្ស័យចំពោះការសម្រេចដាក់ពិរុទ្ធភាពទៅលើជនជាប់ចោទ[45]។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំង

[44] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kupreškić និងជនដទៃទៀត*, សំណុំរឿងលេខ IT-95-16-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០១, ("សាលដីកាក្នុង*រឿងក្តី Kupreškić*"), កថាខណ្ឌ ៣០ និង ៣២។

[45] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Bagilishema*, សំណុំរឿងលេខ ICTR-95-1A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០២, ("សាលដីកាក្នុង*រឿងក្តី Bagilishema*"), កថាខណ្ឌ ១៤។

នឹងសេចក្តីសម្រេចឱ្យរួចខ្លួន អង្គជំនុំជម្រះតុលាការកំពូលអាចត្រឹមតែកែប្រែសំអាងហេតុផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ប៉ុណ្ណោះ នៅពេលដែលខ្លួនយល់ឃើញថា មានកំហុស ប៉ុន្តែ មិនអាចកែប្រែផ្នែកសម្រេចសេចក្តីនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានឡើយ[46]។

១៩. ទោះបីជា ភាគីណាមួយលើកឡើងអំពីកំហុសអង្គហេតុក៏ដោយ ជាលទ្ធផលអង្គជំនុំជម្រះតុលាការកំពូលអាចបដិសេធតែផ្នែកខ្លះ ឬទាំងស្រុងនៃអង្គហេតុណា ដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ភាពមិនយុត្តិធម៌ គឺបណ្តាលឱ្យមាន"លទ្ធផល ដែលមិនយុត្តិធម៌ទាំងស្រុង នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ"[47]។ ដោយហេតុថា កំហុសអង្គហេតុបណ្តាលឱ្យមានភាពមិនយុត្តិធម៌ ដូចនេះ កំហុសនេះ ត្រូវតែមានការប៉ះពាល់យ៉ាង"ធ្ងន់ធ្ងរដល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង"[48]។ ភាគីត្រូវបង្ហាញថា កំហុសអង្គហេតុនេះបានធ្វើឱ្យមានភាពមិនយុត្តិធម៌យ៉ាងជាក់ស្តែង។

២០. នៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ ភាគីមិនអាចលើកឡើងវិញនូវទឡ្ហីករណ៍ដែលត្រូវបានបដិសេធនៅក្នុងដំណាក់កាលជំនុំជម្រះសាលាដំបូងនោះទេ ដរាបណាភាគីអាចបង្ហាញថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធទឡ្ហីករណ៍ទាំងនេះ គឺជាកំហុសមួយ ដែលទាមទារឱ្យមានការអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូល។ អំណះអំណាងដែលភាគីលើកឡើង ហើយពុំមានសក្តានុពលធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធ ឬកែប្រែសេចក្តីសម្រេចដែលរងការជំទាស់បានទេនោះ អង្គជំនុំជម្រះតុលាការកំពូលអាចបដិសេធអំណះអំណាងនេះចោលភ្លាមៗ ហើយមិនចាំបាច់ធ្វើការពិចារណាលើអង្គសេចក្តីឡើយ។ ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការវាយតម្លៃលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ភាគី

---

[46]វិធាន ១១០(៤) នៃវិធានផ្ទៃក្នុង។

[47]សាលដីកាក្នុង*រឿងក្តី Furundžija*, កថាខណ្ឌ ៣៧, យោងលើវចនានុក្រម Black's Law បោះពុម្ពផ្សាយលើកទី ៧ ឆ្នាំ ១៩៩៩។

[48]សាលដីកាក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ២៩។

បាន ភាគីបណ្តឹងសាទុក្ខត្រូវផ្តល់នូវការយោងលេខទំព័រនៃប្រតិចារឹក ដែលពាក់ព័ន្ធឱ្យបានច្បាស់លាស់ ឬកថាខណ្ឌនានានៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលខ្លួនធ្វើការជំទាស់នោះ[49]។ បន្ថែមលើសនេះទៀត អង្គជំនុំជម្រះតុលាការកំពូល"មិនតម្រូវឱ្យពិចារណាសារណារបស់ភាគីជាលម្អិតនោះទេ ប្រសិនបើសារណាទាំងនោះ មានលក្ខណៈមិនច្បាស់លាស់ មានលក្ខណៈផ្ទុយ និងមានលក្ខណៈស្រពេចស្រពិល ឬមានភាពមិនពេញលេញជាផ្លូវការដែលបង្ហាញឱ្យឃើញយ៉ាងជាក់ស្តែង"[50]។ អង្គជំនុំជម្រះតុលាការកំពូល មានឆន្ទានុសិទ្ធិក្នុងការជ្រើសរើសសារណាណាមួយដែលស័ក្តិសម ក្នុងការទទួលបាននូវការពិនិត្យពិចារណាដោយល្អិតល្អន់ជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះតុលាការកំពូលអាចបដិសេធទទ្បីករណ៍ណាដែលមិនមានមូលដ្ឋានសំអាងគ្រប់គ្រាន់ ដោយមិនចាំបាច់ផ្តល់សំអាងហេតុលម្អិតឡើយ។

---

[49] វិធាន ១០៥(៤) នៃវិធានផ្ទៃក្នុង។

[50] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Stakić*, សំណុំរឿងលេខ IT-97-24-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, ("សាលដីកាក្នុង *រឿងក្តី Stakić*"), កថាខណ្ឌ ១២។

## ៣.កំហុសដែលបានលើកឡើងទាក់ទងទៅនឹងយុត្តាធិការលើរូបបុគ្គល (ទឡ្ហីករណ៍ទី ១ នៃបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី)

### ៣.ក.យុត្តាធិការលើរូបបុគ្គលនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូង

២១. នៅក្នុងអំឡុងពេលសវនាការបឋមកាលពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញភាគីឱ្យលើកអញ្ញត្រកម្មអំពីយុត្តាធិការរបស់អង្គជំនុំជម្រះ និងប្រាប់ភាគីឱ្យយកចិត្តទុកដាក់លើបទប្បញ្ញត្តិនៃវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ព្រមទាំងលើផលវិបាកនៃការខកខានក្នុងការលើកការជំទាស់បែបនោះនៅក្នុងសវនាការបឋម[51]។ មេធាវីការពារក្ដីបានលើកនូវអញ្ញត្រកម្មមួយពាក់ព័ន្ធនឹងអាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ និងបានលើកអញ្ញត្រកម្មមួយទៀត ពាក់ព័ន្ធទៅនឹងរយៈពេលនៃការឃុំខ្លួនជនជាប់ចោទមុនពេលជំនុំជម្រះ[52]។ ពុំឃើញមានការលើកឡើងរបស់មេធាវីការពារក្ដីអំពីអញ្ញត្រកម្មស្ដីពីយុត្តាធិការលើរូបបុគ្គលនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល មេធាវីការពារក្ដីបានសន្និដ្ឋានថា អ.វ.ត.ក ពុំមានយុត្តាធិការទៅលើជនជាប់ចោទឡើយ ដោយហេតុថា ជនជាប់ចោទពុំមែនជាជនម្នាក់ក្នុងចំណោម“មេដឹកនាំជាន់ខ្ពស់” ហើយក៏ពុំមែនជាជនម្នាក់ក្នុងចំណោមជនទាំងឡាយ ដែល“ទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលត្រូវបានប្រព្រឹត្តក្នុងដែនកំណត់យុត្តធិការពេលវេលារបស់ អ.វ.ត.ក នោះឡើយ[53]។ ជាពិសេស មេធាវីការពារក្ដីបានសន្និដ្ឋានថា ពាក្យ“មេដឹកនាំជាន់ខ្ពស់”សំដៅតែទៅលើសមាជិកនៃគណៈអចិន្ត្រៃយ៍ប៉ុណ្ណោះ ហើយជនជាប់ចោទគ្រាន់តែអនុវត្តតាមបទបញ្ជា និងមានមនុស្សស្លាប់នៅមន្ទីរឃុំឃាំងផ្សេងៗទៀត ច្រើនជាងនៅមន្ទីរ ស ២១[54]។

---

[51]ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារ E1/3.1 ទំព័រ ៥ ដល់ ៦។

[52]ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារ E1/3.1 ទំព័រ ៦ និង ៨ ដល់ ១០។

[53]ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ E1/80.1 ទំព័រ ៥៩ ដល់ ៧១។

[54]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៤, ជើងទំព័រ ១៩។

២២. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងសាលក្រមរបស់ខ្លួនថា ជនជាប់ចោទខកខានក្នុងការលើកពីការជំទាស់របស់ខ្លួនចំពោះយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក ទៅលើរូបគាត់ ដែលជាអញ្ញត្រកម្មក្នុងអំឡុងពេលសវនាការបឋមស្របតាមវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង[55]។ ដោយពិនិត្យឃើញការលើកឡើងមិនទាន់ពេលវេលានៃការជំទាស់របស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបដិសេធការជំទាស់នេះ[56] ប៉ុន្តែ បានប្រើនូវឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីពិចារណាពីបញ្ហាយុត្តាធិការលើរូបបុគ្គល*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*[57]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅក្នុងជើងទំព័រនៃសាលក្រមថា ពាក្យពេចន៍ដែលថា "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក "សំដៅលើជនសង្ស័យពីរប្រភេទដាច់ដោយឡែកពីគ្នា"[58]។ ដោយផ្អែកតាមការសន្និដ្ឋានដែលបង្ហាញឱ្យឃើញថា ពាក្យពេចន៍នេះ បង្កើតបានជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងបានបន្តពិចារណា ថាតើជនជាប់ចោទស្ថិតនៅក្នុងនិយមន័យជា "មេដឹកនាំជាន់ខ្ពស់" ឬក៏ជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទដែលពីដំបូងជាអនុលេខា និងក្រោយមកជាលេខាមន្ទីរ ស ២១ បានធ្វើឱ្យគាត់ស្ថិតនៅក្នុងចំណោមជនទាំងឡាយណាដែលជា"អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក[59] ហើយថា ខ្លួនពុំចាំបាច់

[55]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៤។

[56]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៥។

[57]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៦។

[58]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២២, ជើងទំព័រ ២៨។

[59]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៣ ដល់ ២៥។

កំណត់បន្ថែមទៀត ថាតើជនជាប់ចោទជា"មេដឹកនាំជាន់ខ្ពស់"នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែរ ឬយ៉ាងណា នោះទេ[60]។

## ៣.ក.១.សារណារបស់ភាគី

២៣. ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរូបបុគ្គលទៅលើខ្លួនគាត់នោះឡើយ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលគួរបដិសេធចោលការសម្រេចដាក់ពិរុទ្ធភាព និងការផ្តន្ទាទោសលើរូបគាត់។ ជនជាប់ចោទបានលើកឡើងថា នៅក្នុងរចនាសម្ព័ន្ធនយោបាយដែលបង្កើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទាំងការទទួលខុសត្រូវផ្នែកប្រតិបត្តិ និងតួនាទីដែលខ្លួនគាត់បានបំពេញ ពុំបានធ្វើឱ្យគាត់ស្ថិតក្នុងអត្ថន័យជា "មេដឹកនាំជាន់ខ្ពស់"មួយរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ នោះទេ[61]។ ជនជាប់ចោទបានអះអាងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ខ្លួនគាត់ជាជនម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រព្រឹត្តក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក[62] ហើយថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដែលអង្គជំនុំជម្រះតុលាការកំពូលអាចពិនិត្យឡើងវិញបាន។ ជនជាប់ចោទលើកឡើងទៀតថា ប្រសិនបើអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេតពុំមានយុត្តាធិការក្នុងការបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះឡើយ ហើយអង្គជំនុំជម្រះសាលាដំបូង ក៏ពុំមានយុត្តាធិការក្នុងការជំនុំជម្រះខ្លួនគាត់ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលអង្គជំនុំជម្រះបានរកឃើញថារូបគាត់ជាអ្នកទទួលខុសត្រូវឡើយ។ ជនជាប់ចោទបានអះអាងថា ដោយសារតែមានកំហុសផ្នែកយុត្តាធិការជាមូលដ្ឋានបែបនេះ អង្គជំនុំជម្រះតុលាការកំពូលគួរតែទទួលយកបណ្តឹងសាទុក្ខរបស់គាត់ ហើយបដិសេធចោលការសម្រេចដាក់ពិរុទ្ធភាព និងការផ្តន្ទាទោសលើរូបគាត់។ តាមខ្លឹមសារនៃសារណារបស់ជនជាប់ចោទដែលស្នើឡើង បាន

---

[60]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៥។

[61]សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី, កថាខណ្ឌ ២០។

[62]បណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី, កថាខណ្ឌ ១៣ ដល់ ៥៥។

ឱ្យដឹងថាពាក្យថា "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺកំណត់នូវលក្ខខណ្ឌតម្រូវចាំបាច់នៃយុត្តាធិការ ដែលអង្គជំនុំជម្រះសាលាដំបូង ត្រូវតែបំពេញជាបុរេលក្ខខណ្ឌដើម្បីបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពិតជាមានយុត្តាធិការលើរូបបុគ្គលទៅលើអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ[63]។

២៤. នៅក្នុងសារណាតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានលើកឡើងថា ទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាក់ទងនឹងយុត្តាធិការលើរូបបុគ្គល មិនអាចទទួលយកបានឡើយ ដោយសារតែសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ពុំបានបំពេញតាមបទដ្ឋានអប្បបរមានៃសារណាការពារបណ្តឹងសាទុក្ខ ដែលបានកំណត់ដោយវិធាន ១០៥ នៃវិធានផ្ទៃក្នុង និងការអនុវត្តជាអន្តរជាតិ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាស្តីពីនីតិវិធីបណ្តឹងសាទុក្ខនៅក្នុងរឿងក្តីព្រហ្មទណ្ឌឡើយ[64]។ ដោយមិនមានផលប៉ះពាល់ដល់សារណានេះ សហព្រះរាជអាជ្ញាក៏បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិបដិសេធសារណារបស់មេធាវីការពារក្តីស្តីពីយុត្តាធិការលើរូបបុគ្គល ដែលធ្វើឡើងមិនទាន់ពេលវេលា[65] និងថា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញត្រឹមត្រូវក្នុងការសន្និដ្ឋានថា ពាក្យថា "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សំដៅលើជនសង្ស័យពីរប្រភេទដាច់ដោយឡែកពីគ្នា[66] និងលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញត្រឹមត្រូវ ក្នុងការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការលើរូបបុគ្គលទៅលើជនជាប់ចោទ ដោយផ្អែកទៅលើឋានៈរបស់គាត់ដែលជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល"ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវ

[63]បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌ ៣ និង ១១។ ការឆ្លើយតបរបស់មេធាវីការពារក្តី, កថាខណ្ឌ ១០។ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ ១៦ និង១៧។

[64]សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៧ ដល់ ៩។

[65]សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១២ ដល់ ២០។ ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ ៦២, ៦៦ ដល់ ៦៧ និង៧៦។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ ៩៨ (ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣)។

[66]សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២១ ដល់ ២៩។

បានប្រព្រឹត្តក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក[67]។ នៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន សហព្រះរាជអាជ្ញាពុំបានជំទាស់ទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា តាមន័យច្បាប់ ពាក្យពេចន៍នេះ គឺជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក។

២៥. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ក៏បានដាក់សារណាតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី និងបានលើកឡើងថា ការតែងតាំងជនជាប់ចោទជាអនុលេខា និងក្រោយមកជាលេខាមន្ទីរ ស ២១ "ដោយសមាជិកអចិន្ត្រៃយ៍នៃគណៈមជ្ឈិមក្នុងជំនាន់នោះ ព្រមទាំងបទពិសោធន៍របស់គាត់ ក្នុងការគ្រប់គ្រងមន្ទីរសន្តិសុខ ម ១៣ ដែលគាត់ទទួលបាននូវទំនុកចិត្តពីសមាជិកគណៈអចិន្ត្រៃយ៍" គឺជា"ភស្តុតាងបញ្ជាក់ថា គាត់មានភក្តីភាពលើរបបនេះ និងជាពិសេសទទួលបានគុណភាពជា*អ្នកសួរចម្លើយដ៏ល្អបំផុត*"[68]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ក៏បានលើកឡើងផងដែរថា មេធាវីការពារក្តីមិនបានជំទាស់ទៅនឹងយុត្តាធិការលើរូបបុគ្គលជនជាប់ចោទរបស់អង្គជំនុំជម្រះសាលាដំបូង ឱ្យបានត្រឹមត្រូវតាមនីតិវិធី[69] ហើយ បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល បដិសេធចោលទឡ្ហីករណ៍ទាំងអស់នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ដោយសារទឡ្ហីករណ៍ទាំងនោះ "គ្មានមូលដ្ឋានច្បាស់លាស់"[70]។

២៦. នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានអញ្ជើញម្ចាស់បណ្តឹងសាទុក្ខ ឱ្យធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទៅលើបញ្ហា ថាតើពាក្យថា "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" "បង្កើតជាលក្ខខណ្ឌយុត្តាធិការ ដែលតម្រូវឱ្យតុលាការពិនិត្យឡើងវិញ ឬជាគោលការណ៍ណែនាំស្តីពីឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ដែលមិន

[67] សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣០ ដល់ ៤៧។

[68] សារណាតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី ៣, កថាខណ្ឌ ១៣។

[69] សារណាតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី ៣, កថាខណ្ឌ ២២។

[70] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី ៣, កថាខណ្ឌ ២៤។

តម្រូវឱ្យតុលាការពិនិត្យឡើងវិញ" ដែរ ឬយ៉ាងណា[71]។ នៅក្នុងអំឡុងពេលសវនាការបណ្តឹងសាទុក្ខ មេធាវីការពារក្តីរបស់ជនជាប់ចោទ ពុំបានធ្វើសេចក្តីសន្និដ្ឋានឱ្យចំបញ្ហាអង្គច្បាប់នេះឡើយ។ សហព្រះរាជអាជ្ញា បានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់ថា ពាក្យពេចន៍នេះមិនមែនជាលក្ខខណ្ឌ តម្រូវផ្នែកយុត្តាធិការ ដែលអាចឱ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យករណីនេះឡើងវិញបាន ឡើយ[72]។

## ៣.ក.២.ការពិចារណា

២៧. អង្គជំនុំជម្រះតុលាការកំពូល នឹងពិចារណាលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលបានលើកឡើងថា ទឡ្ហីករណ៍ស្តីពីយុត្តាធិការលើរូបបុគ្គល ក្នុងបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ គួរតែត្រូវបានប្រកាសថាមិនអាចទទួលយកបាន ដោយហេតុថា ការជំទាស់ទៅនឹងយុត្តាធិការ មិនត្រូវបានធ្វើឡើងនៅដំណាក់កាលសមស្របនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដូចដែលតម្រូវដោយវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង ព្រោះជាការធ្វើឡើងហួសពេលកំណត់ និង/ឬ ដោយហេតុថា សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាការពារបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ពុំបានបំពេញទៅតាមបទដ្ឋាននៃសារណាការពារបណ្តឹងសាទុក្ខ ដែលតម្រូវដោយវិធាន ១០៥ នៃវិធានផ្ទៃក្នុងនោះឡើយ។

## ៣.ក.៣.អញ្ញត្រកម្មតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង

២៨. ក្នុងករណីមានការពាក់ព័ន្ធ វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុងចែងថា "អញ្ញត្រកម្មទាក់ទងទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវលើកឡើងក្នុងសវនាការបឋម បើមិនដូចនោះទេ មិនអាចត្រូវបានទទួលយកឡើយ"[73]។ គោលបំណងទូទៅនៃបទប្បញ្ញត្តិនេះ គឺ

---

[71] ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F20, កថាខណ្ឌ ១។

[72] ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារ F1/2.1 ទំព័រ ៨៣ ដល់ ៨៤។ *ប៉ុន្តែសូមមើល*ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ. ៩៤ ដល់ ៩៥ (បន្ទាត់ ២៤ ដល់ ៥) (ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣)។

[73] *សូមមើលផងដែរ* មាត្រា ៣៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ("អញ្ញត្រកម្មត្រូវតែលើកឡើងមុនដំណាក់កាលការពារដល់អង្គសេចក្តី បើពុំដូច្នេះទេពុំអាចទទួលបាន ឡើយ")។

ដើម្បីកំណត់ពីនីតិវិធីដែលផ្តល់ឱកាសឱ្យភាគី ជាពិសេស ជនជាប់ចោទអាចជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង មុនពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី។ ដូច្នេះ បទប្បញ្ញត្តិនេះ លើកកម្ពស់រដ្ឋបាលតុលាការឱ្យកាន់តែមានប្រសិទ្ធភាព និងសណ្តាប់ធ្នាប់ល្អ ដើម្បីធានាថា បញ្ហាស្តីពីយុត្តាធិការអាចត្រូវបានសម្រេចរួចរាល់ នៅមុនពេលសវនាការលើអង្គសេចក្តី ជៀសវាងការខាតបង់កិច្ចប្រឹងប្រែង និងការចំណាយប្រាក់កាសឥតប្រយោជន៍ពាក់ព័ន្ធទៅនឹងការជំនុំជម្រះដែលមិនបានការ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការក្នុងការសម្រេច[74]។

២៩. ជាទូទៅ អញ្ញត្រកម្មអំពីយុត្តាធិការត្រូវតែសម្រេចដោយផ្អែកលើភស្តុតាង ដែលអាចបង្ហាញបានភ្លាមៗចំពោះបទចោទ ដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[75]។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គ្មានការធានាថា គ្រប់ការជំទាស់អំពីយុត្តាធិការ សុទ្ធតែអាចត្រូវបានសម្រេចជាស្ថាពរនៅមុនពេលចាប់ផ្តើមសវនាការលើអង្គសេចក្តីឡើយ។ ប្រសិនបើការជំទាស់អំពីយុត្តាធិការទាក់ទងទៅនឹងការពិចារណាលើអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង នោះជាការឆាប់រហ័សពេក បើរំពឹងឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចលើការជំទាស់នេះ នៅមុនពេលដែលភស្តុតាងទាំងអស់ត្រូវបានដាក់ដេញដោល។ ប្រការនេះត្រូវបានកំណត់នៅក្នុងវិធាន ៨៩(៣) នៃវិធានផ្ទៃក្នុងដែលបានចែងថា អង្គជំនុំជម្រះសាលាដំបូងអាចចេញសេចក្តីសម្រេចរបស់ខ្លួនលើអញ្ញត្រកម្មអំពីយុត្តាធិការ នៅពេលដំណាលគ្នានឹងសាលក្រមលើអង្គ

---

[74]តុលាការ ICTY បានសង្កេតឃើញថា បទប្បញ្ញត្តិប្រហាក់ប្រហែលដែលតម្រូវឱ្យអញ្ញត្រកម្មស្តីពីយុត្តាធិការត្រូវតែធ្វើឡើងមុនពេលចាប់ផ្តើមការជំនុំជម្រះក្តី "ដើម្បីកុំធ្វើឱ្យប៉ះពាល់ដល់ការពិភាក្សាលើកិច្ចការសំខាន់នៃការជំនុំជម្រះឧក្រិដ្ឋកម្មជាលក្ខណៈអន្តរជាតិ"។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Milutinović,* សំណុំរឿងលេខ IT-05-87-T, "សេចក្តីសម្រេចលើសំណើសុំរបស់ Nebojša Pavković សម្រាប់ការបដិសេធចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹងរូបគាត់ ដោយផ្អែកលើមូលដ្ឋានថា ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដោយខុសច្បាប់", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៤, កថាខណ្ឌ ១៥។

[75]*សូមមើលរដ្ឋអាជ្ញា ទល់នឹង Norman*, សំណុំរឿងលេខ SCSL-04-14-PT-026, "សេចក្តីសម្រេចលើសំណើបឋមរបស់មេធាវីការពារក្តីស្តីពីកង្វះយុត្តាធិការលើរូបបុគ្គលដែលបានដាក់ក្នុងនាមជនជាប់ចោទ Fofana", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៤, កថាខណ្ឌ ៤៤។

សេចក្ដី។ នៅក្នុងស្ថានភាពបែបនេះ ហេតុផលចម្បងសម្រាប់កាតព្វកិច្ច ដែលតម្រូវដោយវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង (ពោលគឺ ដើម្បីជៀសវាងនូវការជំនុំជម្រះក្ដីដោយឥតប្រយោជន៍) មិនពាក់ព័ន្ធទៀតទេ នៅពេលដែលដំណើរការជំនុំជម្រះបង្ហាញឱ្យឃើញពីភស្តុតាងជាមូលដ្ឋានសំខាន់ៗ សម្រាប់ធ្វើសេចក្ដីសម្រេចលើការជំទាស់អំពីយុត្តាធិការនោះ។

៣០. លើសពីនេះទៅទៀត វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង បានចែងសំដៅលើតែ"អញ្ញត្រកម្ម"អំពីយុត្តាធិការប៉ុណ្ណោះ ដោយមិនបានចែងសំដៅលើរាល់ការជំទាស់អំពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ ភាគីត្រូវតែយល់អំពីគោលគំនិតនៃអញ្ញត្រកម្មអំពីយុត្តាធិការតាមកត្តាពីរយ៉ាង។ ទីមួយ គឺអនុលោមទៅតាមការយល់ដឹងរបស់ភាគី។ វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង បានសន្មតទុកជាមុនថា ភាគីនានាអាចរកឃើញនូវកង្វះយុត្តាធិការដែលជាបញ្ហាវិវាទនៅក្នុងអំឡុងពេលដែលបានកំណត់។ ដូច្នេះ តាមការអនុវត្តជាក់ស្ដែង វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង តុលាការអាចប្រើវិធាននេះ ដើម្បីដោះស្រាយបញ្ហាកង្វះយុត្តាធិការដែលស្ដែងឱ្យឃើញច្បាស់ ប៉ុន្តែ មិនអាចប្រើវិធាននេះ ចំពោះបញ្ហាកង្វះយុត្តាធិការដែលមិនស្ដែងឱ្យឃើញច្បាស់នោះឡើយ។ កង្វះយុត្តាធិការដែលស្ដែងឱ្យឃើញច្បាស់ គឺសំដៅលើកង្វះយុត្តាធិការដែលបង្ហាញឱ្យឃើញនៅក្នុងកិច្ចដំណើរការនីតិវិធី នៅមុនពេលកំណត់ដែលមានចែងក្នុងវិធាន៨៩(១) នៃវិធានផ្ទៃក្នុង។ កង្វះយុត្តាធិការដែលមិនស្ដែងឱ្យឃើញច្បាស់ គឺសំដៅលើកង្វះយុត្តាធិការដែលមិនបង្ហាញឱ្យឃើញនៅក្នុងកិច្ចដំណើរការនីតិវិធី ហេតុដូច្នេះហើយបានជាភាគីមិនអាចរកឃើញនៅមុនពេលកំណត់ដែលមានចែងនៅក្នុងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង[76]។

៣១. កត្តាទីពីរ គោលគំនិតនៃអញ្ញត្រកម្មអំពីយុត្តាធិការត្រូវបានបកស្រាយថា គឺជាចរិតលក្ខណៈនៃវិការៈផ្នែកយុត្តាធិការដែលរងការជំទាស់។ បញ្ហាកង្វះយុត្តាធិការដែលបានលើកឡើង អាចមានលក្ខណៈជាវិការៈដែលមិនមានអានុភាពបញ្ចប់ដំណើរការនីតិវិធី *ទាំងស្រុងទេ* ឧទាហរណ៍ ដូចជា តុលាការផ្សេងទៀតមានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីនេះ។ ដូច្នេះ បន្ទាប់ពីការចាប់ផ្ដើម

[76] *ប្រៀបធៀប* ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង (បកប្រែជាភាសាអង់គ្លេស) បានធ្វើបច្ចុប្បន្នភាពថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦, មាត្រា ១៧៣-១, ១៧៤ និង៥៩៥ <http://www.legifrance.gouv.fr/>។

សវនាការលើអង្គសេចក្តី (ឬបន្ទាប់ពីផុតរយៈពេលកំណត់ដូចមានចែងក្នុងច្បាប់) ភាគីមិនអាចលើកឡើងនូវការជំទាស់ទៅនឹងវិការៈផ្នែកយុត្តាធិការបានទេ។ មូលហេតុនៃការហាមឃាត់នេះ គឺតុលាការចាត់ទុកថា ភាគីទាំងអស់បានយល់ព្រមទៅលើយុត្តាធិការរបស់តុលាការ ដោយសារវិការៈត្រូវបានបញ្ចប់តាមរយៈការប្រព្រឹត្តិទៅនៃដំណើរការនីតិវិធី។ ប៉ុន្តែ ប្រសិនបើកង្វះយុត្តាធិការដែលបានលើកឡើងនោះ មានអានុភាពធ្វើឱ្យដំណើរការនីតិវិធីក្លាយជាមោឃៈបាន ភាគីអាចលើកឡើងនូវការជំទាស់ទៅនឹងវិការៈផ្នែកយុត្តាធិការបានគ្រប់ពេលវេលា ក្នុងអំឡុងពេលនៃដំណើរការនីតិវិធី រួមទាំងនៅដំណាក់កាលបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលផងដែរ។ ទោះបីជានីតិវិធីព្រហ្មទណ្ឌកម្ពុជាពុំមានចែងឱ្យបានច្បាស់លាស់អំពីភាពខុសគ្នានេះនៅក្នុងវិការៈផ្នែកយុត្តាធិការក៏ដោយ[77] ក៏ច្បាប់បារាំង ដែលអាចប្រើសម្រាប់ធ្វើការបកស្រាយច្បាប់កម្ពុជាបាននោះ បង្ហាញថា កាលបរិច្ឆេទដែលមានចែងក្នុងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង គប្បីមិនត្រូវយកមកអនុវត្តលើការជំទាស់ទៅនឹងយុត្តាធិការដែលអាចមោឃៈកិច្ចដំណើរការនីតិវិធីបាន[78]។ ដូចគ្នាទៅនឹងអញ្ញត្រកម្មស្តីពីយុត្តាធិការលើ

---

[77]មាត្រា ៣៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧, ("អញ្ញត្រកម្មត្រូវតែលើកឡើងមុនដំណាក់កាលការពារដល់អង្គសេចក្តី បើពុំដូច្នេះទេពុំអាចទទួលបានឡើយ")។ *ប៉ុន្តែសូមមើល* មាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ (ការរៀបរាប់អំពីអសមត្ថកិច្ចរបស់តុលាការនៅក្នុងចំណោមមូលហេតុនានានៃបណ្តឹងសាទុក្ខ)។

[78]មានភាពខុសគ្នារវាងធាតុផ្សំយុត្តាធិការដែលបញ្ចប់នីតិវិធីដាច់ខាត(ឧទាហរណ៍ ការលើកលែងទោស និងអាជ្ញាយុកាល) និងធាតុផ្សំយុត្តាធិការផ្នែកវិការៈនីតិវិធីនៅក្នុងនីតិវិធីព្រហ្មទណ្ឌបារាំង (ឧទាហរណ៍ ដីកាកោះឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការដែលមិន បានជូនដំណឹងត្រឹមត្រូវដល់ជនជាប់ចោទ គប្បីចាត់ទុកជាមោឃៈ)។ ចំពោះធាតុផ្សំយុត្តាធិការផ្នែកវិការៈស្តីពីនីតិវិធី តុលាការអាចពិចារណាបន្ទាប់ពីការកំណត់កាលបរិច្ឆេទបានបញ្ចប់ទៅលើការលះបង់សិទ្ធិរបស់ភាគីក្នុងការមិនលើកអញ្ញត្រកម្ម ប៉ុន្តែអញ្ញត្រកម្មចំពោះធាតុផ្សំយុត្តាធិការដែលបញ្ចប់នីតិវិធីដាច់ខាត អាចបានលើកឡើងគ្រប់ពេលទាំងអស់ រួមទាំងនៅចំពោះមុខតុលាការកំពូលផងដែរ។ អញ្ញត្រកម្មចំពោះធាតុផ្សំយុត្តាធិការដែលបញ្ចប់នីតិវិធីដាច់ខាតដែលមានប្រសិទ្ធភាពនោះ គឺជាការរារាំងតុលាការមិនឱ្យមានមូលដ្ឋានផ្លូវច្បាប់ក្នុងការជំនុំជម្រះលើបទឧក្រិដ្ឋ ទោះបីជាលើកទឡើងនៅពេលណា ឬតាមវិធីណាក៏ដោយ។ *សូមមើល ឧទា.* មាត្រា ១៧១, ៣០៥-១, ៣៨៥, ៣៨៥-១, ៥៨៥, ៥៩៥, ៥៩៨ និង ៨០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។ មានករណីលើកលែងចំពោះវិធានេះគឺ ប្រសិនបើជនជាប់ចោទជាអនីតិជន នៅពេលដែលប្រព្រឹត្តបទល្មើសនោះ។ Cass. crim, 31 mai 1988: Bull.crim.,n° 18។ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង (common law) បែកចែកភាពខុសគ្នារវាងអញ្ញត្រកម្មទាក់ទៅនឹងអសមត្ថកិច្ចយុត្តាធិការ។ *សូមមើល ឧទា.* តុលាការកំពូលនៃប្រទេសស្រីលង្កា បានលើកឡើងក្នុងរឿងក្តីស៊ីវិលថា:

រឿងក្តី យុត្តាធិការលើដែនដី និងយុត្តាធិការលើពេលវេលាដែរ បញ្ហាដែលថា តើជនជាប់ចោទស្ថិតនៅក្នុងដែនយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក ដែរ ឬយ៉ាងណានោះ បានបង្ហាញយ៉ាងច្បាស់ថា គឺជាធាតុផ្សំចាំបាច់នៃយុត្តាធិកា។ កាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាលើអញ្ញត្រកម្ម ចំពោះធាតុផ្សំចាំបាច់នៃយុត្តាធិការនេះ គឺដើម្បីធានាថាអញ្ញត្រកម្មទាំងនេះ នឹងអាចត្រូវបានពិចារណាយ៉ាងសមស្រប ក្នុងករណីមានការបកស្រាយដែលមានលក្ខណៈតឹងរ៉ឹងមិនសមស្របលើវិធាន ៨៩ (១)(ក) នៃវិធានផ្ទៃក្នុង ហើយដែលបណ្តាលឱ្យមានការបដិសេធអញ្ញត្រកម្មនេះ។

៣២. ការអនុវត្តដោយមានកំរិតនូវវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុងនេះ ក៏កើតចេញពីតួនាទីដ៏សំខាន់របស់ អ.វ.ត.ក ផងដែរ ដូចដែលមានចែងក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុងដែលចែងថា៖

> វិធានផ្ទៃក្នុងជាធរមាន (...) ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ (...) ជនជាប់ចោទ (...) និងដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

---

មានភាពខុសគ្នារវាងរឿងក្តីនីមួយៗដែលក្នុងនោះ តុលាការអាចមានភាពអសមត្ថកិច្ចយុត្តាធិការទៅលើករណី ឬលើបញ្ហា ឬលើភាគី និងរឿងក្តីដែលក្នុងនោះតុលាការគ្មានសមត្ថកិច្ចដោះស្រាយ ដោយសារតែមិនបានគោរពតាមលក្ខខណ្ឌតម្រូវនៃនីតិវិធី ដែលចាំបាច់ក្នុងការប្រើប្រាស់អំណាចរបស់តុលាការ...គ្មានការបោះបង់សិទ្ធិមិនលើកអញ្ញត្រកម្ម ឬការសុខចិត្តមិនលើក អាចរលត់ភាពគ្មានសមត្ថកិច្ចយុត្តាធិការបាននោះទេ ពីព្រោះភាគីមិនអាចធ្វើឱ្យតុលាការមានយុត្តាធិការនោះ ទេ ប្រសិនបើតុលាការគ្មានយុត្តាធិការនោះ។ ក្នុងរឿងក្តីដទៃទៀត នៅពេលដែលអសមត្ថកិច្ចយុត្តាធិការរបស់តុលាការ ជាលក្ខណៈយថាហេតុនោះ សាលក្រម ឬដីកាសម្រេចតុលាការនេះគ្មានសុពលភាព តែទៅលើភាគីដែលជំទាស់តែប៉ុណ្ណោះ។ ប៉ុន្តែ ចំពោះភាគីដែលមានការសុខចិត្តមិនលើក ឬលះបង់សិទ្ធិមិនលើក ឬ អំពើអកម្មណាមួយនោះ នោះភាគីមិនអាចលើកឡើងថា តុលាការគ្មានយុត្តាធិការនោះទេ។ (Dr.Ranaraja, J.,C.A.No. 659/90, M.CColombo, No.6431/5, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៧, ផ្សព្វផ្សាយក្នុងគេហទំព័រ <http://www.lawnet.lk/docs/case_law/slr/HTML/1998SLR3V320.htm>។

ក) ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាព រវាងសិទ្ធិរបស់ភាគីទាំងឡាយ (...)។

៣៣. មានគោលការណ៍ដ៏សំខាន់ចំនួនពីរបានស្តែងឡើង នៅពេលដែលវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង ត្រូវបានបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនជាប់ចោទ និងត្រូវគោរពតាមនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវតែមានយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សានូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ ទីមួយ វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង មិនអាចបដិសេធនូវបន្ទុកក្នុងការផ្តល់ភស្តុតាងនៅក្នុងដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក ឡើយ។ សហព្រះរាជអាជ្ញា គឺជាអ្នកទទួលបន្ទុកក្នុងការបង្ហាញឱ្យឃើញពីពិរុទ្ធភាពរបស់ជនជាប់ចោទ ហើយជនជាប់ចោទត្រូវបានសន្មតថា ជាជនគ្មានទោសរហូតដល់ពេលពិរុទ្ធភាពត្រូវបានរកឃើញ[79]។ ដូច្នេះ វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង មិនអាចត្រូវបានបកស្រាយក្នុងន័យបង្ខំឱ្យជនជាប់ចោទជួយសហព្រះរាជអាជ្ញានៅក្នុងរឿងក្តី ដែលប្រឆាំងនឹងខ្លួន ដោយការផ្តល់ព័ត៌មានជាមុន អំពីវិការៈផ្នែកយុត្តាធិការដែលអាចធ្វើឱ្យការជំនុំជម្រះក្តីអស់សុពលភាពបានទេ។ ទីពីរ សិទ្ធិនៅស្ងៀមមិនឆ្លើយ តបរបស់ជនជាប់ចោទ គឺមានរួមបញ្ចូលទាំងសិទ្ធិក្នុងការសម្រេចថា នៅពេលណាដែលខ្លួនត្រូវលើកឡើងនូវការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអាចធ្វើឱ្យការជំនុំជម្រះក្តីអស់សុពលភាពផងដែរ។ នៅពេលដែលជនជាប់ចោទ ទំនងជាមានផល

---

[79]មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ១៩៩៣) ដែលអនុម័តដោយសភាធម្មនុញ្ញ និងចុះហត្ថលេខាដោយប្រធាននៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ ចែងថា ("ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ")។ *សូមមើលរឿងក្តី Woolmington ទល់នឹង អគ្គរដ្ឋអាជ្ញា* (ឆ្នាំ ១៩៣៥) AC 462 at 481, (ឆ្នាំ ១៩៣៥) UKHL 1 (ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៣៥) ("នៅក្នុងប្រព័ន្ធនៃច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសអង់គ្លេស ចំណុចសំខាន់មួយដែលគេតែងតែមើលឃើញ គឺថារដ្ឋអាជ្ញាមានតួនាទីជាអ្នកបង្ហាញពីពិរុទ្ធភាពរបស់អ្នកទោស (...)។ ទោះបីមានការចោទប្រកាន់ពីបទអ្វីក៏ដោយ ឬការជំនុំជម្រះប្រព្រឹត្តឡើងនៅទីណាក៏ដោយ ក៏គោលការណ៍ដែលថា រដ្ឋអាជ្ញាជាអ្នកត្រូវបង្ហាញពិរុទ្ធភាពរបស់អ្នកទោស គឺជាផ្នែកនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង (common law) របស់ប្រទេសអង់គ្លេស ហើយពុំមានការប៉ុនប៉ងណាមួយត្រូវបានធ្វើឡើងក្នុងការលុបបំបាត់គោលការណ៍នេះឡើយ")។

ប្រយោជន៍ខាងផ្លូវច្បាប់ក្នុងការលើកឡើងអំពីអញ្ញត្រកម្ម ជាបញ្ហាចម្បងដើម្បីធ្វើឱ្យការជំនុំជម្រះគ្មានសុពលភាពនោះ តុលាការមិនអាចដាក់ទណ្ឌកម្មជនជាប់ចោទ ដោយសារជនជាប់ចោទ សម្រេចចិត្តថា មិនទាន់លើកការជំទាស់ទៅនឹងយុត្តាធិការ រហូតដល់ពេលណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ឡើយ។ ឧទាហរណ៍ ប្រសិនបើនៅពេលជិតបញ្ចប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ជនជាប់ចោទ បានលើកឡើងនូវការជំទាស់ទៅនឹងកង្វះយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអាចធ្វើឱ្យដំណើរការជំនុំជម្រះក្តីគ្មានសុពលភាព នោះតាមច្បាប់ជាធរមានរបស់ អ.វ.ត.ក ហាមមិនឱ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលការជំទាស់នោះ ដោយគ្រាន់តែផ្តល់សំអាងហេតុថា ជនជាប់ចោទមិនបានគោរពតាមកាលបរិច្ឆេទដែលបានកំណត់នៅក្នុងវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុងនោះទេ។

៣៤. តាមការបកស្រាយវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុងខាងលើនេះ ត្រូវតែយកមកពិចារណាឱ្យស្របតាមអំណាចមុខងាររបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យមានការជឿជាក់ជានិច្ចកាលថា ខ្លួនពិតជាមានយុត្តាធិការក្នុងការជំនុំជម្រះជនជាប់ចោទ។ អាចមានស្ថានភាពដែលមានការលើកឡើងពីបញ្ហាទាក់ទិននឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង នៅដំណាក់កាលក្រោយពេលផុតកំណត់ដែលមានចែងនៅក្នុងវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង។ បញ្ហាបែបនេះអាចត្រូវបានលើកឡើងដោយភាគីនានា ឬ*តាមគំនិតផ្តួចផ្តើម*របស់តុលាការ (*ex proprio motu*)។ នៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធី ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានដឹងថា ខ្លួនប្រហែលជាកំពុងអនុវត្តហួសពីយុត្តាធិការរបស់ខ្លួន ពេលនោះអង្គជំនុំជម្រះត្រូវតែពិនិត្យពិចារណាអំពីបញ្ហានេះ ហើយត្រូវធ្វើយ៉ាងណាឱ្យប្រាកដថា ខ្លួនពិតជាមានយុត្តាធិការចំពោះកិច្ចដំណើរការនីតិវិធីនេះ។ តុលាការដែលមានសមត្ថកិច្ច គឺជាបុរេលក្ខខណ្ឌនៃការជំនុំជម្រះក្តី ប្រកបដោយយុត្តិធម៌។ ការបន្តកិច្ចដំណើរការនីតិវិធីដោយមិនមានយុត្តាធិការ នឹងធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋាននៃអាណត្តិរបស់ អ.វ.ត.ក និងធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងលែងមានអំណាចស្របច្បាប់ដើម្បីជំនុំជម្រះជនជាប់ចោទ។ អាស្រ័យហេតុនេះ ការខកខានរបស់ភាគីក្នុងការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង មិនធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលបាននូវយុត្តាធិការដែលខ្លួនមិនធ្លាប់មានកន្លងមកនោះ

ទេ។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែធ្វើឱ្យប្រាកដខ្លួនឯងថា ខ្លួនពិតជាមានយុត្តាធិការ ទោះបីជា ភាគីមិនបានលើកការជំទាស់ទៅនឹងយុត្តាធិការក្នុងនីតិវិធីមុនអង្គសេចក្តី ឬក្នុងអំឡុងពេលនៃដំណើរការនីតិវិធីលើអង្គសេចក្តីក៏ដោយ។

៣៥. និយាយដោយសង្ខេប វិធាន ៨៩ (១)(ក) នៃវិធានផ្ទៃក្នុង បង្កើតនូវក្របខណ្ឌនីតិវិធីដែលតាមក្របខណ្ឌនេះ ភាគីទាំងអស់ដោយរួមទាំងជនជាប់ចោទផង ត្រូវតែអនុវត្តដើម្បីជៀសវាងបញ្ហា មុននឹងឈានដល់នីតិវិធីជំនុំជម្រះក្តី។ ផលវិបាកផ្នែកនីតិវិធីដែលកើតចេញពីការមិនបានលើកការជំទាស់ស្របតាមវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង នោះនឹងនាំឱ្យរលត់សិទ្ធិក្នុងការទាមទារឱ្យដោះស្រាយអំពីបញ្ហាយុត្តាធិការ ដោយមិនឆ្លងកាត់ការជំនុំជម្រះក្តី។ ទោះបីជាយ៉ាងណាក៏ដោយ ក៏វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង តម្រូវឱ្យអនុវត្តដោយមានកម្រិត។ ជនជាប់ចោទមានសិទ្ធិលើកឡើង នូវការជំទាស់អំពីកង្វះយុត្តាធិការដែលស្តែងឱ្យឃើញច្បាស់ ឬមិនស្តែងឱ្យឃើញច្បាស់ ដែលអាចធ្វើឱ្យការជំនុំជម្រះក្តីគ្មានសុពលភាព នៅពេលណាមួយដែលជនជាប់ចោទសម្រេចចិត្តថា ការជំទាស់ការពារផលប្រយោជន៍របស់ខ្លួន។ ដោយអនុលោមតាមវិធាន ៨៩(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងត្រូវតែពិចារណាលើការជំទាស់ណាមួយ ឬទាំងអស់ទៅនឹងយុត្តាធិការដែលបានលើកឡើងដោយជនជាប់ចោទយ៉ាងយូរបំផុត“នៅពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី”។ ទោះបីជាមិនមានភាគីណាមួយលើកឡើងនូវការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនៅតែមានកាតព្វកិច្ចធានាថា ខ្លួនពិតជាមានយុត្តាធិការលើរឿងក្តីនៅចំពោះមុខខ្លួន ទើបខ្លួនអាចចេញសាលក្រមលើអង្គសេចក្តីបាន។

៣៦. នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធការជំទាស់របស់ជនជាប់ចោទទៅនឹងយុត្តាធិការលើរូបបុគ្គល ដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តី ដោយផ្អែកលើមូលដ្ឋានថា ការជំទាស់នោះធ្វើឡើងមិនស្របតាមវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង[80]។ អង្គជំនុំជម្រះសាលាដំបូងបានបន្តដំណើរ

---

[80] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៤ ដល់ ១៥។

ការនីតិវិធី *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ដើម្បីឱ្យខ្លួនមានការជឿជាក់ថា ខ្លួនពិតជាមានយុត្តាធិការលើរូបបុគ្គលជនជាប់ចោទប្រាកដមែន[81]។ គោលជំហររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការជំទាស់ទៅនឹងយុត្តាធិការរបស់ជនជាប់ចោទ ស្តែងឱ្យឃើញពីភាពមិនច្បាស់លាស់។ ម្យ៉ាងទៀត អង្គជំនុំជម្រះសាលាដំបូងហាក់បីដូចជាទទួលស្គាល់នូវតួនាទីរបស់ខ្លួនក្នុងការពិនិត្យពិចារណាទៅលើបញ្ហាយុត្តាធិការ*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ប៉ុន្តែ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយវិធាន ៨៩(១)(ក) ដើម្បីប្រកាសថា ការជំទាស់លើយុត្តាធិការរបស់ជនជាប់ចោទ មិនអាចទទួលយកបានឡើយ។ ដូចដែលបានបកស្រាយនៅក្នុងកថាខណ្ឌមួយចំនួនខាងដើមរួចហើយ វិធាន ២១(១) នៃវិធានផ្ទៃក្នុង បានតម្រូវថា ភាពមិនច្បាស់លាស់ណាមួយដែលកើតចេញពីការបកស្រាយវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង ត្រូវដោះស្រាយទៅតាមទិសដៅនៃសិទ្ធិរបស់ជនជាប់ចោទ ក្នុងការសម្រេចថា នៅពេលណាដែលត្រូវលើកពីការជំទាស់ទៅនឹងវិការៈខាងយុត្តាធិការដែលស្តែងឱ្យឃើញច្បាស់ ឬមិនស្តែងឱ្យឃើញច្បាស់ ដែលអាចធ្វើឱ្យការជំនុំជម្រះក្តីគ្មានសុពលភាពបាន និងកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបញ្ជាក់ពីយុត្តាធិការរបស់ខ្លួន។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្ទៀងផ្ទាត់ការបកស្រាយវិធាន ៨៩(១)(ក)របស់ខ្លួនទៅនឹងវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងខកខានក្នុងការពិចារណា ថាតើកង្វះយុត្តាធិការដែលត្រូវបានលើកឡើងនោះ ជាកង្វះយុត្តាធិការដែលស្តែងឱ្យឃើញច្បាស់ ឬមិនស្តែងឱ្យឃើញច្បាស់ ឬថាតើការជំទាស់នោះអាច ឬមិនអាចធ្វើឱ្យការជំនុំជម្រះក្តីគ្មានសុពលភាព ដែរ ឬយ៉ាងណា។ ការខកខានបែបនេះ គឺជាកំហុសអង្គច្បាប់ដែលនាំឱ្យសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការមិនបានពិចារណាលើការជំទាស់របស់ជនជាប់ចោទ ក្លាយទៅជាគ្មានសុពលភាព។ ទោះបីជា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបញ្ជាក់អំពីយុត្តាធិការ*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* មិនបានលុបបំបាត់កំហុសអង្គច្បាប់របស់ខ្លួនក៏ដោយ ក៏សេចក្តីសម្រេចនេះមានអានុភាពកាត់បន្ថយកំហុសអង្គច្បាប់របស់ខ្លួន នៅត្រង់ចំណុចដែលថា សេចក្តីសម្រេចនេះបានផ្តល់លទ្ធភាពឱ្យជនជាប់ចោទដាក់បណ្តឹងសាទុក្ខ ដោយមានព័ត៌មានគ្រប់គ្រាន់។

[81] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៧ ដល់ ២៥។

៣៧. អង្គជំនុំជម្រះតុលាការកំពូលក៏កត់សំគាល់ផងដែរថា គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុងដែលកំណត់ថា ការដែលជនជាប់ចោទខកខានក្នុងការអនុវត្តតាមវិធានផ្ទៃក្នុងដែលចែងជាក់លាក់អំពីដំណើរការនីតិវិធីជំនុំជម្រះក្តី អាចកម្រិតអំពីវិសាលភាពនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទប្រឆាំងនឹងសាលក្រមនោះទេ។ វិធានផ្ទៃក្នុងមិនអាចត្រូវបានបកស្រាយក្នុងន័យផ្សេងពីនេះបានទេ ដោយសារជនជាប់ចោទត្រូវបានតុលាការសម្រេចថា មានពិរុទ្ធភាពពីបទឧក្រិដ្ឋ ដូច្នេះ ជនជាប់ចោទត្រូវមាន"សិទ្ធិស្នើសុំឱ្យសាលាជម្រះក្តីជាន់ខ្ពស់ ពិនិត្យអំពីពិរុទ្ធភាព និងការផ្តន្ទាទោសរបស់ខ្លួនឡើងវិញតាមច្បាប់"[82]។ ផ្អែកតាមមូលដ្ឋាននៃសិទ្ធិនេះ ជនជាប់ចោទមានសិទ្ធិប្តឹងសាទុក្ខប្រឆាំងនឹងកំហុសអង្គច្បាប់ ឬអង្គហេតុណាមួយដែលអាចធ្វើឱ្យសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមោឃៈ ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌ រួមទាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើយុត្តាធិការលើរូបបុគ្គលផង ដែរ[83]។ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទស្តីពីយុត្តាធិការនេះ បានបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យទាំងពីរ ដោយសារតែបណ្តឹងសាទុក្ខនេះ បានលើកឡើងអំពីបញ្ហារួមគ្នានៃអង្គហេតុ និងអង្គច្បាប់ដែលនឹងអាចមោឃៈមូលដ្ឋានច្បាប់គាំទ្រការសម្រេចអំពីពិរុទ្ធភាពប្រឆាំងរូបគាត់ ប្រសិនបណ្តឹងសាទុក្ខនេះត្រឹមត្រូវតាមច្បាប់។ លើសពីនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលមានអំណាចតាមច្បាប់ ដើម្បីធានាឱ្យខ្លួនមានការជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងពិតជាមានយុត្តាធិការក្នុងការជំនុំជម្រះជនជាប់ចោទប្រាកដមែន។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលមានអំណាចតាមតួនាទី ដើម្បីពិនិត្យសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងស្តី

---

[82]មាត្រា ១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលត្រូវបានអនុម័តនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦, វ៉ុល ៩៩៩ លេខលំដាប់សន្ធិសញ្ញាអង្គការសហប្រជាជាតិ ទំព័រ ១៧១ (999 UNTS 171) (ចូលជាធរមាន នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦), ("ICCPR")។ *សូមមើលផងដែរ* គណៈកម្មាធិការស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, សេចក្តីអត្ថាធិប្បាយទូទៅលេខ ៣២ - មាត្រា ១៤៖ សិទ្ធិក្នុងការទទួលបានសមភាពនៅចំពោះមុខតុលាការ និងតុលាការឧក្រិដ្ឋកម្មនានា និងទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌, ឯកសារអង្គការសហប្រជាជាតិ CCPR/C/GC/32 (ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧), កថាខណ្ឌ ៤៥ ដល់ ៥១។

[83]វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

អំពីយុត្តាធិការឡើងវិញ[84]។ ប្រសិនបើ ជនជាប់ចោទមិនបានធ្វើបណ្តឹងសាទុក្ខលើបញ្ហាយុត្តាធិការទេនោះ អង្គជំនុំជម្រះតុលាការកំពូលនឹងប្រើអំណាចដែលមានក្នុងរឿងក្តីនេះ ដោយហេតុថា បញ្ហានេះ គឺជាបញ្ហាមួយដែលមានសារៈសំខាន់ជាទូទៅចំពោះយុត្តិសាស្ត្រ និងយុត្តាធិការរបស់ អ.វ.ត.ក ហើយច្បាស់ណាស់ថា បញ្ហានេះមានទំនាក់ទំនងគ្រប់គ្រាន់ជាមួយនឹងអំណះអំណាង ដែលបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងនៅក្នុងបណ្តឹងសាទុក្ខនេះ។

៣៨. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណារបស់សហព្រះរាជអាជ្ញាដែលលើកឡើងថា បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីស្តីពីយុត្តាធិការលើរូបបុគ្គល មិនអាចទទួលយកបានដោយផ្អែកលើមូលដ្ឋានថា ពុំបានអនុវត្តតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង។

## ៣.ក.៤.បទដ្ឋាននៃសារណាបណ្តឹងសាទុក្ខ

៣៩. បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូល នឹងពិនិត្យលើសារណារបស់សហព្រះរាជអាជ្ញាដែលលើកឡើងថា សារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទគួរត្រូវបានប្រកាសមិនអាចទទួលយកបានឡើយ ដោយសារតែសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ពុំបានបំពេញតាមបទដ្ឋានអប្បបរមានៃសារណាការពារបណ្តឹងសាទុក្ខដែលមានចែងនៅក្នុងវិធាន ១០៥ នៃវិធានផ្ទៃក្នុង និងការអនុវត្តជាអន្តរជាតិដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ស្តីពីនីតិវិធីបណ្តឹងសាទុក្ខនៅក្នុងរឿងក្តីព្រហ្មទណ្ឌ[85]។ ជាពិសេស សហព្រះរាជអាជ្ញាបានអះអាងថា សារណារបស់ជនជាប់ចោទ មិនបាននិយាយយោងច្បាស់លាស់ទៅរកផ្នែកដែលខ្លួនបានលើកឡើងនៅក្នុងប្រតិចារឹកនៃដំណើរការនីតិវិធី ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ។ សហព្រះរាជអាជ្ញាអះអាងថា ជនជាប់ចោទបានលើកទឡ្ហីករណ៍ដែលមិនច្បាស់លាស់មានភាពផ្ទុយគ្នា ភាពស្រពិចស្រពិល ឬលើកទឡ្ហីករណ៍មិនគ្រប់គ្រាន់ និង

---

[84] *សូមមើលសាលដីកាក្នុងរឿងក្តី* *Boškoski និង Tarčulovski*, កថាខណ្ឌ ១៩ (ដោះស្រាយទៅលើបញ្ហាយុត្តាធិការ*តាមឆន្ទានុសិទ្ធិរបស់ខ្លួន*ដើម្បីផលប្រយោជន៍នៃយុត្តិធម៌)។

[85] សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៧ ដល់ ៩។

បានរិះគន់សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដោយគ្មានមូលដ្ឋានច្បាប់ ឬគ្មានទទ្បីករណ៍តបទៅនឹងកំហុសឆ្គងដែលបានលើកឡើងនោះឡើយ ហើយបានលើកសំអាងហេតុខុសអំពីអង្គហេតុ និងអង្គច្បាប់ផងដែរ[86]។

៤០. វិធានផ្ទៃក្នុងទាក់ទិនទៅនឹងការធ្វើសេចក្តីសម្រេចលើសារណារបស់សហព្រះរាជអាជ្ញា មានចែងដូចខាងក្រោមនេះ៖

> វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុងចែងថា ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលបញ្ជាក់ពីមូលដ្ឋាននីមួយៗ ត្រូវបញ្ជាក់ពីកំហុសអង្គច្បាប់ ដែលនាំឱ្យសេចក្តីសម្រេចនោះមោឃៈ និងកំហុសអង្គហេតុ ដែលនាំឱ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ បន្ទាប់មកម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់សារណាបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីទទ្បីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗអនុលោមតាមលក្ខខណ្ឌនៅក្នុងវាក្យខណ្ឌ ២ (ក) និង (គ) នៃវិធាននេះ។
>
> (៤) រាល់បណ្តឹងសាទុក្ខត្រូវបង្ហាញផងដែរអំពីមូលដ្ឋាន ឬខ្លឹមសារនៃសេចក្តីសម្រេចដែលខ្លួនជំទាស់ ដោយយោងលេខទំព័រ និងវាក្យខណ្ឌជាក់លាក់នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។
>
> វិធាន ១១១(២) នៃវិធានផ្ទៃក្នុង នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បណ្តឹងសាទុក្ខធ្វើឡើងហួសពេលកំណត់ ឬធ្វើឡើងដោយមានកំហុសនីតិវិធី អង្គជំនុំជម្រះតុលាការកំពូលអាចប្រកាសថា បណ្តឹងសាទុក្ខនោះមិនអាចទទួលយកបាន។

៤១. បទប្បញ្ញត្តិទាំងនេះ តម្រូវឱ្យគ្រប់ភាគីនៃបណ្តឹងសាទុក្ខលើកហេតុផលរបស់ខ្លួន ដោយមានទទ្បីករណ៍ជាក់លាក់គ្រប់គ្រាន់ ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលមានលទ្ធភាពកំណត់បញ្ហា

[86]សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៨ ដល់ ៩។

វិវាទ ដោយយោងទៅលើសំអាងហេតុជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូង។ បទប្បញ្ញត្តិទាំងនេះ មានគោលបំណងមិនត្រឹមតែធានាប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះទេ គឺថែមទាំងធានាថា ភាគីនីមួយៗត្រូវដឹងនូវអំណះអំណាងនានា ដែលខ្លួនអាចធ្វើការឆ្លើយតបបាន។ ដូចដែលតុលាការ ICTY បានកត់សម្គាល់ ទាក់ទិនទៅនឹងបទប្បញ្ញត្តិប្រហាក់ប្រហែលគ្នានេះនៅក្នុងវិធាននៃនីតិវិធីរបស់ខ្លួនថា "ប្រសិនបើសារណាទាំងនោះមានលក្ខណៈមិនច្បាស់លាស់ ផ្ទុយគ្នា ស្រពិចស្រពិល ឬមានវិការៈខាងទម្រង់បែបបទ និងមានចំណុចខ្វះខាតជាក់ស្តែងផ្សេងទៀតនោះ គេមិនអាចរំពឹងឱ្យតុលាការកំពូលពិចារណាលើសារណារបស់ភាគីបានលម្អិតឡើយ"[87]។ ជាវិធានទូទៅ ច្បាប់តម្រូវឱ្យម្ចាស់បណ្តឹងសាទុក្ខបង្ហាញនូវផ្នែកនៃប្រតិចារឹកដែលខ្លួនតវ៉ា បង្ហាញនូវអំណះអំណាងក្នុងកម្រិតមួយ ដែលមានភាពច្បាស់លាស់សមហេតុផលជូនអង្គជំនុំជម្រះសាលាដំបូងឱ្យចំបញ្ហា និងបញ្ជាក់ឱ្យបានច្បាស់លាស់នូវទឡ្ហីករណ៍បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច និងអំណះអំណាងគាំទ្រសំខាន់ៗ[88]។ កាលណាសារណារបស់ភាគីមិនស៊ីសង្វាក់គ្នា ឬខកខានក្នុងការលើកឡើងនូវខ្លឹមសារនៃទឡ្ហីករណ៍ណាមួយនៃបណ្តឹងសាទុក្ខ ដែលមានលក្ខណៈពិសេសគ្រប់គ្រាន់ និងអាចឱ្យអង្គជំនុំជម្រះតុលាការកំពូលមានលទ្ធភាពកំណត់បញ្ហាវិវាទបាននោះទេ នោះសារណាទាំងនេះអាចត្រូវបានប្រកាសបដិសេធចោល ដោយសារមានវិការៈផ្នែកនីតិវិធី[89]។ ពាក្យថា "អាច" នៅក្នុងវិធាន ១១១(២) នៃវិធានផ្ទៃក្នុងបង្ហាញថា អំណាចដែលផ្តល់ដោយវិធានផ្ទៃក្នុងនេះគឺជាអំណាចឆន្ទានុសិទ្ធិ។ ការពិចារណាជាចម្បងរបស់អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងការប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន គឺដើម្បីរក្សាសិទ្ធិឱ្យជនជាប់ចោទអាចធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងការសម្រេចដាក់

[87]សាលដីកាក្នុង*រឿងក្តី Galić*, កថាខណ្ឌ ១១។

[88]*សូមមើលរឿងក្តីរដ្ឋអាជ្ញា ទល់នឹង Ntakirutimana*, សំណុំរឿងលេខ ICTR-96-10-A និង ICTR-96-17-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤, ("សាលដីកាក្នុង*រឿងក្តី Ntakirutimana*"), កថាខណ្ឌ ៣៩៦។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kordić និង Čerkez*, សំណុំរឿងលេខ IT-95-14/2-A, "សាលដីកា",អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤, ("សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez*"), កថាខណ្ឌ ២៣។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kvočka*, សំណុំរឿងលេខ IT-98-30/1-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥, ("សាលដីកាក្នុង*រឿងក្តី Kvočka*"), កថាខណ្ឌ ៤២៥។

[89]វិធាន ១១១(២) នៃវិធានផ្ទៃក្នុង។

ពិរុទ្ធភាព និងការផ្តន្ទាទោសលើខ្លួន។ អង្គជំនុំជម្រះតុលាការកំពូលមិនមានមុខងារក្នុងការពិនិត្យអំពីគុណភាព នៃសារណាការពារបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទឡើយ។

៤២. នៅក្នុងរឿងក្តីនេះ បញ្ហាសំខាន់ៗសម្រាប់ធ្វើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទអំពីយុត្តាធិការលើរូបបុគ្គល មានលក្ខណៈងាយស្រួលអាចកំណត់អត្តសញ្ញាណបានដែរ។ តាមខ្លឹមសារនៃបណ្តឹងសាទុក្ខខាងលើជនជាប់ចោទ (ក) បានលើកឡើងដោយបង្កប់អត្ថន័យថា ពាក្យពេចន៍"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក ហើយ (ខ) បានលើកឡើងដោយមានអត្ថន័យច្បាស់លាស់ថា តាមអង្គហេតុដែលមានភស្តុតាងច្បាស់លាស់ ជនជាប់ចោទមិនមែនជា"មេដឹកនាំជាន់ខ្ពស់" ហើយក៏មិនមែនជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល"ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក នោះទេ។ ដូចគ្នានេះដែរ ផ្នែកពាក់ព័ន្ធនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈអាចកត់សម្គាល់បានយ៉ាងងាយ និងកំណត់បានយ៉ាងច្បាស់ពីសំអាងហេតុដែលនាំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសន្និដ្ឋានបានថា ជនជាប់ចោទ គឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល"ទទួលខុសត្រូវខ្ពស់បំផុត"[90]។ នៅក្នុងកាលៈទេសៈពិសេសទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលអាចពិចារណាលើអង្គសេចក្តីនៃទឡ្ហីករណ៍បណ្តឹងសាទុក្ខនេះ និងពិនិត្យឡើងវិញនូវសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដោយពិចារណាលើអំណះអំណាងដែលត្រូវបានលើកឡើងក្នុងនាមជនជាប់ចោទ អំណះអំណាងរបស់សហព្រះរាជអាជ្ញា និងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣។ ការលើកឡើងដូច្នេះ មិនមែនមានន័យថា អង្គជំនុំជម្រះតុលាការកំពូលមិនបានយកចិត្តទុកដាក់ចំពោះការមិនអនុវត្តតាមវិធាន ១០៥ នៃវិធានផ្ទៃក្នុងនោះទេ។ លក្ខខណ្ឌតម្រូវសម្រាប់សារណាដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ មានលក្ខណៈច្បាស់លាស់ និងចាប់បង្ខំ ហើយក្នុងករណីសមស្រប និងដោយអនុលោមតាមវិធាន

[90]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៣ ដល់ ២៥។

១១១(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល នឹងអនុវត្តអំណាចរបស់ខ្លួនដោយមិនស្ទាក់ស្ទើរក្នុងការប្រកាសបដិសេធអំណះអំណាង ដែលមាននៅក្នុងសារណាដែលមានវិការៈផ្នែកនីតិវិធីដោយសារតែអំណះអំណាងនោះគ្មានភាពស៊ីសង្វាក់គ្នា ឬគ្មានភាពជាក់លាក់គ្រប់គ្រាន់។ បញ្ហាសំខាន់ដែលត្រូវសម្រេចចុងក្រោយនោះ គឺថាតើម្ចាស់បណ្ដឹងសាទុក្ខបានលើកមូលហេតុរបស់ខ្លួន ក្នុងលក្ខណៈដែលផ្ដល់លទ្ធភាពឱ្យភាគីបដិបក្ខ អាចដឹងអំពីបញ្ហាដែលខ្លួនត្រូវប្រឈម និងដែលផ្ដល់លទ្ធភាពឱ្យអង្គជំនុំជម្រះតុលាការកំពូលអាចកំណត់ និងសម្រេចបានលើបញ្ហាវិវាទបាន ដែរ ឬយ៉ាងណា។ បញ្ហា ថាតើលក្ខខណ្ឌតម្រូវត្រូវបានបំពេញ ឬមិនត្រូវបានបំពេញនោះ គឺអាស្រ័យលើកាលៈទេសៈ និងជាពិសេស លើចរិតលក្ខណៈនៃការជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។

៤៣. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលសារណារបស់សហព្រះរាជអាជ្ញាដែលបានលើកឡើងថា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទអំពីយុត្តាធិការលើរូបបុគ្គលមិនអាចទទួលយកបាន ដោយផ្អែកលើមូលដ្ឋានថា សារណាជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទមិនបានគោរពតាមវិធានផ្ទៃក្នុងនោះ។

## ៣.ក.៥.យុត្តាធិការលើរូបបុគ្គល

៤៤. បញ្ហាយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក គឺជាបញ្ហាស្នូលនៃសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី[91]។ សំណើរបស់ជនជាប់ចោទដែលសុំរួចខ្លួនដោយផ្អែកលើមូលដ្ឋានថារូបគាត់មិនស្ថិតនៅក្រោមពាក្យពេចន៍"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"នោះ បានសន្និតទុកជាមុនថា ពាក្យពេចន៍ទាំងមូល ឬមួយផ្នែក គឺជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក ដែលត្រូវតែបានបំពេញទើបអាចឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះក្ដីលើរូបគាត់បាន។ ប្រសិនបើ ការសន្និតទុកជាមុនបែបនេះពិតជាការត្រឹមត្រូវ ហើយប្រសិនបើ ជនជាប់ចោទមិនស្ថិតក្រោមពាក្យពេចន៍

---

[91] *សូមមើលខទា.*ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1 ទំព័រ ១១។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១ , ឯកសារលេខ F1/4.1, ទំព័រ ១០៨ ដល់ ១១៥។

នេះទេនោះ អង្គជំនុំជម្រះសាលាដំបូង ក៏គ្មានយុត្តាធិការក្នុងការជំនុំជម្រះក្តីលើជនជាប់ចោទដែរ ហេតុដូច្នេះ ការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ និងការផ្តន្ទាទោស ពុំមានសុពលភាព ហើយជនជាប់ចោទត្រូវបានដោះលែងជាបន្ទាន់[92] និងគ្មានលក្ខខណ្ឌផងដែរ។ ហេតុដូច្នេះ ដើម្បីធ្វើការសម្រេចអំពីបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូលចាំបាច់ត្រូវតែវាយតម្លៃទៅតាមផ្លូវច្បាប់លើពាក្យថា "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"ក្នុងការកំណត់ ថាតើពាក្យពេចន៍នេះ ទាំងមូល ឬមួយផ្នែកដែលជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក នោះ។ ប៉ុន្តែ ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណាជាមុននូវបញ្ហាវិវាទរវាងភាគីនានា ថាតើពាក្យពេចន៍"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"នេះ សំដៅលើបុគ្គលតែមួយប្រភេទ ឬបុគ្គលពីរប្រភេទ[93]។

### *៣.ក.៥.ក. វិសាលភាពនៃពាក្យថា "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"*

៤៥. ជនជាប់ចោទបានអះអាងថា ពាក្យនេះ សំដៅលើតែបុគ្គលមួយប្រភេទប៉ុណ្ណោះ គឺថា មេដឹកនាំជាន់ខ្ពស់ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[94]។ យោងតាមសំដីរបស់ជនជាប់ចោទនេះ ខ្លួនគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ហេតុដូច្នេះខ្លួនគាត់មិនត្រូវបានគ្របដណ្តប់ដោយពាក្យពេចន៍នេះទេ ហើយតុលាការត្រូវតែសម្រេចឱ្យគាត់រួចផុតពីបទចោទ និងត្រូវដោះលែងគាត់ជាបន្ទាន់[95]។ សហព្រះរាជអាជ្ញា[96] សហចៅក្រមស៊ើបអង្កេត[97]

[92]បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌ ១០០ ដល់ ១០១។

[93]ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ ៥១ ដល់ ៥២ និង ទំព័រ ៨៣ ដល់ ៨៤។

[94]ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ ៥១ ដល់ ៥៣។

[95]ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ ៣១ ដល់ ៣២។

[96]សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២១ ដល់ ២៩។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ ៧៨ និង ទំព័រ ៨៣ ដល់ ៨៥។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ ៩១ (ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣)។

[97]ដីការដំណោះស្រាយ, កថាខណ្ឌ ១២៩។

និងអង្គជំនុំជម្រះសាលាដំបូង[98] បានបកស្រាយពាក្យ "និង"នៅក្នុងពាក្យពេចន៍ខាងលើដោយដាច់ចេញពីគ្នាថា ពាក្យនេះ សំដៅលើបុគ្គលពីរប្រភេទដាច់ដោយឡែកពីគ្នា ដែលមានន័យថា មេដឹកនាំជាន់ខ្ពស់ ឬជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។

៤៦. ជំហានដំបូង ក្នុងការបកស្រាយលើវិសាលភាពនៃពាក្យថា"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺត្រូវពិនិត្យមើលប្រវត្តិនៃការចរចាដែលទាក់ទងទៅនឹងគោលដៅ ដែលបានកំណត់ដើម្បីធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋនៅចំពោះមុខ អ.វ.ត.ក។ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧ នាយករដ្ឋមន្ត្រីទីមួយ និងនាយករដ្ឋមន្ត្រីទីពីរនៃព្រះរាជាណាចក្រកម្ពុជា បានសរសេរលិខិតផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិដើម្បីស្នើសុំ"ជំនួយពីអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិដើម្បីកាត់សេចក្តីជនទាំងឡាយដែលទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩"[99]។ ទោះបីជាសំណើសុំរបស់នាយករដ្ឋមន្ត្រីទាំងពីរ មិនបានលើកឡើងឱ្យបានច្បាស់លាស់ថា ខ្មែរក្រហម គឺជាគោលដៅសម្រាប់ការស្វែងរកយុត្តិធម៌ក៏ដោយ ក៏ក្រោយមកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានសង្ខេបសំណើសុំជំនួយនេះថា ជា"សំណើលើកដំបូងរបស់កម្ពុជាដើម្បីសុំជំនួយពីអង្គការសហប្រជាជាតិ ក្នុងការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម"[100]។

៤៧. នៅក្នុងសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥២/១៣៥ ដែលបានអនុម័តនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៧ បានលើកឡើងថាខ្លួន៖

---

[98]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៧ ដល់ ២៥។

[99]កូហ្វីអាណាន់ *លិខិតដូចគ្នាចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៧ ពីអគ្គលេខាធិការជូនចំពោះប្រធានមហាសន្និបាត និងជូនចំពោះប្រធានក្រុមប្រឹក្សាសន្តិសុខ,* សម័យប្រជុំលើកទី ៥១, របៀបវារៈលេខ ១១០, ឯកសារអង្គការសហប្រជាជាតិ A/51/930 និង S/1997/488 (ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៧), ឧបសម្ព័ន្ធ ("លិខិតចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧ ពីនាយករដ្ឋមន្ត្រីទីមួយ និងទីពីរនៃរាជរដ្ឋាភិបាលកម្ពុជាជូនចំពោះអគ្គលេខាធិការ"), ទំព័រ ២។

[100]កូហ្វីអាណាន់ *សំណួរស្តីពីសិទ្ធិមនុស្ស: លិខិតដូចគ្នាចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ពីអគ្គលេខាធិការជូនចំពោះប្រធានមហាសន្និបាត និងជូនចំពោះប្រធានក្រុមប្រឹក្សាសន្តិសុខ,* សម័យប្រជុំលើកទី ៥៣, របៀបវារៈលេខ ១១០ (ខ), ឯកសារអង្គការសហប្រជាជាតិ A/53/850-S/1999/231 (១៦ មីនា ឆ្នាំ ១៩៩៩), ទំព័រ ៣។

១៥. *គាំទ្រ* មតិយោបល់របស់អ្នកតំណាងពិសេសដែលបានលើកឡើងថា ការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុត នៅក្នុងប្រទេសកម្ពុជាក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ ត្រូវបានប្រព្រឹត្តិឡើងដោយខ្មែរក្រហម និងថាបទឧក្រិដ្ឋរបស់ពួកខ្មែរក្រហម ដែលរួមមានការចាប់ និងការសម្លាប់ចំណាប់ខ្មាំង បានបន្តរហូតមកដល់ពេលបច្ចុប្បន្ន និងកត់សម្គាល់ដោយមានក្តីព្រួយបារម្ភថា មិនទាន់មានមេដឹកនាំខ្មែរក្រហមណាម្នាក់ត្រូវបានកាត់សេចក្តីឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់ខ្លួននៅឡើយ។

១៦. *ស្នើសុំ* អគ្គលេខាធិការអង្គការសហប្រជាជាតិឱ្យពិនិត្យសំណើសុំជំនួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លើយតបទៅនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ កាលពីអតីតកាល ដោយរួមទាំងលទ្ធភាពរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងការតែងតាំងអ្នកជំនាញមួយក្រុម ដើម្បីវាយតម្លៃភស្តុតាងដែលមាន និងលើកសំណើបន្ថែមនូវវិធានការដើម្បីជាមធ្យោបាយនាំមកនូវការផ្សះផ្សាជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការដោះស្រាយបញ្ហានៃការទទួលខុសត្រូវរបស់បុគ្គល[101]។

៤៨. នៅក្នុងខែ កក្កដា ឆ្នាំ ១៩៩៨ អគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្កើតក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជាដែលមានសមត្ថកិច្ចដូចខាងក្រោមនេះ៖

(ក) វាយតម្លៃភស្តុតាងដែលមាន ដើម្បីកំណត់ប្រភេទបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហមនៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

---

[101]*ស្ថានការណ៍នៃសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា,* សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥, សម័យប្រជុំលើកទី ៥២, កិច្ចប្រជុំពេញអង្គលើកទី ៧០, របៀបវារៈលេខ ១១២ (ខ), ឯកសារអង្គការសហប្រជាជាតិ A/Res/52/135 (ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៨)។ នៅក្នុងលិខិតដូចគ្នារបស់គាត់ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ជូនចំពោះប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខ អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិបានរំឭកថា សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ "បានស្នើសុំខ្ញុំឲ្យពិនិត្យសំណើរបស់រដ្ឋាភិបាលកម្ពុជាស្នើសុំជំនួយដើម្បីឆ្លើយតបទៅនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិកាលពីអតីត និងជាពិសេសការរំលោភបំពានដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ហើយក្នុងន័យនេះ គឺដើម្បីពិនិត្យអំពីលទ្ធភាពតែងតាំងក្រុមអ្នកជំនាញ"។ កូហ្វីអាណាន់ *លិខិតដូចគ្នាចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩*, ទំព័រ ១។

(ខ) បន្ទាប់ពីពិគ្រោះយោបល់ជាមួយរដ្ឋាភិបាលពាក់ព័ន្ធនានាត្រូវវាយតម្លៃអំពីលទ្ធភាពនៃការនាំខ្លួនមេដឹកនាំខ្មែរក្រហមមកកាត់សេចក្តី និងវាយតម្លៃអំពីការចាប់ខ្លួន ការឃុំខ្លួន និងការធ្វើបត្យាប័ន ឬការប្រគល់ខ្លួនទៅឱ្យតុលាការព្រហ្មទណ្ឌ ដែលមានយុត្តាធិការ។

(គ) ស្វែងរកជម្រើសនានា សម្រាប់កាត់សេចក្តីមេដឹកនាំខ្មែរក្រហម នៅចំពោះមុខយុត្តាធិការអន្តរជាតិ ឬយុត្តាធិការជាតិ[102]។

៤៩. ក្រុមអ្នកជំនាញបានយល់ពីដែនសមត្ថកិច្ច ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានផ្តល់ឱ្យខ្លួនដូចខាងក្រោមនេះ៖

សមត្ថកិច្ចនេះត្រូវបានកំណត់ត្រឹមតែអំពើទាំងឡាយរបស់ខ្មែរក្រហម ហើយមិនរួមបញ្ចូលនូវអំពើរបស់បុគ្គល ឬរបស់រដ្ឋនានា ដែលបានប្រព្រឹត្តិអំពើរំលោភបំពានលើសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា នៅមុនអំឡុងពេល ក្នុងអំឡុងពេល ឬនៅក្រោយអំឡុងពេលឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ។ សមត្ថកិច្ចនេះសំអាងលើសំណើសុំរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលបានដកស្រង់ខាងលើ។ ក្រុមអ្នកជំនាញ បានគាំទ្រចំពោះការកំណត់សមត្ថកិច្ចនេះ ដោយផ្តោតទៅលើប្រភេទពិសេសនៃឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម[103]។

៥០. អាស្រ័យហេតុនេះ ក្រុមអ្នកជំនាញបានផ្តល់អនុសាសន៍ថា "ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់រាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧ អង្គការសហប្រជាជាតិត្រូវបង្កើតតុលាការអន្តរជាតិពិសេសមួយ ដើម្បីជំនុំជម្រះកម្មាភិបាលខ្មែរក្រហមពីបទឧក្រិដ្ឋ

---

[102]កូហ្វីអាណាន់ *លិខិតដូចគ្នាចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩*, ឧបសម្ព័ន្ធ ("របាយការណ៍អ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបង្កើតឡើងដោយអនុលោមតាមសេចក្តីសម្រេច លេខ ៥២/១៣៥ របស់មហាសន្និបាត") ("របាយការណ៍របស់អ្នកជំនាញ"), កថាខណ្ឌ ៦។

[103]របាយការណ៍អ្នកជំនាញ, កថាខណ្ឌ ១០។

ប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩”[104]។

៥១. កំណត់ហេតុប្រវត្តិនៃការចរចាបានបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលកម្ពុជាក៏មានបំណង ផងដែរថា កម្មាភិបាលខ្មែរក្រហម គឺជាគោលដៅតែមួយសម្រាប់ការចោទប្រកាន់ខាង បទឧក្រិដ្ឋនៅចំពោះមុខ អ.វ.ត.ក[105]។

៥២. ដោយពិនិត្យឡើងវិញពីប្រវត្តិនៃការចរចា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ក្នុង កម្រិតអប្បបរមានៃពាក្យថា “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែល ទទួលខុសត្រូវខ្ពស់បំផុត”បានឆ្លុះបញ្ចាំងនូវគោលបំណងរបស់អង្គការសហប្រជាជាតិ និងរាជ រដ្ឋាភិបាលកម្ពុជា ក្នុងការប្រមូលផ្តុំធនធានដែលមានកម្រិត ដើម្បីធ្វើការចោទប្រកាន់ពីបទ ឧក្រិដ្ឋទៅលើកម្មាភិបាលខ្មែរក្រហមមួយចំនួន ដែលនៅរស់រានមានជីវិត។ អង្គជំនុំជម្រះ តុលាការកំពូលយល់ឃើញផងដែរថា ពាក្យពេចន៍នេះមិនរាប់បញ្ចូលនូវបុគ្គលទាំងឡាយណា ដែលមិនមែនជាកម្មាភិបាលខ្មែរក្រហមនោះទេ។

៥៣. នៅពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិនិត្យពិចារណា ថាតើពាក្យពេចន៍នេះសំដៅលើ កម្មាភិបាលខ្មែរក្រហមមួយប្រភេទ ឬពីរប្រភេទដែលនៅរស់រានមានជីវិត ដែរ ឬយ៉ាងណា។ ប្រវត្តិនៃការរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានផ្តល់នូវ ចម្លើយយ៉ាងច្បាស់ចំពោះបញ្ហានេះ។ ក្នុងអំឡុងកិច្ចពិភាក្សានៅក្នុងរដ្ឋសភាស្តីពីកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងវិសោធនកម្មច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្នាំ ២០០១ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានពន្យល់អំពីវិសាលភាពនៃ

---

[104] របាយការណ៍អ្នកជំនាញ, កថាខណ្ឌ ២១៩(១)។

[105] *សូមមើលជាទូទៅលើសម័យប្រជុំលើកទីមួយនៃនីតិកាលទីបីរបស់រដ្ឋសភាជាតិកម្ពុជា ថ្ងៃទី ៤-៥ ខែ តុលា ឆ្នាំ ២០០៤,* ‘ការពិភាក្សា និងការអនុម័តកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងការអនុម័តវិសោធន កម្ម លើច្បាប់ស្តីពីការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម” (បកប្រែជាភាសាអង់គ្លេសចំនួន ២៩ ទំព័រ នៅក្នុងសំណុំ ឯកសាររបស់អង្គជំនុំជម្រះតុលាការកំពូល)។

ពាក្យថា"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដូចខាងក្រោមនេះ៖

(...) មាត្រា ២ [នៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក] ត្រូវបានរៀបចំឡើងដោយមានការប្រុងប្រយ័ត្នយ៉ាងខ្លាំង និងបានកំណត់មុខសញ្ញាយ៉ាងច្បាស់លាស់ ដែលសំដៅ ទៅលើមេដឹកនាំជាន់ខ្ពស់នានា។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានទស្សនៈមួយផ្សេងទៀត ពាក់ព័ន្ធនឹងជនទាំងឡាយដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ ប៉ុន្តែបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដូចមេដឹកនាំជាន់ខ្ពស់ ហើយនឹងក្លាយជាមុខសញ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញផងដែរ។ ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំសូមធ្វើការបញ្ជាក់ឡើងវិញ ដូចដែលឯកឧត្តម លី ធុច បានបញ្ជាក់កាលពីម្សិលមិញហើយថា មានមុខសញ្ញាពីរប្រភេទគឺ មេដឹកនាំជាន់ខ្ពស់ ដែលជាមុខសញ្ញាសំខាន់បំផុតរបស់អង្គជំនុំជម្រះវិសាមញ្ញ និងជនមួយចំនួនទៀតដែលអាចមិនមែនជាមេដឹកនាំជាន់ខ្ពស់ ប៉ុន្តែ អំពើរបស់ពួកគេមានលក្ខណៈធ្ងន់ធ្ងរខ្លាំងជាង ហើយមានភស្តុតាងគ្រប់គ្រាន់បង្ហាញថាពួកគេពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរខ្លាំងជាងអ្នកដទៃទៀត។

(...)

ដោយពិចារណាអំពីមេដឹកនាំជាន់ខ្ពស់ យើងសំដៅទៅលើមនុស្សមិនលើសពី ១០ នាក់ឡើយ ប៉ុន្តែយើងមិនបញ្ជាក់ច្បាស់ថា ពួកគេជាសមាជិកគណៈអចិន្ត្រៃយ៍នោះទេ។ នេះគឺជាភារកិច្ចរបស់សហព្រះរាជអាជ្ញា (...)។ ទោះបីជាយ៉ាងណាក៏ដោយ នៅមានមុខសញ្ញាទីពីរទៀត។ ពួកគេមិនមែនជាមេដឹកនាំឡើយ ប៉ុន្តែ ពួកគេបានប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលមានលក្ខណៈឃោរឃៅយង់ឃ្នង។ ហេតុដូច្នេះហើយបានជាយើងប្រើពាក្យថាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។ មិនមានចំនួនមនុស្សជាក់លាក់ដែលត្រូវបានចោទប្រកាន់ក្នុងក្រុមទីពីរឡើយ។ ជនទាំងឡាយដែលប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលមានលក្ខណៈឃោរឃៅយង់ឃ្នង អាចនឹងត្រូវបានចោទប្រកាន់[106]។

[106] *សម័យប្រជុំលើកទីមួយនៃនីតិកាលទី ៣ របស់រដ្ឋសភាជាតិកម្ពុជា ថ្ងៃទី៤-៥ ខែ តុលា ឆ្នាំ ២០០៤,* ទំព័រ ១២ និង ២៣។

៥៤. ដូចគ្នានេះដែរ ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា បានធ្វើសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍របស់ខ្លួន ដូចខាងក្រោមនេះ៖

> ក្រុមអ្នកជំនាញមិនជឿថាពាក្យថា "មេដឹកនាំ"(ខ្មែរក្រហម)គួរតែដូចគ្នានឹងបុគ្គលទាំងអស់នៅក្នុងកម្រិតជាន់ខ្ពស់នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬនៃបក្សកុម្មុយនីស្តកម្ពុជាឡើយ។ បញ្ជីឈ្មោះនៃមន្ត្រីកំពូលៗរបស់រដ្ឋាភិបាល និងបក្សអាចមិនត្រូវគ្នាជាមួយនឹងបញ្ជីឈ្មោះជនដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដែលនៅក្នុងនោះ មេដឹកនាំកំពូលៗមួយចំនួនរបស់រដ្ឋាភិបាល អាចត្រូវបានស្ថិតក្នុងស្ថានភាពដែលមិនអាចមិនដឹង និងមិនបានធ្វើសេចក្តីសម្រេច ហើយបុគ្គលផ្សេងទៀតដែលមិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះមេដឹកនាំជាន់ខ្ពស់ អាចមានតួនាទីយ៉ាងសំខាន់នៅក្នុងអំពើឃោរឃៅយង់ឃ្នងទាំងនោះ។ ជាពិសេស ការយល់ឃើញដូច្នេះអាចជាការពិត ទាក់ទិននឹងមេដឹកនាំមួយចំនួននៅថ្នាក់ភូមិភាគ ព្រមទាំងមន្ត្រីនានានៅមន្ទីរសួរចម្លើយ និងធ្វើទារុណកម្មដូចជានៅទួលស្លែងជាដើម[107]។

៥៥. ដូច្នេះ ក្រុមអ្នកជំនាញបានផ្តល់អនុសាសន៍ថា "តុលាការត្រូវផ្តោតទៅលើជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការនេះនឹងរួមបញ្ចូលទាំងមេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវទៅលើការរំលោភបំពានទាំងឡាយ ព្រមទាំងជនទាំងឡាយនៅថ្នាក់ទាបជាងដែលមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអំពើយង់ឃ្នងយ៉ាងធ្ងន់ធ្ងរបំផុត"[108]។

---

[107] របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា, កថាខណ្ឌ ១០៩។

[108] របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា, កថាខណ្ឌ ១១០។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅក្នុងសាលក្រមរបស់ខ្លួន, កថាខណ្ឌ ២១, ពាក្យពេចន៍ប្រហាក់ប្រហែលគ្នាត្រូវបានប្រើប្រាស់ដោយអគ្គលេខាធិការ នៅពេលបញ្ជូនរបាយការណ៍របស់ក្រុមអ្នកជំនាញទៅក្រុមប្រឹក្សាសន្តិសុខ និងមហាសន្និបាត។ កូហ្វីអាណាន់ *លិខិតដូចគ្នាចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩*។

៥៦. លោកសាស្ត្រាចារ្យ David Scheffer ដែលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើត អ.វ.ត.ក ក្នុងឋានៈជាឯកអគ្គរដ្ឋទូតគោចររបស់សហរដ្ឋអាមេរិកសម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម (ឆ្នាំ ១៩៩៧ ដល់ ឆ្នាំ ២០០១) នៅពេលថ្មីៗនេះក៏បានពន្យល់ផងដែរថា៖

> វាមានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់ថា មកដល់ពេលនេះ (ខែមករា ឆ្នាំ ២០០០) ឌុច បានស្ថិតនៅក្នុងមន្ទីរឃុំឃាំងអស់រយៈពេល ៦ខែ រួចមកហើយ និងជាចំណុចយោងមួយដដែលៗ សម្រាប់អ្នកចរចាដែលថា ឌុចទំនងជាចុងចោទម្នាក់។ ការសន្មតថា ឌុច នឹងបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក នៅតែបន្តជាបញ្ហាយ៉ាងរឹងមាំ ក្នុងការចរចាប៉ុន្មានឆ្នាំជាបន្តបន្ទាប់មកទៀត។ លើសពីនេះទៀត អ្នកចរចាពុំដែលបានបញ្ជាក់ប្រាប់គ្នាទៅវិញទៅមកថា ជនសង្ស័យណាក៏ដោយត្រូវតែជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ*ផង* និងជាបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត*ផង* ចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនោះទេ។ ការលើកឡើងបែបនេះ គឺជាការយល់ឃើញមួយមិនសមហេតុផលនោះទេ។ ទស្សនៈបែបនេះ ប្រាកដជានឹងបើកផ្លូវឱ្យមានការជំទាស់តវ៉ាភ្លាមៗពីសំណាក់អ្នកចរចា ពីព្រោះ យើងចង់ធ្វើឱ្យប្រាកដថា បុគ្គលដូចជា ឌុច ដែលប្រហែលជាមិនស្ថិតក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែជាអ្នកទទួលខុសត្រូវចំពោះការប្រព្រឹត្តិក្នុងទ្រង់ទ្រាយធំនៃឧក្រិដ្ឋកម្ម ដែលមានលក្ខណៈឃោរឃៅយង់ឃ្នងនោះនឹងជាកម្មវត្ថុនៃការស៊ើបអង្កេត និងការចោទប្រកាន់ដោយ អ.វ.ត.ក។ ក្រុមទាំងពីរ គឺក្រុមមេដឹកនាំជាន់ខ្ពស់ និងក្រុមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានា ត្រូវស្ថិតនៅក្រោមយុត្តាធិការលើរូបបុគ្គលរបស់តុលាការនេះ។ ខ្ញុំមិនឃើញមានការស្នើឡើងអ្វីផ្សេងពីនេះទៀតឡើយ។
>
> (…)
>
> ទោះបីជាយ៉ាងណាក៏ដោយ យើងប្រាកដជាបានបដិសេធ ឬយ៉ាងហោចណាស់ស្នើឱ្យមានការបដិសេធ នូវការទទួលខុសត្រូវចម្បងៗរបស់មេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម ប្រសិនបើ យើងបានប្រើសន្ធានសព្ទ "ឬ" ដើម្បីបំបែកអត្តសញ្ញាណនៃការដឹកនាំឱ្យដាច់ស្រឡះពីអត្តសញ្ញាណនៃការទទួលខុសត្រូវ។ ការធ្វើដូច្នេះនឹងមានភាពអយុត្តិធម៌ចំពោះមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ទាំងឡាយណា ដែលអាចមិនបានអនុវត្ត

តួនាទីសំខាន់ចំពោះឧក្រិដ្ឋកម្មដែលឃោរឃៅយង់ឃ្នង ប៉ុន្តែត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ដោយសារតែតួនាទីរបស់ពួកគេជាអ្នកដឹកនាំតែប៉ុណ្ណោះ[109]។

៥៧. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ប្រវត្តិនៃការរៀបចំសេចក្តីព្រាងខាងលើនេះ បង្ហាញថា ពាក្យថា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"សំដៅទៅលើកម្មាភិបាលខ្មែរក្រហមពីរប្រភេទខុសគ្នា ប៉ុន្តែ ប្រភេទទាំងពីរនោះទាក់ទងគ្នា។ ប្រភេទទីមួយ គឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត[110] ពីព្រោះមេដឹកនាំជាន់ខ្ពស់ម្នាក់មិនមែនជាជនសង្ស័យដោយផ្អែកតែទៅលើតួនាទីជាអ្នកដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ។ ប្រភេទមួយផ្សេងទៀត គឺអ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែ ជាអ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតផងដែរ។ ជនទាំងពីរប្រភេទនេះត្រូវតែជាកម្មាភិបាលខ្មែរក្រហម និងស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយជនទាំងពីរប្រភេទនេះ គឺជា"ជនសង្ស័យ"ដែលជាកម្មវត្ថុនៃការ

---

[109]ព្រឹត្តប័ត្រនិពន្ធដោយ David Scheffer "ប្រវត្តិនៃការចរចារអំពីយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក" ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១, ទំព័រ ៤ ដល់ ៥, ផ្សព្វផ្សាយនៅគេហទំព័រ <http://www.cambodiatribunal.org/>។ *សូមមើលផងដែរ*ព្រឹត្តប័ត្រនិពន្ធដោយ Sean Morrison ចំណងជើងថា "ពាក្យពេចន៍ដែលមានលក្ខណៈពិសេសនៅក្នុងតុលាការកម្ពុជាៈ ពាក្យពេចន៍ដែលមានលក្ខណៈ ជាការកម្រិត និងយុត្តាធិការលើរូបបុគ្គលរបស់តុលាការកម្ពុជា", ការបោះពុម្ពផ្សាយដែលមានចំណងជើងថា *Capital University Law Review*, លេខ ៣៧ (ឆ្នាំ ២០០៨-២០០៩), ទំព័រ ៦២៧។ *សូមមើលជាទូទៅ* ព្រឹត្តប័ត្រនិពន្ធដោយ David Scheffer, ចំណងជើងថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា", បោះពុម្ពផ្សាយដោយនិពន្ធនាយក M. Cherif Bassiouni (ed.), មានចំណងជើងថា *International Criminal Law* (*ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*) បោះពុម្ពលើកទី ៣, Koninklijke Brill NV, ឆ្នាំ ២០០៨, ទំព័រ ២១៩ ដល់ ២៥៥។ ព្រឹត្តប័ត្រនិពន្ធដោយ Steve Heder, "ការពិនិត្យឡើងវិញនៃការចរចាដែលនាំទៅដល់ការបង្កើតនូវយុត្តាធិការលើរូបបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១ <http://www.cambodiatribunal.org/blog>។

[110]ព្រឹត្តប័ត្រនិពន្ធដោយ Sean Morrison, "ពាក្យពេចន៍ដែលមានលក្ខណៈពិសេសនៅក្នុងតុលាការកម្ពុជាៈ ពាក្យពេចន៍ដែលមានលក្ខណៈជាការកម្រិត និងយុត្តាធិការលើរូបបុគ្គលរបស់តុលាការកម្ពុជា", ទំព័រ ៦២៧ ("ដោយហេតុថា មេដឹកនាំជាន់ខ្ពស់ទាំងអស់ ក៏ត្រូវតែជាអ្នកទទួលខុសត្រូវខ្ពស់បំផុតផងដែរ ទើបការប្រើប្រាស់ពាក្យពេចន៍ពីរនេះ មានលក្ខណៈមិនចាំបាច់។ ប៉ុន្តែ ការបន្ថែមពាក្យ (មេដឹកនាំជាន់ខ្ពស់) ទៅលើយុត្តាធិការតុលាការបានជួយក្នុងការផ្តោតទៅលើការចោទប្រកាន់")។

ចោទប្រកាន់ផ្នែកព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក ដោយអនុលោមតាមមាត្រា ២ ថ្មី នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក។

### *៣.ក.៥.ខ.ការវាយតម្លៃពាក្យ"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"*

៥៨. អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការវាយតម្លៃ ថាតើ ផ្នែកទាំងមូល ឬមួយផ្នែកនៃពេចន៍ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក ដែលត្រូវបានបំពេញដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងជំនុំជម្រះក្ដីលើជនជាប់ចោទបាន។

៥៩. ដោយអនុលោមតាមមាត្រា ៣១(១) នៃអនុសញ្ញាទីក្រុងវីយែន (Vienna) ស្ដីពីច្បាប់សន្ធិសញ្ញា ពាក្យថា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" "ត្រូវបកស្រាយដោយសុទ្ធចិត្តស្របតាមអត្ថន័យធម្មតានៃពាក្យពេចន៍ទាំងនេះដែលមាននៅក្នុងសន្ធិសញ្ញា [ពោលគឺ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា][111] នៅក្នុងបរិបទនៃពាក្យពេចន៍ទាំងនេះ និងទៅតាមកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងនេះ"[112]។ នៅពេលដែលការបកស្រាយតាមមាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយែន "នាំឱ្យមានលទ្ធផលមួយដែលពុំសមហេតុផល និងមិនមានភាពស៊ីសង្វាក់គ្នាយ៉ាងច្បាស់ក្រឡែត" មាត្រា ៣២(ខ) នៃអនុសញ្ញានេះ អនុញ្ញាត"ឱ្យប្រើប្រាស់ (...) មធ្យោបាយបំពេញបន្ថែមនៅក្នុងការបកស្រាយ រួមមានឯកសាររៀបចំសន្ធិសញ្ញា និងកាលៈទេសៈនៃការចុះសន្ធិសញ្ញា ដើម្បី (...) កំណត់អត្ថន័យ"[113]។ អង្គជំនុំជម្រះតុលាការកំពូលក៏អាចស្វែង

---

[111]មាត្រា ២(២) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

[112]មាត្រា ៣១(១) នៃអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញាដែលត្រូវបានអនុម័តនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៦៩, វ៉ុល ១១៥៥ លេខលំដាប់នៃសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិទំព័រ ៣៣១ (1155 UNTS 331), (ដែលចូលជាធរមាននៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៨០) ("VCLT") (អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា)។

[113]មាត្រា ៣២ (ខ) នៃអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា ("VCLT")។ *សូមមើលផងដែរ* សាលដីការបស់អង្គបុរេជំនុំជម្រះស្ដីពីបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១,

រកបទដ្ឋានណែនាំនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ដែលមានបទប្បញ្ញត្តិប្រហាក់ប្រហែលនៅក្នុងយុត្តាធិការផ្សេងៗទៀត[114]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវវាយតម្លៃពាក្យថា"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"ដោយប្រើវិធាននៃការបកស្រាយទាំងនេះ។

៦០. ដោយផ្តើមចេញពីខ្លឹមសារក្នុងអត្ថបទនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដោយផ្ទាល់ មាត្រា ២(១) ចែងថា "(...) កិច្ចព្រមព្រៀងនេះទទួលស្គាល់ផងដែរថា អង្គជំនុំជម្រះវិសាមញ្ញមាន*យុត្តាធិការលើរូបបុគ្គល* ជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានចែងក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀង" (គូសបញ្ជាក់បន្ថែម)។ ការដាក់បញ្ចូលពាក្យថា "យុត្តាធិការលើរូបបុគ្គល"នៅក្នុងមាត្រា ២(១) មានន័យថា ពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាលក្ខខណ្ឌតម្រូវផ្នែកច្បាប់នៃយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើជនជាប់ចោទទាំងស្រុង។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលក៏ត្រូវពិចារណាផងដែរ ថាតើការបកស្រាយពាក្យថា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ថាជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក គឺជាការបកស្រាយស្របទៅនឹងកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែរឬយ៉ាងណា ហើយ ថាតើការបកស្រាយបែបនេះនឹងនាំឱ្យមាន"លទ្ធផលដែលមិនសមស្រប និងមិនសមហេតុផលយ៉ាងច្បាស់ក្រឡែត" ដែរ ឬយ៉ាងណា។ ដូចដែលបានពន្យល់ខាងលើ

---

ឯកសារលេខ D427/1/30, កថាខណ្ឌ ១២២ ("អនុលោមតាមគោលការណ៍នៃការបកស្រាយដែលមានការទទួលស្គាល់*នៅក្នុងការបកស្រាយច្បាប់លក្ខន្តិកៈ និងលិខិតុបករណ៍ជាលាយលក្ខណ៍អក្សរទាំងអស់ ត្រូវប្រកាន់ខ្ជាប់អត្ថន័យនៃពាក្យតាមវេយ្យាករណ៍ និងតាមន័យធម្មតា លើកលែងតែថា អាចនាំឱ្យមានភាពមិនសមហេតុសមផល ឬភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងលិខិតុបករណ៍នោះ ដែលក្នុងករណីនេះ អត្ថន័យតាម វេយ្យាករណ៍ និងតាមន័យធម្មតា អាចត្រូវបានកែប្រែដើម្បីជៀសវាងភាពមិនសមហេតុសមផល ឬភាពមិនស៊ីសង្វាក់គ្នានេះ ប៉ុន្តែមិនត្រូវឱ្យហួសពីនេះទេ*")។ (សេចក្តីដកស្រង់ត្រូវបានលុបចោល)។

[114] មាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

ពាក្យពេចន៍នេះ សំដៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតផង និងសំដៅលើជនទាំងឡាយដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម តែស្ថិតនៅក្នុងចំណោមជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតផងដែរ។ លក្ខណៈវិនិច្ឆ័យរួមនៃជនទាំងពីរប្រភេទនេះ គឺថា ជនសង្ស័យត្រូវតែជាកម្មាភិបាលខ្មែរក្រហម និងស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។ លក្ខណៈវិនិច្ឆ័យដាច់ដោយឡែកនៃជនប្រភេទទី ១ គឺថា ជនសង្ស័យជាមេដឹកនាំជាន់ខ្ពស់។ អង្គជំនុំជម្រះតុលាការកំពូល នឹងធ្វើការវាយតម្លៃលើពាក្យពេចន៍នីមួយៗក្នុងចំណោមពាក្យពេចន៍ទាំងបីនេះ ដើម្បីធ្វើការកំណត់ ថាតើពាក្យពេចន៍ទាំងអស់នេះ ត្រូវបានបកស្រាយដោយសមហេតុផលថា ជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក ដែរ ឬយ៉ាងណា។

### *៣.ក.៥.ខ.១.កម្មាភិបាលខ្មែរក្រហម*

៦១. ជនសង្ស័យម្នាក់ៗនៅចំពោះមុខ អ.វ.ត.ក ត្រូវតែជាកម្មាភិបាលខ្មែរក្រហម។ ពាក្យពេចន៍នេះពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គហេតុប្រវត្តិសាស្ត្រ ដែលមានលក្ខណៈងាយយល់ និងច្បាស់លាស់ ហើយផ្តល់ឆន្ទានុសិទ្ធិតិចតួច ឬមិនបានផ្តល់ឆន្ទានុសិទ្ធិទាល់តែសោះដល់អង្គជំនុំជម្រះសាលាដំបូង។ ទោះបីជាជនជាប់ចោទអាចប្រកែកថា ខ្លួនមិនមែនជាកម្មាភិបាលខ្មែរក្រហមក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង គឺជាអ្នកដែលមានសមត្ថកិច្ចត្រឹមត្រូវជាងគេ នៅក្នុងការសម្រេចលើបញ្ហាអង្គហេតុនេះ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា យុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក គ្របដណ្តប់លើកម្មាភិបាលខ្មែរក្រហម ហើយបញ្ហាចោទដែលថាតើជនជាប់ចោទ គឺជាកម្មាភិបាលខ្មែរក្រហម ដែរ ឬយ៉ាងណា នោះ គឺជាបញ្ហាដែលអាចវិនិច្ឆ័យបាន[115]នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

---

[115]ពាក្យពេចន៍ "អាចវិនិច្ឆ័យបាន" មានន័យថា "ដែលអាចសម្រេចបានដោយតុលាការ"។ តាមវចនានុក្រម Black's Law Dictionary ចេញផ្សាយលើកទី ៩។ យោងតាមសាព័ត៌មាន Thomson Reuters ឆ្នាំ ២០០៩, ទំព័រ ៩៤៥។ ពាក្យ"មិនអាចវិនិច្ឆ័យបាន"មានន័យថា "មិនមានលក្ខណៈត្រឹមត្រូវសម្រាប់ការសម្រេចដោយតុលាការ"។ តាមវចនានុក្រម Black's Law Dictionary ចេញផ្សាយលើកទី ៩ ទំព័រ ១១៥៥។ ក្រមនីតិវិធីបារាំង។ *ប្រៀបធៀប* វចនានុក្រម Black's Law Dictionary បោះពុម្ពផ្សាយលើកទី ៩, ទំព័រ ១២៧៧ (កំណត់និយមន័យ "បញ្ហានយោបាយ" ថា ជាបញ្ហាមួយដែល

00798364



### *៣.ក.៥.ខ.២.អ្នកទទួលខុសត្រូវខ្ពស់បំផុត*

៦២. លក្ខណៈវិនិច្ឆ័យរួមទីពីរនៃជនសង្ស័យនៅចំពោះមុខ អ.វ.ត.ក គឺថា ជនសង្ស័យទាំងនេះគួរតែស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដូចមានរៀបរាប់នៅក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់រួចហើយថា ទាំងកិច្ចព្រមព្រៀង អ.វ.ត.ក ទាំងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពុំបានកំណត់និយមន័យ“អ្នកទទួលខុសត្រូវខ្ពស់បំផុត” ឡើយ[116]។ អត្ថន័យធម្មតានៃ“ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” បង្ហាញនូវកម្រិតនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយប្រៀបធៀបជាមួយនឹងកម្មាភិបាលខ្មែរក្រហមទាំងអស់ ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ផ្ទុយទៅនឹងពាក្យពេចន៍ “កម្មាភិបាលខ្មែរក្រហម” ការបកស្រាយពាក្យពេចន៍“អ្នកទទួលខុសត្រូវខ្ពស់បំផុត” ថាជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក នឹងផ្ទុយទៅនឹងកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ហើយការបកស្រាយបែបនេះអាចនាំឱ្យមានលទ្ធផលមួយមិនសមស្របដូចតទៅ៖ ទីមួយ ពុំមានវិធីសាស្ត្រជាសត្យានុម័តសម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេច ធ្វើការប្រៀបធៀប និងធ្វើការកំណត់ចំណាត់ថ្នាក់ នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កម្មាភិបាលខ្មែរក្រហមទាំងអស់បានឡើយ ហើយ ទីពីរ សញ្ញាណនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលយកមកប្រៀបធៀបគ្នានេះ គឺផ្ទុយទៅនឹងមាត្រា ២៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា “តួនាទី ឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ”។ បទប្បញ្ញត្តិនេះ ក៏បញ្ជាក់យ៉ាងច្បាស់ផងដែរ អំពីគោលការណ៍ដែលថា បញ្ជារបស់ថ្នាក់លើ មិនបង្កើតបានជាមធ្យោបាយការពារឱ្យរួចផុតពីឧក្រិដ្ឋកម្មដូចមានចែងក្នុងជំពូកទី ២ នៃច្បាប់ស្តីពី

---

តុលាការមិនត្រូវពិចារណានោះទេ ពីព្រោះបញ្ហានេះជាប់ពាក់ព័ន្ធទៅនឹងការប្រើអំណាចជាឆន្ទានុសិទ្ធិរបស់អង្គនីតិប្រតិបត្តិ ឬអង្គនីតិបញ្ញត្តិ-ក៏មានប្រើពាក្យ *បញ្ហាដែលមិនអាចធ្វើការវិនិច្ឆ័យបាន*”) (ភាសាដើមជាអក្សរទ្រេត)។

[116]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៩។

ការបង្កើត អ.វ.ត.ក ឡើយ។ ជាការពិត ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងត្រូវចាប់ផ្តើមធ្វើការវាយតម្លៃ ដោយប្រៀបធៀបពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការធ្វើបែបនេះ គឺមានន័យស្មើនឹងការបង្កើតឱ្យមានមធ្យោបាយការពារ ដោយប្រយោលដោយមូលហេតុបញ្ជារបស់ថ្នាក់លើ ហើយផ្ទុយនឹងបទប្បញ្ញត្តិនានាដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមទាំងក្នុងមាត្រា ២៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផងដែរ។ ការចង្អុលបង្ហាញទីបីថា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មិនអាចត្រូវបានបកស្រាយដោយសមហេតុផលថា ជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ អ.វ.ត.ក មានន័យថា ការកំណត់ ថាតើជនជាប់ចោទជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរ ឬយ៉ាងណា តម្រូវឱ្យមានការប្រើឆន្ទានុសិទ្ធិយ៉ាងច្រើន។ ឧទាហរណ៍ តុលាការមិនមានឆន្ទានុសិទ្ធិក្នុងការកំណត់យុត្តាធិការពេលវេលា និងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក នោះទេ។ យុត្តាធិការទាំងពីរនេះត្រូវបានចែងជាក់លាក់ តាមរយៈនិយមន័យច្បាស់លាស់ ដូច្នេះហើយ ជនសង្ស័យ និង អ.វ.ត.ក អាចធ្វើការផ្ទៀងផ្ទាត់បាន ពីព្រោះយុត្តាធិការទាំងពីរនេះពាក់ព័ន្ធទៅនឹងបញ្ហាអង្គហេតុ ឬអង្គច្បាប់សុទ្ធសាធដែលមានលក្ខណៈច្បាស់លាស់ក្នុងការធ្វើការសម្រេចតាមផ្លូវច្បាប់បាន។ ផ្ទុយទៅវិញ ទាំងជនសង្ស័យ និង អ.វ.ត.ក មិនអាចបង្ហាញ ថាតើជនសង្ស័យ គឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឬក៏មិនមែន ដោយអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យច្បាស់លាស់អរូបិយ និងមានស្វ័យភាពបានឡើយ។

៦៣. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការបកស្រាយលក្ខណៈវិនិច្ឆ័យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ក្នុងពាក្យថា "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ថាជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក គឺមិនសមហេតុផលឡើយ។ ម្យ៉ាងវិញទៀត មានកត្តាជាច្រើនដែលចង្អុលបង្ហាញថា ពាក្យពេចន៍"អ្នកទទួលខុសត្រូវខ្ពស់បំផុត"គប្បីត្រូវបានបកស្រាយថា ជាគោលការណ៍ណែនាំនៃការចោទប្រកាន់ និងការស៊ើបអង្កេតសម្រាប់សហព្រះរាជអាជ្ញា

និងសហចៅក្រមស៊ើបអង្កេត ដែលមិនអាចធ្វើការវិនិច្ឆ័យនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ។

៦៤. គោលបំណងនៃគោលការណ៍ណែនាំទាំងនេះ គឺដើម្បីផ្តល់សមត្ថកិច្ចឱ្យទៅការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវទទួលខុសត្រូវលើការបំពេញកិច្ចការស៊ើបអង្កេត[117] និងតម្រូវឱ្យមានភាពឯករាជ្យនៅក្នុងការបំពេញមុខងាររបស់ខ្លួន[118]។ មាត្រា ៥(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាចែងថា "(...) គេត្រូវយល់ថា វិសាលភាពនៃការស៊ើបអង្កេត គឺកំណត់ត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម (...) ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩"។ ដូច្នេះ សហចៅក្រមស៊ើបអង្កេត បានទទួលអំណាចក្នុងការកំណត់ ថាតើការស៊ើបអង្កេតណាមួយស្ថិត ឬពុំស្ថិតនៅក្នុងវិសាលភាពនៃពាក្យពេចន៍ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[119]។ សហព្រះរាជអាជ្ញាទទួលខុសត្រូវលើការងារចោទប្រកាន់[120] ហើយក៏តម្រូវឱ្យមានភាពឯករាជ្យនៅក្នុងការបំពេញមុខងាររបស់ខ្លួនដូច

[117]មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ៥(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

[118]មាត្រា ២៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ មាត្រា ៥(៣) កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

[119]*សូមមើល* សេចក្តីពិចារណា (សំណៅដែលមានកោសលុប) ជាសាធារណៈរបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក Robert Hamil ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១, ឯកសារ D/11/2/4/4 ("ការពិចារណាទៅលើការទទួលយកជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក Hamil"), មតិរបស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល ចៅក្រម ហួត វុទ្ធី, នៅក្នុងកថាខណ្ឌ ៧ (ដែលពន្យល់ថា សហចៅក្រមស៊ើបអង្កេតមានអំណាចចោទប្រកាន់ជនសង្ស័យណាមួយដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា និងបុគ្គលនានាដែលខ្លួនយល់ថា សមស្រប)។

[120]មាត្រា ១៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង មាត្រា ៦(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

គ្នា[121] ហើយត្រូវគោរពតាមពាក្យពេចន៍“ត្រូវយល់ថា” នៅក្នុងមាត្រា ៦(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដែលចែងថា “វិសាលភាពនៃការចោទប្រកាន់ គឺកំណត់ត្រឹមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត”[122]។ ចំណុចនេះបង្ហាញឱ្យឃើញថា សហព្រះរាជអាជ្ញាក៏ទទួលអំណាចផងដែរក្នុងការកំណត់ ថាតើការចោទប្រកាន់ណាមួយស្ថិត ឬពុំស្ថិតនៅក្នុងវិសាលភាពនៃពាក្យពេចន៍“អ្នកទទួលខុសត្រូវខ្ពស់បំផុត”[123]។

៦៥. តួនាទីរបស់អង្គបុរេជំនុំជម្រះនៅក្នុងការដោះស្រាយករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញាទាំងពីររូប ឬរវាងសហចៅក្រមស៊ើបអង្កេតទាំងពីររូប ពុំបានធ្វើឱ្យមានការកែប្រែដល់សេចក្តីសន្និដ្ឋានថា ពាក្យពេចន៍ “អ្នកកទទួលខុសត្រូវខ្ពស់បំផុត”នេះ មិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។ ក្នុងករណីដែលមានការខ្វែងយោបល់គ្នានៅក្នុងវិធាន ៧១ ឬ ៧២ នៃវិធានផ្ទៃក្នុង នៅពេលដែលមានការខ្វែងយោបល់គ្នានេះស្តីពីបញ្ហាកិច្ចប្រតិបត្តិការ ការចេញសេចក្តីសម្រេច ឬការចេញដីកា ដោយសារមូលហេតុថាតើជនសង្ស័យ ឬជនត្រូវចោទ គឺជា“មេដឹកនាំជាន់ខ្ពស់” ឬជា“អ្នកទទួលខុសត្រូវខ្ពស់បំផុត” ដែរ ឬយ៉ាងណានោះ តួនាទីរបស់អង្គបុរេជំនុំជម្រះនឹងត្រូវសម្រេចពីបញ្ហាខ្វែងគំនិតគ្នារបស់សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត[124]។ ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា

---

[121]មាត្រា ១៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ៦(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

[122]មាត្រា ៦(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

[123]*សូមមើល*ការពិចារណាទៅលើការទទួលយកជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក Hamil, មតិរបស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល ចៅក្រម ហួត វុទ្ធី, នៅក្នុងកថាខណ្ឌ ៧ (ដែលពន្យល់ថា សហចៅក្រមស៊ើបអង្កេតត្រូវស្វែងរកការណែនាំពីសហព្រះរាជអាជ្ញា មុនពេលធ្វើការចោទប្រកាន់ជនសង្ស័យដែលមិនមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរណាមួយរបស់សហព្រះរាជអាជ្ញា)។

[124]សេចក្តីពិចារណា (ដែលបានកោសលុប និងជាសាធារណៈ) របស់អង្គបុរេជំនុំជម្រះ ស្តីអំពីការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាម វិធានផ្ទៃក្នុង ៧១, សំណុំរឿងលេខ 001/18-11-2008-ECCC/PTC, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ (ពុំមានលេខឯកសារឡើយ នៅត្រឹមពេលចេញសាលដីកានេះ), កថាខណ្ឌ ២៤។

សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទ គឺជា ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើ អង្គបុរេជំនុំជម្រះមិនអាចទទួលបានសម្លេងគាំទ្រភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[125]។

៦៦. ដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូល ក៏អាចពិនិត្យមើលទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ និងប្រវត្តិនៃការរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើជាគោលការណ៍ណែនាំសម្រាប់វាយតម្លៃពាក្យពេចន៍"អ្នកទទួលខុសត្រូវខ្ពស់បំផុត"ផងដែរ។ ជាដំបូងត្រូវពិនិត្យមើលឯកសារត្រៀមរៀបចំដែលក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា បានផ្តល់អនុសាសន៍ដល់ការបកស្រាយពាក្យពេចន៍"អ្នកទទួលខុសត្រូវខ្ពស់បំផុត" ថាមិនមែនជាលក្ខខណ្ឌផ្នែកយុត្តាធិការរបស់ អ.វ.ត.ក ទាំងស្រុងនោះទេ ប៉ុន្តែ គឺជាគោលការណ៍ណែនាំនៃការចោទប្រកាន់ និងស៊ើបអង្កេត។ អ្នកជំនាញបានផ្តល់អនុសាសន៍នៅក្នុងឯកសារសំណេររបស់ខ្លួនក្នុងឆ្នាំ ១៩៩៩ ថា"តុលាការត្រូវផ្តោតលើជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានធ្ងន់ធ្ងរបំផុតលើសិទ្ធិមនុស្ស ក្នុងអំឡុងរបបគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ"[126]។ អ្នកជំនាញ"បានជឿជាក់"ថា៖

> អត្ថន័យនៃវិសាលភាពនៃការស៊ើបអង្កេត[នេះ] គឺគ្រាន់តែជាគោលការណ៍ណែនាំសម្រាប់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ហើយមិនបង្កើតបានជាធាតុផ្សំនៃយុត្តាធិការរបស់តុលាការណាមួយឡើយ។ ដូច្នេះ លិខិតុបករណ៍ណាក៏ដោយដែលពាក់ព័ន្ធនឹងតុលាការគួរអនុញ្ញាតឱ្យតុលាការមានយុត្តាធិការលើរូបបុគ្គលចំពោះជនទាំងឡាយណា ដែលអំពើរបស់ខ្លួនស្ថិតនៅក្នុងយុត្តាធិការលើរឿងក្តី ហើយសេចក្តីសម្រេចលើការចោទ

---

[125]មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។ *សូមមើល* មាត្រា ៧(៤) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងវិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨)។

[126]របាយការណ៍របស់ក្រុមអ្នកជំនាញ, កថាខណ្ឌ ១១០។

ប្រកាន់ជនណា និងនៅពេលណានោះ គឺជាអំណាចឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាតែមួយគត់ (...)[127]។

៦៧. នៅក្នុង"សេចក្តីសង្ខេបនៃអនុសាសន៍ស្តីពីគោលការណ៍ណែនាំ" នៅក្នុងរបាយការណ៍របស់ខ្លួន អ្នកជំនាញបានផ្តល់អនុសាសន៍ថា "ជាបញ្ហាគោលការណ៍ណែនាំនៃការចោទប្រកាន់ ព្រះរាជអាជ្ញាឯករាជ្យដែលត្រូវបានតែងតាំងដោយអង្គការសហប្រជាជាតិ កម្រិតការចោទប្រកាន់របស់ខ្លួនត្រឹមជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត (...)"[128]។

៦៨. របាយការណ៍របស់អ្នកជំនាញបង្កើតបានជាផ្នែកដ៏សំខាន់មួយនៃ*ការងារត្រៀមរៀបចំ*កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ហើយរបាយការណ៍នេះ មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងពាក្យពេចន៍នៅក្នុងលិខិតុបករណ៍ទាំងនេះ។

៦៩. លើសពីនេះទៀត ការប្រៀបធៀបយ៉ាងហ្មត់ចត់រវាងតុលាការ ICTY និង ICTR ជាមួយ អ.វ.ត.ក ក៏គាំទ្រការចាត់ទុកពាក្យពេចន៍"អ្នកទទួលខុសត្រូវខ្ពស់បំផុត"ថា ជាគោលការណ៍ណែនាំនៃការស៊ើបអង្កេត និងការចោទប្រកាន់ ជាជាងលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក។ មុនពេលសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតុលាការ ICTY ដីកានេះត្រូវតែបានពិនិត្យដោយការិយាល័យមួយជាមុនសិន ដែលការិយាល័យនេះរួមមានសមាសភាពប្រធានអនុប្រធាន និងប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃអង្គជំនុំជម្រះសាលាដំបូងនានា។ ទោះបីជាយុត្តាធិការរបស់តុលាការ ICTY ពន្លាតដល់"អ្នកទទួលខុសត្រូវលើការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិក៏ដោយ" ក៏វិធាន ២៨(ក) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងតម្រូវឱ្យការិយាល័យមួយនេះកំណត់ ថាតើ*តាមសេចក្តីបញ្ជាក់ដំបូង*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ"ផ្តោតលើមេដឹកនាំជាន់ខ្ពស់បំផុតម្នាក់ ឬច្រើននាក់ ដែលត្រូវបានសង្ស័យថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់តុលាការនេះ ដែរ ឬយ៉ាង

---

[127]របាយការណ៍របស់ក្រុមអ្នកជំនាញ, កថាខណ្ឌ ១១១។

[128]របាយការណ៍របស់ក្រុមអ្នកជំនាញ, កថាខណ្ឌ ២១៩(២) (សេចក្តីបញ្ជាក់បន្ថែម)។

ណា"[129]។ តែក្នុងករណីដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះទំនងជាផ្តោតលើបុគ្គលបែបនេះ ទើបដីកានេះត្រូវបញ្ជូនទៅចៅក្រមទោល ដើម្បីធ្វើការសម្រេចតម្កល់។ ប្រសិនបើមិនដូច្នេះទេ ដីកានេះនឹងបញ្ជូនត្រឡប់មកឱ្យរដ្ឋអាជ្ញាវិញ។ ដូចគ្នានេះដែរ វិធាន ២៨ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR តម្រូវឱ្យចៅក្រមទទួលបន្ទុកសំណុំរឿង ដែលត្រូវបានជ្រើសតាំងដោយប្រធានតុលាការ ធ្វើការពិនិត្យឡើងវិញលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលរដ្ឋអាជ្ញាបានដាក់ជូន[130]។ ការដាក់បញ្ចូលបទប្បញ្ញត្តិទាំងនេះ ពុំបានដាក់កំហិតយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងទាំងនោះ មិនឱ្យធ្វើការជំនុំជម្រះជនជាប់ចោទឡើយ ដោយហេតុថា ជនជាប់ចោទមិនអាចជំទាស់ទៅនឹងកង្វះយុត្តាធិការបានទេ ដោយសំអាងទៅលើការខកខានក្នុងការបំពេញតាមលក្ខខណ្ឌនៃវិធាន ២៨(ក)នៃវិធានស្តីពីនីតិវិធី និងភស្តុតាងនៅតុលាការ ICTY ឬ វិធាន ២៨ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងនៅតុលាការ ICTR បាននោះទេ។ ទោះបីជាវិធានទាំងនេះផ្តល់ឆន្ទានុសិទ្ធិធំធេងដល់អង្គជំនុំជម្រះតុលាការ ICTY និងតុលាការ ICTR ក្នុងការកំណត់យកជនសង្ស័យណាខ្លះដែលត្រូវយកមកធ្វើការចោទប្រកាន់ក៏ដោយ ក៏វិធានទាំងនេះ នៅតែមានតួនាទីត្រឹមតែជាគោលការណ៍ណែនាំដែលមានគោលបំណងជួយតុលាការទាំងនេះ ឱ្យប្រមូលធនធានដែលមានតិចតួចរបស់ខ្លួនទៅប្រើប្រាស់ក្នុងការជំនុំជម្រះលើរឿងក្តីដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត ហើយស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួនតែប៉ុណ្ណោះ។

៧០. ប្រហាក់ប្រហែលគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតរបស់ អ.វ.ត.ក ទទួលខុសត្រូវក្នុង "ការចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់" ហើយ"ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា មិនចងសហចៅក្រមស៊ើបអង្កេតឡើយ"[131]។ អនុលោមតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា "ប៉ុន្តែ

---

[129]វិធាន ២៨(ក) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY ("ICTY RPE"), IT/32/Rev. 46 (ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១)។

[130]វិធាន ២៨ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៩ ("វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR ")។

[131]វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨)។

ត្រូវយល់ថា វិសាលភាពនៃការស៊ើបអង្កេត គឺកំណត់ត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត"[132]។ ដូចនៅតុលាការ ICTY និងតុលាការ ICTR ដែរ ជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក មិនអាចជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសំអាងទៅលើមូលដ្ឋានដែលថា សហចៅក្រមស៊ើបអង្កេតពុំបានកំណត់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រឹម"មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[133]នោះបានឡើយ ដោយពុំមានការបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួននោះ ហើយទាំងនេះនឹងត្រូវធ្វើការពិភាក្សានៅខាងក្រោម។ ការកម្រិតឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតនេះមានគោលបំណងជួយ អ.វ.ត.ក ឱ្យយកធនធានមានតិចតួចរបស់ខ្លួន ទៅប្រើប្រាស់ក្នុងការជំនុំជម្រះលើរឿងក្តីដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួន។

៧១. ប្រព័ន្ធបញ្ជូនរឿងក្តីនៅតុលាការ ICTY ក៏បានស្នើឡើងផងដែរថា ពាក្យ"អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជាគោលការណ៍ណែនាំនៃការស៊ើបអង្កេត និងការចោទប្រកាន់ ជាជាងលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក។ ចៅក្រមរបស់តុលាការ ICTY មានអំណាចបញ្ជូនរឿងក្តីទាំងឡាយទៅតុលាការជាតិបាន ចំណែកឯ អ.វ.ត.ក មានអត្ថិភាពនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែលអ.វ.ត.ក អនុវត្តនូវសមត្ថកិច្ចផ្ទាល់មុខ ហើយពុំមានការបញ្ជូនរឿងក្តីណាមួយទៅតុលាការមួយផ្សេងទៀតឡើយ។ តាមប្រព័ន្ធតុលាការ ICTY ជនដែលត្រូវបានរកឃើញថា ពុំមែនជាចារីម្នាក់ក្នុងចំណោមចារីទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មអន្តរជាតិនោះទេ អាចត្រូវបានជំនុំជម្រះ ដោយតុលាការជាតិ។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY បង្កើតនីតិវិធីមួយ ដែលអនុញ្ញាតឱ្យបញ្ជូនរឿង

---

[132]មាត្រា ៥(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

[133]ដោយហេតុថា ពាក្យពេចន៍"អ្នកទទួលខុសត្រូវខ្ពស់បំផុត" មិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក ដូច្នេះ ជនត្រូវចោទមិនអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបានឡើយ ដោយអនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨) ដោយមូលហេតុថា ខ្លួនពុំស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ពីព្រោះខ្លួនមិនមែនជា "មេដឹកនាំជាន់ខ្ពស់" ឬ"អ្នកទទួលខុសត្រូវខ្ពស់បំផុត"។

ក្តីណាមួយទៅអាជ្ញាធរជាតិបាន[134] នៅពេលណាក៏បានបន្ទាប់ពីមានការតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរួចហើយ និងនៅមុនពេលចាប់ផ្តើមការជំនុំជម្រះ។ ដើម្បីសម្រេចគោលដៅនេះ វិធាន ១១ *ស្ទួន* (ក)នៃវិធានស្តីពីនីតិវិធី និងភស្តុតាង បានអនុញ្ញាតឱ្យប្រធានតុលាការធ្វើការចាត់តាំងចៅក្រមចំនួន ៣ រូប មកពីអង្គជំនុំជម្រះសាលាដំបូងទាំងឡាយឱ្យមកធ្វើជាក្រុមប្រឹក្សាផ្ទេរសមត្ថកិច្ច ដែលក្រោយមកត្រូវធ្វើការសម្រេច ថាតើត្រូវធ្វើការបញ្ជូនរឿងក្តីទាំងនេះដែរ ឬយ៉ាងណា[135]។ ហេតុដូច្នេះ តុលាការ ICTY ដំណើរការដោយផ្អែកលើការសន្មតទុកជាមុនអំពីយុត្តាធិការទ្វេ ដែលផ្តល់នូវយន្តការមួយក្នុងការបែងចែករឿងក្តីរវាងតុលាការអន្តរជាតិ និងតុលាការជាតិដែលសមស្រប។ លក្ខណៈវិនិច្ឆ័យសម្រាប់ការបែងចែកបែបនេះ "ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ"[136] ដំណើរការជាគោលការណ៍ណែនាំនៃការចោទប្រកាន់ ប៉ុន្តែ មិនមែនជាការរារាំងផ្នែកយុត្តាធិការឡើយ។

៧២. ការបកស្រាយនៃពាក្យពេចន៍ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក៏មានភាពស្របគ្នាទៅនឹងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានាផងដែរ។ មាត្រា ១(១) នៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (តុលាការ SCSL) គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាគួរឱ្យកត់សម្គាល់ទៅនឹងមាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ បទប្បញ្ញត្តិរបស់តុលាការ SCSL បញ្ញត្តិថា៖

---

[134]ករណីនេះអាចជាអាជ្ញាធររដ្ឋដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើងនៅក្នុងដែនដីរបស់ខ្លួន។ រដ្ឋដែលជនជាប់ចោទត្រូវបានចាប់ខ្លួននៅក្នុងដែនដីរបស់ខ្លួន ឬរដ្ឋណាមួយដែលមានយុត្តាធិការ និងមានឆន្ទៈ ព្រមទាំងត្រៀមខ្លួនយ៉ាងគ្រប់គ្រាន់នៅក្នុងការទទួលយករឿងក្តី។ វិធាន ១១*ស្ទួន*(ក)(១) ដល់ (៣) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY។

[135]វិធាន ១១*ស្ទួន*(ក) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY។

[136]វិធាន ១១*ស្ទួន* (គ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY ។ *ប្រៀបធៀប* វិធាន ១១*ស្ទួន* (គ) វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR។

តុលាការពិសេសនេះ (...) មានអំណាចចោទប្រកាន់ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់របស់ប្រទេសសៀរ៉ាឡេអូន ដែលបានប្រព្រឹត្តឡើងនៅក្នុងដែនដីរបស់ប្រទេសសៀរ៉ាឡេអូន ចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ដោយរួមទាំងមេដឹកនាំទាំងឡាយណា ដែល (...) បានគម្រាមកំហែងដល់ការបង្កើត និងការអនុវត្តដំណើរការសន្តិភាពនៅក្នុងប្រទេសសេរ៉ាឡេអូន[137]។

៧៣. នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brima*[138] អង្គជំនុំជម្រះ*តុលាការ*កំពូលរបស់តុលាការ SCSL បានសម្រេចថា ការបកស្រាយដែលមានន័យសមស្របលើពាក្យពេចន៍"ការទទួលខុសត្រូវខ្ពស់បំផុត" គឺ"ជាគោលការណ៍ណែនាំដល់រដ្ឋអាជ្ញា នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិចោទប្រកាន់របស់ខ្លួន" ហើយ"មិនមានហេតុផលសមស្របទេ ចំពោះការអះអាងដែលថា ឆន្ទានុសិទ្ធិនេះ អាចត្រូវបានអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង ឬដោយអង្គជំនុំជម្រះតុលាការកំពូល នៅកិច្ចចុងក្រោយនៃដំណើរការជំនុំជម្រះ"[139]។ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ SCSL បានបន្តទៀតថា៖

ក្នុងការយល់ឃើញរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា មិនអាចធ្វើបានទេ ដែលថា អង្គជំនុំជម្រះសាលាដំបូងបានចំណាយពេលវេលាយ៉ាងយូរ និងធនធានជាច្រើន ព្រមទាំងរកឃើញថា ជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដោយពុំមានវិមតិសង្ស័យ ប៉ុន្តែ បែរជាអង្គជំនុំជម្រះសាលាដំបូងបានបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះចោល ដោយផ្អែកលើមូលដ្ឋានដែលថា មិនមានភស្តុតាង

---

[137]មាត្រា ១(១) នៃលក្ខន្តិកៈរបស់តុលាការ SCSL ("SCSL Statute") ដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលប្រទេសសៀរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ដែលចុះហត្ថលេខា នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០២, វ៉ុល ២១៧៨ លេខលំដាប់សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ទំព័រ ១៣៨ (ដែលចូលជាធរមាន នៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០២)។

[138]*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Brima*, សំណុំរឿងលេខ SCSL-2004-16-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ ២៧២ ដល់ ២៨៥, ("សាលដីកាក្នុង*រឿងក្តី Brima*")។

[139]សាលដីកាក្នុង*រឿងក្តី Brima*, កថាខណ្ឌ ២៨២។

បង្ហាញថា ជនជាប់ចោទ គឺជាជនមួយរូបក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះ[140]។

៧៤. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជាអង្គជំនុំជម្រះសាលាដំបូង ត្រូវពិចារណាដោយប្រុងប្រយ័ត្នលើរាល់ការជំទាស់ផ្នែកយុត្តាធិការ ដែលមានសុពលភាពក៏ដោយ ក៏ពុំមានភាពសមហេតុផលក្នុងការបកស្រាយពាក្យ"អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងពាក្យពេចន៍"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ថាជាលក្ខខណ្ឌនៃយុត្តាធិការនោះឡើយ។ ផ្ទុយទៅវិញពាក្យពេចន៍"ទទួលខុសត្រូវខ្ពស់បំផុត"នេះ គឺជាបញ្ហានៃគោលការណ៍ណែនាំនៃការស៊ើបអង្កេត និងការចោទប្រកាន់សម្រាប់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតនៅក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដោយឯករាជ្យ ក្នុងពេលចោទប្រកាន់ និងស៊ើបអង្កេតទៅលើជនល្មើសដែលបានប្រព្រឹត្តអំពើល្មើសយ៉ាងធ្ងន់ធ្ងរបំផុត ដែលជននេះស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។

### *៣.ក.៥.ខ.៣.មេដឹកនាំជាន់ខ្ពស់*

៧៥. ដូចបានពន្យល់ក្នុងចំណុចខាងលើ មេដឹកនាំជាន់ខ្ពស់ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត គឺជាជនសង្ស័យមួយប្រភេទក្នុងចំណោមជនសង្ស័យទាំងពីរប្រភេទដែលមាននៅក្នុងពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។ ដោយហេតុថា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ពាក្យ"អ្នកទទួលខុសត្រូវខ្ពស់បំផុត" គឺជាគោលការណ៍ណែនាំនៃការស៊ើបអង្កេត និងចោទប្រកាន់ទាំងស្រុង ដូច្នេះ ជនជាប់ចោទពុំអាចរារាំងយុត្តាធិការរបស់ អ.វ.ត.ក ដោយផ្អែកលើមូលដ្ឋានថា ខ្លួនពុំមែនជាមេដឹកនាំជាន់ខ្ពស់នោះទេ។ ទោះបីជាយ៉ាងនេះក្តី ការវាយតម្លៃសមស្របលើពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់" គឺមានសារៈសំខាន់ណាស់ចំពោះ

[140] សាលដីកាក្នុង *រឿងក្តី Brima*, កថាខណ្ឌ ២៨៣។

យុត្តិសាស្ត្ររបស់ អ.វ.ត.ក ដែលទាមទារឱ្យមានការពិនិត្យពិចារណាដោយអង្គជំនុំជម្រះតុលាការកំពូល។

៧៦. ពាក្យ"អ្នកទទួលខុសត្រូវខ្ពស់បំផុត" ក៏ដូចពាក្យ"មេដឹកនាំជាន់ខ្ពស់"ដែរ មិនត្រូវបានកំណត់និយមន័យនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះទេ។ប្រសិនបើពាក្យ "មេដឹកនាំជាន់ខ្ពស់" ត្រូវបានកម្រិតត្រឹមតែអតីតសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និង/ឬ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជានោះ[141] ការកំណត់បែបនេះនឹងបង្ហាញថាពាក្យពេចន៍នេះ គឺជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ពីព្រោះមានការពាក់ព័ន្ធទៅនឹងបញ្ហាជាក់លាក់នៃអង្គហេតុប្រវត្តិសាស្ត្រ ដែលអង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវធ្វើការឆ្លើយតបចំពោះបញ្ហានេះ។ ក៏ប៉ុន្តែ និយមន័យ"មេដឹកនាំជាន់ខ្ពស់"មានលក្ខណៈបត់បែនបានយ៉ាងគ្រប់គ្រាន់ដែលថា មិនមានភាពចាំបាច់កម្រិតត្រឹមតែអតីតសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និង/ឬ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ប៉ុណ្ណោះនោះទេ។ ផ្ទុយមកវិញ និយមន័យនៃយុត្តាធិការពេលវេលា និងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក ប្រើប្រាស់នូវប្រភេទជាក់លាក់ ដែលជាបែបផែនសម្រាប់លក្ខណៈវិនិច្ឆ័យផ្នែកច្បាប់។ ភាពបត់បែនបែបនេះនៅក្នុងការកំណត់និយមន័យពាក្យ"មេដឹកនាំជាន់ខ្ពស់" បង្ហាញឱ្យឃើញពីចរិតលក្ខណៈដែលមិនមែនជាលក្ខខណ្ឌយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។

៧៧. កិច្ចពិភាក្សានៅក្នុងសភាជាតិកម្ពុជាស្តីអំពីកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងវិសោធនកម្មលើច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្នាំ ២០០១ បានបញ្ជាក់ថា និយមន័យនៃពាក្យពេចន៍"មេដឹកនាំជាន់ខ្ពស់" មិនត្រូវបានកំណត់ជាក់លាក់ ហើយ

---

[141] *សូមមើលជាទូទៅ* ព្រឹត្តប័ត្រនិពន្ធដោយ Steve Heder, "ការពិនិត្យឡើងវិញលើការចរចាដែលនាំឱ្យមានការបង្កើតយុត្តាធិការលើរូបបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"។

ចរិតលក្ខណៈនៃពាក្យពេចន៍នេះ គប្បីដើរតួនាទីជាគោលការណ៍ណែនាំនៃការចោទប្រកាន់ និងការស៊ើបអង្កេត[142]។

៧៨. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពាក្យពេចន៍"មេដឹកនាំជាន់ខ្ពស់" ពុំបង្កើតបានជាផ្នែកមួយនៃយុត្តាធិការរបស់ អ.វ.ត.ក ឡើយ។ ពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ក៏ដូចពាក្យ"មេដឹកនាំជាន់ខ្ពស់"ដែរ គឺជាគោលការណ៍ណែនាំនៃការស៊ើបអង្កេត និងការចោទប្រកាន់ ដែលណែនាំសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួនទាក់ទងទៅនឹងវិសាលភាពនៃការចោទប្រកាន់ និងការស៊ើបអង្កេត។

### *៣.ក.៥.ខ.៤.សេចក្តីសង្ខេបនៃសំអាងហេតុ*

៧៩. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា យុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក គឺគ្របដណ្តប់លើកម្មាភិបាលរបស់ខ្មែរក្រហម។ បញ្ហា ថាតើជនជាប់ចោទជាកម្មាភិបាលរបស់ខ្មែរក្រហម ដែរ ឬយ៉ាងណានោះ គឺជាបញ្ហាដែលត្រូវធ្វើការវិនិច្ឆ័យ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ពាក្យពេចន៍"មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក នោះទេ ប៉ុន្តែ ពាក្យពេចន៍នេះគឺជាគោលការណ៍នៃការស៊ើបអង្កេត និងការចោទប្រកាន់ទាំងស្រុង ក្នុងការណែនាំដល់ឆន្ទានុសិទ្ធិឯករាជ្យរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត នូវមធ្យោបាយល្អបំផុតមួយក្នុងការប្រើប្រាស់ធនធានដែលមានកម្រិតរបស់ខ្លួន ដើម្បីសម្រេចគោលបំណងនៃការបង្កើត អ.វ.ត.ក។ ដូច្នេះ បញ្ហា ថាតើជនជាប់ចោទ គឺជា

[142] *សូមមើលសម័យប្រជុំលើកទីមួយនៃនីតិកាលទីបីរបស់រដ្ឋសភាជាតិកម្ពុជា* ថ្ងៃទី ៤-៥ ខែ តុលា ឆ្នាំ ២០០៤ ទំព័រ ២៣ (ឯកឧត្តម សុខ អាន បញ្ជាក់ថា "ទាក់ទិនទៅនឹងមេដឹកនាំជាន់ខ្ពស់ យើងសំដៅទៅលើបុគ្គលមិនលើសពី ១០ នាក់ឡើយ ប៉ុន្តែយើងមិនបញ្ជាក់ថា ពួកគេជាសមាជិកគណៈអចិន្ត្រៃយ៍ឡើយ។ នេះគឺជាកាតួកិច្ចរបស់សហព្រះរាជអាជ្ញា")។

"មេដឹកនាំជាន់ខ្ពស់" ឬ"អ្នកទទួលខុសត្រូវខ្ពស់បំផុត"នោះ គឺជាបញ្ហាដែលមិនអាចធ្វើការវិនិច្ឆ័យបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[143]។

### *៣.ក.៥.ខ.៥.ការពិនិត្យឡើងវិញលើឆន្ទានុសិទ្ធិនៃការស៊ើបអង្កេត និងការចោទប្រកាន់ដោយផ្អែកលើមូលដ្ឋានផ្សេងទៀត*

៨០. នៅមានបញ្ហាដែលចោទ ថាតើអាចមានមូលដ្ឋានអ្វីផ្សេងទៀត ដែលអង្គជំនុំជម្រះសាលាដំបូងនៅមានយុត្តាធិការសម្រាប់ពិនិត្យឡើងវិញ នូវការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេតនៅក្នុងការជ្រើសរើសរឿងក្ដី ដែរ ឬយ៉ាងណា។ នៅក្នុងរឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង* *Brima* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (SCSL) បានកត់សម្គាល់ឃើញថា នៅក្នុងការជ្រើសរើសរឿងក្ដីទាំងឡាយណា ដែលបានបំពេញទៅតាមលក្ខខណ្ឌមានចែងនៅក្នុងមាត្រា ១(១) នៃលក្ខន្តិកៈរបស់តុលាការនេះ (SCSL) រដ្ឋអាជ្ញាត្រូវអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន"ដោយសុទ្ធចិត្តផ្អែកតាមការ

[143]អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ប្រវត្តិនៃការបង្កើត អ.វ.ត.ក ដូចដែលបានលើកឡើងខាងលើ បានបង្ហាញយ៉ាងច្បាស់លាស់ថា ពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់" និង"អ្នកទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានប្រើប្រាស់នៅក្នុងបរិបទស្ដីអំពីឆន្ទានុសិទ្ធិដ៏ទូលំទូលាយដែលមាននៅក្នុងគោលការណ៍ណែនាំក្នុងការចោទប្រកាន់ និងស៊ើបអង្កេត។ ដូច្នេះមិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ដែលអាចធ្វើវិនិច្ឆ័យបាន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ។ ឆន្ទានុសិទ្ធិនេះ ដែលអនុញ្ញាតឱ្យកម្មាភិបាលខ្មែរក្រហមជាច្រើនទទួលរងការចោទប្រកាន់នោះ គឺជាជម្រើសមួយដែលគេចូលចិត្តលើកយកមកពិភាក្សាជាសាធារណៈជុំវិញការបង្កើត អ.វ.ត.ក។ *សូមមើលជាទូទៅនូវ* បាយការណ៍របស់អង្គការ Open Society Justice Initiative ស្ដីពី៖ *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*, និទាឃរដូវ ឆ្នាំ ២០០៦ និងជាពិសេស ព្រឹត្តប័ត្រនិពន្ធដោយ Kelly Dawn Askin "ការកាត់ទោសមេដឹកនាំជាន់ខ្ពស់ពីបទឧក្រិដ្ឋរបស់ខ្មែរក្រហម", នៅក្នុងព្រឹត្តប័ត្ររបស់ Justice Initiative ចំណងជើងថា៖ *អង្គជំនុំជម្រះវិសាមញ្ញ*, ទំព័រ ៧៦ ("ពាក្យពេចន៍ទាំងនេះមាន ("មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត (...)") អាចបកស្រាយយ៉ាងទូលាយដោយអនុញ្ញាតឱ្យមានភាពបទបែនខ្លះៗ (...)") **<http://www.soros.org/initiatives/justice>**។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា គោលជំហររបស់ខ្លួនទាក់ទងនឹងយុត្តាធិការលើរូបបុគ្គល គឺផ្អែកលើការពិចារណាតាមផ្លូវច្បាប់ ហើយអង្គជំនុំជម្រះតុលាការកំពូលមិនឃើញថាខ្លួនមានតួនាទីក្នុងការកំណត់អំពីវិសាលភាពលើពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់" និង"អ្នកទទួលខុសត្រូវខ្ពស់បំផុត" ក្នុងការធ្វើយុត្តកម្មទៅលើបញ្ហាត្រូវបញ្ចូល ឬត្រូវដកចេញពីការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក នោះទេ។

វិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ"[144]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របលើចំណុចនេះ។ នៅក្នុងបរិបទរបស់ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងមានអំណាចក្នុងការពិនិត្យមើលឡើងវិញលើឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ដោយផ្អែកលើការចោទឡើងថា សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត បានប្រើប្រាស់ឆន្ទានុសិទ្ធិដែលមានចែងនៅក្នុងមាត្រា ៥(៣) និង៦(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលដោយពុំសុទ្ធចិត្ត និងមិនស្របទៅតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ[145]។ អំណាចពិនិត្យមើលឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងមានវិសាលភាពតិចតួចបំផុត ហើយត្រូវប្រើប្រាស់ដោយគោរពឱ្យបានពេញលេញចំពោះឯករាជភាពរបស់ការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត។ អំណាចពិនិត្យមើលឡើងវិញនេះ មិនអាចប្រើប្រាស់ទៅតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត ពុំបានជ្រើសរើស "មេដឹកនាំជាន់ខ្ពស់"ជាក់លាក់ណាមួយ ឬជនណាមួយដែល"ទទួលខុសត្រូវខ្ពស់បំផុត"នោះ។ ដោយហេតុថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិទូលំទូលាយ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនទៅតាមច្បាប់។ ដូចដែលសហព្រះរាជអាជ្ញាបានគូសបញ្ជាក់នៅក្នុងសារណាតប

[144]សាលដីកាក្នុង*រឿងក្តី Brima*, កថាខណ្ឌ ២៨២។

[145]*សូមមើលរឿងក្តីរដ្ឋអាជ្ញា ទល់នឹង Ntakirutimana,* សំណុំរឿងលេខ ICTR-96-17-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៣, កថាខណ្ឌ ៨៧១ (ដោយច្រានចោលបណ្តឹងរបស់ជនជាប់ចោទដែលបានលើកឡើងថា តុលាការនេះមានការពាក់ព័ន្ធនឹងការជ្រើសរើសធ្វើការចោទប្រកាន់ ពីព្រោះ តាមមាត្រា ១៥(២) នៃលក្ខន្តិកៈរបស់តុលាការ ICTR មេធាវីការពារក្តី ពុំបានលើកភស្តុតាងណាមួយក្នុងការបង្ហាញថា រដ្ឋអាជ្ញាមានចេតនារើសអើង ឬខុសច្បាប់នៅក្នុងការចោទប្រកាន់ ឬមិនសមស្របក្នុងការចោទប្រកាន់ ឬនៅក្នុងការបន្តការចោទប្រកាន់លើជនជាប់ចោទឡើយ។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Akayesu,* សំណុំរឿងលេខ ICTR-96-4, "សាលដីកា", អង្គជំនុំជម្រះតុលាកំពូល, ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១, ("សាលដីកាក្នុង*រឿងក្តី Akayesu*"), កថាខណ្ឌ ៩៦ (បដិសេធការលើកឡើងរបស់ជនជាប់ចោទដែលថា តុលាការនេះមានការពាក់ព័ន្ធនឹងការជ្រើសរើសការចោទប្រកាន់ ដោយសារពុំមានភស្តុតាងបង្ហាញទំនាក់ទំនងហេតុ និងផលរវាងគោលការណ៍ណែនាំរបស់រដ្ឋអាជ្ញា និងភាពលម្អៀងដែលបានលើកឡើងនៅក្នុងតុលាការនេះ)។ សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤៥។

របស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខនេះ ការប្រើឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ មិនមែនជាការអនុវត្តដោយស្វ័យប្រវត្តិនោះទេ។ ការធ្វើដូច្នេះ តម្រូវឱ្យមានការថ្លឹងថ្លែងនូវកត្តាពាក់ព័ន្ធនានា ដូចជា បរិមាណ និងគុណភាពនៃភស្តុតាងដែលមាន កម្រិត*ដែលជាសេចក្តីបញ្ជាក់ដំបូង*នៃភស្តុតាងដាក់បន្ទុកលើជនល្មើស ស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ និងលទ្ធភាពដែលឈានទៅដល់ការចាប់ខ្លួនជនសង្ស័យ[146]។ ដោយហេតុថា សេចក្តីសម្រេចធ្វើការចោទប្រកាន់ គឺផ្អែកទៅលើឆន្ទានុសិទ្ធិដែលមានវិសាលភាពដ៏ទូលំទូលាយនោះ ទើបសមត្ថកិច្ចក្នុងការសម្រេចធ្វើការចោទប្រកាន់នេះ មិនមែនអាស្រ័យទៅលើអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ដែលជាអ្នកសម្រេចលើអង្គសេចក្តីអំពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ហើយ សមត្ថកិច្ចនេះត្រូវបញ្ចប់ត្រឹមដំណាក់កាលបុរេជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ដែលប្រើឆន្ទានុសិទ្ធិក្នុងការកំណត់ ថាតើត្រូវធ្វើការចោទប្រកាន់ ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះនេះនឹងដើរតួនាទីជាអយ្យការ ហេតុដូចនេះ នឹងធ្វើឱ្យតួនាទីរបស់ខ្លួនបាត់បង់តម្លៃមកជាមជ្ឈត្តករឥតលំអៀងនៅក្នុងនីតិវិធីតទល់។ ដូច្នេះ ប្រសិនបើមិនមានភស្តុតាងបញ្ជាក់ថា ការប្រើឆន្ទានុសិទ្ធិនេះត្រូវបានធ្វើឡើងដោយពុំសុទ្ធចិត្ត ឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈនោះទេ អង្គជំនុំជម្រះសាលាដំបូងពុំមានអំណាចពិនិត្យឡើងវិញលើការរំលោភឆន្ទានុសិទ្ធិ ដែលបានចោទឡើងចំពោះសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ឡើយ ដោយអនុលោមតាមមាត្រា ៥(៣) និងមាត្រា ៦(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ ចំពោះបញ្ហា ថាតើជនជាប់ចោទ គឺជាមេដឹកនាំជាន់ខ្ពស់មួយរូប ឬជាជនមួយរូបក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដែរ ឬយ៉ាងណានោះ គឺជាសេចក្តីសម្រេចផ្អែកគោលការណ៍ណែនាំតែមួយគត់សម្រាប់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ដែលជាអ្នកទទួលខុសត្រូវ ហើយពុំមែនជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ ។

---

[146]សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤៤។

### *៣.ក.៥.គ.សេចក្តីសន្និដ្ឋាន*

៨១. ដោយផ្អែកលើគោលការណ៍ ដែលមាននៅក្នុងផ្នែកនេះនៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលអង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការ ក្នុងការចាប់ផ្តើមធ្វើការវាយតម្លៃណាមួយ ថាតើជនជាប់ចោទ គឺជាមេដឹកនាំជាន់ខ្ពស់ ឬជាជនមួយរូបក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដែរ ឬយ៉ាងណា នោះឡើយ[147]។ ទោះបីជាយ៉ាងណាក៏ដោយ ការវាយតម្លៃដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើឡើងនោះ គឺបង្ហាញឱ្យឃើញថារឿងក្តីនេះ គឺជាគោលការណ៍ណែនាំនៃការចោទប្រកាន់ និងការស៊ើបអង្កេត។ ដូច្នេះទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទអំពីយុត្តាធិការលើរូបបុគ្គល គ្មានប្រសិទ្ធិភាព ហេតុដូច្នេះ ត្រូវបដិសេធចោលទាំងស្រុង[148]។

---

[147]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៣ ដល់ ២៥។

[148]ទាំងនេះរួមបញ្ចូលនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីដែលលើកឡើងថា ជនជាប់ចោទត្រូវតែរួចផុតពីការចោទប្រកាន់ព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក ដោយផ្អែកលើ *ក្នុងចំណោមនោះ* កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ ១៩៩១, ច្បាប់ឆ្នាំ ១៩៩៤ ស្តីពីការដាក់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" នៅក្រៅច្បាប់, ក្រុមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧, ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦, ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ *សូមមើលឧទា.* បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌ ១៤, ១៧, ៣៤ ដល់ ៣៩, ៦២, ៦៦, ៦៨, ៧០, ៩៥។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ ១៨ ដល់ ២២, ២៨ ដល់ ២៩, ៣១ ដល់ ៣២ (យោងទៅលើ *ក្នុងនោះ*, កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយពេញលេញផ្នែកនយោបាយទៅលើជម្លោះរបស់កម្ពុជា (មានភ្ជាប់នូវឧបសម្ព័ន្ធ), ដែលបានបញ្ចប់នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១, វ៉ុល ១៦៦៣ លេខលំដាប់សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ទំព័រ (ចូលជាធរមាននៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១) និងច្បាប់ស្តីពីការដាក់ក្រុម"កម្ពុជាប្រជាធិបតេយ្យ" នៅក្រៅច្បាប់ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៤, ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤)។

## ៤.កំហុសដែលបានលើកឡើងទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ទឡ្ហីករណ៍ទី ២ និងទី ៣ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា)

៨២. នៅក្នុងទឡ្ហីករណ៍ទី ២ និងទី ៣ នៃបណ្តឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ច្រើនចំណុច ចំពោះការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលបានចោទប្រកាន់លើជនជាប់ចោទដោយអនុលោមតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

៨៣. ទីមួយ យោងតាមទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ ចំពោះការដែលខ្លួនមិនបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទឧក្រិដ្ឋទាំងអស់ដែលជនជាប់ចោទត្រូវទទួលខុសត្រូវ ពោលគឺការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ និងអំពើអមនុស្សធម៌ផ្សេងទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយបានស្រូបបញ្ចូលបទឧក្រិដ្ឋទាំងនេះ ទៅក្នុងបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅវិញ[149]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តមិនត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ដោយហេតុថា បទឧក្រិដ្ឋនីមួយៗនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទត្រូវបានរកឃើញថា ជាអ្នកទទួលខុសត្រូវ មានធាតុផ្សំខុសៗគ្នាពីបទធ្វើទុក្ខបុកម្នេញ ហេតុដូច្នេះ ជនជាប់ចោទគួរតែត្រូវបានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទឧក្រិដ្ឋនីមួយៗ[150]។

៨៤. បន្ថែមពីលើនេះទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា ដោយសារអង្គជំនុំជម្រះសាលាដំបូង បានស្រូបបញ្ចូលបទឧក្រិដ្ឋទាំងអស់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅក្នុងបទ

---

[149] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣២, ១៣៤, ១៩១ និង ២១៦។

[150] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣៤ ដល់ ១៦៦ និង ១៩១។

ឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះសាលាដំបូង បានខកខានក្នុងការបំពេញគោលបំណងទ្វេនៃលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ស្តីពីការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ដូចមានការបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Kordić និង Čerkez*[151]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា "ហានិភ័យដែលកើតចេញពីហេតុផលនៃការមិនអនុញ្ញាតឱ្យមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា"[152]ដូចមានពន្យល់នៅក្នុងមតិជំទាស់ទៅនឹងសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Čelebići* នោះ មិនអាចយកមកអនុវត្តនៅក្នុងរឿងក្តីនេះបានទេ[153]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មិនបានពិចារណាឱ្យបានគ្រប់គ្រាន់លើផលប្រយោជន៍សង្គម នៅក្នុងការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ដូចដែលបានគូសបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR ក្នុងរឿងក្តី *Akayesu*[154]។

៨៥. ចំណុចទីពីរ សហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ នៅពេលអង្គជំនុំជម្រះនេះ បានវាយតម្លៃបទរំលោភលើផ្លូវភេទថា ជាអំពើធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយអង្គជំនុំជម្រះនេះ មិនបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទរំលោភលើផ្លូវភេទ[155]ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដាច់ដោយឡែកឡើយ។ ជាចុងក្រោយ សហព្រះរាជអាជ្ញាលើកឡើងនៅក្នុងទឡ្ហីករណ៍ទី ៣ នៃបណ្តឹងសាទុក្ខរបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ក្នុងការកំណត់និយមន័យនៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋ

---

[151]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣៤, ១៦៧ ដល់ ១៦៩ និង ១៩១។

[152]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៧០។

[153]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣៤, ១៧០ ដល់ ១៧៤ និង ១៩១។

[154]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣៤ និង ១៧៥ ដល់ ១៩១។

[155]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣៣។

កម្មប្រឆាំងមនុស្សជាតិ ដោយខកខានក្នុងការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទធ្វើឱ្យទៅជាទាសករចំពោះអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១[156]។

៨៦. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាប់ចោទ គឺជាអ្នកទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មានដូចជា៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត[157]។ ក៏ប៉ុន្តែ "ដោយផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការ ដែលទាក់ទងទៅនឹងការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា" អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទត្រឹមតែពី"បទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ដោយស្រូបបញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនានា៖ ការសម្លាប់រង្គាល (រួមទាំងការធ្វើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត)"[158]។

៨៧. ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ដំណោះស្រាយចំពោះការលើកឡើងនៅក្នុងទឡ្ហីករណ៍ទី ២ និងទី ៣ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចខាងលើរបស់អង្គជំនុំជម្រះសាលាដំបូង ជាពិសេសចំពោះការយកបទដ្ឋាននៅក្នុងរឿងក្តី *Čelebići* របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY មកអនុវត្ត គឺផ្អែកលើការប្រៀបធៀបរវាងធាតុផ្សំនានានៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះនេះបានរកឃើញ ពីការទទួលខុសត្រូវរបស់ជនជាប់ចោទ។ អាស្រ័យហេតុនេះ ការសម្រេចអំពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះ ចាំបាច់ត្រូវតែផ្អែកលើការពិនិត្យពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលអំពីយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក និងភាពសមស្របនៃការកំណត់

---

[156]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០១។

[157]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៥៩។

[158]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៨។

និយមន័យនៃបទឧក្រិដ្ឋនានា ដែលអង្គជំនុំជម្រះសាលាដំបូងយកមកប្រើប្រាស់។ ការពិនិត្យពិចារណាបែបនេះ តម្រូវឱ្យមានការអនុវត្តគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* *(nullum crimen sine lege)* ដែលត្រូវបានគេស្គាល់ថា ជាគោលការណ៍នីត្យានុកូលភាព ដូចមានចែងក្នុងមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

៨៨. ដូច្នេះ មុននឹងធ្វើការពិចារណាទៅលើបញ្ហាជាក់លាក់នានា ដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះ *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* អង្គជំនុំជម្រះតុលាការកំពូល ជាដំបូងត្រូវតែចង្អុលបង្ហាញអំពីច្បាប់ជាធរមាន ដែលទាក់ទងនឹងគោលការណ៍នីត្យានុកូលភាព។ ក្នុងកម្រិតចាំបាច់នៃបណ្តឹងសាទុក្ខនៅចំពោះមុខខ្លួន បន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូលនឹងពិនិត្យពិចារណាអំពីវិសាលភាពនៃយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដោយផ្អែកតាមគោលការណ៍នីត្យានុកូលភាព។ ជាបន្តមកទៀត អង្គជំនុំជម្រះតុលាការកំពូលនឹងពិនិត្យពិចារណាអំពីយុត្តាធិការលើរឿងក្តីចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានលើកឡើងនៅក្នុងទឡ្ហីករណ៍ទាំងនេះ ពោលគឺ ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ និងការធ្វើទុក្ខបុកម្នេញ។ ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការសន្និដ្ឋានថា ពិរុទ្ធភាពពីបទល្មើសត្រួតគ្នាចំពោះការធ្វើទុក្ខបុកម្នេញ និងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រូវបានអនុញ្ញាត ដែរ ឬយ៉ាងណា។

## ៤.ក.គោលការណ៍នីត្យានុកូលភាព

៨៩. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា អ.វ.ត.ក ត្រូវអនុវត្ត"យុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ឆ្នាំ ១៩៦៦ (ICCPR)"[159]។ មាត្រា ១៥(១)

[159]មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក។

នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR) បានចែង និងកំណត់និយមន័យនៃគោលការណ៍នីត្យានុកូលភាព ក្រោមច្បាប់អន្តរជាតិ និងបានចែងក្នុងផ្នែកពាក់ព័ន្ធថា "គ្មានជនណាម្នាក់ត្រូវបានសម្រេចឱ្យជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬអកម្មណាមួយដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ផ្អែកតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត"[160]។ លើសពីនេះទៀត មាត្រា ១៥(២) នៃកតិកាសញ្ញានេះបានចែងបន្ថែមទៀតថា "គ្មានបទប្បញ្ញត្តិណាមួយក្នុងមាត្រានេះ ធ្វើឱ្យប៉ះពាល់ដល់ការជំនុំជម្រះក្តី និងការផ្តន្ទាទោសលើជនណាម្នាក់ ចំពោះអំពើសកម្ម ឬអកម្ម ដែលជននោះបានប្រព្រឹត្ត ហើយនៅពេលប្រព្រឹត្តអំពើនោះជាបទល្មើសព្រហ្មទណ្ឌ យោងតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ"[161]។

៩០. គោលបំណងសំខាន់នៃគោលការណ៍នីត្យានុកូលភាពដែលបានកំណត់និយមន័យបែបនេះ គឺដើម្បីការពារសិទ្ធិបុគ្គលនៅក្នុងច្បាប់ព្រហ្មទណ្ឌ។ គោលបំណងសំខាន់នេះ មានមុខងារបីយ៉ាង៖ ទីមួយ គឺដើម្បីធានាថា បុគ្គលណាមួយដែលចង់ជៀសផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌបាន ត្រូវតែមានការយល់ដឹងជាមុនពីអំពើ ដែលអង្គការនីតិបញ្ញត្តិបានកំណត់ជាបទល្មើសព្រហ្មទណ្ឌ។ ទីពីរ ជាផ្នែកនីតិវិធី គោលការណ៍នីត្យានុកូលភាព ការពារបុគ្គលឱ្យរួចផុតពីការប្រើប្រាស់តាមទំនើងចិត្តនូវអំណាចនយោបាយ ឬអំណាចតុលាការ[162] ដោយរារាំងអង្គការនីតិបញ្ញត្តិមិនឱ្យកំណត់គោលដៅលើបុគ្គលជាក់លាក់ណាមួយ ដោយមិនមានចែងក្នុងច្បាប់ជាមុន។ ទីបី គោលការណ៍នេះ មានលក្ខណៈដូចគ្នាទៅនឹងការការពារតុលាការជាតិ

---

[160] មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)។

[161] មាត្រា១៥(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ដែលជាទូទៅសំដៅលើ"ការផ្តន្ទាទោសនៅតុលាការ Nuremberg/Tokyo")។

[162] ព្រឹត្តប័ត្រនិពន្ធដោយ M. Cherif Bassiouni, មានចំណងជើងថា៖ *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, បោះពុម្ពផ្សាយលើកទីពីរ, Kluwer Law International, ឆ្នាំ ១៩៩៩, ទំព័រ ១២៧ ដល់ ១៣០។

ដែលអនុវត្តច្បាប់ជាតិ[163] តាមរយៈការបែងចែកអំណាច។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មុខងារក្នុងការរារាំងនៃគោលការណ៍នីត្យានុកូលភាពអន្តរជាតិ គឺមានសារៈសំខាន់ពិសេស នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ពីព្រោះមុខងារនេះរារាំងដល់តុលាការអន្តរជាតិ ឬតុលាការពិសេស មិនឱ្យអនុវត្តដោយឯកឯងហួសពីយុត្តាធិការរបស់ខ្លួន ដែលមុខងារនេះបានផ្តល់នូវដែនកំណត់ច្បាស់លាស់ថា អំពើណាខ្លះជាបទល្មើសព្រហ្មទណ្ឌ។

៩១. គោលការណ៍នីត្យានុកូលភាពអន្តរជាតិ ដែលផ្តោតទៅលើការធានានូវការគោរពសិទ្ធិមនុស្សក្នុងនីតិវិធីព្រហ្មទណ្ឌ គឺជាប់ពាក់ព័ន្ធទៅនឹងគោលការណ៍ទូទៅនៃច្បាប់ ស្តីពីការហាមឃាត់ក្នុងការបង្កើតបទល្មើស និងទណ្ឌកម្មដែលមានលក្ខណៈប្រតិសកម្ម និងការហាមឃាត់ចំពោះការដាក់ទណ្ឌកម្មជាក្រុមចំពោះជនដែលមិនបានចូលរួមប្រព្រឹត្តបទល្មើស។ ដូច្នេះ គោលការណ៍នេះ អនុវត្តស្មើៗគ្នាចំពោះរាល់បទល្មើស ព្រមទាំងរាល់ទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទជាបុគ្គល[164]។ ហេតុដូច្នេះ រាល់បទល្មើស និងរាល់ទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ត្រូវតែមានអត្ថិភាពក្រោមច្បាប់ជាតិ[165] ឬច្បាប់អន្តរជាតិ[166] នៅពេលដែលអំពើល្មើសដែលបានចោទ

---

[163]ព្រឹត្តប័ត្រនិពន្ធដោយ Kenneth E. Gallant, មានចំណងជើងថា៖ *គោលការណ៍នីត្យានុកូលនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិនិងច្បាប់ព្រហ្មទណ្ឌដែលមានលក្ខណៈប្រហាក់ប្រហែល,* ចេញផ្សាយដោយសាកលវិទ្យាល័យ Cambridge, ឆ្នាំ ២០០៩, ទំព័រ ២៦។

[164]*សូមមើលរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Milutinović និងជនដទៃទៀត,* សំណុំរឿងលេខ IT-99-37-AR72, "សេចក្តីសម្រេចស្តីពីសំណើរបស់ Dragolijub Ojdanić ដែលជំទាស់ទៅនឹងយុត្តាធិការចំពោះបញ្ហាសហឧក្រិដ្ឋកម្មរួម" អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងយុត្តាធិការក្នុង*រឿងក្តី Milutinović* (សហឧក្រិដ្ឋកម្មរួម)"), កថាខណ្ឌ ៣៤ ដល់ ៤៤ (ដូចដែលបានអនុវត្តទៅលើសហឧក្រិដ្ឋកម្មរួម)។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Aleksovski*, សំណុំរឿងលេខ IT-95-14/1-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០០, ("សាលដីកាក្នុង*រឿងក្តី Aleksovski*"), កថាខណ្ឌ ១២៦ (ដែលអនុវត្តចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ព្រមទាំងការរំលោភបំពានច្បាប់សង្គ្រាម ឬទំនៀមទម្លាប់សង្គ្រាម)។

[165]មាត្រា ១៥(១) នៃ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)។

[166]មាត្រា ១៥(១) ដល់ (២) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងយុត្តាធិការក្នុង*រឿងក្តី Milutinović* (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ១០ និង ៣៨។

ប្រកាន់នោះ កើតឡើងនៅក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩[167]។

៩២. ទាក់ទងទៅនឹងច្បាប់ជាតិ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ គឺជាច្បាប់ដែលអាចយកមកអនុវត្តបានចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[168]។ ចំពោះច្បាប់អន្តរជាតិជាធរមាន មានបណ្តុំឯកសារយោងទូលំទូលាយជាង ដែលរួមមាន អនុសញ្ញាអន្តរជាតិ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ ដែលអាចយកមកអនុវត្តបាននាពេលនោះ[169]។ បញ្ហាស្មុគស្មាញដែលកើតមានទាក់ទងនឹងការកកើតនិយាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលចេញពីប្រភពខាងលើនេះ និងទំនាក់ទំនងនៃនិយាមទាំងនេះ ត្រូវបានដោះស្រាយយ៉ាងទូលំទូលាយនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍*នានា។ នៅពេលពិចារណាអំពីច្បាប់សន្ធិសញ្ញាអន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលអាចផ្អែកលើសន្ធិសញ្ញា នៅពេលដែលសន្ធិសញ្ញានោះ “(១) ចងកាតព្វកិច្ចភាគីនានាយ៉ាងពិតប្រាកដ នៅពេលដែលបទល្មើសត្រូវបានចោទប្រកាន់ និង (២) ស្រប ឬមិនបដិប្បញ្ញត្តិជាមួយនឹងនិយាមចាប់បង្ខំដាច់ខាតនៃច្បាប់អន្តរជាតិ”[170]។

៩៣. ពាក់ព័ន្ធទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា លក្ខខណ្ឌតម្រូវដែលជាទម្លាប់នៃការអនុវត្តរបស់រដ្ឋ ដែលមានលក្ខណ:“ទូលំទូលាយ និងឯកភាព” អាចមានភាពធូរស្រាលជាងលក្ខខណ្ឌតម្រូវ នៅក្នុងវិស័យផ្សេងៗទៀតនៃច្បាប់អន្តរ

---

[167] មាត្រា ១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[168] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៩។

[169] មាត្រា ១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)។ *សូមមើលផងដែរ* ឧបសម្ព័ន្ធភ្ជាប់ទៅនឹងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ, មាត្រា ៣៨ នៃច្បាប់លក្ខន្តិក:របស់តុលាការយុត្តិធម៌អន្តរជាតិ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៤៥ (“ICJ Statute”)។

[170] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Tadić, សំណុំរឿងលេខ IT-95-14/2-A, “សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំរបស់មេធាវីការពារក្តីទាក់ទងនឹងយុត្តាធិការ”, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥, (សេចក្តីសម្រេចលើបណ្តឹងសាទុក្ខទាក់ទងនឹងយុត្តាធិការក្នុង*រឿងក្តី* Tadić ), កថាខណ្ឌ ៤៤។

ជាតិ ហើយលក្ខខណ្ឌតម្រូវនៃការប្រកាសពីឆន្ទៈទទួលយកជាច្បាប់ អាចមានភាពសំខាន់ជាង ធាតុផ្សំនៃការអនុវត្តទំនៀមទម្លាប់ នៅពេលធ្វើការវាយតម្លៃអំពីការកកើតនូវគោលការណ៍ ឬវិធានទូទៅពាក់ព័ន្ធទៅនឹងអំពើណាមួយដែលរំលោភបំពានច្បាប់មនុស្សជាតិ ឬរំលោភបំពាន ជាពិសេស ទៅលើតម្រូវការនៃមនសិការរួមនោះ[171]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ករណីនេះមានចំណងទាក់ទងយ៉ាងពិសេសទៅនឹងបញ្ហានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល ក្រោមច្បាប់អន្តរជាតិ។ ធាតុផ្សំផ្នែកសត្យានុម័តនៃបទឧក្រិដ្ឋអន្តរជាតិ អាចបង្ហាញឱ្យឃើញតាមរយៈការចោទប្រកាន់ជាក់ស្តែង។ ក្នុងន័យនេះ ត្រូវដឹងថាលក្ខខណ្ឌតម្រូវនៃធាតុផ្សំនេះ មិនត្រឹមតែសន្មតជាមុននូវនិយាមច្បាប់ដែលហាមឃាត់អំពើដែលជាបទឧក្រិដ្ឋតែប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងភស្តុតាងនៃបទឧក្រិដ្ឋផងដែរ រួមទាំងកត្តាស្មុគស្មាញជាច្រើន ដែលអាចនាំឱ្យមានការចោទប្រកាន់បាន។ កត្តាទាំងនេះ រួមមានការកំណត់អត្តសញ្ញាណរបស់ជនជាប់ចោទ អត្ថិភាពនៃភស្តុតាង និងឆន្ទៈនយោបាយ[172]។ ដោយពិចារណាលើភាពលំបាកពាក់ព័ន្ធទាំងអស់ លទ្ធភាពតិចតួចក្នុងការចោទប្រកាន់មិនអាចបោះបង់ដោយស្វ័យប្រវត្តិ នូវអត្ថិភាពនៃការអនុវត្តរបស់រដ្ឋក្នុងបញ្ហានេះ តាមច្បាប់អន្តរជាតិ បានទេ។

៩៤. ត្រូវតែមានការទទួលស្គាល់ថា ច្បាប់សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ តែងតែគាំទ្រ និងបំពេញឱ្យគ្នាទៅវិញទៅមក[173]។ ហេតុដូចនេះ ច្បាប់សន្ធិសញ្ញាអាចជាភស្តុតាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាមរយៈការប្រកាសពីឆន្ទៈទទួលយកជាច្បាប់ (*opinio juris*) របស់រដ្ឋភាគីនានា ឬតាមរយៈការបញ្ជាក់ឱ្យឃើញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអាចយក

---

[171]ព្រឹត្តប័ត្រនិពន្ធដោយ Antonio Cassese, ចំណងជើងថា៖ *ច្បាប់អន្តរជាតិ*, បោះពុម្ពផ្សាយលើកទីពីរ, ចេញផ្សាយដោយសាកលវិទ្យាល័យ Oxford, ឆ្នាំ ២០០៥, ទំព័រ ១៦១។

[172]នៅក្នុងបរិបទនៃការប្រព្រឹត្តិរបស់កងកម្លាំងប្រដាប់អាវុធ *ប្រៀបធៀប* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពី យុត្តាធិការក្នុង*រឿងក្តី Tadić*, កថាខណ្ឌ ៩៧។ មានការលំបាកយ៉ាងខ្លាំង នៅពេលដែលអំពើឃោរឃៅដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានប្រព្រឹត្តឡើងនៅក្រៅរដ្ឋណាមួយ។

[173]សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង*រឿងក្តី Tadić*, កថាខណ្ឌ ៩៨។

00798389



មកអនុវត្តបាន ហើយដែលបានកើតជារូបរាងនៅពេលដែល សន្ធិសញ្ញាត្រូវបានអនុម័ត[174]។ ដូចដែលបានលើកឡើងខាងលើ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលអាចផ្អែកលើទាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់សន្ធិសញ្ញាអន្តរជាតិ ដើម្បីធ្វើជាមូលដ្ឋានច្បាប់សម្រាប់រាល់បទល្មើសដែលចោទប្រកាន់ និងរាល់ទម្រង់នៃការទទួលខុសត្រូវក៏ដោយ ក៏ប៉ុន្តែ មិនមានលក្ខខណ្ឌតម្រូវណាមួយកំណត់ថា រាល់បទល្មើស ឬរាល់ទម្រង់នៃការទទួលខុសត្រូវនេះ ត្រូវតែមាននៅក្នុងច្បាប់ណាមួយ ដើម្បីធ្វើការចោទប្រកាន់បាននោះទេ[175]។

៩៥. ពេលដែលអង្គជំនុំជម្រះបានកំណត់ថា បទល្មើសដែលបានចោទប្រកាន់ ឬទម្រង់នៃការទទួលខុសត្រូវមានអត្ថិភាពនៅក្នុងច្បាប់ជាតិ ឬច្បាប់អន្តរជាតិនៅពេលអំពើនោះជាបទល្មើស នោះគោលការណ៍នីត្យានុកូលភាពអន្តរជាតិ មិនហាមឃាត់អង្គជំនុំជម្រះធ្វើការបកស្រាយ ឬបំភ្លឺច្បាប់ ឬផ្អែកលើសេចក្តីសម្រេចទាំងនោះ ដែលនៅក្នុងរឿងក្តីដទៃទៀត ក៏បានធ្វើដូច្នេះដែរនោះទេ[176]។ ទោះបីជាយ៉ាងណាក៏ដោយ គោលការណ៍នេះពិតជាហាមឃាត់អង្គជំនុំជម្រះ "ចំពោះការបង្កើតច្បាប់ថ្មី ឬចំពោះការបកស្រាយច្បាប់ដែលមានស្រាប់ឱ្យហួសពីដែនកំណត់សមហេតុផលនៃការបំភ្លឺដែលអាចទទួលយកបាន"[177]។

---

[174]សាលដីការក្នុង*រឿងក្តី Galić*, កថាខណ្ឌ ៨៥។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង*រឿងក្តី Tadić*, កថាខណ្ឌ ១១២ និង ១១៧។

[175]*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Hadžihasanović និង Kubura*, សំណុំរឿងលេខ IT-01-47-A, "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំប្រឆាំងនឹងយុត្តាធិការទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣, ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង*រឿងក្តី Hadžihasanović និង Kubura*" *ការទទួលខុសត្រូវរបស់ថ្នាក់លើ*), កថាខណ្ឌ ៣៥។

[176]សាលដីកាក្នុង*រឿងក្តី Aleksovski* , កថាខណ្ឌ ១២៦ ដល់ ១២៧។

[177]*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Ojdanić និងជនដទៃទៀត*, សំណុំរឿងលេខ IT-96-37-AR72, "សេចក្តីសម្រេចនៃបណ្តឹងសាទុក្ខលើសំណើរបស់ Dragoljub Ojdanić ជំទាស់ទៅនឹងយុត្តាធិការនៃសហឧក្រិដ្ឋកម្មរួម", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខក្នុង*រឿងក្តី Ojdanić* ស្តីពីយុត្តាធិការ (សហឧក្រិដ្ឋកម្មរួម)"), កថាខណ្ឌ ៣៨។

៩៦. ជាចុងក្រោយ ដើម្បីជាការធានាបន្ថែម ការព្រួយបារម្ភអំពីភាពយុត្តិធម៌ និងដំណើរការនីតិវិធីឆាប់រហ័ស ដែលជាមូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាពអន្តរជាតិតម្រូវថា រាល់បទល្មើសដែលបានចោទប្រកាន់ ឬរាល់ទម្រង់នៃការទទួលខុសត្រូវ "ត្រូវមានលក្ខណៈអាចយល់ដឹងជាមុនបានគ្រប់គ្រាន់ថា ជាបទល្មើស ហើយថា ជនជាប់ចោទអាចដឹងពីច្បាប់ដែលចែងអំពីការទទួលខុសត្រូវបែបនេះ នាពេលនោះ"[178]។ "ចំពោះភាពអាចយល់ដឹងជាមុនថាជាបទល្មើសនោះ ជនជាប់ចោទត្រូវតែអាចដឹងថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាអំពើព្រហ្មទណ្ឌក្នុងន័យដែលគេអាចយល់ដឹងជាទូទៅ ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយនោះទេ"[179]។ ចំពោះលក្ខខណ្ឌដែលអាចដឹងថាមានច្បាប់ចែងនោះ ក្រៅពីច្បាប់សន្ធិសញ្ញានានា នៅមានច្បាប់នានាដែលផ្អែកលើទំនៀមទម្លាប់ ឬគោលការណ៍ទូទៅ ក្នុងការបញ្ជាក់ថា ជនជាប់ចោទអាចដឹងថាមានច្បាប់ចែងគ្រប់គ្រាន់[180]។ បន្ថែមពីលើនេះ អង្គជំនុំជម្រះ "អាចសំអាងលើច្បាប់ជាតិក្នុងគោលបំណងបញ្ជាក់ថា ជនជាប់ចោទអាចដឹងដោយសមហេតុផលថា បទល្មើសដែលជាបញ្ហានេះ ឬបទល្មើសដែលបានប្រព្រឹត្ត ដូចដែលបានចោទប្រកាន់នៅក្នុង

---

[178]សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង*រឿងក្តី* *Ojdanić* (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ២១ និង ៣៧។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Blagojević *និង* Jokić, សំណុំរឿងលេខ IT-02-60-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥, ("សាលក្រមក្នុង*រឿងក្តី Blagojević និង Jokić*"), កថាខណ្ឌ ៦៩៥, ជើងទំព័រ ២១៤៥។ *សូមមើលផងដែររឿងក្តី S.W. ទល់នឹង ចក្រភពអង់គ្លេស,* តុលាការថ្នាក់តំបន់អឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR), "សាលក្រម", សំណើសុំលេខ 20166/92, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥, កថាខណ្ឌ ៣៥ ដល់ ៣៦ (បានបង្ហាញថា ពាក្យពេចន៍"ច្បាប់"នៅក្នុងមាត្រា ៧ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស "រួមមានច្បាប់ជាលាយលក្ខណ៍អក្សរ ព្រមទាំងច្បាប់ទំនៀមទម្លាប់ដែលមិនមានសរសេរជាលាយលក្ខណ៍អក្សរ និងបង្កប់ន័យលក្ខខណ្ឌតម្រូវគុណសម្បត្តិជាពិសេសលក្ខខណ្ឌទាក់ទងនឹងភាពអាចដឹងថា មានច្បាប់ចែង និងភាពអាចយល់ដឹងជាមុនថាជាបទឧក្រិដ្ឋ")។

[179]សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង*រឿងក្តី Hadžihasanović និង Kubura* (ការទទួលខុសត្រូវរបស់ថ្នាក់លើ), កថាខណ្ឌ ៣៤។

[180]សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង*រឿងក្តី Hadžihasanović និង Kubura* (ការទទួលខុសត្រូវរបស់ថ្នាក់លើ), កថាខណ្ឌ ៣៤។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុងរឿងក្តី *Ojdanić* (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ៣៧ ដល់ ៣៩។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជាអំពើដែលត្រូវបានហាមឃាត់ និងអាចផ្តន្ទាទោសបាន"[181]។ ជាចុងក្រោយ "ថ្វីត្បិតតែ អំពើអសីលធម៌ ឬអំពើដែលមានចរិតលក្ខណៈគួរឱ្យរន្ធត់ មិនអាចចាត់ជាកត្តាគ្រប់គ្រាន់ដើម្បីកំណត់ថា ជាបទល្មើសព្រហ្មទណ្ឌក៏ដោយ (...) ក៏អំពើបែបនេះអាចដើរតួនាទីមួយ (...) ក្នុងការបដិសេធចំពោះការអះអាងណាមួយរបស់ជនជាប់ចោទដែលថា ខ្លួនមិនបានដឹងអំពីចរិតព្រហ្មទណ្ឌនៃអំពើនោះដែរ"[182]។

៩៧. ក្នុងរឿងក្តីនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងផ្អែកយ៉ាងខ្លាំងទៅលើយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* នៅពេលកំណត់អំពីអត្ថិភាពនៃរាល់ឧក្រិដ្ឋកម្ម ឬរាល់ទម្រង់នៃការទទួលខុសត្រូវ ឬនៅពេលធ្វើការបកស្រាយច្បាប់ដែលពាក់ព័ន្ធនឹងបញ្ហាទាំងនេះ។ ជាបញ្ហាបឋម អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា រឿងក្តីទាំងនេះមិនមានអានុភាពចងកាតព្វកិច្ច និង មិនមែនជាប្រភពចំបងនៃច្បាប់អន្តរជាតិសម្រាប់ អ.វ.ត.ក ទេ[183]។ លើសពីនេះទៀត ទោះបីជា អ.វ.ត.ក ពឹងផ្អែកយ៉ាងខ្លាំងទៅលើសំអាងហេតុក្នុងការវិភាគ និងការអភិវឌ្ឍច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់តុលាការ *មិនអចិន្ត្រៃយ៍*ក៏ដោយ ក៏ដោយសារតែមុខងារការពារនៃគោលការណ៍នីត្យានុកូលភាព ដូចបានគូសបញ្ជាក់ខាងលើ អង្គជំនុំជម្រះនៃ អ.វ.ត.ក ត្រូវមានកាតព្វកិច្ចក្នុងការសម្រេចថា ការកំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ អាចយកមកអនុវត្តបាននៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ខ្លួន ហើយជនជាប់ចោទត្រូវតែអាចយល់ដឹងជាមុនថាជាបទល្មើស និងដឹងជាមុនថាមានច្បាប់ចែង។ បន្ថែមពីលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ការពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ន និងដោយមានសំអាងហេតុអំពីការកំណត់ទាំងនេះ មានសារៈសំខាន់ចាំបាច់ណាស់ក្នុងការធានាអំពីធម្មានុរូបរបស់ស្ថាប័ន និងសេចក្តីសម្រេចរបស់ អ.វ.ត.ក[184]។ ដូច្នេះ នៅក្នុងផ្នែកជាបន្តបន្ទាប់ទៀត អង្គជំនុំជម្រះ

---

[181]សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង*រឿងក្តី Ojdanić* (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ៤០។

[182]សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុងរឿងក្តី *Ojdanić* (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ៤២។

[183]*សូមមើល* មាត្រា ៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ Statute)។

[184]ដូចដែល Guénaël Mettreaux បានកត់សម្គាល់នៅក្នុងបរិបទរបស់តុលាការ*មិនអចិន្ត្រៃយ៍នានា* ថា៖ "កេរ្តិ៍ដំណែលនៃយុត្តាធិការដែលឋិតថេរយូរអង្វែងរបស់តុលាការ នឹងផ្អែកយ៉ាងខ្លាំងទៅលើសមត្ថភាពរបស់ខ្លួនក្នុងការចេញសេចក្តីសម្រេច

តុលាការកំពូល នឹងវាយតម្លៃ ថាតើការផ្អែកលើយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍*ពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងបញ្ហាជាក់លាក់ទាំងឡាយដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ មានលក្ខណៈសមស្រប ដែរ ឬយ៉ាងណា។

---

ដោយផ្អែកលើប្រព័ន្ធច្បាប់ដែលមានស្រាប់ មិនមែនផ្អែកទៅលើការចង់បានជាទ្រឹស្តីរបស់អ្នកធ្វើសេចក្តីព្រាងនោះឡើយ។ តុលាការទាំងពីរអាចក្លាយជាតុលាការ ដែលមិនអាចផ្តល់នូវទំនុកចិត្តជាប្រវត្តិសាស្ត្រ និងត្រឹមត្រូវតាមច្បាប់បានឡើយ ប្រសិនបើតុលាការទាំងនេះ ហាក់បីដូចជាគិតតែពីការពារនូវសេចក្តីពេញចិត្តផ្នែកគំនិតបញ្ញាផ្ទាល់ខ្លួន ឬការបកស្រាយច្បាប់មិនត្រឹមត្រូវនោះ"។ ព្រឹត្តប័ត្រនិពន្ធដោយ Guénaël Mettreaux, ស្តីពី"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរវ៉ាន់ដា" *ព្រឹត្តប័ត្រច្បាប់អន្តរជាតិនៃសាកលវិទ្យាល័យ* Harvard, វ៉ុល ៤៣ (ក្នុងសិសិរដូវ ឆ្នាំ ២០០២), ទំព័រ ២៣៩។ *សូមមើលផងដែរព្រឹត្តប័ត្រនិពន្ធដោយ* *Kenneth E. Galant, ស្តីពី៖ គោលការណ៍នីត្យានុកូលភាពនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា*, ទំព័រ ២៤ (ស្តីពីតម្លៃនៃការបកស្រាយក្នុងន័យបែបចង្អៀតបំផុត ដែលផ្ទុយពីប្រព័ន្ធតុលាការដែលដណ្តើមតួនាទីអង្គនីតិបញ្ញត្តិ ដោយធ្វើការអនុវត្តច្បាប់ ដែលមានលក្ខណៈមិនច្បាស់លាស់។

## ៤.ខ.ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាឧក្រិដ្ឋកម្មអន្តរជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩

៩៨. នៅពេលនេះ អង្គជំនុំជម្រះតុលាការកំពូល នឹងពិចារណាជាបញ្ហាទូទៅ អំពីវិសាលភាពនៃយុត្តាធិការ អ.វ.ត.ក ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងបរិបទនៃគោលការណ៍នីត្យានុកូលភាពអន្តរជាតិ។ ក្នុងការពិចារណាបែបនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្រប ជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងថា ដើម្បីឱ្យបទល្មើសដែលត្រូវបានចោទប្រកាន់ និងទម្រង់នៃការចូលរួមស្ថិតនៅក្នុងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក បទល្មើស និងទម្រង់នៃការចូលរួមទាំងនោះត្រូវតែ៖ ១) "មានចែងនៅក្នុង*ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក* ដោយច្បាស់លាស់ ឬដោយប្រយោល"[185] និង ២) មានអត្ថិភាពក្រោមច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិ[186] នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និង ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[187]។

៩៩. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ដោយអនុលោមតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អ.វ.ត.ក មានយុត្តាធិការលើរឿងក្តីយ៉ាងច្បាស់លាស់ ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយអនុលោមតាមគោលការណ៍នីត្យានុកូលភាព គឺថា ការរៀបរាប់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមែនជាប្រភពនៃការកំណត់ពីអំពើដែលមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌឡើយ ដូច្នេះហើយ មិនបង្កើតបានជាមូលដ្ឋានឯករាជ្យមួយក្នុងការសម្រេចដាក់ពិរុទ្ធភាពនៅចំពោះមុខ អ.វ.ត.ក ឡើយ។ ក៏ប៉ុន្តែ ទោះបីជា មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផ្តល់ឱ្យ អ.វ.ត.ក នូវ*យុត្តាធិការដែលសន្មតទុកជា*

---

[185] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង*រឿងក្តី Ojdanić,* (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ២១។ *សូមមើលផងដែរ*សាលក្រមក្នុង*រឿងក្តី Blagojević និង Jokić*, កថាខណ្ឌ ៦៩៥, ជើងទំព័រ ២១៤៥។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Stakić*, សំណុំរឿងលេខ IT-97-24-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣, ("សាលក្រមក្នុង*រឿងក្តី Stakić*"), កថាខណ្ឌ ៤៣១។

[186] មាត្រា ១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)។ *សូមមើលផងដែរ*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង*រឿងក្តី Ojdanić* (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ១០ និង ៣៨។

[187] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៨។

*មុន* (*a priori jurisdiction*) ទៅលើអំពើនានាដែលបានរៀបរាប់ខាងលើក៏ដោយ ក៏ការអនុវត្តយុត្តាធិការរបស់ខ្លួន ត្រូវស្ថិតនៅក្រោមការសម្រេច ថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបញ្ញត្តិហាមឃាត់ក្រោមច្បាប់អន្តរជាតិ[188]ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ នៅពេលដែលមានការប្រព្រឹត្តអំពើឧក្រិដ្ឋត្រូវបានចោទប្រកាន់នៅក្នុងរឿងក្តីនេះ ដែរ ឬយ៉ាងណា។

១០០. ទីពីរ ដោយសន្មតថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពិតជាមានអត្ថិភាព ក្រោមច្បាប់អន្តរជាតិនៅពេលបទល្មើសបានប្រព្រឹត្តឡើង ដូច្នេះការអនុវត្តយុត្តាធិការរបស់អង្គជំនុំជម្រះត្រូវបានកម្រិតដោយនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលមានកំណត់តាមច្បាប់អន្តរជាតិ នៅពេលដែលអំពើល្មើសត្រូវបានចោទប្រកាន់បានប្រព្រឹត្តឡើង។ម្យ៉ាងវិញទៀត មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមជាមួយនឹងបញ្ជីរាយឈ្មោះនៃបទល្មើសនានាក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែល អ.វ.ត.ក មាន*យុត្តាធិការដែលសន្មតទុកជាមុន* (*a priori jurisdiction*) ទៅលើឧក្រិដ្ឋកម្មទាំងនោះ មិនអាចត្រូវបានបកស្រាយថា ជាវិសោធនកម្មច្បាប់ដែលមានអានុភាពប្រតិសកម្មចំពោះនិយមន័យនេះ នោះឡើយ។

១០១. ទាក់ទិននឹងបញ្ហាទីមួយអំពីអត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា សញ្ញាណដំបូងទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាប់ផ្តើមមានតាំងពីពេលនិពន្ធសៀវភៅរបស់ Hugo Grotius មកម្ល៉េះ[189]។ ក្នុងសតវត្សទី ១៨ នៅក្នុងបុព្វកថានៃសេចក្តីប្រកាសទីក្រុង សាំង ប៉េធើស៊្បឺក

---

[188]អង្គជំនុំជម្រះ ពុំពិចារណាអំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ពីព្រោះឧក្រិដ្ឋកម្មទាំងនេះមិនត្រូវបានហាមឃាត់ក្រោមច្បាប់កម្ពុជានៅពេលអនុវត្តច្បាប់នេះ។

[189]អ្នកនិពន្ធ Hugo Grotius, សៀវភៅឈ្មោះ *De jure Belli ac Paci*, (អ្នកបកប្រែឈ្មោះ Francis W. Kelsey, ចេញផ្សាយសាកលវិទ្យាល័យ Oxford, ឆ្នាំ ១៩២៥), គន្លឺ II, ជំពូក ២០, ផ្នែក XL(1) (សៀវភៅបានបោះពុម្ពផ្សាយលើកទីមួយ ឆ្នាំ ១៦២៥) <http://www.lonang.com/exlibris/grotius/index.html>:

> ការពិតត្រូវបានគេទទួលស្គាល់ផងដែរថា ស្តេច និងអ្នកដែលមានសិទ្ធិស្មើនឹងស្តេចមានសិទ្ធិធ្វើការទាមទារផ្តន្ទាទោសមិនត្រឹមតែចំពោះព្យសនកម្មមកលើខ្លួន ឬមកលើវត្ថុរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំង

(Declaration of St. Petersburg) ក្នុងឆ្នាំ ១៨៦៨ ដែលមានការលើកឡើងអំពីការរំលោភបំពានលើ"ច្បាប់មនុស្សជាតិ"[190]។ មានពាក្យពេចន៍ប្រហាក់ប្រហែលគ្នានេះក្នុងគោលការណ៍ម៉ាថឹន (Martens Clause) នៅក្នុងអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៨៩៩[191] និងឆ្នាំ ១៩០៧[192] ផងដែរ។

---

ចំពោះព្យសនកម្ម ដែលមិនបានប៉ះពាល់ដល់ខ្លួនដោយផ្ទាល់ផងដែរ ដោយសារជាការរំលោភច្បាប់ធម្មជាតិហួសហេតុ ឬច្បាប់ជាតិដែលទាក់ទងទៅនឹងបុគ្គលណាមួយនោះ។

*សូមមើលផងដែរ* Hugo Grotius, *De jure Belli ac Paci*, គន្ថី II, ជំពូក ២៥, ផ្នែក ៨ (២) "ប៉ុន្តែ ប្រសិនបើ រដ្ឋមានកំហុសច្បាស់នោះ, ដូចជាក្នុងករណី Busiris, Phalaris, or Thracian Diomede ដែលបានប្រព្រឹត្តអំពើខុសឆ្គងទៅលើប្រជាជនរបស់ខ្លួន ដែលអំពើនេះមិនមានលក្ខណៈសមស្របនោះ សង្គមទាំងមូលមានសិទ្ធិក្នុងការធ្វើអន្តរាគមន៍បាន")។ អ្នកនិពន្ធ Emerich de Vattel, ច្បាប់មនុស្សជាតិ ឬ គោលការណ៍ច្បាប់ធម្មជាតិអនុវត្តចំពោះការដឹកនាំ និងកិច្ចការរបស់ប្រជាជាតិ និងម្ចាស់អធិបតេយ្យ, ទីក្រុង Philadelphia, ឆ្នាំ ១៨៨៣, គន្ថី II, ជំពូក ៤, ទំព័រ ២៩៨, (អះអាងបញ្ជាក់ថាអធិបតេយ្យភាពមិនមានអន្ទានុសិទ្ធិពេញលេញនៅក្នុងការគ្រប់គ្រងប្រជាជនរបស់ខ្លួននោះទេ៖ "ប្រសិនបើ ស្តេចដែលប្រឆាំងនឹងច្បាប់ជាមូលដ្ឋាន បានផ្តល់នូវមូលហេតុជាធម្មានុរូបថា ប្រជាជនធ្វើការប្រឆាំងនឹងខ្លួននោះ ឬប្រសិនបើមេដឹកនាំម្នាក់ប្រើអំពើផ្តាច់ដែលធ្វើឲ្យប្រជាជនទ្រាំលែងបាននោះដែលត្រូវតែក្រោកឡើងប្រឆាំងនោះ ប្រទេសមហាអំណាចបរទេសណាមួយ តម្រូវឲ្យផ្តល់ការជ្រោមជ្រែងទៅតាមការស្នើសុំរបស់ប្រជាជនដែលទទួលរងការគាបសង្កត់")។

[190] គណៈកម្មការយោធាអន្តរជាតិ, *សេចក្តីប្រកាសអំពីការបញ្ឈប់ការប្រើប្រាស់គ្រាប់ផ្លោងដែលមានទម្ងន់ក្រោម ៤០០ ក្រាម ក្នុងអំឡុងពេលសង្គ្រាម*, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៨៦៨, ដែលបោះពុម្ពផ្សាយសារជាថ្មីនៅក្នុង*ព្រឹត្តប័ត្រអាមេរិកស្តីពីច្បាប់អន្តរជាតិ*, វ៉ុល ១:២ (សេចក្តីបំពេញបន្ថែម៖ ឯកសារផ្លូវការ) (ខែ មេសា ឆ្នាំ ១៩០៧), ទំព័រ ៩៥ ដល់ ៩៦, បុព្វកថា (ដែលប្រកាសថា "ការប្រើប្រាស់អាវុធបែបនេះ*ផ្ទុយទៅនឹងច្បាប់មនុស្សជាតិ*" (សេចក្តីបញ្ជាក់បន្ថែម)។

[191] អនុសញ្ញាទីក្រុងឡាអេ (II) ស្តីអំពីច្បាប់ និងទំនៀមទម្លាប់សង្គ្រាមផ្លូវគោក, ដែលត្រូវបានអនុម័តនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩, វ៉ុល ៣២ បោះពុម្ពផ្សាយដោយ Stat. ទំព័រ ១៨០៣, វ៉ុល ១ បោះពុម្ពផ្សាយដោយ Bevans ទំព័រ ២៤៧, វ៉ុល ២៦ បោះពុម្ពផ្សាយដោយ Martens Nouveau Recueil (ser. 2) ទំព័រ ៩៤៩, វ៉ុល ១៨៧ បោះពុម្ពផ្សាយដោយ Consol. T.S. ទំព័រ ៤២៩ (ចូលជាធរមាននៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ១៩០០) ("អនុសញ្ញាទីក្រុងឡាអេ II ឆ្នាំ ១៨៩៩"), បុព្វកថា។

[192] អនុសញ្ញាទីក្រុងឡាអេ (IV) ស្តីអំពីច្បាប់ និងទំនៀមទម្លាប់សង្គ្រាមផ្លូវគោក, ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧, វ៉ុល ៣៦ បោះពុម្ពផ្សាយដោយ Stat. ទំព័រ ២២៧៧, វ៉ុល ១ បោះពុម្ពផ្សាយដោយ Bevans ទំព័រ ៦៣១, វ៉ុល ២០៥ បោះពុម្ពផ្សាយដោយ Consol. T.S. ទំព័រ ២៧៧, វ៉ុល ៣ បោះពុម្ពផ្សាយដោយ Martens Nouveau Recueil (ser. 3) ទំព័រ ៤៦១ (ចូលជាធរមានថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩១០), បុព្វកថា។

១០២. ទោះបីជាយ៉ាងណាក៏ដោយ ពាក្យពេចន៍“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”ដែលកំពុងប្រើបច្ចុប្បន្ន មាននវត្តមានដំបូងនៅក្នុងឆ្នាំ ១៩១៥ នៅក្នុងសេចក្តីប្រកាសរួមដោយប្រទេសមហាអំណាចសម្ព័ន្ធមិត្ត រុស្ស៊ី ចក្រភពអង់គ្លេស និងបារាំង ដែលបានប្រកាសថ្កោលទោសចំពោះការសម្លាប់រង្គាលជនជាតិអាមេនី[193]។ ក្រោយសង្គ្រាមលោកលើកទី I សន្និសីទលើកដំបូងស្តីពីសន្តិភាពទីក្រុង Versailles ឆ្នាំ ១៩១៩ បានបង្កើតគណៈកម្មការមួយទទួលបន្ទុកដោះស្រាយការទទួលខុសត្រូវរបស់អ្នកបង្កសង្គ្រាម និងការអនុវត្តទណ្ឌកម្ម (“គណៈកម្មការ”) ដែលបានអភិវឌ្ឍទស្សនទានស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងកម្រិតមានកំណត់មួយ។ នៅក្នុងរបាយការណ៍ផ្សព្វផ្សាយរបស់ខ្លួន គណៈកម្មការនេះបានរកឃើញថា អាល្លឺម៉ង់ និងសម្ព័ន្ធមិត្តរបស់ខ្លួន បានចាប់ផ្តើមធ្វើសង្គ្រាម“ដោយប្រើវិធីសាស្ត្រអធម្មានុរូប ឬឃោរឃៅ ដោយរំលោភបំពានទៅលើច្បាប់ជាសារវន្តនៃមនុស្សជាតិ”[194]។ គណៈកម្មការនេះក៏បានស្នើឡើងបន្ថែមទៀតថា ពួកឈ្លានពានអាល្លឺម៉ង់ និង អូតូម៉ាន (Ottoman) ត្រូវតែបានជំនុំជម្រះទោសពីអំពើ “ការរំលោភច្បាប់ និងទំនៀមទម្លាប់សង្គ្រាម *និង* ច្បាប់មនុស្សជាតិ”[195] ហើយថា

---

[193]សេចក្តីប្រកាសរួមមួយដោយប្រទេសមហាអំណាចសម្ព័ន្ធមិត្ត រុស្ស៊ី ចក្រភពអង់គ្លេស និងបារាំង, ទូរសារមកពីនាយកដ្ឋាននៅសហរដ្ឋអាមេរិក, វ៉ាស៊ីនតោនផ្ញើទៅកាន់ស្ថានទូតសហរដ្ឋអាមេរិក, នៅទីក្រុង Constantinople, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩១៥: “ដោយពិចារណាទៅលើ*ឧក្រិដ្ឋកម្ម*ថ្មីៗទាំងនេះរបស់ប្រទេសទួរគី*ប្រឆាំងមនុស្សជាតិ* និងអារ្យធម៌ រដ្ឋាភិបាលសម្ព័ន្ធមិត្តប្រកាសជាសាធារណៈដល់រដ្ឋាភិបាល Sublime Porte (អូតូម៉ាន) ថា រាល់សមាជិករបស់រដ្ឋាភិបាលអូតូម៉ាន (Ottoman) និងសមាជិកនៃភ្នាក់ងារនោះដែលជាប់ពាក់ព័ន្ធនៅក្នុងការសម្លាប់រង្គាលនេះ គឺជាអ្នកទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មទាំងនេះ” (សេចក្តីបញ្ជាក់បន្ថែម) ) <http://www.armenian-genocide.org/>។

[194]គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កសង្គ្រាម និងការពង្រឹងនូវការផ្តន្ទាទោស, *របាយការណ៍ដែលបានបញ្ជូនទៅកាន់សន្និសីទបឋមស្តីពីសន្តិភាព*, នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩១៩, ដែលត្រូវបានដកស្រង់និងបោះពុម្ពក្នុង*ព្រឹត្តប័ត្រអាមេរិកស្តីពីច្បាប់អន្តរជាតិ* (*American Journal of International Law*), វ៉ុល ១៤ (ឆ្នាំ ១៩២០), ទំព័រ ៩៥ និង ១១៥។

[195]គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កសង្គ្រាម និងការពង្រឹងនូវការផ្តន្ទាទោស *របាយការណ៍ត្រូវបានបង្ហាញទៅកាន់សន្និសីទបឋមស្តីពីសន្តិភាព*នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩១៩ ដែលត្រូវបានបោះពុម្ពឡើងវិញ ក្នុងព្រឹត្តិប័ត្រច្បាប់អន្តរជាតិអាមេរិក (*American Journal of International Law*) វ៉ុល ១៤ (ឆ្នាំ ១៩២០), ទំព័រ ៩៥ និង១១៨ (សេចក្តីបញ្ជាក់បន្ថែម)។

តុលាការអន្តរជាតិមួយគួរត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនេះ[196]។ ដូច្នេះ អំពើឃោរឃៅដែលពួកឈ្លានពានបានប្រព្រឹត្តក្នុងអំឡុងសង្គ្រាមលោកលើកទី I បានជួយបង្កើតក្របខណ្ឌផ្នែកទស្សនទាន ដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានក្លាយជាច្បាប់អន្តរជាតិវិជ្ជមានក្រោយសង្គ្រាមលោកលើកទី II ។ លើសពីនេះទៅទៀត ការដាក់បញ្ចូលគ្នា នៃ"ច្បាប់ និងទំនៀមទម្លាប់សង្គ្រាម" និង"ច្បាប់មនុស្សជាតិ" សន្មតទុកជាមុនយ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មនានាដែលមានចែងយ៉ាងដូច្នេះ កើតចេញពីការរំលោភបំពានលើរបបគតិយុត្តពីរផ្សេងគ្នា។

១០៣. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបញ្ចូលជាបន្តបន្ទាប់នៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងសម្ព័ន្ធមិត្តក្នុងឆ្នាំ ១៩៤៥ ("ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រង")[197] ធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ("IMTFE")[198] ឆ្នាំ ១៩៤៦ និងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០[199] បន្ទាប់ពីការកកើតលើកដំបូងនៃច្បាប់

---

[196]គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កសង្គ្រាម និងការពង្រឹងនូវការផ្តន្ទាទោស, *របាយការណ៍បានបង្ហាញទៅកាន់សន្និសីទបឋមស្តីពីសន្តិភាព*, ទំព័រ ៩៥ និង ១២២។

[197]មាត្រា II (១)(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងសម្ព័ន្ធមិត្ត, ការផ្តន្ទាទោសទៅលើបុគ្គលទាំងឡាយណាដែលមានពិរុទ្ធពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងប្រឆាំងមនុស្សជាតិ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥, *ក្រុមប្រឹក្សាគ្រប់គ្រង Gazette ជាផ្លូវការសម្រាប់ប្រទេសអាល្លឺម៉ង់ ទំព័រ ៥០ ដល់ ៥៥* (ឆ្នាំ ១៩៤៦) ("ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង")។ ។

[198]ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៤៦, ("ធម្មនុញ្ញរបស់ តុលាការ IMTFE"), បោះពុម្ពឡើងវិញនៅក្នុងព្រឹត្តប័ត្រនិពន្ធដោយ Neil Boister and Robert Cryer (eds.), *ឯកសារស្តីអំពីតុលាការយោធាអន្តរជាតិទីក្រុងតូក្យូ៖ ធម្មនុញ្ញ ការចោទប្រកាន់ និងសាលក្រម*, ចេញផ្សាយដោយសារព័ត៌មានរបស់សាកលវិទ្យាល័យ Oxford, ឆ្នាំ ២០០៨, ទំព័រ ៧ ដល់ ១១, មាត្រា ៥(គ)។

[199]គោលការណ៍ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់នៅក្នុងធម្មនុញ្ញរបស់តុលាការ Nürnberg និងក្នុងសាលក្រមរបស់តុលាការនេះ, ក្នុងរបាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីសម័យប្រជុំរបស់ខ្លួននៅថ្ងៃទី ០៥ ខែ មិថុនា ដល់ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៥០, ឯកសាររបស់ អ.ស.ប លេខ A/CN.4/34, ផ្នែកទី ៣, គោលការណ៍ VI(គ), "បោះពុម្ពដោយមានការកែប្រែលើសេចក្តីព្រាងបន្តិចបន្តួច ទៅជាឯកសារលេខ A/1316" នៅក្នុង*សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មាធិការស្តីពីច្បាប់អន្តរជាតិ*, ឆ្នាំ ១៩៥០, វ៉ុល II, ឯកសាររបស់អង្គការសហប្រជាជាតិលេខ A/CN.4/SER.A/1950/Add.1 (ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៥៧), ទំព័រ ៣៧៤ ដល់ ៣៧៨។ *សូមមើលការអះអាងទទួលស្គាល់គោលការណ៍នៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយធម្មនុញ្ញរបស់តុលាការ Nürnberg*, សេចក្តីសម្រេចរបស់មហាសន្និបាត

ទាំងពីរនេះ (“ច្បាប់ និងទំនៀមទម្លាប់សង្គ្រាម” និង“ច្បាប់មនុស្សជាតិ”) ក្នុងច្បាប់អន្តរជាតិ នៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ Nuremberg (IMT) ឆ្នាំ ១៩៤៥[200] ដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងឆ្នាំ ១៩៤៥ ស្តីពីការចោទប្រកាន់ និងផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃសម្ព័ន្ធមិត្ត Axis អឺរ៉ុប ដែលត្រូវបានអនុម័តដោយរដ្ឋចំនួន ១៩[201]។ លើសពីនេះទៀត ឧក្រិដ្ឋកម្មទាំងនេះត្រូវបានធ្វើការចោទប្រកាន់ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង នៅចំពោះមុខតុលាការយោធាអន្តរជាតិ[202] និងតុលាការយោធា Nuremberg (“NMTs”) នៅក្នុងប្រទេសអាល្លឺម៉ង់ ដែលជាតំបន់ត្រូវបានកាន់កាប់[203]។ ជាចុងក្រោយ បន្ទាប់ពីបញ្ចប់សង្គ្រាមលោកលើកទី II ភ្លាម សន្ធិសញ្ញាស្តីពីសន្តិភាពមួយចំនួន ជាមួយនឹង

---

លេខ ១/៩៥ (I), របាយការណ៍ផ្លូវការរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ (UN GAOR), សម័យប្រជុំលើកទី ១, កិច្ចប្រជុំពេញអង្គលើកទី ១២៣, ឯកសាររបស់អង្គការសហប្រជាជាតិលេខ A/RES/1/95 (ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦) (“*ការអះអាងទទួលស្គាល់គោលការណ៍*”)។

[200]ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ ដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងទីក្រុងឡុងដ៍, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥, *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ*, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ – ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦, វ៉ុល I, ទំព័រ ១០ ដល់ ១៨, មាត្រា ៦(គ) នៃ ធម្មនុញ្ញតុលាការយោធាអន្តរជាតិ (“IMT”) http://avalon.law.yale.edu/subject_menus/imt.asp។

[201]កិច្ចព្រមព្រៀងស្តីពីជំនុំជម្រះក្តី និងការផ្តន្ទាទោសទៅលើឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗរបស់ពួកអាក់ស៊ីសអឺរ៉ុប និងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥, វ៉ុល ៨២ នៃកម្រងសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ទំព័រ ២៨០ (82 U.N.T.C. 280), (“កិច្ចព្រមព្រៀងទីក្រុងឡុងដ៍”) (រដ្ឋហត្ថលេខីមានដូចជា៖ ប្រទេស អូស្ត្រាលី បែលហ្ស៊ិក ឆេកូស្លូវ៉ាគី ដាណឺម៉ាក អេត្យូពី ក្រិក ហៃទី ហុងឌូរ៉ាស ឥណ្ឌា លុចសំបួ ហូឡង់ នូវែលសេឡង់ ន័រវែស ប៉ាណាម៉ា ប៉ារ៉ាហ្គាយ ប៉ូឡូញ សាធារណរដ្ឋស៊ែប អ៊ុយរូហ្គាយ វ៉េណេស៊ុយអេឡា)។

[202]*សូមមើលឧទា. ការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ*, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦, វ៉ុល I ដល់ XXII, (“សាលក្រមរបស់តុលាការយោធាអន្តរជាតិ”), វ៉ុល I, ទំព័រ ១៧៣ ដល់ ១៧៤ និង ទំព័រ ២៥៣ ដល់ ២៥៥។

[203]*សូមមើលឧទា.* រឿងក្តីនានាយោងតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងដែលបានយោងនៅក្នុងសាលដីកានេះក្នុងការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើឱ្យទៅជាទាសករ បទធ្វើទារុណកម្ម និងបទធ្វើទុក្ខបុកម្នេញនៅ ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ប្រទេសសម្ព័ន្ធមិត្ត Axis និងសម្ព័ន្ធមិត្តរបស់ពួកគេ ដោយរួមបញ្ចូលផងដែរនូវសន្ធិសញ្ញាស្តីពីសន្តិភាពជាមួយប្រទេសអ៊ីតាលី រ៉ូម៉ានី និងប៊ុលហ្គារី បានចែងហាមឃាត់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងដាក់កាតព្វកិច្ចឱ្យរដ្ឋជាភាគីធ្វើការចោទប្រកាន់អំពើឧក្រិដ្ឋទាំងនេះ[204]។ ជាលទ្ធផល តុលាការថ្នាក់ជាតិ បានសម្រេចដាក់ពិរុទ្ធភាពសម្រាប់បទល្មើសនានាក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលទាក់ទងទៅនឹងអំពើដែលកើតមាននៅមុនឆ្នាំ ១៩៧៥[205]។

---

[204] *សូមមើលឧទា.* មាត្រា ៤៥ នៃសន្ធិសញ្ញាសន្តិភាពជាមួយប្រទេសអ៊ីតាលី និងមាត្រា ៦ នៃសន្ធិសញ្ញាជាមួយប្រទេសរ៉ូម៉ានី និងមាត្រា ៥ នៃសន្ធិសញ្ញាសន្តិភាពជាមួយប៊ុលហ្គារី ដែលបានដក់ស្រង់នៅក្នុងព្រឹត្តប័ត្របោះពុម្ពផ្សាយដោយនិពន្ធនាយក Amelia C. Leiss Raymond Dennett (eds), *ស្តីពីសន្ធិសញ្ញាសន្តិភាពបន្ទាប់ពីសង្គ្រាមលោកលើកទី II: ការចរចា និងឯកសារនៃសន្ធិសញ្ញាជាមួយប្រទេសអ៊ីតាលី ប៊ុលហ្គារី ហុងគ្រី រ៉ូម៉ានី និង ហ្វាំងឡង់,* មូលនិធិសន្តិភាពពិភពលោក, ឆ្នាំ ១៩៥៤, ទំព័រ ១៧៧, ២៥២ និង ៣០០។

[205] *សូមមើលឧទា. រឿងក្តី ប្រទេស ប៉ូឡូញ ទល់នឹង Greiser*, សំណុំរឿងលេខ ៧៤, "សាលក្រម" ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៤៦, *របាយការណ៍ច្បាប់នៃការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមៈ ដែលត្រូវបានជ្រើសរើស និងរៀបចំដោយ គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គសហប្រជាជាតិ,* គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, ឆ្នាំ ១៩៤៩, វ៉ុល XIII, ("*រឿងក្តី Greiser*"), ទំព័រ ១០៤ ដល់ ១០៦។ *អគ្គរដ្ឋអាជ្ញានៃរដ្ឋាភិបាលរបស់ Israel ទល់នឹង Adolf Eichmann*, សាលដីការអង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៦២, *របាយការណ៍ស្តីពីច្បាប់អន្តរជាតិ*, វ៉ុល ៣៦, ទំព័រ ២៧៧ ដល់ ៣៤២ ("*រឿងក្តី Eichmann*")។ *រឿងក្តី Republique Francaise au nom du Peuple Francais ទល់នឹង Barbie* តុលាការកំពូលរបស់បារាំង (អង្គជំនុំជម្រះព្រហ្មទណ្ឌ)(ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៨៨) "ការតម្កល់ការផ្តន្ទាទោស", *របាយការណ៍ស្តីពីច្បាប់អន្តរជាតិ*, វ៉ុល ១០០, ("*រឿងក្តី Barbie* ឆ្នាំ ១៩៨៨"), ទំព័រ ៣៣០ ដល់ ៣៣៧។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kupreškić និងជនដទៃទៀត*, សំណុំរឿងលេខ IT-95-16-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០, ("សាលក្រមក្នុង*រឿងក្តី Kupreškić*"), កថាខណ្ឌ ៦០២, ដកស្រង់ចេញពី *រឿងក្តី Artuković*, តុលាការជាន់ដំបូងក្នុងទីក្រុង Zagreb, ឯកសារលេខ K-1/84-61, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៨៦, ("*រឿងក្តី Artuković*"), ទំព័រ ២៣ និង ២៦។

១០៤. ផ្អែកតាមសេចក្តីបញ្ជាក់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូង[206] ត្រង់ចំណុចដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មអន្តរជាតិស្ថិតក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

១០៥. បញ្ហាទីពីរ ពោលគឺ ថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់និយមន័យបែបណានៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ នោះ ហើយអង្គជំនុំជម្រះតុលាការកំពូលរំឭកថា តាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជា:

> អំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលណាមួយ ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា និង អំពើអមនុស្សធម៌ផ្សេងៗទៀត[207]។

១០៦. និយមន័យនេះ មិនត្រឹមតែកំណត់អត្ថន័យនៃអំពើជាមូលដ្ឋានដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប៉ុណ្ណោះទេ ថែមទាំងគូសបញ្ជាក់ពីលក្ខខណ្ឌ*ទៅតាមបរិបទ*ដែលត្រូវតែស្វែងរកឱ្យឃើញថា កើតមានដើម្បីញែកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចេញពីឧក្រិដ្ឋកម្មតាមច្បាប់ជាតិ និងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀត។ លក្ខខណ្ឌ*ទៅតាមបរិបទ*នេះ រួមមាន: ១) ការវាយប្រហារជាទូទៅ និងមានការរៀបចំជាប្រព័ន្ធ ២) ប្រឆាំងដោយផ្ទាល់ទៅលើប្រជាជនស៊ីវិល ៣) ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា និង ៤) ការបង្ហាញឱ្យឃើញពីអំពើជាមូលដ្ឋានដែលបានប្រព្រឹត្ត គឺជា“ផ្នែកនៃ”ការវាយប្រហារ។

១០៧. ជាបន្តទៀត ដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ផ្នែកបន្តបន្ទាប់ទៀតនេះ នឹងដោះស្រាយបញ្ហា ថាតើអំពើធ្វើទុក្ខបុកម្នេញ អំពើធ្វើទារុណកម្ម អំពើរំលោភ

---

[206] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៨៥ ដល់ ២៨៩។

[207] មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

លើផ្លូវភេទ និងអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទំលាប់អន្តរជាតិ ត្រឹមឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណា។ ការពិចារណាលើបញ្ហា ថាតើអំពើជាមូលដ្ឋានផ្សេងទៀតដែលមានកំណត់ក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវបានចាត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនាពេលអំពើល្មើសបានប្រព្រឹត្តឡើង ដែរ ឬយ៉ាងណានោះ គឺស្ថិតនៅក្រៅវិសាលភាពនៃបណ្តឹងសាទុក្ខនេះ។

១០៨. ក្នុងការកំណត់អំពីវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ធម្មនុញ្ញតុលាការយោធាអន្តរជាតិបានគូសបញ្ជាក់ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចតទៅ:

> (គ) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ពោលគឺ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តប្រឆាំងប្រជាជនស៊ីវិលណាមួយ មុន ឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅក្នុងការអនុវត្ត ឬការជាប់ទាក់ទងជាមួយនឹងឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ ទោះបីជា អំពើទាំងនេះរំលោភបំពាន ឬមិនរំលោភបំពានច្បាប់ជាតិនៃប្រទេសដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្ត ក៏ដោយ[208]។

១០៩. រយៈពេលពីរខែបន្ទាប់ពីចេញសាលក្រមរបស់តុលាការយោធាអន្តរជាតិ នៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ ដែលបានសម្រេចដាក់ពិរុទ្ធភាពពីអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួចមក មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តជាឯកច្ឆន្ទនូវសេចក្តីសម្រេចលេខ ៩៥ (I) ដែលជាភស្តុតាងបញ្ជាក់អំពី*ការប្រកាសឆន្ទៈទទួលយកជាច្បាប់* ក្នុងចំណោមរដ្ឋសមាជិកអង្គការសហប្រជាជាតិដែលធម្មនុញ្ញតុលាការយោធាអន្តរជាតិ និងសាលក្រមនេះបានឆ្លុះបញ្ចាំង

---

[208]មាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT)។ និយមន័យនេះត្រូវបានធ្វើក្រមនីយកម្មនៅក្នុងមាត្រា ៥(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE)។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការ IMTFE ពុំដែលបានសម្រេចដាក់ពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

អំពីគោលការណ៍ទូទៅនៃនីតិអន្តរជាតិ នាពេលនោះ[209]។ បន្ទាប់ពីចេញសេចក្តីសម្រេចលេខ ៩៥ (I) នេះ មហាសន្និបាតអង្គការសហប្រជាជាតិ បានដាក់សេចក្តីបង្គាប់ដល់គណៈកម្មការនីតិអន្តរជាតិ (ILC) ឱ្យរៀបចំ និងបកស្រាយគោលការណ៍ទាំងនេះ[210]។ ជាលទ្ធផល ក្នុងឆ្នាំ ១៩៥០ គណៈកម្មការ ILC បានអនុម័តគោលការណ៍ Nuremberg។

១១០. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា សាលក្រមតុលាការយោធានោះ មិនចាត់ទុកជាយុត្តិសាស្ត្រដែលមានអានុភាពចងកាតព្វកិច្ចសម្រាប់ អ.វ.ត.ក ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយរួមបញ្ចូលជាមួយនឹងធម្មនុញ្ញតុលាការយោធាអន្តរជាតិ និងសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៩៥ (I) សាលក្រមនេះ បង្ហាញឱ្យឃើញពីភស្តុតាងយ៉ាងរឹងមាំនៃគោលការណ៍នីតិព្រហ្មទណ្ឌអន្តរជាតិ ដែលរួមមានទាំងគោលការណ៍ដែលទើបកកើតថ្មី និងទាំងគោលការណ៍ដែលមានស្រាប់[211]។ ទាក់ទងនឹងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៩៥ (I) មិនទទួលស្គាល់នូវការកំណត់ជាក់លាក់

[209] *ការអះអាងទទួលស្គាល់គោលការណ៍នៃច្បាប់អន្តរជាតិ* ។

[210] *ការបង្កើតនូវគោលការណ៍ដែលត្រូវបានទទួលស្គាល់នៅក្នុងធម្មនុញ្ញនៃតុលាការ Nürnberg និងក្នុងសាលក្រមរបស់តុលាការនេះ,* សេចក្តីសម្រេចរបស់មហាសន្និបាតលេខ 2/177 (II), របាយការណ៍ផ្លូវការរបស់អង្គការសហប្រជាជាតិ, សម័យប្រជុំលើកទី ២ កិច្ចប្រជុំពេញអង្គលើកទី ១២៣, ឯកសាររបស់អង្គការសហប្រជាជាតិ A/RES/2/177 (ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧) ("ការបង្កើតនូវគោលការណ៍")។

[211] ផ្ទុយទៅនឹងទៅនឹងយុត្តិសាស្ត្រនៅក្នុងសាលក្រមរបស់តុលាការយោធាអន្តរជាតិ, *សូមមើល*ព្រឹត្តប័ត្រនិពន្ធដោយ Hans Kelsen, "តើសាលក្រមរបស់តុលាការ Nuremberg គឺជាយុត្តិសាស្ត្រនៅក្នុងច្បាប់អន្តរជាតិ ដែរ ឬទេ ?" ព្រឹត្តប័ត្រស្តីពីច្បាប់អន្តរជាតិដែលចេញបួនដងក្នុងមួយឆ្នាំ *(International Law Quarterly)*, វ៉ុល ១:២ (ក្នុងរដូវក្តៅ ឆ្នាំ ១៩៤៧), ទំព័រ ១៥៣ ដល់ ១៧១។ និពន្ធដោយ Egon Schwelb, "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ", *ព្រឹត្តប័ត្រប្រចាំឆ្នាំរបស់ប្រទេសអង់គ្លេសស្តីពីច្បាប់អន្តរជាតិ*, វ៉ុល ២៣ (ឆ្នាំ ១៩៤៦), ទំព័រ ១៧៨ ដល់ ២២៦។ អ្នកនិពន្ធដទៃទៀតបញ្ជាក់អំពីការជម្រុញដែលសាលក្រមរបស់តុលាការយោធា អន្តរជាតិបានផ្តល់ឲ្យមានការអភិវឌ្ឍន៍លទ្ធិច្បាប់ក្នុងច្បាប់អន្តរជាតិ ជាពិសេសទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ *សូមមើលឧទា.* ព្រឹត្តប័ត្រនិពន្ធដោយ Otto Kranzbuhler, ឈ្មោះ "តុលាការ Nuremberg ដប់ប្រាំបីឆ្នាំក្រោយមក", បោះពុម្ពផ្សាយដោយ *DePaul Law Review*, វ៉ុល ១៤ (ឆ្នាំ ១៩៦៤ ដល់ ១៩៦៥), ទំព័រ ៣៣៣ ដល់ ៣៤៧។

ឬការបកស្រាយគោលការណ៍ទូទៅនៃនីតិអន្តរជាតិដែលមាននៅក្នុងធម្មនុញ្ញ និងសាលក្រម របស់តុលាការយោធាអន្តរជាតិនេះឡើយ។ គោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ត្រូវបាន អនុម័តដោយគណៈកម្មការ ILC បន្ទាប់ពីសេចក្ដីសម្រេចលេខ ៩៥ (I) ប៉ុន្តែ គោលការណ៍ទាំងនេះមិនត្រូវបានអនុម័តជាផ្លូវការដោយមហាសន្និបាតអង្គការសហប្រជាជាតិ ឡើយ។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលមានឆន្ទានុសិទ្ធិក្នុងការសម្រេចថា អ្វីទៅជាគោលការណ៍ទូទៅនៃនីតិអន្តរជាតិដែលមាននៅក្នុងធម្មនុញ្ញ និងសាលក្រមរបស់តុលាការយោធាអន្តរជាតិនេះត្រឹមឆ្នាំ១៩៤៦ ហើយ ថាតើគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់លាស់អំពីគោលការណ៍ទូទៅនេះ ដែរ ឬយ៉ាងណា។

១១១. ជាពិសេស ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា គោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ចែងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជា:

> ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលត្រូវបានប្រព្រឹត្តប្រឆាំងប្រជាជនស៊ីវិលណាមួយ ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅពេលដែលអំពើទាំងនេះត្រូវបានប្រព្រឹត្តឡើង ឬការធ្វើទុក្ខបុកម្នេញបែបនេះ ត្រូវបានប្រព្រឹត្តឡើងដោយមានទំនាក់ទំនង ឬដោយការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាមណាមួយ[212]។

១១២. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការកំណត់និយមន័យនេះឆ្លុះបញ្ចាំងអត្ថន័យដូចគ្នាយ៉ាងខ្លាំងទៅនឹងនិយមន័យ ដែលមាននៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ[213]។

---

[212]គោលការណ៍ VI(គ) នៃគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ។

[213]ភាពខុសគ្នាតែមួយគត់នោះគឺថា និយមន័យនៃគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ បានលុបចោលលក្ខខណ្ឌតម្រូវដែលថា "មុនពេល ឬក្នុងអំឡុងពេលសង្គ្រាម" ដែលលក្ខខណ្ឌនេះពុំមានភាពចាំបាច់ឡើយនៅក្នុងសាលក្រមរបស់តុលាការយោធាអន្តរជាតិ។ ចៅក្រមមិនត្រូវបានអនុញ្ញាតឱ្យសម្រេចដាក់ពិរុទ្ធភាពណាមួយ ទាក់ទងទៅនឹងអំពើ"មុនពេល" សង្គ្រាម។ បន្ថែមលើនេះទៀត "ក្នុងអំឡុងពេលសង្គ្រាម" មិនមានភាពចាំបាច់ចំពោះលក្ខខណ្ឌតម្រូវដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែបានប្រព្រឹត្តឡើង ដោយមាន"ទំនាក់ទំនងឧក្រិដ្ឋកម្មណាមួយប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្ម

តុលាការតំបន់ និងតុលាការជាតិមួយចំនួន បានបកស្រាយជាបន្តបន្ទាប់អំពីគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ថាជាការឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទំលាប់អន្តរជាតិ[214]។

---

សង្គ្រាមណាមួយ"។ របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិនៅក្នុងសម័យប្រជុំលើកទីពីររបស់ខ្លួន, ចុះថ្ងៃទី ០៥ ដល់ ២៩ ខែ កក្កដា ឆ្នាំ ១៩៥០, កថាខណ្ឌ ១២៣ ("ដែលក្នុងនោះ ការកំណត់និយមន័យរបស់គណៈកម្មការស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានលុបចោលឃ្លាមួយថា "មុនពេល ឬក្នុងអំឡុងពេលសង្គ្រាម" ដែលមានចែងក្នុងមាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការ Nürnberg ដោយសារឃ្លានេះសំដៅលើសង្គ្រាមជាក់លាក់មួយ គឺសង្គ្រាមក្នុងឆ្នាំ ១៩៣៩។ ការលុបចោលឃ្លានេះមិនមានន័យថា គណៈកម្មការយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចលុបចោលតែក្នុងអំឡុងពេលសង្គ្រាមនោះទេ។ ផ្ទុយទៅវិញ គណៈកម្មការយល់ឃើញថា ឧក្រិដ្ឋកម្មទាំងនេះ អាចកើតឡើងនៅមុនពេលសង្គ្រាម ដោយជាប់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព")។

[214] *សូមមើលរឿងក្តី Eichmann*, ទំព័រ ២៧៧ ដល់ ២៧៨។ *Touvier*, តុលាការកំពូលរបស់ប្រទេសបារាំង (អង្គជំនុំជម្រះព្រហ្មទណ្ឌ), ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩២, *របាយការណ៍ស្តីពីច្បាប់អន្តរជាតិ*, វ៉ុល ១០០, ទំព័រ ៣៣៨។ *រឿងក្តីសហព័ន្ធជាតិ ទទួលបន្ទុកជននិរទេស និងអ្នកតស៊ូ និងស្នេហាជាតិ និងជនផ្សេងទៀត ទល់នឹង Barbie*, "សាលដីកា", តុលាការកំពូលរបស់បារាំង (សភាព្រហ្មទណ្ឌ), *របាយការណ៍ស្តីពីច្បាប់អន្តរជាតិ*, វ៉ុល ៧៨ (ឆ្នាំ ១៩៨៥), (*"រឿងក្តី Barbie"*), ទំព័រ ១៣៩។ *រឿងក្តី Kolk និង Kisyly ទល់នឹង Estonia*, តុលាការអឺរ៉ុបថ្នាក់តំបន់ស្តីពីសិទ្ធិមនុស្ស (ECtHR), *"សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ", សំណើលេខ 23052/04 និង 24018/04, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៦, ទំព័រ ៣* (*ដែលក្នុងនោះ* សាលាឧទ្ធរណ៍ទីក្រុងតាលិននៃប្រទេសអេស្តូនីពិចារណាថា "ការនិរទេសដែលម្ចាស់បណ្តឹងសាទុក្ខបានប្រព្រឹត្តនោះ ត្រូវបានប្រទេសដែលមានអារ្យធម៌ចាត់ទុកថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៤៩។ អំពើបែនេះត្រូវបានកំណត់និយមន័យថា ជាអំពើល្មើសតាមមាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (តុលាការ Nuremberg) ហើយត្រូវបានទទួលស្គាល់ថា ជាគោលការណ៍នៃច្បាប់អន្តរជាតិដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦ ក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ ៩៥"។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Ivica Vrdoljak*, តុលាការរបស់ Bosnia និង Herzegovina, ផ្នែក I ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម X-KR-08488, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៨, ទំព័រ ១២។ *រឿងក្តី Korbely ទល់នឹង ប្រទេសហុងគ្រី*, តុលាការអឺរ៉ុបថ្នាក់តំបន់ស្តីពីសិទ្ធិមនុស្ស (តុលាការ ECtHR), "សាលដីកាដែលមានការទទួលស្គាល់យ៉ាងច្រើន", ពាក្យបណ្តឹងលេខ 9174/02, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨, កថាខណ្ឌ ៨១ (ផ្អែកតាមមាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងទីក្រុងឡុងដ៍ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥ ដែលជាការបង្កើតគោលការណ៍ជាបឋមមួយក្នុងចំណោមការបង្កើតទាំងឡាយសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ),"មតិជំទាស់របស់ចៅក្រម Loucaides" (ជាការផ្អែកយ៉ាងជាក់ច្បាស់ទៅលើគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ដែលចែងថាៈ "ទស្សនៈដែលថា គោលការណ៍ Nuremberg គឺជាច្បាប់ទម្លាប់អន្តរជាតិនោះ មិនមានការជំទាស់ឡើយ បន្ទាប់ពីមានសេចក្តីសម្រេចលេខ ៣០៧៤ (XXVIII) របស់មហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៧៣ ដែលប្រកាសទទួលស្គាល់ភាពចាំបាច់សម្រាប់ការសហការជាអន្តរ

អង្គជំនុំជម្រះតុលាការកំពូលយល់ស្រប និងយល់ឃើញថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមាននៅក្នុងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ឆ្លុះបញ្ចាំងឱ្យឃើញពីអ្វីដែលមានកន្លងមកនូវលក្ខន្តិកៈនៃច្បាប់ទំនៀមទំលាប់អន្តរជាតិស្តីពីនិយមន័យ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមាននៅឆ្នាំ ១៩៤៦។

១១៣. ទោះបីជាមានការគាំទ្រទៅលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានក្នុងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ក៏ដោយ ក៏ដំបូង អង្គជំនុំជម្រះតុលាការកំពូលចាំបាច់ត្រូវតែសម្រេច ថាតើនិយមន័យនេះបន្តអត្ថិភាពក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ឬថាតើការអនុវត្តតៗគ្នារបស់រដ្ឋ និង*ការប្រកាសពីឆន្ទៈទទួលយកជាច្បាប់* បានបង្ហាញអំពីការវិវត្តនៃនិយមន័យខាងលើ និងការកកើតនូវវិធានថ្មីនានាត្រឹមឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណា ហើយបន្ទាប់មកនឹងធ្វើការដោះស្រាយទឡ្ហីករណ៍បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា នៅក្នុងផ្នែកខាងក្រោម។ មានការអះអាងនាពេលនោះថា បទដ្ឋាននានាមានការផ្លាស់ប្តូរ ក្នុងលក្ខណៈមួយដែលនាំឱ្យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវរួមបញ្ចូលវិសាលភាពយ៉ាងទូលំទូលាយ នៃអំពើរបស់មនុស្សតាមច្បាប់ទំនៀមទំលាប់អន្តរជាតិ ជាងវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមាននៅក្នុងនិយមន័យនៃគោលការណ៍ Nuremberg ឆ្នាំ ១៩៥០។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ត្រូវសម្រេច ថាតើការអះអាងនេះ មានភស្តុតាងជាបង្អែកដែរ ឬយ៉ាងណា។

១១៤. ចំពោះបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឮកថា ចាប់ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៩៦ គណៈកម្មការ ILC បានបង្កើត និងអនុម័តអត្ថបទកំណែសេចក្តីព្រាងក្រមស្តីពីបទល្មើសអន្តរជាតិជាច្រើនដង ដោយអនុលោមតាមសេចក្តីបង្គាប់របស់មហាសន្និបាតអង្គការសហប្រជាជាតិ នៅឆ្នាំ ១៩៤៧ តាមសេចក្តីសម្រេចលេខ ១៧៧ (II)[215]។ ទោះបីជា មិនមានសេចក្តីព្រាងណាមួយ ត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិនៅទីបញ្ចប់យ៉ាងណាក៏ដោយ

---

ជាតិក្នុងការស៊ើបអង្កេត ចាប់ខ្លួន ការធ្វើបត្យាប័ន និងការផ្តន្ទាទោសជនដែលមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ")។

[215] *ការបង្កើតនូវគោលការណ៍* ។

ក៏អង្គជំនុំជម្រះតុលាការកំពូល ពិចារណាថា សេចក្តីព្រាងទាំងនេះ *អាច*ឆ្លុះបញ្ចាំងអំពីការអនុវត្តតៗគ្នារបស់រដ្ឋ និង*ការប្រកាសពីឆន្ទៈទទួលយកជាច្បាប់* ចំពោះការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាយូរឆ្នាំណាស់មកហើយ ដោយហេតុថាអាណត្តិមួយក្នុងចំណោមអាណត្តិទាំងឡាយរបស់គណៈកម្មការ ILC គឺដើម្បីបំពេញការងារដែលមានកន្លងមកដោយផ្តល់នូវ "ការរៀបចំតាក់តែង និងធ្វើឱ្យទៅជាប្រព័ន្ធ *មានភាពច្បាស់លាស់ជាងមុន* ចំពោះវិធាននៃនីតិអន្តរជាតិ ក្នុងវិស័យ*ដែលមាន*ការអនុវត្តតៗគ្នារបស់រដ្ឋ យុត្តិសាស្ត្ររបស់តុលាការ និងលទ្ធិនៃនីតិយ៉ាងទូលំទូលាយរួចហើយ"ដូចដែលគណៈកម្មការ ILC បានធ្វើដូចគ្នានេះដែរ ចំពោះគោលការណ៍ Nuremberg ឆ្នាំ ១៩៥០[216]។

១១៥. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលរំឭកបន្ថែមទៀតថា គណៈកម្មការ ILC ក៏មានភារៈកិច្ចផងដែរ"ក្នុងការលើកកម្ពស់ការអភិវឌ្ឍន៍ជឿនលឿននៃនីតិអន្តរជាតិ និងការធ្វើក្រមនីយកម្មនៃនីតិអន្តរជាតិនេះ"[217]។ ជាលទ្ធផល សេចក្តីព្រាងក្រមស្តីពីបទល្មើសអន្តរជាតិដែលត្រូវបានបង្កើតដោយគណៈកម្មការ ILC នៅចន្លោះឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៩៦ បានឆ្លុះបញ្ចាំងនូវការប្រែប្រួលរវាងអាណត្តិទាំងពីរនេះ ជាពិសេស នៅពេលដែលគណៈកម្មការនេះ បានពង្រីកវិសាលភាពនៃឧក្រិដ្ឋកម្មអន្តរជាតិជាហូរហែរ រួមបញ្ចូលទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនានា[218]។ ជាទីបញ្ចប់ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែង

---

[216]មាត្រា ១៥ នៃលក្ខន្តិកៈរបស់គណៈកម្មការនីតិអន្តរជាតិ ឆ្នាំ ១៩៤៧ អនុម័តដោយមហាសន្និបាតនៅក្នុងសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ១៧៤ (II) ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧ ដែលបានវិសោធនកម្មដោយសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៤៨៥ (V) (ថ្ងៃទី ១២ ធ្នូ ឆ្នាំ ១៩៥០), ៩៨៤ (X) (ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៥៥), ៩៨៥ (X) (ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៥៥) និង ៣៦/៣៩ (ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៨១), ("លក្ខន្តិកៈរបស់គណៈកម្មការនីតិអន្តរជាតិ") (សេចក្តីបញ្ជាក់បន្ថែម)។

[217]មាត្រា ១ នៃលក្ខន្តិកៈរបស់គណៈកម្មការនីតិអន្តរជាតិ។

[218]ដោយប្រៀបធៀបគោលការណ៍ Nuremberg ឆ្នាំ ១៩៥០, សេចក្តីព្រាងក្រមរបស់គណៈកម្មការនីតិអន្តរជាតិឆ្នាំ ១៩៥៤ ស្តីពីបទល្មើស មានគោលបំណងកែសម្រួលធាតុផ្សំតាមបរិបទ។ *សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំង សន្តិភាព និងសន្តិសុខមនុស្សជាតិ*, របាយការណ៍ទីបីរបស់លោក J. Spiropoulos, អ្នកធ្វើសេចក្តីរាយការណ៍ពិសេស, ឯកសាររបស់អង្គការសហប្រជាជាតិលេខ A/CN.4/85 (ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៥៤), ផ្នែកទី ២, មាត្រា ២ (១០), ដែលបានបោះពុម្ពក្នុង*ព្រឹត្តប័ត្រប្រចាំឆ្នាំរបស់គណៈកម្មការនីតិអន្តរជាតិ*, ឆ្នាំ ១៩៥៤, វ៉ុល II, ឯកសាររបស់អង្គការសហប្រជាជាតិ

របស់គណៈកម្មការ ILC នៅតែជាសមិទ្ធផល"ការងារនៅក្រោមអានុភាពរបស់តុលាការ Nuremberg"[219] នៅក្នុងឆ្នាំ ១៩៩៦[220] នៅពេលដែលគណៈកម្មការនេះបានបង្កើតសេចក្ដីព្រាងក្រមស្ដីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ បន្ទាប់ពីការបង្កើត

---

លេខ A/CN.4/SER.A/1954/Add.l, ទំព័រ ១១២ ដល់ ១២១។ មហាសន្និបាតពុំបានអនុម័តសេចក្ដីព្រាងនេះឡើយ ទោះបីជាហេតុផលសំខាន់មិនមែនជាប់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏ប៉ុន្តែជាប់ទាក់ទងទៅនឹងការខ្វះនូវការឯកភាពគ្នាស្ដីពីនិយមន័យនៃអំពើឈ្លានពាន។ *សេចក្ដីព្រាងក្រមស្ដីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ,* សេចក្ដីសម្រេចរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិលេខ 897 (IX) (ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៥៤)។ ទើបតែដល់ឆ្នាំ ១៩៨១ ជាពេលដែលមហាសន្និបាតអំពាវនាវឲ្យគណៈកម្មការនីតិអន្តរជាតិបន្តការងាររបស់ខ្លួនទៅលើសេចក្ដីព្រាងក្រមស្ដីពីបទល្មើស។ *សេចក្ដីព្រាងក្រមស្ដីពីបទល្មើសប្រឆាំង សន្តិភាព និងសន្តិសុខមនុស្សជាតិ,* សេចក្ដីសម្រេចរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិលេខ 36/106 (ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨១) មាត្រា ១។ សេចក្ដីព្រាងបន្តបន្ទាប់ត្រូវបានដាក់នៅក្នុងឆ្នាំ ១៩៨៦ និងដាក់ម្ដងទៀតនៅឆ្នាំ ១៩៩១ ដែលបានរួមបញ្ចូលការកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគួរឲ្យកត់សម្គាល់ដែលមានបទល្មើសថ្មីនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ និងបទល្មើសនៃការប្រើប្រាស់គ្រឿងញៀន។ *របាយការណ៍ទីបួនស្ដីពីសេចក្ដីព្រាងក្រមស្ដីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ,* ដោយលោក Doudou Thiam អ្នកធ្វើសេចក្ដីរាយការណ៍ពិសេស, ឯកសាររបស់អង្គការសហប្រជាជាតិលេខ A/CN.4/398 (ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៨៦), ដែលត្រូវបានបោះពុម្ពផ្សាយក្នុង*ព្រឹត្តប័ត្រប្រចាំឆ្នាំ របស់គណៈកម្មការនីតិអន្តរជាតិ,* ឆ្នាំ ១៩៨៦, វ៉ុល II, (ផ្នែកទី ១) ឯកសារស្ដីពីសម័យប្រជុំលើកទី ៣៨ ឯកសាររបស់អង្គការសហប្រជាជាតិលេខ A/CN.4/SER.A/1986/Add.l (ផ្នែកទី ១), ទំព័រ ៥៥ ដល់ ៦១, ៨៥ ដល់ ៨៦។ *របាយការណ៍របស់គណៈកម្មការនីតិអន្តរជាតិស្ដីពីកិច្ចការនៃសម័យប្រជុំរបស់ខ្លួន លើកទី ៤៣,* ថ្ងៃទី ២៩ ខែ មេសា ដល់ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩១, របាយការណ៍ផ្លូវការនៃមហាសន្និបាតអង្គការសហប្រជាជាតិ (U.N. GAOR), សម័យប្រជុំលើកទី ៤៦, សេចក្ដីបំពេញបន្ថែមលេខលេខ ១០, ឯកសាររបស់អង្គការសហប្រជាជាតិ A/46/10, ទំព័រ ១០១ ដល់ ១០៣។

[219]ព្រឹត្តប័ត្រនិពន្ធដោយ M.Cherif Bassiouni ចំណងជើងថា៖ *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ,* បោះពុម្ពលើកទី ២, ទំព័រ ១៨៨។

[220]*សេចក្ដីព្រាងក្រមស្ដីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ,* នៅក្នុងរបាយការណ៍របស់គណៈកម្មាការនីតិអន្តរជាតិស្ដីពីកិច្ចការនៃសម័យប្រជុំលើកទី ៤៨ របស់ខ្លួន, ថ្ងៃទី ០៦ ខែ ឧសភា ដល់ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦), ឯកសាររបស់អង្គការសហប្រជាជាតិ លេខ A/51/10 ដែលបានបោះពុម្ពផ្សាយនៅក្នុង*ព្រឹត្តប័ត្រប្រចាំឆ្នាំរបស់គណៈកម្មការនីតិអន្តរជាតិ,* ឆ្នាំ ១៩៩៦, វ៉ុល II, (ផ្នែកទី ២) ឯកសាររបស់អង្គការសហប្រជាជាតិលេខ A/CN.4/SER.A/1996/Add.l (ផ្នែកទី ២), ទំព័រ ១៥ ដល់ ៥៦ (សូមមើលជាពិសេស មាត្រា ១៨ ត្រង់ទំព័រ ៤៧ ដល់ ៥០ ស្ដីអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។

តុលាការ *មិនអចិន្ត្រៃយ៍*ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ លក្ខន្តិកៈតុលាការ ICTY[221] និង ICTR[222] មានលក្ខណៈដូចគ្នាទៅនឹងធម្មនុញ្ញតុលាការយោធាអន្តរជាតិដែរ ក្នុងការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយនៅពេលបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិទាំងនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិបានកត់សម្គាល់យ៉ាងច្បាស់អំពីឋានៈជាច្បាប់ទំនៀមទំលាប់អន្តរជាតិនៃនិយមន័យនេះ[223]។ ជាបន្តទៀត និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមាននៅក្នុងសេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិឆ្នាំ ១៩៩៦ បានត្រឡប់ទៅរកនិយមន័យនៅក្នុងអត្ថបទកំណែដើមដែលមានលក្ខណៈដូចគ្នាច្រើនទៅនឹងនិយមន័យដែលមាននៅក្នុងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ប៉ុន្តែ មានភាពជាក់លាក់បន្ថែមទៀត។

១១៦. ដោយសារតែមានការប្រែប្រួលយ៉ាងសកម្ម និងការដែលគណៈកម្មការ ILC មិនបានបែងចែកឱ្យបានច្បាស់លាស់អំពីការងារដែលត្រូវបំពេញតាមអាណត្តិរបស់ខ្លួន[224] ទើបអង្គជំនុំជម្រះ

[221]មាត្រា ៥ នៃលក្ខន្តិកៈរបស់តុលាការ ICTY។

[222]មាត្រា ៣ នៃលក្ខន្តិកៈរបស់តុលាការ ICTR។

[223]*របាយការណ៍របស់អគ្គលេខាធិការ ដោយអនុលោមតាមកថាខណ្ឌ ២ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨០៨,* របាយការណ៍ផ្លូវការរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសប្រជាជាតិ (U.N. SCOR) ឯកសារអង្គការសហប្រជាជាតិលេខ S/25704 (ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៣), កថាខណ្ឌ ៣៥។

[224]មាត្រា ១៥ នៃលក្ខន្តិកៈរបស់គណៈកម្មាការនីតិអន្តរជាតិ (នៅក្នុងនោះ គណៈកម្មាធិការនីតិអន្តរជាតិបានបញ្ជាក់ពីគោលបំណងរបស់ខ្លួនថាជា"ការបង្កើតនិងការរៀបចំជាប្រព័ន្ធ ដែលមានលក្ខណៈច្បាស់លាស់ជាងមុននៃវិធាននានានៃនីតិអន្តរជាតិនៅក្នុងផ្នែកដែលមានទ្រឹស្តីច្បាប់ យុត្តិសាស្ត្រ និងការអនុវត្តរបស់រដ្ឋក្នុងលក្ខណៈទូលំទូលាយរួចមកហើយ")។ *ប៉ុន្តែ សូមមើលផងដែរ* មាត្រា ១ នៃលក្ខន្តិកៈរបស់គណៈកម្មការនីតិអន្តរជាតិ ដែលបញ្ជាក់អំពីគោលបំណងរបស់គណៈកម្មការនីតិអន្តរជាតិថា ជា"ការជម្រុញដល់ការអភិវឌ្ឍន៍ច្បាប់អន្តរជាតិ និងក្រមនីយកម្មរបស់ខ្លួន"។ *សូមមើលផងដែរ របាយការណ៍របស់គណៈកម្មាធិការនីតិអន្តរជាតិស្តីពីសម័យប្រជុំលើកទីពីរ,* ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៥០, កថាខណ្ឌ ៩៦ បញ្ជាក់ថា "ចាប់តាំងពីពេលដែលគោលការណ៍ Nürnberg ត្រូវបានទទួលស្គាល់ដោយមហាសន្និបាតរួចមក ភារកិច្ចដែលបានប្រគល់ជូនគណៈកម្មការ គឺមិនត្រឹមតែសម្តែងអំពីការទទួលយក ដោយរឹករាយនូវគោលការណ៍នៃច្បាប់អន្តរជាតិប៉ុណ្ណោះទេ ថែមទាំងបានបង្កើតគោលការណ៍នេះឡើងផងដែរ"។ *របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិកត់ត្រាកិច្ចការនៅក្នុងសម័យប្រជុំលើកទីបីរបស់ខ្លួន,* ថ្ងៃទី ១៦ ខែ ឧសភា ដល់ ២៧ ខែ កក្កដា ឆ្នាំ ១៩៥១, A/1858,

តុលាការកំពូលមិនអាចសន្និដ្ឋានជាស្វ័យប្រវត្តិថា សេចក្តីព្រាងក្រមស្តីពីបទល្មើសអន្តរជាតិរបស់គណៈកម្មការ ILC តែងតែឆ្លុះបញ្ចាំងពី "ការអនុវត្តតៗគ្នារបស់រដ្ឋ យុត្តិសាស្ត្ររបស់តុលាការ និងលទ្ធិនៃនីតិយ៉ាងទូលំទូលាយ" បាននោះទេ។ ហេតុដូច្នេះ នៅពេលពិចារណាអំពីបញ្ហាជាក់លាក់នានាជុំវិញធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមាននៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលត្រូវតែវាយតម្លៃដោយប្រុងប្រយ័ត្នអំពីសេចក្តីព្រាងក្រមរបស់គណៈកម្មការ ILC តាមរយៈភស្តុតាងនៃការអនុវត្តតៗគ្នារបស់រដ្ឋ និង*ការប្រកាសពីឆន្ទៈទទួលយកជាច្បាប់*នាពេលនោះ ដើម្បីមានលទ្ធភាពក្នុងការសម្រេចថាតើ នៅពេលណាដែលសេចក្តីព្រាងទាំងនេះ បានឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទំលាប់អន្តរជាតិ ប៉ុន្តែមិនមែន ថាតើនៅពេលណាដែលសេចក្តីព្រាងទាំងនោះបង្ហាញឱ្យឃើញអំពីការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការ ILC អំពីការអភិវឌ្ឍច្បាប់នាពេលអនាគតនោះទេ។

## ៤.គ. ការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩
## (ទឡ្ហីករណ៍ទី ៣ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា)

១១៧. នៅក្នុងទឡ្ហីករណ៍ទី ៣ នៃបណ្តឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង "មានកំហុសអង្គច្បាប់ ដោយសារមិនបានសម្រេចអំពីពិរុទ្ធភាពលើជន

---

*សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការនីតិអន្តរជាតិ*, ឆ្នាំ១៩៥១, វ៉ុល II, ឯកសារអង្គការសហប្រជាជាតិលេខ A/CN.4/SER.A/1951/Add.1, កថាខណ្ឌ ៥៥ ៥៧ ដល់ ៥៨ (ភាន់ច្រឡំក្នុងការដាក់លេខកថាខណ្ឌ ៥៨ ទៅជាកថាខណ្ឌ ៥២ នៅក្នុងឯកសារដើម) (ក្នុងការបង្កើតរូបមន្តស្តីពីបទល្មើសនៅក្នុងសេចក្តីព្រាងនៃក្រម គណៈកម្មការ ILC បានមើលរំលងក្រមនីយកម្មនៃគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ និងការអភិវឌ្ឍន៍នៃច្បាប់ដែលត្រូវបានជម្រុញឱ្យបានប្រសើរនៅក្នុងពេលនោះ។ គណៈកម្មការមិនបានចាត់ទុកថា "ជាការចាំបាច់ក្នុងការបង្ហាញនូវវិសាលភាពជាក់លាក់ដែលគោលការណ៍ Nürnberg ផ្សេងៗទៀត បានបញ្ចូលនៅក្នុងសេចក្តីព្រាងក្រមនៃបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ។ មានតែការសំអាងទូទៅទៅលើគោលករណ៍ទាំងនេះប៉ុណ្ណោះ ដែលត្រូវបានចាត់ទុកថាអាចអនុវត្តបាន")។

ជាប់ចោទពីបទធ្វើឱ្យទៅជាទាសករចំពោះអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១"[225]។ សហព្រះរាជអាជ្ញាបានអះអាងដូច្នេះ ដោយផ្អែកលើទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូង "មានកំហុសអង្គច្បាប់ នៅក្នុងការកំណត់និយមន័យនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដោយ"ដាក់បញ្ចូលធាតុផ្សំនៃពលកម្មដោយបង្ខំ ទៅក្នុងនិយមន័យនេះ"[226] និង"តម្រូវថា ពលកម្មដោយបង្ខំជាធាតុផ្សំចាំបាច់មួយនៃបទឧក្រិដ្ឋនេះ"[227]។ សហព្រះរាជអាជ្ញាអះអាងថា ការធ្វើដូច្នេះ"មិនស្របទៅនឹងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ" នោះទេ និងថា នាពេលនោះ ការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានធ្វើទៅលើពួកអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១[228]។ សហព្រះរាជអាជ្ញាអះអាងថា និយមន័យដែលត្រឹមត្រូវនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជា"ការប្រើប្រាស់អំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស"[229] និងសន្និដ្ឋានថា ស្របតាមនិយមន័យខាងលើ សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១ "បានបំពេញតាមលក្ខខណ្ឌតម្រូវនៃនិយមន័យនៃការធ្វើឱ្យទៅជាទាសករ (...)"[230]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការកំណត់និយមន័យនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទការធ្វើឱ្យទៅជាទាសករ ចំពោះអ្នកជាប់ឃុំឃាំងទាំងអស់នៅ

---

[225]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១០។

[226]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០១។

[227]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០២។

[228]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០៦ និង ២០៩។

[229]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០១, ដកស្រង់ចេញពី *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kunarac និងជនដទៃទៀត*, សំណុំរឿងលេខ IT-96-23&23/1, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១, ("សាលក្រមក្នុងរឿងក្តី *Kunarac*"), កថាខណ្ឌ ៥៣៩។

[230]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០៨ ដល់ ២០៩, ដកស្រង់ចេញពីសាលក្រមអង្គជំនុំជម្រះសាលាដំបូង *រឿងក្តី Kunarac*, កថាខណ្ឌ ៥៣៩។

មន្ទីរ ស ២១ "ដោយពុំចាំបាច់កំណត់ ថាតើអ្នកជាប់ឃុំឃាំងទាំងអស់ត្រូវបានគេបង្ខំឱ្យធ្វើការ ឬដោយមិនស្ម័គ្រចិត្ត ដែរ ឬយ៉ាងណា"[231] នោះឡើយ។

១១៨. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា យោងតាមមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក អ.វ.ត.ក មានយុត្តាធិការ"វិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (...) ណាមួយដូចជាៈ (...) ការធ្វើឱ្យទៅជាទាសករ (...)"[232]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ពីបទការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវផ្ទាល់ខ្លួន និងដោយផ្អែកលើការទទួលខុសត្រូវរបស់ថ្នាក់លើរបស់ជនជាប់ចោទយោងតាមមាត្រា ២៩ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[233]។

១១៩. នៅពេលអង្គជំនុំជម្រះសាលាដំបូងគូសបញ្ជាក់អំពីច្បាប់ដែលត្រូវយកមកអនុវត្ត ពាក់ព័ន្ធនឹងការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះនេះបានសន្និដ្ឋានថា "ការហាមឃាត់ការធ្វើទាសភាព គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិយ៉ាងច្បាស់លាស់"[234]។ បើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ធាតុផ្សំសត្យានុម័តនៃការធ្វើឱ្យទៅជាទាសករ"ត្រូវបានកំណត់ចរិតលក្ខណៈ តាមរយៈការប្រើប្រាស់អំណាចណាមួយ ឬទាំងអស់

---

[231]បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០៩។

[232]មាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។

[233]សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៤៨ ដល់ ៥៤៩។

[234]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤២, ដកស្រង់ចេញពី *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Krnojelac*, សំណុំរឿងលេខ IT-97-25-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២, ("សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្ដី Krnojelac*"), កថាខណ្ឌ ៣៥៣។

ក្នុងនាមជាម្ចាស់លើមនុស្ស”[235]។ លើសពីនេះទៅទៀត អង្គជំនុំជម្រះនេះបានយល់ឃើញថា សញ្ញាណនៃការធ្វើឱ្យទៅជាទាសករ រួមមានៈ

> ការគ្រប់គ្រងលើការដើរហើររបស់មនុស្សណាម្នាក់ ការគ្រប់គ្រងជារូបវន្តលើកន្លែងរស់នៅ ការគ្រប់គ្រងលើផ្លូវចិត្ត ការចាត់វិធានការនានាដើម្បីទប់ស្កាត់ ឬរារាំងមិនឱ្យគេចខ្លួន ការប្រើកម្លាំង ការគំរាមកំហែងនឹងប្រើកម្លាំង ឬការបង្ខិតបង្ខំ រយៈពេលនៃការធ្វើជាទាសករ ការអះអាងជាម្ចាស់កម្មសិទ្ធិផ្តាច់មុខ ការដាក់ឱ្យស្ថិតនៅក្រោមការប្រព្រឹត្តយ៉ាងព្រៃផ្សៃ និងការរំលោភបំពាន ការគ្រប់គ្រងលើផ្លូវភេទ និងការធ្វើពលកម្មដោយបង្ខំ[236]។

១២០. ពាក់ព័ន្ធទៅនឹងពលកម្មដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្តនេះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា អំពើនេះ“ក៏អាចចាត់ជាការធ្វើឱ្យទៅជាទាសករផងដែរ”[237]។ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា នៅពេលកំណត់ ថាតើជាពលកម្មដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត ហើយឈានដល់កម្រិតនៃការធ្វើឱ្យទៅជាទាសករ អង្គជំនុំជម្រះត្រូវផ្អែកលើ“កត្តាដែលបានគូសបញ្ជាក់ខាងលើ”[238]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា ក្នុងកាលៈទេសៈជាក់លាក់មួយចំនួន ធាតុផ្សំនៃបទល្មើសការធ្វើឱ្យទៅជាទាសករ តាមរយៈការធ្វើពលកម្មដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត អាចមានលក្ខណៈគ្រប់គ្រាន់“ដោយមិនចាំបាច់មាន

[235] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤២, ដកស្រង់ចេញពី *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kunarac និងជនដទៃទៀត*, សំណុំរឿងលេខ IT-96-23&23/1, “សាលដីកា”, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២, (“សាលដីកាក្នុង *រឿងក្តី Kunarac*”), កថាខណ្ឌ ១១៦។

[236] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤២, ដកស្រង់ចេញពីសាលដីកាក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ១១៩។

[237] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៤, ដកស្រង់ចេញពី *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Sesay,* សំណុំរឿងលេខ SCSL-04-15-T, “សាលក្រម”, អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩, (“សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Sesay*”), កថាខណ្ឌ ២០២។

[238] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៤, ដកស្រង់ចេញពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Sesay*, កថាខណ្ឌ ២០២។

ភស្តុតាងអំពីការធ្វើបាបបន្ថែម"[239]នោះទេ។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា "មិនចាំបាច់មានភស្តុតាងបង្ហាញថា ជនរងគ្រោះយល់ព្រម ឬមិនយល់ព្រមធ្វើជាទាសករនោះទេ ពីព្រោះការធ្វើឱ្យទៅជាទាសករ ត្រូវបានកំណត់ដោយការប្រើប្រាស់អំណាចរបស់ចារី"[240]។

១២១. ចំណែកឯ*ធាតុផ្សំអត្តនោម័ត*នៃការធ្វើឱ្យទៅជាទាសករ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា សហព្រះរាជអាជ្ញាត្រូវតែមានការបង្ហាញថា "ចារីបានប្រើប្រាស់ដោយចេតនានូវអំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស"[241]។

១២២. នៅពេលយកនិយមន័យនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មកអនុវត្តចំពោះអង្គហេតុ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងកម្រិតត្រឹមតែ "អ្នកទោសមួយចំនួននៅមន្ទីរ ស ២១ និងព្រៃ ស ត្រូវគេបង្ខំឱ្យធ្វើការ" ប៉ុណ្ណោះ ដែលចំណុចនេះស្របគ្នាទៅនឹងអង្គហេតុប្តឹងចោទប្រកាន់ដែលមានក្នុងដីកាដំណោះស្រាយ នៅត្រង់ចំណុចបទចោទនៃការធ្វើឱ្យទៅជាទាសករ[242]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា "ពលកម្មដោយបង្ខំ ឬមិនស្ម័គ្រចិត្ត ដែលរួមទាំង ការឃុំខ្លួន (...)" នៃអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២៤ និង"អ្នកជាប់ឃុំឃាំងមួយចំនួនតូច ដែលត្រូវបានចាត់ឱ្យ

---

[239]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៤, ដកស្រង់ចេញពី*រឿងក្តី U.S ទល់នឹង Pohl និងជនដទៃទៀត,* "សាលក្រម", ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧, បោះពុម្ពផ្សាយក្នុងព្រឹត្តប័ត្រស្តីពី*ការជំនុំជម្រះក្តីលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, ខែ តុលា ឆ្នាំ ១៩៤៦ ដល់ ខែ មេសា ឆ្នាំ ១៩៤៩, វ៉ុល V, ការិយាល័យបោះពុម្ពផ្សាយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក, ឆ្នាំ ១៩៤៩ ដល់ ១៩៥៣, ("*រឿងក្តី Pohl*"), ទំព័រ ៩៧០, សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Sesay*, កថាខណ្ឌ ២០៣។

[240]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៣, ដកស្រង់ចេញពីសាលដីកាក្នុង*រឿងក្តី* Kunarac, កថាខណ្ឌ ១២០។

[241]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៥, ដកស្រង់ចេញពីសាលដីកាក្នុង*រឿងក្តី* Kunarac, កថាខណ្ឌ ១១៦។

[242]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២២៥, ដកស្រង់ចេញពីដីកាដំណោះស្រាយដែលត្រូវបានកែប្រែ, កថាខណ្ឌ ១៣៥។

ធ្វើការនៅក្នុងមន្ទីរ ស ២១ (ទួលស្លែង)" បង្កើតបានជាអំពើធ្វើឱ្យទៅជាទាសករ[243]។ បុគ្គលិកមន្ទីរ ស ២១ "បានប្រើប្រាស់អំណាច និងគ្រប់គ្រងទាំងស្រុង" លើអ្នកជាប់ឃុំឃាំងទាំងនេះ ដែលពួកគេ"ពុំមានសិទ្ធិបដិសេធការងារដែលគេចាត់ឱ្យធ្វើនោះទេ ហើយក៏មិនបានយល់ព្រមទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួនរបស់ពួកគេដែរ"[244]។

១២៣. ដើម្បីដោះស្រាយទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា មានបញ្ហាពីរនៅចំពោះមុខ៖

ក) ថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការកំណត់និយមន័យនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ។ និង

ខ) ថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទធ្វើឱ្យទៅជាទាសករ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះតែអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ មួយចំនួនប៉ុណ្ណោះ ដែលបានរងការដាក់ឱ្យធ្វើពលកម្មដោយបង្ខំ ហើយមិនចំពោះអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១ នោះទេ។

ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិនិត្យចំណុចនីមួយៗ ដូចខាងក្រោម។

## ៤.គ.១.ការកំណត់និយមន័យនៃការធ្វើឱ្យទៅជាទាសកររបស់អង្គជំនុំជម្រះសាលាដំបូង

១២៤. ក្នុងការកំណត់ ថាតើនិយមន័យនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ របស់អង្គជំនុំជម្រះសាលាដំបូង គឺជានិយមន័យដែលអាចអនុវត្តបាន ដែរ ឬយ៉ាងណា យោងតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ដោយផ្អែកលើគោល

[243]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៦។

[244]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៦។

ការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាជាបឋមទៅលើការអះអាងរបស់សហព្រះរាជអាជ្ញាដែលថា អង្គជំនុំជម្រះសាលាដំបូង "មានកំហុសក្នុងការដាក់បញ្ចូលធាតុផ្សំពលកម្មដោយបង្ខំ ទៅក្នុងនិយមន័យនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[245] ថាជាធាតុផ្សំដែលតម្រូវចាំបាច់មួយនៃឧក្រិដ្ឋកម្មនេះ[246]។

១២៥. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខ្លឹមសារនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង បានពន្យល់ច្បាស់លាស់រួចហើយលើបញ្ហានេះ។ អង្គជំនុំជម្រះសាលាដំបូងពុំបានកំណត់ដោយជាក់លាក់ ឬដោយប្រយោលអំពីការធ្វើពលកម្មដោយបង្ខំថា ជាធាតុផ្សំចាំបាច់មួយនៃការធ្វើឱ្យទៅជាទាសករនោះឡើយ នៅពេលកំណត់អំពីធាតុផ្សំសត្យានុម័តនៃការធ្វើឱ្យទៅជាទាសករថា ជា"ការប្រើប្រាស់អំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស"[247]។ នៅពេលធ្វើការពិចារណាពាក់ព័ន្ធនឹងការវិភាគអំពីការធ្វើឱ្យទៅជាទាសករ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "ពលកម្មដោយបង្ខំ" គ្រាន់តែជាកត្តាមួយដែលត្រូវយកមកពិចារណាក្នុងចំណោម "សញ្ញាណជាច្រើននៃការធ្វើឱ្យទៅជាទាសករ"ប៉ុណ្ណោះ[248]។ ពុំមានកត្តាណាមួយត្រូវបានអង្គជំនុំជម្រះសាលាដំបូងជ្រើសយកជាកត្តាដែលសំខាន់ និងពាក់ព័ន្ធជាងគេ ដើម្បីកំណត់បានជាអំពើធ្វើឱ្យទៅជាទាសករនោះទេ[249]។

១២៦. លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងយ៉ាងច្បាស់ថា "ពលកម្មដោយបង្ខំ (...) អាចជាការធ្វើឱ្យទៅជាទាសករ"*បានផងដែរ*[250]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ប្រសិនបើពិនិត្យមើលសញ្ញាណដែលពាក់ព័ន្ធដទៃទៀត ពលកម្មដោយបង្ខំ អាច

---

[245]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០១។

[246]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០២។

[247]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤២, ដកស្រង់ចេញពីសាលដីកាក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ១១៦។

[248]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤២។

[249]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤២។

[250]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៤, ដកស្រង់ចេញពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Sesay*, កថាខណ្ឌ ២០២ (សេចក្តីបញ្ជាក់បន្ថែម)។

ឈានទៅដល់កម្រិតជាអំពើធ្វើឱ្យទៅជាទាសករបាន ដោយពុំចាំបាច់មានភស្តុតាងបន្ថែមអំពីការធ្វើបាបនោះទេ[251]។ ជាលទ្ធផលនៃការកំណត់ទាំងនេះមានន័យថា ពលកម្មដោយបង្ខំ មិនមែនជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់កំណត់ថា ជាអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះឡើយ។

១២៧. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាត្រឹមតែថាតើមានអំពើធ្វើឱ្យទៅជាទាសករក្នុងសំណុំរឿងនេះ ដែរ ឬយ៉ាងណា ពាក់ព័ន្ធនឹងអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ (ទួលស្លែង) និង ស ២៤ ដែលបានទទួលរងនូវការបង្ខំឱ្យធ្វើពលកម្ម។ ប៉ុន្តែ ការវិភាគអង្គហេតុដោយមានកម្រិតបែបនេះ ពុំអាចឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងចាត់ទុកពលកម្មដោយបង្ខំថា ជាធាតុផ្សំចាំបាច់នៃនិយមន័យតាមផ្លូវច្បាប់នៃអំពើធ្វើឱ្យទៅជាទាសករ នោះទេ។ ផ្ទុយទៅវិញ នៅពេលយកនិយមន័យនៃការធ្វើឱ្យទៅជាទាសករមកអនុវត្តចំពោះការផ្តល់សំអាងហេតុរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង គោរពតាមវិសាលភាពនៃបទចោទអំពីការធ្វើឱ្យទៅជាទាសករនៅក្នុងដីកាដំណោះស្រាយដែលបានកម្រិតចំពោះតែអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ (ទួលស្លែង) និង ស ២៤ ដូចខាងក្រោម៖

> អ្នកទោសមួយចំនួននៅមន្ទីរ ស ២១ និង ព្រៃស ត្រូវគេបង្ខំឱ្យធ្វើការ។ គ្រប់ទិដ្ឋភាពនៃការរស់នៅរបស់ពួកគេត្រូវបានឃាមកាមយ៉ាងតឹងរ៉ឹង និងត្រូវបានចាត់ទុកជាវត្ថុផ្តាច់មុខដែលត្រូវបានបង្ហាញតាមរយៈការកម្រិតការដើរហើរ និងកន្លែងរស់នៅ ការចាត់វិធានការទប់ស្កាត់ ឬធ្វើឱ្យពួកគេញញើតនឹងការរត់គេច និងតាមរយៈការអនុវត្តដែលនាំឱ្យពួកគេប្រឈមនឹងអំពើឃោរឃៅ។ ជាលទ្ធផលនៃអំពើទាំងនេះ អ្នកទោសត្រូវបានដកហូតនូវសេរីភាពរបស់ពួកគេ[252]។

---

[251]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៤, ដកស្រង់ចេញពី *រឿងក្តី Pohl*, ទំព័រ ៩៧០។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Sesay*, កថាខណ្ឌ ២០៣។

[252]ដីកាដំណោះស្រាយដែលត្រូវបានកែប្រែ, កថាខណ្ឌ ១៣៥។

១២៨. តាមការលើកឡើងនេះ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង កម្រិតឱ្យអង្គជំនុំជម្រះសាលាដំបូង ពិចារណាតែចំពោះ "អង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ"។ ប៉ុន្តែ វិធាននេះមិនបានដាក់កំហិតឱ្យអង្គជំនុំជម្រះសាលាដំបូង ពិចារណាចំពោះអង្គហេតុដែលមានទំនាក់ទំនងយ៉ាងច្បាស់លាស់ជាមួយបទចោទនៅក្នុងដីកាដំណោះស្រាយ នោះទេ[253]។ ជាការពិត"អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន (...)"[254]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងបន្តពិចារណា ថាតើសំអាងហេតុទាំងមូលរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងមន្ទីរ ស ២១ ចំពោះបទចោទដទៃទៀត បានគាំទ្រដល់ការកំណត់តាមផ្លូវច្បាប់ថា អ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១ ត្រូវបានគេធ្វើឱ្យទៅជាទាសករដែរ ឬ យ៉ាងណា។

១២៩. ផ្អែកលើមូលដ្ឋានខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការអះអាងរបស់សហព្រះរាជអាជ្ញាដែលថា និយមន័យនៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឱ្យមានភស្តុតាងបញ្ជាក់អំពីពលកម្មដោយបង្ខំនោះ ពុំមានមូលដ្ឋានត្រឹមត្រូវ នោះទេ។

១៣០. ចំពោះការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការធ្វើឱ្យទៅជាទាសករដូចបានកត់សម្គាល់ខាងលើ មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តម្រូវឱ្យអង្គជំនុំជម្រះ អនុវត្តយុត្តាធិការរបស់ខ្លួនលើរឿងក្តី ស្របតាមគោលការណ៍នីត្យានុកូលភាពអន្តរជាតិ ដូចមានចែងក្នុងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែលកំណត់ថា គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬអកម្មណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ[255]។

---

[253]វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។

[254]វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។

[255]មាត្រា ៣៣ ថ្មី (២) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ មាត្រា ១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

១៣១. អនុសញ្ញាឆ្នាំ ១៩២៦ ស្តីពីការទប់ស្កាត់ការជួញដូរទាសករ និងទាសភាព ("អនុសញ្ញាស្តីពីទាសភាព") ដែលចូលជាធរមាននៅឆ្នាំ ១៩២៧ ពីដំបូងបានកំណត់និយមន័យទាសភាពថា ជា "ស្ថានភាព ឬលក្ខខណ្ឌនៃមនុស្សម្នាក់ដែលស្ថិតក្រោមការប្រើប្រាស់អំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់"[256]។ អនុសញ្ញាស្តីពីទាសភាពនេះត្រូវបានបំពេញបន្ថែមដោយអនុសញ្ញាបន្ថែមឆ្នាំ ១៩៥៦ ស្តីពីការលុបបំបាត់ទាសភាព ការជួញដូរទាសករ និងស្ថាប័ន និងទីកន្លែងអនុវត្តដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងទាសភាព ("អនុសញ្ញាបន្ថែមស្តីពីទាសភាព") ដែលចូលជាធរមានក្នុងឆ្នាំ ១៩៥៧ និងបានបញ្ជាក់ឡើងវិញអំពីនិយមន័យនៃទាសភាពដែលមានកំណត់នៅក្នុងអនុសញ្ញាស្តីពីទាសភាព[257]។ ត្រឹមឆ្នាំ ១៩៧៥ មានរដ្ឋសរុបទាំងអស់ចំនួន ៥៦ បានក្លាយជាភាគីនៃអនុសញ្ញាស្តីពីទាសភាពនេះ[258] និងមានរដ្ឋចំនួន ៨២ បានក្លាយជាភាគីនៃអនុសញ្ញាបន្ថែមស្តីពីទាសភាព[259]។ ប្រទេសកម្ពុជាបានចូលជាភាគីនៃអនុសញ្ញា

---

[256]អនុសញ្ញាស្តីពីការបង្ក្រាបពាណិជ្ជកម្មទាសករ និងទាសភាព អនុម័តថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩២៦ និងចូលជាធរមាននៅថ្ងៃទី ៩ ខែ មីនា ឆ្នាំ ១៩២៧, វ៉ុល ៦០ សម្ព័ន្ធនៃលេខលំដាប់សន្ធិសញ្ញាប្រជាជាតិ ទំព័រ ២៥៤ (60 LNTS 254), ("ចូលជាធរមាននៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩២៧") ("អនុសញ្ញាទាសភាព") មាត្រា ១(១)។

[257]មាត្រា ៧(ក) នៃអនុសញ្ញាបំពេញបន្ថែមស្តីពីការលុបបំបាត់ទាសភាព ពាណិជ្ជកម្មទាសករ និងស្ថាប័ន និងការអនុវត្តប្រហាក់ប្រហែលទៅនឹងទាសភាពដែលត្រូវបានអនុម័ត ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៥៦, វ៉ុល ២២៦ លេខលំដាប់សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ទំព័រ ៣ (226 U.N.T.S 3), (ចូលជាធរមាននៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៥៧) ("អនុសញ្ញាទាសភាពបំពេញបន្ថែម") ។

[258]កម្រងអនុសញ្ញាអង្គការសហប្រជាជាតិ, សន្ធិសញ្ញាពហុភាគីដែលបានដាក់នៅអគ្គលេខាធិការ (MTDSG), ឋានៈរបស់សន្ធិសញ្ញា, ជំពូក XVIII.3, "បញ្ហាព្រហ្មទណ្ឌ៖ អនុសញ្ញាទាសភាព"< http://treaties.un.org/Home.aspx?lang=en>។ តួលេខនេះរួមមានការចូលជាសមាជិក សន្តតិកម្ម និងការឲ្យសច្ចាប័ន។

[259]កម្រងអនុសញ្ញាអង្គការសហប្រជាជាតិ, សន្ធិសញ្ញាពហុភាគីដែលបានដាក់នៅអគ្គលេខាធិការ, ឋានៈរបស់សន្ធិសញ្ញា, ជំពូក XVIII.4, "បញ្ហាព្រហ្មទណ្ឌ៖ អនុសញ្ញាបំពេញបន្ថែមស្តីពីការលុបបំបាត់ទាសភាព ពាណិជ្ជកម្មទាសករ ទាំងស្ថាប័ន និងការអនុវត្តប្រហាក់ប្រហែលទៅនឹងទាសភាព"។

បន្ថែមស្តីពីទាសភាពនេះ នៅឆ្នាំ ១៩៥៧[260]។ និយមន័យនៃទាសភាពនៅក្នុងអនុសញ្ញាទាំងនេះ ត្រូវបានបន្តប្រើប្រាស់[261] និងទទួលស្គាល់ជាសាកលថា ជាបទប្បញ្ញត្តិគ្រឹះសម្រាប់និយមន័យ នៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[262] តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិផងដែរ។

១៣២. បន្ទាប់ពីមានអនុសញ្ញាស្តីពីទាសភាព ការធ្វើឱ្យទៅជាទាសករត្រូវបានបញ្ញត្តិលើកដំបូងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងមាត្រា ៦(គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ (IMT) មាត្រា ៥(គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE) មាត្រា II (១)(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងគោលការណ៍ Nuremberg VI (គ) គោលការណ៍ Nuremberg ឆ្នាំ ១៩៥០[263]។ តុលាការដែលបង្កើតក្រោយសង្គ្រាមលោកលើកទី II ដែលជាតុលាការដំបូងគេបង្អស់ក្នុងការចោទប្រកាន់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ

[260] កម្រងអនុសញ្ញាអង្គការសហប្រជាជាតិ, MTDSG, ឋានៈរបស់សន្ធិសញ្ញា, ជំពូក XVIII.4, "បញ្ហាព្រហ្មទណ្ឌ៖ អនុសញ្ញាបំពេញបន្ថែមស្តីពីការលុបបំបាត់ទាសភាព ពាណិជ្ជកម្មទាសករ និងស្ថាប័ន និងការអនុវត្តប្រហាក់ប្រហែលទៅនឹងទាសភាព" ។

[261] *សូមមើលឧទា.* មាត្រា ៧(២)(គ) នៃលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ អនុម័តនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨, វ៉ុល ២១៨៧ លេខលំដាប់សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ទំព័រ ៣ (2187 U.N.T.S 3), (ចូលជាធរមាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២) ("លក្ខន្តិកៈរបស់តុលាការ ICC")។

[262] *សូមមើលឧទា.* សាលដីកាក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ១១៧ ដល់ ១២៤។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Sesay*, កថាខណ្ឌ ១៩៦ ដល់ ២០០។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Krnojelac*, កថាខណ្ឌ ៣៥០ និង ៣៥៣។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ៥១៩ ដល់ ៥៣៧ និងកថាខណ្ឌ ៥៣៩ ដល់ ៥៤៣។ នៅពេលដែលរឿងក្តីទាំងនេះបកស្រាយពន្យល់អំពីការវិវត្តនៃសញ្ញាណផ្សេងៗនៃទម្រង់ថ្មីនៃអំពើធ្វើឱ្យទៅជាទាសករថា ជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុលោមតាមច្បាប់អន្តរជាតិ ចាប់តាំងពីអនុសញ្ញាទាសភាពដែលស្ថិតនៅក្រៅដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក រឿងក្តីទាំងនេះគូសបញ្ជាក់ដោយឥតស្ទៀងនូវនិយមន័យជាមូលដ្ឋាននៃពាក្យទាសភាពនេះ ដែលដំបូងឡើយត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងអនុសញ្ញាទាសភាព ថាជានិយមន័យដែលយកមកអនុវត្តបាននៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

[263] មាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ។ មាត្រា ៥(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិចុងបូព៌ា។ មាត្រា II(១)(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។ គោលការណ៍ VI(គ) នៃគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ។

ពុំបានបញ្ជាក់ឱ្យច្បាស់លាស់អំពីធាតុផ្សំផ្លូវច្បាប់នៃអំពើធ្វើឱ្យទៅជាទាសករ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬបកស្រាយនិយមន័យដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីទាសភាពនោះឡើយ។ ប៉ុន្តែ តុលាការនេះបានវិភាគទៅលើខ្លឹមសារ ដែលតុលាការអន្តរជាតិដែលបង្កើតក្រោយៗមកទៀតបានឃើញថា កត្តាដែលកើតចេញពីការវិភាគនេះ គឺជាការបង្ហាញពីអំពើធ្វើឱ្យទៅជាទាសករដែលជាបទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[264]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សេចក្តីសន្និដ្ឋានដែលបានធ្វើដោយតុលាការបង្កើតក្រោយសង្គ្រាមលោកលើកទី II រួមជាមួយនឹងនិយមន័យនៃទាសភាពដែលបានកំណត់ក្នុងអនុសញ្ញាស្តីពីទាសភាពឆ្នាំ ១៩២៦ បានបង្ហាញអំពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពាក់ព័ន្ធនឹងនិយមន័យនៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នាពេលនោះ។

១៣៣. នៅក្នុងសាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) ជនជាប់ចោទចំនួន ១២ នាក់ ត្រូវបានសម្រេចដាក់ពិរុទ្ធភាព ពីបទធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម តាមរយៈការចូលរួមរបស់ពួកគេនៅក្នុងកម្មវិធីពលកម្មទាសកររបស់ពួកណាហ្ស៊ី (Nazi) ហើយជនជាប់ចោទម្នាក់ទៀត គឺ Baldur Von Shirach ត្រូវបានតុលាការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[265]។ នៅក្នុងសំអាងហេតុរបស់ខ្លួន តុលាការនេះបានផ្តោតលើទិដ្ឋភាពនៃកម្មវិធី ដូចខាងក្រោម៖

- ថាតើ ពលករទាំងឡាយមានសេរីភាពកម្រិតណាក្នុងការជ្រើសរើសធ្វើការងារឱ្យពួកអាល្លឺម៉ង់

[264]សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ៥២៣ ដល់ ៥២៥ និង ៥៤២។ *សូមមើលផងដែរ* សាលដីកាក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ១១៩។

[265]សាលក្រមរបស់តុលាការយោធាអន្តរជាតិ, វ៉ុល I, ទំព័រ ២៧៩ ដល់ ២៨២, ២៨៨ ដល់ ៣០១, ៣០៤ ដល់ ៣០៧, ៣១៧ ដល់ ៣២២, ៣២៧ ដល់ ៣៣៣, ៣៣៨ ដល់ ៣៤១។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅក្នុងការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទធ្វើឲ្យទៅជាទាសករ តុលាការយោធាអន្តរជាតិ (IMT) ពុំបានបែងចែក ឲ្យដាច់ពីគ្នារវាងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ។

- ថាតើ ពលករទាំងនោះត្រូវបានផ្ទេរ និងចាត់ចែង ក្នុងលក្ខខណ្ឌយ៉ាងណាខ្លះ និង

- ថាតើ ពលករទាំងនោះត្រូវបានជ្រើសរើស និងជិះជាន់ពលកម្មក្នុងគោលបំណងអ្វីខ្លះ[266]។

១៣៤. តុលាការនេះយល់ឃើញថា យ៉ាងហោចណាស់មានមនុស្សចំនួន ៥.០០០.០០០ (ប្រាំលាន) នាក់ ត្រូវបាននាំទៅប្រទេសអាល្លឺម៉ង់ ដើម្បីធ្វើការក្នុងវិស័យឧស្សាហកម្ម និងកសិកម្មអាល្លឺម៉ង់[267]។ បន្ទាប់ពីថ្លឹងថ្លែងភស្តុតាង ក្នុងនោះរួមទាំងចម្លើយរបស់ជនជាប់ចោទ Fritz Saukel ជាឧត្តមសេនីយ៍វិសាមញ្ញទទួលបន្ទុកលើការប្រើប្រាស់កម្លាំងពលកម្ម ដែលបានលើកឡើងថា "ក្នុងចំណោមកម្មករចំនួន ៥.០០០.០០០ (ប្រាំលាន) នាក់ ដែលបានមកដល់ប្រទេសអាល្លឺម៉ង់ មានកម្មករចំនួន ២០០.០០០ (ពីរសែន) នាក់ ពុំបានមកដោយស្ម័គ្រចិត្តនោះទេ"[268] តុលាការបានសន្និដ្ឋានថា ទោះបីជាមានពលករមួយចំនួនដែលមកពីអឺរ៉ុបខាងលិច ពីដំបូងត្រូវបានគេជ្រើសរើសឱ្យធ្វើការដោយស្ម័គ្រចិត្តក៏ដោយ ក៏ពលករមួយចំនួនធំ ត្រូវបានគេបង្ខំឱ្យចាកចេញពីលំនៅដ្ឋាន ដើម្បីទៅធ្វើការក្នុងវិស័យឧស្សាហកម្ម និងធ្វើសឹកសង្គ្រាមរបស់អាល្លឺម៉ង់[269]។ មានករណីជាច្រើន ដែលការកេណ្ឌកម្លាំងពលករ ត្រូវបានធ្វើឡើងដោយវិធីបន្ទាន់ និងហិង្សា[270]។

១៣៥. តុលាការនេះក៏បានយល់ឃើញផងដែរថា ជាទូទៅ ពលករទាំងឡាយត្រូវបានគេប្រព្រឹត្តលើយ៉ាងព្រៃផ្សៃ និងអមនុស្សធម៌ នៅពេលដែលពួកគេត្រូវបាននាំទៅដល់ប្រទេសអាល្លឺម៉ង់ និង

---

[266]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៤៣ ដល់ ២៤៧។

[267]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៤៣។

[268]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I ទំព័រ ២៤៤។

[269]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I ទំព័រ ២៤៥ ដល់ ២៤៥។

"ការតាមស្វែងរកចាប់មនុស្សបានប្រព្រឹត្តទៅនៅតាមផ្លូវថ្នល់ នៅតាមរោងភាពយន្ត និងតាមវិហារសាសនាគ្រិស្ត និងនៅពេលយប់ នៅតាមផ្ទះនីមួយៗ។ ជួនកាល ផ្ទះទាំងនេះត្រូវបានដុតកម្ទេចចោល ហើយចាប់សមាជិកគ្រួសារធ្វើជាចំណាប់ខ្មាំង គឺជាអំពើដែលជនជាប់ចោទ Rosenberg បានពិពណ៌នាថា មានប្រភពរបស់វាចេញមកពី***យុគសម័យដ៏ខ្មៅងងឹតនៃពាណិជ្ជកម្មទាសករ***"។ សាលក្រមតុលាការយោធាអន្តរជាតិ, វ៉ុល I, ទំព័រ ២៤៥។

នៅពេលធ្វើការនៅក្នុងវិស័យឧស្សាហកម្មរបស់អាល្លឺម៉ង់[271]។ ការប្រព្រឹត្តលើពលករបានធ្វើឡើងតាមរយៈការណែនាំរបស់ជនជាប់ចោទ Sauckel ដែលតម្រូវឱ្យ"ពលករប្រុសៗទាំងអស់ត្រូវទទួលអាហារ ទទួលជម្រក និងការប្រព្រឹត្តគ្រប់មធ្យោបាយដើម្បីកេងប្រវ័ញ្ចពួកគេឱ្យបានច្រើនបំផុត តាមដែលអាចធ្វើទៅបាន ដោយធ្វើយ៉ាងណាឱ្យមានការចំណាយតិចបំផុត"[272]។ ជារឿយៗ ពលករទាំងឡាយពុំទទួលបានម្ហូបអាហារ សម្លៀកបំពាក់ គ្រឿងសម្ភារៈអនាម័យ និងកំដៅគ្រប់គ្រាន់ ហើយត្រូវបានគេដាក់ទណ្ឌកម្មយ៉ាងសាហាវយង់ឃ្នង[273]។ ជំរំប្រមូលផ្ដុំត្រូវបានគេប្រើប្រាស់ធ្វើជាកន្លែងសម្រាប់ផ្ដល់កម្លាំង ពលកម្ម ហើយអ្នកដែលនៅក្នុងជំរំនោះត្រូវបានគេបង្ខំឱ្យ"ធ្វើការឱ្យអស់ពីកម្លាំងកាយ"[274]។ បន្ថែមលើនេះ មានភស្តុតាងបង្ហាញឱ្យឃើញថា ពលការិនីដែលត្រូវបានគេនាំទៅធ្វើការជាអ្នកបម្រើតាមផ្ទះ និងតាមកសិដ្ឋាន ពុំទទួលបានពេលឈប់សម្រាក ប៉ុន្តែ មានឱកាសតិចតួចបំផុតដែលពួកគាត់ត្រូវបានគេផ្ដល់រង្វាន់ដោយអនុញ្ញាតឱ្យចេញក្រៅផ្ទះបានពីរ ឬបីម៉ោង ចំពោះការបំពេញការងារបានល្អ[275]។

១៣៦. លើសពីនេះទៅទៀត តុលាការរកឃើញថា៖

---

[271]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៤៦៖

> ភស្តុតាងបានបង្ហាញថា កម្មករដែលត្រូវកំណត់យកទៅចក្រភពទីបីអាល្លឺម៉ង់ ត្រូវបានបញ្ជូនទៅក្រោមការយាមកាម ហើយជារឿយៗ ពួកគេទាំងនេះត្រូវបានដាក់ប្រជ្រៀតគ្នាក្នុងទូរថភ្លើង ដោយពុំមានកំដៅ អាហារ សម្លៀកបំពាក់ ឬបរិក្ខារអនាម័យគ្រប់គ្រាន់ឡើយ។ ភស្តុតាងបានបង្ហាញទៀតថា ការប្រព្រឹត្តមកលើពលករនៅប្រទេសអាល្លឺម៉ង់ ក្នុងករណីជាច្រើន គឺត្រូវបានធ្វើឡើងដោយព្រៃផ្សៃ និងប្រមាថមាក់ងាយ។ ភស្តុតាងពាក់ព័ន្ធនឹងការងារ Krupp Works នៅ Essen បានបង្ហាញថា កម្មករត្រូវបានដាក់ទណ្ឌកម្មដែលជាប្រភេទសាហាវយង់ឃ្នងបំផុត។

[272]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៤៥។

[273]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៤៦។

[274]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៤៦។

[275]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល III, កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៤៥ ដល់ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៤៥, ទំព័រ ៤៥២។

"គោលនយោបាយទូទៅ ក្នុងការកេណ្ឌកម្លាំងពលកម្មទាសករ" ដូចដែលជនជាប់ចោទឈ្មោះ SAUCKEL បានលើកឡើងថា "ដើម្បីប្រើប្រាស់រាល់ធនធានដ៏សម្បូរបែប និងមហិមាដែលកងកម្លាំងប្រដាប់អាវុធរបស់យើងវាយដណ្តើមបាន និងរក្សាឱ្យបានគង់វង់សម្រាប់ពួកយើង (...) ដើម្បីបំពាក់សព្វាវុធដល់កងកម្លាំងប្រដាប់អាវុធ និងផ្គត់ផ្គង់មាតុភូមិ ផងដែរ។ វត្ថុធាតុដើមព្រមទាំងទឹកដីមានជីវជាតិ និងកម្លាំងពលកម្មមនុស្សដែលយើងវាយដណ្តើមបាន នឹងត្រូវប្រើប្រាស់ឱ្យបានពេញលេញ និងយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីជាប្រយោជន៍ដល់ប្រទេសអាល្លឺម៉ង់ និងសម្ព័ន្ធមិត្តរបស់អាល្លឺម៉ង់ (...)"[276]។

១៣៧. អាស្រ័យហេតុនេះ សេវាពលកម្មដោយបង្ខំត្រូវតែបង្កើតឱ្យមាននៅលើទឹកដីដែលបានកាន់កាប់ទាំងនោះ ដើម្បី"ជួយដល់សេដ្ឋកិច្ចសង្គ្រាមអាល្លឺម៉ង់" ហើយពលករបរទេសត្រូវបាននាំទៅប្រទេសអាល្លឺម៉ង់ផងដែរ ដើម្បីបំពេញតម្រូវការកម្លាំងពលកម្ម ក្នុងវិស័យឧស្សាហកម្មអាល្លឺម៉ង់[277]។ យ៉ាងហោចណាស់ មានពលការិនីចំនួន ៥០០.០០០ (ប្រាំសែន) នាក់ ត្រូវបានគេនាំទៅប្រទេសអាល្លឺម៉ង់ ដើម្បីធ្វើការងារជា "ពលការិនីក្នុងស្រុក" អ្នកបម្រើតាមផ្ទះ និងនៅតាមស្រែចំការ[278]។ ជាទីបញ្ចប់ គោលបំណងមួយទៀតនៃកម្មវិធីពលកម្មទាសករ យោងតាមការបញ្ជាក់របស់ជនជាប់ចោទ Hermann Wilhelm Göring[279] គឺ"សម្រាប់ហេតុផលសន្តិសុខដើម្បីកុំឱ្យពួកវាបញ្ចេញសកម្មភាពនៅក្នុងប្រទេសរបស់ពួកវា និងដើម្បីកុំឱ្យប្រឆាំងនឹងយើង"[280]។

១៣៨. ការសម្រេច ដាក់ពិរុទ្ធភាពពីបទធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយតុលាការ បានផ្អែកស្ទើរទាំងស្រុងលើតួនាទីរបស់ជនជាប់ចោទក្នុងការរៀបចំផែនការ

---

[276]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៤៧។

[277]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៤៣ ដល់ ២៤៤។

[278]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ៣៤០។

[279]តុលាការរកឃើញថា ជនជាប់ចោទ"ជាមនុស្សដែលមានការកត់សម្គាល់ជាងគេបំផុតនៅក្នុងរបបណាហ្ស៊ី"បន្ទាប់ពី Hitler, សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៧៩។

[280]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៨១។

បញ្ជា អនុវត្ត ត្រួតត្រា ឬ ចូលរួមក្នុងការផ្ទេរមនុស្ស ការជ្រើសរើសមនុស្សមកធ្វើការ និងការរំលោភបំពានជាប្រព័ន្ធលើពលករដែលមិនស្ម័គ្រចិត្ត នៅក្រោមគោលនយោបាយពលកម្មទាសកររបស់ពួកណាហ្ស៊ី (Nazi)[281]។ ពាក់ព័ន្ធនឹង*ធាតុផ្សំអត្តនោម័ត*របស់ជនជាប់ចោទ តុលាការបានយល់ឃើញថា ជនជាប់ចោទនីមួយៗសុទ្ធតែមានចេតនាចូលរួមក្នុងកម្មវិធីពលកម្មទាសករ ដោយផ្អែកលើភស្តុតាងដែលបញ្ជាក់ថា ជនជាប់ចោទបានដឹង និងបានចូលរួមដោយស្ម័គ្រចិត្តក្នុងកម្មវិធីនេះ[282]។

១៣៩. បន្ទាប់មកទៀត មានសាលក្រមជាច្រើនរបស់តុលាការយោធា Nuremberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង បានរកឃើញបន្ថែមទៀតនូវកត្តានានាទាក់ទិនទៅនឹងការកំណត់និយមន័យ នៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ នៅពេលធ្វើការពិចារណាពីអំពើធ្វើឱ្យទៅជាទាសករ ក្នុងផ្នែកនៃឧក្រិដ្ឋកម្មសង្គ្រាមនៅពេលនោះ អំពើទាំងនេះត្រូវបានគេចាត់ទុកថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងពេលជាមួយគ្នានោះដែរ[283]។ ប្រហាក់ប្រហែលទៅនឹងសាលក្រមរបស់តុលាការយោធាអន្តរជាតិដែរ ពាក់ព័ន្ធនឹងធាតុផ្សំសត្យានុម័តនៃអំពើធ្វើឱ្យទៅជាទាសករ តុលាការទាំងនេះបានពិចារណាអំពីលក្ខខណ្ឌនៃការកេណ្ឌកម្លាំងពលករ ការផ្ទេរ និងការប្រព្រឹត្តទៅលើពលករទាំងឡាយ ក្នុងកម្មវិធីពលកម្មទាសកររបស់ពួកណាហ្ស៊ី (Nazi) ជាមួយនឹងគោលបំណងនៃកម្មវិធីនេះ ក្នុងការកំណត់ ថាតើពលកម្មដោយបង្ខំ ចាត់ទុកជាអំពើធ្វើឱ្យទៅជាទាសករ[284]ដែរ ឬយ៉ាងណា។ ចំពោះ*ធាតុផ្សំអត្តនោម័ត*វិញ តុលាការបានពិចារណា

---

[281]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I,ទំព័រ ២៧៩ ដល់ ៣៤១។

[282]*សូមមើលឧទា.* សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៨១, ២៩០, ២៩៣, ២៩៦, ២៩៨, ៣០១, ៣០៦ ដល់ ៣០៧, ៣១៨ ដល់ ៣២១, ៣២៩ ដល់ ៣៣០, ៣៣៩ ដល់ ៣៤០។

[283]*សូមមើលឧទា. រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Milch*, បោះពុម្ពឡើងវិញព្រឹត្តប័ត្រស្តីពីការ*ការជំនុំជម្រះក្តីនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuernberg នៅក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, វ៉ុល II, (“*រឿងក្តី Milch*”), ទំព័រ ៧៩១។

[284]*សូមមើលឧទា. រឿងក្តី Milch* ទំព័រ ៧៧៩ ដល់ ៧៨៥ និង ទំព័រ ៧៨៩ ដល់ ៧៩០។ *រឿងក្តី Poh* , ទំព័រ ៩៧០។ *រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Flick និងជនដទៃទៀត*, បោះពុម្ពឡើងវិញព្រឹត្តប័ត្រស្តីពី*ការជំនុំជម្រះក្តីលើឧក្រិដ្ឋជន*

ថាតើជនជាប់ចោទមានចេតនា ដែរ ឬយ៉ាងណា នៅពេលដឹងពីគោលនយោបាយពលកម្មទាសករ និងបានចូលរួមដោយស្ម័គ្រចិត្តក្នុងកម្មវិធីនេះ[285]។

១៤០. ជាឧទាហរណ៍ នៅក្នុងរឿងក្តី *Milch* ជនជាប់ចោទ Erhard Milch ដែលគ្រប់គ្រងឧស្សាហកម្មយន្តហោះអាល្លឺម៉ង់[286] ត្រូវបានសម្រេចដាក់ពិរុទ្ធភាពចំពោះពលកម្មទាសករ និងការនាំមនុស្សទៅធ្វើពលកម្មទាសករ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[287]។ នៅពេលតុលាការយោធា Nuernberg បានបដិសេធពាក្យការពារខ្លួនរបស់ជនជាប់ចោទដែលបានលើកឡើងថា ពលករទាំងឡាយមានសេរីភាពក្នុងការជ្រើសរើស នៅពេលចុះ“កិច្ចសន្យាការងារ”ជាមួយឧស្សាហកម្មយោធាអាល្លឺម៉ង់ដែលតុលាការនេះ បានលើកឡើងនៅក្នុងប្រយោគដែលត្រូវបានគេលើកយកជាញឹកញាប់ថា៖

---

*សង្គ្រាម នៅចំពោះមុខតុលាការយោធា* Nuernberg *នៅក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, វ៉ុល VI, (“*រឿងក្តី Flick*”), ទំព័រ ១១៩៥ ដល់ ១១៩៦។ *រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Krauch និងជនដទៃទៀត*, បោះពុម្ពឡើងវិញក្នុងព្រឹត្តប័ត្រស្តីពី *ការជំនុំជម្រះក្តីលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuernberg នៅក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, វ៉ុល VIII, (“*រឿងក្តី I.G. Farben*”), ទំព័រ ១១៧២ ដល់ ១១៧៣។ *រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Krupp និងជនដទៃទៀត*, បោះពុម្ពឡើងវិញក្នុងព្រឹត្តប័ត្រស្តីពី *ការជំនុំជម្រះក្តីលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuernberg នៅក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, វ៉ុល IX, (“*រឿងក្តី Krupp*”), ទំព័រ ១៣៩៦ ដល់ ១៤០៩។ *រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Weizsaecker និងជនដទៃ ទៀត*, បោះពុម្ពឡើងវិញក្នុងព្រឹត្តប័ត្រស្តីពីការ *ការជំនុំជម្រះក្តីលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuernberg នៅក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, វ៉ុល XIV, (“*រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*”), ទំព័រ ៧៩៤ ដល់ ៨០០។

[285] *សូមមើលឧទា. រឿងក្តី Milch*, ទំព័រ ៧៨៥ ដល់ ៧៨៨, *រឿងក្តី Pohl*, ទំព័រ ៩៨០ ដល់ ៩៨៤, ៩៩០, ទំព័រ ៩៩៣ ដល់ ៩៩៥, ទំព័រ ៩៩៧ ដល់ ៩៩៩, ទំព័រ ១០០០ ដល់ ១០០១, ទំព័រ ១០០៥ ដល់ ១០០៩, ទំព័រ ១០១៤ ដល់ ១០១៥, ទំព័រ ១០២១ ដល់ ១០២៣, ទំព័រ ១០៤៥ ដល់ ១០៤៨, ទំព័រ ១០៥០ ដល់ ១០៥១។ *រឿងក្តី Flick*, ទំព័រ ១២០២។ *រឿងក្តី I.G Farben*, ទំព័រ ១១៧៩-១១៩៥។ *រឿងក្តី Krupp*, ទំព័រ ១៤៣៨ ដល់ ១៤៤២ និងទំព័រ ១៤៤៩។ *រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*, ទំព័រ ៨០០ ដល់ ៨៥៤។

[286] *រឿងក្តី Milch*, ទំព័រ ៧៧៩ និង ៧៨៥។

[287] *រឿងក្តី Milch*, ទំព័រ ៧៧៩ និង ៧៩០។

[ពួកជ្វីហ្វ Slavic] គឺពិតជាទាសករដែលត្រូវបានចាប់ជំរិត ចាត់ជាក្រុម និងគ្រប់គ្រងយ៉ាងតឹងរ៉ឹងឃ្លាលក្រោមការឃាមកាមពីឆ្មាំប្រដាប់អាវុធ និងត្រូវធ្វើការរហូតដល់ស្លាប់ ដោយសារជំងឺ ភាពអត់ឃ្លាន [និង] ការបាក់កម្លាំង។ (...) ចំណែកឯពលករបរទេសទាំងឡាយដែលមិនមែនជាពួកជ្វីហ្វវិញ (...) ពួកគេត្រូវបានដកហូតសិទ្ធិក្នុងការដើរហើរដោយសេរី ឬសិទ្ធិក្នុងការជ្រើសរើសលំនៅដ្ឋានរបស់ខ្លួន សិទ្ធិរស់នៅក្នុងគេហដ្ឋានជុំក្រុមគ្រួសារ សិទ្ធិចិញ្ចឹមបីបាច់ថែរក្សា និងអប់រំកូនចៅរបស់ខ្លួន សិទ្ធិរៀបការ សិទ្ធិដើរហើរទៅកាន់ទីសាធារណៈតាមចំណូលចិត្តរបស់ខ្លួន សិទ្ធិចរចាជាលក្ខណៈបុគ្គល ឬតាមរយៈអ្នកតំណាងតាមការជ្រើសរើសនូវលក្ខខណ្ឌការងាររបស់ខ្លួន សិទ្ធិក្នុងការបង្កើតសហជីព សិទ្ធិបញ្ចេញមតិ ឬទស្សនៈដោយសេរីផ្សេងៗទៀត សិទ្ធិក្នុងការប្រមូលផ្តុំគ្នាដោយអហិង្សា ហើយជាញឹកញាប់ ពួកគេត្រូវបានដកហូតសិទ្ធិក្នុងការគោរពបូជាសាសនាទៅតាមជំនឿរបស់ខ្លួន។ ទាំងអស់នេះ គឺជាសញ្ញាណនៃទាសភាព មិនមែនជាការបំពេញការងារដោយសេរីតាមកិច្ចសន្យា នោះទេ[288]។

១៤១. ពាក់ព័ន្ធទៅនឹងភស្តុតាងនៃ*ធាតុផ្សំអត្តនោម័ត*របស់ជនជាប់ចោទ ពីបទធ្វើឱ្យទៅជាទាសករ តុលាការនេះបានកត់សម្គាល់ថា ជនជាប់ចោទបានដឹងអំពីរបៀបកេណ្ឌ និងរបៀបប្រព្រឹត្តលើពលករ[289]។ ជនជាប់ចោទបានចូលរួមនៅក្នុងកិច្ចប្រជុំយ៉ាងហោចណាស់ចំនួន ១៥ ដង ដែលត្រូវបានគេលាតត្រដាងថា មានការប្រើប្រាស់នូវវិធីសាស្ត្រដ៏សាហាវឃោរឃៅ ដើម្បីបង្ខំឱ្យជនស៊ីវិលបរទេសមកធ្វើការនៅក្នុងឧស្សាហកម្មអាល្លឺម៉ង់[290]។ ម៉្យាងវិញទៀត ជនជាប់ចោទបានជំរុញដោយផ្ទាល់នូវការអនុវត្តមគោលនយោបាយដ៏តឹងរ៉ឹង និងបង្ខិតបង្ខំយ៉ាងខ្លាំងជាងមុន ដើម្បីធានានូវការផ្គត់ផ្គង់កម្លាំងពលករឱ្យបានគ្រប់គ្រាន់[291]។

១៤២. លើសពីនេះទៅទៀត នៅក្នុងរឿងក្តី *Pohl និងជនដទៃទៀត* នៅពេលសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទមួយចំនួនធំ ដែលជាសមាជិករបស់ទីស្នាក់ការកណ្តាល ("ទីស្នាក់ការ

[288] *រឿងក្តី Milch*, ទំព័រ ៧៨៩។

[289] *រឿងក្តី Milch*, ទំព័រ ៧៨៥ ដល ៧៨៧។

[290] *រឿងក្តី Milch*, ទំព័រ ៧៨៥ ដល់ ៧៨៦។

[291] *រឿងក្តី Milch*, ទំព័រ ៧៨៦ ដល់ ៧៨៧។

កណ្តាល") ដែលជានាយកដ្ឋានមួយក្នុងចំណោមនាយកដ្ឋានចម្បងៗទាំង ១២ នៃស្ថាប័នសន្តិសុខ (SS)[292] ពីបទធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តុលាការយោធា Nuernberg បានកត់សម្គាល់ថា ជនជាប់ចោទបានចាត់ទុកជនស៊ីវិលនៅប្រទេសដែលខ្លួនកាន់កាប់ ត្រូវបាននាំមកដើម្បីធ្វើពលកម្មទាសករ ថា ត្រឹមតែជា"ផ្នែកមួយនៃជ័យភណ្ឌរបស់អ្នកឈ្នះ"តែប៉ុណ្ណោះ[293]។ ក្នុងការកំណត់អំពីវិសាលភាពនៃ*ធាតុផ្សំសត្យានុម័ត* នៃអំពើធ្វើឱ្យទៅជាទាសករ តុលាការបានសន្និដ្ឋានថា ពាក់ព័ន្ធនឹងអ្នកជាប់ឃុំឃាំងក្នុងជំរំប្រមូលផ្តុំដែលត្រូវបានគេប្រើប្រាស់ជាកម្លាំងពលកម្មទាសករសម្រាប់ឧស្សាហកម្មអាល្លឺម៉ង់ "យើងអាចលុបបំបាត់ចោលរាល់ភស្តុតាងនៃការធ្វើបាប អាចមើលរំលងការស្រេកឃ្លាន ការវាយដំ និងអំពើឃោរឃៅដទៃទៀត ប៉ុន្តែ អង្គហេតុនៃទាសភាពដែលត្រូវបានទទួលស្គាល់ គឺការធ្វើពលកម្មដោយបង្ខំ និងគ្មានប្រាក់កម្រៃ នៅតែមានអត្ថិភាពដដែល។ (...) ទាសភាពដែលមិនមានការស្ម័គ្រចិត្ត នៅតែជាទាសភាពដដែល ទោះបីជាមានការប្រព្រឹត្តដោយមនុស្សធម៌ខ្លះៗក៏ដោយ"[294]។

១៤៣. ពាក់ព័ន្ធនឹង*ធាតុផ្សំអត្តនោម័ត*របស់ជនជាប់ចោទចំពោះអំពើធ្វើឱ្យទៅជាទាសករ តុលាការនេះបានកត់សម្គាល់ថា ជនជាប់ចោទ Oswald Pohl គឺជាប្រធានទីស្នាក់ការកណ្តាល (SS)[295]។ ហេតុដូច្នេះ ជនជាប់ចោទមានសមត្ថកិច្ចលើរដ្ឋបាលនៃជំរំប្រមូលផ្តុំ[296] ហើយមានតួនាទីអនុវត្ត និងពិតជាបានអនុវត្តការតាមដាន និងត្រួតត្រាយ៉ាងពេញលេញ លើការជិះជាន់កម្លាំងពលកម្មរបស់អ្នកជាប់ឃុំឃាំងក្នុងជំរំ ដើម្បីផ្គត់ផ្គង់ឧស្សាហកម្មសង្គ្រាម[297]។ តុលាការនេះក៏បានកត់សម្គាល់ផងដែរថា Pohl បានធ្វើទស្សនកិច្ចនៅតាមជំរំនានា ហើយបានដឹងលម្អិតនូវ

---

[292] *រឿងក្តី Milch*, ទំព័រ ៧៦២។

[293] *រឿងក្តី Pohl*, ទំព័រ ៩៧០។

[294] *រឿងក្តី Pohl*, ទំព័រ ៩៧០។

[295] *រឿងក្តី Pohl*, ទំព័រ ៩៨០។

[296] *រឿងក្តី Pohl*, ទំព័រ ៩៨១។

[297] *រឿងក្តី Pohl*, ទំព័រ ៩៨២ និង ៩៩០។

ហេតុការណ៍ដែលបានកើតឡើងនៅជំរំ[298]។ Pohl "បានធ្វើការជំរុញយ៉ាងសកម្ម ដើម្បីឱ្យអ្នកជាប់ឃុំឃាំងក្នុងជំរំធ្វើការឱ្យអស់ពីកម្លាំងកាយដើម្បីពន្លឿនវិស័យសេដ្ឋកិច្ច និងសឹកសង្គ្រាមរបស់ចក្រភពអាល្លឺម៉ង់ទីបី (Third Reich)"[299] ហើយ"ទាមទារបង្កើនម៉ោងការងារឱ្យបានយូរជាងមុន ការប្រឹងប្រែងខ្លាំងក្លាជាងមុន ផលិតកម្មច្រើនជាងមុន ការជ្រើសរើសជំនាញពិសេសៗ របបទំប៉ុងតិចជាងមុន និងការគ្រប់គ្រងឱ្យបានតឹងរ៉ឹងជាងមុន"[300]។ ប្រហាក់ប្រហែលគ្នានេះដែរ តុលាការនេះ បានសម្រេចដាក់ពិរុទ្ធភាពលើសមាជិកនាំមុខផ្សេងទៀតនៃទីស្នាក់ការកណ្តាលរបស់ Pohl ក្នុងនោះរួមមាន ជនជាប់ចោទ August Frank, Heinz Karl Fanslau, Hans Loerner, Georg Loerner, Erwin Tschentscher, Max Kiefer, Hans Baier និង Leo Volk ពីបទធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយហេតុថា ជនជាប់ចោទទាំងនេះ បានដឹងអំពីកម្មវិធីពលកម្មទាសករ ជាពិសេសទិសដៅនៃគោលនយោបាយរបស់កម្មវិធីនេះ វិធីសាស្ត្រនៃការកេណ្ឌពលករ និងហេតុការណ៍នានាដែលបានកើតឡើងនៅជំរំប្រមូលផ្តុំ ហើយបានជួយគ្រប់គ្រងរដ្ឋបាល ឬបានជួយសម្រួលកម្មវិធីនេះយ៉ាងសកម្ម និងប្រកបដោយការទទួលខុសត្រូវ[301]។

១៤៤. ដូចបានបង្ហាញខាងលើ ដោយហេតុថា យុត្តិសាស្ត្ររបស់តុលាការនៅក្នុងយុគសម័យ Nuremberg ផ្តោតលើធាតុផ្សំពលកម្មដោយបង្ខំ និងជាកាតព្វកិច្ចនៃអំពើធ្វើឱ្យទៅជាទាសករ ក៏ប៉ុន្តែ សំអាងហេតុទាំងនោះ ត្រូវបានគូសបញ្ជាក់ដោយការប្រកាសជាទូទៅអំពីការចាត់ទុកជនរងគ្រោះជាទំនិញ ("ជ័យភណ្ឌសង្គ្រាម"[302]ដូចគ្នាទៅនឹង"វត្ថុធាតុដើម ក៏ដូចជា ជីវជាតិនៃទឹកដីវាយដណ្តើមបាន"[303] ដែលត្រូវតែ"ជិះជាន់ពលកម្មក្នុងកម្រិតខ្លាំងក្លាបំផុត និងចំណាយ

[298] *រឿងក្តី Pohl*, ទំព័រ ៩៨៣ ដល់ ៩៨៤។

[299] *រឿងក្តី Pohl*, ទំព័រ ៩៨២។

[300] *រឿងក្តី Pohl*, ទំព័រ ៩៨២ ដល់ ៩៨៣។

[301] *រឿងក្តី Pohl*, ទំព័រ ៩៨៣ ដល់ ៩៨៥, ទំព័រ ៩៩៧ ដល់ ១០០១, ទំព័រ ១០០៤ ដល់ ១០០៩, ទំព័រ ១០១៤ ដល់ ១០១៥, ទំព័រ ១០២១ ដល់ ១០២៣, ទំព័រ ១០៤៥ ដល់ ១០៤៨, ទំព័រ ១០៥០ ដល់ ១០៥១។

[302] *រឿងក្តី Pohl*, ទំព័រ ៩៧០។

[303] សាលក្រមតុលាការយោធាអន្តរជាតិ (ITM), វ៉ុល I, ទំព័រ ២៤៧។

ឱ្យអស់តិចតួចបំផុត"[304])។ ដូច្នេះ បានបញ្ជាក់ថា ឫសគល់នៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺស្របនឹងនិយមន័យនៃអំពើទាសភាពនៅក្នុងអនុសញ្ញាស្តីពីទាសភាព។

១៤៥. នៅពេលថ្មីៗនេះ អង្គជំនុំជម្រះនានានៅតាមបណ្តាតុលាការព្រហ្មទណ្ឌអន្តរជាតិ *មិនអចិន្ត្រៃយ៍* មួយចំនួន បានវែកញែកអំពីធាតុផ្សំនៃការកំណត់និយមន័យនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងកត្តានានាដែលជាសញ្ញាណនៃ *ធាតុផ្សំសត្យានុម័ត* នៃការប្រើប្រាស់អំណាចទាំងឡាយក្នុងនាមជាម្ចាស់តាមនិយមន័យនោះ។ អង្គជំនុំជម្រះនៃតុលាការ ICTY បានធ្វើការកត់សម្គាល់អំពីការវិវឌ្ឍផ្នែកទស្សនទាននៃការធ្វើឱ្យទៅជាទាសករតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយបានព្យាយាមពង្រីកនិយមន័យនៃទាសភាព ដែលមានចែងនៅក្នុងអនុសញ្ញា និងអនុសញ្ញាបន្ថែមស្តីពីទាសភាព ព្រមទាំងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II ស្តីពីការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអនុសញ្ញា និងយុត្តិសាស្ត្រទាំងអស់នេះបង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥។

១៤៦. នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនដទៃទៀត*[305]របស់តុលាការ ICTY នៅក្នុងផ្នែកដែលពាក់ព័ន្ធ មានការចោទប្រកាន់ពីបទធ្វើឱ្យទៅជាទាសករចំពោះអំពើចាប់ស្ត្រី និងកុមារីឃុំឃាំងអស់រយៈពេលជាច្រើនខែ ដែលក្នុងពេលនោះជនរងគ្រោះត្រូវបានគេរំលោភលើផ្លូវភេទ និងបង្ខំឱ្យធ្វើការងារក្នុងផ្ទះ ព្រមទាំងឱ្យគោរពតាមបញ្ជាគ្រប់បែបយ៉ាង[306]។ នៅពេលអះអាងអំពីការកំណត់និយមន័យនៃទាសភាព ដែលមានចែងក្នុងអនុសញ្ញាស្តីពីទាសភាព អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តី *Kunarac* បានយល់ឃើញថា "នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ រួមមានការប្រើប្រាស់អំណាចណាមួយ

---

[304]សាលក្រមតុលាការយោធាអន្តរជាតិ (ITM), វ៉ុល I, ទំព័រ ២៤៥។

[305]សាលក្រមក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ៥១៨ ដល់ ៥៣៨។

[306]សាលក្រមក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ៨ ដល់ ៩។

ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស”[307]។ លើសពីនេះទៀត “*ធាតុផ្សំអត្តនោម័ត* នៃការរំលោភបំពាន គឺការអនុវត្តដោយចេតនានូវអំណាចនេះ”[308]។ អង្គជំនុំជម្រះសាលាដំបូងនេះបានបញ្ជាក់បន្ថែមទៀតថា វិសាលភាពដ៏ទូលាយនៃការធ្វើឱ្យទៅជាទាសករ គឺ“បង្ហាញឱ្យឃើញយ៉ាងជាក់លាក់នៅក្នុងរឿងក្ដីនានាចាប់ពីសង្គ្រាមលោកលើកទី II មកម្ល៉េះ (...) ដែលបានរួមបញ្ចូលនូវពលកម្មដោយបង្ខំ និងជាកាតព្វកិច្ច”[309]។ ហេតុដូច្នេះ ទោះបីជាមានការកំណត់យ៉ាងត្រឹមត្រូវក្រោយឆ្នាំ ១៩៧៩ ក៏ដោយ ក៏ការគូសបញ្ជាក់នៅក្នុងរឿងក្ដី *Kunarac* អំពីកត្តានានាពាក់ព័ន្ធនឹងការវិភាគ[310]លើអំពើធ្វើឱ្យទៅជាទាសករ ដូចដែលនឹងពិភាក្សានៅខាងក្រោមនេះ មានមូលដ្ឋានមួយផ្នែកនៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II ដែលទាមទារឱ្យអង្គជំនុំជម្រះតុលាការកំពូលងាកទៅរកយុត្តិសាស្ត្រនេះ ដើម្បីបញ្ជាក់អំពីភស្តុតាងយ៉ាងសំខាន់នៃស្ថានភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលនោះ។

១៤៧. តាមនិយមន័យក្នុងពេលបច្ចុប្បន្ននៃការធ្វើឱ្យទៅជាទាសករ ក្នុងរឿងក្ដី *Kunarac* អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា៖

> សញ្ញាណនៃអំពើធ្វើឱ្យទៅជាទាសករ ដោយរួមបញ្ចូលនូវធាតុផ្សំនៃការត្រួតត្រា និងកម្មសិទ្ធិ ការដាក់កំហិត ឬការត្រួតត្រាលើស្វ័យភាពរបស់បុគ្គល សេរីភាពក្នុងការជ្រើសរើស ឬសេរីភាពក្នុងការដើរហើរ និងជាញឹកញាប់ ការបង្កើននូវផលចំណេញមួយចំនួនដល់ចារី។ ការយល់ព្រម ឬការស្ម័គ្រចិត្តពីជនរងគ្រោះ មិនមានអត្ថិភាពឡើយ។ ឧទាហរណ៍ ជាញឹកញាប់ ការយល់ព្រម ឬការស្ម័គ្រចិត្តនេះ មិនអាចកើតមាន ឬ មិនអាចធ្វើទៅរួចនោះទេ ដោយសារមានការគំរាមកំហែង ឬ ការប្រើប្រាស់កម្លាំង ឬ ទម្រង់នៃការបង្ខិតបង្ខំដទៃៗទៀត ការភ័យខ្លាចអំពើហិង្សា ការបោកបញ្ឆោត ឬ ការសន្យាមិនពិត ការរំលោភអំណាច ស្ថានភាពងាយរងគ្រោះរបស់

[307]សាលក្រមក្នុង *រឿងក្ដី Kunarac*, កថាខណ្ឌ ៥៣៩។

[308]សាលក្រមក្នុង *រឿងក្ដី Kunarac*, កថាខណ្ឌ ៥៤០។

[309]សាលក្រមក្នុង *រឿងក្ដី Kunarac*, កថាខណ្ឌ ៥៤១។

[310]សាលក្រមក្នុង *រឿងក្ដី Kunarac*, កថាខណ្ឌ ៥៤១ ដល់ ៥៤២។

ជនរងគ្រោះ ការឃុំឃាំង ឬ ការចាប់ឃុំឃាំងតាមអំពើចិត្ត ការគាបសង្កត់ផ្លូវចិត្ត ឬ ស្ថានភាពសេដ្ឋកិច្ចសង្គម។ សញ្ញាណបន្ថែមទៀតនៃអំពើធ្វើឱ្យទៅជាទាសករ រួមមាន ការជិះជាន់កម្លាំងពលកម្ម ការកេណ្ឌកម្លាំងពលកម្ម ឬសេវាដោយបង្ខំ ឬជាកាតព្វកិច្ច ជាញឹកញាប់ ដោយមិនមានកម្រៃ និងញឹកញាប់ ទោះបីមិនចាំបាច់ក៏ដោយ ពាក់ព័ន្ធ នឹងទុក្ខលំបាកខាងផ្លូវកាយ ផ្លូវភេទ ពេស្យាចារ និងការជួញដូរមនុស្ស[311]។

១៤៨. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះនេះបានបង្ហាញនូវ "ការឯកភាពជាទូទៅ" ជាមួយនឹងកត្តានានា ដែលអយ្យការ បានផ្តល់អនុសាសន៍ ដូចខាងក្រោម៖

> ការត្រួតត្រាលើសេរីភាពក្នុងការដើរហើររបស់បុគ្គលណាម្នាក់ ការត្រួតត្រាទីកន្លែងរស់នៅ ការគាបសង្កត់ផ្លូវចិត្ត ការចាត់វិធានការទប់ស្កាត់ ឬធ្វើឱ្យពួកគេញញើតនឹងការរត់គេច អំពើហិង្សា ការគំរាមកំហែងថានឹងប្រើហិង្សា ឬការបង្ខិតបង្ខំ ការកំណត់ថិរវេលា ការអះអាងថាជាកម្មសិទ្ធិផ្តាច់មុខ ការដាក់ឱ្យឋិតនៅក្រោមការធ្វើបាប និងការបំពានឃោរឃៅ ការគាប់សង្កត់លើសេរីភាពក្នុងទំនាក់ទំនងផ្លូវភេទ និងពលកម្មដោយបង្ខំ[312]។

១៤៩. នៅពេលសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទធ្វើឱ្យទៅជាទាសករ នៅក្នុងរឿងក្តី *Kunarac* អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា អង្គហេតុនៃរឿងក្តីនេះ ដែលរួមមាន ការបម្រើការងារផ្ទះ និងការបម្រើផ្លូវភេទដោយមិនមានការស្ម័គ្រចិត្ត គឺដូចគ្នាទៅនឹងការចាត់ទុកស្ត្រីភេទ និងក្មេងស្រីជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន[313] ហើយដែលបង្កើតបានជាអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[314]។

---

[311] សាលក្រមក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ៥៤២។

[312] សាលក្រមក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ៥៤៣ (ការដកស្រង់ត្រូវបានលុបចោល)។

[313] សាលក្រមក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ៧៤២។

[314] សាលក្រមក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ៨៨៣ និងកថាខណ្ឌ ៨៨៦។ សាលក្រមក្នុង *រឿងក្តី Kunarac*, ឧបសម្ព័ន្ធ IV - ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែលើកទី ៣ (IT-96-23-PT), កថាខណ្ឌ ១០.១ ដល់ ១១.៧។

១៥០. ក្នុងរឿងក្តី *Kunarac* អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រការបង្កើតទស្សនទានស្តីពីអំពើធ្វើឱ្យទៅជាទាសកររបស់អង្គជំនុំជម្រះសាលាដំបូង និងវិធីសាស្ត្រវិភាគលើកត្តាជាច្រើនដែលមាននៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kunarac*[315] ហើយអង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា "តើហេតុការណ៍ពិសេសជាក់លាក់ណាមួយជាទម្រង់មួយនៃអំពើធ្វើឱ្យទៅជាទាសករ ដែរ ឬយ៉ាងណានោះ គឺអាស្រ័យលើអត្ថិភាពនៃកត្តានានា ឬសញ្ញាណនៃការធ្វើឱ្យទៅជាទាសករដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង"[316]។

១៥១. យុត្តិសាស្ត្រតុលាការអន្តរជាតិក្រោយៗមកទៀត ក៏បានគាំទ្រវិធីសាស្ត្រក្នុងរឿងក្តី *Kunarac* ដូចគ្នាដែរ[317]។ នាពេលថ្មីៗនេះ ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Sesay* នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា៖

> *ធាតុផ្សំសត្យានុម័ត* នៃបទល្មើសគឺថា ជនជាប់ចោទបានប្រើប្រាស់អំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្សណាម្នាក់ ឬច្រើននាក់ចំណែកឯ*ធាតុផ្សំអត្តនោម័ត* គឺជាចេតនាក្នុងការប្រើប្រាស់អំណាចបែបនេះ។ ក្នុងការសម្រេច ថាតើអំពើធ្វើឱ្យទៅជាទាសករបានកើតឡើង ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះបានពិចារណាអំពីសញ្ញាណនៃការធ្វើឱ្យទៅជាទាសករ ត្រូវបានកំណត់ដោយតុលាការ ICTY នៅក្នុងរឿងក្តី *Kunarac* និងជនជាប់ចោទផ្សេងទៀតដូចតទៅៈ "ការត្រួតត្រាលើសេរីភាពក្នុងការដើរហើររបស់បុគ្គលណាម្នាក់ ការត្រួតត្រាទីកន្លែងរស់នៅ ការគាបសង្កត់ផ្លូវចិត្ត ការចាត់វិធានការទប់ស្កាត់ ឬធ្វើឱ្យពួកគេញញើតនឹងការរត់គេច អំពើហិង្សា ការគំរាមកំហែងថានឹងប្រើហិង្សា ឬការបង្ខិតបង្ខំ ការកំណត់ចិរវេលា ការអះអាងថា

[315]សាលក្រមក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ១១៧ ដល់ ១១៨ និង កថាខណ្ឌ ១២២។

[316]សាលក្រមក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ១១៩។

[317]សាលក្រមក្នុង *រឿងក្តី Sesay*, កថាខណ្ឌ ១៩៩។ សាលក្រមក្នុង *រឿងក្តី Krnojelac*, កថាខណ្ឌ ៣៥០, កថាខណ្ឌ ៣៥៨ ដល់ ៣៥៩។

ជាកម្មសិទ្ធិផ្តាច់មុខ ការដាក់ឱ្យឋិតនៅក្រោមការធ្វើបាប និងការបំពានឃោរឃៅ ការគាបសង្កត់លើសេរីភាពក្នុងទំនាក់ទំនងផ្លូវភេទ និងពលកម្មដោយបង្ខំ"[318]។

១៥២. យោងតាមយុត្តិសាស្ត្ររបស់តុលាការដែលសមស្របបំផុតនេះ អង្គជំនុំជម្រះតុលាការកំពូលគាំទ្រនិយមន័យជាមូលដ្ឋាន នៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងថា ជានិយមន័យដែលអាចយកមកអនុវត្តបានចាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។ ដោយមាន*ធាតុផ្សំសត្យានុម័ត*នៃអំពើធ្វើឱ្យទៅជាទាសករ"ដែលត្រូវបានកំណត់ចរិតលក្ខណៈតាមរយៈការប្រើអំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស"[319] និង*ធាតុផ្សំអត្តនោម័ត*ដែលជាការប្រើប្រាស់ដោយចេតនានូវ"អំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស"[320]។ ដូចដែលបានគូសបញ្ជាក់ខាងលើ និយមន័យនេះ ត្រូវបានដកស្រង់ចេញពីអនុសញ្ញាស្តីពីទាសភាព ឆ្នាំ ១៩២៦ ដែលត្រូវបានទទួលស្គាល់ជារួមថា ជាប្រភពនៃបញ្ញត្តិមូលដ្ឋាននៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

១៥៣. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលបំភ្លឺថា ចំពោះ*ធាតុផ្សំសត្យានុម័ត* នៃនិយមន័យដែលបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូងនៅទីនេះ ច្បាប់អន្តរជាតិមិនទទួលស្គាល់ "សិទ្ធិក្នុងនាមជាម្ចាស់លើមនុស្សទេ"[321]។ ហេតុដូច្នេះ ពាក្យពេចន៍ដែលសមស្របជាងនេះ គឺ"ការប្រើប្រាស់អំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស"[322]។ ពាក្យ

---

[318]សាលក្រមក្នុង*រឿងក្តី Sesay*, កថាខណ្ឌ ១៩៨ ដល់ ១៩៩។

[319]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤២, ដកស្រង់ចេញពីសាលដីកាក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ១១៦។

[320]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៥, ដកស្រង់ចេញពីសាលដីកាក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ១១៦។

[321]សាលដីកាក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ១១៨។

[322]សាលដីកាក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ១១៨ ("មាត្រា ១(១) នៃអនុសញ្ញាស្តីពីទាសភាព ឆ្នាំ ១៩២៦ ចែងជាលក្ខណៈការពារលើបុគ្គលដែលទទួលរងនូវការប្រើប្រាស់អំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់មកលើខ្លួន"។ ពាក្យពេចន៍នេះ ត្រូវបានទទួលស្គាល់ដោយពេញចិត្ត")។

ពេចន៍នេះ ក៏មានលក្ខណៈស្របជាមួយពាក្យពេចន៍ដែលបានបញ្ញត្តិយ៉ាងច្បាស់នៅក្នុងមាត្រា ១(១) នៃអនុសញ្ញាស្តីពីទាសភាព ឆ្នាំ ១៩២៦ ដែលកំណត់និយមន័យនៃអំពើទាសភាពថា ជា "ស្ថានភាព ឬលក្ខខណ្ឌនៃមនុស្សណាម្នាក់ ដែលត្រូវបានគេប្រើប្រាស់អំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស មកលើខ្លួន"[323]។

១៥៤. ចំពោះការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូង ពីសញ្ញាណដែលទាក់ទងទៅនឹងការវិភាគលើអំពើធ្វើឱ្យទៅជាទាសករ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែលើកឡើងម្តងទៀតនូវកត្តាមួយចំនួនដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនៅក្នុងសាលក្រមក្នុងរឿងក្តី *Kunarac*[324]។ នៅពេលពិនិត្យទៅលើយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កត្តាទាំងឡាយនោះដែលត្រូវបានគូសបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូង មានការពាក់ព័ន្ធក្នុងការកំណត់ពីអត្ថិភាព នៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលថែងមានលក្ខណៈស្របនឹងលក្ខខណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។ កត្តាទាំងនោះ បានពន្យល់ច្បាស់ជាងមុន និងបានបំបែកអំពើធ្វើឱ្យទៅជាទាសករចេញពីឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀត។

១៥៥. ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជា ការលើកឡើងជាថ្មីទៀតអំពីកត្តាមួយចំនួនក្នុងរឿងក្តី *Kunarac* មានលក្ខណៈសមស្របក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង ក្នុងការវិភាគរបស់ខ្លួន ខកខានក្នុងការកំណត់ជាអាទិភាពអំពីសារៈសំខាន់នៃធាតុផ្សំទាំងពីរគឺ ធាតុផ្សំ*អត្តនោម័ត* និង*សត្យានុម័ត* នៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលសំដៅទៅលើការប្រើប្រាស់អំណាចទាំងឡាយ*ក្នុងនាមជាម្ចាស់*លើមនុស្សម្នាក់ទៀតនោះទេ។ នេះគឺមានន័យថា អង្គជំនុំជម្រះតុលាការកំពូល គាំទ្រចំពោះសាលដីកានៅក្នុងរឿងក្តី *Kunarac* ដែលថា សញ្ញាណនៃអំពើធ្វើឱ្យទៅជាទាសករ ដែលផ្តោតជាសំខាន់លើ

[323]មាត្រា ១(១) នៃអនុសញ្ញាស្តីពីទាសភាព។

[324]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤២។ សាលក្រមក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ៥៤៣។

កម្មសិទ្ធិនោះ គឺមិនមែនដូចគ្នានឹង“ទាសភាពក្នុងនាមជាម្ចាស់លើចលនវត្ថុ” នោះទេ[325]។ ទាសភាពក្នុងនាមជាម្ចាស់លើចលនវត្ថុបង្កប់ន័យនៃកម្មសិទ្ធិទាំងមូលលើមនុស្ស ហើយដើម្បីឱ្យមានស្ថេរភាពបានទាមទារ យ៉ាងហោចណាស់ឱ្យមានការទទួលស្គាល់មួយផ្នែកតូចពីសង្គម ជាពិសេសពីប្រព័ន្ធគតិយុត្តិ។ នៅក្នុងទម្រង់ដែលមានលក្ខណៈធ្ងន់ធ្ងរបំផុតនោះ ទាសភាពក្នុងនាមជាម្ចាស់លើចលនវត្ថុបានគ្របដណ្តប់រហូតដល់កម្មសិទ្ធិលើបច្ឆាញាតិ សន្តតិកម្មនៃកម្មសិទ្ធិ រួមមានតាមរយៈការផ្ទេរមរតក ទីផ្សារទាសករ ការការពារតាមច្បាប់ព្រហ្មទណ្ឌប្រឆាំងការរំលោភបំពាន។ នៅក្នុងសម័យទំនើប ដោយសារមានការថ្កោលទោសជាសាកលលើទាសភាពយន្តការ និងកាលៈទេសៈនៃសង្គម ដែលបង្កឱ្យមានអំពើធ្វើឱ្យទៅជាទាសករដោយផ្អែកលើការប្រើប្រាស់អំណាចទាំងស្រុងក្នុងនាមជាម្ចាស់ តាមស្មារតីនៃច្បាប់រដ្ឋប្បវេណី កម្រកើតមានណាស់។ ការប្រើប្រាស់អំណាចមួយចំនួនក្នុងនាមជាម្ចាស់លើមនុស្ស ជាធម្មតាអាចកើតមានតែក្នុងកម្រិតនៃសកម្មភាពឧក្រិដ្ឋ និង/ឬនៅក្នុងស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងរដ្ឋដែលដួលរលំ ឬប្រព័ន្ធគ្រប់គ្រងរដ្ឋដែលនៅទន់ខ្សោយតែប៉ុណ្ណោះ។

១៥៦. ទោះក្នុងករណីណាក៏ដោយ អំពើធ្វើឱ្យទៅជាទាសករ ចាំបាច់ត្រូវតែមានធាតុផ្សំបង្ហាញអំពីអាកប្បកិរិយាជាកម្មសិទ្ធិ ហេតុដូច្នេះ អង្គហេតុចោទប្រកាន់លើអំពើធ្វើឱ្យទៅជាទាសករ ត្រូវតែវាយតម្លៃឱ្យស្របតាមអត្ថន័យនៃកម្មសិទ្ធិដែលត្រូវបានគេយល់ថា ជាប្រភេទនៃច្បាប់រដ្ឋប្បវេណី និងសេដ្ឋកិច្ច។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះដែលពិនិត្យមើលពីសញ្ញាណនៃអំពើធ្វើឱ្យទៅជាទាសករ ជាសំខាន់នោះ ត្រូវតែកំណត់អំពីសញ្ញាណនៃ“កម្មសិទ្ធិ”គឺថា អង្គហេតុទាំងឡាយដែលចង្អុលបញ្ជាក់ថា ជនរងគ្រោះ ត្រូវបានគេបន្ទាបឋានៈមកជាទំនិញ មានន័យថាបុគ្គលនោះគឺជាកម្មវត្ថុនៃ“ការចាត់ចែង” ដែលជនរងគ្រោះជាបុរស ឬស្ត្រី ត្រូវគេប្រើប្រាស់ (ឧទាហរណ៍...ក្នុងគោលបំណងផ្លូវភេទ) ត្រូវបានគេជិះជាន់ជាប្រយោជន៍សេដ្ឋកិច្ច ត្រូវបានគេប្រើប្រាស់ក្នុងគោលបំណងសម្រាប់ដោះដូរសេវិរាង្គ ហើយទីបញ្ចប់ ត្រូវបានគេបោះចោល។ ច្បាស់ណាស់ថា ការប្រើប្រាស់អំណាចទាំងឡាយក្នុងនាមជាម្ចាស់លើមនុស្ស តម្រូវឱ្យមានការត្រួតត្រាយ៉ាងតឹងរ៉ឹងលើជនរងគ្រោះ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ អំពើធ្វើឱ្យទៅ

[325] សាលដីកាក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ១១៧។

ជាទាសករ មិនមានអត្ថិភាពឡើយនៅក្នុងករណីដែលការត្រួតត្រាមានគោលដៅមួយច្បាស់លាស់ផ្សេង ក្រៅពីការផ្តល់លទ្ធភាពឱ្យមានការប្រើប្រាស់អំណាចទាំងឡាយក្នុងនាមជាម្ចាស់។

១៥៧. ធាតុផ្សំនៃផលប្រយោជន៍សេដ្ឋកិច្ច ឬ កិច្ចខិតខំប្រឹងប្រែងដើម្បី"បង្កើន(...)ផលចំណេញ" តាមរយៈការប្រើប្រាស់អំណាចក្នុងនាមជាម្ចាស់ និងការត្រួតត្រាលើជនរងគ្រោះ[326] មានលក្ខណៈស្របជាមួយនឹងសញ្ញាណនៃកម្មសិទ្ធិដែលជាមូលដ្ឋានចំបងនៃអំពើធ្វើឱ្យទៅជាទាសករ ដែលសញ្ញាណនេះចាំបាច់ក្នុងការកំណត់និយមន័យនៃអំពើធ្វើឱ្យទៅជាទាសករ ដែលមាននៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II។ សំខាន់បំផុត ផលចំណេញសេដ្ឋកិច្ចបែបនេះ មិនចាំបាច់ទាល់តែជាប្រាក់កាស នោះទេ[327]។ យោងតាមយុត្តិសាស្ត្ររបស់តុលាការនេះ មិនមានសំអាងហេតុណាមួយដែលថា អំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលនៅក្នុងអំពើនោះកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនផលចំណេញមិនមែនជាធាតុសំខាន់ចំបងនោះទេ។ នៅក្នុងការរៀបរាប់អំពីសញ្ញាណនៃការធ្វើឱ្យទៅជាទាសករ ក្នុងរឿងក្តី *Kunarac* ធាតុផ្សំនៃផលប្រយោជន៍សេដ្ឋកិច្ច ក៏មានរៀបរាប់ផងដែរ តែមិនចាត់ទុកជាធាតុសំខាន់ឡើយ ដោយហេតុថា ការរៀបរាប់អំពីសញ្ញាណនេះ ផ្តោតព្រមគ្នាទៅលើលក្ខខណ្ឌ និងមធ្យោបាយនានានៃការត្រួតត្រាលើជនរងគ្រោះ ការអនុវត្តការត្រួតត្រា ផលប៉ះពាល់ដែលកើតចេញពីការត្រួតត្រាលើជនរងគ្រោះ និងគោលបំណងនៃការធ្វើឱ្យទៅជាទាសករ[328]។ ទោះបីជាយ៉ាងណាក៏ដោយ យុត្តិសាស្ត្ររបស់តុលាការនៅក្នុងរឿងក្តី *Kunarac* មិនងាកចេញពីទស្សនទានដែលចាត់ទុកជនរងគ្រោះថាជាទំនិញនោះឡើយ។ តាមអង្គហេតុនានានៅក្នុងរឿងក្តី *Kunarac* ជនរងគ្រោះ ពិតជាត្រូវបានចាត់ទុកថា ជាទ្រព្យសម្បត្តិ ពោលគឺ ជនរងគ្រោះ ត្រូវបានប្រើប្រាស់ក្នុងគោលបំណងផ្លូវភេទ និងត្រូវបានជិះជាន់កម្លាំងពលកម្ម

[326]សាលដីកាក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ៥៤២។

[327]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ២៨១។

[328]សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ៥៤៣។

សម្រាប់ការងារផ្ទះ[329] ហើយជនរងគ្រោះ អាចត្រូវបានប្រើប្រាស់សម្រាប់បម្រើផ្លូវភេទឱ្យអ្នកដទៃ[330] ហើយត្រូវបានបោះចោល នៅពេលណាមួយក៏បាន រួមទាំងតាមរយៈការលក់ដូរផងដែរ[331]។

១៥៨. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា នៅក្នុងការវិភាគរបស់ខ្លួនពីអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់ឱ្យបានច្បាស់ថា ធាតុផ្សំ*សត្យានុម័ត*ដែលចាំបាច់សម្រាប់អំពើធ្វើឱ្យទៅជាទាសករនៅចំពោះមុខខ្លួន គឺការខិតខំប្រឹងប្រែងក្នុងការបង្កើនផលចំណេញ តាមរយៈការប្រើប្រាស់អំណាចទាំងឡាយក្នុងនាមជាម្ចាស់លើជនរងគ្រោះនោះឡើយ។ ជាពិសេស ការផ្អែកជាមូលដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងលើការជិះជាន់កម្លាំងពលកម្ម ក្នុងន័យបដិសេធសិទ្ធិទាំងឡាយរបស់ជនរងគ្រោះ និងដាក់ឱ្យស្ថិតនៅក្រោមការត្រួតត្រាទាំងស្រុងពីសំណាក់ពួកជិះជាន់ ថាជាការសន្មតលើការរកឃើញនៃអំពើធ្វើឱ្យទៅជាទាសករ ការផ្អែកលើមូលដ្ឋានបែបនេះ គឺមានន័យថា បានទទួលស្គាល់ទស្សនទាននេះដូចគ្នា។ ដូច្នេះ ធាតុផ្សំ*អត្តនោម័ត* និង*សត្យានុម័ត*ដែលចាំបាច់នៃបទឧក្រិដ្ឋនៅចំពោះមុខខ្លួន គឺការខិតខំប្រឹងប្រែងក្នុងការបង្កើនផលចំណេញ តាមរយៈការប្រើប្រាស់អំណាចទាំងឡាយក្នុងនាមជាម្ចាស់លើជនរងគ្រោះ។ ធាតុផ្សំនៃផលចំណេញមិនមែនជាធាតុផ្សំបន្ថែមនៃបទឧក្រិដ្ឋនោះទេ ប៉ុន្តែផ្ទុយទៅវិញ គឺជាគោលបំណងដោយប្រយោលតាមរយៈការប្រើអំណាចក្នុងនាមជាម្ចាស់។

១៥៩. បន្ទាប់ពីបានបញ្ជាក់យ៉ាងច្បាស់លើការកំណត់និយមន័យនេះ អង្គជំនុំជម្រះតុលាការកំពូលនាពេលនេះ លើកយកលក្ខខណ្ឌតម្រូវបន្ថែមទៀត តាមគោលការណ៍នីត្យានុកូលភាពដែលថាជនជាប់ចោទអាចយល់ដឹងជាមុនបានគ្រប់គ្រាន់ពីអំពើល្មើសដែលត្រូវបានចោទប្រកាន់ និងច្បាប់ដែលចែងអំពីការទទួលខុសត្រូវចំពោះអំពើល្មើសនាពេលនោះ។ ទោះបីជា លក្ខខណ្ឌ

[329]សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ៨ ដល់ ៩។

[330]សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ៧៤២ និង ៧៤៩។

[331]សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ៧៥៦ និង ៧៨១។

តម្រូវនេះ ត្រូវបានកំណត់យ៉ាងត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូងក៏ដោយ[332]ក៏លក្ខខណ្ឌនេះពុំត្រូវបានអនុវត្តតាមដោយមានការវិភាគយ៉ាងហ្មត់ចត់នោះដែរ។

១៦០. អង្គជំនុំជម្រះតុលាការកំពូល គាំទ្រការបកស្រាយលក្ខខណ្ឌតម្រូវនៃភាពអាចយល់ដឹងបានជាមុនថាជាបទល្មើស ដូចដែលបានរៀបរាប់លម្អិតនៅក្នុងយុត្តិសាស្ត្រមុនៗរបស់ អ.វ.ត.ក។ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ និងដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃភាពអាចយល់ដឹងបានជាមុនថាជាបទល្មើស ជនជាប់ចោទ"ត្រូវតែមានលទ្ធភាពយល់ដឹងថា ទង្វើនេះ គឺជាបទល្មើសព្រហ្មទណ្ឌ ក្នុងន័យទូទៅ ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយឡើយ"[333]។ម្យ៉ាងវិញទៀត "ផលវិបាកនានាផ្នែកព្រហ្មទណ្ឌ ដែលអាចកើតចេញពីអំពើទាំងឡាយដូចបានចោទប្រកាន់ [ត្រូវតែ] អាចឱ្យគេយល់ដឹងបានជាមុន"[334]។ លក្ខខណ្ឌនៃការដឹងថាមានច្បាប់ចែងអាចបង្ហាញតាមរយៈអត្ថិភាពនៃសន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអាចអនុវត្តបាននៅអំឡុងពេលនោះ[335]។

១៦១. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កំណត់ហេតុនៃបទចោទ និងការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅត្រឹមឆ្នាំ ១៩៧៥។ ដូចបានកត់សម្គាល់ខាងលើ នៅក្នុងសាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) ជនជាប់ចោទ

[332]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៨។

[333]*រឿងក្តីព្រះរាជអាជ្ញា ទល់នឹង នួន ជា និងជនដទៃទៀត*, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៤៥ និង ១៤៦), "សាលដីកាលើបណ្តឹងឧទ្ធរណ៍ ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ", អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ D427/2/15 ("សាលដីកាអង្គបុរេជំនុំជម្រះលើយុត្តាធិការ"), កថាខណ្ឌ ១០៦, ដកស្រង់ចេញពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហឧក្រិដ្ឋកម្មរួម (អង្គបុរេជំនុំជម្រះ ៣៨), ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០, ឯកសារលេខ D97/15/9 ("សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋកម្មរួម"), កថាខណ្ឌ ៤៥។

[334]សាលដីកាអង្គបុរេជំនុំជម្រះលើយុត្តាធិការ, កថាខណ្ឌ ១២០។

[335]សាលដីកាអង្គបុរេជំនុំជម្រះលើយុត្តាធិការ, កថាខណ្ឌ ១០៦, ដកស្រង់ចេញពីសេចក្តីសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៤៥។

ចំនួន ១៣ នាក់ ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើឱ្យទៅជាទាសករ ទោះបីជាសាលក្រមនេះ នៅក្នុងផ្នែកជាច្រើនមិនបានញែកឱ្យដាច់ពីគ្នារវាងអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងនៅក្នុងឧក្រិដ្ឋកម្មសង្គ្រាមក៏ដោយ។ ប៉ុន្តែ ចំណុចសំខាន់បំផុតនោះគឺទង្វើរបស់ជនជាប់ចោទ Baldur Von Shirach ដែលត្រូវបានសម្រេចថា មានពិរុទ្ធភាពនោះត្រូវចាត់ចូលជាប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយ៉ាងជាក់លាក់[336]។ លើសពីនេះទៀត នៅក្នុងរឿងក្តី *Milch* តុលាការយោធា Nuernberg បានរកឃើញថា ជនជាប់ចោទមាន ពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារជនជាប់ចោទមានតួនាទីនៅក្នុងប្រព័ន្ធពលកម្មទាសកររបស់ពួកណាហ្ស៊ី (Nazi)[337]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បន្ទាប់ពីមានសាលក្រម ឬសាលដីកាដែលចេញដោយតុលាការក្រោយសង្គ្រាមលោកលើកទី II ដូចដែលបានពិភាក្សាក្នុងចំណុចខាងលើ នឹងអាចយល់ដឹងបានជាមុនថា អំពើមួយចំនួន ជាពិសេស អំពើដែលពាក់ព័ន្ធនឹងពលកម្មដោយបង្ខំអាចត្រូវបានផ្តន្ទាទោសពីបទធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥។

១៦២. បន្ថែមពីលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ច្បាប់អន្តរជាតិដែលអនុវត្តក្នុងអំឡុងពេលនោះ បានធ្វើឱ្យជនជាប់ចោទអាចដឹងបានពីអង្គហេតុនៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជាក់ស្តែងដែលថា អំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាផ្នែកមួយនៃច្បាប់អន្តរជាតិ ដែលអនុវត្តបាននៅប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧៥។ ប្រទេសកម្ពុជាបានចូលជាភាគីនៃអនុសញ្ញាបន្ថែមស្តីពីទាសភាពនៅក្នុងឆ្នាំ ១៩៥៧ ដែលក្នុងនោះ មាត្រា ៦ ចែងថា "អំពើធ្វើឱ្យបុគ្គលណាម្នាក់ទៅជាទាសករ (...) ឬ ការប៉ុនប៉ងធ្វើអំពើនេះ (...) គឺជាបទល្មើសព្រហ្មទណ្ឌ"[338]។ និយមន័យនៃទាសភាពនៅក្នុងអនុសញ្ញាបន្ថែមស្តីពីទាសភាព ដែលដូចគ្នាទៅនឹងអនុសញ្ញាស្តីពីទាសភាពបង្កើតរូបមន្ត

---

[336]សាលក្រមតុលាការយោធាអន្តរជាតិ (IMT), វ៉ុល I, ទំព័រ ៣១៨ ដល់ ៣២០។

[337] *រឿងក្តី Milch*, ទំព័រ ៨៥៧។

[338]មាត្រា ៦ នៃអនុសញ្ញាបន្ថែមស្តីពីទាសភាព។

មូលដ្ឋាននៃការធ្វើឱ្យទៅជាទាសករថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអំឡុងពេលដែលពាក់ព័ន្ធ[339]។ លើសពីនេះទៀត ដូចបានកត់សម្គាល់នៅក្នុងចំណុចខាងលើ ការធ្វើឱ្យទៅជាទាសករត្រូវបានកំណត់ថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុលោមតាមមាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) មាត្រា ៥(គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE) មាត្រា II(១)(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងគោលការណ៍ VI(គ) នៃគោលការណ៍ Nuremberg ឆ្នាំ ១៩៥០។ *ការសម្រេច*របស់មហាសន្និបាតនៅក្នុងឆ្នាំ ១៩៤៦ *លើគោលការណ៍នេះ* និងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានអនុម័តដោយគណៈកម្មការនីតិអន្តរជាតិ (ILC) នៅក្នុងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ អនុលោមតាមសេចក្តីសម្រេចលេខ ១៧៧ (II) ត្រង់កថាខណ្ឌ (ក) របស់មហាសន្និបាតអង្គការសហប្រជាជាតិ បានឆ្លុះបញ្ចាំងនូវគោលការណ៍ទូទៅ នៃច្បាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនាពេលនោះ[340]។ ផ្អែកលើការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជនជាប់ចោទអាចយល់ដឹងជាមុនថាជាបទឧក្រិដ្ឋ និងអាចដឹងថាមានច្បាប់ចែងថា ខ្លួនអាចត្រូវបានតុលាការចោទប្រកាន់អំពីការធ្វើឱ្យទៅជាទាសករ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។

## ៤.គ.២.ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ និងអំពើធ្វើឱ្យទៅជាទាសករ

១៦៣. ជាចុងក្រោយ ដោយផ្អែកលើសំអាងហេតុពាក់ព័ន្ធទៅនឹងមន្ទីរ ស ២១ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិចារណា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការខកខានដាក់ពិរុទ្ធភាពលើជនជាប់ចោទពីអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធទៅនឹងអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១។ ដូចបានលើកឡើងខាងលើរួចហើយ ទោះបីជាមានហេតុ

---

[339]មាត្រា ៧(ក) នៃអនុសញ្ញាបន្ថែមស្តីពីទាសភាព។

[340]គោលការណ៍ទី VI (គ) នៃគោលការណ៍ Nuremberg ឆ្នាំ ១៩៥០។

ផលសមស្របសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការកម្រិត នូវការស៊ើបអង្កេតរបស់ខ្លួនទៅលើតែអ្នកជាប់ឃុំឃាំងទាំងឡាយ ដែលបានទទួលរងនូវពលកម្មដោយបង្ខំ ជាពិសេសដូចមាននៅក្នុងអំពើដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយក៏ដោយ[341] ក៏អង្គជំនុំជម្រះសាលាដំបូងមិនមានកាតព្វកិច្ចក្នុងការកម្រិតខ្លួនឯង ចំពោះអង្គហេតុទាំងនោះឡើយ។ វិធាន ៩៨(២) នៃវិធានផ្ទៃក្នុងចែងថា "សាលក្រមត្រូវសម្រេចតែលើអង្គហេតុណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប៉ុណ្ណោះ"[342]។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងអាច "ផ្លាស់ប្តូរការកំណត់បទចោទ ដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន"។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងអាចបំពេញកិច្ចទៅតាមអំណាចរបស់ខ្លួននៅពេលពិនិត្យយ៉ាងហ្មត់ចត់លើកំណត់ត្រាអង្គហេតុទាំងអស់ ដើម្បីស្វែងរកសញ្ញាណនៃការធ្វើឱ្យទៅជាទាសករ។ ដោយសារនាពេលនេះ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសនៅក្នុងការកម្រិតសំអាងហេតុរបស់ខ្លួនចំពោះអំពើធ្វើឱ្យទៅជាទាសករ ពាក់ព័ន្ធទៅនឹងអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ដែលបានទទួលរងពលកម្មដោយបង្ខំ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងដោះស្រាយបញ្ហានេះ ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមនិយមន័យសមស្រប នៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានរៀបរាប់ខាងលើ។

១៦៤. តាមរយៈការទទួលស្គាល់របស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់នូវសំអាងហេតុពាក់ព័ន្ធនឹងអ្នកជាប់ឃុំឃាំងទាំងឡាយ ដែលមិនបានទទួលរងនូវពលកម្មដោយបង្ខំ ដោយបានបង្ហាញតែអំពីការគ្រប់គ្រងដោយចេតនា"ទៅលើសកម្មភាពរបស់អ្នកជាប់ឃុំឃាំង លើស្ថានភាពផ្លូវកាយ ផ្លូវចិត្ត វិធានការនានាដើម្បីទប់ស្កាត់ ឬធ្វើឱ្យខ្លាចរអែងក្នុងការរត់គេច ការគំរាមកំហែងថានឹងប្រើហិង្សា ឬការបង្ខិតបង្ខំ ឬការដាក់ឱ្យឋិតនៅក្រោមការគ្រប់

---

[341]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២២៥, ដកស្រង់ចេញពីដីកាដំណោះស្រាយ ដែលត្រូវបានកែប្រែ, កថាខណ្ឌ ១៣៥។

[342]វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។

គ្រង និងការបំពានយ៉ាងសាហាវ"[343]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានយ៉ាងច្បាស់ថា ជនជាប់ចោទជាអ្នកទទួលខុសត្រូវលើការឃុំឃាំងជនរងគ្រោះ"ដោយដាក់ច្រវ៉ាក់ និងដាក់ខ្នោះជើងភ្ជាប់ទៅនឹងរនងដែកនៅក្នុងបន្ទប់ឃុំខ្លួន" "ក្រោមការយាមកាមពីសំណាក់អ្នកយាមប្រដាប់ដោយអាវុធជាប់ជាប្រចាំ" និង"ដោយដាក់ខ្នោះដៃ និងចងមុខអ្នកជាប់ឃុំឃាំងជានិច្ច"នៅពេលគេយកចេញ[344] និង"ការហូបមិនគ្រប់គ្រាន់"[345] និងមិនអាច"ងូតទឹកតាមលក្ខណៈអនាម័យបាន"[346] និងការបន្ទាបបន្ថោកបង្ខំឱ្យ"នោម និងបន្ទោរបង់ក្នុងបន្ទប់ឃុំឃាំងរបស់ពួកគេ"[347] "ធ្វើឱ្យចុះខ្សោយ (...) សុខភាពផ្លូវចិត្ត (...) និងស្ថានភាពភ័យខ្លាចជានិច្ច" ដោយសារ"ស្ថានភាពរស់នៅដែលរួមបញ្ចូលទាំងការឃុំខ្លួន ការសួរចម្លើយ និងការបាត់ខ្លួនអ្នកជាប់ឃុំឃាំង"[348]"ស្នាមវាយ ស្នាមដាច់ ស្នាមជាំ និងស្នាមមុត"ពីកន្លែងសួរចម្លើយ[349] ការដកហូតសិទ្ធិជាមូលដ្ឋានទាំងអស់ ការធ្វើទារុណកម្ម និងការសម្លាប់[350]។

១៦៥. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គហេតុដែលបានរៀបរាប់លម្អិតខាងលើ គឺជាសញ្ញាបញ្ជាក់ពីអត្ថិភាពនៃគោលនយោបាយនៃការធ្វើទារុណកម្ម និងការសម្លាប់រង្គាល ដែលការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើបាប គឺជាមធ្យោបាយដើម្បីសម្រេចនូវ គោលដៅទាំងពីរនេះ[351]។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញទៀតថា អង្គហេតុដូចបានរៀបរាប់លម្អិតខាងលើ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងធ្វើការវិភាគយ៉ាងពេញលេញ ក្នុងការសម្រេចដាក់ឱ្យជនជាប់ចោទទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំង

---

[343]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០៧ (ការដកស្រង់ត្រូវបានលុបចោល)។

[344]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៦០ និង ២៦៣។

[345]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៦៨។

[346]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៧០។

[347]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៧២។

[348]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៥៨។

[349]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៦៤។

[350]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២០៨, ២៤១, ២៥៩។

[351]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២០៥ ដល់ ២០៦ និង ៣៤៦។

មនុស្សជាតិទាក់ទងនឹងការសម្លាប់រង្គាល (ដោយស្រូបបញ្ចូលនូវអំពើ មនុស្សឃាត) ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញ[352]។ ក៏ប៉ុន្តែ ពុំមានចំណុចណាមួយនៅក្នុងសំអាងហេតុទាំងនេះ បង្ហាញនូវភស្តុតាងនៃការខិតខំរបស់ជនជាប់ចោទនៅក្នុងការទទួលផលចំណេញមួយចំនួនសម្រាប់ខ្លួន ពីជនជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស ២១ ឬ បើមិនដូច្នោះទេ បង្ហាញនូវការចាត់ទុកអ្នកជាប់ឃុំឃាំងទាំងអស់នោះជាទំនិញឡើយ។

១៦៦. ផ្ទុយទៅវិញ ចំពោះអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២៤ វិញ ទោះបីជាជនទាំងនេះត្រូវបានគេឃុំឃាំង ដាក់ខ្នោះជើងនៅពេលយប់ បន្ទាបបន្ថោក និងការធ្វើបាបយ៉ាងសាហាវក៏ដោយ[353] ក៏គោលបំណងទាំងមូលនៃការអនុវត្តការគ្រប់គ្រងលើពួកគេ គឺមិនមែនដើម្បីឱ្យពួកគេស្លាប់នោះទេ ក៏ប៉ុន្តែ ដើម្បី"កែប្រែ និងកសាងយុទ្ធជន ព្រមទាំងធ្វើស្រែដើម្បីផ្គត់ផ្គង់មន្ទីរ ស ២១ និងសាខានានា"[354]។ ករណីនេះដូចគ្នាទៅនឹងជនជាប់ឃុំឃាំងនៅមន្ទីរ ស ២១ មួយក្រុមតូចដែលត្រូវបានគេជ្រើសរើសដើម្បីឱ្យធ្វើពលកម្មដោយបង្ខំ ដែលបានទទួលស្ថានភាពប្រសើរជាងជនជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ដទៃទៀត និងគួរឱ្យកត់សំគាល់នោះ គឺពួកគាត់នៅរស់រានមានជីវិត[355]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា បើទោះជាអំពើរបស់ជនជាប់ចោទលើជនជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ដូចបានលើកឡើងលម្អិតនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាអំពើឧក្រិដ្ឋក៏ដោយ ក៏អំពើបែបនេះដែលពាក់ព័ន្ធនឹងជនជាប់ឃុំឃាំងមិនទទួលរងនូវពលកម្មដោយបង្ខំ មិនបង្កើតជាការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុស នៅក្នុងការថែងក្នុងសំអាងហេតុរបស់ខ្លួនលើការធ្វើឱ្យទៅជា

---

[352]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤១, ៣៥១, ៣៦០, ៣៧២ ដល់ ៣៧៣, ៣៨៩ ដល់ ៣៩០។

[353]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២២៧, ២២៩ ដល់ ២៣០។

[354]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២២៦។

[355]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៣២ ដល់ ២៣៣។

ទាសករដែលសំដៅទៅតែលើជនជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ដែលបានទទួលរងនូវពលកម្ម ដោយបង្ខំឡើយ។

## ៤.គ.៣.សេចក្តីសន្និដ្ឋាន

១៦៧. ផ្អែកតាមមូលដ្ឋានដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោល ទឡ្ហីករណ៍ទី ៣ នៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អ.វ.ត.ក/អ.ជ.ត.ក
ឯកសារលេខ F28

# ៤.ឃ.ការរំលោភលើផ្លូវភេទ គឺជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ (ទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា)

១៦៨. ទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយបានកំណត់យកអំពើរំលោភលើផ្លូវភេទដែលបានប្រព្រឹត្តនៅមន្ទីរ ស ២១ ថាជាប្រភេទមួយនៃអំពើធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[356]។ ទោះបីជា សហព្រះរាជអាជ្ញាទទួលស្គាល់យុត្តិសាស្ត្រតុលាការអន្តរជាតិដែលបានកំណត់ថា "អំពើរំលោភលើផ្លូវភេទអាចជាអំពើធ្វើទារុណកម្ម"ក៏ដោយ ក៏សហព្រះរាជអាជ្ញាលើកអំណះអំណាងថា "តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានាបានកំណត់ដោយស្របគ្នាថា អំពើរំលោភលើផ្លូវភេទ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដាច់ដោយឡែកពីអំពើធ្វើទារុណកម្ម ទោះបីជាអំពើនេះ បង្កើតបានជាបទរំលោភលើផ្លូវភេទផង និងអំពើធ្វើទារុណកម្មផងក៏ដោយ"[357] ហេតុដូចនេះ ជា"ការឆ្លុះបញ្ចាំងយ៉ាងពេញលេញអំពីស្ថានទម្ងន់នៃបទល្មើស"[358]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាលើជនជាប់ចោទពីបទរំលោភលើផ្លូវភេទ និងបទធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[359]។

១៦៩. អង្គជំនុំជម្រះតុលាការកំពូលសូមរំឭកថា អ.វ.ត.ក មានយុត្តាធិការលើរឿងក្តីចំពោះ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (...) មានជាអាទិ៍៖ (...) ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ (...)"[360] ដោយអនុលោមតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

---

[356]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣៣។

[357]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩៦។

[358]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩៧។

[359]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០០។

[360]មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

១៧០. នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានរកឃើញនូវអង្គហេតុនៃការរំលោភលើផ្លូវភេទចំនួនមួយករណីត្រូវបានបង្ហាញដោយសហព្រះរាជអាជ្ញា៖

> ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ក៏បានបង្ហាញផងដែរថា មានភស្តុតាង យ៉ាងហោចណាស់ក៏មួយករណីដែរ អំពីការរំលោភលើផ្លូវភេទដែលត្រូវបានប្រព្រឹត្តនៅមន្ទីរ ស ២១។ ជនជាប់ចោទបានទទួលស្គាល់ថា នៅក្នុងពេលសួរចម្លើយ បុគ្គលិកមន្ទីរស ២១ ម្នាក់ បានយកឈើរុកចូលក្នុងយោនីរបស់អ្នកជាប់ឃុំឃាំងម្នាក់។ (...) អង្គជំនុំជម្រះយល់ឃើញថា អង្គហេតុនេះ មានភស្តុតាងបញ្ជាក់តាមបទដ្ឋានតម្រូវពិតប្រាកដមែន[361]។

១៧១. ដោយគូសបញ្ជាក់អំពីច្បាប់ដែលត្រូវយកមកអនុវត្តទាក់ទងនឹងការរំលោភលើផ្លូវភេទ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ការរំលោភលើផ្លូវភេទ ត្រូវបានហាមឃាត់ជាយូរយារណាស់មកហើយ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ (...)"[362] ហើយក៏បានយល់ឃើញថែមទៀតថា៖

> ទោះបីការរំលោភលើផ្លូវភេទ គឺជាបទល្មើសដាច់ដោយឡែក និងត្រូវបានគេទទួលស្គាល់ទាំងនៅក្នុងច្បាប់ អ.វ.ត.ក និងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ក៏មិនមានការជំទាស់នោះទេដែលថា ការរំលោភលើផ្លូវភេទ អាចបង្កើតបានជាការធ្វើទារុណកម្ម នៅពេលដែលធាតុផ្សំផ្សេងៗទៀតនៃអំពើធ្វើទារុណកម្ម ត្រូវបានបំពេញ (ផ្នែក ២.៥.៣.៧)។ អង្គជំនុំជម្រះយល់ឃើញថា អំពើដែលបានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ដែលបង្កើតបានជាការរំលោភលើផ្លូវភេទ គឺវាបានបំពេញយ៉ាងច្បាស់នូវធាតុផ្សំផ្លូវច្បាប់ទាំងបទល្មើសការរំលោភលើផ្លូវភេទ និងការធ្វើទារុណកម្ម។ លើសពីនេះទៀត អង្គជំនុំជម្រះ ក៏បានវាយតម្លៃទៅលើភស្តុតាងដែលអាចជឿជាក់បាន ដើម្បីគាំទ្រចំពោះការចោទប្រកាន់នេះផងដែរ (ផ្នែក ២.៤.៤.១.១)។ អង្គជំនុំជម្រះយល់ឃើញថា ករណីការរំលោភលើផ្លូវភេទនេះ បង្កើត

[361] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៤៦។

[362] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៦១។

ឱ្យមាននូវភាពធ្ងន់ធ្ងរនៃការធ្វើទារុណកម្មរយៈពេលយូរ និងមានភាពព្រៃផ្សៃមុនពេលដែលគាត់ត្រូវបានគេយកទៅសម្លាប់ ដូច្នេះ ចរិតលក្ខណៈនៃអំពើនេះបង្កើតបានជាបទល្មើសការធ្វើទារុណកម្ម[363]។

១៧២. បន្ទាប់មកទៀត អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ទាក់ទិននឹងអង្គហេតុនៃការរំលោភលើផ្លូវភេទមួយករណីដែលមានភស្តុតាងបញ្ជាក់នេះ ជនជាប់ចោទត្រូវទទួលខុសត្រូវពីបទធ្វើទារុណកម្ម ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (រួមទាំងការរំលោភលើផ្លូវភេទផងដែរ) ដោយអនុលោមតាមមាត្រា ៥ និងមាត្រា ២៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ អង្គជំនុំជម្រះសាលាដំបូង មិនបានសម្រេចឱ្យជនជាប់ចោទទទួលខុសត្រូវពីបទរំលោភលើផ្លូវភេទ ដែលជាបទល្មើសមួយដាច់ដោយឡែក នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ[364]។

១៧៣. ដើម្បីដោះស្រាយផ្នែកនេះក្នុងទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលពិចារណាបញ្ហាចោទចំពោះមុខដែលត្រូវដោះស្រាយ មានដូចតទៅៈ ១) ដោយពិចារណាអំពីគោលការណ៍នីត្យានុកូលភាព ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសម្រេចថា ការរំលោភលើផ្លូវភេទ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលស្ថិតនៅក្នុងយុត្តាធិការលើរឿងក្តីរបស់អ.វ.ត.ក ចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរ ឬយ៉ាងណា។ ២) ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសចំពោះ ករណីខាងលើនេះទេ ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ចំពោះការដែលខ្លួនខកខានក្នុងការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា លើជនជាប់ចោទពីបទល្មើសដាច់ដោយឡែកពីគ្នារវាងបទរំលោភលើផ្លូវភេទនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាមួយនឹងបទធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះអង្គហេតុនៃការរំលោភលើផ្លូវភេទដែលបានកើតឡើងនៅមន្ទីរស ២១។ និង ៣) ថាតើអង្គជំនុំជម្រះសាលាដំបូង មានកំហុស ដែរ ឬយ៉ាងណា ចំពោះការសម្រេចស្រូបបញ្ចូលបទរំលោភលើផ្លូវភេទ ទៅក្នុងបទធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្ថិតនៅក្នុងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក ក្នុង

[363]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៦៦។

[364]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧៧។

អំឡុងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។ អង្គជំនុំជម្រះតុលាការកំពូលនឹងដោះស្រាយបញ្ហាចោទនីមួយៗ ដូចខាងក្រោមៈ

## ៤.ឃ.១. ការរំលោភលើផ្លូវភេទគឺជាបទឧក្រិដ្ឋមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

១៧៤. ចំពោះបញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការរំលោភលើផ្លូវភេទ គឺជាបទល្មើសមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលស្ថិតនៅក្នុងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ដូចដែលបានកត់សម្គាល់ពីមុនមក ការអនុវត្តយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងស្របតាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវគោរពគោលការណ៍នីត្យានុកូលភាពដែលមានចែងក្នុងមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[365]។ អង្គជំនុំជម្រះតុលាការកំពូល មិនអាចចាត់ទុកបទរំលោភលើផ្លូវភេទថា ជាបទល្មើសមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកតែលើស្ថានទម្ងន់នៃបទល្មើសតែមួយនោះឡើយ។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលក៏ត្រូវពិនិត្យផងដែរ ថាតើការរំលោភលើផ្លូវភេទ គឺជាបទឧក្រិដ្ឋមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកតាមច្បាប់អន្តរជាតិ ឬច្បាប់ជាតិ ឬ គោលការណ៍ទូទៅនៃច្បាប់នៅពេលប្រព្រឹត្តបទឧក្រិដ្ឋក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរ ឬយ៉ាងណា។

១៧៥. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ចាប់តាំងពីពេលចាប់ផ្តើមអនុវត្តយុត្តាធិការពេលវេលារបស់ អ.វ.ត.ក មក ការហាមឃាត់អំពើរំលោភលើផ្លូវភេទដែលជាឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានធ្វើឡើងជាយូរមកហើយតាមច្បាប់អន្តរជាតិ[366] ទោះបីជា មិនមានច្បាប់ចែងច្បាស់

---

[365]មាត្រា ៣៣ ថ្មី ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (យោងទៅលើមាត្រា ១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធពលរដ្ឋ និងនយោបាយ (ICCPR))។

[366]*សេចក្តីណែនាំសម្រាប់កងទ័ពរដ្ឋាភិបាលសហរដ្ឋអាមេរិកនៅសមរភូមិ*, រៀបរៀងដោយ Francis Lieber, ត្រូវបានប្រកាសឲ្យប្រើជាបទបញ្ជាលេខ ១០០ ដោយប្រធានាធិបតី Abraham Lincoln នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី, ចុះថ្ងៃទី

លាស់ក៏ដោយ[367]។ ការរំលោភលើផ្លូវភេទ ត្រូវបានហាមឃាត់យ៉ាងច្បាស់នៅក្នុងជម្លោះប្រដាប់អាវុធ យោងតាមអនុសញ្ញាទីក្រុងហ្សឺណែវ IV ឆ្នាំ ១៩៤៩[368] ព្រមទាំងពិធីសារបន្ថែម I[369] និង II[370] ឆ្នាំ ១៩៧៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩។ ទោះបីជាធម្មនុញ្ញ

---

២៤ ខែ មេសា ឆ្នាំ ១៨៦៣, ("ក្រម Lieber"), មាត្រា ៤៤ ចែងថា៖ ("អំពើហិង្សាដោយគ្មានត្រាប្រណីទាំងអស់ដែលប្រព្រឹត្តលើជននៅក្នុងប្រទេសដែលខ្លួនឈ្លានពាន (...) *ការរំលោភលើផ្លូវភេទ*ទាំងអស់ ការរងរបួស ការធ្វើឲ្យពិការ ឬការសម្លាប់អ្នកស្រុកនៃប្រទេសខ្លួនឈ្លានពានត្រូវបានហាមឃាត់ក្រោមការដាក់ទោសទណ្ឌប្រហារជីវិត ឬការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរដែលអាចសមល្មមចំពោះភាពធ្ងន់ធ្ងរនៃបទល្មើស") (គូសបញ្ជាក់បន្ថែម)។ មាត្រា ៤៩ នៃ*ច្បាប់សង្គ្រាមផ្លូវគោក* ទីក្រុង Oxford ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៨៨០ ("សៀវភៅណែនាំរបស់ Oxford")។ មាត្រា ៣៨ នៃ*គម្រោងនៃសេចក្តីប្រកាសអន្តរជាតិពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាម*, ទីក្រុង Brussels ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៨៧៤ ("សេចក្តីប្រកាស Brussels")។ មាត្រា ៤៦ នៃបទបញ្ជា Hague ពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមផ្លូវគោក ដែលភ្ជាប់ជាឧបសម្ព័ន្ធអនុសញ្ញា (IV) ទាក់ទងនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមផ្លូវគោក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ ("បទបញ្ជាទីក្រុង Hague ឆ្នាំ ១៩០៧")។ មាត្រា ៤៦ នៃបទបញ្ជា Hague ពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមផ្លូវគោក ដែលភ្ជាប់ជាឧបសម្ព័ន្ធអនុសញ្ញា (II) ទាក់ទងនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមផ្លូវគោក ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ ("បទបញ្ជាទីក្រុង Hague ឆ្នាំ ១៨៩៩")។ បុព្វកថានៃអនុសញ្ញាទីក្រុង Hague ឆ្នាំ ១៨៩៩។ បុព្វកថានៃអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៩០៧ ("រហូតដល់ចេញក្រមពេញលេញនៃច្បាប់សង្គ្រាមសិន រដ្ឋជាភាគីយល់ថាត្រឹមត្រូវក្នុងការប្រកាសថា នៅក្នុងករណីដែលមិនមានចែងនៅក្នុងបទបញ្ជាដែលអនុម័តដោយរដ្ឋជាភាគី ប្រជាជន និងអ្នកឈ្លានពាន ត្រូវស្ថិតក្រោមការការពារ និងបណ្តាំនៃគោលការណ៍ច្បាប់អន្តរជាតិ ដោយសារតែវាចេញមកពីការអនុវត្តដែលបង្កើតឡើងដោយប្រជាជាតិមានអរិយធម៌ ចេញមកពីច្បាប់មនុស្សធម៌ និងលក្ខខណ្ឌតម្រូវនៃមនសិការរបស់សាធារណជន")។

[367]ព្រឹត្តប័ត្រនិពន្ធដោយ M. Cherif Bassiouni, *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, បោះពុម្ពផ្សាយលើកទីពីរ, ទំព័រ ៣៤៨ (ចង្អុលបង្ហាញអំពីជម្រើសនៃការប្រើពាក្យ ដើម្បីអធិប្បាយការរំលោភលើផ្លូវភេទ)។

[368]មាត្រា ២៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម អនុម័តនៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩, វ៉ុល ៧៥ លេខលំដាប់សន្ធិសញ្ញាអង្គការសហប្រជាជាតិ ទំព័រ ២៨៧ (ចូលជាធរមានថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០), ("អនុសញ្ញាទីក្រុងហ្សឺណែវ IV ឆ្នាំ ១៩៤៩")។

[369]មាត្រា ៧៦(១) នៃពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងទាក់ទិនទៅ នឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ អនុម័តថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧, វ៉ុល ១១២៥ លេខលំដាប់សន្ធិសញ្ញាអង្គការសហប្រជាជាតិ ទំព័រ ៣ (ចូលជាធរមានថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៧៨), ("ពិធីសារបន្ថែម I លើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩")។

តុលាការយោធាអន្តរជាតិ (IMT) ធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE) និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង មិនបានចាត់ទុកការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មសង្គ្រាម ក៏ដោយ ក៏តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE) និងគណៈកម្មាធិការយោធារបស់សហរដ្ឋអាមេរិក បានសម្រេចដាក់ពិរុទ្ធភាពលើមេដឹកនាំជប៉ុន ដូចជាឧត្តមសេនីយ៍ Iwane Matsui និងរដ្ឋមន្ត្រីការបរទេស Kōki Hirota ពីបទឧក្រិដ្ឋកម្មសង្គ្រាម ដោយសារតែខកខានក្នុងការរារាំងកងកម្លាំងយោធា ដែលស្ថិតក្រោមបង្គាប់របស់ខ្លួន ពីការរំលោភលើផ្លូវភេទទៅលើស្ត្រីប្រហែល ២០.០០០ នាក់ នៅណានឃីង (Nanking) ដែរ[371]។

១៧៦. ហេតុនេះ ទោះបីជាការរំលោភលើផ្លូវភេទត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មមួយនៅក្នុងឧក្រិដ្ឋកម្មសង្គ្រាមត្រឹមឆ្នាំ ១៩៧៥ ក៏ដោយ ក៏ចំណាត់ថ្នាក់របស់វានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយយោងតាមច្បាប់អន្តរជាតិ ពុំទាន់លេចចេញជារូបរាងពិតប្រាកដនៅឡើយទេ។ ទោះបីជា ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងបានចែងថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោយសង្គ្រាមលោកលើកទី II[372] ក៏ដោយ "ក៏មិនមានជនជាប់ចោទណា

---

[370]មាត្រា ៤(២)(ង) នៃពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងទាក់ទិនទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ អនុម័តថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧, វ៉ុល ១១២៥ លេខលំដាប់សន្ធិសញ្ញាអង្គការសហប្រជាជាតិ ទំព័រ ៦០៩ (1125 UNTS 609) (ចូលជាធរមានថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៧៨), ("ពិធីសារបន្ថែម II លើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩")។

[371]ចំពោះ"ការរំលោភលើផ្លូវភេទនៅ Nanking" និងការរំលោភលើផ្លូវភេទជាទូទៅ, សូមមើលការចេញផ្សាយរបស់ Neil Boister និង Robert Cryer, មានចំណងជើងថា៖ ឯកសារស្តីពីតុលាការយោធាអន្តរជាតិតូក្យូ៖ *ធម្មនុញ្ញ ការចោទប្រកាន់ និងសាលក្រម*, ទំព័រ ៥៣៥ ដល់ ៥៣៩, ៦០៤, ៦១២។ *សូមមើលផងដែរ*ការជំនុំជម្រះក្តីឧត្តមសេនីយ Tomoyuki Yamashita, សំណុំរឿងលេខ ២១, គណៈកម្មាធិការយោធាសហរដ្ឋអាមេរិក, ទីក្រុងម៉ានីល (Manila), ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៤៥, ដូចដែលត្រូវបានបោះពុម្ពឡើងវិញនៅក្នុង*របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម*, ត្រូវបានជ្រើសរើស និងរៀបចំដោយគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ, វ៉ុល IV, បោះពុម្ពនៅទីក្រុងឡុងដ៍ ឆ្នាំ ១៩៤៨។ *រឿងក្តី In re Yamashita*, វ៉ុល ៣២៧ U.S. ទំព័រ ១ (ឆ្នាំ ១៩៤៦) លេខទិន្នន័យ (LexisNexis)។

[372]មាត្រា II(១)(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។

មួយនៅចំពោះមុខតុលាការយោធា (NMT) ត្រូវបានដាក់ពិរុទ្ធភាពពីបទរំលោភលើផ្លូវភេទឡើយ[373]"។ បន្ថែមពីលើនេះ ទាំងធម្មនុញ្ញតុលាការយោធាអន្តរជាតិ ឬធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE) មិនបានចាត់ទុកការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ។ ដូច្នេះ ទោះបីជា ភស្តុតាងអំពីការរំលោភលើផ្លូវភេទត្រូវបានលើកឡើងក្នុងកំណត់ហេតុដោយរដ្ឋអាជ្ញាចំពោះមុខតុលាការយោធាអន្តរជាតិ (IMT)[374]ក៏ដោយ ក៏ប៉ុន្តែតុលាការនេះមិនបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទណាមួយ ចំពោះឧក្រិដ្ឋកម្មនេះដែរ។ ករណីដូចគ្នានេះ ក៏ត្រូវបានអនុវត្តនៅក្នុងដំណើរការនីតិវិធីចំពោះមុខតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE) ផងដែរ។ ជាលទ្ធផល ការរំលោភលើផ្លូវភេទនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រូវបានដាក់បញ្ចូលទៅក្នុងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ នោះទេ។ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់បន្ថែមថា ត្រឹមឆ្នាំ ១៩៧៥ និងរហូតដល់ឆ្នាំ ១៩៧៩ គ្មានសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិណាមួយ ត្រូវបានអនុម័តដើម្បីហាមឃាត់ការរំលោភលើផ្លូវភេទ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះទេ។

១៧៧. បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា បានដកស្រង់ករណីមួយចំនួនពីតុលាការព្រហ្មទណ្ឌអន្តរជាតិ *មិនអចិន្ត្រៃយ៍*យកមកធ្វើជាសំអាងផ្លូវច្បាប់ សម្រាប់ការអះអាងដែលថា "'អាស្រ័យទៅលើកាលៈទេសៈនានាតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ការរំលោភលើផ្លូវភេទអាចនឹងទទួលបាននូវឋានៈជាឧក្រិដ្ឋកម្មមួយផ្សេងពីការធ្វើទារុណកម្ម"[375] ព្រមទាំងជាបទល្មើសមួយដាច់

---

[373]ព្រឹត្តប័ត្រនិពន្ធដោយ Kevin Jon Heller, *តុលាការយោធា Nuremberg និង ដើមកំណើតនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* ចេញផ្សាយដោយសាកលវិទ្យាល័យ Oxford, ឆ្នាំ ២០១១, ទំព័រ ៣៨១។

[374]ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៤៦។ សាលក្រមតុលាការយោធាអន្តរជាតិ, វ៉ុល VI, ទំព័រ ៤០៤ ដល់ ៤០៧។ ប្រតិចារឹក ចុះថ្ងៃទី ១៤ កុម្ភៈ ឆ្នាំ ១៩៤៦, សាលក្រមតុលាការយោធាអន្តរជាតិ, វ៉ុល VII, ទំព័រ ៤៥៦ ដល់ ៤៥៧ (អានជាឯកសារភស្តុតាង "កំណត់ត្រា Molotov" ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៤២)។

[375]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩៤, ដកស្រង់ចេញពី*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Furundžija,* សំណុំរឿងលេខ IT-95-17/1-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨, ("សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Furundžija*"), កថាខណ្ឌ ១៦៥។

ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[376]។ អង្គជំនុំជម្រះសាលាដំបូង បានដកស្រង់ករណីដូចគ្នា ព្រមទាំងករណីបន្ថែមផ្សេងទៀតពីតុលាការ ICTY តុលាការ ICTR និងតុលាការព្រហ្មទណ្ឌពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL) នៅពេលដែលខ្លួនគូសបញ្ជាក់អត្ថន័យអំពីការរំលោភលើផ្លូវភេទដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[377]។

១៧៨. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា យុត្តិសាស្ត្រខាងលើ ដែលមានការដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា ចំពោះការរំលោភលើផ្លូវភេទ ដែលជាបទល្មើសមួយដាច់ឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺស្ថិតនៅក្រៅដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ តុលាការ ICTY ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៣ ហើយយុត្តាធិការពេលវេលារបស់តុលាការនេះគ្របដណ្តប់លើអំពើឧក្រិដ្ឋនានាដែលបានប្រព្រឹត្តចាប់ពីឆ្នាំ ១៩៩១[378]។ តុលាការ ICTR ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៤ ដោយយុត្តាធិការរបស់តុលាការនេះគ្របដណ្តប់លើអំពើឧក្រិដ្ឋនានា ដែលបានប្រព្រឹត្តក្នុងអំឡុងឆ្នាំដូចគ្នានោះ[379]។ យុត្តាធិការពេលវេលារបស់តុលាការ SCSL អនុវត្តលើអំពើឧក្រិដ្ឋនានា ដែលបានប្រព្រឹត្តពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ

---

[376]ជាពិសេស សហព្រះរាជអាជ្ញាបង្ហាញនូវរឿងក្តីនៅតុលាការ ICTR, *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Akayesu*, សំណុំរឿងលេខ ICTR-94-4-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ ("សាលក្រមក្នុង*រឿងក្តី Akayesu*") និង *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Semanza*, សំណុំរឿងលេខ ICTR-97-20-T, "សាលក្រម និងការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣, ("ការផ្តន្ទាទោស និងសាលក្រមក្នុងរឿងក្តី *Semanza*"), និងរឿងក្តីនៅតុលាការ ICTY, សាលក្រមក្នុង*រឿងក្តី Kunarac*។ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩៧ ដល់ ១៩៩។

[377]អង្គជំនុំជម្រះសាលាដំបូងក៏បានដកស្រង់ចេញពីសាលក្រមក្នុង*រឿងក្តី Furundžija*។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kvočka*, សំណុំរឿងលេខ ICTR-95-1B-T, "សាលក្រម និងការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៥, ("សាលក្រមក្នុង*រឿងក្តី Muhimana និងការផ្តន្ទាទោស*")។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Bagosora និងជនដទៃ ទៀត* និង *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Sesay*, សំណុំរឿងលេខ ICTR-98-41-T, "សាលក្រម និងការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨, ("សាលក្រមក្នុង*រឿងក្តី Bagosora និងការផ្តន្ទាទោស*") និង សាលក្រមក្នុង*រឿងក្តី Sesay*។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៦១ ដល់ ៣៦៥។

[378]មាត្រា ១ នៃលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY)។

[379]មាត្រា ១ នៃលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា (ICTR)។

១៩៩៦[380]។ ដូច្នេះ ការសម្រេចដាក់ពិរុទ្ធភាពជាក់លាក់ទាំងនេះ មិនផ្តល់ការគាំទ្រចំពោះការយល់ឃើញដែលថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់អន្តរជាតិ ចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ។ លើសពីនេះទៀត នៅក្នុងការដាក់ពិរុទ្ធភាពពីបទរំលោភលើផ្លូវភេទជាបទល្មើសមួយដាច់ដោយឡែក នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តុលាការទាំងនោះ មិនបានពឹងផ្អែកលើប្រភពបន្ថែមនានានៃច្បាប់អន្តរជាតិ ឬច្បាប់ក្នុងស្រុក ដែលបានចាត់ទុកការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានពីមុន ឬនៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក នោះទេ[381]។

១៧៩. ផ្ទុយមកវិញ យុត្តិសាស្ត្ររបស់តុលាការដែលជាសំអាងរបស់ជនជាប់ចោទ និងរបស់អង្គជំនុំជម្រះសាលាដំបូង បង្ហាញថា នៅក្នុងសម័យកាលនៃតុលាការ *មិនអចិន្ត្រៃយ៍* ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅតែជាសញ្ញាណមួយ ដែលទើបតែកកើតនៅឡើយ[382]។ តាមពិត ការទទួលស្គាល់ការរំលោភលើផ្លូវភេទថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

---

[380]មាត្រា ១ នៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL)។

[381]ជាការកត់សម្គាល់ សាលក្រមសំខាន់ៗនាពេលថ្មីៗរបស់តុលាការ ICTR ក្នុង*រឿងក្តី Akayesu* និងសាលក្រម សំខាន់ៗនាពេលថ្មីៗរបស់តុលាការ ICTY ក្នុង*រឿងក្តី Kunarac*, ទទួលយកលក្ខន្តិកៈរបស់តុលាការទាំងនោះ ធ្វើជាប្រភពនៃការផ្តន្ទាទោសបទរំលោភលើផ្លូវភេទដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងសាលក្រមក្នុង*រឿងក្តី Akayesu* នៅពេលពិចារណាទៅលើ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការរំលោភលើផ្លូវភេទ)" អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានលើកឡើងថា ឧក្រិដ្ឋកម្មនេះ"អាចផ្តន្ទាទោសបានតាមមាត្រា ៣(ឆ) នៃលក្ខន្តិកៈតុលាការនេះ" (កថាខណ្ឌ ៦៨៥), ដោយយល់ឃើញថា "ជនជាប់ចោទត្រូវបានវិនិច្ឆ័យថា ជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌតាមមាត្រា ៣(ឆ) នៃលក្ខន្តិកៈនេះចំពោះ (...) ឧបទ្ទវហេតុនៃការរំលោភលើផ្លូវភេទ" (កថាខណ្ឌ ៦៩៦)។ នៅក្នុងសាលក្រមក្នុង*រឿងក្តី Kunarac*, តុលាការ ICTY បានលើកឡើងថា "ការរំលោភលើផ្លូវភេទត្រូវបានចោទប្រកាន់លើជនជាប់ចោទបីនាក់ថាបានរំលោភច្បាប់ ឬទំនៀមទម្លាប់សង្គ្រាម តាមមាត្រា ៣ និង*ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមមាត្រា ៥ នៃលក្ខន្តិកៈនេះ*។ លក្ខន្តិកៈនេះចាត់ទុកយ៉ាងច្បាស់ថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមយុត្តាធិការរបស់តុលាការក្នុងមាត្រា ៥(ឆ)" (កថាខណ្ឌ ៤៣៦) (សេចក្តីបញ្ជាក់បន្ថែម)។

[382]ព្រឹត្តប័ត្រនិពន្ធដោយ Kelly D. Askin, "ការកាត់សេចក្តីលើការរំលោភលើផ្លូវភេទ នៅក្នុងពេលសង្គ្រាម និងបទល្មើសទាក់ទងនឹងយ៉េនឌ័រផ្អែកតាមច្បាប់អន្តរជាតិ៖ ការរីកចម្រើនជាពិសេស ការតស៊ូនឹងឧបសគ្គ") *ព្រឹត្តិប័ត្រច្បាប់អន្តរជាតិនិពន្ធដោយ Berkeley*, វ៉ុល ២១ (ឆ្នាំ ២០០៣) , ទំព័រ ៣១៩ ដល់ ២២។

ជាតិ មិនបានលេចចេញជារូបរាងនៅឡើយទេ រហូតដល់ទសវត្សរ៍ឆ្នាំ ១៩៩០[383] បន្ទាប់ពីមានសេចក្តីរាយការណ៍ពីការរំលោភលើផ្លូវភេទ ដែលត្រូវបានប្រើប្រាស់ជាឧបករណ៍ក្នុងការអនុវត្តការវាយប្រហារជាទូទៅ និងជាប្រព័ន្ធទៅលើប្រជាជននៅប្រទេសហៃទី (Haiti)[384] បូស្នី (Bosnia)[385] និងរវ៉ាន់ដា (Rwanda)[386]។

---

[383] *សូមមើលឧទា.* របាយការណ៍របស់សន្និសីទពិភពលោកលើកទីបួនស្តីពីស្ត្រីដែលលើកឡើងថា "ជាញឹកញាប់ ភាគីនៃជម្លោះរំលោភផ្លូវភេទលើស្ត្រី តែទទួលបាននិទណ្ឌភាព ជួនកាលប្រើការរំលោភលើផ្លូវភេទជាប្រព័ន្ធដែលជាកលយុទ្ធនៃសង្គ្រាម និងអំពើភេរវកម្ម"។ របាយការណ៍នៃអង្គការសហប្រជាជាតិរបស់សន្និសីទពិភពលោកលើកទីបួនស្តីពីស្ត្រី, ឯកសារអង្គការសហប្រជាជាតិលេខ A/CONF.177/20 (ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥), កថាខណ្ឌ ១៣៥។ *សូមមើលផងដែរ*បាយការណ៍ស្តីពីស្ថានភាពកុមារនៅទូទាំងពិភពលោករបស់អង្គការ UNICEF ដែលអះអាងថា "ក្នុងពេលមានសង្គ្រាម វិធានការដែលផ្អែកទៅលើសហគមន៍ជាមូលដ្ឋាន ជាការចាំបាច់សម្រាប់ត្រួតពិនិត្យពីស្ថានភាព និងតម្រូវការរបស់ស្ត្រី និងកុមារ និងជាពិសេសដើម្បីធានាសន្តិសុខរបស់ពួកគេ ដោយសារតែអំពើគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដែល ពួកគេប្រឈមដូចជាអំពើហិង្សាលើផ្លូវភេទ ឬការរំលោភលើផ្លូវភេទ"។ UNICEF "របៀបវារៈប្រឆាំងនឹងសង្គ្រាម" នៅក្នុងស្ថានភាពនៃរបាយការណ៍ស្តីពីកុមារនៅទូទាំងពិភពលោកឆ្នាំ ១៩៩៦, គេហទំព័រ៖<http://www.unicef.org/sowc96/antiwar.htm>។

[384] *សូមមើលឧទា.* របាយការណ៍ឆ្នាំ ១៩៩៤ ពីអ្នករាយការណ៍ពិសេសរបស់គណៈកម្មកាសិទ្ធិមនុស្សស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសហៃទី ទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិដែលបានសង្កេតឃើញថា "អ្វីដែលអ្នករាយកាណ៍ពិសេសមានកង្វល់បំផុតនោះ គឺមានលេចឡើងនូវបញ្ហាថ្មីមួយក្នុងប្រទេសហៃទី នៅឆ្នាំ ១៩៩៤៖ ការលេចឡើងនូវការរំលោភលើផ្លូវភេទ ដែលបានជម្រុញទឹកចិត្តដោយនយោបាយ និងការប្រើប្រាស់ការបៀតបៀនលើផ្លូវភេទ ដែលជាឧបករណ៍សម្រាប់គាបសង្កត់ និងធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ"។ *របាយការណ៍បណ្តោះអាសន្នស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសហៃទី ដែលបានដាក់ជូនដោយអ្នករាយការណ៍ពិសេសរបស់គណៈកម្មការសិទ្ធិមនុស្ស អនុលោមទៅតាមសេចក្តីសម្រេចរបស់គណៈកម្មការលេខ ១៩៩៤/៨០ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមលេខ ១៩៩៤/២៦៦*, ឯកសារអង្គការសហប្រជាជាតិលេខ A/49/513 (ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៤), ឧបសម្ព័ន្ធ, កថាខណ្ឌ ១៦។ របាយការណ៍របស់គណៈកម្មការនីតិអន្តរជាតិឆ្នាំ ១៩៩៦ ដែលថ្លែងថា មហាសន្និបាតអង្គការសហប្រជាជាតិ "បានបញ្ជាក់សាជាថ្មីជាឯកច្ឆន្ទថា ការរំលោភលើផ្លូវភេទក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅតាមកាលៈទេសៈមួយចំនួន" ហើយបានដកស្រង់ចេញពីរបាយការណ៍ឆ្នាំ ១៩៩៤ ដោយគណៈកម្មការជាតិស្វែងរកការពិត និងយុត្តិធម៌ ដែលបានសន្និដ្ឋានថា "អំពើហិង្សាលើផ្លូវភេទដែលបានប្រព្រឹត្តឡើងចំពោះស្ត្រីក្នុងលក្ខណៈជាប្រព័ន្ធ ដោយមូលហេតុនយោបាយនៅប្រទេសហៃទីក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។ របាយការណ៍របស់គណៈកម្មាការនីតិអន្តរជាតិស្តីពីកិច្ចការនៃសម័យប្រជុំលើកទី ៤៨ របស់ខ្លួន, ថ្ងៃទី ០៦ ខែ ឧសភា ដល់ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៦, ទំព័រ ៥០។

---

[385] *សូមមើលឧទា.* របាយការណ៍ឆ្នាំ ១៩៩៤ របស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីពីការបំពារបំពានលើច្បាប់ទីក្រុងហ្សឺណែវនៅក្នុងអតីតប្រទេសយូហ្គោស្លាវីដែលថ្លែងថា "ករណីការរំលោភលើផ្លូវភេទ និងអំពើហិង្សាលើផ្លូវភេទមួយចំនួនដែលបានរាយការណ៍ដែលបានប្រព្រឹត្តដោយពួកស៊ែប ភាគច្រើនប្រឆាំងនឹងពួកមូស្លីម ច្បាស់លាស់ គឺជាលទ្ធផលនៃអំពើរបស់បុគ្គលនីមួយៗ ឬក្រុមតូចៗ (...)។ ទោះជាយ៉ាងណាក្តីក៏ដោយ ភាគច្រើនត្រូវបានគេមើលឃើញថា ជាផ្នែកមួយនៃទម្រង់ទូទៅ (...)" ដែល"បង្ហាញយ៉ាងច្បាស់អំពីការកើតមាននូវគោលនយោបាយស្តីពីការរំលោភលើផ្លូវភេទជាប្រព័ន្ធ"។ គណៈកម្មការនៃក្រុមជំនាញរបស់អង្គកាសហប្រជាជាតិស្តីពីការបំពារបំពានទៅលើច្បាប់ទីក្រុងហ្សឺណែវ នៅក្នុងអតីតប្រទេសយូហ្គោស្លាវី, របាយការណ៍ចុងក្រោយរបស់គណៈកម្មការក្រុមជំនាញបង្កើតឡើងដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៧៨០ (ឆ្នាំ ១៩៩២), ឯកសារ អង្គការសហប្រជាជាតិលេខ S/1994/674 (ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៤), កថាខណ្ឌ ២៥២ ដល់ ២៥៣។ "របាយការណ៍ស្តីពីស្ថានភាពកុមារនៅទូទាំងពិភពលោករបស់អង្គការ UNICEF ឆ្នាំ ១៩៩៦" ដែលថ្លែងថា "អំពើហិង្សាលើផ្លូវភេទកើតមានជាទូទៅនៅក្នុងបណ្តាលជម្លោះរវាងជាតិពន្ធុ។ នៅក្នុងការប្រយុទ្ធគ្នានៅប្រទេសបូស្នី និងហឺហ្សេហ្គោវីណា និង ក្រូអាត្សុី មានការបង្កើគោលនយោបាយដោយចេតនាមួយដើម្បីធ្វើការរំលោភលើផ្លូវភេទចំពោះស្ត្រីវ័យជំទង់ និងបង្ខំពួកគេឱ្យពរពោះដែលហៅថា*កូនរបស់សត្រូវ*"។ អង្គការ UNICEF, "នៅក្នុងរបាយការណ៍ស្តីពីកុមារនៅទូទាំងពិភពលោកឆ្នាំ ១៩៩៦: ការធ្វើទារុណកម្ម និងការរំលោភលើផ្លូវភេទ", ឆ្នាំ ១៩៩៦ គេហទំព័រ៖<http://www.unicef.org/sowc96/3torrape.htm>។

[386] *សូមមើលឧទា.* របាយការណ៍ចុងក្រោយរបស់គណៈកម្មការក្រុមជំនាញសម្រាប់ប្រទេសរវ៉ាន់ដា ដែលកត់ត្រាថា "របាយការណ៍ដែលបង្ហាញការកង្វល់នានា ដែលត្រូវបានដាក់ជូនគណៈកម្មការជំនាញដែលកត់ត្រាពីការចាប់ពង្រាត់ និងការរំលោភលើផ្លូវភេទលើស្ត្រី និងកុមារីនៅប្រទេសរវ៉ាន់ដា (...)"។ របាយការណ៍ចុងក្រោយរបស់គណៈកម្មការជំនាញស្តីពីប្រទេសរវ៉ាន់ដាបង្កើតឡើងដោយអនុលោមតាមសេចក្តីសម្រេចលេខ ៩៣៥ (ឆ្នាំ ១៩៩៤), ឯកសារអង្គការសហប្រជាជាតិលេខ S/1994/1405, (ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៤), ឧបសម្ព័ន្ធ, កថាខណ្ឌ ១៣៦។ របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិដែលបានរាយការណ៍ពីប្រទេសរវ៉ាន់ដា ដែលបានកត់សម្គាល់ថា "ការរំលោភលើផ្លូវភេទជាវិធានទូទៅ និងពុំមានការលើកលែងទេ"។ របាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសរវ៉ាន់ដាដែលបានដាក់ជូនដោយ Rene Degni-Segui អ្នករាយការណ៍ពិសេសរបស់គណៈកម្មការសិទ្ធិមនុស្ស តាមកថាខណ្ឌ ២០ នៃសេចក្តីសម្រេចលេខ S-3/1 ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៤, ឯកសារអង្គការសហប្រជាជាតិលេខ E/CN.4/1996/68 (ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៦), កថាខណ្ឌ ១៦។ *សូមមើលព្រឹត្តប័ត្រនិពន្ធដោយ* Kelly D. Askin "ការកាត់សេចក្តីលើការរំលោភលើផ្លូវភេទនៅក្នុងពេលសង្គ្រាម និងបទល្មើសទាក់ទងនឹងយ៉ែនឌ័រដោយផ្អែកតាមច្បាប់អន្តរជាតិ", ទំព័រ ៣៤៧ ("ដប់ឆ្នាំមុន ដោយសារតែមានការចាប់អារម្មណ៍តិចតួចចំពោះការរំលោភលើផ្លូវភេទក្នុងពេលមានសង្គ្រាម មានការពិភាក្សាគ្នា ថាតើការរំលោភលើផ្លូវភេទ គឺជាឧក្រិដ្ឋកម្មសង្គ្រាមមួយដែរ ឬយ៉ាងណា។ ចាប់តាំងពីពេលនោះមក តុលាការនានាបានបង្កើតយ៉ាងច្រើននូវយុត្តិសាស្ត្រស្តីពីឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ការរីកចម្រើនជាពិសេសដែលមាននៅក្នុងតុលាការនានាស្តីពីការដោះស្រាយឧក្រិដ្ឋកម្មទាក់ទិននឹងយ៉ែនឌ័រ គឺ

១៨០. ជាការសន្និដ្ឋាន អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការអង្កេតស្រាវជ្រាវពីទំនៀមទម្លាប់ និងសន្ធិសញ្ញានានា ដែលមានពីមុន និងក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក បង្ហាញថា ការរំលោភលើផ្លូវភេទមិនមែនជាបទល្មើសមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ យោងតាមប្រភពនានានៃច្បាប់អន្តរជាតិ ក្នុងពេលនោះ។

១៨១. បញ្ហាបន្ទាប់គឺ ថាតើជាការស្របនឹងគោលការណ៍នីត្យានុកូលភាព ដែរ ឬយ៉ាងណា ការដែលចាត់ទុកថា ការរំលោភលើផ្លូវភេទជាបទល្មើសព្រហ្មទណ្ឌនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ ដែលជាបញ្ហាមួយរបស់ច្បាប់កម្ពុជា ឬយោងតាមគោលការណ៍ទូទៅនៃនីតិ ដែលបានទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ ដែលជាប្រភពជម្រើសមួយផ្សេងទៀតនៃច្បាប់អន្តរជាតិ[387]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការរំលោភលើផ្លូវភេទត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ របស់ប្រទេសកម្ពុជា[388] ដែលមានអានុភាពអនុវត្តក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ បន្ថែមពីលើនេះទៀត មកត្រឹមឆ្នាំ ១៩៧៥ ការរំលោភលើផ្លូវភេទ ត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌយ៉ាងទូលំទូលាយនៅក្នុងយុត្តាធិការជាតិផ្សេងទៀតរួចហើយ[389]។

១៨២. ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ជាតិ មិនអាចផ្តល់សំអាងផ្លូវច្បាប់ពាក់ព័ន្ធក្នុងករណីនេះទេ។ អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយអង្គបុរេជំនុំជម្រះដែលថា “ដោយហេតុថាធាតុផ្សំបទល្មើសទាំងពីរប្រភេទមិនដូចគ្នាបេះបិទនោះ ទើបបទល្មើសជាតិ និងបទល្មើសអន្តរ

ជាលទ្ធផលដែលបានមកពីការខិតខំប្រឹងប្រែងយ៉ាងខ្លាំងរបស់អ្នកសិក្សាស្រាវជ្រាវ សកម្មជន និងអ្នកអនុវត្តជាក់ស្តែងទាំងនៅក្នុង និងក្រៅតុលាការនានាដែលអ្នកទាំងនោះ បានពុះពារជម្នះឧបសគ្គ អស់ពេលយ៉ាងយូរ និងយ៉ាងពិបាក ដើម្បីធានាថា ឧក្រិដ្ឋកម្មទាក់ទិននឹងយ៉េនឌ័រ និងផ្លូវភេទត្រូវបានចោទប្រកាន់ ស៊ើបអង្កេត និងបញ្ជូនទៅជំនុំជម្រះយ៉ាងត្រឹមត្រូវ”)។

[387]មាត្រា ១៥(២) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)។

[388]មាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦។

[389]សាលដីកាអង្គបុរេជំនុំជម្រះលើយុត្តាធិការ, កថាខណ្ឌ ១៥៣, ជើងទំព័រ ៣៦០ (មានឧទាហរណ៍អំពីការរំលោភលើផ្លូវភេទដែលត្រូវបានចាត់ទុកជាបទឧក្រិដ្ឋតាមច្បាប់ជាតិ)។

ជាតិត្រូវបានចាត់ទុកជាបទល្មើសដាច់ពីគ្នា"[390]។ នៅទីនេះ មានភាពមិនស៊ីសង្វាក់គ្នារវាងធាតុផ្សំការរំលោភលើផ្លូវភេទយោងតាមច្បាប់ជាតិ រួមមានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ និងធាតុផ្សំឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[391]។ ខុសពីការកំណត់ជាបទឧក្រិដ្ឋនៅក្នុងច្បាប់ជាតិ សម្រាប់រាល់ប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលផ្សាភ្ជាប់ធាតុផ្សំតាមបរិបទ (Chapeau Elements) ទាំងនេះទៅនឹងបរិបទទូលាយមួយដែលឧក្រិដ្ឋកម្មបានកើតឡើង។ ហេតុដូច្នេះ បទប្បញ្ញត្តិប្រឆាំងនឹងការរំលោភលើផ្លូវភេទនៅក្នុងកម្រិតជាតិ មិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឱ្យការរំលោភលើផ្លូវភេទនេះ ក្លាយជាទម្រង់មួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមគោលការណ៍ទូទៅនៃនីតិ ដែលទទួលស្គាល់ដោយបណ្ដាប្រជាជាតិទាំងឡាយនោះទេ[392]។ ម្យ៉ាងវិញទៀត គំរូនៃការកំណត់ជាបទឧក្រិដ្ឋនៅក្នុងច្បាប់ជាតិ ជួយស្រាយបំភ្លឺនិយមន័យនៃការរំលោភលើផ្លូវភេទ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាពិសេសធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័ត នៅពេលដែលអត្ថិភាពនៃបទរំលោភលើផ្លូវភេទនៅក្នុងឧក្រិដ្ឋកម្ម

---

[390]សាលដីកាអង្គបុរេជំនុំជម្រះលើយុត្តាធិការ, កថាខណ្ឌ ១៥៣។

[391]មានការលើកលែងមួយគួរឱ្យកត់សម្គាល់ចំពោះភាពស្ងៀមស្ងាត់នៃច្បាប់ជាតិចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ស្ដីពីឧក្រិដ្ឋភាពនៃការរំលោភលើផ្លូវភេទនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងច្បាប់ស្ដីពី(តុលាការ)ព្រហ្មទណ្ឌអន្តរជាតិឆ្នាំ ១៩៧៣ ប្រទេសបង់ក្លាដេសបានចែងអំពីយុត្តាធិការរបស់តុលាការដែលបង្កើតដោយច្បាប់នេះ រួមមាន"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ត្រូវបានកំណត់ដោយរួមបញ្ចូល"ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការចាប់ពង្រត់ ការឃុំខ្លួន ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ឬអំពើអមនុស្សធម៌ដទៃទៀត ដែលបានប្រព្រឹត្តឡើងលើប្រជាជនស៊ីវិល ឬការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ជាតិពន្ធុ ឬសាសនា" ទោះបីពុំមានការផ្ដន្ទាទោសតាមច្បាប់នេះក៏ដោយ។ ច្បាប់ស្ដីពី(តុលាការ)ព្រហ្មទណ្ឌអន្តរជាតិរបស់បង់ក្លាដេស ឆ្នាំ ១៩៧៣ (ច្បាប់លេខ XIX ឆ្នាំ ១៩៧៣), ផ្នែក ៣(២)(ក) (សេចក្ដីបញ្ជាក់បន្ថែម)។

[392]*សូមមើល* សាលដីកាអង្គបុរេជំនុំជម្រះលើយុត្តាធិការ, កថាខណ្ឌ ១៥៣ (ទាក់ទងនឹងភាពមិនសមហេតុផលនៃការបញ្ចូលឧក្រិដ្ឋកម្មតាមច្បាប់ជាតិជាស្វ័យប្រវត្តិទៅក្នុងឋានានុក្រមគតិយុត្តិព្រហ្មទណ្ឌអន្តរជាតិ)។ ដើម្បីបង្ហាញសំអាងហេតុផ្ទុយដែលអាចនាំឱ្យមានការសន្និដ្ឋានភ័ន្តច្រឡំ អង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណាថា ឧក្រិដ្ឋភាពពីបុរាណ និងជាសាកលលើអំពើលួច ឬអំពើមនុស្សឃាត ដោយយោងតាមភាពសមហេតុផលនៃការបញ្ចូលឧក្រិដ្ឋកម្មទាំងនេះ នឹងអាចបង្កើតជាឧក្រិដ្ឋកម្មអន្តរជាតិ។

ប្រឆាំងមនុស្សជាតិ ត្រូវបានបង្កើតឡើងរួចហើយ យោងតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នោះ[393]។

១៨៣. ដោយសារមិនមានការគាំទ្រគ្រប់គ្រាន់ចំពោះអត្ថិភាពនៃការរំលោភលើផ្លូវភេទ ដែលជាបទល្មើសមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក យោងតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងក្នុងការសន្និដ្ឋានថា ការរំលោភលើផ្លូវភេទដែលបានកើតឡើងនៅមន្ទីរ ស ២១ គឺជាការរំលោភលើផ្លូវភេទដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានហាមឃាត់យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធផ្នែកនេះនៃទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាដែលលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយមិនបានផ្តន្ទាទោសត្រួតគ្នាទៅលើជនជាប់ចោទ ពីបទរំលោភលើផ្លូវភេទ និងបទធ្វើទារុណកម្ម ដែលជាបទល្មើសដាច់ដោយឡែកពីគ្នានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះបទរំលោភលើផ្លូវភេទដែលបានប្រព្រឹត្តនៅមន្ទីរ ស ២១។

## ៤.ឃ.២.ការរំលោភលើផ្លូវភេទ គឺជាអំពើធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

១៨៤. ចំពោះបញ្ហាចុងក្រោយនៃទឡ្ហីករណ៍បណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងសម្រេច*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* (*ex proprio motu*) ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការដែលខ្លួនយល់ឃើញថា អំពើរំលោភលើផ្លូវភេទដែលបានកើតឡើងនៅមន្ទីរ ស ២១ អាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់

---

[393]សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Furundžija*, កថាខណ្ឌ ១៧៧៖ ("ដើម្បីទទួលបាននិយមន័យការរំលោភលើផ្លូវភេទដោយផ្អែកតាមគោលការណ៍ច្បាប់ព្រហ្មទណ្ឌស្តីពីភាពជាក់លាក់ (...) ជាការចាំបាច់ដែលត្រូវតែស្វែងរកគោលការណ៍ច្បាប់ព្រហ្មទណ្ឌ ដែលមានភាពទូទៅចំពោះប្រព័ន្ធច្បាប់សំខាន់ៗក្នុងពិភពលោក")។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ៤៣៩ ដល់ ៤៦០។

អ.វ.ត.ក ដែរ ឬយ៉ាងណា។ ម្យ៉ាងទៀត ដោយយោងតាមគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណា ថាតើការធ្វើទារុណកម្ម គឺជាបទល្មើសមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ដែរ ឬយ៉ាងណា ហើយប្រសិនបើមានប្រាកដមែន ថាតើនៅក្នុងនិយមន័យនៃការធ្វើទារុណកម្ម មានរួមបញ្ចូលទាំងអំពើរំលោភលើផ្លូវភេទ ដែរ ឬយ៉ាងណា។

១៨៥. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដូចគ្នានឹងការរំលោភលើផ្លូវភេទដែរ ការធ្វើទារុណកម្មត្រូវបានបញ្ញត្តិហាមឃាត់ជាក់លាក់នៅក្នុងច្បាប់សង្គ្រាម[394]។ ទោះបីជា នៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) ឬធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE) មិនបានចាត់ទុកការធ្វើទារុណកម្មថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏មាត្រា II (១)(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងបានដាក់បញ្ចូលនូវអំពើធ្វើទារុណកម្មទៅក្នុងនិយមន័យនៃ“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” មានដូចជា៖ “អំពើឃោរឃៅ និងបទល្មើសនានា ដោយរួមបញ្ចូលទាំង (...) អំពើធ្វើទារុណកម្ម ប៉ុន្តែ មិនកម្រិតត្រឹមតែអំពើធ្វើទារុណកម្មប៉ុណ្ណោះទេ (...)”។ យោងតាមច្បាប់នោះ ការដាក់ពិរុទ្ធភាពពីបទ

---

[394]មាត្រា ៣(១)(ក) មាត្រា ១២ មាត្រា ៥០ នៃអនុសញ្ញាទីក្រុងហ្សឺណែវ (I) ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពអ្នករងរបួស និងអ្នកជំងឺនៅក្នុងកងកម្លាំងប្រដាប់អាវុធនៅសមរភូមិ អនុម័តថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩, វ៉ុល ៧៥ លេខលំដាប់សន្ធិសញ្ញាអង្គការសហប្រជាជាតិ ទំព័រ ៣១ (ចូលជាធរមានថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០)។ មាត្រា ៣(១)(ក) មាត្រា ១២ មាត្រា ៥១ នៃអនុសញ្ញាទីក្រុងហ្សឺណែវ (II) ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពអ្នករងរបួស និងអ្នកជំងឺ និងអ្នករងគ្រោះដោយលិចកប៉ាល់នៅក្នុងកងកម្លាំងប្រដាប់អាវុធនៅសមុទ្រ អនុម័តថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩, វ៉ុល ៧៥ លេខលំដាប់សន្ធិសញ្ញាអង្គការសហប្រជាជាតិ ទំព័រ ៨៥ (ចូលជាធរមានថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០)។ មាត្រា ៣(១)(ក) មាត្រា ១៣, ១៤, ១៣០ នៃអនុសញ្ញា ទីក្រុងហ្សឺណែវ (III) ទាក់ទិន ទៅនឹងការប្រព្រឹត្តចំពោះឈ្លើយសឹក អនុម័តថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩, វ៉ុល ៧៥ លេខលំដាប់សន្ធិសញ្ញាអង្គការសហប្រជាជាតិ ទំព័រ ១៣៥ (ចូលជាធរមានថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០)។ មាត្រា ៣(១)(ក) មាត្រា ២៧ មាត្រា ១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ឆ្នាំ ១៩៤៩។ មាត្រា៧៥(២) (ii) នៃពិធីសារបន្ថែម I ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។ មាត្រា ៤(២) (ក) នៃពិធីសារបន្ថែម II ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។

ធ្វើទារុណកម្ម ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានសម្រេចនៅក្នុងរឿងក្តីមួយចំនួននៅតុលាការយោធា Nuremberg[395]។

១៨៦. ឧទាហរណ៍ នៅក្នុងរឿងក្តីទាក់ទងនឹង*វេជ្ជសាស្ត្រ* ជារឿយៗ តុលាការតែងតែផ្តោតលើការធ្វើទារុណកម្មជាបទល្មើសមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលដែលខ្លួនផ្តល់សំអាងហេតុចំពោះការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ ជនជាប់ចោទជាវេជ្ជបណ្ឌិតធ្លាប់មានទំនាក់ទំនងជាមួយចក្រភពអាល្លឺម៉ង់ទី ៣ (Third Reich) បានយកបុគ្គលទាំងឡាយ ដែលត្រូវបានឃុំឃាំងនៅក្នុងជំរំប្រមូលផ្តុំមកធ្វើការពិសោធន៍វេជ្ជសាស្ត្រដោយបង្ខំ[396] រួមមាន ការពិសោធន៍"រយៈកម្ពស់ខ្ពស់"[397] និង"ការពិសោធជាតិពុល"[398]។ នៅពេលសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ Karl Brandt ដែលមានការកត់សម្គាល់ជាងគេ តុលាការបានរកឃើញថា ជនជាប់ចោទ៖

---

[395] *សូមមើលរឿងក្តី U.S. ទល់នឹង Brandt និងជនដទៃទៀត*, "សាលក្រម", ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៤៦, បោះពុម្ពឡើងវិញក្នុងព្រឹត្តប័ត្រស្តីពី*ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuernberg ផ្អែកតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, វ៉ុល II, (*"រឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ") (Medical Case)*, ទំព័រ ១៩៨, ២១៦ ដល់ ២១៧, ២៤០, ២៤៧ ដល់ ២៤៨, ២៧១។ *រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Altstoetter និងជនដទៃទៀត*, "សាលក្រម", ថ្ងៃទី ០៣ ដល់ ០៤ ខែ ធ្នូ ឆ្នាំ ១៩៧៤, បោះពុម្ពឡើងវិញក្នុងព្រឹត្តប័ត្រស្តីពី*ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuerenberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, វ៉ុល III, (*"រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌"*), ទំព័រ ៣ ដល់ ៤, ២៣ ដល់ ២៥, ១០៨៧ ដល់១០៨៨, ១០៩២ ដល់១០៩៣, ១១០៧, ១១៥៥ ដល់ ១១៥៦, ១១៦៦, ១១៧០។ *រឿងក្តីជាប់ពាក់ព័ន្ធនឹងក្រសួងផ្សេងៗ (Ministries Case)*, ទំព័រ ៤៦៧ ដល់ ៤៦៧ និង ៤៧១។ *រឿងក្តី Pohl*, ទំព័រ ៩៦៥ ដល់ ៩៦៦, ៩៧០ ដល់ ៩៧១, ១០៣៦ ដល់ ១០៣៨។

[396] *រឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ*, វ៉ុល II, ទំព័រ១៨៣, ២២៣ ដល់ ២២៧, ២៤០, ២៤៨។

[397] នៅក្នុងការពិសោធន៍វេជ្ជសាស្ត្រទាំងនេះ "ជនរងគ្រោះជាច្រើនបានស្លាប់ (...) និងអ្នកផ្សេងទៀត បានទទួលរងរបួសធ្ងន់ធ្ងរ ការធ្វើទារុណកម្ម និងការធ្វើបាប" បន្ទាប់ពីពួកគេត្រូវបានដាក់ទៅក្នុងបន្ទប់ដែលមានសម្ពាធទាប ដែលបន្ទប់នោះត្រូវបានរៀបចំឡើងឲ្យមានស្ថានភាពដែលរយៈកម្ពស់ខ្ពស់ខ្លាំង ដែលគោលបំណងនៃការពិសោធន៍នេះ គឺដើម្បី"ស៊ើបអង្កេតកម្រិតនៃភាពអំណត់ និងអត្ថិភាពរបស់មនុស្ស" នៅក្នុងស្ថានភាពទាំងនោះ។ *រឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ*, វ៉ុល II, ទំព័រ ១៧៥។

[398] នៅក្នុងការពិសោធន៍វេជ្ជសាស្ត្រទាំងនេះ "ជនរងគ្រោះត្រូវបានបាញ់ដោយគ្រាប់កាំភ្លើងដែលមានថ្នាំពុល និងបានទទួលរងការធ្វើទារុណកម្ម និងស្លាប់" នៅក្នុងនីតិវិធីដែលវេជ្ជបណ្ឌិតបានបាញ់ភ្លៅអ្នកទោសដោយថ្នាំ aconitin nitrate ហើយ

> បានទទួលខុសត្រូវ បានជួយ និងជំរុញ បានចូលរួមដោយមានការយល់ព្រម និងមានការជាប់ពាក់ព័ន្ធនឹងផែនការ និងគម្រោងដែលពាក់ព័ន្ធនឹងការពិសោធន៍វេជ្ជសាស្ត្រ ដែលធ្វើឡើងចំពោះប្រជាជនដែលមិនមែនជាជនជាតិអាល្លឺម៉ង់ ដោយមិនមានការយល់ព្រមពីអ្នកទាំងនេះ និងអំពើឃោរឃៅផ្សេងទៀត នៅពេលប្រព្រឹត្តអំពើកាប់សម្លាប់ អំពើព្រៃផ្សៃ អំពើគ្មានមេត្តាធម៌ *អំពើធ្វើទារុណកម្ម* និងអំពើអមនុស្សធម៌ផ្សេងទៀត។ ដោយសារអំពើឧក្រិដ្ឋទាំងនេះ មិនស្ថិតក្នុងឧក្រិដ្ឋកម្មសង្គ្រាម ដូច្នេះ អំពើឧក្រិដ្ឋទាំងនេះ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[399]។

ពាក្យពេចន៍ប្រហាក់ប្រហែលគ្នានេះ មានប្រើនៅក្នុងផ្នែកផ្សេងៗនៃសាលក្រមដែលសម្រេចដាក់ពិរុទ្ធភាពលើសហចារីមួយចំនួនទៀតរបស់ជនជាប់ចោទ Brandt[400]។

១៨៧. លើសពីនេះទៀត ក្នុងរឿងក្តីពាក់ព័ន្ធនឹង*វិស័យយុត្តិធម៌* មានជនជាប់ចោទច្រើនរូបដែលជាអតីតសមាជិករបស់ក្រសួងយុត្តិធម៌នៃចក្រភពអាល្លឺម៉ង់ (Reich Ministry of Justice) អតីតសមាជិករបស់តុលាការពិសេស និងតុលាការប្រជាជន ត្រូវបានចោទប្រកាន់ និងសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន អំពើធ្វើទារុណកម្ម ដែលបានប្រព្រឹត្តលើជនស៊ីវិលជនជាតិអាល្លឺម៉ង់ ព្រមទាំងប្រជាពលរដ្ឋក្នុងប្រទេសនានា ដែលត្រួតត្រាដោយអាល្លឺម៉ង់[401]។ ក្នុងចំណោមបទចោទនានា ជនជាប់ចោទទាំងនោះ ត្រូវបានសម្រេចដាក់ពិរុទ្ធភាពក្នុងការប្រើប្រាស់តួនាទីជាអ្នកអនុវត្តក្រឹត្យ"រាត្រី និងអ័ព្ទ"របស់ហ៊ីត្លែរ ដែលនៅក្នុងក្រឹត្យនោះ "នៅក្នុងបណ្តាប្រទេសត្រួតត្រាដោយអាល្លឺម៉ង់ ចំពោះជនស៊ីវិលដែលបានចោទប្រកាន់ពីបទល្មើសធ្វើសកម្មភាពប្រឆាំងនឹងកងកម្លាំងត្រួតត្រារបស់អាល្លឺម៉ង់ ត្រូវបានចាប់បញ្ជូនទៅ

---

បន្ទាប់មកបានកត់ត្រាពីការសង្កេតរបស់ពួកគេ នៅពេលដែលថ្នាំពុលនោះសម្លាប់អ្នកទោសបន្តិចម្តងៗយ៉ាងឈឺចាប់។ *រឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ*, វ៉ុល II, ទំព័រ ១៧៨ និង ២៤៥ ដល់ ២៤៦។

[399] *រឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ*, វ៉ុល II, ទំព័រ ១៩៨។

[400] *រឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ*, វ៉ុល II, ទំព័រ ២១៦ ដល់ ២១៧, ២៤០, ២៤៧ ដល់ ២៤៨, ២៧១, ២៨១, ២៨៥, ២៩០, ២៩២, ២៩៥ និង ២៩៧។

[401] *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ២៣។ *សូមមើលផងដែរ*, ទំព័រ ៣ ដល់ ៤, ២៤ ដល់ ២៥, ១០៨៧ ដល់ ១០៨៨, ១០៩២ ដល់ ១០៩៣, ១១០៧, ១១៥៥ ដល់ ១១៥៦, ១១៦៦, ១១៧០។

ធ្វើការជំនុំជម្រះជាសម្ងាត់”[402] ដោយមានគោលបំណង “ដើម្បីបង្កភាពភ័យខ្លាច ធ្វើទារុណកម្ម ហើយនៅតាមតំបន់ដែលខ្លួនត្រួតត្រាមួយចំនួន គឺដើម្បីសម្លាប់រង្គាលប្រជាជនស៊ីវិលទាំងអស់តែម្តង”[403]។

១៨៨. ការអនុវត្តបែបនេះ រួមជាមួយនឹងបណ្តុំទស្សនទាននៃ“អំពើអមនុស្សធម៌ផ្សេងៗ”នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានបញ្ចូលក្នុងលក្ខន្តិកៈរបស់តុលាការយោធាអន្តរជាតិនានា[404] បានទទួលស្គាល់អត្ថិភាពអំពីបទធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥។

១៨៩. នាពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិចារណា ទៅលើនិយមន័យនៃបញ្ហានេះ ទៅតាមពេលវេលាពាក់ព័ន្ធ។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា៖

> បទឧក្រិដ្ឋនៃការធ្វើទារុណកម្មមានចែង និងកំណត់និយមន័យ ដោយលិខិតុបករណ៍អន្តរជាតិជាច្រើន រួមមាន សេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ១៩៧៥ ស្តីពីការធ្វើទារុណកម្មត្រូវបានអនុម័តជាឯកច្ឆន្ទ និងអនុសញ្ញាឆ្នាំ ១៩៨៤ ប្រឆាំងនឹងការធ្វើទារុណកម្ម។ និយមន័យនៅក្នុងអនុសញ្ញាឆ្នាំ ១៩៨៤ ប្រឆាំងនឹងការធ្វើទារុណកម្ម ដែលឆ្លុះបញ្ចាំងអំពីសេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្មត្រូវបានទទួលយកដោយតុលាការ ICTY ថាជាសេចក្តីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាំងពីពេលចាប់ផ្តើមទទួលយក

[402] *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៣១។

[403] *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៦០។

[404] ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ កំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចជា “ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និង*អំពើអមនុស្សធម៌ផ្សេងៗទៀត* ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនស៊ីវិល មុន ឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ក្នុងការប្រព្រឹត្ត ឬពាក់ព័ន្ធនឹងបទល្មើសនៅក្នុងយុត្តាធិការរបស់តុលាការ ថាតើនៅពេលប្រព្រឹត្តនោះ គឺជាការរំលោភបំពានច្បាប់ជាតិដែល ឬ យ៉ាងណា” មាត្រា ៦ នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (សេចក្តីបញ្ជាក់បន្ថែម)។

អនុសញ្ញានេះដំបូងមកម្ល៉េះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការកំណត់និយមន័យនេះ ត្រូវបានទទួលយកជាទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥[405]។

១៩០. អង្គជំនុំជម្រះសាលាដំបូង ពុំបានផ្តល់សំអាងហេតុណាមួយចំពោះការយល់ឃើញរបស់ខ្លួនដែលថា ការកំណត់និយមន័យនៅក្នុងអនុសញ្ញាឆ្នាំ ១៩៨៤ ស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្មដែលបានបង្កើតឡើងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ប្រើជាអត្ថបទសម្រាប់សេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្មតែប៉ុណ្ណោះ។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូង បានផ្អែកលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ *មិនអចិន្ត្រៃយ៍* ដើម្បីបកស្រាយនិយមន័យនៅក្នុងអនុសញ្ញាឆ្នាំ ១៩៨៤ ព្រមទាំងធ្វើការវិភាគអត្ថន័យអំពីធាតុផ្សំ *សត្យានុម័ត* និង*អត្តនោម័ត* តម្រូវសម្រាប់បទធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[406]។

១៩១. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជា និយមន័យនៃការធ្វើទារុណកម្មដែលមានចែងក្នុងអនុសញ្ញាឆ្នាំ ១៩៨៤ ស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម មានលក្ខណៈស្រដៀងនឹងនិយមន័យដែលមានចែងក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម ក៏ដោយ ក៏នៅមានលក្ខណៈខុសគ្នាសំខាន់ៗមួយចំនួនដែរ។ មាត្រា ១ នៃសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្មបានកំណត់និយមន័យនៃការធ្វើទារុណកម្មដូចខាងក្រោមនេះ៖

> អំពើណាមួយដែលបង្កឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងធ្ងន់ធ្ងរផ្នែករាងកាយ ឬស្មារតី ដែលបានប្រព្រឹត្តឡើងដោយចេតនា ឬដោយការញុះញង់ពីមន្ត្រីសាធារណៈ ទៅលើបុគ្គលណាមួយ ក្នុងគោលបំណង ដើម្បីទទួលបានព័ត៌មាន ឬចម្លើយសារភាពពីបុគ្គលនោះ ឬពីតតីយជន ឬដើម្បីដាក់ទណ្ឌកម្មបុគ្គលនោះចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ឬត្រូវបានគេសង្ស័យថាបានប្រព្រឹត្ត ឬដើម្បីបំភិតបំភ័យបុគ្គលនោះ ឬក៏បុគ្គលដទៃ

---

[405]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៥៣ (ការដកស្រង់ត្រូវបានលុបចេញ)។

[406]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៥៤ ដល់ ៣៥៨។

ទៀត។ (...) ការធ្វើទារុណកម្មមានទម្រង់ជាការធ្វើបាប ឬការដាក់ទណ្ឌកម្មដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកដែលធ្ងន់ធ្ងរ និងដោយចេតនា[407]។

ចំណែកឯអនុសញ្ញាឆ្នាំ ១៩៨៤ ស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម បានកំណត់និយមន័យនៃការធ្វើទារុណកម្មថាៈ

> អំពើណាមួយដែលបង្កឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងធ្ងន់ធ្ងរផ្នែករាងកាយ ឬស្មារតីដែលបានប្រព្រឹត្តឡើងដោយចេតនា ទៅលើបុគ្គលណាមួយ ក្នុងគោលបំណងដើម្បីទទួលបានព័ត៌មាន ឬចម្លើយសារភាពពីបុគ្គលនោះ ឬពីតតីយជន ឬដើម្បីដាក់ទណ្ឌកម្មបុគ្គលនោះចំពោះអំពើដែលខ្លួន ឬក៏តតិយជនបានប្រព្រឹត្ត ឬត្រូវបានគេសង្ស័យថាបានប្រព្រឹត្ត ឬដើម្បីបំភិតបំភ័យ ឬបង្ខិតបង្ខំបុគ្គលនោះ ឬតតិយជន ឬដើម្បីហេតុផលណាមួយផ្អែកលើទម្រង់នៃការរើសអើងណាមួយ នៅពេលដែលការឈឺចាប់ ឬការរងទុក្ខដែលបានប្រព្រឹត្តឡើងដោយខ្លួនឯង ឬដោយមានការញុះញង់ ឬដោយការយល់ព្រម ឬដោយការស្រុះស្រួលពីមន្ត្រីសាធារណៈ ឬពីបុគ្គលផ្សេងទៀតដែលបំពេញភារៈកិច្ចក្នុងសមត្ថកិច្ចផ្លូវការ[408]។

១៩២. សេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម បានកំណត់និយមន័យអំពីការធ្វើទារុណកម្មនេះ ក្នុងលក្ខណៈចង្អៀតជាង។ ឧទាហរណ៍ ការរៀបរាប់អំពីគោលបំណង ឬមូលហេតុជាក់លាក់នៃការបង្កការឈឺចាប់ ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរដែលបានប្រព្រឹត្តទៅលើបុគ្គលដទៃ ដែលបានកំណត់និយមន័យនៅក្នុងអនុសញ្ញាឆ្នាំ ១៩៨៤ ស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម គឺមានលក្ខណៈទូលំទូលាយជាង។ ដូចគ្នាទៅនឹងការកំណត់និយមន័យនៅក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្មដែរ និយមន័យនៅក្នុងអនុសញ្ញាឆ្នាំ ១៩៨៤ ស្តីពីការប្រឆាំងនឹង

---

[407] មាត្រា ១ នៃសេចក្តីប្រកាសស្តីពីការការពារជនគ្រប់រូបមិនឱ្យទទួលរងនូវការធ្វើទារុណកម្ម និងការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តដ៏ឃោរឃៅ បន្ទាបបន្ថោក ឬអមនុស្សធម៌ផ្សេងៗទៀត, សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៣៤៥២ (XXX), ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៧៥, ("សេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីទារុណកម្ម")។

[408] មាត្រា ១ នៃ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តិព្រៃផ្សៃ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤, វ៉ុល ១៤៦៥ លេខលំដាប់សន្ធិសញ្ញាអង្គការសហប្រជាជាតិ ទំព័រ ៨៥, (ចូលជាធរមាននៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧), ("អនុសញ្ញាឆ្នាំ ១៩៨៤ ស្តីពីការប្រឆាំងនឹងទារុណកម្ម")។

ការធ្វើទារុណកម្ម បានបញ្ជាក់យ៉ាងច្បាស់ពីគោលបំណងនៃការទទួលបាននូវព័ត៌មាន ឬចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម និងការបំភិតបំភ័យ។ ប៉ុន្តែ និយមន័យក្នុងអនុសញ្ញាឆ្នាំ ១៩៨៤ ស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ក៏កំណត់ផងដែរ សម្រាប់ហេតុផលនៃការបង្ខិតបង្ខំ ឬ"ហេតុផលណាមួយដោយផ្អែកលើទម្រង់នៃការរើសអើង"[409] ពាក្យពេចន៍ដែលមិនមាននៅក្នុងនិយមន័យ ដែលមានកំណត់ក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្មឡើយ។

១៩៣. និយមន័យដែលមានកំណត់ក្នុងអនុសញ្ញាឆ្នាំ ១៩៨៤ ស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ក៏បានដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវក្នុងន័យទូលាយជាងស្តីពីមន្ត្រីសាធារណៈ[410]។ ខុសពីនិយមន័យដែលមានកំណត់ក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម និយមន័យនៃការធ្វើទារុណកម្មតាមអនុសញ្ញាឆ្នាំ ១៩៨៤ ប្រឆាំងនឹងការធ្វើទារុណកម្ម អាចបង្កឡើងដោយ "មាន*ការយល់ព្រម ឬការស្រុះស្រួល*"ពីមន្ត្រីទាំងនោះ[411]។ ជាងនេះទៀត មន្ត្រីសាធារណៈពិតប្រាកដ បុគ្គលផ្សេងទៀតដែល"*កំពុងបំពេញភារៈកិច្ចក្នុងសមត្ថកិច្ចផ្លូវការ*" ក៏អាចប្រព្រឹត្តអាចញុះញង់ អាចផ្តល់ការយល់ព្រម ឬស្រុះស្រួលបានដែរដល់ការប្រព្រឹត្តអំពើធ្វើទារុណកម្មនេះ[412]។

១៩៤. លើសពីនេះទៀត បើទោះជាអង្គជំនុំជម្រះសាលាដំបូងបានកំណត់យ៉ាងត្រឹមត្រូវថា និយមន័យនៃការធ្វើទារុណកម្ម នៅក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ និងនៅក្នុងអនុសញ្ញាឆ្នាំ ១៩៨៤ មានន័យដូចគ្នាទាំងស្រុងក៏ដោយ ក៏មិនមានន័យថា ដោយសារតែអនុសញ្ញាស្តីពីការប្រឆាំងនឹង

---

[409]មាត្រា ១ នៃអនុសញ្ញាស្តីពីការប្រឆាំងនឹងទារុណកម្ម។

[410]*សូមមើលជាទូទៅ* Manfred Nowak and McArthur, *អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម: សេចក្តីអធិប្បាយ*, ចេញផ្សាយដោយសាកលវិទ្យាល័យ Oxford, ឆ្នាំ ២០០៨, ទំព័រ ៤៤, កថាខណ្ឌ ៣៩ និងទំព័រ ៧៧ ដល់ ៧៩, ១១៦ ដល់ ១១៩។

[411]មាត្រា ១ នៃអនុសញ្ញាស្តីពីការប្រឆាំងនឹងទារុណកម្ម (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលរឿងក្តី Elmi ទល់នឹង Australia*, យោបល់របស់គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម, ឯកសារអង្គការសហប្រជាជាតិលេខ CAT/C/22/D/120/1998, (ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៦.៥)។

[412]មាត្រា ១ នៃអនុសញ្ញាស្តីពីការប្រឆាំងនឹងទារុណកម្ម (សេចក្តីបញ្ជាក់បន្ថែម)។

ការធ្វើទារុណកម្មឆ្នាំ ១៩៨៤ ដែលជាសេចក្តីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលនោះ ទើបធ្វើឱ្យនិយមន័យនៃការធ្វើទារុណកម្មនៅក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ក្លាយជាសេចក្តីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានតាំងពីជិតដប់ឆ្នាំមុនដែរនោះទេ។ សេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម គឺជាសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលមិនមានអានុភាពចងកាតព្វកិច្ចនោះឡើយ ហេតុដូច្នេះហើយតម្រូវឱ្យមានភស្តុតាងជាច្រើនបន្ថែមទៀត មុននឹងឈានដល់ការកំណត់ថា និយមន័យនៃការធ្វើទារុណកម្មដែលបានកំណត់ក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ត្រូវបានចាត់ទុកជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ នាពេលនោះ។

១៩៥. ជាលទ្ធផល បញ្ហានៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺថាតើនិយមន័យដែលមានលក្ខណៈចង្អៀតស្តីអំពីការធ្វើទារុណកម្មដែលមានកំណត់នៅក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម គឺជាសេចក្តីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ស្ថិតក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា តាមនិយមន័យនៅឆ្នាំ ១៩៧៥ ធាតុផ្សំនៃការធ្វើទារុណកម្មមានដូចតទៅៈ

(ក) អំពើណាមួយដែលបណ្តាលឱ្យមានការឈឺចាប់ ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរ ផ្នែករាងកាយ ឬស្មារតី (ធាតុផ្សំសត្យានុម័ត)

(ខ) ដែលប្រព្រឹត្តឡើងដោយចេតនា ទៅលើបុគ្គលណាមួយ (ធាតុផ្សំអត្តនោម័ត)

(គ) ដោយមន្ត្រីសាធារណៈ ឬដោយការញុះញង់ពីមន្ត្រីសាធារណៈ

(ឃ) ក្នុងគោលបំណង ដើម្បីទទួលបាននូវព័ត៌មាន ឬចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ។

១៩៦. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ទោះបីជាមានសេចក្តីប្រកាស និងសន្ធិសញ្ញាអន្តរជាតិជាច្រើនដែលត្រូវបានអនុម័តមុនឆ្នាំ ១៩៧៥ បានហាមឃាត់ការធ្វើទារុណកម្មក៏ដោយ ក៏សេចក្តីប្រកាស និងសន្ធិសញ្ញាទាំងនោះ មិនបានកំណត់និយមន័យនៃការធ្វើទារុណកម្មឡើយ[413]។

---

[413]មាត្រា ៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ២១៧ A (III), កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ, សម័យប្រជុំលើកទី ៣ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨។

ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សម្រាប់ជាព័ត៌មានមួយដែលពិនិត្យលើយុត្តិសាស្ត្ររបស់តុលាការយោធា Nuremberg ពីឆ្នាំ ១៩៤៦ ដល់ឆ្នាំ ១៩៤៩ ស្តីពីការធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង សេចក្តីអត្ថាធិប្បាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិអំពីអនុសញ្ញាទីក្រុងហ្សឺណែវ IV ឆ្នាំ ១៩៤៩ *រឿងក្តីប្រទេសក្រិក* ឆ្នាំ ១៩៦៩ ដោយគណៈកម្មការអឺរ៉ុបសិទ្ធិមនុស្ស និងដំណើរការជុំវិញការអនុម័តសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម។ ភស្តុតាងនេះបង្ហាញឱ្យឃើញថា និយមន័យ និងធាតុផ្សំការធ្វើទារុណកម្ម ដែលមានកំណត់នៅក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្មត្រូវបានចាត់ទុកជាសេចក្តីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

១៩៧. ចំណុចទីមួយ យោងតាមរឿងក្តី ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ហេតុទាំងនេះបង្ហាញថា និយមន័យនៃការធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានអនុវត្តដោយតុលាការនោះ រាប់បញ្ចូលមិនត្រឹមតែការបង្កដោយចេតនានូវការឈឺចាប់ ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរទៅលើមនុស្សដទៃទៀតប៉ុណ្ណោះទេ[414] ថែមទាំងរាប់បញ្ចូលផងដែរនូវការចូលរួមយ៉ាងសកម្មពីសំណាក់មន្ត្រីរបស់រដ្ឋ រួមជាមួយគោលបំណងមិនស្របច្បាប់ ដោយឡែក គឺការទទួលបាននូវចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម។ រាល់រឿងក្តីដែលបានរៀបរាប់ខាងលើ បានដាក់ឱ្យមានការទទួលខុសត្រូវចំពោះអំពើធ្វើទារុណកម្ម ដែលបានប្រព្រឹត្តឡើង

---

មាត្រា ៣(១)(ក) នៃអនុសញ្ញាទីក្រុងហ្សឺណែវ I-IV ឆ្នាំ ១៩៤៩។ មាត្រា ៣២ និង ១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ឆ្នាំ ១៩៤៩។ មាត្រា ៣ នៃអនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន បើកឱ្យចុះហត្ថលេខានៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០, វ៉ុល ២១៣ លេខលំដាប់សន្ធិសញ្ញាអង្គការសហប្រជាជាតិ ទំព័រ ២២១ (213 UNTS 221), (ចូលជាធរមាននៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៥៣) និងបានធ្វើវិសោធនកម្មដោយពិធីសារលេខ ១១ និង ១៤ ("អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស")។ មាត្រា ៧ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)។

[414] *សូមមើលឧទា. រឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ*, វ៉ុល II, ទំព័រ ១៧៥, ១៧៨, ២៤៥ ដល់ ២៤៦។ *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៦១, ១០៩៤។ *រឿងក្តី Pohl*, វ៉ុល V, ទំព័រ ៩៧០ ដល់ ៩៧១, ១០៣៦ ដល់ ១០៣៧, ១០៨៦ (មតិស្របរបស់ចៅក្រម Michael A. Musmanno)។

ដោយផ្ទាល់ ឬដោយមានការញុះញង់ពីមន្ត្រីរដ្ឋាភិបាលអាល្លឺម៉ង់ នៅក្នុងបរិបទនៃជំរំប្រមូលផ្ដុំ[415]។ ជាឧទាហរណ៍ នៅក្នុងរឿងក្ដី *ពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ* ការពិសោធន៍នានា៖

> មិនមែនជាអំពើដាច់ដោយឡែក និងដោយខ្វះការប្រុងប្រយ័ត្នរបស់វេជ្ជបណ្ឌិត ឬអ្នកវិទ្យាសាស្ត្រដែលបំពេញការងារតែម្នាក់ឯង ក្នុងលក្ខណៈជាបុគ្គល ក្រោមការទទួលខុសត្រូវរៀងៗខ្លួននោះឡើយ ប៉ុន្តែជាលទ្ធផលនៃការបង្កើតគោលនយោបាយរួម និងធ្វើផែនការ នៅកម្រិតរដ្ឋាភិបាល យោធា និងបក្សណាហ្ស៊ី (Nazi) ហើយគោលនយោបាយ នេះត្រូវបានអនុវត្តជារួម ក្នុងយុទ្ធនាការសង្គ្រាមទាំងមូលតែម្ដង។ ពួកគេត្រូវបានបញ្ជា ដាក់ទណ្ឌកម្ម អនុញ្ញាត ឬផ្ដល់ការយល់ព្រមដោយបុគ្គលនានាដែលមានតួនាទីនៅក្នុងអាជ្ញាធរ[416]។

រឿងក្ដីពាក់ព័ន្ធនឹង*វិស័យយុត្តិធម៌* បានបញ្ជាក់បន្ថែមទៀតថា ចំពោះរាល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ការចូលរួមរបស់រដ្ឋាភិបាល គឺជាធាតុផ្សំសត្យានុម័ត"[417]។

១៩៨. សម្រាប់គោលបំណងក្នុងការហាមឃាត់ ការធ្វើទារុណកម្មដែលមាននៅក្នុងរឿងក្ដីច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ហាក់ដូចជាមានការទាក់ទងគ្នាជាមួយនឹងការបង្ខំឱ្យផ្ដល់

---

[415] *សូមមើលរឿងក្ដីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៣៣៨ ("ជាការប្រាកដណាស់ថា កម្មវិធីឈ្លានពាន និងការកេងប្រវ័ញ្ចរបស់ពួកណាហ្ស៊ី ដែលមានលក្ខណៈលម្អិត ផ្សេងៗគ្នា និងស្មុគស្មាញជាច្រើន មិនអាចអនុវត្តទៅបានដោយខ្លួនឯងនោះទេ ប៉ុន្តែភាពជោគជ័យនៃកម្មវិធីនេះកើតមានដោយពឹងផ្អែកជាចំបាច់ទៅលើវិធានការ ដែលមានទ្រង់ទ្រាយធំ ដោយសារមានការលះបង់ ព្រមទាំងជំនាញរបស់បុគ្គលដែលមានតួនាទីនៅក្នុងអាជ្ញាធរ ក្នុងនាយកដ្ឋានជាច្រើននៅក្នុងរដ្ឋាភិបាលចក្រភពអាល្លឺម៉ង់ ដែលត្រូវរងការចោទប្រកាន់ពីបទចាត់ចែង និងអនុវត្តកម្មវិធីនេះ (...)។ គោលការណ៍ដែលបានបញ្ជាក់នៅទីនេះ គឺអាចអនុវត្តបានដូចគ្នាចំពោះចុងចោទនៅទីនេះ ដែលជាសមាជិកនៃគណៈរដ្ឋមន្ត្រី ព្រមទាំងអនុវត្តបានចំពោះចុងចោទទាំងឡាយណាដែលមានតួនាទីទទួលខុសត្រូវ និងអំណាចនៅក្នុងក្រសួងនានា")។ *រឿងក្ដី Pohl*, វ៉ុល V, ទំព័រ ៩៦២ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះអះអាងបន្ថែមទៀតថា ចុងចោទទាំងអស់ដែលជាប់ពាក់ព័ន្ធជាមួយនឹងស្នាក់ការកណ្ដាលផ្នែករដ្ឋបាល និងសេដ្ឋកិច្ចដែលត្រូវបានគេហៅថា "WVHA" ដែលនេះជានាយកដ្ឋានមួយក្នុងចំណោមនាយកដ្ឋានសំខាន់ៗចំនួន ១២ នៅក្នុងមន្ទីរ SS")។

[416] *រឿងក្ដីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ*, វ៉ុល II, ទំព័រ ១៨១។

[417] *រឿងក្ដីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ៩៨៤។

ចម្លើយសារភាពពីអ្នកទោស[418] ក៏ដូចជាការដាក់ទណ្ឌកម្មផងដែរ។ ការដាក់ទណ្ឌកម្មដែលជាគោលបំណងក្នុងការហាមឃាត់ ត្រូវបានបង្ហាញយ៉ាងច្បាស់ក្នុងរឿងក្តីពាក់ព័ន្ធនឹង*វេជ្ជសាស្ត្រ:*

> ជនជាប់ចោទព្យាយាមជំទាស់នឹងបទចោទនេះ ដោយលើកឡើងនូវមធ្យោបាយការពារថា បុគ្គលដែលត្រូវគេយកមកប្រើក្នុងការពិសោធន៍នេះ សុទ្ធតែជាអ្នកដែលត្រូវផ្តន្ទាទោសប្រហារជីវិត ដូច្នេះ លោក Mrguwosky ត្រូវបានគេជ្រើសរើសជាពេជ្ឈឃាដ។
>
> (...) មធ្យោបាយការពារនេះ មិនមានសុពលភាពនោះទេ។ នេះមិនមែនជាការអនុវត្តទោសប្រហារជីវិតស្របច្បាប់នោះទេ (...) ប៉ុន្តែ នេះជាការពិសោធន៍ផ្នែកវេជ្ជសាស្ត្រដែលមានលក្ខណៈជាបទឧក្រិដ្ឋ (...)។ ជនរងគ្រោះដ៏អភ័ព្វដោយសារការធ្វើទារុណកម្មគួរឱ្យខ្លាចរអានេះ គឺជាឈ្លើយសឹកជនជាតិរុស្ស៊ី ដែលមានសិទ្ធិទទួលបានការការពារដោយច្បាប់របស់បណ្តាប្រជាជាតិដែលមានអរិយធម៌ (...) ដែល ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ក៏មិនអនុញ្ញាតឱ្យមានការសម្លាប់ដោយការធ្វើទារុណកម្ម ឬការធ្វើកាយវិកលកម្មនោះទេ[419]។

១៩៩. ចំណុចទីពីរ យោងតាមសេចក្តីអត្ថាធិប្បាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិត្រង់មាត្រា ៣២ និង មាត្រា ១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ឆ្នាំ ១៩៤៩ កំណត់ថា៖

> ការធ្វើទារុណកម្ម គឺជាការវាយប្រហារទៅលើមនុស្ស ដែលជាការរំលោភបំពានទៅលើសិទ្ធិមនុស្សជាសារវន្ត (...) ។ ការវាយប្រហារមិនចាំបាច់តែទៅលើរូបរាងកាយនោះទេ ព្រោះថា "ភាពរីកចម្រើន"នៃវិទ្យាសាស្ត្រអាចមានការប្រើប្រាស់នូវវិធីសាស្ត្រដែលមិនចាំបាច់បង្កឱ្យមានរបួសស្នាមលើរូបរាងកាយ ប៉ុន្តែ អាចជាការឈឺចាប់ផ្នែករូបរាងកាយបានដែរ[420]។

២០០. បន្ថែមពីនេះទៀត អត្ថន័យតាមផ្លូវច្បាប់នៃការធ្វើទារុណកម្ម រួមមាន៖

---

[418] *សូមមើលខទា. រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៨៨ ដល់ ១០៩៣។

[419] *រឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ*, វ៉ុល II, ទំព័រ ២៤៦ ដល់ ២៤៧។

[420] និពន្ធនាយក Pictet (ed.), *សេចក្តីអត្ថាធិប្បាយស្តីពីអនុសញ្ញាទីក្រុងហ្សឺណែវ IV ទាក់ទងដល់ការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម*, ឆ្នាំ ១៩៥៨, ទំព័រ ២២៣ <http://www.icrc.org/eng/>។

> ការបង្កឱ្យមានការឈឺចាប់ដល់បុគ្គលណាមួយ ដើម្បីទទួលបាននូវចម្លើយសារភាព ឬព័ត៌មានពីបុគ្គលនោះ ឬបុគ្គលដទៃទៀត (...)។ ការបង្កឱ្យមានការឈឺចាប់នេះ មានលក្ខណៈធ្ងន់ធ្ងរជាងការវាយប្រហារទៅលើបូរណភាពបុគ្គលផ្នែករាងកាយ ឬស្មារតី។ ចំណុចដែលសំខាន់ គឺមិនសំដៅតែលើការឈឺចាប់ដែលជាគោលដៅនៅពីក្រោយការវាយប្រហារបង្កឱ្យមានការឈឺចាប់នោះឡើយ (...)[421]។

២០១. បំណកស្រាយនានាអំពីនិយមន័យនៃការធ្វើទារុណកម្ម ដែលមានកំណត់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ IV ឆ្នាំ ១៩៤៩ បានជួយគាំទ្រខ្លះដែរ ទៅលើ*ធាតុផ្សំសត្យានុម័ត* និង*អត្តនោម័ត* នៃសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម ក៏ដូចជាលក្ខខណ្ឌតម្រូវដែលថា ការធ្វើទារុណកម្មត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងទទួលបាននូវព័ត៌មាន ឬចម្លើយសារភាព។

២០២. ចំណុចទីបី នៅពេលធ្វើការបកស្រាយ និងអនុវត្តនូវចំណុចហាមឃាត់ការធ្វើទារុណកម្ម ដែលមានចែងក្នុងមាត្រា ៣ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស នៅក្នុងរឿងក្តី*ក្រិក* ឆ្នាំ ១៩៦៩ គណៈកម្មការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានកំណត់និយមន័យនៃការធ្វើទារុណកម្ម ខាងក្រោមដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនឹងនិយមន័យនៃការធ្វើទារុណកម្ម ដែលមានកំណត់ក្នុងសេចក្តីប្រកាស ឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្មៈ

> រាល់អំពើធ្វើទារុណកម្ម ត្រូវតែជាអំពើប្រព្រឹត្តឡើងដោយអមនុស្សធម៌ និងបន្ទាបបន្ថោក ហើយ អំពើអមនុស្សធម៌នោះ ក៏ជាការបន្ទាបបន្ថោក ផងដែរ។ សញ្ញាណនៃអំពើអមនុស្សធម៌ យ៉ាងហោចណាស់រួមមាន ការប្រព្រឹត្តដោយចេតនា បង្កឱ្យមានការឈឺចាប់រាងកាយ ឬស្មារតីដែលក្នុងស្ថានភាពជាក់លាក់ណាមួយក៏ដោយ ក៏មិនអាចចាត់ទុកថាមានភាពត្រឹមត្រូវតាមច្បាប់បានឡើយ។

---

[421]និពន្ធនាយក Pictet (ed.), *សេចក្តីអត្ថាធិប្បាយស្តីពីអនុសញ្ញាទីក្រុងហ្សឺណែវ IV ទាក់ទងដល់ការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម*, ឆ្នាំ ១៩៥៨, ទំព័រ ៥៩៨។

ពាក្យថា "ការធ្វើទារុណកម្ម" ត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីពណ៌នាពីអំពើអមនុស្សធម៌ ដែលមានគោលដៅទទួលបាននូវព័ត៌មាន ឬចម្លើយសារភាព ឬក៏ជាការដាក់ទណ្ឌកម្ម ហើយជាទូទៅ មានទម្រង់ជាអំពើអមនុស្សធម៌យ៉ាងធ្ងន់ធ្ងរ[422]។

២០៣. និយមន័យនេះមានធាតុផ្សំដូចជា៖ ការប្រព្រឹត្តដោយចេតនាទៅលើបុគ្គលណាមួយ (*ធាតុផ្សំអត្តនោម័ត*) ការឈឺចាប់យ៉ាងធ្ងន់ធ្ងរផ្នែករូបកាយ ឬស្មារតី (*ធាតុផ្សំសត្យានុម័ត*) សម្រាប់គោលបំណង ជាពិសេស ទទួលបាននូវព័ត៌មាន ឬចម្លើយសារភាព ឬក៏ការដាក់ទណ្ឌកម្ម។ មានចំណុចផ្សេងទៀតនៅក្នុងសេចក្តីសម្រេចរបស់គណៈកម្មការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ក៏បានពិចារណាអំពីលក្ខខណ្ឌតម្រូវនៃការចូលរួមជាផ្លូវការផងដែរ បើទោះជាសេចក្តីសម្រេចនោះបានបកស្រាយត្រឹមតែថា រដ្ឋាភិបាលក្រិកបានរំលោភទៅលើកាតព្វកិច្ចរបស់ខ្លួនដែលមានកំណត់ក្នុងអនុសញ្ញា ជាជាងថាមានធាតុផ្សំនៃអំពើធ្វើទារុណកម្ម ក៏ដោយ[423]។

២០៤. ជាចុងក្រោយ ទោះបីជានិយមន័យនៃការធ្វើទារុណកម្មដែលមានកំណត់ក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម ត្រូវបានអនុម័តដោយរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិតាមរយៈសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិដែលមានអានុភាព មិនចងកាតព្វកិច្ចក៏ដោយ ក៏ការអនុម័តដោយសេចក្តីសម្រេច "ដោយគ្មានការបោះឆ្នោត" (ពោលគឺ មានការគាំទ្រជាឯកច្ឆន្ទ)[424] នេះ គឺជាភស្តុតាងមួយដែលបង្ហាញថា និយមន័យនៃការធ្វើទារុណកម្មនៅក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយដោយសហគមន៍អន្តរជាតិ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នាពេលនោះ សមាជិកចូលរួមបោះឆ្នោតក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ សរុបមានចំនួន ១៤៤ រដ្ឋ[425]។

---

[422] *រឿងក្តីក្រិក, ព្រឹត្តប័ត្រប្រចាំឆ្នាំនៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស*, វ៉ុល ១២ (ឆ្នាំ ១៩៦៩), ទំព័រ ១៨៦។

[423] *រឿងក្តីក្រិក*, ទំព័រ ១៩៥ ដល់ ១៩៦ និង ៥០៤។

[424] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Furundžija*, កថាខណ្ឌ ១៦០។ *សូមមើល* UNBISnet, ប្រព័ន្ធព័ត៌មានស្តីពីប្រវត្តិនិងការផលិតសៀវភៅរបស់អង្គការសហប្រជាជាតិ, ការស្រាវជ្រាវកំណត់ត្រានៃការបោះឆ្នោត លើស្លាកសញ្ញានៃសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលេខ៖ A/RES/3452(XXX)។

[425] អង្គការសហប្រជាជាតិ, *ការកើនឡើងនូវចំនួនសមាជិករបស់អង្គការសហប្រជាជាតិ ពីឆ្នាំ ១៩៤៥ ដល់បច្ចុប្បន្ន*, <http://www.un.org/en/members/growth.shtml>។

២០៥. ហេតុដូច្នេះ ផ្អែកលើមូលដ្ឋានដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា និយមន័យនៃការធ្វើទារុណកម្មដែលមានកំណត់នៅក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម ដូចដែលបានកត់សម្គាល់មកនេះ គឺជាសេចក្តីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

២០៦. ដោយហេតុថា និយមន័យនៃការធ្វើទារុណកម្មដែលមានកំណត់នៅក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម អាចអនុវត្តបានតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិសម្រាប់គោលបំណងនៃសំណុំរឿងនេះ នោះបញ្ហាគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺថាតើអំពើរំលោភលើផ្លូវភេទបែបនេះដែលបានប្រព្រឹត្តនៅមន្ទីរ ស ២១ អាចចាត់ទុកថា ជាអំពើធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្របតាមការប្រកាសនៅឆ្នាំ ១៩៧៥ ដែរឬយ៉ាងណា។

២០៧. ចំពោះករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ទាក់ទងទៅនឹងធាតុផ្សំសត្យានុម័តនៃអំពើធ្វើទារុណកម្ម "អំពើមួយចំនួនត្រូវបានចាត់ទុកថា ជាអំពើដែលនឹងនាំឱ្យមានការឈឺចាប់ និងរងទុក្ខធ្ងន់ធ្ងរ *ដោយផ្អែកលើចរិតនៃអំពើទាំងនោះ*។ អំពើទាំងនោះរួមមាន ការរំលោភលើផ្លូវភេទ (...)[426]។ ហេតុដូច្នេះ "មិនមានការជំទាស់នោះទេដែលថា ការរំលោភលើផ្លូវភេទ អាចបង្កើតបានជាការធ្វើទារុណកម្ម នៅពេលដែលរាល់ធាតុផ្សំផ្សេងៗទៀតនៃអំពើធ្វើទារុណកម្មត្រូវបានបំពេញ"[427]។

២០៨. អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង ដែលថានិយមន័យនៃការរំលោភលើផ្លូវភេទ ដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ថាជាការបញ្ចូលអង្គជាតដោយគ្មានការយល់ព្រមពីជនរងគ្រោះ[428] ដែលប្រព្រឹត្តដោយចារី ដោយ

---

[426]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៥៥ (សេចក្តីបញ្ជាក់បន្ថែម)។

[427]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៦៦។

[428]និយមន័យពេញលេញនៃពាក្យថា ការរំលោភលើផ្លូវភេទ គឺជា"ការបញ្ចូលអង្គជាត ទោះបីជាមិនបានស៊ីជម្រៅក៏ដោយទៅក្នុងរន្ធយោនី ឬរន្ធគូទរបស់ជនរងគ្រោះដោយអង្គជាតរបស់ចារី ឬវត្ថុផ្សេងៗទៀតដែលប្រើប្រាស់ដោយចារី ឬការ

មានចេតនា និងដឹងថា គ្មានការយល់ព្រម[429]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានកត់សម្គាល់នៅក្នុងរឿងក្តី *Kunarac* ថា "អំពើមួយចំនួនដែលប្រព្រឹត្តឡើងបង្កឱ្យមានការឈឺចាប់ទៅលើបុគ្គលណាមួយ។ ការរំលោភលើផ្លូវភេទ គឺជាអំពើដែលស្តែងឱ្យឃើញបែបនេះ។ (...) អំពើហិង្សាលើផ្លូវភេទចាំបាច់ត្រូវតែបង្កឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងធ្ងន់ធ្ងរ ទោះបីផ្នែករូបកាយ ឬស្មារតី និងដោយស្របតាមមធ្យោបាយនេះហើយ ទើបចាត់ទុកអំពើរំលោភលើផ្លូវភេទថា ជាអំពើធ្វើទារុណកម្ម"[430]។ លើសពីនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTR ក្នុងរឿងក្តី *Alkayesu* បានបញ្ជាក់ថា ការរំលោភលើផ្លូវភេទ ជាញឹកញាប់ត្រូវបានប្រព្រឹត្តឡើង "ក្នុងគោលបំណងបំភិតបំភ័យ [ឬ] ដាក់ទណ្ឌកម្ម (...)។ ដូចគ្នានឹងអំពើធ្វើទារុណកម្មដែរ ការរំលោភលើផ្លូវភេទ គឺជាការបំពានលើសេចក្តីថ្លៃថ្នូររបស់បុគ្គល ហើយជាការពិត ការរំលោភលើផ្លូវភេទនេះ គឺជាអំពើធ្វើទារុណកម្ម នៅពេលដែលអំពើនេះប្រព្រឹត្តឡើងដោយផ្ទាល់ ឬដោយមានការញុះញង់ពី (...) មន្ត្រីសាធារណៈ (...)[431]។

---

បញ្ចូលតាមមាត់របស់ជនរងគ្រោះដោយអង្គជាតរបស់ចារី នៅពេលដែលការបញ្ចូលអង្គជាតនោះ កើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ"។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៦២ (ការដកស្រង់ត្រូវបានលុបចេញ)។

[429]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៦៥។

[430]សាលដីកាក្នុង *រឿងក្តី Kunarac*, កថាខណ្ឌ ១៥០។

[431]សាលក្រមក្នុង *រឿងក្តី Akayesu*, កថាខណ្ឌ ៥៧៩។ *សូមមើល* ការពិភាក្សារបស់លោកស្រី Valerie Oosterveld ស្តីពីបទឧក្រិដ្ឋផ្អែកលើយ៉េនឌ័រនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនមនុស្សជាតិ ដែលក្នុងនោះ លោកស្រីបានសរសេរថា "មានភាពសំខាន់ក្នុងការរក្សានូវលទ្ធភាពដើម្បីធ្វើការចោទប្រកាន់អំពើដែលមានមូលដ្ឋានលើយ៉េនឌ័រ ដែលស្ថិតក្នុងដែនកំណត់នៃអំពើដែលត្រូវបានហាមឃាត់ (...) ដូចជា (...) អំពើធ្វើទារុណកម្ម (...)" ដោយសំអាងលើហេតុផលជាច្រើនខុសៗគ្នា រួមទាំង "ការប្រព្រឹត្តនូវអំពើដែលត្រូវបានហាមឃាត់ អាចកើតឡើងនៅក្នុងចរិតលក្ខណៈដែលជាប់ពាក់ព័ន្ធនឹងយ៉េនឌ័រ" ហើយថា "អំពើជាក់លាក់មួយអាចត្រូវបានបង្ហាញបានដោយសារការប្រព្រឹត្តអំពើដែរមានមូលដ្ឋានលើយ៉េនឌ័រ ដែលជាភស្តុតាងមួយក្នុងចំណោមភស្តុតាងជាច្រើន"។ លោកស្រី Valerie Oosterveld, "បទឧក្រិដ្ឋដែលមានមូលដ្ឋានលើយ៉េនឌ័រនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ", និពន្ធនាយក Leila Nadya Sadat (ed.), *បង្កើតអនុសញ្ញាមួយស្តីអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*, ចេញផ្សាយដោយសាកលវិទ្យាល័យ Cambridge (Cambridge University Press), ឆ្នាំ ២០១១, ទំព័រ ១០០។

២០៩. ក្នុងសំណុំរឿងនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នៅមន្ទីរ ស ២១ "មានវិធីសាស្ត្រធ្វើទារុណកម្មជាច្រើន"[432] សម្រាប់គោលដៅសួរយកចម្លើយ "ដែលវិធីសាស្ត្រទាំងនេះ ត្រូវបានអនុវត្តក្នុងស្ថានភាព ដែលពោរពេញទៅដោយការភ័យខ្លាចយ៉ាងខ្លាំង ដែលការគំរាមកំហែងទាំងនេះ ត្រូវបានប្រើប្រាស់ជាប្រចាំ និងធ្វើឱ្យអ្នកជាប់ឃុំឃាំងមានការឈឺចាប់ធ្ងន់ធ្ងរទាំងរូបរាងកាយ និងផ្លូវចិត្ត"[433]។ វិធីសាស្ត្រសួរយកចម្លើយទាំងនេះ រួមមាន"ការរំលោភលើផ្លូវភេទមួយករណី"[434]។ បន្ថែមពីលើនេះ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា"បុគ្គលិកមន្ទីរ ស ២១ (...) ដែលបានប្រព្រឹត្តអំពើធ្វើទារុណកម្ម គឺបានបំពេញភារកិច្ចក្នុងសមត្ថកិច្ចផ្លូវការរបស់ពួកគេ"[435]។ បុគ្គលិកទាំងនោះ បានប្រព្រឹត្តអំពើដែលបង្កើតជាបទល្មើសនៃការធ្វើទារុណកម្ម "ក្នុងគោលបំណងដើម្បីទទួលបានចម្លើយសារភាព ឬក្នុងគោលបំណងដាក់ទណ្ឌកម្ម"[436]។

២១០. តាមសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញឱ្យឃើញថា វិធីសាស្ត្រសួរយកចម្លើយត្រូវបានធ្វើឡើងដោយចេតនារបស់បុគ្គលិកនៅមន្ទីរ ស ២១ ក្នុងគោលបំណងដាក់លាក់ និងដើម្បីបង្កឱ្យមានការឈឺចាប់ និងរងទុក្ខយ៉ាងធ្ងន់ធ្ងរ។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញបន្ថែមទៀតថា អំពើរំលោភលើផ្លូវភេទត្រូវបានយកមកប្រើក្នុងបរិបទដែលរួមមានគោលបំណងនៃការទាញយកព័ត៌មានពីជនរងគ្រោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសនោះទេក្នុងការយល់ឃើញថា អំពើរំលោភលើផ្លូវភេទឈានដល់កម្រិតចាត់ទុកជាអំពើធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទោះជាយ៉ាងណាក្តី ដោយហេតុដូចបានលើកឡើងខាងលើរួចមកហើយថា ការរំលោភលើផ្លូវភេទមិនទាន់ត្រូវបានចាត់ជាបទល្មើសមូលដ្ឋានមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនាពេលនោះនៅឡើយទេ ហេតុដូច្នេះ អំពើរំលោភ

---

[432]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ២៤១។

[433]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៦០។

[434]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៥៩ ដល់ ៣៦០។

[435]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៥៩។

[436]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៦០។

លើផ្លូវភេទនេះ មិនអាចស្រូបបញ្ចូលទៅក្នុងអំពើទារុណនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ។

២១១. ទាក់ទងនឹងគោលការណ៍នីត្យានុកូលភាពវិញ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដោយសារតែយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី ២ ស្របតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ជនជាប់ចោទអាចយល់ដឹងជាមុនដោយខ្លួនឯងថា ខ្លួនពិតជាអាចរងការចោទប្រកាន់ពីអំពើធ្វើទារុណកម្ម ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នាពេលប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវប្តឹងចោទប្រកាន់នោះ។ លើសពីនេះទៀត នៅក្នុងពេលនោះដែរ ជនជាប់ចោទបានដឹងពីនិយមន័យនៃអំពើធ្វើទារុណកម្មក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម ដូចដែលឆ្លុះបញ្ចាំង និងមានការគាំទ្រដោយនិយមន័យនៃអំពើធ្វើទារុណកម្មដែលបានដកស្រង់ចេញពីអង្គហេតុនានានៅក្នុងរឿងក្តី ផ្អែកតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ក៏ដូចជានិយមន័យនៃអំពើធ្វើទារុណកម្មដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ I-IV ឆ្នាំ ១៩៤៩ ព្រមទាំងនិយមន័យនៃអំពើធ្វើទារុណកម្មដែលមានកំណត់ក្នុងមាត្រា ៣ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សឆ្នាំ ១៩៥០ ដូចដែលបានបង្ហាញយ៉ាងច្បាស់ក្នុង*រឿងក្តីក្រិក*ឆ្នាំ ១៩៦៩។ បន្ថែមពីលើនេះទៀត តាមរយៈនិយមន័យនៃអំពើទារុណកម្មដែលចូលជាធរមានក្នុងឆ្នាំ ១៩៧៥ ជនជាប់ចោទអាចយល់ដឹងជាមុនថា ខ្លួនអាចនឹងត្រូវរងការចោទប្រកាន់ពីអំពើធ្វើទារុណកម្ម ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារតែតាមធាតុផ្សំសត្យានុម័ត បង្កើតបានជាអំពើរំលោភលើផ្លូវភេទ ហើយរាល់ធាតុផ្សំដទៃទៀតត្រូវបានបំពេញ។

២១២. ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងដែលថា "ទោះបីជាអំពើអសីលធម៌ ឬអំពើដែលមានចរិតឃោរឃៅ ពុំមែនជាកត្តាគ្រប់គ្រាន់ដែលអាចចាត់ជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏ប៉ុន្តែជាការពិតអំពើអសីលធម៌ ឬអំពើដែលមានចរិតឃោរឃៅនេះ មានតួនាទីនៅក្នុងរឿងព្រហ្មទណ្ឌនៅក្នុងកម្រិតមួយដែលអាចបដិសេធការអះអាងរបស់មេធាវីការពារក្តី ដែលបានលើកឡើងថា ជន

ជាប់ចោទមិនបានដឹងពីអំពើឧក្រិដ្ឋរបស់ខ្លួននោះ"[437]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នាពេលជនជាប់ចោទប្រព្រឹត្តអំពើឧក្រិដ្ឋ គឺមានភាពច្បាស់លាស់ណាស់ដែលថា អំពើធ្វើទារុណកម្ម គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិជាសារវន្តរបស់បុគ្គល។ ដូចដែលបានកត់សម្គាល់កន្លងរួចមកហើយថា ត្រឹមឆ្នាំ ១៩៧៥ អំពើធ្វើទារុណកម្មត្រូវបានហាមឃាត់ដាច់ខាតក្នុងចំណោមអំពើទាំងឡាយនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរបំផុត ទៅលើសិទ្ធិមនុស្ស ដូចដែលមានកំណត់នៅក្នុងសន្ធិសញ្ញា និងសេចក្តីប្រកាសជាអន្តរជាតិនានាជាច្រើន[438]។ ហេតុដូច្នេះ ការទទួលស្គាល់យ៉ាងទូលំទូលាយ ដោយបណ្តាសហគមន៍ប្រជាជាតិនានាអំពីភាពធ្ងន់ធ្ងរនៃអំពើធ្វើទារុណកម្ម បានបង្ហាញពីភាពអាចយល់ដឹងជាមុនថា មានការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើបែបនេះថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ៤.ឃ.៣.សេចក្តីសន្និដ្ឋាន

២១៣. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើរំលោភលើផ្លូវភេទ គឺជាបទល្មើសមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយយោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការស្រូបបញ្ចូលបទរំលោភលើផ្លូវភេទ ដែលជាបទល្មើសដាច់ដោយឡែកមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងបទធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទោះជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសទេ ក្នុងការសន្និដ្ឋានថា ករណីនៃការរំលោភលើផ្លូវភេទមួយដែលស្ថិតក្រោមនិយមន័យនៃអំពើទារុណកម្ម ដែលមានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ មានចែងក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ប្រឆាំងនឹងអំពើទារុណ

[437] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣២ (ការដកស្រង់ត្រូវបានលុបចេញ)។

[438] អង្គជំនុំជម្រះតុលាការកំពូលសូមកត់សម្គាល់ថា មាត្រា ៧ នៃសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម បានអំពាវនាវដល់រដ្ឋទាំងអស់ឱ្យ "ធានាថា អំពើទារុណកម្មទាំងអស់ ដូចមានចែងក្នុងមាត្រា ១ គឺជាបទល្មើសដែលស្ថិតក្រោមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន។ ការធានានេះក៏ត្រូវអនុវត្តដូចគ្នាសម្រាប់អំពើទាំងឡាយដែលជាការចូលរួម ការសមគំនិត ការញុះញង់ ឬក៏ការប៉ុនប៉ងប្រព្រឹត្តអំពើទារុណកម្ម"ផងដែរ។ មាត្រា ៧ នៃសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម។

កម្ម។ លើសនេះទៅទៀត ដោយសារថា ការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនត្រូវបានចែងច្បាស់លាស់នាពេលនោះ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសទេ នៅពេលដែលខ្លួនមិនបានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាទៅលើជនជាប់ចោទ ពីបទធ្វើទារុណកម្ម ជាមួយនឹងបទរំលោភលើផ្លូវភេទដែលជាបទល្មើសដាច់ដោយឡែកពីគ្នា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

២១៤. ហេតុដូច្នេះ ដោយផ្អែកលើមូលដ្ឋានដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធផ្នែកនេះនៃទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

## ៤.ខ.ការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩

២១៥. ដើម្បីឆ្លើយតបទៅនឹងបញ្ហាជាក់លាក់ ដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណា ថាតើការធ្វើទុក្ខបុកម្នេញ គឺជាបទល្មើសមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់អន្តរជាតិក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដែរ ឬយ៉ាងណា បើផ្អែកតាមគោលការណ៍នីត្យានុកូលភាព។ ប្រសិនបើ ការធ្វើទុក្ខបុកម្នេញ គឺជាបទល្មើសមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះតុលាការកំពូលនឹងកំណត់ធាតុផ្សំតម្រូវចាំបាច់នៃបទល្មើស ដោយផ្អែកតាមនិយមន័យនៃឧក្រិដ្ឋកម្មនេះ តាមតែធាតុផ្សំដែលបានកំណត់ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ដូចដែលបានកត់សម្គាល់ពីមុន ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា បានចែងយ៉ាងច្បាស់ថា ជាបទល្មើសមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[439]។

### ៤.ខ.១.អត្ថិភាពនៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

២១៦. ឫសគល់នៃការធ្វើទុក្ខបុកម្នេញនៅក្នុងច្បាប់អន្តរជាតិ បានចាប់ផ្តើមជាច្រើនសតវត្សរ៍មកហើយ មុនពេលដែលធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) បានចងក្រងជាលើកដំបូងនូវបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិថា ជាឧក្រិដ្ឋកម្មអន្តរជាតិ[440]។ នៅឆ្នាំ ១៦២៥ Hugo Grotius បាននិពន្ធជាស្នាដៃសំខាន់សម្រាប់ការផ្សព្វផ្សាយរបស់គាត់ ដែលមានចំណងជើង

[439]មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[440]មាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការយោធា (IMT)។

*De jure belli ac pacis* ដែលជាស្នាដៃមួយក្នុងចំណោមស្នាដៃគ្រឹះនៃនីតិអន្តរជាតិ[441]។ Grotius បាននិពន្ធជាស្នាដៃនេះក្នុងយុគសម័យកែទម្រង់ នៅពេលដែលមានការលេចឡើងនូវនិកាយគ្រីស្តសាសនាផ្សេងៗ ដែលភ្ជាប់មកជាមួយនូវការកើនឡើងនៃការធ្វើទុក្ខបុកម្នេញ។ ទាក់ទងនឹងព្រឹត្តិការណ៍ទាំងនេះ Grotius បានចាត់ទុកថា ជាអំពើ"អយុត្តិធម៌ក្នុងការធ្វើទុក្ខបុកម្នេញដោយដាក់ទណ្ឌកម្មដល់បុគ្គលទាំងឡាយ ដែលទទួលយកច្បាប់ព្រះគ្រីស្តថា ត្រឹមត្រូវ ប៉ុន្តែបុគ្គលនោះនៅមានគំនិតមន្ទិលសង្ស័យ ឬមានកំហុស ចំពោះចំណុចបន្ទាប់បន្សំមួយចំនួននៃច្បាប់ព្រះគ្រីស្ត ដោយយល់ថា ចំណុចទាំងនោះមិនមានអត្ថន័យច្បាស់លាស់ ឬខុសពីគ្រីស្តសាសនិកអភិរក្សនិយម"[442]។ Grotius បានពន្លាតគោលការណ៍មិនធ្វើទុក្ខបុកម្នេញនេះ រហូតដល់អ្នកដែលមិនកាន់សាសនាគ្រីស្តទៀត ដោយផ្អែកលើមូលហេតុថា "ព្រះគ្រីស្តដែលជាអ្នកបង្កើតច្បាប់ថ្មី នឹងមិនតម្រូវឱ្យនរណាម្នាក់ត្រូវប្រតិបត្តិតាមលទ្ធិរបស់ព្រះអង្គ ដោយសារភ័យខ្លាចពីការដាក់ទណ្ឌកម្មនោះទេ"[443]។

២១៧. បន្ថែមពីលើនេះ ជាយូរលង់មកហើយ នៅមុនពេលដែលតុលាការជំនុំជម្រះលើឧក្រិដ្ឋកម្មអន្តរជាតិ រដ្ឋជាច្រើន បានជំទាស់ជាញឹកញាប់ទៅនឹងអំពើធ្វើទុក្ខបុកម្នេញរបស់រដ្ឋមួយចំនួនផ្សេងទៀត ជាពិសេសនៅពេលជនរងគ្រោះ គឺជាក្រុមជនជាតិភាគតិចដែលមានចំណងទាក់ទងជាមួយនឹងរដ្ឋជំទាស់នោះ។ នៅក្នុងករណីមួយចំនួន រដ្ឋបានចុះសន្ធិសញ្ញាទ្វេភាគី ដើម្បីបញ្ញត្តិប្រព្រឹត្តកម្មចំពោះជនជាតិភាគតិចណាមួយ និងដើម្បីការពារអ្នកទាំងនោះពីការធ្វើទុក្ខបុកម្នេញដែលមានការគាំទ្រពីរដ្ឋ[444]។ លើសពីនេះទៅទៀត ប្រជាជាតិទាំងឡាយដែលបានធ្វើ

[441] ព្រឹតបត្រនិពន្ធដោយ Hedley Bull, Benedict Kingsbury និង Adam Roberts, ចំណងជើងថា *Hugo Grotius និងទំនាក់ទំនងអន្តរជាតិ*, ចេញផ្សាយដោយសាកលវិទ្យាល័យ Oxford (Oxford University Press), ឆ្នាំ ១៩៩២, ទំព័រ ៩៥។

[442] អ្នកនិពន្ធ Grotius, សៀវភៅចំណងជើងថា *De jure belli ac pacis*, គន្ថី II, ឆ្នាំ ១៦២៥, ជំពូក ២០ , កថាខណ្ឌ L។

[443] អ្នកនិពន្ធ Grotius, សៀវភៅចំណងជើងថា *De jure belli ac pacis*, គន្ថី II, ឆ្នាំ ១៦២៥, ជំពូក ២០, កថាខណ្ឌ XLVIII។

[444] *សូមមើលឧទា. សន្ធិសញ្ញាមិត្តភាពពាណិជ្ជកម្ម និងការធ្វើនាវាចរណ៍* បារាំង-កូរ៉េ ចុះហត្ថលេខា ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៨៨៦, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៨៨៦, ដែលមានចំណងជើងថា Parry Consolidated Treaty Series, វ៉ុល ១៦៨, ទំព័រ

ទុក្ខបុកម្នេញលើគ្រីស្តសាសនិក បានផ្តល់ដល់ប្រទេសដែលកាន់គ្រីស្តសាសនា នូវយុត្តិកម្ម ដើម្បីបង្កសង្គ្រាមជាមួយប្រទេស ដែលបានធ្វើទុក្ខបុកម្នេញលើគ្រីស្តសាសនិកនោះ[445]។ នៅក្នុងករណីធ្ងន់ធ្ងរបំផុត ប្រទេសនានាស្វែងរកកិច្ចការពារដល់ក្រុមជនជាតិភាគតិច នៅក្នុងប្រទេសផ្សេងទៀត តាមរយៈការប្រកាសសង្គ្រាម[446]។

២១៨. ដូច្នេះ រដ្ឋនានាបានស្វែងរកកិច្ចការពារប្រឆាំងនឹងការធ្វើទុក្ខបុកម្នេញ ផ្អែកតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានជាយូរលង់ណាស់មកហើយ តាំងពីមុនសង្គ្រាមលោកនាសតវត្សទី ២០ ទៅទៀត។ តែទោះបីជាយ៉ាងណាក៏ដោយ ការធ្វើទុក្ខបុកម្នេញត្រូវបានចាត់ទុកថា ជា*បទល្មើស*ផ្អែកតាមនីតិអន្តរជាតិសាធារណៈ បើពិនិត្យនៅក្នុងបរិបទនៃមូលហេតុត្រឹមត្រូវសម្រាប់ប្រទេសមួយ ក្នុងការបង្កសង្គ្រាមប្រឆាំងនឹងប្រទេសមួយផ្សេងទៀត មិនមែនជាឧក្រិដ្ឋកម្មអន្តរជាតិ ដែលតម្រូវឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលនោះទេ។

២១៩. រហូតដល់ចប់សង្គ្រាមលោកលើកទី I ទើបមានការលើកឡើងជាលើកដំបូងថា ការធ្វើទុក្ខបុកម្នេញ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតម្រូវឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល។ នៅពេលពិនិត្យលើការបំពារបំពានច្បាប់ និងទំនៀមទម្លាប់សង្គ្រាម និងច្បាប់មនុស្សជាតិ ដែលបានប្រព្រឹត្តឡើងដោយប្រទេសអាល្លឺម៉ង់ និងសម្ព័ន្ធមិត្តរបស់ខ្លួនក្នុងអំឡុង

---

៤៩, មាត្រា ៤ (វាក្យខណ្ឌ ២), (ធានាថា នាពេលអនាគត ពលរដ្ឋជនជាតិបារាំង នឹងមាន"សេរីភាពក្នុងការប្រតិបត្តិសាសនា")។

[445]អ្នកនិពន្ធ Grotius, សៀវភៅចំណងជើងថា *De jure belli ac pacis*, គន្លឹ II, ជំពូក ២០ កថាខណ្ឌ XLIX ("អំពើឃោរឃៅលើអ្នកកាន់សាសនាគ្រីស្ត គឺជាយុត្តិកម្មមួយសម្រាប់បង្កសង្គ្រាម")។

[446]*សូមមើលឧទា.* បដិវត្តន៍ Bohemian ឆ្នាំ ១៦១៨ រីករាលដាលជាសង្គ្រាមកាន់តែធំឡើង នៅពេលព្រះអង្គម្ចាស់ប្រូតេស្តង់ដែលនៅជាប់ប្រទេសជាមួយគ្នា បានបញ្ជូនកម្លាំងយោធាទៅជួយជនរួមជាតិសាសនានៅ Bohemia ដែលភ័យខ្លាចការធ្វើទុក្ខបុកម្នេញសាសនាដោយចក្រភពរ៉ូម៉ាំងកាតូលិក (Catholic Holy Roman Empire)។ ទីបំផុត ជម្លោះនេះបានក្លាយជាសង្គ្រាមរយៈពេលសាមសិបឆ្នាំ ដែលត្រូវបានបញ្ចប់ដោយការចុះសន្ធិសញ្ញាសន្តិភាព Westphalia ឆ្នាំ ១៦៤៨។ សន្ធិសញ្ញាទាំងនេះ ចែងបទប្បញ្ញត្តិដែលហាមឃាត់មិនឱ្យធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ។ *សូមមើលឧទា. សន្ធិសញ្ញាសន្តិភាព* ចក្រភពរ៉ូម៉ាំង Sweden-Holy ចុះហត្ថលេខា នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៦៤៨, ដែលមានចំណងជើងថា Parry Consolidated Treaty Series, វ៉ុល ១, ទំព័រ ២០៩, មាត្រា XXVIII-XXXIV។

ពេលសង្គ្រាមលោកលើកទី I គណៈកម្មការដែលមានសមាជិក ១៥(ដប់ប្រាំ) ប្រទេស (Commission of Fifteen Members) បានបង្កើតឡើងក្នុងឆ្នាំ ១៩១៩ ដោយសន្និសីទលើកដំបូងស្តីពីសន្តិភាព (Preliminary Peace Conference) បានសន្និដ្ឋាននៅក្នុងរបាយការណ៍របស់ខ្លួនថា "បុគ្គលទាំងអស់របស់ប្រទេសបច្ចាមិត្ត (...) ដែលមានពិរុទ្ធភាពពីបទល្មើសប្រឆាំងនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាម ឬ*ច្បាប់មនុស្សជាតិ* ត្រូវទទួលខុសត្រូវចំពោះការចោទប្រកាន់ពីបទឧក្រិដ្ឋ"[447]។ គណៈកម្មការនេះបានភ្ជាប់ជាឧបសម្ព័ន្ធនូវបញ្ជីនៃការរំលោភបំពាននានានៅក្នុងរបាយការណ៍របស់ខ្លួន រួមបញ្ចូលទាំងការរំលោភបំពានទាំងឡាយដែលត្រូវបានចាត់ជាប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះគឺ"ការសម្លាប់រង្គាលលើជនជាតិអាម៉េនី (Armenians) ដែលដឹកនាំដោយពួកទួរគី (Turks) និងការសម្លាប់រង្គាល *ការធ្វើទុក្ខបុកម្នេញ* និងការបណ្តេញប្រជាជននិយាយភាសាក្រិកចេញពីប្រទេសទួរគី ព្រមទាំងជនជាតិអំបូរអឺរ៉ុប និងអាស៊ី"[448]។ ទោះបីជាយ៉ាងណាក៏ដោយ ទើបតែក្រោយសង្គ្រាមលោកលើកទី II ប៉ុណ្ណោះ ទើបការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលចំពោះការធ្វើទុក្ខបុកម្នេញ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានគេយកមកអនុវត្តយ៉ាងពិតប្រាកដ ដោយផ្អែកលើនីតិអន្តរជាតិ។ "ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា" ត្រូវបានដាក់បញ្ចូលទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានចងក្រងនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ (IMT)[449] ធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE)[450] ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[451] និងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០[452]។

[447]អ្នកនិពន្ធ Schwelb, "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ", ទំព័រ ១៨១។

[448]អ្នកនិពន្ធ Schwelb, "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ", ទំព័រ ១៨១ (សេចក្តីបញ្ជាក់បន្ថែម)។

[449]មាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការយោធា IMT។

[450]មាត្រា ៥(គ) នៃធម្មនុញ្ញរបស់តុលាការយោធា IMTFE។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ធម្មនុញ្ញរបស់តុលាការយោធា IMTFE មិនបានរួមបញ្ចូលសាសនា ថាជាមូលហេតុនៃអំពើធ្វើទុក្ខបុកម្នេញឡើយ។

[451]មាត្រា II(១)(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។

[452]គោលការណ៍ VI (គ) នៃគោលការណ៍ Nuremberg ឆ្នាំ ១៩៥០។

២២០. នៅទីបំផុត តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE) មិនបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទជាជនជាតិជប៉ុនណាម្នាក់ពីបទធ្វើទុក្ខបុកម្នេញ ឬបទល្មើសណាមួយផ្សេងទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ។ ផ្ទុយទៅវិញ ការជំនុំជម្រះលើពួកណាស៊ីដែលជាគ្រឿងមួយ (Nazi) បានផ្តល់នូវប្រភពភស្តុតាងយ៉ាងសំខាន់សម្រាប់ការវិវឌ្ឍនៃការធ្វើទុក្ខបុកម្នេញ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) បានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ ដូចជា Hermann Wilhelm Göring, Joachim Von Ribbentrop, Alfred Rosenberg, Hans Frank, Wilhelm Frick, Julius Streicher, Walter Funk, Arthur Seyss-Inquart និង Martin Bormann ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយរួមបញ្ចូលទាំងអំពើធ្វើទុក្ខបុកម្នេញ ជាពិសេសសំដៅប្រឆាំងនឹងជនស៊ីវិលជាជនជាតិជ្វីហ្វ និងប៉ូឡូញនៅក្នុងប្រទេសអាល្លឺម៉ង់ និងនៅក្នុងទឹកដីដែលខ្លួនត្រួតត្រា ដោយមូលហេតុនយោបាយ និងពូជសាសន៍[453]។ បន្ថែមពីលើនេះ ជនជាប់ចោទ Bormann ដែលជាលេខារបស់ Adolf Hitler "បានអនុវត្តយ៉ាងសកម្មបំផុតនៅក្នុងការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ មិនមែនត្រឹមតែនៅក្នុងប្រទេសអាល្លឺម៉ង់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងប្រទេសដែលខ្លួនដណ្តើមបាន ឬដាក់ក្រោមការត្រួតត្រាទៀតផង។ គាត់បានចូលរួមនៅក្នុងកិច្ចពិភាក្សា ដែលនាំឱ្យមានការជម្លៀសជនជាតិជ្វីហ្វចំនួន ៦០.០០០ (ហុកសិបពាន់) នាក់ ពីទីក្រុងវីយែន (Vienna) ទៅកាន់ប្រទេសប៉ូឡូញ"[454]។ បន្ថែមពីលើនេះ ជនជាប់ចោទ "បានលះបង់ពេលវេលាជាច្រើនរបស់ខ្លួន ក្នុងការធ្វើទុក្ខបុកម្នេញលើវិហារសាសនាគ្រឹស្ត (...) នៅក្នុងប្រទេសអាល្លឺម៉ង់"[455]។

---

[453]សាលក្រមតុលាការយោធា IMT, វ៉ុល I, ទំព័រ ៦៦ ដល់ ៦៧, ២៨២, ២៨៧ ដល់ ២៨៨, ២៩៥ ដល់ ២៩៨, ៣០០ ដល់ ៣០៧, ៣២៨ ដល់ ៣៣០, ៣៣៩ ដល់ ៣៤១។

[454]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៨៦។

[455]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៨៥។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា តុលាការយោធា IMT សម្រេចសំអាងហេតុនេះនៅក្នុងបរិបទនៃកិច្ចពិភាក្សារបស់ខ្លួនអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ Bormann យោងតាមផ្នែកស្តីពី"បទឧក្រិដ្ឋប្រឆាំងសន្តិភាព"។ ទោះជាយ៉ាងណាក៏ដោយ ជាការបង្ហាញអំពីទស្សនៈរបស់ខ្លួនថា អង្គហេតុដែលបានលើកឡើង បានបង្ហាញថា ជនជាប់ចោទមានជាប់ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា។

២២១. ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងការជំនុំជម្រះរបស់តុលាការយោធា Nuremberg នៅក្នុងតំបន់ត្រួតត្រាដោយអាល្លឺម៉ង់ មានការសម្រេចដាក់ពិរុទ្ធភាពជាច្រើនពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា។ ឧទាហរណ៍ នៅក្នុងរឿងក្តីពាក់ព័ន្ធ*វិស័យយុត្តិធម៌* ជនជាប់ចោទ Oswald Rothaug ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍លើជនជាតិប៉ូឡូញ និងជ្វីហ្វ[456]។ ជនជាប់ចោទ Curt Rothenberger មួយរូបទៀត ក៏ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញលើជនជាតិប៉ូឡូញ និងជនជាតិជ្វីហ្វ ដោយសារជនជាប់ចោទបានដកហូតសិទ្ធិរបស់ជនរងគ្រោះទាំងនោះ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី[457]។ លើសពីនេះទៀត នៅក្នុងរឿងក្តី *RuSHA* តុលាការបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទមួយចំនួន ដែលជាសមាជិកនៃភ្នាក់ងារមួយក្នុងចំណោមភ្នាក់ងារនៃមន្ទីរសន្តិសុខ (SS) ទាំងបួនដែលជាប់ពាក់ព័ន្ធនឹងចំណុចផ្សេងៗ នៃកម្មវិធីពូជសាសន៍របស់ណាហ្ស៊ី (Nazi)[458]។ តុលាការបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទធ្វើទុក្ខបុកម្នេញលើជនជាតិប៉ូឡូញ និងជ្វីហ្វ ដោយមូលហេតុពូជសាសន៍[459]។

២២២. ឧទាហរណ៍ផ្សេងមួយទៀត នៅក្នុងរឿងក្តីទាក់ទងនឹង*ក្រសួងផ្សេងៗ* (*Ministries Case*) ដែលមានជនជាប់ចោទ Richard Walther Darré, Otto Dieterich, Hans Heinrich Lammers, Wilhelm Stuckart និង Lutz Schwerin von Krosigk ត្រូវបានរកឃើញថាមានពិរុទ្ធពីបទធ្វើទុក្ខបុកម្នេញ[460] លើជនជាតិប៉ូឡូញ ជ្វីហ្វ និង"បច្ចាមិត្ត និងអ្នកប្រឆាំងនឹង

---

[456] *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ២៣ ដល់ ២៥ និង ១១១៤ ដល់ ១១៥៦។

[457] *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១១១០ ដល់ ១១១៤, ១១១៨។

[458] *រឿងក្តីសហរដ្ឋអាមេរិក ទល់នឹង Greifelt និងជនដទៃទៀត*, "សាលក្រម", ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៤៨ បោះពុម្ពឡើងវិញព្រឹត្តប័ត្រ*នៅក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, វ៉ុល IV-V, ("រឿងក្តី *RuSHA*") វ៉ុល V, ទំព័រ ១៥២ ដល់ ១៥៣, ១៥៥, ១៥៨ ដល់ ១៦២។

[459] *រឿងក្តី RuSHA*, វ៉ុល V, ទំព័រ ១៥២ ដល់ ១៥៣, ១៥៥, ១៥៨ ដល់ ១៦២។

[460] *រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ* វ៉ុល XIV, ទំព័រ ៥៦៣ ដល់ ៥៦៥, ៥៧៥ ដល់ ៥៧៦, ៦០០ ដល់ ៦០១, ៦០៣ ដល់ ៦០៥, ៦៤៥ ដល់ ៦៤៦, ៦៧៥ ដល់ ៦៨០។ *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg*

លទ្ធិសង្គមនិយមជាតិនិយម (National Socialism)" ដោយមូលហេតុពូជសាសន៍ និងនយោបាយ[461]។ លើសពីនេះទៀត ទោះបីជាជនជាប់ចោទ Gustav Adolf Steengracht von Moyland, Ernst von Weizsaecker និង Ernst Woermann ជាចុងក្រោយត្រូវបានរកឃើញថា គ្មានពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយមូលហេតុសាសនា ដោយសារមិនមានភស្តុតាងគ្រប់គ្រាន់ អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលក៏ដោយ[462] ក៏តុលាការរកឃើញថា របបណាហ្ស៊ី (Nazi) មាន"ផែនការថ្នាក់រដ្ឋាភិបាលច្បាស់លាស់"[463] ដើម្បីធ្វើទុក្ខបុកម្នេញវិហារកាតូលិក អ្នកមានឋានៈខ្ពស់ក្នុងសាសនាបុព្វជិត ដូនជី និងគ្រីស្តបរិស័ទនៅក្នុងប្រទេសអាល្លឺម៉ង់ និងទឹកដីដែលអាល្លឺម៉ង់ត្រួតត្រា[464]។

២២៣. បន្ថែមពីលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានអនុវត្តចំពោះមន្ត្រីណាហ្ស៊ី (Nazi) និងសម្ព័ន្ធមិត្តរបស់ខ្លួន ត្រូវបានយកមកអនុវត្តបន្ទាប់ពីបញ្ចប់ដំណើរការនីតិវិធីរបស់តុលាការយោធាអន្តរជាតិ (IMT) និងតុលាការយោធា Nuremberg។ នៅក្នុងឆ្នាំ ១៩៤៦ តុលាការកំពូលរបស់ប្រទេសប៉ូឡូញ បានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ Artur Greiser ពីបទធ្វើទុក្ខបុកម្នេញលើជនជាតិប៉ូឡូញ ជ្វីហ្វ អ្នកកាន់សាសនាកាតូលិក និងប្រូតេស្តង់[465]។ ក្រោយមកទៀត នៅឆ្នាំ ១៩៦៨ តុលាការកំពូលរបស់ប្រទេសអ៊ីស្រាអែលបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ Adolf Eichmann ពីបទធ្វើទុក្ខបុកម្នេញ និងបានគាំទ្រការសម្រេចដាក់ពិរុទ្ធភាព ដោយគូសបញ្ជាក់អំពីអង្គហេតុដែលថា "ក្នុងការប្រព្រឹត្តអំពើដូចបានរៀបរាប់ខាងលើ (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការ

*ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង* វ៉ុល XIII, ទំព័រ ១១៨ (បទជាប់ពាក់ព័ន្ធនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរួមបញ្ចូលអំពើធ្វើទុក្ខបុកម្នេញ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។

461 *រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៦០៤។

462 *រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៥២៦ ដល់ ៥២៨។

463 *រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៥២០។

464 *រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៥២០ ដល់ ៥២២។

465 *រឿងក្តី Greiser*, ទំព័រ ២ ដល់ ៤ និង ១០៥។

បង្អត់អាហារ ការនិរទេសជនស៊ីវិលជាជនជាតិជ្វីហ្វ) ជនជាប់ចោទបានធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ ដោយមូលហេតុជាតិ ពូជសាសន៍ សាសនា និងនយោបាយ”[466]។

២២៤. ដូចគ្នានេះដែរ នៅឆ្នាំ ១៩៨៥ តុលាការកំពូលរបស់ប្រទេសបារាំង អនុញ្ញាតឱ្យមានការចោទប្រកាន់ជនជាប់ចោទ Klaus Barbie ពី“បទធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ ដោយមូលហេតុពូជសាសន៍ និងសាសនា ក្នុងការសម្លាប់រង្គាល (...) ដើម្បីសម្រេច*គោលបំណងចុងក្រោយ*” ក្នុងអំឡុងសង្គ្រាមលោកលើកទី II[467]។ ជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព និងប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅឆ្នាំ ១៩៨៧ ដែលត្រូវបានសម្រេចតម្កល់ ដោយតុលាការកំពូលរបស់ប្រទេសបារាំងនៅឆ្នាំ ១៩៨៨[468]។ នៅឆ្នាំ ១៩៨៦ សាលាដំបូងក្រុង Zagreb របស់ប្រទេសក្រូអាស៊ីបានប្រកាសទោសប្រហារជីវិតលើជនជាប់ចោទ Andrija Artuković ដែលជាសមាជិកជាន់ខ្ពស់របស់ចលនា Ustaša នៅក្នុងសង្គ្រាមលោកលើកទី II[469]។ សាលាដំបូងក្រុង Zagreb បានរកឃើញថា ដោយសារមាគ៌ានយោបាយនៃចលនា Ustaša ជនជាប់ចោទ Artuković បានបញ្ជាឱ្យសម្លាប់ជាទ្រង់ទ្រាយធំ និងឱ្យជម្លៀសមនុស្សទៅជំរំប្រមូលផ្តុំដែលជាផ្នែកនៃកម្មវិធីមួយក្នុងការបង្កើតប្រទេស ដែលមានជនជាតិក្រូអាតសុទ្ធតែមួយ[470]។ កម្មវិធីនេះបានអនុវត្តនូវ “ការធ្វើទុក្ខបុកម្នេញ ជំរំប្រមូលផ្តុំ និងការសម្លាប់ជាទ្រង់ទ្រាយធំលើជនជាតិស៊ែប ជ្វីហ្វ ជីពស៊ី (Gypsies) ព្រមទាំងក្រូអាត ដែលមិនព្រមទទួលយកមនោគមន៍វិជ្ជានេះ”[471]។

---

[466] *រឿងក្តី Eichmann*, ទំព័រ ២៧៧ ទំព័រ ២៧៨។

[467] *រឿងក្តី Barbie*, ទំព័រ ១៣៩។

[468] *រឿងក្តី Barbie*, ឆ្នាំ ១៩៨៨ ទំព័រ ៣៣២។

[469] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៦០២, ដកស្រង់ចេញពី *រឿងក្តី Artuković*, ទំព័រ ២៣។

[470] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៦០២, ដកស្រង់ចេញពី *រឿងក្តី Artuković*, ទំព័រ ២៣។

[471] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៦០២, ដកស្រង់ចេញពីរឿងក្តី *Artuković*, ទំព័រ ២៣។

២២៥. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ត្រឹមឆ្នាំ ១៩៧៥ មានភស្តុតាងបង្ហាញយ៉ាងច្បាស់អំពី *ទស្សនៈច្បាប់* (opinio juris) និងការអនុវត្តរបស់រដ្ឋ ក្នុងការទទួលស្គាល់ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ សាសនា ឬនយោបាយ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដូចបានកត់សម្គាល់ខាងលើ ការធ្វើទុក្ខបុកម្នេញមិនត្រឹមតែត្រូវបានធ្វើក្រមនីយកម្ម ដោយសន្ធិសញ្ញាអន្តរជាតិនៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ[472] ដែលត្រូវបានទទួលស្គាល់ ដោយរដ្ឋចំនួន ១៩ ប៉ុណ្ណោះទេ[473] ប៉ុន្តែ ត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទមួយចំនួន ដោយតុលាការយោធាអន្តរជាតិនេះ។ លើសពីនេះទៀត មហាសន្និបាតបានអនុម័តសេចក្តីសម្រេចលេខ ៩៥(I) ជាឯកច្ឆន្ទ ដោយយល់ឃើញថា ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ និងសាលក្រមផ្តះបញ្ចាំងដូចគ្នាទៅនឹងគោលការណ៍ច្បាប់អន្តរជាតិ[474]។ ចុងបញ្ចប់ អំពើធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាម ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវទទួលស្គាល់តាមរយៈការអនុវត្តរបស់រដ្ឋ ដែលបានធ្វើការចោទប្រកាន់ជនជាប់ចោទមួយចំនួនចំពោះអំពើធ្វើទុក្ខបុកម្នេញថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅចំពោះមុខតុលាការយោធាក្នុនកាត់ និងក្នុងតុលាការជាតិពីបទល្មើសដែលបានប្រព្រឹត្តឡើង នៅក្នុងសង្គ្រាមលោកលើកទី II[475]។

---

[472]បទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏ត្រូវបានធ្វើក្រមនីយកម្មនៅក្នុងធម្មនុញ្ញរបស់តុលាការយោធា IMTFE ទោះបីជា តុលាការមិនបានសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋនេះឡើយ។ មាត្រា ៥(គ) នៃធម្មនុញ្ញរបស់តុលាការយោធា IMTFE។

[473]ប្រទេសអូស្ត្រាលី បែលហ្ស៊ិក ឆេកូស្លូវ៉ាគី ដាណឺម៉ាក អេត្យូពី ក្រិច ហៃទី ហុងឌុយរ៉ាស ឥណ្ឌា លុចសំបួរ ហូឡង់ នូវែលសេឡង់ ន័រវេ ប៉ាណាម៉ា ប៉ារ៉ាហ្គាយ ប៉ូឡូញ សាធារណរដ្ឋសែប៊ី អ៊ុយរុយហ្គាយ វេណេហ្ស៊ុយអេឡា, គណៈកម្មការអន្តរជាតិកាកបាទក្រហម, “កិច្ចព្រមព្រៀងសម្រាប់ការចោទប្រកាន់ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋជនសង្គ្រាមធំៗនៃពួកអាក់ស៊ីសអឺរ៉ុប និងធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ។ ទីក្រុងឡុងដ៍ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥, រដ្ឋភាគី/រដ្ឋហត្ថលេខី ”, <http://www.icrc.org/ihl.nsf/WebSign?ReadForm&id=350&ps=P>។

[474]ការទទួលស្គាល់គោលការណ៍ (“*មហាសន្និបាត* (...) *ទទួលស្គាល់*គោលការណ៍ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការ Nürnberg និង សាលក្រមរបស់តុលាការ”)។

[475]អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខ្លួនបានពិនិត្យទៅលើការជំនុំជម្រះជាតិមួយចំនួនដែលបានកើតឡើងក្រោយយុត្តាធិការក្នុងពេលវេលារបស់ អ.វ.ត.ក នៅក្នុងការធ្វើសេចក្តីសន្និដ្ឋាននេះ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះ

### ៤.ខ.២.និយមន័យនៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

២២៦. នៅពេលពិនិត្យពិចារណាអំពីនិយមន័យ នៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ក្នុងការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយនៅក្នុងរឿងក្តីនេះ[476] អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មនេះ ដូចខាងក្រោមៈ

(១) "អំពើសកម្ម ឬអកម្មដែល (...) ពិតជារើសអើង ហើយដកហូត ឬរំលោភទៅលើសិទ្ធិជាមូលដ្ឋាន ដែលមានចែងនៅក្នុងច្បាប់សន្ធិសញ្ញាអន្តរជាតិ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ..."[477] (*ធាតុផ្សំសត្យានុម័ត*)។ និង

(២) ចារីត្រូវតែបានប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដោយមានចេតនារើសអើង...ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា... (*ធាតុផ្សំអត្តនោម័ត*)[478]។

២២៧. ទាក់ទិនទៅនឹងធាតុផ្សំ*សត្យានុម័ត* អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អំពើធ្វើទុក្ខបុកម្នេញ *មិនកំណត់ត្រឹម*បទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ និងការធ្វើទារុណកម្មនោះទេ[479]។ ជាលទ្ធផល អំពើធ្វើទុក្ខបុកម្នេញ ក៏អាចរួមបញ្ចូលផងដែរនូវ "ការឃាយី ការបន្ទាបបន្ថោក និងការធ្វើបាបផ្លូវចិត្ត ការឃុំខ្លួនក្រោមលក្ខខណ្ឌអមនុស្សធម៌ ការធ្វើបាបដោយអមនុស្សធម៌និងឃោរឃៅ

---

ចាត់ទុករឿងក្តីទាំងនេះ ជាភស្តុតាងចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងយុត្តាធិការក្នុងពេលវេលារបស់ អ.វ.ក.ត ពីព្រោះ តុលាការជាតិទាំងនេះបានសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសដែលបានប្រព្រឹត្តឡើងមុនឆ្នាំ ១៩៧៥, ពិនិត្យលើច្បាប់ដែលមានជាធរមាននៅក្នុងពេលនោះ។

[476]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧៧។

[477]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៦ (ការដកស្រង់ត្រូវបានលុបចោល)។

[478]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៩។

[479]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៨។

ការនិរទេស ការជម្លៀស និងការផ្លាស់ប្តូរលំនៅដោយបង្ខំ និងការធ្វើពលកម្មដោយបង្ខំ”[480]។ ដូច្នេះ បញ្ជីឈ្មោះនៃអំពើធ្វើទុក្ខបុកម្នេញ មិនបានគ្របដណ្តប់គ្រប់អំពើទាំងអស់នោះទេ។ ប៉ុន្តែ អំពើដែលមិនត្រូវបានកំណត់ថា ជាបទល្មើសមួយក្នុងចំណោមបទល្មើសមូលដ្ឋានដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ “ត្រូវតែមានស្ថានទម្ងន់ស្មើគ្នាទៅនឹងបទល្មើសមូលដ្ឋាន ជាក់លាក់ ដើម្បីបង្កើតបានជាអំពើធ្វើទុក្ខបុកម្នេញ”[481]។ ក្នុងការកំណត់ ថាតើអំពើសកម្ម ឬអកម្មមួយចំនួន មានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ដែរ ឬយ៉ាងណា ដើម្បីបង្កើតបានជាអំពើធ្វើទុក្ខបុកម្នេញនោះ អំពើទាំងនេះ“ត្រូវតែធ្វើការថ្លឹងថ្លែងដោយពិនិត្យទៅលើអានុភាពត្រួតគ្នានៃអំពើទាំងនោះ ដោយមិនគ្រាន់តែពិនិត្យទៅលើអំពើនីមួយៗដាច់ដោយឡែកពីគ្នានោះទេ”[482]។ លើសពីនេះទៀត “ជាទូទៅ” អំពើសកម្ម ឬអកម្ម តម្រូវឱ្យមានការដកហូតនូវសិទ្ធិមនុស្សជាមូលដ្ឋានដោយកម្រោល ឬដោយឥតលាក់លៀម”[483]។

២២៨. បន្ថែមលើនេះទៀត នៅពេលបញ្ជាក់ថា អំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញត្រូវតែមាន “ការរើសអើងពិតប្រាកដ”នោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់ថា “អំពើសកម្ម ឬអកម្មនេះ ត្រូវតែមានការរើសអើង*ដោយពិតប្រាកដ* ។ ចេតនានៃការរើសអើងតែមួយមិនគ្រប់គ្រាន់ទេ ហើយអំពើសកម្ម ឬអកម្មនេះ ត្រូវតែជាបច្ច័យដែលបណ្តាលមកពីការរើសអើងនោះ”[484]។ អំពើសកម្ម ឬអកម្មណាមួយចាត់ទុកថា ជាអំពើរើសអើង នៅពេលណាដែលជនរងគ្រោះត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែជនរងគ្រោះនោះជាសមាជិកនៅក្នុងក្រុមណាមួយដែលចារីបានកំណត់ដោយអត្តនោម័ត ដោយមូលហេតុ“នយោបាយ ពូជសាសន៍ ឬ សាសនា”[485]។

---

[480]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៨។

[481]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៨ (សញ្ញាបង្ហាញការដកស្រង់ត្រូវបានលុបចេញ)។

[482]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៨។

[483]សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៨។

[484]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៦ ដល់ ៣៧៧ (សេចក្តីបញ្ជាក់បន្ថែម)។

[485]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៧។

២២៩. ទាក់ទិនទៅនឹង*ធាតុផ្សំអត្តនោម័ត* អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បន្ថែមលើចេតនា ដែលជាលក្ខខណ្ឌតម្រូវចាំបាច់សម្រាប់អំពើសកម្ម ឬអកម្មនោះ "អត្ថិភាពនៃចេតនាជាក់លាក់ដែលធ្វើឱ្យបុគ្គលណាម្នាក់រងគ្រោះដោយសារតែគាត់ស្ថិតនៅក្នុងសហគមន៍ ឬក្រុមជាក់លាក់ណាមួយ គឺគ្រប់គ្រាន់ក្នុងការបង្កើតឱ្យមានធាតុចេតនា ដែលជាធាតុផ្សំចាំបាច់សម្រាប់បទល្មើសនៃការធ្វើទុក្ខបុកម្នេញហើយ"[486]។ ទោះបីជាយ៉ាងណាក៏ដោយ "ធាតុចេតនាជាក់លាក់នេះ មិនមែនជាធាតុផ្សំផ្នែកច្បាប់នៃបទល្មើសមូលដ្ឋានមួយចំនួននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ"[487]។ ជាចុងក្រោយ ដើម្បីបង្ហាញនូវអត្ថិភាពនៃចេតនារើសអើងជាក់លាក់ ធាតុចេតនាមិនអាចទាញចេញដោយគ្រាន់តែមើលទៅលើលក្ខណៈនៃការរើសអើងជាទូទៅនៃការវាយប្រហារដ៏ទូលំទូលាយនោះបានទេ[488]។ ប៉ុន្តែ ធាតុចេតនានេះអាចទាញចេញបានពីបរិបទនៃការវាយប្រហារបែបនេះ ប្រសិនបើអង្គហេតុនៃរឿងក្តីនេះបង្ហាញថា កាលៈទេសៈជាក់លាក់"ជុំវិញការប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ បញ្ជាក់អំពីអត្ថិភាពនៃចេតនា [រើសអើង] ដូច្នោះ"[489]។

២៣០. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានយកនិយមន័យនេះពីយុត្តិសាស្ត្ររបស់តុលាការ*មិនអចិន្ត្រៃយ៍នានា*។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ទោះបីជា ការធ្វើទុក្ខបុកម្នេញពិតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់អន្តរជាតិក្រោយសង្គ្រាមលោកលើកទី II ក៏ដោយ ក៏ធាតុផ្សំនៃបទល្មើសនេះមិនត្រូវបានពន្យល់បញ្ជាក់ឱ្យបានក្បោះក្បាយដោយតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ក្រោយសង្គ្រាមលោកលើកទី II ឬដោយតុលាការជាតិនានា នៅមុនពេលមានយុត្តិសាស្ត្ររបស់តុលាការ*មិនអចិន្ត្រៃយ៍* នៅក្នុង

---

[486]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៩។

[487]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៩។

[488]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៨០។

[489]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៨០ (ដកស្រង់ចេញពី*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Blaškic*, សំណុំរឿងលេខ IT-95-14-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ ("សាលដីកាក្នុង*រឿងក្តី Blaškic*"), កថាខណ្ឌ ១៦៤។ សាលដីកាក្នុង*រឿងក្តី Krnojelac*, កថាខណ្ឌ ១៨៤។

ទសវត្សរ៍ឆ្នាំ ១៩៩០[490]។ ដូច្នេះ "ការកំណត់*ប្រភេទ*នៃបទល្មើសនេះ" គឺអាស្រ័យទៅលើតុលាការ *មិនអចិន្ត្រៃយ៍*ទាំងនោះ[491]។ នៅពេលដំណាលគ្នានេះដែរ ក្នុងការទទួលយកនូវការបញ្ជាក់របស់តុលាការ *មិនអចិន្ត្រៃយ៍*នានានោះ អង្គជំនុំជម្រះសាលាដំបូងបានគាំទ្រសេចក្តីបញ្ជាក់ ដែលមាននៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ក្នុងរឿងក្តី *Kordić និង Čerkez* ដែលបានកត់សម្គាល់ថា៖

> ទាំងច្បាប់សន្ធិសញ្ញាអន្តរជាតិ ទាំងយុត្តិសាស្ត្ររបស់តុលាការនានាសុទ្ធតែមិនបានផ្តល់ធាតុផ្សំចាំបាច់ឱ្យបានក្បោះក្បាយស្តីពីអំពើខុសច្បាប់ ដែលត្រូវចោទប្រកាន់ថាជាការធ្វើទុក្ខបុកម្នេញនោះទេ ហើយការធ្វើទុក្ខបុកម្នេញនេះមិនត្រូវបានទទួលស្គាល់ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌសំខាន់ៗក្នុងពិភពលោកនៅឡើយទេ។ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY យល់ស្របថា បទល្មើសនៃការធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានការវិវឌ្ឍន៍ ដោយប្រយ័ត្នប្រយែង និងគិតគូរឱ្យបានច្បាស់លាស់ផ្អែកតាមគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង*[492]។

២៣១. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា យុត្តិសាស្ត្ររបស់តុលាការជាតិ ឬអន្តរជាតិក្រោយសង្គ្រាមលោកលើកទី II ពុំបានកំណត់ច្បាស់លាស់នូវធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បន្ថែមលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ក្នុងរឿងក្តី *Kordić* យុត្តិសាស្ត្រផ្សេងៗទៀតរបស់តុលាការ ICTY បានទទួលស្គាល់នូវកង្វះខាតនៃធាតុផ្សំដែលត្រូវកំណត់ឱ្យបានច្បាស់លាស់[493]។ កង្វះខាតនេះ មួយផ្នែកបណ្តាលមកពីភាពមិនច្បាស់លាស់នៃទំនាក់ទំនង

---

[490]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៥។

[491]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៥ (សេចក្តីបញ្ជាក់បន្ថែម)។

[492]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៥, ដកស្រង់ចេញពី *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Kordić និង Čerkez, សំណុំរឿងលេខ IT-95-14/2-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០០១ ("សាលក្រមក្នុងរឿងក្តី *Kordić* និង *Čerkez*"), កថាខណ្ឌ ១៩២។

[493]*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Tadić*, សំណុំរឿងលេខ IT-94-1-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ១៩៩៧, ("សាលក្រមក្នុង*រឿងក្តី Tadić*"), កថាខណ្ឌ ៦៩៤, បញ្ជាក់ឡើងវិញនៅក្នុងសាលក្រមក្នុង*រឿងក្តី*

រវាងការធ្វើទុក្ខបុកម្នេញ និងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាំងពីដំណាក់កាលដំបូងបង្អស់នៃការចងក្រងជាឧក្រិដ្ឋកម្មអន្តរជាតិមកម្ល៉េះ។ តាមពិត ក្នុងអំឡុងនៃការធ្វើសេចក្តីព្រាងធម្មនុញ្ញតុលាការយោធាអន្តរជាតិ (IMT) គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិជាដំបូង (UNWCC) បានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថា ជា"ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងលើជនណាម្នាក់ ដោយមូលហេតុពូជសាសន៍ សញ្ជាតិ ជំនឿផ្នែកនយោបាយ ឬសាសនា ដោយមិនគិតពីសញ្ជាតិ រួមបញ្ចូលទាំងជនគ្មានសញ្ជាតិ និងដោយមិនគិតថា ឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តនៅទីកន្លែងណានោះទេ"[494]។ ដូច្នេះ និយមន័យនៅក្នុងសេចក្តីព្រាងនេះ គឺបង្ហាញនូវការពិតដែលថា ពីដំបូងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានគេយល់ថា ដើម្បីបង្កើតបានជាអំពើធ្វើទុក្ខបុកម្នេញនោះ រាល់បទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានចេតនារើសអើងពិសេស។

២៣២. ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសេចក្តីព្រាងចុងក្រោយនៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ (IMT) ការធ្វើទុក្ខបុកម្នេញមានលក្ខណៈខុសគ្នាពីបទឧក្រិដ្ឋដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចខាងក្រោមនេះ ៖

(គ) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពោលគឺ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនស៊ីវិល មុនពេល ឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅក្នុងការអនុវត្ត ឬពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ ទោះបីជាបទល្មើស

---

*Kordić និង Čerkez*, កថាខណ្ឌ ១៩២។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Blaškić*, សំណុំរឿងលេខ IT-95-14-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០, ("សាលក្រមក្នុង*រឿងក្តី Blaškić*"), កថាខណ្ឌ ២១៩។ សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ២១៩។

[494]គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ, *ប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ និងការអភិវឌ្ឍន៍នៃច្បាប់សង្គ្រាម*, ទីក្រុងឡុងដ៍៖ ការិយាល័យសម្ភារៈសិក្សារបស់ព្រះករុណា, ឆ្នាំ ១៩៤៨ ទំព័រ ១៧៦។

នោះរំលោភ ឬមិនរំលោភលើច្បាប់ជាតិរបស់ប្រទេសនោះក៏ដោយ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត[495]។

២៣៣. អនុលោមតាមខ្លឹមសារនេះ ការធ្វើទុក្ខបុកម្នេញត្រូវបានញែកចេញយ៉ាងច្បាស់ពីបទឧក្រិដ្ឋដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការប្រើសញ្ញាចុចក្បៀស (;) និងសន្ធានសព្ទ "ឬ"នៅក្នុងឃ្លានោះ។ លើសពីនេះទៀត វិធីសាស្ត្រពិសេសចំពោះការធ្វើទុក្ខបុកម្នេញនៅក្នុងធម្មនុញ្ញនេះ រួមបញ្ចូលលក្ខខណ្ឌតម្រូវពីទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព។ លក្ខខណ្ឌតម្រូវនៃទំនាក់ទំនងនេះ ក្រោយៗមកទៀត ត្រូវបានពង្រីកវិសាលភាព ដើម្បីយកមកអនុវត្តចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមពិធីសារទីក្រុងប៊ែរឡាំង (Berlin) ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៤៥ ដោយប្រើសញ្ញាក្បៀស (,) ជំនួសឱ្យសញ្ញាចុចក្បៀស (;)[496]។ ការបកស្រាយរបស់តុលាការយោធាអន្តរជាតិ (IMT) អំពីធម្មនុញ្ញរបស់ខ្លួន[497] និងចុងក្រោយពីគោលការណ៍ Nuremberg ឆ្នាំ ១៩៥០[498]។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលអ្នកធ្វើអត្ថាធិប្បាយម្នាក់បានកត់សម្គាល់រួចមកហើយ "ការដកចេញនូវសញ្ញាចុចក្បៀស (;) មិនត្រូវបានបកស្រាយថា ជាការពង្រីកវិសាលភាពទៅលើមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាដែលតម្រូវចាំបាច់ចំពោះគ្រប់ទម្រង់ទាំងអស់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុលោមតាមសេចក្តីព្រាងមុនៗឡើយ"[499]។ ប៉ុន្តែ បន្ទាប់ពីការអនុម័តពិធីសារទីក្រុងប៊ែរឡាំង (Berlin) គណៈកម្មាធិការច្បាប់នៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិបានសន្និដ្ឋានថា នៅមានសេសសល់បទឧក្រិដ្ឋចំនួនពីរប្រភេទទៀតនៅក្នុង

---

[495]មាត្រា ៦(គ) នៃធម្មនុញ្ញតុលាការយោធា IMT (សេចក្តីបញ្ជាក់បន្ថែម)។

[496]សាលក្រមរបស់តុលាការយោធា IMT, វ៉ុល I, ទំព័រ ១១។

[497]សាលក្រមរបស់តុលាការយោធា IMT, វ៉ុល I, ទំព័រ ២៥៤។

[498]គោលការណ៍ VI(គ) នៃគោលការណ៍ Nuremberg ឆ្នាំ ១៩៥០។

[499]ព្រឹត្តប័ត្រនិពន្ធដោយ Ken Roberts, ដែលមានចំណងជើងថា "ការខិតខំក្នុងការកំណត់និយមន័យៈ ច្បាប់ស្តីពីអំពើធ្វើទុក្ខបុកម្នេញចាប់ពីប្រភពដើមរបស់ខ្លួនទៅដល់តុលាការ ICTY", និពន្ធនាយកឈ្មោះ Hirad Abtahi and Gideon Boas, (eds.), ដែលមានចំណងជើងថា៖ កំលាំងនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ *(The Dynamics of International Criminal Justice)*, ចេញផ្សាយដោយ Martinus Nijhoff Publishers, ឆ្នាំ ២០០៦, ទំព័រ ២៦៣។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺ"ប្រភេទបទធ្វើមនុស្សឃាត មានដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងបទឧក្រិដ្ឋប្រហាក់ប្រហែលផ្សេងទៀត និងប្រភេទបទធ្វើទុកបុកម្នេញដែលបទធ្វើទុកបុកម្នេញនេះប្រព្រឹត្តឡើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា"[500]។

២៣៤. ដោយសារភាពមិនច្បាស់លាស់ និងកង្វះខាតនូវការណែនាំច្បាស់លាស់ពាក់ព័ន្ធនឹងចំណុចសំខាន់ៗនៃធាតុផ្សំការធ្វើទុក្ខបុកម្នេញ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា ដោយអនុលោមតាមគោលការណ៍នីត្យានុកូលភាព ចំណុចសំខាន់ៗនៃធាតុផ្សំបទល្មើស ត្រូវសន្និដ្ឋានដោយប្រុងប្រយ័ត្នចេញពីអង្គហេតុ និងសំអាងហេតុរបស់តុលាការ ក្រោយសង្គ្រាមលោកលើកទី II។ ការធ្វើដូច្នេះ គឺជាការចាំបាច់ដើម្បីកំណត់ ថាតើ ត្រឹមឆ្នាំ ១៩៧៥ ជនជាប់ចោទដឹងជាមុនថាមានច្បាប់ចែង និងអាចយល់ដឹងថា អំពើរបស់ខ្លួនជាបទល្មើស ដែរ ឬយ៉ាងណា នៅក្នុងរឿងក្តីនេះ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា គោលការណ៍នីត្យានុកូលភាពពុំបានហាមឃាត់អង្គជំនុំជម្រះក្នុងការបកស្រាយ ឬបំភ្លឺច្បាប់ ឬដែនកំណត់នៃធាតុផ្សំបទល្មើសនោះឡើយ[501]។ លើសពីនេះទៀត គោលការណ៍នេះ ពុំបានរារាំងអង្គជំនុំជម្រះក្នុងការអភិវឌ្ឍន៍ច្បាប់ជាបន្តបន្ទាប់ទៀតនោះដែរ[502]។ ទោះបីជាយ៉ាងណាក៏ដោយ គោលការណ៍នេះពុំអនុញ្ញាតឱ្យអង្គជំនុំជម្រះ *បង្កើតច្បាប់ថ្មី* ឬបកស្រាយច្បាប់ដែលមានស្រាប់ឱ្យហួសពីដែនកំណត់នៃការបំភ្លឺដ៏សមហេតុផលនោះឡើយ[503]។

២៣៥. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលមានកាតព្វកិច្ចក្នុងការសម្រេច ថាតើការកំណត់ធាតុផ្សំការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចយកតាមយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍នានា* មានលក្ខណៈត្រឹមត្រូវ ដែរ ឬ

[500] *ប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ និងការអភិវឌ្ឍន៍នៃច្បាប់សង្គ្រាម*, ទំព័រ ១៧៨។

[501] សាលដីកាក្នុង *រឿងក្តី Aleksovski*, កថាខណ្ឌ ១២៦ ដល់ ១២៧។

[502] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង *រឿងក្តី Ojdanić* (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ៣៨។

[503] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការក្នុង *រឿងក្តី Ojdanić* (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ៣៨។

យ៉ាងណា។ ក្នុងការសម្រេចបែបនេះ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ថា តុលាការ *មិនអចិន្ត្រៃយ៍ទានា* បានចាប់ផ្តើមកំណត់និយមន័យរបស់ខ្លួននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ហើយ បានឈានដល់សេចក្តីសម្រេចមួយ បន្ទាប់ពីមានការប្រែប្រួលផ្ទៃក្នុង នៅក្នុងយុត្តិសាស្ត្រ តុលាការអស់រយៈពេលជាច្រើនឆ្នាំ ពោលគឺជាង ២០ ឆ្នាំ *ក្រោយ*ដែនកំណត់យុត្តាធិការពេល វេលារបស់ អ.វ.ត.ក។ ទាក់ទិនទៅនឹងគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះតុលាការ កំពូលត្រូវតែពិចារណា ថាតើការពិភាក្សាទៅលើនិយមន័យនេះ មានពាក់ព័ន្ធទៅនឹងការបក ស្រាយ ឬក៏ការបំភ្លឺអំពីដែនកំណត់នៃធាតុផ្សំការធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណា ដោយសារ ធាតុផ្សំទាំងនេះ មានអត្ថិភាពនៅក្នុងច្បាប់ត្រឹមឆ្នាំ ១៩៧៥។ ជម្រើសម៉្យាងទៀត អង្គជំនុំ ជម្រះតុលាការកំពូលត្រូវតែកំណត់ ថាតើការបកស្រាយស៊ីជម្រៅអំពីធាតុផ្សំទាំងនេះ គឺជា ច្បាប់ថ្មី ដែលពុំមានអត្ថិភាពនៅពេលនោះសម្រាប់ អ.វ.ត.ក ហើយនេះជាការរំលោភលើ គោលការណ៍នីត្យានុកូលភាព ដែរ ឬយ៉ាងណា។

### *៤.ង.២.ក.ធាតុផ្សំអត្តនោម័ត*

២៣៦. ទីមួយ ទាក់ទិនទៅនឹងលក្ខខណ្ឌតម្រូវនៃធាតុផ្សំ*អត្តនោម័ត*ដែលចាំបាច់ត្រូវមានការប្រព្រឹត្ត "ដោយចេតនា" នូវអំពើសកម្ម ឬអកម្ម ដែលមានគោលបំណងដាក់លាក់ក្នុងការធ្វើទុក្ខបុក ម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនានោះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ធាតុផ្សំការធ្វើទុក្ខបុកម្នេញនេះត្រូវបានគាំទ្រដោយយុត្តិសាស្ត្រតុលាការក្រោយ សង្គ្រាមលោកលើកទី II។ សំអាងហេតុរបស់តុលាការយោធាអន្តរជាតិ (IMT) និងតុលាការ យោធា Nuremberg បានបង្ហាញយ៉ាងស៊ីសង្វាក់គ្នាថា ចារីត្រូវបានសម្រេចដាក់ពិរុទ្ធភាព ចំពោះការប្រព្រឹត្តអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញដោយចេតនា និងដឹងជាមុន ហើយ ការប្រព្រឹត្តនេះមានចេតនារើសអើង ដែលត្រូវបានស្តែងឱ្យឃើញនៅក្នុងបរិបទនៃការចូលរួម នៅក្នុងផែនការធ្វើទុក្ខបុកម្នេញរបស់រដ្ឋាភិបាលអាល្លឺម៉ង់ ដោយស្ម័គ្រចិត្ត និងដឹងជាមុន[504]។

---

[504] សាលក្រមតុលាការយោធា IMT, វ៉ុល I, ទំព័រ ២៨២, ២៨៧ ដល់ ២៨៨, ២៩៥ ដល់ ២៩៩, ៣០០ ដល់ ៣០៧, ៣២៨ ដល់ ៣៣០, ៣៣៩ ដល់ ៣៤១។ វ៉ុល XXII, ទំព័រ ៥៧៦។ *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៨១,

តុលាការនេះ បានសន្និដ្ឋានអំពីចេតនារើសអើងដោយទាញចេញមិនត្រឹមតែពីអត្ថិភាពនៃផែនការប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងពីកាលៈទេសៈជាក់លាក់ នៅជុំវិញការប្រព្រឹត្តអំពើធ្វើទុក្ខបុកម្នេញដែលបានលើកឡើងនោះ។ ដូចបានធ្វើការកត់សម្គាល់ខាងក្រោម ជនជាប់ចោទកំណត់គោលដៅតែលើជនរងគ្រោះប៉ុណ្ណោះ ដោយសារពួកគាត់ជាសមាជិកនៃក្រុមគោលដៅជាក់លាក់ណាមួយ និងជាញឹកញាប់ជនជាប់ចោទបានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈដែលបញ្ជាក់អំពីភាពរើសអើងយ៉ាងពិតប្រាកដ។ ទោះបីជាយ៉ាងណាក៏ដោយ ចេតនាជាក់លាក់ដែលជាលក្ខខណ្ឌតម្រូវ មិនចាំបាច់មានវិសាលភាពរហូតដល់តម្រូវថា ចាំត្រូវតែមានការជាប់ពាក់ព័ន្ធនឹងមូលហេតុផ្តាច់ការជាមូលដ្ឋានជាក់លាក់នៃរបបគ្រប់គ្រង ដែលអនុវត្តយុទ្ធនាការ ឬនយោបាយធ្វើទុក្ខបុកម្នេញនោះទេ[505]។

២៣៧. លើសពីនេះទៀត ដូចដែលបានកត់សម្គាល់ខាងលើ ដោយយោងតាមពាក្យពេចន៍យ៉ាងច្បាស់នៃធម្មនុញ្ញរបស់ខ្លួន តុលាការក្រោយសង្គ្រាមលោកលើកទី II បានចាត់ទុកអំពើសកម្ម ឬអកម្មថា ជាអំពើធ្វើទុក្ខបុកម្នេញយ៉ាងពិតប្រាកដ ក្នុងករណីដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើង

---

១១១០ ដល់ ១១១៤, ១១៤៤ ដល់ ១១៥៦។ *រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៥៥៥ ដល់ ៥៥៦, ៥៦៣ ដល់ ៥៦៤, ៥៧៥ ដល់ ៥៧៦, ៦៤៥ ដល់ ៦៤៦, ៦៧៨ ដល់ ៦៨០។

[505] *រឿងក្តីអគ្គរដ្ឋអាជ្ញានៃប្រទេសអ៊ីស្រាអែល ទល់នឹង* Enigster, តុលាការជាន់ដំបូងរបស់ទីក្រុង Tel Aviv (ឆ្នាំ ១៩៥២), *របាយការណ៍ស្តីពីច្បាប់អន្តរជាតិ*, វ៉ុល ១៨, ("*រឿងក្តី Enigster*"), ទំព័រ ៥៤២ ("បុគ្គលដែលទទួលរងការធ្វើទុក្ខបុកម្នេញ និងការបង្ខាំងនៅក្នុងជំរំដូចគ្នា តាមទស្សនៈផ្នែកច្បាប់ អាចជាប់ពិរុទ្ធភាពពីបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើគាត់ប្រព្រឹត្តអំពើអមនុស្សធម៌ប្រឆាំងនឹងអ្នកទោសដូចគាត់ដែរ។ ផ្ទុយទៅនឹងឧក្រិដ្ឋជនសង្គ្រាម ចារីដែលប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំចាំបាច់ជាជនដែលបានបង្ហាញពីអត្តសញ្ញាណខ្លួនឯងនៅក្នុងរបបនៃការធ្វើទុក្ខបុកម្នេញ ឬគោលបំណងទុច្ចរិតរបស់របបនោះឡើយ")។ *រឿងក្តី J and R* (ឆ្នាំ ១៩៤៨), តុលាការកំពូលដែលស្ថិតក្នុងតំបន់ដែលត្រូវបានត្រួតត្រារបស់ចក្រភពអង់គ្លេស, *តំបន់* Entscheidungen des Obersten Gerichtshofes fur die Britishe – Entescheidungen in Strafsachen, អ្នកបោះពុម្ពផ្សាយ Walter de Gruyter, ឆ្នាំ ១៩៤៩ ដល់ ឆ្នាំ ១៩៥១, វ៉ុល I, ទំព័រ ១៦៧ ដល់ ៧១ ("ទំនាក់ទំនងនេះទៅនឹងអំពើហិង្សា និងអំណាចផ្តាច់ការ ពុំចាំបាច់ (...) មាននៅក្នុងការគាំទ្រអំពើផ្តាច់ការនោះឡើយ ប៉ុន្តែ ជាឧទាហរណ៍ ក៏អាចមានការប្រើប្រាស់ប្រព័ន្ធនៃអំពើហិង្សា និងអំពើផ្តាច់ការផងដែរ")។

ប្រឆាំងនឹងបុគ្គលទាំងឡាយ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[506]។ ការចោទប្រកាន់តាមច្បាប់ជាតិក្រោយៗមកទៀតលើអតីតពួកណាហ្ស៊ី (Nazi) នៅក្នុងប្រទេសប៉ូឡូញ អ៊ីស្រាអែល បារាំង និងក្រូអាស៊ី ចំពោះអំពើធ្វើទុក្ខបុកម្នេញ ក៏បានយកមកអនុវត្តដូចគ្នាឡើងវិញ ចំពោះធាតុផ្សំចាំបាច់នៃការស្អប់ខ្ពើមដែលមានលក្ខណៈរើសអើងនេះ[507]។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា "បទពិសោធន៍ក្នុងរឿងក្តីណាហ្ស៊ី (Nazi) ក៏បានបង្ហាញផងដែរថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចត្រូវបានប្រព្រឹត្តឡើងដោយសារមូលហេតុនៃការរើសអើង ជាជាង ដោយសារហេតុផលទាំងឡាយដែលត្រូវបានរៀបរាប់ (...) ដូចជា ពិការភាពផ្នែករាងកាយ ឬសតិបញ្ញា ឬភាពទន់ខ្សោយដោយមូលហេតុអាយុ និងរូបកាយ ឬចំណង់ផ្នែកផ្លូវភេទ"[508]។ ទោះបីជាយ៉ាងណាក៏ដោយ យុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានកម្រិតដោយមូលហេតុនៃការរើសអើង ដែលបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពោលគឺ "ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា"[509]។

២៣៨. លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា មិនមានលក្ខខណ្ឌតម្រូវថាចេតនារើសអើងជាក់លាក់ ត្រូវតែយកមកអនុវត្តចំពោះរាល់បទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ[510]។ ពាក្យពេចន៍សាមញ្ញក្នុងមាត្រា ៥ នៃច្បាប់ស្តី

---

[506]សាលក្រមតុលាការយោធា IMT, វ៉ុល I, ទំព័រ ២៨២, ២៨៧ ដល់ ២៨៨, ២៩៥ ដល់ ២៩៨, ៣00 ដល់ ៣0៧, ៣២៨ ដល់ ៣៣0, ៣៣៩ ដល់ ៣៤១។ *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌,* វ៉ុល III, ទំព័រ ១១១0 ដល់ ១១១៤, ១១១៨, ១១៥៤ ដល់ ១១៥៦។ *រឿងក្តី RuSHA,* វ៉ុល V, ទំព័រ ១៥២ ដល់ ១៥៣, ១៥៥, ១៥៨ ដល់ ១៦២។ *រឿងក្តីពាក់ព័ន្ធក្រសួងផ្សេងៗ,* វ៉ុល XIV, ទំព័រ ៥២០ ដល់ ៥២២, ៦២៦ ដល់ ៥២៨, ៥៦៣ ដល់ ៥៦៥, ៥៧៥ ដល់ ៥៧៦, ៦00 ដល់ ៦0១, ៦0៣ ដល់ ៦0៥, ៦៤៥ ដល់ ៦៤៦, ៦៧៥ ដល់ ៦៨0។

[507]*រឿងក្តី Greiser,* ទំព័រ ១0៥។ *រឿងក្តី Eichmann,* ទំព័រ ២៧៨។ *រឿងក្តី Barbie,* ទំព័រ ១៣៩។ សាលក្រមក្នុង*រឿងក្តី Kupreškić,* ដកស្រង់ចេញពីរឿងក្តី *Artuković* , ទំព័រ ២៦។

[508]*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Tadić,* សំណុំរឿងលេខ IT-94-1-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩, ("សាលដីកាក្នុង*រឿងក្តី Tadić*"), កថាខណ្ឌ ២៨៥។

[509]មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[510]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៩។

ពីការបង្កើត អ.វ.ត.ក ក៏ដូចជាការញែកអំពើធ្វើទុក្ខបុកម្នេញ ឱ្យដាច់ចេញយ៉ាងច្បាស់ពីបទល្មើសមូលដ្ឋានដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងប្រវត្តិនៃការតាក់តែងសេចក្តីព្រាងធម្មនុញ្ញតុលាការយោធាអន្តរជាតិ (IMT) និងធម្មនុញ្ញនេះ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ដែលបានកត់សម្គាល់ខាងលើ បានគាំទ្រការសម្រេចនេះ។ មិនត្រឹមតែអត្ថន័យសាមញ្ញនៃលិខិតុបករណ៍ទាំងនេះបានគាំទ្រការសម្រេចបែបនេះប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំង“មិនសមហេតុផល” និង“មិនមានសារៈសំខាន់ទាល់តែសោះ”សម្រាប់ឱ្យអ្នកធ្វើសេចក្តីព្រាងបង្ហាញយ៉ាងជាក់លាក់ថា ការធ្វើទុក្ខបុកម្នេញនេះ បានប្រព្រឹត្តឡើង ដោយមូលហេតុ“នយោបាយ ពូជសាសន៍ ឬសាសនា” ប្រសិនបើលក្ខខណ្ឌតម្រូវអំពីចេតនាជាក់លាក់នេះ ត្រូវយកមកអនុវត្តចំពោះរាល់បទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ[511]។ ការបកស្រាយលិខិតុបករណ៍ទាំងនេះដោយផ្អែកលើកម្មវត្ថុ និងគោលបំណងដើម្បីមនុស្សធម៌របស់ធម្មនុញ្ញទាំងនេះ បានគាំទ្របន្ថែមទៀតចំពោះសេចក្តីសម្រេចខាងលើនេះ។ គោលដៅរបស់អ្នកធ្វើសេចក្តីព្រាងគឺ ៖

> ដើម្បីឱ្យរាល់បទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចផ្តន្ទាទោសបាន រួមទាំងបទឧក្រិដ្ឋទាំងឡាយណា ដែលបានបំពេញនូវរាល់លក្ខខណ្ឌស្តីពីសញ្ញាណនៃឧក្រិដ្ឋកម្មបែបនេះ ទោះបីជា ការប្រព្រឹត្តអាច ឬមិនអាចបង្កឡើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាក៏ដោយ (...) អ្វីដែលមើលមិនឃើញនោះគ្រង់ថា ប្រសិនបើអ្នកធ្វើសេចក្តីព្រាង បានកម្រិតឱ្យបានម៉ឹងម៉ាត់ពីចេតនារើសអើងចំពោះរាល់ប្រភេទនៃបទល្មើស ដែលមាននៅក្នុងវិសាលភាពនៃ“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” នោះបទល្មើសទាំងឡាយនៃឧក្រិដ្ឋកម្មប្រឆាំងប្រជាជនជាជនស៊ីវិល ដែលបានប្រព្រឹត្តជាប្រព័ន្ធក្នុងទ្រង់ទ្រាយធំ និងសាហាវឃោរឃៅ ពិតជាស្ថិតក្រៅប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារតែគ្មានចេតនារើសអើង[512]។

[511] សាលដីកាក្នុងរឿងក្តី *Tadić*, កថាខណ្ឌ ២៨៣ ដល់ ២៨៤។

[512] សាលដីកាក្នុងរឿងក្តី *Tadić*, កថាខណ្ឌ ២៨៥។

២៣៩. ជាមួយគ្នាផងដែរ នៅក្នុងយុត្តិសាស្ត្រតុលាការជាតិនៃប្រទេសផ្សេងៗ បន្ទាប់ពីសង្គ្រាមលោកលើកទី II ភ្លាមៗ តុលាការទាំងនោះបានយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនចាំបាច់មានសកម្មភាពរើសអើង ឬធ្វើទុក្ខបុកម្នេញឡើយ[513]។ ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ធាតុផ្សំ*អត្តនោម័ត* អំពីការធ្វើទុក្ខបុកម្នេញដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបានគាំទ្រដោយសេចក្ដីសម្រេចគ្មានការជំទាស់នៅក្នុងការប្រើប្រាស់ទម្រង់ដូចគ្នានៃធាតុផ្សំ*អត្តនោម័ត* នេះ នៅក្នុងយុត្តិសាស្ត្រតុលាការ *មិនអចិន្ត្រៃយ៍*[514]។

---

[513] *សូមមើលឧទា.* In re Ahlbrecht (*លេខ ២*) (ឆ្នាំ ១៩៤៩), តុលាការកំពូលពិសេសហូឡង់, *របាយការណ៍ស្ដីពីច្បាប់អន្តរជាតិ*, វ៉ុល ១៦, ទំព័រ ៣៩៦ ដល់ ៣៩៨។ *រឿងក្ដី* Enigster, ទំព័រ ៥៤១ ("ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យើងពុំមានការស្ទាក់ស្ទើរឡើយក្នុងការបដិសេធនូវទឡ្ហីករណ៍របស់មេធាវីការពារក្ដីដែលថា អំពើណាមួយក៏ដោយក្នុងចំណោមអំពើទាំងឡាយដែលរៀបរាប់លម្អិតនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែប្រព្រឹត្តឡើងដោយមានចេតនាធ្វើទុក្ខបុកម្នេញជនរងគ្រោះ ដោយមូលហេតុនយោបាយ សញ្ជាតិ ឬសាសនា។ ជាការច្បាស់ណាស់ថា លក្ខខណ្ឌនេះអាចយកមកអនុវត្តបានតែនៅពេលដែលធាតុផ្សំសំខាន់នៃបទល្មើស គឺជាការធ្វើទុក្ខបុកម្នេញ ប៉ុណ្ណោះ")។

[514] *សូមមើល ឧទា.* សាលដីកាក្នុង*រឿងក្ដី* Stakić, កថាខណ្ឌ ៣២៧ ដល់ ៣២៨។ *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង* Deronjić, សំណុំរឿងលេខ IT-02-61-A, "សាលដីកាលើបណ្ដឹងសាទុក្ខស្ដីពីការផ្ដន្ទាទោស", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៥, ("សាលដីកាក្នុង*រឿងក្ដី Deronjić*"), កថាខណ្ឌ ១០៩។ សាលដីកាក្នុង*រឿងក្ដី Kvočka,* កថាខណ្ឌ ៣១៩ ដល់ ៣២០។ សាលដីកាក្នុង*រឿងក្ដី Kordić និង Čerkez,* កថាខណ្ឌ ១០១ ដល់ ១០២ និង១១០។ សាលដីកាក្នុង*រឿងក្ដី Blaškič,* កថាខណ្ឌ ១៣១។ សាលដីកាក្នុង*រឿងក្ដី Krnojelac,* កថាខណ្ឌ ១៨៥។ *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Vasiljević,* សំណុំរឿងលេខ IT-98-32-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤, ("សាលដីកាក្នុង*រឿងក្ដី Vasiljević* "), កថាខណ្ឌ ១១៣។ *រឿងក្ដី Nahimana ទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខ ICTR-99-52-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ("សាលដីកាក្នុង*រឿងក្ដី Nahimana*"), កថាខណ្ឌ ៩៨៥។ *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង* Nyiramasuhuko *និងជនដទៃទៀត*, សំណុំរឿងលេខ ICTR-98-42-T, "សាលក្រម និងការផ្ដន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១, ("សាលក្រមក្នុង*រឿងក្ដី Nyiramasuhuko*"), កថាខណ្ឌ ៦០៩៦។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង និងការផ្ដន្ទាទោសក្នុង*រឿងក្ដី Bagosora*"), កថាខណ្ឌ ២២០៨។ *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Bikindi,* សំណុំរឿងលេខ ICTR-01-72-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨, ("សាលក្រមក្នុង*រឿងក្ដី Bikindi*"), កថាខណ្ឌ ៣៩១។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពីររបស់តុលាការ ICTY និងអង្គជំនុំជម្រះសាលាដំបូងមួយរបស់តុលាការ ICTR បានយល់ឃើញផងដែរថា *ធាតុផ្សំអត្តនោម័ត* សម្រាប់អំពើធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានការបង្ហាញ

២៤០. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល យល់ស្របតាមការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូង អំពីធាតុផ្សំ *អត្តនោម័ត* នៃការធ្វើទុក្ខបុកម្នេញមកត្រឹមឆ្នាំ ១៩៧៥។ លើសពីនេះទៀត ដោយបានពិនិត្យឡើងវិញនូវសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តីនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា មតិភាគច្រើនមិនមានកំហុសនោះទេនៅក្នុងការយកធាតុផ្សំ *អត្តនោម័ត* នៃការធ្វើទុក្ខបុកម្នេញមកធ្វើជាសំអាងហេតុរបស់ខ្លួន[515]ដើម្បីសម្រេចថា "ជនជាប់ចោទមានចេតនាចូលរួមយ៉ាងពេញទំហឹង ក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីបោសសម្អាតរាល់ខ្មាំងនយោបាយរបស់បក្សទាំងអស់ ដែលបានកំណត់អត្តសញ្ញាណដោយមជ្ឈិមបក្ស ក្នុងការឃុំឃាំង ការធ្វើទារុណកម្ម ការសម្លាប់ និងការធ្វើបាបដោយអមនុស្សធម៌ទៅលើអ្នកជាប់ឃុំឃាំង ដោយមូលហេតុនយោបាយនៅមន្ទីរ ស ២១"[516] លើសពីនេះទៀត ជនជាប់ចោទ"មានឥទ្ធិពលក្នុងការកំណត់ក្រុមគោលដៅដែលត្រូវកម្ទេចក្រោមគោលនយោបាយរើសអើងរបស់បក្សកុម្មុយនីស្តកម្ពុជានេះ"[517]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា "សេចក្តីសន្និដ្ឋានដ៏ច្រើន" ដែលទាញចេញពីការអនុវត្តគោលនយោបាយរើសអើងរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយដឹងជាមុន ដោយស្ម័គ្រចិត្ត និងដោយ

---

ភស្តុតាងថា ការដកហូតសិទ្ធិត្រូវតែ"ស្ថិតក្នុងគោលបំណងក្នុងការបំបាត់មនុស្សទាំងនោះចេញពីក្នុងសង្គមដែលពួកគេរស់នៅជាមួយថាវី ឬបំបាត់ពួកគេមិនឱ្យមានភាពជាមនុស្សតែម្តង"។ សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៦៣៤។ *សូមមើលផងដែរ*សាលក្រមក្នុង*រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១២៤។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Ruggiu*, សំណុំរឿងលេខ ICTR-97-32-I, "សាលក្រម និងការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០០ ("សាលក្រមក្នុង*រឿងក្តី Ruggiu*"), កថាខណ្ឌ ២២។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY និងតុលាការ ICTR ពុំបានអនុម័តលក្ខខណ្ឌតម្រូវនេះទេ។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជាបញ្ហានេះក្លាយជាគោលដៅចុងក្រោយនៃផែនការធ្វើទុក្ខបុកម្នេញរបស់ពួកណាហ្ស៊ី មកលើជនជាតិជ្វីហ្វ ជាពិសេសយ៉ាងណាក៏ដោយ ក៏តុលាការបង្កើតឡើងក្រោយសង្គ្រាមលោកលើកទី II ហាក់ដូចជាមិនតម្រូវឱ្យមានភស្តុតាងបែបនេះឡើយ សម្រាប់ជនជាប់ចោទម្នាក់ៗ និងគ្រប់ជនជាប់ចោទទាំងអស់ទាក់ទិននឹងអំពើធ្វើទុក្ខបុកម្នេញជាក់លាក់ដែលខ្លួនទទួលរងការផ្តន្ទាទោស។

[515]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៩១ ដល់ ៣៩៦។

[516]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៩២។

[517]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៩៥។

ពេញចិត្តប្រឆាំងនឹងខ្មាំងរបស់បក្សដោយជនជាប់ចោទបានដឹងនោះ បានបង្ហាញថា "ជនជាប់ចោទមានចេតនាជាក់លាក់ ដែលជាលក្ខខណ្ឌតម្រូវនៃបទធ្វើទុក្ខបុកម្នេញ"[518]។ មូលហេតុជាក់លាក់ដែលជនជាប់ចោទពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញ គឺថាតើការដែលជនជាប់ចោទបានយល់ពីគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជា នៅពីក្រោយគោលនយោបាយធ្វើទុក្ខបុកម្នេញនោះ ឬគ្រាន់តែចង់បង្ហាញថា ខ្លួនជាសមាជិកដែលមានភក្តីភាព និងមានប្រសិទ្ធភាពចំពោះបក្ស ដែរ ឬយ៉ាងណានោះ[519] គឺមិនពាក់ព័ន្ធឡើយចំពោះការយល់ឃើញដែលថា ជនជាប់ចោទមានចេតនាជាក់លាក់ចាំបាច់នោះទេ។

### *៤.ង.២.ខ.ធាតុផ្សំសត្យានុម័ត*

២៤១. ទីពីរ ទាក់ទិនទៅនឹងធាតុផ្សំ*សត្យានុម័ត* នៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខ្លឹមសារនៃធាតុផ្សំនេះនៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើក ទី II មានលក្ខណៈមិនសូវច្បាស់លាស់។ ការមិនមានលក្ខណៈច្បាស់លាស់នៅក្នុងធាតុផ្សំនេះ បានបង្ហាញឱ្យឃើញតាមរយៈខ្លឹមសារ និងសំអាងហេតុនៃយុត្តិសាស្ត្រទាំងនោះ ព្រមទាំងតាមរយៈការពិភាក្សាស្តីអំពីធាតុផ្សំ*សត្យានុម័ត* នៅក្នុងវេទិការបស់តុលាការ *មិនអចិន្ត្រៃយ៍* ជាបន្តបន្ទាប់ និងចម្រូងចម្រាសអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ដូច្នេះ ដោយពិនិត្យលើគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះតុលាការកំពូលត្រូវតែពិចារណាដោយប្រុងប្រយ័ត្ន ថាតើមកត្រឹមឆ្នាំ ១៩៧៥ ជនជាប់ចោទនៅក្នុងរឿងក្តីនេះ បានដឹងជាមុនដោយសមហេតុផល ដែរ ឬយ៉ាងណា នូវការបញ្ជាក់អំពីធាតុផ្សំ*សត្យានុម័ត* ដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើង ដែលការបញ្ជាក់នេះទើបតែក្លាយជាយុត្តិសាស្ត្រនៅក្នុងតុលាការ *មិនអចិន្ត្រៃយ៍* នានានៅត្រឹមឆ្នាំ ២០០៣ តែប៉ុណ្ណោះ[520]។

---

518 សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៩៦។

519 សាលក្រមអង្គជំនុំជម្រះសាលាដំបូង, មតិជំទាស់របស់លោកស្រីចៅក្រម Sylvia Cartwright, កថាខណ្ឌ ៣៩៩។

520 ក្នុងឆ្នាំ ២០០៣ បន្ទាប់ពីមានការបកស្រាយខុសគ្នាៗអំពីនិយមន័យនៃការធ្វើទុក្ខបុកម្នេញអស់រយៈពេលជាច្រើនឆ្នាំនៅក្នុងអង្គជំនុំជម្រះសាលាដំបូងរួចមក អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបង្កើតយ៉ាងជាក់លាក់នូវនិយមន័យនៃការធ្វើទុក្ខបុកម្នេញនៅក្នុងសាលដីកាក្នុង*រឿងក្តី Krnojelac*, កថាខណ្ឌ ១៨៥។

ដូចដែលបានកត់សម្គាល់ខាងលើ នៅពេលធ្វើការពន្យល់អំពីធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញបង្កើតបានជាអំពើសកម្ម ឬអកម្មៈ ១) "ដែលដកហូត ឬរំលោភទៅលើសិទ្ធិសារវន្ត ដែលមានចែងនៅក្នុងច្បាប់សន្ធិសញ្ញាអន្តរជាតិ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ" និង ២) "រើសអើងជាក់ស្តែង"[521]។

### *៤.៦.២.ខ.១.អំពើសកម្ម ឬអកម្មដែលដកហូត ឬរំលោភទៅលើសិទ្ធិសារវន្តដែលមានចែងនៅក្នុងច្បាប់សន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ*

២៤២. ត្រឡប់ទៅផ្នែកទីមួយនៃធាតុផ្សំនេះ ដែលកំណត់និយមន័យផ្នែកទាំងមូលនៃអំពើសកម្ម ឬអកម្ម ដែលអាចបង្កើតបានជាការធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះតុលាការកំពូល រំឭកថាតុលាការយោធាអន្តរជាតិ (IMT) បានពិពណ៌នាអំពើធ្វើទុក្ខបុកម្នេញនៃរបបណាហ្ស៊ី (Nazi) ដូច ខាងក្រោមនេះ៖

> ការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វក្នុងកណ្តាប់ដៃរដ្ឋាភិបាលណាហ្ស៊ី (. . . .) គឺជាកំណត់ហេតុមួយនៃអំពើអមនុស្សធម៌ជាប្រព័ន្ធ និងស៊ីសង្វាក់គ្នាជាទ្រង់ទ្រាយធំ[522]។
>
> នៅពេលក្តោបក្តាប់បានអំណាច ការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វកាន់តែមានលក្ខណៈខ្លាំងក្លាឡើង។ ច្បាប់ដែលមានលក្ខណៈរើសអើងមួយចំនួនត្រូវបានអនុម័ត ដែលកំហិតការិយាល័យ និងវិជ្ជាជីវៈសម្រាប់ជនជាតិជ្វីហ្វ និងមានការដាក់កំហិតទៅលើជីវិតគ្រួសារ និងសិទ្ធិនៃភាពជាពលរដ្ឋរបស់ពួកគេ។ នៅត្រឹមសរទរដូវឆ្នាំ ១៩៣៨ គោលនយោបាយរបស់ណាស៊ី ចំពោះជនជាតិជ្វីហ្វបានឈានទៅដល់ដំណាក់កាលដែលមានទិសដៅដកជនជាតិជ្វីហ្វចេញទាំងស្រុងពីជីវិតជនជាតិអាល្លឺម៉ង់។ ចលនាសម្លាប់រង្គាលជនជាតិជ្វីហ្វត្រូវបានបង្កើតឡើង ដែលរួមបញ្ចូលការដុតបំផ្លាញ និងកម្ទេចវិហារជនជាតិជ្វីហ្វ ការលួចប្លន់ហាងជំនួញជនជាតិជ្វីហ្វ និងការចាប់ខ្លួនពាណិជ្ជករធំៗជាជនជាតិជ្វីហ្វ។ មានការផាកពិន័យជារួមលើជនជាតិជ្វីហ្វចំនួនមួយ

---

[521]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៦។

[522]សាលក្រមតុលាការយោធា IMT, វ៉ុល, XXII, ទំព័រ ៤៩១។

ពាន់លានម៉ាក (រូបិយវត្ថុអាល្លឺម៉ង់) មានការអនុញ្ញាតឱ្យមានការរឹបអូសទ្រព្យសម្បត្តិជនជាតិជ្វីហ្វ ហើយសេរីភាពក្នុងការដើរហើររបស់ជនជាតិជ្វីហ្វ ត្រូវបានរឹតបន្តឹងដោយបទបញ្ជាទៅតាមពេលវេលាជាក់លាក់ និងស្រុកមួយចំនួន។ ការបង្កើតតំបន់ក្រីក្រដាច់ដោយឡែកសម្រាប់ជនជាតិជ្វីហ្វ ត្រូវបានអនុវត្តឡើងក្នុងទ្រង់ទ្រាយធំ និងតាមរយៈបទបញ្ជារបស់នគរបាលសន្តិសុខ ហើយជនជាតិជ្វីហ្វត្រូវបានបង្ខំឱ្យពាក់រូបសញ្ញាផ្កាយពណ៌លឿងនៅលើទ្រូង និងខ្នង[523]។

ទោះបីជាយ៉ាងណាក៏ដោយ ការធ្វើទុក្ខបុកម្នេញរបស់ពួកណាហ្ស៊ី (Nazi) ទៅលើជនជាតិជ្វីហ្វក្នុងប្រទេសអាល្លឺម៉ង់មុនពេលសង្គ្រាមដែលមានលក្ខណៈឃោរឃៅ និងគាបសង្កត់នោះ មិនអាចប្រៀបជាមួយនឹងគោលនយោបាយ ដែលត្រូវបានគេអនុវត្តបន្តក្នុងអំឡុងសង្គ្រាមនៅក្នុងទឹកដីដែលត្រូវបានកាន់កាប់នោះឡើយ។ *ពីដំបូង គោលនយោបាយនោះស្រដៀងទៅនឹងគោលនយោបាយ ដែលមានជាធរមាន នៅក្នុងប្រទេសអាល្លឺម៉ង់*។ ជនជាតិជ្វីហ្វត្រូវបានតម្រូវឱ្យចុះឈ្មោះ បង្ខំឱ្យរស់នៅក្នុងតំបន់ក្រីក្រដាច់ដោយឡែកសម្រាប់ជនជាតិជ្វីហ្វ បង្ខំឱ្យពាក់រូបសញ្ញាផ្កាយពណ៌លឿង និងត្រូវបានប្រើប្រាស់ជាពលករទាសករ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងរដូវក្តៅ ឆ្នាំ ១៩៤១ មានការរៀបចំផែនការសម្រាប់“ដំណោះស្រាយចុងក្រោយ” លើបញ្ហាជនជាតិជ្វីហ្វនៅទូទាំងទ្វីបអឺរ៉ុប។ “ដំណោះស្រាយចុងក្រោយ”នេះមានន័យថា សម្លាប់ជនជាតិជ្វីហ្វឱ្យផុតពូជ (...)[524]។

២៤៣. តុលាការយោធាអន្តរជាតិ (IMT) កត់សម្គាល់ថា ពួកណាហ្ស៊ី (Nazi) បានអនុវត្តវិធីសាស្ត្រយង់ឃ្នងផ្សេងៗគ្នា រួមទាំងការធ្វើពិសោធន៍វេជ្ជសាស្ត្រ ដើម្បីសម្លាប់ជនជាតិជ្វីហ្វឱ្យផុតពូជ។ ឧទាហរណ៍ នៅក្នុងជំរំប្រមូលផ្តុំ ជនជាតិជ្វីហ្វដែលមានកម្លាំងអាចធ្វើការបានត្រូវបានយកមកប្រើជាពលករទាសករ ចំណែកឯអ្នកផ្សេងទៀតដែលពុំមានកម្លាំងអាចធ្វើការបានត្រូវបានសម្លាប់ចោលនៅក្នុងបន្ទប់សម្លាប់មនុស្សដែលប្រើដោយឧស្ម័នពុល[525]។ ជនជាតិជ្វីហ្វ

---

[523]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៤៩២។

[524]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៤៩៣ (សេចក្តីបញ្ជាក់បន្ថែម)។

[525]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៤៩៥។

ជាច្រើនក៏បានស្លាប់ដោយសារជំងឺ និងការបង្អត់អាហារផងដែរ[526]។ "ការវាយដំ ការបង្អត់អាហារ ការធ្វើទារុណកម្ម និងការសម្លាប់ គឺមានលក្ខណៈជាទូទៅ"[527]នៅក្នុងជំរំ។ សម្លៀកបំពាក់ លុយកាក់ និងវត្ថុមានតម្លៃរបស់អ្នកទោស ត្រូវបានប្រមូលយកមកទុកប្រើប្រាស់ ហើយសូម្បីតែសក់របស់អ្នកទោសស្ត្រីជនជាតិជ្វីហ្វ ហើយផេះ ឆ្អឹងរបស់ជនជាតិជ្វីហ្វដែលបានស្លាប់ ក៏ត្រូវបានគេយកមកប្រើប្រាស់ផ្នែកសេដ្ឋកិច្ចផងដែរ[528]។ តុលាការយោធាអន្តរជាតិ (IMT) ក៏បានកត់សម្គាល់ផងដែរថា បេសកកម្មពិសេសត្រូវបានបញ្ជូនទៅប្រទេសដែលត្រូវបានត្រួតត្រា ដើម្បីរៀបចំការនិរទេសជនជាតិជ្វីហ្វជាទ្រង់ទ្រាយធំ ដើម្បី"កម្ចាត់ចោល"[529]។ Adolf Eichmann ដែលទទួលបន្ទុកកម្មវិធីនេះបានប៉ាន់ប្រមាណឃើញថា មានជនជាតិជ្វីហ្វសរុបចំនួនប្រាំមួយលាននាក់ត្រូវបានសម្លាប់ ដោយសារតែនយោបាយប្រឆាំងនឹងជនជាតិជ្វីហ្វ ដោយក្នុងនោះជនជាតិជ្វីហ្វចំនួនបួនលាននាក់"ត្រូវបានសម្លាប់នៅទីកន្លែងសម្រាប់សម្លាប់ឱ្យផុតពូជ"[530]។

២៤៤. កម្រងនៃអង្គហេតុទាំងនេះ រួមជាមួយនឹងព័ត៌មានស្តីអំពីការធ្វើទុក្ខបុកម្នេញផ្សេងៗទៀត គឺជាមូលដ្ឋាន សម្រាប់ការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទជាច្រើននាក់ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារអំពើរើសអើងដែលជាការរំលោភលើសិទ្ធិបុគ្គល។ ការរំលោភបំពានទាំងនេះមានលក្ខណៈកាន់តែធ្ងន់ធ្ងរឡើងៗ ចាប់ពីការដកហូតសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច និងសង្គម រហូតដល់ការនិរទេស ការធ្វើពលកម្មទាសករ និងការសម្លាប់ឱ្យផុតពូជ។

២៤៥. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅក្នុងករណីជាច្រើន តុលាការយោធាអន្តរជាតិ (IMT) បានរកឃើញថា មន្ត្រីណាហ្ស៊ី (Nazi) បានប្រព្រឹត្តអំពើធ្វើទុក្ខបុកម្នេញតាមរយៈ

---

[526]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៤៩៥។

[527]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៤៩៥។

[528]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៤៩៦។

[529]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៤៩៦។

[530]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៤៩៦។

អំពើនានា ដូចជា អំពើរើសអើងផ្នែកសេដ្ឋកិច្ច ដែលមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ អំពើទាំងនេះត្រូវបានប្រព្រឹត្តឡើងនៅក្នុងបរិបទនៃផែនការ ឬ គោលនយោបាយធ្វើទុក្ខបុកម្នេញយ៉ាងទូលំទូលាយមួយរបស់រដ្ឋ ហើយនិងដើម្បីជួយជ្រោមជ្រែងដល់អំពើដទៃទៀតដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា ការនិរទេស ការធ្វើឱ្យទៅជាទាសករ និងចុងក្រោយ គឺការសម្លាប់ឱ្យផុតពូជ។

២៤៦. ឧទាហរណ៍ ជនជាប់ចោទ Göring បានពិភាក្សាជាមួយរដ្ឋមន្ត្រីសេដ្ឋកិច្ចណាហ្ស៊ី (Nazi) Walther Funk អំពីការហាមឃាត់ជនជាតិជ្វីហ្វមិនឱ្យធ្វើសកម្មភាពជំនួញទាំងអស់ ដែលជាផ្នែកមួយនៃដំណោះស្រាយចំពោះបញ្ហាជនជាតិជ្វីហ្វ[531]។ ជនជាប់ចោទ Funk ខ្លួនឯងផ្ទាល់ "បានចូលរួមនៅក្នុងកម្មវិធីរើសអើងដំបូងរបស់ពួកណាហ្ស៊ី ផ្នែកសេដ្ឋកិច្ចប្រឆាំងនឹងជនជាតិជ្វីហ្វ" និងបានស្នើឱ្យមានក្រឹត្យមួយ ហាមឃាត់ជនជាតិជ្វីហ្វមិនឱ្យធ្វើរាល់សកម្មភាពជំនួញទាំងអស់[532]។ នៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈមួយ គាត់បានប្រកាស"ថា ការបំបាត់មិនឱ្យជនជាតិជ្វីហ្វមានជីវិតសេដ្ឋកិច្ចកើតឡើងតាមក្រោយ ដោយសមហេតុផលពីការបំបាត់មិនឱ្យពួកគេមានជីវិតនយោបាយ"[533]។ លើសពីនេះទៀត ជនជាប់ចោទ Göring បានពិន័យជារួមលើជនជាតិជ្វីហ្វចំនួនមួយពាន់លានម៉ាក (marks) ដែលជាផ្នែកនៃគោលបំណងចុងក្រោយនៃការនាំមកនូវ"ដំណោះស្រាយពេញលេញលើបញ្ហានៃជនជាតិជ្វីហ្វ"[534]។ ប្រហាក់ប្រហែលគ្នានេះដែរ ជនជាប់ចោទ Frick ដែលរើសអើងយ៉ាងខ្លាំងប្រឆាំងនឹងអម្បូរ Semitic ត្រូវបានសម្រេចដាក់ពិរុទ្ធពីបទល្មើសដោយឡែកមួយចំនួនដូចជា "បានធ្វើសេចក្តីព្រាង បានចុះហត្ថលេខា និងបានរៀបចំច្បាប់ជាច្រើន ដើម្បីលុបបំបាត់ជនជាតិជ្វីហ្វចេញពីសេដ្ឋកិច្ច និងជីវិតរបស់ជនជាតិអាល្លឺម៉ង់"[535] ដែល"ជាការត្រួសត្រាយផ្លូវសម្រាប់ដំណោះស្រាយចុង

[531]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៥១។

[532]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៥១។

[533]សាលក្រមតុលាការយោធា IMT វ៉ុល, XXII, ទំព័រ ៥៥១។

[534]សាលក្រមតុលាការយោធា IMT វ៉ុល, XXII, ទំព័រ ៤៩២ និង ៥២៧។

[535]សាលក្រមតុលាការយោធា IMT វ៉ុល, XXII, ទំព័រ ៥៤៥។

ក្រោយ”[536]។ ជនជាប់ចោទ ក៏ត្រូវបានរកឃើញថា មានការទទួលខុសត្រូវផងដែរក្នុងការហាមឃាត់ជនជាតិជ្វីហ្វមិនឱ្យអនុវត្តវិជ្ជាជីវៈនានា និងទទួលខុសត្រូវក្នុងការរឹបអូសទ្រព្យសម្បត្តិរបស់ពួកគេ[537]។ តុលាការយោធាអន្តរជាតិ (IMT) បានរកឃើញទៀតថា ជនជាប់ចោទ Seyss-Inquart ក្នុងនាមជាស្នងការនៃចក្រភពអាល្លឺម៉ង់ទី ៣ (Third Reich) របស់ប្រទេសអាល្លឺម៉ង់ប្រចាំប្រទេសហូឡង់ បានចេញក្រឹត្យមួយចំនួនក្នុងគោលបំណងធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ ដោយ“ដាក់ឱ្យមានការរើសអើងផ្នែកសេដ្ឋកិច្ចប្រឆាំងនឹងជនជាតិជ្វីហ្វ” “តម្រូវឱ្យពួកគេចុះឈ្មោះ” “បង្ខំពួកគេឱ្យរស់នៅក្នុងតំបន់ក្រីក្រ និងពាក់សញ្ញារូបផ្កាយ David”[538]។

២៤៧. ការជំនុំជម្រះក្ដីក្រោយៗមកទៀតលើឧក្រិដ្ឋជនជាជនជាតិអាល្លឺម៉ង់ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងនៅចំពោះមុខតុលាការយោធា Nuremberg បានទទួលស្គាល់នូវការបកស្រាយដ៏ទូលំទូលាយ ប្រហាក់ប្រហែលគ្នានេះដែរ ចំពោះអំពើធ្វើទុក្ខបុកម្នេញដែលបានគ្របដណ្ដប់លើអំពើខុសៗគ្នាជាច្រើន លើសពីបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលរួមទាំងទម្រង់នៃការធ្វើទុក្ខបុកម្នេញផ្នែកសេដ្ឋកិច្ច-សង្គម នយោបាយ និងសិទ្ធិពលរដ្ឋ ដែលតែងតែត្រូវបានដាក់ចេញជាផ្នែកនៃផែនការដ៏ទូលំទូលាយមួយ ក្នុងការបំបាត់ចោលទាំងស្រុងនូវពូជសាសន៍មួយនេះ[539]។ ឧទាហរណ៍ នៅក្នុងរឿងក្ដីទាក់ទងនឹង*ក្រសួងផ្សេងៗ* (*Ministries Case*) តុលាការយល់ឃើញថា៖

> ការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វបានប្រព្រឹត្តទៅជាហូរហែរ ពីដំណាក់កាលមួយទៅដំណាក់កាលមួយ ហើយទីបំផុតរហូតធ្វើឱ្យជនរងគ្រោះស្លាប់យ៉ាងអាណោចអាធ័ម។ ជនជាតិជ្វីហ្វនៅប្រទេសអាល្លឺម៉ង់ ដំបូងពួកគេត្រូវបានដកហូតសិទ្ធិពលរដ្ឋ

[536]សាលក្រមតុលាការយោធា IMT វ៉ុល, XXII, ទំព័រ ៥៤៦។

[537]សាលក្រមតុលាការយោធា IMT វ៉ុល, XXII, ទំព័រ ៥៤៥ ដល់ ៥៤៦។

[538]សាលក្រមតុលាការយោធា IMT វ៉ុល, XXII, ទំព័រ ៥៧៦។

[539]*សូមមើលឧទា. រឿងក្ដីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៦៣។ *រឿងក្ដី RuSHA*, វ៉ុល V, ទំព័រ ១៥២។

បន្ទាប់មក ដកហូតសិទ្ធិមិនឱ្យបង្រៀន ប្រកបវិជ្ជាជីវៈ ទទួលបានការអប់រំ ឬធ្វើជំនួញ ហើយត្រូវបានហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ លើកលែងតែអាពាហ៍ពិពាហ៍ជាមួយជនជាតិជ្វីហ្វដូចគ្នា និងអ្នកដែលប្រតិបត្តិសាសនាដូចគ្នា ព្រមទាំងទទួលរងនូវការចាប់ និងឃុំឃាំងនៅក្នុងជំរំប្រមូលផ្តុំ ទទួលរងនូវការវាយដំ កាយវិកលកម្ម និងការធ្វើទារុណកម្ម។ លើសពីនេះ ទ្រព្យសម្បត្តិរបស់ជនរងគ្រោះត្រូវបានរឹបអូស ហើយជនរងគ្រោះ ត្រូវបានប្រមូលផ្តុំឱ្យទៅរស់នៅតំបន់ក្រីក្រ ព្រមទាំង ត្រូវបានបង្ខំឱ្យធ្វើចំណាកស្រុក និងទិញលិខិតអនុញ្ញាតដើម្បីធ្វើចំណាកស្រុក។ ជនរងគ្រោះត្រូវបាននិរទេសទៅប៉ែកបូព៌ា ហើយនៅទីនោះ ពួកគាត់ត្រូវបានបង្ខំឱ្យធ្វើការរហូតបាក់កម្លាំង និងស្លាប់ ហើយបានក្លាយជាពលករទាសករ និងជាចុងក្រោយត្រូវបានសម្លាប់អស់ចំនួនជាង ៦.០០០.០០០ (ប្រាំមួយលាន) នាក់[540]។

២៤៨. លើសពីនេះទៀត តុលាការយោធា Nuremberg យល់ឃើញថា “ការធ្វើទុក្ខបុកម្នេញតាមរយៈតុលាការ” ដែលជាផ្នែកដ៏សំខាន់នៅក្នុងរឿងក្តីពាក់ព័ន្ធនឹង*ក្រសួងផ្សេងៗ* (*Ministries Case*) មានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ដាក់ពិរុទ្ធភាពលើជនជាប់ចោទ Hans Lammers ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដោយផ្តល់សំអាងហេតុថា ៖

> ដោយសារតែមានការប្រព្រឹត្តមិនប្រក្រតីរបស់ប្រព័ន្ធតុលាការនេះ បានធ្វើឱ្យជនជាតិជ្វីហ្វ និងអ្នកប្រឆាំង ព្រមទាំងសត្រូវដទៃទៀតរបស់សង្គមនិយមជាតិនិយម ត្រូវបានដកហូតសិទ្ធិដែលបានទទួលស្គាល់ជាទូទៅ និងជាធម្មតាក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងទទួលរងនូវការដាក់ទោស រួមទាំងទោសប្រហារជីវិតដែលពុំសមស្របទាល់តែសោះទៅនឹងបទល្មើសដែលបានប្រព្រឹត្តឡើង[541]។

២៤៩. ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅក្នុងរឿងក្តីពាក់ព័ន្ធនឹង*វិស័យយុត្តិធម៌* (*Justice Case*) ចៅក្រមអាល្លឺម៉ង់ ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញលើជនជាតិប៉ូឡូញ និងជ្វីហ្វ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមូលហេតុ

---

[540] *រឿងក្តីពាក់ព័ន្ធក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៤៧១។

[541] *រឿងក្តីពាក់ព័ន្ធក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៦០៤។

ការអនុវត្តច្បាប់ដោយរើសអើង[542]។ ដំបូង តុលាការយោធា Nuremberg បានពិនិត្យទៅលើកម្មវិធី ឬផែនការជាតិសម្រាប់ការធ្វើទុក្ខបុកម្នេញលើពូជសាសន៍[543]។ តុលាការនេះ បានកត់សម្គាល់ថា "ជាមូលដ្ឋាន កម្មវិធីនោះ គឺជាកម្មវិធីមួយមានគោលបំណងសម្លាប់ឱ្យផុតពូជយ៉ាងពិតប្រាកដលើជនជាតិប៉ូឡូញ និងជ្វីហ្វ តាមរយៈការឃុំឃាំងនៅក្នុងជំរំប្រមូលផ្តុំ ឬការសម្លាប់"[544]។ ទន្ទឹមគ្នានោះដែរ តុលាការនេះបានកត់សម្គាល់ថា "ទម្រង់នៃការធ្វើទុក្ខបុកម្នេញលើពូជសាសន៍មានលក្ខណៈស្រាលៗ" ដែលត្រូវបានអនុវត្តជាប្រព័ន្ធដោយអាជ្ញាធររដ្ឋាភិបាល ក៏ជាផ្នែកមួយនៅក្នុងកម្មវិធី ឬគោលនយោបាយទូទៅ[545]។ ទម្រង់ទាំងនេះមានដូចជា ការដកហូតសិទ្ធិរបស់ជនជាតិជ្វីហ្វក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យច្បាប់ ការហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងជនជាតិជ្វីហ្វ និងបុគ្គលទាំងឡាយដែលមានឈាមជ័រអាល្លឺម៉ង់ ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរលើជនជាតិជ្វីហ្វចំពោះការរួមភេទរវាងជនជាតិជ្វីហ្វ និងអាល្លឺម៉ង់ ការហាមឃាត់ជនជាតិជ្វីហ្វក្នុងការបម្រើការនៅក្នុងការិយាល័យសាធារណៈ "ស្ថាប័នអប់រំ និងសហគ្រាសជំនួញជាច្រើន" និងការរឹបអូសទ្រព្យសម្បត្តិជនជាតិជ្វីហ្វ[546]។ ទាក់ទិននឹងការពង្រឹងនៃការអនុវត្តច្បាប់រើសអើងប្រឆាំងនឹងជនជាតិជ្វីហ្វ តុលាការនេះបានកត់សម្គាល់ថា៖

> ច្បាប់ប្រឆាំងនឹងជនជាតិប៉ូឡូញ និងជ្វីហ្វ (...) ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង។ ជនជាតិប៉ូឡូញ និងជ្វីហ្វ ដែលមានទោសចំពោះបទល្មើសជាក់លាក់ណានោះ ត្រូវបានទទួលរងនូវការដាក់ទណ្ឌកម្មខុសគ្នាពីការដាក់ទណ្ឌកម្មទៅលើជនជាតិអាល្លឺម៉ង់ ដែលបានប្រព្រឹត្តបទល្មើសដូចគ្នា។ សិទ្ធិរបស់ពួកគេជាជនជាប់ចោទនៅក្នុងតុលាការ ត្រូវបានរឹតត្បិតយ៉ាងតឹងរ៉ឹង។ ទោះបីជា ច្បាប់មិនមានចែងពីទោសប្រហារជីវិតក៏ដោយ ក៏តុលាការប្រើអំណាចផ្តន្ទាទោសប្រហារជីវិតទៅលើជនជាតិប៉ូឡូញ និងជ្វីហ្វបាន ប្រសិនបើ មានភស្តុតាងបង្ហាញអំពី "មូលហេតុពិសេសដែលតុលាការនោះមិនអាច

---

[542] *រឿងក្តីពាក់ព័ន្ធវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៦៣។

[543] *រឿងក្តីពាក់ព័ន្ធវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៦៣។

[544] *រឿងក្តីពាក់ព័ន្ធវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៦៣។

[545] *រឿងក្តីពាក់ព័ន្ធវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៦៣។

[546] *រឿងក្តីពាក់ព័ន្ធវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៦៣ ដល់ ១០៦៤។

ទទួលយកបាន"។ ហើយចុងក្រោយ ប៉ូលីសអាល្លឺម៉ង់ក៏មាន*អំណាចពេញលេញ*ក្នុងការដាក់ទណ្ឌកម្មរាល់អំពើ"ឧក្រិដ្ឋ" ដែលប្រព្រឹត្តដោយជនជាតិជ្វីហ្វដោយពុំចាំបាច់ប្រើប្រាស់នីតិវិធីតាមផ្លូវតុលាការនោះទេ[547]។

២៥០. នៅក្នុងករណីផ្សេងៗទៀត តុលាការយោធាអន្តរជាតិ (IMT) បានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទនានាចំពោះអំពើធ្វើទុក្ខបុកម្នេញ ដែលបង្កើតបានជាបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល និងការនិរទេស។ ឧទាហរណ៍ ជនជាប់ចោទ Von Ribbentrop "បានដើរតួនាទីយ៉ាងសំខាន់នៅក្នុង*ដំណោះស្រាយចុងក្រោយ*របស់ហ៊ីត្លែរ (Hitler) ចំពោះបញ្ហាជនជាតិជ្វីហ្វ"[548]។ ជនជាប់ចោទបានបញ្ជាឱ្យតំណាងទូតអាល្លឺម៉ង់ប្រចាំនៅប្រទេសរណបរបស់ខ្លួន បង្កើនការនិរទេសជនជាតិជ្វីហ្វទៅកាន់ប៉ែកបូព៌ា"[549]។ ប្រហាក់ប្រហែលគ្នានេះដែរ ទាក់ទិននឹងជនជាប់ចោទ Rosenberg តុលាការនេះរកឃើញថា ៖

> អ្នកក្រោមបង្គាប់របស់ជនជាប់ចោទ បានជាប់ពាក់ព័ន្ធនឹងការសម្លាប់រង្គាលលើជនជាតិជ្វីហ្វ ហើយអ្នករដ្ឋការស៊ីវិលជាន់ខ្ពស់របស់ជនជាប់ចោទនៅប៉ែកបូព៌ា បានយល់ឃើញថា ការបោសសម្អាតជនជាតិជ្វីហ្វចេញពីទឹកដីដែលខ្លួនត្រួតត្រានៅប៉ែកបូព៌ា គឺជាការចាំបាច់។ នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៤១ ជនជាប់ចោទបានផ្តល់យោបល់ទៅហ៊ីត្លែរ (Hitler) ថា នៅពេលត្រូវការបាញ់សម្លាប់ចំណាប់ខ្មាំងចំនួន ១០០ (មួយរយ)នាក់ គឺគួរយកតែជនជាតិជ្វីហ្វមកសម្លាប់ប៉ុណ្ណោះ[550]។

២៥១. ដូចគ្នានេះដែរ ជនជាប់ចោទ Bormann គឺជា"ជនសកម្មបំផុតក្នុងការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ" និងបានគាំទ្រឱ្យមានការប្រើប្រាស់"កម្លាំងយ៉ាងព្រៃផ្សៃ" ដើម្បីធានាឱ្យបាននូវ

---

[547] *រឿងក្តីពាក់ព័ន្ធវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៦៤។

[548] សាលក្រមតុលាការយោធា IMT, វ៉ុល I, ទំព័រ ២៨៧។

[549] សាលក្រមតុលាការយោធា IMT, វ៉ុល I, ទំព័រ ២៨៧។

[550] សាលក្រមតុលាការយោធា IMT, វ៉ុល I, ទំព័រ ២៩៥ ដល់ ២៩៦។

"ការលុបបំបាត់ចោលជនជាតិជ្វីហ្វជានិរន្តរ៍"[551]។ អំពើធ្វើទុក្ខបុកម្នេញរបស់ជនជាប់ចោទបានរួមបញ្ចូលនូវការចូលរួមក្នុងការនិរទេសប្រជាជនជាជនជាតិជ្វីហ្វ ក្នុងទ្រង់ទ្រាយធំចេញពីទីក្រុងវីយែន[552]។ ជនជាប់ចោទ Frank ជាអគ្គទេសាភិបាលអាល្លឺម៉ង់ប្រចាំប្រទេសប៉ូឡូញ ត្រូវបានរកឃើញថា មានពិរុទ្ធពីបទ"ការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ [ដែល] អំពើនេះបានចាប់ផ្តើមភ្លាមៗ" នៅពេលដែលជនជាប់ចោទបានត្រួតត្រាប្រទេសប៉ូឡូញ[553]។ នៅក្នុងសាលក្រមរបស់ខ្លួន តុលាការយោធាអន្តរជាតិ (IMT) បានកត់សម្គាល់ថា ការធ្វើទុក្ខបុកម្នេញរបស់ជនជាប់ចោទ Frank បានធ្វើឱ្យចំនួនប្រជាជនប៉ូឡូញដែលជាជនជាតិជ្វីហ្វ បានថយចុះពី ២.៥០០.០០០ (ពីរលានប្រាំសែន) ឬ ៣.០០០.០០០ (បីលាន) នាក់ មកនៅត្រឹម ១០០.០០០ (មួយសែន) នាក់ ចាប់តាំងពីពេលដែលជននេះបានចូលកាន់តំណែង រហូតមកត្រឹមដើមឆ្នាំ ១៩៤៤[554]។ តុលាការយោធាអន្តរជាតិ (IMT) ក៏បានរកឃើញផងដែរថា ជនជាប់ចោទក៏បានកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ចលើជនជាតិប៉ូឡូញ រហូតដល់កម្រិតមួយដែលធ្វើឱ្យជនរងគ្រោះស្លាប់ដោយអត់អាហារ ហើយមានជំងឺរាតត្បាតបានរីករាលដាល"[555]។ ប្រហាក់ប្រហែលគ្នានេះដែរ តុលាការនេះបានរកឃើញថា ជនជាប់ចោទ Seyss-Inquart "បានគាំទ្រការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ"[556] ហើយក្នុងនាមជាស្នងការនៃចក្រភពអាល្លឺម៉ង់ទី៣ (Third Reich) របស់ប្រទេសអាល្លឺម៉ង់ប្រចាំប្រទេសហូឡង់ ជននេះបានអនុញ្ញាតឱ្យមាន "ការនិរទេសជនជាតិជ្វីហ្វក្នុងទ្រង់ទ្រាយធំចំនួន ១២០.០០០ (មួយសែនពីរម៉ឺន) នាក់ ពីក្នុងចំណោម ១៤០.០០០ (មួយសែនបួនម៉ឺន) នាក់ នៅក្នុងប្រទេសហូឡង់ទៅកាន់តំបន់អូសហ្វីត (Auschwitz) ហើយបានអនុញ្ញាតឱ្យមានការអនុវត្តដំណោះស្រាយចុងក្រោយ[557]។

[551]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៨៦។

[552]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៨៦។

[553]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៤២ ដល់ ៥៤៣។

[554]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៤៣។

[555]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៤២។

[556]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៧៥។

[557]សាលក្រមតុលាការយោធា IMT, វ៉ុល XXII, ទំព័រ ៥៧៦។

២៥២. ដូចគ្នានេះដែរ ការជំនុំជម្រះនៅចំពោះមុខតុលាការយោធា Nuremberg ក៏បានទទួលស្គាល់ផងដែរនូវអំពើធ្វើទុក្ខបុកម្នេញដោយគ្របដណ្តប់ទាំងបទល្មើសមូលដ្ឋានដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើឱ្យទៅជាទាសករ។ នៅក្នុងរឿងក្តីពាក់ព័ន្ធនឹង *វិស័យយុត្តិធម៌* (*Justice* Case) ជនជាប់ចោទ Rothaug ត្រូវបានសម្រេចដាក់ពិរុទ្ធពីបទល្មើសមួយក្នុងចំណោមបទល្មើសជាច្រើន ដោយសារជននេះបានវិនិច្ឆ័យរឿងក្តីមួយ ដោយបានផ្តន្ទាទោសប្រហារជីវិតលើជនជាប់ចោទ ដោយសារតែជាជនជាតិជ្វីហ្វ[558]។ ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងរឿងក្តី *ពាក់ព័ន្ធនឹងក្រសួងផ្សេងៗ* (*Ministries* Case) តុលាការយោធាអន្តរជាតិ (IMT) បានរកឃើញថា ជនជាប់ចោទ Richard Walther Darré បានដឹងអំពីផែនការ"ដកហូតដីធ្លីពីជនជាតិជ្វីហ្វ និងជនជាតិប៉ូឡូញដោយខុសច្បាប់ និងបានបន្ទាបបន្ថោកជនរងគ្រោះទៅជាទាសករ"[559]ព្រមទាំងបង្ខំឱ្យជនរងគ្រោះធ្វើពលកម្មទាសករ ហើយបានចូលរួមអនុវត្តផែនការនានាដោយដឹងជាមុន និងស្ម័គ្រចិត្តក្នុងតួនាទីជាអ្នកដឹកនាំ នៅក្នុងស្ថាប័ននានាដែលអនុវត្តផែនការទាំងនោះ[560]។ ទន្ទឹមគ្នានោះដែរ ជនជាប់ចោទ Otto Dietrich ត្រូវបានរកឃើញថា មានពិរុទ្ធភាពចំពោះការចូលរួមក្នុងអំពើធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ ដោយប្រកាសសេចក្តីណែនាំតាមសារព័ត៌មានអំពាវនាវឱ្យមានការបំបាត់ជនជាតិនេះចោលទាំងស្រុង[561]។

២៥៣. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វិសាលភាពនៃធាតុផ្សំសត្យានុម័តនៃអំពើធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ គឺមានការកត់សម្គាល់ពិសេសចំនួនពីរចំណុច។ ទីមួយ យុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II ពិពណ៌នាពីអំពើជាមូលដ្ឋានច្រើនប្រភេទ ដែលអាចបង្កើតបានជាអំពើធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំង

---

[558] *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១១៥៥។

[559] *រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៥៦៣។

[560] *រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៥៦៣ ដល់ ៥៦៤។

[561] *រឿងក្តីពាក់ព័ន្ធនឹងក្រសួងផ្សេងៗ*, វ៉ុល XIV, ទំព័រ ៥៧៥ ដល់ ៥៧៦។

មនុស្សជាតិ[562]។ អំពើទាំងនេះរួមមានឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត ដូចជា បទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[563] ឬឧក្រិដ្ឋកម្មសង្គ្រាម[564] ដែលមានចែងរួច

[562]ព្រឹត្តប័ត្រនិពន្ធដោយ Heller, *ស្តីពីតុលាការយោធា Nuremberg និងប្រភពដើមនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ,* ទំព័រ ២៤៥ ដល់ ២៤៩។

[563] *សូមមើលឧទា.* ការផ្តល់សំអាងហេតុលើបញ្ហានេះនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី* *Kupreškić,* កថាខណ្ឌ ៥៩៤៖

> ទាក់ទិននឹងបញ្ហា ថាតើការធ្វើទុក្ខបុកម្នេញអាចរួមបញ្ចូលនូវអំពើទាំងឡាយដែលបានចែងនៅក្នុងចំណងជើងតូចៗផ្សេងទៀតនៃមាត្រា ៥ ដែរ ឬយ៉ាងណានោះ ហើយជាពិសេស ឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាត និងការនិរទេស អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា មានឧទាហរណ៍ជាច្រើនអំពីការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដែលកើតចេញពីសង្គ្រាមលោកលើកទី II។ នៅក្នុងសំអាងហេតុរបស់ខ្លួនស្តីពីការធ្វើទុក្ខបុកម្នេញ តុលាការយោធា IMT បានដាក់បញ្ចូលបទល្មើសជាច្រើន ដែលបច្ចុប្បន្ននេះស្ថិតនៅក្រោមចំណងជើងតូចៗផ្សេងទៀតនៃមាត្រា ៥។ អំពើទាំងនេះរួមបញ្ចូលនូវអំពើមនុស្សឃាតក្នុងទ្រង់ទ្រាយធំលើជនជាតិជ្វីហ្វ ពីសំណាក់ *Einsatzgruppen* និង *SD* និងការសម្លាប់រង្គាល ការវាយដំ ការធ្វើទារុណកម្ម និង ការសម្លាប់ ដែលរាលដាលទូទៅនៅក្នុងជំរំប្រមូលផ្តុំ។ ស្រដៀងគ្នានេះដែរ សាលក្រមដែលបានចេញ អនុលោមតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង បានដាក់បញ្ចូលនូវបទល្មើសនានាដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្មនៅក្នុងសំអាងហេតុរបស់សាលក្រមទាំងនោះស្តីពីការធ្វើទុក្ខបុកម្នេញជនជាតិជ្វីហ្វ និងក្រុមផ្សេងៗទៀត ក្នុងអំឡុងយុគសម័យណាហ្ស៊ី (Nazi)។ ដូច្នេះ តុលាការយោធានៅទីក្រុង Nuremberg យល់ឃើញថា ការធ្វើទុក្ខបុកម្នេញអាចរួមបញ្ចូលនូវបទល្មើសទាំងនោះដែលមាននៅក្នុងចំណងជើងតូចៗផ្សេងទៀតនៃមាត្រា ៥ នៃលក្ខន្តិកៈ។

[564]*សូមមើលឧទា.* ការវិភាគលើចំណុចនេះនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី* *Tadić,* កថាខណ្ឌ ៧០០ ដល់ ៧០១៖

> ដូចដែលបានបញ្ជាក់ដោយតុលាការយោធាសហរដ្ឋអាមេរិក នៅក្នុង*រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌* និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង បានហាមឃាត់"<u>មិនត្រឹមតែ</u>ឧក្រិដ្ឋកម្មសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអំពើទាំងឡាយដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងនិយមន័យពីមុននៃឧក្រិដ្ឋកម្មសង្គ្រាម"។ សេចក្តីអត្ថាធិប្បាយចំពោះករណីនេះបញ្ជាក់ថា "ជាការច្បាស់ណាស់ដែលថា ឧក្រិដ្ឋកម្មសង្គ្រាមក៏អាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផង

ហើយនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ (IMT) និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ឬអំពើផ្សេងៗទៀតដែលមិនបានចែងច្បាស់លាស់នៅក្នុងលិខិតុបករណ៍ និងច្បាប់នេះ នៅពេលដែលអំពើទាំងនេះ បានបំពេញតាមលក្ខខណ្ឌតម្រូវផ្សេងៗទៀតតាមនិយមន័យនៃការធ្វើទុក្ខបុកម្នេញ។

២៥៤. ទីពីរ អំពើផ្សេងៗទៀត ដែលមិនមានចែងនៅក្នុងលិខិតុបករណ៍នានា បង្កើតបានជាការរំលោភបំពានយ៉ាងច្រើនទៅលើសិទ្ធិបុគ្គលដែលរួមមាន សិទ្ធិលើកម្មសិទ្ធិ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ សិទ្ធិក្នុងការទទួលបានការការពារដោយស្មើៗគ្នានៅចំពោះមុខច្បាប់ សិទ្ធិជាពលរដ្ឋ សិទ្ធិក្នុងការជ្រើសរើសមុខរបរ សិទ្ធិក្នុងការទទួលបានការអប់រំ សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ សិទ្ធិឯកជន និងសេរីភាពក្នុងការដើរហើរ។ ទោះបីជាយ៉ាងណាក៏ដោយ "មិនមែនរាល់ការដកហូតសិទ្ធិមនុស្ស (...) សុទ្ធតែបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[565] តាមយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II នោះទេ។ ប៉ុន្តែ ដូចដែលបានកំណត់នៅក្នុងរឿងក្តី *Flick* ហើយក្រោយមកទៀតបានបញ្ជាក់ឡើងវិញនៅក្នុងរឿងក្តី *I.G. Farben* លទ្ធិច្បាប់ស្តីអំពីប្រភេទដូចគ្នា (*ejusdem generis*) ត្រូវបានប្រើប្រាស់ដើម្បីធ្វើការបកស្រាយធម្មនុញ្ញរបស់តុលាការនានា ក្នុងការបែងចែក"ដែនកំណត់ដែលបានបញ្ជាក់ច្បាស់លាស់រួចហើយ ចំពោះប្រភេទនៃអំពើដែលជាការធ្វើទុក្ខបុក

ដែរ។ បទល្មើសដូចគ្នាអាចជាប្រភេទនៃបទឧក្រិដ្ឋទាំងពីរ"។ នេះ គឺជាវិធីសាស្ត្រដែលតុលាការ Nürnberg អនុវត្តតាមផងដែរ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១ រួមមានបទចោទប្រកាន់អំពីឧក្រិដ្ឋកម្មសង្គ្រាមទាំងពីរ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងរួមមានសេចក្តីបញ្ជាក់ដែលថា "ការចោទប្រកាន់នឹងផ្អែកទៅលើអង្គហេតុដែលត្រូវបានថ្លែងសំអាងក្រោមបទចោទទីបី [ឧក្រិដ្ឋកម្មសង្គ្រាម] ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ"។ (...) សេចក្តីបញ្ជាក់ស្រដៀងគ្នានេះដែរមាននៅក្នុងរឿងក្តីដទៃទៀត ដែលត្រូវបានជំនុំជម្រះដោយផ្អែកលើច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ឧទាហរណ៍, *ការជំនុំជម្រះក្តី Otto Ohlendorf និងជនដទៃទៀត* ("*រឿងក្តី Einsatzgruppen*") និង *រឿងក្តី Pohl*" (សេចក្តីបញ្ជាក់បន្ថែម។ សេចក្តីដកស្រង់ត្រូវបានលុបចោល)។

[565] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៦១៨។

ម្មេញ"[566]។ លទ្ធិច្បាប់នេះតម្រូវថា ក្នុងកម្រិតអប្បបរមា អំពើធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវតែមានស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរស្មើគ្នាទៅនឹងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[567]។ នៅក្នុងរឿងក្តី *Flick* ទាក់ទិននឹងការរឹបអូសយកទ្រព្យសម្បត្តិផ្នែកឧស្សាហកម្មរបស់ជនជាតិជ្វីហ្វ ដែលមានបញ្ជាក់នៅក្នុងសំអាងហេតុដូចខាងក្រោម៖

> ទោះបីជាមានការបកស្រាយយ៉ាងត្រឹមត្រូវនូវផ្នែកនៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏អង្គហេតុ[ការរឹបអូសដោយបង្ខំនូវទ្រព្យសម្បត្តិផ្នែកឧស្សាហកម្មរបស់ជនជាតិជ្វីហ្វ] មិនតម្រូវឱ្យមានការដាក់ពិរុទ្ធភាព ទេ។ "អំពើឃោរឃៅ និងបទល្មើសនានា" ដែលបានរៀបរាប់ មានដូចជា"អំពើមនុស្សឃាត ការសម្លាប់រង្គាល"ជាអាទិ៍ សុទ្ធតែជាបទល្មើសប្រឆាំងនឹងបុគ្គល ដោយមិនមានការនិយាយអំពីទ្រព្យសម្បត្តិនោះទេ។ យោងតាមលទ្ធិច្បាប់ស្តីអំពីប្រភេទដូចគ្នា (*ejusdem generis*) "ការធ្វើទុក្ខបុកម្នេញផ្សេងៗទៀត"ដែលជាពាក្យពេចន៍ក្តោបន័យរួម ត្រូវបានចាត់ទុកថា រួមបញ្ចូលតែអំពើទាំងឡាយណាដែលប៉ះពាល់ដល់ជីវិត និងសេរីភាពរបស់មនុស្សដែលទទួលរងការគាបសង្កត់ ប៉ុណ្ណោះ។ ការរឹបអូសយកទ្រព្យសម្បត្តិផ្នែកឧស្សាហកម្មមិនស្ថិតនៅក្នុងប្រភេទនេះទេ ទោះបីជាអំពើនេះសមនឹងទទួលទោសក៏ដោយ[568]។

២៥៥. ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *Kupreškić* បានសម្រេចថា សេចក្តីសន្និដ្ឋានតែមួយគត់ដែលអាចទាញចេញពីការប្រើប្រាស់លទ្ធិច្បាប់ស្តីអំពីប្រភេទដូចគ្នា (*ejusdem generis*) គឺថា "ការដកហូតសិទ្ធិមនុស្សជាសារវន្តដោយកំរោល ឬដោយឥតលាក់លៀម" ដែលប៉ះពាល់ដល់ជីវិត និងសេរីភាពបុគ្គលប៉ុណ្ណោះ ទើបអាចចាត់ទុកថា ឈានដល់កម្រិតធ្ងន់ធ្ងរ ឬស្ថានទម្ងន់នៃបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[569]។

---

[566]សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៦១៨ (សេចក្តីបញ្ជាក់ត្រូវបានដកចេញ)។

[567]សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៦១៩។

[568]*រឿងក្តី Flick*, ទំព័រ ១២១៥។ *សូមមើលផងដែរ I.G. Farben*, ទំព័រ ១១២៩ ដល់ ១១៣០។

[569]សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៦២០ (សេចក្តីបញ្ជាក់ត្រូវបានដកចេញ)។

២៥៦. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា តុលាការព្រហ្មទណ្ឌនានាក្រោយសង្គ្រាមលោកលើកទី II ពុំធ្លាប់បានពិចារណាអំពីការធ្វើទុក្ខបុកម្នេញដាច់ដោយឡែកតែឯងនោះទេ។ ប៉ុន្តែ តុលាការទាំងនេះ បានពិចារណាលើអំពើទាំងឡាយដែលស្ថិតក្នុងបរិបទនៃការចូលរួមជម្រុញកិច្ចប្រតិបត្តិការធ្វើទុក្ខបុកម្នេញក្នុងទ្រង់ទ្រាយធំដែលគោលបំណង និងលទ្ធផលចុងក្រោយនៃកិច្ចប្រតិបត្តិការនេះ គឺបានរំលោភយ៉ាងកំរោលទៅលើសិទ្ធិសារវន្ត ដែលជាញឹកញាប់បង្កើតបានជាបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ តុលាការទាំងនេះបានវាយតម្លៃថា អំពើទាំងនេះជាផ្នែកនៃព្រឹត្តិការណ៍ដែលកើតឡើងតៗគ្នា ហើយដែលផលវិបាកនៃអំពើតៗគ្នានេះ មានលក្ខណៈធ្ងន់ធ្ងរយ៉ាងខ្លាំង។ ប្រហាក់ប្រហែលគ្នានេះដែរ តុលាការបានវិភាគអំពើទាំងនេះដោយផ្សាភ្ជាប់ជាមួយនឹងការរំលោភយ៉ាងធ្ងន់ធ្ងរផ្សេងៗទៀតលើសិទ្ធិមនុស្ស ដោយសារតែពួកគេបានប្រើប្រាស់តួនាទីជាមធ្យោបាយ ដែលនាំឱ្យមានការរំលោភសិទ្ធិជាសារវន្ត។ លើសពីនេះទៀត តុលាការពុំបានពិចារណាអំពើធ្វើទុក្ខបុកម្នេញដាច់ដោយឡែកតែឯងនោះឡើយ ផ្ទុយទៅវិញ តុលាការបានពិចារណាលើអំពើទាំងនេះជារួមដោយភ្ជាប់អំពើទាំងនោះជាមួយគ្នាទៅវិញទៅមក ដោយពិនិត្យលើផលប៉ះពាល់គ្រួតគ្នានៃអំពើទាំងនោះទៅលើប្រជាជនទាំងមូល។

២៥៧. សរុបមក អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាទូទៅជាមួយអង្គជំនុំជម្រះសាលាដំបូងដែលថា ចំណុចទីមួយនៃ*ធាតុផ្សំសត្យានុម័ត*អំពើធ្វើទុក្ខបុកម្នេញ គឺថា ធាតុផ្សំនេះ បង្កើតបានជាអំពើសកម្ម ឬអកម្មដែលដកហូត ឬរំលោភសិទ្ធិសារវន្តដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់សន្ធិសញ្ញា។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា យោងតាមយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II ចំណុចសំខាន់បំផុតនៃការវិភាគនេះ គឺមិនមែនឋិតនៅលើការកំណត់ ថាតើអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញជាក់លាក់*នេះ* រំលោភលើសិទ្ធិមនុស្សដែលជាសិទ្ធិសារវន្ត ដែរឬយ៉ាងណា នោះឡើយ។ ប៉ុន្តែ ស្ថិតនៅលើការកំណត់ ថាតើអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញនេះ នៅពេលដែលពិចារណាជារួម និងទៅតាមបរិបទ នាំឱ្យមានការរំលោភលើសិទ្ធិជាសារវន្ត ដោយកំរោល ឬឥតលាក់លៀម ដែល *មានភាពធ្ងន់ធ្ងរ ឬស្ថានទម្ងន់ស្មើគ្នាទៅ*

*នឹងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា*។ ជាការពិត៖

> ទៅតាមបរិបទនៃអំពើនីមួយៗ និងភាពចាំបាច់ ដែលអំពើទាំងនេះ រួមទាំងការរំលោភបំពានដែលបង្កឡើងដោយសារអំពើនេះ ត្រូវតែពិនិត្យជារួមដើម្បីកំណត់ពីស្ថានទម្ងន់នៃអំពើនេះទាំងមូល ហើយថា ស្ថានទម្ងន់នេះបានកំណត់លើបញ្ហា ថាតើសិទ្ធិដែលត្រូវបានរំលោភបំពាននោះជាសិទ្ធិ"សារវន្ត" ដែរ ឬយ៉ាងណា ចំពោះគោលបំណងនៃឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញ[570]។

២៥៨. ជាការពិត ដូចដែលបានបង្ហាញដោយយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II ដែលបានយោងខាងលើជាញឹកញាប់ ទោះបីជាការធ្វើទុក្ខបុកម្នេញ គឺជាអំពើតៗគ្នាក៏ដោយ ក៏អំពើសកម្ម ឬអកម្មតែមួយ អាចត្រូវបានចាត់ទុកថា មានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីចាត់ទុកថា ជាអំពើធ្វើទុក្ខបុកម្នេញ ពីព្រោះអំពើនេះបណ្តាលឱ្យមានការដកហូតសិទ្ធិមនុស្សជាសារវន្តដោយកំរោល ឬដោយឥតលាក់លៀម ផ្អែកតាមសន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ[571]។ ប្រហាក់ប្រហែលគ្នានេះដែរ អំពើសកម្ម ឬអកម្ម ដែលបង្កើតបានជាឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត ជាពិសេសជាបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏អាចបង្កើតបានជាអំពើធ្វើទុក្ខបុកម្នេញផងដែរ[572]។

២៥៩. ដើម្បីបញ្ជាក់ជាថ្មីថា ក្នុងការវិភាគអំពីស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរនៃអំពើប្រព្រឹត្តមានកត្តាផ្សេងទៀតដែលត្រូវយកមកពិចារណា រួមមាន ថាតើអំពើសកម្ម ឬអកម្មនេះត្រូវបានប្រព្រឹត្តក្នុង

---

[570]សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Brđanin*, សំណុំរឿងលេខ IT-99-36-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៥, ("សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Brđanin*"), ជើងទំព័រ ២៥៨៥។

[571]សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១០២, ដកស្រង់ចេញពី*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Blaškić*, សំណុំរឿងលេខ IT-95-14-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤, ("សាលដីកាក្នុង*រឿងក្តី Blaškić*"), កថាខណ្ឌ ១៣៥, ដកស្រង់សាលដីកា*ក្នុងរឿងក្តី* Vasiljević, កថាខណ្ឌ ១១៣។

[572]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៨។

បរិបទ ឬជាផ្នែកនៃព្រឹត្តិការណ៍ដែលកើតឡើងតៗគ្នានៅក្នុងប្រតិបត្តិការនៃការធ្វើទុក្ខបុកម្នេញក្នុងទ្រង់ទ្រាយធំជាងមុនដែលគោលដៅ និងលទ្ធផលចុងក្រោយនៃប្រតិបត្តិការនេះ មានភាពធ្ងន់ធ្ងរបំផុត ដែលបានបណ្តាលឱ្យមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិជាសារវន្ត ដែលជាញឹកញាប់ គឺជាបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បន្ថែមពីលើនេះទៀត មានសារៈសំខាន់ណាស់ ក្នុងការកត់សម្គាល់លើផលប៉ះពាល់ត្រួតគ្នានៃអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញ នៅពេលដែលអំពើនេះត្រូវបានប្រព្រឹត្តដោយភ្ជាប់ជាមួយនឹងអំពើសកម្ម ឬអកម្មប្រហាក់ប្រហែលគ្នាផ្សេងទៀត។ ជាចុងក្រោយ ត្រូវតែយកមកពិចារណា ថាតើអំពើសកម្ម ឬអកម្មនេះ បានឈានដល់កម្រិតនៃអំពើធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណានោះ មិនមែនគ្រាន់តែមាន"អំពើសាហាវឃោរឃៅជាក់ស្តែងតែមួយប៉ុណ្ណោះទេ ដែលដើរតួនាទីសំខាន់នោះ ប៉ុន្តែ ត្រូវរួមបញ្ចូលទាំងផលប៉ះពាល់ដែលជាលក្ខណៈរើសអើងទៀតផង ដែលអំពើទាំងនេះបានជំរុញឱ្យប្រជាជនជាទូទៅ"[573]ប្រឆាំងនឹងក្រុមដែលជាគោលដៅ។ ម្យ៉ាងវិញទៀត អង្គហេតុដែលថា អំពើសកម្ម ឬអកម្មដែល មានគោលដៅប្រឆាំងបុគ្គលជាក់លាក់មួយចំនួន ដោយគ្រាន់តែបុគ្គលនោះជាសមាជិកនៅក្នុងក្រុមណាមួយនោះ ពិតជាធ្វើឱ្យស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរកាន់តែខ្លាំងជាងមុន។

២៦០. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា យុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* បានសម្រេចស្របគ្នាថា បទល្មើសនៃការធ្វើទុក្ខបុកម្នេញ អាចគ្របដណ្តប់លើបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[574] ឬបទល្មើសផ្សេងៗដែលមានចែងក្នុង

---

[573]Fausto Pocar, "ការធ្វើទុក្ខបុកម្នេញដែលជាបទល្មើសក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" *ព្រឹត្តិប័ត្រស្តីពីច្បាប់ និងគោលនយោបាយសន្តិសុខជាតិ,* វ៉ុល ២ ( ឆ្នាំ ២០០៨), ទំព័រ ៣៦០, ការដកស្រង់ចេញពីសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី* Blaškić, កថាខណ្ឌ ២២៧។

[574]*សូមមើលឧទា. រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Brđanin, សំណុំរឿងលេខ IT-99-36-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧, ("សាលដីកាក្នុង*រឿងក្តី Brđanin*"), កថាខណ្ឌ ២៩៦។ សាលដីកាក្នុង *រឿងក្តី* Kordić *និង* Čerkez, កថាខណ្ឌ ១០៦។ សាលដីកាក្នុង *រឿងក្តី* Blaškić, កថាខណ្ឌ ១៤៣។ សាលដីកាក្នុង *រឿងក្តី Kronjelac*, កថាខណ្ឌ ២១៩។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Perišić, សំណុំរឿងលេខ IT-04-81-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១, ("សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Perišić*"), កថាខណ្ឌ

---

១១៩។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* *Gotovina និងជនដទៃទៀត*, សំណុំរឿងលេខ IT-06-90-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១១, ("អង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Gotovina*"), កថាខណ្ឌ ១៨០៣។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Đorđević*, សំណុំរឿងលេខ IT-05-87/1-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១, ("សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Đorđević*"), កថាខណ្ឌ ១៧៥៧។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Popović*, សំណុំរឿងលេខ IT-05-88-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ ("សាលក្រមក្នុង*រឿងក្តី Popović*"), កថាខណ្ឌ ៩៦៦។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Lukić និង Lukić*, សំណុំរឿងលេខ IT-98-32/1-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៩, ("សាលក្រមក្នុង*រឿងក្តី Lukić និង Lukić* កថាខណ្ឌ ៩៩៣។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Milutinović និងជនដទៃទៀត*, សំណុំរឿងលេខ IT-05-87-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩, ("សាលក្រមក្នុង*រឿងក្តី Milutinović*"), កថាខណ្ឌ ១៧៨ ដល់ ១៧៩។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Martić*, សំណុំរឿងលេខ IT-95-11-T "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧, ("សាលក្រមក្នុង*រឿងក្តី Martić*"), កថាខណ្ឌ ១១៥។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Krajišnik*, សំណុំរឿងលេខ IT-00-39-T, "សាលក្រម", អង្គជំនុំជម្រះ សាលាដំបូង, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦, ("សាលក្រមក្នុង*រឿងក្តី Krajišnik*"), កថាខណ្ឌ ៧៣៥។ សាលក្រមក្នុង*រឿងក្តី Blagojević និង Jokić*, កថាខណ្ឌ ៥៨០។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Simić និងជនដទៃទៀត*, សំណុំរឿងលេខ IT-95-9-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣ ("សាលក្រមក្នុង*រឿងក្តី Simić*"), កថាខណ្ឌ ៤៨។ សាលក្រមក្នុង*រឿងក្តី Stakić*, កថាខណ្ឌ ៧៣៥។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Naletilić និង Martinović*, សំណុំរឿងលេខ IT-98-34-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣, ("សាលក្រមក្នុង*រឿងក្តី Naletilić និង Martinović*"), កថាខណ្ឌ ៦៣៥។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Vasiljević*, សំណុំរឿងលេខ IT-98-32-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ("សាលក្រមក្នុងរឿងក្តី *Vasiljević*"), កថាខណ្ឌ ២៤៦។ សាលក្រមក្នុង*រឿងក្តី Krnojelac*, កថាខណ្ឌ ៤៣៣។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kvočka និងជនដទៃទៀត*, សំណុំរឿងលេខ IT-98-30/1-T "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០១, ("សាលក្រមក្នុង*រឿងក្តី Kvočka*"), កថាខណ្ឌ ១៨៥ ដល់ ១៨៦។ សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៥៩៤, ៦០០, ៦០៤ ដល់ ៦០៥, ៦១៥, ៦១៧។ សាលក្រមក្នុង *រឿងក្តី Nyiramasuhuko*, កថាខណ្ឌ ៦០៩៨ ដល់ ៦០៩៩។ *ប៉ុន្តែ សូមមើល* សាលក្រមក្នុង*រឿងក្តី Tadić*, កថាខណ្ឌ ៧០២, (ដែលអង្គជំនុំជម្រះយល់ឃើញថា ក្រុមប្រឹក្សាសន្តិសុខមានចេតនាបកស្រាយលក្ខន្តិកៈរបស់តុលាការ ICTY តាមរបៀបដែលថា អំពើទាំងឡាយដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមផ្នែកផ្សេងទៀតនៃមាត្រា ៥ មិនត្រូវបានយកមកពិចារណាជាការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ)។ អង្គជំនុំជម្រះតុលាការកំពូល*ក្នុងរឿងក្តី Tadić* បានសម្រេចថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស ហើយយុត្តិសាស្ត្រក្រោយៗមកទៀតរបស់តុលាការ ICTY មិនបានអនុវត្តតាមសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Tadić* នោះទេ។ សាលដីកាក្នុង*រឿងក្តី Tadić*, កថាខណ្ឌ ២៨១, ៣០៥។

លក្ខន្តិកៈរបស់តុលាការទាំងនោះ[575] ឬអំពើដទៃទៀត ដែលមិនមានចែងនៅក្នុងលក្ខន្តិកៈទាំងនោះ[576]។ អង្គជំនុំជម្រះនៅក្នុងតុលាការទាំងនេះបានយល់ឃើញស្របគ្នាថា អំពើទាំងនេះចាំបាច់ត្រូវតែមានភាពធ្ងន់ធ្ងរ និងស្ថានទម្ងន់ស្មើគ្នាទៅនឹងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[577]។ អ្វីដែលតុលាការទាំងនេះបានយល់ខុសគ្នាបន្តិចបន្តួចនោះ

[575]សាលដីកាក្នុង*រឿងក្តី Brđanin*, កថាខណ្ឌ ២៩៦។ សាលដីកាក្នុង*រឿងក្តី Kronjelac*, កថាខណ្ឌ ២១៩។ សាលដីកាក្នុង*រឿងក្តី Perišić*, កថាខណ្ឌ ១១៩។ សាលដីកាក្នុង*រឿងក្តី Gotovina*, កថាខណ្ឌ ១៨០៣។ សាលដីកាក្នុង*រឿងក្តី Đorđević*, កថាខណ្ឌ ១៧៥៧។ សាលដីកាក្នុង*រឿងក្តី Popović*, កថាខណ្ឌ ៩៦៦។ សាលដីកាក្នុង*រឿងក្តី Lukić និង Lukić*, កថាខណ្ឌ ៩៩៣។ សាលដីកាក្នុង*រឿងក្តី Milutinović* , កថាខណ្ឌ ១៧៩។ សាលដីកាក្នុង*រឿងក្តី Martić*, កថាខណ្ឌ ១១៥។ សាលដីកាក្នុង*រឿងក្តី Krajišnik*, កថាខណ្ឌ ៧៣៥។ សាលដីកាក្នុង*រឿងក្តី Simić*, កថាខណ្ឌ ៤៨។ សាលដីកាក្នុង*រឿងក្តី Stakić*, កថាខណ្ឌ៧៣៥។ សាលដីកាក្នុង*រឿងក្តី Naletilić និង Martinović*, កថាខណ្ឌ ៦៣៥។ សាលដីកាក្នុង*រឿងក្តី Vasiljević*, កថាខណ្ឌ ២៤៦។ សាលដីកាក្នុង*រឿងក្តី Krnojelac*, កថាខណ្ឌ ៤៣៣។ សាលដីកាក្នុង*រឿងក្តី Kvočka*, កថាខណ្ឌ ១៨៥ ដល់ ១៨៦។ សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez* , កថាខណ្ឌ ១៩៨។ សាលដីកាក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៦១៧។ សាលដីកាក្នុង*រឿងក្តី Tadić* , កថាខណ្ឌ ៦៩៩ ដល់ ៧០០ និង ៧០២។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Serugendo*, សំណុំរឿងលេខ ICTR-2005-84-I, "សាលក្រម និងការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៦, ("សាលក្រមក្នុង*រឿងក្តី Serugendo*"), កថាខណ្ឌ ៤, ៩, ៣០, ៨៣។

[576]*សូមមើលឧទា.*សាលដីកាក្នុងរឿងក្តី *Brđanin*, កថាខណ្ឌ ២៩៦។ សាលដីកាក្នុង*រឿងក្តី Kvočka*, កថាខណ្ឌ ៣២១ ដល់ ៣២៣។ សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៥៨១, ៦១៤ ដល់ ៦១៥, ៦១៧។ សាលក្រមក្នុង*រឿងក្តី Tadić*, កថាខណ្ឌ ៧០៣ ដល់ ៧១០។ សាលក្រមក្នុង*រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១៩៣ ដល់ ១៩៤។ សាលក្រមក្នុង*រឿងក្តី Kronjelac*, កថាខណ្ឌ ៤៣៣។ សាលក្រមក្នុង*រឿងក្តី Vasiljević*, កថាខណ្ឌ ២៤៦។ សាលក្រមក្នុង*រឿងក្តី Naletilić* និង *Martinović*, កថាខណ្ឌ ៦៣៥។ សាលក្រមក្នុងរឿងក្តី *Stakić*, កថាខណ្ឌ ៧៣៥។ សាលក្រមក្នុងរឿងក្តី *Simić*, កថាខណ្ឌ ៤៨។ សាលក្រមក្នុង*រឿងក្តី Krajišnik*, កថាខណ្ឌ ៧៣៥។ សាលក្រមក្នុង*រឿងក្តី Martić*, កថាខណ្ឌ ១១៥។ សាលក្រមក្នុង*រឿងក្តី Milutinović*, កថាខណ្ឌ ១៧៩។ សាលក្រមក្នុង*រឿងក្តី Lukić* និង *Lukić*, កថាខណ្ឌ ៩៩៣។ សាលក្រមក្នុង*រឿងក្តី Popović*, កថាខណ្ឌ ៩៦៦។ សាលក្រមក្នុង*រឿងក្តី Đorđević*, កថាខណ្ឌ ១៧៥៧។ សាលក្រមក្នុង*រឿងក្តី Gotovina*, កថាខណ្ឌ ១៨០៣។ សាលក្រមក្នុង*រឿងក្តី Perišić*, កថាខណ្ឌ ១១៩។ សាលក្រមក្នុង*រឿងក្តី Bikindi*, កថាខណ្ឌ ៣៩២។

[577]*សូមមើលឧទា.* សាលដីកាក្នុង*រឿងក្តី Brđanin*, កថាខណ្ឌ ២៩៦។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Simić និងជនដទៃទៀត*, សំណុំរឿងលេខ IT-95-9-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ("សាលដីកាក្នុងរឿងក្តី *Simić*"), កថាខណ្ឌ ១៧៧។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Naletilić និង Martinović*, សំណុំរឿងលេខ IT-98-

គឺនៅត្រង់ចំណុច ថាតើអំពើប្រព្រឹត្តប្រភេទណាដែលឈានដល់កម្រិតស្ថានទម្ងន់ និងភាពធ្ងន់ធ្ងរចាំបាច់នោះ។ អង្គជំនុំជម្រះមួយចំនួនតូចនៃតុលាការ ICTY យល់ឃើញថា មានតែឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀតប៉ុណ្ណោះដែលស្ថិតនៅក្នុងប្រភេទនៃអំពើនេះ[578]។ ទន្ទឹមគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY នៅក្នុងរឿងក្តី *Stakić* បានសម្រេចថា អំពើដែលបណ្តាលឱ្យមានការរំលោភបំពានសិទ្ធិមនុស្ស*ណាមួយ* តាមសន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាចបង្កើតបានជាអំពើធ្វើទុក្ខបុកម្នេញ[579]។ ប៉ុន្តែ អង្គជំនុំជម្រះមួយផ្សេងទៀតនៃតុលាការ ICTY ពោលគឺ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Krnojelac* បានសម្រេចថា ពុំមានលក្ខខណ្ឌតម្រូវដាច់ដោយឡែកនៃការដកហូតសិទ្ធិសារវន្តរបស់មនុស្សដោយកំរោល ឬដោយឥតលាក់លៀមនោះទេ ប៉ុន្តែ អ្វីដែលសំខាន់នោះ គឺជាអំពើសកម្ម ឬអកម្មនៃការធ្វើទុកបុកម្នេញដែលឈានដល់កម្រិតស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរចាំបាច់ដូចគ្នានឹង

---

34-A, "សាលដីកា", អង្គជំនុំជម្រះតុលាកាកំពូល, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ ("សាលដីកាក្នុងរឿងក្តី *Naletilić និង Martinović*, កថាខណ្ឌ ៥៧៤។ សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១០២ និង១០៥។ សាលដីកាក្នុង*រឿងក្តី Blaškić*, កថាខណ្ឌ ១៣៥។ សាលដីកាក្នុង*រឿងក្តី Kvočka*, កថាខណ្ឌ ៣២១ ដល់ ៣២៥។ សាលដីកា*ក្នុងរឿងក្តី Krnojelac*, កថាខណ្ឌ ២២១។ សាលក្រមក្នុង*រឿងក្តី Perišić*, កថាខណ្ឌ ១១៩។ សាលក្រមក្នុង*រឿងក្តី Gotovina*, កថាខណ្ឌ ១៨០៣។ សាលក្រមក្នុង*រឿងក្តី Đorđević*, កថាខណ្ឌ ១៧៥៧។ សាលក្រមក្នុង*រឿងក្តី Popović*, កថាខណ្ឌ ៩៦៦។ សាលក្រមក្នុង*រឿងក្តី Lukić* និង *Lukić*, កថាខណ្ឌ ៩៩៣។ សាលក្រមក្នុង*រឿងក្តី Milutinović*, កថាខណ្ឌ ១៧៩ ដល់ ១៧៩។ សាលក្រមក្នុង*រឿងក្តី Martić*, កថាខណ្ឌ ១១៦។ សាលក្រមក្នុង*រឿងក្តី Krajišnik*, កថាខណ្ឌ ៧៣៥។ សាលក្រមក្នុង*រឿងក្តី Blagojević និង Jokić*, កថាខណ្ឌ ៥៨០។ សាលក្រមក្នុង*រឿងក្តី Simić*, កថាខណ្ឌ ៤៨។ សាលក្រមក្នុង*រឿងក្តី Stakić*, កថាខណ្ឌ ៧៣៦។ សាលក្រមក្នុង*រឿងក្តី Vasiljević*, កថាខណ្ឌ ២៤៧។ សាលក្រមក្នុង*រឿងក្តី Kronjelac*, កថាខណ្ឌ ៤៣៤។ សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៦១៩។ សាលដីកាក្នុង*រឿងក្តី Nahimana*, កថាខណ្ឌ ៩៨៧។ សាលក្រមក្នុង*រឿងក្តី Ruggiu*, កថាខណ្ឌ ២១។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Nahimana និងជនដទៃទៀត*, សំណុំរឿងលេខ ICTR-99-52-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៣ ("សាលក្រមក្នុង*រឿងក្តី Nahimana*"), កថាខណ្ឌ ១០៧២។ សាលក្រមក្នុង*រឿងក្តី Bikindi*, កថាខណ្ឌ ៣៩២ ដល់ ៣៩៤។ សាលក្រមក្នុង*រឿងក្តី Nyiramasuhuko*, កថាខណ្ឌ ៦០៩៦។

[578]សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១០៣។ សាលដីកាក្នុង*រឿងក្តី Blaškić*, កថាខណ្ឌ ២០០។ អង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Kordić*, កថាខណ្ឌ ១៩២ និង២០៩ ដល់ ២១០។

[579]សាលក្រមក្នុង*រឿងក្តី Stakić*, កថាខណ្ឌ ៧៧៣។

បទល្មើសផ្សេងទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[580]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងនេះ បានសន្និដ្ឋាននាពេលនោះថា មានតែ"ការដកហូតសិទ្ធិសារវន្ត របស់មនុស្សដោយកំរោល ឬដោយឥតលាក់លៀម"ប៉ុណ្ណោះ ទើបបំពេញបាននូវលក្ខណៈវិនិច្ឆ័យនៃស្ថានទម្ងន់[581]។

២៦១. ទោះបីជាមានការសម្រេចថា អំពើធ្វើទុក្ខបុកម្នេញ មិនចាំបាច់ជាបទល្មើសអន្តរជាតិ[582] ប៉ុន្តែជាធម្មតា គឺជាអំពើដែលបណ្តាលឱ្យមានការរំលោភបំពានលើសិទ្ធិសារវន្តរបស់មនុស្ស តាមសន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិដើម្បីឈានដល់កម្រិតចាំបាច់នៃស្ថានទម្ងន់ និងភាពធ្ងន់ធ្ងរក៏ដោយ[583] ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការពិភាក្សាក្នុងចំណោមអង្គ

---

[580]សាលក្រមក្នុង *រឿងក្តី Krnojelac*, កថាខណ្ឌ ៤៣៤, ជើងទំព័រ ១៣០៣។

[581]សាលក្រមក្នុង *រឿងក្តី Krnojelac*, កថាខណ្ឌ ៤៣៤។

[582]*សូមមើល ឧទា.* សាលដីកាក្នុង *រឿងក្តី Nahimana*, កថាខណ្ឌ ៩៨៥។ សាលដីកាក្នុង *រឿងក្តី Brđanin*, កថាខណ្ឌ ២៩៦។ សាលដីកាក្នុង *រឿងក្តី Kvočka*, កថាខណ្ឌ ៣២៣ និង៣២៥។ *សូមមើលផងដែរ* សាលដីកាក្នុង *រឿងក្តី Naletilić និង Martinović*, កថាខណ្ឌ ៥៧៤។

[583]សាលដីកាក្នុង *រឿងក្តី Simić*, កថាខណ្ឌ ១៧៧។ សាលដីកាក្នុង *រឿងក្តី Stakić*, កថាខណ្ឌ ៣២៧។ សាលដីកាក្នុង *រឿងក្តី Deronjić*, កថាខណ្ឌ ១០៩។ សាលដីកាក្នុង *រឿងក្តី Kvočka*, កថាខណ្ឌ ៣២០ ដល់ ៣២១។ សាលដីកាក្នុង *រឿងក្តី Vasiljević*, កថាខណ្ឌ ១១៣។ សាលដីកាក្នុង *រឿងក្តី Krnojelac* កថាខណ្ឌ ១៨៥ និង២២១។ សាលក្រមក្នុង *រឿងក្តី Perišić*, កថាខណ្ឌ ១១៨ ដល់ ១១៩។ សាលក្រមក្នុង *រឿងក្តី Gotovina*, កថាខណ្ឌ ១៨០២ ដល់ ១៨០៣។ សាលក្រមក្នុង *រឿងក្តី Đorđević*, កថាខណ្ឌ ១៧៥៥ និង១៧៥៧។ សាលក្រមក្នុង *រឿងក្តី Popović* កថាខណ្ឌ ៩៦៤ និង៩៦៦។ សាលក្រមក្នុង *រឿងក្តី Lukić និង Lukić*, កថាខណ្ឌ ៩៩២ ដល់ ៩៩៣។ សាលក្រមក្នុង *រឿងក្តី Milutinović*, កថាខណ្ឌ ១៧៥, ១៧៨ ដល់ ១៧៩។ សាលក្រមក្នុង *រឿងក្តី Bikindi*, កថាខណ្ឌ ៣៩១, ៣៩៣, ៤៣៥។ សាលក្រមក្នុង *រឿងក្តី Martić*, កថាខណ្ឌ ១១៣ និង១១៦។ សាលក្រមក្នុង *រឿងក្តី Krajišnik*, កថាខណ្ឌ ៧៣៤ ដល់ ៧៣៥។ សាលក្រមក្នុង *រឿងក្តី Blagojević និង Jokić*, កថាខណ្ឌ ៥៧៩ ដល់ ៥៨០។ សាលក្រមក្នុង *រឿងក្តី Brđanin*, កថាខណ្ឌ ៩៩២ និង៩៩៥។ សាលក្រមក្នុង *រឿងក្តី Simić*, កថាខណ្ឌ ៤៧ ដល់ ៤៨។ សាលក្រមក្នុង *រឿងក្តី Stakić*, កថាខណ្ឌ ៧៣២ ដល់ ៧៣៣ និង៧៣៦។ សាលក្រមក្នុងរឿងក្តី *Naletilić និង Martinović*, កថាខណ្ឌ ៦៣៤ ដល់ ៦៣៥។ សាលក្រមក្នុង *រឿងក្តី Vasiljević*, កថាខណ្ឌ ២៤៤ និង២៤៧។ សាលក្រមក្នុង *រឿងក្តី Krnojelac*, កថាខណ្ឌ ៤៣១ និង៤៣៣។ សាលក្រមក្នុង *រឿងក្តី Kvočka*, កថាខណ្ឌ ១៨៤ ដល់ ១៨៥។ សាលក្រមក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៦១៦ និង៦១៩ ដល់ ៦២១ និង៦២៧។ *សូមមើលផងដែរ* សាលដីកាក្នុង *រឿងក្តី Nahimana*, កថាខណ្ឌ ៩៨៥ និង ៩៨៧។ សាលក្រមក្នុង *រឿងក្តី*

ជំនុំជម្រះមួយចំនួនតូចនៃតុលាការ *មិនអចិន្ត្រៃយ៍* នៅមុនពេលសម្រេចលទ្ធផលនេះ មិនរំលោភលើគោលការណ៍នីត្យានុកូលភាពនៅក្នុងរឿងក្តីនេះទេ។ ដូចដែលបានកត់សម្គាល់ខាងលើ ត្រឹមឆ្នាំ ១៩៧៥ យុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II បានបង្ហាញយ៉ាងច្បាស់ថា ការធ្វើទុក្ខបុកម្នេញអាចគ្របដណ្តប់"អំពើផ្សេងទៀត" ដែលមិនមានចែងក្នុងធម្មនុញ្ញតុលាការទាំងនេះ បន្ថែមលើបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ដែលមានចែងនៅក្នុងធម្មនុញ្ញទាំងនេះ នៅពេលដែលយោងតាមលទ្ធិច្បាប់ស្តីពីប្រភេទដូចគ្នា *(ejusdem generis)* អំពើនេះបានឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរ និងស្ថានទម្ងន់នៃបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបណ្តាលឱ្យមានការរំលោភបំពានលើសិទ្ធិសារវន្តរបស់មនុស្ស។ លទ្ធិច្បាប់នេះដែលត្រូវបានយកមកប្រើប្រាស់ជាដំបូង ក្រោយសង្គ្រាមលោកលើកទី II គឺនៅក្នុងរឿងក្តី *Flick* បានរារាំងប្រភេទនៃអំពើធ្វើទុក្ខបុកម្នេញតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនឱ្យមានលក្ខណៈទូលំទូលាយ ឬស្រពិចស្រពិលពេក ហើយលទ្ធិច្បាប់នេះ បានកម្រិតដែនកំណត់ជាក់លាក់ទៅលើប្រភេទនៃអំពើនានាដែលអាចចាត់ជាអំពើធ្វើទុក្ខបុកម្នេញ។ ការពិភាក្សានៅតុលាការ *មិនអចិន្ត្រៃយ៍* គឺគ្រាន់តែផ្តោតទៅលើការបកស្រាយអំពីលក្ខណៈវិនិច្ឆ័យនៃភាពធ្ងន់ធ្ងរ និងស្ថានទម្ងន់ដែលមានភស្តុតាងបញ្ជាក់ច្បាស់លាស់ ដូចដែលអង្គជំនុំជម្រះនានានៅក្នុងតុលាការទាំងនេះ មានបំណងកម្រិតដែនកំណត់នៃប្រភេទអំពើធ្វើទុក្ខបុកម្នេញ ទៅតាមអង្គហេតុស្មុគស្មាញនៃរឿងក្តីជាក់លាក់មួយចំនួន។

២៦២. សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលទទួលយកចំណុចទីមួយនៃការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី*ធាតុផ្សំសត្យានុម័ត* នៃអំពើធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកតាមការស្រាយបំភ្លឺទាំងនេះ។ លើសពីនេះទៅទៀតអង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសនោះទេ នៅពេលដែលខ្លួនយល់ឃើញថា ផ្នែកនៃ*ធាតុផ្សំ*

---

*Nyiramasuhuko*, កថាខណ្ឌ ៦០៨៦។ សាលក្រមក្នុង*រឿងក្តី Bagosora*, កថាខណ្ឌ ២២០៨។ សាលក្រមក្នុង*រឿងក្តី Serugendo*, កថាខណ្ឌ ១០។ សាលក្រមក្នុង*រឿងក្តី Nahimana*, កថាខណ្ឌ ១០៧២។ សាលក្រមក្នុង*រឿងក្តី Ruggiu*, កថាខណ្ឌ ២១ ដល់ ២២។

*សត្យានុម័ត*នេះ បានបំពេញលក្ខខណ្ឌតាមអង្គហេតុនៃរឿងក្តីនេះ ដោយហេតុថា អំពើជាមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវនោះ គឺជាបទល្មើសដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[584] ហេតុដូច្នេះ អំពើនេះពិតជាអំពើដែលមានស្ថានទម្ងន់យ៉ាងខ្លាំង ដែលបណ្តាលឱ្យមានការរំលោភបំពានលើសិទ្ធិសារវន្ត[585]។

### ៤.៦.២.ខ.២.អំពើសកម្ម ឬអកម្មដែលមានការរើសអើងជាក់ស្តែង

២៦៣. នៅពេលពិនិត្យពិចារណាចំណុចទីពីរ នៃការកំណត់និយមន័យធាតុផ្សំ*សត្យានុម័ត* ដោយអង្គជំនុំជម្រះសាលាដំបូងដែលថា អំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញត្រូវតែ“មានការរើសអើងជាក់ស្តែង” ទើបនាំឱ្យមានផលវិបាកដែលមានលក្ខណៈរើសអើងជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សំអាងហេតុនៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II ដូចដែលបានលើកឡើងក្នុងផ្នែកខាងលើ បានគាំទ្រលក្ខខណ្ឌតម្រូវបែបនេះ។ អង្គជំនុំជម្រះតុលាការកំពូល មិនអាចរកឃើញរឿងក្តីណាមួយនៅចំពោះមុខតុលាការយោធាអន្តរជាតិ (IMT) ឬតុលាការយោធា Nuremberg (NMT) ដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើអត្ថិភាពនៃចេតនាជាក់លាក់ដោយមូលហេតុនៃការរើសអើងតែឯងនោះទេ។ តុលាការទាំងនេះតែងតែចង្អុលបង្ហាញនូវអំពើរបស់ជនជាប់ចោទដែលមានគោលបំណងយ៉ាងច្បាស់លាស់ទៅលើបុគ្គលនានា ដែលជាសមាជិកនៃក្រុមគោលដៅថា ជាការរើសអើងដោយចេតនា។ ដូចដែលអ្នកអត្ថាធិប្បាយមួយរូបបានធ្វើការកត់សម្គាល់ដោយដកស្រង់ ជាឧទាហរណ៍ នូវរឿងក្តីពាក់ព័ន្ធនឹង*ក្រសួងផ្សេងៗ* (*Ministries Case*) របស់តុលាការយោធា Nuremberg (NMT) ថា ការធ្វើទុក្ខបុក

[584] អំពើមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវ រួមមាន អំពើធ្វើមនុស្សឃាត អំពើសម្លាប់រង្គាល អំពើធ្វើឲ្យទៅជាទាសករ អំពើដាក់ក្នុងមន្ទីរឃុំឃាំង អំពើធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

[585] *សូមមើល* សាលក្រម អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ២៨០, ៣៨១, ៦៧៧។

ម្នេញត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាពី *អំពើរើសអើង* ឬ“*ការធ្វើបាបដល់ជនជាតិជ្វីហ្វ និងក្រុមផ្សេងទៀត* ដែលពួកណាហ្ស៊ី (Nazis) បានកំណត់គោលដៅជាពិសេស”[586]។

២៦៤. ផ្អែកតាមយុត្តិសាស្ត្រខាងលើនេះ លក្ខខណ្ឌតម្រូវនៃការរើសអើងជាក់ស្តែង ត្រូវបានអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY លើកឡើងក្នុងរឿងក្តីដំបូង គឺរឿងក្តី *Tadić*[587] ហើយដែលកិច្ចការនេះ ត្រូវបានកត់សម្គាល់ ឬអនុវត្តយ៉ាងជាក់ច្បាស់នៅក្នុងរឿងក្តីក្រោយៗមកទៀត[588] រហូតដល់ពេលដែលអង្គជំនុំជម្រះសាលាដំបូងនៃរឿងក្តី *Kvočka* បានសម្រេចផ្សេងដោយធ្វើការបដិសេធនូវទស្សនៈស្តីពីធាតុផ្សំ *សត្យានុម័ត*នេះ ដែលផ្ទុយគ្នាទៅនឹងយុត្តិសាស្ត្រដែលបានបញ្ជាក់ខាងលើ[589]។ ការសម្រេចនៅក្នុងរឿងក្តី *Kvočka* នេះត្រូវបានធ្វើឡើងដោយផ្អែកលើភាពជាក់ស្តែងដែលថា លក្ខន្តិកៈរបស់តុលាការ ICTY មិនបានចែងច្បាស់លាស់ ថាតើអំពើដែលបានប្រព្រឹត្តដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាត្រូវតែកើតមានយ៉ាងពិតប្រាកដ នូវការរើសអើងប្រឆាំងនឹងក្រុមជន ដែលត្រូវបានកំណត់គោលដៅ ដែរ ឬយ៉ាងណា។ ផ្អែកតាមលក្ខន្តិកៈរបស់តុលាការ ICTY អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុថា “មូលហេតុនៃការរើសអើង គឺជាទម្រង់ចាំបាច់នៃធាតុផ្សំបទល្មើស ដោយមិនគិតពីភាពជាសមាជិកនៃក្រុមជាក់លាក់នោះទេ” ដែលនេះបញ្ជាក់ពីអត្ថន័យថា “មូលហេតុនៃការរើសអើង” គឺអនុវត្តតែចំពោះធាតុផ្សំ *អត្តនោម័ត*ប៉ុណ្ណោះ ដោយមិនចាំបាច់អនុវត្តចំពោះធាតុផ្សំ *សត្យានុម័ត* នោះទេ[590]។

---

[586] *សូមមើល*ព្រឹត្តប័ត្ររបស់ Ken Roberts, ដែលមានចំណងជើងថា “កិច្ចខិតខំប្រឹងប្រែងក្នុងការកំណត់និយមន័យស្តីពី៖ ច្បាប់ស្តីពីអំពើធ្វើទុក្ខបុកម្នេញ តាំងពីប្រភពដើមដល់តុលាការ ICTY”, ទំព័រ២៦៤, ២៦៦ (សេចក្តីបញ្ជាក់បន្ថែម)។

[587] សាលក្រមក្នុង *រឿងក្តី Tadić*, កថាខណ្ឌ ៧១៥។

[588] *សូមមើលរឿងក្តី រដ្ឋអាជ្ញា ទល់នឹង* *Krstić*, សំណុំរឿងលេខ IT-98-33-T, “សាលក្រម”, អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១, (“សាលក្រមក្នុង*រឿងក្តី Krstić*”), កថាខណ្ឌ ៥៣៤ ដល់ ៥៣៥។ សាលក្រមក្នុង*រឿងក្តី Kordić*, កថាខណ្ឌ ១៩៥។ សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៥៧២ និង៦២១។

[589] សាលក្រមក្នុង *រឿងក្តី Kvočka*, កថាខណ្ឌ ១៩៥។

[590] សាលក្រមក្នុង *រឿងក្តី Kvočka*, កថាខណ្ឌ ១៩៧។

២៦៥. ក្នុងរឿងក្តី *Krnojelac* អង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបនៅក្នុងសំអាងហេតុថា វិធីសាស្ត្រនៃការបកស្រាយច្បាប់បែបនេះ អាចនាំឱ្យបុគ្គលនានាត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញ នៅពេលដែលគ្មានបុគ្គលណាម្នាក់បានប្រព្រឹត្តបទធ្វើទុក្ខបុកម្នេញដោយពិតប្រាកដនោះទេ ហើយថា "ចេតនារើសអើងដែលពាក់ព័ន្ធ ត្រូវបានសន្មតថាមាន ដរាបណាជនរងគ្រោះ គឺជាសមាជិកនៃក្រុមនយោបាយ ពូជសាសន៍ ឬសាសនា"[591]។ ជាការពិត ចេតនារើសអើងជាញឹកញាប់ ត្រូវបានបង្ហាញឱ្យឃើញមួយផ្នែកដោយមូលហេតុជនរងគ្រោះស្ថិតនៅក្នុងក្រុមជាក់លាក់ណាមួយ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានលើកសំអាងហេតុថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kvočka* ដែលតម្រូវឱ្យមានតែចេតនារើសអើង ដោយមិនចាំបាច់តម្រូវឱ្យមានអំពើរើសអើងនោះ គឺនាំឱ្យមានភាពស្រពិចស្រពិលក្នុងការញែកឱ្យបានច្បាស់លាស់រវាងអំពើធ្វើទុក្ខបុកម្នេញ និងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងពីដំបូងនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ (IMT)។ បន្ថែមពីលើនេះ វិធីសាស្ត្រនេះមិនស្របទៅនឹងកម្មវត្ថុ និងគោលបំណងនៃច្បាប់ប្រឆាំងនឹងការធ្វើទុក្ខបុកម្នេញ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលការពារជាពិសេសចំពោះ"សមាជិកនៃក្រុមនយោបាយ ពូជសាសន៍ និងសាសនា ឱ្យរួចផុតពីការរើសអើងដោយមូលហេតុស្ថិតនៅក្នុងក្រុមណាមួយនៃក្រុមទាំងនេះ"[592]។

២៦៦. បន្ទាប់ពីការបដិសេធវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kvočka* ដោយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Krnojelac* អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Krnojelac* បានគាំទ្រលក្ខខណ្ឌតម្រូវថា ធាតុផ្សំ*សត្យានុម័ត* អំពើធ្វើទុក្ខបុក

---

[591] សាលក្រមក្នុង*រឿងក្តី* *Krnojelac*, កថាខណ្ឌ ៤៣២ និងជើងទំព័រ ១២៩៤។ *សូមមើលផងដែរ* អង្គជំនុំជម្រះសាលាដំបូង *Blaškić*, កថាខណ្ឌ ២៣៥។

[592] សាលក្រមក្នុងរឿងក្តី *Krnojelac*, កថាខណ្ឌ ៤៣២ ជើងទំព័រ ១២៩៤។ *សូមមើលផងដែរ* សាលក្រមក្នុង*រឿងក្តី* *Blaškić*, កថាខណ្ឌ ២៣៥ (លើកឡើងថា "ចារីដែលប្រព្រឹត្តការធ្វើទុក្ខបុកម្នេញ ជាដំបូង មិនបានកំណត់គោលដៅលើបុគ្គលទេ ប៉ុន្តែគ្រាន់តែកំណត់គោលដៅលើសមាជិកនៅក្នុងក្រុមពូជសាសន៍ សាសនា ឬនយោបាយមួយចំនួន")។

ម្នេញ តម្រូវឱ្យមានការរើសអើងជាក់ស្តែង[593] ហើយបន្ទាប់មក យុត្តិសាស្ត្រតុលាការ ICTY និងតុលាការ ICTR បានអនុវត្តតាមសេចក្តីសម្រេចបែបនេះរហូតមក[594]។

២៦៧. ដោយផ្អែកលើការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ត្រឹមឆ្នាំ ១៩៧៥ "ការរើសអើងជាក់ស្តែង" ឬការបង្ហាញជាចាំបាច់ពីលទ្ធផលដែលជាការរើសអើងពិតប្រាកដនោះ គឺពិតជាផ្នែកចាំបាច់នៃធាតុផ្សំ*សត្យានុម័ត*នៃអំពើធ្វើទុក្ខបុកម្នេញ ដូចដែលបានគូសបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូង។ មិនត្រឹមតែសំអាងហេតុនៅក្នុងការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញ ដោយយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II ប៉ុណ្ណោះទេ ថែមទាំងយុត្តិសាស្ត្ររបស់តុលាការ*មិនអចិន្ត្រៃយ៍*នានា ដែលកើតក្រោយយុត្តាធិការពេលវេលារបស់ អ.វ.ត.ក សុទ្ធតែគាំទ្រការយល់ឃើញដូចខាងលើនេះដែរ។ ទោះបីជាមានអង្គជំនុំជម្រះសាលាដំបូងចំនួន ០១ របស់តុលាការ ICTY បានអនុវត្តខុសពីលក្ខខណ្ឌតម្រូវបែបនេះក្តី ក៏សេចក្តីសម្រេចនោះត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលក្នុងនាមជាតុលាការវិនិច្ឆ័យលើអង្គច្បាប់ចុងក្រោយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ករណីខ្វែងគំនិតគ្នានេះមិនក្លាយជាបញ្ហាសម្រាប់ការសម្រេចរបស់ខ្លួនដោយផ្អែកតាមគោលការណ៍នីត្យានុកូលភាពនោះទេ។

---

[593]សាលដីកាក្នុង*រឿងក្តី Krnojelac*, កថាខណ្ឌ ១៨៥។

[594]*សូមមើល ឧទា.* សាលដីកាក្នុង*រឿងក្តី Simić*, កថាខណ្ឌ ១៧៧។ សាលដីកាក្នុង*រឿងក្តី Stakić*, កថាខណ្ឌ ៣២៧។ សាលដីកាក្នុង*រឿងក្តី Deronjić*, កថាខណ្ឌ ១០៩។ សាលដីកាក្នុង*រឿងក្តី Kvočka*, កថាខណ្ឌ ៣២០។ សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១០១ ដល់ ១០២។ សាលដីកាក្នុង*រឿងក្តី Blaškić*, កថាខណ្ឌ ១៣១ និង ១៣៥។ សាលដីកាក្នុង*រឿងក្តី Vasiljević*, កថាខណ្ឌ ១១៣។ សាលក្រមក្នុង*រឿងក្តី Perišić*, កថាខណ្ឌ ១១៨។ សាលក្រមក្នុង*រឿងក្តី Gotovina*, កថាខណ្ឌ ១៨០២។ សាលក្រមក្នុង*រឿងក្តី Đorđević*, កថាខណ្ឌ ១៧៥៥ និង ១៧៥៨។ សាលក្រមក្នុង*រឿងក្តី Popović*, កថាខណ្ឌ ៩៦៤។ សាលក្រមលើ*រឿងក្តី Lukić និង Lukić*, កថាខណ្ឌ ៩៩២ ដល់ ៩៩៣។ សាលក្រមក្នុង*រឿងក្តី Milutinović*, កថាខណ្ឌ ១៧៥ និង១៧៧។ សាលក្រមក្នុង*រឿងក្តី Martić*, កថាខណ្ឌ ១១៣ និង ១១៧។ សាលក្រមក្នុង*រឿងក្តី Krajišnik*, កថាខណ្ឌ ៧៣៤។ សាលក្រមក្នុង*រឿងក្តី Blagojević និង Jokić*, កថាខណ្ឌ ៥៧៩។ សាលក្រមក្នុង*រឿងក្តី Naletilić និង Martinović*, កថាខណ្ឌ ៦៣៦។ សាលដីកាក្នុង*រឿងក្តី Nahimana*, កថាខណ្ឌ ៩៨៥។ សាលក្រមក្នុង*រឿងក្តី Bikindi* កថាខណ្ឌ ៣៩១ និង៤៣៥។ សាលក្រមក្នុង*រឿងក្តី Bagosora*, កថាខណ្ឌ ២២០៨។ សាលក្រមក្នុង*រឿងក្តី Nyiramasuhuko*, កថាខណ្ឌ ៦០៩៦។

២៦៨. បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សេចក្តីសន្និដ្ឋានខាងលើ បាន ស្របគ្នាជាមួយ នឹងការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងអនុសញ្ញាស្តីពី អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ ដែលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នេះស្ថិតក្នុង*ប្រភេទ* ដូចគ្នាជាមួយនឹងអំពើធ្វើទុក្ខបុកម្នេញត្រង់ចំណុចដែលថា ចារីនៃអំពើប្រល័យពូជសាសន៍មាន គោលដៅចំពោះជនរងគ្រោះ ដោយផ្អែកលើមូលដ្ឋានជាសមាជិកនៃក្រុមណាមួយ[595]។ យោង តាមការកំណត់និយមន័យបែបនេះ ធាតុផ្សំ*សត្យានុម័ត*នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវតែ មានកំណត់គោលដៅ*ជាក់ស្តែង*លើសមាជិកមួយ ឬច្រើននៃក្រុមមួយ[596]។ “ទោះបីជាមាន ភាពច្បាស់លាស់ថា ចេតនាសំខាន់ក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មានលក្ខណៈធ្ងន់ធ្ងរជាង ចេតនាសំខាន់ក្នុងការធ្វើទុក្ខបុកម្នេញ (ដោយមានចេតនាជាក់លាក់ក្នុងការបំផ្លាញក្រុមមួយ)

---

[595]សាលក្រមក្នុង*រឿងក្តី* *Kupreškić*, កថាខណ្ឌ ៦៣៦ (ចែងថា “ទាំងការធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មប្រល័យពូជ សាសន៍ គឺជាបទល្មើសដែលប្រព្រឹត្តឡើងប្រឆាំងនឹងបុគ្គលដែលស្ថិតនៅក្នុងក្រុមពិសេសមួយ ឬបុគ្គលដែលត្រូវបានគេ កំណត់គោលដៅដោយសារតែស្ថិតនៅក្នុងក្រុមនោះ”។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Jelišić*, សំណុំរឿងលេខ IT-95-10-T, “សាលក្រម”, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ (“អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Jelišić*”), កថាខណ្ឌ ៦៨ (សម្រេចថា “ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយនឹងបទល្មើសនៃការធ្វើ ទុក្ខបុកម្នេញ” ពីព្រោះចារី “បានរើសជនរងគ្រោះរបស់ខ្លួន ដោយសារតែពួកគាត់ស្ថិតនៅក្នុងក្រុមមនុស្សពិសេសមួយ”)។

[596]*សូមមើល* មាត្រា ២ នៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ ដែលចែងថា៖

> ក. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មានន័យថា ជាអំពើណាមួយក្នុងចំណោមអំពើទាំងប៉ុន្មានខាងក្រោម នេះ ដែលប្រព្រឹត្តក្នុងបំណងបំផ្លិចបំផ្លាញទាំងស្រុងក្តី ឬដោយផ្នែកក្តី ដល់ប្រជាជាតិមួយ ក្រុមជាតិពន្ធុ មួយ ពូជសាសន៍មួយ ឬក្រុមសាសនាមួយ៖
>
> (ក) ការសម្លាប់សមាជិកក្រុម។
>
> (ខ) ការបង្កការឈឺចាប់ និងការខូចខាតធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញានៃសមាជិក របស់ក្រុម។
>
> (គ) ការបង្ខមហន្តរាយដោយចេតនាដល់ជីវភាពរស់នៅរបស់សង្គមមនុស្ស តាមរយៈការ កម្ទេច ការបំផ្លិចបំផ្លាញក្រុមទាំងមូល ឬមួយផ្នែកនៃសង្គម។
>
> (ឃ) ការបង្ខំឲ្យអនុវត្តវិធានការនានា ដែលរារាំងការផ្តល់កំណើតទារកនៅក្នុងក្រុម។
>
> (ង) ការជម្លៀសកុមារដោយបង្ខំពីក្រុមមួយ ទៅដាក់នៅក្នុងក្រុមមួយទៀត។

ក៏ដោយ ក៏មិនមែនមានន័យថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តម្រូវឱ្យមានលទ្ធផលមួយស្រប ទៅនឹង "ចេតនារើសអើង"តែការធ្វើទុក្ខបុកម្នេញបែរជាមិនតម្រូវឱ្យមាននោះទេ"[597]។

២៦៩. ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា យុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* ខ្វះនូវភាពស្របគ្នាផ្ទៃក្នុងមួយចំនួនទាក់ទងនឹង*ការបកស្រាយ* និងការអនុវត្តនូវលក្ខខណ្ឌតម្រូវនៃ "ការរើសអើងជាក់ស្តែង" ដែលផ្ទុយទៅនឹងអ្វីដែលមានចែងក្នុងច្បាប់។ ការពិភាក្សាមួយចំនួនផ្តោតជុំវិញបញ្ហា ថាតើអាចមានការរើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា នៅពេលចារីមានការភាន់ច្រឡំជាសត្យានុម័ត លើសមាជិកភាពរបស់ជនរងគ្រោះនៅក្នុងក្រុមគោលដៅ[598]។

២៧០. ជាថ្មីម្តងទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការពិភាក្សាដេញដោលនេះមិនចោទជាបញ្ហាលើការបញ្ជាក់ពីលក្ខខណ្ឌតម្រូវនៃ "ការរើសអើងជាក់ស្តែង" នៅក្នុងធាតុផ្សំ *សត្យានុម័ត*នៃការធ្វើទុក្ខបុកម្នេញត្រឹមឆ្នាំ ១៩៧៥ តាមគោលការណ៍នីត្យានុកូលភាពឡើយ។ ការមិនស្របគ្នានៅក្នុងយុត្តិសាស្ត្ររបស់តុលាការ*មិនអចិន្ត្រៃយ៍* ខាងលើ មិនបានជំទាស់ទៅ

---

[597]ព្រឹត្តប័ត្រនិពន្ធដោយ Ken Roberts, ដែលមានចំណងជើងថា "កិច្ចខិតខំប្រឹងប្រែងក្នុងការកំណត់និយមន័យស្តីពីច្បាប់ស្តីពីការធ្វើទុក្ខបុកម្នេញ ចាប់តាំងពីប្រភពដើមដល់តុលាការ", ទំព័រ ២៧៥។

[598]*សូមមើលឧទា.* សាលក្រមក្នុង*រឿងក្តី* *Krnojelac*, កថាខណ្ឌ ៤៣២, ជើងទំព័រ ១២៨៣ (បានលើកឡើងថា ប្រសិនបើចារីកំណត់អត្តសញ្ញាណជនរងគ្រោះដោយភ័ន្តច្រឡំថា ជាផ្នែកនៃក្រុមកំណត់គោលដៅ "ការលើកទឡ្ហីករណ៍ថា ការកំណត់អត្តសញ្ញាណខុសនេះ គឺជាការធ្វើទុក្ខបុកម្នេញ ប្រសិនបើប្រព្រឹត្តឡើយដោយចេតនារើសអើង ពុំចាំបាច់ពង្រីកដល់ការការពារដល់បុគ្គលចំពោះឧក្រិដ្ឋកម្មនោះ ដែលបុគ្គលនោះមិនមែនជាសមាជិកម្នាក់នៃក្រុមដែលមានក្នុងបញ្ជី ដែលតម្រូវឲ្យមានការការពារនៅក្នុងករណីនោះទេ")។ *ប៉ុន្តែសូមមើល*សាលដីកាក្នុងរឿងក្តី *Krnojelac*, កថាខណ្ឌ ១៨៥។ សាលក្រមក្នុង*រឿងក្តី* *Milutinović*, កថាខណ្ឌ ១៧៧។ សាលក្រមក្នុង*រឿងក្តី* *Martić*, កថាខណ្ឌ ១១៧ ដល់ ១១៨។ សាលក្រមក្នុង*រឿងក្តី* *Blagojević និង Jokić*, កថាខណ្ឌ ៥៧៩ និង៥៨៣។ សាលក្រមក្នុង*រឿងក្តី* *Brđanin*, កថាខណ្ឌ ៩៩៣។ សាលក្រមក្នុង*រឿងក្តី* *Stakić*, កថាខណ្ឌ ៧៣៣ ដល់ ៧៣៤។ សាលក្រមក្នុង*រឿងក្តី* *Simić*, កថាខណ្ឌ ៤៩។ សាលក្រមក្នុង*រឿងក្តី* *Naletilić និង Martinović*, កថាខណ្ឌ ៦៣៦, ជើងទំព័រ ១៥៧២ (កត់សម្គាល់ថា ចារីបានកំណត់ក្រុមគោលដៅ ហើយ"ប្រសិនបើបុគ្គលណាមួយត្រូវបានចារីកំណត់ថាជាក្រុមគោលដៅ ដូចនេះនិយមន័យនេះ ក្លាយជា "ការរើសអើងជាក់ស្តែង" ចំពោះជនរងគ្រោះ ដោយសារតែមិនអាចជំទាស់បាន ទោះបីជាការចាត់ចំណាត់បែបនោះ អាចនឹងមិនត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យសត្យានុម័ត")។ សាលក្រមក្នុង*រឿងក្តី* *Kvočka*, កថាខណ្ឌ ១៩៥។

នឹងការលើកឡើងដែលថា ការរើសអើងជាក់ស្តែង គឺជាលក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់នោះទេ។ ប៉ុន្តែ មានបញ្ហាចោទឡើង ថាតើកាលៈទេសៈអ្វីខ្លះដែលពិតជាបង្កើតបានជាការរើសអើងជាក់ស្តែងនោះ។ ហេតុដូចនេះ ការពិភាក្សានេះមានជាប់ពាក់ព័ន្ធទៅនឹងការស្រាយបំភ្លឺខ្លឹមសារ និងដែនកំណត់នៃលក្ខខណ្ឌតម្រូវខាងលើនេះ នៅពេលយកលក្ខខណ្ឌតម្រូវនេះមកអនុវត្តចំពោះកាលៈទេសៈនៃអង្គហេតុនៅក្នុងរឿងក្តីជាក់លាក់ណាមួយនោះ។

២៧១. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសឡើយ នៅពេលដែលខ្លួនបានអនុវត្តទៅតាម លក្ខខណ្ឌតម្រូវនៃការរើសអើងជាក់ស្តែងដោយផ្អែកតាមធាតុផ្សំ*សត្យានុម័ត*នៃការធ្វើទុក្ខបុកម្នេញ។

២៧២. លើសពីនេះទៀត ទាក់ទងទៅនឹងការបកស្រាយអំពីលក្ខខណ្ឌតម្រូវនៃការរើសអើងជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងដែលថា អំពើសកម្ម ឬអកម្ម គឺជាការរើសអើងជាក់ស្តែង នៅពេលដែល “ជនរងគ្រោះត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែជនរងគ្រោះជាសមាជិកនៅក្នុងក្រុមណាមួយ *ដែលចារីបានកំណត់* ដោយមូលហេតុជាក់លាក់មួយចំនួន ពោលគឺ មូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា”[599]។ ជាពិសេសទាក់ទងទៅនឹងមូលហេតុនយោបាយ ចារីអាចកំណត់ក្រុមគោលដៅជនរងគ្រោះ ដោយផ្អែកលើការវាយតម្លៃជាអត្តនោម័តចំពោះក្រុមណាខ្លះ ដែលបង្កការគម្រាមកំហែង ឬគ្រោះថ្នាក់ដល់នយោបាយ។ ក្រុមដែលទទួលរងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អាចរួមបញ្ចូលក្រុមមនុស្សផ្សេងៗ ដូចជាអ្នករាជការ ឬសកម្មជននយោបាយ ក្រុមជនដែលមានទស្សនៈ និន្នាការ និងជំនឿណាមួយ ឬក្រុមជនដែលជាជនជាតិភាគតិចណាមួយ ឬក្រុមជននៃសញ្ជាតិណាមួយ ឬក្រុមជនដែលតំណាងឱ្យវណ្ណៈណាមួយនៅក្នុងសង្គម (ឧទាហរណ៍ “បញ្ញាវន្ត” បុព្វជិត ឬវណ្ណៈគហបតី)។ លើសពីនេះទៀត ក្រុមគោលដៅមូលហេតុនយោបាយ អាចត្រូវបានចារីកំណត់យ៉ាងទូលំទូលាយ ដូច្នេះ ក្រុមនេះអាចត្រូវបានកំណត់ក្នុងន័យអវិជ្ជមាន និងរួមបញ្ចូលអ្នកជាប់ពាក់ព័ន្ធជិតស្និទ្ធ ឬអ្នកគាំទ្រ ព្រមទាំង

[599] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៧ (សេចក្តីបញ្ជាក់បន្ថែម)។

ជនដែលសង្ស័យផងដែរ[600]។ តាមការជាក់ស្តែង អំពើប្រព្រឹត្តលើជនដែលសង្ស័យ អ្នកគាំទ្រ និងអ្នកជាប់ពាក់ព័ន្ធ បង្កើតបានជាការរើសអើង ដោយហេតុថា ពួកគេទទួលរងនូវផលប៉ះពាល់អំពីគោលដៅជាបឋមនៃការរើសអើង បន្ថែមទៅលើការគាបសង្កត់ និងការដាក់ឱ្យនៅដាច់ដោយឡែកពីគេទាំងស្រុង។ ដូច្នេះ អំពើសកម្ម ឬអកម្មរបស់ចារីដែលបានប្រព្រឹត្តទៅលើក្រុមគោលដៅដូចជា ជនដែលសង្ស័យ អ្នកគាំទ្រ និងអ្នកជាប់ពាក់ព័ន្ធ នៅតែជាអំពើសកម្ម ឬអកម្មដែលបានប្រព្រឹត្ត ទៅលើក្រុមគោលដៅទាំងមូល។

២៧៣. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសក្នុងការយល់ឃើញថា តាមលក្ខខណ្ឌតម្រូវនៃការរើសអើងជាក់ស្តែង ក្រុមគោលដៅដោយមូលហេតុនយោបាយក្នុងរឿងក្តីនេះ រួមបញ្ចូល"*ទាំងអ្នកប្រឆាំងនឹងនយោបាយ (បក្សកុម្មុយនីស្តកម្ពុជា) ពិតប្រាកដ និងតាមការសន្មត ដោយរួមទាំងសាច់ញាតិជិតស្និទ្ធ ឬអ្នកជាប់ពាក់ព័ន្ធផ្សេងៗទៀត*" ដូចដែលបានកំណត់ដោយមជ្ឈិមបក្ស[601]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ផ្អែកតាមអង្គហេតុនៃរឿងក្តីនេះ ការរៀបរាប់ដែលត្រឹមត្រូវច្បាស់លាស់ជាងនេះ គឺ"រាល់ខ្មាំងនយោបាយរបស់បក្ស ដែលត្រូវបានកំណត់អត្តសញ្ញាណដោយមជ្ឈិមបក្ស"[602] ដោយរួមទាំងសាច់ញាតិជិតស្និទ្ធ ឬអ្នកជាប់ពាក់ព័ន្ធផ្សេងៗទៀត។ មានន័យថា ពាក្យពេចន៍នេះសង្កត់ធ្ងន់ថា បក្សកុម្មុយនីស្តកម្ពុជាមិនបានផ្តោតលើសកម្មភាពនយោបាយជាក់ស្តែង ឬនិន្នាការនយោបាយរបស់ក្រុមគោលដៅនោះទេ

---

[600]សាលក្រមក្នុង*រឿងក្តី Simić*, កថាខណ្ឌ ៤៩, ជើងទំព័រ ៨៩។ សាលក្រមក្នុង*រឿងក្តី Stakić*, កថាខណ្ឌ ៧៣៣ ដល់ ៧៣៤។ សាលក្រមក្នុង*រឿងក្តី Naletilić និង Martinović*, កថាខណ្ឌ ៦៣៦។ សាលក្រមក្នុង*រឿងក្តី Krnojelac*, កថាខណ្ឌ ៥០។ សាលក្រមក្នុង*រឿងក្តី Kvočka*, កថាខណ្ឌ ១៩៥, ត្រូវបានបញ្ជាក់អះអាងនៅក្នុងសាលដីកាក្នុង*រឿងក្តី Kvočka*, កថាខណ្ឌ ៣៦៣។ *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល VI, ទំព័រ ៨១, ជើងទំព័រ ១។

[601]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៨០ (សេចក្តីបញ្ជាក់បន្ថែម)។

[602]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៨២ ដល់ ៣៨៨។

ប៉ុន្តែ បានផ្តោតលើការកំណត់ដោយខ្លួនឯងនូវក្រុមមនុស្សមួយចំនួនដែលបក្សចាត់ទុកថា អាចបង្កឱ្យមានការគម្រាមកំហែងដល់នយោបាយ[603]។

២៧៤. បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា លក្ខខណ្ឌតម្រូវនៃការរើសអើងជាក់ស្តែង គឺមានទំនាក់ទំនងជាមួយលក្ខខណ្ឌតម្រូវដែលថា ជនរងគ្រោះ *ជាការពិតត្រូវតែស្តែងឱ្យឃើញច្បាស់លាស់*គ្រប់គ្រាន់ថា ស្ថិតក្នុងក្រុម នយោបាយ ពូជសាសន៍ ឬសាសនាណាមួយ។ លក្ខខណ្ឌតម្រូវនេះ បានបង្ហាញយ៉ាងច្បាស់នៅក្នុងលទ្ធិច្បាប់[604] និងយុត្តិសាស្ត្ររបស់តុលាការដែលទទួលយកទ្រឹស្តីនៃ"ការរើសអើងជាក់ស្តែង"។ លក្ខខណ្ឌតម្រូវនេះ ក៏ត្រូវបានបញ្ចូលយ៉ាងជាក់ច្បាស់ទៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") ដែលកំណត់និយមន័យអំពើធ្វើទុក្ខបុកម្នេញថា ជាអំពើដែលត្រូវប្រព្រឹត្តឡើងចំពោះជនណាមួយនៅក្នុង"ក្រុមដែលមានអត្តសញ្ញាណច្បាស់លាស់ ឬសហគមន៍ប្រមូលផ្តុំ"ណាមួយ[605]។

---

[603]ក្រុមដែលត្រូវបានកំណត់ រួមមានប្រភេទនៃបុគ្គលដូចខាងក្រោម៖ មន្ត្រី និងយោធានៃរបបមុន បញ្ញវន្ត សិស្ស បុគ្គលិកការទូត ជនជាតិបរទេស ជាពិសេស ជនជាតិវៀតណាម ព្រះសង្ឃ សាសនា និងក្រុមជនភាគតិចផ្សេងទៀតដែលមានសាសនា និងអ្នកមកពីទីក្រុង។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៨៣, ៣៨៦ ដល់ ៣៨៨។

[604]សាលក្រមក្នុង *រឿងក្តី Krnojelac*, កថាខណ្ឌ ៤៣២, ជើងទំព័រ ១២៩៤ ("ចេតនាធ្វើទុក្ខបុកម្នេញដែលពាក់ព័ន្ធ សន្មតជាមុនដោយចាំបាច់ថា ជនរងគ្រោះគឺជាសមាជិកម្នាក់នៃក្រុមពូជសាសន៍ សាសនា ឬនយោបាយ")។ សាលក្រមក្នុងរឿងក្តី *Blaškić*, កថាខណ្ឌ ២៣៥ ("ចារីដែលប្រព្រឹត្តការធ្វើទុក្ខបុកម្នេញ ជាដំបូងមិនបានកំណត់គោលដៅលើបុគ្គលទេ ប៉ុន្តែគ្រាន់តែកំណត់គោលដៅលើសមាជិកនៅក្នុងក្រុមពូជសាសន៍ សាសនា ឬនយោបាយមួយចំនួន")។ *សូមមើលផងដែរ* ព្រឹត្តប័ត្រនិពន្ធដោយ M. Cherif Bassiouni, មានចំណងជើងថា៖ *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់អន្តរជាតិ*, បោះពុម្ពលើកទី ២, ទំព័រ ៣២៧ (ស្នើឡើងថា ជនរងគ្រោះត្រូវបានកំណត់មុខសញ្ញា ដោយសារតែជំនឿ ទស្សនៈ ឬជាសមាជិកនៅក្នុងក្រុមដែលគេកំណត់អត្តសញ្ញាណច្បាស់លាស់ ឬប្រភេទមួយដែលត្រូវបានកំណត់ដោយចារី)។ ព្រឹត្តប័ត្រនិពន្ធដោយ Gerhard Werle, មានចំណងជើងថា៖ *គោលការណ៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, បោះពុម្ពលើកទី ១, សារព័ត៌មានរបស់ TMC Asser Press, ឆ្នាំ ២០០៥, ទំព័រ ២៥៤ ("ធាតុផ្សំសត្យានុម័តតម្រូវឲ្យមានអំពើធ្វើទុក្ខបុកម្នេញលើសហគមន៍ ឬក្រុមដែលគេអាចកំណត់អត្តសញ្ញាណច្បាស់លាស់បាន")។

[605]មាត្រា ៧(១)(ជ) នៃលក្ខន្តិកៈតុលាការ ICC (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ធាតុផ្សំបទឧក្រិដ្ឋរបស់តុលាការ ICC, មាត្រា ៧(១)(ជ), ធាតុផ្សំ ២។

២៧៥. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលមិនយល់ស្របជាមួយនឹងការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកទៅលើសាលក្រមក្នុងរឿងក្តី *Naletilić និង Martinović* ថា "នៅពេលការសន្មតរបស់ចារីត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ការរើសអើងដែលបានចោទឡើងនេះ ផលវិបាក (នៃការរើសអើង) គឺពិតជាមានសម្រាប់ជនរងគ្រោះ ទោះបីជាការចាត់ចំណាត់ថ្នាក់របស់ចារី អាចមិនត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យជាសត្យានុម័តក្តី"[606]។ អង្គជំនុំជម្រះតុលាការកំពូលទទួលយកការលើកឡើងនេះ ត្រឹមតែអត្ថន័យថា ចារី គឺជាអ្នកកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់គោលដៅអំពីមូលហេតុនយោបាយ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចដែលថា ខ្លួនបានអនុញ្ញាតឱ្យមានចេតនាធ្វើទុក្ខបុកម្នេញតែឯកឯងជាការគ្រប់គ្រាន់ក្នុងការបង្កើតឱ្យមាននូវបទឧក្រិដ្ឋនៃអំពើធ្វើទុក្ខបុកម្នេញ ដោយមិនចាំបាច់គិតអំពីបញ្ហា ថាតើជនរងគ្រោះ គឺពិតជាសមាជិកក្នុងក្រុមគោលដៅដែលស្តែងឱ្យឃើញច្បាស់លាស់ដែរ ឬយ៉ាងណា នោះទេ។

២៧៦. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ដោយស្របតាមលក្ខខណ្ឌតម្រូវដែលថា អំពើធ្វើទុក្ខបុកម្នេញ ត្រូវតែមានការរើសអើងជាក់ស្តែង ហើយថា "ជនរងគ្រោះត្រូវបានកំណត់គោលដៅ ដោយសារតែជនរងគ្រោះគឺជាសមាជិកក្នុងក្រុមមួយ ដែលត្រូវបានកំណត់អត្តសញ្ញាណដោយចារីដោយផ្អែកលើមូលហេតុជាក់លាក់ដូចជា នយោបាយ ពូជសាសន៍ ឬសាសនា"[607] ផលវិបាកនៃការធ្វើទុក្ខបុកម្នេញដែលជាលក្ខខណ្ឌតម្រូវ ត្រូវតែកើតមានទៅលើក្រុមនេះ ដោយហេតុថា ការបដិសេធសិទ្ធិសារវន្តរបស់ជនរងគ្រោះនីមួយៗ ធ្វើឱ្យមានផលប៉ះពាល់ស្តីពីការរើសអើងដល់ក្រុមទាំងមូល។ ផ្ទុយទៅវិញ នៅពេលដែលអំពើសកម្ម ឬអកម្មដែលបានប្រព្រឹត្តឡើងដោយមានចេតនាធ្វើទុក្ខបុកម្នេញ ទៅលើបុគ្គលណាម្នាក់ដែលមិនមែនជាសមាជិកនៃក្រុមគោលដៅទេនោះ ផលវិបាកនៃអំពើនេះ "កើតមានពិតប្រាកដ

[606]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣១៧, ដកស្រង់ចេញពីសាលក្រមក្នុង*រឿងក្តី Naletilić និង Martinović*, កថាខណ្ឌ ៦៣៦, ជើងទំព័រ ១៥៧២។

[607]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៧។

ចំពោះជនរងគ្រោះ” ក្នុងន័យថា ជាការបដិសេធនូវសិទ្ធជាសារវន្ត ប៉ុន្តែ មិនមែនការរើសអើងជាក់ស្តែងដូចដែលតម្រូវដោយអំពើធ្វើទុក្ខបុកម្នេញនោះទេ[608]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងគោលជំហរដែលបានលើកឡើងត្រង់ចំណុចនេះ ដោយអង្គជំនុំជម្រះនៃតុលាការ ICTY នៅក្នុងសាលក្រមនៃរឿងក្តី *Krnojelac*[609]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភាពសមហេតុផលនៅក្នុងរឿងក្តីនេះមានលក្ខណៈប្រសើរជាងយុត្តិសាស្ត្រនានារបស់តុលាការ ICTY[610]។

២៧៧. ជាសរុប ដើម្បីឱ្យមានការធ្វើទុក្ខបុកម្នេញ ចាំបាច់ត្រូវតែមានអំពើសកម្ម ឬអកម្មដែលរើសអើងជាក់ស្តែង និងរើសអើងប្រឆាំងនឹងក្រុមជាក់លាក់ណាមួយដែលបានកំណត់នៅក្នុងលក្ខណៈវិនិច្ឆ័យណាមួយ។ ផ្ទុយមកវិញ មិនមានការរើសអើងជាក់ស្តែងនោះទេ នៅពេលដែល ១) នៅក្នុងអង្គហេតុ ចារីមានការភាន់ច្រឡំលើជនរងគ្រោះដោយមិនដឹង ថាតើជនរងគ្រោះពិតជាស្ថិតនៅក្នុងក្រុមគោលដៅ ដែលត្រូវបានកំណត់ដោយអត្តនោម័ត ដែរ ឬយ៉ាងណា[611] ឬ ២) ចារីកំណត់គោលដៅជនរងគ្រោះដោយមិនគិត ថាតើជនរងគ្រោះស្ថិតនៅក្នុង

---

[608]តាមន័យទូទៅ អំពើរើសអើងយ៉ាងខ្លាំងដែលដូចគ្នាទៅនឹងបទឧក្រិដ្ឋណាមួយនោះ ឬដូចទៅនឹងការវាយប្រហារដែលរើសអើងប្រឆាំងនឹងអ្នកទាំងឡាយដែលជាអ្នកទទួលរងអំពើទាំងនេះ ដោយប្រៀបធៀបនឹងអ្នកទាំងឡាយដែលមិនបានទទួលរងអំពើទាំងនេះ។

[609]សាលក្រមក្នុង *រឿងក្តី Krnojelac*, កថាខណ្ឌ ៤៣២, ជើងទំព័រ ១២៩៣។ *សូមមើលផងដែរ* ព្រឹត្តប័ត្រនិពន្ធដោយ Ken Roberts “កិច្ចខិតខំប្រឹងប្រែងក្នុងការកំណត់និយមន័យៈ ច្បាប់ស្តីពីអំពើធ្វើទុក្ខបុកម្នេញ ចាប់តាំងពីប្រភពដើមរហូតដល់តុលាការ ICTY” (Striving for Definition: The Law of Persecution from its Origins to the ICTY), ទំព័រ ២៧២ ដល់ ២៧៤ (ដែលរិះគន់ចំពោះទ្រឹស្តីដែលផ្ទុយដោយបង្ហាញថា នៅពេលដែលជនរងគ្រោះត្រូវបានគេកំណត់គោលដៅដោយ “ភាន់ច្រឡំនោះ” ហើយទទួលរងព្យសនកម្ម តុលាការពុំមានទឡ្ហីករណ៍ណាមួយដើម្បីសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញឡើយ)។

[610]ជើងទំព័រ ៥៩៧ នៅខាងលើ។

[611]អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយសាលក្រមរបស់តុលាការ ICTY ក្នុង *រឿងក្តី Krnojelac*, កថាខណ្ឌ ៤៣២, ជើងទំព័រ ១២៩៣។ *សូមមើល* ព្រឹត្តប័ត្រនិពន្ធដោយ Ken Roberts “កិច្ចខិតខំប្រឹងប្រែងក្នុងការកំណត់និយមន័យៈ ច្បាប់ស្តីពីអំពើធ្វើទុក្ខបុកម្នេញ ចាប់តាំងពីប្រភពដើមរហូតដល់តុលាការ ICTY” (Striving for Definition: The Law of Persecution from its Origins to the ICTY), ទំព័រ ២៧២ ដល់ ២៧៤ (ដែលរិះគន់ចំពោះទ្រឹស្តីដែលផ្ទុយដោយ

លក្ខណៈវិនិច្ឆ័យនៃការរើសអើង ដែរ ឬយ៉ាងណា ឬក៏អាចនិយាយបានថា នៅពេលដែលចារី កំណត់គោលដៅ*ដោយមិនរើសមុខ*[612]។

### ៤.ង.២.គ.សេចក្តីសន្និដ្ឋាន

២៧៨. ជាការសន្និដ្ឋាន អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការកំណត់របស់អង្គជំនុំជម្រះសាលាដំបូង អំពីនិយមន័យនៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនមានកំហុសនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសត្រង់ផ្នែកខ្លះ នៅក្នុង*ការបកស្រាយ*របស់ខ្លួនអំពីលក្ខខណ្ឌតម្រូវនៃការរើសអើងជាក់ស្តែងក្រោមធាតុផ្សំ*សត្យានុម័ត* នៃការធ្វើទុក្ខបុកម្នេញ។

### ៤.ខ.៣.ភាពអាចយល់ដឹង និងភាពអាចដឹងជាមុនថា អំពើធ្វើទុក្ខបុកម្នេញ គឺជាបទល្មើសនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

២៧៩. ដោយយល់ស្របតាមការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ អង្គជំនុំជម្រះតុលាការកំពូលធ្វើការវិភាគបន្ថែមថា តើតាមលក្ខខណ្ឌតម្រូវនៃគោលការណ៍នីត្យានុកូលភាព ជនជាប់ចោទអាចយល់ដឹងបានគ្រប់គ្រាន់ថា អំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយជាបទល្មើសព្រហ្មទណ្ឌ ដែរ ឬយ៉ាងណា និងថាតើជនជាប់ចោទអាចដឹងជាមុនថា មានច្បាប់ចែងពីអំពើធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណា នៅពេលនោះ ។

---

បង្ហាញថា នៅពេលដែលជនរងគ្រោះត្រូវបានគេកំណត់គោលដៅដោយ“ភាន់ច្រឡំ” ហើយទទួលរងព្យសនកម្ម តុលាការពុំមានទឡ្ហីករណ៍ណាមួយដើម្បីសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញឡើយ និងមានការពិភាក្សាយបន្ថែមទៀតទៅលើកង្វះយុត្តាធិការរបស់តុលាការ ICTY ស្តីពី“អំពើធ្វើទុក្ខបុកម្នេញដោយចេតនា”)។

[612]ដូច្នេះ ក្នុងកម្រិតណាមួយនោះ នៅក្នុងសំណុំរឿងបច្ចុប្បន្ន ដែលត្រូវពិភាក្សាក្នុងផ្នែកខាងក្រោម។

២៨០. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដោយពិចារណាលើការដាក់ពិរុទ្ធភាពដែលបានសម្រេចនៅក្នុងយុត្តិសាស្ត្ររបស់តុលាការយោធាអន្តរជាតិ (IMT) ក្រោយសង្គ្រាមលោកលើកទី II និងការជំនុំជម្រះក្តីរបស់តុលាការយោធា Nuremberg ព្រមទាំងនៅចំពោះមុខតុលាការជាតិនានា មុនឆ្នាំ ១៩៧៥ បានបង្ហាញថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលចំពោះអំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលដែលជនជាប់ចោទប្រព្រឹត្តអំពើឧក្រិដ្ឋ។ លើសពីនេះទៀត អំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយត្រូវបានធ្វើក្រមនីយកម្ម នៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ (IMT)[613] ធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE)[614] ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[615] និងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០[616]។ ដូច្នេះ ជនជាប់ចោទ (ឌុច) ក្នុងនាមជាកម្មាភិបាលម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យអាចយល់ដឹងយ៉ាងគ្រប់គ្រាន់ថា ខ្លួននឹងអាចត្រូវចោទប្រកាន់ពីអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញ ចាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ទោះបីជា អង្គជំនុំជម្រះសាលាដំបូង បានយកនិយមន័យនៃការធ្វើទុក្ខបុកម្នេញពីយុត្តិសាស្ត្រតុលាការ *មិនអចិន្ត្រៃយ៍* នានាក៏ដោយ ក៏ធាតុផ្សំនៃអំពើធ្វើទុក្ខបុកម្នេញ ដូចដែលបានបញ្ជាក់អះអាងខាងលើ ត្រូវបានសន្និដ្ឋានពីការផ្តល់សំអាងហេតុ និងអង្គហេតុរបស់តុលាការក្រោយសង្គ្រាមលោកលើកទី II និងជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលអាចយកមកអនុវត្តបាននៅកម្ពុជាក្នុងឆ្នាំ ១៩៧៥[617]។ ដូច្នេះ ជនជាប់ចោទអាចដឹងជាមុនបានយ៉ាងគ្រប់គ្រាន់ថា មានច្បាប់កំណត់អំពី

---

[613]មាត្រា ៦(គ) នៃធម្មនុញ្ញតុលាការយោធា IMT ។

[614]មាត្រា ៥(គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិចុងបូព៌ា។

[615]មាត្រា II(១)(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។

[616]គោលការណ៍ VI (គ) នៃគោលការណ៍ Nuremberg ឆ្នាំ ១៩៥០។

[617]សូមមើលជាទូទៅព្រឹត្តប័ត្រនិពន្ធដោយ Heller, ចំណងជើងថា៖ តុលាការយោធា Nuremberg និងប្រភពដើមរបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ, ទំព័រ ៣៨៧ ដល់ ៣៨៨។

និយមន័យនៃឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញ នៅពេលប្រព្រឹត្តបទល្មើសដែលត្រូវរងការចោទប្រកាន់នេះ។

## ៤.ខ.៤.ការយល់ឃើញអំពីអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការធ្វើទុក្ខបុកម្នេញលើអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១

២៨១. ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ចំពោះការសន្និដ្ឋានថា អ្នកជាប់ឃុំឃាំង*ទីមួយៗ*នៅមន្ទីរ ស ២១ បានក្លាយជាជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញ ដោយសារអ្នកជាប់ឃុំឃាំងទាំងនេះត្រូវបានកំណត់ជាគោលដៅដោយមូលហេតុនយោបាយ[618]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ក្នុងអំឡុងរបបគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា មានក្រុមមនុស្សខុសៗគ្នាត្រូវបានកំណត់គោលដៅថា ជាខ្មាំងនយោបាយតាមការកំណត់ ហើយត្រូវបានឃុំឃាំងនៅមន្ទីរ ស ២១ ក្រោមលក្ខណៈវិនិច្ឆ័យផ្សេងៗ។ បុគ្គលទាំងនេះត្រូវបានកំណត់ជាគោលដៅ ដោយសារពួកគេ៖ ជាអតីតមន្ត្រី និងទាហាននៃរបប លន់ នល់ ដែលត្រូវសង្ស័យថា ធ្លាប់បាន ឬកំពុងមានទំនាក់ទំនងជាមួយជនបរទេស ឬបង្កើតសម្ព័ន្ធមិត្តជាមួយមហាអំណាចបរទេស ជាបញ្ញវន្ត និស្សិត ឬជាមន្ត្រីការទូតដែលត្រូវបានហៅត្រឡប់មកមាតុភូមិវិញ ជាយុទ្ធជន និងកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា ដែលមានប្រវត្តិរូប ឬទំនាក់ទំនងគួរឱ្យសង្ស័យជាមួយនឹងអ្នកដែលអង្គការសន្មតថាជាខ្មាំង ជាជនបរទេស ជាព្រះសង្ឃ ជាសមាជិកនៃក្រុមសាសនា ឬជនជាតិភាគតិចកម្ពុជា[619] ឬជាអ្នកដែលរស់នៅទីក្រុង[620]។

[618]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៨៩។

[619]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៨៣ និង ៣៨៥ ដល់ ៣៨៨។

[620]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១០៥ (កត់សម្គាល់ "សេចក្តីបញ្ជាក់ស្តីពីប្រជាជន "ថ្មី" ដែលមកពីទីក្រុង")។

២៨២. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញផងដែរថា ជនរងគ្រោះរួមមានបុគ្គលិកមន្ទីរ ស ២១ ត្រូវបានចាត់ទុកថា បានធ្វើវិទ្ធង្សនាប្រឆាំងនឹងអង្គការ ក្រោយពេលអ្នកទាំងនោះត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ឬមានកំហុសនៅពេលធ្វើការ ឬជាបុគ្គលដែលពុំបានបង្ហាញនូវការគាំទ្រដោយសាទរដ៏ពេញទំហឹង ចំពោះបក្សកុម្មុយនីស្តកម្ពុជា។ នៅចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដំណើរការបោសសម្អាតខ្មាំងរបស់អង្គការ បានធ្វើឱ្យបុគ្គលមួយចំនួនមានការភ័យខ្លាចមិនទុកចិត្តគ្នា និងកាប់សម្លាប់គ្នាពេញផ្ទៃប្រទេស”[621] នៅពេលដែល“មជ្ឈិមបក្សបានចាប់ផ្តើមសង្ស័យថា មានខ្មាំងនៅគ្រប់ទីកន្លែង និងចាប់ផ្តើមព្រួយបារម្ភ ចំពោះខ្មាំងខាងក្នុងជាងខ្មាំងខាងក្រៅ”[622]។ បុគ្គលទាំងឡាយត្រូវបានកំណត់អត្តសញ្ញាណ និងត្រូវបានរកឃើញថា មានទោស“ដោយគ្រាន់តែត្រូវបានគេចោទប្រកាន់ប៉ុណ្ណោះ”[623]។ ផ្អែកទៅលើអង្គហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលធ្វើការពិចារណាថា ដោយខ្មាំងនយោបាយ ត្រូវបានកំណត់តាមគោលនយោបាយមួយដែលប្រើប្រាស់លក្ខណៈវិនិច្ឆ័យទូទៅ នៅខណៈដែលប្រជាជនដទៃទៀតទទួលបានសេរីភាព ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការយល់ឃើញថា មានអំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

២៨៣. ទោះបីជាយ៉ាងណាក៏ដោយ ខណៈពេលដែលបដិវត្តកំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងបោសសម្អាតដោយមិនរើសមុខ និងដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផល ដោយមូលហេតុនយោបាយនោះទេ។ សកម្មភាពបែបនេះ មិនមែនជាការធ្វើទុក្ខបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែ បង្កើតឱ្យមានការភ័យខ្លាចដែលពុំមានលក្ខណៈវិនិច្ឆ័យដែលស្តែងឱ្យឃើញក្នុងការកំណត់គោលដៅលើជនរងគ្រោះឡើយ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចជាឯកច្ឆន្ទថា ជនជាប់ចោទបានដឹងថា អ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១ មិនមែនសុទ្ធតែជាខ្មាំងរបស់បក្សនោះទេ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ

---

[621]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៨៨។

[622]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៨៥។

[623]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៨៨។

អ្នកជាប់ឃុំឃាំងទាំងអស់នោះ ត្រូវបានឃុំខ្លួន សួរចម្លើយ និងសម្លាប់[624]។ ជនជាប់ចោទបានប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ រួមទាំងការធ្វើទារុណកម្ម និងបានព្យាយាមដោយយកចិត្តទុកដាក់ ក្នុងការអនុវត្តនូវមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ហើយបានបន្តផ្តល់ជូនថ្នាក់លើ នូវឈ្មោះមនុស្សទាំងអស់ដែលខ្លួនបានដឹងយ៉ាងច្បាស់ថា ទីបំផុត មនុស្សទាំងនេះនឹងត្រូវចាត់ទុកថា ជាជនក្បត់ និងជាសត្រូវនយោបាយ[625]។ ដូចនេះបង្ហាញឱ្យឃើញថា នៅក្នុងសកម្មភាពល្មើសរបស់ខ្លួន ជនជាប់ចោទបានធ្វើបាបដោយចេតនាលើអ្នកដែលមិនស្ថិតក្នុងប្រភេទបុគ្គលដែលត្រូវធ្វើទុក្ខបុកម្នេញនោះទេ ការដែលជនជាប់ចោទធ្វើដូច្នេះ គឺមិនមែនដើម្បីរើសអើងប្រឆាំងនឹងសត្រូវនយោបាយទេ ប៉ុន្តែ គឺដើម្បីបង្ហាញឱ្យបក្សឃើញអំពីភាពស្មោះស្ម័គ្រ និងប្រសិទ្ធភាពនៃការងាររបស់ខ្លួន។ ដោយសារតែគ្មានលក្ខណៈវិនិច្ឆ័យជាទូទៅណាមួយ សម្រាប់កំណត់គោលដៅជនរងគ្រោះទាំងនោះ ដូច្នេះអំពើឃោរឃៅនានាដែលបានប្រព្រឹត្តទៅលើជនរងគ្រោះ មិនមែនជាការរើសអើងជាក់ស្តែង ហើយក៏មិនមែនកើតចេញពីចេតនារើសអើង និងធ្វើទុក្ខបុកម្នេញផងដែរ។ ពាក់ព័ន្ធនឹងអំពើនានាដែលបានប្រព្រឹត្តទៅលើបុគ្គលទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ដោយបានកំណត់អំពើទាំងនេះថា ជាអំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

២៨៤. ហេតុដូច្នេះ យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទរបស់អង្គជំនុំជម្រះសាលាដំបូង ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាប់ពាក់ព័ន្ធទៅនឹងបុគ្គលមិនជាក់លាក់មួយចំនួនដែលបានឃុំខ្លួន សួរចម្លើយ ធ្វើឱ្យទៅជាទាសករ និងសម្លាប់នៅមន្ទីរ ស ២១ នោះ មិនមែនដោយមូលហេតុនយោបាយ ប៉ុន្តែ ដោយសារតែជនជាប់ចោទបានកំណត់គោលដៅមិនរើសមុខ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ថា ការដាក់ពិរុទ្ធភាពនេះត្រូវសម្រេចដាក់ពីបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទ

---

[624]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៩៤ និង ៣៩៨។

[625]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៩៤ និង ៣៩៨។

ត្រូវបានរកឃើញដោយអង្គជំនុំជម្រះសាលាដំបូងថា ជាអ្នកទទួលខុសត្រូវលើបទល្មើសនានា ដែលបានប្រព្រឹត្តមកលើជនរងគ្រោះ ដូចជា ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត។

## ៤.ច.ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា

២៨៥. បន្ទាប់ពីបានកំណត់និយមន័យនៃអំពើធ្វើទុក្ខបុកម្នេញ អំពើធ្វើទារុណកម្ម និងអំពើធ្វើឱ្យទៅជាទាសករ ថាជាបទឧក្រិដ្ឋដាច់ដោយឡែកពីគ្នានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលស្ថិតក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក រួចមក អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិចារណាលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាត្រង់ចំណុចទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយមិនបានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាលើជនជាប់ចោទពីបទឧក្រិដ្ឋមូលដ្ឋាននានានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានរកឃើញថាជនជាប់ចោទជាអ្នកទទួលខុសត្រូវនោះ[626]។ ដូចបានកត់សម្គាល់ពីខាងដើមរួចមកហើយថា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ចំពោះបទល្មើសនានានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មានដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផង) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត[627]។ ប៉ុន្តែ បើពិនិត្យមើលអំពីលក្ខណៈវិនិច្ឆ័យរបស់តុលាការ ICTY នៅក្នុងរឿងក្តី *Čelebići* និងយុត្តិសាស្ត្រក្រោយៗមកទៀតរបស់តុលាការ*មិនអចិន្ត្រៃយ៍* ហើយដែលអនុវត្តតាមលក្ខណៈវិនិច្ឆ័យនេះឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខ្លួនអាចសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទបានតែចំពោះអំពើធ្វើទុក្ខបុកម្នេញ ដោយមូលហេតុ

---

[626]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣២។

[627]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៥៩។

នយោបាយប៉ុណ្ណោះ ដោយសារតែបទឧក្រិដ្ឋនេះមានភាពជាក់លាក់ជាងគេ[628] ហេតុដូច្នេះហើយ ទើបខ្លួនសម្រេចស្រូបបញ្ចូលអំពើសម្លាប់រង្គាល (តាមលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* មានការស្រូបបញ្ចូលនូវការធ្វើមនុស្សឃាត)[629] ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (ដែលរួមបញ្ចូលទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ) និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[630]។

---

[628]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦០ ដល់ ៥៦១ និង ៥៦៣ ដល់ ៥៦៤។

[629]អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ត្រង់កថាខណ្ឌ ១៣២ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងគប្បីសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាលើជនជាប់ចោទពីបទ ធ្វើមនុស្សឃាត និងបទល្មើសដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចោទប្រកាន់។ មិនតែប៉ុណ្ណោះ ត្រង់កថាខណ្ឌ ១៣៤, ១៣៨ ដល់ ១៤២ សហព្រះរាជអាជ្ញាបានអះអាងថា អំពើធ្វើមនុស្សឃាត និងអំពើធ្វើទុក្ខបុកម្នេញ មានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័តដែលតម្រូវឱ្យធ្វើការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទល្មើសទាំងពីនេះ ទើបជាការសមរម្យ។ នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទជាអ្នកទទួលខុសត្រូវចំពោះបទធ្វើមនុស្សឃាត ដែលត្រូវបានស្រូបបញ្ចូលទៅក្នុងបទសម្លាប់រង្គាលដែល ជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលស្រូបបញ្ចូលទៅក្នុងបទធ្វើទុក្ខបុកម្នេញ។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៦ និង៥៦៨។ ប៉ុន្តែ នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាពុំបានជំទាស់ ឬបង្ហាញទឡ្ហីករណ៍ពាក់ព័ន្ធនឹងជំហរជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូង ដូចអ្វីដែលខ្លួនបានធ្វើពាក់ព័ន្ធនឹងការដែលអង្គជំនុំជម្រះបញ្ចូលការរំលោភលើផ្លូវភេទទៅក្នុងការធ្វើទារុណ្ណកម្ម ថាជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៩២ ដល់ ២០០។ លើសពីនេះទៅទៀត នៅក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាបានសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្តន្ទាទោសត្រួតគ្នាលើ ជនជាប់ចោទពីបទសម្លាប់រង្គាល (ស្រូបបញ្ចូលបទធ្វើមនុស្សឃាត) និងបទល្មើសដទៃទៀតនៅក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលត្រូវបានចោទប្រកាន់។ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១៦។ ដូច្នេះ បើពិនិត្យមើលបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាទាំងមូល អង្គជំនុំជម្រះតុលាការកំពូលពុំបានពិចារណាទៅលើបញ្ហាដែលថា តើបទធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងស្រូបបញ្ចូលសមស្របទៅក្នុងបទសម្លាប់រង្គាលដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលបញ្ហានេះត្រូវបានលើកឡើងយ៉ាងត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដែរ ឬយ៉ាងណានោះទេ។ ប៉ុន្តែ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលនឹងពិនិត្យមើលបញ្ហានេះ នៅពេលពិនិត្យការអនុវត្តនៃលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ដែលអង្គជំនុំជម្រះសាលាដំបូងយកមកប្រើ។ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣២, ១៣៤, ២១៦។

[630]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៨។

២៨៦. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ត្រង់ផ្នែកនេះ មានជាប់ពាក់ព័ន្ធទៅនឹងបទល្មើសត្រួតគ្នា *(concursus delictorum)* ដែលមានន័យថា ច្បាប់ដែលពាក់ព័ន្ធទៅនឹងបទល្មើសត្រួតគ្នា ឬការវិនិច្ឆ័យពីបទល្មើសត្រួតគ្នាលើជនជាប់ចោទតែម្នាក់ ពាក់ព័ន្ធនឹងអង្គហេតុមួយដែលមានកាលៈទេសៈនៃបទល្មើសច្រើន[631]។ *គោលការណ៍បទល្មើសត្រួតគ្នា* គឺមានជាប់ពាក់ព័ន្ធទៅនឹង"ស្ថានភាពត្រួតគ្នានៃបទល្មើសដែលមានប្រភេទខុសៗគ្នា ឬស្ថានភាពត្រួតគ្នាដែលកើតពីផ្នែកមួយចំនួននៃអង្គហេតុ ឬស្ថានភាពទាំងពីរ"[632]។ បើផ្អែកតាមមូលដ្ឋាននៃបណ្តឹងសាទុក្ខនេះឃើញថា បញ្ហាជាក់លាក់មួយនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺត្រូវកំណត់ពីវិធានសម្រាប់ធ្វើការដោះស្រាយអំពីបញ្ហាបទល្មើសត្រួតគ្នានេះ ហើយត្រូវមានដំណោះស្រាយសមស្របបែបណា នៅពេលដែលអំពើប្រព្រឹត្តដូចគ្នានេះ បានបំពេញទៅតាមនិយមន័យនៃបទល្មើសដែលកំណត់ដោយច្បាប់ ហើយដែលអំពើនេះបង្កើតឱ្យមានបទល្មើសច្រើនផ្អែកតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ការបង្កើតនូវវិធានដែលអាចដោះស្រាយបានចំពោះបញ្ហានេះ គឺជាការសំខាន់ណាស់ទាក់ទងទៅនឹងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក ទៅលើបទឧក្រិដ្ឋអន្តរជាតិនៃឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ដែល"បើទោះបីជា បទឧក្រិដ្ឋទាំងនោះ មានប្រភពខុសគ្នាក៏ដោយ (...) ក៏នៅតែអាចឈានដល់កម្រិតដូចគ្នាខ្លាំងបានដែរ ហើយក៏អាចមានអំពើឧក្រិដ្ឋមួយចំនួន អាចបំពេញបានតាមលក្ខខណ្ឌតម្រូវនៃបទល្មើសច្រើន"[633]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចជាបញ្ហាបឋម ថាតើអង្គជំនុំជម្រះ

---

[631]ព្រឹត្តប័ត្រនិពន្ធដោយ Stuckenberg, Carl-Friedrich ចំណងជើងថា "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា", នៅក្នុងការបោះពុម្ពផ្សាយដោយនិពន្ធនាយក Horst Fischer, Claus Kreß and Sascha Rolf Lüder (eds.)។ *ការចោទប្រកាន់ចំពោះបទល្មើសក្រោមច្បាប់ជាតិ និងអន្តរជាតិ អនុលោមតាមច្បាប់អន្តរជាតិ*, BMV, ឆ្នាំ ២០០៤, ទំព័រ ៥៥៩។

[632]ព្រឹត្តប័ត្រនិពន្ធដោយ Stuckenberg "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា", ទំព័រ ៥៦៣។

[633]ព្រឹត្តប័ត្រនិពន្ធដោយ Mettraux, Guénaëll, ចំណងជើថា៖ *បទឧក្រិដ្ឋអន្តរជាតិ និងតុលាការមិនអចិន្ត្រៃយ៍*, ចេញផ្សាយដោយសាព័ត៌មានសាកលវិទ្យាល័យ Oxford, ឆ្នាំ ២០០៦, ទំព័រ ៣១៥។ ឧទាហរណ៍ អំពើសម្លាប់មនុស្សម្នាក់ទៀត ក្នុងកាលៈទេសៈសមស្រប អាចបង្កើតបានជាអំពើប្រល័យពូជសាសន៍ អំពើធ្វើមនុស្សឃាត ឬអំពើសម្លាប់រង្គាល នៅក្នុងបទ

សាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការយកលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* មកដោះស្រាយចំពោះបញ្ហានេះ។

### ៤.ច.១.លក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići*

២៨៧. លក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ត្រូវបានបង្កើតឡើងជាដំបូងដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY នៅក្នុងរឿងក្តី *ព្រះរាជអាជ្ញា ទល់នឹង Delalić និងជនដទៃទៀត*។ សាលដីកាលើបណ្តឹងសាទុក្ខ ដែលមានខ្លឹមសារដូចខាងក្រោម ៖

> ការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា(ពិរុទ្ធភាពត្រួតគ្នា)ដែលបានកំណត់ដោយបទប្បញ្ញត្តិផ្សេងៗគ្នា ប៉ុន្តែ បានផ្អែកលើអំពើតែមួយនោះ គឺអាចធ្វើទៅបានតែក្នុងករណីដែលបទប្បញ្ញត្តិពាក់ព័ន្ធនីមួយៗនោះ មានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត ដែលពុំមាននៅក្នុងបទល្មើសផ្សេងទៀតទេ។ ធាតុផ្សំមួយមានភាពដាច់ដោយឡែកជាសត្យានុម័តពីធាតុផ្សំមួយផ្សេងទៀត គឺថា ប្រសិនបើនៅពេលមានតម្រូវការឱ្យបង្ហាញភស្តុតាងអំពីអង្គហេតុមួយចំពោះធាតុផ្សំនេះ នោះមិនទាមទារឱ្យធ្វើដូច្នេះឡើយចំពោះធាតុផ្សំផ្សេងមួយទៀត។
>
> នៅពេលដែលមិនអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះបាន អង្គជំនុំជម្រះត្រូវសម្រេច ថាតើបទល្មើសមួយណាដែលខ្លួនត្រូវសម្រេចដាក់ពិរុទ្ធភាព។ កិច្ចការនេះអាចសម្រេចបាន ដោយផ្អែកលើគោលការណ៍ថា ការសម្រេចដាក់ពិរុទ្ធភាព ត្រូវអនុលោមតាមបទប្បញ្ញតិដែលមានភាពជាក់លាក់ជាងគេ។ ដូច្នេះ ប្រសិនបើអង្គហេតុកើតឡើងមួយស្ថិតក្រោមបទប្បញ្ញត្តិពីរ ដោយបទប្បញ្ញត្តិមួយមានធាតុផ្សំដាច់ដោយ

---

ឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬអំពើសម្លាប់មនុស្សដោយចេតនា ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។ មាត្រា ៣ ថ្មី ដល់មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

ឡែកជាសត្យានុម័តបន្ថែមលើសគេនោះ ការសម្រេចដាក់ពិរុទ្ធភាពត្រូវអនុលោមតាមបទប្បញ្ញត្តិដែលមានភាពជាសត្យានុម័តលើសគេនោះ[634]។

២៨៨. ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យនេះ នៅពេលដែលអំពើប្រព្រឹត្តមួយ បង្កើតឱ្យមានបទល្មើសច្រើនស្របតាមនិយមន័យនៃបទល្មើស ដែលកំណត់ដោយច្បាប់នោះ អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា(ពិរុទ្ធភាពត្រួតគ្នា) ចំពោះបទល្មើសទាំងនោះបាន ប៉ុន្តែអង្គជំនុំជម្រះនេះអាចធ្វើដូច្នេះបាន តែក្នុងករណីដែលបទឧក្រិដ្ឋទាំងនោះត្រូវបានចាត់ទុកថាមានលក្ខណៈដាច់ដោយឡែកពីគ្នាយ៉ាងគ្រប់គ្រាន់ ឬមាន"ធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត"ដែលធាតុផ្សំនោះ មិនមានកំណត់នៅក្នុងបទល្មើសមូលដ្ឋានដទៃទៀតទេ។ ម្យ៉ាងវិញទៀត នៅពេលដែលបទឧក្រិដ្ឋពីរ មិនមានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័តរៀងៗខ្លួនទេនោះ បទឧក្រិដ្ឋដែលមានធាតុផ្សំដាច់ដោយឡែកជាសត្យានុម័តត្រូវចាត់ទុកថា ជាបទឧក្រិដ្ឋដែលមានធាតុផ្សំជាក់លាក់ជាងគេ ហើយបទឧក្រិដ្ឋនេះត្រូវស្រូបបញ្ចូលនូវបទឧក្រិដ្ឋផ្សេងទៀត រីឯការសម្រេចដាក់ពិរុទ្ធភាព គឺត្រូវយកតែបទឧក្រិដ្ឋមួយប៉ុណ្ណោះ។ ការសម្រេចនេះ គឺទាក់ទងទៅនឹងការប្រៀបធៀបធាតុផ្សំផ្លូវច្បាប់នៃបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ ហើយអង្គហេតុជាក់លាក់ក្នុងរឿងក្តីមិនមានតួនាទីអ្វីទេ[635]។ ដោយអនុលោមតាមយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* លក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ត្រូវបានយកមកអនុវត្តជាដំបូងពាក់ព័ន្ធនឹងធាតុផ្សំ *ទៅតាមបរិបទ*នៃបទឧក្រិដ្ឋអន្តរជាតិ ហើយនៅពេលដែលអំពើដូចគ្នាបានបំពេញលក្ខខណ្ឌតាមនិយមន័យ នៃមាត្រាច្បាប់ដែលមានចែងអំពី

---

[634] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Delalić, Mučić, Delic និង Landžo ("Čelebići")*, សំណុំរឿងលេខ IT-96-21-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២០ ខែ កុម្ភៈ ២០០១, ("សាលដីកាក្នុង *រឿងក្តី Čelebići*"), កថាខណ្ឌ ៤១២ ដល់ ៤១៣។

[635] សាលដីកាក្នុង *រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១០៤០។ ផ្អែកតាមន័យច្បាប់ ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា គឺជាការចាំបាច់។ ដូចដែលបានលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ថា "នៅពេលមានភស្តុតាងគាំទ្រការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាចំពោះអំពើមូលដ្ឋានដូចគ្នា លក្ខណៈវិនិច្ឆ័យដូចមានចែងក្នុង *រឿងក្តី Čelebići* (. . .) មិនអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តឆន្ទានុសិទ្ធិ សម្រេចដាក់ពិរុទ្ធភាពពីបទល្មើសមួយ ឬច្រើនបាននោះទេ ដរាបណាបទឧក្រិដ្ឋទាំងពីរនេះ មិនមានធាតុផ្សំដាច់ជាសត្យានុម័ត"។ សាលដីកាក្នុង *រឿងក្តី Stakić*, កថាខណ្ឌ ៣៥៨។

បទល្មើស គឺថា"ការវិនិច្ឆ័យនោះក៏អាចយកមកអនុវត្តបានផងដែរ ចំពោះធាតុផ្សំ*សត្យានុម័ត* និងធាតុផ្សំ*អត្តនោម័ត* សម្រាប់បទល្មើសដែលត្រូវបានចោទប្រកាន់នៅក្នុងបទប្បញ្ញត្តិច្បាប់តែមួយនោះ"[636]។

២៨៩. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ទោះបីជាច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬវិធានផ្ទៃក្នុង មិនបានចែងច្បាស់លាស់ដើម្បីដោះស្រាយបញ្ហា*បទល្មើសត្រួតគ្នានេះ*ក៏ដោយ ក៏ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានចង្អុលបង្ហាញដល់អង្គជំនុំជម្រះសាលាដំបូងអំពីច្បាប់ជាធរមានដែលត្រូវតែអនុវត្តតាម ទាំងផ្នែកសារធាតុ[637] និងនីតិវិធី[638]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា ច្បាប់ដែលកំណត់អំពីការវិនិច្ឆ័យលើបញ្ហាបទល្មើសត្រួតគ្នាសម្រាប់អំពើប្រព្រឹត្តតែមួយ គឺជាបញ្ហានៃច្បាប់ព្រហ្មទណ្ឌផ្នែកសារធាតុ"ដែលស្ថិតនៅក្នុងចន្លោះព្រំដែនរវាងបទប្បញ្ញត្តិទូទៅក្នុងច្បាប់ព្រហ្មទណ្ឌ និងវិធានស្តីពីការកំណត់ទោស" ជាមួយនឹងផលវិបាកផ្នែកនីតិវិធី[639]។ ការអះអាងបែបនេះ ដោយសារតែបទឧក្រិដ្ឋ ដែលបានលើកឡើងនៅក្នុងផ្នែកនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានេះ គឺជាបទឧក្រិដ្ឋអន្តរជាតិ ដូច្នេះ ជាការ

---

[636]ព្រឹត្តប័ត្រនិពន្ធដោយ Mettraux, *បទឧក្រិដ្ឋអន្តរជាតិ និងតុលាការមិនអចិន្ត្រៃយ៍ (International Crimes and the Ad Hoc Tribunals)*, ទំព័រ ៣១៨។

[637]មាត្រា ២(ថ្មី) ដល់ ៨ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ចែងថា ចំពោះបទឧក្រិដ្ឋក្រោមច្បាប់ជាតិ ច្បាប់ជាធរមាន គឺក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ចំណែកឯបទល្មើសក្រោមច្បាប់អន្តរជាតិ ច្បាប់ជាធរមានគឺអនុសញ្ញាអន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។

[638]មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវមើលច្បាប់នីតិវិធីកម្ពុជាដែលមានជាមុនសិន ប៉ុន្តែ ប្រសិនបើច្បាប់នោះមិនអាចដោះស្រាយចំពោះបញ្ហាជាក់លាក់ណាមួយបាន និងមានភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្ត ឬមានភាពមិនស៊ីសង្វាក់គ្នានឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិបាន)។

[639]ព្រឹត្តប័ត្រនិពន្ធដោយ Stuckenberg, "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា", ទំព័រ ៥៥៩។ ច្បាប់នេះអាចមានផលវិបាកផ្នែកនីតិវិធី ឧទាហរណ៍ លើទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងការអនុវត្តក្នុងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ឬលើវិសាលភាព*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*។ *ប្រៀបធៀប* សាលក្រមក្នុង*រឿងក្តី* *Kupreškić*, កថាខណ្ឌ ៦៧០។

សមស្របសម្រាប់អង្គជំនុំជម្រះសាលាដំបូង គួរស្វែងរកមើលវិធានដែលមានចែងក្នុងច្បាប់អន្តរជាតិ ជាជាងយកតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។

២៩០. ទោះជាយ៉ាងនេះក្តី ការប្រកាសយ៉ាងដូច្នេះ មិនអាចដោះស្រាយបញ្ហានេះបានទាំងស្រុងនោះទេ។ នៅតែចោទជាសំណួរនៅឡើយ ថាតើអង្គជំនុំជម្រះសាលាដំបូងបានធ្វើត្រឹមត្រូវ ដែរ ឬយ៉ាងណា នៅពេលដែលខ្លួនជ្រើសយកវិធានដែលមានបង្កើតឡើងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* ដែលផ្ទុយទៅនឹងប្រភពដើមនៃច្បាប់អន្តរជាតិ។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាបឋម គឺពុំមានអនុសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិណាមួយ ដែលចែងជាក់លាក់សម្រាប់ដោះស្រាយបញ្ហា*បទល្មើសត្រួតគ្នាសម្រាប់បទឧក្រិដ្ឋអន្តរជាតិ*នោះទេ។ តុលាការយោធាអន្តរជាតិ (IMT) និងតុលាការយោធា Nuremberg (NMT) បានសម្រេចដាក់ពិរុទ្ធភាពជនជាប់ចោទច្រើននាក់ពីបទឧក្រិដ្ឋកម្មសង្គ្រាមផង និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិផង ដោយផ្អែកលើមូលដ្ឋាននៃអំពើដូចគ្នា ដោយមិនមានការពិចារណាផ្លូវច្បាប់អំពីបញ្ហាបទល្មើសត្រួតគ្នានេះទេ[640] ហើយតុលាការនេះផ្តោតជាសំខាន់ តែទៅលើលក្ខខណ្ឌតម្រូវនៃភាពទាក់ទងគ្នា (nexus) រវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាមួយនឹងបទឧក្រិដ្ឋដទៃទៀត ដែលមានចែងក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) ឬច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ជាជាងផ្តោតទៅលើមូលដ្ឋាននៃទ្រឹស្តីអំពីការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា(ពិរុទ្ធភាពត្រួតគ្នា)[641]។ លើសពីនេះទៀត បើពិនិត្យ

---

[640]សាលក្រមតុលការ IMT, វ៉ុល I, ទំព័រ ២៨១ ដល់ ២៨២, ២៨៧ ដល់ ២៩៨, ៣០០ ដល់ ៣០១, ៣០៥ ដល់ ៣០៧, ៣២០ ដល់ ៣២២, ៣២៤ ដល់ ៣២៥, ៣២៧ ដល់ ៣៣០, ៣៣១ ដល់ ៣៣៦។ *រឿងក្តីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌*, វ៉ុល III, ទំព័រ ១០៨៧, ១១០៧, ១១១៨, ១១២៨, ១១៣២, ១១៣៤, ១១៤២, ១១៧០។ វ៉ុល VI, ទំព័រ ៣៤ ដល់ ៣៦។ *រឿងក្តី Pohl*, វ៉ុល V, ទំព័រ ៩៦២, ៩៩២, ៩៩៧, ៩៩៩, ១០០១, ១០១០, ១០១៥, ១០២៣, ១០៣១, ១០៣៤ ដល់ ១០៣៥, ១០៣៩ ដល់ ១០៤០, ១០៤២, ១០៤៧, ១០៥១, ១០៥៦, ១០៥៩។

[641]យោងតាម Henri Donnedieu de Vabres ចៅក្រមបារាំងនៅតុលាការយោធា IMT បានឱ្យដឹងថា វិធីបែបនេះអនុញ្ញាតឱ្យចៅក្រមរក្សាការអនុវត្តតាមស្មារតីនៃខ្លឹមសារនៃគោលការណ៍គ្មានទោសបើគ្មានច្បាប់ចែង។ "អនុលោមតាមមាត្រា ៦ នៃលក្ខន្តិកៈនេះ តុលាការមិនបានបោះបង់ចោលគោលគំនិតនៃ"បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ" គាត់សរសេរថា "ប៉ុន្តែ ជាការចាំបាច់ យើងត្រូវពន្យល់អំពីកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយផលវិបាករបស់វាឱ្យនៅត្រឹមកម្រិតអប្បបរមា (...)

00798545



លើគោលការណ៍ទូទៅនៃច្បាប់ ដែលមានការយល់ដឹងជាទូទៅនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា អំពីការអនុវត្តជាក់ស្តែងជារួមពាក់ព័ន្ធទៅនឹងបទល្មើសត្រួតគ្នា ចំពោះអំពើប្រព្រឹត្តដូចគ្នា ប្រសិនបើ បទល្មើសទាំងនោះមានប្រភេទដាច់ដោយឡែកពីគ្នាគ្រប់គ្រាន់តាមច្បាប់កម្ពុជា[642] នោះនឹង

---

ចំណែកឯរយៈពេលនៃសង្គ្រាមវិញ អង្គជំនុំជម្រះយល់ឃើញថា "បទឧក្រិដ្ឋសង្គ្រាម" និង "បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ" គឺស្ថិតនៅក្រោមប្រធានបទតែមួយសម្រាប់ជនជាប់ចោទស្ទើរតែគ្រប់គ្នា ម្ល៉ោះហើយ ប្រកានេះបានបង្កើតឲ្យមានការខុសគ្នាមួយចំនួនដែលនាំឲ្យមានបញ្ហា និងការច្របាច់បញ្ចូលគ្នានូវប្រភេទបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ចូលគ្នាជាមួយនឹងបទឧក្រិដ្ឋសង្គ្រាម"។ Henri Donnedieu de Vabres "ការជំនុំជម្រះក្តីនៅ Nuremberg និង គោលការណ៍សម័យទំនើបនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" នៅក្នុងការបោះពុម្ពផ្សាយដោយនិពន្ធនាយក Guénaëll Mettreaux (ed.), *អំពីទិដ្ឋភាពស្តីពីការជំនុំជម្រះនៅ Nuremberg*, ចេញផ្សាយដោយសារព័ត៌មានសាកលវិទ្យាល័យ Oxford, ឆ្នាំ២០០៨, ទំព័រ ២៤១។

[642]ប្រទេសប្រកាន់ច្បាប់ស៊ីវិល (Civil law) ទំនងជាធ្វើដូច្នេះ ដោយសម្អាងលើទ្រឹស្តី"ការត្រួតស៊ីគ្នាតែមួយ"។ *សូមមើល ឧទា.* មាត្រា ១៤(២) (១) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦, "មិនត្រូវទុកជាបទល្មើសច្រើនបទទេ កាលណា បើអំពើទាំងឡាយដដែលៗនោះ មានប្រភេទព្រហ្មទណ្ឌដូចគ្នា និងមិនត្រូវផ្តន្ទាទោសច្រើនបទនោះទេ"។ *រឿងក្តី Oliveira ទល់នឹង ប្រទេសស្វីស* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការអឺរ៉ុបសិទ្ធិមនុស្ស (84/1997/868/1080) ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៨, កថាខណ្ឌ ២៦៖

> នោះគឺ ជាឧទាហរណ៍គំរូមួយនៃអំពើតែមួយ ប៉ុន្តែបង្កើតបានជាបទល្មើសខុសៗគ្នា (*concours idéal d'infractions*)។ លក្ខណៈនៃទ្រឹស្តីនេះគឺថា អំពើឧក្រិដ្ឋតែមួយ គឺត្រូវបំបែកជាបទល្មើសពីរដាច់ពីគ្នា ក្នុងករណីនេះគឺការមិនបានគ្រប់គ្រងយានយន្តឲ្យបានល្អ និងភាពធ្វេសប្រហែសដែលបង្កឲ្យមានរបួសស្នាមលើរាងកាយ។ ក្នុងករណីទាំងនេះ ការកំណត់ពិរុទ្ធភាព នឹងត្រូវស្របតាមបទល្មើសដែលស្រាលជាង។ ប៉ុន្តែក្នុងស្ថានភាពនោះគឺគ្មានអ្វីរំលោភបំពានលើមាត្រា ៤ នៃពិធីសារលេខ ៧ នោះទេ ដោយសារបទប្បញ្ញត្តិនោះ ហាមប្រាមមិនឲ្យកាត់ទោសមនុស្សពីរដងចំពោះបទល្មើសដូចគ្នា ក្នុងករណីដែលពាក់ព័ន្ធនឹងអំពើតែមួយដែលបង្កើតបានជាបទល្មើសខុសៗគ្នា (*concours idéal d'infractions*) អំពើល្មើសតែមួយបង្កើតបានជាបទល្មើសពីរដាច់ដោយឡែកពីគ្នា។

*សូមមើលផងដែរ* ការស្ទង់មតិផ្នែកប្រព័ន្ធជាតិក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Kupreškić* កថាខណ្ឌ ៦៦២ និង៦៨៥។ ព្រឹត្តប័ត្រនិពន្ធដោយ Stuckenberg, "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា" ទំព័រ ៥៩៦ ដល់ ៥៩៧។ ដូចគ្នានេះដែរ ប្រទេសជាច្រើនដែលប្រកាន់ច្បាប់អង់គ្លូសាក់សុង (common law) ក៏ធ្វើដូច្នេះដែរ ដោយអនុវត្តតាមទ្រឹស្តីនៃលក្ខណៈពិសេសទ្វេរ ម៉្យាងវិញទៀត នៅពេលដែលនិយមន័យច្បាប់នៃបទល្មើសនីមួយៗមានធាតុផ្សំមួយខុសប្លែកគ្នា។ *សូមមើលផងដែរឧទា.* នៅសហរដ្ឋអាមេរិក ក្នុង*រឿងក្តី Blockburger ទល់នឹង សហរដ្ឋអាមេរិក*

មាន"ទ្រឹស្តីខ្វែងគ្នា និងតែងតែមិនអាចរកចំណុចរួមបាននៅក្នុងប្រព័ន្ធច្បាប់កម្ពុជា"[643]ដែលនេះគឺជាផលវិបាកនៃភាពត្រួតគ្នានេះ[644]។ នេះជាការពិត ទាក់ទងនឹងផ្នែកទាំងពីរ គឺទាំងផ្នែកនៃការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា(ពិរុទ្ធភាពត្រួតគ្នា) និងការប្រកាសទោស[645]

---

តុលាការកំពូលសហរដ្ឋអាមេរិក (ឆ្នាំ ១៩៣២) វ៉ុល ២៨៤ U.S. ទំព័រ ២៩៩, ៣០៤ ("នៅពេលដែលអំពើតែមួយ ឬការប្រព្រឹត្តតែមួយបង្កើតបានជាការរំលោភបំពានលើបទប្បញ្ញត្តិពីរដាច់ដោយឡែកពីគ្នាដែលកំណត់ដោយច្បាប់ លក្ខណៈវិនិច្ឆ័យដែលត្រូវយកមកអនុវត្តដើម្បីសម្រេចថាតើ មានបទល្មើសពីរ ឬមានតែមួយ គឺថាតើបទប្បញ្ញត្តិនីមួយៗតម្រូវឲ្យមានភស្តុតាងបញ្ជាក់អំពីអង្គហេតុមួយ ដែលខុសពីបទល្មើសមួយទៀត ដែរ ឬយ៉ាងណា")។ នៅប្រទេសកាណាដា *រឿងក្តី R. ទល់នឹង Prince*, តុលាការកំពូលប្រទេសកាណាដា (ឆ្នាំ ១៩៨៦) វ៉ុល ២ កំណត់ហេតុរបស់ក្រុមប្រឹក្សាសន្តិសុខ ទំព័រ ៤៨០ (2 S.C.R. 480), កថាខណ្ឌ ៣២ ("វិធាននៅក្នុង Kienapple ដែលត្រូវយកមកអនុវត្តដើម្បីហាមឃាត់ ការដាក់ពិរុទ្ធភាពត្រួតគ្នាតែប៉ុណ្ណោះ "ក្នុងករណីដែលពុំមានធាតុផ្សំខុសគ្នាបន្ថែមដែលនាំឲ្យមានការដាក់ពិរុទ្ធភាព នៅក្នុងបទល្មើសបន្ថែមនោះ")។ នៅប្រទេសនូវែលសេឡង់ សាលាឧទ្ធរណ៍ *រឿងក្តី R. ទល់នឹង Moore*, ទីក្រុងវែលីងតោន, (ឆ្នាំ ១៩៧៤) វ៉ុល ១ NZLR ទំព័រ ៤១៧, វ៉ុល ១៩៧៣ NZLR LEXIS ទំព័រ ៧៥១, ទំព័រ ១៨ ("ថាតើបទល្មើសដែលជនជាប់ចោទត្រូវផ្តន្ទាទោស ឬត្រូវលើកលែងការចោទប្រកាន់ ក្នុងករណីដែលកើតមានដូចនេះ ដោយផ្អែកទៅលើការចោទប្រកាន់កាលពីដំបូង គឺជាបទល្មើសដូចគ្នា ឬតាមការអនុវត្ត ឬតាមខ្លឹមសារ ដូចគ្នា ទៅនឹងបទល្មើសដែលជនជាប់ចោទក្រោយមកទៀតតុលាការបានចោទប្រកាន់ពីបទល្មើសនោះ")។ នៅប្រទេសអូស្ត្រាលី *រឿងក្តី R. ទល់នឹង Lucy Dudko,* សភាព្រហ្មទណ្ឌនៃប្រទេស New South Wales, (ឆ្នាំ ២០០២), NSWCCA 336, កថាខណ្ឌ ១០៩ និង ១១៣ (អនុញ្ញាតឲ្យផ្តន្ទាទោសត្រួតគ្នាចំពោះបទល្មើសច្រើន ដែលកើតចេញពីអំពើដូចគ្នា នៅពេលដែល"ធាតុផ្សំ"បន្ថែមរបស់បទឧក្រិដ្ឋនីមួយៗដែលត្រូវបានចោទប្រកាន់ មានភាពដាច់ដោយឡែកពីគ្នា)។ *សូមមើលផងដែរ* សាលក្រមក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៦៨០ ដល់ ៦៨២។ ព្រឹត្តប័ត្រនិពន្ធដោយ Stuckenberg, "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា", ទំព័រ ៥៩៧ ដល់ ៥៩៨។

[643]ព្រឹត្តប័ត្រនិពន្ធដោយ Stuckenberg, "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា", ទំព័រ ៥៦៣។

[644]សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៧១៧។ ព្រឹត្តប័ត្រនិពន្ធដោយ Stuckenberg, "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា" ទំព័រ ៥៩៦ ដល់ ៥៩៨។

[645]*សូមមើលឧទា.* មាត្រា ៥៤(១) នៃក្រមព្រហ្មទណ្ឌជប៉ុន ("កាលណាអំពើតែមួយបង្កើតបានជាបទក្រិដ្ឋពីរ ឬច្រើនដាច់ដោយឡែកពីគ្នានោះ ឬកាលណាអំពើមួយគឺជាមធ្យោបាយ ឬលទ្ធផលនៃបទឧក្រិដ្ឋមួយ ដែលបង្កើតបានជាបទឧក្រិដ្ឋផ្សេងមួយទៀត ត្រូវផ្តន្ទាទោសធ្ងន់ជាងគេបំផុតដែលមានចែងពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងនេះ")។ មាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌស្វីស "ប្រសិនបើជនល្មើស តាមរយៈការប្រព្រឹត្តបទល្មើសមួយ ឬច្រើន បានបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃការដាក់ទោសពីរ ឬច្រើន តុលាការត្រូវដាក់ទោសពីបទល្មើសដែលធ្ងន់ធ្ងរបំផុតនិងបូកបន្ថែមកម្រិតទោសសមស្រប"។ អនុលោម

តាមក្រមព្រហ្មទណ្ឌនៃសាធារណរដ្ឋហុងគ្រី ផ្នែក ៨៥(១)-(៣) ("ក្នុងករណីមានបទល្មើសត្រួតគ្នា តុលាការត្រូវកំណត់ដាក់ទោសតែមួយប៉ុណ្ណោះ។ ការដាក់ទោសសំខាន់ជាងគេនេះ គឺត្រូវកំណត់យកទោសណាដែលមានស្ថានទម្ងន់ធ្ងន់ជាងគេបំផុតនៃបទល្មើសក្នុងចំណោមការដាក់ទោសត្រួតគ្នា។ ក្នុងករណីមានបទល្មើសច្រើនបទ ប្រសិនបើការដាក់ទោសជាប់ពន្ធនាគារសម្រាប់រយៈពេលកំណត់មួយ ត្រូវបានកំណត់ដោយច្បាប់ទាក់ទងនឹងអំពើល្មើសយ៉ាងហោចចំនួនពីរ តុលាការត្រូវបង្កើនទោសមួយកន្លះទៅលើទោសអតិបរមាដែលជាធរមាននោះ ប៉ុន្តែមិនត្រូវឲ្យលើសពីទោសសរុបនៃការផ្តន្ទាទោសអតិបរមាដែលបានកំណត់សម្រាប់អំពើល្មើសនេះទេ")។ មាត្រា ៦២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្របែលហ្ស៊ិក ("ក្នុងករណីមានបទឧក្រិដ្ឋត្រួតគ្នា តុលាការត្រូវដាក់ទោសធ្ងន់ធ្ងរបំផុតតែមួយប៉ុណ្ណោះ។ តុលាការ អាចតម្លើងទោស ៥ ឆ្នាំពីលើទោសអតិបរមានោះ")។ អនុលោមតាម ក្រមព្រហ្មទណ្ឌសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ផ្នែក ៥២(១)-(២) ("ប្រសិនបើអំពើដូចគ្នា រំលោភបំពានលើសពីច្បាប់មួយ ឬច្បាប់ដូចគ្នាលើសពីមួយដង តុលាការត្រូវសម្រេចកំណត់ទោសតែមួយប៉ុណ្ណោះ។ ប្រសិនបើអំពើនោះរំលោភច្បាប់លើសពីមួយ ការកំណត់ទោសត្រូវធ្វើឡើងទៅតាមច្បាប់ដែលចែងអំពីទោសធ្ងន់បំផុត។ ទោសនេះមិនត្រូវស្រាលជាងច្បាប់ជាធរមានដែលកំណត់ទោសនេះនោះទេ។ ក្រមព្រហ្មទណ្ឌនៃសាធារណរដ្ឋ Zambia ជំពូក IV ផ្នែក ៣៦ ចែងថា កាលណាអំពើមួយ បង្កើតបានជាបទល្មើសច្រើន ឬកាលណាអំពើច្រើន ត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងឧក្រិដ្ឋតែមួយ ជននោះត្រូវទទួលទោសចំពោះទង្វើនីមួយៗដែលបានចោទប្រកាន់ដែលជាបទឧក្រិដ្ឋដាច់ដោយឡែកពីគ្នា ហើយតុលាការ ត្រូវផ្តន្ទាទោសដាច់ដោយពីគ្នាចំពោះអំពើនីមួយៗផងដែរ។ ប្រសិនបើ តុលាការបង្គាប់ដាក់ពន្ធនាគារ ការបង្គាប់ដាក់ពន្ធនាគារនេះអាចកើតឡើងដំណាលគ្នា ឬជាបន្តបន្ទាប់គ្នា។ ប្រសិនបើតុលាការសម្រេចដាក់ទោសជាបន្តបន្ទាប់គ្នា ទោសពន្ធនាគារសរុបនេះ មិនត្រូវលើសពីរយៈពេលជាប់ពន្ធនាគារខ្ពស់បំផុតជាអតិបរមាដែលច្បាប់អនុញ្ញាតនោះទេ ពាក់ព័ន្ធនឹងការផ្តន្ទាទោសដែលច្បាប់ចែងអំពីរយៈពេលជាប់ពន្ធនាគារដ៏យូរបំផុតនោះ។ នៅសហរដ្ឋអាមេរិក បញ្ហានេះត្រូវបានកំណត់យ៉ាងពិស្តារនៅក្នុងសេចក្តីណែនាំរបស់គណៈកម្មាការក្នុងការដាក់ទោសរបស់សហរដ្ឋអាមេរិកឆ្នាំ ២០១១ ដែលត្រង់ជំពូក ៣ ផ្នែក ឃ ("បទចោទត្រួតគ្នា") (ចែងថា កាលណាជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសមួយ ឬច្រើន ពាក់ព័ន្ធនឹងអំពើ ឬការប្រព្រឹត្តតែមួយ តុលាការត្រូវបញ្ចូលជាក្រុមចំពោះបទល្មើសដែលពាក់ព័ន្ធបំផុត និងត្រូវអនុវត្តទោស ដែលមានចែងសម្រាប់ការបញ្ចូលបទល្មើសជាក្រុមនោះ ក្នុងកម្រិតទោសនៃបទល្មើសដែលធ្ងន់ធ្ងរបំផុត និងត្រូវបង្កើនកម្រិតនៃបទល្មើសទៅតាមចំនួនដែលមានចែងក្នុងតារាងដែលផ្តល់ឲ្យ។ យោងតាមសេចក្តីអត្ថាធិប្បាយ ("*ជាទូទៅតុលាការមានសិទ្ធិក្នុងការដាក់ទោសបន្ថែមដល់កម្រិតខ្ពស់បំផុតដែលច្បាប់អនុញ្ញាតចំពោះបទល្មើសធ្ងន់ធ្ងរ* ")។ នៅប្រទេស នូវែលសេឡង់ ច្បាប់ស្តីពីបទឧក្រិដ្ឋឆ្នាំ ១៩៦១ ផ្នែក ១០(៣) ("កាលណាអំពើសកម្ម ឬអកម្មណាមួយ គឺជាបទល្មើសនៅក្រោមបទប្បញ្ញត្តិពីរ ឬច្រើន នៃច្បាប់នេះ ឬច្បាប់ដទៃទៀត ជនល្មើសអាចត្រូវបានចោទប្រកាន់ *និងផ្តន្ទាទោស*ទៅតាមបទប្បញ្ញត្តិណាមួយនៃបទប្បញ្ញត្តិទាំងនោះ") (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ការស្ទង់មតិនៃវិធីសាស្ត្រជាតិ ដែលធ្វើឡើងក្នុងសាលដីកាក្នុង*រឿងក្តី* Čelebići កថាខណ្ឌ ៤០៦ ដល់ ៤០៩។ សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៧១៤ ដល់ ៧១៦។ ព្រឹត្តប័ត្រនិពន្ធដោយ Stuckenberg, "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា", ទំព័រ ៥៩៦ ដល់ ៥៩៩។

ដោយសារតែជាផ្នែកមួយ នៃ *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*[646]។ ដូច្នេះហើយ ទោះបីមានការសន្និដ្ឋានថា ដំណោះស្រាយចំពោះបញ្ហាបទល្មើសច្រើននៅក្នុងការអនុវត្តប្រព័ន្ធច្បាប់អង់គ្លូសាក់សុង (common law) និងយុត្តាធិការក្នុងប្រព័ន្ធច្បាប់ស៊ីវិល (civil law) មិនមានភាពខុសគ្នាផ្នែកលទ្ធផល ហើយខុសគ្នាផ្នែកទម្រង់យ៉ាងណាក្តី[647] ក៏មិនអាចនិយាយបានថា មានគោលការណ៍ច្បាប់ដែលចែងអំពីភាពត្រួតគ្នានៃបទល្មើសច្រើនខុសៗគ្នា ចំពោះអំពើដូចគ្នានោះដែរ[648]។

[646] *សូមមើលឧទា.* នៅចក្រភពអង់គ្លេស *រឿងក្តី R. ទល់នឹង Thomas*, (ឆ្នាំ ១៩៥០) វ៉ុល ១ ចេញផ្សាយដោយ K.B. ទំព័រ ២៦, ទំព័រ ៣១ ("ច្បាប់មិនបានចែងថា ជនណាម្នាក់មិនអាចត្រូវបានផ្តន្ទាទោសពីរដងចំពោះអំពើដូចគ្នានោះទេ។ ពុំដែលមានការលើកឡើងដូច្នេះដែរ ហើយវិធានក្នុងបកស្រាយក៏មិនបានចែងដូច្នេះដែរ។ អ្វីដែលមានចែងក្នុងវិធាននោះ គឺថា "គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីរដងចំពោះបទល្មើសដដែលនោះទេ"")។ នៅប្រទេស នូវែលសេឡង់ ច្បាប់ស្តីពីបទឧក្រិដ្ឋឆ្នាំ ១៩៦១, ផ្នែក ១០(៣) និង (៤) ("កាលណាអំពើសកម្ម ឬអកម្មណាមមួយ គឺជាបទល្មើស ស្ថិតនៅក្រោមបទប្បញ្ញត្តិពីរ ឬច្រើននៃច្បាប់នេះ ឬច្បាប់ដទៃទៀត ជនល្មើសអាចត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសទៅតាមបទប្បញ្ញត្តិណាមួយក៏បាននៃបទប្បញ្ញត្តិទាំងនោះ"។ ទោះបីជាយ៉ាងណាក៏ដោយ "មិនចំពោះថាក្នុងពេលសម្រេចផ្តន្ទាទោស ឬពេលចោទប្រកាន់ ឬពេលផ្តន្ទាទោសតាមនីតិវិធីសង្ខេបនោះទេ គ្មានជនណាម្នាក់ត្រូវទទួលខុសត្រូវផ្តន្ទាទោសពីរដងចំពោះបទល្មើសដដែលនោះទេ")។ អនុលោមតាមក្រមព្រហ្មទណ្ឌរបស់សាធារណរដ្ឋសំប៊ី, ជំពូក IV, ផ្នែក ២០ ចែងថា ("គ្មានជនណាម្នាក់អាចត្រូវបានផ្តន្ទាទោសពីរដងនៅក្រោមបទបញ្ញត្តិនៃក្រមនេះ ឬនៅក្រោមបទបញ្ញត្តិនៃច្បាប់ដទៃផ្សេងទៀតចំពោះអំពើសកម្ម ឬអកម្មតែមួយនោះឡើយ លើកលែងតែក្នុងករណីដែលអំពើសកម្ម ឬអកម្មរបស់ជនជាប់ចោទនោះបង្កឱ្យមានការស្លាប់ដល់អ្នកដទៃផ្សេងទៀតប៉ុណ្ណោះ ដែលនៅក្នុងករណីនេះជនជាប់ចោទអាចត្រូវបានផ្តន្ទាទោសចំពោះបទល្មើសដែលខ្លួនបានបង្កឱ្យមានការស្លាប់បន្ថែមទៀតនេះ ទោះបីជាខ្លួនត្រូវបានតុលាការសម្រេចផ្តន្ទាទោសរួចមកហើយក៏ដោយពីបទល្មើសដូចគ្នានេះដែលបានប្រព្រឹត្តឡើយ ដោយសារអំពើសកម្ម ឬអកម្មរបស់ខ្លួន")។ ម៉្យាងវិញទៀត នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល (civil law) *គោលការណ៍គ្មានការកាត់ទោសពីរដងនេះ* គឺប្រើសំដៅលើការការពារប្រឆាំងនឹងការផ្តន្ទាទោស និងការដាក់ទណ្ឌកម្មច្រើនដងចំពោះ*អង្គហេតុដូចៗគ្នា*។ ព្រឹត្តប័ត្រនិពន្ធដោយ Stuckenberg, Carl-Friedrich"ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា", ទំព័រ ៥៦១, ជើងទំព័រ ៤ (សេចក្តីបញ្ជាក់បន្ថែម)។

[647] ព្រឹត្តប័ត្ររបស់ Gerhard Werle *ស្តីពីគោលការណ៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពលើកទី ២ ដោយសាព័ត៌មាន TMC Asser, ឆ្នាំ ២០០៩, ទំព័រ ២៤២, ជើងទំព័រ ៥៦៨។

[648] សាលដីកាក្នុង*រឿងក្តី Čelebići*, កថាខណ្ឌ ៤០៦។ សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៧១៨។ ព្រឹត្តប័ត្ររបស់ Stuckenberg, "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា", ទំព័រ ៥៦៣។ ព្រឹត្តប័ត្ររបស់ Fulvio

២៩១. ដោយសារតែកង្វះគោលការណ៍ណែនាំពីសន្និសញ្ញា ទំនៀមទម្លាប់ និងគោលការណ៍ច្បាប់ទូទៅ អង្គជំនុំជម្រះតុលាការកំពូល នឹងពិនិត្យមើលភាពត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដែលអង្គជំនុំជម្រះនេះយកលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ធ្វើជាសំអាង។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មានការរិះគន់ចំពោះលក្ខណៈវិនិច្ឆ័យនេះ ដោយសារតែបានអនុញ្ញាតឱ្យ“ដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា ដោយផ្អែកលើអំពើដូចគ្នាក្រោមប្រភេទឧក្រិដ្ឋកម្មផ្សេងគ្នា” តាមរយៈការប្រៀបធៀបនៃធាតុផ្សំ*តាមបរិបទ* (chapeau) នៃបទឧក្រិដ្ឋអន្តរជាតិ ជាជាងផ្អែកទៅលើធាតុផ្សំ*សត្យានុម័ត* និង*អត្តនោម័ត*នៃបទល្មើសទាំងនោះដែលភាគច្រើនជាបទល្មើសដូចគ្នា ប៉ុន្តែស្ថិតនៅក្រោមប្រភេទឧក្រិដ្ឋកម្មផ្សេងគ្នា[649]។ ដូច្នេះមានការជំទាស់ថា លក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ដែលអនុញ្ញាតឱ្យសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា(ពិរុទ្ធភាពត្រួតគ្នា) ដោយផ្អែកលើមូលដ្ឋាននៃអំពើដូចគ្នាចំពោះបទឧក្រិដ្ឋអន្តរជាតិ ដែលពុំមានលក្ខណៈដាច់ដោយឡែកពីគ្នាយ៉ាង*ពិតប្រាកដនោះ* បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ[650]។

២៩២. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការជំទាស់ដែលបានធ្វើឡើងនោះ មិនផ្អែកតាមភាពសមហេតុផលនៃលក្ខណៈវិនិច្ឆ័យនោះទេ ប៉ុន្តែ បានផ្តោតទៅលើដំណើរការរបស់លក្ខណៈវិនិច្ឆ័យនេះ នៅពេលដែលយកលក្ខណៈវិនិច្ឆ័យនេះ ទៅអនុវត្តនៅក្នុងបរិបទនៃឧក្រិដ្ឋកម្មអន្តរជាតិដែលមាននិយមន័យមានលក្ខណៈទូលំទូលាយ ស្មុគស្មាញ ហើយមិនច្បាស់លាស់។ បទឧក្រិដ្ឋ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចែងអំពីប្រភេទនៃអំពើជាច្រើន ដែលអាចគ្របដណ្តប់លើអំពើឧក្រិដ្ឋជាច្រើនដែលអំពើទាំងនេះបានកើតឡើងក្នុងរយៈពេលយូរអង្វែងមកហើយ។ លើសពីនេះទៀត ដោយសារតែប្រភេទ

---

Maria Palombino, “តើអំពើប្រល័យពូជសាសន៍អាចអាចស្រូបបញ្ចូលក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិបាន ឬ ទេ ?” *ព្រឹត្តប័ត្រស្តីពីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ*, វ៉ុល ៣, (ឆ្នាំ ២០០៥), ទំព័រ ៧៨៣។

[649]ព្រឹត្តប័ត្ររបស់ Mettraux, Guénaëll *ស្តីពីបទឧក្រិដ្ឋអន្តរជាតិ និងតុលាការមិនអចិន្ត្រៃយ៍*, ទំព័រ ៣១៨។

[650]*សូមមើលជាទូទៅ* សាលដីកាក្នុងរឿងក្តី *Čelebići*, មិនជំទាស់ដាច់ដោយឡែករបស់ចៅក្រម David Hunt and Judge Mohamed Bennouna។ *សូមមើលផងដែរ*ព្រឹត្តប័ត្ររបស់ Mettraux, Guénaëll *ស្តីពីបទឧក្រិដ្ឋអន្តរជាតិ និងតុលាការមិនអចិន្ត្រៃយ៍*, ទំព័រ ៣១៨។

ដែលនិយមន័យនោះបានកើតចេញ ដូចជា ពីទំនៀមទម្លាប់ ឬសន្ធិសញ្ញា រួមផ្សំជាមួយនឹងការកែសម្រួលខាងនយោបាយផងនោះ និយមន័យទាំងនេះមិនបានរក្សាអត្ថន័យរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនជាប្រព័ន្ធ ដូចជានិយមន័យនៅថ្នាក់ជាតិនោះទេ។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kupreškić* ដោយផ្អែកតាមបទឧក្រិដ្ឋដែលមានចែងក្នុងលក្ខន្តិកៈរបស់តុលាការ ICTY បានកត់សម្គាល់ថា៖

> ខុសពីបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាតិ ឬប្រទេសដែលមិនប្រកាន់ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង (common law) វិធាននៃច្បាប់ព្រហ្មទណ្ឌដែលមានចែងយ៉ាងច្បាស់ក្នុងយុត្តិសាស្ត្រដែលពាក់ព័ន្ធ ឬមាននៅក្នុងវិសោធនកម្មដែលកំណត់ដោយច្បាប់ មាត្រានីមួយៗ (...) ពុំបានកម្រិតខ្លួនឯងត្រឹមការកំណត់ចំណាត់ថ្នាក់តែមួយនៃអំពើដែលត្រូវបានកំណត់ន័យច្បាស់លាស់រួចហើយ ដូចជាអំពើមនុស្សឃាត ឬមនុស្សឃាតដោយចេតនា ឬដោយអចេតនា ចោរកម្ម ។ល។ នោះទេ។ ផ្ទុយទៅវិញ មាត្រាទាំងនេះ បានចែងគ្របយ៉ាងទូលំទូលាយចំពោះប្រភេទនៃបទល្មើសជាក្រុម ដែលមានធាតុផ្សំផ្នែកច្បាប់ទូទៅ (...)។ ឧទាហរណ៍ ការធ្វើមនុស្សឃាត ការធ្វើទារុណ្ណកម្ម ឬការរំលោភលើផ្លូវភេទលើជនស៊ីវិលដែលស្ថិតក្នុងក្រុមបដិបក្ខ តាមធម្មតាបង្កើតបានជាបទឧក្រិដ្ឋសង្គ្រាម ប៉ុន្តែប្រសិនបើអំពើទាំងអស់នេះ គឺជាផ្នែកមួយនៃការអនុវត្តទូលំទូលាយ ឬជាប្រព័ន្ធ នោះគេអាចកំណត់និយមន័យរបស់វាថាជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិបាន[651]។

២៩៣. ពាក់ព័ន្ធនឹងការត្រួតគ្នានេះ មានការខិតខំទាំងផ្នែកយុត្តិសាស្ត្រ និងអក្សរសាស្ត្រ ដើម្បីផ្តល់រូបមន្តសម្រាប់ដោះស្រាយបញ្ហាត្រួតគ្នានៃបទឧក្រិដ្ឋអន្តរជាតិ ដែលកើតចេញពីទ្រឹស្តីនៃច្បាប់ព្រហ្មទណ្ឌជាតិ ដូចជាភាពខុសគ្នានៃផលប្រយោជន៍ដែលទទួលបានការការពារ[652] និងការ

---

[651]សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៦៩៧ ដល់ ៦៩៨។

[652]*សូមមើល ឧទា. រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kayishema និង Ruzindana*, សំណុំរឿងលេខ ICTR-95-1-T "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៦៣៥។ សាលក្រមក្នុង*រឿងក្តី Akayesu*, កថាខណ្ឌ ៤៦៨។

ត្រួតគ្នាច្បាស់លាស់ ជាក់ស្តែង និងពិតប្រាកដ[653]។ មានការលើកឡើងផងដែរថា បុរេលក្ខខណ្ឌផ្នែកច្បាប់ ឬធាតុផ្សំតាមបរិបទនៅក្នុងការកំណត់និយមន័យនៃបទឧក្រិដ្ឋដែលមិនមានអានុភាពទៅលើអំពើជាក់ស្តែងរបស់ជនជាប់ចោទទេនោះ គប្បីមិនត្រូវយកមកពិចារណាឡើយ[654] ឬមានការលើកឡើងថា លក្ខណៈវិនិច្ឆ័យនេះគប្បីត្រូវបង្កើតឡើងសម្រាប់ប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណបទឧក្រិដ្ឋដែលមានការកត់សម្គាល់ជាងគេ[655]។ ទស្សនទានទាំងនេះ ពុំទទួលបានការគាំទ្រទូលំទូលាយក្នុងយុត្តិសាស្ត្ររបស់តុលាការនោះទេ[656]។

២៩៤. អង្គជំនុំជម្រះតុលាការកំពូល កម្រិតសាលដីការបស់ខ្លួនមកត្រឹមតែបណ្តឹងសាទុក្ខដែលមាននៅចំពោះមុខនាពេលបច្ចុប្បន្នតែប៉ុណ្ណោះ មានន័យថា គឺជាការយកលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* មកអនុវត្តលើធាតុផ្សំ*សត្យានុម័ត* និង*អត្តនោម័ត*នៃបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានធាតុផ្សំ*តាមបរិបទ*តែមួយ។ ទោះបីជាយ៉ាងណាក៏ដោយ ការពិភាក្សាវែកញែកអំពីការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នានេះ មានការជាប់ពាក់ព័ន្ធទៅនឹងអ្វី ដែលជាការព្រួយបារម្ភដែលកើតមាននៅក្នុងតុលាការ *មិនអចិន្ត្រៃយ៍*ទាក់ទងទៅនឹងការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយធ្វើឱ្យមានការខ្វែងយល់គ្នារវាងចៅក្រមនៅក្នុងយុត្តិសាស្ត្រ

---

[653] *សូមមើល ឧទា.* សាលដីកាក្នុង*រឿងក្តី* *Čelebići*, កថាខណ្ឌ ៤០៧។ សាលក្រមក្នុង*រឿងក្តី* *Kupreškić*, កថាខណ្ឌ ៦៦២, ៦៧៨ ដល់ ៦៩៥។ សាលក្រមក្នុង*រឿងក្តី* *Akayesu*, កថាខណ្ឌ ៤៦៧។

[654] សាលដីកាក្នុង*រឿងក្តី* *Čelebići*, មតិជំទាស់ដាច់ដោយឡែករបស់ចៅក្រម David Hunt និងចៅក្រម Mohamed Bennouna, កថាខណ្ឌ ២៦ និងកថាខណ្ឌបន្តបន្ទាប់។

[655] សាលក្រម និងការផ្តន្ទាទោសក្នុង*រឿងក្តី* *Semanza*, មតិជំទាស់របស់ចៅក្រម Dolenc, កថាខណ្ឌ ១៤, ១៧ ដល់ ១៩, ២២ ដល់ ២៦។ ព្រឹត្តប័ត្ររបស់ Olaoluwa Olusanya *ស្តីពីការកាត់ទោសពីរដងដោយគ្មានដែនកំណត់៖ នការកំណត់បទចោទជាថ្មីក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, បោះពុម្ពផ្សាយដោយ Intersentia ឆ្នាំ ២០០៤, ទំព័រ ២៤១ ដល់ ២៥៥។ ព្រឹត្តប័ត្ររបស់ Fulvio Maria Palombino "តើអំពើប្រល័យពូជសាសន៍គួរស្រូបបញ្ចូលក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សបានដែរឬទេ?", ទំព័រ ៧៨៩។

[656] ព្រឹត្តប័ត្ររបស់ Gerhard Werle *ស្តីពីគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, បោះពុម្ពលើកទី ២, ទំព័រ ២៤៤ ដល់ ២៤៥, ជើងទំព័រ ៥៨៣ ដល់ ៥៨៥។

របស់តុលាការ ដូចដែលបានលើកឡើងនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងនៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

២៩៥. ជាទូទៅ យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិពិចារណាថា លក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* បម្រើផលប្រយោជន៍យុត្តិធម៌ ដោយធានាថា ការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ ពិតជាឆ្លុះបញ្ចាំងដោយត្រឹមត្រូវ និងពេញលេញអំពីវិសាលភាពនៃអំពើល្មើសរបស់ជនជាប់ចោទ[657]។ នៅពេលទន្ទឹមគ្នានេះ មានការទទួលស្គាល់ថា ការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា(ពិរុទ្ធភាពត្រួតគ្នា)បង្កើតឱ្យមានព្យសនកម្មធ្ងន់ធ្ងរចំនួនបី ដល់សិទ្ធិរបស់ជនជាប់ចោទ: ទីមួយ ជនជាប់ចោទត្រូវប្រឈមនឹងភាពអាម៉ាសក្នុងសង្គម ដោយការសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋបន្ថែមទៀត។ ទីពីរ ការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា(ពិរុទ្ធភាពត្រួតគ្នា)អាចធ្វើឱ្យការផ្តន្ទាទោសមានកម្រិតខ្ពស់ និងប៉ះពាល់ជាអវិជ្ជមានដល់លទ្ធភាពក្នុងការទទួលបានការដោះលែងឱ្យមានសេរីភាពមុនពេលកំណត់ ដោយអនុលោមតាមច្បាប់របស់រដ្ឋស្តីពីការអនុវត្តទោស និងទីបី អាចមានហានិភ័យដល់ការបង្កើនទណ្ឌកម្មនៅពេលសម្រេចដាក់ពិរុទ្ធភាពជាបន្តបន្ទាប់ ដោយអនុវត្តតាមច្បាប់ស្តីពីជនល្មើសមិនរាងចាល[658]។ នៅពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងបកស្រាយអំពីការព្រួយបារម្ភទូទៅពីរចំណុច ហើយផលប៉ះពាល់ជាក់លាក់នៃការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ដែលពាក់ព័ន្ធនឹងស្ថានភាពរបស់ជនជាប់ចោទ នឹងត្រូវបកស្រាយ នៅផ្នែកខាងក្រោម។

---

[657]សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១០៣៣ ("លក្ខណៈវិនិច្ឆ័យនៃការដាក់ពិរុទ្ធភាពត្រួតគ្នាមានគោលបំណងពីរគឺ ធានាថា ជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធញភាពតែបទល្មើសផ្សេងដាច់ដោយឡែកពីគ្នាប៉ុណ្ណោះ ហើយក៏ធានាថា ការសម្រេចដាក់ពិរុទ្ធភាពត្រូវតែឆ្លុះបញ្ចាំងទាំងស្រុងនូវឧក្រិដ្ឋភាពរបស់ជនជាប់ចោទ")។

[658]សាលដីកាក្នុង*រឿងក្តី Čelebići*, មតិជំទាស់ជំទាស់ដាច់ដោយឡែករបស់ចៅក្រម Hunt និង Bennouna, កថាខណ្ឌ ២៣។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Mučić, Delic និង Landžo*, សំណុំរឿងលេខ IT-96-21-A*bis*, "សាលដីកាលើបណ្តឹងសាទុក្ខស្តីពីការផ្តន្ទាទោស", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៣, កថាខណ្ឌ ២៥។ សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez*, មតិជំទាស់រួមរបស់ចៅក្រម Schomburg និងចៅក្រម Güney ទៅលើការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា, កថាខណ្ឌ ២។

២៩៦. ដោយពិចារណាទៅលើភាពអាម៉ាសក្នុងសង្គមដែលថា ជនជាប់ចោទប្រឈមការសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋ"បន្ថែម" អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការអនុវត្តតាមលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* មិនបណ្តាលឱ្យមានព្យសនកម្មដោយពុំសមហេតុផលទៅលើជនជាប់ចោទនោះទេ។ ដោយសារតែអំពើរបស់ជនជាប់ចោទបានបំពេញធាតុផ្សំបទឧក្រិដ្ឋច្រើន ភាពអាម៉ាសដែលខ្លួនត្រូវទទួល គឺជាផលដ៏សមរម្យនៃការសម្រេចដាក់ពិរុទ្ធភាពតាមផ្លូវច្បាប់។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ការជំទាស់ទៅនឹងគោលការណ៍បទល្មើសត្រួតគ្នា (*concursus delictorum*) ផ្ទុយទៅវិញបានផ្តល់នូវការបរិយាយដ៏ត្រឹមត្រូវផ្នែកច្បាប់ចំពោះអំពើឧក្រិដ្ឋ ដើម្បីឱ្យមានលក្ខណៈច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ហើយមិនធ្វើឱ្យមានការច្របូកច្របល់ ឬភ័ន្តច្រឡំទាក់ទងទៅនឹងអំពើល្មើសដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវពិតប្រាកដមែន។ ទោះបីជា មានការកត់សម្គាល់ឃើញថា "ការកើតឡើងនូវគោលការណ៍បទល្មើសត្រួតគ្នា (*concursus delictorum*) និងវិធីសាស្ត្រសម្រាប់ដោះស្រាយ គឺជាការបង្ហាញអំពីភាពស្របគ្នាផ្ទៃក្នុង ភាពស្មុគស្មាញ ភាពសមហេតុផលទូទៅនៃច្បាប់ព្រហ្មទណ្ឌ"[659] និងដោយកត់សម្គាល់ឃើញទៀតថា "នេះមិនមែនជាបញ្ហាស្តីពីវចនាបទ ឬទ្រឹស្តីនោះទេ ដោយហេតុថា កង្វះនូវភាពស្របគ្នាផ្ទៃក្នុងអាចបណ្តាលឱ្យមានការរំខានមានកំហុសផ្នែកវិជ្ជាជីវៈតុលាការ និងភាពអយុត្តិធម៌"[660]ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា គ្មានភាពអយុត្តិធម៌នឹងត្រូវកើតឡើងជាស្វ័យប្រវត្តិ ដោយការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា(ពិរុទ្ធភាពត្រួតគ្នា) ដោយយោងទៅលើលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* នោះទេ។

២៩៧. នៅពេលពិចារណាអំពីព្យសនកម្មដែលអាចប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់លក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* អង្គជំនុំជម្រះតុលាការកំពូល

---

[659] ព្រឹត្តប័ត្ររបស់ Carl-Friedrich Stuckenberg, "ដំណោះស្រាយសម្រាប់គោលការណ៍បទល្មើសត្រួតគ្នានៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ?", *វេទិការច្បាប់ព្រហ្មទណ្ឌ*, វ៉ុល ១៦, ( ឆ្នាំ ២០០៥), ទំព័រ ៣៦២។

[660] ព្រឹត្តប័ត្ររបស់ Stuckenberg, "ដំណោះស្រាយសម្រាប់គោលការណ៍បទល្មើសត្រួតគ្នា នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ?", ទំព័រ ៣៦២។

កត់សម្គាល់ថា "ពុំមានភស្តុតាងច្បាស់លាស់ដែលថា ការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា(ពិរុទ្ធភាពត្រួតគ្នា)ចំពោះអំពើដូចគ្នា អាចបណ្ដាលឱ្យមានការផ្ដន្ទាទោសកាន់តែធ្ងន់ធ្ងរ" ឬអាចបណ្ដាល ឱ្យមានការជំនុំជម្រះបន្តបន្ទាប់លើជនជាប់ចោទ នៅចំពោះមុខតុលាការអន្តរជាតិ ចំពោះអង្គហេតុដូចគ្នានោះទេ[661]។ នៅក្នុងប្រព័ន្ធតុលាការជាតិ ក៏មានការប្រើប្រាស់រូបមន្តផ្សេងៗគ្នា ដែលធ្វើឱ្យការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ត្រូវបានបន្ធូរបន្ថយផងដែរ[662]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី *Čelebići* កំណត់ថា "គោលដៅរួមទូទៅក្នុងការផ្ដន្ទាទោស គឺត្រូវតែធានាថា ការប្រកាសទោសចុងក្រោយ ឬទោសរួម បានឆ្លុះបញ្ចាំងពីស្ថានភាពទាំងអស់នៃ*អំពើ*ឧក្រិដ្ឋ និងពិរុទ្ធភាពរួមរបស់ចារី"[663]។ ក្នុងករណីដែលមិនមាននិយាមជាក់លាក់សម្រាប់កំណត់អំពីផលវិបាកនៃការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា នៅពេលផ្ដន្ទាទោស គឺជាតួនាទីរបស់តុលាការក្នុងការធានាថា ជនជាប់ចោទ "មិនត្រូវទទួលរងព្យសនកម្មដោយសារ ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាលើជនជាប់ចោទ ដោយផ្អែកទៅលើអង្គហេតុដូចគ្នានោះទេ"[664]។

២៩៨. សរុបសេចក្ដីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសនោះទេ ក្នុងការដែលយកលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្ដី *Čelebići* មកធ្វើជាសេចក្ដីណែនាំរបស់ខ្លួន។ លក្ខណៈវិនិច្ឆ័យនេះបានធានាជាអប្បបរមាថា ដើម្បីធ្វើការវិនិច្ឆ័យពីបទល្មើសត្រួតគ្នាចំពោះអំពើតែមួយ បទល្មើសទាំងឡាយត្រូវតែមានលក្ខណៈដាច់ដោយឡែកពីគ្នាទាំងស្រុង ហើយលក្ខណៈវិនិច្ឆ័យនេះ ក៏កំណត់ផងដែរអំពីលទ្ធផលសមស្របមួយ ពោលគឺការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ដែលបង្ហាញយ៉ាងពេញលេញនូវវិសាលភាពនៃបទដ្ឋានគតិយុត្តដែលត្រូវបានរំលោភបំពាន។ បន្ថែមលើនេះទៀត លក្ខណៈវិនិច្ឆ័យនេះ ក៏បានកំណត់ផងដែរអំពីលទ្ធផលដ៏សមស្របមួយ នៅពេលដែលបទល្មើសច្រើនមិនមានភាពដាច់ដោយ

---

[661]ព្រឹត្តប័ត្ររបស់ Stuckenberg, "ដំណោះស្រាយសម្រាប់គោលការណ៍បទល្មើសត្រួតគ្នា នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ?", ទំព័រ ៣៦២។

[662]ព្រឹត្តប័ត្ររបស់ Stuckenberg "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា", ទំព័រ ៥៨៦ ដល់ ៦០៣។

[663]សាលដីកាក្នុង*រឿងក្ដី Čelebići*, កថាខណ្ឌ ៤៣០ (សេចក្ដីបញ្ជាក់បន្ថែម)។

[664]ព្រឹត្តប័ត្ររបស់ Mettraux *បទឧក្រិដ្ឋអន្តរជាតិ និងតុលាការមិនអចិន្ត្រៃយ៍*, ទំព័រ ៣១៩។

ឡែកពីគ្នាទាំងស្រុង ហើយត្រូវបានសម្រេចដាក់ពិរុទ្ធភាពចំពោះតែបទល្មើសជាក់លាក់ ដោយអនុវត្តនូវ *គោលការណ៍ច្បាប់ពិសេស* ដែលជាគោលការណ៍ទូទៅមួយនៃច្បាប់អន្តរជាតិ[665]។

២៩៩. ផ្ទុយទៅវិញ នៅពេលបទល្មើសដែលត្រូវបានចោទប្រកាន់នោះ មានភាពដាច់ដោយឡែកពីគ្នាទាំងស្រុង ការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសតែមួយ គឺមិនបានការពារតម្លៃនៃសង្គមផ្សេងៗគ្នា ដែលជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋខុសៗគ្នាទាំងនោះទេ។ ចៅក្រម Shahabuddeen បានផ្តល់សំអាងហេតុនៅក្នុងរឿងក្តី *Jelisić* នៅតុលាការ ICTY ថា៖

> ទោះបីជាអំពើជាក់ស្តែង អាចដូចគ្នាក៏ដោយ ក៏បទឧក្រិដ្ឋអាចបណ្តាលឱ្យមានព្យសនកម្មដល់ផលប្រយោជន៍សាធារណៈផ្សេងៗគ្នា។ អត្ថិភាពនៃផលប្រយោជន៍សាធារណៈផ្សេងៗគ្នា អាចបង្ហាញឱ្យឃើញកាន់តែច្បាស់អំពីធាតុផ្សំពិសេសដោយឡែកពីគ្នា (...)។ ការការពារផលប្រយោជន៍សង្គមផ្សេងៗគ្នាទាំងនេះ តម្រូវឱ្យមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា។ ការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសតែមួយ គឺជាការមើលរំលងទៅលើព្យសនកម្មចំ ពោះផលប្រយោជន៍ផ្សេងៗទៀតនៃសង្គមអន្តរជាតិ និងមិនបានបរិយាយឱ្យពេញលេញ នូវវិសាលភាពនៃអំពើឧក្រិដ្ឋរបស់ជនជាប់ចោទ[666]។

៣០០. ជាទីបញ្ចប់ ភាពសមស្របនៃលក្ខណៈវិនិច្ឆ័យនេះសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានបញ្ជាក់ឱ្យឃើញថា បន្ទាប់ពីបានចេញសាលដីកាក្នុងរឿងក្តី *Čelebići* នៅក្នុងឆ្នាំ ២០០១ រួចមក អង្គជំនុំជម្រះនានានៅតុលាការ ICTY, ICTR និង SCSL និងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានអនុវត្តដោយស្របៗគ្នាទៅលើលក្ខណៈវិនិច្ឆ័យនេះ និងបានអនុញ្ញាតឱ្យមានការចោទប្រកាន់ត្រួតគ្នា ហើយសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា(ពិរុទ្ធភាពត្រួតគ្នា)ចំពោះ

---

[665]សាលក្រមក្នុង*រឿងក្តី Kupreškić*, កថាខណ្ឌ ៦៨៣ ដល់ ៦៨៤។ ព្រឹត្តប័ត្ររបស់ Stuckenberg, "ពហុភាពនៃបទល្មើស៖ គោលការណ៍បទល្មើសត្រួតគ្នា", ទំព័រ ៥៨៦ ដល់ ៥៨៨។ ព្រឹត្តប័ត្ររបស់ Antonio Cassese ដែលមានចំណងជើងថា *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, បោះពុម្ពលើកទីពីរ ចេញផ្សាយដោយសាកលវិទ្យាល័យ Oxford, ឆ្នាំ ២០០៨, ទំព័រ ១៨២។

[666]*សូមមើលរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Jelisić*, សំណុំរឿងលេខ IT-95-10-A "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០១, យោបល់ជំទាស់ដោយផ្នែករបស់ចៅក្រម Shahabuddeen, កថាខណ្ឌ ៤២។

អំពើដូចគ្នា ដែលអំពើនេះស្របតាមនិយមន័យនៃបទល្មើសអន្តរជាតិច្រើនដែលបទល្មើសទាំងនេះត្រូវបានយល់ឃើញថា មានលក្ខណៈខុសៗគ្នាជាសត្យានុម័ត[667]។

---

[667] *សូមមើលឧទា.* សាលដីកាក្នុង*រឿងក្តី* Jelisić, កថាខណ្ឌ ៨២។ សាលដីកាក្នុង*រឿងក្តី* Kordić *និង* Čerkez, កថាខណ្ឌ ១០៣៣។ សាលដីកាក្នុង*រឿងក្តី* Naletilić *និង* Martinović, កថាខណ្ឌ ៥៨៩ ដល់ ៥៩០ (ដែលអនុញ្ញាតឱ្យមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទធ្វើទារុណកម្ម)។ សាលដីកាក្នុង*រឿងក្តី* Stakić, កថាខណ្ឌ ៣៦៦ (ដែលអនុញ្ញាតឱ្យមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ បទធ្វើមនុស្សឃាត និងអំពី អមនុស្សធម៌ផ្សេងទៀត)។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Strugar, សំណុំរឿងលេខ IT-01-42-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨, ("សាលដីកាក្នុង*រឿងក្តី* Strugar"), កថាខណ្ឌ ៣២១ ដល់ ៣២២។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Krajišnik, សំណុំរឿងលេខ IT-00-39-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ ("សាលដីកាក្នុង*រឿងក្តី* Krajišnik"), កថាខណ្ឌ ៣៨៦ (ដែលសម្រេចតម្កល់ការអនុវត្តលក្ខណៈវិនិច្ឆ័យក្នុង*រឿងក្តី* Čelebići)។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* D. Milošević, សំណុំរឿងលេខ IT-98-29/1-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ("សាលដីកាក្នុង*រឿងក្តី* D. Milošević"), កថាខណ្ឌ ៣៩។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Popović, សំណុំរឿងលេខ (IT-05-88-T), "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០, ("សាលក្រមក្នុង*រឿងក្តី* Popović"), កថាខណ្ឌ ២១១១។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Musema, សំណុំរឿងលេខ ICTR-96-13, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០១, ("សាលដីកាក្នុង*រឿងក្តី* Musema"), កថាខណ្ឌ ៣៥៨ ដល់ ៣៦៩ ("អង្គជំនុំជម្រះតុលាការកំពូលសម្រេចដម្កល់ថា លក្ខណៈវិនិច្ឆ័យក្នុង*រឿងក្តី* Čelebići គឺជាលក្ខណៈវិនិច្ឆ័យសម្រាប់អនុវត្តចំពោះការដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា ដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់តុលាការ ICTR")។ សាលដីកាក្នុង*រឿងក្តី* Nahimana, កថាខណ្ឌ ១០២៦ ដល់ ១០២៧។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Brima *និងជនដទៃទៀត* (*រឿងក្តី* AFRC), សំណុំរឿងលេខ SCSL-04-16-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ ("សាលក្រមក្នុង*រឿងក្តី* AFRC"), កថាខណ្ឌ ២០៩៩ (ដែលបានអនុវត្តលក្ខណៈវិនិច្ឆ័យក្នុង*រឿងក្តី* Čelebići សម្រាប់ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា)។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Sesay *និងជនដទៃទៀត*, សំណុំរឿងលេខ SCSL-04-15-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៩ ("សាលដីកាក្នុង *រឿងក្តី* Sesay"), កថាខណ្ឌ ១១៩០។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Bemba Gombo, សំណុំរឿងលេខ ICC-01/05-01/08, "សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១ (៧) (ក) និង (ខ)នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីបទចោទប្រឆាំងនឹង Jean-Pierre Bemba Gombo", អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩, កថាខណ្ឌ ២០២ ("អង្គជំនុំជម្រះពិចារណាឃើញថា សម្រាប់ភាពយុត្តិធម៌ និងកិច្ចដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស មានតែបទល្មើសដាច់ពីដោយឡែកពីគ្នាទេ ដែលអាចជាយុត្តិកម្មសម្រាប់ការចោទប្រកាន់រួមបាន ហើយចុងក្រោយបង្អស់ នឹងត្រូវបានបញ្ជាក់ថាជាបទចោទ។ នេះគឺជាតែមួយគត់ ដរាបណាបទប្បញ្ញត្តិនៃលក្ខន្តិកៈនីមួយៗដែលរងការចោទថា រងការរំលោភបំពាន ជុំវិញអំពើប្រព្រឹត្តិមួយដែលដូចគ្នា តម្រូវថា យ៉ាងហោចណាស់ធាតុផ្សំជាសត្យានុម័តបន្ថែមនេះខុសប្លែកពីគ្នា"។

## ៤.ច.២.បទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយយោងតាមលក្ខណៈវិនិច្ឆ័យ ក្នុងរឿងក្តី *Čelebići*

៣០១. អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិនិត្យ ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដែរ ឬយ៉ាងណា ក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ចំពោះបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទត្រូវបានរកឃើញថា ជាអ្នកត្រូវទទួលខុសត្រូវពីបទ ដូចជា មនុស្សឃាត សម្លាប់រង្គាល ធ្វើឱ្យទៅជាទាសករ ដាក់ក្នុងមន្ទីរឃុំឃាំង ធ្វើទារុណកម្ម (រួមបញ្ចូលការរំលោភផ្លូវភេទមួយករណី) និងអំពើអមនុស្សធម៌ផ្សេងៗទៀត[668]។ នៅក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រូវបានអនុញ្ញាតឡើយ ដោយហេតុថា៖

> នៅពេល ប្រៀបធៀបជាមួយបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ធាតុផ្សំបន្ថែមនៃបទធ្វើទុក្ខបុកម្នេញ ត្រូវតែជាចេតនារើសអើងពីសំណាក់ចារី (...)។
>
> យុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* បានធ្វើការពិចារណាយ៉ាងលម្អិតទៅលើទំនាក់ទំនងរវាងបទធ្វើទុក្ខបុកម្នេញ និងបទល្មើសមូលដ្ឋានដទៃទៀត ដែលអាចមានការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញ។ ទោះបីជា យុត្តិសាស្ត្ររបស់តុលាការមុនៗមានទស្សនៈមួយផ្សេងពីនេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ទំនងជាមានទំនោរទៅរកការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ចំពោះបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកលើហេតុផលថា បទធ្វើទុក្ខបុកម្នេញមានធាតុផ្សំខុសគ្នាជាសត្យានុម័ត ពីធាតុផ្សំនៃបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

[668] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧៧។

នៅក្នុងសាលដីកានៃរឿងក្តី *Kordić និងជនដទៃទៀត* ដែលឆ្លុះបញ្ចាំងនូវយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបង្ហាញថា មានចៅក្រមពីររូបក្នុងចំណោមចៅក្រមប្រាំរូប បានជំទាស់ថា ការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញ អាចដាក់ត្រួតលើការសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលដែលការសម្រេចដាក់ពិរុទ្ធភាពទាំងនេះបានផ្អែកទៅលើអំពើឧក្រិដ្ឋដូចគ្នា ។ ដោយសារតែមានភាពខុសគ្នារវាងធាតុផ្សំបទធ្វើទុក្ខបុកម្នេញ និងបទល្មើសមូលដ្ឋានដទៃទៀតនៅពេលពិចារណាក្នុងន័យអរូបិយ ទើបមានបញ្ហាលើកឡើង ថាតើធាតុផ្សំទាំងនេះមានលក្ខណៈខុសគ្នា*ជាសត្យានុម័ត* ដែរឬយ៉ាងណា បើយោងតាមលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ។ ថាតើបទល្មើសនីមួយៗមានធាតុផ្សំ ដែលតម្រូវឱ្យមានការបង្ហាញភស្តុតាងថា មិនមាននៅក្នុងបទល្មើសដទៃទៀត ដែរ ឬយ៉ាងណា។ ឧទាហរណ៍ ប្រសិនបើ ការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញត្រូវបានសំអាងទៅលើអំពើមនុស្សឃាត ឬអំពើអមនុស្សធម៌ ហើយបទចោទប្រកាន់ មានភស្តុតាងបង្ហាញច្បាស់លាស់ អយ្យការមិនចាំបាច់បង្ហាញភស្តុតាងបន្ថែម ដើម្បីបញ្ជាក់ពីពិរុទ្ធភាពចំពោះអំពើមនុស្សឃាត ឬអំពើអមនុស្សធម៌ឡើយ។ ភស្តុតាងដែលបង្ហាញថា ជនជាប់ចោទបានប្រព្រឹត្តអំពើធ្វើទុក្ខបុកម្នេញ តាមរយៈអំពើមនុស្សឃាត ឬអំពើអមនុស្សធម៌ *ចាំបាច់ត្រូវ*រួមបញ្ចូលភស្តុតាងនៃអំពើធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌ដទៃទៀត។ បទល្មើសទាំងនេះត្រូវបានស្រូបបញ្ចូលទៅក្នុងបទធ្វើទុក្ខបុកម្នេញ។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY គាំទ្រការអនុវត្តលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ប៉ុន្តែ ក៏បានយល់ស្របថា ចាំបាច់ត្រូវមានការរៀបរាប់ឱ្យបានលម្អិត អំពីការទទួលខុសត្រូវព្រហ្មទណ្ឌទាំងស្រុងរបស់ពិរុទ្ធជន នៅក្នុងផ្នែកសម្រេចសេចក្តី ហេតុដូច្នេះ ត្រូវចង្អុលបង្ហាញនូវអំពើជាក់លាក់ ដែលជាមូលដ្ឋានក្នុងការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញ[669]។

៣០២. សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា ជាក់ស្តែង លក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* នាំឱ្យមានលទ្ធផលផ្ទុយពីនេះត្រង់ចំណុចថា បទធ្វើទុក្ខបុកម្នេញមិនបានបង្ហាញឱ្យឃើញថា មានការស្រូបបញ្ចូលនូវបទល្មើសណាមួយនៃបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំង

[669]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៣ ដល់ ៥៦៥ (សេចក្តីដកស្រង់ត្រូវបានលុបចោល)។

មនុស្សជាតិ ដែលជនជាប់ចោទត្រូវបានរកឃើញថា ជាអ្នកទទួលខុសត្រូវជាបុគ្គលនោះទេ ដោយហេតុថា "បទឧក្រិដ្ឋមូលដ្ឋាននីមួយៗនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (...) សុទ្ធតែមានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត"[670]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា ៖ ការខកខានក្នុងការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ធ្វើឱ្យអន្តរាយដល់គោលបំណងទ្វេរនៃលក្ខណៈវិនិច្ឆ័យចំពោះការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា (...) ហើយបទដ្ឋាននៃការមិនអនុញ្ញាតឱ្យមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា មិនអាចអនុវត្តនៅក្នុងរឿងក្តីនេះបានទេ" ហើយសេចក្តីសម្រេចដែលស្របបញ្ចូលបទឧក្រិដ្ឋមូលដ្ឋានដទៃទៀត មិនបានឆ្លុះបញ្ចាំងឱ្យឃើញពីអត្ថប្រយោជន៍ដល់សង្គម នៅក្នុងកំណត់ហេតុជាប្រវត្តិសាស្ត្រពេលលេញមួយ ចំពោះអំពើឧក្រិដ្ឋរបស់ជនជាប់ចោទនោះឡើយ[671]។

៣០៣. ដើម្បីសម្រេចលើផ្នែកនេះ នៅក្នុងទឡ្ហីករណ៍ទីពីរនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា ការអនុញ្ញាតឱ្យមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាសម្រាប់អំពើឧក្រិដ្ឋដូចគ្នា ត្រូវតែបានបំពេញទៅតាមលក្ខខណ្ឌតម្រូវដែលចែងថា "បទប្បញ្ញត្តិនៃច្បាប់លក្ខន្តិកៈដែលពាក់ព័ន្ធនីមួយៗ មានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត ដែលធាតុផ្សំនេះ មិនមាននៅក្នុងបទប្បញ្ញត្តិនៃច្បាប់លក្ខន្តិកៈដទៃទៀត"[672]។ ក្នុងន័យនេះជាការចាំបាច់ក្នុងការស្វែងយល់ឱ្យបានត្រឹមត្រូវទៅលើអត្ថន័យនៃពាក្យពេចន៍ដែលថា "ធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត"នោះ។ ដូចដែលបានធ្វើការកត់សម្គាល់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY នៅក្នុងរឿងក្តី *Čelebići* បានកំណត់និយមន័យនៃពាក្យពេចន៍នេះថា ជាធាតុផ្សំមួយដែល"តម្រូវឱ្យមានការបង្ហាញភស្តុតាងដែលមិនមាននៅក្នុងបទល្មើសដទៃទៀតឡើយ"[673]។

---

[670]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣៤។

[671]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣៤។

[672]សាលដីកាក្នុង *រឿងក្តី Čelebići*, កថាខណ្ឌ ៤១២។

[673]សាលដីកាក្នុង *រឿងក្តី Čelebići*, កថាខណ្ឌ ៤១២។

៣០៤. ត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* សម្រាប់ការអនុវត្តនូវលក្ខខណ្ឌតម្រូវ នៅក្នុងបរិបទមួយដែល ថាតើអាចមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា។ បើទោះជា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា សាលដីកាក្នុងរឿងក្តី *Kordić* និង *Čerkez* នៅតុលាការ ICTY និងសេចក្តីសម្រេចក្រោយៗរបស់តុលាការ ICTY និង ICTR បានសម្រេចថា បទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័តក៏ដោយ[674] ក៏អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សំអាងហេតុនៃមតិជំទាស់នៅក្នុងសាលដីកាក្នុងរឿងក្តី *Kordić* និង *Čerkez* មានលក្ខណៈគួរឱ្យជឿបាន ហើយអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា សំអាងហេតុនេះឆ្លុះបញ្ចាំងពី"យុត្តិសាស្ត្រដែលអង្គជំនុំជម្រះនោះ បានបង្កើតកន្លងមក"[675]។

៣០៥. ហេតុដូច្នេះ ជាដំបូង អង្គជំនុំជម្រះតុលាការកំពូល ត្រូវពិចារណាទៅលើទំនាក់ទំនងយុត្តិសាស្ត្រពាក់ព័ន្ធរបស់តុលាការសម្រាប់ជាការណែនាំក្នុងការកំណត់ ថាតើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញត្រឹមត្រូវ ដែរ ឬយ៉ាងណា ទៅលើពាក្យពេចន៍"ធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត" ដោយយោងតាមលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ទាក់ទងនឹងការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខ្លួនមិនត្រូវបានជាប់កាតព្វកិច្ចដោយសេចក្តីសម្រេចនៅក្នុងសាលដីកាក្នុងរឿងក្តី *Kordić* និង *Čerkez* និងយុត្តិសាស្ត្រក្រោយៗទៀតនៃសាលដីកានេះ ឬក៏យុត្តិសាស្ត្រពីមុនណាមួយរបស់តុលាការ *មិនអចិន្ត្រៃយ៍* នោះទេ។ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងចាត់ទុកសេចក្តីសម្រេចរបស់តុលាការទាំងនេះថា ជាឯកសារសំអាងផ្លូវច្បាប់ ដែលមានលក្ខណៈគួរឱ្យជឿជាក់បាន ហើយអង្គជំនុំជម្រះតុលាការកំពូលនឹងអនុវត្តវិធីសាស្ត្រមួយដែលខ្លួនយល់

[674]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៤

[675]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៥។

ឃើញថា ត្រឹមត្រូវទៅតាមផ្លូវច្បាប់។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលនឹងយកសំអាងហេតុនោះ មកអនុវត្តចំពោះបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទត្រូវបានរកឃើញថា ជាអ្នកទទួលខុសត្រូវនៅក្នុងរឿងក្តីនេះ ហើយធ្វើការពិនិត្យលើធាតុផ្សំបទឧក្រិដ្ឋទាំងនោះ ដូចដែលបានបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង ឬ ដូចដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ[676]។

### *៤.ច.២.ក.យុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍*

៣០៦. ដើម្បីដោះស្រាយបញ្ហានៅក្នុងរឿងក្តីទីមួយរបស់ខ្លួន ពោលគឺ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Kupreškić និង ជនដទៃទៀត* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[677]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា អំពើមនុស្សឃាត និងអំពើធ្វើទុក្ខបុកម្នេញ គឺជាបទល្មើសដាច់ដោយឡែកពីគ្នាដោយបានផ្តល់សំអាងហេតុថា បទល្មើសទាំងពីរនេះ មាន“ធាតុផ្សំពិសេសរៀងៗខ្លួន” ដែលបទធ្វើមនុស្សឃាតតម្រូវឱ្យមាន

[676]ដូចបានកត់សម្គាល់រួចមកហើយនៅក្នុងសាលដីកានេះ វិសាលភាពនៃបណ្តឹងសាទុក្ខដែលមាននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធទៅនឹងអំពើជាមូលដ្ឋាននានា ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវបានកម្រិតមកត្រឹមការពិចារណាលើអំពើធ្វើទុក្ខបុកម្នេញ អំពើធ្វើទារុណកម្ម និង អំពើធ្វើឱ្យទៅជាទាសករ។ ហេតុដូច្នេះ នៅក្នុងផ្នែកស្តីពីការការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា អង្គជំនុំជម្រះនឹងអនុវត្តធាតុផ្សំនានានៃបទឧក្រិដ្ឋជាក់លាក់ទាំងនោះដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលត្រូវបានកំណត់នៅក្នុងបណ្តឹងសាទុក្ខនេះ។ សម្រាប់បទឧក្រិដ្ឋនៅសេសសល់នានានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចោទប្រកាន់នោះ ដែលជនជាប់ចោទត្រូវបានរកឃើញថាជាអ្នកទទួលខុសត្រូវ ចំពោះអំពើដូចជា អំពើសម្លាប់រង្គាល (រួមបញ្ចូលអំពើធ្វើមនុស្សឃាត) អំពើដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត អង្គជំនុំជម្រះនឹងអនុវត្តធាតុផ្សំដូចដែលអង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់រួចមកហើយ ដែលសហព្រះរាជអាជ្ញាមិនបានជំទាស់លើបញ្ហានេះ។ ហើយសម្រាប់បទឧក្រិដ្ឋដែលនៅសេសសល់នានានៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយដែលត្រូវបានចោទប្រកាន់នោះ ដែលជនជាប់ចោទត្រូវបានរកឃើញថាមានការទទួលខុសត្រូវ ដែលមានដូចជា ការសម្លាប់រង្គាល (រួមទាំងការធ្វើមនុស្សឃាតផងដែរ) ការដាក់ឱ្យជាប់ឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀតនោះ អង្គជំនុំជម្រះនឹងអនុវត្តធាតុផ្សំ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់រួចមកហើយ ហើយដែលសហព្រះរាជអាជ្ញាមិនបានជំទាស់លើបញ្ហានេះ។

[677]សាលក្រមក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៧០៥ ដល់ ៧១០។

ភស្តុតាងបង្ហាញអំពី "ការដកហូតដោយចេតនានូវជីវិតរបស់ជនស៊ីវិលដែលគ្មានកំហុស" រីឯបទធ្វើទុក្ខបុកម្នេញវិញ តម្រូវឱ្យមានភស្តុតាងបង្ហាញអំពី"ចេតនារើសអើង"[678]។ ហេតុដូច្នេះ បទល្មើសទាំងពីរនេះបំពេញនូវលក្ខខណ្ឌតម្រូវរបស់ប្រព័ន្ធច្បាប់*ស៊ីវិល* (Civil Law) ស្តីពីលក្ខណៈពិសេសដែលអាចជំនួសគ្នាបាន ដែលបានឆ្លុះបញ្ចាំងនៅក្នុងលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Blockburger* នៅសហរដ្ឋអាមេរិក[679]។ ហេតុដូច្នេះ អង្គជំនុំជម្រះនេះយល់ឃើញថា បុគ្គលម្នាក់អាចត្រូវបានចោទប្រកាន់ត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ (ដោយសារតែមានអំពើជាច្រើនត្រូវបានចោទ រួមទាំងអំពើមនុស្សឃាត) និងបទធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយអំពើមនុស្សឃាតដូចគ្នានេះដែលត្រូវបានបង្ហាញថា គ្មានវិមតិសង្ស័យ អាចនាំទៅដល់ការសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋទាំងពីរនេះ[680]។ នៅក្នុងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានយល់ស្របថា ជាទូទៅ ការចោទប្រកាន់ត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចអនុវត្តទៅបាន[681]។ ប៉ុន្តែ នៅចុងក្រោយ អង្គជំនុំជម្រះនេះមិនបានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទធ្វើមនុស្សឃាតលើជនជាប់ចោទនោះទេ ដោយសារតែជនជាប់ចោទបានបោះបង់នូវបណ្តឹងសាទុក្ខរបស់ខ្លួន[682]។

៣០៧. សាលដីកាក្រោយៗមកទៀតនៅតុលាការ ICTY បានច្រានចោលនូវការដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលពិនិត្យលើអំពើជាក់លាក់ដែលជាមូលដ្ឋានក្នុងការសម្រេចដាក់ពិរុទ្ធភាពទាំងនេះ ដែលផ្ទុយទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *Kurpreškić* ។ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krnojelac* អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនូវលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* ចំពោះការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញ និងបទដាក់ក្នុងមន្ទីរ

[678]សាលក្រមក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៧០៦ និង ៧០៨។
[679]សាលក្រមក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៧០៦ និង ៧០៨។
[680]សាលក្រមក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៧០៦ ដល់ ៧០៨។
[681]សាលដីកាក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៣៨៤។
[682]សាលដីកាក្នុង *រឿងក្តី Kupreškić*, កថាខណ្ឌ ៣៨៥។

ឃុំឃាំង ព្រមទាំងអំពើអមនុស្សធម៌ផ្សេងទៀតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងអំពើឧក្រិដ្ឋដូចគ្នា[683]។ ជាចុងក្រោយ អង្គជំនុំជម្រះនេះបានសម្រេចដាក់ពិរុទ្ធភាពតែពីបទធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ តែមិនបានសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ ហើយអង្គជំនុំជម្រះនេះបានផ្តល់សំអាងហេតុថា "ដោយសារតែមានភាពច្បាស់លាស់ដែលថា បទដាក់ក្នុងមន្ទីរឃុំឃាំង និង អំពើអមនុស្សធម៌ផ្សេងទៀត គ្មានធាតុផ្សំណាមួយដែលដាច់ដោយឡែកជាសត្យានុម័តពីធាតុផ្សំបទធ្វើទុក្ខបុកម្នេញឡើយ។ ដោយហេតុថា បទធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានធាតុផ្សំដាច់ដោយឡែកជាសត្យានុម័ត គឺអំពើរើសអើង និងចេតនារើសអើងនោះ ទើបការតម្រូវនេះគឺជាបទប្បញ្ញត្តិមួយ ដែលមានលក្ខណៈជាក់លាក់ជាងលក្ខខណ្ឌតម្រូវដទៃទៀត"[684]។ ដូចគ្នានេះដែរ បើទោះជា ការដាក់ពិរុទ្ធភាពត្រួតគ្នាមិនមែនជាបញ្ហាមួយក្នុងចំណោមបញ្ហានានាដែលត្រូវលើកឡើងនៅក្នុងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសម្រេចថា ការដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញក្នុងទម្រង់នៃអំពើអមនុស្សធម៌នានាតាមរយៈការវាយធ្វើបាបនោះ ត្រូវស្រូបបញ្ចូលទាំងការដាក់ពិរុទ្ធភាពពីបទអំពើអមនុស្សធម៌ផ្សេងទៀតនៅក្នុងឧក្រិដ្ឋប្រឆាំងមនុស្សជាតិ នៅពេលដែលការសម្រេចដាក់ពិរុទ្ធភាពទាំងពីរនេះ បានផ្អែកទៅលើអង្គហេតុដូចគ្នា[685]។

៣០៨. ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង* *Vasiljević* ជនជាប់ចោទត្រូវបានចោទពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដូចជា អំពើមនុស្សឃាត អំពើអមនុស្សធម៌នានា និងអំពើធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើមូលដ្ឋាននៃអំពើដូចគ្នា[686]។ នៅពេលអនុវត្តលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY យល់ឃើញថា អំពើធ្វើទុក្ខបុកម្នេញ គឺជាបទល្មើសជាក់លាក់ជាងគេ ដោយផ្អែកលើមូលដ្ឋានថា បន្ថែមពីលើ

---

[683]សាលក្រមក្នុង*រឿងក្តី Krnojelac*, កថាខណ្ឌ ៥០២ ដល់ ៥០៣។

[684]សាលក្រមក្នុង*រឿងក្តី Krnojelac*, កថាខណ្ឌ ៥០៣។

[685]សាលដីកាក្នុង*រឿងក្តី Krnojelac*, កថាខណ្ឌ ១៨៨ (ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការសម្រេចរបស់ខ្លួន អង្គជំនុំជម្រះមិនបានយោងទៅលើ ឬអនុវត្តលក្ខណៈវិនិច្ឆ័យក្នុង*រឿងក្តី Čelebići* នោះទេ)។

[686]សាលដីកាក្នុង*រឿងក្តី Vasiljević*, កថាខណ្ឌ ១៣៥។

ធាតុផ្សំតម្រូវសម្រាប់បទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញតម្រូវឱ្យមាន "ធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត គឺអំពើរើសអើង និងចេតនារើសអើង"[687]។ ដោយយល់ស្របទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសម្រេចថា មិនត្រូវសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាលើជនជាប់ចោទពីបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[688]។

៣០៩. នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krstić* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានអនុវត្តវិធីសាស្ត្រប្រហាក់ប្រហែលគ្នានេះដែរ ក្នុងការសម្រេចបដិសេធនូវសំណើរបស់រដ្ឋអាជ្ញាដែលសុំឱ្យមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងទៀត ជាមួយនឹងបទធ្វើទុក្ខបុកម្នេញ ដែលបទធ្វើទុក្ខបុកម្នេញនេះត្រូវបានប្រព្រឹត្តឡើងតាមរយៈបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[689]។ នៅក្នុងរឿងក្តី *Krstić* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចមិនដាក់ពិរុទ្ធភាពលើជនជាប់ចោទដែលជាឧត្តមសេនីយ៍ជនជាតិបូស្នីសែប (Bosnian Serb) ពីបទធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកលើមូលដ្ឋានថា បទឧក្រិដ្ឋទាំងពីរនេះត្រូវបាន"ស្រូបបញ្ចូលទៅក្នុងបទធ្វើទុក្ខបុកម្នេញ"[690]។ ស្របតាមការអះអាងរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY លើបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានពិនិត្យទៅលើការប្រព្រឹត្តអំពើល្មើសជាមូលដ្ឋាន[691]។ អង្គជំនុំជម្រះនេះយល់ឃើញថា នៅពេលដែល"អំពើធ្វើទុក្ខបុកម្នេញត្រូវបានផ្អែកលើអំពើមនុស្សឃាត និងអំពើអមនុស្សធម៌នានា ហើយការចោទប្រកាន់លើអំពើទាំងនេះមានភស្តុតាង

---

[687]សាលដីកាក្នុង*រឿងក្តី Vasiljević*, កថាខណ្ឌ ១៤៦។

[688]សាលដីកាក្នុង*រឿងក្តី Vasiljević*, កថាខណ្ឌ ១៣៥ និង ១៤៦។

[689]*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Krstić*, សំណុំរឿងលេខ IT-98-33-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤, ("សាលដីកាក្នុង*រឿងក្តី Krstić*"), កថាខណ្ឌ ២៣១ ដល់ ២៣៣។

[690]សាលដីកាក្នុង*រឿងក្តី Krstić*, កថាខណ្ឌ ២៣០។

[691]សាលដីកាក្នុង*រឿងក្តីKrstić*, កថាខណ្ឌ ២៣២។

បង្ហាញនោះ អយ្យការមិនចាំបាច់បង្ហាញភស្តុតាងបន្ថែមណាមួយ ដើម្បីគាំទ្រដល់ការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌ផ្សេងទៀតឡើយ”[692]។

៣១០. ទោះជាយ៉ាងនេះក៏ដោយ សាលដីកានាពេលថ្មីៗមួយចំនួននៅតុលាការ ICTY បានបកស្រាយ និងអនុវត្តលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ដោយស្របគ្នា ដែលបានអនុញ្ញាតឱ្យមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលដែលអំពើធ្វើទុក្ខបុកម្នេញនេះត្រូវបានប្រព្រឹត្តឡើងតាមរយៈអំពើនានា ដែលជាបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងឆ្នាំ ២០០៤ ក្នុងរឿងក្តី *Kordić* និង រឿងក្តី *Čerkez* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសម្រេចបដិសេធសេចក្តីសម្រេចមុនៗរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានស្របបញ្ចូលបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងបទធ្វើទុក្ខបុកម្នេញ ហើយនៅពេលអង្គជំនុំជម្រះនេះបានអនុញ្ញាតឱ្យមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ ព្រមទាំងពីបទធ្វើមនុស្សឃាត អំពើអមនុស្សធម៌ផ្សេងៗទៀត និងបទដាក់ក្នុងមន្ទីរឃុំឃាំងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[693]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY យល់ឃើញថា “មូលហេតុដែលគួរឱ្យជឿបាន” តម្រូវឱ្យមានការអនុវត្តខុសពីរឿងក្តីមុនៗ ពីព្រោះរឿងក្តីទាំងនោះមិនបានអនុវត្តត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ដែលបាន“ធ្វើការបដិសេធយ៉ាងច្បាស់នូវវិធីសាស្ត្រមួយដែលចាត់ទុកអំពើជាក់ស្តែងរបស់ជនជាប់ចោទជាកត្តាកំណត់អំពីបញ្ហា ថាតើការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាចំពោះអំពើល្មើសនេះ អាចអនុវត្តបាន ដែរ ឬយ៉ាងណា”នោះទេ[694]។ បន្ថែមលើនេះទៀត រឿងក្តីទាំងនេះ មានលក្ខណៈផ្ទុយទៅនឹងយុត្តិសាស្ត្ររបស់តុលាការនៅក្នុងរឿងក្តី *Jelisić,* រឿងក្តី *Kupreškić,* រឿងក្តី *Kunarać* និងរឿងក្តី *Musema* ទាក់ទងទៅនឹងការអនុវត្តលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* ពីព្រោះ រឿងក្តីទាំងនេះ បានពិនិត្យទៅលើ

---

[692]សាលដីកាក្នុង*រឿងក្តី Krstić,* កថាខណ្ឌ ២៣២។

[693]សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez,* កថាខណ្ឌ ១០៤៤។

[694]សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez,* កថាខណ្ឌ ១០៤០។

អំពើរបស់ជនជាប់ចោទ ជាជាងទៅលើធាតុផ្សំផ្លូវច្បាប់នៃបទល្មើសមូលដ្ឋានដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់លក្ខន្តិកៈ[695]។ ហេតុដូច្នេះ អង្គជំនុំជម្រះនេះយល់ឃើញថា ដោយអនុវត្តដ៏សមស្របនូវលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* អំពើធ្វើទុក្ខបុកម្នេញមានធាតុផ្សំដាច់ដោយឡែកជាសត្យានុម័តពីអំពើមនុស្សឃាត អំពើអមនុស្សធម៌ផ្សេងទៀត និងអំពើដាក់ក្នុងមន្ទីរឃុំឃាំង ដែលជាបទល្មើសមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីព្រោះបទធ្វើទុក្ខបុកម្នេញ តម្រូវឱ្យមានភស្តុតាងបង្ហាញពីចេតនារើសអើងជាក់លាក់ និងការរើសអើងជាក់ស្តែង នៅពេលដែលបទល្មើសមូលដ្ឋាននីមួយៗនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានភស្តុតាងបង្ហាញអំពី*ធាតុផ្សំសត្យានុម័ត* (*actus reus*) ជាក់លាក់មួយដែលមិនមាននៅក្នុងនិយមន័យនៃបទធ្វើទុក្ខបុកម្នេញឡើយ[696]។

៣១១. សាលក្រមបន្តបន្ទាប់មកទៀតនៅតុលាការ ICTY បានអនុវត្តដោយស្របគ្នាតាមសំអាងហេតុដែលមាននៅក្នុងសាលដីកាក្នុងរឿងក្តី *Kordić* និង *Čerkez* ពាក់ព័ន្ធនឹងការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Stakić អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានផ្អែកដោយផ្ទាល់ទៅលើសេចក្តីសម្រេចនៅក្នុងសាលដីកាក្នុងរឿងក្តី *Kordić* និង *Čerkez* ដែលអនុញ្ញាតឱ្យមានការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ បទសម្លាប់រង្គាល បទជម្លៀស និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយសំអាងលើមូលដ្ឋានថា បទឧក្រិដ្ឋនីមួយៗតម្រូវឱ្យមានភស្តុតាងបង្ហាញអំពីធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័តដែលមិនមាននៅក្នុងបទឧក្រិដ្ឋដទៃទៀត[697]។

៣១២. ដូចគ្នានេះដែរ នៅក្នុងរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង* Naletilić *និង* Martinović អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY អនុវត្តតាមការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Kordić* និង *Čerkez* ទៅលើលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ហើយ

---

[695]សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១០៤០។

[696]សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១០៤១ ដល់ ១០៤៣។

[697]សាលដីកាក្នុង*រឿងក្តី Stakić*, កថាខណ្ឌ ៣៥៦, ៣៥៩ ដល់ ៣៦៦។

បានដំកល់ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទធ្វើទារុណកម្ម ដោយផ្អែកទាំងស្រុងលើការប្រៀបធៀបរវាងធាតុផ្សំផ្លូវច្បាប់បទឧក្រិដ្ឋនីមួយៗ[698]។ នៅក្នុងរឿងក្តី *Naletilić* និង *Martinović* អង្គជំនុំជម្រះនេះបានសម្រេចប្រហាក់ប្រហែលគ្នានេះដែរថា ការពិនិត្យលើអំពើជាមូលដ្ឋាននៃបទល្មើស មិនមែនជាការពិចារណាដ៏សមស្របនោះទេ បើយោងតាមការអនុវត្តលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* នៅក្នុងបរិបទនេះ[699]។

៣១៣. ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Krajišnik* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសម្រេចបដិសេធនូវអំណះអំណាងរបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ដែលលើកឡើងប្រឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[700]។ អង្គជំនុំជម្រះនេះ បានចង្អុលបង្ហាញអំពីការកើនឡើងនៃរឿងក្តី ដែលអនុវត្តតាមការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Kordić* និង *Čerkez* ទៅលើលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ដោយយល់ឃើញថា "ពុំមានមូលហេតុដែលគួរឱ្យជឿបាន ក្នុងការមិនអនុវត្តតាមយុត្តិសាស្ត្ររបស់តុលាការនាពេលបច្ចុប្បន្ននេះទេ ពាក់ព័ន្ធទៅនឹងការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាដូចមានចែងនៅក្នុងមាត្រា ៥ នៃលក្ខន្តិកៈរបស់តុលាការ ICTY"[701]។

៣១៤. រឿងក្តីចំនួនពីរដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក៏បានដោះស្រាយលើបញ្ហានៃការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Popović* អង្គជំនុំជម្រះនេះយល់ឃើញថា បទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានអនុញ្ញាតឱ្យសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា

---

[698]សាលដីកាក្នុង*រឿងក្តី Naletilić និង Martinović*, កថាខណ្ឌ ៥៩០។

[699]សាលដីកាក្នុង*រឿងក្តី Naletilić និង Martinović*, កថាខណ្ឌ ៥៩០។

[700]*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Krajišnik*, សំណុំរឿងលេខ IT-00-39-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ ("សាលដីកាក្នុង*រឿងក្តី Krajišnik*"), កថាខណ្ឌ ៣៨៩ ដល់ ៣៩១។

[701]សាលដីកាក្នុង*រឿងក្តី Krajišnik*, កថាខណ្ឌ ៣៨៩ និង៣៩១។

ដោយមិនចាំបាច់ធ្វើការពិចារណា ទៅលើធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័តនោះទេ[702]។ ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Dordević អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានដកស្រង់ពីសាលដីកាក្នុងរឿងក្តី *Kordić* និង *Čerkez* ហើយបានយល់ឃើញថា ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា មានលក្ខណៈសមស្របចំពោះបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បើទោះជា បទឧក្រិដ្ឋទាំងពីរនេះ បានផ្អែកលើអំពើល្មើសជាមូលដ្ឋានដូចគ្នាក៏ដោយ[703]។ បើទោះជារឿងក្តីទាំងពីរនេះ កំពុងរង់ចាំការសម្រេចនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលក៏ដោយ ក៏មានការបញ្ជាក់ច្បាស់ថា ការអនុវត្តលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* របស់អង្គជំនុំជម្រះតុលាការតុលាការកំពូលនៅក្នុងរឿងក្តី *Kordić* និង *Čerkez* ចំពោះការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា បានក្លាយទៅជាយុត្តិសាស្ត្រជាក់លាក់ទៅហើយ នៅតុលាការ ICTY។

៣១៥. តុលាការ ICTR ក៏បានពិចារណាលើការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមការអនុវត្តលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* នេះផងដែរ។ នៅក្នុងឆ្នាំ ២០០៧ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTR បានសម្រេចអនុវត្តតាមវិធីសាស្ត្រក្នុងរឿងក្តី *Kordić* និង *Čerkez* ក្នុងការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Nohimana *និងជនដទៃទៀត* ដែលក្នុងរឿងក្តីនេះ ជនជាប់ចោទចំនួនបីរូប ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងជនជាតិ Tutsis បន្ថែមពីលើបទសម្លាប់រង្គាល និងបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[704]។ ជនជាប់ចោទពីររូបនៅក្នុងរឿងក្តី *Nohimana និងជនដទៃទៀត*នេះ បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទសម្លាប់រង្គាល និងបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកលើ

---

[702]សាលក្រមក្នុង *រឿងក្តី Popović*, កថាខណ្ឌ ២១១៣។

[703]សាលក្រមក្នុង *រឿងក្តី Dordević*, កថាខណ្ឌ ២១៩៦ ដល់ ២២០០។

[704]សាលដីកាក្នុង *រឿងក្តី Nohimana*, កថាខណ្ឌ ២ ដល់ ៤ និង ៦។

មូលដ្ឋានថា បទធ្វើទុក្ខបុកម្នេញ"ខ្វះធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័តមួយ ដែលត្រូវតែបង្ហាញថា មិនមែនជាធាតុផ្សំនៅក្នុងបទសម្លាប់រង្គាលនោះទេ"[705]។ នៅពេលសម្រេចតម្កល់ការដាក់ពិរុទ្ធភាពត្រួតគ្នា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានដកស្រង់ដោយផ្ទាល់ពីយុត្តិសាស្ត្រជាក់លាក់របស់តុលាការ ICTY ក្នុងរឿងក្តី *Kordić* និង *Čerkez* ហើយធ្វើការសម្រេចថា "បទសម្លាប់រង្គាល តម្រូវឱ្យមានភស្តុតាងបង្ហាញថា ជនជាប់ចោទបានបង្កឱ្យមនុស្សជាច្រើននាក់ស្លាប់បាត់បង់ជីវិត" ទាំងនេះមានលក្ខណៈខុសប្លែកពីបទធ្វើទុក្ខបុកម្នេញដែល"តម្រូវឱ្យមានភស្តុតាងបង្ហាញថា អំពើសកម្ម ឬអកម្មណាមួយ គឺជាអំពើរើសអើងជាក់ស្តែង ហើយអំពើសកម្ម ឬអកម្មនេះ ត្រូវបានប្រព្រឹត្តឡើងដោយចេតនារើសអើងជាក់លាក់"[706]។ នៅក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* តុលាការ ICTR បានបដិសេធចំពោះការវិភាគអំពីការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ដែលបានសំអាងលើអំពើល្មើសជាមូលដ្ឋាន[707]។

### ៤.ច.២.ខ.ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នានៅក្នុងរឿងក្តីនេះ

៣១៦. យោងតាមសំអាងហេតុខាងក្រោម អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងការបកស្រាយ និងការអនុវត្តបច្ចុប្បន្នរបស់តុលាការ ICTY និង ICTR នូវលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* ដែលអាចមានការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញ និងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកលើមូលដ្ឋាននៃអំពើល្មើសដូចគ្នា។

៣១៧. ចំណុចទីមួយ នៅពេលផ្អែកលើសំអាងហេតុនៃមតិជំទាស់នៅក្នុងរឿងក្តី *Kordić* និង *Čerkez* អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តដោយពុំត្រឹមត្រូវជាសារវន្តលើលក្ខខណ្ឌតម្រូវនៃ"ធាតុផ្សំ

[705] សាលដីកាក្នុង *រឿងក្តី Nohimana*, កថាខណ្ឌ ១០២៤។

[706] សាលដីកាក្នុង *រឿងក្តី Nohimana*, កថាខណ្ឌ ១០២៦, ដកស្រង់ចេញពីសាលដីកាក្នុង *រឿងក្តី Stakić*, កថាខណ្ឌ ៣៦៤ និង ៣៦៧។

[707] សាលដីកាក្នុង *រឿងក្តី Nohimana*, កថាខណ្ឌ ១០២៦។

ដាច់ដោយឡែកពីគ្នាជាសត្យានុម័ត”យោងតាមលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići*[708]។ មតិជំទាស់នៅក្នុងរឿងក្តី *Kordić* និង *Čerkez* ព្រមទាំងរឿងក្តី *Naletilić* និង *Martinović* ផ្តល់សំអាងហេតុថា បទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែយល់ថាគ្រាន់តែជា“ទម្រង់មួយ” មានតួនាទី“មិនសំខាន់ដែលបង្កើតឡើងដើម្បីគ្របដណ្តប់លើរាល់អំពើដទៃទៀត ដែលអាចជាបទល្មើសមូលដ្ឋាន”[709]។ យោងតាមការយល់បែបនេះ *ធាតុផ្សំសត្យានុម័ត* និង*ធាតុផ្សំអត្តនោម័ត*នៃអំពើធ្វើទុក្ខបុកម្នេញ គឺជា*ធាតុផ្សំ*នៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលត្រូវបានកំណត់តាមរយៈអង្គហេតុ។ ដូច្នេះ ការរកឃើញពីអំពើធ្វើទុក្ខបុកម្នេញ ចាំបាច់ត្រូវដាក់បញ្ចូលនូវធាតុផ្សំបទល្មើសមូលដ្ឋានទាំងនេះ។ ដូច្នេះ ភាពខុសគ្នាតែមួយគត់រវាងបទធ្វើទុក្ខបុកម្នេញ និងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលស្របបញ្ចូលទៅក្នុងបទធ្វើទុក្ខបុកម្នេញ គឺស្ថិតនៅត្រង់លក្ខខណ្ឌតម្រូវនៃភស្តុតាងជាក់លាក់ និងបន្ថែមនូវការរើសអើងនៅក្នុង*ធាតុផ្សំអត្តនោម័ត* និងការរើសអើងជាក់ស្តែងនៅក្នុងធាតុផ្សំសត្យានុម័ត។ ក្នុងន័យនេះ ការធ្វើទុក្ខបុកម្នេញអាចត្រូវបានបកស្រាយថាជាធាតុផ្សំតាមបរិបទ ឬជាកត្តាចេតនាធ្ងន់ធ្ងរចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ប៉ុន្តែ ពុំមែនជាបទល្មើសមួយដែលមានធាតុផ្សំដាច់ដោយឡែកជាសត្យានុម័តនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បន្ថែមពីលើគោលការណ៍ដែលមាននៅក្នុងយុត្តិសាស្ត្រពីមុនរបស់តុលាការ ICTY ការយល់ឃើញរបស់អ្នកប្រាជ្ញមួយចំនួន ក៏បានគាំទ្រចំពោះការយល់ឃើញបែបនេះ ឬប្រហាក់ប្រហែលគ្នាចំពោះការធ្វើទុក្ខបុកម្នេញនេះផងដែរ[710]។

---

[708]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៥។

[709]សាលដីកាក្នុង*រឿងក្តី Naletilić និង Martinović*, មតិជំទាស់ដោយផ្នែកដាច់ដោយឡែករបស់ចៅក្រម Schomburg, កថាខណ្ឌ ៩។ សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez* មតិជំទាស់រួមគ្នារបស់ចៅក្រម Schomburg និងចៅក្រម Guney, កថាខណ្ឌ ៦។

[710]*សូមមើលឧទា.* ព្រឹត្តប័ត្រនិពន្ធដោយ M. Cherif Bassiouni ដែលមានចំណងជើងថា “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”, បោះពុម្ពលើកទីពីរ, Kluwer Law International, ទំព័រ ២៥៩។ “មាត្រា ៦(គ) សំដៅលើ “ការធ្វើទុក្ខបុកម្នេញ” និងបញ្ហាចោទលេចឡើងចំពោះករណី ថាតើពាក្យនេះមានបំណងបង្កើតជាបទល្មើសជាក់លាក់មួយផ្សេងទៀតដែរ ឬក៏យ៉ាងណា ឬក៏ពាក្យនេះមានបំណងបង្ហាញនូវ “សកម្មភាព ឬគោលនយោបាយរបស់រដ្ឋ”។ នៅក្នុងទស្សនៈរបស់អ្នកនិពន្ធពាក្យនេះមានបំណងដោយសមហេតុផលសំដៅលើ “សកម្មភាព ឬគោលនយោបាយរបស់រដ្ឋ” ហេតុដូច្នេះពាក្យនេះត្រូវ

ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ការយល់ឃើញនេះពុំមែនជាការទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងថា ជានិយមន័យនៃអំពើធ្វើទុក្ខបុកម្នេញ ដែលមានជាធរមាននៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក ឡើយ។ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា ការធ្វើទុក្ខបុកម្នេញ គឺជាបទល្មើសជាក់លាក់ និងដាច់ដោយឡែកមួយ[711] ហើយការប្រៀបធៀបដោយយោងតាមលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* គួរតែបានធ្វើឡើងដោយគោរពទៅតាមនិយមន័យជាក់ស្តែងដែលបានអនុវត្ត ប៉ុន្តែមិនគោរពទៅតាមការបកស្រាយពីអំពើធ្វើទុកបុកម្នេញថា គ្រាន់តែជា"ទម្រង់មួយ"ប៉ុណ្ណោះនោះទេ។

៣១៨. ដូចអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់រួចមកហើយ[712] នៅពេលធ្វើការប្រៀបធៀបបទធ្វើទុក្ខបុកម្នេញ ជាមួយនឹងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* លក្ខខណ្ឌតម្រូវចំពោះ"ធាតុផ្សំដាច់ដោយឡែកជាសត្យានុម័ត" សម្រាប់ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា មានន័យថា ធាតុផ្សំនៅក្នុងនិយមន័យនៃអំពើធ្វើទុក្ខបុកម្នេញ ត្រូវទាមទារឱ្យមានការបង្ហាញភស្តុតាង ដែលពុំមាននៅក្នុងធាតុផ្សំនៃបទល្មើសមូលដ្ឋានដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងផ្ទុយមកវិញ[713]។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តដោយពុំត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវ "ឱ្យមានការបង្ហាញភស្តុតាង ដែលពុំមាននៅក្នុងលក្ខណៈវិនិច្ឆ័យផ្សេងទៀត" សម្រាប់ធាតុផ្សំ ដាច់ដោយឡែកជាសត្យានុម័ត[714] ដោយអង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើ

---

បកស្រាយបន្ថែមលើពីពាក្យ "ការរើសអើង" (...) ។ ក៏ប៉ុន្តែករណីនេះពុំមែនមិនឲ្យពិចារណា"ការធ្វើទុក្ខបុកម្នេញ"ជាបទឧក្រិដ្ឋជាក់លាក់ដោយឡែកមួយនោះទេ ដែលខ្លឹមសារបទឧក្រិដ្ឋក្នុងរឿងក្តីនេះត្រូវកំណត់ជាមួយនឹងកម្រិតដ៏ជាក់លាក់មួយចំនួនដើម្បីបំពេញ"គោលការណ៍នីត្យានុកូលភាព"។ *សូមមើលផងដែរ*ព្រឹត្តប័ត្រនិពន្ធដោយ M. Cherif Bassiouni ដែលមានចំណងជើងថា *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*, បោះពុម្ពផ្សាយលើកទីពីរ, ទំព័រ ៣២៧។

[711]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៧៦ ដល់ ៣៨០។

[712]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦០។

[713]សាលដីកាក្នុង*រឿងក្តី Čelebići*, កថាខណ្ឌ ៤១២ ដល់ ៤១៣។

[714]សាលដីកាក្នុង*រឿងក្តី Čelebići*, កថាខណ្ឌ ៤១២។

ការញែកឱ្យដាច់ពីគ្នារវាងអង្គហេតុដែលមាន*លក្ខណៈគ្រប់គ្រាន់* ជាមួយនឹងអង្គហេតុដែល*ទាមទារឱ្យមាន*ការបង្ហាញភស្តុតាងអំពីធាតុផ្សំនៃអំពើធ្វើទុក្ខបុកម្នេញ និងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលចំណុចនេះ គឺជាចំណុចសំខាន់ក្នុងការយល់ដឹងអំពីលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići*។

៣១៩. អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការប្រៀបធៀប តាមរយៈឧទាហរណ៍រវាងធាតុផ្សំនៃអំពើធ្វើទុក្ខបុកម្នេញជាមួយនឹងអំពើសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាបទល្មើសមួយ ក្នុងចំណោមបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទត្រូវបានតុលាការរកឃើញថា ជាអ្នកទទួលខុសត្រូវនៅក្នុងរឿងក្តីនេះ។ ដូចបានលើកឡើងពីមុនមកនៅក្នុងសាលដីកានេះ អំពើធ្វើទុក្ខបុកម្នេញ គឺជា៖

> (១) នៅពេលពិចារណាតាមបរិបទ និងអំពីអានុភាពត្រួតគ្នា អំពើសកម្ម ឬអកម្មដែល (...) រើសអើងជាក់ស្តែង ដែលមានភាពធ្ងន់ធ្ងរ ឬស្ថានទម្ងន់ស្មើគ្នាទៅនឹងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបណ្តាលឱ្យមានការដកហូត ឬរំលោភលើសិទ្ធិជាសារវន្តដែលមានចែងនៅក្នុងច្បាប់សន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ (*ធាតុផ្សំសត្យានុម័ត*)។ និង
>
> (២) ការប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដែលមានចេតនារើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា (*ធាតុផ្សំអត្តនោម័ត*)។

៣២០. ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា អំពើសម្លាប់រង្គាល គឺជា៖

> (១) "អំពើសកម្ម អំពើអកម្ម ឬការដាក់បញ្ចូលគ្នានៃអំពើទាំងពីរ ដែលនាំឱ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ (*ធាតុផ្សំសត្យានុម័ត*)[715]។ និង

---

[715]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៣៤, ដកស្រង់ចេញពីសាលក្រមក្នុង*រឿងក្តី* Blagojević *និង* Jokic, កថាខណ្ឌ ៥៧២។ *រឿងក្តី រដ្ឋអាជ្ញាទល់នឹង* Seromba, ICTR-01-66-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៨, ("សាលដីកាក្នុង*រឿងក្តី* Seromba"), កថាខណ្ឌ ១៨៩។

(២) "ចេតនាក្នុងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬបង្ករបួសលើរូបកាយធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឱ្យមានការស្លាប់ ដោយមានការដឹងជាមុនដោយសមហេតុផលថា អំពើសកម្ម ឬ អកម្មនោះ អាចបង្កឱ្យបាត់បង់ជីវិតមនុស្សច្រើន (*ធាតុផ្សំអត្តនោម័ត*)[716]។

៣២១. ពាក់ព័ន្ធនឹង*ធាតុផ្សំសត្យានុម័ត*នៃអំពើធ្វើទុក្ខបុកម្នេញ ទោះបីភស្តុតាងបង្ហាញថា ជនជាប់ចោទបានបង្កឱ្យមានការបាត់បង់ជីវិតមនុស្សជាច្រើន ឬ*ធាតុផ្សំសត្យានុម័ត*នៃអំពើសម្លាប់រង្គាល មានលក្ខណៈ*គ្រប់គ្រាន់*ក្នុងការបំពេញផ្នែកខ្លះនៃធាតុផ្សំសត្យានុម័តនៃអំពើធ្វើទុក្ខបុកម្នេញក៏ដោយ ក៏ការបង្ហាញភស្តុតាងនៃអង្គហេតុនោះ ពុំមែនជា*លក្ខខណ្ឌតម្រូវ*ឡើយ។ នៅតែមានលទ្ធភាពបង្ហាញភស្តុតាងថា មានការធ្វើទុក្ខបុកម្នេញ ប្រសិនបើអំពើសកម្ម ឬអកម្មនោះបណ្តាលឱ្យមានការស្លាប់បាត់បង់ជីវិតជាក់ស្តែងនោះ។ ជាការពិត ប្រសិនបើ ចារីបានប្រព្រឹត្តអំពើមួយដែលជនរងគ្រោះទាំងឡាយបានទទួលរងត្រឹមតែរបួសយ៉ាងធ្ងន់ធ្ងរប៉ុណ្ណោះ នោះជនជាប់ចោទពុំអាចត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាលឡើយ ដោយហេតុថាលក្ខខណ្ឌតម្រូវនៃ*ធាតុផ្សំសត្យានុម័ត* ពុំត្រូវបានបំពេញ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលសន្មតថា រាល់ទិដ្ឋភាពផ្សេងទៀតនៃការកំណត់និយមន័យនៃអំពើធ្វើទុក្ខបុកម្នេញត្រូវបានបំពេញ ជនជាប់ចោទនៅតែអាចមានពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញ ដោយហេតុថា ការបង្ករបួសស្នាមបានបំពេញលក្ខខណ្ឌតម្រូវនៃ*ធាតុផ្សំសត្យានុម័ត*នៃបទធ្វើទុក្ខបុកម្នេញ ពោលគឺអំពើសកម្ម ឬអកម្ម ត្រូវមានភាពធ្ងន់ធ្ងរ ឬស្ថានទម្ងន់ស្មើគ្នាទៅនឹងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបណ្តាលឱ្យមានការដកហូត ឬរំលោភលើសិទ្ធិជាសារវន្ត។ ហេតុដូច្នេះ ការបង្ហាញភស្តុតាងដែលថា មនុស្សជាច្រើនត្រូវបានសម្លាប់នោះនឹងមានលក្ខណៈគ្រប់គ្រាន់ អាចបំពេញធាតុផ្សំសត្យានុម័តនៃបទធ្វើទុក្ខបុកម្នេញបានមួយផ្នែក។ ក៏ប៉ុន្តែ ពុំមានភាពចាំបាច់ក្នុងការបង្ហាញភស្តុតាងបែបនេះឡើយ។

[716] សាលក្រមអង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ ៣៣៨ ដកស្រង់ចេញពីសាលក្រមក្នុង*រឿងក្តី* *Bagosora*, កថាខណ្ឌ ២១៩១។ ការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងលើអំពើសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមាននៅក្នុងបណ្តឹងសាទុក្ខចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលទេ។ ហេតុដូច្នេះ នៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះតុលាការកំពូល ពុំពិនិត្យមើលឡើងវិញ ថាតើនិយមន័យនេះត្រឹមត្រូវតាមច្បាប់ ដែរ ឬ យ៉ាងណានោះឡើយ។

៣២២. ផ្ទុយមកវិញ ការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំជាក់ស្តែង គឺជា*លក្ខខណ្ឌតម្រូវ*ដែលទាមទារឱ្យបំពេញនៅក្នុង*ធាតុផ្សំសត្យានុម័ត*នៃបទសម្លាប់រង្គាល ពោលគឺ អំពើសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំនេះ គឺជាធាតុផ្សំដាច់ដោយឡែកជាសត្យានុម័តដោយយោងតាមលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ដែលទាមទារឱ្យមានការបង្ហាញភស្តុតាងនៃអង្គហេតុមួយ ដែលពុំមែនជាលក្ខខណ្ឌតម្រូវសម្រាប់អំពើធ្វើទុក្ខបុកម្នេញនោះទេ។ ប្រហាក់ប្រហែលគ្នានេះដែរ ទោះបីជាការបង្ហាញភស្តុតាងនៃអំពើសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ បានបំពេញ*ធាតុផ្សំសត្យានុម័ត*សម្រាប់បទសម្លាប់រង្គាលក៏ដោយ ក៏ការបង្ហាញភស្តុតាងបែបនេះ ពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការបំពេញ*ធាតុផ្សំសត្យានុម័ត*ចំពោះបទធ្វើទុក្ខបុកម្នេញឡើយ ប្រសិនបើការសម្លាប់នោះមិនបង្កើតបានជាការរើសអើងជាក់ស្តែងនោះទេ។ ដូច្នេះ *ធាតុផ្សំសត្យានុម័ត*សម្រាប់បទធ្វើទុក្ខបុកម្នេញ ក៏មានធាតុផ្សំដាច់ដោយឡែកជាសត្យានុម័ត ដែលទាមទារឱ្យមានការបង្ហាញភស្តុតាងនៃអង្គហេតុ ដែលពុំមានសម្រាប់បទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា អំពើសម្លាប់រង្គាលជាដើម។

៣២៣.ម្យ៉ាងវិញទៀត ឧទាហរណ៍នៃធាតុផ្សំដាច់ដោយឡែកជាសត្យានុម័តនេះ ពុំកម្រិតត្រឹមការពិនិត្យពិចារណាតែ*ធាតុផ្សំសត្យានុម័ត*នៃបទធ្វើទុក្ខបុកម្នេញប៉ុណ្ណោះទេ។ លក្ខខណ្ឌតម្រូវ*ធាតុផ្សំអត្តនោម័ត*នៃបទធ្វើទុក្ខបុកម្នេញ ដែលមានចេតនាគិតទុកជាមុនដោយជាក់លាក់ក្នុងការរើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា មានធាតុផ្សំ ដាច់ដោយឡែកជាសត្យានុម័ត ពី*ធាតុផ្សំអត្តនោម័ត*នៃបទសម្លាប់រង្គាល ដែលមានចេតនា សម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬបង្ករបួសខាងរូបកាយយ៉ាងធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលបណ្តាលឱ្យមានការបាត់បង់ជីវិតមនុស្ស ដោយបានដឹងជាមុនដោយសមហេតុផលថា អំពើសកម្ម ឬអកម្មនេះ នឹងអាចបណ្តាលឱ្យមានការបាត់បង់ជីវិតមនុស្សមានចំនួនដ៏ច្រើន។ បន្ថែមលើឧទាហរណ៍ខាងលើនេះ ដែលបទធ្វើទុក្ខបុកម្នេញ និងបទសម្លាប់រង្គាល ត្រូវបានផ្អែកលើអំពើដូចគ្នា ចារីដែលប្រព្រឹត្តអំពើសកម្ម ឬអកម្មលើក្រុមគោលដៅណាមួយ ដោយមូលហេតុនយោបាយ ដោយមានចេតនាគិតទុកជាមុនក្នុងការបង្ករបួសខាងរូបកាយ យ៉ាងធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលបណ្តាលឱ្យបាត់បង់ជីវិតមនុស្ស ប៉ុន្តែពុំបានដឹងដោយសម

ហេតុផល ថាតើអំពើសកម្ម ឬអកម្មនេះ នឹងអាចបណ្តាលឱ្យបាត់បង់ជីវិត មនុស្សមានចំនួនដ៏ច្រើន ដែរ ឬយ៉ាងណានោះទេ ករណីនេះគ្មានភស្តុតាងបង្ហាញពីការទទួលខុសត្រូវចំពោះអំពើសម្លាប់រង្គាលនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពបែបនេះ នៅតែបំពេញបាននូវលក្ខខណ្ឌតម្រូវនៃ*ធាតុផ្សំអត្តនោម័ត*នៃបទធ្វើទុក្ខបុកម្នេញដដែល។ ហេតុដូច្នេះ ការដឹងដោយសមហេតុផលថា អំពើសកម្ម ឬអកម្ម នឹងបណ្តាលឱ្យបាត់បង់ជិវិតមនុស្សមានចំនួនដ៏ច្រើន គឺជាអង្គហេតុមួយ ដែលត្រូវតែមានភស្តុតាងបង្ហាញថា អង្គហេតុនេះមិនតម្រូវឱ្យមានសម្រាប់អំពើធ្វើទុក្ខបុកម្នេញដែលធ្វើឱ្យ*ធាតុផ្សំអត្តនោម័ត*នៃបទសម្លាប់រង្គាល មានធាតុផ្សំដាច់ដោយឡែកមួយជាសត្យានុម័ត។ ផ្ទុយមកវិញ ក្នុងករណីដែលការដឹងជាមុនដោយសមហេតុផលត្រូវបានបង្ហាញ ប៉ុន្តែ ចេតនារើសអើងជាក់លាក់ពុំត្រូវបានបង្ហាញ នោះលក្ខខណ្ឌតម្រូវនៃ*ធាតុផ្សំអត្តនោម័ត*សម្រាប់បទសម្លាប់រង្គាលត្រូវបានបំពេញ ប៉ុន្តែ*ធាតុផ្សំអត្តនោម័ត*សម្រាប់បទធ្វើទុក្ខបុកម្នេញពុំត្រូវបានបំពេញឡើយ។ ហេតុដូច្នេះ ភស្តុតាងនៃចេតនារើសអើងជាក់លាក់ដែលតម្រូវឱ្យមានបានធ្វើឱ្យ*ធាតុផ្សំអត្តនោម័ត*នៃបទធ្វើទុក្ខបុកម្នេញ មានធាតុផ្សំដាច់ដោយឡែកមួយជាសត្យានុម័ត យ៉ាងពិតប្រាកដផងដែរ។

៣២៤. ចំណុចទីពីរ នៅពេលយកលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* មកអនុវត្ត អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការពិចារណាដែលបានផ្តោតទៅលើតែកាលៈទេសៈអង្គហេតុនៃអំពើល្មើស ជាជាងការផ្តោតទៅលើធាតុផ្សំផ្លូវច្បាប់ចំពោះបទល្មើសមូលដ្ឋាននីមួយៗនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចោទប្រកាន់ ដែលជាលក្ខខណ្ឌតម្រូវតាមលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* នោះ។ ទោះបីជា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថាខ្លួនត្រូវពិនិត្យពិចារណា នៅក្នុងការយល់ឃើញរបស់ខ្លួនអំពី"ធាតុផ្សំផ្លូវច្បាប់នៃបទល្មើសនីមួយៗដែលអាចជាកម្មវត្ថុនៃការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ជាជាងត្រូវពិនិត្យពិចារណាពីអង្គហេតុនៃបទល្មើសមូលដ្ឋាននោះ"[717]ក៏ដោយ ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងនៅតែបន្តពិនិត្យពិចារណាពីអង្គហេតុនៃបទល្មើសមូលដ្ឋានទាំងនោះ នៅពេលខ្លួនពិចារណាអំពីការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ដោយបានសន្និដ្ឋានថា៖

[717]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦១

ទោះបីជាធាតុផ្សំនៃបទធ្វើទុក្ខបុកម្នេញ និងបទល្មើសមូលដ្ឋានដទៃទៀត អាចមានលក្ខណៈខុសគ្នានៅពេលពិចារណាតាមបែបអរូបិយ ក៏ដោយ យោងតាមលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ក៏បញ្ហា ថាតើមានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត ដែរ ឬយ៉ាងណា ពោលគឺ ថាតើបទល្មើសមូលដ្ឋាននីមួយៗមានធាតុផ្សំដែលតម្រូវឱ្យមានភស្តុតាងនៃអង្គហេតុ ដែលមិនតម្រូវសម្រាប់បទល្មើសផ្សេងទៀត ដែរ ឬយ៉ាងណា។ ឧទាហរណ៍ នៅពេលបទធ្វើទុក្ខបុកម្នេញ មានមូលដ្ឋានលើអំពើធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌ ហើយមានភស្តុតាងបង្ហាញពីបទចោទនេះ នោះអយ្យការមិនចាំបាច់មានភស្តុតាងបង្ហាញអំពីអង្គហេតុបន្ថែមណាមួយក្នុងការធានាការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌ ឡើយ។ ភស្តុតាងដែលថា ជនជាប់ចោទបានប្រព្រឹត្តអំពើធ្វើទុក្ខបុកម្នេញ តាមរយៈអំពើធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌ ចាំបាច់ត្រូវរួមបញ្ចូលនូវភស្តុតាងនៃអំពើធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌ រួចទៅហើយ។ បទល្មើសទាំងនេះត្រូវបានស្រូបបញ្ចូលទៅក្នុងអំពើធ្វើទុក្ខបុកម្នេញដែល *មានលក្ខណៈជាក់លាក់ជាង*[718]។

៣២៥. ជាថ្មីម្តងទៀត អង្គជំនុំជម្រះតុលាការកំពូលមិនយល់ស្របជាមួយនឹងការយល់ឃើញខាងលើរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញយ៉ាងច្បាស់ថា ខ្លួនមិនពិចារណាអំពីធាតុផ្សំផ្លូវច្បាប់ និងភស្តុតាងនៃអង្គហេតុដែលតម្រូវឱ្យមានចំពោះធាតុផ្សំទាំងនេះ ដែលជាភស្តុតាងគាំទ្រអំពើជាមូលដ្ឋានសម្រាប់បទធ្វើមនុស្សឃាត ឬបទអំពើអមនុស្សធម៌ផ្សេងទៀត ហើយអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពុំចាំបាច់បង្ហាញពី *អំពើ* បន្ថែមទៀត ដើម្បីអាចសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសមូលដ្ឋានទាំងនោះឡើយ[719]។ ក៏ប៉ុន្តែ ជាការពិត ធាតុផ្សំផ្លូវច្បាប់“អរូបិយ” និងភស្តុតាងនៃអង្គហេតុដែលតម្រូវឱ្យមានចំពោះធាតុផ្សំទាំងនេះ ត្រូវយកមកធ្វើការប្រៀបធៀបនៅពេលវិភាគ

[718]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៥ (សម្រង់ត្រូវបានលុបចោល)។

[719]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៥។

00798577



អំពីការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា ជាជាងយកកាលៈទេសៈនៃអង្គហេតុជុំវិញអំពើមូលដ្ឋានមកវិភាគវិញ[720]។

៣២៦. ទោះបីជា ធាតុផ្សំផ្លូវច្បាប់ទាំងនេះ ទំនងជាមានអត្ថិភាពជាអរូបិយក៏ដោយ ក៏ធាតុផ្សំទាំងនេះពិតជាបង្កើតបាននូវលក្ខខណ្ឌតម្រូវដាច់ដោយឡែកពិតប្រាកដ ដើម្បីឱ្យអយ្យការធ្វើការបង្ហាញភស្តុតាងចំពោះបទល្មើសមូលដ្ឋាននីមួយៗដាច់ដោយឡែកពីគ្នា។ នៅពេលបន្តលើកឡើងនូវឧទាហរណ៍ខាងលើចំពោះអំពើសម្លាប់រង្គាល និងអំពើធ្វើទុក្ខបុកម្នេញ អយ្យការត្រូវបង្ហាញឱ្យឃើញថា មានការបាត់បង់ជីវិតមនុស្សមានចំនួនដ៏ច្រើនពិតប្រាកដ ដែលជាលទ្ធផលនៃអំពើសម្លាប់រង្គាលរបស់ជនជាប់ចោទ។ ក៏ប៉ុន្តែ ចំពោះអំពើធ្វើទុក្ខបុកម្នេញ អយ្យការត្រូវបង្ហាញថា អំពើនេះ បានរំលោភបំពានលើសិទ្ធិជាសារវន្ត និងមានការរើសអើងជាក់ស្តែង។ នៅក្នុងឧទាហរណ៍នេះ អំពើជាមូលដ្ឋាននេះ គឺជាអំពើដូចគ្នា ពោលគឺ ជនជាប់ចោទបានសម្លាប់មនុស្សមានចំនួនដ៏ច្រើនដែលនៅក្នុងក្រុមគោលដៅ។ ក៏ប៉ុន្តែ ធាតុផ្សំផ្លូវច្បាប់ដែលមានលក្ខណៈដាច់ដោយឡែកជាសត្យានុម័តទាំងនេះ តម្រូវឱ្យអយ្យការបង្ហាញភស្តុតាងនៃអង្គហេតុខុសៗគ្នា។ ដូច្នេះ ជាការពុំសមស្របនោះទេដែលអង្គជំនុំជម្រះសាលាដំបូង ក្នុងការវិភាគរបស់ខ្លួនទៅលើការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា បានផ្តោតទៅលើអំពើជាមូលដ្ឋាននៅក្នុងបទចោទ ជាជាងផ្តោតទៅលើភស្តុតាងនៃអង្គហេតុដែលតម្រូវឱ្យមាន សម្រាប់ធាតុផ្សំផ្លូវច្បាប់ដែលមានលក្ខណៈដាច់ដោយឡែកពីគ្នាទាំងនេះ។ ក្រោយពីបានទទួលស្គាល់ថា អំពើធ្វើទុក្ខបុកម្នេញ គឺជាបទល្មើសមូលដ្ឋានដាច់ដោយឡែកមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារ*ធាតុផ្សំសត្យានុម័ត* និង*ធាតុផ្សំអត្តនោម័ត*ដាច់ដោយឡែករបស់វាដែលមានលក្ខណៈខុសពីបទល្មើស ដែលទាមទារឱ្យមានធាតុផ្សំតាមបរិបទ ឬគ្រាន់តែ"ជាទម្រង់"ប៉ុណ្ណោះ ទាំងនេះជាការពុំសមហេតុផលនោះទេ ដែលអង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ ក៏ដូចជាពីបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានចោទប្រកាន់ យោងតាមលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ។

---

[720]សាលដីកាក្នុង*រឿងក្តី Kordić និង Čerkez*, កថាខណ្ឌ ១០៤០។

៣២៧. ចំណុចចុងក្រោយ ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាលើជនជាប់ចោទពីបទឧក្រិដ្ឋនីមួយៗ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទជាអ្នកទទួលខុសត្រូវនោះ ពិតជាមិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទនោះទេ។ ចំណុចទីមួយ ភាពអាម៉ាសរបស់ជនជាប់ចោទនៅក្នុងសង្គម ពិតជាពុំកើតមានដោយសារការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើមនុស្សឃាត បទសម្លាប់រង្គាល បទធ្វើឱ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត បន្ថែមទៅលើបទធ្វើទុក្ខបុកម្នេញ ឡើយ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើបទល្មើសទាំងនោះរួចហើយ[721]។ ជាទូទៅ ទោះបីភាពអាម៉ាសនៅក្នុងសង្គម ដែលអាចកើតមានដោយសារការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសមួយដែលអាចលើសពីភាពអាម៉ាស់ ដោយសារការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក៏ដោយ ក៏ស្ថានទម្ងន់នៃអំពើរបស់ជនជាប់ចោទ និងផលប៉ះពាល់យ៉ាងខ្លាំងនៃអំពើនេះលើប្រទេសកម្ពុជា ពុំអាចចាត់ទុកថា ជនជាប់ចោទបានទទួលភាពអាម៉ាសបន្ថែមដោយសារការសម្រេចដាក់ពិរុទ្ធភាពជាផ្លូវការនេះឡើយ។

៣២៨. ចំណុចទីពីរ ជាទំនៀមទម្លាប់ ហានិភ័យដែលកើតមានដល់ជនជាប់ចោទ គឺកើតចេញពីលទ្ធភាពដែលថា យុត្តាធិការជាតិដែលអនុវត្តទោស នឹងសម្រេចអំពីឱកាសក្នុងការទទួលបានការដោះលែងមុនពេលកំណត់ដោយអនុលោមតាមច្បាប់ជាតិ ដោយផ្អែកមួយផ្នែកលើចំនួននៃការសម្រេចដាក់ពិរុទ្ធភាព ពោលគឺ នៅពេលណាដែលមានការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសកាន់តែច្រើន ឱកាសក្នុងការទទួលបានការដោះលែងមុនពេលកំណត់នឹងមានកាន់តែតិចទៅ[722]។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងបរិបទ អ.វ.ត.ក ដោយអនុលោមតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បញ្ហាជាក់លាក់នៃសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការដោះលែង មុនពេលកំណត់មានចែងនៅក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា[723]។

---

[721]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៧។

[722]សាលដីកាក្នុង *រឿងក្តី Čelebići* ,មតិជំទាស់ដាច់ដោយឡែករបស់ចៅក្រម Hunt និង Bennouna, កថាខណ្ឌ ២៣។

[723]មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

ដោយអនុលោមតាមច្បាប់នេះ សិទ្ធិក្នុងការទទួលបានការដោះលែងមុនពេលកំណត់ត្រូវបានសម្រេចតាមរយៈការពិនិត្យមើលរយៈពេលនៃទោសរួមមួយដែលត្រូវបានប្រកាស មិនមែនតាមរយៈបទល្មើសច្រើនដែលត្រូវបានចោទប្រកាន់ត្រួតគ្នានោះទេ[724]។ ដូច្នេះ ក្របខណ្ឌគតិយុត្តជាធរមាន មានការការពារក្នុងការលុបបំបាត់ហានិភ័យណាមួយដែលថា ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នានឹងមានផលប៉ះពាល់ជាអវិជ្ជមានចំពោះលទ្ធភាព ក្នុងការទទួលបានការដោះលែងមុនពេលកំណត់។

៣២៩. ជាចុងក្រោយ ជនជាប់ចោទពុំប្រឈមនឹងហានិភ័យដោយសារបទប្បញ្ញត្តិច្បាប់ស្តីពីជនល្មើសមិនរាងចាល ឬហានិភ័យដោយសារការបង្កើនទម្ងន់ទោស នៅពេលសម្រេចដាក់ពិរុទ្ធភាពនាពេលក្រោយមកនោះទេ ដោយហេតុថា ទោះបីជាអង្គជំនុំជម្រះសាលាដំបូងអាចចាត់ទុកការសម្រេចដាក់ពិរុទ្ធភាពមុនៗពីបទល្មើសនានាអនុលោមតាមយុត្តាធិការរបស់ខ្លួនថា ជាកត្តាស្ថានទម្ងន់នៅពេលប្រកាសទោសក៏ដោយ[725] ក៏យោងតាមកាលៈទេសៈនៃរឿងក្តីនេះពុំអាចមានហានិភ័យណាមួយដែលថា ជនជាប់ចោទនឹងត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសដែលកើតមានជាហូរហែនៅក្នុងប្រទេសកម្ពុជា ឬទីកន្លែងផ្សេងទៀតក្រោយពីការអនុវត្តទោសបច្ចុប្បន្នរបស់ខ្លួនរួចហើយនោះទេ។

៣៣០. ក៏ប៉ុន្តែ ទោះបីជាការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា នឹងមិនប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់ជនជាប់ចោទក៏ដោយ ក៏ការដែលពុំបានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាលើជនជាប់ចោទ បានធ្វើ

---

[724]មាត្រា ៥១២ និង ៥១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ចែងថា គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើ(ក)ទណ្ឌិតនេះបានបង្ហាញឲ្យឃើញថាខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និង (ខ)មានសម្បទា ដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន។ (គ) លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលទណ្ឌិតត្រូវបានទទួលរួចរាល់ហើយ)។ មាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ចែងថា (“កាលបើនៅក្នុងពេលចោទប្រកាន់តែមួយជនជាប់ចោទត្រូវបានគេរកឃើញថាមាន ពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវប្រកាសឡើង។ ប៉ុន្តែ កាលបើទោសត្រូវទទួលមានច្រើន ហើយ មានប្រភេទដូចគ្នាតុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ”)។

[725]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៨៣, ដកស្រង់ចេញពីលក្ខន្តិកៈស្តីពីនីតិវិធីថ និងភស្តុតាងរបស់ដែលចុះហត្ថលេខា និងចូលជាធរមាននៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០២ (“ICCRPE”), វិធាន ១៤៥(២)(ខ))។

ឱ្យប៉ះពាល់ដល់ផលប្រយោជន៍សង្គម នៅក្នុងការបង្ហាញអំពី"ពិរុទ្ធភាពទាំងអស់របស់ជនជាប់ចោទណាមួយ ឬនៅក្នុងការផ្តល់នូវរូបភាពពេញលេញមួយដែលបង្ហាញពីអំពើល្មើសរបស់ជនជាប់ចោទរូបនេះ"[726]។ នៅពេលពិចារណាអំពីបទចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទជាអ្នកទទួលខុសត្រូវ ការសម្រេចដាក់ពិរុទ្ធភាពតែពីបទធ្វើទុក្ខបុកម្នេញលើជនជាប់ចោទ ពុំបានផ្តល់នូវរូបភាពឱ្យបានពេញលេញ និងច្បាស់លាស់ ចំពោះភាពធ្ងន់ធ្ងរនៃអំពើល្មើសរបស់ជនជាប់ចោទនោះឡើយ ដោយហេតុថា អំពើធ្វើទុក្ខបុកម្នេញអាចរួមបញ្ចូលនូវកម្រិតខុសៗគ្នានៃអំពើឧក្រិដ្ឋ។ និយមន័យដ៏ទូលាយមួយនៃអំពើធ្វើទុក្ខបុកម្នេញ អាចអនុញ្ញាតឱ្យមានការកំណត់អំពើជាច្រើនថា ជាអំពើធ្វើទុក្ខបុកម្នេញដែលមានន័យថា ទោះបីជា អំពើគួរស្អប់ខ្ពើមទាំងឡាយអាចបង្កើតបានជាអំពើធ្វើទុក្ខបុកម្នេញក៏ដោយ ក៏ការរំលោភបំពានលើសិទ្ធិជាសារវន្តដែលមិនសូវជាធ្ងន់ធ្ងរ ក៏អាចបង្កើតបានជាអំពើធ្វើទុក្ខបុកម្នេញដូចគ្នានេះដែរ ដរាបណាអំពើរំលោភបំពានទាំងនេះ មានភាពធ្ងន់ធ្ងរស្មើគ្នាទៅនឹងបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលពិចារណាទៅតាមបរិបទ និងនៅពេលពិចារណាអំពីការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នា។ ផលប៉ះពាល់ដែលកើតមាននេះ គឺថា ការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញ អាចផ្អែកលើអំពើដកហូតសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ឬអាចផ្អែកលើអំពើដែលមានលក្ខណៈធ្ងន់ធ្ងរដូចគ្នាទៅនឹងអំពើសម្លាប់រង្គាលជាដើម។

៣៣១. នៅត្រង់ចំណុចនេះ ជនជាប់ចោទត្រូវបានរកឃើញថា ជាអ្នកទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើធ្ងន់ធ្ងរបំផុតមួយចំនួន ក្នុងចំណោមអំពើល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា អំពើមនុស្សឃាត អំពើសម្លាប់រង្គាល អំពើធ្វើឱ្យទៅជាទាសករ អំពើដាក់ក្នុងមន្ទីរឃុំឃាំង អំពើធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ ក៏ប៉ុន្តែ ការសម្រេចដាក់ពិរុទ្ធភាពបច្ចុប្បន្នលើជនជាប់ចោទ គ្រាន់តែឆ្លុះបញ្ចាំងពីបទធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ។ ទោះបីជា ការស្រូបបញ្ចូលគ្នា ដែលជាគោលការណ៍ច្បាប់ បង្ហាញពិរុទ្ធភាពនៃ

---

[726]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦០, ដកស្រង់ចេញពីសាលដីកាក្នុង*រឿងក្តី Kunarac*, កថាខណ្ឌ ១៦៩។

អំពើល្មើសក៏ដោយ ក៏ភាពខុសៗគ្នានៃបទល្មើសតាមផ្លូវច្បាប់នេះ ពុំមានលក្ខណៈច្បាស់លាស់នោះទេ។ ហេតុដូច្នេះ ការស្របបញ្ចូលបទល្មើសមូលដ្ឋានទាំងអស់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានរកឃើញថា ជនជាប់ចោទជាអ្នកទទួលខុសត្រូវ ទៅក្នុងការសម្រេចដាក់ពិរុទ្ធភាពតែពីបទធ្វើទុក្ខបុកម្នេញ ដោយពុំបានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នានោះ គឺជាការសម្រេច ពុំបានដោះស្រាយឲ្យបានគ្រប់គ្រាន់ពីព្យសនកម្មចំពោះផលប្រយោជន៍នីមួយៗនៅក្នុងសង្គម ដែលមានបញ្ញត្តិការពារដែលបញ្ញត្តិទាំងនេះបានចែងពីបទឧក្រិដ្ឋខុសៗគ្នានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៣៣២. សរុបមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការអនុវត្តដ៏ត្រឹមត្រូវនូវលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* នាំទៅដល់ការសន្និដ្ឋានថា ជនជាប់ចោទគប្បីត្រូវបានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) បទធ្វើឱ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត និងបទធ្វើទុក្ខបុកម្នេញ ដោយហេតុថា បទល្មើសនីមួយៗដែលត្រូវបានចោទប្រកាន់ មានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត ដែលពុំមាននៅក្នុងបទល្មើសផ្សេងទៀតឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញខាងលើរួចហើយ អំពីធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត ដែលបានរកឃើញនៅក្នុងបទសម្លាប់រង្គាល និងបទធ្វើទុក្ខបុកម្នេញ។ ចំពោះអំពើសម្លាប់រង្គាល និងអំពើមនុស្សឃាត អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើសម្លាប់រង្គាលគឺជា៖

(១) អំពើសកម្ម អកម្ម ឬការរួមបញ្ចូលគ្នានៃអំពើទាំងពីរនេះដែលនាំឱ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ[727] (*ធាតុផ្សំសត្យានុម័ត*)។ និង

(២) "ចេតនាក្នុងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬបង្ករបួសលើរូបរាងកាយធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឱ្យមានការស្លាប់ដោយយល់ដឹងដោយ

[727]សាលក្រមអង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ ៣៣៤, ដកស្រង់ចេញពីសាលក្រមក្នុង*រឿងក្តី* Blagojević *និង* Jokić, កថាខណ្ឌ ៥៧២។ សាលដីកាក្នុង*រឿងក្តី* Seromba, កថាខណ្ឌ ១៨៩។

សមហេតុផលថា អំពើសកម្ម ឬអកម្មនោះមុខជាបង្កឱ្យមានការបាត់បង់ជីវិតមនុស្ស មានចំនួនដ៏ច្រើន"(*ធាតុផ្សំអត្តនោម័ត*)[728] ។

៣៣៣. ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យនៃអំពើធ្វើមនុស្សឃាតថាជា៖

(១) អំពើសកម្ម ឬ អកម្ម ដែលបណ្តាលឱ្យជនរងគ្រោះស្លាប់ (*ធាតុផ្សំសត្យានុម័ត*)[729]។ និង

(២) "ចេតនាសម្លាប់ ឬបង្កឱ្យមានព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ ដោយយល់ដឹងដោយសមហេតុផលថា អំពើសកម្ម ឬ អកម្មនោះមុខជាបង្កឱ្យមានការបាត់បង់ជីវិតមនុស្ស"[730] (*ធាតុផ្សំអត្តនោម័ត*)។

៣៣៤. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា យោងតាមលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Čelebići* អំពើសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាបទល្មើសដាក់លាក់មួយផងនោះ បានស្រូបបញ្ចូលអំពើធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចគ្នា[731]។ បទល្មើសទាំងពីរនេះមាន*ធាតុផ្សំសត្យានុម័ត* និង*ធាតុផ្សំអត្តនោម័ត*ដូចគ្នា លើកលែងតែអំពើសម្លាប់រង្គាល ដែលមានលក្ខខណ្ឌតម្រូវបន្ថែម គឺអំពើសម្លាប់ក្នុង*ទ្រង់ទ្រាយធំ* ដែលធ្វើឱ្យអំពើសម្លាប់រង្គាលនេះ មានលក្ខណៈដាច់ដោយឡែកជាសត្យានុម័តពីអំពើធ្វើមនុស្សឃាត[732]។

[728]សាលក្រមអង្គជំនុំជម្រះសាលាដំបូង,កថាខណ្ឌ ៣៣៨, ដកស្រង់ចេញពីសាលក្រមក្នុង*រឿងក្តី* Bagosora, កថាខណ្ឌ ២១៩១។

[729]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៣១។

[730]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៣៣, ដកស្រង់ចេញពីសាលក្រមក្នុង*រឿងក្តី* Blagojević *និង* Jokić, កថាខណ្ឌ ៥៥៦។ និយមន័យដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងលើការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំនៅក្នុងបណ្តឹងសាទុក្ខចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ ហេតុដូច្នេះ នៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះតុលាការកំពូលពុំពិនិត្យមើលឡើងវិញ ថាតើនិយមន័យនេះត្រឹមត្រូវតាមច្បាប់ ដែរ ឬយ៉ាងណា នោះទេ។

[731]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៦។

[732]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៦។

៣៣៥. ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋទាំងបួន ដែលអង្គជំនុំជម្រះសាលាដំបូងបានស្រូបបញ្ចូលទៅក្នុងបទធ្វើទុក្ខបុកម្នេញ ដោយបទឧក្រិដ្ឋនីមួយៗនេះ សុទ្ធតែមានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត ពីបទធ្វើទុក្ខបុកម្នេញ។ ដូច្នេះ ការសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទល្មើសទាំងប្រាំ ទើប ជាការត្រឹមត្រូវ។ ក្នុងចំណោមបទឧក្រិដ្ឋទាំងបួន មិនមានបទឧក្រិដ្ឋណាមួយតម្រូវឱ្យមានការបង្ហាញអំពីចេតនារើសអើងជាក់លាក់ដែលជាធាតុផ្សំចាំបាច់ ដូចមាននៅក្នុងបទធ្វើទុក្ខបុកម្នេញនោះទេ[733]។ ស្រដៀងគ្នានេះដែរ យ៉ាងហោចណាស់ ក៏មានធាតុផ្សំមួយនៃ*ធាតុផ្សំសត្យានុម័ត* នៃបទឧក្រិដ្ឋនីមួយៗក្នុងចំណោមបទឧក្រិដ្ឋទាំងបួន ខ្ពស់ជាងលក្ខខណ្ឌតម្រូវអប្បរមានៃ"អំពើសកម្ម ឬអកម្មដែល... រើសអើងជាក់ស្ដែង ហើយដែលបដិសេធសិទ្ធិជាសារវន្ត ឬរំលោភបំពានសិទ្ធិជាសារវន្ត" ដែលជាលក្ខខណ្ឌតម្រូវ*ធាតុផ្សំសត្យានុម័ត*តែមួយគត់នៃអំពើធ្វើទុក្ខបុកម្នេញ[734]។ ដូច្នេះ ជាការសមស្របដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពត្រួតគ្នាពីបទធ្វើទុក្ខបុកម្នេញ រួមទាំងបទសម្លាប់រង្គាល បទធ្វើឱ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង និងបទធ្វើទារុណកម្ម និងអំពើមនុស្សធម៌ផ្សេងៗទៀត។

## ៤.ច.៣.សេចក្ដីសន្និដ្ឋាន

៣៣៦. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលទទួលយកទឡ្ហីករណ៍ទីពីរត្រង់ផ្នែកនេះនៅក្នុងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ហើយអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការស្រូបបញ្ចូលបទឧក្រិដ្ឋមូលដ្ឋាន

---

[733]ផ្នែកនានាខាងលើចែងអំពីនិយមន័យដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងលើការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ *សូមមើលផងដែរ*សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤៧ (ចែងអំពីនិយមន័យដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងលើការដាក់ក្នុងមន្ទីរឃុំឃាំង) និងកថាខណ្ឌ ៣៦៧ ដល់ ៣៧១ (បញ្ជាក់អំពីនិយមន័យដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងចំពោះអំពើអមនុស្សធម៌ផ្សេងទៀត)។ ការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងលើការដាក់ក្នុងមន្ទីឃុំឃាំង និងអំពើអមុស្សធម៍ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនបានលើកឡើងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលឡើយ។ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូល មិនតម្រូវឱ្យពិនិត្យឡើងវិញថា តើការកំណត់និមយន័យទាំងនេះត្រឹមត្រូវតាមច្បាប់ ដែរ ឬយ៉ាងណាឡើយ។

[734]*សូមមើល* ផ្នែកមុននៅក្នុងសាលដីកានេះស្ដីពីការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញ ហួសពីវិមតិសង្ស័យ ទៅក្នុងការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទធ្វើទុក្ខបុកម្នេញ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ថា បន្ថែមពីលើការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ត្រូវសម្រេចដាក់ពិរុទ្ធភាពដាច់ដោយឡែកផ្សេងទៀតផងដែរលើជនជាប់ ចោទពីបទសម្លាប់រង្គាល (ដោយរួមទាំងបទធ្វើមនុស្សឃាត) បទធ្វើឱ្យទៅជាទាសករ បទ ដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត[735]។

[735]ចំពោះការបង្គាប់បែបនោះតុលាការកំពូលកត់សម្គាល់ថា តុលាការបានអនុវត្តដោយអនុលោមតាមវិធាន ១១០(៤) នៃ វិធានផ្ទៃក្នុងនៅពេលកែប្រែផ្នែកសម្រេចសេចក្ដីរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្ដីនេះ ពីព្រោះអង្គជំនុំជម្រះ សាលាដំបូងមិនបានឲ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ពីបទល្មើសទាំងនេះនោះទេ។ បន្ថែមពីលើនេះអង្គជំនុំជម្រះ តុលាការកំពូលកត់សម្គាល់ថាការបញ្ចូលការសម្រេចដាក់ពិរុទ្ធភាពជាផ្លូវការនៅទីនេះ គឺអនុលោមតាមវិធាន ១១០(២) នៃ វិធានផ្ទៃក្នុង និងមាត្រា ៤០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ដែលតុលាការឧទ្ធរណ៍ អាច កែប្រែបទចោទ ដោយមិនត្រូវបន្ថែមធាតុផ្សំថ្មីនៃបទល្មើសណាមួយដែលមិនបានដាក់ជូននៅអង្គជំនុំជម្រះសាលាដំបូងដើម្បី សម្រេចនោះទេ។

# ៥.កំហុសដែលបានលើកឡើងទាក់ទងទៅនឹងការប្រកាសទោស (ទឡ្ហីករណ៍ ទី ២ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី និងទឡ្ហីករណ៍ទី ១ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា)

## ៥.ក.ទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី

៣៣៧. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ទឡ្ហីករណ៍ទីពីរនៃបណ្តឹងសាទុក្ខរបស់ **កាំង ហ្កេកអ៊ាវ** ដូចដែលបានបង្ហាញនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ បានលើកឡើងពី "កំហុសឆ្គងទាក់ទងនឹងការផ្តន្ទាទោសដាក់ពន្ធនាគារសរុបរួមមានកំណត់ ៣៥ ឆ្នាំ"[736]។ អំណះអំណាងដែលបានលើកឡើងនៅក្នុងទឡ្ហីករណ៍ទីពីរនេះ គឺដើម្បី"បញ្ជាក់អំពីកំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈ"ការប្រកាសទោសនេះ[737] ហាក់ដូចជាទាក់ទិនដោយផ្ទាល់ជាមួយទឡ្ហីករណ៍ទីមួយនៃបណ្តឹងសាទុក្ខរបស់ **កាំង ហ្កេកអ៊ាវ** ស្តីពីយុត្តាធិការលើរូបបុគ្គល។ ឧទាហរណ៍ មេធាវីការពារក្តី **កាំង ហ្កេកអ៊ាវ** បានលើកឡើងនៅក្នុងសារណារបស់ខ្លួនស្តីពីយុត្តាធិការលើរូបបុគ្គលនូវកត្តាស្ថានសម្រាលទោសមានដូចជា "ឋានៈពិតប្រាកដរបស់*ជនជាប់ចោទ*ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"[738] និង"ភាពជាក់ស្តែងដែលថា ជនជាប់ចោទបានសហការយ៉ាងពេញលេញជាមួយអង្គជំនុំជម្រះ"[739]។ សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីក៏បានផ្តោតផងដែរ ទៅលើយុត្តាធិការលើរូបបុគ្គលនៅក្នុងផ្នែកដែលបានលើកឡើងពី "ទឡ្ហីករណ៍ទី ២៖ កំហុសឆ្គងទាក់ទងនឹងការសម្រេចពីពិរុទ្ធភាព និងការផ្តន្ទាទោស"[740]។

---

[736]សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, ចំណងជើងពាក់ព័ន្ធនឹង កថាខណ្ឌ ៨ ដល់ ៩។

[737]វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។

[738]សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, ថាខណ្ឌ ៨។

[739]សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, ថាខណ្ឌ ៨។

[740]ការផ្តោតនេះស្របគ្នាទៅនឹងយុទ្ធសាស្ត្ររបស់មេធាវីការពារក្តីដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់។ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, ទំព័រ ១១ បន្ទាត់ (១៥ ដល់ ១៧)។ ប្រតិចារឹក

៣៣៨. ផ្អែកលើផលប្រយោជន៍ផ្លូវច្បាប់របស់ **កាំង ហ្គេកអ៊ាវ** និងចេតនាដែលបានសន្មតទុកជាមុននៅក្នុងបណ្តឹងសាទុក្ខរបស់ **កាំង ហ្គេកអ៊ាវ** ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា មេធាវីការពារក្តីលើកឡើងថា នៅក្នុងការប្រកាសទោស អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាអំពីតួនាទីរបស់ **កាំង ហ្គេកអ៊ាវ** នៅក្នុងឋានានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យ[741] និងភាពគ្មានអំណាចក្នុងការធ្វើសេចក្តីសម្រេច[742] ដែលជាកត្តាស្ថានសម្រាលទោស។ មេធាវីការពារក្តីក៏បានលើកឡើងផងដែរក្នុងអំឡុងសវនាការលើបណ្តឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយខកខានក្នុងការថ្លឹងថ្លែងឱ្យបានសមស្របទៅលើកិច្ចសហការ និងការសំដែងនូវវិប្បដិសារីរបស់ **កាំង ហ្គេកអ៊ាវ**[743]។ មេធាវីការពារក្តីលើកទឡ្ហីករណ៍ថា កត្តាស្ថានសម្រាលទោសទាំងនេះ តម្រូវឱ្យមានការកំណត់ទោសអតិបរមាត្រឹមតែ ៣០ ឆ្នាំប៉ុណ្ណោះ ប៉ុន្តែ មេធាវីការពារក្តីលើកឡើងថា ការដាក់ពន្ធនាគាររយៈពេលកំណត់ ១៥ ឆ្នាំ ជាការសមស្របបំផុត[744]។ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិចារណាឱ្យបានសមស្របទៅលើសេចក្តីសន្និដ្ឋានទាំងនេះ ដែលនឹងត្រូវលើកយកមកពិចារណារួមជាមួយនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងការប្រកាសទោស។

៣៣៩. ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីលើកទឡ្ហីករណ៍យ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសម្រេចផ្តន្ទាទោសមិនសមស្រប ដោយខកខានក្នុងការ

---

ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/3.2 ទំព័រ ២០ (បន្ទាត់ ២៣ ដល់ ២៥) និង ទំព័រ ២១ (បន្ទាត់ ១ ដល់ ៧) ។

[741]សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌ ៣៦ (ដែលបានបញ្ជាក់ថា ផ្អែកតាមច្បាប់ទំនៀមទម្លាប់របស់កម្ពុជា ចារីអាចត្រូវបានរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬបានទទួលការសម្រាលទោស ប្រសិនបើ បទឧក្រិដ្ឋនោះត្រូវបានប្រព្រឹត្តឡើង ដោយសារតែទទួលបញ្ជាពីបុគ្គលដទៃទៀត។ ការយោងបានធ្វើឡើងផងដែរនៅក្នុងជើងទំព័រ ២៣ នៃរឿងនិទានខ្មែរ ដែលមានបំណងបានផ្តល់ជាភស្តុតាងដល់ច្បាប់ទំនៀមទម្លាប់នេះ)។

[742]បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌ ៨៧ ដល់ ៩០។

[743]ប្រតិចារឹកចុះថ្ងៃទី២៩ខែមីនាឆ្នាំ២០១១, ឯកសារF1/3.2ទំព័រ ២៦ (បន្ទាត់៤ ដល់ ៥)។

[744]ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារF1/3.2 ទំព័រ ២៥ (បន្ទាត់ ២២ ដល់ ២៥) ដល់ទំព័រ ២៦ (បន្ទាត់ ១ ដល់ ២២) និង ទំព័រ ៦៩ (បន្ទាត់ ២១ ដល់ ២៥)។

ពិចារណាឱ្យបានគ្រប់គ្រាន់ទៅលើមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩[745]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សេចក្តីសន្និដ្ឋានជាពិសេសរបស់មេធាវីការពារក្តីនេះ គឺចង់មានន័យថា ច្បាប់អន្តរជាតិ រួមទាំងយុត្តិសាស្ត្រនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា មិនអាចយកមកអនុវត្តបានឡើយចំពោះការប្រកាសទោសនៅចំពោះមុខ អ.វ.ត.ក។ ពាក់ព័ន្ធនឹងបញ្ហានេះ គ្រប់ភាគីត្រូវបានអង្គជំនុំជម្រះតុលាការកំពូលអញ្ជើញ[746]ឱ្យបញ្ចេញយោបល់របស់ខ្លួនលើអានុភាពនៃមាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ដែលបានចូលជាធរមានក្រោយការចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងការឆ្លើយតបនាពេលសវនាការលើបណ្តឹងសាទុក្ខ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា ដោយពុំមានភាពខុសគ្នារវាងក្រមព្រហ្មទណ្ឌកម្ពុជា និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ជនជាប់ចោទគួរតែទទួលបានផលប្រយោជន៍ពីបទប្បញ្ញត្តិណាមួយនៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ដែលក្រមនេះផ្តល់ផលប្រយោជន៍ច្រើនជាងដល់ជនជាប់ចោទ[747]។

៣៤០. ជាការឆ្លើយតប សហព្រះរាជអាជ្ញាលើកឡើងថា ទឡ្ហីករណ៍ទីពីរនៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីមិនមានមូលដ្ឋានត្រឹមត្រូវជាក់ស្តែងឡើយ ហើយម្យ៉ាងទៀតទឡ្ហីករណ៍នេះខកខានក្នុងការបំពេញលក្ខខណ្ឌតម្រូវអប្បបរមានៃសារណាការពារបណ្តឹងសាទុក្ខ ហេតុដូច្នេះអង្គជំនុំជម្រះតុលាការកំពូលគប្បីមិនពិចារណា[748]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា តាមពិតសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ដែលទាក់ទងទៅនឹងការប្រកាសទោស គឺមិនមានអ្វីខុសប្លែកទៅនឹងសារណារបស់ខ្លួន ដែលទាក់ទងទៅនឹងបញ្ហាយុត្តាធិការលើរូបបុគ្គលនោះទេ ដូច្នេះហើយគប្បីត្រូវបដិសេធចោល[749]។

---

[745]បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌ ៩១។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/3.2, ទំព័រ ៦៩ (បន្ទាត់ ១៧ ដល់ ២៥), ទំព័រ ៧០ (បន្ទាត់ ៨ ដល់ ១០) និង ទំព័រ ៧១ (បន្ទាត់ ៣ ដល់ ១៤)។

[746]ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខទំព័រ ៤។

[747]ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារ F1/3.2, ទំព័រ ៦៣ (បន្ទាត់ ១១) ដល់ ទំព័រ ៦៦ (បន្ទាត់ ១៣)។

[748]សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៧ ដល់ ៩។

[749] សារណាតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៥០ ដល់ ៥១។

៣៤១. ទាក់ទិននឹងការអនុវត្តក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ជាពិសេស មាត្រា ១០ មាត្រា ៩៥ និងមាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ នេះ សហព្រះរាជអាជ្ញាបានលើកឡើងថា បទប្បញ្ញត្តិទាំងនេះពុំអាចជាបង្អែកមួយនៃរបបប្រកាសទោសដែលអាចយកមកអនុវត្តបានចំពោះកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នោះឡើយ ដូច្នេះហើយមិនគប្បីលើកមកពិចារណាទេ។ ទីមួយ សហព្រះរាជអាជ្ញាអះអាងថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មានលក្ខណៈសម្បត្តិជា"ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស" ដូចមានចែងនៅក្នុងមាត្រា ៦៦៨(៣) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩[750]។ ហេតុដូច្នេះ "បទប្បញ្ញត្តិទូទៅ"[751]នៅក្នុងមាត្រា ៦៦៨(២) ដែលចែងអំពីការអនុលោមតាមគន្លឹះទី ១ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ក្នុងករណីដែលក្រមនេះមានទំនាស់ជាមួយបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែករួមទាំងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផង គឺមិនអាចយកមកអនុវត្តបានឡើយ[752]។ ទីពីរ សហព្រះរាជអាជ្ញាអះអាងថា បទប្បញ្ញត្តិទាក់ទងទៅនឹងការប្រកាសទោសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ពុំចងកាតព្វកិច្ច អ.វ.ត.ក ឡើយ ពីព្រោះថា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានបង្កើត"ស្ថាប័ន*ពិសេស*"[753] ដែលត្រូវអនុវត្តនូវរបបនៃការប្រកាសទោសដោយជាក់លាក់ ដូចដែលមានចែងនៅក្នុងមាត្រា ១០ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[754]។ ទឡ្ហីករណ៍

---

[750]ប្រតិចារឹកថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/3.2, ទំព័រ ៣៣ (បន្ទាត់ ៨ ដល់ ១០) ទំព័រ ៣៧ (បន្ទាត់ ១៥ ដល់ ១៩) និងទំព័រ ៥៩ (បន្ទាត់ ១ ដល់ ៨)។

[751]ប្រតិចារឹក ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១១, ឯកសារលេខ F1/3.2, ទំព័រ ៣២ (បន្ទាត់ ២០ ដល់ ២១)។

[752]ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/3.2, ទំព័រ ៣២ (បន្ទាត់ ១៣) ដល់ ទំព័រ ៣៧ (បន្ទាត់ ១៩) ទំព័រ ៥៧ (បន្ទាត់ ២០) ដល់ទំព័រ ៦០ (បន្ទាត់ ១២) និងទំព័រ ៦២ (បន្ទាត់ ១៦ ដល់ ២២)។

[753]ប្រតិចារឹកថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារ F1/3.2, ទំព័រ ៣៤ (បន្ទាត់ ២ ដល់ ៣)។

[754]ប្រតិចារឹកថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារ F1/3.2, ទំព័រ ៣៣ (បន្ទាត់ ២១) ដល់ ទំព័រ ៣៦ (បន្ទាត់ ១៥)។

ដែលលើកឡើងនៅក្នុងការឆ្លើយតបរបស់មេធាវីការពារក្តី គឺមិនបានលើកឡើងទាក់ទងទៅនឹងការប្រកាសទោសឡើយ[755]។

### ៥.ក.១.ច្បាប់ជាធរមានទាក់ទងទៅនឹងរបបនៃការប្រកាសទោស

៣៤២. ដើម្បីដោះស្រាយទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ជាដំបូងអង្គជំនុំជម្រះតុលាការកំពូលពិចារណាលើសារណានានាដែលពាក់ព័ន្ធនឹងច្បាប់ ដែលត្រូវយកមកអនុវត្តចំពោះរបបនៃការប្រកាសទោស។ វិធាន ៩៨(៥) នៃវិធានផ្ទៃក្នុង ចែងថា៖

> ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានទោស អង្គជំនុំជម្រះត្រូវផ្តន្ទាទោសជនជាប់ចោទនោះ ឱ្យស្របទៅនឹងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុងនេះ[756]។

៣៤៣. មាត្រា ១០ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ចែងថា ទណ្ឌកម្មជាអតិបរមាសម្រាប់ផ្តន្ទាទោស គឺកំណត់ត្រឹមដាក់ពន្ធនាគារអស់មួយជីវិត[757]។ បន្ថែមពីលើនេះ មាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ចែងថា៖

> ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣ ថ្មី មាត្រា ៤ មាត្រា ៥ មាត្រា ៦ មាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះត្រូវផ្តន្ទាទោសឧក្រិដ្ឋ ដាក់ពន្ធនាគារពី ៥ ឆ្នាំ រហូតដល់មួយជីវិត[758]។

៣៤៤. បទប្បញ្ញត្តិទាំងនេះ ផ្តល់អំណាចដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការជ្រើសរើសការប្រកាសទោសដាក់ពន្ធនាគារដែលមានរយៈពេលកំណត់ពី ៥ ឆ្នាំឡើងទៅ ឬដាក់ពន្ធនាគារអស់មួយជីវិត។

---

[755]ការឆ្លើយតបរបស់មេធាវីការពារក្តី ផ្តោតទៅលើយុត្តាធិការលើរូបបុគ្គលលើ កាំង ហ្គេកអ៊ាវ។

[756]វិធាន៩៨(៥) នៃវិធានផ្ទៃក្នុង។

[757]មាត្រា ១០ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

[758]មាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

៣៤៥. បញ្ហាដែលត្រូវដោះស្រាយ ថាតើបទប្បញ្ញត្តិមួយចំនួននៅក្នុងគន្ថីទីមួយនៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩[759] ជាពិសេសមាត្រា ១០ និងមាត្រា ៩៥ អាចយកមកអនុវត្តបាន ដែរ ឬយ៉ាងណាក្នុងការកំណត់ទោស។ ខាងក្រោមនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិចារណាអំពីការអនុវត្តបាន ឬមិនបានចំពោះមាត្រាទាំងនេះ។

៣៤៦. មាត្រា ១០(១) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ធានាអំពីគោលការណ៍នៃច្បាប់ដែលកំណត់ពីទោស*ស្រាលជាង* ដែលមានខ្លឹមសារថា "បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសស្រាលជាងត្រូវតែយកមកអនុវត្តភ្លាម"[760]។ មាត្រា ៩៥ នៃក្រមនេះបានចែងថា "កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជិវិត ចៅក្រម ដែលផ្តល់ស្ថានសម្រាលទោសអាចប្រកាសទោសដាក់ពន្ធនាគារក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) ឆ្នាំ និង ៣០ (សាមសិប) ឆ្នាំ"។

៣៤៧. ដោយផ្អែកតាមបទប្បញ្ញត្តិទាំងនេះ មេធាវីការពារក្តីលើកឡើងថា រយៈពេលនៃការដាក់ពន្ធនាគារ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ គប្បីមានអានុភាពក្នុងការអនុវត្តជាង ពីព្រោះថាមានកម្រិតទោសស្រាលជាងរយៈពេលនៃទោស ដែលមានចែងក្នុងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក។ ទោះបីជាមេធាវីការពារក្តីពុំបានលើកឡើងច្បាស់លាស់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូល ធ្វើការបកស្រាយចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តីថា ទឡ្ហីករណ៍របស់មេធាវីការពារក្តីក៏បានផ្អែកផងដែរ ទៅលើបទប្បញ្ញត្តិផ្សេងទៀតនៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ជាពិសេសមាត្រា ៤៦ ដែលមិនអនុញ្ញាតឱ្យមានការប្រកាស

---

[759]ដោយហេតុថា គន្ថីទីមួយ (បទប្បញ្ញត្តិទូទៅ) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៩ បានចូលជាធរមាន នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៩ ដូច្នេះ បទប្បញ្ញត្តិដទៃទៀតនៃក្រមនេះ អាចអនុវត្តបានបន្ទាប់ពីមួយឆ្នាំក្រោយមក។ មាត្រា ៦៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ព្រះរាជក្រម នស/រកម/១១០៩/០២២ ថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩, ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១០ (កាលបរិច្ឆេទដាក់ឯកសារ), ឯកសារលេខ E 180.1។ មាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[760]មាត្រា ១០(១) នៃក្រមព្រហ្មទណ្ឌ។ *សូមមើលផងដែរ* មាត្រា ១៥(១) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។

ទោសដែលមានរយៈពេលកំណត់លើសពី ៣០ (សាមសិប) ឆ្នាំឡើយ។ មាត្រា ៤៦ (និយមន័យនៃបទឧក្រិដ្ឋ) នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ចែងថាៈ

> បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ៖
>
> (១) ជាទោសដាក់ពន្ធនាគារអស់មួយជីវិត។
>
> (២) ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ។

៣៤៨. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទំនាក់ទំនងរវាងមាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ត្រូវធ្វើការពិចារណាដើម្បីឆ្លុះបញ្ចាំងអំពីគោលការណ៍នៃច្បាប់ដែលមានចរិតពិសេស។ ដោយហេតុថាក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ គឺជាច្បាប់ទូទៅដែលដាក់ឱ្យអនុវត្តសម្រាប់តុលាការជាតិកម្ពុជា រីឯច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវបានតាក់តែងឡើងជាពិសេសសម្រាប់គោលបំណងពិសេសរបស់ អ.វ.ត.ក តាមអាណត្តិ យុត្តាធិការ ចរិត និងរចនាសម្ព័ន្ធរបស់ខ្លួន។ ដូច្នេះ ផ្អែកតាមគោលការណ៍នៃ*ច្បាប់ពិសេស* ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវមានអានុភាពអនុវត្តចំពោះកម្រិតទណ្ឌកម្មនៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។

៣៤៩. សេចក្តីសន្និដ្ឋាននេះផ្អែកទៅលើការបកស្រាយបទប្បញ្ញត្តិចំនួនពីរ គឺមាត្រា ៨ និងមាត្រា ៦៦៨ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។ មាត្រា ៦៦៨ (ការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក) នៃក្រមនេះចែងថា៖

> (១) ចំពោះបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសដោយច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកផ្សេងទៀត ដែលកំពុងនៅជាធរមាន ត្រូវអនុវត្ត ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះ។

(២) នៅក្នុងករណីដែលមានទំនាស់រវាងច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក និងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវអនុវត្ត ដោយអនុលោមតាមវិធានដែលមានចែងក្នុងគន្ថី ទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ។

(៣) បទប្បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើ មិនត្រូវយកមកអនុវត្ត ចំពោះច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស។

៣៥០. មាត្រា ៨ (អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ) នៃក្រមនេះចែងថាៈ

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរដែលកំណត់ដោយច្បាប់ដោយឡែក ទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ។

៣៥១. ក្រោយពីបានពិចារណាទៅលើពាក្យពេចន៍ និងខ្លឹមសារនៃបទប្បញ្ញត្តិទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជា "ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស" យោងតាមអត្ថន័យនៃមាត្រា ៦៦៨(៣) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។ ហេតុដូច្នេះ បទប្បញ្ញត្តិនៃគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ មិនមានអានុភាពជាងបទប្បញ្ញត្តិណាមួយនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឡើយ ក្នុងករណីដែលមានទំនាស់រវាងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ជាពិសេស ក្នុងករណីដែលតុលាការប្រកាសទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ ដែលមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មិនអនុញ្ញាតឱ្យមានការប្រកាសទោសលើសពី ៣០ (សាមសិប) ឆ្នាំទេ ប៉ុន្តែ មាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិញ មិនបានកំហិត អ.វ.ត.ក ក្នុងការប្រកាសទោសដាក់ពន្ធនាគារចាប់ពី ៣០ (សាមសិប) ឆ្នាំ រហូតដល់អស់មួយជីវិតនោះទេ។ ការកំណត់ខុសគ្នាបែបនេះ បង្កើតបានជាទំនាស់រវាងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក លើបញ្ហា ថាតើ អ.វ.ត.ក អាចកំណត់ទោសដាក់ពន្ធនាគារមានរយៈពេលកំណត់លើសពី ៣០ (សាមសិប)ឆ្នាំ

បានដែរ ឬយ៉ាងណា។ អាស្រ័យហេតុនេះ មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មិនត្រូវយកមកអនុវត្តលើរឿងក្ដីនានានៅចំពោះមុខ អ.វ.ត.ក នោះទេ ហើយកម្រិតនៃទណ្ឌកម្ម អាចស្ថិតនៅចន្លោះណាមួយរវាងទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ រហូតដល់ទោសអស់មួយជីវិត ដូចមានចែងនៅក្នុងមាត្រា ៣៩ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។ ដោយពិចារណាឃើញថា មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មិនមានអានុភាពចងកាតព្វកិច្ច អ.វ.ត.ក ទេ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ច្បាប់ដែលកំណត់ពី*ទោសស្រាលជាង* មិនអាចយកមកអនុវត្តក្នុងរឿងក្ដីបច្ចុប្បន្ននេះបានឡើយ[761]។

## ៥.ក.២.សេចក្ដីសន្និដ្ឋាន

៣៥២. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលទឡ្ហីករណ៍ទី ២ នៃបណ្ដឹងសាទុក្ខរបស់ **កាំង ហ្គេកអ៊ាវ** ត្រង់ចំណុចប្រឆាំងនឹងការផ្ដន្ទាទោស ដែលស្នើសុំឱ្យមានការកំណត់ទោសក្នុងកម្រិតទណ្ឌកម្ម ដូចដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។

## ៥.ខ.បទដ្ឋាននៃការពិនិត្យឡើងវិញស្ដីពីរបបនៃការប្រកាសទោស

៣៥៣. មុនពេលចាប់ផ្ដើមពិនិត្យលើទឡ្ហីករណ៍ទីមួយនៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើការបញ្ជាក់អំពីបទដ្ឋានជាធរមាននៃការពិនិត្យឡើងវិញ មុនពេលធ្វើការវាយតម្លៃទៅលើការសម្រេចផ្ដន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បណ្ដឹងសាទុក្ខប្រឆាំងនឹងការផ្ដន្ទាទោសត្រូវអនុលោមតាមវិធាន ១០៤ នៃវិធានផ្ទៃក្នុងដែលចែងថា៖

---

[761] *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង* Nikolić, សំណុំរឿងលេខ IT-94-02-A, "សាលដីកាលើបណ្ដឹងសាទុក្ខប្រឆាំងនឹងការប្រកាសទោស" អង្គជំនុំជម្រះតុលាការកំពូលថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ ("សាលដីកាក្នុង*រឿងក្ដី Nikolić*"), កថា ខណ្ឌ ៨១ (ដែលអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា គោលការណ៍នៃ*ការអនុវត្តច្បាប់ដែលចែងអំពីទោសដែលស្រាល*ទាក់ទងតែនឹងច្បាប់ដែលចងកាតព្វកិច្ចលើតុលាការប៉ុណ្ណោះ)។

(១) អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖

ក. កំហុសលើអង្គច្បាប់ ដែលនាំឱ្យមោឃៈសេចក្តីសម្រេចនោះ ឬ

ខ. កំហុសនៃអង្គហេតុ ដែលនាំឱ្យសេចក្តីសម្រេចនោះ មានភាពមិនយុត្តិធម៌។

(...)

(២) អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចតម្កល់ ឬ ទុកជាមោឃៈ ឬ កែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមួយផ្នែក ឬទាំងស្រុងបាន ដូចមានចែងក្នុងវិធាន ១១០។

(៣) សេចក្តីសម្រេចនៃអង្គជំនុំជម្រះតុលាការកំពូល គឺជាសេចក្តីសម្រេចចុងក្រោយ និងមិនត្រូវបង្វិលឱ្យអង្គជំនុំជម្រះសាលាដំបូងវិញឡើយ[762]។

៣៥៤. ទោះបីជាយ៉ាងណាក៏ដោយ ក៏មិនមានគោលការណ៍ណែនាំនៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ឬច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការកម្ពុជាពាក់ព័ន្ធនឹងការអនុវត្តវិធាន ១០៤(១) (ក) (ខ) នៃវិធានផ្ទៃក្នុងទៅលើបណ្តឹងសាទុក្ខប្រឆាំងនឹងការផ្តន្ទាទោសឡើយ។ ក្នុងកាលៈទេសៈបែបនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវស្វែងរកគោលការណ៍ណែនាំក្នុងកម្រិតអន្តរជាតិ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្រប និងទទួលយកបទដ្ឋានដែលបានគូសបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ថា ជាការបកស្រាយអំពីការអនុវត្តដ៏ត្រឹមត្រូវនៃវិធាន ១០៤(១) (ក) (ខ) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទាក់ទងទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងការផ្តន្ទាទោសដែលមានដូចខាងក្រោម:

---

[762]វិធាន ១០៤ នៃវិធានផ្ទៃក្នុង។

ដោយយោងតាមកាតព្វកិច្ចក្នុងការអនុវត្តគោលការណ៍ឯកត្តកម្មនៃទោស ដើម្បីឱ្យសមស្របទៅតាមស្ថានភាពរបស់ជនជាប់ចោទ និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ ក្នុងការកំណត់ការផ្តន្ទាទោសយ៉ាងសមស្រប រួមបញ្ចូលទាំងការថ្លឹងថ្លែងអំពីស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោស។ តាមវិធានទូទៅ អង្គជំនុំជម្រះតុលាការកំពូលនឹងមិនធ្វើការកែប្រែទោសឡើយ លើកលែងតែអង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ឬខកខានមិនបានអនុវត្តតាមច្បាប់ជាធរមាន។ ម្ចាស់បណ្តឹងសាទុក្ខត្រូវបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានថ្លឹងថ្លែងអំពីកត្តានានាដែលមិនជាប់ពាក់ព័ន្ធ ឬក្រៅសាច់រឿង ឬខកខានមិនបានថ្លឹងថ្លែង ឬថ្លឹងថ្លែងមិនបានគ្រប់គ្រាន់ចំពោះកត្តាពាក់ព័ន្ធនានា ដែលបណ្តាលឱ្យមានកំហុសអង្គហេតុយ៉ាងច្បាស់ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ឬត្រូវបង្ហាញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនមានសំអាងហេតុអ្វីទាល់តែសោះ ឬមានភាពមិនយុត្តិធម៌ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលអាចលើកឡើងបានថា អង្គជំនុំជម្រះសាលាដំបូងពិតជាខកខានមិនបានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវមែន[763]។

## ៥.គ.ទទ្បីករណ៍ទី ១ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

៣៥៥. នៅក្នុងទទ្បីករណ៍ទីមួយនៃបណ្តឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាលើកឡើងថា៖ អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយមិនបានផ្តន្ទាទោសកម្រិតខ្ពស់បំផុតដែលអង្គជំនុំជម្រះសាលាដំបូងអាចសម្រេចបាន ដោយផ្អែកតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពោលគឺទោសដាក់ពន្ធនាគារអស់មួយជីវិត។ ការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៣៥ (សាមសិបប្រាំ)ឆ្នាំ មិនបានដាក់ទម្ងន់ឱ្យបានគ្រប់គ្រាន់ទៅលើស្ថានទម្ងន់ដែលជាកត្តាសត្យានុម័តនៃបទល្មើស ដែលតម្រូវឱ្យដាក់ទោសកម្រិតខ្ពស់បំផុតនោះទេ។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការដាក់ទោស ដែលមានលក្ខណៈស្រាលពេក និងមានភាពមិនយុត្តិធម៌ដែលបានស្តែងចេញយ៉ាងច្បាស់ ដោយមិនបានពិចារណាអំពីកាលៈទេសៈជាក់លាក់របស់ កាំង ហ្គេកអ៊ាវ។ ក្រោយពីបានវាយតម្លៃលើស្ថានទម្ងន់ទោស ដោយផ្អែកលើកត្តាទាំងឡាយដែលសហព្រះរាជអាជ្ញាបាន

---

[763]សាលដីកាក្នុង *រឿងក្តី D.Milošević*, កថាខណ្ឌ ២៩៧។

ស្មើឡើង អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្តល់ទម្ងន់ឱ្យបានគ្រប់គ្រាន់ទៅលើស្ថានទម្ងន់ទោសទាំងនេះទេ ជាពិសេសការរំលោភអំណាច និងអំពើគ្មានមេត្តាធម៌ចំពោះជនរងគ្រោះដែលមិនមានមធ្យោបាយការពារខ្លួនអ្វីទាល់តែសោះ និងស្ថិតក្នុងស្ថានភាពងាយរងគ្រោះបំផុត ហើយឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយមានចេតនារើសអើង[764]។

៣៥៦. សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានរកឃើញស្ថានសម្រាលទោសដែលលើកឡើងដោយ កាំង ហ្គេកអ៊ាវ មានទម្ងន់"នៅមានកម្រិត" ឬ "តិចតួច"ក៏ដោយ ក៏នៅក្នុងការប្រកាសទោសចុងក្រោយរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបែរជាចាត់ទុកស្ថានសម្រាលទោសទាំងនោះថា "មានសារៈសំខាន់"ទៅវិញ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយភ័ន្តច្រឡំថា ទោសដាក់ពន្ធនាគារអស់មួយជីវិតចាំបាច់ត្រូវបន្ថយមក"ទោសដែលមានរយៈពេលកំណត់" ៣៥ (សាមសិបប្រាំ) ឆ្នាំ។ អង្គជំនុំជម្រះសាលាដំបូង ខកខានក្នុងការពិចារណាលើសេចក្តីសន្និដ្ឋានបើកការដេញដោលរបស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងថា កាំង ហ្គេកអ៊ាវ គប្បីទទួលបានការបន្ថយទោសតិចតួចប៉ុណ្ណោះ ចំពោះកិច្ចសហការ "ជាទូទៅ" របស់ខ្លួនជាមួយនឹងតុលាការ ការទទួលស្គាល់ការទទួលខុសត្រូវតិចតួច និងផលប៉ះពាល់ដែលអាចមានលើការផ្សះផ្សាជាតិ។ អង្គជំនុំជម្រះសាលាដំបូង ក៏ខកខានក្នុងការពិចារណាលើសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលរបស់សហព្រះរាជអាជ្ញាដែលថា អង្គជំនុំជម្រះសាលាដំបូង មិនគួរយកស្ថានសម្រាលទោសមកពិចារណាឡើយ ដោយសារការផ្លាស់ប្តូរនូវវិធីការពារក្តីរបស់ កាំង ហ្គេកអ៊ាវ និងសំណើសុំឱ្យរួចផុតពីបទចោទ[765]។

៣៥៧. សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមទៀតថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ខកខានក្នុងការផ្តល់សំអាងហេតុ ចំពោះការសម្រេចផ្តន្ទាទោស កាំង ហ្គេកអ៊ាវ ឱ្យជាប់ពន្ធនាគាររយៈពេលកំណត់ ៣៥ (សាមសិបប្រាំ)ឆ្នាំ ហេតុដូច្នេះហើយ សាលក្រមនេះបានសម្រេចផ្តន្ទាទោស ដោយមិនសមហេតុផល មិនផ្អែកលើយុត្តិសាស្ត្ររបស់តុលាការចំពោះរឿងក្តីណាមួយ

[764]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៣២, ៣៤, ៤៣, ៥០ ដល់ ៥៥។

[765]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៦១, ៦៣។

ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា និងមិនផ្អែកលើច្បាប់ពាក់ព័ន្ធទាំងឡាយ ដូចសហព្រះរាជអាជ្ញាបានលើកឡើងនៅពេលជំនុំជម្រះនោះឡើយ។ ជាក់ស្តែងណាស់ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ នៅពេលសម្រេចផ្តន្ទាទោស កាំង ហ្គេកអ៊ាវ ដោយមិនមានភាពយុត្តិធម៌។ ការផ្តន្ទាទោសនេះស្ថិតនៅក្រៅដែនកំណត់នៃទោសយ៉ាងច្បាស់ក្រឡែតដែលអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចនៅក្នុងកាលៈទេសៈនៃរឿងក្តីនេះ ហើយការផ្តន្ទាទោសនេះ មិនបានឆ្លុះបញ្ចាំងឱ្យបានគ្រប់គ្រាន់ពីគោលបំណងជាសារវន្តនៃការផ្តន្ទាទោសក្នុងរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ ជាពិសេសគោលបំណងនៃការធ្វើឱ្យរាងចាល និងការស្តារនីតិសម្បទាឡើងវិញនោះទេ។ ការផ្តន្ទាទោសដែលទាបជាងទោសដាក់ពន្ធនាគារអស់មួយជីវិតមិនបានឆ្លុះបញ្ចាំងឱ្យបានគ្រប់គ្រាន់ពីកំហឹងរបស់សហគមន៍ជាតិ និងអន្តរជាតិ ចំពោះអំពើឧក្រិដ្ឋទាំងឡាយរបស់ជនជាប់ចោទ និងមិនបានព្រមានឱ្យបានគ្រប់គ្រាន់ ដើម្បីទប់ស្កាត់មិនឱ្យមានការប្រព្រឹត្តនូវឧក្រិដ្ឋកម្មប្រភេទនេះនាពេលអនាគតនោះឡើយ[766]។

៣៥៨. យោងតាមសំអាងហេតុខាងលើ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលៈ

(ក) កែប្រែការប្រកាសទោស ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចឱ្យទៅជាទោសដាក់ពន្ធនាគារអស់មួយជីវិត។

(ខ) បង្គាប់ថា ទោសខាងលើនេះត្រូវកាត់បន្ថយមកនៅត្រឹមទោសដាក់ពន្ធនាគាររយៈពេលកំណត់ ៤៥ (សែសិបប្រាំ)ឆ្នាំ ដើម្បីជាការផ្តល់សំណងមួយដ៏សមស្របសម្រាប់ការឃុំខ្លួនជនជាប់ចោទដោយខុសច្បាប់នីតិវិធី នៅតុលាការយោធា។

(គ) បង្គាប់ថា ការកាត់បន្ថយទោសបន្ថែមទៀតត្រូវធ្វើឡើងឱ្យបានសមស្របចំពោះស្ថានសម្រាលទោសដែលមានកម្រិតតិចតួចបំផុតនៅក្នុងរឿងក្តីនេះ ដោយត្រូវកាត់បន្ថយទោសជាអតិបរមាត្រឹម ៥ (ប្រាំ) ឆ្នាំ និង

---

[766] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៩២, ១២១។

(ឃ) សម្រេចថា ជនជាប់ចោទនឹងត្រូវអនុវត្តទោសដោយពុំមានលទ្ធភាពទទួលបានការដោះលែងដោយមានលក្ខខណ្ឌឡើយ[767]។

៣៥៩. មេធាវីការពារក្តីមិនបានដាក់សារណាតបជាលាយលក្ខណ៍អក្សរ ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាឡើយ។ សារណារបស់មេធាវីការពារក្តីដែលមិនបានលើកឡើងលម្អិតទាក់ទងទៅនឹងស្ថានសម្រាលទោស និងការផ្តន្ទាទោសដ៏សមស្របនោះ ត្រូវបានសង្ខេបនៅផ្នែកខាងលើរួចហើយ ហើយនឹងត្រូវដោះស្រាយនៅផ្នែកខាងក្រោម ដោយរួមជាមួយនឹងសារណារបស់សហព្រះរាជអាជ្ញា។

### ៥.គ.១.សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការប្រកាសទោស

៣៦០. នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របជាមួយសហព្រះរាជអាជ្ញាថា តួនាទីរបស់ កាំង ហ្កេកអ៊ាវ នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ផលប៉ះពាល់នៃឧក្រិដ្ឋកម្មទាំងនេះទៅលើជនរងគ្រោះ និងក្រុមគ្រួសារជនរងគ្រោះ ព្រមទាំងស្ថានភាពបុគ្គលរបស់ កាំង ហ្កេកអ៊ាវ គឺជាកត្តាពាក់ព័ន្ធក្នុងការកំណត់អំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា កាំង ហ្កេកអ៊ាវ គឺជាអ្នកទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មនានា ដែលមានលក្ខណៈសាហាវឃោរឃៅ និងគួរឱ្យតក់ស្លុតរន្ធត់យ៉ាងខ្លាំង ហើយអង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ឧក្រិដ្ឋកម្មរបស់ជនជាប់ចោទមានលក្ខណៈធ្ងន់ធ្ងរបំផុត។ អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញផងដែរនូវស្ថានទម្ងន់ទោសនានា ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង ជាពិសេស:

(ក) ការរំលោភអំណាច ឬការរំលោភមុខងារផ្លូវការរបស់ជនជាប់ចោទ

(ខ) ភាពសាហាវឃោរឃៅនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត

(គ) នត្ថិភាពនៃមធ្យោបាយការពារខ្លួនរបស់ជនរងគ្រោះ និង

---

[767]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២១៦។

(ឃ) ចេតនារើសអើងក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម[768]។

ទាក់ទងនឹងស្ថានសម្រាលទោសវិញ អង្គជំនុំជម្រះសាលាដំបូងបាន:

(ក) ថ្លឹងថ្លែងតិចតួចចំពោះបរិយាកាសគាបសង្កត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងតំណែងរបស់ជនជាប់ចោទ ក្នុងនាមជាអ្នកនៅក្រោមបង្គាប់ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។

(ខ) ពិចារណាថា ការសហការរបស់ជនជាប់ចោទជាមួយ អ.វ.ត.ក អាចចាត់ទុកជាស្ថានសម្រាលទោសបាន។

(គ) រកឃើញថា ការដែលជនជាប់ចោទមិនបានទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនឱ្យបានពេញលេញ និងច្បាស់លាស់ ធ្វើឱ្យអានុភាពនៃស្ថានសម្រាលទោសចំពោះការសម្តែងវិប្បដិសារីរបស់ជនជាប់ចោទត្រូវបានកាត់បន្ថយ និងស្ទើរតែមិនមាន និង

(ឃ) ពិចារណាបន្តិចបន្តួចចំពោះលទ្ធភាពក្នុងការកែប្រែខ្លួនរបស់ជនជាប់ចោទ[769]។

៣៦១. ក្នុងការប្រកាសទោស អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដូចតទៅ៖

ដើម្បីកំណត់ទោសមួយឱ្យបានសមស្រប អង្គជំនុំជម្រះបានពិចារណានូវកាលៈទេសៈទាំងអស់នៃរឿងក្តីនេះ រួមទាំងគោលការណ៍នៃការផ្តន្ទាទោសដែលពាក់ព័ន្ធ និងកត្តាទាំងអស់ដែលបានពិភាក្សាពីមុននេះ។

អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានជាឯកច្ឆន្ទថា ពិតជាមានស្ថានសម្រាលទោសដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះ កំណត់ទោសដាក់ពន្ធនាគារដែលមានរយៈពេលកំណត់ជាក់លាក់មួយបាន ក្នុងករណីដែលទោសដាក់ពន្ធនាគារអស់មួយជីវិតមិនត្រូវបានយកមក

[768]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៩៦ ដល់ ៥៩៧,៦០០ ដល់ ៦០៥។

[769]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦០៨ ដល់ ៦១១។

អនុវត្តនោះ។ ស្ថានសម្រាលទោសទាំងនេះ មានដូចជា៖ កិច្ចសហការរបស់ជនជាប់ចោទជាមួយអង្គជំនុំជម្រះ ការទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្លួន ការសម្តែងវិប្បដិសារីរបស់ខ្លួន (ទោះបីជាត្រូវកាត់បន្ថយនូវការសម្រាល ដោយសារគាត់បានស្នើសុំឱ្យរួចផុតពីការចោទប្រកាន់លើរូបគាត់ នៅក្នុងសម្តីចុងក្រោយរបស់គាត់យ៉ាងណាក្តី) បរិយាកាសបង្ខិតបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលគាត់បានបំពេញការងារ និងសក្តានុពលដែលអាចស្តារនីតិសម្បទាបានរបស់គាត់។

អង្គជំនុំជម្រះកត់សម្គាល់បន្ថែមផងដែរ លើស្ថានទម្ងន់ទោសជាច្រើន រួមទាំងលក្ខណៈនៃបទល្មើសដែលគួរឱ្យតក់ស្លុតរន្ធត់យ៉ាងខ្លាំង និងសាហាវយង់ឃ្នងដែលត្រូវបានប្រព្រឹត្តមកលើជនរងគ្រោះយ៉ាងតិច ១២.២៧៣ នាក់ ក្នុងរយៈពេលដែលបានអូសបន្លាយយ៉ាងយូរ។ នៅពេលធ្វើការពិចារណារួមគ្នាទាំងមូល កត្តាទាំងអស់នេះអាចឱ្យអង្គជំនុំជម្រះកំណត់រយៈពេលមួយជាក់លាក់សម្រាប់ផ្តន្ទាទោសដាក់ពន្ធនាគារបាន។

តាមមូលដ្ឋានដូចបានរៀបរាប់ខាងលើ មតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះ (លោកចៅក្រម Lavergne ជំទាស់) សម្រេចកំណត់រយៈពេលដាក់ពន្ធនាគារចំនួន ៣៥ (សាមសិបប្រាំ) ឆ្នាំ[770]។

៣៦២. យោងតាមការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងចំណោមកត្តាស្ថានសម្រាលទោសទាំងបួន កត្តាចំនួនពីរមានអានុភាពសម្រាលទោស"តិចតួច"ប៉ុណ្ណោះ ហើយអានុភាពនៃស្ថានសម្រាលទោសរបស់កត្តាទីបី "ត្រូវបានកាត់បន្ថយ" និង"ស្ទើរតែមិនមាន" នោះទេ។ ប៉ុន្តែ នៅក្នុងផ្នែកក្រោយទៀតនៃសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បែរជាបានរៀបរាប់អំពីកត្តាស្ថានសម្រាលទោសទាំងបួនថា ជាកត្តាដែល"មានសារៈសំខាន់"ទៅវិញ[771] ដោយមិនមានការពន្យល់អ្វីនោះទេ។ ជាការសន្និត អានុភាពត្រួតគ្នានៃកត្តាស្ថានសម្រាលទោសទាំងបីដែលមានអានុភាព"តិចតួច" ឬ"ស្ទើរតែមិនមាន"នោះ រួមផ្សំជាមួយនឹងកិច្ចសហ

[770]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦២៨ ដល់ ៦៣១។

[771]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦០៨ ដល់ ៦១១ និង៦២៩។

ការរបស់ កាំង ហ្គេកអ៊ាវ បានធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កត្តាស្ថាន សម្រាលទោសទាំងនេះ "មានសារៈសំខាន់"ទៅវិញ។

៣៦៣. ទោះបីជា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការថ្លឹងថ្លែងអំពីកត្តាស្ថាន សម្រាលទោសយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មានកំហុស អង្គច្បាប់ចំពោះអានុភាពនៃកត្តាស្ថានសម្រាលទោស នៅក្នុងការសម្រេចដាក់ទោសរបស់ អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូល នឹងពិនិត្យកត្តាស្ថានសម្រាលទោស នីមួយៗដើម្បីសម្រេចទៅលើសារណារបស់សហព្រះរាជអាជ្ញាដែលលើកឡើងថា កត្តាស្ថាន សម្រាលទោសទាំងនេះទទួលបានការផ្តល់ទម្ងន់ហួសហេតុក្នុងការផ្តន្ទាទោស។

៣៦៤. ទីមួយ ទោះបីជាពុំមានភស្តុតាងបង្ហាញពីការបង្ខិតបង្ខំណាមួយក៏ដោយ ក៏អង្គជំនុំជម្រះសាលា ដំបូងបានធ្វើការពិចារណាតែបន្តិចបន្តួចទៅលើ "បរិយាកាសគាបសង្កត់នៅក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទជាអ្នកនៅក្រោមបង្គាប់គេ ក្នុងបក្សកុម្មុយនីស្ត កម្ពុជា" ផងដែរ[772]។ ការយល់ឃើញនេះ គឺមាននៅក្នុងកថាខណ្ឌស្តីពីការបង្ខិតបង្ខំដោយ ហេតុថា ការបង្ខិតបង្ខំនេះមានហេតុផលចម្បង ទោះបីជាក្នុងកម្រិតតិចតួចក៏ដោយ ក៏ការផ្តន្ទា ទោសគប្បីធ្វើឡើងឱ្យសមស្របទៅនឹងលទ្ធភាពដែលមានតិចតួចរបស់ កាំង ហ្គេកអ៊ាវ ក្នុង ការជ្រើសរើសយកជម្រើសផ្សេង ដែលមានលក្ខណៈសីលធម៌ ដោយហេតុថាការបដិសេធក្នុង ការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ នឹងនាំទៅដល់ការគំរាមកំហែងដល់អាយុជីវិតរបស់ កាំង ហ្គេកអ៊ាវ។ ក្នុងរឿងក្តីបច្ចុប្បន្ននេះ កាំង ហ្គេកអ៊ាវ បានខកខានក្នុងការបង្ហាញថា ខ្លួនមិនមាន ជម្រើសអ្វីក្រៅពីការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ឬថាខ្លួនបានទទួលការគំរាម កំហែងដល់អាយុជីវិត ឬថាខ្លួនបានព្យាយាមក្នុងការផ្តាច់ខ្លួនចេញពីអំពើឧក្រិដ្ឋរបស់ខ្លួន ឡើយ[773]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ជនជាប់ចោទខ្លួនឯងបានចូលរួម

---

[772] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦០៨។

[773] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Erdemović*, សំណុំរឿងលេខ IT-96-22-T*ស្ទួន*, "សាលក្រមស្តីពីការប្រកាសទោស", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩៩៨, កថាខណ្ឌ ១៧ (ដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការគំរាមកំហែងគឺជាកត្តាស្ថានសម្រាលទោសមួយ នៅពេលដែលជនជាប់ចោទអាចបង្ហាញថា ជីវិតរបស់ក្រុមគ្រួសារ និង

ដោយស្ម័គ្រចិត្ត និងដោយសកម្ម"[774] ក្នុងការប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងឡាយ ដោយប្រើសិទ្ធិអំណាចរបស់គាត់ "ក្នុងការអនុវត្តនូវមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា" តាមរយៈ "ការប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់"[775]។ ហេតុដូច្នេះ ស្ថានសម្រាលទោសដោយមូលហេតុ "បរិយាកាសគាបសង្កត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[776] គឺមានកម្រិតអប្បបរមា។

៣៦៥. ទីពីរ អានុភាពនៃស្ថានសម្រាលទោស ដែលអាចមានក្នុង"តួនាទីរបស់ កាំង ហ្កេកអ៊ាវ ជាអ្នកស្ថិតក្រោមបង្គាប់គេ"[777]ត្រូវវាយតម្លៃតាមរយៈបទបញ្ជារបស់ថ្នាក់លើ ដែល កាំង ហ្កេកអ៊ាវ បានទទួលយកមកអនុវត្ត។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយ ដោយហេតុថា កាំង ហ្កេកអ៊ាវ បានដឹងថា បទបញ្ជាទាំងនេះខុសច្បាប់[778] និងថាបទបញ្ជាទាំងនេះមិន"មានការគំរាមកំហែងដែលនាំទៅដល់ការបង្ខិតបង្ខំ"[779] ទើបអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា មិនមានអានុភាពនៃស្ថានសម្រាលទោសសម្រាប់ការបង្ខិតបង្ខំនេះទេ។

---

ជីវិតរបស់ខ្លួនស្ថិតក្រោមការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរនិងជាក់ច្បាស់ប៉ុណ្ណោះទេ នឹងថែមទាំងត្រូវបង្ហាញដល់តុលាការថាខ្លួនបានបង្ហាញឆន្ទៈមិនគោរពតាមបញ្ជាដែលជាបទល្មើសមកលើខ្លួនជាច្រើនលើកច្រើនសារ)។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Erdemović,* សំណុំរឿងលេខ IT-96-22-TA "មតិជំទាស់ដាច់ដោយឡែករបស់ចៅក្រម Casseses", អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ១៩៩៧, កថាខណ្ឌ ១៥ ("ប្រសិនបើ បញ្ជារបស់ថ្នាក់លើបង្ហាញថាខុសច្បាប់តាមច្បាប់អន្តរជាតិនោះ អ្នកក្រោមបង្គាប់មានកាតព្វកិច្ចក្នុងការបដិសេធបញ្ជានេះ។ បន្ទាប់ពីបានបដិសេធហើយ ប្រសិនបើបញ្ជានេះត្រូវបានធ្វើឡើងសាជាថ្មីទៀតដោយមានការគំរាមកំហែងណាមួយដល់អាយុជីវិត ឬអវៈយវៈណាមួយនោះ សិទ្ធិក្នុងការពារខ្លួនពីការគំរាមកំហែងនេះ អាចត្រូវបានលើកយកការពារខ្លួនដោយស្របច្បាប់")។

[774]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៥៧។

[775]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៩៥។

[776]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦០៨។

[777]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦០៨។

[778]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៥២។

[779]*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Mrđa,* សំណុំរឿងលេខ IT-02-59-S, "សាលក្រមស្តីពីការប្រកាសទោស", អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣១ខែមីនាឆ្នាំ២០០៤កថាខណ្ឌ៦៧ ("អង្គហេតុដែលថា ជនជាប់ចោទស្តាប់បង្គាប់តាមបទបញ្ជាដែលខុសគ្នាទៅនឹងការអនុវត្តតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់នោះមិនសមនឹងទទួលបានការសម្រាលទោស" ដោយពុំមានភស្តុតាងបង្ហាញអំពីការគំរាមកំហែងនោះឡើយ)។

៣៦៦. ទីបី អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ការសហការរបស់ កាំង ហ្កេកអ៊ាវ ជាមួយនឹង អ.វ.ត.ក ជាកត្តាស្ថានសម្រាលទោស[780] ហើយសម្រេចថា "ការសហការនេះ បានសម្រួលដល់ដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះ" និង"បានជួយក្នុងការស្វែងរកការផ្សះផ្សាជាតិ"[781]។ តុលាការព្រហ្មទណ្ឌអន្តរជាតិដ៏ទៃទៀត ក៏បានទទួលស្គាល់ការសហការយ៉ាងច្រើនជាមួយនឹងអយ្យការ ដែលជាកត្តានៃស្ថានសម្រាលទោសមួយក្នុងការផ្តន្ទាទោស[782]ផងដែរ។ ក្នុងករណីនេះ ការពិចារណាត្រឹមត្រូវត្រូវតែមានចំពោះកិច្ចសហការរបស់ជនជាប់ចោទ ដូចជាការបំភ្លឺអំពីភាពមន្ទិលសង្ស័យនៃការស៊ើបអង្កេត ដែលរួមមានបទឧក្រិដ្ឋនានាដែលរដ្ឋអាជ្ញា[783] ពុំបានដឹងពីមុនមក និងការទទួលស្គាល់អង្គហេតុ[784] និងការជួយសម្រួលដល់កិច្ចប្រតិបត្តិការដែលនាំទៅដល់ការចាប់ខ្លួនជនសង្ស័យដទៃទៀត[785] និងការយល់ព្រមផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី នៅក្នុងដំណើរការនីតិវិធីផ្សេងៗទៀត[786]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានសម្រេចរួចហើយថា:

---

[780]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧។

[781]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ៦០៨។

[782]វិធាន ១៤៥(ក)(២) នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ វិធាន ១០១(ខ)(២) នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់តុលាការ ICTY។ វិធាន ១០១(ខ)(២) នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់តុលាការ ICTR និង វិធាន ១០១(ខ)(២) នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់តុលាការ SCSL។ សាលដីកាក្នុង*រឿងក្តី Galić*, កថាខណ្ឌ ៤៣៤។

[783]*សូមមើលឧទា.* សាលក្រម*ក្នុងរឿងក្តី Serugendo*, កថាខណ្ឌ ៦១ និង ៦២។

[784]*សូមមើលឧទា. រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Musema*, សំណុំរឿងលេខ ICTR-96-13-A, "សាលក្រម និងការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០ ("សាលក្រមក្នុង*រឿងក្តី Musema*"), កថាខណ្ឌ ១០០៧។

[785]*សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Serushago*, សំណុំរឿងលេខ ICTR-98-39-S, "ការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ("ការផ្តន្ទាទោសក្នុង *រឿងក្តី Serushago*"), កថាខណ្ឌ ៣២។

[786]*សូមមើលឧទា.* ការផ្តន្ទាទោសក្នុង*រឿងក្តី Serugendo*, កថាខណ្ឌ ៣៣។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Todorović*សំណុំរឿងលេខ IT-95-9/1-S, "សាលក្រមស្តីពីការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១, កថាខណ្ឌ ៨៤។

ភាពស្មោះត្រង់ និងកម្រិតនៃការសហការរបស់ជនជាប់ចោទជាមួយនឹងរដ្ឋអាជ្ញា គឺជាកត្តានៃការសម្រេច ថាតើមានមូលហេតុក្នុងការកាត់បន្ថយទោសដោយផ្អែកលើមូលដ្ឋាននេះ ដែរ ឬយ៉ាងណា។ ហេតុដូច្នេះ ការវាយតម្លៃអំពីកិច្ចសហការរបស់ជនជាប់ចោទ គឺអាស្រ័យទៅលើបរិមាណ និងគុណភាពនៃព័ត៌មានដែលជនជាប់ចោទបានផ្ដល់ជូនតុលាការ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងផ្ដោតជាពិសេសទៅលើការសហការដោយស្ម័គ្រចិត្ត និងដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ដែលត្រូវបានផ្ដល់ដោយមិនមានការស្នើសុំអ្វីមួយជាថ្នូរ[787]។

៣៦៧. នៅក្នុងរឿងក្ដីបច្ចុប្បន្ននេះ សហព្រះរាជអាជ្ញាបានលើកឡើងថា ការសហការរបស់ កាំង ហ្គេកអ៊ាវ មានកម្រិតតិចតួច បានជួយសម្រួលតិចតួចដល់ការសន្សំសំចៃនៃកិច្ចដំណើរការនីតិវិធី ហើយជាចុងក្រោយ មិនបានពេញលេញ ដោយត្រូវសៗ និងបែបឱកាសនិយម[788]។ មេធាវីការពារក្ដីមិនបានលើកឡើងនូវទឡ្ហីករណ៍ ដែលមានលក្ខណៈរឹងមាំនៅក្នុងសារណាតបរបស់ខ្លួនឡើយ។ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងទទួលបាននូវឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយក្នុងការវាយតម្លៃអំពីកត្តាស្ថានសម្រាលទោស។ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលនៅតែកត់សម្គាល់ថា សេចក្ដីសន្និដ្ឋាននៅពេលសវនាការដែលមានលក្ខណៈលម្អិត និងមានសេចក្ដីយោងត្រឹមត្រូវរបស់សហព្រះរាជអាជ្ញាដែលអះអាងថា កត្តាស្ថានសម្រាលនេះគួរតែទទួលបាននូវទម្ងន់តិចតួចប៉ុណ្ណោះ ហើយសេចក្ដីសន្និដ្ឋានទាំងនេះមិនត្រូវបានយកមកពិចារណាទាល់តែសោះ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។

៣៦៨. អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយសហព្រះរាជអាជ្ញាដែលថា កាំង ហ្គេកអ៊ាវ បានខកខានក្នុងការផ្ដល់នូវទិដ្ឋភាពពេញលេញនៃការយល់ដឹងអំពីអង្គហេតុរបស់ខ្លួន នៅក្នុងរឿងក្ដីនេះ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយជាអតិបរមានូវតួនាទីរបស់ខ្លួននៅក្នុងឧក្រិដ្ឋកម្មទាំងឡាយ។ កាំង ហ្គេកអ៊ាវ បានគេចវេសដោយប្រុងប្រយ័ត្ន ក្នុងការឆ្លើយតបដោយពេញ

[787]សាលក្រមក្នុង *រឿងក្ដី Blaškić*, កថាខណ្ឌ ៧៧៤ (សេចក្ដីដកស្រង់ត្រូវបានលុបចោល)។

[788]សារណាដេញដោលបញ្ចប់នៃការជំនុំជម្រះរបស់សហព្រះរាជអាជ្ញា, ឯកសារលេខ E159/9, ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩, កថាខណ្ឌ ៦៦ ដល់ ៧០, ៤២៣ ដល់ ៤២៧។

លេញនៅពេលប្រឈមទៅនឹងការចោទប្រកាន់នានា ដែលទាក់ទិននឹងការចូលរួមដោយផ្ទាល់របស់ខ្លួននៅក្នុងឧក្រិដ្ឋកម្មទាំងឡាយ ដោយទម្លាក់ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះទៅលើអ្នកដទៃវិញ ហើយបានធ្វើសេចក្ដីថ្លែងការណ៍ដែលមិនស៊ីសង្វាក់ជាមួយនឹងភស្តុតាងដែលមាន។ ជាសរុប បន្ទាប់ពីបានពិនិត្យឡើងវិញនូវសកម្មភាពទាំងមូលរបស់ កាំង ហ្កេកអ៊ាវ នៅក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការសហការរបស់ កាំង ហ្កេកអ៊ាវ មិនបានផ្ដល់នូវព័ត៌មានយ៉ាងច្រើនទាំងបរិមាណ និងគុណភាពទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ការសហការនេះទទួលបានទម្ងន់តិចតួចប៉ុណ្ណោះ។

៣៦៩. ទីបួន ចំពោះការសម្ដែងវិប្បដិសារី អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ទោះបីជាមានការសុំទោសជាសាធារណៈក៏ដោយ ក៏“ការខកខានក្នុងការបង្ហាញនូវការទទួលខុសត្រូវរបស់ កាំង ហ្កេកអ៊ាវ ឱ្យបានពេញលេញ និងដោយគ្មានលក្ខខណ្ឌ បានប៉ះពាល់ដល់ស្ថានសម្រាលទោសដែលអាចនឹងបានមកពីការសម្ដែងវិប្បដិសារីរបស់គាត់” ជាពិសេស ការស្នើសុំឱ្យរួចខ្លួន[789]ដែលបានធ្វើឡើងនាពេលក្រោយ។ អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា ការបដិសេធមិនទទួលខុសត្រូវ និងការស្នើសុំឱ្យរួចខ្លួន គឺជាសិទ្ធិជាសារវន្តរបស់ កាំង ហ្កេកអ៊ាវ។ ក៏ប៉ុន្តែ ក្នុងករណីនេះគប្បីមានការកត់សម្គាល់ថា ការស្នើសុំឱ្យរួចខ្លួនមិនបានផ្អែកលើការបដិសេធនូវអង្គហេតុ និងពិរុទ្ធភាពឡើយ ហើយតាមតថភាព និងផ្លូវច្បាប់ ការសុំនេះមិនបានប៉ះពាល់ទៅដល់ការសម្ដែងវិប្បដិសារីឡើយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅក្នុងអំឡុងពេលសវនាការលើបណ្ដឹងសាទុក្ខ កាំង ហ្កេកអ៊ាវ បានចំណាយពេលដែលបានផ្ដល់ឱ្យស្ទើរតែទាំងស្រុង ទៅលើសេចក្ដីថ្លែងការណ៍ចុងក្រោយរបស់ខ្លួន ក្នុងការសុំកាត់បន្ថយជាអតិបរមានូវការទទួលខុសត្រូវរបស់ខ្លួន ដោយបានទម្លាក់ការទទួលខុសត្រូវនេះ ទៅលើ“មេដឹកនាំជាន់ខ្ពស់”ទៅវិញ។ នៅក្នុងអំឡុងពេលធ្វើសេចក្ដីថ្លែងការណ៍ចុងក្រោយដែលមានរយៈពេលជិតសាមសិបនាទី កាំង ហ្កេកអ៊ាវ បានលើកឡើងយ៉ាងលម្អិតអំពីហេតុផលដែលគាត់ជឿជាក់ថា ខ្លួនគាត់មិនស្ថិតនៅក្នុងដែនយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក ទេ

[789]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦១០។

ទន្ទឹមគ្នានេះដែរ ការសម្តែងអំពីវិប្បដិសារី និងការសុំទោស មានកម្រិតតិចតួចត្រឹមតែពីរបីប្រយោគប៉ុណ្ណោះ ដែលក្នុងនោះ កាំង ហ្កេកអ៊ាវ "នៅតែប្រកាន់ជំហរសុំអភ័យទោស"ពីជនរងគ្រោះ និងក្រុមគ្រួសារឱ្យ"ទទួលយកការសុំអភ័យទោសរបស់ខ្លួន[790]"។ ឥរិយាបទនេះបង្ហាញថា កាំង ហ្កេកអ៊ាវ បាត់បង់ឱកាសចុងក្រោយក្នុងការបង្ហាញពីភាពស្មោះត្រង់ក្នុងការធ្វើសេចក្តីថ្លែងការណ៍ពីមុនស្តីពីវិប្បដិសារី និងការសុំអភ័យទោស[791]។ ដោយបានពិចារណាលើបញ្ហាទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទម្ងន់នៃការសម្តែងវិប្បដិសារីដែលជាកត្តាសម្រាលទោសនោះ មានកម្រិតតិចតួចប៉ុណ្ណោះ។

៣៧០. កត្តាស្ថានសម្រាលទោសចុងក្រោយ ដែលត្រូវបានយកមកពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងនោះ គឺជាលទ្ធភាពនៃការស្តារនីតិសម្បទារបស់ កាំង ហ្កេកអ៊ាវ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងការយល់ឃើញ ដែលបានគាំទ្រដោយយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ដែលថា "គប្បីធ្វើការពិចារណាតិចតួចប៉ុណ្ណោះ"ទៅលើកត្តានៃការស្តារនីតិសម្បទានេះក្នុងការប្រកាសទោស[792]។

៣៧១. ជាសរុប អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា កត្តាស្ថានសម្រាលទោសដែលបានរៀបរាប់ខាងលើ មានឥទ្ធិពលបន្តិចបន្តួចប៉ុណ្ណោះទៅលើការប្រកាសទោស។ លើសពីនេះទៅទៀត កត្តាស្ថានទម្ងន់ទោសដែលកត់សម្គាល់ជាងគេ និងវិសាលភាពនៃឧក្រិដ្ឋកម្មដែលមានលក្ខណៈ

---

[790]ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារ F1/4.1, ទំព័រ ១១៣ (បន្ទាត់ ២៣) ដល់ទំព័រ ១១៤ (បន្ទាត់ ២) ដែលជនជាប់ចោទបានបញ្ជាក់ថា ៖ "ខ្ញុំនៅតែរក្សាជំហររបស់ខ្ញុំចំពោះការទទួលខុសត្រូវតាមច្បាប់ចំពោះជនរងគ្រោះដែលទទួលព្យសនកម្មនៅ មន្ទីរ ស ២១ និងការខូចខាតខាងផ្លូវចិត្តចំពោះជនរងគ្រោះទូទាំងប្រទេស។ ខ្ញុំនៅតែរក្សាជំហររបស់ខ្ញុំក្នុងសុំអភ័យទោសដល់វិញ្ញាណក្ខន្ធរបស់ជនរងគ្រោះ ចំនួន ១២.៧៣៣ នាក់ដែលបានបាត់បង់អាយុជីវិតនៅមន្ទីរ ស ២១ និងដល់ក្រុមគ្រួសារជនរងគ្រោះមេត្តាទទួលនូវការសុំអភ័យទោសរបស់ខ្ញុំ"។

[791]សាលដីកាក្នុង*រឿងក្តី Nikolić*, កថាខណ្ឌ ១១៧, ដកស្រង់ចេញពីរឿងក្តីរបស់តុលាការ ICTY និង ICTR ចំពោះសេចក្តីអះអាងដែលថាវិប្បដិសារីត្រូវបានទទួលស្គាល់ថាជាកត្តាស្ថានសម្រាលទោសដរាបណាវិប្បដិសារីនេះជាការពិតនិងស្មោះត្រង់។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Rugambarara*, សំណុំរឿងលេខ ICTR-00-59-T, "សាលក្រមស្តីពីការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧, កថាខណ្ឌ ៣៣។

[792]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦១១។

ធំធេង និងពិសេសដែល កាំង ហ្កេកអ៊ាវ ជាអ្នកទទួលខុសត្រូវនោះ នឹងត្រូវលើកយកមកពិចារណានៅក្នុងផ្នែកខាងក្រោម នឹងធ្វើឱ្យបាត់បង់នូវឥទ្ធិពលចំពោះកត្តាស្ថានសម្រាលទោសទាំងនេះ។

៣៧២. អានុភាពទន់ខ្សោយនៃកត្តាស្ថានសម្រាលទោសនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ មានលក្ខណៈគ្រប់គ្រាន់ ដើម្បីធ្វើការបដិសេធនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា កត្តាស្ថានសម្រាលទោសទាំងនេះមាន"សារៈសំខាន់" "តម្រូវឱ្យមាន"ការប្រកាសទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ ដោយមិនបានយោងលើសំអាងផ្លូវច្បាប់ណាមួយនោះ។ អង្គជំនុំជម្រះសាលាដំបូង ថែមទាំងខកខានក្នុងការពិចារណាលើច្បាប់ជាតិ និងអន្តរជាតិដែលបានអនុញ្ញាតឱ្យមានការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត ដោយមិនគិតពីកត្តាស្ថានសម្រាលទោសនានា ហេតុដូច្នេះអាចសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់នូវទម្ងន់ណាមួយទៅលើច្បាប់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធទាំងនោះទេ។ នៅក្នុងកម្រិតជាតិ មាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ បានផ្តល់ឆន្ទានុសិទ្ធិដល់ចៅក្រមក្នុងការសម្រេច ថាតើ ផ្តល់ ឬមិនផ្តល់ប្រយោជន៍នៃស្ថានសម្រាលទោសជាទម្រង់នៃការប្រកាសទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[793]។ នៅក្នុងកម្រិតអន្តរជាតិ គោលការណ៍នៅក្នុងសាលដីការបស់តុលាការ *មិនអចិន្ត្រៃយ៍* បានបញ្ជាក់យ៉ាងច្បាស់ថា ការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតនៅតែរក្សាទុក នៅពេលដែលស្ថានទម្ងន់នៃឧក្រិដ្ឋកម្មតម្រូវឱ្យប្រកាសទោសបែបនេះ ទោះបីជាមានកត្តាស្ថានសម្រាលទោសនានាក៏ដោយ[794]។

---

[793]មាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាចែងថា ('កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោសអាច"បន្ថយការផ្តន្ទាទោសដូចដែលមានចែង) (សេចក្តីបញ្ជាក់បន្ថែម)។

[794]*សូមមើល ឧទា.រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Renzaho*, សំណុំរឿងលេខ ICTR-97-31-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០១ ("សាលដីកាលើ *រឿងក្តីRenzaho*") កថាខណ្ឌ ៦១២, ដែលដក ស្រង់ចេញពី *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Karera*, សំណុំរឿងលេខ ICTR-01-74-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩, កថាខណ្ឌ ៣៩០។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Niyitegeka*, សំណុំរឿងលេខ ICTR-96-

៣៧៣. អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ទម្ងន់មិនសមហេតុផលចំពោះស្ថានសម្រាលទោស និងមិនបានផ្ដល់ទម្ងន់ឱ្យបានគ្រប់គ្រាន់ចំពោះស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងស្ថានទម្ងន់ទោស ហើយជាចុងក្រោយ បានប្រកាសទោសដែលមិនបានឆ្លុះបញ្ចាំងអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងនេះ គឺជាកំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈការប្រកាសទោសនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន ១០៤(១)(ក) នៃវិធានផ្ទៃក្នុង។ ក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវអន្តរាគមជាចាំបាច់ ដើម្បីធ្វើការប្រកាសទោសមួយដ៏សមស្រប។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលទទួលយកទឡ្ហីករណ៍ទីមួយនៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

## ៥.គ.២.ការប្រកាសទោសដែលត្រូវកែប្រែដោយអង្គជំនុំជម្រះតុលាការកំពូល

៣៧៤. ដោយសារតែមិនមានយុត្តិសាស្ត្រប្រហាក់ប្រហែលគ្នានៅតុលាការកម្ពុជានោះ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូល បន្តធ្វើការពិនិត្យទៅលើការប្រកាសទោសរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀត ដែលដោះស្រាយបញ្ហាអង្គហេតុ និងអង្គច្បាប់ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញពីការចាំបាច់ក្នុងការពិចារណាអំពីស្ថានភាពនៃសំណុំរឿងនីមួយៗ និងស្ថានភាពរបស់ជនជាប់ចោទ ព្រមទាំងហានិភ័យក្នុងការពឹងផ្អែកទៅលើសំណុំរឿងដែលមិនមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មានសារៈប្រយោជន៍ក្នុងការ

14-A, “សាលដីកា”របស់អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៤, កថាខណ្ឌ ២៦៧ និងសាលដីកាក្នុង *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Musema*, កថាខណ្ឌ ៣៩៦។ សាលដីកាក្នុង *រឿងក្ដី Seromba*, កថាខណ្ឌ ២២៦ ដល់ ២៣៩ (សម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតលើជនជាប់ចោទ ថ្វីបើមានស្ថានសម្រាលទោសក្ដី)។ សាលដីកាក្នុង *រឿងក្ដី Galić*, កថាខណ្ឌ ៤៥៣ ដល់ ៤៥៦ (ដែលបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការដាក់ទោសតែរយៈពេល ២០ ឆ្នាំ ទោះបីជាមានសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនមានវិវាទលើមូលដ្ឋានអង្គហេតុទាក់ទិននឹងអត្ថិភាពនៃស្ថានសម្រាលទោសយ៉ាងណាក៏ដោយ ដោយពិចារណាទៅលើកម្រិតនៃស្ថានទម្ងន់នៃការប្រព្រឹត្តបទឧក្រិដ្ឋនិងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទហើយចុងក្រោយបានផ្ដន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារអស់មួយជីវិត។

ចាត់ទុកការប្រកាសទោស នៅក្នុងសំណុំរឿងដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ថាជាប្រភពនៃការណែនាំ[795]។

៣៧៥. នៅក្នុងយុត្តិសាស្ត្រតុលាការអន្តរជាតិជាច្រើនបានបង្ហាញយ៉ាងច្បាស់ថា ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មរបស់ពិរុទ្ធជន គឺជាកត្តាចំបងនៅក្នុងការប្រកាសទោស[796]។ ដោយសាររាល់ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក បានរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះ ហេតុនេះមានកត្តាពាក់ព័ន្ធមួយចំនួនសម្រាប់លើកយកមកធ្វើការវាយតម្លៃ អំពីស្ថានទម្ងន់នៃបទល្មើសជាក់លាក់ណាមួយ[797]។ ធាតុផ្សំទាំងនេះ ពាក់ព័ន្ធជុំវិញស្ថានភាពជាក់លាក់នៃរឿងក្តី ដោយរួមបញ្ចូលទាំងទម្រង់ និងកម្រិតនៃការចូលរួមរបស់ពិរុទ្ធជន រួមមាន ចំនួន និងភាពងាយរងគ្រោះបំផុតរបស់ជនរងគ្រោះ ផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ និងសាច់ញាតិរបស់ពួកគាត់ ចេតនារើសអើងរបស់

[795] *សូមមើល ឧទា.* សាលដីកាក្នុង *រឿងក្តី* Čelebići, កថាខណ្ឌ ៧៥៦ (ដែលបញ្ជាក់ជាទូទៅថា ភាពស៊ីសង្វាក់គ្នាក្នុងការផ្តន្ទាទោស គឺជា"ការឆ្លុះបញ្ចាំងដ៏សំខាន់នៃសញ្ញាណយុត្តិធម៌ស្មើភាពគ្នា" និងកថាខណ្ឌ ៧៥៨ និង ៨៥១ (ដែលយល់ឃើញថា ទណ្ឌកម្មដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងផ្សេងខ្លះ មិនគ្រប់គ្រាន់នោះទេ ដោយសារតែមិនស៊ីសង្វាក់គ្នាជាមួយនឹងរឿងក្តីដែលពាក់ព័ន្ធនៅក្នុងស្ថានភាពស្រដៀងគ្នា)។

[796] *សូមមើលឧទា.* សាលដីកាក្នុង *រឿងក្តី* Nahimana, កថាខណ្ឌ ១០៦០ (ដែលយល់ឃើញថា "ស្ថានទម្ងន់នៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបង្ហាញឲ្យឃើញជាក់ស្តែង គឺជាកត្តាសម្រាប់កំណត់អំពីការផ្តន្ទាទោស")។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Mucić និងជនដទៃទៀត*, សំណុំរឿងលេខ IT-96-21, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨, កថាខណ្ឌ ១២២៥ ("ការពិចារណាដ៏មានសារសំខាន់ជាងគេបំផុត ... គឺស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម"។ សាលដីកាក្នុង *រឿងក្តី* Aleksovski, កថាខណ្ឌ ១៨២ ("ការពិចារណាអំពីស្ថានទម្ងន់នៃអំពើរបស់ជនជាប់ចោទ គឺធម្មតា ជាចំណុចចាប់ផ្តើមសម្រាប់ការពិចារណាអំពីការកំណត់ទោសដ៏សមស្រប")។ សាលដីកាក្នុង *រឿងក្តី* Kambanda, កថាខណ្ឌ ១២៥។ សាលដីកាក្នុង *រឿងក្តី* Kupreškić, កថាខណ្ឌ ៤៤២។ សាលដីកាក្នុង *រឿងក្តី* Čelebići, កថាខណ្ឌ ៧៣១។

[797] *សូមមើលឧទា.* សាលក្រម និងការផ្តន្ទាទោសក្នុង *រឿងក្តី* Semanza, កថាខណ្ឌ ៥៥៥ ("ឧក្រិដ្ឋកម្មទាំងអស់ដែលមានចែងនៅក្នុងលក្ខន្តិកៈ [តុលាការ ICTR] គឺជាប្រភេទឧក្រិដ្ឋកម្មដែលមានលក្ខណៈធ្ងន់ធ្ងរយ៉ាងខ្លាំង" ដោយហេតុនេះមានភាពសំខាន់ជាងការពិនិត្យ"អំពីស្ថានទម្ងន់អរូបិយនៃឧក្រិដ្ឋកម្ម" ដើម្បីវាយតម្លៃអំពីស្ថានភាពពាក់ព័ន្ធនៃរឿងក្តី)។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Karera, សំណុំរឿងលេខ ICTR-01-74-T, "សាលក្រម និងការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧, កថាខណ្ឌ ៥៧៤។

ពិរុទ្ធជននៅពេលដែលចេតនានេះមិនមែនជាធាតុផ្សំនៃបទឧក្រិដ្ឋ ទំហំ និងភាពសាហាវព្រៃផ្សៃនៃបទល្មើស និងតួនាទីរបស់ជនជាប់ចោទ[798]។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានសម្រេចផ្តន្ទាទោសកម្រិតខ្ពស់បំផុត ដោយរួមបញ្ចូលទាំងការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះរឿងក្តីនានាដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលមានលក្ខណៈធ្ងន់ធ្ងរពិសេស[799]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមថា តុលាការ *មិនអចិន្ត្រៃយ៍* បានសម្រេចប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត ភាគច្រើនចំពោះរឿងក្តីដែលពិរុទ្ធជនបានរំលោភលើមុខដំណែងដឹកនាំ តាមរយៈការរៀបចំផែនការ ឬបញ្ជាឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់[800] ព្រមទាំងរឿងក្តីនានាដែលមានភស្តុតាងបង្ហាញអំពីភាពឃោរឃៅ ឬការបំពេញ

---

[798] *សូមមើល*សាលក្រមក្នុង*រឿងក្តី* *Milutinović*, កថាខណ្ឌ ១១៤៧។ សាលក្រមក្នុង*រឿងក្តី* *Lukić និង Lukić*, កថាខណ្ឌ ១០៥០, ដកស្រង់ចេញពីសាលដីកាក្នុង*រឿងក្តី* *Čelebići*, កថាខណ្ឌ ១២៦០។ សាលដីកាក្នុង*រឿងក្តី* *Blaškić*កថាខណ្ឌ ៦៨៣។ សាលដីកាក្នុង*រឿងក្តី* *Kunarac*, កថាខណ្ឌ ៣៥២, ៣៥៧។ សាលដីកាក្នុង *រឿងក្តី* *Tadić*, កថាខណ្ឌ ៣០៥។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Deli*, សំណុំរឿងលេខ IT-04-83-A, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨, កថាខណ្ឌ ៥៦៣។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Boškoski និង Tarčulovski*, សំណុំរឿងលេខ IT-04-82-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៨, កថាខណ្ឌ ៥៨៨។

[799] *សូមមើល ឧទា.* សាលដីកាក្នុង*រឿងក្តី* *Galić*, កថាខណ្ឌ ៤៥៥ (ដែលសម្រេចប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតដែលបដិសេធចោលការប្រកាសទោសដាក់ពន្ធនាគាររយៈពេល ២០ ឆ្នាំរបស់អង្គជំនុំជម្រះសាលាដំបូងដោយសារតែការប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូង មិនបានឆ្លុះបញ្ចាំងជាពិសេសទៅលើលក្ខណៈធ្ងន់ធ្ងន់នៃឧក្រិដ្ឋកម្មរបស់ជនជាប់ចោទក្នុងការរៀបចំឲ្យមានការបាញ់គ្រាប់កាំភ្លើងធំ និងការវាយប្រហារដោយលបបាញ់ដែលទង្វើទាំងនេះ បានសម្លាប់ប្រជាជនស៊ីវិលរាប់រយនាក់)។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Kayishema និង Ruzindana*, សំណុំរឿងលេខ ICTR-95-1-A, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩, កថាខណ្ឌ ១៥ ដល់ ១៦, ២៦ ដល់ ២៧ (ដែលសម្រេចប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះជនជាប់ចោទម្នាក់ក្នុងចំណោមជនជាប់ចោទពីរនាក់ផ្អែកតាមការរួមចំណែកទៅនឹងការសម្លាប់រង្គាលចំនួនបួន ដែលសម្លាប់មនុស្សប្រុសស្រីនិងកុមារជាច្រើនពាន់នាក់នៅរវ៉ាន់ដា មុខតំណែងក្នុងសមត្ថកិច្ចរបស់គាត់និងការពេញចិត្តចំពោះភារកិច្ចពិសេសដែលគាត់បានគ្រប់គ្រងលើឧក្រិដ្ឋកម្មទាំងនេះ)។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Kayishema និង Ruzindana*, សំណុំរឿងលេខ ICTR-95-1-A, "សាលដីកា (សំអាងហេតុ)", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១ ("សាលដីកាក្នុង*រឿងក្តី* *Kayishema និង Ruzindana*", កថាខណ្ឌ ៣៧១។

[800] *សូមមើល ឧទា.* សាលដីកាក្នុង*រឿងក្តី* *Galić*, កថាខណ្ឌ ៤១១ ដល់ ១២, ៤៥៥ ដល ៤៥៦ (ដែលបន្ថែមការប្រកាសទោសដាក់ពន្ធនាគារជនជាប់ចោទពីរយៈពេល ២០ ឆ្នាំរហូតដល់ការដាក់ពន្ធនាគារអស់មួយជីវិតដើម្បីឆ្លុះបញ្ចាំងឲ្យឃើញ

ភារកិច្ចរបស់ខ្លួនដោយពេញចិត្ត[801]។ ហេតុដូច្នេះ ដើម្បីធ្វើការប្រកាសទោសឱ្យបានសមស្រប អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ព្រមទាំងកត្តាស្ថានទម្ងន់

---

អំពីមុខតំណែងដឹកនាំរបស់គាត់ក្នុងនាមជាមន្ត្រីយោធាជាន់ខ្ពស់មួយរូប។ សាលក្រមក្នុងរឿងក្តី *Musema*, កថាខណ្ឌ ១០០២ ដល់ ១០០៣ (ដែលសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទៅលើនាយករោងចក្រតែដ៏មានឥទ្ធិពលមួយរូប ដែលគាត់បាននាំកម្មករនានាឱ្យទៅវាយប្រហារលើជនភៀសខ្លួន Tutsi)។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kambanda*, សំណុំរឿងលេខ ICTR-97-23-S, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៨, កថាខណ្ឌ ៦១ ដល់ ៦២ (ដែលសម្រេចដាក់ពន្ធនាគារអស់មួយជីវិតដោយសារតែជនជាប់ចោទបំពារបំពានលើសមត្ថកិច្ចរបស់គាត់តាមរយៈការញុះញង់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ក្នុងនាមគាត់ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលបណ្តោះអាសន្នរបស់ប្រទេសរវ៉ាន់ដា)។*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Niyitegeka*, សំណុំរឿងលេខ ICTR-96-14-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៣, កថាខណ្ឌ ៤៩៩ (ដែលសម្រេចដាក់ពន្ធនាគារអស់មួយជីវិតដោយសារតែជនជាប់ចោទបានបំពារបំពានមុខតំណែងរបស់គាត់តាមរយៈការញុះញង់ឱ្យប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ក្នុងនាមគាត់ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន)។*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Ndindabahizi*, សំណុំរឿងលេខ ICTR-2001-71-T, "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ៥០៨ (ដែលសម្រេចដាក់ពន្ធនាគារអស់មួយជីវិតពីព្រោះជនជាប់ចោទគាំទ្រគោលនយោបាយអំពើប្រល័យពូជសាសន៍នៅតំបន់កំណើតរបស់គាត់ ក្នុងនាមគាត់ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ)។ *រឿងក្តីរដ្ឋអាជ្ញាទល់នឹង Nchamihigo*, សំណុំរឿងលេខ ICTR-01-63-T, "សាលក្រម និងការផ្តន្ទាទោស", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ("សាលក្រម និងការផ្តន្ទាទោសក្នុង *រឿងក្តី Nchamihigo*"), កថាខណ្ឌ ៣៩១ និង ៣៩៦ (ដែលបានសម្រេចដាក់ពន្ធនាគារអស់មួយជីវិតដោយសារតែក្នុងនាមជា "រដ្ឋអាជ្ញារង (ជនជាប់ចោទ) ត្រូវបានគេសង្ឃឹមថា គោរពតាមវិធានច្បាប់និងគោលការណ៍ស្តីពីក្រមសីលធម៌")។

[801] *សូមមើល ឧទា.* សាលក្រមក្នុង*រឿងក្តី Lukić និង Lukić*, កថាខណ្ឌ ១០៦០ ដល់ ១០៦៩ (ដែលពិចារណាអំពីភាពសាហាវព្រៃផ្សៃពិសេសរបស់ជនជាប់ចោទនៅក្នុងការវាយដំយ៉ាងធ្ងន់ធ្ងរលើអ្នកទោស ដុតជនរងគ្រោះទាំងរស់ និងនៅក្នុងករណីមួយនោះជនជាប់ចោទបានសើចសប្បាយនៅពេលបាញ់លើស្ត្រីពីរគ្រាប់)។ សាលក្រម និងការផ្តន្ទាទោសក្នុង*រឿងក្តី Bagosoro*, កថាខណ្ឌ ២២៦៥ ដល់ ២២៦៧ (ដែលពិចារណាអំពីភាពសាហាវព្រៃផ្សៃជាពិសេសរបស់ជនជាប់ចោទនៅពេលកាត់អវៈយវៈ និងធ្វើកាយវិកលកម្មលើប្រដាប់ភេទរបស់ជនរងគ្រោះ)។ សាលដីកាក្នុង*រឿងក្តី Kayishema និង Ruzindana*, កថាខណ្ឌ ៣៦១ (ដែលពិចារណាអំពីការពេញចិត្តរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម និងកម្រិតនៃការបង្កនូវព្យសនកម្ម និងជាពិសេសពិចារណាលើព្យសនកម្មដែលមិនអាចជួសជុលបាន ដោយសារការធ្វើកាយវិកលកម្ម)។ សាលក្រម និងការផ្តន្ទាទោសក្នុង*រឿងក្តី Nchamihigo*, កថាខណ្ឌ ៣៩១ (ដែលពិចារណាអំពីភាពឃោរឃៅយ៉ាងខ្លាំងរបស់ជនជាប់ចោទ ក្នុងការលួចប្លន់ក្នុងផ្ទះដែលធ្វើឱ្យជនរងគ្រោះឆេះស្លាប់ព្រមទាំងការបង្ហាញអំពីការពេញចិត្តរបស់គាត់ក្នុងការធ្វើដំណើរទៅឆ្ងាយៗ ជាច្រើនកន្លែងដើម្បីអន្តរាគមន៍ក្នុងការសម្លាប់មនុស្ស)។ សាលក្រម និងការផ្តន្ទាទោស

ទោសនានាដែលបានបង្ហាញនៅក្នុងរឿងក្ដីនេះ ដូចជាតួនាទីដឹកនាំរបស់ កាំង ហ្គេកអ៊ាវ និងការប្រព្រឹត្តឧក្រិដ្ឋកម្មដោយភាពឃោរឃៅ និងពេញចិត្តដែលមានភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងរឿងក្ដីបច្ចុប្បន្ននេះ។

៣៧៦. នៅក្នុងរឿងក្ដីនេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ បានប្រព្រឹត្ត គឺមាន"លក្ខណៈសាហាវយង់ឃ្នង និងគួរឱ្យព្រឺខ្លាច" ដោយផ្អែកតាមចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់មិនតិចជាង ១២.២៧២ នាក់នោះទេ ព្រមទាំងការធ្វើទារុណកម្មជាប្រព័ន្ធ និងស្ថានភាពអាក្រក់ទូទៅដែលជនរងគ្រោះទទួលរងថែមទៀតផង[802]។ សហព្រះរាជអាជ្ញាបានបង្ហាញថា សំណុំរឿងបច្ចុប្បន្ននេះ ជាសំណុំរឿងមួយក្នុងចំណោមសំណុំរឿងដែលមានភាពធ្ងន់ធ្ងរជាងគេបំផុត បើគិតពីចំនួនជនរងគ្រោះយ៉ាងច្រើនដែលបានសម្លាប់ និងអំពើកាប់សម្លាប់មានរយៈពេលវែងជាងគេបំផុត បើប្រៀបធៀបទៅនឹងសំណុំរឿងដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាចំនួនប្រាំពីរ ដែលត្រូវបានប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងនោះមានសំណុំរឿងចំនួនពីរនៅតុលាការ ICTY[803] និងសំណុំរឿងចំនួនប្រាំនៅ

---

ក្នុង*រឿងក្ដី Muhimana*, កថាខណ្ឌ ៦១២ (ដែលពិចារណាអំពីប្រភេទគួរឱ្យព្រឺខ្លាចពិសេសនៃឧក្រិដ្ឋកម្មរបស់ជនជាប់ចោទដោយរួមបញ្ចូលឧទាហរណ៍មួយទាក់ទងនឹងការធ្វើកាយវិកលកម្មលើស្ត្រីមានផ្ទៃពោះ)។

[802] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៩៧។

[803] ឧបសម្ព័ន្ធភ្ជាប់ទៅនឹងសារណាផ្ទាល់មាត់របស់សហព្រះរាជអាជ្ញាអំពីការប្រកាសទោស នៅក្នុងសវនាការលើបណ្ដឹងសាទុក្ខរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/3.1, ជាមួយនឹងឯកសារភ្ជាប់នានា, ឯកសារលេខ F1/3/1.1។ សាលដីកាក្នុង*រឿងក្ដី Galić*, កថាខណ្ឌ ៤៥៥ ដល់ ៤៥៦ (ដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតលើជនជាប់ចោទចំពោះភាពធ្ងន់ធ្ងរនៃយុទ្ធនាការលបបាញ់ និងការបាញ់គ្រាប់កាំភ្លើងដែលបានកើតឡើងជាច្រើនខែនិងបណ្ដាលឱ្យជនស៊ីវិលស្លាប់រាប់រយនាក់និងជនស៊ីវិលរងរបួសរាប់ពាន់នាក់)។ សាលក្រមក្នុង*រឿងក្ដី Lukić* និង *Lukić*, កថាខណ្ឌ ១០៦៣ ដល់ ១០៦៩ (ដែលប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតដល់ជនជាប់ចោទមួយរូបក្នុងចំណោមពីររូប ចំពោះអំពើឃោរឃៅជាពិសេសដែលគាត់បានប្រព្រឹត្តការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយជាតិសាសន៍ និងសាសនា ការធ្វើមនុស្សឃាតអំពើអមនុស្សធម៌ និងការសម្លាប់រង្គាលដោយរួមបញ្ចូលទាំងការធ្វើមនុស្សឃាតលើពួកមូស្លីមប៊ូស្នៀយ៉ាងតិចណាស់ ១៣២ នាក់)។

តុលាការ ICTR[804]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ទៅលើរឿងក្តីមួយចំនួនទៀត ដែលក្នុងនោះ ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងរឿងក្តីនេះ ក៏បានប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតផងដែរ[805]។ ចំនួនអ្នកស្លាប់យ៉ាងច្រើនដែល

---

[804]ឧបសម្ព័ន្ធភ្ជាប់ទៅនឹងសារណាផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា។ សាលដីកាក្នុង*រឿងក្តី Akayesu* (បានប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតដល់ជនជាប់ចោទ ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់រួមមានការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការញុះញង់ឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ការធ្វើទារុណកម្មការរំលោភលើផ្លូវភេទនិងការធ្វើមនុស្សឃាតលើពួក Tutsis យ៉ាងតិចណាស់ ២០០០ នាក់ នៅទីក្រុងដែលជនជាប់ចោទជាអភិបាលក្រុង)។ សាលដីកាក្នុង*រឿងក្តី Karera*, កថាខណ្ឌ ៣៩៣, ៣៩៨ (ដែលប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតដល់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ការសម្លាប់រង្គាលនិងការធ្វើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយរួមបញ្ចូលការវាយប្រហារនៅវិហារគ្រិស្តដែលបានសម្លាប់ជនភៀសខ្លួន Tutsi រាប់រយនាក់)។ សាលដីកាក្នុង*រឿងក្តី Kayishema និង Ruzindana*, កថាខណ្ឌ ២៩១, ៣៧១ ដល់ ៣៧២ (ដែលប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត ចំពោះជនជាប់ចោទមួយរូបក្នុងចំណោមជនជាប់ចោទពីររូបចំពោះការចូលរួមក្នុងសម្លាប់រង្គាលចំនួនបួនដែលបណ្តាលឲ្យស្លាប់មនុស្សរាប់ពាន់នាក់)។ សាលក្រម និងការប្រកាសទោសក្នុង*រឿងក្តី Bagosora*, កថាខណ្ឌ ៤១, ២២៥៨ (ដែលប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតដល់ជនជាប់ចោទបីរូបក្នុងចំណោមជនជាប់ចោទបួនរូប ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាម ដោយរួមបញ្ចូលទាំងការសម្លាប់ជនស៊ីវិល Tutsi រាប់ពាន់នាក់។ សាលដីកាក្នុង*រឿងក្តី Renzaho*, កថាខណ្ឌ ៦២១ ដល់ ៦២២ (ដែលប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតដល់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ដោយរួមបញ្ចូលការបញ្ជាឲ្យសម្លាប់ជនភៀសខ្លួន Tutsi រាប់រយនាក់ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។

[805]*សូមមើលឧទា.រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Gacumbitsi*, សំណុំរឿងលេខ ICTR-2001-64A-A "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦, ("សាលដីកាក្នុង*រឿងក្តី Gacumbitsi*"), កថាខណ្ឌ ២០៤, ២០៦ (ដែលបានប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតលើជនជាប់ចោទចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលរួមបញ្ចូលការវាយប្រហារដែលសម្លាប់ប្រជាជនរាប់ពាន់នាក់អង្គជំនុំជម្រះដាក់ទម្ងន់លើ "តួនាទីស្នូលរបស់ជនជាប់ចោទក្នុងការរៀបចំផែនការការញុះញង់ការបញ្ជាការប្រព្រឹត្តនិងការជួយទំនុកបម្រុង"ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម)។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kajelijeli*, សំណុំរឿងលេខ ICTR-98-44A-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៥ ("សាលដីកាក្នុង*រឿងក្តី Kajelijeli*"), កថាខណ្ឌ ៣២៤ (ដែលប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតលើជនជាប់ចោទដោយផ្អែកលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ទោះបីជាការបន្ធូរបន្ថយទោសចុងក្រោយត្រឹមរយៈពេល ៤៥ ឆ្នាំ សម្រាប់ជាការទូទាត់សងចំពោះការបំពារបំពានលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ក្នុងអំឡុងពេលឃុំខ្លួនបណ្តោះអាសន្នខុសច្បាប់ក៏ដោយ)។

កាំង ហ្គេកអ៊ាវ ជាអ្នកទទួលខុសត្រូវ ព្រមទាំងបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងរយៈពេលដ៏វែង (លើសពីបីឆ្នាំ) គឺពិតជាធ្វើឱ្យសំណុំរឿងនេះ ជាសំណុំរឿងមួយដែលមានលក្ខណៈធ្ងន់ធ្ងរជាងគេបំផុត នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា។

៣៧៧. ពាក់ព័ន្ធនឹងកត្តាស្ថានទម្ងន់ទោស កាំង ហ្គេកអ៊ាវ មានតួនាទីជាមេដឹកនាំធំជាងគេនៅមន្ទីរ ស ២១ ហើយបានបំពានតួនាទីរបស់ខ្លួនដោយបានបង្ហាត់បង្រៀន បញ្ជា និងគ្រប់គ្រងទៅលើបុគ្គលិកក្នុងការធ្វើទារុណកម្មជាប្រព័ន្ធ និងការសម្លាប់អ្នកទោសដែលត្រូវបានចាត់ទុកថា ជាសត្រូវរបស់របបកម្ពុជាប្រជាធិបតេយ្យ[806] ដោយបង្ហាញពី"ការខិតខំប្រឹងប្រែងបំពេញភារកិច្ចដើម្បីធ្វើឱ្យមន្ទីរ ស ២១ ដំណើរការទៅបានយ៉ាងរលូន"[807]។ ការដែល កាំង ហ្គេកអ៊ាវ មិនមែនជាជនកំពូលនៃខ្សែសង្វាក់បញ្ជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចធ្វើជាយុត្តិកម្មក្នុងការកាត់បន្ថយទោសនោះបានទេ។ តាមការពិត មិនមានវិធានណាមួយដែលចែងអំពីកម្រិតនៃការផ្តន្ទាទោសខ្ពស់បំផុតចំពោះចារី ដែលត្រូវបានចាត់ទុកជាជនកំពូលនៃខ្សែសង្វាក់បញ្ជានោះទេ[808]។ ប៉ុន្តែ យុត្តិសាស្ត្រតុលាការអន្តរជាតិបានរក្សាការផ្តន្ទាទោសកម្រិត

[806]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦០២។

[807]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦០៧។

[808]សាលក្រមក្នុង*រឿងក្តី Lukić និង Lukić* កថាខណ្ឌ ១០៥៥ (ដែលតម្កល់សេចក្តីសម្រេចពីមុនរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបដិសេធមិនធ្វើយុត្តិកម្មទៅលើការផ្តន្ទាទោសស្រាល ដោយគ្រាន់តែសំអាងថា ជនជាប់ចោទស្ថិតក្នុងថ្នាក់បញ្ជាការកម្រិតទាប ដោយសារតែ"ការផ្តន្ទាទោសត្រូវតែឆ្លុះបញ្ចាំងជានិច្ចអំពីកម្រិតនៃស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម" ដែលអាចជាយុត្តិកម្មដាក់ទោសកម្រិតធ្ងន់ទោះបីជានៅពេលដែល"ជនជាប់ចោទមិនមែនជាមេដឹកនាំជាន់ខ្ពស់នៅក្នុងរចនាសម្ព័ន្ធបញ្ជាការទាំងមូលក្តី"។ ព្រឹត្តប័ត្រនិពន្ធដោយ Jens David Ohlin៖ "ការកំណត់ទោស ដែលមានលក្ខណៈសមមាត្រគ្នានៅតុលាការ ICTY" - *កេរ្តិ៍ដំណែលរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយ៉ូហ្គោស្លាវី,* បោះពុម្ពផ្សាយដោយ Bert Swart, Goran Sluiter, Alezander Zahar-(eds.), ចេញផ្សាយដោយសាព័ត៌មាននៃសាកលវិទ្យាល័យ Oxford, ឆ្នាំ ២០១១, ទំព័រ ២ ដល់ ៣ (ពន្យល់ថា នៅពេលដែល ការកំណត់ទោសផ្អែកលើ"សមមាត្រគ្នានៃស្ថានទម្ងន់បទល្មើស" ដូចទៅនឹងការអនុវត្តរបស់តុលាការ ICTR ជនជាប់ចោទទួលទោសសមមាត្រទៅនឹងអំពើល្មើសរបស់ខ្លួន។ ដូច្នេះ បទល្មើសធ្ងន់ធ្ងរ ត្រូវទទួលការផ្តន្ទាទោសកម្រិតធ្ងន់ប្រហែលជាការផ្តន្ទាទោសកម្រិតធ្ងន់បំផុតដោយមិនគិត ថាតើបុគ្គលនោះ បានប្រព្រឹត្តនូវបទឧក្រិដ្ឋធ្ងន់ធ្ងរជាងនេះទេ។ ការកំណត់ទោសនេះមានលក្ខណៈមិនស្របទៅនឹង "សមមាត្រទាក់ទងទៅនឹងជនជាប់ចោទ" ដែលបានអនុវត្តតាមដោយតុលាការ ICTY ចំណែកជនជាប់ចោទដែលទទួលខុសត្រូវស្រាល

អតិបរមាទៅលើ "ជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត"[809]ដែលត្រូវបានគេស្គាល់ថា ជាជនដែលមានមុខតំណែងគួរឱ្យកត់សម្គាល់ នៅក្នុងអំឡុងពេលនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ជាពិសេសបំផុតធ្វើតាមរយៈការបញ្ជា ឬការរៀបចំផែនការ ឬការដឹកនាំការប្រព្រឹត្តអំពើបែបនេះ និង/ឬតាមរយៈការអនុវត្តឱ្យបានសម្រេចទៅតាមសេចក្ដីណែនាំដែលខ្លួនបានទទួល ដោយក្ដីពេញចិត្ត ឬដោយក្ដីសាទរ ឬដោយប្រសិទ្ធិភាព ក្នុងលក្ខណៈមួយដែលបង្ហាញយ៉ាងច្បាស់ពីឆន្ទៈរបស់ពិរុទ្ធជនក្នុងការចូលរួមយ៉ាងសកម្មដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម[810]។ ទោះបីជាសំណើចុងក្រោយរបស់ កាំង ហ្គេកអ៊ាវ សុំឱ្យរួចខ្លួនពីបទចោទ ដោយផ្អែកលើអង្គហេតុដែលថា គាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ[811]ក៏ដោយ ក៏តុលាការយល់ឃើញថា ការផ្តន្ទាទោសគួរតែសមស្របទៅនឹងឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ បានប្រព្រឹត្តដោយមិនគិតថា មានអ្នកដទៃផ្សេងទៀតបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាងនោះទេ។

---

ទទួលការផ្តន្ទាទោសស្រាលជាងជនជាប់ចោទ ដែលទទួលខុសត្រូវច្រើនដោយមិនគិតពីស្ថានទម្ងន់នៃបទល្មើសរបស់ជនជាប់ចោទឡើយ)។

[809] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Ntagerura *និងជនដទៃទៀត,* សំណុំរឿងលេខ ICTR-99-46-T "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤, ("សាលក្រម និងការប្រកាសទោសក្នុង*រឿងក្តី* Ntagerura") កថាខណ្ឌ ៨១៥។ *សូមមើលផងដែរ* សាលក្រម និងការប្រកាសទោសក្នុង*រឿងក្តី* Semanza, កថាខណ្ឌ ៥៥៩ ("ទោសដាក់ពន្ធនាគារអស់មួយជីវិត ដែលជាការដាក់ទោសខ្ពស់បំផុតនៅតុលាការនេះគឺតែងប្រើសម្រាប់ជនឧក្រិដ្ឋដែលប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត)។

[810] *សាលក្រម និងការប្រកាសទោសក្នុងរឿងក្តី* Ntagerura, កថាខណ្ឌ ៨១៥។ សាលក្រម និងការប្រកាសទោសក្នុង*រឿងក្តី* Semanza, កថាខណ្ឌ ៥៥៧ និង៥៥៩ (ដែលបដិសេធចោលសំណើរបស់រដ្ឋអាជ្ញាសុំឲ្យដាក់ពន្ធនាគារអស់មួយជីវិតដោយផ្អែកលើមូលដ្ឋានសំខាន់ថា គ្រាន់តែមានការទទួលខុសត្រូវក្នុងនាមជាចារីប្រយោលគាត់មិនបានស្ថិតនៅក្នុងប្រភេទនៃ"ជនឧក្រិដ្ឋធ្ងន់ធ្ងរបំផុត" នោះទេ។ សាលក្រម និងការប្រកាសទោសក្នុង*រឿងក្តី* Nchamihigo កថា ខណ្ឌ ៣៨៨ (នៅក្នុងតុលាការនេះការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតជាទូទៅប្រើសម្រាប់ជនទាំងឡាយ ដែលរៀបចំផែនការ ឬបញ្ជាឱ្យប្រព្រឹត្តអំពើកាចសាហាវយង់ឃ្នងនិងជនទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយការពេញចិត្តពិសេសចំពោះការប្រព្រឹត្តរបស់ខ្លួន ឬសេចក្តីសប្បាយដោយបានធ្វើបាបគេ"។

[811] ប្រតិចារឹកចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១១, ឯកសារ F1/4.1, ទំព័រ ១០៨ (បន្ទាត់ ២៥) ដល់ទំព័រ ១០៩ (បន្ទាត់ ១ ដល់ ២)។

៣៧៨. តាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល តួនាទីដឹកនាំរបស់ កាំង ហ្គេកអ៊ាវ និងការពេញចិត្តយ៉ាងខ្លាំងក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ គឺជាកត្តាស្ថានទម្ងន់ទោសដែលគួរតែទទួលបាននូវទម្ងន់ធ្ងន់ក្នុងការកំណត់ទោសលើជនជាប់ចោទ បើធៀបទៅនឹងទម្ងន់ដែលមានកម្រិតតិចតួចនៃស្ថានសម្រាលទោស។

៣៧៩. អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់បន្ថែមទៀតលើរឿងក្តីជាច្រើននៅតុលាការ *មិនអចិន្ត្រៃយ៍* នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការទាំងនោះ បានបង្កើនទម្ងន់ទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ[812] រួមបញ្ចូលទាំងការដាក់ពន្ធនាគារអស់មួយជីវិត[813]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូង ទទួលបាននូវឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយក្នុងការប្រកាសទោសយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលមានអំណាចផ្លាស់ប្តូរទម្ងន់ទោសជាថ្មី ដូចនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ នៅពេលដែល"ការប្រកាសទោសរបស់អង្គជំនុំជម្រះសាលា

---

[812] *សូមមើលឧទា. រឿងក្តី* Semanza *ទល់នឹងរដ្ឋអាជ្ញា,* សំណុំរឿងលេខ ICTR-97-20-A "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៥, កថាខណ្ឌ ៣៣៨ ដល់ ៣៩ (បានបន្ថែមទោសដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងពី ១៥ ឆ្នាំ ទៅ ២៥ ឆ្នាំ ដោយសារតែទោសនេះ មិនបានឆ្លុះបញ្ចាំងនូវស្ថានទម្ងន់នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលដែលជនជាប់ចោទបានប្រព្រឹត្ត)។ សាលដីកាក្នុង*រឿងក្តី* Aleksovski កថាខណ្ឌ ១៨៧, ១៩១ (ដែលសម្រេចដាក់ពន្ធនាគារប្រាំពីរឆ្នាំបន្ទាប់ពីយល់ឃើញថា ទោសជាប់ពន្ធនាគារពីរឆ្នាំកន្លះដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងគឺ "មានលក្ខណៈមិនគ្រប់គ្រាន់យ៉ាងជាក់ច្បាស់" និងបានផ្តល់នូវស្ថានទម្ងន់មិនគ្រប់គ្រាន់ទៅលើភាពធ្ងន់ធ្ងរនៃអំពើរបស់ជនជាប់ចោទ)។ សាលដីកាក្នុង*រឿងក្តី* Čelebići កថាខណ្ឌ ៨៥១ (ដែលយល់ឃើញថា នៅក្នុងករណីជនជាប់ចោទម្នាក់ក្នុងចំណោមជនជាប់ចោទទាំងបីនាក់ ដែលត្រូវបានរកឃើញថា មានពិរុទ្ធភាព អង្គជំនុំជម្រះសាលាដំបូងពុំបានយកចិត្តទុកដាក់ឲ្យបានគ្រប់គ្រាន់ទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់គាត់ឡើយ និងបង្វែររឿងក្តីនេះទៅឲ្យអង្គជំនុំជម្រះសាលាដំបូងដែលត្រូវបានបង្កើតឡើងវិញដើម្បីបន្ថែមទោស)។

[813] *សូមមើលឧទា.* សាលដីកាក្នុង*រឿងក្តី* Galić, កថាខណ្ឌ ៤៥៥ ដល់ ៤៥៦ (ដែលបានប្រកាសដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិត បន្ទាប់ពីយល់ឃើញថា ទោសជាប់ពន្ធនាគាររយៈពេល ២០(ម្ភៃ)ឆ្នាំ ដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ពុំបានឆ្លុះបញ្ចាំងឲ្យបានគ្រប់គ្រាន់ចំពោះភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទឡើយ។ សាលដីកាក្នុង*រឿងក្តី* Gacumbitsi, កថាខណ្ឌ ២០៦ (ដែលប្រកាសដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិត បន្ទាប់ពីសម្រេចថា ទោសជាប់ពន្ធនាគាររយៈពេល ៣០ (សាមសិប) ឆ្នាំ ដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងពុំបាន"ផ្តល់នូវស្ថានទម្ងន់សមស្របចំពោះភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលម្ចាស់បណ្តឹងសាទុក្ខបានប្រព្រឹត្ត និងចំពោះតួនាទីសំខាន់របស់គាត់នៅក្នុងបទឧក្រិដ្ឋទាំងនោះឡើយ")។

ដំបូងមិនស្របទៅនឹងរបបនៃការប្រកាសទោស"[814]។ ប្រសិនបើពិចារណាឱ្យបានត្រឹមត្រូវពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងកាលៈទេសៈពិសេសនៃរឿងក្ដី។

៣៨០. ក្នុងចំណោមគោលបំណងមួយចំនួនក្នុងការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដោយសារស្ថានទម្ងន់នៃឧក្រិដ្ឋកម្មរបស់ កាំង ហ្គេកអ៊ាវ ការដាក់ទោសដែលសមនឹងទទួល និងការធ្វើឱ្យរាងចាល គឺជាគោលបំណងសំខាន់នៅក្នុងរឿងក្ដីនេះ[815]។ ទណ្ឌកម្មត្រូវតែមានទម្ងន់គ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងដើម្បីទប់ស្កាត់កុំឱ្យឧក្រិដ្ឋកម្មបែបនេះកើតឡើងជាថ្មីទៀត។ ឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ បានប្រព្រឹត្តក្នុងរឿងក្ដីនេះ គឺពិតជាឧក្រិដ្ឋកម្មមួយនៅក្នុងចំណោមឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។ ឧក្រិដ្ឋកម្មទាំងនេះសមនឹងទទួលនូវទណ្ឌកម្មធ្ងន់ធ្ងរបំផុត ដើម្បីជាការឆ្លើយតបប្រកបដោយយុត្តិធម៌ និងគ្រប់គ្រាន់ចំពោះអំពើសាហាវឃោរឃៅ ដែលឧក្រិដ្ឋកម្មទាំងនោះបង្កឡើងទៅលើជនរងគ្រោះ ក្រុមគ្រួសារ

---

[814]សាលដីកាក្នុង *រឿងក្ដី Gacumbitsi*, កថាខណ្ឌ ២០៥។

[815]*សូមមើលជាទូទៅ*សាលដីកាក្នុង *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Nahimana*, កថាខណ្ឌ ១០៥៧ ("ដោយពិចារណាលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្មនានា ដែលតុលាការមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មទាំងនោះ គោលបំណងសំខាន់ពីរក្នុងការដាក់ទោស គឺ ការផ្ដន្ទាទោស និងការធ្វើឱ្យរាងចាល"។ *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Rutaganda*, សំណុំរឿងលេខ ICTR-96-3-T, "សាលក្រម និងការប្រកាសទោស", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ៤៥៥ ("វា ច្បាស់ណាស់ថា ទណ្ឌកម្មដែលបានដាក់ទៅលើជនជាប់ចោទដែលតុលាការបានរកឃើញថាមានពិរុទ្ធភាពនោះ គឺទីមួយត្រូវសំដៅទៅលើការផ្ដន្ទាទោសដែលសមនឹងទទួលរបស់ជនជាប់ចោទទាំងនោះ ដែលត្រូវតែមើលឃើញថា បទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តត្រូវបានផ្ដន្ទាទោស ហើយម្យ៉ាងវិញទៀតគឺសំដៅទៅលើការធ្វើឱ្យរាងចាល ពោលគឺដើម្បីទប់ស្កាត់អ្នកដទៃទៀតដែលអាចត្រូវបានគេបញ្ឆេះបញ្ឆូលឱ្យប្រព្រឹត្តអំពើឃោរឃៅបែបនេះ នៅពេលអនាគតដោយបង្ហាញប្រាប់ ពួកគេថា សហគមន៍អន្តរជាតិមិនត្រូវអត់ឱនឡើយចំពោះការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ និងសិទ្ធិមនុស្ស")។ *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Gacumbitsi*, សំណុំរឿងលេខ ICTR-2001-64-T "សាលក្រម", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៤, កថាខណ្ឌ ៣៣៥ ដល់ ៣៦ ("ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃបទល្មើស ដែលប្រព្រឹត្តនៅក្នុងប្រទេសរវ៉ាន់ដាក្នុងឆ្នាំ ១៩៩៤ វាមានសារៈសំខាន់ជាទីបំផុតដែលថា សហគមន៍អន្តរជាតិផ្ដន្ទាទោសចំពោះបទល្មើសដែលបានរៀបរាប់ទាំងនោះ នៅក្នុងលក្ខណៈមួយដែលនឹងទប់ស្កាត់កុំឱ្យបទឧក្រិដ្ឋទាំងនោះកើតឡើងម្ដងទៀតនៅក្នុងប្រទេសរវ៉ាន់ដា ឬក៏នៅកន្លែងផ្សេងទៀត"។

និងសាច់ញាតិ ក៏ដូចជាប្រជាជនកម្ពុជា និងមនុស្សជាតិទាំងមូល។ សហព្រះរាជអាជ្ញាមិនបានបំផ្លើសឡើយ នៅពេលដែលសហព្រះរាជអាជ្ញាបានសំដៅទៅលើមន្ទីរ ស ២១ ថាជា "ទីកន្លែងសម្លាប់មនុស្សដ៏ធំ ដោយមានការរៀបចំ"[816]។ កាំង ហ្គេកអ៊ាវ បានបញ្ជា និងប្រតិបត្តិការទីកន្លែងសម្លាប់មនុស្សនេះអស់រយៈពេលជាងបីឆ្នាំ។ កាំង ហ្គេកអ៊ាវ បានសម្លាប់មនុស្សអស់យ៉ាងតិច ១២.២៧២ (ដប់ពីរពាន់ពីររយចិតសិបពីរ) នាក់ ដោយគ្មានធម៌មេត្តា ដែលក្នុងនោះរួមមានស្ត្រី និងកុមារផងដែរ។

៣៨១. ទោះបីជាឧក្រិដ្ឋកម្មទាំងឡាយបានកើតឡើងជាង ៣០ ឆ្នាំហើយក៏ដោយ ក៏ការកន្លងផុតដ៏យូរនេះមិនអាចកាត់បន្ថយភាពចាំបាច់ក្នុងការផ្តន្ទាទោសធ្ងន់ធ្ងរនោះទេ។ ការឈឺចាប់របស់ជនរងគ្រោះ ព្រមទាំងក្រុមគ្រួសារ និងសាច់ញាតិ គឺមិនត្រឹមតែជារឿងអតីតកាលប៉ុណ្ណោះទេ ក៏ប៉ុន្តែការឈឺចាប់អស់ទាំងនេះបានបន្ត និងនៅតែបន្តរហូតអស់មួយជីវិត។ ទោះបីជាការដាក់ទណ្ឌកម្មលើ កាំង ហ្គេកអ៊ាវ មិនអាចព្យាបាលឱ្យជាសះស្បើយទាំងស្រុងនូវការឈឺចាប់ទាំងអស់នេះក៏ដោយ ក៏ជនរងគ្រោះសមនឹងទទួលបានយុត្តិធម៌យ៉ាងពេញលេញតាមក្តីរំពឹងដ៏ត្រឹមត្រូវ និងសមហេតុផលរបស់ខ្លួន។ ឧក្រិដ្ឋកម្មរបស់ កាំង ហ្គេកអ៊ាវ បានបង្កឱ្យមានការឈឺចាប់ដែលមិនអាចព្យាបាលបាន ចំពោះប្រជាជនកម្ពុជាទាំងមូល។ ប្រជាជនកម្ពុជាទាំងមូលនៅតែប្រឈមជាមួយបញ្ហាដែលមិនធ្លាប់ជួបប្រទះ ក្នុងការធ្វើឱ្យធូរស្បើយនូវសោកនាដកម្ម ដែលបង្កឡើងដោយឧក្រិដ្ឋកម្មរបស់ កាំង ហ្គេកអ៊ាវ និងអ្នកដែលទទួលខុសត្រូវចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

៣៨២. ភាពចាំបាច់ក្នុងការសម្រេចនូវគោលបំណងធ្វើឱ្យរាងចាល ដើម្បីដាក់ទោសពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ត្រូវបានចងក្រងជាប្រចាំធ្វើជាឯកសារ តាមរយៈរបាយការណ៍របស់រដ្ឋាភិបាលនានាដែលប្រឆាំងនឹងប្រជាជនរបស់ខ្លួន និងតាមរយៈការកើនឡើងនៃសំណុំរឿងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅខណៈពេលដែលសាលដីកានេះកំពុងត្រូវបានធ្វើឡើង។

[816]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២១០។

គោលបំណងធ្វើឱ្យរាងចាលនេះ ទាមទារឱ្យមានសេចក្តីថ្លែងការណ៍មួយដែលថា ទោះបីជាពេលវេលាបានកន្លងទៅ ក៏មិនអាចនាំឱ្យមាននិទណ្ឌភាព និងការដាក់ទោសស្រាលដែលមិនត្រឹមត្រូវនោះដែរ។

៣៨៣. យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ការប្រកាសទោសដាក់ពន្ធនាគាររយៈពេល ៣៥ (សាមសិបប្រាំ)ឆ្នាំ ដោយអង្គជំនុំជម្រះសាលាដំបូង មិនបានឆ្លុះបញ្ចាំងឱ្យបានសមរម្យទៅនឹងស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងស្ថានភាពបុគ្គលរបស់ កាំង ហ្គេកអ៊ាវ ឡើយ។ អង្គជំនុំជម្រះសាលាដំបូង ពិតជាមានកំហុសក្នុងការប្រកាសទោសដែលមានលក្ខណៈមិនគ្រប់គ្រាន់យ៉ាងច្បាស់ក្រឡែត និងបានភាន់ច្រឡំក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន។ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូល សម្រេចប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតលើ កាំង ហ្គេកអ៊ាវ។

### ៥.គ.៣.ការដោះលែងដោយមានលក្ខខណ្ឌ

៣៨៤. សហព្រះរាជអាជ្ញាបានលើកឡើងថា កាំង ហ្គេកអ៊ាវ មិនមានសិទ្ធិទទួលបាននូវការដោះលែងដោយមានលក្ខខណ្ឌនោះទេ ដោយសារតែមានសំអាងហេតុជាច្រើន[817] ហើយសហព្រះរាជ

---

[817]សំអាងហេតុទាំងនោះរួមមាន៖ (ក) ដោយបានសម្រេចលើសចំនួនឆ្នាំចំពោះការកំណត់ទោសដាក់ពន្ធនាគាររយៈពេលជាក់លាក់ ដែលមានចែងក្នុងច្បាប់កម្ពុជានោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពីរបបនៃការកំណត់ទោស*ពិសេសដាច់ដោយឡែកមួយ* (*sui generis*) របស់តុលាការនេះ ហើយអង្គជំនុំជម្រះសាលាដំបូង ក៏បានសង្កត់ធ្ងន់ពីលទ្ធភាពរបស់ខ្លួនក្នុងការសម្រេចលើការកំណត់ទោស ដោយមិនបានគោរពតាមការអនុវត្តក្នុងស្រុករបស់ប្រទេសកម្ពុជាឡើយ។ (ខ) ខណៈដែលការដោះលែងដោយមានលក្ខខណ្ឌទទួលបានការអនុញ្ញាតនៅតុលាការអន្តរជាតិដទៃទៀត ដោយមានបទប្បញ្ញត្តិជាក់លាក់ស្តីពីការដោះលែងដោយមានលក្ខខណ្ឌ នៅក្នុងលក្ខន្តិកៈ និងវិធានស្តីពីនីតិវិធី និងភ័ស្តុតាងក៏ដោយក៏មិនមានឯកសារណាមួយនៅ អ.វ.ត.ក យោងទៅដល់ការដោះលែងដោយមានលក្ខខណ្ឌចំពោះជនជាប់ចោទឡើយ។ (គ) ដោយសារជនជាប់ចោទត្រូវបានផ្តន្ទាទោសតែពីបទឧក្រិដ្ឋអន្តរជាតិប៉ុណ្ណោះ ហេតុនេះមានតែរបបនៃការប្រកាសទោសជាលក្ខណៈអន្តរជាតិប៉ុណ្ណោះដែលគួរយកមកអនុវត្ត។ (ឃ) បទប្បញ្ញត្តិច្បាប់ក្នុងស្រុកទាក់ទិននឹងការដោះលែងដោយមានលក្ខខណ្ឌ មិនអនុវត្តនៅតុលាការនេះទេ ដោយសារតែលក្ខណៈពិសេសនៃការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋអន្តរជាតិទាំងឡាយ។ (ង) ការអនុញ្ញាតឱ្យមានការដោះលែងដោយមានលក្ខខណ្ឌនៅក្រោមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺជាការដកជនជាប់ចោទចេញពីយុត្តាធិការរបស់ អ.វ.ត.ក ដែលវាផ្ទុយពីគោលការណ៍នានានៃតុលាការអន្តរជាតិ។ បើតាមគោលការណ៍អន្តរជាតិ

អាជ្ញាបានស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា កាំង ហ្កេកអ៊ាវ ត្រូវអនុវត្តទោសដោយមិនមានលទ្ធភាពទទួលបាននូវការដោះលែងដោយមានលក្ខខណ្ឌនោះឡើយ[818]។ មេធាវីការពារក្តីមិនបានធ្វើសេចក្តីសន្និដ្ឋានណាមួយស្តីពីបញ្ហានេះទេ។

៣៨៥. មាត្រា ៥១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ ចែងថា "គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឱ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន"។ ដូច្នេះ លទ្ធភាពទទួលបានការដោះលែងដោយមានលក្ខខណ្ឌលើកទឹកចិត្តឱ្យមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ ដែលសម្រួលដល់ការបញ្ចូលខ្លួនទៅក្នុងសង្គមវិញ។ គោលបំណងនៃការដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធច្បាប់ជាច្រើននៅលើពិភពលោកថា ជាកត្តាដ៏សំខាន់មួយនៃការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ។ នៅក្នុងកម្រិតអន្តរជាតិ រាល់ការបន្ធូរបន្ថយទោសទៅលើទោសដាក់ពន្ធនាគារអាចអនុវត្តបានចំពោះទណ្ឌិតទាំងអស់ និងរួមទាំងទណ្ឌិតដែលទទួលទោសដាក់ពន្ធនាគារអស់មួយជីវិតផងដែរ។ ឧទាហរណ៍ មាត្រា ១១០(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម ចែងអំពីការតម្រូវឱ្យពិនិត្យឡើងវិញនូវទោសដាក់ពន្ធនាគារអស់មួយជីវិតបន្ទាប់ពីបានទទួលទោសអស់រយៈពេល ២៥ (ម្ភៃប្រាំ)ឆ្នាំ[819]។

៣៨៦. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ បានចែងថា ទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលការដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតបានទទួលទោស

---

តុលាការដែលសម្រេចផ្តន្ទាទោសមុនគេ គឺមិនមានអំណាចចេញសេចក្តីសម្រេចលើបញ្ហាកាត់បន្ថយរយៈពេលនៃទោសឡើយ។ (បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា,កថាខណ្ឌ ១២២ ដល់ ២៩)។

[818]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១២២។

[819]វិធាន ២២៤(៣) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC។ មាត្រា ២៨ នៃលក្ខន្តិកៈរបស់តុលាការ ICTY។ វិធាន ១២៣ ដល់ ១២៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY។ មាត្រា ២៧ នៃលក្ខន្តិកៈរបស់តុលាការ ICTR។ វិធាន ១២៤ ដល់ ១២៦ នៃវិធានស្តីពីនីតិវិធីនិងភ័ស្តុតាងរបស់តុលាការ ICTR។ មាត្រា ២៣ នៃលក្ខន្តិកៈរបស់តុលាការ SCSL។ វិធាន ១២៣ ដល់ ១២៤ នៃវិធានស្តីពីនីតិវិធីនិងភ័ស្តុតាងរបស់តុលាការ SCSL។

ជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០ (ម្ភៃ)ឆ្នាំ រួចហើយ។ ការដោះលែងដោយមានលក្ខខណ្ឌត្រូវផ្តល់ឱ្យដោយប្រធានតុលាការជាន់ដំបូងនៃទីកន្លែងឃុំខ្លួន។ សេចក្តីសម្រេចរបស់ប្រធានតុលាការនេះអាចត្រូវប្តឹងឧទ្ធរណ៍ទៅប្រធានសាលាឧទ្ធរណ៍ ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញានៃតុលាការសាមី[820]។

៣៨៧. ការដោះលែងដោយមានលក្ខខណ្ឌ គឺជានីតិវិធីដាច់ដោយឡែកមួយនៅក្នុងដំណាក់កាលនៃការអនុវត្តទោសជាប់ពន្ធនាគារ។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា នត្ថិភាពនៃបទប្បញ្ញត្តិពិសេសស្តីពីការដោះលែងដោយមានលក្ខខណ្ឌ នៅក្នុងឯកសារផ្លូវច្បាប់នានារបស់ អ.វ.ត.ក បង្ហាញឱ្យឃើញថា បញ្ហានេះគួរត្រូវបានពិចារណាទៅតាមនីតិវិធីក្នុងស្រុកជាធរមាន នាពេលដែលការដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវបានលើកមកពិចារណាសម្រាប់ទណ្ឌិតជាក់លាក់ណាម្នាក់ ហើយអាចជាពេលវេលាមួយដែល អ.វ.ត.ក បានបញ្ចប់អាណត្តិការងាររបស់ខ្លួន បន្ទាប់ពីការបញ្ចប់ដំណើរការនីតិវិធីទាំងស្រុងរួចហើយ។ លើសពីនេះទៀត ផ្ទុយពីសារណារបស់សហព្រះរាជអាជ្ញា[821] លទ្ធភាពដែលអាចពិចារណាក្នុងពេលអនាគតទៅលើការដោះលែងដោយមានលក្ខខណ្ឌ ដោយអាជ្ញាធរតុលាការដែលមានសមត្ថកិច្ចផ្សេងពីស្ថាប័ន អ.វ.ត.ក នឹងមិនធ្វើឱ្យមានផលប៉ះពាល់ដល់អាណត្តិការងាររបស់ អ.វ.ត.ក ក្នុងការវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួននោះឡើយ។

៣៨៨. ជាសន្និដ្ឋាន អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ខ្លួនមិនមានសមត្ថកិច្ចសម្រេចអំពីសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ក្នុងការទទួលបានការដោះលែងដោយមានលក្ខខណ្ឌនោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធសំណើរបស់សហព្រះរាជអាជ្ញា។

---

[820]មាត្រា៥១៣ ដល់ ៥១៤ និង ៥១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

[821]បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១២៩។

## ៥.គ.៤.ការឃុំខ្លួននៅចំពោះមុខតុលាការយោធាកម្ពុជា

៣៨៩. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការកាត់បន្ថយទោសចំនួន ៥ (ប្រាំ)ឆ្នាំ និងការគិតបញ្ចូលរយៈពេលដែលបានជាប់ឃុំក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា[822] គឺជាការផ្តល់សំណងសមរម្យចំពោះការរំលោភលើសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ដោយសារការឃុំខ្លួនខុសច្បាប់នីតិវិធីដោយតុលាការយោធាកម្ពុជា ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧។ សហព្រះរាជអាជ្ញា មិនត្រឹមតែពុំបានជំទាស់ទៅនឹងផ្នែកសម្រេចសេចក្តីនេះទេ[823] ថែមទាំងពុំបានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានចេញនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ទៀតផង[824]។ ប៉ុន្តែដោយហេតុថា ការប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានកែប្រែ អង្គជំនុំជម្រះតុលាការកំពូលនឹងពិនិត្យពិចារណា*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ថាតើ សំណងនេះគួរតែរក្សា

[822] សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩, ឯកសារលេខ E39/5 ("'សេចក្តីសម្រេចលើសំណើសុំដោះលែង'"), កថាខណ្ឌ២៩ និងកថាខណ្ឌ ៧ និង ៨ នៅក្នុងផ្នែកសម្រេចសេចក្តី (ដែលចង្អុលបង្ហាញថា ការគិតបញ្ចូលមិនត្រូវបានផ្តល់ជូនទេអនុលោមតាមច្បាប់ជាតិដែលពាក់ព័ន្ធដែលត្រូវបានរកឃើញថា មិនអាចអនុវត្តបានប៉ុន្តែ"ជាសំណង"។ ពិតណាស់ការកាត់បន្ថយទោស មានលក្ខណៈជា"សំណងបន្ថែម")។ អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ឲ្យបានច្បាស់អំពីមូលហេតុអ្វីក្នុងការតម្រូវឲ្យការទូទាត់នោះជាសំណង ប៉ុន្តែ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលគឺថា សំណងត្រូវបានផ្តល់ដោយពាក់ព័ន្ធនឹងការរំលោភសិទ្ធិដែលត្រូវបានចោទប្រកាន់និងនៅក្នុងបរិបទដូចគ្នាដែលការកាត់បន្ថយទោសត្រូវបានផ្តល់។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២៤ (ដែលពិពណ៌នាអំពីសំណងនេះជា "ការកាត់បន្ថយទោសបន្ថែមទៀត") និងកថាខណ្ឌ ៦៨១ (ដែលបញ្ជាក់ឡើងវិញតាមរយៈជើងទំព័រថាការគិតបញ្ចូលរយៈពេលនៃការជាប់ឃុំក្រោមតុលាការយោធាត្រូវបានផ្តល់ឲ្យ ដោយយោងតាមសេចក្តីសម្រេចលើសំណើសុំដោះលែង)។

[823] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣០ និង ១៣១។ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/3.2, ទំព័រ ៤៨ (បន្ទាត់ ២៥) ដល់ទំព័រ ៤៩ (បន្ទាត់ ៩) (សហព្រះរាជអាជ្ញាបានអះអាងឡើងវិញថា ទោសជាប់ពន្ធនាគារអស់មួយជីវិតគឺជាការដាក់ទោសមួយដ៏សមស្រប ហើយការកាត់បន្ថយទោសមកត្រឹម ៤៥ឆ្នាំ ដែលតម្រូវដោយច្បាប់គឺគ្រាន់តែដើម្បីទូទាត់សងចំពោះការឃុំខ្លួនដោយខុសច្បាប់ ដែលជនជាប់ចោទបានទទួលរង។ ដីកាសន្និដ្ឋានបញ្ចប់សវនាការដេញដោលរបស់សហព្រះរាជអាជ្ញាជាមួយឧបសម្ព័ន្ធ ១ ដល់ ៥, ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារលេខ E159/9, កថាខណ្ឌ ៤៥៩។

[824] សេចក្តីសម្រេចលើសំណើសុំដោះលែង។

ទុក ដែរ ឬយ៉ាងណា តាមអង្គច្បាប់ដោយមិនចាំបាច់ពិចារណាលើការយល់ឃើញអំពីអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ[825]។

៣៩០. មូលដ្ឋានផ្លូវច្បាប់សម្រាប់ការផ្តល់សំណងរបស់អង្គជំនុំជម្រះសាលាដំបូង គឺផ្អែកលើការសន្និដ្ឋានរបស់ខ្លួនដែលថា យោងតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR "ជនជាប់ចោទមានសិទ្ធិទាមទារការទូទាត់សំណង ចំពោះការរំលោភបំពានលើសិទ្ធិរបស់ខ្លួនដោយអាជ្ញាធរជាតិ" ទោះបីជាការរំលោភបំពានបែបនេះ មិនមែនជាការទទួលខុសត្រូវរបស់តុលាការអន្តរជាតិ ឬមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវខ្ពស់ ដែលបង្កើតឱ្យមានការរំលោភបំពាននីតិវិធីក៏ដោយ[826]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានទៀតថា ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធភាព កាំង ហ្គេកអ៊ាវ ត្រូវទទួលបានផងដែរ[827]នូវការកាត់បន្ថយទោស។ ដោយឡែកក្នុងករណីដែល កាំង ហ្គេកអ៊ាវ ត្រូវបានសម្រេចឱ្យរួចខ្លួន កាំង ហ្គេកអ៊ាវ មានសិទ្ធិទាមទារសំណងសមរម្យនៅចំពោះមុខសមត្ថកិច្ចជាតិ[828]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ច្បាប់ដែលអាចយកមកអនុវត្តបាននៅ អ.វ.ត.ក រួមទាំងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមិនបានបង្ហាញថា ការរំលោភសិទ្ធិរបស់ កាំង ហ្គេកអ៊ាវ គួរត្រូវបានទូទាត់សងដោយ អ.វ.ត.ក ឡើយ នៅពេលពុំមានភស្តុតាងបង្ហាញថា អ.វ.ត.ក ជាអ្នករំលោភកិច្ចនីតិវិធី ឬជាអ្នកទទួលខុសត្រូវចំពោះការរំលោភសិទ្ធិទាំងនោះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញដូចខាងក្រោមថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដែលពាក់ព័ន្ធត្រង់ចំណុចដែលមានខ្លឹមសារថា ការរំលោភបំពានទៅលើសិទ្ធិរបស់

---

[825] *សូមមើលរឿងក្តីរដ្ឋអាជ្ញា ទល់នឹង Erdemović*, សំណុំរឿងលេខ IT-96-22-A, "សាលដីកា", អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៧, កថាខណ្ឌ ១៦ (អង្គជំនុំជម្រះតុលាការកំពូលមិនត្រូវបានកម្រិតត្រឹមតែបញ្ហាទាំងឡាយដែលត្រូវបានលើកឡើងជាផ្លូវការដោយភាគីនោះឡើយ")។

[826] សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ៣៥។

[827] ការផ្តល់សំណងដោយការកាត់បន្ថយទោសត្រូវបានផ្តល់បន្ថែមទៅនឹងការគិតបញ្ចូលរយៈពេល ដែលជាប់ឃុំឃាំងក្រោមសមត្ថកិច្ចរបស់តុលាកាយោធា។

[828] សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ៣៦ ដល់ ២៧ និងកថាខណ្ឌ ៥ និង ៨ នៃផ្នែកសម្រេចសេចក្តី។

កាំង ហ្កេកអ៊ាវ គប្បីត្រូវទទួលបាននូវការទូទាត់ពី អ.វ.ត.ក *ទោះបី*ជាមិនមែនជាការរំលោភបំពានរបស់ អ.វ.ត.ក និងទោះបីជា មិនមានការរំលោភលើកិច្ចនីតិវិធីក៏ដោយ។

៣៩១. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មិនមានបទប្បញ្ញត្តិណាមួយដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ទាក់ទិននឹងការផ្តល់សំណងចំពោះការរំលោភលើសិទ្ធិមនុស្សនោះទេ។ ការផ្តល់សំណងតាមវិធីកាត់បន្ថយទោសមិនមានចែងនៅក្នុងច្បាប់ និងការអនុវត្តនៃប្រព័ន្ធតុលាការកម្ពុជាឡើយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលស្វែងរកគោលការណ៍ណែនាំនៅកម្រិតអន្តរជាតិ។

៣៩២. យុត្តិសាស្ត្រតុលាការអន្តរជាតិបញ្ជាក់យ៉ាងដាច់ខាតថា "មុនពេលអាចទទួលបានសំណងដែលខ្លួនទាមទារនោះ ជនជាប់ចោទត្រូវតែបង្ហាញថា ការរំលោភលើសិទ្ធិរបស់ខ្លួនមានជាប់ពាក់ព័ន្ធនឹងស្ថាប័នតុលាការណាមួយ ឬបង្ហាញថា យ៉ាងហោចណាស់ តុលាការមានការទទួលខុសត្រូវមួយចំនួនចំពោះការរំលោភសិទ្ធិនេះ"[829]។ ម៉្យាងវិញទៀត តុលាការអន្តរជាតិមានកាតព្វកិច្ចទូទាត់សំណងចំពោះការរំលោភបំពានដែលមានភស្តុតាងបង្ហាញពី "សកម្មភាពរួមគ្នា" រវាងស្ថាប័នតុលាការទាំងនេះ និងស្ថាប័នខាងក្រៅដែលនាំឱ្យកើតមាននូវការរំលោភបំពានសិទ្ធិទាំងនេះ។ ផ្ទុយទៅវិញ លទ្ធិច្បាប់ដែលមានឫសគល់នៅក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់ស៊ុងស្តីពីការរំលោភលើកិច្ចនីតិវិធី ដូចដែលត្រូវបានបកស្រាយនៅកម្រិតអន្តរជាតិនោះ តម្រូវឱ្យតុលាការបដិសេធយុត្តាធិការរបស់ខ្លួនពាក់ព័ន្ធនឹងទម្រង់នៃសំណងនេះ ដោយមិនចាំបាច់ពិចារណាថា

[829] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Karadžić*, សំណុំរឿងលេខ IT-95-5/18-PT, "សេចក្តីសម្រេចលើសំណើសុំផ្តល់សំណងរបស់ជនជាប់ចោទចំពោះការរំលោភសិទ្ធិទាក់ទងនឹងការចាប់ខ្លួន", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចក្នុង*រឿងក្តី* *Karadžić* ស្តីពីសំណងរបស់ជនជាប់ចោទចំពោះការរំលោភសិទ្ធិទាក់ទងនឹងការចាប់ខ្លួន"), កថាខណ្ឌ ៦។ *សូមមើលផងដែររឿងក្តី* *Barayagwiza ទល់នឹងរដ្ឋអាជ្ញា*, សំណុំរឿងលេខ ICTR-97-19-AR72, "សេចក្តីសម្រេច", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ (សាលដីកាលើ*រឿងក្តី* *Barayagwiza*), កថាខណ្ឌ ៦៧, ៧១, ៩០, ៩៩។ សាលដីកាក្នុង*រឿងក្តី* *Kajelijeli*, កថាខណ្ឌ ២៥២ ដល់ ២៥៣។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Rwamakuba*, សំណុំរឿងលេខ ICTR-98-44C-A, "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការផ្តល់សំណងសមស្រប"របស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៧, កថាខណ្ឌ ២៨។

ស្ថាប័នណាមួយជាអ្នកទទួលខុសត្រូវលើការរំលោភលើសិទ្ធិទាំងនេះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់យ៉ាងត្រឹមត្រូវថា លទ្ធិច្បាប់នេះ"ត្រូវបានបកស្រាយក្នុងន័យចង្អៀត និងមានកម្រិតចំពោះតែករណីទាំងឡាយដែលការរំលោភសិទ្ធិនេះ បានធ្វើឱ្យប៉ះពាល់ដល់នីតិរដ្ឋ ក្នុងការនាំយកជនជាប់ចោទទៅជំនុំជម្រះ"[830]។

៣៩៣. ក្នុងពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិនិត្យពិចារណា ថាតើការឃុំខ្លួន កាំង ហ្កេកអ៊ាវ ដោយតុលាការយោធាកម្ពុជា មានជាប់ពាក់ព័ន្ធនឹង អ.វ.ត.ក ឬស្ថាប័ននានារបស់ អ.វ.ត.ក ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា អ.វ.ត.ក គឺជា "តុលាការមួយដែលត្រូវបានបង្កើតឡើងដាច់ដោយឡែក ឯករាជ្យ និងមានលក្ខណៈអន្តរជាតិ" ដែលទោះបីជា អ.វ.ត.ក ត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់យ៉ាងណាក៏ដោយ ក៏ អ.វ.ត.ក គឺជា"ស្ថាប័នមួយឯករាជ្យ"[831]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានបញ្ជាក់ផងដែរថា "ពុំមានភស្តុតាងបង្ហាញអំពីការជាប់ពាក់ព័ន្ធជាមួយនឹងស្ថាប័នតុលាការរបស់ អ.វ.ត.ក នៅក្នុងសំណុំរឿងរបស់តុលាការយោធាកម្ពុជាពាក់ព័ន្ធ កាំង ហ្កេកអ៊ាវ ឡើយ និងជាពិសេស នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទាក់ទិននឹងការឃុំខ្លួនជនត្រូវជាប់ចោទ"[832]។ ប្រហាក់ប្រហែលគ្នានេះដែរ អង្គបុរេជំនុំជម្រះ"ពុំបានរកឃើញភស្តុតាងដែលបង្ហាញថាតុលាការយោធាកម្ពុជាបានបំពេញកិច្ចជំនួស អ.វ.ត.ក ក្នុងការឃុំខ្លួនជនត្រូវចោទ ឬពុំឃើញមានភស្តុតាងបង្ហាញពីសកម្មភាពរួមគ្នារវាងស្ថាប័ន អ.វ.ត.ក និងតុលាការយោធាកម្ពុជាឡើយ"[833]។ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានហេតុផលណាមួយដែលខុសពីអង្គហេតុដែលគ្មានការជំទាស់ខាងលើនេះឡើយ។

---

[830] សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ៣៣។

[831] សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ១០។

[832] សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ១៤។

[833] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៧, ឯកសារលេខ C5/45, កថាខណ្ឌ ២១។

៣៩៤. ពាក់ព័ន្ធនឹងលទ្ធិច្បាប់ស្តីពីការរំលោភកិច្ចនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់ថា[834]ករណីនេះ ពុំមានភស្តុតាងបង្ហាញថា ក្នុងអំឡុងនៃការឃុំខ្លួនរបស់តុលាការយោធាកម្ពុជា ជនជាប់ចោទបានទទួលរងនូវ"ការធ្វើទារុណកម្ម ឬការធ្វើបាបយ៉ាងធ្ងន់ធ្ងរ"[835] ឬក៏ថា ខ្លួនបានទទួលរងនូវការរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរ ដែលបង្ហាញឱ្យឃើញនូវការប៉ះពាល់ដល់សុចរិតភាពរបស់ អ.វ.ត.ក ឡើយ[836]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការរំលោភសិទ្ធិនេះ មិនមានហេតុផលក្នុងការបដិសេធយុត្តាធិការឡើយ។

៣៩៥. ផ្អែកតាមការយល់ឃើញទាំងពីរនេះ ដោយគ្មានការរំលោភបំពានសិទ្ធិជនជាប់ចោទដោយ អ.វ.ត.ក និងការរំលោភកិច្ចនីតិវិធីនោះ អង្គជំនុំជម្រះសាលាដំបូងគួរតែត្រូវបដិសេធសំណើរបស់ជនជាប់ចោទក្នុងការសុំឱ្យផ្តល់សំណង។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការផ្តល់សំណង ដោយផ្អែកលើ"យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR"[837] ដោយអង្គជំនុំជម្រះសាលាដំបូងបានធ្វើការបកស្រាយដោយភាន់ច្រឡំនេះ បើតាមការវិភាគឱ្យបានស៊ីជម្រៅជាងនេះ។

៣៩៦. ជាបឋម ឯកសារសំអាងផ្លូវច្បាប់តែមួយគត់ ដែលអង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ គឺរឿងក្តី *Barayagwiza* ពាក់ព័ន្ធនឹងករណីមួយ ដែលការរំលោភកិច្ចនីតិវិធី *មានភស្តុតាងបង្ហាញយ៉ាងច្បាស់លាស់* ។ ដូច្នេះហើយ មិនអាចអះអាងឱ្យបានច្បាស់ ថាតើអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ក្នុងរឿងក្តី *Barayagwiza* បានសម្រេចផ្តល់សំណង ដែរ ឬយ៉ាងណា ក្នុងករណីគ្មានការរំលោភសិទ្ធិ ដែលជាការទទួលខុសត្រូវរបស់តុលាការ និងគ្មានការរំលោភកិច្ចនីតិវិធីនោះ។ ការពិត ការដែលជនជាប់ចោទ Barayagwiza បានទទួលសំណងទាក់ទងទៅនឹងការរំលោភសិទ្ធិ ដែលមិនមែនជាការទទួលខុសត្រូវរបស់តុលាការ

---

[834]សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ៣៤។ *សូមមើលផងដែរ*សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ១៦។

[835]សេចក្តីសម្រេចក្នុង*រឿងក្តី Karadžić* ស្តីពីសំណងចំពោះការរំលោភសិទ្ធិទាក់ទងនឹងការចាប់ខ្លួន, កថាខណ្ឌ ៧។

[836]*សូមមើល*សេចក្តីសម្រេចក្នុង*រឿងក្តី* Barayagwiza, កថាខណ្ឌ ៧៤ និង ៧៧។

[837]សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ៣៥។

ICTR នោះ គឺមិនដូចគ្នានឹងរឿងក្តីបច្ចុប្បន្ននេះឡើយ ដោយហេតុថា ក្នុងរឿងក្តីបច្ចុប្បន្ននេះ គ្មានភស្តុតាងស្តែងឱ្យឃើញអំពីការរំលោភកិច្ចនីតិវិធីនោះទេ[838]។

៣៩៧. លើសពីនេះទៀត រឿងក្តីទាំងមូលដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បាន សម្រេចផ្តល់សំណង បានបង្ហាញឱ្យឃើញថា ការរំលោភសិទ្ធិ ដែលតុលាការនេះបានយក មកពិចារណានោះ គឺការរំលោភសិទ្ធិដែលត្រូវបានប្រព្រឹត្តឡើង បន្ទាប់ពីរដ្ឋអាជ្ញាបានស្នើឱ្យ ចាប់ខ្លួន ឬផ្ទេរជនជាប់ចោទ ដោយអនុលោមតាមវិធាន ៤០ និងវិធាន ៤០ *ស្ទួន* នៃវិធាន ស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR ហេតុដូច្នេះ បង្ហាញឱ្យឃើញថា យ៉ាងហោច ណាស់ក៏ការរំលោភសិទ្ធិនោះមានជាប់ពាក់ព័ន្ធទៅនឹងតុលាការ ICTR ដែរ។ នៅក្នុងរឿងក្តី *Semanza* ការសម្រេចផ្តល់សំណងត្រូវបានធ្វើឡើងចំពោះការរំលោភសិទ្ធិ ដែលស្ថិត ក្រោមការទទួលខុសត្រូវរបស់តុលាការទាំងស្រុង។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានពិចារណាត្រឹមតែការរំលោភសិទ្ធិជនជាប់ចោទ ដែលកើតឡើងចាប់ពីពេលដែល រដ្ឋអាជ្ញាបានស្នើឱ្យមានការឃុំខ្លួនបណ្តោះអាសន្ន ទោះបីជាជនជាប់ចោទ កំពុងត្រូវបានឃុំខ្លួន ដោយអាជ្ញាធររបស់ប្រទេសកាមេរូនក៏ដោយ[839]។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការ កំពូលមិនបានពិចារណាទៅលើការរំលោភណាមួយ ដែលកើតឡើងក្នុងអំឡុងពេលដែលរដ្ឋ អាជ្ញាបានសម្រេចតម្កល់រឿងទុកឥតចាត់ការ រហូតដល់ពេលដែលខ្លួនស្នើសុំឱ្យមានការចាប់ ខ្លួនជាលើកទីពីរ ក្នុងអំឡុងពេលដែលជនជាប់ចោទ *Semanza* ត្រូវបានអាជ្ញាធរតុលាការ

[838]សេចក្តីសម្រេចក្នុង*រឿងក្តី* *Barayagwiza*, កថាខណ្ឌ ១០១ (យល់ឃើញថា អង្គហេតុនៃរឿងក្តីនេះបានយុត្តិកម្មទៅលើ គោលការណ៍នៃការរំលោភដំណើរការនីតិវិធី)។

[839]*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* *Semanza*, សំណុំរឿងលេខ ICTR-97-20-A, “សេចក្តីសម្រេច”, អង្គជំនុំជម្រះតុលាការ កំពូល, ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០, កថាខណ្ឌ ៤, ៥, ៧៩ (កំណត់ថ្ងៃចាប់ផ្តើមនៃការរំលោភបំពានសិទ្ធិនៅថ្ងៃ ដែលរដ្ឋអាជ្ញាបានចេញសំណើទីមួយរបស់ខ្លួន អនុលោមតាមវិធាន ៤០ នៃវិធានស្តីពីនីតិវិធីនិងការដាក់ភស្តុតាងរបស់ តុលាការ ICTR ទោះបីជាជនជាប់ចោទកំពុងត្រូវបានជាប់ឃុំខ្លួនអនុលោមតាមដីកាចាប់ខ្លួនអន្តរជាតិដែលផ្អែកលើការ ចោទប្រកាន់ស្រដៀងគ្នា។ *សូមមើលផងដែរ*សេចក្តីសម្រេច និងការប្រកាសទោសក្នុង*រឿងក្តី* *Semanza*, កថាខណ្ឌ ៥៨៣ ដល់ ៥៨៤។

ប្រទេសកាមេរូនសម្រេចឃុំខ្លួនដោយឯកឯងនោះទេ[840]។ នៅក្នុងរឿងក្តី *Kajelijeli* ជនជាប់ចោទត្រូវបានផ្តល់ការកាត់បន្ថយទោសចំពោះការរំលោភសិទ្ធិជនជាប់ចោទដែលកើតមានឡើងបន្ទាប់ពីរដ្ឋអាជ្ញាស្នើសុំឱ្យមានការចាប់ខ្លួន[841]។ ជាចុងក្រោយ នៅក្នុងរឿងក្តី *Rwamakuba* តុលាការបានសម្រេចផ្តល់សំណងផ្នែកហិរញ្ញវត្ថុ ចំពោះការរំលោភសិទ្ធិរបស់ជនជាប់ចោទដែលទាក់ទងទៅនឹងជំនួយផ្នែកច្បាប់ ដែលកើតឡើងនៅពេលដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់តុលាការ ICTR ។ ផ្ទុយទៅវិញ សំណើរបស់ជនជាប់ចោទ Rwamakuba ដែលសុំឱ្យពិនិត្យឡើងវិញអំពីលក្ខខណ្ឌក្នុងការឃុំខ្លួនគាត់ក្នុងប្រទេសណាមីប៊ីត្រូវបានតុលាការ ICTR បដិសេធចោល ដោយសំអាងលើការដែលគ្មានសកម្មភាពរួមគ្នារវាងអាជ្ញាធរជាតិ និងតុលាការ ICTR នាពេលនោះ[842]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR សម្រេចថា"ការជំទាស់ណាមួយនៅក្នុងបញ្ហានេះ ត្រូវស្ថិតនៅក្រោមការដោះស្រាយចំពោះមុខយុត្តាធិការរបស់ណាមីប៊ី"[843]។

៣៩៨. យុត្តិសាស្ត្រខាងលើរបស់តុលាការ ICTR បង្ហាញឱ្យឃើញថា ដើម្បីអាចផ្តល់សំណងដល់ជនជាប់ចោទបាន ការរំលោភសិទ្ធិមនុស្សត្រូវតែជាការរំលោភកិច្ចនិតិវិធី ឬក៏ជាការរំលោភសិទ្ធិដែលជាការទទួលខុសត្រូវរបស់តុលាការ និងត្រូវបង្ហាញឱ្យឃើញផងដែរថា សំណងទាំងនេះជានិច្ចកាលត្រូវសម្រេចផ្តល់ឱ្យក្នុងករណី ដែលមានការខកខានក្នុងការបំពេញកិច្ចពីសំណាក់រដ្ឋអាជ្ញា ឬស្ថាប័នផ្សេងណាមួយរបស់តុលាការនោះ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា៖

---

[840]សេចក្តីសម្រេចក្នុង*រឿងក្តី Semanza*, កថាខណ្ឌ ៧៩ និង៨៨។

[841]សាលដីកាក្នុង*រឿងក្តី Kajelijeli*, កថាខណ្ឌ ២២៧, ៣២៣ ដល់ ៣២៤។

[842]*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Rwamakuba, សំណុំរឿងលេខ ICTR-98-44-T, "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងការចាប់ខ្លួនដោយខុសច្បាប់ និងការឃុំខ្លួនជនជាប់ចោទដោយខុសច្បាប់", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០០ ("សេចក្តីសម្រេចក្នុង*រឿងក្តី* Rwamakuba ស្តីពីការចាប់ខ្លួន និងការឃុំខ្លួនដោយខុសច្បាប់"), កថាខណ្ឌ ២៧ និង៣០។

[843]សេចក្តីសម្រេចក្នុង*រឿងក្តី Rwamakuba*, ស្តីពីការចាប់ខ្លួន និងការឃុំខ្លួនដោយខុសច្បាប់, កថាខណ្ឌ ៣០។

គួរកត់សម្គាល់ថា នៅគ្រប់ករណីទាំងអស់ដែលជនជាប់ចោទយកមកធ្វើជាសំអាង ដើម្បីគាំទ្រគោលជំហររបស់ខ្លួនដែលថា ការទទួលខុសត្រូវរបស់តុលាការពុំមែនជាលក្ខខណ្ឌតម្រូវចាំបាច់ក្នុងការសម្រេចផ្តល់សំណងនោះ គឺថា សំអាងហេតុ និងការពិចារណាសំខាន់ៗ បានផ្តោតជាចុងក្រោយជុំវិញការទទួលខុសត្រូវរបស់រដ្ឋអាជ្ញាចំពោះការរំលោភសិទ្ធិ ជាជាងការទទួលខុសត្រូវរបស់អាជ្ញាធរជាតិ[844]។

៣៩៩. យោងតាមហេតុផលដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះតុលាការកំពូល (ចៅក្រម Klonowiecka-Milart និង ចៅក្រម Jayasinghe ជំទាស់) យល់ឃើញថា នេះមិនមែនជាករណីដែល អ.វ.ត.ក គប្បីសម្រេចផ្តល់សំណងចំពោះការរំលោភសិទ្ធិរបស់ កាំង ហ្គេកអ៊ាវ ឡើយ។ ដោយសារតែនេះជាបញ្ហាផ្នែកច្បាប់ អង្គជំនុំជម្រះសាលាដំបូងមិនមានឆន្ទានុសិទ្ធិក្នុងការផ្តល់សំណង ចំពោះការចោទប្រកាន់អំពីការរំលោភសិទ្ធិរឿងក្តីបច្ចុប្បន្ននេះឡើយ ហើយកំហុសអង្គច្បាប់នេះ ប៉ះពាល់ដោយផ្ទាល់ដល់ការប្រកាសទោសស្ថាពរដែល កាំង ហ្គេកអ៊ាវ ត្រូវទទួល។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេច (ចៅក្រម Klonowiecka-Milart និង ចៅក្រម Jayasinghe ជំទាស់) ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដែលនាំឱ្យមោឃៈការប្រកាសទោសក្នុងការសម្រេចកាត់បន្ថយរយៈពេលផ្តន្ទាទោសចំនួន ៥(ប្រាំ)ឆ្នាំ និងការគិតបញ្ចូលនូវរយៈពេលជាប់ឃុំឃាំង ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលជាការផ្តល់សំណងសមស្របចំពោះការរំលោភសិទ្ធិ កាំង ហ្គេកអ៊ាវ។

### ៥.គ.៥.ការគិតបញ្ចូលនូវថិរវេលានៃការឃុំខ្លួនមុនដំណាក់កាលជំនុំជម្រះ

៤០០. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កាំង ហ្គេកអ៊ាវ មានសិទ្ធិទទួលបាននូវការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទាំងស្រុងចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ (នៅក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា) និងរយៈពេលឃុំខ្លួនបណ្តោះអាសន្ន ចាប់ពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ រហូតដល់ពេល

[844] សេចក្តីសម្រេចក្នុង *រឿងក្តី Karadžić* ស្តីពីសំណងចំពោះការរំលោភសិទ្ធិទាក់ទងនឹងការចាប់ខ្លួន, កថាខណ្ឌ ៦។

សាលក្រមនេះចូលជាស្ថាពរ (នៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក)[845]។ យោងតាមអង្គជំនុំជម្រះសាលាដំបូង ចំពោះរយៈពេលឃុំខ្លួនដំបូងនៅក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជាត្រូវបានផ្តល់ឱ្យ កាំង ហ្កេកអ៊ាវ ជាផ្នែកមួយនៃការទូទាត់សំណងសម្រាប់ការឃុំខ្លួនខុសច្បាប់[846] រីឯរយៈពេលឃុំខ្លួនបណ្តោះអាសន្នបន្ទាប់ដែលស្ថិតក្រោមសមត្ថកិច្ច អ.វ.ត.ក ត្រូវបានគិតបញ្ចូលទៅក្នុងថិរវេលានៃទោសដោយផ្អែកតាមសិទ្ធិ ដែលមានចែងនៅក្នុងមាត្រា ៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧[847]។ ដោយហេតុថា រយៈពេលឃុំខ្លួនបណ្តោះអាសន្នបន្ទាប់ដែលស្ថិតក្រោមសមត្ថកិច្ច អ.វ.ត.ក ពុំមែនជាចំណោទបញ្ហាតទៅទៀត អង្គជំនុំជម្រះតុលាការកំពូលត្រូវពិនិត្យពិចារណាទៅលើរយៈពេលឃុំខ្លួនដំបូង នៅក្រោមសមត្ថកិច្ចរបស់តុលាការយោធា។

៤០១. ដោយហេតុថា នៅក្នុងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ពុំមានបទប្បញ្ញត្តិស្តីពីការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។ មាត្រា ៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ បានចែងថា ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដែលបានប្រកាស ឬជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា។ មាត្រា ៥១ (ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ចែងស្រដៀងគ្នាថា ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល។ តាមការអនុវត្តជាក់ស្តែងរបស់កម្ពុជា ក៏ដូចជាអន្តរជាតិដែរការគិតបញ្ចូលត្រូវបានយកមកអនុវត្ត

[845] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៨១។

[846] សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ២៨ និងកថាខណ្ឌ ៧ នៃផ្នែកសម្រេចសេចក្តី។

[847] សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ២៧ និងកថាខណ្ឌ ៦ នៃផ្នែកសម្រេចសេចក្តី។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦២៤, ៦៨១។

ដោយតុលាការព្រហ្មទណ្ឌ ក្នុងរឿងក្តីនានាដែលនាំឱ្យមានការប្រកាសទោសដែលមានរយៈពេលកំណត់ និងការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត[848]។

៤០២. ដោយហេតុថា ការទូទាត់សំណងដោយសារការរំលោភលើសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ នៅមុនពេលជំនុំជម្រះក្តី គឺជាបញ្ហាមួយដាច់ដោយឡែកពីការគិតបញ្ចូលរយៈពេលឃុំខ្លួនបណ្តោះអាសន្នទៅក្នុងថិរវេលានៃទោសដែលបានប្រកាស[849]។ ទោះបីជាសំណងដែលបានផ្តល់ឱ្យដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបានបដិសេធទាំងស្រុងក៏ដោយ ក៏មិនមែនមានន័យថាមិនគិតបញ្ចូលនូវថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នពីមុននោះទេ។

៤០៣. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងថា ការចោទប្រកាន់ទាំងឡាយដែលតុលាការយោធាកម្ពុជាបានយកមកធ្វើជាសំអាងដើម្បីឃុំខ្លួនជនជាប់ចោទ គឺ "មានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំង"[850] ទៅនឹងការចោទប្រកាន់ទាំងឡាយនៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ ពិតណាស់ នេះគឺជាហេតុផលដែលតុលាការយោធាកម្ពុជាបានបញ្ចប់យុត្តាធិការរបស់ខ្លួននៅពេលដែល អ.វ.ត.ក ត្រូវបានបង្កើតឡើង[851]។ យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ*មិនអចិន្ត្រៃយ៍* បញ្ជាក់ថា ក្នុងកាលៈទេសៈបែបនេះ ដោយសារតែហេតុផលនៃយុត្តិធម៌ រយៈពេលដែលជនជាប់ចោទស្ថិតក្នុងការឃុំខ្លួនជាបណ្តោះអាសន្ននៅក្រោមអំណាចតុលាការជាតិតែម្នាក់ឯង គឺត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោស

---

[848] *សូមមើលឧទា.*សាលក្រមក្នុង*រឿងក្តី Lukić និង Lukić*, កថាខណ្ឌ ១១២០។ សាលដីកាក្នុង*រឿងក្តី Galić*, កថាខណ្ឌ ៥ នៃផ្នែកសម្រេចសេចក្តី។ សាលដីកាក្នុង*រឿងក្តី Seromba*, កថាខណ្ឌ ៩ នៃផ្នែកសម្រេចសេចក្តី។

[849] សាលដីកាក្នុង*រឿងក្តី Semanza*, កថាខណ្ឌ ៣២៨។

[850] សេចក្តីសម្រេចរបស់លើសំណើសុំដោះលែង, កថាខណ្ឌ ២៨។

[851] "ដីកាសម្រេច", ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា, ឯកសារខ្មែរចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៨, ឯកសារបកប្រែភាសាអង់គ្លេសដាក់នៅថ្ងៃទី ២៥ ខែ ឧសភាគ ឆ្នាំ ២០០៩, ឯកសារលេខ E52/4.66 ("យល់ឃើញថា ក្រោយពេលបង្កើត អ.វ.ត.ក ឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ក្នុងអំឡុងពេលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ ដូច្នេះតុលាការយោធាមិនមានយុត្តាធិការទៅលើបទល្មើសទាំងអស់ដែលមានចែងក្នុងយុត្តាធិការ អ.វ.ត.ក ទៀតឡើយ")។

00798632



ដែលសម្រេចចុងក្រោយ[852]។ លើសពីនេះទៀត មាត្រា ៧៨(២) នៃលក្ខន្តិកៈទីក្រុងរ៉ូមបានចែងពីលទ្ធភាពក្នុងការ“គិតបញ្ចូលនូវរយៈពេលណាមួយ ដែលជនជាប់ចោទត្រូវបានឃុំខ្លួន *ទាក់ទងទៅនឹង*ការប្រព្រឹត្តបទឧក្រិដ្ឋជាមូលដ្ឋាន”[853]។

៤០៤. ដោយពិចារណាលើបទដ្ឋានអន្តរជាតិទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញជាឯកច្ឆន្ទថា កាំង ហ្គេកអ៊ាវ មានសិទ្ធិទទួលបាននូវការគិតបញ្ចូលនូវថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទាំងស្រុង ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ មក ដោយមិនរាប់បញ្ចូលថ្ងៃចេញសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចអនុវត្តការគិតបញ្ចូលទៅក្នុងថិរវេលា នៃការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះ កាំង ហ្គេកអ៊ាវ ដោយប្រកាសថា កាំង ហ្គេកអ៊ាវ បានទទួលរងទោសរបស់ខ្លួនអស់រយៈពេល ១២ ឆ្នាំ និង ២៦៩ ថ្ងៃរួចហើយដែលជារយៈពេលជននេះស្ថិតក្នុងការឃុំខ្លួនជាបណ្តោះអាសន្នចាប់ពី ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ ដល់ ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២ នេះផងដែរ។

## **៥.ឃ.សេចក្តីសន្និដ្ឋាន**

៤០៥. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ហើយសម្រេចទទួលយកផ្នែកខ្លះ និងសម្រេចបដិសេធផ្នែកខ្លះនៃទឡ្ហីករណ៍ទី ១ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

---

[852] *សូមមើល ឧទា.*សាលដីកាក្នុង*រឿងក្តី* Kajelijeli, កថាខណ្ឌ ៣២២, ៣២៤(ដែលតម្កល់ការសម្រេចនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR ត្រង់កថាខណ្ឌ ៩៦៦។ សាលក្រមក្នុង*រឿងក្តី* Semanza, កថាខណ្ឌ ៥៨៤។

[853] មាត្រា ៧៨(២) នៃលក្ខន្តិកៈរបស់តុលាការ ICC។

## ៦.កំហុសដែលបានលើកឡើងទាក់ទងទៅនឹងភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, ២ និង៣)

### ៦.ក.ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការបង្កើតសញ្ញាណថ្មីនៃជនរងគ្រោះ

#### ៦.ក.១.សារណា

៤០៦. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ក្រុម ២ និងក្រុម ៣ (ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី) បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយអនុវត្តលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានលក្ខណៈតឹងរ៉ឹងពេក និងដែលមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង។ កំហុសអង្គច្បាប់នេះមានការពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតម្រូវដែលថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមែនជាសមាជិកគ្រួសារផ្ទាល់របស់ជនរងគ្រោះផ្ទាល់ដែលបានមរណភាពដោយឧក្រិដ្ឋកម្មនានា ដែលត្រូវបានចោទប្រកាន់ ត្រូវបង្ហាញអំពីចំណងសាច់ញាតិជាមួយនឹងជនរងគ្រោះផ្ទាល់ និងអំពីកាលៈទេសៈនានា ដែលបណ្តាលឱ្យមាន“ចំណងពិសេសនៃក្តីស្រលាញ់” ឬភាពនៅក្នុងបន្ទុកជាមួយនឹងជនរងគ្រោះផ្ទាល់ផង[854]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ លើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង បានធ្វើឱ្យប៉ះពាល់ដល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ដោយហេតុថា លក្ខណៈវិនិច្ឆ័យអំពី“ចំណងពិសេសនៃក្តីស្រលាញ់”នេះ មិនអាចដឹងជាមុនបាន ហើយអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានជូនដំណឹងអំពីលក្ខណៈវិនិច្ឆ័យនេះ នៅមុនពេលចេញសាលក្រមរបស់ខ្លួន[855]។

---

[854] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, **ទឡ្ហីករណ៍ទី ២**, កថាខណ្ឌ ៤០ ដល់ ៦២។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ស្តីពីភាពអាចទទួលយកបាន**ទឡ្ហីករណ៍ទី ៤** កថាខណ្ឌ ៩១ ដល់ ១០៩។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ **ទឡ្ហីករណ៍ទី៣**, កថាខណ្ឌ ៨៥ ដល់ ៩៤។

[855] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ៤០ ដល់ ៦២។

៤០៧. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបង្ហាញដល់អង្គជំនុំជម្រះសាលាដំបូងអំពីអត្ថិភាពនៃកំហុសរបស់ កាំង ហ្គេកអ៊ាវ ដែលមានទំនាក់ទំនងហេតុ និងផលដោយផ្ទាល់ទៅនឹងព្យសនកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងដោយផ្ទាល់ ហើយដែលអាចបង្ហាញបាន[856]។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ ហើយបានយល់ឃើញថា ពាក្យពេចន៍"ផលវិបាកផ្ទាល់" ដែលត្រូវបានប្រើប្រាស់នៅក្នុងបទប្បញ្ញត្តិនេះ សង្កត់ធ្ងន់ទៅលើទំនាក់ទំនងរវាងឧក្រិដ្ឋកម្ម និងព្យសនកម្មដែលបានទទួលរង ជាជាងទៅលើគោលដៅដែលជាចេតនានៃអំពើល្មើសនេះ[857]។ ដូចនេះ ការទទួលខុសត្រូវរបស់ កាំង ហ្គេកអ៊ាវ មិនត្រូវបានកម្រិតត្រឹមជនទាំងឡាយណាដែលរងគ្រោះដោយសារឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តប៉ុណ្ណោះទេ ថែមទាំងអាចពន្លាតដល់ក្រុមជនរងគ្រោះដែលមានចំនួនច្រើនជាងនេះ[858]។ ដោយមានការពន្យល់បន្តិចបន្តួច[859] អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា សមាជិកគ្រួសារផ្ទាល់ គឺស្ថិតនៅក្នុងវិសាលភាពនៃវិធាន ២៣(២)(ខ) នៃវិធានផ្ទៃក្នុង ប៉ុន្តែ"ការបង្ហាញការខូចខាតដោយផ្ទាល់ទៅលើសមាជិកគ្រួសារ

[856]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៣៩ ដល់ ៦៤០។

[857]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤២។

[858]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤២។

[859]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤២ ដល់ ៦៤៣ និង ជើងទំព័រ ១០៧៥ ដល់ ១០៧៦។ អង្គជំនុំជម្រះសាលាដំបូងយោងលើការយល់ពាក្យ"ជនរងគ្រោះ" នៅក្នុងយុត្តាធិការផ្សេងៗទៀត និងនៅក្នុងគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ និងគោលការណ៍ណែនាំនានាស្ដីពីសិទ្ធិក្នុងការទទួលបានដំណោះស្រាយ និងការជួសជុលសំណងសម្រាប់ជនរងគ្រោះចំពោះការរំលោភទាំងស្រុងលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ, សេចក្ដីសម្រេចរបស់មហាសន្និបាតលេខ (G.A. Res. 60/147), កំណត់ហេតុផ្លូវការរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ (UN GAOR), សម័យប្រជុំលើកទី ៦០, ឯកសារលេខ A/RES/60/147 (ថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៦) ("គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្ដីពីសំណង") ដោយគ្មានការបំភ្លឺ ថាតើអង្គជំនុំជម្រះសាលាដំបូងចាត់ទុកប្រភពទាំងអស់នេះ ជាការបញ្ជាក់អំពីការចងភ្ជាប់នឹងបទដ្ឋានអន្តរជាតិ សមត្ថកិច្ចដែលអាចជឿជាក់បានពាក់ព័ន្ធនឹងការបកប្រែ ឬដែលក្រោយមកជាបទដ្ឋាននៃការបង្ហាញភស្តុតាង ឬយ៉ាងណាឡើយ។

សាច់ញាតិឆ្ងាយៗ ពិតជាមានការលំបាកណាស់"[860]។ អង្គជំនុំជម្រះសាលាដំបូងបាន ពិចារណាថែមទៀតថា នៅក្នុងករណីលើកលែងមួយចំនួន ការខូចខាតដែលបានចោទឡើង ដោយសមាជិកនៃគ្រួសារសាច់ញាតិឆ្ងាយៗ ក៏អាចចាត់ទុកជាផលវិបាកផ្ទាល់នៃបទល្មើស បាននៅពេលដែលអ្នកដាក់ពាក្យសុំ អាចបង្ហាញពីភាពជាសាច់ញាតិជាមួយនឹងជនរងគ្រោះ ផ្ទាល់ ក៏ដូចជាចំណងពិសេសនៃក្ដីស្រលាញ់ ឬភាពនៅក្នុងបន្ទុកជាមួយជនរងគ្រោះផ្ទាល់[861]។

៤០៨. នៅក្នុងទស្សីករណ៍នានានៃបណ្ដឹងសាទុក្ខនេះ បញ្ហាបឋមនៅចំពោះមុខអង្គជំនុំជម្រះតុលាការ កំពូល គឺថាតើអ្នកណាខ្លះដែលអាចត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះ មុខ អ.វ.ត.ក។ បញ្ហាដែលត្រូវពិចារណាបន្តទៀត គឺបញ្ហា ថាតើការយល់ឃើញជាទូទៅ របស់អង្គជំនុំជម្រះសាលាដំបូងដែលថា "សមាជិកក្រុមគ្រួសារផ្ទាល់របស់ជនរងគ្រោះ គឺស្ថិត នៅក្នុងវិសាលភាពនៃវិធាន ២៣(២)(ខ) នៃវិធានផ្ទៃក្នុង"[862] មានសុពលភាពថា ជាការ យល់ឃើញផ្នែកអង្គច្បាប់ ឬជាការយល់ឃើញផ្នែកអង្គហេតុ។ បន្ទាប់មកទៀត ផ្អែកតាម ចម្លើយនានាដែលទទួលបាន អង្គជំនុំជម្រះតុលាការកំពូលនឹងពិនិត្យមើល ថាតើអង្គជំនុំជម្រះ សាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការតម្រូវឱ្យមានការបង្ហាញពីចំណងពិសេសនៃ ក្ដីស្រលាញ់ ឬភាពនៅក្នុងបន្ទុក ដើម្បីទទួលយកពាក្យសុំរបស់គ្រួសារសាច់ញាតិឆ្ងាយនៃជន រងគ្រោះផ្ទាល់ដែលបានទទួលមរណភាព។

## ៦.ក.២.សញ្ញាណនៃដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក

៤០៩. ជាចំណុចចាប់ផ្ដើមនៃការវិភាគ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងម្ដងទៀតថា យោង តាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ និង មាត្រា ៣៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ច្បាប់កម្ពុជា នៅតែជាច្បាប់នីតិវិធីគ្រប់គ្រង សម្រាប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក លើកលែងតែក្នុងករណីដែលច្បាប់

[860]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៣។

[861]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៣។

[862] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៣។

កម្ពុជាមិនមានលក្ខណៈគ្រប់គ្រាន់ យោងតាមលក្ខណៈវិនិច្ឆ័យដែលបានបញ្ជាក់នៅក្នុងបទបញ្ញត្តិទាំងអស់នេះ[863]។ ការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ហាញនៅក្នុង វិធាន ២៣(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) ដែលដូចគ្នាទៅនឹងមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ចែងដូចខាងក្រោមថា:

> ដើម្បីឱ្យពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលយកបាន ព្យសនកម្មត្រូវតែជា:
>
> ក) ការខូចខាតខាងរាងកាយ សម្ភារៈ ឬ ផ្លូវចិត្ត និង
>
> ខ) ជាផលវិបាកដោយផ្ទាល់ពីបទល្មើសជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន។

៤១០. ដោយបានពិចារណា ថាតើការកំណត់និយមន័យនៃដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានចែងគ្រប់គ្រាន់ដោយច្បាប់កម្ពុជា ដែរ ឬ យ៉ាងណានោះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា វិធាន ២៣ (២) នៃវិធានផ្ទៃក្នុង ត្រូវបានចាត់ទុកថា ជាការថ្លែងឡើងវិញនូវមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ដែលដូចគ្នាបេះបិទទៅនឹងមាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង[864]។ ចំណុចសំខាន់របស់និយមន័យនៃពាក្យដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងលិខិតូបករណ៍គតិយុត្តទាំងអស់នេះ មិនមែនជាការបង្ហាញអំពីចំណាត់ថ្នាក់ផ្លូវការជាក់លាក់របស់សមាជិកក្នុងគ្រួសារនោះទេ ប៉ុន្តែ គឺជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់ទៅលើព្យសនកម្មជាក់ស្តែង ដែលជាផលវិបាកផ្ទាល់នៃបទល្មើសតែប៉ុណ្ណោះ។

៤១១. វិធីសាស្ត្រក្នុងការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្អែកលើលក្ខណៈវិនិច្ឆ័យសំខាន់នេះ គឺស្របជាមួយនឹងគោលការណ៍ដែលថា ការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ មានទំនាក់ទំនងដែលមិនអាចដាច់ចេញពីគ្នាបានជាមួយនឹង

---

[863]មាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[864]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៧៥។

បណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ប្រព័ន្ធច្បាប់ជាតិដែលទទួលស្គាល់សិទ្ធិក្នុងការចូលរួមរបស់ជនរងគ្រោះ ដោយមិនទាក់ទងទៅនឹងបណ្តឹងរដ្ឋប្បវេណីនោះ អាចកំណត់ប្រភេទក្រុមនៃបុគ្គលទាំងឡាយដែលត្រូវបានអនុញ្ញាត បើតាមន័យជាផ្លូវការ និងមានលក្ខណៈចង្អៀត ការផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី បានតែចំពោះបុគ្គលណាដែលត្រូវបានគេរំលោភសិទ្ធិ ឬទទួលរងគ្រោះដោយសារអំពើនានាដែលត្រូវបានចោទប្រកាន់ និងបានតែចំពោះបុគ្គលដែលមានឈ្មោះជាក្រុមគ្រួសារសាច់ញាតិផ្ទាល់ នៅក្នុងករណីនៃមរណៈភាពរបស់ជនរងគ្រោះផ្ទាល់តែប៉ុណ្ណោះ[865]។ បុគ្គលដែលត្រូវបានគេរំលោភសិទ្ធិ ឬទទួលរងគ្រោះ តម្រូវឱ្យធ្វើការបង្ហាញអំពីការរំលោភសិទ្ធិ ឬការបង្កគ្រោះថ្នាក់ដល់ខ្លួនតែប៉ុណ្ណោះ ចំណែកឯបុគ្គលដែលមានឈ្មោះជាក្រុមគ្រួសារសាច់ញាតិផ្ទាល់ ត្រូវធ្វើការបង្ហាញអំពីការពិតដែលថា ខ្លួនស្ថិតនៅក្នុងប្រភេទជាសិទ្ធិវន្តដែលត្រូវបានអនុញ្ញាត។ វិធីសាស្ត្រផ្លូវ

[865] *សូមមើល ឧទា.* មាត្រា ៣៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់ (ចែងអំពីសិទ្ធិរបស់ជនរងគ្រោះ ដែលអាចបំពេញតួនាទីជា"រដ្ឋអាជ្ញាបន្ទាប់បន្សំឯកជន (private accessory prosecutor)" ("Nebenklage") ដោយសិទ្ធិនេះផ្តល់ឱ្យតែជនរងគ្រោះណាដែលត្រូវបានសម្លាប់ដោយអំពើខុសច្បាប់ (ឬក៏កូន ឪពុកម្តាយ បងប្អូន ឬប្តីប្រពន្ធ) ហើយការប្រើប្រាស់សិទ្ធិនេះ គឺជាបណ្តឹងរដ្ឋប្បវេណីឯករាជ្យ។ មាត្រា ៤៩ ដល់ ៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប៉ូឡូញឆ្នាំ ១៩៩៧ (ចែងថាជនរងគ្រោះអាចដើរតួជារដ្ឋអាជ្ញាជំនួយបាន ហើយក្នុងករណី ដែលជនរងគ្រោះបានទទួលមរណភាពសិទ្ធិនានារបស់ជនរងគ្រោះអាចត្រូវបានអនុវត្តដោយសាច់ញាតិ ដែលសិទ្ធិទាំងនេះត្រូវបានចែងយ៉ាងច្បាស់។ នៅ New South Wales និងស្រដៀងគ្នានៅរដ្ឋផ្សេងទៀតរបស់អូស្ត្រាលី ជនរងគ្រោះអាចដាក់"សេចក្តីថ្លែងការណ៍អំពីផលប៉ះពាល់លើជនរងគ្រោះ" ក្រោយពេលមានការសម្រេចពីពិរុទ្ធភាពប៉ុន្តែមុនពេលការប្រកាសទោស។ (នីតិវិធីនៃការប្រកាសទោស) មាត្រា ២៨(១) ឆ្នាំ ១៩៩៩ នៃច្បាប់ស្តីពីបទល្មើសរបស់ប្រទេស New South Wales នៅក្នុងករណីនៃមរណភាពរបស់ជនរងគ្រោះដំបូង (ជនរងគ្រោះផ្ទាល់) ជនរងគ្រោះជាក្រុមគ្រួសារ (សមាជិកគ្រួសារ) អាចដាក់សេចក្តីថ្លែងការណ៍អំពីផលប៉ះពាល់លើជនរងគ្រោះបាន (មាត្រា ២៨(៣))។ ជនរងគ្រោះជាក្រុមគ្រួសារ "មានន័យថាជាបុគ្គលដែលជាសមាជិកម្នាក់ក្នុងចំណោមក្រុមគ្រួសារផ្ទាល់របស់ជនរងគ្រោះដំបូង នៅពេលបទល្មើសត្រូវបានប្រព្រឹត្តនិងរួមទាំងបុគ្គលបែបនេះមិនថាជាអ្នកដែលទទួលរងនូវព្យសនកម្មផ្ទាល់ខ្លួន ដោយសារបទល្មើសឬអត់នោះទេ" (មាត្រា ២៦)។ ក្រុមគ្រួសារផ្ទាល់រួមមាន៖ "(ក) ប្តីឬប្រពន្ធរបស់ជនរងគ្រោះ ឬ (ខ) ដៃគូតាមហេតុការណ៍ជាក់ស្តែងរបស់ជនរងគ្រោះ ឬ(ខ១) បុគ្គលដែលភ្ជាប់ពាក្យដើម្បីរៀបការជាមួយជនរងគ្រោះ ឬ (គ) ឪពុកម្តាយជីដូនជីតាអាណាព្យាបាលឬឪពុកម្តាយចុងរបស់ជនរងគ្រោះ ឬ (ឃ) កូនចៅឬកូនចុងរបស់ជនរងគ្រោះ ឬកូនមួយចំនួនផ្សេងទៀតដែលស្ថិតក្រោមអាណាព្យាបាលរបស់ជនរងគ្រោះ ឬ (ង) បងប្អូនប្រុសស្រីបងប្អូនប្រុសស្រីដែលមានតែឪពុក ឬម្តាយរួមបងប្អូនប្រុសស្រីចុងរបស់ជនរងគ្រោះ" (មាត្រា ២៦)។

ការ ហើយតឹងរ៉ឹងជាងនេះ ក្នុងការទទួលស្គាល់ជនរងគ្រោះនានាជាភាគីនោះ គឺមានលក្ខណៈត្រឹមត្រូវទៅតាមគោលការណ៍នៃបណ្តឹងអាជ្ញា គោលការណ៍សមភាពនៃសិទ្ធិរបស់ភាគី និងគោលការណ៍ស្តីពីផលប្រយោជន៍សេដ្ឋកិច្ចនៃកិច្ចដំណើរការនីតិវិធី ដែលមានតួនាទីកម្រិតសិទ្ធិចូលរួមនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ក្នុងការគាំទ្រដល់បណ្តឹងអាជ្ញា និងដើម្បីកម្រិតពេលវេលាសម្រាប់ការសម្រេចអំពី ភាពអាចទទួលយកបានរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ទោះបីជាយ៉ាងណាក៏ដោយ ពាក់ព័ន្ធទៅនឹងបណ្តឹងរដ្ឋប្បវេណី ឋានៈជាភាគីជាប់ពាក់ព័ន្ធតែទៅនឹងអង្គហេតុនៃការទាមទារសំណងរដ្ឋប្បវេណី ពីអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ ដោយគ្មានការកម្រិតជាផ្លូវការណាមួយទាក់ទិនទៅនឹងបុគ្គលដែលទាមទារសំណងនោះឡើយ។ មានការសង្កត់ធ្ងន់ទៅលើការវាយតម្លៃភស្តុតាងដែលគាំទ្រដល់ការទាមទារ ជាជាងទៅលើការបង្កើតឱ្យមានការទទួលស្គាល់ជាផ្លូវការ។

៤១២. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ទោះបីជាវិធានផ្ទៃក្នុងមានចរិតលក្ខណៈលាយចម្រុះគ្នា ហើយត្រូវបានធ្វើវិសោធនកម្មជាច្រើនដង ទៅលើទម្រង់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងវិធានផ្ទៃក្នុងក៏ដោយ ក៏និយមន័យនៃពាក្យដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងនៅក្នុងសំណៅដើមនៃវិធាន ២៣(២) នៃវិធានផ្ទៃក្នុង (ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧) ជាចាំបាច់នៅតែមិនត្រូវបានផ្លាស់ប្តូរនោះទេ ដូចនេះ គឺជាការបញ្ជាក់អំពីសុពលភាពដ៏យូរអង្វែងរបស់និយមន័យនេះនៅចំពោះមុខ អ.វ.ត.ក[866]។

---

[866]លក្ខណៈវិនិច្ឆ័យស្តីពីភាពអាចទទួលយកបាននិងបទដ្ឋាននៃការបង្ហាញភស្តុតាង ត្រូវបានបញ្ជាក់បំភ្លឺនៅក្នុងវិសោធនកម្មលើកទី៥ នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ*វិធាន ២៣*ស្ទួន* (១) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨) ចែងថា៖ "ដើម្បីឲ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ៖ ក- បង្ហាញពីអត្តសញ្ញាណឲ្យបានច្បាស់លាស់។ និង ខ- បង្ហាញ ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព"។ ការបញ្ជាក់បំភ្លឺនេះមិនតម្រូវឲ្យមានការផ្លាស់ប្តូរ នៅក្នុងខ្លឹមសារនៃការកំណត់និយមន័យនៃដើមបណ្តឹងរដ្ឋប្បវេណីទេ។

៤១៣. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា លក្ខណៈវិនិច្ឆ័យដើម្បីកំណត់អំពីជនរងគ្រោះនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងបទដ្ឋានអន្តរជាតិ និងនៅចំពោះមុខ អ.វ.ត.ក មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ដែលអនុញ្ញាតឱ្យមានការចូលរួមពីជនរងគ្រោះ[867]។ ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើគោលការណ៍ជាមូលដ្ឋានរបស់

---

[867] *សូមមើល ឧទា.* វិធាន ៨៥(ក) នៃវិធាននីតិវិធី និងភស្តុតាងនៅតុលាការ ICC (កំណត់និយមន័យជនរងគ្រោះថា ជា "រូបវន្តបុគ្គល ដែលបានទទួលរងព្យសនកម្ម ដែលកើតឡើងដោយសារការប្រព្រឹត្តិបទល្មើសណាមួយ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ"។ *ស្ថានភាពនៅក្នុងប្រទេសសាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ នៅក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06-1432, "សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I លើការចូលរួម របស់ជនរងគ្រោះកាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨", តុលាការកំពូល, ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨, កថាខណ្ឌ ៣៨ (ដែលចៅក្រមបួនរូបក្នុងចំណោមចៅក្រមប្រាំរូប បានសម្រេចថា "សញ្ញាណរបស់ជនរងគ្រោះ ត្រូវចាំបាច់បញ្ជាក់អំពីអត្ថិភាពនៃព្យសនកម្មផ្ទាល់ខ្លួន ប៉ុន្តែ មិនចាំបាច់បញ្ជាក់អំពីអត្ថិភាពនៃព្យសនកម្មផ្ទាល់នោះទេ"។ ទស្សនទានរបស់តុលាការ ICC ចំពោះពាក្យពេចន៍ "ជនរងគ្រោះ" អាចមានលក្ខណៈខុសគ្នាតិចតួចពីពាក្យ "ជនរងគ្រោះ" ដែលមានចែងនៅក្នុងវិធាន ២៣(២) នៃវិធានផ្ទៃក្នុង និង មាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ("CCP") ដែលចាំបាច់តម្រូវឱ្យព្យសនកម្ម គឺជា "ផលវិបាកផ្ទាល់នៃបទល្មើស"។ លក្ខណៈវិនិច្ឆ័យ"ផលវិបាកផ្ទាល់នៃបទល្មើស"ហាក់ដូចជាត្រូវបានគាំទ្រដោយចៅក្រម G.M Pikis នៅក្នុង"សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង I ស្តីពីការចូលរួមរបស់ជនរងគ្រោះ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨" "មតិជំទាស់ដោយផ្នែករបស់ចៅក្រម G.M Pikis", ទំព័រ ៣៧ ដល់ ៣៨, កថាខណ្ឌ ៣ ("ត្រូវតែមានការទាក់ទងផ្ទាល់រវាងបទល្មើស និងព្យសនកម្ម ក្នុងន័យហេតុ និងផល។ ព្យសនកម្ម ផ្លូវចិត្តអាចត្រូវបានទទួលរងយ៉ាងច្បាស់លាស់ ដោយគ្មានព្យសនកម្មផ្នែករាងកាយមុននេះទេ ប៉ុន្តែ បទល្មើសនោះ ត្រូវតែជាមូលហេតុដែលបង្កឱ្យមានព្យសនកម្ម នៅពេលដែលអាចជាករណីបំផ្លិចបំផ្លាញ ការរំលោភបំពាន ឬការធ្វើឱ្យខូចកិត្តិយសរបស់អ្នកដែលនៅក្បែរ និងជាទីស្រលាញ់របស់ជនរងគ្រោះ"។ វាមិនច្បាស់លាស់ទេថា ចៅក្រមភាគច្រើននៃអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICC មិនយល់ស្របថា "បទល្មើសនោះត្រូវតែជាមូលហេតុដែលបង្កឱ្យមានព្យសនកម្ម"។ នៅក្នុងករណីណាក៏ដោយ នៅ អ.វ.ត.ក ព្យសនកម្មដែលជនរងគ្រោះផ្ទាល់ ឬដោយប្រយោលបានទទួលរងដូចគ្នា ត្រូវតែជាព្យសនកម្ម "ផ្ទាល់" ក្នុងន័យហេតុ និងផល និងផ្ទាល់ខ្លួន។ នៅតុលាការពិសេសសម្រាប់ប្រទេស លីបង់ ("តុលាការ STL") ជនរងគ្រោះ ត្រូវបានកំណត់និយមន័យថាជា "រូបវន្តបុគ្គលដែលបានទទួលរងព្យសនកម្មរាងកាយ សម្ភារៈ ឬផ្លូវចិត្តដែលជា លទ្ធផលផ្ទាល់នៃការវាយប្រហារដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ" (គូសបញ្ជាក់បន្ថែម)។ "ជនរងគ្រោះដែលចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី"ត្រូវបានកំណត់និយមន័យថាជា "ជនរងគ្រោះនៃការវាយប្រហារ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការដែលត្រូវបានយល់ព្រម

អង្គការសហប្រជាជាតិស្តីពីការផ្តល់សំណង អាចជាគំរូនៃបទដ្ឋានអន្តរជាតិ ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការកំណត់និយមន័យនៃជនរងគ្រោះដែលមានចែងក្នុងនោះ មានការពាក់ព័ន្ធទៅនឹងគោលបំណងនៃឯកសារ *ក្នុងន័យទូលាយ* *(sensu largo)*។ គោលបំណងនេះ បានកំណត់អំពីកាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់ដំណោះស្រាយ និងសំណងទៅដល់ជនរងគ្រោះ ជាជាងអំពីទម្រង់ជាក់លាក់នៃការចូលរួមរបស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ បន្ថែមពីលើនេះ គោលការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានដំណោះស្រាយ បានអនុញ្ញាត

---

អនុញ្ញាតដោយចៅក្រមអង្គបុរេជំនុំជម្រះ ដើម្បីបង្ហាញពីទស្សនៈ និងការព្រួយបារម្ភ របស់ខ្លួននៅដំណាក់កាលមួយ ឬច្រើននៃកិច្ចដំណើរការនីតិវិធី បន្ទាប់ពីដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានបញ្ជាក់អះអាង”។ (វិធាន ២(ក) នៃវិធានស្តីពីនីតិវិធី និងភស្តុតាង (អនុម័តថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០))។ ហេតុដូច្នេះ នីតិបុគ្គល និងអ្នកទាំងឡាយណាដែលអាចទទួលរងនូវព្យសនកម្មដោយប្រយោលមិនទទួលនូវឋានៈ ជា“ជនរងគ្រោះ”នៅចំពោះមុខតុលាការពិសេសសម្រាប់ប្រទេសលីបង់ទេ។ ភាពខុសគ្នាផ្សេងទៀតរវាង អ.វ.ត.ក និងតុលាការ ICC ទាក់ទងនឹងបញ្ហានៃសិទ្ធិវ័ន្ត។ យុត្តិសាស្ត្ររបស់តុលាការ ICC បានបដិសេធចោលអំណះអំណាងរបស់ជនរងគ្រោះដោយផ្អែកលើសិទ្ធិវ័ន្ត ដោយយុត្តិសាស្ត្រនេះអនុញ្ញាតឲ្យលើកអំណះអំណាងផ្អែកលើសិទ្ធិផ្ទាល់របស់ជនរងគ្រោះ។ *សូមមើល ឧទា. ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ,* សំណុំរឿងលេខ ICC-01/04-423-Corr-tENG, “ការកែតម្រូវចំពោះ “សេចក្តីសម្រេចលើពាក្យសុំចូលរួមដែលបានដាក់ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរនៅក្នុងសាធារណរដ្ឋប្រជាមានិតកុងហ្គោចាប់ពីលេខa/0004/06 ដល់ a/0009/06, a/0016/06 ដល់ a/0063/06, a/0071/06 ដល់ a/0080/06 និង a/0105/06 ដល់ a/0110/06, a/0188/06, a/0128/06 ដល់ a/0162/06, a/0199/06, a/0203/06, a/0209/06, a/0214/06, a/0220/06 ដល់ a/0222/06, a/0224/06, a/0227/06 ដល់ a/0230/06, a/0234/06 ដល់ a/0236/06, a/0240/06, a/0225/06, a/0226/06, a/0231/06 ដល់ a/0233/06, a/0237/06 ដល់ a/0239/06 and a/0241/06 ដល់ a/0250/06”,អង្គបុរេជំនុំជម្រះ (ចៅក្រមតែម្នាក់), ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨, កថាខណ្ឌ ២៣ ដល់ ២៥។ *ស្ថានភាពនៅក្នុងរឿងក្តី Darfur* ប្រទេសស៊ូដង់, សំណុំរឿងលេខ ICC-02/05-111-Corr “ការកែតម្រូវចំពោះសេចក្តីសម្រេចលើពាក្យសុំចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់អ្នកដាក់ពាក្យសុំលេខ a/0011/06 ដល់ a/0015/06, a/0021/07, a/0023/07 ដល់ a/0033/07 និង a/0035/07 ដល់ a/0038/07”, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ៣៥។ ផ្ទុយទៅវិញ ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក បានអនុញ្ញាតយ៉ាងច្បាស់លាស់ឲ្យសិទ្ធិវ័ន្តរបស់ជនរងគ្រោះ ដាក់ពាក្យបណ្តឹងក្នុងនាមជនរងគ្រោះ។ មាត្រា ១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ (“ក្នុងករណីមរណភាពនៃជនរងគ្រោះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានផ្តើមធ្វើ ឬបន្តបានដោយសិទ្ធិវ័ន្ត”)។

យ៉ាងច្បាស់លាស់ឱ្យច្បាប់ជាតិ[868]ធ្វើការកំណត់វិសាលភាពនៃជនរងគ្រោះមិនផ្ទាល់។ ឯកសាររបស់អង្គការសហប្រជាជាតិកាលពីដំបូង ដែលមានការពាក់ព័ន្ធដោយផ្ទាល់ជាងនេះទៅនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺជាសេចក្តីប្រកាសអំពីគោលការណ៍ជាមូលដ្ឋាននៃភាពយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច[869]។ សេចក្តីប្រកាសនេះក៏មានការកំណត់ពាក្យពេចន៍ដែលពាក់ព័ន្ធនឹងជនរងគ្រោះដែលមិនផ្ទាល់ផងដែរ[870]ថា ទីបំផុតសេចក្តីសម្រេចស្តីពីវិសាលភាពនៃជនរងគ្រោះ មិនផ្ទាល់ស្ថិតនៅក្រោមការកំណត់របស់ច្បាប់ជាតិ។

៤១៤. ហេតុដូច្នេះ មិនអាចលើកឡើងបានថា វិធាន ២៣(២) នៃវិធានផ្ទៃក្នុង និងមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានរំលោភលើបទដ្ឋានអន្តរជាតិឡើយ។ ហេតុដូច្នេះ បទប្បញ្ញត្តិទាំងនេះ នៅតែជាបទប្បញ្ញត្តិមានន័យគ្រប់គ្រងលើវិសាលភាពនៃពាក្យ "ដើមបណ្តឹង

[868] "*សម្រាប់គោលបំណងនៃឯកសារបច្ចុប្បន្ន*ជនរងគ្រោះទាំងឡាយ គឺជាជនដែលទទួលរងព្យសនកម្មដោយឡែក ឬព្យសនកម្មរួម ដោយរួមបញ្ចូលទាំងព្យសនកម្មផ្នែករាងកាយឬផ្លូវចិត្តការឈឺចាប់ផ្លូវអារម្មណ៍ការបាត់បង់ផ្នែកសេដ្ឋកិច្ច ឬការខូចខាតសំខាន់នៃសិទ្ធិជាមូលដ្ឋាននានារបស់ខ្លួន (...)។ *តាមករណីសមស្រប* ពាក្យថា "ជនរងគ្រោះ" ក៏រួមទាំងសមាជិកគ្រួសារផ្ទាល់ ឬអ្នកស្ថិតនៅក្នុងបន្ទុករបស់ជនរងគ្រោះដោយផ្ទាល់ ព្រមទាំងបុគ្គលទាំងឡាយដែលទទួលរងនូវព្យសនកម្មនៅក្នុងការធ្វើអន្តរាគមន៍ជួយជនរងគ្រោះពីទុក្ខភ័យ ឬការពារកុំឱ្យរងគ្រោះផងដែរ"។ កថាខណ្ឌ ៨ (សេចក្តីបញ្ជាក់បន្ថែម)។

[869] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 40/34, កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ (UN GAOR), សម័យប្រជុំលើកទី ៤០, ឯកសារអង្គការសហប្រជាជាតិលេខ A/RES/40/34 (ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥) (សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តធម៌សម្រាប់ជនរងគ្រោះ)។

[870] "ជនរងគ្រោះ" មានន័យថា ជាបុគ្គលទាំងឡាយដែលបានទទួលរងនូវព្យសនកម្មដោយឡែកឬជារួម ដោយរួមបញ្ចូលទាំងការខូចខាតផ្នែករាងកាយ ឬផ្លូវចិត្តការឈឺចាប់ផ្លូវអារម្មណ៍ការបាត់បង់ផ្នែកសេដ្ឋកិច្ចឬ ការខូចខាតសំខាន់នៃសិទ្ធិនានាជាមូលដ្ឋានរបស់ខ្លួនតាមរយៈអំពើសកម្ម ឬអកម្ម ដែលបំពារបំពានលើច្បាប់ព្រហ្មទណ្ឌ ដែលអនុវត្តនៅក្នុងរដ្ឋជាសមាជិក (...)។ *តាមករណីសមស្រប*ពាក្យថា "ជនរងគ្រោះ" ក៏រួមបញ្ចូលទាំងក្រុមគ្រួសារផ្ទាល់ ឬអ្នកស្ថិតនៅក្នុងបន្ទុករបស់ជនរងគ្រោះដោយផ្ទាល់ និងបុគ្គលទាំងឡាយដែលបានទទួលរងនូវព្យសនកម្មនៅក្នុងការធ្វើអន្តរាគមន៍ជួយជនរងគ្រោះពីទុក្ខភ័យ ឬការពារកុំឱ្យរងគ្រោះផងដែរ" សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ, ថាខណ្ឌ ១ ដល់ ២ (សេចក្តីបញ្ជាក់បន្ថែម)។

រដ្ឋប្បវេណី" នៅ អ.វ.ត.ក ហើយ យោងលើបទដ្ឋានអន្តរជាតិ ពុំមានមូលដ្ឋានណាមួយដែលចង្អុលបង្ហាញឱ្យធ្វើការកំណត់និយមន័យឡើងវិញនូវពាក្យនេះឡើយ។ ហេតុនេះ សញ្ញាណនៃដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែធ្វើការបកស្រាយដោយយោងលើនីតិវិធីកម្ពុជា និងបកស្រាយតែក្នុងករណីដែលនីតិវិធីនេះមិនឆ្លើយតប នៅក្នុងផ្នែកដែលពាក់ព័ន្ធប៉ុណ្ណោះ ទើប"ត្រូវធ្វើការស្វែងរកការណែនាំនៅក្នុងនីតិវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ"[871]។

៤១៥. យោងតាមការកំណត់និយមន័យជាក់លាក់នៃដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ព្យសនកម្មដែលកើតចេញមកពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ គឺជាលក្ខណៈវិនិច្ឆ័យដែលកំណត់ន័យ និងដាក់កំហិតតែមួយគត់សម្រាប់ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ពាក្យ "ព្យសនកម្ម" ចង្អុលបង្ហាញនូវការឈឺចាប់ ការខូចខាត ឬ ការអន្តរាយ ដែលកើតឡើងតាមរយៈការបាត់បង់ ឬការបំផ្លិចបំផ្លាញ[872]។ វិធាន ២៣(២) នៃវិធានផ្ទៃក្នុង ចែងថា ព្យសនកម្ម

[871]មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[872]អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅ អ.វ.ត.ក និងនៅក្នុងយុត្តិសាស្ត្រអន្តរជាតិពាក្យ"ព្យសនកម្ម" ត្រូវបានប្រើប្រាស់ផ្លាស់ប្តូរគ្នាបានជាមួយនឹងពាក្យ "ការខូចខាត"។ នៅក្នុងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៅក្នុងសំណុំរឿង ០០២ ដែលបានចេញនៅខែ សីហា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានប្រើពាក្យ "ការខូចខាត" និង "ព្យសនកម្ម" ផ្លាស់ប្តូរគ្នាបាន។ *សូមមើល ឧទា.* ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្នុងក្រុងកែប ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D392។ *សូមមើលផងដែរ* ដីកាសម្រេចលេខ D393, D394, D395, D396, D397, D398, D399, D401, D403, D404, D406, D408, D409, D410, D411, D414, D415, D416, D417, D418, D419, D423, D424, D426( ជារួមហៅថា "ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការទទួលយកនៅក្នុងសំណុំរឿង ០០២")។ នៅអង្គបុរេជំនុំជម្រះរបស់ អ.វ.ត.កបាន ប្រើប្រាស់ពាក្យទាំងនេះស្រដៀងគ្នាដែរ នៅក្នុងសំណុំរឿង ០០២។ *សូមមើល ឧទា.* សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារលេខ D404/2/4, ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារលេខ D411/3/6 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ (ជារួមហៅថា "សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាន")។ នៅតុលាការឧក្រិដ្ឋកម្មអន្តរ

ត្រូវតែជា "ការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត" និងត្រូវតែ "កើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន"[873]។ ការខូចខាតខាងរាងកាយមានន័យថាជាការខូចខាតខាងជីវសាស្ត្រខាងសរីរាង្គ ឬខាងប្រព័ន្ធដំណើរការនៃសរីរាង្គ។ ការខូចខាតខាងរូបកាយនេះអាចជារបួសស្នាម កាយវិកលកម្ម ការខូចទ្រង់ទ្រាយ មានជំងឺ ការបាត់បង់ ឬ ការមិនដំណើរការនៃសរីរាង្គណាមួយ ឬ មរណភាព។ ព្យសនកម្មខាងសម្ភារៈ សំដៅដល់ការបាត់បង់តម្លៃជាវត្ថុរូបិយ ដូចជា ការខូចខាតទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងស្រុង ឬ មួយផ្នែក ឬ ការបាត់បង់ប្រាក់ចំណូលជាដើម។ ជាចុងក្រោយ ដូចអង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់បានគ្រប់គ្រាន់រួចមកហើយថា ព្យសនកម្ម"អាចជាការខូចខាតខាងផ្លូវចិត្ត ហើយរួមបញ្ចូលទាំងជំងឺផ្លូវចិត្ត ឬវិកលចរិត ដូចជា ជំងឺបាក់ស្បាត"[874]។

៤១៦. ព្យសនកម្មដែលអាចកើតឡើងជាយថាហេតុ ឬអាចមានរូបភាពពិតប្រាកដ នៅពេលដែលមានការរំលោភសិទ្ធិកើតឡើង។ ប៉ុន្តែមិនមែនរាល់ការរំលោភសិទ្ធិទាំងអស់ជានិច្ចកាលត្រូវបានសន្មតទុកជាមុនថា មានព្យសនកម្ម ឬសុទ្ធតែបង្កឱ្យមានព្យសនកម្មនោះទេ។ អនុលោមតាមលក្ខណៈវិនិច្ឆ័យលើព្យសនកម្ម ពាក្យថា "ដើមបណ្តឹងរដ្ឋប្បវេណី" ជាធម្មតារួមបញ្ចូលនូវ

---

ជាតិ ("ICC") ពាក្យថា "ការខូចខាត" និង"ព្យសនកម្ម" ត្រូវបានប្រើប្រាស់ទាំងនៅក្នុងវិធាននីតិវិធី និងភស្តុតាង និងលក្ខន្តិកៈទីក្រុងរ៉ូម (វិធាន ៨៥, ៨៤, ៩៧, ១៤៥(គ) និង ២១៨) និងមាត្រា ៦ ដល់ ៨, ៧៥ នៃលក្ខន្តិកៈរបស់តុលាការ ICC។ នៅក្នុង*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Lubanga*, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC ដោយយោងលើវចនានុក្រមច្បាប់ Black's Law និងវចនានុក្រមភាសាអង់គ្លេស Oxford បានពន្យល់ថា៖"ពាក្យ"ព្យសនកម្ម"ក្នុងន័យធម្មតាសំដៅលើការឈឺចាប់ ការខូចខាត និងការខូចប្រយោជន៍។ ពាក្យព្យសនកម្មមានន័យដូចគ្នានៅក្នុងអត្ថបទគតិយុត្តិដែលមានន័យជាការខូចខាត ការបាត់បង់ ឬការខូចប្រយោជន៍ និងជាអត្ថន័យនៃ "ព្យសនកម្ម" នៅក្នុងវិធាន ៨៥(ក)។ "សាលដីកាលើបណ្តឹងឧទ្ធរណ៍នានារបស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I លើការចូលរួមរបស់ជនរងគ្រោះ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨", កថាខណ្ឌ ៣១។ ដើម្បីមានភាពងាយស្រួលសម្រាប់ការយោង និងដោយសារតែតុលាការកំពូលរកឃើញថាគ្មានភាពខុសគ្នានៅក្នុងអត្ថន័យនៃពាក្យ "ព្យសនកម្ម" និង "ការខូចខាត" ទេនោះ ដូចនេះវាមិនមានការកែប្រែការជ្រើសរើសភាសានៅក្នុងសាលក្រមនោះទេ។

[873] វិធាន ២៣(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣)។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ១៣ ("ការខូចខាតអាចជាការខូចខាតចំពោះទ្រព្យសម្បត្តិ ឬរាងកាយ ឬការខូចខាតផ្លូវចិត្ត")។

[874] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤១, ជើងទំព័រ ១០៧៣។

00798644



ពាក្យដែលត្រូវបានសម្គាល់ជាទូទៅ ដោយពាក្យ“ជនរងគ្រោះ” ពោលគឺ បុគ្គលណាមួយដែលសិទ្ធិទាំងឡាយរបស់ខ្លួនទទួលរងដោយអំពើព្រហ្មទណ្ឌ ដែលជាអំពើមួយត្រូវបានចោទប្រកាន់ថា “បានប្រព្រឹត្តមកលើខ្លួន”។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីឱ្យទទួលបានឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវច្បាប់ ជាការចាំបាច់ណាស់ដែលបុគ្គលនេះ បានទទួលរងព្យសនកម្ម[875]។ ដើម្បីឱ្យមានភាពច្បាស់លាស់ អង្គជំនុំជម្រះតុលាការកំពូលនឹងប្រើប្រាស់ពាក្យ“ជនរងគ្រោះផ្ទាល់”សម្រាប់ក្រុមបុគ្គលណា ដែលសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន ឬទទួលរងការប៉ះពាល់ដែលបណ្ដាលមកពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ ពាក្យនេះមានលក្ខណៈដាច់ដោយឡែកពីក្រុមបុគ្គលដែលទទួលរងព្យសនកម្ម ដែលជា“ផលវិបាកដោយផ្ទាល់” ពីអំពើព្រហ្មទណ្ឌនោះ[876] ។ នៅក្នុងរឿងក្ដីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល

---

[875]ដើម្បីបង្ហាញចំណុចសំខាន់នៃព្យសនកម្មចំពោះទស្សនាទានដើមបណ្ដឹងរដ្ឋប្បវេណី ចូរយើងប្រើប្រាស់ឧទាហរណ៍នៃអំពើគាស់ទម្លុះផ្ទះ ដែលបានប្រព្រឹត្តលើគ្រួសារ NN នៅពេលគ្រួសារនេះលំហែវិស្សមកាល។ ចោរគាស់ផ្ទះត្រូវបានចាប់ខ្លួនភ្លាមៗបន្ទាប់ពីរកឃើញប័ណ្ណកម្មសិទ្ធអចលទ្រព្យនិងទ្រព្យដែលបានលួចទៅនោះមកវិញ។ កម្មសិទ្ធិករនៃទ្រព្យទាំងនេះបានដឹងអំពីអំពើគាស់ទម្លុះផ្ទះក្រោយពីខ្លួនបានវិលត្រឡប់មកវិញបន្ទាប់ពីវិស្សមកាល។ ទោះបីជា NN ជាជនរងគ្រោះដោយផ្ទាល់នៃបទល្មើសគាស់ទម្លុះផ្ទះនេះក៏ដោយក៏ NN មិនបានទទួលរងនូវព្យសនកម្ម ហើយឋានៈក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី គឺមិនទំនងជាអាចទទួលបានឡើយ។ ដូចគ្នានេះដែរ បើតាមសម្មតិកម្ម ជនដែលត្រូវបានខ្មែរក្រហមចាប់ខ្លួនតាមអំពើចិត្ត អាចជាជនរងគ្រោះនៃការចាប់ខ្លួន ប៉ុន្តែ ប្រសិនបើជនរងគ្រោះបានចូលរួមភ្លាមៗជាមួយនឹងរបបដែលមានការគាបសង្កត់ (*ឧទា.* នៅពេលសួរចម្លើយដំបូង) ជនរងគ្រោះនេះអាចគេចផុតពីការទទួលរងព្យសនកម្មបាន ហេតុដូច្នេះបុគ្គលនេះពិតជាពិបាក ក្នុងការបង្ហាញនូវការអះអាងថា ខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីឡើយ។ *សូមមើលផងដែរ* គណៈកម្មាធិការអន្តរជាតិស្ដីពីសំណងសម្រាប់ជនរងគ្រោះនៃជម្លោះប្រដាប់អាវុធ របាយការណ៍កិច្ចប្រជុំនៅទីក្រុងឡាអេ (Hague)(ឆ្នាំ ២០១០) (“សេចក្ដីព្រាងសេចក្ដីប្រកាសរបស់គោលការណ៍ច្បាប់អន្តរជាតិ ស្ដីពីសំណងសម្រាប់ជនរងគ្រោះនៃជម្លោះប្រដាប់អាវុធ (បញ្ហាសំខាន់)”, ទំព័រ ៩ ដល់ ១០ (“ការទទួលស្គាល់“ការខូចខាតសំខាន់នៃសិទ្ធិនានាជាមូលដ្ឋាន” ថា ជាហានីយភ័យនៃការខូចខាតបានរាប់បញ្ចូលបញ្ហា ថាតើការរំលោភបំពានច្បាប់ បានកើតឡើងដោយមានបញ្ហាថាតើបានបង្កព្យសនកម្ម ដែរ ឬយ៉ាងណា (...) ព្យសនកម្មអាចទទួលរងមិនត្រឹមតែបុគ្គលដែលត្រូវបានរំលោភបំពានលើសិទ្ធិរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែ តតិយជនទទួលរងព្យសកម្ម” <http://www.ila-hq.org/en/committees/index.cfm/cid/1018>។

[876]អង្គជំនុំជម្រះសាលាដំបូង និងសហចៅក្រមស៊ើបអង្កេតសំដៅលើជនរងគ្រោះដោយផ្ទាល់ថា ជាជនរងគ្រោះ។ *សូមមើលឧទា.*សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៣ ដល់ ៦៤៤, ៦៤៨ ដល់ ៦៥០, ៦៦៧។ ដីកាសម្រេចស្ដី

ជនរងគ្រោះផ្ទាល់ គឺមិនតិចជាង ១២.២៧៣ នាក់នោះទេ ដែលជាអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ដែលទទួលរងការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និង ជាច្រើនករណី[877] ការធ្វើមនុស្សឃាត។ មានជនរងគ្រោះដោយផ្ទាល់មួយចំនួនតូចតែប៉ុណ្ណោះដែលនៅរស់រានមានជីវិតរហូតមកទល់សព្វថ្ងៃនេះ។

៤១៧. បញ្ហាចោទមួយទៀតនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺថាតើចរិតលក្ខណៈនានានៃ "ព្យសនកម្ម" ដូចដែលបានគូសបញ្ជាក់ខាងលើ គ្របដណ្តប់លើព្យសនកម្មរបស់បុគ្គលណាមួយ ក្រៅពីជនរងគ្រោះដោយផ្ទាល់ ដែរ ឬយ៉ាងណា។ យោងតាមនិយមន័យសំខាន់នៃពាក្យដើមបណ្តឹងរដ្ឋប្បវេណី *ជនរងគ្រោះមិនផ្ទាល់*ចាំបាច់ត្រូវតែទទួលរងនូវព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើជនរងគ្រោះផ្ទាល់(ទាំងនោះ)។ ជនរងគ្រោះមិនផ្ទាល់ទាំងនោះ រួមបញ្ចូលទាំងជនទាំងឡាយណាដែលពិតជាបានទទួលរងព្យសនកម្មខាងផ្លូវចិត្ត ឧទាហរណ៍ ដោយសារលទ្ធផលនៃព្យសនកម្មដែលកើតមានចំពោះអ្នកជាទីស្រលាញ់របស់ខ្លួន ទោះបីជាអចិន្ត្រៃយ៍ ឬមួយរយៈពេលខ្លីក៏ដោយ។ ព្យសនកម្មខាងផ្លូវចិត្តកើតចេញពីភាពពុំប្រាកដប្រជា និងភាពភ័យខ្លាចអំពីជោគវាសនារបស់ជនរងគ្រោះផ្ទាល់ ការដឹងអំពីការឈឺចាប់របស់ជនរងគ្រោះទាំងនោះ[878] ឬការមានអារម្មណ៍ភ័យខ្លាចអំពីសុវត្ថិភាព និងបូរណភាពខាងផ្លូវចិត្ត[879]។ នៅក្នុងករណីធ្ងន់ធ្ងរ ឬអូសបន្លាយព្យសនកម្មខាងផ្លូវចិត្តអាច

ពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្នុងខេត្តរតនគិរី ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ D394។

[877]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៣៤០, ជើងទំព័រ ៦១៨។

[878]នៅក្នុងកិច្ចសវនាការ អ្នកជំនាញ ឈឹម សុធារ៉ា រៀបរាប់លម្អិតអំពីផលវិបាកនៃស្ថានភាពផ្លូវចិត្ត និងរូបរាងកាយរបស់សមាជិកគ្រួសាររបស់ជនរងគ្រោះដោយផ្ទាល់នៅមន្ទីរ ស ២១ និងលក្ខណៈនៃការបាក់ស្បាត ដែលកើតចេញពីការដឹងឮអំពីមរណភាពនៃសាច់ញាតិនៅទីនោះ រួមទាំង នៅក្នុងចំណោមនោះគឺ ការរកឃើញនូវការឈឺចាប់របស់ជនរងគ្រោះ ពិរុទ្ធភាព ភាពគ្មានទីពឹង និងស្ថានភាពផ្លូវចិត្ត ដូចជា ជំងឺបាក់ស្បាត។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៧៣។

[879]ជនរងគ្រោះដោយប្រយោលនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដូចជា មរណភាព ឬ ការធ្វើទារុណកម្ម អាចទទួលរងពីជំងឺ "បាក់ស្បាត" ឬ "នៅឯកោ"។ ផលវិបាកក្នុងរយៈពេលយូរនឹងរួមមានអារម្មណ៍ថាខ្លួនខុស ភាពគ្មានទីពឹង ការផ្ទេរការទម្លាក់កំហុស ដែលនាំឱ្យមានការបាក់បែកទំនាក់ទំនងគ្រួសារ និងការរុកគួនរំខាន ដែលធ្វើឱ្យជនរងគ្រោះពុំមានលទ្ធភាព

បណ្តាលឱ្យមានព្យសនកម្មខាងរាងកាយដោយបង្កជាជំងឺដង្កាត់ផ្សេងៗ។ ព្យសនកម្មខាងផ្លូវចិត្ត និងខាងរូបកាយអាចទទួលរងដោយជនងាយរងគ្រោះ ដូចជា ទារក កុមារ មនុស្សចាស់ និងអ្នកជំងឺ ដោយសារតែការបាត់បង់អ្នកបីបាច់ថែរក្សារបស់ខ្លួន។ ព្យសនកម្មខាងសម្ភារៈអាចធ្លាក់ទៅលើជនទាំងឡាយដែលជនរងគ្រោះដោយផ្ទាល់ បានផ្ទេរទៅឱ្យនៅពេលទទួលរងគ្រោះ ឬនឹងអាចផ្ទេរទៅឱ្យនាពេលអនាគត ដូចជានៅក្នុងទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។ ព្យសនកម្មខាងសម្ភារៈអាចត្រូវបានបង្កឡើង ឬអាចជាផលវិបាកខាងសម្ភារៈដោយសារការធ្វើឱ្យខូចខាតដល់បេតិកភណ្ឌរបស់គ្រួសារ[880]។ ជាយថាហេតុ ព្យសនកម្មខាង

---

បង្កើតទំនាក់ទំនងផ្លូវអារម្មណ៍ជាមួយនឹងជនដទៃ។ *សូមមើលរឿងក្តី* Paniagua Morales *និងជនដទៃទៀត ទល់នឹង* *Guatemala (“រឿងក្តី the white van”),* សាលក្រមរបស់តុលាការ IACtHR, (សំណង និងសោហ៊ុយ) ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៦៦ (មានការរៀបរាប់ពន្យល់អំពីការខូចខាតខាងផ្លូវចិត្ត)។ *នៅក្នុងរឿងក្តី* Caracazo *ទល់នឹង* Venezuela, តុលាការ IACtHR បានបញ្ជាក់ថា ការខូចខាតខាងផ្លូវចិត្តអាចរួមបញ្ចូលទាំង “ការខូចខាតដល់គម្រោងរស់នៅរបស់ជនរងគ្រោះដោយសារការរំលោភបំពានលើសិទ្ធិទទួលបានការព្យាបាលបែបមនុស្សធម៌ ដរាបណារបួសដែលបានទទួលនេះ បានបង្កើតជាឧបសគ្គរាំងមិនឲ្យទទួលបានការងាររបស់ខ្លួន (...)”។ *រឿងក្តី* Caracazo *ទល់នឹង វេណេស៊ុយអេឡា*, តុលាការ IACtHR, សាលក្រមស្តី(សំណង និងសោហ៊ុយ), ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០២, កថាខណ្ឌ ៩៧(ខ)។ នៅក្នុងការវាយតម្លៃលើវិសាលភាពនៃផលប៉ះពាល់ខាងផ្លូវចិត្តដោយសារតែកូនរបស់ខ្លួនទទួលមរណភាព តុលាការកំពូលរបស់ប្រទេសកាណាដា បានលើកឡើងថា តុលាការគួរពិចារណាលើកត្តាដូចតទៅ “*នៅក្នុងនោះរួមមាន៖* កាលៈទេសៈនៃមរណភាព វ័យរបស់អ្នកស្លាប់ និងឪពុក ឬ ម្តាយ លក្ខណៈ និងតម្លៃនៃទំនាក់ទំនងរវាងសព និងឪពុក ឬ ម្តាយ បុគ្គលិកលក្ខណៈ និងលទ្ធភាពរបស់ឪពុក ឬ ម្តាយ ក្នុងការគ្រប់គ្រងលើផលវិបាក ផ្នែកអារម្មណ៍របស់សព និងផលប៉ះពាល់នៃមរណភាពមកលើជីវិតឪពុក ម្តាយ *ក្នុងនោះគឺ* ពេលមានកូនផ្សេងទៀត ឬលទ្ធភាពដែលអាចមានកូនផ្សេងទៀត”។ *រឿងក្តី* Augustus *ទល់នឹង* Gosset (ឆ្នាំ ១៩៩៦) វ៉ុល ៣ នៃកំណត់ហេតុក្រុមប្រឹក្សាសន្តិសុខ ទំព័រ ២៦៨ (3 S.C.R. 268), កថាខណ្ឌ ៥០។ *សូមមើលផងដែរ រឿងក្តី* Çakici *ទល់នឹង ប្រទេសទួគី,* ECtHR, សេចក្តីសម្រេចដ៏ប្រណិតរបស់អង្គជំនុំជម្រះ, បណ្តឹងលេខ 23657/94, ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៩៨ (ដែលពិភាក្សាលើភាពធ្ងន់ធ្ងរនៃការខូចខាតខាងផ្លូវចិត្ត៖ “ធាតុផ្សំពាក់ព័ន្ធផ្សេងទៀតនឹងរួមបញ្ចូលទាំងភាពជិតស្និទនៃទំនាក់ទំនងគ្រួសារ នៅក្នុងបរិបទនេះគឺ ទម្ងន់មួយចំនួននឹងភ្ជាប់ទៅនឹងទំនាក់ទំនងរវាងឪពុក ឬ ម្តាយ និងកូន ជាពិសេស កាលៈទេសៈនៃទំនាក់ទំនង ដែលសមាជិកគ្រួសារបានឃើញហេតុការណ៍ដែលបានកើតឡើង ការចូលរួមរបស់សមាជិក គ្រួសារនៅក្នុងការព្យាយាមទទួលព័ត៌មានអំពីអ្នក ដែលបានបាត់ខ្លួន និងមធ្យោបាយដែលអាជ្ញាធរឆ្លើយតបទៅនឹងសំណួរទាំងនោះ”។

[880] ជនរងគ្រោះនៅចំពោះមុខតុលាការអាមេរិកស្តីពីសិទ្ធិមនុស្ស (“តុលាការ IACtHR”) អាចទាមទារសំណងជាថវិកាចំពោះការខូចខាតលើបេតិកភណ្ឌរបស់គ្រួសារ ការបាត់បង់ទ្រព្យសម្បត្តិដែលរកបាន និងផលវិបាកកើតចេញពីការខូចខាត

សម្ភារៈ អាចមានប្រភពនៅក្នុងបណ្ដឹងទាមទាររបស់ជនរងគ្រោះផ្ទាល់ដោយផ្អែកលើច្បាប់ ឬដោយផ្អែកលើកិច្ចសន្យា ដែលឧក្រិដ្ឋកម្មនេះបានរារាំងដល់ការអនុវត្ត។ ដូចនេះ អត្ថន័យនៃពាក្យ"ព្យសនកម្ម" យោងតាមមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ នៅក្នុងបរិបទនៃជនរងគ្រោះមិនផ្ទាល់ គឺត្រូវស្ថិតនៅក្នុងសេណារីយ៉ូជាច្រើន ដែលពាក់ព័ន្ធនឹងប្រភេទនៃបុគ្គលជាច្រើន។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពជាក់ស្ដែងនីមួយៗនៃព្យសនកម្មត្រូវតែបង្ហាញទៅតាមករណីជាក់លាក់នីមួយៗ។

៤១៨. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា លក្ខខណ្ឌតម្រូវនៃព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃបទល្មើស នៅក្នុងវិធាន ២៣(២)(ក)-(ខ) នៃវិធានផ្ទៃក្នុង ពុំបានដាក់កំហិតលើការទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីត្រឹមតែជនរងគ្រោះផ្ទាល់ប៉ុណ្ណោះនោះទេ ប៉ុន្តែ អាចរួមបញ្ចូលទាំងជនរងគ្រោះមិនផ្ទាល់ដែលទទួលរងដោយផ្ទាល់នូវព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តលើជនរងគ្រោះផ្ទាល់ផងដែរ។ ក្នុងករណីពុំមានបទប្បញ្ញត្តិណាមួយដាក់កំហិតដូច្នេះ ប្រភេទនៃជនរងគ្រោះមិនផ្ទាល់ពុំត្រូវបានកំហិតត្រឹមតែប្រភេទបុគ្គលជាក់លាក់ទាំងឡាយ មានដូចជាសមាជិកក្រុមគ្រួសារនោះឡើយ[881]។ ប្រភេទនៃជនរងគ្រោះមិនផ្ទាល់ អាចរួមបញ្ចូលទាំងសហព័ន្ធនៅក្នុងប្រព័ន្ធអង្គការសាក់សុង ញាតិសាច់ឆ្ងាយ មិត្តភក្តិ ឪពុកម្ដាយធម៌ និងកូនធម៌*តាមព្រឹត្តិន័យ* ឬអត្ថាគាហកផ្សេងទៀត នៅពេលដែលអាចបង្ហាញថា ព្យសនកម្មបានកើតមានចំពោះខ្លួន។

---

ទាំងនេះ ដូចជា ការចំណាយលើពិធីបុណ្យសព និងការចំណាយលើការព្យាបាល។ *រឿងក្ដី Caracaza ទល់នឹង Venezuela*, សាលក្រមស្ដីពី (សំណង និងសោហ៊ុយ), កថាខណ្ឌ ៨០ ដល់ ៨៤។

[881]*សូមមើល* គណៈកម្មាធិការអន្តរជាតិស្ដីពីសំណងសម្រាប់ជនរងគ្រោះនៃជម្លោះប្រដាប់អាវុធ សមាគមនីតិអន្តរជាតិ របាយការណ៍ប្រជុំនៅទីក្រុងឡាអេ (Hague) (ឆ្នាំ ២០១០) "សេចក្ដីព្រាងសេចក្ដីប្រកាសគោលការណ៍នីតិអន្តរជាតិ ស្ដីពីសំណងសម្រាប់ជនរងគ្រោះនៃជម្លោះប្រដាប់អាវុធ (បញ្ហាសំខាន់), ទំព័រ ១០ ("គណៈកម្មាធិការយល់ឃើញថា មានតែការទទួលរងព្យសនកម្មប៉ុណ្ណោះ ដើម្បីអាចឲ្យតតិយជនមានឋានៈជាជនរងគ្រោះ")។ វាមិនមានមូលហេតុច្បាស់លាស់ដើម្បីដាក់កំហិតជាមុនដល់ក្រុមតតិយជននេះ មិនឲ្យចាត់ទុកជា "គ្រួសារផ្ទាល់" "អ្នកស្ថិតនៅក្នុងបន្ទុក" ឬ "បុគ្គលទាំងឡាយដែលទទួលរងព្យសនកម្ម ក្នុងការធ្វើអន្តរាគមន៍ជួយជនរងគ្រោះពីទុក្ខភ័យ ឬការពារកុំឲ្យរងគ្រោះ" ដូចមានចែងនៅក្នុងគោលការណ៍មូលដ្ឋាន")។

ផ្ទុយមកវិញ ជនទាំងឡាយដែលពុំអាចបង្ហាញថា ជនរងគ្រោះផ្ទាល់បានទទួលរងនូវព្យសនកម្មនោះទេ ជននោះពុំត្រូវបានចាត់ទុកថា ជាជនរងគ្រោះមិនផ្ទាល់នោះទេ។ (ផ្ទុយមកវិញ ជនទាំងឡាយដែលមិនបានទទួលរងព្យសនកម្ម ពុំត្រូវបានចាត់ទុកថាជាជនរងគ្រោះមិនផ្ទាល់នោះទេ ទោះបីជាជននោះជាសមាជិកសាច់ញាតិផ្ទាល់របស់ជនរងគ្រោះ ផ្ទាល់ក៏ដោយ (ក្នុងប្រព័ន្ធអង់គ្លូសាក់សុង)។ បន្ថែមលើសពីនេះ ការអនុវត្តសិទ្ធិរបស់ជនរងគ្រោះមិនផ្ទាល់ គឺមានលក្ខណៈឯករាជ្យពីសិទ្ធិរបស់ជនរងគ្រោះផ្ទាល់។ នេះមានន័យថា ជនរងគ្រោះមិនផ្ទាល់អាចទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ទោះបីជាក្នុងករណីដែលជនរងគ្រោះផ្ទាល់នៅរស់រានមានជីវិត ហើយមិនបានប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយខ្លួនឯងក៏ដោយ។

៤១៩. នៅក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ មានយន្តការចំនួនពីរដែលសមាជិកគ្រួសារនៃជនរងគ្រោះផ្ទាល់ អាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌបាន ពោលគឺ យោងតាមមាត្រា ១៣ នៃក្រមនេះ ការចូលរួមក្នុងនាមជាជនរងគ្រោះមិនផ្ទាល់ ដែលបានទទួលរងព្យសនកម្មផ្ទាល់ខ្លួន ដែលជាលទ្ធផលនៃព្យសនកម្មពីសមាជិកគ្រួសាររបស់ខ្លួន (ម៉្យាងវិញទៀត គឺ*ក្នុងនាមខ្លួនឯងផ្ទាល់)* ឬការចូលរួមក្នុងនាមជាសិទ្ធិវ័ន្តរបស់ជនរងគ្រោះផ្ទាល់ ដោយដាក់ ឬគាំទ្របណ្តឹងទាមទារ ក្នុងនាមជនរងគ្រោះដែលទទួលមរណភាព (ម៉្យាងវិញទៀត គឺ*ក្នុងនាមសិទ្ធិវ័ន្ត*) យោងតាមមាត្រា ១៦ នៃក្រមនេះដែលចែងថា “នៅក្នុងករណីមរណភាពរបស់ជនរងគ្រោះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានចាប់ផ្តើមធ្វើ ឬបន្តដោយសិទ្ធិវ័ន្ត”។

៤២០. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅក្នុងសេចក្តីសម្រេចពីមុនរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានយល់ឃើញថា ការធ្វើបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការព្រហ្មទណ្ឌ គឺជាសិទ្ធិពិសេសមួយដែលត្រូវ“បកស្រាយយ៉ាងតឹងរ៉ឹងនៅក្នុងព្រំដែនកំណត់ដោយច្បាប់”[882]។ ជាក់ស្តែង យោងតាមមាត្រា ១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧[883]

[882]សេចក្តីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៩, ឯកសារ E2/5/3 (“សេចក្តីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី”), កថាខណ្ឌ ៨។

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ដើម្បីទទួលបានសំណងផ្លូវចិត្ត សិទ្ធិវ័ន្តនៃជនរងគ្រោះដែលទទួលមរណភាព ដែលមានបំណងធ្វើបណ្តឹងទាមទារក្នុងនាមភាគីក្នុងរឿងក្តីនេះ ត្រូវបង្ហាញថា ខ្លួនបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ"[884]។ នៅពេលពុំមានភស្តុតាងបង្ហាញអំពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដាក់នៅមុនមរណភាពនៃជនរងគ្រោះដោយផ្ទាល់នោះទេ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា "សិទ្ធិវ័ន្តអាចត្រឹមតែស្វែងរកសំណងសម្រាប់ព្យសនកម្មផ្ទាល់ខ្លួន ដែលកើតចេញពីមរណភាពរបស់ជនរងគ្រោះប៉ុណ្ណោះ ហើយមរណភាពនេះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងបទល្មើសដែលជនជាប់ចោទត្រូវបានចោទប្រកាន់"[885]។

៤២១. ទោះបីជា ពុំមានបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការទទួលយកសិទ្ធិវ័ន្តរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលមរណភាពហើយក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មានការចាំបាច់ក្នុងការបំភ្លឺថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានកម្រិតវិសាលភាពនៃសិទ្ធិរបស់សិទ្ធិវ័ន្តស្របច្បាប់ត្រឹមតែករណីដែលជនរងគ្រោះ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់នៅមុនពេលមរណភាពនោះ សេចក្តីសម្រេចនេះ ពុំមានមូលដ្ឋាននៅក្នុងច្បាប់ជាធរមានឡើយ[886]។

---

[883]អង្គជំនុំជម្រះសាលាដំបូងយោងលើ"បទប្បញ្ញត្តិចុងក្រោយ" ហើយបទប្បញ្ញត្តិនេះត្រូវបានដកស្រង់ចេញពីចេញពីមាត្រា ១៦។ ដូច្នេះអាចសន្មតបានថា អង្គជំនុំជម្រះសាលាដំបូងមានបំណងយោងលើមាត្រា ១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។ សេចក្តីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១១។

[884]សេចក្តីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១១។

[885]សេចក្តីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១២។

[886]ចំពោះលទ្ធភាពដែលថា អង្គជំនុំជម្រះសាលាដំបូង "បានបង្កើតថ្មី" ស្របតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ផ្នែកខាងក្រោមនៃសាលដីកានេះ ត្រូវបានយកមកអនុវត្តដោយដាក់ជាចំណុចយោង។

## ៦.ក.៣.ការកំណត់និយមន័យឡើងវិញលើដើមបណ្ដឹងរដ្ឋប្បវេណី ឬការសន្មតទុកជាមុន

៤២២. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញបន្ថែមថា នៅក្នុងក្របខណ្ឌគតិយុត្តដែលផ្អែកតាមមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ និងវិធាន ២៣(២) នៃវិធានផ្ទៃក្នុង ពុំមានការបែងចែករវាងជនរងគ្រោះផ្ទាល់ និងជនរងគ្រោះមិនផ្ទាល់ឡើយ។ ក្នុងការអនុវត្តជាក់ស្ដែង ការសម្រេចលើបណ្ដឹងទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជាគោលការណ៍ គឺជាបញ្ហាភស្តុតាងដែលត្រូវសង្កត់ធ្ងន់លើអត្ថិភាពនៃព្យសនកម្មដោយផ្ទាល់ ដែលជាលទ្ធផលបណ្ដាលមកពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ ដូចបានបង្ហាញខាងលើ ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សមាជិកគ្រួសារផ្ទាល់ដែលស្ថិតនៅក្នុងវិសាលភាពនៃវិធាន ២៣(២)(ក)-(ខ) នៃវិធានផ្ទៃក្នុង គឺមានលក្ខណៈដាច់ខាតពេក បើប្រៀបធៀបទៅនឹងក្របខណ្ឌគតិយុត្តជាធរមាន។ សំអាងហេតុមិនគ្រប់គ្រាន់ដែលផ្ដល់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចសេចក្ដី ហាក់ដូចជាមានការបង្កើតសញ្ញាណថ្មីមួយដោយដាក់បញ្ចូលគ្នារវាងបញ្ហានិយមន័យនៃពាក្យព្យសនកម្ម ដែលជាមូលដ្ឋានសំខាន់ផ្លូវច្បាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងបញ្ហាភស្តុតាងដែលត្រូវបង្ហាញថា មានព្យសនកម្មផ្ទាល់។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងអាចប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចអំពីអង្គហេតុក៏ដោយ ក៏តុលាការនេះពុំមានឆន្ទានុសិទ្ធិក្នុងការកំណត់និយមន័យឡើងវិញចំពោះពាក្យពេចន៍ ដែលមានចែងនៅក្នុងច្បាប់ឡើយ។ ដូច្នេះ ភាពស្រពិចស្រពិលដែលមាននៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបង្កើតជាបញ្ហាចោទ ថាតើអង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកនិយមន័យបច្ចុប្បន្នស្ដីពីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងបរិបទ អ.វ.ត.ក. ថាមានលក្ខណៈមិនសមស្របដែរ ឬយ៉ាងណា ហើយក៏បានជ្រើសរើសយក "ការបង្កើតសញ្ញាណថ្មីមួយ" ដោយយោងតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ឬថា តើចេតនារបស់អង្គជំនុំជម្រះសាលាដំបូង គឺដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីការសន្មតទុកជាមុននូវអង្គហេតុ ដែរ ឬយ៉ាងណា។ ដោយពិចារណាឃើញថា បញ្ហានេះមិនត្រឹមតែជាបញ្ហាដែលកើតមាននៅក្នុងរឿងក្ដីបច្ចុប្បន្ននេះប៉ុណ្ណោះទេ តែហាក់បីដូចជាមានការជាប់ពាក់ព័ន្ធទៅនឹងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ផង

ដែរ[887]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាពីលទ្ធភាពនៃផលប៉ះពាល់នីមួយៗនេះ។

---

[887]ក្នុងសម្រេចតាមផ្លូវច្បាប់ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ជនរងគ្រោះនៅក្នុងសំណុំរឿងលេខ ០០២ សហចៅក្រមស៊ើបអង្កេតបង្កើតការសន្មតទុកជាមុនចំនួនពីរប្រភេទគឺ "ជាក់លាក់" និង "ពាក់ព័ន្ធ" ដោយពុំបានពន្យល់លើផលប៉ះពាល់តាមផ្លូវច្បាប់នៃភាពខុសគ្នារវាងប្រភេទទាំងពីរ ឬអំណាចក្នុងការបង្កើតការសន្មតទុកជាមុននេះឡើយ៖

ក. មានការសន្មតទុកជាមុននៃការខូចខាតខាងផ្លូវចិត្តចំពោះសមាជិកគ្រួសារបង្កើតរបស់ជនរងគ្រោះដោយផ្ទាល់។ នៅ ពេលអនុវត្តលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងដីកានេះ សញ្ញាណនៃគ្រួសារផ្ទាល់មិនត្រឹមរាប់បញ្ចូលទាំងឪពុក ម្តាយ និងកូនៗនោះទេ វាថែមទាំងរួមបញ្ចូលទាំងសហព័ទ្ធ និងបងប្អូនបង្កើតរបស់ជនរងគ្រោះដោយផ្ទាល់ផង ដែរ។ ការសន្មតទុកជាមុននេះនឹងត្រូវយកមកពិចារណាថាជាកត្តាជាក់លាក់នៅក្នុងស្ថានភាពខាងក្រោម៖

១.នៅពេលជនរងគ្រោះដោយផ្ទាល់បានទទួលមរណភាព ឬ បានបាត់ខ្លួនដោយសារផលវិបាកដោយផ្ទាល់លើអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេត។

២. នៅពេលជនរងគ្រោះដោយផ្ទាល់ត្រូវបានគេជម្លៀស និងបំបែកចេញដោយបង្ខំពីគ្រួសារផ្ទាល់ ដោយសារផលវិបាកផ្ទាល់នៃអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេត។ ការបំបែកចេញបែបនេះនាំឲ្យមានការឈឺចាប់លើសមាជិកគ្រួសារផ្ទាល់ ដែលបានបំពេញលក្ខខណ្ឌអប្បបរមានៃការខូចខាតខាងផ្លូវចិត្តលើបុគ្គល។

៣. នៅពេលជនរងគ្រោះដោយផ្ទាល់ត្រូវបានគេបង្ខំឲ្យរៀបការ កាលៈទេសៈបែបនេះ បានបណ្តាលឲ្យមានការឈឺចាប់ដោយជៀសមិនរួច ដែលបំពេញទៅតាមលក្ខខណ្ឌអប្បបរមានៃការខូចខាតខាងផ្លូវចិត្តដោយផ្ទាល់លើឪពុកម្តាយ សហព័ទ្ធ និងកូនៗ។

គ. សហចៅក្រមស៊ើបអង្កេតយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងដែលបានរកឃើញថា *"ការខូចខាត ដោយផ្ទាល់អាចមានលក្ខណៈពិបាកក្នុងការបង្ហាញចំពោះទំនាក់ទំនងគ្រួសារដែលពុំសូវជិតស្និទ"* ហើយសហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថាការសន្មតទុកជាមុនពាក់ព័ន្ធមានអត្ថិភាពចំពោះសមាជិកគ្រួសារសាច់ឆ្ងាយ (ជីដូនជីតាឪពុកមា និងម្តាយមីងក្មួយៗបងប្អូនជីដូនមួយសាច់ថ្លៃ និងញាតិសណ្តានមិនផ្ទាល់ផ្សេងទៀត។ នៅក្នុងករណីបែបនេះ សហចៅក្រមស៊ើបអង្កេតនឹងធ្វើការវាយតម្លៃទៅតាមករណីនីមួយៗ

៤២៣. យោងតាមការអនុវត្តនៅ អ.វ.ត.ក រហូតមកដល់បច្ចុប្បន្ននេះ ទម្រង់នៃ"ការបង្កើតសញ្ញាណថ្មី"ដែលអនុញ្ញាតដោយមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវបានសម្រេចតាមរយៈការអនុម័តវិធានផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងដំណើរការពិភាក្សាផ្លាស់ប្តូរយោបល់ និងមានការឯកភាពយល់ព្រមពីចៅក្រមភាគច្រើនរបស់ អ.វ.ត.ក[888]។ ទោះបីជាមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬវិធានផ្ទៃក្នុង ពុំបានហាមឃាត់ការបង្កើតសញ្ញាណថ្មី *ពិសេស* ដោយការិយាល័យ ឬ អង្គជំនុំជម្រះណាមួយនៅក្នុងករណីចាំបាច់ក៏ដោយ ក៏ការអនុវត្តនូវសញ្ញាណថ្មីនេះក្នុងបច្ចេកទេសនីតិវិធីជាក់លាក់របស់អង្គជំនុំជម្រះ ត្រូវមានកម្រិតដោយសារការពុំបានជូនដំណឹងជាមុន និងពុំមានអានុភាពចងកាតព្វកិច្ច អ.វ.ត.ក ជារួម។

---

ថាតើមានធាតុផ្សំគ្រប់គ្រាន់ក្នុងការសន្មតលើចំណងនៃក្តីស្រលាញ់ ឬការពឹងផ្អែកគ្នារវាងអ្នកដាក់ពាក្យសុំនិងជនរងគ្រោះដោយផ្ទាល់ដែរឬទេ។ ការសន្មតទុកជាមុននេះនឹងចាត់ទុកជាកត្តាកំណត់មួយនៅពេលជនរងគ្រោះដោយផ្ទាល់ បានទទួលមរណភាពឬបានបាត់ខ្លួនដោយសារផលវិបាកដោយផ្ទាល់នៃអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេត។

ដីកាសម្រេចរបស់ ស.ច.ស ស្តីពីភាពអាចទទួលយកពាក្យសុំនៅក្នុងសំណុំរឿង ០០២ កថាខណ្ឌ ១៤ រួមគ្នា (D392 ដល់ D399, D394, D401, D403 ដល់ D404, D406, D408)។ អង្គជំនុំជម្រះតុលាការកំពូលសន្មតថាសហចៅក្រមស៊ើបអង្កេតមានបំណងចង់បង្កើតការសន្មតទុកជាមុនដែលអាច ឬពុំអាចតវ៉ាបាន។ យោងតាមទស្សនៈរបស់អង្គជំនុំជម្រះតុលាការកំពូល ប្រភេទទីមួយនោះនឹងទាមទារឲ្យចេញសេចក្តីសម្រេចតាមផ្លូវច្បាប់មួយស្របតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលបាននៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានច្រានចោល ការសន្មតទុកជាមុន"ជាក់លាក់"ថាៈ "អង្គបុរេជំនុំជម្រះសង្កេតឃើញបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតកំណត់និយមន័យ"ការខូចខាតខាងផ្លូវចិត្តដោយផ្ទាល់" នៅក្នុងដីកាសម្រេចរបស់ខ្លួនក្នុងន័យតឹងរ៉ឹង។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ក្នុងករណីរកឃើញថា ទំនាក់ទំនងគ្រួសារជាលក្ខខណ្ឌទាមទារ នោះសហចៅក្រមស៊ើបអង្កេតបានអនុវត្តលក្ខខណ្ឌកម្រិតដោយពុំបានពិចារណាឬពុំមានមូលដ្ឋានសមស្រប។ ការសន្មតទុកជាមុនពាក់ព័ន្ធនឹងការខូចខាតខាងផ្លូវចិត្តត្រូវបានយកមកប្រើប្រាស់ដើម្បីពុំរាប់បញ្ចូលសេចក្តី ពិចារណាផ្សេងៗ និងត្រូវបានសន្និដ្ឋានជាមួយនឹងការលើកឡើងដោយគ្មានសំអាងនៅក្នុងកថាខណ្ឌ១៤យនៃដីកាសម្រេច។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលបាននៅក្នុងសំណុំរឿង ០០២, កថាខណ្ឌ ៤៨ រួម"។

[888] វិធាន ២ នៃវិធានផ្ទៃក្នុង។

ទោះបីជា មានការអនុញ្ញាតដោយមាត្រា ៣៣ ថ្មី នេះក៏ដោយ ក៏ការបង្កើតសញ្ញាណថ្មីនានារបស់អង្គជំនុំជម្រះនីមួយៗទាក់ទងទៅនឹងទស្សនៈទានផ្លូវច្បាប់ និងធ្វើឱ្យទស្សនៈទានទាំងនេះមានភាពខុសគ្នាមិនអាចទទួលយកបាន ហើយបានប៉ះពាល់ដល់សច្ចភាពតាមផ្លូវច្បាប់នៃដំណើរការរបស់ អ.វ.ត.ក។ តាមការអនុវត្តជាក់ស្តែង ពុំមានការបង្កើតសញ្ញាណថ្មីទាំងនេះនោះទេ[889]។

៤២៤. ពាក់ព័ន្ធទៅនឹងខ្លឹមសារនៃ"ការបង្កើតសញ្ញាណថ្មី" ផ្អែកតាមសម្មតិកម្មវិញ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា បញ្ហាចោទអាចកើតមានឡើងពាក់ព័ន្ធទៅនឹង*អ្វីដែលគួរតែជាច្បាប់* *(de lege ferenda)* គឺ ថាតើប្រព័ន្ធមួយដែលអនុញ្ញាតឱ្យជនរងគ្រោះចូលរួមយ៉ាងទូលំទូលាយ ប៉ុន្តែ ត្រូវផ្អែកយ៉ាងខ្លាំងលើការបង្ហាញឱ្យឃើញថា មានព្យសនកម្មនោះ គឺមានលក្ខណៈស្របគ្នា ដែរ ឬយ៉ាងណា ទៅនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិសំខាន់ៗ ដែលជនរងគ្រោះមានចំនួនច្រើន។ ទោះបីជាយ៉ាងនេះក្តី ដូចបានពិភាក្សាខាងលើ សញ្ញាណនៃដើមបណ្តឹងរដ្ឋប្បវេណី ដូចបានចែងយ៉ាងច្បាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ និងវិធានផ្ទៃក្នុង មានអត្ថន័យយ៉ាងច្បាស់លាស់ និងជាលក្ខណៈសំខាន់ពិសេសមួយនៃគំរូជាក់លាក់ដែល អ.វ.ត.ក បានជ្រើសរើស។ ការធ្វើអន្តរាគមទាក់ទងទៅនឹងនិយមន័យនេះ នឹងជំរុញឱ្យមានការពិចារណាឡើងវិញទាំងស្រុងពីភាពស៊ីសង្វាក់គ្នានៃគំរូនេះ។ ដូច្នេះ នឹងមានការរំពឹងទុកថា សេចក្តីសម្រេចក្នុងការកំណត់និយមន័យឡើងវិញលើសញ្ញាណនៃដើមបណ្តឹងរដ្ឋប្បវេណី បានផ្អែកទៅលើមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក យ៉ាងជាក់ច្បាស់ ហើយបានពិភាក្សាជាពិសេសលើលក្ខណៈវិនិច្ឆ័យ ដែលផ្តល់ជាយុត្តិកម្មលើការកំណត់និយមន័យនេះ និងប្រើប្រាស់ពាក្យដែលមានអត្ថន័យជាក់លាក់ ដែលខុសពីពាក្យពេចន៍មិនច្បាស់លាស់ ដូចជា ពាក្យ"គ្រួសារផ្ទាល់" ជាដើម។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបែរជាមិនអនុវត្តទៅវិញ។ លើសពីនេះទៀត ក្នុងដំណាក់កាលចេញសាលក្រម គឺជាពេលវេលាមួយដែលមិនសមស្របនោះទេក្នុងការកែប្រែច្បាប់ ទោះបីជាតាមបទដ្ឋានណាក៏ដោយ។ យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះ

[889]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៦២ (ពាក់ព័ន្ធនឹងទម្រង់នៃសំណង)។

តុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូង ពុំបានបញ្ជាក់អំពីការបង្កើតសញ្ញាណថ្មីពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ការពន្យល់នៅក្នុងកថាខណ្ឌ ៦៤៣ នៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទំនងជាបង្ហាញថា សញ្ញាណថ្មីនេះ គឺជាការសន្មតទុកជាមុន។

## ៦.ក.៤.ការសន្មតទុកជាមុនតាមផ្លូវច្បាប់ ឬតាមឆន្ទានុសិទ្ធិ

៤២៥. អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយបញ្ហា ថាតើការយល់ឃើញជាទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សមាជិកក្រុមគ្រួសារផ្ទាល់របស់ជនរងគ្រោះផ្ទាល់ស្ថិតនៅក្នុងវិសាលភាពនៃវិធាន ២៣(២)(ក)-(ខ) នៃវិធានផ្ទៃក្នុង ជាការសន្មតទុកជាមុនដែលមានសុពលភាពតាមផ្លូវច្បាប់ ដែរ ឬយ៉ាងណា។ តុលាការកំពូលកត់សម្គាល់ឃើញថា ការសន្មតទុកជាមុនមិនលុបបំបាត់ធាតុផ្សំដែលចាំបាច់នៃការកំណត់និយមន័យ (អត្ថិភាពនៃព្យសនកម្មដោយផ្ទាល់ និងផ្ទាល់ខ្លួន) នោះទេ ប៉ុន្តែយោងតាមលក្ខខណ្ឌមួយចំនួន ការសន្មតទុកជាមុននេះអាចបន្ថយបន្ទុកនៃការបង្ហាញភស្តុតាងអំពីធាតុផ្សំនោះ។

៤២៦. ជាចំណុចចាប់ផ្តើម អង្គជំនុំជម្រះតុលាការកំពូលរំឭកអំពីភាពខុសគ្នានៃការសន្មតទុកជាមុនដែលបង្កើតឡើងដោយច្បាប់ (*praesumptio iuris* ការសន្មតទុកជាមុនតាមច្បាប់ ឬតាមអាណត្តិ) និងការសន្មតទុកជាមុនដែលបង្កើតឡើងដោយតុលាការ (*praesumptio iudicis* ការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ) នៅក្នុងប្រពន្ធ័ច្បាប់ស៊ីវិល។ ការសន្មតទុកជាមុនដែលបង្កើតឡើងដោយច្បាប់ ត្រូវបានដកស្រង់ចេញពីគោលការណ៍ច្បាប់មួយចំនួន ឬឯកសារសំអាងផ្លូវច្បាប់ រីឯការសន្មតទុកជាមុនដែលបង្កើតឡើងដោយតុលាការកើតមានឡើង នៅពេលគ្មានច្បាប់ចែងលើចំណុចនេះ ហើយចៅក្រមត្រូវប្រុងប្រយ័ត្នក្នុងការធ្វើសេចក្តីសន្និដ្ឋានទៅតាមកាលៈទេសៈជាក់ស្តែងនានា។ តាមករណីទាំងពីរខាងលើ ពាក្យ“ការសន្មតទុកជាមុន” មានន័យថា ជាការប៉ាន់ស្មានដោយសមហេតុផលមួយ ពាក់ព័ន្ធនឹងបញ្ហាអ្វីមួយដែលមានមន្ទិលសង្ស័យកើតចេញពីការអះអាង និងការបង្ហាញនានា ហើយដែលអាចទទួលយកជាភស្តុតាងដោយសារកាលៈទេសៈតម្រូវ។ ការសន្មតទុកជាមុនដែលមាននៅក្នុងច្បាប់ គឺដើម្បី

ការពារផលប្រយោជន៍ដែលត្រូវបានទទួលស្គាល់ជាទូទៅ ជាធម្មានុរូប និងស្ថិតស្ថេរ ដូចជា សច្ចភាពផ្លូវច្បាប់ ការរារាំងការរំលោភអំណាច និងវិធានការព្រមាន។ ការសន្មតជាមុននៅក្នុងច្បាប់កម្ពុជា មានដូចជា ការសន្មតទុកជាមុនថាគ្មានទោស និងការសន្មតទុកជាមុនដទៃទៀតដែលមាននៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល[890] ឬនៅក្នុងសាលក្រម សិទ្ធិស្របច្បាប់ និងឯកសារផ្លូវការផ្សេងៗ[891]។ ការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ ត្រូវបានបង្កើតឡើងដោយផ្អែកលើមូលដ្ឋានពិសេស *(ad hoc)* សម្រាប់គោលបំណងឱ្យមានប្រសិទ្ធភាពដល់កិច្ចដំណើរការនីតិវិធី។ ទោះបីជាយ៉ាងណាក៏ដោយមិនមានន័យថា ដើម្បីផ្តល់ឱ្យភាគីមួយនូវផលប្រយោជន៍ហួសហេតុ ឬគ្រាន់តែជួយសម្រួលដល់កិច្ចដំណើរការនីតិវិធីរបស់តុលាការនោះទេ។ ការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិត្រូវបានអនុញ្ញាតដោយក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា[892]។

៤២៧. ការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ ដែលបង្កើតឡើងដោយតុលាការ មិនត្រូវឱ្យផ្ទុយទៅនឹងការសន្មតទុកជាមុនដែលបង្កើតឡើងដោយច្បាប់នោះឡើយ។ ការសន្មតទុកជាមុនតាមច្បាប់ចងកាតព្វកិច្ចគ្រប់ភាគីទាំងអស់ ចំណែកឯការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ អាចអនុវត្តបានតែនៅចំពោះមុខតុលាការ ដែលបានបង្កើតការសន្មតទុកជាមុននេះតែប៉ុណ្ណោះ ហើយអាចជាកម្មវត្ថុនៃការជំទាស់ និងការពិនិត្យឡើងវិញដោយតុលាការជាន់ខ្ពស់សំអាងលើអង្គហេតុ។ ការសន្មតទុកជាមុនតាមច្បាប់ អាច ឬមិនអាចជំទាស់ ចំណែកឯការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ អាចជំទាស់ជានិច្ច។ ការសន្មតទុកជាមុនតាមច្បាប់ត្រូវបានចាត់ទុកថា មានតម្លៃស្មើនឹងភស្តុតាង និងជាបន្ទុកលើភាគីជំទាស់។ ហេតុដូច្នេះ តុលាការអាចផ្អែកការសម្រេចរបស់ខ្លួនទៅលើការសន្មតទុកជាមុនតាមច្បាប់បាន ទោះបីជាតុលាការមានការមន្ទិលសង្ស័យទៅលើភាពស្របគ្នារវាងការសន្មតទុកជាមុន និងអង្គហេតុនៃរឿងក្តីនេះក៏ដោយ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើមានភាពផ្ទុយគ្នាខ្លាំងពេកនោះ តុលាការមិនអាចសម្រេចដោយផ្អែកទៅលើ

---

[890] *សូមមើលឧទា.* មាត្រា ៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ (ការសន្មតបិតុភាពរបស់ស្វាមីបច្ចុប្បន្ន) មាត្រា ៨២ ដល់ ៨៣ (ការសន្មតបិតុភាព)។ មាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៣ (ការសន្មតបិតុភាព) និងមាត្រា ២៣៤(៤) (ការសន្មតកម្មសិទ្ធិស្របច្បាប់)។

[891] *សូមមើលឧទា.* មាត្រា ១៥៥(២) និង ១៥៥(៤)-(៥) នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

[892] *សូមមើលឧទា.* មាត្រា ១២៣(១)-(២) និងមាត្រា ៩៦(១) នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ។

ការសន្និតទុកជាមុនដែលខ្លួនបានបង្កើតដោយផ្ទាល់នោះទេ។ ដើម្បីអនុញ្ញាតឱ្យមានការសម្រេចទៅលើបញ្ហារដ្ឋប្បវេណីបាន ការសន្និតទុកជាមុនតាមឆន្ទានុសិទ្ធិត្រូវតែមានការគាំទ្រពីធាតុផ្សំមួយចំនួនដែលជាធាតុបន្ទាប់បន្សំ ដូចជា ភស្តុតាងគាំទ្រ ភស្តុតាងមិនផ្ទាល់ ឬការទទួលស្គាល់ដោយប្រយោល។ អាស្រ័យហេតុនេះ ការសន្និតទុកជាមុនតាមឆន្ទានុសិទ្ធិមិនបានកាត់បន្ថយភាពចាំបាច់នៃការបង្ហាញភស្តុតាងឡើយ។ ហេតុដូច្នេះ ការប្រើប្រាស់ការសន្និតទុកជាមុនតាមឆន្ទានុសិទ្ធិ បង្ហាញឱ្យឃើញជាចម្បងនៅក្នុងការបង្ហាញភស្តុតាងដែល *ជាសេចក្តីបញ្ជាក់ដំបូង* ដូចជា នៅពេលដែលការសម្រេចមិនទាន់ជាស្ថាពរនៅឡើយ (ឧទាហរណ៍ នៅក្នុងសេចក្តីសម្រេចបឋមអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) ឬ នៅពេលដែលស្ថិតនៅក្នុងឆន្ទានុសិទ្ធិទូលំទូលាយ ដែលមិនប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់ណាមួយនោះ (ឧទាហរណ៍ដូចជា នៅក្នុងការអនុញ្ញាតឱ្យមានការពន្យារកាលបរិច្ឆេទ)។ ដោយហេតុថា ដើម្បីអនុញ្ញាតឱ្យមានការសម្រេចអំពីអង្គសេចក្តីនៃវិវាទរដ្ឋប្បវេណី គឺតម្រូវឱ្យការសន្និតទុកជាមុនមួយដោយមានការគាំទ្រពីធាតុផ្សំទាំងឡាយ ដែលជាធាតុបន្ទាប់បន្សំ ឧទាហរណ៍ដូចជា ភស្តុតាងគាំទ្រ ភស្តុតាងមិនផ្ទាល់ ឬការទទួលស្គាល់ដោយប្រយោល។

៤២៨. ចំពោះបញ្ហាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌវិញ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាត្រូវតែបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យលើហេតុការណ៍ដែលបណ្តាលឱ្យមានព្យសនកម្ម ហើយដែលជាមូលដ្ឋាននៃអង្គហេតុចំពោះការចោទប្រកាន់ពីបទព្រហ្មទណ្ឌ[893]។ ការសន្និតទុកជាមុនថាធាតុផ្សំនេះពិតជាមានអត្ថិភាពពាក់ព័ន្ធទៅនឹងបទចោទនោះ អាចនឹងផ្ទុយពីគោលការណ៍នៃការសន្និតទុកជាមុនថាគ្មានទោស។ ផ្ទុយទៅវិញ ធាតុផ្សំណាមួយនៃបណ្តឹងរដ្ឋប្បវេណីដែលហួសពីធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់នោះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញនៅក្នុងកម្រិតនៃភស្តុតាងដែលតម្រូវក្នុងរឿងក្តីរដ្ឋប្បវេណី។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅក្នុងការចោទប្រកាន់ពីឧក្រិដ្ឋកម្មអន្តរជាតិចម្បងៗ ដូចជា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក នោះ ចំនួនជនរងគ្រោះ ឬអត្តសញ្ញាណរបស់ពួកគេមិន

[893]វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

បង្កើតបានជាធាតុផ្សំបទល្មើស ហើយមិនចាំបាច់ដាក់បញ្ចូលទៅក្នុងបទចោទទាំងនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាទូទៅ ព័ត៌មានលម្អិតរបស់ជនរងគ្រោះផ្ទាល់ មិនត្រូវបានបង្ហាញដោយសហព្រះរាជអាជ្ញានោះទេ ប៉ុន្តែ នឹងត្រូវបង្ហាញដោយដើមបណ្តឹងរដ្ឋប្បវេណីទៅវិញ។ ដូចគ្នានេះដែរ ព្យសនកម្មដែលទទួលដោយជនរងគ្រោះមិនផ្ទាល់ដែលបណ្តាលមកពីបទល្មើស ជាធម្មតា ស្ថិតនៅក្រៅវិសាលភាពនៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ហាញភស្តុតាងក្នុងកម្រិតអតិបរមា លើកលែងតែច្បាប់តម្រូវឱ្យមានលក្ខខណ្ឌទាបជាងនេះ[894]។

៤២៩. ដោយពិចារណាឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ និងវិធានផ្ទៃក្នុងមិនបានកាត់បន្ថយបន្ទុកក្នុងការបង្ហាញភស្តុតាងចំពោះក្រុមជនរងគ្រោះណាមួយ ហើយមិនបានអនុញ្ញាតច្បាស់លាស់ឱ្យមានការបង្កើត និងការអនុវត្តការសន្មតទុកជាមុន ប៉ុន្តែ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា បានអនុញ្ញាតឱ្យមានការបង្កើត និងអនុវត្តការសន្មតទុកជាមុនដោយតុលាការនោះ ទើបមានបញ្ហាចោទឡើង ថាតើក្នុងលក្ខខណ្ឌអ្វីដែលអាចឱ្យស្ថាប័នតុលាការរបស់ អ.វ.ត.ក បង្កើតការសន្មតទុកជាមុននេះបាន។

៤៣០. ទាក់ទងទៅនឹងការសន្មតទុកជាមុនតាមច្បាប់ ដែលជាការផ្ទេរបន្ទុកក្នុងការបង្ហាញភស្តុតាងនោះ តម្រូវឱ្យមានការប្រុងប្រយ័ត្នទៅលើអានុភាពនៃការសន្មតទុកជាមុនទាំងនោះ នៅក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក ។ ដូចដែលបានពន្យល់ខាងលើ ប្រសិនបើការសន្មតទុកជាមុនដែលច្បាប់អនុញ្ញាតឱ្យបង្កើតឡើងដោយការិយាល័យ ឬអង្គជំនុំជម្រះណាមួយរបស់ អ.វ.ត.ក នោះ ការសន្មតទុកជាមុននេះមិនមានលក្ខណៈរឹងមាំនោះទេ។ ដោយសារតែការផ្ទេរបន្ទុកក្នុងការបង្ហាញភស្តុតាងចងកាតព្វកិច្ចភាគីទាំងឡាយនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ទើបកង្វះអានុភាពចងកាតព្វកិច្ចទៅលើ អ.វ.ត.ក ទាំងមូល បានលុបបំបាត់ចោលនូវលក្ខណៈខុសគ្នារវាងការសន្មតទុកជាមុនតាមច្បាប់ (*praesumpio iuris*) និងការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ

[894]មាត្រា ៩២ និងមាត្រា ១២៤(១) នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

(*praesumpio iudicis*)[895]។ ពាក់ព័ន្ធទៅនឹងអង្គសេចក្តីវិញ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅក្នុងបរិបទ អ.វ.ត.ក ការសន្មតទុកជាមុនតាមច្បាប់ អាចត្រូវបានបង្កើតឡើងនៅក្រោមលក្ខខណ្ឌដូចគ្នា ដែលអនុញ្ញាតឱ្យងាកចេញពីនីតិវិធីដែលបានកំណត់ដោយច្បាប់ដែលអាចជា "ការបង្កើតសញ្ញាណថ្មី"ដោយផ្អែកតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ដូចគ្នានេះដែរ បន្ថែមទៅលើការបញ្ជាក់អំពីភាពខ្វះចន្លោះនៅក្នុងច្បាប់ស្តីពីនីតិវិធីរបស់កម្ពុជា ការសន្មតទុកជាមុនតាមច្បាប់ដែលត្រូវបានបង្កើតឡើងថ្មីៗ អាចសំអាងទៅលើច្បាប់អន្តរជាតិ ឬការអនុវត្តជាក់ស្តែងដែលពាក់ព័ន្ធនឹងបរិបទរបស់ អ.វ.ត.ក ដោយបង្ហាញ នូវលក្ខណៈប្រហាក់ប្រហែលគ្នានៃភាពស្មុគស្មាញតាមផ្លូវច្បាប់ និងតាមកាលៈទេសៈជាក់ស្តែង ហើយគោលនយោបាយសាធារណៈដូចគ្នាត្រូវតែជាប់ទាក់ទងទៅនឹងការបញ្ជាក់អំពីការផ្ទេរបន្ទុកនៃការបង្ហាញភស្តុតាង។

៤៣១. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា យុត្តិសាស្ត្ររបស់ អ.វ.ត.ក[896] សំអាងយ៉ាងខ្លាំងទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស (IACtHR) និងតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) ដែលជាតុលាការថ្នាក់តំបន់ដែលបានបង្កើតឡើង

[895] ចំណុចនេះត្រូវបានបង្ហាញនៅក្នុងការសន្មតទុកជាមុន "ប្រកបដោយសេចក្តីសម្រេចចិត្ត" និង "ដែលជាប់ពាក់ព័ន្ធ" ដែលបានប្រើនៅក្នុងដីការបស់ ស.ច.ស សម្រេចអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានបដិសេធដោយអង្គបុរេជំនុំជម្រះ នៅក្នុងសាលដីការបស់ខ្លួនសម្រេចអំពីបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីជំទាស់នឹងដីការបស់ ស.ច.ស សម្រេចអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២, កថាខណ្ឌ ៤៨ រួម។

[896] *សូមមើលឧទា.* ដីការបស់ ស.ច.ស សម្រេចអំពីភាពអាចទទួលយកនៅក្នុងសំណុំរឿង ០០២, ជើងទំព័រ ១១ ដល់ ១៣ និង ១៥។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៧៦។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ អំពីភាពអាចទទួលយកបាន, ឯកសារលេខ F11, កថាខណ្ឌ ៥៦។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស អំពីភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២, ជើងទំព័រ ៧៧, ១១១ និង ១២៩។

តាមអនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស[897](ACHR) និងអនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (ECHR)។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បណ្ដឹងទាមទារឱ្យមានសំណង ប្រហែលជាពាក់ព័ន្ធផ្នែកអង្គហេតុសម្រាប់ការវិភាគនៅ អ.វ.ត.ក ព្រោះបណ្ដឹងទាំងនេះកើតចេញពីទម្រង់នៃការរំលោភសិទ្ធិមនុស្ស ។ ប៉ុន្តែដោយសារតែតុលាការសិទ្ធិមនុស្សថ្នាក់តំបន់ផ្ដោតសំខាន់តែទៅលើការទទួលខុសត្រូវរបស់រដ្ឋ ចំពោះការរំលោភលើកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ជាជាងផ្ដោតទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ទើបតុលាការទាំងពីរនេះ (ECtHR) និង (IACtHR) ចាំបាច់ត្រូវប្រតិបត្តិការក្នុងក្របខណ្ឌគតិយុត្ត ហើយត្រូវបង្កើតគោលនយោបាយផ្សេងពី អ.វ.ត.ក ។

៤៣២. ហេតុដូច្នេះ ពាក្យបណ្ដឹង និងសំណើនានា យោងតាមអនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស (ECHR) និងអនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស (ACHR) ត្រូវតែកើតចេញពីការរំលោភសិទ្ធិទាំងឡាយ ដែលត្រូវបានការពារដោយអនុសញ្ញានីមួយៗ[898] ពីសំណាក់រដ្ឋភាគីណាមួយ។ ដោយផ្អែកជាពិសេសតាមច្បាប់អន្តរជាតិ តុលាការសិទ្ធិមនុស្សថ្នាក់តំបន់ទាំងនេះត្រូវអភិវឌ្ឍនីតិវិធីរបស់ខ្លួនឱ្យបានទូលំទូលាយតាមរយៈយុត្តិសាស្ត្ររបស់ខ្លួនផ្ទាល់[899] និងនៅ

---

[897]អនុញ្ញាតឱ្យចុះហត្ថលេខានៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៦៩, លេខលំដាប់សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ វ៉ុល ១១៤៤ លេខលំដាប់សន្ធិសញ្ញាអង្គារសហប្រជាជាតិ ទំព័រ ១៤៣ (1144 UNTS 143) (ចូលជាធរមាននៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨)។

[898]មាត្រា ៣៤ នៃអនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស៖ (ដើមបណ្ដឹងត្រូវតែអះអាងថា "ខ្លួនជាជនរងគ្រោះដោយការរំលោភបំពានពីសំណាក់រដ្ឋជាភាគីនូវសិទ្ធិ ដែលមានចែងក្នុងអនុសញ្ញានេះ និងពិធីសារនានា")។ មាត្រា ៤៤ នៃអនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស៖ ("ជនណាម្នាក់ ឬក្រុមមនុស្សណាមួយ ឬស្ថាប័នមិនមែនរដ្ឋាភិបាលណាមួយ ដែលត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់នៅក្នុងរដ្ឋជាសមាជិកមួយ ឬច្រើននៃអង្គការនេះ អាចដាក់ពាក្យពាក្យបណ្ដឹងទៅគណៈកម្មាធិការសិទ្ធិមនុស្សដោយមានការចោទប្រកាន់ ឬប្ដឹងតវ៉ាចំពោះការរំលោភអនុសញ្ញានេះពីសំណាក់រដ្ឋភាគី") មាត្រា ៦៣(១) ចែងថា៖ ("ប្រសិនបើតុលាការរកឃើញថា មានការរំលោភសិទ្ធិ ឬសេរីភាព ដែលបានការពារដោយអនុសញ្ញានេះ តុលាការត្រូវសម្រេចថា ភាគីរងគ្រោះត្រូវបានធានាចំពោះការទទួលបានសិទ្ធិ ឬសេរីភាពរបស់ខ្លួនដែលត្រូវបានរំលោភនេះ")។

[899] តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្សសង្កត់ធ្ងន់ថា ពាក្យ "ជនរងគ្រោះ" ត្រូវបានបកស្រាយដោយឯករាជ្យ និងដោយមិនគិតពីច្បាប់ក្នុងស្រុកនោះឡើយ ដូចជា បញ្ហាពាក់ព័ន្ធនឹងផលប្រយោជន៍ ឬសមត្ថភាពចាត់វិធានការ។ *សូមមើលខទា. រឿងក្ដី Gorraiz Lizarraga និងជនដទៃទៀត ទល់នឹង ប្រទេសអេស្ប៉ាញ,* ECtHR, សាលក្រមរបស់អង្គជំនុំជម្រះ, បណ្ដឹងលេខ

ក្នុងការកំណត់អំពីអត្ថាគាហកនៃសំណាងទាំងនេះ តុលាការសិទ្ធិមនុស្សទាំងនេះបានអនុវត្ត ឆន្ទានុសិទ្ធិទូលំទូលាយជាងឆន្ទានុសិទ្ធិ ដែលបានអនុញ្ញាតតាមក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ទៅទៀត[900]។ យុត្តិសាស្ត្ររបស់តុលាការដែលបានបង្កើតឡើងស្របតាមអនុសញ្ញា

---

62543/00, ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៤ កថាខណ្ឌ ៣៥។ តុលាការនេះបានលើកឡើងបន្ថែមទៀតថា "លក្ខខណ្ឌគ្រប់គ្រងទៅលើពាក្យបណ្តឹងរបស់បុគ្គលម្នាក់ៗអនុលោមតាមមាត្រា ២៥ (បច្ចុប្បន្ននេះ មាត្រា ៣៤)នៃអនុសញ្ញា មិនចាំបាច់ដូចគ្នាទៅនឹងលក្ខណៈវិនិច្ឆ័យនៅក្នុងច្បាប់ជាតិដែលទាក់ទងទៅនឹងសិទ្ធិក្នុងការដាក់ពាក្យបណ្តឹង និងបង្ហាញជូនតុលាការពីការជាប់ពាក់ព័ន្ធទៅនឹងព្យសនកម្ម (*locus standi*)ទេ។ នៅក្នុងករណីនេះ ច្បាប់ជាតិអាចបម្រើគោលបំណងផ្សេងពីគោលបំណងទាំងឡាយដែលបានគិតប្រមើលឃើញនៅក្នុងមាត្រា ២៥ ហើយក្នុងពេលខ្លះ គោលបំណងទាំងនេះអាចមានលក្ខណៈប្រហាក់ប្រហែលគ្នាប៉ុន្តែមិនចាំបាច់ត្រូវតែដូចគ្នានោះទេ"។ *រឿងក្តី Norris ទល់នឹង ប្រទេសអៀកឡង់*, ECtHR, សេចក្តីសម្រេចកិច្ចប្រជុំពេញអង្គ, បណ្តឹងលេខ 10581/83 ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៨៨, កថាខណ្ឌ ៣១។ ដូចគ្នានេះដែរ តុលាការ IACHR សង្កត់ធ្ងន់ថា "កាតព្វកិច្ចដែលមានចែងក្នុងមាត្រា ៦៣(១) នៃអនុសញ្ញានេះត្រូវបានគ្រប់ដណ្តប់ដោយច្បាប់អន្តរជាតិនៅគ្រប់ផ្នែកទាំងអស់ ដូចជា វិសាលភាព ចរិតលក្ខណៈ និងអត្ថប្រយោជន៍របស់វា។ល។" *រឿងក្តី Aloeboetoe និងជនដទៃទៀត ទល់នឹង* Suriname, ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩៣, កថាខណ្ឌ ៥៤។

[900]នៅចំពោះមុខតុលាការ ECtHR ការបកស្រាយពាក្យ "ជនរងគ្រោះ" គឺធ្វើឡើងដើម្បីពង្រីកទៅតាមលក្ខខណ្ឌនៅក្នុងសង្គមតាមសហកាល និងត្រូវតែយកមកអនុវត្តដោយមិនមានទម្រង់និយមហួសហេតុ។ *រឿងក្តី Gorraiz Lizarraga និងជនដទៃទៀត ទល់នឹង ប្រទេសអេស្ប៉ាញ* , សាលក្រមអង្គជំនុំជម្រះ, កថាខណ្ឌ ៣៨។ *រឿងក្តី Monnat ទល់នឹង ប្រទេសស្វីស*, ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 73604/01, ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៣០ ដល់ ៣៣។ *រឿងក្តី Stukus និងជនដទៃទៀត ទល់នឹង ប្រទេសប៉ូឡូញ*, ECtHR,សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 12534/03, ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨, កថាខណ្ឌ ៣៥។ *រឿងក្តី Zietal ទល់នឹង ប្រទេសប៉ូឡូញ*, ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 64972/01, ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ៥៤ ដល់ ៥៩។ តុលាការបានទទួលស្គាល់ថា "ជាទូទៅ ករណីសិទ្ធិមនុស្សទាំងអស់នៅចំពោះមុខខ្លួនក៏មានការថ្លឹងថ្លែងអំពីបញ្ហាសីលធម៌ផងដែរ(...) ប្រសិនបើបញ្ហាជាចម្បងដែលបានលើកឡើងក្នុងរឿងក្តីវាលើសពីបញ្ហាបុគ្គល ហើយផលប្រយោជន៍របស់ដើមបណ្តឹង និងទាយាទរបស់ខ្លួន អាចប៉ះពាល់ដល់អ្នកដទៃទៀត"។ *រឿងក្តី Micallef ទល់នឹង ប្រទេសម៉ាល់តា*, ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 17056/06, ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០០៩, កថាខណ្ឌ ៤៥។ តុលាការ IACtHR បានពន្យល់អំពីសមត្ថកិច្ចរបស់ខ្លួនក្នុងការពិចារណាទាំងប្រភេទនៃសិទ្ធិវ័ន្ត និងជនរងគ្រោះ ដែលត្រូវបានទទួលសំណងទៅតាមសិទ្ធិរបស់ពួកគេផ្ទាល់។ *សូមមើលឧទា. រឿងក្តី Juan Humberto Sánchez ទល់នឹង ប្រទេសហុងឌូរ៉ាស់*,IACtHR, សាលក្រមអង្គជំនុំជម្រះស្តីពី(ការបកស្រាយនៅក្នុងសាលក្រមអំពីអញ្ញត្រកម្ម អង្គសេចក្តី និងសំណង") ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៣, កថាខណ្ឌ ៥៧ និងកថាខណ្ឌ ៥៩ ដល់ ៦៦។ *រឿងក្តី Myrna Mack Chang ទល់នឹង ប្រទេសហ្គាតេម៉ាឡា*, IACtHR, សាលក្រម (អង្គសេចក្តី សំណង និងសោហ៊ុយ) "សំអាងហេតុនៃមតិស្របរបស់ចៅក្រម

ទាំងពីរនេះ បានប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យទូលំទូលាយជាងសម្រាប់ការទទួលស្គាល់បុគ្គលនានាជាដើមបណ្តឹងរដ្ឋប្បវេណី ក្រៅពីជនរងគ្រោះផ្ទាល់។ នៅពេលអនុវត្តបទដ្ឋាននៃ "ទំនាក់ទំនងផ្ទាល់ដោយពេញលេញរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងព្យសនកម្មដែលពួកគេយល់ឃើញថា ពួកគេបានទទួលរងដោយសារការរំលោភសិទ្ធិមនុស្ស ដូចដែលបានចោទឡើងនេះ[901]" តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) បានទទួលយកពាក្យបណ្តឹងជា*បណ្តោះអាសន្ន* ពីសាច់ញាតិរបស់អ្នកដែលបានទទួលមរណភាព ក្នុងករណីដែលពាក្យសុំទាំងនេះត្រូវបានបង្ហាញហេតុផលសមស្របតាមរយៈចរិតលក្ខណៈនៃការរំលោភសិទ្ធិមនុស្ស ដូចដែលបានចោទប្រកាន់ និងការពិចារណាអំពីការអនុវត្តអនុសញ្ញានេះប្រកបដោយប្រសិទ្ធភាព[902]។

---

Garcia-Ramirez", ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៣, កថាខណ្ឌ ៥៧៖ ("នៅក្នុងផ្នែកមួយនៃ"ការវិវត្តន៍ ករណីយុត្តិសាស្ត្រ" មានបុគ្គលមួយប្រភេទដែលមិនស្ថិតនៅក្នុងប្រភេទជនរងគ្រោះដោយផ្ទាល់ ហើយកំពុងតែត្រូវបានចាប់ផ្តើមចាត់ថ្នាក់ថា ជាជនរងគ្រោះដោយប្រយោល ប៉ុន្តែ ជាអ្នកដែលមានសិទ្ធទទួលសំណង ដោយសារពួកគេត្រូវបានទទួលរងអន្តរាយដោយអង្គហេតុដែលបានដាក់ជូនតុលាការឲ្យធ្វើការពិចារណា។ ជាសង្ខេប កម្មវត្ថុទាំងអស់នេះត្រូវបានគ្របដណ្តប់ដោយទស្សនៈនៃ"អត្តគាហក" (...) ដែលតុលាការប្រើប្រាស់ជាទូទៅ ដែលគ្របដណ្តប់ទៅលើជនរងគ្រោះផ្ទាល់ ជនរងគ្រោះមិនផ្ទាល់ និងអ្នកដទៃទៀត ដែលត្រូវបានដាក់ឲ្យស្ថិតនៅខ្សែបន្ទាត់បែងចែកចង្អៀត និងពិបាកបកស្រាយរវាងប្រភេទបុគ្គលចុងក្រោយនេះ និងតតិយជន"។

[901] *រឿងក្តី Gorraiz Lizarraga និងជនដទៃទៀត ទល់នឹង ប្រទេសអេស្ប៉ាញ*, សាលក្រមរបស់អង្គជំនុំជម្រះ, កថាខណ្ឌ ៣៥។ *សូមមើលផងដែរ រឿងក្តី Fairfield និង ជនដទៃទៀត ទល់នឹង ចក្រភពអង់គ្លេស*, ECtHR, សាលក្រមរបស់អង្គជំនុំជម្រះ, *បណ្តឹងលេខ* 24790/04, ចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ២០០៥ ទំព័រ ៤ ដល់ ៥។

[902] តុលាការ ECtHR បានបញ្ជាក់អះអាងថា "បុគ្គលដែលជាសាច់ញាតិរបស់ជនដែលបានស្លាប់នៅក្នុងកាលៈទេសៈដែលនាំឲ្យកើតមានបញ្ហា ដូចមានចែងក្នុង*មាត្រា ២* នៃអនុសញ្ញានេះ អាចដាក់ពាក្យសុំជាដើមបណ្តឹងនៅក្រោមសិទ្ធិរបស់ខ្លួនផ្ទាល់" ប៉ុន្តែបានសម្រេចថា "នេះគឺជាស្ថានភាពពិសេស"។ *រឿងក្តី Fairfield និងជនដទៃទៀត ទល់នឹង ចក្រភពអង់គ្លេស,* ទំព័រ ៥ (គូសបញ្ជាក់បន្ថែម)។*សូមមើលផងដែរ រឿងក្តី Biç និងជនដទៃទៀត ទល់នឹង ប្រទេសតួគី*, ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 55955/00, ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៦, កថាខណ្ឌ ២២ (បានបដិសេធពាក្យសុំរបស់សាច់ញាតិដែលបានដាក់ដោយយោងតាមមាត្រា ៥ និង មាត្រា ៦ នៃអនុសញ្ញា)។ *ប៉ុន្តែសូមមើល រឿងក្តី Grădinar ទល់នឹង ប្រទេសម៉ុលដូវ៉ា (Moldova)*, ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 7170/02), ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០៨, កថាខណ្ឌ ៩១ (បានទទួលយកពាក្យបណ្តឹងរបស់សាច់ញាតិ ដែលបានប្តឹងអំពីការរំលោភទៅលើមាត្រា ៣ ហើយបានបញ្ជាក់ថា "តុលាការបានបដិសេធដូចគ្នាថា មិនអាចទទួលយកបានចំពោះពាក្យសុំ*ដែលមានអំណះអំណាង* ដែលបានដាក់ដោយសាច់ញាតិរបស់អ្នកស្លាប់ ពាក់ព័ន្ធទៅនឹងការរំលោភលើសិទ្ធិដែលមិនមានចែងក្នុងមាត្រា ២ និង ៣ នៃ

---

អនុសញ្ញានេះ”) (គូសបញ្ជាក់បន្ថែម)។ ប៉ុន្តែ នៅក្នុងសាលក្រមល្បីល្បាញនៅក្នុង*រឿងក្តី Kurt ទល់នឹង ប្រទេសតួគី,* ការយល់ឃើញរបស់តុលាការចំពោះការរំលោភបំពានមាត្រា ៣ នៃអនុសញ្ញា ត្រូវបានបញ្ជាក់ដោយអង្គហេតុដែលថា រឿងក្តីពាក់ព័ន្ធនឹងម្តាយរបស់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ហើយខ្លួនអ្នកស្រីផ្ទាល់ជាជនរងគ្រោះដោយការព្រងើយកន្តើយរបស់អាជ្ញាធរ ចំពោះការខឹងសម្បារ និងទុក្ខសោករបស់អ្នកស្រី។ *រឿងក្តី Kurt ទល់នឹង ប្រទេសតួគី,* ECtHR, សាលក្រមអង្គជំនុំជម្រះ , បណ្តឹងលេខ 24276/94, កថាខណ្ឌ ១៣០ ដល់ ១៣៤។ *សូមមើលផងដែររឿងក្តី Varnava និងជនដទៃទៀត ទល់នឹង ប្រទេសតួគី,* ECtHR, សាលក្រមប្រណិតអង្គជំនុំជម្រះ, បណ្តឹងលេខ 16064/90, 16065/90, 16066/90, 16068/90, 16069/90, 16070/90, 16071/90, 16072/90 និង 16073/90, ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩ កថាខណ្ឌ ២០០ ដល់ ២០២។ ទាក់ទងនឹងមាត្រា ៥ (សិទ្ធិទទួលបានសេរីភាព)៖ តុលាការ ECtHR បានទទួលយកពាក្យបណ្តឹងរបស់សហព័ទ្ធដែលជាស្វាមីរបស់ជនរងគ្រោះ ដែលត្រូវបានបញ្ជូនដោយបង្ខំទៅមន្ទីរពេទ្យវិកលចរិតបន្ទាប់ពីវិជ្ជបណ្ឌិតបានបញ្ចុះបញ្ចូលឲ្យគាត់ជឿថា ការបញ្ជូនភរិយារបស់គាត់ទៅមន្ទីរពេទ្យដោយបង្ខំ គឺជាការចាំបាច់។ *រឿងក្តី Houtman និង Meeus ទល់នឹង ប្រទេសបែលហ្ស៊ិក,* ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 22945/07, ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៩, កថាខណ្ឌ ២៧ ដល់ ៣១។ ទាក់ទងនឹងមាត្រា ៦ (សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌)៖ តុលាការ ECtHR បានទទួលយកដើមបណ្តឹងដែលបានស្វែងរកការការពារកិត្តិយសរបស់ប្តីប្រពន្ធ ប៉ុន្តែតុលាការបានកត់សម្គាល់ថា ដើមបណ្តឹងគឺជាទាយាទរបស់អ្នកដែលទទួលមរណភាព។ *រឿងក្តី Grădinar ទល់នឹង ប្រទេស ម៉ុលដូវ៉ា (Moldova),* ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 7170/02, ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០៨, កថាខណ្ឌ ៩២ ដល់ ៩៥។ សម្រាប់រឿងក្តីផ្សេងទៀត ទាក់ទងនឹង មាត្រា ៦ នៃអនុសញ្ញា ECHR រួមមាន *រឿងក្តី Brudnicka និងជនផ្សេងទៀត ទល់នឹង ប្រទេសប៉ូឡូញ,* ECtHR, សាលក្រម អង្គជំនុំជម្រះ, បណ្តឹងលេខ 54723/00, ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០០៥, កថាខណ្ឌ ៣២ ដល់ ៣៤។ *រឿងក្តី Marie-Louise Loyen និង Bruneel ទល់នឹង ប្រទេសបារាំង,* ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 55929/00, ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ២៩។ តុលាការបានទទួលយកពាក្យបណ្តឹងពីស្ត្រីមេម៉ាយម្នាក់ ដែលជាភរិយារបស់ចុងចោទ ដែលជាជនរងគ្រោះដោយការរំលោភសិទ្ធិក្នុងសន្មតទុកជាមុនថាឥតទោស។ *រឿងក្តី Nölkenbockhoff ទល់នឹង ប្រទេសអាល្លឺម៉ង់,* ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 10300/83, ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៨៧, កថាខណ្ឌ ៣៣។ ប៉ុន្តែ តុលាការបានច្រានចោលការទាមទាររបស់ពីសាច់ញាតិរបស់ដើមបណ្តឹង ដែលទាក់ទងទៅនឹងព្យសនកម្មដែលមិនមែនជាប្រាក់កាសចំពោះការតានតឹងក្នុងចិត្ត និងការប្រមាថមើលងាយ ដែលពួកគេបានរងការឈឺចាប់ ដោយសារតែលទ្ធផលនៃការជាប់ពន្ធនាគាររបស់ដើមបណ្តឹង ក្រោយពីការរកឃើញថាពួកគេមិនទទួលបានឋានៈជាជនរងគ្រោះនៅក្នុងរង្វង់អត្ថន័យនៃមាត្រា ៣៤ នៃអនុសញ្ញា។ *រឿងក្តី Stoimenov ទល់នឹង ប្រទេសម៉ាសេដូនៀ “Macedonia” នៃអតីតសាធារណៈរដ្ឋយូហ្គោស្លាវី,* ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 17995/02, ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០០៧, កថាខណ្ឌ ៥០ និង ៥៣)។ ផ្អែកតាមមាត្រា ១០ (សេរីភាពក្នុងការបញ្ចេញមតិ)៖ តុលាការបានទួលស្គាល់សម្បទារបស់ស្ត្រីមេម៉ាយដែលជាភរិយារបស់ដើមបណ្តឹង ដោយអង្គហេតុដែលបានបញ្ជាក់ថា ជនរងគ្រោះបានដាក់ពាក្យបណ្តឹងដោយខ្លួនឯងផ្ទាល់ ហើយពាក្យ

យោងតាមអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ACHR) ជនរងគ្រោះមិនផ្ទាល់អាចដាក់សំណើសុំដោយយោងតាមទស្សនទានស្តីពីសន្តតិកម្ម បន្ទាប់ពីជនរងគ្រោះផ្ទាល់[903] ឬយោងតាមលទ្ធិច្បាប់ស្តីពីការរំលោភសិទ្ធិ ទទួលបានការការពារបូរណភាពផ្លូវចិត្តរបស់ជនរងគ្រោះមិនផ្ទាល់ រួមជាមួយនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ពីតុលាការ[904]។

---

បណ្តឹងនេះត្រូវបានបន្តដោយស្ត្រីមេម៉ាយរូបនេះ។ *រឿងក្តី Dalban ទល់នឹង ប្រទេសរូម៉ានី*, ECtHR, សាលក្រមប្រណិតរបស់អង្គជំនុំជម្រះ, បណ្តឹងលេខ 28114/95, ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៣៨ ដល់ ៣៩។ តុលាការបានបញ្ជាក់អះអាងអំពីសមត្ថកិច្ចរបស់ខ្លួនដើម្បីសម្រេច ថាតើវាសមស្របឬអត់ក្នុងការ បន្តការសួរដេញដោលរបស់ខ្លួនសម្រាប់គោលបំណងនៃការការពារសិទ្ធិមនុស្ស និងការពិចារណាអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ទូទៅដែរឬយ៉ាងណា។ *រឿងក្តី Karner ទល់នឹង ប្រទេសអូទ្រីស*, ECtHR, សាលក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 40016/98, ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៣, កថាខណ្ឌ ២៥ ដល់ ២៨។ *រឿងក្តី Marie-Louise Loyen និង Bruneel ទល់នឹង ប្រទេសបារាំង*, សាលក្រមអង្គជំនុំជម្រះ, កថាខណ្ឌ ២៩។

[903] *សូមមើលឧទា. រឿងក្តី Aloeboetoe និងជនដទៃទៀត ទល់នឹង ស៊ូរីណាម (Suriname)*, សាលក្រម (សំណង និង សោហ៊ុយ"), កថាខណ្ឌ ៥៤ ("ព្យសនកម្មដែលជនរងគ្រោះទាំងនេះបានទទួលរងរហូតមកទល់នឹងពេលពួកគេទទួលមរណៈភាពនោះបានផ្តល់សិទ្ធិឱ្យពួកគេទទួលបានសំណង។ សិទ្ធិទទួលបានសំណងនេះត្រូវបានផ្ទេរទៅឱ្យទាយាទរបស់ពួកគេតាមរយៈសន្តតិកម្ម")។ *រឿងក្តី Garrido និង Baigorria ទល់នឹង ប្រទេសអាហ្សង់ទីន*, តុលាការ IACtHR, សាលក្រមស្តីពី(សំណង និងសោហ៊ុយ"), ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥០។ *រឿងក្តី white* van, សាលក្រមស្តីពី(សំណង និងសោហ៊ុយ), កថាខណ្ឌ ៨៤។ *រឿងក្តី Juan Humberto Sánchez ទល់នឹង ប្រទេសហុងឌូរ៉ាស*, សាលក្រមស្តីពី(ការបកស្រាយនៅក្នុងសាលក្រមអំពីអញ្ញត្រកម្ម អង្គសេចក្តី និង សំណង"), កថាខណ្ឌ ៥៩ ដល់ ៦៦។

[904] *រឿងក្តី Myrna Mack Chang ទល់នឹងប្រទេសហ្គាតេម៉ាឡា* ដែលតុលាការអនុវត្តតាមតុលាការ ECtHR នៅក្នុង *រឿងក្តី Kurt ទល់នឹង ប្រទេសទួគី* ដោយបានរកឃើញការរំលោភសិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរតាមផ្លូវសីលធម៌នៃសាច់ញាតិជិតស្និទ្ធរបស់ជនរងគ្រោះដោយផ្ទាល់ បន្ទាប់ពីការរកឃើញថា អាជ្ញាធរបានធ្វើទុក្ខបុកម្នេញ និងគំរាមកំហែងពួកគេរួចមក។ *រឿងក្តី Myrna Mack Chang ទល់នឹង Guatemala* សាលក្រមស្តីពី(អង្គសេចក្តី សំណង សោហ៊ុយ), កថាខណ្ឌ ២៣២, ២៣៤។ *រឿងក្តី La Cantuta ទល់នឹង ប្រទេសប៉េរូ* (តុលាការ IACtHR បានសម្រេចថា "ក្នុងរឿងក្តីពាក់ព័ន្ធនឹងការបាត់ខ្លួនមនុស្សដោយបង្ខំ អាចត្រូវបានគេយល់ថា ការរំលោភសិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរតាមផ្លូវចិត្ត និងផ្លូវសីលធម៌របស់សាច់ញាតិជិតស្និទ្ធជនរងគ្រោះ គឺពិតជាផលវិបាកដោយផ្ទាល់នៃព្រឹត្តិការណ៍នោះ ដែលបណ្តាលឱ្យពួកគេទទួលរងការឈឺចាប់យ៉ាងធ្ងន់ធ្ងរ ហើយវាកាន់តែអាក្រក់ទៅទៀត ដោយការបន្តបដិសេធពីសំណាក់អាជ្ញាធររដ្ឋមិនផ្តល់ព័ត៌មានថាតើជនរងគ្រោះស្ថិតនៅទីណានោះ ឬមិនបំពេញកិច្ចស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពដើម្បីបំភ្លឺការពិត"។ *រឿងក្តី La Cantuta ទល់នឹង ប្រទេសប៉េរូ*, តុលាការ IACtHR, សាលក្រមស្តីពី (អង្គសេចក្តី សំណង សោហ៊ុយ), កថាខណ្ឌ

៤៣៣. បើប្រៀបធៀបទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក ទំនាក់ទំនងហេតុ និងផលដែលជាប់ទាក់ទងទៅនឹងដំណើរការនីតិវិធីយោងតាមលិខិតុបករណ៍ ស្តីពីសិទ្ធិមនុស្សថ្នាក់តំបន់ បានផ្តោតទៅលើសិទ្ធិជាជាងផ្តោតទៅលើព្យសនកម្ម។ ជួនកាល ទំនាក់ទំនងហេតុ និងផលនេះ នាំទៅដល់ការបង្រួមវិសាលភាពនៃសិទ្ធិរបស់ជនរងគ្រោះ[905]

---

១២៣។ នៅក្នុងរឿងក្តីផ្សេងៗទៀត តុលាការក៏បានសង្កត់ធ្ងន់ទៅលើការរំលោភបំពានសិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរតាមផ្លូវសីលធម៌ ដោយមិនគិតពីទង្វើរបស់អាជ្ញាធរក្នុងការដោះស្រាយចំពោះសាច់ញាតិជិតស្និទ្ធទេ។ *សូមមើលផងដែរ រឿងក្តី Blake ទល់នឹង ហ្គាតេម៉ាឡា*, តុលាការ IACtHR, សាលក្រមស្តីពី"អង្គសេចក្តី", ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៨ កថាខណ្ឌ ១១៤ ដល់ ១១៦។ *រឿងក្តី Bámaca Velásquez ទល់នឹង ប្រទេសហ្គាតេម៉ាឡា*, IACtHR, សាលក្រមលើ"អង្គសេចក្តី", ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២000, កថាខណ្ឌ ១៦០។ ទាក់ទងនឹងមាត្រា ៨(១) និងមាត្រា ២៥ នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស តុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្សបានលើកឡើងថា៖ "មាត្រា ៨(១) នៃអនុសញ្ញានេះត្រូវតែទទួលបានការបកស្រាយឱ្យបានទូលំទូលាយដោយសំអាងទាំងលើសាលក្រម និងស្មារតីនៃបទប្បញ្ញត្តិនេះ (...)។ ដូច្នេះការបកស្រាយដូចបានលើកឡើងខាងលើ ក្នុងមាត្រា ៨(១) នៃអនុញ្ញានេះ ក៏រាប់បញ្ចូលនូវសិទ្ធិរបស់សាច់ញាតិជនរងគ្រោះក្នុងការទទួលបានការធានាតាមផ្លូវតុលាការផងដែរ"។ *រឿងក្តី Blake ទល់នឹង ប្រទេសហ្គាតេម៉ាឡា*, សាលក្រមលើ (អង្គសេចក្តី), កថាខណ្ឌ ៩៦ ដល់ ៩៧។

[905]នៅក្នុង*រឿងក្តី white van*, តុលាការ IACtHR បានសង្កត់ធ្ងន់អំពីភាពមិនពាក់ព័ន្ធនឹងការទទួលខុសត្រូវជាបុគ្គល៖ "ខុសពីច្បាប់ព្រហ្មទណ្ឌក្នុងស្រុក គេមិនចាំបាច់ក្នុងការសម្រេចអំពីការទទួលខុសត្រូវ ឬចេតនារបស់ជនល្មើសដើម្បីរកឱ្យឃើញថា សិទ្ធិដែលមានចែងក្នុងអនុសញ្ញានេះ ត្រូវបានរំលោភ ហើយក៏មិនចាំបាច់កំណត់អត្តសញ្ញាណភ្នាក់ងារទាំងឡាយដែលបានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សនោះដែរ។ មានលក្ខខណ្ឌតម្រូវតែមួយគត់ ដើម្បីបង្ហាញឱ្យឃើញថា អាជ្ញាធររដ្ឋបានគាំទ្រ ឬ បានអត់ឱនដល់ការរំលោភសិទ្ធិ ដែលបានទទួលស្គាល់នៅក្នុងអនុសញ្ញា"។ *រឿងក្តី white van*, សាលក្រមលើ"អង្គសេចក្តី", ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៨, កថាខណ្ឌ ៩១។ ការផ្តោតទៅលើការទទួលខុសត្រូវរបស់រដ្ឋនាំឱ្យសម្រេចបាននូវសញ្ញាណរបស់ជនរងគ្រោះក្នុងកម្រិតចង្អៀត នៅចំពោះមុខតុលាការ ECtHR។ *រឿងក្តី Çakici ទល់នឹង ប្រទេសទួគី*, កថាខណ្ឌ ៩៨៖ "*រឿងក្តី Kurt* មិន (...) បង្កើតគោលការណ៍ទូទៅណាមួយថា សមាជិកគ្រួសារណាម្នាក់របស់"អ្នកបាត់ខ្លួន" គឺជាជនរងគ្រោះដោយការប្រព្រឹត្តផ្ទុយទៅនឹងមាត្រា ៣។ ទោះបីជាសមាជិកគ្រួសារណាម្នាក់ជាជនរងគ្រោះបែបនេះ ឬមិនមែនជាជនរងគ្រោះបែបនេះក៏ដោយ វានឹងអាស្រ័យទៅលើអត្ថិភាពនៃកត្តាពិសេសៗមួយចំនួន ដែលបង្កឱ្យមានការឈឺចាប់ដល់ដើមបណ្តឹង ទាំងទំហំ និងចរិតលក្ខណៈនៃការឈឺចាប់ ដែលខុសពីការតានតឹងផ្លូវអារម្មណ៍ដែលអាចចាត់ទុកថា មិនអាចចៀសរួច ដែលបានកើតមានឡើងចំពោះសាច់ញាតិរបស់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ(...)។ (...) ខ្លឹមសារនៃការរំលោភបែបនេះ មិនសំអាងទៅលើ "ការបាត់ខ្លួន"សមាជិកគ្រួសារខ្លាំងក្លានោះទេ ប៉ុន្តែ វាពាក់ព័ន្ធទៅនឹងប្រតិកម្ម និងឥរិយាបថ របស់អាជ្ញាធរចំពោះស្ថានភាពនេះ នៅពេលដែលការរំលោភបែបនេះត្រូវ

ពេលខ្លះទៀតនាំទៅដល់ការពង្រីកវិសាលភាពនៃសិទ្ធិរបស់ជនរងគ្រោះទៅវិញ[906]។ម្យ៉ាងវិញទៀត អាណត្តិនៃយន្តការការពារសិទ្ធិមនុស្សថ្នាក់តំបន់ទាំងនេះ បានពង្រីកហួសពីការជំនុំជម្រះរឿងក្តីនៅទីក្រុង Strasbourg និង San José។ ដូចដែលតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) បានកត់សម្គាល់៖

> "តុលាការតែងតែបានលើកឡើងថា តាមពិត សាលក្រមរបស់ខ្លួនមិនត្រឹមតែសម្រេចទៅលើរឿងក្តីទាំងឡាយដែលបានប្តឹងមកខ្លួនតែប៉ុណ្ណោះទេ ថែមទាំង ជាទូទៅ គឺដើម្បីស្រាយបំភ្លឺ ការពារ និងអភិវឌ្ឍនូវវិធានទាំងឡាយដែលបានបង្កើតឡើងដោយអនុសញ្ញានេះ តាមរយៈការរួមចំណែកក្នុងការប្រតិបត្តិតាមពីសំណាក់រដ្ឋទាំងឡាយ ដែលមានការជាប់ពាក់ព័ន្ធក្នុងនាមខ្លួនជារដ្ឋភាគីនៃអនុសញ្ញានេះ (...) ទោះបីជាគោលបំណងចម្បងនៃអនុសញ្ញានេះ គឺដើម្បីផ្តល់ដំណោះស្រាយនីមួយៗ ក៏ដោយ ក៏បេសកកម្មរបស់អនុសញ្ញានេះ គឺដើម្បីសម្រេចទៅលើបញ្ហាទាំងឡាយស្តីពីមូលដ្ឋាន

---

បានគេយកមកឲ្យអាជ្ញាដោះស្រាយ។ ជាពិសេស ពាក់ព័ន្ធទៅនឹងចំណុចចុងក្រោយដែលថា សាច់ញាតិអាចអះអាងដោយផ្ទាល់ ថាជាជនរងគ្រោះដោយអំពើរបស់អាជ្ញាធរ។ *រឿងក្តី Micallef ទល់នឹង ប្រទេសម៉ាល់តា,* សាលក្រមដ៏ប្រណិតរបស់អង្គជំនុំជម្រះ, "មតិយោបល់ជំទាស់មួយផ្នែករបស់ចៅក្រម Björgvinsson និងចៅក្រម Malinverni", កថាខណ្ឌ ៤(ខ)៖ ("(...) ក្នុងករណីដែលជនរងគ្រោះដោយផ្ទាល់ទទួលមានមរណភាព *មុនពេល*ដាក់ពាក្យបណ្តឹងទៅតុលាការ នោះសេចក្តីសម្រេចក្នុងរឿងក្តីក្រោយនេះនឹងទទួលស្គាល់សមាជិកគ្រួសាររបស់ជនរងគ្រោះ ក្នុងករណីលើកលែងបំផុត ថាមានឋានៈជាជនរងគ្រោះ") (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែររឿងក្តី Lipencov ទល់នឹង ប្រទេសម៉ាល់តា,* តុលាការ ECtHR, សាក្រមអង្គជំនុំជម្រះ, បណ្តឹងលេខ 27763/05, ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១១, កថាខណ្ឌ ២៧ (បានសម្រេចថា ក្នុងករណីដែលឋានៈរបស់ដើមបណ្តឹងជាជនរងគ្រោះផ្ទាល់ នៅក្រោមមាត្រា ៣ លើសពីវិមតិសង្ស័យ នោះមិនតម្រូវឲ្យពិនិត្យពាក្យបណ្តឹងមួយផ្សេងទៀតពីម្តាយរបស់ដើមបណ្តឹងដែលស្ថិតនៅក្រោមមាត្រា ៣ "ដែលមានទុក្ខសោកយ៉ាងខ្លាំង" និងដែលមាន"កង្វល់ និងការតានតឹងអារម្មណ៍" ពាក់ព័ន្ធនឹងសុខមាលភាពកូនប្រុសរបស់គាត់ នៅពេលដែលកូនប្រុសរបស់គាត់ ត្រូវបានគេឃុំឃាំងខ្លួន បើពិនិត្យទៅលើអាយុ និងភាពអសមត្ថភាពរបស់គាត់។

[906]ដើម្បីមានលក្ខណៈសម្បត្តិជាជនរងគ្រោះនៅក្នុងអត្ថន័យនៃមាត្រា ៣៤ របស់តុលាការ ECHR មិនមានលក្ខខណ្ឌត្រូវថា អ្នកដាក់ពាក្យសុំ ត្រូវទទួលរងនូវព្យសនកម្មជាក់លាក់ឡើយ។ តុលាការបានទទួលស្គាល់ថា នៅក្នុងបរិបទនៃមាត្រា ៣ ការរំលោភបំពានដែលអាចកើតមាននៅពេលអនាគត អាចមានលក្ខណៈគ្រប់គ្រាន់ក្នុងបំពេញនូវលក្ខខណ្ឌតម្រូវជាជនរងគ្រោះ។ *សូមមើលរឿងក្តី Soering ទល់នឹង ចក្រភពអង់គ្លេស,* ECtHR, សេចក្តីសម្រេចរបស់កិច្ចប្រជុំពេញអង្គ, បណ្តឹងលេខ 14038/88, ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៩៨៩, កថាខណ្ឌ ៩០។

គោលនយោបាយសាធារណៈ នៅក្នុងផលប្រយោជន៍រួមដែលតាមរយៈនេះ នាំឱ្យមានការលើកឡើងអំពីបទដ្ឋានទូទៅនៃការការពារសិទ្ធិមនុស្ស និងការពង្រីកយុត្តិសាស្ត្រ ស្តីពីសិទ្ធិមនុស្ស នៅទូទាំងសហគមន៍របស់បណ្តារដ្ឋជាសមាជិកនៃអនុសញ្ញានេះផងដែរ[907]។

៤៣៤. នៅពេលដែលបានស្វែងយល់យ៉ាងទូលំទូលាយអំពីបេសកកម្មនេះ ដំណើរការនីតិវិធីនៅចំពោះមុខតុលាការថ្នាក់តំបន់ស្តីពីសិទ្ធិមនុស្ស (ECtHR) និង (IACtHR) អនុញ្ញាតឱ្យមានការប្រើប្រាស់ឆន្ទានុសិទ្ធិទូលំទូលាយ ក្នុងការសម្រេចអំពីការទទួលយកជនរងគ្រោះ និងការទាមទារសំណង ជាជាងត្រឹមតែធានានូវឆន្ទានុសិទ្ធិនេះ តាមគោលការណ៍ជំនុំជម្រះក្តីដោយយុត្តិធម៌នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប៉ុណ្ណោះទេ។ ការបន្ធូរបន្ថយលក្ខខណ្ឌទាំងនេះ នឹងធ្វើឱ្យមានភាពស្មុគស្មាញដល់បទដ្ឋាននៃការបង្ហាញភស្តុតាង[908] វិសាលភាពនៃអត្តគាហក[909]

[907] *រឿងក្តី* Karner *ទល់នឹង ប្រទេសអូទ្រីស,* កថាខណ្ឌ ២៦, ដកស្រង់ចេញពី *រឿងក្តីប្រទេសអៀរឡង់ ទល់នឹង ចក្រភពអង់គ្លេស,* សេចក្តីសម្រេចកិច្ចប្រជុំពេញអង្គ, បណ្តឹងលេខ 5310/71, ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៧៨ កថាខណ្ឌ ១៥៤។ *រឿងក្តី* Guzzardi *ទល់នឹង ប្រទេសអ៊ីតាលី,* សេចក្តីសម្រេចកិច្ចប្រជុំពេញអង្គ, បណ្តឹងលេខ 7367/76, ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៨០, កថាខណ្ឌ ៨៦។ ភាពខុសគ្នានៃអាណត្តិនិងឥទ្ធិពលរបស់វាលើការអនុវត្តយុត្តាធិការត្រូវបានកត់សម្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងផ្នែកពិភាក្សាទៅលើសំណង។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៦២ ដល់ ៦៦៣។

[908] *សូមមើល ឧទា. រឿងក្តី* white van, សាលក្រមស្តីពី(សំណង និងសោហ៊ុយ), កថាខណ្ឌ ៥១៖ "តុលាការធ្លាប់បានចង្អុលបង្ហាញថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ មិនស្ថិតនៅក្រោមទម្រង់បែបបទ ដូចគ្នាទៅនឹងកិច្ចដំណើរការនីតិវិធីជាតិឡើយ (...)។ យុត្តិសាស្ត្រអន្តរជាតិបានតម្កល់អំណាចរបស់តុលាការក្នុង ការវាយតម្លៃលើភស្តុតាងនៅក្នុងកម្រិតនៃឆន្ទានុសិទ្ធិ*របស់*តុលាការដ៏ត្រឹមត្រូវ *ហើយ*តែងតែបានបញ្ចៀសនូវការធ្វើសេចក្តីសម្រេចដ៏តឹងរ៉ឹងអំពីចំនួននៃភស្តុតាង ដែលតម្រូវឱ្យមានដើម្បីគាំទ្រដល់សាលក្រម"។ *រឿងក្តី* Juan Humberto Sánchez *ទល់នឹង* Honduras, សាលក្រម (ការបកស្រាយសាលក្រមអំពីអញ្ញត្រកម្ម អង្គសេចក្តី និងសំណង)", កថាខណ្ឌ ៤២។ ("ពាក់ព័ន្ធនឹងបញ្ហានេះ គោលការណ៍ណែនាំ" គឺយុត្តិធម៌ 'មិនអាចត្រូវបានលះបង់ដើម្បីតែទម្រង់បែបបទប៉ុណ្ណោះឡើយ" ហើយដូច្នេះ តុលាការសិទ្ធិមនុស្សអន្តរជាតិមានភាពបត់បែន និងវិសាលភាពធំជាង នៅពេលធ្វើការវាយតម្លៃលើភស្តុតាង។

[909] *សូមមើល ឧទា. រឿងក្តី* Garrido *និង* Baigorria *ទល់នឹង ប្រទេសអាហ្សង់ទីន,* សាលក្រមស្តីពី (សំណង និងសោហ៊ុយ), កថាខណ្ឌ ៦៣ ដល់ ៦៤ (បានសម្រេចផ្តល់សំណងជូនបងប្អូនបង្កើតរបស់ជនរងគ្រោះទោះបីជាបានរកឃើញថា 'ពួកគាត់ពុំបានផ្តល់ភ័ស្តុតាងបញ្ជាក់អំពីទំនាក់ទំនងផ្លូវចិត្តដែលការបាត់ខ្លួនរបស់បងប្អូនប្រុសរបស់ពួកគាត់ បាន

និងបន្ទុកនៃការបង្ហាញភស្តុតាង[910]។

---

បណ្តាលឲ្យពួកគាត់ទទួលរងការឈឺចាប់ធ្ងន់ធ្ងរឡើយ។ អ្នកខ្លះរស់នៅចម្ងាយ ១.០០០ គម ពីកន្លែងដែល(ជនរងគ្រោះរស់នៅ) ហើយពុំមានភស្តុតាងបង្ហាញថា ពួកគាត់បានទៅសួរសុខទុក្ខគ្នាជាញឹកញាប់ ឬក៏ថា ពួកគាត់បានចាប់អារម្មណ៍ច្រើនពីជីវិតរស់នៅរបស់បងប្អូនប្រុសរបស់ពួកគាត់ឡើយ")។ *រឿងក្តី Juan Humberto Sánchez ទល់នឹង ប្រទេសហុងឌូរ៉ាស* Honduras, សាលក្រមស្តីពី(ការបកស្រាយសាលក្រមអំពីអញ្ញត្រកម្ម អង្គសេចក្តី និងសំណង)" *ចុះថ្ងៃទី* ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ កថាខណ្ឌ ៥៨ ដល់ ៥៩ (បានទទួលស្គាល់សិទ្ធិក្នុងការទទួលបានសំណង (តាមរយៈសន្តតិកម្ម ឬសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគាត់) នៅលើផ្នែកនៃប្រពន្ធចុងពីរនាក់បន្តបន្ទាប់គ្នារបស់អ្នកស្លាប់)។ *រឿងក្តី Caracazo ទល់នឹង ប្រទេសវ៉េណេស៊ុយអេឡា*, សាលក្រមស្តីពី (សំណង និងសោហ៊ុយ) កថាខណ្ឌ ៩១ (ភាគរយជាក់លាក់នៃសំណងជំងឺចិត្តត្រូវបានផ្តល់តាមរយៈសន្តតិកម្មទៅឲ្យកូន សហពន្ធ័ ឬដៃគូ ឪពុកម្តាយ ឬអ្នកទាំងឡាយណាដែលមានទំនាក់ទំនងផ្លូវចិត្តនៃលក្ខណៈស្រដៀងគ្នា ជាឪពុកចុង ម្តាយមីង/អ៊ំស្រី ពូ/អ៊ំប្រុស ឬជីដូន/ជីតា។ ប្រសិនបើពុំមានអ្នកទាំងនេះទេ តុលាការសម្រេចថា សំណងជំងឺចិត្តត្រូវផ្តល់ជូនជាភាគរយស្មើគ្នាទៅឲ្យឪពុកម្តាយ និងបងប្អូនបង្កើតរបស់ជនរងគ្រោះ។ តុលាការ ECHR ដោះស្រាយអំពីសញ្ញាណនៃជនរងគ្រោះជាទូទៅក្នុងលក្ខណៈតឹងរ៉ឹងជាង។ *សូមមើល ឧទា. រឿងក្តី Velikova ទល់នឹងប្រទេសប៊ុលហ្គារី* សេចក្តីសម្រេចរបស់តុលាការ ECtHR (បណ្តឹងលេខ 41488/98 ) ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ទំព័រ ១២ ("ស្ថាប័ននៃអនុសញ្ញានេះតែងតែបានចាត់ទុកដោយគ្មានលក្ខខណ្ឌនៅក្នុងយុត្តិសាស្ត្ររបស់ខ្លួនថា ឪពុក/ម្តាយបងប្អូនបង្កើត ឬក្មួយប្រុសរបស់បុគ្គលដែលការស្លាប់របស់បុគ្គលនោះត្រូវបានចោទប្រកាន់ថាជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋាភិបាលដែលជាចុងបណ្តឹងអាចអះអាងថា ជាជនរងគ្រោះនៃការរំលោភបំពានដែលត្រូវបានចោទប្រកាន់នៃមាត្រា ២ នៃអនុសញ្ញាទោះបីជាសាច់ញាតិជិតជាងនេះដូចជាកូនរបស់អ្នកស្លាប់ពុំបានដាក់ពាក្យសុំក៏ដោយ។ នៅក្នុងរឿងក្តីទាំងអស់នេះបញ្ហាថាតើអ្នកដាក់ពាក្យសុំគឺ ជាទាយាទស្របច្បាប់របស់អ្នកស្លាប់ ឬយ៉ាងណានោះគឺពុំពាក់ព័ន្ធឡើយ"ដកស្រង់*ចេញពីរឿងក្តី Yaşa ទល់នឹង ប្រទេសទួគី* សេចក្តីសម្រេចរបស់តុលាការ ECtHR(បណ្តឹងលេខ 22495/93) ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៦៦)។ ហេតុផលដែលថាក្មួយប្រុស នៅក្នុងរឿងក្តី *Yaşa* ត្រូវបានចាត់ទុក "ដោយគ្មានលក្ខខណ្ឌ" ថាជាជនរងគ្រោះមិនត្រូវពន្យល់នៅក្នុងទស្សនាទាន នៃសន្តតិកម្ម ឬសិទ្ធិផ្ទាល់ខ្លួនរបស់ក្មួយប្រុសឡើយ។ *រឿងក្តី Yaşa ទល់នឹង ប្រទេសទួគី* កថាខណ្ឌ ៦១ ដល់ ៦៦។

[910] *រឿងក្តី Juan Humberto Sánchez ទល់នឹងប្រទេសហុងឌូរ៉ាស*, សាលក្រម (ការបកស្រាយរបស់សាលក្រមអំពីអញ្ញត្រកម្ម អង្គសេចក្តី និងសំណង) កថាខណ្ឌ ៤៧៖ "(...) ក្នុងកិច្ចដំណើរការនីតិវិធីដើម្បីសម្រេចអំពីការរំលោភសិទ្ធិមនុស្ស ការការពាររបស់រដ្ឋមិនអាចត្រូវបានផ្អែកលើភាពអលទ្ធភាពរបស់អ្នកដាក់ពាក្យបណ្តឹង ក្នុងការចោទប្រកាន់អំពីភស្តុតាងនៅពេលដែលភ័ស្តុតាងនោះ មិនអាចទទួលបានដោយគ្មានកិច្ចសហការណ៍របស់រដ្ឋនោះឡើយ ដូច្នេះភាគី និងជាពិសេសរដ្ឋត្រូវតែផ្តល់ឲ្យតុលាការនូវធាតុផ្សំជាភ័ស្តុតាងចាំបាច់ទាំងអស់"។ ជាក់ស្តែង នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ តុលាការមិនអាចដាក់កាតព្វកិច្ចទៅលើមេធាវីការពារក្តីដើម្បីឲ្យផ្តល់នូវធាតុផ្សំ ជាភស្តុតាង ហើយតុលាការក៏មិនអាចអះអាងឲ្យអនុវត្តដូចគ្នានេះ ដោយបង្កើតនូវការសន្មតទុកជាមុនឡើយ។

៤៣៥. យោងតាមសំអាងហេតុទាំងនេះ ទស្សនទានតាមផ្លូវច្បាប់នៃយន្តការស្តីពីសិទ្ធិមនុស្សថ្នាក់តំបន់ មិនចាំបាច់ផ្តល់ការណែនាំសម្រាប់បណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីព្រហ្មទណ្ឌនានានោះទេ។ ផលប្រយោជន៍ខុសៗគ្នាដែលជាប់ពាក់ព័ន្ធ តម្រូវឱ្យមានការប្រុងប្រយ័ត្ននៅក្នុងការបែងចែកបន្ទុកនៃការបង្ហាញភស្តុតាង។ គ្រប់ករណីទាំងអស់ មុនពេលធ្វើការដកស្រង់ការសន្មតទុកជាមុនមួយពីយុត្តិសាស្ត្រណាមួយរបស់តុលាការមកអនុវត្តនៅក្នុងបរិបទរបស់ អ.វ.ត.ក ត្រូវមានសុភវិនិច្ឆ័យក្នុងការចាត់ទុក បញ្ហាមុខងារគំរូ *ជាច្បាប់* (ការសន្មតទុកជាមុនតាមផ្លូវច្បាប់) ឬក៏ជាការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ។

៤៣៦. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ត្រង់ចំណុចនេះថា អំណាចរបស់ អ.វ.ត.ក ក្នុងការប្រើប្រាស់ការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ កើតចេញពីគោលការណ៍នៃការវាយតម្លៃភស្តុតាងដោយសេរី។ ហេតុដូច្នេះ ការសន្មតទុកជាមុនបែបនេះអាចយកមកអនុវត្តបានដោយកម្រិតទៅតាមការលើកឡើងខាងលើ។ ដោយហេតុថា មានចំណុចពីរដែលមិនអាចបំបែកបាននៅក្នុងការសន្មតទុកជាមុនតាមច្បាប់នោះ ទើបតុលាការត្រូវយកចំណុចនេះមកពិចារណាយ៉ាងពិសេសនៅក្នុងការបង្ហាញអំពីការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ ដែលចំណុចពីរនេះ គឺភាពសមហេតុសមផល និងភាពអាចយល់ដឹងជាមុនបាន។

៤៣៧. មូលដ្ឋាននៃការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ គឺជាសេចក្តីសន្និដ្ឋានដែលមានលក្ខណៈប្រហែល"តាមធម្មជាតិ" បើតាមសញ្ញាណនៃតក្កវិជ្ជា វិទ្យាសាស្ត្រ និងបទពិសោធន៍រួមរបស់មនុស្ស សេចក្តីសន្និដ្ឋាននេះត្រូវបានកើតចេញពីអ្វីដែលកើតឡើងតាមធម្មតានៅក្នុងជីវិតទូទៅ និងចេញពីការពិចារណាទៅលើកត្តាជំរុញនានា ដែលជាធម្មតាធ្វើឱ្យបុគ្គលនានាប្រែប្រួលទៅតាមកាលៈទេសៈជាក់លាក់មួយចំនួន។ ដូច្នេះ បង្ហាញឱ្យឃើញថា ដើម្បីជៀសវាងកុំឱ្យមានការសម្រេចដោយមិនសមស្រប ការសន្មតទុកជាមុនបែបនេះ ត្រូវតែផ្ទុះបញ្ចាំងអំពីច្បាប់ជាជាងផ្ទុះបញ្ចាំងជាករណីពិសេស។ បើពុំដូច្នេះទេ អានុភាពនៃការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិនេះ នឹងប្រែប្រួលអាស្រ័យទៅតាមកាលៈទេសៈដែលកើតចេញពីការសន្មតទុកជាមុនទាំងនេះ។ ជានិច្ចកាល ខ្លឹមសារនៃការសន្មតទុកជាមុនទាំងនេះ គឺជាព្រឹត្តិការណ៍ដែលអាចនឹងកើតឡើង ដែលសំអាងទៅលើអង្គហេតុនានា ប៉ុន្តែមិនសំអាងទៅលើបទដ្ឋានផ្លូវច្បាប់

ឡើយ។ ក្នុងករណីនេះ ការសន្មតទុកជាមុនដែលបានលើកឡើងដោយតុលាការ និងតុលាការពិសេសនៅកម្រិតអន្តរជាតិ អាចមានការជាប់ពាក់ព័ន្ធនឹង អ.វ.ត.ក ដោយមូលហេតុថា ការសន្មតទុកជាមុនទាំងនេះត្រូវបានទាញចេញពីកាលៈទេសៈប្រហាក់ប្រហែលគ្នា ដែលគួរឱ្យជឿជាក់បាន ឬបង្ហាញពីទំនាក់ទំនងជាក់ស្តែង ដែលជាទូទៅត្រូវបានចាត់ទុកថា ជាការពិត។

៤៣៨. បញ្ហាជាប់ពាក់ព័ន្ធនឹងភាពត្រឹមត្រូវតម្រូវជាចាំបាច់ថា ដើម្បីឱ្យការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ អាចបើកសិទ្ធិឱ្យជំទាស់តវ៉ា ឬបដិសេធបាននោះ ត្រូវតែមានការជូនដំណឹងឱ្យបានគ្រប់គ្រាន់ដល់ភាគីទាំងអស់។ ការជូនដំណឹងនេះ មិនតម្រូវឱ្យធ្វើឡើងនោះទេ ប្រសិនបើការសន្មតទុកជាមុន បានឆ្លុះបញ្ចាំងអំពីព្រឹត្តិការណ៍ដែលអាចនឹងកើតមានឡើង ដោយសារអំណះអំណាងដែលមានលក្ខណៈច្បាស់លាស់។ ផ្ទុយទៅវិញ ការសន្មតទុកជាមុនក្នុងដំណាក់កាលចេញសាលក្រមធ្វើឱ្យភាគី មិនបានទទួលការជូនដំណឹងឱ្យបានគ្រប់គ្រាន់ ហើយសិទ្ធិរបស់ខ្លួនត្រូវបានរំលោភដោយសារសាលក្រមនេះនាពេលអនាគត។

៤៣៩. ការពិនិត្យឡើងវិញនូវយុត្តិសាស្ត្ររបស់អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ACHR) បង្ហាញឱ្យឃើញថា ការសន្មតទុកជាមុនទាំងឡាយ ដែលត្រូវបានអនុវត្តដោយតុលាការអន្តរទ្វីបអាមេរិក[911] គឺភាគច្រើនជាការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ។ ដូច្នេះ ការសន្មតទុកជាមុន

[911] នៅក្នុងរឿងក្តីដំបូង តុលាការ IACtHR បានសម្រេចថា "ទាក់ទិននឹង [សន្តតិជន] មានការអះអាងថា មរណភាពរបស់ជនរងគ្រោះ បានបណ្តាលពួកគាត់ទទួលរងនូវការខូចខាតផ្នែកផ្លូវចិត្ត និងការខូចខាតជាក់ស្តែង ហើយបន្ទុកក្នុងការបង្ហាញភស្តុតាង គឺស្ថិតនៅលើភាគីម្ខាងទៀតក្នុងការបង្ហាញថា ការខូចខាតទាំងនោះ ពុំមានអត្ថិភាពឡើយ"។ *រឿងក្តី Aloeboetoe និងជនដទៃទៀត ទល់នឹង Suriname* សាលក្រម (សំណង និងសោហ៊ុយ)" កថាខណ្ឌ ៥៤។ តុលាការបានបន្តបកស្រាយសញ្ញាណនៃសន្តតិជនពីវិធានបញ្ញត្តិទូទៅ ដោយយោងទៅលើវិធានទូទៅនានា ដែលទទួលស្គាល់ដោយសហគមន៍នៃបណ្តាប្រទេសនានា ដែលចង្អុលបង្ហាញថា តុលាការយល់ឃើញថា និយមន័យនៃសន្តតិជន ជាប្រភេទដែលត្រូវបានបង្កើតឡើងដោយច្បាប់អន្តរជាតិ ទោះបីជាពាក្យសនកម្មនៅលើផ្នែករបស់ពួកគាត់ត្រូវបានសន្មតថា ជាបញ្ហាអង្គហេតុក៏ដោយ។ *រឿងក្តី Aloeboetoe និង ជនដទៃទៀត ទល់នឹង Suriname* សាលក្រម (សំណង និងសោហ៊ុយ)", កថាខណ្ឌ៥៤, ៦២, ៧១, ៧៦។ *សូមមើលផងដែរ រឿងក្តី Castillo–Páez ទល់នឹង ប្រទេសប៉េរូ* សាលក្រមរបស់តុលាការ IACtHR (សំណង និងសោហ៊ុយ)" ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៨៦ ដល់ ៩០។ នៅ អ.វ.ត.ក សិទ្ធិរបស់សន្តតិជន ក្នុងការបន្តបណ្តឹងរដ្ឋប្បវេណី និងសន្តតិកម្មបែបនេះត្រូវបានកំណត់ដោយច្បាប់កម្ពុជា។

ទាំងនោះតម្រូវទៅតាមរឿងក្តីជាក់លាក់មួយចំនួន ដោយហេតុថាការសន្និដ្ឋាននេះ បានឆ្លុះបញ្ចាំងពីទំនាក់ទំនងជាក់ស្តែង ដែលជាទូទៅត្រូវបានទទួលស្គាល់ថា ជាការពិត។ ដូច្នេះ តុលាការនេះយល់ឃើញថា ពុំតម្រូវឱ្យមានភស្តុតាងក្នុងការទទួលស្គាល់ថា ជនរងគ្រោះបានទទួលរងព្យសនកម្មផ្លូវចិត្តនោះឡើយ "ពីព្រោះ ការដែលថា បុគ្គលណាមួយដែលទទួលរងពីអំពើឈ្លានពាន និងការរំលោភបំពាន (ដូចជា ការឃុំឃាំងដោយខុសច្បាប់ ការប្រព្រឹត្តិអំពើឃោរឃៅ និងអមនុស្សធម៌ ការធ្វើឱ្យបាត់ខ្លួន និងការសម្លាប់) នឹងទទួលរងការឈឺចាប់ផ្លូវចិត្តនោះ គឺជាលក្ខណៈធម្មជាតិរបស់មនុស្ស"[912]។ ដូចគ្នានេះដែរ តុលាការនេះបានលើកឡើងដោយស៊ីសង្វាក់គ្នាថា "អាចសន្មតបានថា ឪពុកម្តាយបានទទួលរងការឈឺចាប់ផ្លូវចិត្ត ដែលបណ្តាលមកពីការបាត់បង់អាយុជីវិតកូនរបស់ខ្លួនដោយអំពើព្រៃផ្សៃ ពីព្រោះ នេះជាការពិតដែលមនុស្សគ្រប់រូបមានអារម្មណ៍ឈឺចាប់ ចំពោះការធ្វើបាបមកលើកូនរបស់ខ្លួន"[913]។ នៅក្នុងករណីជាក់លាក់មួយចំនួន ការសន្មតទុកជាមុននៃព្យសនកម្មផ្លូវចិត្ត ត្រូវបានពន្លាតរហូតទៅដល់កូនរបស់ជនរងគ្រោះផ្ទាល់[914] ប៉ុន្តែ ចំពោះបងប្អូនបង្កើតមិនបានពន្លាតខ្លាំងណាស់ណានោះទេ[915]។ ការសម្រេចដែលមានលក្ខណៈទូលំទូលាយជាងនេះ បានបង្កើត

[912] *រឿងក្តី* Aloeboetoe *និងជនដទៃទៀត ទល់នឹង* Suriname, សាលក្រម (សំណង និងសោហ៊ុយ), កថាខណ្ឌ ៥២។ *សូមប្រៀបធៀប រឿងក្តី the white van* សាលក្រម (សំណង និងសោហ៊ុយ), កថាខណ្ឌ ១០៦។ *រឿងក្តី Castillo–Páez ទល់នឹង ប៉េរូ*, សាលក្រម (សំណង និងសោហ៊ុយ), កថាខណ្ឌ ៨៦។

[913] *រឿងក្តី* Aloeboetoe *និងជនដទៃទៀត ទល់នឹង* Suriname សាលក្រម (សំណង និងសោហ៊ុយ) កថាខណ្ឌ ៧៦។ *រឿងក្តី* Castillo–Páez *ទល់នឹង ប៉េរូ* សាលក្រម (សំណង និងសោហ៊ុយ) កថាខណ្ឌ ៨៨។ *រឿងក្តី the white van* សេចក្តីសម្រេច (សំណង និងសោហ៊ុយ) កថាខណ្ឌ ១០៨។ *រឿងក្តី Loayza-Tamayo ទល់នឹង ប៉េរូ* សាលក្រមរបស់តុលាការ IACtHR (សំណង និងសោហ៊ុយ) ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ កថាខណ្ឌ ១៤២។ *រឿងក្តីGarrido និង Baigorria ទល់នឹង អាហ្សង់ទីន* សេចក្តីសម្រេច (សំណង និងសោហ៊ុយ)" ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ១៩៩៨ កថាខណ្ឌ ៦២។

[914] *រឿងក្តី Loayza-Tamayo ទល់នឹង ប៉េរូ* សេចក្តីសម្រេច (សំណង និងសោហ៊ុយ), កថាខណ្ឌ ១៤០។ *រឿងក្តី the white van* សេចក្តីសម្រេច (សំណង និងសោហ៊ុយ), កថាខណ្ឌ ១០៨។

[915] *រឿងក្តី Loayza-Tamayo ទល់នឹង ប្រទេសប៉េរូ និងនៅក្នុងរឿងក្តី "Street Children"* តុលាការ IACtHR បានសម្រេចថា "យើងអាចសន្មតថា មរណភាពរបស់បុគ្គលមួយរូប បង្កឱ្យមានព្យសនកម្មមិនមែនជាប្រាក់កាសដល់សាច់ញាតិរបស់គាត់"។ *រឿងក្តី Villagrán Morales ទល់នឹង* Guatemala *(រឿងក្តី "Street Children")* សេចក្តីសម្រេចរបស់តុលាការ IACtHR (សំណង និងសោហ៊ុយ) ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៦៨។ *រឿងក្តី Loayza-Tamayo*

ឱ្យមានការសន្មតទុកជាមុននៃការឈឺចាប់ផ្លូវចិត្តរបស់សមាជិកគ្រួសារជិតស្និទ្ធបំផុត ជាពិសេស អ្នកដែលមានទំនាក់ទំនងស្និទ្ធស្នាលបំផុតជាមួយជនរងគ្រោះដែលបាត់បង់ជីវិត ឬបាត់ខ្លួន[916]។

៤៤០. ក្នុងពេលថ្មីៗនេះ ក្នុងការសង្ខេបយុត្តិសាស្ត្ររបស់ខ្លួន តុលាការអន្តរទ្វីបអាមេរិក[917] បានសម្រេចថា នៅពេលយកការសន្មតទុកជាមុនតាមច្បាប់ ដែលទទួលរងការជំទាស់ (presumption *iuris tantum*/legal rebuttable presumption) មកអនុវត្តនោះ គឺបង្ហាញឱ្យឃើញថា មានការរំលោភលើបូរណភាពផ្លូវចិត្ត និងសីលធម៌របស់សាច់ញាតិផ្ទាល់របស់ជនរងគ្រោះ ដូចជា ឪពុកម្តាយ កូនប្រុសស្រី ប្តីប្រពន្ធ និងអ្នករស់នៅជាអនីតិសង្វាស នៅពេលដែលបញ្ហានេះបានឆ្លើយតបទៅនឹងកាលៈទេសៈជាក់លាក់នៃរឿងក្តីនានា ដូចជានៅក្នុងករណី

---

*ទល់នឹង ប្រទេសប៉េរូ* សេចក្តីសម្រេច (សំណង និងសោហ៊ុយ), កថាខណ្ឌ ១៤៣។ *រឿងក្តី the white van,* តុលាការយល់ឃើញថា "វាចាំបាច់ត្រូវពិចារណាអំពីកម្រិតនៃទំនាក់ទំនង និងក្តីស្រឡាញ់ ដែលមានរវាង (ជនរងគ្រោះ និងសាច់ញាតិរបស់គាត់)"។ *រឿងក្តី the white van,* សេចក្តីសម្រេច (សំណង និងសោហ៊ុយ) កថាខណ្ឌ ១០៩។ ស្រដៀងគ្នានេះដែរ នៅក្នុង*រឿងក្តី Garrido និង Baigorria ទល់នឹង អាហ្សង់ទីន* តុលាការយល់ឃើញថា សាច់ញាតិមិនអាចបង្ហាញថា មាន"ទំនាក់ទំនងនៃក្តីស្រឡាញ់"ជាមួយជនរងគ្រោះដោយផ្ទាល់។ *រឿងក្តី Garrido និង Baigorria ទល់នឹង ប្រទេសអាហ្សង់ទីន* សេចក្តីសម្រេច (សំណង និងសោហ៊ុយ), កថាខណ្ឌ ៦៣ ដល់ ៦៤។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការមិនបានបដិសេធចោលសំណងជាលក្ខណៈសាច់ញាតិទេ ប៉ុន្តែគ្រាន់តែកាត់បន្ថយសំណងដោយផ្តល់ជាសំណងនិមិត្តរូបវិញ ដែលវាហាក់ដូចជាទទួលស្គាល់ចំណងមនោសញ្ចេតនាដែលបន្សល់ទុករវាងសាច់ញាតិ។ ស្រដៀងគ្នានេះដែរ ទាក់ទងនឹងសំណងជាប្រាក់កាស តុលាការរកឃើញនូវព្យសនកម្មទូទៅមួយលើកេរ្តិ៍មរតករបស់ក្រុមគ្រួសារ ដែលបណ្តាលមកពីមរណភាពរបស់សាច់ញាតិ។ *រឿងក្តី the white van,* សេចក្តីសម្រេច (សំណង និងសោហ៊ុយ), កថាខណ្ឌ ៩៩។

[916] *រឿងក្តី the white van,* សេចក្តីសម្រេច (សំណង និងសោហ៊ុយ) កថាខណ្ឌ ១០៦។ *រឿងក្តី Juan Humberto Sánchez ទល់នឹង ហុងឌូរ៉ាស* សេចក្តីសម្រេចរបស់តុលាការ IACtHR (អញ្ញត្រកម្ម អង្គសេចក្តី សំណង និង សោហ៊ុយ") ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៣ កថាខណ្ឌ ១៥៦។

[917] *រឿងក្តី Valle-Jaramillo និងជនដទៃទៀត ទល់នឹង Colombia* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ) ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ កថាខណ្ឌ ១១៩។ *រឿងក្តី Kawas-Fernández ទល់នឹង ប្រទេស ហុងឌូរ៉ាស* សេចក្តីសម្រេចរបស់តុលាការ IACtHR (អង្គសេចក្តី សំណង និងសោហ៊ុយ)" ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៩, កថាខណ្ឌ ១២៨ ដល់ ១២៩។

នៃការសម្លាប់រង្គាល[918] ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[919] និងការសម្លាប់ក្រៅច្បាប់[920]។ ទាក់ទងនឹងបញ្ហាសាច់ញាតិផ្ទាល់បែបនេះ រដ្ឋមានកាតព្វកិច្ចជំទាស់ទៅនឹងការទាមទាររបស់ពួកគេ។

៤៤១. នៅក្នុងករណីផ្សេងទៀត តុលាការអន្តរទ្វីបអាមេរិកត្រូវតែវិភាគ ថាតើភស្តុតាងនៅក្នុងកំណត់ត្រាបង្ហាញថា មានការរំលោភសិទ្ធិរបស់ជនរងគ្រោះមិនផ្ទាល់ក្នុងការទទួលបានប្រព្រឹត្តកម្មមនុស្សធម៌ ដែរ ឬយ៉ាងណានោះ ដោយមិនគិតពីបញ្ហាថា ជនរងគ្រោះមិនផ្ទាល់នេះ គឺជាសាច់ញាតិ ឬមិនមែនជាសាច់ញាតិរបស់ជនរងគ្រោះផ្ទាល់នៅក្នុងរឿងក្តីនេះនោះទេ។ ទាក់ទងនឹងជនទាំងឡាយដែលតុលាការមិនបានសន្និដ្ឋានថា សិទ្ធិទទួលបានប្រព្រឹត្តកម្មមនុស្សធម៌របស់ខ្លួនត្រូវបានរំលោភបំពាន ដោយសារតែពួកគេមិនមែនជាសាច់ញាតិផ្ទាល់នោះ ទើបតុលាការត្រូវវាយតម្លៃ ថាតើមានចំណងសាច់ញាតិជិតស្និទ្ធបំផុតរវាងពួកគេ និងជនរងគ្រោះផ្ទាល់ ដែរ ឬយ៉ាងណា។ តុលាការនេះ ក៏ត្រូវវាយតម្លៃផងដែរ ថាតើជនរងគ្រោះមិនផ្ទាល់បានចូលរួមយ៉ាងសកម្ម នៅក្នុងការស្វែងរកយុត្តិធម៌ក្នុងរឿងក្តីជាក់លាក់នេះដែរ ឬយ៉ាងណា[921]

---

[918] *រឿងក្តី "Mapiripán Massacre" ទល់នឹងប្រទេស កូឡុំប៊ី* សេចក្តីសម្រេចរបស់តុលាការ IACtHR (អង្គសេចក្តី សំណង និងសោហ៊ុយ)" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៥ កថាខណ្ឌ ១៤៦។ *រឿងក្តី Ituango Massacres ទល់នឹងប្រទេសកូឡុំប៊ី* សេចក្តីសម្រេចរបស់តុលាការ IACtHR (អញ្ញត្រកម្ម អង្គសេចក្តី សំណង និង សោហ៊ុយ) ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ២៦២។

[919] *រឿងក្តី Blake ទល់នឹង Guatemala* សេចក្តីសម្រេច (អង្គសេចក្តី) កថាខណ្ឌ១១៤។ *រឿងក្តី Heliodoro Portugal ទល់នឹង ប្រទេស ប៉ាណាម៉ា* សេចក្តីសម្រេចរបស់តុលាការ IACtHR សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ) កថាខណ្ឌ ១៧៤ ដល់ ១៧៥។ *រឿងក្តី Goiburú និងជនដទៃទៀត ទល់នឹង ប៉ារ៉ាហ្គាយ* សេចក្តីសម្រេចរបស់តុលាការ IACtHR (អង្គសេចក្តី សំណង និងសោហ៊ុយ)" ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ៩៦ ដល់៩៧។

[920] *រឿងក្តី La Cantuta ទល់នឹង ប្រទេស ប៉េរូ* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ)" ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦, កថាខណ្ឌ ២១៨។

[921] *រឿងក្តី Bámaca Velásquez ទល់នឹង Guatemala* សេចក្តីសម្រេច (អង្គសេចក្តី) កថាខណ្ឌ ១៦៣។ *រឿងក្តី Heliodoro-Portugal ទល់នឹង ប្រទេស ប៉ាណាម៉ា* (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ), កថាខណ្ឌ ១៦៣។ *រឿងក្តី Valle-Jaramillo និងជនដទៃទៀត ទល់នឹង ប្រទេស កូឡុំប៊ី* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ)" កថាខណ្ឌ ១១៩។

ឬថាតើពួកគេបានទទួលរងនូវការឈឺចាប់ដែលបណ្តាលមកពីអង្គហេតុនៃរឿងក្តីនេះ ឬដោយសារអំពើសកម្ម ឬអកម្មជាបន្តបន្ទាប់របស់អាជ្ញាធររដ្ឋដែលជាប់ពាក់ព័ន្ធទៅនឹងឧប្បត្តិហេតុទាំងនេះ ដែរ ឬយ៉ាងណានោះ[922]។

៤៤២. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅក្នុងរឿងក្តីភាគច្រើនដែលបានអនុវត្តការសន្មតទុកជាមុនទាក់ទងនឹងអត្ថិភាពនៃព្យសនកម្មនោះ តុលាការអន្តរទ្វីបអាមេរិកបានសំអាងបន្ថែមទៅលើកត្តាដទៃទៀតដែលគាំទ្រដល់ការសន្មតទុកជាមុននេះ ដូចជា ចម្លើយរបស់ជនរងគ្រោះដែលទទួលបានដោយផ្ទាល់ ឬតាមសារណា[923] ការទទួលស្គាល់របស់រដ្ឋចំពោះការទទួលខុសត្រូវ[924]ទោះបីជាក្រោយមកត្រូវបានដកចេញទៅវិញក្តី[925] ការទទួលស្គាល់អង្គហេតុតាមការសន្មតពីសំណាក់រដ្ឋ (ដោយគ្មានការជំទាស់តវ៉ា)[926] រឿងក្តីមុនៗរបស់

---

[922] *រឿងក្តី Blake ទល់នឹង Guatemala* សេចក្តីសម្រេច (អង្គសេចក្តី) កថាខណ្ឌ ១១៤។ *រឿងក្តី Heliodoro Portugal និងជនដទៃទៀត ទល់នឹង ប៉ាណាម៉ា* សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ) កថាខណ្ឌ ១៦៣។ *រឿងក្តី Valle-Jaramillo និងជនដទៃទៀត កូឡុំប៊ី* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ) កថាខណ្ឌ ១១៩។

[923] *រឿងក្តី Kawas-Fernández ទល់នឹង ហុងឌូរ៉ាស* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ), កថាខណ្ឌ១៣១ ដល់ ១៣៨។ *រឿងក្តី Valle-Jaramillo និងជនដទៃទៀត ទល់នឹង កូឡុំប៊ី* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ) កថាខណ្ឌ១២១។ *រឿងក្តី Caracazo ទល់នឹង វេណេស៊ុយអេឡា* សេចក្តីសម្រេច (សំណង និង សោហ៊ុយ)", កថាខណ្ឌ ៦៣។

[924] *រឿងក្តី Aloeboetoe និងជនដទៃទៀត ទល់នឹង Suriname* សេចក្តីសម្រេច (សំណង និងសោហ៊ុយ), កថាខណ្ឌ ៥២។ *រឿងក្តី Valle-Jaramillo និងជនដទៃទៀត ទល់នឹង កូឡុំប៊ី* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ), កថាខណ្ឌ ១១៥។

[925] *រឿងក្តី Caracazo ទល់នឹង វេណេស៊ុយអេឡា* សេចក្តីសម្រេច (សំណង និងសោហ៊ុយ)", កថាខណ្ឌ ៥២ (អនុលោមតាមគោលការណ៍ *estoppel* (...) ការទទួលស្គាល់នូវអង្គហេតុដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង និងការទទួលស្គាល់នូវការទទួលខុសត្រូវទាក់ទនឹងអង្គហេតុទាំងនោះ ដែលលើកឡើងដោយរដ្ឋ មានសារៈសំខាន់។

[926] *រឿងក្តី Valle-Jaramillo និងជនដទៃទៀត ទល់នឹងកូឡុំប៊ី* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ)", កថាខណ្ឌ ១១៥។ *រឿងក្តី Caracazo ទល់នឹង វេណេស៊ុយអេឡា* សេចក្តីសម្រេច (សំណង និងសោហ៊ុយ), កថាខណ្ឌ ៥៤។

តុលាការ[927] លិខិតធ្វើសច្ចាប្រណិធាន ឬរបាយការណ៍អ្នកជំនាញឯកជន[928] សេចក្តីប្រកាសរបស់ជនរងគ្រោះដែលបានចុះហត្ថលេខាដោយមានវត្តមានរបស់សារការី[929] និងឯកសារភស្តុតាងផ្សេងៗទៀត។

៤៤៣. ទោះបីជានៅក្នុងរឿងក្តីដែលមានការលើកឡើងអំពី*ការសន្មតទុកជាមុនតាមច្បាប់* ប៉ុន្តែដោយសារ រដ្ឋបានជំទាស់ទៅនឹងការសម្រេចណាមួយទាក់ទងទៅនឹងការរំលោភបំពាន ដែលត្រូវបានចោទឡើងក៏ដោយ ក៏តុលាការបានបន្តពិនិត្យភស្តុតាងដែលបានបង្ហាញដោយអ្នកតំណាងរបស់រដ្ឋនោះដែរ[930]។ នៅក្នុងការពិចារណា ថាតើមានទំនាក់ទំនងជិតស្និទ្ធ ដែរ ឬយ៉ាងណានោះ តុលាការបានពិនិត្យភស្តុតាងដែលបានផ្តល់ឱ្យ និងបានសួរសំណួរមួយចំនួន ដូចជាៈ តើមានការប្រាស្រ័យទាក់ទងគ្នាជាប្រចាំ ដែរ ឬយ៉ាងណា ឬតើមានបានផ្តល់ការថែទាំ ដែរ ឬយ៉ាងណា ឬតើមានការឈឺចាប់ផ្លូវចិត្ត ដែរ ឬយ៉ាងណា ឬតើមានការគាំទ្រផ្នែកហិរញ្ញវត្ថុ ដែរ ឬយ៉ាងណា[931] តុលាការនេះបានតម្រូវថា "យ៉ាងហោចណាស់ ត្រូវផ្តល់ភស្តុតាងតាមរយៈសក្ខីកម្ម"[932]។ ទោះបីជាមានចរិតលក្ខណៈ "ច្បាប់" មិនរឹងមាំក៏ដោយ ក៏យុត្តិសាស្ត្រនេះបង្ហាញឱ្យឃើញថា ការសន្មតអំពីព្យសនកម្មត្រូវបានអនុវត្ត*តាមព្រឹត្តិហេតុ*ថា ជាការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ ដែលការសន្មតបែបនេះមានអានុភាពតែក្នុងករណីដែលភាគីដទៃ

[927] *រឿងក្តី Castillo–Páez ទល់នឹង ប្រទេសប៉េរូ* សេចក្តីសម្រេច (សំណង និងសោហ៊ុយ), កថាខណ្ឌ ៨៦។ *រឿងក្តី the white van,* សេចក្តីសម្រេច (សំណង និងសោហ៊ុយ)", កថាខណ្ឌ ១០៨។

[928] *រឿងក្តី Castillo–Páez ទល់នឹង ប្រទេស ប៉េរូ សេចក្តីសម្រេច* (សំណង និងសោហ៊ុយ), កថាខណ្ឌ ៣៣។ *រឿងក្តី Valle-Jaramillo និងជនដទៃទៀត ទល់នឹង ប្រទេសកូឡុំប៊ី* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ), កថាខណ្ឌ ១២៤។

[929] *រឿងក្តី Castillo–Páez ទល់នឹង ប្រទេស ប៉េរូ សេចក្តីសម្រេច* (សំណង និងសោហ៊ុយ), កថាខណ្ឌ ៨១។

[930] *រឿងក្តី Kawas-Fernández ទល់នឹង ប្រទេស ហុងឌូរ៉ាស* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ), កថាខណ្ឌ ១៣០ ដល់ ១៣៩។

[931] *រឿងក្តី Kawas-Fernández ទល់នឹង ប្រទេស ហុងឌូរ៉ាស* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ), កថាខណ្ឌ ១៣០ ដល់ ១៣៩។

[932] *រឿងក្តី Kawas-Fernández ទល់នឹង ប្រទេស ហុងឌូរ៉ាស* សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ), កថាខណ្ឌ ១៣០ ដល់ ១៣៩។

ទៀតមិនបានជំទាស់តែប៉ុណ្ណោះ។

៤៤៤. ជាសរុប យុត្តិសាស្ត្រដែលអនុវត្តតាមអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ACHR) បង្ហាញថា នៅពេលដែលមានបទដ្ឋាននៃការអនុវត្តការសន្មតទុកជាមុន ទាក់ទងនឹងវិសាលភាពនៃសញ្ញាណជនរងគ្រោះ នោះសេចក្តីសន្និដ្ឋានជាក់លាក់ មិនត្រូវបានចាត់ទុកថា ជាច្បាប់នោះទេ ប៉ុន្តែ ត្រូវបានចាត់ជាការអះអាងផ្នែកអង្គហេតុ ដែលទាញចេញពីការពិចារណាទៅលើកាលៈទេសៈនៃរឿងក្តី[933]។ ការសន្មតទុកជាមុនទាំងនេះអាចជាជំនួយសម្រាប់ អ.វ.ត.ក ដោយសារថា ការសន្មតទាំងនេះបានបង្ហាញពីភាពទូទៅនៃព្រឹត្តិការណ៍អាចនឹងកើតមានឡើងជាក់លាក់មួយចំនួន នៅក្នុងកាលៈទេសៈណាមួយ។ ប៉ុន្តែ អ.វ.ត.ក ប្រើប្រាស់ឆន្ទានុសិទ្ធិផ្ទាល់ខ្លួន ក្នុងការបង្កើតការសន្មតទុកជាមុនទៅតាមបរិបទជាក់ស្តែងនៃរឿងក្តីនៅចំពោះមុខ។

## ៦.ក.៥.ការវាយតម្លៃទៅលើការសន្មតទុកជាមុនដែលអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង

៤៤៥. ដោយសារតែមិនមានការប្រកាសឱ្យបានច្បាស់លាស់ ចំពោះការបង្កើតសញ្ញាណថ្មីតាមផ្លូវច្បាប់ស្របតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងដោយមិនមានការពន្យល់អំពីមូលដ្ឋានគតិយុត្តិ និងមិនមានសំអាងហេតុនៃការមិនពន្យល់នោះ អង្គជំនុំជម្រះតុលាការកំពូលធ្វើការសន្មតលើកថាខណ្ឌ ៦៤៣ នៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងថា ជាការបញ្ជាក់អំពីការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិ ហើយនឹងបន្តវាយតម្លៃអំពីការសន្មតទុកជាមុននេះ។

៤៤៦. ការជំទាស់តវ៉ានៅទីនេះ គឺពាក់ព័ន្ធទៅនឹងជនរងគ្រោះមិនផ្ទាល់ដែលមិនមែនជាសមាជិក "គ្រួសារផ្ទាល់" ដែលប្រឈមមុខនឹងលក្ខខណ្ឌតម្រូវឱ្យបង្ហាញអំពី"ចំណងពិសេសនៃក្តី

---

[933]ដូចដែលបានបញ្ជាក់ដោយតុលាការ IACtHR ដោយពាក់ព័ន្ធទៅនឹងសំណងចំពោះព្យសនកម្មផ្លូវចិត្ត៖ "តុលាការពិចារណាថា យុត្តិសាស្ត្រអាចយកមកធ្វើជាការណែនាំមួយដើម្បីបង្កើតជាគោលការណ៍នៅក្នុងបញ្ហានេះទោះបីជាយុត្តិសាស្ត្រមិនអាចយកមកប្រើជាលក្ខណៈវិនិច្ឆ័យដាច់ខាតមួយ ដោយសារតែលក្ខណៈពិសេសនៃរឿងក្តីនីមួយៗត្រូវតែពិចារណា"។ *រឿងក្តី the white van* សេចក្តីសម្រេច (សំណង និងសោហ៊ុយ), កថាខណ្ឌ ១០៤។

ស្រឡាញ់ ឬអ្នករស់នៅក្នុងបន្ទុករបស់ជនរងគ្រោះផ្ទាល់ សម្រាប់ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន។

៤៤៧. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា លក្ខណៈវិនិច្ឆ័យនៃចំណងពិសេសនៃក្តីស្រឡាញ់ ឬការរស់នៅក្នុងបន្ទុកដែលជាប់ទាក់ទងរវាងអ្នកដាក់ពាក្យសុំ ជាមួយនឹងជនរងគ្រោះផ្ទាល់ គឺគ្របដណ្តប់ទៅលើសារៈសំខាន់នៃទំនាក់ទំនងផ្ទាល់ខ្លួនទៅវិញទៅមក ហើយការខូចខាត គឺជាលទ្ធផលនៃព្យសនកម្មដែលប៉ះពាល់ទៅលើជនរងគ្រោះមិនផ្ទាល់។ លក្ខណៈវិនិច្ឆ័យនេះអនុវត្តចំពោះមនុស្សគ្រប់រូបដែលបានអះអាងថា ជាជនរងគ្រោះមិនផ្ទាល់ ទោះបីជាសមាជិកគ្រួសារក្តី ឬមិនមែនជាសមាជិកគ្រួសារក្តី ដោយហេតុថា ប្រសិនបើ មិនមានចំណងទាក់ទងពីមុនដែលចងភ្ជាប់ម្ចាស់បណ្តឹងទាមទារសំណង តាមផ្លូវមនោសញ្ចេតនា ញាតិលោហិត ឬសេដ្ឋកិច្ច ជាមួយនឹងជនរងគ្រោះផ្ទាល់ទេនោះ ព្យសនកម្មដែលបណ្តាលមកពីការប្រព្រឹត្តបទល្មើសនេះ មិនអាចកើតមានចំពោះម្ចាស់បណ្តឹងទាំងនេះបានទេ។ ដោយសារតែពាក្យពេចន៍បែបនេះអាចត្រូវបានបង្ហាញជាលើកដំបូង នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[934] ទើបលក្ខណៈវិនិច្ឆ័យ ដែលបានបញ្ជាក់ក្នុងសាលក្រមនេះ គឺជាប់ទាក់ទងទៅនឹងសញ្ញាណនៃព្យសនកម្មនៅក្នុងអត្ថន័យនៃមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ដែលអាចអនុវត្តចំពោះជនរងគ្រោះមិនផ្ទាល់[935]បាន។ ហេតុដូច្នេះ ការប្រើប្រាស់លក្ខខណ្ឌតម្រូវនេះ គឺ

---

[934] *ប៉ុន្តែសូមមើល* គណៈកម្មាធិការស្តីពីសំណងចំពោះជនរងគ្រោះក្នុងសង្គ្រាម សមាគមន៍ច្បាប់អន្តរជាតិ របាយការណ៍កិច្ចប្រជុំ Rio 2008 "សេចក្តីព្រាងសេចក្តីប្រកាសគោលការណ៍ច្បាប់អន្តរជាតិស្តីពីសំណងសម្រាប់ជនរងគ្រោះក្នុងសង្គ្រាម (បញ្ហាចាំបាច់)" ទំព័រ ៧ ("ផ្អែកតាមវិធានទូទៅ បុគ្គលដែលរងការប៉ះពាល់ដោយផ្ទាល់ នឹងត្រូវចាត់ទុកថាជាជនរងគ្រោះប៉ុណ្ណោះ។ ការលើកឡើងនេះ មិនបានបដិសេធថា នាពេលអនាគត បុគ្គលដែលមាន*ចំណងទំនាក់ទំនងពិសេស* ដូចជាចំណងគ្រួសារ ឬអារម្មណ៍ខ្លាំងក្លា ចំពោះបុគ្គលដែលទទួលរងព្យសនកម្មដោយផ្ទាល់ អាចត្រូវបានចាត់ទុកថាជាជនរងគ្រោះ" (សេចក្តីបញ្ជាក់បន្ថែម) <http://www.ila-hq.org/en/committees/index.cfm/cid/1018>។

[935] *សូមមើលផងដែររឿងក្តី Lubanga*, សំណុំរឿងលេខ ICC-01/04-01/06-1813, "សំណៅដែលកោសលុបនៃ 'សេចក្តីសម្រេចស្តីពី 'ជនរងគ្រោះមិនផ្ទាល់''", អង្គជំនុំជម្រះសាលាដំបូង I, ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៩, កថាខណ្ឌ ៥០ ("អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICC បានសម្រេចថា ទំនាក់ទំនងជិតស្និទ្ធផ្ទាល់ខ្លួនរវាងឪពុកម្តាយនិងកូន គឺជាបុរេលក្ខខណ្ឌក្នុងការចូលរួមជាក្នុងនាមជាជនរងគ្រោះមិនផ្ទាល់", ដកស្រង់ចេញពី*រឿងក្តី Lubanga*, "សាលដីកា

ត្រឹមត្រូវតាមផ្លូវច្បាប់ និងអាចយល់ដឹងជាមុនបាន ដូចគ្នាទៅនឹងលក្ខខណ្ឌតម្រូវឱ្យបង្ហាញព្យសនកម្ម ដែលត្រូវតែអាចយល់ដឹងជាមុនបាន ចំពោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។ អាស្រ័យហេតុនេះ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលលើកឡើងពីកំហុសអង្គច្បាប់ដោយសារភាពមិនអាចយល់ដឹងជាមុន ទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវនៃ"ចំណងពិសេសនៃក្តីស្រលាញ់ ឬការរស់នៅក្នុងបន្ទុក" ត្រូវបានបដិសេធចោល។

៤៤៨. ជាជម្រើសមួយទៀត បញ្ហាដែលបានចោទឡើងជាអង្គហេតុនោះ គឺថា តើអ្នកដាក់ពាក្យសុំមួយចំនួនអាចត្រូវបានសន្មតថា មានចំណងពិសេសនៃក្តីស្រឡាញ់ ឬជាអ្នករស់នៅក្នុងបន្ទុករបស់ជនរងគ្រោះផ្ទាល់ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ចំណងនៃក្តីស្រឡាញ់ និងការរស់នៅក្នុងបន្ទុក គឺជាឥទ្ធិពលដែលមានជាធម្មតានៅក្នុងចំណោមសមាជិកគ្រួសារជិតស្និទ្ធបំផុត។ អាស្រ័យហេតុនេះ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការឃុំឃាំងក្នុងពន្ធនាគារ ការធ្វើទារុណកម្ម និងការសម្លាប់ជាយថាហេតុនូវសមាជិកគ្រួសារណាម្នាក់ អាចនាំឱ្យមានការឈឺចាប់ ប៉ះទង្គិចផ្លូវចិត្ត និងប្រភេទនៃព្យសនកម្មដទៃទៀតដែលកើតឡើងចំពោះសមាជិកគ្រួសារជិតស្និទ្ធបំផុត ដូចជា ការបាត់បង់ផ្នែកហិរញ្ញវត្ថុជាដើម។ សេចក្តីសន្និដ្ឋាននេះមានការគាំទ្រដោយភស្តុតាងដែលមាននៅក្នុងរឿងក្តីនេះ ដោយសុភវិនិច្ឆ័យ និងដោយការយល់ឃើញ ដែលមានភស្តុតាងជាសំអាងតាមតុលាការអាមេរិកស្តីពីសិទ្ធិមនុស្ស (ACHR) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)[936]។ ហេតុដូច្នេះ គឺជាការត្រឹមត្រូវ ឬ

---

ស្តីពីបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ស្តីពីការចូលរួមរបស់ជនរងគ្រោះនៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨", កថាខណ្ឌ ៣២)។

[936] *សូមមើលឧទា. ស្ថានភាពនៅ Darfur, ប្រទេសស៊ូដង់, ក្នុងរឿងក្តីរដ្ឋអាជ្ញា ទល់នឹង Bahar Idriss Abu Garda*, សំណុំរឿងលេខ ICC-02/05-02/09-255, សេចក្តីសម្រេចស្តីពីបណ្តឹងលេខ a/0655/09, a/0656/09, a/0736/09 ដល់ a/0747/09, និង a/0750/09 to a/0755/09 សុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងដំណាក់កាលបុរេជំនុំជម្រះនៃរឿងក្តីនេះ, អង្គបុរេជំនុំជម្រះ I (ចៅក្រមមួយរូបគត់), ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១០, កថាខណ្ឌ ២៨, ៣០ (ទាក់ទងនឹង"មីងមា, បងប្អូនជីដូនមួយ, ក្មួយប្រុងស្រី, កូនប្រុសរបស់ម្តាយមីង និងមិត្តភ័ក្តស្និទ្ធស្នាលរបស់ទាហាន រក្សាសន្តិសុខដែលបានទទួលមរណភាព", "ចៅក្រមមួយរូបបានពិចារណាថា ដើម្បីទទួលស្គាល់ជាជនរងគ្រោះនៅក្នុង កិច្ចដំណើរការនីតិវិធីចំពោះមុខតុលាការ, ពាក្យសុំរបស់សមាជិកគ្រួសារសាច់ញាតិផ្ទាល់របស់អ្នកស្លាប់ជាជនរងគ្រោះ ជាធម្មតាតម្រូវឱ្យមានព័ត៌មាន

សមហេតុផល ក្នុងការមិនដាក់បន្ទុកទៅលើគ្រួសារសាច់ញាតិផ្ទាល់ឱ្យបង្ហាញភស្តុតាងអំពីព្យសនកម្ម បន្ទាប់ពីបានកំណត់ និយមន័យនៃគ្រួសារសាច់ញាតិផ្ទាល់បានច្បាស់លាស់ហើយ និងបានជូនដំណឹងដល់ភាគីនោះ។

៤៤៩. ទាក់ទងទៅនឹងវិសាលភាពនៃការសន្មតទុកជាមុនអំពីព្យសនកម្ម ជាការសមហេតុសមផល ក្នុងការកំណត់និយមន័យនៃគ្រួសារសាច់ញាតិផ្ទាល់ ដោយគិតអំពីប្រភេទព្យសនកម្មដែលទាមទារនៅក្នុងបរិបទនៃចំណងគ្រួសារក្នុងសង្គមកម្ពុជា។ ក្នុងករណីនេះ អ្នកជំនាញមួយរូបដែលបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូងបានផ្តល់សក្ខីកម្មថា ជាទូទៅ គ្រួសារក្នុងសង្គមកម្ពុជារស់នៅជិតស្និទ្ធនឹងគ្នា និងពឹងអាស្រ័យគ្នាទៅវិញទៅមកដែលជាទូទៅបង្កើតបានជាចំណងទាក់ទងដ៏រឹងមាំបែបនេះ។ គ្រួសារមិនមែនរាប់បញ្ចូលត្រឹមតែប្តីប្រពន្ធ និងកូនប៉ុណ្ណោះទេ ប៉ុន្តែ រាប់បញ្ចូលទាំង"សមាជិកផ្សេងទៀតដែរ ដូចជា ឪពុកម្តាយចាស់ជរា" ឬ "បងប្អូនបង្កើត និងក្រុមគ្រួសាររបស់ពួកគេ" ឬ"ជីដូនជីតា បងប្អូនជីដូនមួយ ម្តាយមីង និងឪពុកមា"[937]។ នៅក្នុងវប្បធម៌នៃសង្គមកម្ពុជា មានប្រពៃណីគោរពបូជា និងការគោរពសមាជិកគ្រួសារដែលមានវ័យចាស់។ ក្នុងកាលៈទេសៈភាគច្រើន មនុស្សដែលមានវ័យចាស់ជាងត្រូវធ្វើជាគំរូនៅក្នុងជីវិតរស់នៅសម្រាប់មនុស្សជំនាន់ក្រោយ។ ហេតុដូច្នេះ កត្តាទាំងនេះបង្កើតបានជាចំណងពិសេស និងជិតស្និទ្ធបំផុត[938]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសញ្ញាណដ៏ទូលំទូលាយស្តីពីសមាជិកគ្រួសារសាច់ញាតិផ្ទាល់*ទៅតាមព្រឹត្តិហេតុ* ប៉ុន្តែក្រោយមកយល់ឃើញថា "នៅក្នុងករណីលើកលែងតែប៉ុណ្ណោះ" សមាជិកគ្រួសារដែលមិនមែនជា

---

និង/ឬ ភស្តុតាងតិចតួចនិយាយអំពីទំនាក់ទំនងជាមួយនឹងអ្នកស្លាប់ដើម្បីអាចទទួលស្គាល់ជាជនរងគ្រោះ, ដោយហេតុថាសមាជិកនៃគ្រួសារនេះ ជាធម្មតាទទួលរងការប៉ះពាល់យ៉ាងខ្លាំងបំផុត ចំពោះមរណភាពរបស់សមាជិកគ្រួសារខ្លួន។ ហេតុដូច្នេះ ព្យសនកម្មផ្លូវចិត្ត គឺពុំសូវបង្ហាញឱ្យឃើញច្បាស់នោះឡើយ ក្នុងករណីដែលបុគ្គលនោះជាខ្សែស្រឡាយសាច់ឆ្ងាយ ឬក្រៅរង្វង់សមាជិកគ្រួសារ ហើយព័ត៌មាន និង/ឬភស្តុតាង អាចនឹងជាលក្ខខណ្ឌតម្រូវក្នុងការគាំទ្រអំណះអំណាងរបស់ខ្លួន ដែលថាខ្លួនមានទំនាក់ទំនងជាមួយអ្នកស្លាប់ជាជនរងគ្រោះនោះ ហើយការស្លាប់នេះបានធ្វើឱ្យមានព្យសនកម្មផ្លូវចិត្តដល់ខ្លួន និង/ឬបណ្តាលឱ្យបាត់បង់ការគាំពារ ផ្នែកសេដ្ឋកិច្ច")។

[937]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៧៧។

[938]ប្រតិចារឹកថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩, ឯកសារ E1/68.1, ទំព័រ ៣៧ (បន្ទាត់ ២២) ដល់ទំព័រ ៣៨ (បន្ទាត់ ៩)។

សាច់ញាតិផ្ទាល់ ត្រូវបានចាត់ទុកថាមាន "ចំណងពិសេសនៃសេចក្ដីស្រលាញ់ ឬជាអ្នករស់នៅក្នុងបន្ទុក" ជាមួយជនរងគ្រោះផ្ទាល់[939]។ ដោយហេតុថា សេចក្ដីសន្និដ្ឋាននេះបានកំណត់និយមន័យនៃវិសាលភាពការសន្មតទុកជាមុនក្នុងន័យចង្អៀតជាងវិសាលភាព ដែលបានបញ្ជាក់អះអាងក្នុងសក្ខីកម្មរបស់អ្នកជំនាញដែលបានចាត់តាំងនោះ ដូច្នេះសេចក្ដីសន្និដ្ឋាននេះ មិនបានរំលោភសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ដោយហេតុថា ការបង្កើតការសន្មតទុកជាមុននេះ គឺផ្អែកលើឆន្ទានុសិទ្ធិរបស់តុលាការ មិនមែនផ្អែកលើសិទ្ធិរបស់ភាគីដើម្បីទទួលបានអត្ថប្រយោជន៍ពីការសន្មតទុកជាមុននេះទេ។

៤៥០. ប្រហាក់ប្រហែលគ្នានេះដែរ ការដែលមិនបានជូនដំណឹងជាមុននោះ មិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ដោយហេតុថា ដើមបណ្ដឹងរដ្ឋប្បវេណីមានបន្ទុកក្នុងការបង្ហាញភស្តុតាងអំពីព្យសនកម្ម។ ដូច្នេះ បណ្ដឹងសាទុក្ខរបស់ម្ចាស់បណ្ដឹងសាទុក្ខស្ដីពីការបដិសេធចោលនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ ត្រូវបដិសេធចោល។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណានៅក្នុងផ្នែកខាងក្រោមលើបញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ក្នុងការសម្រេចអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ ដែរ ឬ យ៉ាងណា។

## ៦.ខ.ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការអនុវត្តបទដ្ឋាននៃការពិនិត្យឡើងវិញចំពោះភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាពីរដំណាក់កាល

### ៦.ខ.១.សារណា

៤៥១. ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ ក្រុម ២ និងក្រុម ៣ បានលើកឡើងនូវទឡ្ហីករណ៍ជាច្រើននៃបណ្ដឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយអនុវត្តបទដ្ឋាននៃការ

[939] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៣។

សម្រេចអំពីឋានៈដើមបណ្តឹងរដ្ឋប្បវេណីជាពីរដំណាក់កាលនៅក្នុងសំណុំរឿង ០០១។ ជំហានដំបូងគឺជាការវាយតម្លៃបឋមដែលធ្វើឡើង មុនពេល ក្នុងអំឡុងពេល ឬក្រោយពីសវនាការបឋម ដោយអាស្រ័យលើអ្នកដាក់ពាក្យសុំ ហើយជំហានទីពីរធ្វើឡើងនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា បទដ្ឋាននៃការសម្រេចជាពីរដំណាក់កាលមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក ឬច្បាប់កម្ពុជាឡើយ។ ជាពិសេស ម្ចាស់បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំក្នុងការផ្អែកលើវិធាន ១០០(១) នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៣) ដើម្បីធ្វើយុត្តិកម្មក្នុងការវាយតម្លៃឡើងវិញលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសាលក្រមរបស់ខ្លួន។ តាមទស្សនៈរបស់ខ្លួនបានឱ្យដឹងថា វិធាន ១០០(១) នៃវិធានផ្ទៃក្នុង បានចែងទាក់ទងតែចំពោះសេចក្តីសម្រេចលើការទាមទារសំណងប៉ុណ្ណោះ ហើយមិនបានចែងទាក់ទងទៅនឹងសេចក្តីសម្រេច លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តក្រៅដែនយុត្តាធិការពេលវេលារបស់ខ្លួន[940] ក្នុងការសម្រេចអំពីឋានៈដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលចេញសាលក្រម ដោយហេតុថា វិធាន ២៣(៤) នៃវិធានផ្ទៃក្នុងបានចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលចាប់ផ្តើមដំណើរការនីតិវិធីជំនុំជម្រះ។ លើសពីនេះទៀត យោងតាមវិធាន ៨៣(១) នៃវិធានផ្ទៃក្នុងបានចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវពិនិត្យរាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលសវនាការបឋម[941]។

---

[940]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ២៦។

[941]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ កថាខណ្ឌ ១៨ ដល់ ១៩។ (“ទទ្បីករណ៍ទី ១ ៖ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើ វិធាន ១០០(១)នៃវិធានផ្ទៃក្នុង ក្នុងការវាយតម្លៃឡើងវិញអំពីឋានៈរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ដែលបណ្តាលឲ្យមានការប៉ះពាល់ដល់សិទ្ធិជនរងគ្រោះ”)។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ កថាខណ្ឌ ២១ ដល់ ៤៩ (“ទទ្បីករណ៍ទី ១ នៃបណ្តឹងសាទុក្ខ៖ (...) ផ្អែកលើកំហុសអង្គច្បាប់/វិធានផ្ទៃក្នុងដែលធ្វើឲ្យសាលក្រមមោឃៈដោយរំលោភលើវិធាន ២១(១) ២១(១)(ក) ២១(១)(គ) ២៣(៤) ៨៣(១) និង១០០”)។ បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងក្រុម ៣, កថាខណ្ឌ ៣៨ ដល់ ៤០ (“ទទ្បីករណ៍ទី ១៖ កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងការទទួលយកម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី (...)”)។

៤៥២. ដោយយោងតាមវិធាន ២៣(៤) នៃវិធានផ្ទៃក្នុង ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី លើកឡើងថា "នៅពេលដែលពាក្យសុំត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង មិនទាន់ត្រូវបានប្រកាសថា មិនអាចទទួលយកបាន ម្ចាស់បណ្តឹងសាទុក្ខត្រូវបានចាត់ទុកថា បាន'ចូលរួម' ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី"[942] ដោយមានអានុភាពដូចដែលមានចែងនៅក្នុងវិធាន ២៣(៦) នៃវិធានផ្ទៃក្នុង[943]។ ម្ចាស់បណ្តឹង សាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ខ្លួនបានប្រើប្រាស់សិទ្ធិ និងកាតព្វកិច្ចក្នុងការ ចូលរួមរបស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ហើយការដកឋានៈរបស់ពួកគាត់នៅ ដំណាក់កាលក្រោយមកទៀតនោះ ធ្វើឱ្យមាន"ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផ្លូវចិត្តរបស់ម្ចាស់ បណ្តឹងសាទុក្ខជាថ្មីម្តងទៀត" ជាពិសេស ធ្វើឡើង"ដោយគ្មានការជូនដំណឹងឱ្យបានគ្រប់គ្រាន់ ជាមុន"[944]។ បន្ទាប់ពីបានរំលឹកឡើងវិញយ៉ាងលម្អិតជាសាធារណៈ នូវរឿងរ៉ាវពីអតីតកាល ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផ្លូវចិត្តរបស់ពួកគាត់រួចមក ការដកហូតឋានៈនេះបានបណ្តាល ឱ្យមាន"ភាពតានតឹង តប់ប្រមល់ និងឈឺចាប់យ៉ាងច្រើនបន្ថែមទៀត"[945]។ លើសពីនេះទៀត វិធីសាស្ត្រខុសឆ្គងដែលអង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសនេះ គឺមិនបានយកចិត្តទុក ដាក់ដល់ក្តីកង្វល់ចំពោះការប្រើប្រាស់ពេលវេលា និងធនធានយ៉ាងច្រើនឡើយ[946]។ ប៉ុន្តែ ម្ចាស់ បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីពុំបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមិន

---

[942]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ២៨។

[943]វិធាន ២៣ (៦) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) ("ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពដូចតទៅ៖ ក) នៅពេលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជនរងគ្រោះក្លាយជាភាគីក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានសាកសួរក្នុងឋានៈដូចសាក្សីធម្មតាបានទេ ចំពោះរឿងដដែល និងអនុលោមទៅតាមវិធាន ៦២ ស្តីពីដីកាចាត់ឲ្យស៊ើបសួរជំនួសដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអាចត្រូវបានសាកសួរក្នុងលក្ខខណ្ឌដូចគ្នាជាមួយនឹងជនត្រូវចោទឬជនជាប់ចោទ។ ខ) អង្គជំនុំជម្រះមិនត្រូវចេញសេចក្តីសម្រេចចំពោះបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្ទុយគ្នាទៅនឹងសេចក្តីសម្រេចផ្នែកបណ្តឹងអាជ្ញាចំពោះករណីរឿងតែមួយឡើយ ហើយ គ) សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះអាចចាត់វិធានការការពារដើមបណ្តឹងរដ្ឋប្បវេណីដូចមានចែងក្នុងវិធាន ២៩")។

[944]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ៣៤ ដល់ ៣៨។

[945]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ៥៦។

[946]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ៥៣។

អាចដកហូតឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលឋានៈនោះត្រូវបានផ្តល់រួចហើយនោះឡើយ។ ផ្ទុយទៅវិញ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយនោះ ឋានៈនេះគប្បីរក្សាទុករហូត លើកលែងតែមានភស្តុតាងជាក់លាក់ និងច្បាស់លាស់បង្ហាញអំពីភាពសង្ស័យទៅលើឋានៈនេះ[947]។

៤៥៣. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់បន្ថែមទៀតថា ច្បាប់ជាធរមាននៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ពុំបានចែងអំពីបទដ្ឋាននៃការសម្រេចជាពីរដំណាក់កាលស្តីពីឋានៈរបស់ជនរងគ្រោះឡើយ[948]។ តាមរយៈសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភលើគោលការណ៍ជាសារវន្តធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាពដូចដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង[949]។ ការអនុវត្តបទដ្ឋាននៃការសម្រេចជាពីរដំណាក់កាលនាំឱ្យមានការផ្តល់សិទ្ធិខុសគ្នា ដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ក្រុមជនរងគ្រោះផ្សេងៗគ្នា[950]។ ជនរងគ្រោះបានចង្អុលបង្ហាញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវស្ថិតនៅក្រោមបទដ្ឋាននៃការត្រួតពិនិត្យឡើងវិញ អំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីមានបីដំណាក់កាល[951]។

---

[947] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ៣១។

[948] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ២១ ដល់ ២៨។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣, កថាខណ្ឌ ៣៨។

[949] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ៤៥ ដល់ ៤៩។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣, កថាខណ្ឌ ៣៨។

[950] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ២៩ ដល់ ៣៤។

[951] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ៣៣។

៤៥៤. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីសម្តែងនូវក្តីបារម្ភដោយហេតុថា វិធានផ្ទៃក្នុងពុំអនុញ្ញាតឱ្យពួកគាត់ ប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសម្រេចអំពីសំណាងរបស់អង្គជំនុំជម្រះសាលាដំបូង ពីព្រោះជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលនឹងចេញសេចក្តីសម្រេចស្តាពរលើឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្រោយពេលដែលសិទ្ធិធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីសំណាងរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវផុតរលត់។ ម្ចាស់បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីដែលជំទាស់បាន ដោយជោគជ័យប្រឆាំងនឹងសេចក្តីសម្រេចបដិសេធឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនេះ នឹងត្រូវបាត់ឱកាសជារៀងរហូតក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីសំណាងនេះ។ ដូច្នេះ ការវាយតម្លៃឡើងវិញអំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង គឺពិតជាបានអនុវត្តផ្ទុយទៅនឹងផលប្រយោជន៍ផ្នែកយុត្តិធម៌[952]។

## ៦.១.២.សាវតានីតិវិធី

៤៥៥. ដូចមានការលម្អិតខាងក្រោម ក្នុងចំណោមម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២នាក់[953] ម្ចាស់បណ្តឹងសាទុក្ខខ្លះបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយបានចាប់ផ្តើមចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ក្នុងអំឡុងដំណាក់កាលស៊ើបអង្កេត និងនៅតែបន្តធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការបឋម។ ម្ចាស់បណ្តឹងសាទុក្ខខ្លះទៀតបាន

[952] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ៣៥ ដល់ ៤៤។

[953] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩ នាក់ មកពីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១៖ លី ហ៊ ហៅ អ៊ាហ៊ីវ (E2/61) ; Joshua ROTHSCHILD (E2/88) ; Jeffrey JAMES (E2/86); ហ៊ឹម មុំ (E2/62); សួន សៀង (D25/15); ង៉ែត អ៊ុយ (E2/74); ធៀវ នាប (E2/75); លឹម យ៉ុន (E2/69); នង សាវ៉ាត (E2/73)។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥ នាក់ មកពីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២៖ ណាំ ម៉ុន (E2/32); ឆាយ កន ហៅ លៀង កន (E2/35); ហុង សាវ៉ាត (E2/83); ឈឹម ស៊ីថា (E2/22); ញ៉ិប គឹមស្រ៊ា (E2/64)។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៨ នាក់ (ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣)៖ សូ សូង (E2/34); ឃួន សារិន (D25/11); ម៉ន សុធា (E2/82); ចាន់ យឿង (E2/70); សឹម ពៅ (E2/71); ប៉ាន់ ប៉ិច (E2/63); ភោគ ខន (E2/33); ឡាយ ចាន់ (E2/23)។

ដាក់ពាក្យសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយបានទទួលនូវលិខិតទទួលស្គាល់ជាបណ្តោះអាសន្នពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ហើយឋានៈរបស់ពួកគាត់ត្រូវបានប្រកាសទទួលស្គាល់ពេញលេញនៅពេលសវនាការបឋម។ ម្ចាស់បណ្តឹងសាទុក្ខដទៃទៀតបានដាក់ពាក្យសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយត្រូវបានទទួលយកនៅពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី។ ម្ចាស់បណ្តឹងសាទុក្ខដទៃទៀតបានដាក់ពាក្យសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយត្រូវបានទទួលយកក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះតាមរយៈសេចក្តីសម្រេចដាច់ដោយឡែករបស់អង្គជំនុំជម្រះសាលាដំបូង។ ពាក្យសុំភាគច្រើនក្នុងចំណោមពាក្យសុំទាំងនេះ ត្រូវបានតវ៉ាជាបន្តបន្ទាប់ដោយមេធាវីការពារក្តីក្នុងអំឡុងពេលសវនាការ។ ជាទីបញ្ចប់ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីទាំង ២២ នាក់នេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធនៅក្នុងសាលក្រមរបស់ខ្លួន។

### ៦.២.៣.ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត

៤៥៦. ម្ចាស់បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណី ឃួន សារិន (D25/11) និង សួន សៀង (D25/15) បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងដំណាក់កាលស៊ើបអង្កេត។ ម្ចាស់បណ្តឹងសាទុក្ខនីមួយៗក្នុងចំណោមម្ចាស់បណ្តឹងសាទុក្ខទាំងនេះ បានទទួលលិខិតមួយច្បាប់ពីក្រឡាបញ្ជីរបស់ សហចៅក្រមស៊ើបអង្កេត ដែលបានជូនដំណឹងដល់ពួកគាត់ ដូចខាងក្រោមនេះថា៖

> "១. ទម្រង់បែបបទសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក លោកស្រី ត្រូវបានទទួលដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ហើយតាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។ ដូច្នេះ លើកលែងតែមានសេចក្តីសម្រេចផ្លាស់ប្តូរនៅពេលក្រោយរបស់សហចៅក្រមស៊ើបអង្កេត (សូមអាន កថាខណ្ឌ ២) លោក លោកស្រី នៅពេលនេះ ត្រូវបានចាត់ទុក

ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការទាក់ទិននឹងរឿងក្តីនេះ។

២. សូមរំឭកថា នៅគ្រប់ពេលនៃដំណើរការស៊ើបអង្កេតរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអាចធ្វើសេចក្តីសម្រេចជាផ្លូវការមួយទាក់ទិននឹងពាក្យសុំរបស់លោក លោកស្រី ដែលអាចជាការសម្រេចយល់ព្រម ឬ បដិសេធ ប្រសិនបើសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា លោក លោកស្រីមិនមែនជាជនរងគ្រោះ ឬថា លក្ខណៈវិនិច្ឆ័យទាំងឡាយដែលកំណត់ដោយវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះមិនត្រូវបានបំពេញ។

៣. លោក លោកស្រី ក៏ត្រូវដឹងផងដែរថា តាមរយៈការចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី លោក លោកស្រី និងមេធាវីរបស់លោក លោកស្រី អាចដឹងអំពីព័ត៌មានសម្ងាត់ដែលមាននៅក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ”[954]។

៤៥៧. នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ដូចខាងក្រោមថាៈ

នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេត ដោយផ្អែកតាមវិធាន ២៣ នៃវិធានផ្ទៃក្នុង មានបុគ្គលប្រាំបីរូបបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលក្នុងនោះមានអតីតអ្នកទោសនៃមន្ទីរ ស ២១ និងសមាជិកក្រុមគ្រួសារអតីតអ្នកទោសដែលត្រូវបានសម្លាប់នៅមន្ទីរនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០ រូបផ្សេងទៀតបានដាក់ពាក្យបណ្តឹងនៅចន្លោះពេលនៃការបញ្ចប់កិច្ចស៊ើបអង្កេត និងពេលចេញដីកាដំណោះស្រាយ[955]។

---

[954]ឋានៈនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៨, ឯកសារលេខ D25/11/4 និង D25/15/3, ។ *សូមមើលផងដែរ*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៦។ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតបានចេញលិខិតទទួលស្គាល់បណ្តោះអាសន្នជូនដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនម្ភៃប្រាំបី ដែលអ្នកទាំងនោះបានស្នើសុំក្នុងអំឡុងពេលដំណាក់កាលនៃដំណើរការនីតិវិធីស៊ើបសួរ។ មិនដូចគ្នានឹងលិខិតដទៃផ្សេងទៀត លិខិតទីមួយនៃលិខិតទាំងនេះ មានបន្ថែមកថាខណ្ឌមួយពីមុខ, កថាខណ្ឌ ២ ដែលចែងថា “ពាក្យសុំរបស់លោក លោកស្រីកំពុងត្រូវបានវាយតម្លៃ និងធ្វើការជូនដំណឹងជូនលោក លោកស្រីនៅពេលក្រោយតាមពេលវេលាសមស្រប”។ កថាខណ្ឌនេះ ត្រូវបានលុបចោលនៅក្នុងលិខិតទទួលស្គាល់ផ្សេងទៀត ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេត។

[955]ដីកាបញ្ជូនរឿងទៅជំនុំជម្រះកថាខណ្ឌ ៦។

៤៥៨. នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ក្នុងអំឡុងពេលសវនាការបឋម អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី D25/11 និង D25/15 "នៅតែជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីប្រឆាំងនឹងជនជាប់ចោទ"[956]។ បន្ទាប់មក ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងសាទុក្ខ D25/11 និង D25/15 ត្រូវបានបដិសេធនៅក្នុងសាលក្រម[957]។

## ៦.២.៤.ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

៤៥៩. នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងបានចេញលិខិតទទួលស្គាល់ជាបណ្តោះអាសន្ន ចំពោះម្ចាស់បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម នេះ៖ ឈឹម ស៊ីថា (E2/22)[958], លៀង កន (E2/35)[959], ណាំ ម៉ុន (E2/32)[960], ឡាយ ចាន់ (E2/23)[961], អោគ ខន (E2/33)[962], និង សូ សួង (E2/34)[963]។ បន្ទាប់មកទៀត នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងបានចេញលិខិតទទួលស្គាល់ជាបណ្តោះអាសន្ន ចំពោះម្ចាស់បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោមនេះ ៖ លី ហ៊ំ ហៅ អ៊ា ហ៊ីវ (E2/61)[964], ហ៊ឹម មុំ (E2/62)[965], ញិប គីមស្រ៊ា

[956]ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារE1/3/1, ទំព័រ ២៧ (បន្ទាត់ ២៥) ដល់ ទំព័រ ២៨ (បន្ទាត់ ២)។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារលេខ E188 ("សាលក្រម"), កថាខណ្ឌ ៦៣៧។

[957]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។

[958]ការទទួលស្គាល់ជាបណ្តោះអាសន្នដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/22/3។

[959]ការទទួលស្គាល់ជាបណ្តោះអាសន្នដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/35/3។

[960]ការទទួលស្គាល់ជាបណ្តោះអាសន្នដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/32/3។

[961]ការទទួលស្គាល់ជាបណ្តោះអាសន្នដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/23/3។

[962]ការទទួលស្គាល់ជាបណ្តោះអាសន្នដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/33/4។

[963]ការទទួលស្គាល់ជាបណ្តោះអាសន្នដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/34/4។

[964]ការទទួលស្គាល់ជាបណ្តោះអាសន្នដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E2/61/3។

(E2/64)[966], ប៉ាន់ ប៊ុច (E2/63)[967]។ លិខិតទាំងអស់នេះមានខ្លឹមសារដូចៗគ្នា ដូចខាងក្រោមនេះ ៖

២. ដើម្បីជាវិធានការបណ្តោះអាសន្ន លោក លោកស្រី ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធី រហូតដល់សវនាការបឋមនៅក្នុងរឿងក្តីនេះ ដែលនៅពេល នោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក លោកស្រី នឹងត្រូវលើកមកពិចារណាស្របតាមបញ្ញត្តិនៃវិធាន ៨៣ (...)។

៤. អង្គជំនុំជម្រះសាលាដំបូងអាចធ្វើសេចក្តីសម្រេចជាផ្លូវការក្នុងការទទួលយកពាក្យសុំរបស់ លោក លោកស្រី ហើយក៏អាចបដិសេធចោលផងដែរនូវពាក្យសុំនេះ ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ពាក្យសុំរបស់លោក លោកស្រី មិនបានបំពេញតាមលក្ខខណ្ឌផ្លូវច្បាប់ថា ជាជនរងគ្រោះដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីអំពីការចូលរួមរបស់ជនរងគ្រោះ។

៥. លោក លោកស្រី ត្រូវដឹងថាតាមរយៈការចូលរួមរបស់លោក លោកស្រីជាភាគីដើមបណ្តឹងរដ្ឋប្បវេណី លោក លោកស្រី មេធាវី និង/ឬបុគ្គលផ្សេងទៀតដែលជួយដល់លោក លោកស្រី អាចទទួលព័ត៌មានសម្ងាត់ដែលមាននៅក្នុងសំណុំរឿងបាន។

៦. បន្ទាប់ពីចេញលិខិតទទួលស្គាល់ជាបណ្តោះអាសន្ន មេធាវីរបស់លោក លោកស្រីនឹងត្រូវទទួលបានការជូនដំណឹងអំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដែលសហព្រះរាជអាជ្ញាមានបំណងកោះហៅឱ្យចូលរួម សវនាការ ព្រមទាំងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត។ យោងតាមបញ្ញត្តិនៃវិធាន ៨០(២) នៃវិធានផ្ទៃក្នុង រាល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានបំណងកោះហៅសាក្សី ឬអ្នកជំនាញណាមួយដែលមិនមានឈ្មោះនៅក្នុងបញ្ជីដែលផ្តល់ឱ្យដោយសហព្រះរាជអាជ្ញា ត្រូវដាក់បញ្ជីឈ្មោះសាក្សី

---

[965]ការទទួលស្គាល់ជាបណ្តោះអាសន្នដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E2/62/3។

[966]ការទទួលស្គាល់ជាបណ្តោះអាសន្នដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E2/64/3។

[967]ការទទួលស្គាល់ជាបណ្តោះអាសន្នដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E2/63/3។

បន្ថែមក្នុងរយៈពេល ១៥ ថ្ងៃគិតចាប់ពីថ្ងៃទទួលដំណឹងនៃបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញានេះ។

៤៦០. នៅពេលសវនាការបឋម ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ អង្គជំនុំជម្រះសាលាដំបូង "បានទទួលស្គាល់យ៉ាងពេញលេញនូវឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយណា ដែលត្រូវបានទទួលស្គាល់ជាបណ្ដោះអាសន្នរួចហើយជាដើមបណ្ដឹងរដ្ឋប្បវេណី (...)"[968]។ ចៅក្រម Lavergne បានបញ្ជាក់នៅពេលសវនាការបឋមថា៖

> ក្រោយពីស្ដាប់សេចក្ដីសន្និដ្ឋានផ្សេងៗគ្នារបស់ភាគី អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចដូចតទៅ ៖ មុនពេលចេញការទទួលស្គាល់បណ្ដោះអាសន្ន អង្គជំនុំជម្រះសាលាដំបូងបានធ្វើការពិនិត្យយ៉ាងហ្មត់ចត់ លើរាល់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ហើយអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋាននៃការពិនិត្យភស្តុតាងបឋម។ ប្រការនេះមិនមែនជាការពិនិត្យលើខ្លឹមសារ ឬលើអង្គសេចក្ដីឡើយ។ ទាក់ទិននឹងអត្ថិភាពនៃលក្ខណៈវិនិច្ឆ័យ សម្រាប់ការវាយតម្លៃលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះបានតម្កល់ឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយណា ដែលត្រូវបានទទួលស្គាល់ជាបណ្ដោះអាសន្នរួចហើយថា ពួកគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីប្រឆាំងនឹង ជនជាប់ចោទ (...)[969]។

៤៦១. ក្នុងអំឡុងពេលសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងបានសម្រេច "ទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណី" ចំពោះគ្រប់ "អ្នកដាក់ពាក្យសុំចុងក្រោយនេះ" ដែលរួមមានម្ចាស់បណ្ដឹងសាទុក្ខដើមបណ្ដឹងរដ្ឋប្បវេណី នង សាវ៉ាត (E2/73), Jeffrey JAMES (E2/86), Joshua ROTHSCHILD (E2/88), ធៀវ នាប *ហៅ* ខៀវ នាប (E2/75), ហុង សាវ៉ាត (E2/83),

---

[968]ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០ ៩, ឯកសារ E1/3/1, ទំព័រ ៣៧ (បន្ទាត់ ៣ ដល់ ៥)។

[969]ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារ E1/3/1, ទំព័រ ៣៦ (បន្ទាត់ ២៤ ដល់ ២៥) ដល់ ទំព័រ ៣៧ (បន្ទាត់ ១ ដល់ ៧)។

ចាន់ យឿង (E2/70), សឹម ពៅ (E2/71), ម៉ន សុធា (E2/82)។ ចៅក្រម Lavergne បានបញ្ជាក់ថា៖

> អង្គជំនុំជម្រះសាលាដំបូង បានធ្វើការពិនិត្យយ៉ាងហ្មត់ចត់លើរាល់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ ដោយអនុវត្តបទដ្ឋាននៃការពិនិត្យភស្តុតាងបឋមសម្រាប់អត្ថិភាពនៃលក្ខណៈ វិនិច្ឆ័យសម្រាប់វាយតម្លៃលើពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងក្រោយពីបានស្តាប់យោបល់របស់ភាគីផ្សេងៗទៀតរួចមក អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសថា រាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅសល់ដែលពុំទាន់មានការទទួលស្គាល់បណ្តោះអាសន្ន គឺត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីប្រឆាំងនឹងជនជាប់ចោទ លើកលែងតែអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/69, E2/74, E2/87 តែប៉ុណ្ណោះ។
>
> តាមរយៈឯកសារដែលសន្យាថាដាក់ជូនមកអង្គជំនុំជម្រះនៅព្រឹកនេះ អង្គជំនុំជម្រះនឹងធ្វើការពិនិត្យឡើងវិញ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/69, E2/74, E2/87 ហើយនឹងចេញសេចក្តីសម្រេចទាក់ទងទៅនឹងពាក្យសុំទាំងនេះ នៅក្នុងពេលវេលាសមស្រប និងឱ្យបានមុនសវនាការលើអង្គសេចក្តី”[970]។

៤៦២. នៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩[971] អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចទទួលយកម្ចាស់បណ្តឹងសាទុក្ខ ង៉ែត អ៊ុយ (E2/74) និងនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៩[972] អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចទទួលយកម្ចាស់បណ្តឹងសាទុក្ខ លឹម យ៉ុន (E2/69) ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងប្រឆាំងនឹង កាំង ហ្កេកអ៊ាវ។

---

[970]ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារ E1/3/1, ទំព័រ ៣៩ (បន្ទាត់ ១៧ ដល់ ២៥) ដល់ ទំព័រ ៤០ (បន្ទាត់ ១ ដល់ ២)។

[971]សេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូង ស្តីពីការបញ្ជាក់ភស្តុតាងលើអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E2/94។

[972]សេចក្តីសម្រេចអំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះអ្នកដាក់ពាក្យសុំ, ឯកសារលេខ E2/36, E2/51 និង E2/69 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៩, ឯកសារលេខ E2/94/2។

៤៦៣. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ ក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី មេធាវីការពារក្តី បានជំទាស់[973]ទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន រួមមានពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤ នាក់ ដូចខាងក្រោមនេះ៖

ឈឹម ស៊ីថា (E2/22), សួន សៀង (D25/15), ឆាយ កន ហៅ លៀង កន (E2/35), ហ៊ឹម មុំ (E2/62), ញ៉ិប គឹមស្រ៊ា (E2/64), ប៉ាន់ ប៊ិច (E2/63), លឹម យ៉ុន (E2/69), ចាន់ យឿង (E2/70), សឹម ពៅ (E2/71), នង សារ៉ាត (E2/73), ង៉ែត អ៊ុយ (E2/74), ឆៀវ នាប ហៅ ខៀវ នាប (E2/75), ម៉ន សុធា (E2/82) និង ហុង សារ៉ាត (E2/83)។ នៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានជំទាស់ដោយមេធាវីការពារក្តីទាំងនោះឱ្យដាក់ភស្តុតាងបន្ថែម។ សេចក្តីបង្គាប់ ដែលត្រូវបានចេញដោយប្រធានអង្គជំនុំជម្រះសាលាដំបូង មានខ្លឹមសារនៅក្នុងផ្នែកពាក់ព័ន្ធដូចខាងក្រោមនេះ ៖

> ១. ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណា ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនត្រូវបាន ជំទាស់តវ៉ាពីភាពស្របច្បាប់ក្នុងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សូមដាក់ជូនភ័ស្តុតាងជាឯកសារ បន្ថែមដល់អង្គជំនុំជម្រះ ដើម្បីបញ្ជាក់អំពីភាពជាប់ពាក់ព័ន្ធទាំងឡាយរវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៃសំណុំរឿង ០០១។ ២. ប្រសិនអាចធ្វើទៅបាននោះ សូមភាគីដើមបណ្តឹងរដ្ឋប្បវេណីដាក់នូវភស្តុតាង ជាឯកសារទាំងនោះដល់អង្គជំនុំជម្រះ យ៉ាងយូរបំផុតត្រឹមថ្ងៃព្រហស្បតិ៍ ទី ៣ ខែ កញ្ញា ឆ្នាំ ២០០៩ វេលាម៉ោង ៤ និង ៣០ នាទី ល្ងាច[974]។

[973] ប្រតិចារិកចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩, ឯកសារលេខ E1/68.1, ទំព័រ ៥១ (បន្ទាត់ ២៣ ដល់ ២៥) ដល់ ទំព័រ ៥៦ (បន្ទាត់ ១ ដល់ ២២)។

[974] ប្រតិចារិកចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩, ឯកសារលេខ E1/70.1, ទំព័រ ២ (បន្ទាត់១០ ដល់ ១៦)។

៤៦៤. ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨ នាក់[975] ក្នុងចំណោមម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីដែលប្តឹងសាទុក្ខនោះ មិនត្រូវបានជំទាស់តវ៉ាដោយមេធាវីការពារក្តីឡើយ ដូច្នេះហើយអង្គជំនុំជម្រះសាលាដំបូងមិនបានស្នើឱ្យដាក់ភស្តុតាងបន្ថែមឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសាលក្រម ពួកគាត់បានឃើញឈ្មោះពួកគាត់ស្ថិតក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំង ២៤ នាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ពុំមានភស្តុតាងដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា ពួកគាត់បានទទួលរងព្យសនកម្មជាផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មដែល កាំង ហ្កេកអ៊ាវ ជាអ្នកទទួលខុសត្រូវ។

៤៦៥. ក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងធ្វើការសង្ខេបបទដ្ឋាននៃការសម្រេចជាពីរដំណាក់កាលរបស់ខ្លួនលើពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោមនេះ៖

> ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសម្រេចជាបឋមថា អាចទទួលយកបាននៅពេលពាក្យសុំនោះឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យ សម្រាប់ការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបំពេញ។ ជាទូទៅ ដោយផ្អែកតាមការអនុវត្តរបស់តុលាការអន្តរជាតិស្រដៀងគ្នានេះ អង្គជំនុំជម្រះ បានធ្វើការវាយតម្លៃលើសេចក្តីបញ្ជាក់ដំបូងអំពីការជឿជាក់លើព័ត៌មាន ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ឱ្យ។ នីតិវិធីនៃការសម្រេចទទួលយកពាក្យសុំបែបនេះ មានលក្ខណៈខុសគ្នាពីការសម្រេចរបស់អង្គជំនុំជម្រះ ដែលសម្រេចលើអង្គសេចក្តីនៃពាក្យសុំទាំងអស់នៅ

[975] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ (ឯកសារលេខ E2/61, E2/86, E2/88)។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ (ឯកសារលេខ E2/32)។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ (ឯកសារលេខ E2/23, E2/33, E2/34, D25/11)។ អ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងឯកសារE2/38 និង E2/37 មិនបានប្តឹងបណ្តឹងសាទុក្ខចំពោះការបដិសេធចោលពាក្យសុំរបស់ខ្លួននោះទេ។ មេធាវីការពារក្តីមិនបានជំទាស់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងស្រុងរបស់ម្ចាស់ដើមបណ្តឹងរដ្ឋប្បវេណីណាំម៉ុន (E2/32) ប៉ុន្តែគ្រាន់តែជំទាស់ថាណាំម៉ុនមិនមែនជាបុគ្គលិកនៅមន្ទីរ ស ២១ និងសំណើសុំដាក់សារណាជាលាយលក្ខណ៍អក្សរទៅកាន់អង្គជំនុំជម្រះសាលាដំបូង (ប្រតិចារិក ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩, ឯកសារ E1/70.1, ទំព័រ ៣៩ ដល់ ៤១។ អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៣៨ ជើងទំព័រ ១០៦៧ ដល់ ១០៦៨។

ក្នុងសាលក្រម ដែលផ្អែកលើមូលដ្ឋាននៃភស្តុតាងទាំងអស់ដែលបានដាក់ជូននៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធី[976]។

(...)

នៅពេលប្រកាសទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលដំបូងនៃដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញដល់អង្គជំនុំជម្រះអំពីទំនាក់ទំនងដោយផ្ទាល់រវាងកំហុសរបស់ជនជាប់ចោទ និងព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងដោយផ្ទាល់"[977]។

## ៦.ខ.៥.ច្បាប់ជាធរមាន

### *៦.ខ.៥.ក.ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*

៤៦៦. ដោយពិចារណាទៅលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលចាប់ផ្តើមពិនិត្យបទប្បញ្ញត្តិពាក់ព័ន្ធនានានៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការសម្រេច ថាតើវិធាននៃផ្ទៃក្នុងនៃ អ.វ.ត.ក មានលក្ខណៈខុសគ្នាពីប្រព័ន្ធនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែរឬយ៉ាងណា ហើយប្រសិនបើខុសគ្នាមែននោះ តើខុសគ្នានៅក្នុងកម្រិតណា។

៤៦៧. យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ នៅមុនដំណាក់កាលជំនុំជម្រះ ជនរងគ្រោះ អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលានៅក្នុងកិច្ចដំណើរការនីតិវិធីដែលកំពុងបន្ត[978] ឬអាចដាក់ពាក្យប្តឹងជូនចៅក្រមស៊ើបសួរដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[979]។ ទោះបីជាពុំមានចែងនៅក្នុងក្រមនីតិវិធី

---

[976]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៣៦ (សេចក្តីបញ្ជាក់បន្ថែម)។

[977]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៣៨។

[978]មាត្រា ១៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។

[979]មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។

ព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ក៏ដោយ ក៏ការពិនិត្យបឋមអប្បបរមាមួយចំនួនលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានសារៈសំខាន់ចាំបាច់ដើម្បីចុះបញ្ជីកត់ត្រាទុកនូវការទាមទាររបស់ជនរងគ្រោះថា ការទាមទារទាំងនោះ ពិតជាពាក់ព័ន្ធនឹងព្រឹត្តការណ៍របស់តុលាការ។ ចៅក្រមស៊ើបសួរជាបឋមត្រូវតែពិនិត្យ ថាតើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យោងទៅលើរឿងក្តីព្រហ្មទណ្ឌយ៉ាងច្បាស់លាស់ដែលកំពុងផ្អាករង់ចាំនៅចំពោះមុខខ្លួន ឬត្រូវចាត់ទុកថាជាបណ្តឹងព្រហ្មទណ្ឌ ឬត្រូវបញ្ជូនទៅតុលាការរដ្ឋប្បវេណី ជាបណ្តឹងរដ្ឋប្បវេណីស្វយ័ត។ ទោះបីជាយ៉ាងណាក៏ដោយ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ពុំបានចែងអំពីការពិនិត្យរបស់ចៅក្រមស៊ើបសួរ ទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថាតើពាក្យសុំនោះបំពេញនូវលក្ខណៈវិនិច្ឆ័យនៅក្នុងមាត្រា ១៣ ស្តីពីការបង្ហាញឃើញថា មានព្យសនកម្មទាក់ទិនទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដែរ ឬយ៉ាងណានោះឡើយ។ ពុំមានបទប្បញ្ញត្តិណាមួយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ចែងថា ចៅក្រមស៊ើបសួរអាចចេញដីកា“ទទួលស្គាល់ជាបណ្តោះអាសន្ន” ជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះជនរងគ្រោះឡើយ។ នៅក្នុងការអនុវត្តជាទូទៅរបស់តុលាការកម្ពុជា ក្រឡាបញ្ជីពុំអាចចេញនូវលិខិតទទួលស្គាល់បណ្តោះអាសន្នជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡើយ។

៤៦៨. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ចែងអំពីការចេញដីកាសម្រេចមិនអាចទទួលយកបាននូវពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែក្នុងករណីដែលអ្នកដាក់ពាក្យប្តឹងនោះខកខានក្នុងការបង់ប្រាក់តម្កល់ទុកដែលតម្រូវជាចាំបាច់តែប៉ុណ្ណោះ[980]។ ក្រៅពីនេះជាការច្បាស់ណាស់ដែលថា អ្នកដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី និងអនុវត្តសិទ្ធិនានាដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។ លើសពីនេះទៀត នៅពេលដែលជនរងគ្រោះដាក់ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសេចក្តីសម្រេចចុងក្រោយរបស់ចៅក្រមស៊ើបសួរ

[980]មាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។

សម្រេចធ្វើការស៊ើបសួរ និង/ឬ របស់ព្រះរាជអាជ្ញា[981] ចាប់ពីពេលនេះតទៅ ជនរងគ្រោះនេះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ប្រសិនបើការស៊ើបសួរដែលចាប់ផ្តើមធ្វើដោយផ្អែកទៅលើមូលដ្ឋានតែមួយប៉ុណ្ណោះនៃបណ្តឹងរបស់ជនរងគ្រោះនោះ ត្រូវបានរកឃើញនៅដំណាក់ក្រោយទៀតថា នីតិវិធីនេះធ្វើឡើង "ដោយរំលោភ ឬដោយអូសបន្លាយពេលវេលា"[982]។ សេណារីយ៉ូនេះមិនមានចែងនៅក្នុងប្រព័ន្ធ អ.វ.ត.ក ឡើយ ដោយសារតែសិទ្ធិក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានកម្រិត ដោយគ្រាន់តែគាំទ្រដល់ការចោទប្រកាន់ប៉ុណ្ណោះ[983] ប៉ុន្តែមិនអាចផ្តួចផ្តើមឱ្យមានការស៊ើបសួរផ្នែកព្រហ្មទណ្ឌឡើយ[984]។

៤៦៩. អនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាននៅចំពោះមុខតុលាការ ប្រសិនបើខ្លួនពុំទាន់បានតាំងខ្លួននៅឡើយនៅចំពោះមុខចៅក្រមស៊ើបសួរ[985]។ ជនរងគ្រោះក៏អាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានផងដែរ ក្នុងអំឡុងពេលសវនាការ[986]។ ជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយនៅពេលស៊ើបសួរនោះ មិនចាំបាច់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាថ្មីទៀត នៅចំពោះមុខតុលាការឡើយ។ ចុងក្រោយ អនុលោមតាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ "នៅក្នុងសាលក្រមតែមួយជាមួយរឿងព្រហ្មទណ្ឌ តុលាការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។ តុលាការវិនិច្ឆ័យអំពីភាព

[981] មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧, កថាខណ្ឌ ២ និង ៥។

[982] មាត្រា ១៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។

[983] វិធាន ២៣(១)(ក), ៥៥(៥)(ក), ៥៩,៨៣,៩១(១)(ក) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣)។

[984] វិធាន ២៣(១) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) ("គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ (...) ដោយ*គាំទ្រ*ដល់ការចោទប្រកាន់"។ (សេចក្តីបញ្ជាក់បន្ថែម)។ ពុំមានបទប្បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុងស្រដៀងគ្នាទៅនឹងបទប្បញ្ញត្តិនៃមាត្រា ១៣៨ ដល់ ១៣៩, កថាខណ្ឌទីមួយ និងទីប្រាំ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ឡើយ។

[985] មាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧, កថាខណ្ឌ ៣។

[986] មាត្រា ៣១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧, កថាខណ្ឌ ១។

00798695



អាចទទួលយកបាននៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសម្រេចអំពីពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះជនជាប់ចោទ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី”[987]។

៤៧០. ជាសង្ខេប នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងមូល ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ បញ្ចូលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងទូលំទូលាយ និងសន្មតជាមុនថា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺជាការទទួលខុសត្រូវចំពោះហានិភ័យដោយខ្លួនឯង។ នៅពេលដែលតុលាការបានទទួលយកការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ តុលាការត្រូវពិនិត្យលើអង្គសេចក្តីនៃការទាមទារសំណងរដ្ឋប្បវេណី នៅពេលទន្ទឹមគ្នានឹងការសម្រេចអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ។ រាល់បញ្ហាពាក់ព័ន្ធ ដែលរួមមានអត្ថិភាពនៃព្យសនកម្មដូចមានចែងក្នុងមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ទំនាក់ទំនងហេតុនិងបច្ច័យពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ការទទួលខុសត្រូវរដ្ឋប្បវេណីរបស់ជនជាប់ចោទ និងជាចុងក្រោយ សំណងរដ្ឋប្បវេណីត្រូវសម្រេចនៅក្នុងសាលក្រម។ ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ពិតជាមិនបានចែងអំពីបទដ្ឋាននៃការពិនិត្យឡើងវិញជាពីរដំណាក់កាលទៅលើការទាមទារសំណងផ្នែករដ្ឋប្បវេណីក៏ដោយ ក៏ក្រមនេះចែងយ៉ាងច្បាស់ថា ការវាយតម្លៃយ៉ាងទំលំទូលាយអំពីការទាមទារសំណងផ្នែករដ្ឋប្បវេណី រួមទាំងឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវសម្រេចនៅក្នុងដំណាក់កាលចេញសាលក្រម។

***៦.ខ.៥.ខ.ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្របខណ្ឌ អ.វ.ត.ក***

៤៧១. ដោយធ្វើការប្រៀបធៀបជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ចែងអំពីការពិនិត្យរបស់តុលាការទៅលើលក្ខខណ្ឌតម្រូវអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អនុលោមតាមវិធាន ២៣(៣) នៃវិធានផ្ទៃក្នុង (វិសោធនកម្ម លើកទី ៣) “នៅពេលណាក៏ដោយក្នុងអំឡុងពេលស៊ើបសួរ ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខសហចៅក្រម

---

[987]មាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។

ស៊ើបអង្កេត ត្រូវដាក់ពាក្យសុំនោះ ជាលាយលក្ខណ៍អក្សរ"។ វិធានផ្ទៃក្នុងអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតសម្រេច "ចេញដីកាដោយមានសំអាងហេតុបដិសេធពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន។ ដីកានេះ ត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍ (...)"[988]ទៅអង្គបុរេជំនុំជម្រះ។ នៅក្នុងក្របខណ្ឌនេះ នៅពេលដែលជនរងគ្រោះបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងបន្តបណ្តឹងរដ្ឋប្បវេណីទៀត លើកលែងតែមានដីកាសម្រេចដែលមានសំអាងហេតុ ដែលចេញដោយសហចៅក្រមស៊ើបអង្កេត ប្រកាសបដិសេធពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ។ យោងទៅលើវិធានផ្ទៃក្នុង ២៤(៤) "ជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលស៊ើបសួរ មិនតម្រូវអោយដាក់ពាក្យជាថ្មីម្តងទៀតនៅចំពោះមុខអង្គជំនុំជម្រះឡើយ"។

៤៧២. គ្មានការអនុញ្ញាតឱ្យសម្រេច "ទទួលស្គាល់ជាបណ្តោះអាសន្ន" និងទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានចែងច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) នោះឡើយ។ អានុភាពគតិយុត្តិនៃការទទួលស្គាល់ជាបណ្តោះអាសន្ន ឬភាពអាចឬមិនអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងអានុភាពរួមនៃទង្វើទាំងនេះ នាំឱ្យមានការបកស្រាយផ្សេងៗគ្នា[989]។ ដូចដែលមានបញ្ជាក់នៅក្នុងលិខិតរបស់

---

[988]វិធានផ្ទៃក្នុង ២៣(៣) នៃវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៣)។ *សូមមើលផងដែរ* វិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៣)។

[989]*សូមមើលឧទា.* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខឯកសារ D250/3/3, ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកាសម្រេចលេខ D250/3/2, ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១០, ឯកសារលេខ D250/3/2/1/5។ "មតិយោបល់របស់ចៅក្រម ចៅក្រម Marchi-Uhel ចៅក្រម ហួត វុទ្ធី និងចៅក្រម ន័យ ថុល ទាក់ទងនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយក", កថាខណ្ឌ ១១ (បញ្ជាក់ថា ទោះបីជា"ឋានៈបណ្តោះអាសន្នមិនអាចបំពេញលក្ខខណ្ឌនៃសច្ចភាព ដូចមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏ឋានៈនេះមានប្រយោជន៍សម្រាប់ជនរងគ្រោះជាងសេចក្តីសម្រេចសេចក្តីសម្រេចតឹងរ៉ឹងដែលបដិសេធអ្នកដាក់ពាក្យសុំនូវសិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី"។ ប៉ុន្តែ "មតិរបស់ចៅក្រម ROWAN DOWNING និងចៅក្រម ប្រាក់ គីមសាន ទាក់ទងទៅនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវ

ក្រឡាបញ្ជីខាងលើ សហចៅក្រមស៊ើបអង្កេតបានបកស្រាយវិធានផ្ទៃក្នុងថា មិនតម្រូវឱ្យខ្លួនចេញសេចក្តីសម្រេច“ជាផ្លូវការ”ទៅលើភាពអាច ឬមិនអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ ហើយ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតត្រូវគិតថាខ្លួនពុំជាប់កាតព្វកិច្ចដោយលិខិត “ទទួលស្គាល់ជាបណ្តោះអាសន្ន”នោះឡើយ។

៤៧៣. នៅដំណាក់កាលជំនុំជម្រះ ជនរងគ្រោះអាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅអង្គជំនុំជម្រះសាលាដំបូងយ៉ាងតិចដប់ថ្ងៃមុនកាលបរិច្ឆេទនៃសវនាការបឋម[990]។ នៅក្នុងពេលសវនាការបឋម“អង្គជំនុំជម្រះសាលាដំបូង ត្រូវពិនិត្យរាល់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ ដូចមានចែងក្នុងវិធាន ២៣(៤)”[991]។ អង្គជំនុំជម្រះសាលាដំបូង “តាមរយៈសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយមានសំអាងហេតុ អាចសម្រេចថា ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមិនអាចទទួលយកបាន” ដោយហេតុថាពាក្យសុំនោះមិនបានដាក់ឱ្យទាន់ពេលវេលា ឬដោយពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់[992]។ អំណាចនេះត្រូវបានបង្កើតឡើង ដើម្បីការពារផលប្រយោជន៍របស់ភាគីដែលរួមមានជនរងគ្រោះ និងជនត្រូវចោទ[993] និងដើម្បីគោរពផលប្រយោជន៍សេដ្ឋកិច្ចនៃកិច្ចដំណើរ

បានទទួលស្គាល់”, កថាខណ្ឌ ៨ ដល់ ១២ (សម្រេចថា ដំណើរការពីរជំហានរំលោភទៅលើលក្ខខណ្ឌតម្រូវជាមូលដ្ឋានសម្រាប់សច្ចភាពផ្លូវច្បាប់ និងភាពយុត្តិធម៌លើដំណើរការនីតិវិធី។ ពួកគាត់បានពិចារណាថា លិខិតទទួលស្គាល់បណ្តោះអាសន្ន ដែលចេញដោយក្រឡាបញ្ជីតំណាងឱ្យសេចក្តីសម្រេចជាផ្លូវការដោយសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) និងយល់ឃើញថា អនុលោមតាមច្បាប់ជាធរមាន ស.ច.ស មិនអាចចេញសេចក្តីសម្រេចនៅពេលក្រោយទៀតទៅលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ ពីព្រោះវិធានផ្ទៃក្នុងពុំបានចែងឱ្យមានការចេញសេចក្តីសម្រេចពីរដង ទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតែមួយឡើយ ហើយការធ្វើបែបនេះ នឹងនាំឱ្យសហចៅក្រមស៊ើបអង្កេតអនុវត្ត *ហួសដែនអំណាចរបស់ខ្លួន* និងរំលោភទៅលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបាននូវ “ភាពយុត្តិធម៌លើដំណើរការនីតិវិធី”)។

[990] វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង។

[991] វិធាន ៨៣(១) នៃវិធានផ្ទៃក្នុង។

[992] វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង។

[993] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

00798698



ការនីតិវិធី[994] ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការប្រើប្រាស់អំណាចនេះស្ថិតលើឆន្ទានុសិទ្ធិរបស់តុលាការដែរ។ ដោយហេតុថា ពុំមានការកំណត់អំពីកាលបរិច្ឆេទចុងក្រោយសម្រាប់ការចេញសេចក្តីសម្រេចបែបនេះ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង អាចប្រកាសបដិសេធមិនទទួលយកពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលណាមួយ នៅក្នុងដំណាក់កាលជំនុំជម្រះនៃរឿងក្តីនេះបាន។ បើពុំមានសេចក្តីសម្រេចបែបនេះទេ នោះអ្នកដាក់ពាក្យសុំនឹងត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងសវនាការក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។

៤៧៤. ដោយហេតុថា នៅក្នុងវិធាននៃផ្ទៃក្នុងពុំមានចែងអំពីការអនុញ្ញាតឱ្យសម្រេច“ទទួលស្គាល់ជាបណ្តោះអាសន្ន” និងទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយអង្គជំនុំជម្រះសាលាដំបូងទេ ដូចនេះអានុភាពនៃទង្វើណាមួយ ឬក៏អានុភាពរួមគ្នានៃទង្វើទាំងនេះ ត្រូវស្ថិតនៅលើការបកស្រាយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏វិធាន ១០០(១) នៃវិធានផ្ទៃក្នុង និងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ បានចែងដូចគ្នាថា “អង្គជំនុំជម្រះត្រូវសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីនៅក្នុងសាលក្រម។ អង្គជំនុំជម្រះត្រូវសម្រេចអំពីភាពដែលអាចទទួលយកបាន និងខ្លឹមសារនៃការទាមទារចំពោះជនជាប់ចោទ”[995]។

៤៧៥. ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធ ក្នុងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វិធាន ២៣(៤) នៃវិធានផ្ទៃក្នុងបានចែងថា “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបើកផ្លូវឱ្យប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល” “លើកលែងតែពាក្យសុំនោះត្រូវបានបដិសេធចោល ដោយសារមិនគោរពពេលកំណត់ដែលមានចែងនៅក្នុងអនុវិធាននេះ”។ វិធាន ១០៤(៤)(ង) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) បានបញ្ជាក់បន្ថែមទៀតថា “សេចក្តីសម្រេច”ដែលអាចប្តឹងសាទុក្ខបានដោយយោងតាមវិធាន ២៣(៤) នៃវិធានផ្ទៃក្នុងនេះ គឺជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេច“បដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី”។ វិធានផ្ទៃក្នុងមិនបានកំណត់ឡើយទាក់ទិនទៅនឹងបញ្ហា ថាតើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលសម្រេចច្រានចោល

---

[994] វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

[995] វិធាន ១០០(១) នៃវិធានផ្ទៃក្នុង។

ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលសម្រេចមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពត្រឹមតែជា"លក្ខខណ្ឌតម្រូវបឋម" ឬក៏ជាសេចក្តីសម្រេចដែលមានអានុភាពជាស្ថាពរអំពីភាពអាចទទួលយកបាននេះ ដែលជាហេតុរារាំងដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចឡើងវិញអំពីបញ្ហានេះ ដោយអនុលោមតាមវិធាន ១០០(១) នៃវិធានផ្ទៃក្នុង[996] ដែរ ឬយ៉ាងណា។

### *៦.ខ.៥.គ.ការអនុវត្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ*

៤៧៦. ឆ្លើយតបចំពោះអំណះអំណាងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះបានប្រើប្រាស់ វិធីសាស្ត្រ*សេចក្តីបញ្ជាក់ដំបូង* ដើម្បីធ្វើការវាយតម្លៃអំពីភាពជឿជាក់ចំពោះព័ត៌មានដែលផ្តល់ដោយអ្នកដាក់ពាក្យសុំ ស្របតាមការអនុវត្តរបស់តុលាការអន្តរជាតិ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានោះ ឃើញថាមានទទ្បីករណ៍មួយបានលើកឡើងម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីថា នីតិវិធីដែលមានពីរដំណាក់កាលបែបនេះ មិនមានការគាំទ្រក្នុងការអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ឡើយ[997]។ ដើម្បីឆ្លើយតបទៅនឹងអំណះអំណាងនេះអង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណា ថាតើវិធានដែលបង្កើតឡើងដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា បានគាំទ្រការអះអាងនេះ ដែរ ឬទេ ហើយប្រសិនបើមានការគាំទ្រមែន ថាតើស្ថិតត្រឹមកម្រិតណាដែរ។

---

[996]បញ្ហាចុងក្រោយនេះ មិនពាក់ព័ន្ធចំពោះបណ្តឹងសាទុក្ខឡើយ ហើយដោយសារតែមានការកែប្រែនៅក្នុងវិធានផ្ទៃក្នុង បញ្ហានេះ នឹងមិនកើតមានឡើយនៅក្នុងយុត្តិសាស្ត្រនារបស់តុលាការនាពេលអនាគតឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា សាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខភ្លាមៗ គឺជាសាលដីកាស្ថាពរ និងមានកាតព្វកិច្ចអនុវត្តតាមច្បាប់ និងជាសាលដីកាស្ថាពរ និងមានកាតព្វកិច្ចអនុវត្តតាមស្ថានភាពនៃអង្គហេតុដែលយកមកវិនិច្ឆ័យ។ ដូច្នេះ សេចក្តីសម្រេចទទួលយករបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ ស្តីពីភាពអាចទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនឹងចូលជាស្ថាពរ ទាក់ទិននឹងស្ថានភាពនៃភ័ស្តុតាងដែលមាននៅពេលធ្វើការវិនិច្ឆ័យ ដោយមិនធ្វើឲ្យប៉ះពាល់ដល់សំអាងហេតុថ្មីៗ ដោយផ្អែកលើភ័ស្តុតាងថ្មីដែលបានផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។

[997]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ២១ ដល់ ២៨។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣, កថាខណ្ឌ ៣៨។ បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣, កថាខណ្ឌ ៣៨។

៤៧៧. ក្រៅពី អ.វ.ត.ក ក៏នៅមានតុលាការឧក្រិដ្ឋកម្មដែលមានចរិតលក្ខណៈអន្តរជាតិពីរទៀត គឺតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ (STL) ដែលអនុញ្ញាតឱ្យមានការចូលរួមរបស់ជនរងគ្រោះ។ ក្នុងចំណោមតុលាការទាំងពីរនេះ គឺមានតែតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ប៉ុណ្ណោះ ដែលមានយុត្តាធិការផ្តល់សំណងដល់ជនរងគ្រោះ។ នៅក្នុងផ្នែកនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិចារណាលម្អិតតែទៅលើឋានៈរបស់ជនរងគ្រោះដែលអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC)ប៉ុណ្ណោះ ហើយអង្គជំនុំជម្រះតុលាការកំពូល នឹងពិចារណាតែលើក្របខណ្ឌគតិយុត្តរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ (STL) ដោយហេតុថា ការអនុវត្តនៅតុលាការនេះកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍប៉ុណ្ណោះ។

៤៧៨. ដើម្បីពិចារណាអំពីប្រព័ន្ធស្តីពីឋានៈជនរងគ្រោះ នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) គួរមានការកត់សម្គាល់អំពីភាពខុសគ្នាមួយយ៉ាងសំខាន់។ នៅអ.វ.ត.ក ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រួមបញ្ចូលជាស្វ័យប្រវត្តិនូវសិទ្ធិចូលរួមយ៉ាងពេញលេញដែលដើមបណ្តឹងរដ្ឋប្បវេណីមាន ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាននៃផ្ទៃក្នុង នៅមុនដំណាក់កាលជំនុំជម្រះ ដំណាក់កាលជំនុំជម្រះ នៅអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល។ ផ្ទុយទៅវិញ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ជនរងគ្រោះមិនមានឋានៈជាភាគីមួយនៅក្នុងកិច្ចដំណើរការនីតិវិធីនោះទេ ប៉ុន្តែជនរងគ្រោះមានឋានៈ*ពិសេសរបស់ខ្លួន*។ ដូចមានចែងនៅក្នុងមាត្រា ៦៨(៣)នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) ៖

> កាលណាមានការប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះ តុលាការត្រូវអនុញ្ញាតឱ្យជនរងគ្រោះបង្ហាញនូវទស្សនៈ និងការកង្វល់របស់ខ្លួន ហើយតុលាការត្រូវពិចារណាអំពីបញ្ហានេះ នៅក្នុងដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីដែលតុលាការយល់ឃើញថាសមស្រប និងនៅក្នុងលក្ខណៈមួយដែលមិនប៉ះពាល់ ឬមិន

ស៊ីសង្វាក់គ្នាជាមួយសិទ្ធិរបស់ជនជាប់ចោទ និងការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងភាពមិនលំអៀង[998]។

៤៧៩. ហេតុដូច្នេះ ការផ្តល់នូវឋានៈជាជនរងគ្រោះ មិនមែនផ្តល់ជាស្វ័យប្រវត្តិនូវសិទ្ធិចូលរួមនោះទេ ប៉ុន្តែតុលាការនឹងផ្តល់នូវសិទ្ធិចូលស្តាប់សវនាការ និងសិទ្ធិចូលរួមផ្សេងៗទៀត[999]នៅពេលដែលមានការបង្ហាញអំពីផលប្រយោជន៍ជាក់លាក់ណាមួយប៉ុណ្ណោះ[1000]។

៤៨០. ទាក់ទងនឹងនីតិវិធីទូទៅក្នុងការចូលរួមជាជនរងគ្រោះ វិធាននីតិវិធីនិងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បញ្ជាក់ថា ដើម្បី"បង្ហាញទស្សនៈ និងការកង្វល់របស់ខ្លួន" ជន

[998]មាត្រា ៦៨(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការ ICC។

[999]*សូមមើលឧទា. រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Lubanga* "សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា និង មេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I លើការការចូលរួមរបស់ជនរងគ្រោះ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨", កថាខណ្ឌ ៣ (បង្ហាញអំពីអំណាចនាំឱ្យដាក់ភស្តុតាង និងការតវ៉ាភាពអាចទទួលយកបាននូវភស្តុតាង)។

[1000]*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Katanga និង Chui*, សំណុំរឿងលេខ (ICC-01/04-01/07-2288), "សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Katanga ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០ ដែលមានចំណងជើងថា"សេចក្តីសម្រេចលើទម្រង់នៃការចូលរួមរបស់ជនរងគ្រោះនៅពេលសវនាការ""របស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៩។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Lubanga*, (ICC-01/04-01/06-1119) "សេចក្តីសម្រេចលើការចូលរួមរបស់ជនរងគ្រោះ" របស់អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ កថាខណ្ឌ ៩៦៖ (បានសម្រេចថា "បន្ទាប់ពីមានសេចក្តីសម្រេចបឋមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា ជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី [ឧទា. ឋានៈជាជនរងគ្រោះ] បន្ទាប់ពីនោះមកដើម្បីចូលរួមនៅក្នុងដំណាក់កាលជាក់លាក់ក្នុងកិច្ចដំណើរការនីតិវិធី ឧទា. ក្នុងអំឡុងពេលសួរដេញដោលសាក្សីជាក់លាក់ ឬការពិភាក្សាអំពីបញ្ហាផ្នែកច្បាប់ជាក់លាក់ ឬប្រភេទនៃភស្តុតាង ជនរងគ្រោះនឹងតម្រូវឱ្យបង្ហាញនូវមូលហេតុនៅក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរដាច់ដោយឡែក ថាហេតុអ្វីបានជាផលប្រយោជន៍របស់គាត់ត្រូវបានប៉ះពាល់ដោយភស្តុតាង ឬបញ្ហាដែលកើតមាននៅក្នុងរឿងក្តី និងលក្ខណៈ និងវិសាលភាពនៃការចូលរួមដែលពួកគាត់ស្វះស្វែងរក។ ផលប្រយោជន៍ទូទៅនៅក្នុងលទ្ធផលនៃរឿងក្តី ឬនៅក្នុងបញ្ហានានា ឬភស្តុតាង ដែលអង្គជំនុំជម្រះនឹងធ្វើការពិចារណានៅដំណាក់កាលនោះ គឺហាក់បីដូចជាមិនគ្រប់គ្រាន់ឡើយ"។ "មតិយោបល់ជំទាស់ និងដាច់ដោយឡែករបស់ចៅក្រម René Blattmann", កថាខណ្ឌ ២១ ដល់ ២២, ៣១។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Lubanga*, "សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា និង មេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I លើការការចូលរួមរបស់ជនរងគ្រោះ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨", កថាខណ្ឌ ៩៩។

រងគ្រោះ"ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលតុលាការ"[1001]។ រដ្ឋបាលតុលាការបញ្ជូនពាក្យសុំទៅអង្គជំនុំជម្រះដែលពាក់ព័ន្ធ អង្គជំនុំជម្រះអាចបដិសេធចោលពាក្យសុំ នៅពេលអ្នកដាក់ពាក្យសុំមិនមែនជាជនរងគ្រោះ ឬមិនត្រូវបានបំពេញតាមលក្ខខណ្ឌនៅក្នុងមាត្រា ៦៨(៣) នៃលក្ខន្តិកៈ។ "ជនរងគ្រោះណាមួយ ដែលពាក្យសុំរបស់ខ្លួនត្រូវបានបដិសេធចោលនោះ អាចដាក់ពាក្យសុំជាថ្មី នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលក្រោយៗទៀតបាន"[1002]។ ដើម្បីទទួលយកពាក្យសុំ អង្គជំនុំជម្រះដែលពាក់ព័ន្ធត្រូវ"បញ្ជាក់ពីកិច្ចដំណើរការនីតិវិធី និងរបៀបនៃការចូលរួមដែលចាត់ទុកថាសមស្រប"[1003]។ គួរកត់សម្គាល់ថា "អង្គជំនុំជម្រះអាច*កែប្រែ*សេចក្តីសម្រេចរបស់ខ្លួន ដែលបានសម្រេចកន្លងមកបាន"[1004]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ក្នុងការកែប្រែសេចក្តីសម្រេចរបស់ខ្លួនដែលបានធ្វើកន្លងមក មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងកិច្ចការ ដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក បានធ្វើឡើងទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដូចបានរៀបរាប់ខាងលើ។

៤៨១. នៅក្នុងការអនុវត្តជាក់ស្តែង តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានបង្កើតវិធីសាស្ត្រមួយដែល មានលក្ខណៈអនុគ្រោះដល់ការចូលរួមរបស់ជនរងគ្រោះ នៅក្រោយដំណាក់កាលស៊ើបអង្កេត[1005]ដោយសម្រេចថា បុគ្គលទាំងឡាយដែលបានទទួលឋានៈជាជនរងគ្រោះនៅមុខអង្គ

---

[1001]វិធាន ៨៩(១) វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងរបស់តុលាការ ICC។

[1002]វិធាន ៨៩(២) វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងរបស់តុលាការ ICC។

[1003]វិធាន ៨៩(១) វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងរបស់តុលាការ ICC។

[1004]វិធាន ៩១(១) វិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងរបស់តុលាការ ICC (សេចក្តីបញ្ជាក់បន្ថែម)។

[1005]*ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យនៅប្រទេសកុងហ្គោ*, សំណុំរឿងលេខ ICC-01/04-556, "សាលដីកាស្តីពីការចូលរួមរបស់ជនរងគ្រោះ នៅក្នុងដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធីនៅក្នុងបណ្តឹងសាទុក្ខរបស់ OPCD ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧ និងបណ្តឹងសាទុក្ខរបស់ OPCD និងរដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០០៧" អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ២,៤៣ ដល់ ៤៤, ៥៧, ៥៩ (ដែលអះអាងថាជនរងគ្រោះលែង

បុរេជំនុំជម្រះ រួចហើយ ត្រូវអនុញ្ញាតជាស្វ័យប្រវត្តិឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលជំនុំជម្រះ ដោយមិនតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងចុះបញ្ជី និងវាយតម្លៃពាក្យសុំរបស់ពួកគេទៀតឡើយ[1006]។ ប៉ុន្តែ ការសម្រេចបែបនេះបង្ហាញឱ្យឃើញត្រឹមតែជាការសន្មតទុកជាមុនអំពីផលប្រយោជន៍ផ្លូវច្បាប់ក្នុងការបន្តចូលរួមរបស់ជនរងគ្រោះរហូតដល់ដំណាក់កាលជំនុំជម្រះ ជាជាងការលើកទឡ្ហីករណ៍ថា ការសម្រេចបែបនេះ គឺជាការសម្រេចស្ថាពរអំពីឋានៈរបស់ជនរងគ្រោះដោយអង្គបុរេជំនុំជម្រះសម្រាប់កិច្ចដំណើរការនីតិវិធី ដែលត្រូវមានបន្តទៀត។ ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានសម្រេចថា ដើម្បីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំរបស់ភាគីជនរងគ្រោះ ដែលបានចូលរួមក្នុងនីតិវិធី អង្គជំនុំជម្រះ“នឹងមិនធ្វើការសាកសួរអំពីបញ្ហា

---

ទទួលបានសិទ្ធិទូទៅ ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលស៊ើបអង្កេតនៃស្ថានការណ៍នេះ) ទទួលស្គាល់នៅក្នុង*ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យក្នុងប្រទេសកុងហ្គោ*, សំណុំរឿងលេខ ICC-01/04 “សេចក្តីសម្រេចស្តីពីការចូលរួមរបស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធីទាក់ទងនឹងស្ថានការណ៍នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ”, អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ១៥ ដល់ ១៧។

[1006] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Katanga និង Chui*, សំណុំរឿងលេខ ICC-01/04-01/07-933-tENG, “សេចក្តីសម្រេចលើការពិចារណាអំពីពាក្យសុំចូលរួម” អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ១០។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Bemba*, ICC-01/05-01/08, “សេចក្តីសម្រេចកំណត់ឋានៈជនរងគ្រោះចំនួន ៥៤ នាក់ ដែលបានចូលរួម នៅដំណាក់កាលមុនជំនុំជម្រះនិងស្នើឱ្យភាគីដាក់សេចក្តីសន្និដ្ឋានទៅលើពាក្យសុំចូលរួមរបស់អ្នកដាក់ពាក្យសុំចំនួន ៨៦ នាក់” អង្គជំនុំជម្រះសាលាដំបូង III ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១០ កថាខណ្ឌ ១៧ ដល់ ២២។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Banda and Jerbo*, សំណុំរឿងលេខ ICC-02/05-03/09-231, “សាលក្រមលើរបាយការណ៍ក្រឡាបញ្ជីស្តីពីពាក្យសុំចំនួនប្រាំមួយ ដើម្បីចូលរួមកិច្ចដំណើរការនីតិវិធី” របស់អង្គជំនុំជម្រះសាលាដំបូង IV កថាខណ្ឌ ១៥ ដល់ ១៧។ ទោះបីជា អង្គជំនុំជម្រះសាលាដំបូងI វាយតម្លៃលើបណ្តឹងស្នើសុំឋានៈជាជនរងគ្រោះរបស់បុគ្គលចំនួនបួនរូប ដែលត្រូវបានផ្តល់ឋានៈដោយអង្គបុរេជំនុំជម្រះ។ ជនរងគ្រោះទាំងបួនរូបនេះ បានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងត្រូវបានផ្តល់សិទ្ធិឱ្យចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំនៅក្នុងរឿងក្តីរបស់អង្គជំនុំជម្រះតុលាការកំពូល។ *រឿងក្តី Lubanga*, សំណុំរឿងលេខ ICC-01/04-01/06-1119, “សាលក្រមលើការចូលរួមរបស់ជនរងគ្រោះ”, អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ កថាខណ្ឌ ១១២។ *រឿងក្តី Lubanga*, សំណុំរឿងលេខ ICC-01/04-01/06-1556, “សាលក្រមលើបណ្តឹងរបស់ជនរងគ្រោះដើម្បីចូលរួមកិច្ចដំណើរការនីតិវិធី”, អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៥៤ ដល់ ៥៩។

ឋានៈរបស់ជនរងគ្រោះនោះទេ ប៉ុន្តែ នឹងត្រូវសាកសួរដំណាក់កាលបន្ទាប់ទៀតអំពីបញ្ហាថាតើមានការប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះដោយសារបណ្តឹងសាទុក្ខបន្ទាន់បន្ទំនេះដែរ ឬយ៉ាងណា"[1007]។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនៅតែអាចបដិសេធការចូលរួមរបស់ជនរងគ្រោះបានដែរ ចំពោះស្ថានភាពដែលជនរងគ្រោះត្រូវបានអនុញ្ញាតរួចហើយ ឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធី នៅដំណាក់កាលបុរេជំនុំជម្រះ[1008] ដោយផ្អែកលើមូលដ្ឋានការចោទប្រកាន់ដែលជាយថាហេតុ មិនទាន់មានការសម្រេចច្បាស់លាស់ដោយអង្គបុរេជំនុំជម្រះ ឬនៅពេលដែលមានអង្គហេតុថ្មីដែលបង្ហាញឱ្យឃើញថា ការផ្តល់ឋានៈឱ្យជនរងគ្រោះ មិនមានមូលដ្ឋានត្រឹមត្រូវ[1009]។

---

[1007] *រឿងក្តី* *Lubanga,* សំណុំរឿងលេខ ICC-01/04-01/06-1335, "សាលដីកានៅពេលជិតចាប់ផ្តើមសវនាការលើការចូលរួមរបស់ជនរងគ្រោះនៅក្នុងបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សេចក្តីសម្រេចលើការចូលរួមរបស់ជនរងគ្រោះ"" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ៣៧។ *សូមមើលផងដែរ រឿងក្តី Bemba,* សំណុំរឿងលេខ ICC-01/05-01/08, "សាលដីកាសម្រេចលើការចូលរួមរបស់ជនរងគ្រោះនៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹង"សេចក្តីសម្រេចលើពាក្យសុំដោះលែងបណ្តោះអាសន្ន", អង្គជំនុំជម្រះសាលាដំបូង III" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ ៨។

[1008] *រឿងក្តី Katanga និង Chui* "សេចក្តីសម្រេចលើការពិចារណាអំពីពាក្យសុំចូលរួម", កថាខណ្ឌ ១១។ *រឿងក្តី Bemba* "សេចក្តីសម្រេចកំណត់ឋានៈជនរងគ្រោះចំនួន ៥៤ នាក់ ដែលបានចូលរួមនៅដំណាក់កាលមុនជំនុំជម្រះនិងស្នើឱ្យ ភាគីដាក់សេចក្តីសន្និដ្ឋានទៅលើពាក្យសុំចូលរួមរបស់អ្នកដាក់ពាក្យសុំចំនួន ៨៦ នាក់" កថាខណ្ឌ ១៩ (អង្គជំនុំជម្រះ ឯកភាពថាការចូលរួមមិនអាចបន្តទៀតបានទេប្រសិនបើព្រឹត្តិការណ៍ដែលបានលើកឡើងថាបានទទួលរងនោះ តាមការអង្កេតបឋមមិនមែនជាលទ្ធផលនៃបទឧក្រិដ្ឋយ៉ាងតិចមួយដែលត្រូវបានអះអាង ដោយអង្គបុរេជំនុំជម្រះ នោះឡើយ)។

[1009] *រឿងក្តី Katanga និង Chui* "សេចក្តីសម្រេចលើការពិចារណាអំពីពាក្យសុំចូលរួម", កថាខណ្ឌ ១២។ ("វាអាច ដូច្នេះមែន ឧទាហរណ៍ សម្រាប់ជនរងគ្រោះដែលត្រូវបានអនុញ្ញាតដោយខុសឆ្គងឱ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិ វិធីដោយផ្អែកលើមូលដ្ឋាននៃឯកសារគាំទ្រដែលក្រោយមកបានក្លាយជាគ្មានសុពលភាព។ ក្នុងករណីនោះ គឺជាតួនាទីរបស់ក្រឡាបញ្ជី ឬភាគីនានាធ្វើការជូនដំណឹងភ្លាមទៅអង្គជំនុំជម្រះ ដើម្បីឱ្យអង្គជំនុំជម្រះអាចសម្រេចលើបញ្ហា នោះ")។

៤៨២. មានមធ្យោបាយមួយផ្សេងទៀតសម្រាប់ការចូលរួមរបស់ជនរងគ្រោះ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) គឺនៅពេលដែលតុលាការនេះសម្រេចអំពីពិរុទ្ធភាពលើជនជាប់ចោទ។ អនុលោមតាមមាត្រា ៧៥(១)នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)៖

> តុលាការត្រូវបង្កើតគោលការណ៍នានាដែលទាក់ទងនឹងសំណង ឬទាក់ទងនឹងជនរងគ្រោះរួមមាន បដិទាន សំណងជំងឺចិត្ត និងការស្តារនីតិសម្បទាឡើងវិញ។ ដោយឈរលើមូលដ្ឋាននេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន [ពោលគឺ សាលក្រម/សាលដីកា] តុលាការអាចសម្រេចតាមសំណើ ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួននៅក្នុងកាលៈទេសៈពិសេសអំពីកម្រិតវិសាលភាព និងកម្រិតនៃការខូចខាត ការបាត់បង់ និងព្យសនកម្មណាមួយ ឬទាក់ទងនឹងជនរងគ្រោះ ហើយបញ្ជាក់ពីគោលការណ៍អនុវត្ត។

៤៨៣. ចំពោះការទាមទារសំណងវិញ បុគ្គលណាមួយដែលមានឋានៈជាជនរងគ្រោះក្នុងគោលបំណងចូលរួមក្នុងនីតិវិធីជំនុំជម្រះក្តី មិនមានសិទ្ធិជាស្វ័យប្រវត្តិក្នុងការទទួលបានសំណងទេ។ ដូចដែលបានលើកឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ថា "ការចូលរួមរបស់ជនរងគ្រោះ នៅពេលជំនុំជម្រះ (...) មិនមែនជាបុរេលក្ខខណ្ឌសម្រាប់ទាមទារសំណងនោះទេ" ដោយហេតុថា "សំណងដែលបានកំណត់ក្នុងលក្ខន្តិកៈ អាចទាមទារបានតែពីបុគ្គលដែលត្រូវបានរកឃើញថាមានពិរុទ្ធភាពប៉ុណ្ណោះ (មាត្រា ៧៧ (២))"[1010]។ ដោយហេតុថា លក្ខខណ្ឌតម្រូវនៃទំនាក់ទំនងរវាងការទាមទារសំណង និងការរកឃើញថាមានពិរុទ្ធភាព គឺជាលទ្ធភាពមួយដែលថា អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) នឹងវាយតម្លៃឡើងវិញអំពីឋានៈជនរងគ្រោះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ដើម្បីសម្រេចអំពីការផ្តល់សំណង។

[1010] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Lubanga*, ICC-01/04-01/06-1432, "សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញានិងមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I លើការចូលរួមរបស់ជនរងគ្រោះ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ "យោបល់ជំទាស់ដោយផ្នែករបស់ចៅក្រម G. M. Pikis", កថាខណ្ឌ ១៨។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញាទល់នឹង Katanga និង Chui*, ICC-01/04-01/07-1491-Red-tENG, "មូលដ្ឋានចំពោះសេចក្តីសម្រេចលើពាក្យសុំចូលរួមចំនួន ៣៤៥ នៅក្នុងកិច្ចដំណើរការនីតិវិធីដែលបានដាក់ដោយជនរងគ្រោះ" អង្គជំនុំជម្រះសាលាដំបូង II ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៩, កថាខណ្ឌ ៥៥។

៤៨៤. ជាការសន្និដ្ឋាន ដោយផ្អែកតាមមាត្រា ៦៨(៣) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) អង្គជំនុំជម្រះតុលាការនេះបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងទូលាយ ក្នុងការសម្រេចអំពីការចូលរួមរបស់ជនរងគ្រោះ នៅតាមដំណាក់កាលផ្សេងៗគ្នានៃកិច្ចដំណើរការនីតិវិធី។ ដោយអនុលោមតាមលក្ខន្តិកៈ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបានសម្រេចទទួលស្គាល់ឋានៈជាជនរងគ្រោះរួចហើយ មិនមានអានុភាពចងកាតព្វកិច្ចដល់អង្គជំនុំជម្រះនេះមិនឱ្យកែប្រែសេចក្តីសម្រេចរបស់ខ្លួននោះឡើយ។ ក្របខណ្ឌគតិយុត្តសម្រាប់ការចូលរួមរបស់ជនរងគ្រោះ (*ក្នុងន័យទូលាយ* (*sensu largo*) ដែលរួមបញ្ចូលផងដែរនូវការទាមទារសំណង) មិនបានកំណត់ឱ្យបានច្បាស់អំពីការវាយតម្លៃឡើងវិញ លើឋានៈរបស់ជនរងគ្រោះនោះទេ ហើយក៏មិនបានបដិសេធមិនឱ្យវាយតម្លៃឡើងវិញបែបនេះដែរ។ ដូចដែលបានបង្ហាញខាងលើ យុត្តិសាស្ត្ររបស់តុលាការដែលកំណត់អំពីកាលៈទេសៈ ដែលនាំឱ្យមានការបដិសេធឋានៈជនរងគ្រោះនោះគឺអាចបណ្តាលមកពី ការដាក់ភស្តុតាងថ្មី ការផ្លាស់ប្តូរប្រភេទគតិយុត្តនៃអង្គហេតុចោទប្រកាន់ ឬការបំពេញនូវលក្ខណៈវិនិច្ឆ័យបន្ថែមដើម្បីអនុញ្ញាតឱ្យជនរងគ្រោះចូលរួមបាននៅក្នុងដំណាក់កាលផ្សេងៗគ្នានៃកិច្ចដំណើរការនីតិវិធី ឬ ការវាយតម្លៃផ្សេងៗអំពីផលប្រយោជន៍របស់ជនរងគ្រោះក្នុងការចូលរួមនេះ[1011]។

៤៨៥. ប្រហាក់ប្រហែលគ្នានឹងប្រព័ន្ធតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ដែរ របបនៃតុលាការពិសេស សម្រាប់ប្រទេសលីបង់ (STL) បានអនុញ្ញាតឱ្យតុលាការមានឆន្ទានុសិទ្ធិ ក្នុងការសម្រេចឱ្យមានការចូលរួមរបស់ជនរងគ្រោះ ដោយយោងលើលក្ខណៈវិនិច្ឆ័យដូចគ្នាដែលមាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។ យោងតាមវិធាននីតិវិធី និងភស្តុតាងរបស់តុលាការ

---

[1011] ទោះបីជាត្រូវបានចេញក្រោយពេលប្រកាសសាលដីកាណ្តឹងសាទុក្ខនេះក៏ដោយ, *សូមមើលរឿងក្តី Lubanga*, សំណុំរឿងលេខ ICC-01/04-01/06-2842, សាលក្រមដោយយោងតាមមាត្រា ៧៤ នៃលក្ខន្តិកៈ, អង្គជំនុំជម្រះសាលាដំបូង I, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២, កថាខណ្ឌ ៤៨៤, ៥០២, ១៣៦២ ដល់ ១៣៦៣។ មតិជំទាស់ដាច់ដោយឡែករបស់ចៅក្រម Odio Benito, កថាខណ្ឌ ២២ ដល់ ៣៥។

ពិសេសសម្រាប់ប្រទេសលីបង់ (STL)[1012] នៅពេលពាក្យសុំរបស់ជនរងគ្រោះដើម្បីចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី[1013] "ត្រូវបានពិនិត្យថា មានលក្ខណៈគ្រប់គ្រាន់" តាមទម្រង់បែបបទរបស់អង្គភាពជនរងគ្រោះរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់(STL) រួចហើយនោះ[1014] ពាក្យសុំនេះត្រូវបានបញ្ជូនទៅចៅក្រមអង្គបុរេជំនុំជម្រះដើម្បីពិនិត្យឡើងវិញ និងធ្វើការសម្រេចលើពាក្យសុំរបស់ជនរងគ្រោះដើម្បីចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ បន្ទាប់ពីពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1015]។ ដំណាក់កាលបន្ទាប់គឺថា "ជនណាដែលត្រូវបានបញ្ជាក់អត្តសញ្ញាណច្បាស់លាស់នៅក្នុងសាលស្ថាពរថាជាជនរងគ្រោះ ឬចាត់ទុកខ្លួនថាជាជនរងគ្រោះ (...) នៃឧក្រិដ្ឋកម្មរបស់ជនជាប់ចោទដែល ត្រូវបានសម្រេចដាក់ពិរុទ្ធភាពដោយតុលាការឧក្រិដ្ឋកម្ម"[1016] អាចប្តឹងទាមទារសំណងនៅចំពោះមុខតុលាការជាតិបាន[1017]។ មិនដូចគ្នាទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) និង អ.វ.ត.ក នោះទេ គឺថា តុលាការពិសេសសម្រាប់ប្រទេសលីបង់ (STL) មិនមានសមត្ថកិច្ចសម្រេចអំពីសំណងឡើយ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដើម្បីឱ្យការទាមទារសំណងនេះអាចធ្វើទៅបានតាមរយៈប្រព័ន្ធតុលាការជាតិនោះ តុលាការពិសេសនេះត្រូវបញ្ជាក់អត្តសញ្ញាណជនរងគ្រោះឱ្យបានច្បាស់លាស់នៅក្នុងសាលក្រម។ ដូច្នេះ បង្ហាញថា "ការបញ្ជាក់អត្តសញ្ញាណនៅក្នុងសាលក្រម" គឺ

---

[1012]វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ STL (អនុម័តនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៩, ធ្វើវិសោធនកម្មនៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ និងធ្វើការកែប្រែនៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០) ("STL RPE") (វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ STL)។

[1013]វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ២ ("ជនរងគ្រោះដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធីៈ ជនរងគ្រោះនៃការវាយប្រហារនៅក្នុងយុត្តាធិការរបស់តុលាការ ដែលត្រូវបានផ្តល់ការអនុញ្ញាតដោយអង្គ បុរេជំនុំជម្រះ ក្នុងការបង្ហាញទស្សនៈរបស់ខ្លួន និងការព្រួយបារម្ភនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីបន្ទាប់ពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ។

[1014]វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ៥១ (ខ)(៣)។

[1015]វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ៨៦។

[1016]វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ៨៦(ឆ)។ *សូមមើលផងដែរ* លក្ខន្តិកៈរបស់តុលាការ STL S/RES/1757(ឆ្នាំ ២០០៧) ("លក្ខន្តិកៈរបស់តុលាការSTL") មាត្រា ២៥។

[1017]វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ៨៦(ឆ)។ និងលក្ខន្តិកៈរបស់តុលាការ STL, មាត្រា ២៥(៤)។

ជាសេចក្ដីសម្រេចស្ថាពរលើឋានៈជនរងគ្រោះ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងអាចផ្លាស់ប្ដូរសេចក្ដីសម្រេចរបស់អង្គបុរេ ដោយយោងតាមលទ្ធផលនៃការជំនុំជម្រះ។

៤៨៦. ដោយពិចារណាអំពីភាពខុសគ្នាជាសារវន្តនៃឋានៈរបស់ជនរងគ្រោះ នៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា និងនៅចំពោះមុខ អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការអនុវត្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះស្ដីពីការណែនាំដល់ការសម្រេចលើភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មានកម្រិតតិចតួច។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ច្បាប់និងការអនុវត្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា មិនគាំទ្រការលើកឡើងរបស់ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណី អំពី“អនីត្យានុកូលភាព”នៃបទដ្ឋានក្នុងការសម្រេចជាពីរដំណាក់កាល ទៅលើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញបន្ថែមទៀតថា ការអនុវត្តនេះ មិនបានផ្ដល់ការគាំទ្រដល់បទដ្ឋាននៃពិនិត្យឡើងវិញជាពីរដំណាក់កាលដែលបានសម្រេចនៅក្នុងសំណុំរឿង ០០១ នោះទេ។

## ៦.២.៦.ការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល

៤៨៧. ដើម្បីដោះស្រាយទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណី អំពីអនីត្យានុកូលភាព និងភាពមិនអាចយល់ដឹងជាមុននូវបទដ្ឋាននៃការសម្រេចជាពីរដំណាក់កាលចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់នូវមូលដ្ឋានដូចខាងក្រោម។

៤៨៨. ទីមួយ ចំណុចដែលខុសគ្នាទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ (STL) គឺថា នៅចំពោះមុខ អ.វ.ត.ក ជនរងគ្រោះមានឋានៈជា

ភាគីមួយ[1018]។ នៅពេលដែលទទួលស្គាល់នៅក្នុងកិច្ចដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីទទួលបាននូវសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងអាចទទួលបាន៖

(១) សិទ្ធិទទួលបាននូវវិធានការការពារ[1019]

(២) សិទ្ធិទទួលបានមេធាវីតំណាង[1020]

(៣) សិទ្ធិអាចត្រូវបានចោទសួរដោយមានវត្តមានមេធាវីរបស់ខ្លួន[1021]

(៤) សិទ្ធិស្នើសុំឱ្យមានកិច្ចស៊ើបសួរ[1022]

(៥) សិទ្ធិប្តឹងឧទ្ធរណ៍[1023]

(៦) ជាទូទៅសិទ្ធិក្នុងការចូលរួមជាភាគីមួយនៅក្នុងបណ្តឹងសាទុក្ខ[1024]

(៧) សិទ្ធិគាំទ្របណ្តឹងអាជ្ញា យោងតាមវិធាន[1025]

(៨) សិទ្ធិទាមទារសំណងផ្លូវចិត្ត និងសមូហភាព[1026]

(៩) សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការជំនុំជម្រះ[1027]

(១០) សិទ្ធិកោះហៅសាក្សី[1028]

(១១) សិទ្ធិមើលសំណុំរឿង[1029]

(១២) សិទ្ធិឆ្លើយតបទៅនឹងអញ្ញត្រកម្ម[1030]

---

[1018]វិធាន ២៣ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣)។ សទ្ទានុក្រមវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) ("ភាគី" សំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី")។

[1019]វិធាន ២៣(៦)(គ) និង ២៩(១) នៃវិធានផ្ទៃក្នុង។

[1020]វិធាន ២៣(៧) និង ៨៣ (១) នៃវិធានផ្ទៃក្នុង។

[1021]វិធាន ២៣(៦)(ក) នៃវិធានផ្ទៃក្នុង។

[1022]វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

[1023]វិធាន ៧៤(៤) នៃវិធានផ្ទៃក្នុង។

[1024]វិធាន ៧៤(៤) នៃវិធានផ្ទៃក្នុង។

[1025]វិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង។

[1026]វិធាន ២៣(១)(ខ) នៃវិធានផ្ទៃក្នុង។

[1027]វិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង។

[1028]វិធាន ៨០(២) នៃវិធានផ្ទៃក្នុង។

[1029]វិធាន ៨៦ នៃវិធានផ្ទៃក្នុង។

00798710



(១៣) សិទ្ធិសួរសំណួរជនជាប់ចោទ[1031]

(១៤) សិទ្ធិស្តាប់ចម្លើយក្នុងសវនាការ[1032]

(១៥) សិទ្ធិដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ[1033] និង

(១៦) សិទ្ធិធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល[1034]

៤៨៩. ដោយហេតុថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការគាំទ្របណ្តឹងរដ្ឋប្បវេណី និងបណ្តឹងអាជ្ញា ដែលរួមបញ្ចូលនូវលទ្ធភាពក្នុងការបង្ហាញភស្តុតាង និងក្នុងការអនុវត្តសិទ្ធិស្តាប់ចម្លើយនៅក្នុងសវនាការ ដើម្បីអាចប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចបាន និងអានុភាពដែលការគាំទ្រនេះ អាចមានទៅលើបញ្ហានៃគុណភាពតទល់ទើបធ្វើឱ្យកិច្ចនីតិវិធីណាមួយ ដែលបណ្តាលឱ្យមានការទទួលស្គាល់បុគ្គលណាម្នាក់ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ មានសារៈសំខាន់ក្នុងការអនុវត្តជាក់ស្តែង។ សារៈសំខាន់នេះកាន់តែមានភាពប្រសើរឡើងថែមទៀត នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនកាន់តែច្រើន។ ហេតុដូច្នេះ យោងតាមទស្សនៈនៃគោលការណ៍មួយចំនួនដូចជាៈ សិទ្ធិទទួលបានមេធាវីការពារក្តី[1035] ការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌[1036] សច្ចភាពផ្លូវច្បាប់[1037] និងផលប្រយោជន៍សេដ្ឋកិច្ចនៃកិច្ចដំណើរការនីតិវិធី[1038] ដែលមានផលប្រយោជន៍ផ្លូវច្បាប់ក្នុងការ"រៀបចំ"កិច្ចដំណើរការនីតិវិធីឱ្យមានស្ថេរភាពនៅមុនពេលចាប់ផ្តើមការជំនុំជម្រះ។

---

[1030] វិធាន ៨៩(២) នៃវិធានផ្ទៃក្នុង។

[1031] វិធាន ៩០(២) នៃវិធានផ្ទៃក្នុង។

[1032] វិធាន ៨៨(១) និង វិធាន៩១(១) នៃវិធានផ្ទៃក្នុង។

[1033] វិធាន ៩២ នៃវិធានផ្ទៃក្នុង។

[1034] វិធាន ៩៤(១)(ក) នៃវិធានផ្ទៃក្នុង។

[1035] វិធាន ២៣(៧) និងវិធាន (៨) នៃវិធានផ្ទៃក្នុង។

[1036] វិធាន ២១(១) (ក) នៃវិធានផ្ទៃក្នុង។

[1037] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[1038] វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

៤៩០. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា តាមវិធាន ៨៣(១) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការ“ពិចារណា”ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលសវនាការបឋមដោយអនុលោមតាមវិធាន ២៣(៤) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) ដែលគ្រាន់តែបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងអាចចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរដោយមានសំអាងហេតុ នៅក្នុងដំណាក់កាលណាមួយក្នុងការជំនុំជម្រះថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា បទប្បញ្ញត្តិទាំងនេះត្រូវបានបកស្រាយថាជាការផ្ដល់ឆន្ទានុសិទ្ធិដោយគ្មានកម្រិតដល់សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូងដើម្បីជម្រើស ថាតើខ្លួនត្រូវធ្វើការពិនិត្យអំពីការទទួលយកបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែរ ឬទេ។ ប៉ុន្ដែការបកស្រាយបែបនេះមិនមានភាពស៊ីសង្វាក់គ្នាទៅនឹងទស្សនៈរបស់ជនរងគ្រោះក្នុងនាមជាភាគីនៃនីតិវិធីព្រហ្មទណ្ឌទេ។ នៅក្នុងបរិបទនេះ ហាក់បីដូចជាមានភាពខុសឆ្គងក្នុងការអនុវត្តតាមឆន្ទានុសិទ្ធិរបស់តុលាការព្រហ្មទណ្ឌអន្ដរជាតិ ដែលមានភាពទូលំទូលាយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា ដោយសារបណ្ដឹងទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីមានចំនួនច្រើន ដូច្នេះតម្រូវឱ្យតុលាការមានការពិចារណាឱ្យបានល្អិតល្អន់ ដើម្បីជៀសវាងកុំឱ្យមានបណ្ដឹងដែលមិនត្រឹមត្រូវ ឬគ្មានមូលដ្ឋានដែលការធ្វើបែបនេះមិនស្របទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ក្នុងការទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីតាមការទទួលខុសត្រូវចំពោះហានិភ័យដោយខ្លួនឯង។ នៅក្នុងករណីបែបនេះ អនុលោមតាមសច្ចភាពផ្លូវច្បាប់ និងផលប្រយោជន៍សេដ្ឋកិច្ចនៃកិច្ចដំណើរការនីតិវិធី ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីគួរតែបានពិនិត្យទៅតាមវិធាន នៅក្នុងជំហានដំបូងបំផុត និងមុនពេលចាប់ផ្ដើមសវនាការជំនុំជម្រះ ដើម្បីឱ្យអ្នកដាក់ពាក្យសុំដែលត្រូវបានបដិសេធមានឱកាសអាចប្ដឹងឧទ្ធរណ៍ ឬអាចបំពេញបន្ថែមលើពាក្យសុំរបស់ខ្លួនដែលមិនគ្រប់គ្រាន់។

៤៩១. នៅពេលនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយមតិភាគតិចរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ដែលថា“លិខិតទទួលស្គាល់ជាបណ្ដោះអាសន្ន” គឺជាសេចក្ដី

00798712



សម្រេចរបស់តុលាការក្នុងការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ដោយទទួលបានបន្ថែមនូវរាល់សិទ្ធិនិងកាតព្វកិច្ចក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី[1039]។ បន្ទាប់ពីចេញសេចក្តីសម្រេចទទួលស្គាល់ទាំងនេះ ចៅក្រមនោះ ត្រូវបានចាត់ទុកថា*បានបំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់*ក្នុងការត្រួតពិនិត្យលើពាក្យសុំទាំងនេះ *(functus officio)*[1040] លើកលែងតែច្បាប់អនុញ្ញាតឱ្យមានការពិនិត្យសេចក្តីសម្រេចទាំងនេះឡើងវិញ។ សេចក្តីសម្រេចបន្តបន្ទាប់ទៀតដែលចេញដោយអង្គជំនុំជម្រះសាលាដំបូងលើបញ្ហាដដែលនេះ គួរតែផ្អែកទៅលើការប្រែប្រួលនៃកាលៈទេសៈនៃរឿងក្តី ភស្តុតាងថ្មី ឬការកើនឡើងនូវលក្ខខណ្ឌតម្រូវនៃកម្រិតភស្តុតាងចំពោះរឿងក្តី ដែលឈានទៅរកដំណាក់កាលថ្មីនៃកិច្ចដំណើរការនីតិវិធី។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សេចក្តីសន្និដ្ឋានទាំងនេះមិនមានមូលដ្ឋានច្បាស់លាស់នៅក្នុងក្របខណ្ឌគតិយុត្តនៃវិធានផ្ទៃក្នុងនាពេលនោះទេ ហេតុដូច្នេះ មិនបានធ្វើឱ្យដីកាក្រោយៗដែលសម្រេចពី“ការទទួលស្គាល់ជាបណ្តោះអាសន្ននេះ”មោឃៈនោះទេ។

៤៩២. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា វិសោធនកម្មជាបន្តបន្ទាប់លើវិធានផ្ទៃក្នុងបានលុបចោលនូវចន្លោះប្រហោងមួយចំនួនពាក់ព័ន្ធនឹងបទប្បញ្ញត្តិ ដែលមានអានុភាពលើការ

---

[1039] សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 និងដីកាសម្រេចឯកសារលេខ D250/3/2 ស្តីពីការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី “មតិយោបល់របស់ចៅក្រមប្រាក់ គីមសាន និងចៅក្រម ROWAN DOWNING ទាក់ទងទៅនឹងការបដិសេធភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានប្រកាស”, កថាខណ្ឌ ១។

[1040] សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 និងដីកាសម្រេចឯកសារលេខ D250/3/2 ស្តីពីការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី “មតិយោបល់របស់ចៅក្រមប្រាក់ គីមសាន និងចៅក្រម ROWAN DOWNING ទាក់ទងទៅនឹងការបដិសេធភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានប្រកាស”, កថាខណ្ឌ ៩។ (“នៅពេលចេញសេចក្តីសម្រេច អនុលោមតាមវិធាន ២៣ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត*បំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់* ពោលគឺខ្លួនបានប្រើប្រាស់អស់អំណាចរបស់ខ្លួនលើករណីនេះរួចហើយ។ សហចៅក្រមស៊ើបអង្កេតមិនអនុញ្ញាតឱ្យចេញសេចក្តីសម្រេចជាលើកទីពីរឡើយ ហើយក៏មិនអនុញ្ញាតឱ្យពិចារណា និងសើរើសេចក្តីសម្រេចរបស់ខ្លួនឡើងវិញដែរ។ ការរក្សាសិទ្ធិនៅក្នុងកថាខណ្ឌ ទីពីរនៃលិខិតនេះ គឺ *ហួសដែនអំណាចរបស់ខ្លួន* បានន័យថា វាហួសពីដែនអំណាចដែលសហចៅក្រមស៊ើបអង្កេតមាន”)។

សម្រេចពី ភាពដែលអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[1041]។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា តាមក្របខណ្ឌនៃវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៣) តុលាការនៅតែមានលទ្ធភាពធ្វើការពិនិត្យឡើងវិញឱ្យបានច្បាស់លាស់និងត្រឹមត្រូវនូវពាក្យសុំទាំងនេះ មុនពេលឈានដល់ដំណាក់កាលចេញសាលក្រម។ ការចេញ“លិខិតទទួលស្គាល់ជាបណ្តោះអាសន្ន”ជាច្រើនដំណាក់កាល និងរួមទាំងការប្រកាសទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី“នៅក្នុងសំណុំរឿង” ហើយនិងការសម្រេចទទួលស្គាល់នៅក្នុង“លិខិតទទួលស្គាល់ជាបណ្តោះអាសន្ន” ដោយរួមបញ្ចូលនូវការពិតដែលថា ទាំងវិធានផ្ទៃក្នុង និង “លិខិតទទួលស្គាល់ជាបណ្តោះអាសន្ន” ពុំបានបញ្ជាក់ច្បាស់លាស់ ថាតើពាក្យសុំនោះត្រូវបានពិនិត្យរួចហើយ ដែរ ឬយ៉ាងណានោះទេ ហើយប្រសិនបើបានពិនិត្យវិញ ថាតើអនុលោមតាមបទដ្ឋាននៃការបង្ហាញភស្តុតាងអ្វី ករណីទាំងអស់នេះអាចបណ្តាលឱ្យមានភាពច្របូកច្របល់អំពីឋានៈតាមផ្លូវច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី[1042]។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា លិខិតទទួលស្គាល់ជាបណ្តោះអាសន្នដែលក្រឡាបញ្ជីរបស់អង្គជំនុំ

[1041]វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៥) ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១០ (វិធាន ៨៣ ត្រូវបាននិរាករណ៍ ហើយវិធាន ២៣ *ស្ទួន* (៣) និងវិធាន ៧៧ *ស្ទួន* ថ្មី បានបង្កើត ដែលជាប់ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ ពុំមែនបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលឡើយ ហើយវិធាននេះចែងថា៖“សេចក្តីសម្រេចរបស់អង្គបុរេ ជំនុំជម្រះបិទផ្លូវតវ៉ា”។ វិធាន ១១០(៥) ដែលត្រូវបានរក្សាទុកមកពីវិធានផ្ទៃក្នុង វិសោធនកម្មលើកទីបួន អនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល “តែលើបញ្ហាផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ”)។

[1042]*សូមមើល* បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ កថាខណ្ឌ ៤៧ (សំដៅលើការបដិសេធមិនទទួលស្គាល់នៅក្នុងសាលក្រមថាជា “សេចក្តីសម្រេចលើកទីពីរ”)។ *សូមមើល*ផងដែរ Silke Studzinsky “ការចូលរួមរបស់ជនរងគ្រោះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” នៅក្នុង *Zeitschrift fur Internationale Strafrechtsdogmatik* ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៨៨៧, អាចមើលបានតាមរយៈ http://www.zis-online.com/dat/artikel/2011_10_627.pdf, ទំព័រ ៨៨៧ (បានលើកឡើងថា“ដោយសារការគាបសង្កត់របស់សាធារណជនឱ្យចាប់ផ្តើមសវនាការឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានចេញសេចក្តីសម្រេចលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីដំបូងឡើយ។ ផ្ទុយមកវិញ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ដល់ពួកគេនូវ “ឋានៈបណ្តោះអាសន្ន ឬបានចាប់ផ្តើមហៅពួកគេថាជា “ដើមបណ្តឹងរដ្ឋប្បវេណី” ទោះបីសេចក្តីសម្រេចស្តីពីការទទួលយកនេះ មិនទាន់បានធ្វើឡើងក៏ដោយ”)។

ជម្រះសាលាដំបូង បានចេញនោះបង្កប់ន័យថា នៅក្នុងពេលបណ្តោះអាសន្ននេះ ការទទួលស្គាល់នឹងមានអានុភាពរហូតត្រឹមពេលសវនាការបឋមតែប៉ុណ្ណោះ ដែលនៅពេលនោះនឹងមានការសម្រេចលើពាក្យសុំ[1043] ហើយសេចក្តីសម្រេចផ្លូវការមួយនឹងធ្វើឡើង ប្រសិនបើមិនបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យផ្លូវច្បាប់សម្រាប់ការកំណត់ឋានៈជនរងគ្រោះ[1044]។ ជុំវិញបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងដែលបានបំពេញកិច្ចនេះ នៅក្នុងពេលសវនាការបឋមក្នុងការពន្យល់*ស្ថានភាពបច្ចុប្បន្ន*របស់ជនរងគ្រោះអាចមិនគ្រប់គ្រាន់នោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពីការពិនិត្យឡើងវិញរបស់ខ្លួនដែលពុំទាន់ចប់សព្វគ្រប់នោះ[1045] ពុំមានលក្ខណៈច្បាស់លាស់នៅឡើយ ដែលយ៉ាងហោចណាស់ ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី "ដែលត្រូវបានទទួលស្គាល់"នៅក្នុងដំណាក់កាលស៊ើបអង្កេត ដែលករណីនេះអាចយល់ថា ជាបញ្ហាពាក់ព័ន្ធនឹងការ

---

[1043] *សូមមើល ឧទា.* លិខិតទទួលស្គាល់បណ្តោះអាសន្ន ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/22/3 ("លិខិតទទួលស្គាល់បណ្តោះអាសន្ន, ឯកសារលេខ E2/22/3") ("២. យោងតាមវិធានការបណ្តោះអាសន្ន លោក លោកស្រី ត្រូវបានទទួលស្គាល់នាពេលនេះជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ពេលធ្វើសវនាការបឋមនៅក្នុងសំណុំរឿងនេះ ដែលនៅពេលនោះពាក្យសុំរបស់លោកលោកស្រីនឹងត្រូវយកមកពិចារណាស្របតាមវិធាន ៨៣ នៃវិធានផ្ទៃក្នុង")។

[1044] *សូមមើល ឧទា.* លិខិតទទួលស្គាល់បណ្តោះអាសន្ន, ឯកសារលេខ E2/22/3 ("៤.អង្គជំនុំជម្រះសាលាដំបូង អាចចេញសេចក្តីសម្រេចផ្លូវការមួយពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃពាក្យសុំរបស់ លោក លោកស្រី ហើយអាចបដិសេធពាក្យសុំទាំងនេះចោលបានប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា លក្ខណៈវិនិច្ឆ័យតាមផ្លូវច្បាប់ដែលកំណត់ឋានៈជនរងគ្រោះដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ពុំត្រូវបានបំពេញ")។

[1045] ប្រតិចារិក ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E1/3.1, ទំព័រ ៣៦ (បន្ទាត់ ២៥) ដល់ ទំព័រ ៣៧ (បន្ទាត់ ៩) ("មុនពេលចេញការទទួលស្គាល់បណ្តោះអាសន្ន អង្គជំនុំជម្រះបានទទួលដោយយកចិត្តទុកដាក់លើពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ហើយអង្គជំនុំជម្រះបានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងបឋម។ នេះពុំមែន ជាការពិនិត្យលើខ្លឹមសារ ឬ លក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ")។

ទទួលស្គាល់បណ្ដោះអាសន្ននៅក្នុងដំណាក់កាលស៊ើបអង្កេតតែប៉ុណ្ណោះ ហើយមិនមែនជាការសម្រេចទទួលស្គាល់ ដោយអង្គជំនុំជម្រះសាលាដំបូងឡើយ[1046]។

៤៩៣. ជាសន្និដ្ឋាន ទោះបីជាមិនអាចលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានបំពេញកិច្ចក្រៅក្របខណ្ឌនៃវិធានផ្ទៃក្នុងក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ក្របខណ្ឌគតិយុត្ត ក្នុងការសម្រេចអំពីភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណី នៅមានលក្ខណៈស្រពេចស្រពិល។ ដូច្នេះភាពស្រពេចស្រពិលនេះកាន់តែធ្វើឱ្យស្មុគស្មាញឡើងៗនៅចន្លោះរវាងដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលជំនុំជម្រះ ដោយមានការប្រកាសជាច្រើនលើកច្រើនសារអំពីឋានៈដើមបណ្ដឹងរដ្ឋប្បវេណី ដោយគ្មានការពិនិត្យឱ្យបានល្អិតល្អន់ទៅលើលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

៤៩៤. ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណី ជំទាស់ទៅនឹងនីត្យានុកូលភាពនៃការវាយតម្លៃជាលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងទៅលើឋានៈដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានធ្វើឡើងនៅក្នុងសាលក្រម និងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយផ្អែកលើវិធាន ១០០(១) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) ជាមូលដ្ឋានគតិយុត្តសម្រាប់ការវាយតម្លៃនេះ[1047]។ ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងថា ពាក្យពេចន៍“បណ្ដឹងទាមទារ”ដែលបានប្រើប្រាស់នៅក្នុងវិធាន ១០០(១) នៃវិធានផ្ទៃក្នុង ពុំរាប់

---

[1046] *សូមមើល ឧទា.* លិខិតទទួលស្គាល់បណ្ដោះអាសន្ន, ឯកសារលេខ E2/22/3 (“២. លោក លោកស្រីត្រូវបានទទួលស្គាល់នាពេលនេះជាដើមបណ្ដឹងរដ្ឋប្បវេណីរហូតដល់ពេលធ្វើសវនាការបឋមនៅក្នុងសំណុំរឿងនេះ ដែលនៅពេលនោះពាក្យសុំរបស់លោកលោកស្រីនឹងត្រូវយកមកពិចារណាស្របតាមវិធាន ៨៣ នៃវិធានផ្ទៃក្នុង”)។

[1047] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៣៦, ជើងទំព័រ ១០៦៤ (ដោយដកស្រង់“‘សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (ក្រុម ២) - ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល’ E159/6 ចុះថ្ងៃទី ១២ [*ទាំងស្រុង*] ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៦ ដល់ ៨ (ដោយស្នើសុំអង្គជំនុំជម្រះ[សាលាដំបូង] ឲ្យចាត់ទុកដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ដែលត្រូវបានទទួលស្គាល់ជាបណ្ដោះអាសន្នជាដើមបណ្ដឹងរដ្ឋប្បវេណី)” ដើម្បីទទួលស្គាល់ថា យ៉ាងហោចណាស់មានមេធាវីតំណាង ដើមបណ្ដឹងរដ្ឋប្បវេណីខ្លះបានយល់ថា នៅពេលនោះ (ថ្ងៃដាក់ឯកសារទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩) លក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចជាស្ថាពរនៅត្រឹមពេលនេះឡើយ។

បញ្ចូលនូវបញ្ហាស្តីពីឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២[1048] បានចង្អុលបង្ហាញយ៉ាងត្រឹមត្រូវលើភាពខុសគ្នារវាងវិធានផ្ទៃក្នុងជាភាសាអង់គ្លេស និង ភាសាបារាំង (វិសោធនកម្មលើកទី ៣)។ ជាការពិត វិធាន ១០០(១) នៃវិធានផ្ទៃក្នុងជា ភាសាបារាំង (វិសោធនកម្មលើកទី ៣) "បានភ្ជាប់ទំនាក់ទំនងរវាងលក្ខខណ្ឌតម្រូវនៃភាពអាច ទទួលយកបាន ទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [សម្រាប់ឋានៈ]" ដែល ករណីនេះពុំមានចែងច្បាស់លាស់នៅក្នុងភាសាអង់គ្លេស និងភាសាខ្មែរឡើយ។ ទោះបីជា យ៉ាងណាក៏ដោយ យោងតាមសំអាងហេតុដូចខាងក្រោម អង្គជំនុំជម្រះតុលាការកំពូលយល់ ឃើញថា ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើវិធាន ១០០(១) នៃវិធានផ្ទៃ ក្នុង មានលក្ខណៈត្រឹមត្រូវ ហើយភាពខុសគ្នារវាងភាសាអង់គ្លេស-ខ្មែរ និងភាសាបារាំងមិន សំខាន់នោះឡើយចំពោះសេចក្តីសន្និដ្ឋាននេះ។

៤៩៥. វិធាន ១០០(១) នៃវិធានផ្ទៃក្នុង មានអត្ថន័យដូចគ្នានឹងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជាឆ្នាំ ២០០៧ ត្រង់ខ្លឹមសារដែលចែងយ៉ាងច្បាស់ថា៖ "នៅក្នុងសាលក្រមតែមួយជាមួយ រឿងព្រហ្មទណ្ឌ តុលាការ[ជាន់ដំបូង]សម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។ តុលាការ វិនិច្ឆ័យអំពីភាពអាចទទួលយកបាននៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសម្រេច អំពីពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើជនជាប់ចោទ និងលើអ្នកទទួលខុសត្រូវ រដ្ឋប្បវេណី"[1049]។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏បានបញ្ជាក់ច្បាស់ផងដែរថា "ពាក្យសុំតាំង ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" សំដៅលើពាក្យសុំរបស់ជនរងគ្រោះដើម្បីតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណី[1050]។ ពាក្យ"ភាពអាចទទួលយកបាន" ត្រូវបានចែងបំភ្លឺនៅក្នុងមាត្រា ១៣៨ នៃក្រមនិតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ និងវិធាន ២៣(២) នៃវិធានផ្ទៃក្នុង។ យោងតាមបទប្បញ្ញត្តិទាំងនេះ អង្គហេតុដែលកំណត់អំពីឋានៈរបស់អ្នកដាក់ពាក្យសុំថា ជាជន រងគ្រោះនោះ ត្រូវបានដាក់បញ្ចូលយ៉ាងជាក់លាក់នៅក្នុងចំណោមធាតុផ្សំ ដែលចាំបាច់

---

[1048]បណ្តឹងសាទុក្ខស្តីពីស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ, កថាខណ្ឌ ៣៧។

[1049]មាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។

[1050]មាត្រា ១៣៧, ១៣៨ និង ៣១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។

ត្រូវបង្ហាញដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានមូលដ្ឋានផ្លូវច្បាប់ តាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ក្នុងការសម្រេចអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ នៅក្នុងសាលក្រមរបស់ខ្លួន។

៤៩៦. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពិតជាបានជូនដំណឹងជាមុន និងផ្តល់ឱកាសគ្រប់គ្រាន់ដល់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី។ ជាគោលការណ៍ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មាត្រា ៣៥៥ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ និងវិធាន ១០០(១) នៃវិធានផ្ទៃក្នុង មានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ចំពោះការជូនដំណឹងរួចហើយ។ រាល់មេធាវីជាតិ និងអន្តរជាតិដែលតំណាងឱ្យម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី គួរតែយល់ដឹងអំពីនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលតម្រូវយ៉ាងជាក់លាក់ឱ្យតុលាការជាន់ដំបូងសម្រេចជាចុងក្រោយ លើការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសាលក្រមរបស់ខ្លួន។ ទោះបីជាមានវិមតិសង្ស័យលើការសម្រេចនានារបស់ស្ថាប័ននៃអ.វ.ត.ក នៅក្នុងដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធីក៏ដោយ ក៏ក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក មានលក្ខណៈច្បាស់លាស់ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អង្គជំនុំជម្រះនៅក្នុងការវាយតម្លៃយ៉ាងទូលំទូលាយអំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម។

៤៩៧. លើសពីនេះទៅទៀត បើទោះជាមានការប្រកាសជាច្រើនលើកច្រើនសារអំពីឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចន្លោះរវាងដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពិតជា បានផ្តល់ជាសញ្ញានូវការពុំទាន់បញ្ចប់លើការវាយតម្លៃ*ដែលជាសេចក្តីបញ្ជាក់ដំបូង* នៅក្នុងសវនាការបឋម។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់អំពីការលើកឡើងរបស់ចៅក្រម Lavergne ដែលថា៖

> "ខ្ញុំគិតថា ភាគីទាំងអស់គ្នាយល់យ៉ាងច្បាស់ហើយថា យើងនឹងមិនពិនិត្យលើខ្លឹមសារនៃពាក្យសុំទាំងនេះឡើយ យើងគ្រាន់តែពិចារណាលើអត្ថិភាពនៃការខូចខាតដែលអាច

ទំនងជាមាន។ យើងយល់យ៉ាងច្បាស់ថា ក្នុងពេលសវនាការលើអង្គសេចក្តី យើងត្រូវពិនិត្យមើលពាក្យសុំនីមួយៗដើម្បីឱ្យយើងច្បាស់ទាំងអស់គ្នាថា ការខូចខាតដូចបានចោទប្រកាន់ពិតជាបានកើតឡើងមែន”[1051]។

៤៩៨. អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ការលើកឡើងខាងលើដោយអង្គជំនុំជម្រះសាលាដំបូង បើទោះជាពុំត្រូវបានចាត់ទុកថា “មានលក្ខណៈយ៉ាងច្បាស់លាស់” ដែលពាក់ព័ន្ធនឹងអ្វីដែលតុលាការបានពិនិត្យរួចហើយក៏ដោយ ក៏ការលើកឡើងបែបនេះបាន “បញ្ជាក់យ៉ាងច្បាស់ថា” អង្គជំនុំជម្រះពុំបានចាត់ទុកថា លទ្ធផលនៃការពិនិត្យរបស់ខ្លួនលើពាក្យសុំទាំងនេះថាជាការពិនិត្យចុងក្រោយនោះទេ។ ម្យ៉ាងវិញទៀត ទោះបីជាការលើកឡើងនេះពុំបញ្ជាក់ច្បាស់ដល់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីក្តី ក៏ពិតជាបានផ្តល់ឱកាសដល់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការស្នើសុំការបញ្ជាក់បំភ្លឺបន្ថែមទៀតពីអង្គជំនុំជម្រះលើបញ្ហានេះ។

៤៩៩. ពាក់ព័ន្ធនឹងការផ្តល់ឱកាសក្នុងការដាក់សារណានៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ដែលមានរយៈពេលបីខែនៅមុនពេលបញ្ចប់ការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់មេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថា “សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើមាន ត្រូវបញ្ជាក់នូវមូលដ្ឋានអង្គហេតុ និងអង្គច្បាប់សម្រាប់គាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីចូលរួមកិច្ចដំណើរការនីតិវិធី ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី”[1052]។ សេចក្តីបង្គាប់នេះទំនងជាជម្រុញឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ធ្វើការស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល“ឱ្យប្រកាសទទួលយកភ្លាមៗ

---

[1051] ប្រតិចារិកចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E1/3.1, ទំព័រ ៣៤ (បន្ទាត់ ៣ ដល់ ៦) ។

[1052] សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល, ឯកសារលេខ E159 ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ (សេចក្តីណែនាំ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩) កថាខណ្ឌ ៥។ *សូមមើលផងដែរ* កថាខណ្ឌទី ១ សេចក្តីណែនាំ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ នៅក្នុងទំព័រទី ១ (កំណត់កាលបរិច្ឆេទ នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៩ សម្រាប់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាជាលាយលក្ខណ៍អក្សរ)។

នូវដើមបណ្ដឹងរដ្ឋប្បវេណីដែល"បណ្ដោះអាសន្ន"ទាំងអស់ ដោយសារលទ្ធផលនៃការសន្មត មិនច្បាស់លាស់ពីភាពអាចទទួលយកបាន"[1053]។ អ្វីដែលមិនបានបង្ហាញច្បាស់នោះគឺថា "អំណះអំណាងផ្លូវច្បាប់ និងអង្គហេតុ ដែលគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីចូលរួមកិច្ចដំណើរការនីតិវិធីក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី" ដូចដែលបានបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូងនោះ ពុំឃើញលើកឡើងនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពីរមានការភាន់ច្រឡំលើអង្គហេតុ និងអង្គច្បាប់ នៅពេលចាត់ទុកសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងថា ជា"អនុសាសន៍ ជាជាងការចងកាតព្វកិច្ច ឬលក្ខខណ្ឌតម្រូវនោះ"[1054]។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់យ៉ាងច្បាស់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីថា សារណាបញ្ចប់ការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ"ណាមួយ" "ត្រូវបង្ហាញអំណះអំណាងផ្លូវច្បាប់ និងអង្គហេតុដែលគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីចូលរួមកិច្ចដំណើរការនីតិវិធីក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី"។ ឯកសារនេះដែលមានចំណងជើងថា "សេចក្ដីបង្គាប់" ក៏បានបញ្ជាក់នូវលក្ខខណ្ឌតម្រូវផងដែរ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពីរសម្រេចចិត្តមិនទាញយកប្រយោជន៍ពីឱកាស ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ឱ្យនោះទេ ហើយផ្ទុយមកវិញបានលើកពីទឡ្ហីករណ៍ដែលពុំពាក់ព័ន្ធដោយយោងទៅតាមកាលៈទេសៈថា ជនរងគ្រោះបានក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណីរួចមកហើយ។

៥០០. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ ក្នុងការវាយតម្លៃលើទិដ្ឋភាពដែលថា តើភាពជាជនរងគ្រោះបានបង្ហាញគ្រប់

[1053]សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (ក្រុម ២) សារណាចុងក្រោយ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ E159/6 ("ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ២"), កថាខណ្ឌ ២១(១)។ *សូមមើលផងដែរ* ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ៦ ដល់ ៨ ដូចបានយោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៣៦, យោងជើងទំព័រ ១០៦៤។

[1054]ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៣។

00798720



គ្រាន់ ដែរ ឬយ៉ាងណា នៅពេលដែលខ្លួនសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសាលក្រម។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញបន្ថែមទៀតថា ទោះបីជា អ.វ.ត.ក. ទំនងជាធ្វើឱ្យមានភាពស្រពិចស្រពិលលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលជំនុំជម្រះពីដំបូងយ៉ាងណាក៏ដោយ ក៏ពុំបានបណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះរបស់ម្ចាស់បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណី នោះឡើយ។

៥០១. បើទោះជាអង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា មានការយល់ច្រឡំជាសារវន្តរវាងអង្គជំនុំជម្រះសាលាដំបូង និងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងអានុភាពតាមផ្លូវច្បាប់នៃការពិនិត្យបឋមលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះតុលាការកំពូលក៏ទទួលស្គាល់ផងដែរថា ដំណើរការទទួលស្គាល់ និងការបដិសេធឋានៈដើមបណ្តឹងរដ្ឋប្បវេណីអាចបណ្តាលឱ្យមានការប៉ះពាល់ផ្លូវចិត្ត និងការខកចិត្តដោយការចូលរួមដោយឥតប្រយោជន៍នៅក្នុងកិច្ចដំណើរការនីតិវិធីកន្លងមក[1055]។ ក្រោយពីបានពិចារណាអំពីចរិតលក្ខណៈថ្មី និង

---

[1055] *សូមមើលជាទូទៅ Phuong Pham និងអ្នកនិពន្ធដទៃទៀត,* “ការចូលរួមរបស់ជនរងគ្រោះ និងការជំនុំជម្រះជនជាប់ចោទ ឌុច នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” *ព្រឹត្តប័ត្រស្តីពីការអនុវត្តសិទ្ធិមនុស្ស* វ៉ុល ៣:៣ ឆ្នាំ ២០១១ ទំព័រ ២៨៤៖

> ក. ក្នុងចំណោមអ្នកដែលសុំឱ្យធ្វើការបដិសេធឋានៈរបស់ខ្លួនចោល ដោយសារការខឹងសម្បា គ្មានមធ្យោបាយការពារខ្លួន ភាពអាម៉ាស់ និងមានអារម្មណ៍ថាមិនមានប្រយោជន៍។ នៅពេលដែលការបដិសេធត្រូវបានធ្វើឡើងនៅពេលបញ្ចប់ការជំនុំជម្រះ សារណាតបត្រូវតែបង្ហាញអំពីភាពចាំបាច់ទាក់ទងនឹងជនរងគ្រោះ ដើម្បីឱ្យការបដិសេធអំពីឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានគិតថា ជាការអស់សង្ឃឹម។ នេះមានន័យថា មិនត្រឹមតែបានជូនដំណឹងដល់ម្ចាស់បណ្តឹងដើមបណ្តឹងរដ្ឋប្បវេណីអំពីការបដិសេធប៉ុណ្ណោះទេ ប៉ុន្តែពន្យល់មូលហេតុដែលកើតឡើង ដើម្បីពួកគាត់អាចភ្ជាប់ការបដិសេធនេះទៅនឹងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

ពិសេសនៃក្របខណ្ឌដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក និងភាពមិនច្បាស់លាស់ដែលអាចមើលឃើញ ទាក់ទិនទៅនឹងការរៀបចំជាក់លាក់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់នូវលទ្ធភាពដែលអាចកើតមានឡើងថា មានម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន អាចមានការយល់ច្រឡំចំពោះបញ្ហា ថាតើនៅតែមានការទាមទារឱ្យពួកគាត់ដាក់ភស្តុតាងបន្ថែមទៀតដែរ ឬយ៉ាងណា។ ហេតុដូច្នេះ ដើម្បីផ្តល់នូវឱកាសដែលបានបាត់បង់របស់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកសំណើរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីសុំដាក់ភស្តុតាងបន្ថែម ដោយមិនចាំបាច់ពិចារណា ថាតើភស្តុតាងទាំងនេះមានរួចហើយនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការជាន់ដំបូង ដែរ ឬយ៉ាងណានោះឡើយ។

## ៦.គ.ថាតើអង្គជំនុំជម្រះសាលាដំបូងអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាង ត្រឹមត្រូវ ដែរ ឬយ៉ាងណា ក្នុងការសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម

### ៦.គ.១.សារណា

៥០២. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ក្រុម ២ និងក្រុម ៣ បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមាន កំហុសអង្គច្បាប់ ក្នុងការវាយតម្លៃឡើងវិញទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមដោយហេតុថា អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងដែលមិនត្រឹមត្រូវ[1056]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ និងក្រុម ២ បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនូវបទដ្ឋាននៃការបង្ហាញភស្តុតាងមិនសម

*សូមមើលផងដែរ* Eric Stover *និងអ្នកនិពន្ធដទៃទៀត*, “ប្រឈមនឹងរឿងក្តី*ឌុច*៖ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” *ព្រឹត្តប័ត្តស្តីពីការពិនិត្យឡើងវិញជាអន្តរជាតិរបស់កាកបាទក្រហម* វ៉ុល ៩៣:៨៨២ (ខែ មិថុនា ឆ្នាំ ២០១១), ទំព័រ ៣៨ ដល់ ៤៤។

[1056]បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ៥០។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ៦, ៦៣, ៦៨។

ហេតុផល[1057] និងកត់សម្គាល់ថា វិធាននៃផ្ទៃក្នុងមិនបានចែងអំពីបទដ្ឋាននៃការបង្ហាញភស្តុតាង សម្រាប់ការសម្រេច អំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ[1058]។ ដើមបណ្តឹងរដ្ឋប្បវេណីគ្រប់ក្រុមទាំងអស់បានកត់សម្គាល់ថា នៅពេលកំណត់ជាដំបូង អំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅមុខពេលចាប់ផ្តើមសវនាការ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាង ដោយផ្អែកលើ*សេចក្តីបញ្ជាក់ដំបូង* ។ នៅក្នុងដំណាក់កាលចេញសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងមួយដែលថ្មី និងគ្មានការកំណត់ច្បាស់លាស់[1059]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ អះអាងថា បទដ្ឋាននេះត្រូវបានសម្រេចទទួលយកដោយមិនមានការជូនដំណឹងជាមុនដែលជាហេតុធ្វើឱ្យបាត់បង់ប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់គ្នា[1060]។

៥០៣. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានលើកឡើងថា វិសោធនកម្មចំពោះវិធាននៃផ្ទៃក្នុងដែលបានធ្វើឡើងក្រោយការធ្វើវិសោធនកម្មលើកទី ៣ អាចប្រើប្រាស់ជាគោលការណ៍ណែនាំសម្រាប់បទដ្ឋាននៃការបង្ហាញភស្តុតាង ដែលមានភាពត្រឹមត្រូវបាន។ ជាពិសេស ដើមបណ្តឹងរដ្ឋប្បវេណីក្រុមនេះ បានយោងទៅលើវិសោធនកម្មលើកទី ៥ នៃវិធាននៃផ្ទៃក្នុងដែលបានអនុម័តនៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០ ដែលមានរយៈពេលប្រាំខែ មុនពេលចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ វិធាន ២៣ *ស្ទួន*(១) នៃវិធាននៃផ្ទៃក្នុង ដែលបានធ្វើវិសោធនកម្មលើកទី ៥ បានចែងថា"នៅពេលពិចារណាអំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុ

[1057]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១, កថាខណ្ឌ ៦៣ ដល់ ៧៥។ បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៥៥ ដល់ ៧០។

[1058]បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៥១។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ កថាខណ្ឌ ៦៥។

[1059]បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៩១ ដល់ ១០៩។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១, កថាខណ្ឌ ៦៨។

[1060]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១, កថាខណ្ឌ ៦៨, ៧៦។

ដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ មានភាពពិតប្រាកដ”។ ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងថា បទដ្ឋាននេះ មានសារៈសំខាន់ណាស់សម្រាប់ភស្ដុតាង ទោះបីជាភស្ដុតាងនេះ មានកម្រិតទាបក្ដី[1061]។ ដោយយោងទៅលើការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) និងតុលាការសិទ្ធិមនុស្សអន្តរជាតិនានា[1062] ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះ បានសន្និដ្ឋានថា អ.វ.ត.ក គប្បីប្រើប្រាស់បទដ្ឋាននៃការបង្ហាញភស្ដុតាង ដែលផ្អែកលើ*សេចក្ដីបញ្ជាក់ដំបូង* ដែលបានអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ទាំងនៅដំណាក់កាលមុនពេលជំនុំជម្រះ និងនៅដំណាក់កាលជំនុំជម្រះ[1063]។ បទដ្ឋាននៃការបង្ហាញភស្ដុតាងនេះ គប្បីត្រូវយកមកអនុវត្តជំនួសការសម្រេចអំពីភាពអាចទទួលយកបានជាដើមបណ្ដឹងរដ្ឋប្បវេណី ជាពិសេសការវាយតម្លៃទៅលើសេចក្ដីបញ្ជាក់របស់អ្នកដាក់ពាក្យសុំអំពីអង្គហេតុ ដែលមានខ្លឹមសារស៊ីសង្វាក់ច្បាស់លាស់។

៥០៤. ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ៣ លើកទឡ្ហីករណ៍បន្ថែមថា វិធាន ២៣(៥) នៃវិធានផ្ទៃក្នុង បានអនុញ្ញាតឲ្យមាន“សេរីភាពក្នុងការដាក់ភស្ដុតាង”[1064]។ សេរីភាពនេះត្រូវតែបកស្រាយដោយផ្អែកទៅលើបរិបទប្រវត្តិសាស្ត្រនៃការឃុំខ្លួននៅមន្ទីរ ស ២១ និងមន្ទីរ ស ២៤ និងអង្គហេតុដែលថា កំណត់ហេតុនៅមន្ទីរឃុំឃាំងទាំងនោះមានលក្ខណៈមិនពេញលេញ ឬត្រូវបានបាត់បង់ ឬត្រូវបានរក្សាទុកនៅក្នុងលក្ខខណ្ឌមិនល្អ។ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់បន្ថែមថា វិធានស្ដីពីភស្ដុតាងត្រូវតែវាយតម្លៃដោយយោងទៅលើផលវិបាកនៃឧក្រិដ្ឋកម្មទាំងនេះ ដែលមានមកលើជនរងគ្រោះ[1065]។ ដើមបណ្ដឹងរដ្ឋប្បវេណីសង្កេតឃើញថា តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ក៏បានទទួលស្គាល់ផងដែរនូវភស្ដុតាងដោយប្រយោល នៅពេល

---

[1061] បណ្ដឹងសាទុក្ខស្ដីពីភាពអាចទទួលយកបានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៥៣។

[1062] បណ្ដឹងសាទុក្ខស្ដីពីភាពអាចទទួលយកបានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៥៥ ដល់ ៦៩។

[1063] បណ្ដឹងសាទុក្ខស្ដីពីភាពអាចទទួលយកបានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៧០។

[1064] បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៤៥។

[1065] បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ៤១ ដល់ ៨៤។

ដែលបន្ទុកនៃការបង្ហាញភស្តុតាង មិនអាចបង្ហាញបាន ដោយសារតែឧបសគ្គជាសត្យានុម័ត[1066]។

៥០៥. ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ទទួលយកថា “ជាការត្រឹមត្រូវហើយដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីចាំបាច់ត្រូវផ្តល់ភស្តុតាងមួយចំនួនបន្ថែមទៀត ដើម្បីបញ្ជាក់ឲ្យច្បាស់លាស់អំពីអត្តសញ្ញាណរបស់ខ្លួន”[1067]ក្តី ក៏ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ លើកទឡ្ហីករណ៍ថា នៅក្នុងការពិនិត្យភស្តុតាងអំពីអត្តសញ្ញាណ អង្គជំនុំជម្រះសាលាដំបូងមិនបានបង្ហាញអំពីភាពបត់បែនទេ ដែលនេះ ជាចំណុចខុសគ្នាពីតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។ ឧទាហរណ៍ “[អង្គជំនុំជម្រះសាលាដំបូង] បានយល់ព្រមទទួលយកចម្លើយរបស់ជនជាប់ចោទ ទាក់ទងនឹងសុពលភាពនៃពាក្យសុំតាំងខ្លួនជា[ដើមបណ្តឹងរដ្ឋប្បវេណី] ជាជាងពិចារណាទៅលើឯកសារ និងសេចក្តីបញ្ជាក់របស់[ដើមបណ្តឹងរដ្ឋប្បវេណី]”[1068]។ យោងតាមសេចក្តីសម្រេចនៅក្នុង*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Omar Hassan Achmad Al-Bashir*[1069] ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ បានលើកឡើងអំពីការទទួលស្គាល់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ដែលថា “ទោះបីជាពាក្យសុំត្រូវផ្អែកលើភស្តុតាងជាឯកសារក៏ដោយ ក៏ស្ថានភាពនៃសង្គ្រាម និងចលាចលអាចជាឧបសគ្គរារាំងចំពោះការដាក់ភស្តុតាង ដើម្បីបញ្ជាក់លើអត្តសញ្ញាណកម្មនេះ”[1070]។

---

[1066]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៥៦ ដល់ ៥៧, ជើងទំព័រ ៦ (យោងទៅលើ*ស្ថានការណ៍ នៅប្រទេសអ៊ូហ្គង់ដា* សំណុំរឿងលេខ ICC-02/04-101 “សេចក្តីសម្រេចលើពាក្យសុំរបស់ជនរងគ្រោះសម្រាប់ការចូលរួម a/0010/06, a/0064/06 to a/0070/06, a/0081/06 to a/0104/06 និង a/0111/06 ដល់ a/0127/06” អង្គបុរេជំនុំជម្រះ (ចៅក្រមតែម្នាក់) ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧, កថាខណ្ឌ ១៥។

[1067]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ៧២។

[1068]បណ្តឹងសាទុក្ខរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១, កថាខណ្ឌ ៧៣។

[1069]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១, ជើងទំព័រ ៧៨។

[1070]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម១, កថាខណ្ឌ ៧២។

## ៦.គ.២.សាលក្រមអង្គជំនុំជម្រះសាលាដំបូង

៥០៦. នៅចំណុចចាប់ផ្តើមដំបូងក្នុងផ្នែក "ប្រវត្តិនីតិវិធី" ត្រង់ចំណុចដែលមានចំណងជើងថា "សំណងរដ្ឋប្បវេណី" អង្គជំនុំជម្រះសាលដំបូងបានលើកឡើងដូចខាងក្រោម៖

> ជាទូទៅ ដោយផ្អែកតាមការអនុវត្តរបស់តុលាការអន្តរជាតិស្រដៀងគ្នានេះ អង្គជំនុំជម្រះបានធ្វើការវាយតម្លៃលើ *សេចក្តីបញ្ជាក់ដំបូង* អំពីការជឿជាក់លើព័ត៌មានដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ឱ្យ។ នីតិវិធីនៃការសម្រេចទទួលយកពាក្យសុំបែបនេះ មានលក្ខណៈខុសគ្នាពីការសម្រេចរបស់អង្គជំនុំជម្រះ ដែលសម្រេចលើអង្គសេចក្តីនៃពាក្យសុំទាំងអស់នៅ ក្នុងសាលក្រមដែលផ្អែកលើមូលដ្ឋាននៃភស្តុតាងទាំងអស់ ដែលបានដាក់ជូននៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធី[1071]។

៥០៧. ការប្រើប្រាស់ពាក្យពេចន៍"បទដ្ឋាននៃការបង្ហាញភស្តុតាង" នៅក្នុងផ្នែក"សំណងរដ្ឋប្បវេណី" មានតែនៅក្នុងជើងទំព័រមួយប៉ុណ្ណោះ ដែលបានលើកឡើងថា "លក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបាននៃពាក្យសុំ និងបទដ្ឋាននៃការបង្ហាញភស្តុតាងទាំងនេះ ត្រូវបាន *បញ្ជាក់ច្បាស់* នៅក្នុងវិសោធនកម្ម(វិធានផ្ទៃក្នុង) ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គលើកទី ៧"[1072]។ នៅក្នុងជើងទំព័រដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនូវវិធាន ២៣ *ស្ទួន* (១) នៃវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៥)ទាំងស្រុងថា៖

> ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ:
>
> ក - បង្ហាញពីអត្តសញ្ញាណឱ្យបានច្បាស់លាស់
>
> ខ - បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជា

[1071] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៣៦។

[1072] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៧២ (សេចក្តីបញ្ជាក់បន្ថែម)។

បានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព ។

នៅពេលពិចារណា អំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ មានភាពពិតប្រាកដ។

៥០៨. ជាការច្បាស់ណាស់ថា អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"លើកបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់" នៅក្នុងពាក្យសុំរបស់ខ្លួន។ ក្នុងករណីនេះ អង្គជំនុំជម្រះបានចាត់ទុកបញ្ហានៃភាពអាចជឿជាក់លើសេចក្តីបញ្ជាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជាបញ្ហាសំខាន់ជាចម្បង ប៉ុន្តែ អង្គជំនុំជម្រះបានលើកឡើងថា"មិនអាចកំណត់ថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានភស្តុតាងបញ្ជាក់គ្រប់គ្រាន់ដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រឹមត្រូវនោះទេ"[1073]។ ដូច្នេះ ទាក់ទងនឹងម្ចាស់បណ្តឹងសាទុក្ខមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពួកគាត់មិនបានផ្តល់"ភស្តុតាងជាក់ស្តែង" និងថា "ការរៀបរាប់អំពីស្ថានភាពឃុំខ្លួន" "មានភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងជាច្រើន ដែលដាក់ជូនអង្គជំនុំជម្រះទាក់ទងនឹងប្រតិបត្តិការនៅមន្ទីរ ស ២១"[1074]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញដែរថា "ភាពមិនស៊ីសង្វាក់គ្នារវាងព័ត៌មាន ដែលបានរៀបរាប់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនឹងចម្លើយដែលពួកគាត់បានឆ្លើយនៅពេលសវនាការ ព្រមទាំងសារណាដែលបានដាក់ជាបន្តបន្ទាប់នោះ" ហើយទោះបីជាមាន"ផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត និងការកន្លងផុតនៃពេលវេលា"ក៏ដោយ ក៏មិនអាចឲ្យសន្និដ្ឋានបានថា អ្នកទាំងនោះត្រូវបានឃុំខ្លួន

[1073]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៧៩។

[1074]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៧, ទំព័រ ២២៣ (សំអាងហេតុទាក់ទងនឹងអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី E2/23) និងទំព័រ ២២៤ ដល់ ២២៥ (ស្តីពីអង្គហេតុទាក់ទងនឹងឯកសារលេខ E2/33 និង E2/61)។

នៅមន្ទីរ ស ២១ ដែរ[1075]។ នៅក្នុងករណីផ្សេងទៀត អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពីខ្លួនរកឃើញថា អ្នកដាក់ពាក្យសុំទាំងនោះ មិនបានផ្តល់ឯកសារ ឬលិខិតបញ្ជាក់សម្រាប់គាំទ្រដល់សេចក្តីអះអាង អំពីភាពញាតិសន្តានជាមួយនឹងជនរងគ្រោះផ្ទាល់[1076]។

៥០៩. ទោះបីជាយ៉ាងណាក៏ដោយ ក៏មិនច្បាស់ទេ ថាតើអង្គជំនុំជម្រះសាលាដំបូងមានគោលបំណងអនុវត្តនូវបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលមានកំណត់នៅក្នុងវិធានផ្ទៃក្នុង ដែលបានធ្វើវិសោធនកម្មលើកទី ៥ (អាចជាការពិត) នៅក្នុង“ការសម្រេចអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់” ដែលមានភាពផ្ទុយទៅនឹង“ការវាយតម្លៃរបស់ខ្លួនដោយផ្អែកលើ*សេចក្តីបញ្ជាក់ដំបូង*” ដែរ ឬយ៉ាងណា។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលក៏មានភាពមិនច្បាស់ដែរ ថាតើបទដ្ឋាននៃការបង្ហាញភស្តុតាងណាមួយ ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ នៅពេលដែលខ្លួន បានប្រើប្រាស់ពាក្យពេចន៍“បទដ្ឋានតម្រូវ” រហូតដល់ចំនួនប្រាំដង ក្នុងការសម្រេចបដិសេធចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[1077]។ ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ពិតជាបានអះអាងត្រឹមត្រូវហើយដែលថា បទដ្ឋាននៃការបង្ហាញភស្តុតាងដែលប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូង គឺ“មិនមានកំណត់ច្បាស់លាស់”នោះទេ[1078]។ ជាអប្បបរមា ចំណុចនេះបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់នូវបទដ្ឋាន“អាចជាការពិត” ដែលមានលក្ខណៈជាការណែនាំមានសារៈប្រយោជន៍ ក្នុងការសម្រេចអំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមរបស់ខ្លួន។

---

[1075]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៧ ទំព័រ ២២៣ (សំអាងហេតុទាក់ទងនឹងម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឯកសារលេខ E2/32)។

[1076]*សូមមើល ឧទា.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨, ទំព័រ ២២៦ (ស្តីពីសំអាងហេតុទាក់ទងនឹងអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីឯកសារលេខ E2/62 និងអ្នកផ្សេងទៀត ក្រោមប្រភេទដូចគ្នា)។

[1077]សាលក្រមអង្គជំនុំជម្រះសាលាដំបូង ទំព័រ ២២៣, ២២៥, ២២៩។

[1078]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ៦៨។

## ៦.គ.៣.ច្បាប់ដែលត្រូវយកមកអនុវត្ត

៥១០. វិធានផ្ទៃក្នុងបានចែងអំពីការណែនាំ ស្តីពីលក្ខណៈវិនិច្ឆ័យ ដែលពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបំពេញឲ្យបានគ្រប់គ្រាន់ ដើម្បីអាចទទួលយកបាន[1079] ប៉ុន្តែ វិធានផ្ទៃក្នុងមិនបាន ចែងអំពីបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលកំណត់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការវាយតម្លៃនៅក្នុងសាលក្រមនោះទេ។ ដូចដែលបានកត់សម្គាល់កន្លងមកនៅក្នុងសាលដីកានេះ ដោយអនុលោមតាមរបបគតិយុត្តស្តីពីបណ្តឹងរដ្ឋប្បវេណីទូទៅ ពោលគឺ ធាតុផ្សំអង្គហេតុនៃបណ្តឹងទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនស្ថិតក្រោមបណ្តឹងអាជ្ញា ហើយដែលមិនអាចមានភស្តុតាងគ្រប់គ្រាន់សម្រាប់ប្តឹងចោទប្រកាន់បាន នោះធាតុផ្សំអង្គហេតុនេះ ត្រូវតែបង្ហាញភស្តុតាង ដោយដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមបទដ្ឋានស្តីពីឧត្តមានុភាពនៃភស្តុតាង[1080]។ មានបញ្ហាមួយចោទឡើង ថាតើឧត្តមានុភាពនៃភស្តុតាង គឺជាបទដ្ឋានសមស្រប ចំពោះកាលៈទេសៈនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក ដែរ ឬយ៉ាងណា។ ហើយមានបញ្ហាផ្សេងមួយទៀត ថាតើកម្រិតនៃភស្តុតាងដែលតម្រូវដោយ អ.វ.ត.ក សម្រាប់កំណត់អំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលដំបូង នៅតែបន្តអនុវត្តដោយគ្មានការប្រែប្រួល ដែរ ឬយ៉ាងណា នៅដំណាក់កាលចេញសាលក្រម ជាពេលដែលភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានពិចារណាសម្រេចជាស្ថាពរ។

---

[1079]វិធាន ២៣(៥) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) (បានតម្រូវថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់"ត្រូវមានព័ត៌មានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យពិនិត្យបញ្ជាក់អំពីភាពសមស្របរបស់ពាក្យបណ្តឹងជាមួយនឹងវិធានផ្ទៃក្នុងនេះ។ ជាពិសេស ពាក្យបណ្តឹងត្រូវផ្តល់ព័ត៌មានលម្អិតអំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងភ្ជាប់មកជា មួយនូវភស្តុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជនដែលត្រូវចោទប្រកាន់")។

[1080]*សូមមើល* កថាខណ្ឌ ៤២៨ ខាងលើ។

៥១១. ហាក់បីដូចជាអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តរួចហើយ ដូចអ្វីដែលម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី[1081]បានទទួលស្គាល់ថា បទដ្ឋាននៃការបង្ហាញភស្តុតាងដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៥) ("ដែលអាចជាការពិត") គឺជាគោលការណ៍ណែនាំធម្មានុរូប សម្រាប់ការកំណត់អំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីដែលអនុលោមតាមវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៣)។ ប៉ុន្តែ បទដ្ឋាននៅក្នុងវិសោធនកម្មលើកទី ៥ នេះ មានគោលបំណងអនុវត្តនៅដំណាក់កាល"សហចៅក្រមស៊ើបអង្កេត" ដូច្នេះ មានន័យថា អនុវត្តតែនៅដំណាក់កាលមុនការជំនុំជម្រះប៉ុណ្ណោះ។ បន្ទាប់មកក៏កើតមានបញ្ហាចោទ ថាតើមានលក្ខណៈត្រឹមត្រូវ ដែរ ឬយ៉ាងណា ក្នុងការយកបទដ្ឋាននៃការបង្ហាញភស្តុតាងនៅដំណាក់កាលមុនការជំនុំជម្រះអង្គសេចក្តី មកអនុវត្តនៅដំណាក់កាលសម្រេចពីសំណង។ ជាចម្លើយតបចំពោះសំណួរនេះ ជាដំបូងត្រូវមានការកត់សម្គាល់ថា បន្ទាប់ពីបានដកចេញនូវចំណុច ដែលបើកលទ្ធភាពឲ្យមានការដាក់បណ្តឹងទាមទារជាបុគ្គលនៅដំណាក់កាលសវនាការរួចមក[1082] វិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៥) ក៏បានដកហូតសមត្ថកិច្ចពីអង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចអំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គលដែរ[1083]។ អនុលោមតាមវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៥) ក៏ដូចជានៅក្នុងវិធានផ្ទៃក្នុងនាពេលបច្ចុប្បន្ន (វិសោធនកម្មលើកទី ៨) ដែរ អំណាចក្នុងការសម្រេចអំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល គឺត្រូវប្រគល់ឲ្យទៅសហចៅក្រមស៊ើបអង្កេត ហើយដែលបើកផ្លូវប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ ស្រដៀង

---

[1081] *សូមមើល ឧទា.* បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៥, ១៣, ៥៣។

[1082] វិធាន ២៣(៥) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៥)។

[1083] ឧទាហរណ៍ ពាក្យ"ដើមបណ្តឹងរដ្ឋប្បវេណី" ដែលកំណត់និយមន័យនៅក្នុងសទ្ទានុក្រមនៃវិសោធនកម្មលើកទី ៥ គឺសំដៅទៅលើ"ជនរងគ្រោះដែលដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬ*អង្គបុរេជំនុំជម្រះ* ដោយយោងទៅលើវិធានផ្ទៃក្នុងនេះ" រីឯនៅក្នុងសទ្ទានុក្រមនៃវិសោធនកម្មលើកទី ៤ កំណត់និយមន័យពាក្យនេះថាជា "ជនរងគ្រោះដែលដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬ*អង្គជំនុំជម្រះសាលាដំបូង*ដោយយោងទៅលើវិធានផ្ទៃក្នុងនេះ" (សេចក្តីបញ្ជាក់បន្ថែម)។

គ្នានេះដែរ អនុលោមតាមវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៣) អំណាចក្នុងការសម្រេច អំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល ត្រូវប្រគល់ឲ្យទៅអង្គជំនុំជម្រះសាលាដំបូង ហើយបើកផ្លូវប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល[1084]។ ដូច្នេះ ដោយអនុលោមតាមវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៣) និងវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៥) ក៏ដូចជា(វិសោធនកម្មលើកទី ៨) ទាំងសហចៅក្រមស៊ើបអង្កេត និងទាំងអង្គជំនុំជម្រះសាលាដំបូង ត្រូវមានការទទួលខុសត្រូវដូចគ្នា ក្នុងការសម្រេចអំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលការសម្រេចទាំងនោះត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍ និងប្តឹងសាទុក្ខ។ លក្ខណៈរួមរវាងវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៣) និងវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៥) អនុញ្ញាតឲ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណាអំពីភាពពាក់ព័ន្ធនៃបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៥) នៅពេលដែលយកវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៣) មកអនុវត្ត។

៥១២. ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្ត អាចមានភាពខុសគ្នាយ៉ាងសំខាន់កើតមានរវាងដំណាក់កាលមុនការជំនុំជម្រះ និងដំណាក់កាលនៃការសម្រេចអំពីសំណង ដែលរួមមានទាំងបរិមាណ និងគុណភាពនៃភស្តុតាងដែលមានឥទ្ធិពលដល់ឋានៈដើមបណ្តឹងរដ្ឋប្បវេណី និងសំណើទាមទារសំណង ដែលកើតចេញពីភស្តុតាងដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី និងពីសំអាងហេតុនានា ដែលទាក់ទិននឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវតែកំណត់យកនូវបទដ្ឋានមួយដែលមានលក្ខណៈសមស្រប សម្រាប់កិច្ចដំណើរការនីតិវិធីនៃការសម្រេចពីសំណង។ នៅក្នុងការស្វែងរកចម្លើយទៅនឹងសំណួរដែលបានចោទឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចពិចារណា ថាតើ

[1084]បានចែងថា ពាក្យសុំមិនត្រូវបានសហចៅក្រមស៊ើបអង្កេត និង/ឬ អង្គបុរេជំនុំជម្រះទទួលបន្ទុកបណ្តឹងឧទ្ធរណ៍ បដិសេធថា មិនអាចទទួលយកបានរួចហើយនោះទេ។ (វិធាន ២៣(៣), វិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣))។

មានការណែនាំណាមួយ អាចត្រូវបានបង្កើតឡើង“នៅក្នុងបទដ្ឋាននីតិវិធីក្នុងកម្រិតអន្តរជាតិដែរ ឬយ៉ាងណា”[1085]។

### ៦.ឥ.៣.ក.វិធានស្តីពីនីតិវិធីដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ

#### ៦.ឥ.៣.ក.១.តុលាការព្រហ្មទណ្ឌអន្តរជាតិ (“តុលាការ ICC”) និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ (“តុលាការ STL”)

៥១៣. នៅពេលដែលបុគ្គលម្នាក់ដាក់ពាក្យសុំឋានៈជាជនរងគ្រោះ នៅក្នុងរឿងក្តីមួយទៅអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC ទាំងនៅដំណាក់កាលមុនពេលចាប់ផ្តើមឬនៅក្នុងអំឡុងពេលសវនាការ អង្គជំនុំជម្រះនេះត្រូវតែធ្វើឱ្យខ្លួនឯងមានភាពជឿជាក់អំពីភាពអាចទទួលយកបាននៃពាក្យសុំនោះ[1086] ដោយអនុវត្តនូវបទដ្ឋាននៃការបង្ហាញភស្តុតាងដែលមានលក្ខណៈ

---

[1085]មាត្រា ១២(១) នៃកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[1086]*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Jean-Pierre Bemba Gombo*, សំណុំរឿងលេខ ICC-01/05-01/08-1017, “សេចក្តីសម្រេចលើពាក្យសុំ ៧៧២ ធ្វើឡើងដោយជនរងគ្រោះសុំចូលរួមក្នុង កិច្ចដំណើរការនីតិវិធី”, អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ ៣៨ (ដែលបង្កើតនូវលក្ខខណ្ឌតម្រូវ ដើម្បីបង្ហាញ ៖ (១) ថា អ្នកដាក់ពាក្យសុំ គឺជារូបវន្តបុគ្គល ឬនីតិបុគ្គល (២) អ្នកដាក់ពាក្យសុំបានទទួលរងព្យសនកម្ម (៣) ថា ព្រឹត្តការណ៍ដែលអ្នក ដាក់ពាក្យសុំបានពិពណ៌នា គឺជាឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ ហើយ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនោះ និង(៤) ថា មានទំនាក់ទំនងរវាងព្យសនកម្មដែលបានទទួលរង និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងរឿងក្តីចំពោះមុខ”។ លក្ខណៈវិនិច្ឆ័យនេះ គឺស្រដៀងទៅនឹងលក្ខណៈវិនិច្ឆ័យដែលអនុវត្តដោយអង្គបុរេជំនុំជម្រះនៃតុលាការ ICC ក្នុងអំឡុងដំណាក់កាលមុនជំនុំជម្រះនៃរឿងក្តី។ *សូមមើល ឧទា. ស្ថានភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល នៅក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Jean-Pierre Bemba Gombo*, សំណុំរឿងលេខ ICC-01/05-01/08-320, “សេចក្តីសម្រេចលើកទី ៤ លើការចូលរួមរបស់ជនរងគ្រោះ” អង្គបុរេជំនុំជម្រះ (ចៅក្រមតែម្នាក់) ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៣០។ *ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Germain Katanga and Chui*, សំណុំរឿងលេខ ICC-01/04-01/07-357, “សេចក្តីសម្រេចលើពាក្យសុំចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់អ្នកដាក់ពាក្យសុំ a/0327/07 ដល់ a/0337/07 និង a/0001/08” អង្គបុរេជំនុំជម្រះ (ចៅក្រមតែម្នាក់) ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៨។ *ស្ថានភាពនៅ Darfur, ស៊ូដង់ នៅក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Bahar Idriss Abu Garda*, សំណុំរឿងលេខ ICC-02/05-02/09-255, “សេចក្តីសម្រេចលើពាក្យសុំ a/0655/09, a/0656/09, a/0736/09 ដល់

*ជាសេចក្តីបញ្ជាក់ដំបូង*[1087]។ នៅដំណាក់កាលជំនុំជម្រះ ជាការបន្ថែមទៅលើលក្ខណៈវិនិច្ឆ័យដែលអាចអនុវត្តបាននៅមុនដំណាក់កាលជំនុំជម្រះ តុលាការត្រូវតែពិចារណា ថាតើព្យសនកម្មដែលបានអះអាងថា បានទទួលរងនោះ *ពិតជាមានសេចក្តីបញ្ជាក់ដំបូងថា* ជា

---

a/0747/09, និង a/0750/09 ដល់ a/0755/09 សុំចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលបុរេជំនុំជម្រះនៃរឿងក្តី" អង្គបុរេជំនុំជម្រះ (ចៅក្រមតែម្នាក់) ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ កថាខណ្ឌ ៨។ *ស្ថានភាព នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង* *Callixte Mbarushimana*, សំណុំរឿងលេខ ICC-01/04-01/10-351, អង្គបុរេជំនុំជម្រះ (ចៅក្រមតែម្នាក់) ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១, កថាខណ្ឌ ១៩។ *ស្ថានភាពនៅសាធារណរដ្ឋកេនយ៉ា នៅក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង William Samoei Ruto, Henry Kiprono Kosgey* និង *Joshua Arap Sang*, សំណុំរឿង ICC-01/09-01/11-17, "សេចក្តីសម្រេចលើកទី ១ លើការចូលរួមរបស់ជនរងគ្រោះនៅក្នុងរឿងក្តី", អង្គបុរេជំនុំជម្រះ (ចៅក្រមតែម្នាក់) ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, កថាខណ្ឌ ៦។

[1087]មុនពេលចាប់ផ្តើមសវនាការ *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា ទល់នឹង រឿងក្តី Thomas Lubanga Dyilo*, សំណុំរឿង ICC-01/04-01/06-1119, "សេចក្តីសម្រេចលើការចូលរួមរបស់ជនរងគ្រោះ" របស់អង្គជំនុំជម្រះសាលា ដំបូង ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ កថាខណ្ឌ ៩៩។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Katanga and Chui*, មូលដ្ឋាននានាសម្រាប់ធ្វើសេចក្តីសម្រេចលើពាក្យសុំចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ទាំង ៣៤៥ ពាក្យសុំ ដែល ត្រូវបានដាក់ដោយជនរងគ្រោះនានា កថាខណ្ឌ ៥៧ ("អង្គជំនុំជម្រះបានយល់ឃើញទៀតថា អ្នកដាក់ពាក្យសុំត្រូវ តម្រូវឲ្យបង្ហាញថា លក្ខណៈវិនិច្ឆ័យបួនទាំងនេះត្រូវបានបំពេញ *តាមការវិភាគបឋម* ដោយពុំចាំបាច់តម្រូវឲ្យ អង្គជំនុំជម្រះធ្វើការវាយតម្លៃឲ្យបានស៊ីជម្រៅអំពីភាពគួរឲ្យជឿជាក់បាននៃការអះអាងរបស់ពួកគេ")។ ក្នុងអំឡុង សវនាការ *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06-2659-Corr-Red, "សំណៅកោសលុបនៃកំហុសនៃសេចក្តីសម្រេចលើពាក្យសុំធ្វើឡើងដោយជនរងគ្រោះ ១៥ នាក់ សុំចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១, កថាខណ្ឌ ២៨, ៣០ ("កាតព្វកិច្ចទៅលើអ្នកដាក់ពាក្យសុំត្រូវបានកម្រិតត្រឹមការផ្តល់ឲ្យអង្គជំនុំជម្រះនូវភស្តុតាងគ្រប់គ្រាន់ ដើម្បីបង្ហាញ *បឋម* នូវអត្តសញ្ញាណរបស់ខ្លួន និងទំនាក់ទំនងរវាងព្យសនកម្មដែលបានទទួលរង និងការចោទប្រកាន់នានាប្រឆាំងនឹងជនជាប់ចោទ . . . អ្នកដាក់ពាក្យសុំទាំង ១៥ នាក់នេះ គ្រាន់តែស្នើសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ប៉ុណ្ណោះ ហើយនៅពេលនេះ ពួកគាត់មិនបានស្នើសុំនូវតួនាទីសកម្មជាងនេះនៅក្នុងសវនាការឡើយ ហើយពួកគាត់ក៏ មិនមែនជាសាក្សីនៅសវនាការដែរ")។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06-2764-Red, "សំណៅកោសលុបនៃកំហុសនៃសេចក្តីសម្រេចលើពាក្យសុំធ្វើឡើងដោយជនរងគ្រោះ ០៧ នាក់ សុំចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ ២៣។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Jean-Pierre Bemba Gombo*, សំណុំរឿងលេខ ICC-01/05-01/08-1862, "សេចក្តីសម្រេចលើពាក្យសុំ ២៧០ ធ្វើឡើងដោយជនរងគ្រោះសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធី", អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១, កថាខណ្ឌ ២៧, ៣០។

លទ្ធផលនៃឧក្រិដ្ឋកម្ម ដែលយ៉ាងហោចណាស់ក៏មានមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលត្រូវរកឃើញថា មានពិរុទ្ធ ដែរ ឬយ៉ាងណា[1088]។ មធ្យោបាយនៃការបង្ហាញភស្តុតាងគឺអាចទទួលយកបានយ៉ាងទូលំទូលាយ[1089] ហើយពុំតម្រូវឱ្យមានកាតព្វកិច្ចក្នុងការប្រើប្រាស់ទម្រង់ពិសេសនៃភស្តុតាងឡើយ លើកលែងតែភស្តុតាងជាឯកសារស្តីពីអត្តសញ្ញាណ និងឯកសារស្តីពីការប្រគល់សិទ្ធិ[1090]។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC

---

[1088] *រឿងក្តី Lubanga,* "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង I លើការចូលរួមរបស់ជនរងគ្រោះ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨", កថាខណ្ឌ ៦១ ដល់ ៦៦។ *រឿងក្តី* Katanga និង Chui, សេចក្តីសម្រេចលើការពិចារណាអំពីពាក្យសុំចូលរួម កថាខណ្ឌ ១៣។ *រឿងក្តីរដ្ឋអាជ្ញាទល់នឹង Jean-Pierre Bemba Gombo,* សំណុំរឿងលេខ ICC-01/05-01/08-699, "សេចក្តីសម្រេចកំណត់ឋានៈជនរងគ្រោះចំនួន ៥៤ នាក់ ដែលបានចូលរួមនៅដំណាក់កាលមុនជំនុំជម្រះ និងស្នើឲ្យភាគីដាក់សេចក្តីសន្និដ្ឋានទៅលើពាក្យសុំចូលរួមរបស់អ្នកដាក់ពាក្យសុំចំនួន ៨៦ នាក់" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១០, កថាខណ្ឌ ១៩។

[1089] *ស្ថានភាពនៅក្នុងប្រទេសអ៊ុយហ្គង់ដា* "សេចក្តីសម្រេចលើពាក្យសុំចូលរួមរបស់ជនរងគ្រោះ a/0010/06, a/0064/06 to a/0070/06, a/0081/06 to a/0104/06 និង a/0111/06 to a/0127/06", កថាខណ្ឌ ១៥ ("មានការរំពឹងទុកដោយសមហេតុផលថា ជនរងគ្រោះពិតជានឹងមិន ឬតែងតែនឹងមិនស្ថិតក្នុងតួនាទីក្នុងការធ្វើយុត្តិកម្មឲ្យបាន ពេញលេញលើអំណះអំណាងរបស់ពួកគាត់ឡើយ។ វាត្រូវបានគេទទួលស្គាល់ផងដែរថា ជាគោលការណ៍ទូទៅនៃច្បាប់ដែលថា "ការបង្ហាញភស្តុតាងដោយប្រយោល" (ខ. ការសន្និដ្ឋាននៃអង្គហេតុ និងភស្តុតាងប្រយោល) គឺអាចទទួលយកបាន ប្រសិនបើបង្ហាញឲ្យឃើញថា ភាគីដែលមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាងត្រូវបានរារាំងដោយ ឧបសគ្គសត្យានុម័តមិនឲ្យប្រមូលនូវភស្តុតាងផ្ទាល់អំពីធាតុផ្សំពាក់ព័ន្ធដែលគាំទ្រដល់ការអំណះអំណាងរបស់គាត់។ ជាងនេះទៅទៀត នៅពេលដែលភស្តុតាងប្រយោលបែបនេះទំនងជាផ្អែកទៅលើ"អង្គហេតុមួយចំនួនដែលមាន ទំនាក់ទំនងជាមួយគ្នា ហើយនាំឲ្យមានការសន្និដ្ឋានតែមួយដោយសមហេតុផល"។ ដោយមានលក្ខណៈស្រដៀងគ្នា ទៅនឹងវិធីសាស្ត្រដែលអង្គបុរេជំនុំជម្រះ I បានអនុវត្តតាម ដូច្នេះចៅក្រមតែម្នាក់ជាដំបូងនឹងធ្វើការវាយតម្លៃលើការ បញ្ជាក់នីមួយៗរបស់ជនរងគ្រោះជាអ្នកដាក់ពាក្យសុំ ហើយមុនគេបង្អស់នោះគឺទៅលើអង្គសេចក្តីនៃភាពស៊ីសង្វាក់គ្នា ដ៏សំខាន់នៃសេចក្តីបញ្ជាក់នោះ ព្រមទាំងទៅលើមូលដ្ឋាននៃព័ត៌មានផ្សេងពីនេះដែលអង្គជំនុំជម្រះមាន")។

[1090] *សូមមើល រឿងក្តី Bemba* "សេចក្តីសម្រេចលើពាក្យសុំ ៧៧២ ដែលធ្វើឡើងដោយជនរងគ្រោះសុំចូលរួមនៅក្នុង កិច្ចដំណើរការនីតិវិធី", កថាខណ្ឌ ៣៩ (ពាក្យសុំពេញលេញនូវឋានៈក្នុងការចូលរួមក្នុងអំឡុងសវនាការ ឲត្រូវតែមានព័ត៌មានដូចខាងក្រោមនេះ៖ (១) អត្តសញ្ញាណនៃ [ជនរងគ្រោះ] អ្នកដាក់ពាក្យសុំ (២) កាលបរិច្ឆេទនៃឧក្រិដ្ឋកម្ម (៣) ទីតាំងនៃឧក្រិដ្ឋកម្ម (៤) ការពិពណ៌នាអំពីព្យសនកម្មដែលត្រូវបានទទួលរងជាលទ្ធផលនៃការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ (៥) ឯកសារបញ្ជាក់ពីអត្តសញ្ញាណ[របស់អ្នកដាក់ពាក្យសុំជាជនរងគ្រោះ] (៦) ប្រសិនបើពាក្យ

បានសម្រេចផ្តន្ទាទោសជនជាប់ចោទ សំណើទាមទារសំណងដែលអនុលោមតាមមាត្រា ៧៥ នៃលក្ខន្តិកៈរបស់តុលាការ ICC *មានប្រការមួយក្នុងចំណោមប្រការផ្សេងទៀត* បានកំណត់ថា "*ស្ថិតក្នុងកម្រិតដែលអាចកំណត់បាន* ត្រូវមានអត្តសញ្ញាណរបស់បុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ដែលជនរងគ្រោះជឿជាក់ថា ជាអ្នកទទួលខុសត្រូវចំពោះការខូចខាត ការបាត់បង់ ឬព្យសនកម្ម"[1091]។ ស្រដៀងគ្នានេះដែរ សំណើទាមទារសំណង ត្រូវបានដាក់ជូន"*ដោយស្ថិតក្នុងកម្រិតដែលអាចរកបាន*នូវឯកសារគាំទ្រដែលពាក់ព័ន្ធណាមួយ រួមមានទាំងឈ្មោះ និងអាសយដ្ឋានរបស់សាក្សី"[1092]។

៥១៤. ដូច្នេះ ហាក់បីដូចជាអាចធ្វើទៅបានដែលថា ដើម្បីសម្រេចអំពីសំណង អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC នឹងធ្វើការវាយតម្លៃឡើងវិញអំពីឋានៈជាជនរងគ្រោះ នៅក្នុង ឬបន្ទាប់ពីខ្លួនចេញសាលក្រមចុងក្រោយស្តីពីពិរុទ្ធភាព[1093]។ ហាក់បីដូចជាអាចធ្វើបានផងដែរថា

---

សុំត្រូវបានធ្វើឡើងដោយបុគ្គលដែលធ្វើឡើង ដោយមានការយល់ព្រមពីជនរងគ្រោះត្រូវបញ្ជាក់ ពីការយល់ព្រមរបស់ជនរងគ្រោះនោះ (៧) ប្រសិនបើពាក្យសុំត្រូវបានធ្វើឡើងដោយបុគ្គលក្នុងនាមជាជនរងគ្រោះ នៅក្នុងករណីដែលជនរងគ្រោះជាកុមារ ត្រូវបង្ហាញភស្តុតាងអំពីភាពជាសាច់ញាតិ ឬភាពជាអាណាព្យាបាល ស្របច្បាប់ ឬនៅក្នុងករណីដែលជនរងគ្រោះដែលជនពិការ ត្រូវបង្ហាញភស្តុតាងអំពីភាពជាអាណាព្យាបាលស្របច្បាប់ (៨) ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំនៅលើឯកសារនៅខាងក្រោមបំផុតនៃទំព័រ ចុងក្រោយនៃពាក្យសុំ)។

[1091] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC វិធាន ៩៤(១)(គ) (សេចក្តីបញ្ជាក់បន្ថែម)។

[1092] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC វិធាន ៩៤(១)(ឆ) (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC វិធាន ៩៧(២) ចែងថា៖

> ក. តាមសំណើរបស់ជនរងគ្រោះ ឬតាមរយៈតំណាងស្របច្បាប់របស់ពួកគេ ឬតាមសំណើរបស់ទណ្ឌិត ឬតាមការស្នើរបស់ខ្លួនតុលាការអាចតែងតាំងអ្នកជំនាញសមស្របដើម្បីជួយតុលាការនៅក្នុងការកំណត់វិសាលភាព ទំហំនៃព្យសនកម្ម ការបាត់បង់ និងការខូចខាតដល់ ឬទាក់ទងនឹងជនរងគ្រោះ និងស្នើឡើងនូវជម្រើសនានា ទាក់ទិននឹងប្រភេទ និងទម្រង់ដ៏ សមស្របនៃសំណង។

[1093] លក្ខន្តិកៈតុលាការ ICC មាត្រា ៧៥ (១) ចែងថា ៖

> ក. តុលាការត្រូវបង្កើតជាគោលការណ៍ដែលទាក់ទងដល់ការជួសជុលដល់ ឬទាក់ទងនឹងជន រងគ្រោះ រួមមាន ការសងវិញសំណងជម្ងឺចិត្ត និងការស្តារនីតិសម្បទាឡើងវិញ។ ដោយឈរលើមូលដ្ឋាននេះ

នៅក្នុងដំណាក់កាលនៃការសម្រេចពីសំណងក្នុងរឿងក្តីមួយ តម្រូវការក្នុងការបង្ហាញភស្តុតាងរបស់អ្នកដាក់ពាក្យសុំឋានៈជាជនរងគ្រោះ នៅតែមានភាពអាចបត់បែនបាន ជាពិសេស ពុំមានលក្ខខណ្ឌតម្រូវផ្នែកទម្រង់ អំពីការបង្ហាញភស្តុតាងជាឯកសារនោះឡើយ។ ម៉្យាងវិញទៀត មធ្យោបាយក្នុងការបង្ហាញភស្តុតាង ដែលអាចរកបានតាមច្បាប់ក្នុងការសម្រេចអំពីសំណង គឺមានលក្ខណៈទូលំទូលាយដែលបង្ហាញពីសមត្ថកិច្ចរបស់តុលាការក្នុងការទាមទារឱ្យផ្តល់សំអាងហេតុស្របតាមបទដ្ឋានស្តីពីឧត្តមានុភាពនៃភស្តុតាង។

៥១៥. ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែរហូតមកទល់ពេលនេះ នៅមិនទាន់មានសាលក្រមនៅក្នុងរឿងក្តីណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC ទេ ទើបជាការឆាប់រហ័សពេកក្នុងការសន្និដ្ឋាន ថាតើតុលាការ ICC បានធ្វើការវាយតម្លៃឡើងវិញអំពីឋានៈជាជនរងគ្រោះ នៅក្នុង ឬបន្ទាប់ពីខ្លួនចេញសាលក្រមចុងក្រោយស្តីពីពិរុទ្ធភាព ដែរ ឬយ៉ាងណា ហើយប្រសិនបើជាបានធ្វើដូច្នេះមែន ថាតើបទដ្ឋាននៃការបង្ហាញភស្តុតាងណាមួយ ដែលតុលាការ ICC យកមកអនុវត្តក្នុងការវាយតម្លៃឡើងវិញនេះ[1094]។ ស្រដៀងគ្នានេះដែរ ទោះបីជា

---

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការអាចកំណត់តាម សំណើ ឬតាមការស្នើរបស់ខ្លួននៅក្នុងកាលៈទេសៈពិសេសៗ នូវកម្រិតវិសាលភាព និង ទំហំនៃព្យសនកម្ម ការបាត់បង់ និងការខូចខាតដល់ ឬទាក់ទងនឹងជនរងគ្រោះ ហើយថ្លែង ពីគោលការណ៍ទាំងឡាយដែលខ្លួនកំពុងសំអាងលើ។

[1094]មានការបញ្ចេញទស្សនៈប្រឆាំងទៅនឹងការវាយតម្លៃឡើងវិញនៅដំណាក់កាលមុនជំនុំជម្រះ និងដំណាក់កាល ជំនុំជម្រះ និងនៅពេលធ្វើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ។ *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06-824 "សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ដែលមានចំណងជើងថា "សេចក្តីសម្រេចលើសំណើសុំដោះលែងឱ្យមានសេរីភាពបណ្តោះអាសន្នរបស់ជនជាប់ចោទ Thomas Lubanga Dyilo" "យោបល់ជំទាស់របស់ចៅក្រម Sang-Hyun Song ពាក់ព័ន្ធនឹងការចូលរួមរបស់ជនរងគ្រោះ" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧, កថាខណ្ឌ ៥ ដល់ ៨ (ដែលបានលើកទឡ្ហីករណ៍ថា នៅពេលដែលជនរងគ្រោះអាចបង្ហាញនូវផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ នៅក្នុងរឿងក្តីនោះ ផលប្រយោជន៍ទាំងនេះត្រូវបានប៉ះពាល់នៅក្នុងគ្រប់ដំណើរការនីតិវិធីទាំងអស់ដែលកើតចេញពីរឿងក្តីនោះ)។*រឿងក្តី Lubanga* "សេចក្តីសម្រេចមុនការចាប់ផ្តើមសវនាការលើការចូលរួមរបស់ជនរងគ្រោះ នៅក្នុងបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ដែលមានចំណងជើងថា "សេចក្តីសម្រេចលើការចូលរួមរបស់ជនរងគ្រោះ" "យោបល់ដាច់ដោយឡែករបស់ចៅក្រម Georghios M. Pikis", កថាខណ្ឌ ៣ (កត់

ចៅក្រមនៅអង្គបុរេជំនុំជម្រះនៃតុលាការពិសេសសម្រាប់ប្រទេសលីបង់ (តុលាការ STL) ត្រូវតែសម្រេច "ថាតើអ្នកដាក់ពាក្យសុំបានផ្តល់ភស្តុតាងដែល *ជាសេចក្តីបញ្ជាក់ដំបូង* ដើម្បីកំណត់ថា ជននោះជាជនរងគ្រោះ ដូចដែលមានចែងនៅក្នុងវិធានស្តីពីនីតិវិធី និងភស្តុតាង" ដែរ ឬយ៉ាងណា[1095]ក៏ដោយ ក៏ជាការឆាប់រហ័សពេកនៅក្នុងអត្ថិភាពនៃតុលាការ នេះ ក្នុងការសន្និដ្ឋាន ថាតើតុលាការនេះធ្វើការវាយតម្លៃឡើងវិញអំពីឋានៈរបស់ជនរងគ្រោះ សម្រាប់ការចូលរួមនៅក្នុងនីតិវិធី នៅក្នុង ឬបន្ទាប់ពីមានសាលក្រមស្តីពីពិរុទ្ធភាព ហើយប្រសិនបើបានធ្វើដូច្នេះមែន ថាតើបទដ្ឋាននៃការបង្ហាញភស្តុតាងណាមួយដែលតុលាការ STL បានយកមកអនុវត្តក្នុងការវាយតម្លៃឡើងវិញនេះ[1096]។

### *៦.ឥ.៣.ក.២.តុលាការថ្នាក់តំបន់ស្តីពីសិទ្ធិមនុស្ស*

៥១៦. យុត្តិសាស្ត្រដែលបានមកពីស្ថាប័នសិទ្ធិមនុស្សប្រចាំតំបន់នានា ដែលត្រូវបានបង្កើតឡើងស្របតាមអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ACHR) និងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR) អាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការពិចារណាបាន ប៉ុន្តែ ដូចដែលបានពិភាក្សាកន្លងមកនៅក្នុងសាលដីកានេះឃើញថា ទាំងតុលាការអឺរ៉ុប និងទាំងតុលាការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស បានទាមទារឲ្យមានវិធីសាស្ត្រដាច់ដោយឡែកស្តីពីការបង្ហាញភស្តុតាងដែល

---

សម្គាល់ថា មានការដោះស្រាយតាមច្បាប់ថា បុគ្គលដែលឋានៈរបស់ពួកគាត់ត្រូវបានទទួលស្គាល់ដោយសាលាដំបូងរួចហើយនោះ មិនចាំបាច់កំណត់ឋានៈនោះម្តងទៀតឡើយ នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល)។

[1095]វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL 86(B)(១)។

[1096]*សូមមើលជាទូទៅ រឿងក្តី* Jerome de Hemptinne, "ការជំទាស់តវ៉ាដែលបានលើកឡើងដោយការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការពិសេសសម្រាប់លីបង់" ព្រឹត្តិប័ត្រយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ វ៉ុល 8 (2010) ទំព័រ ១៧១ (ដែលធ្វើការកត់សម្គាល់ថា បទដ្ឋាន*បឋម* ដែលយកមកអនុវត្តដោយតុលាការ STL "គឺស្របគ្នាជាមួយនឹងយុត្តិសាស្ត្ររបស់គណៈកម្មការទូទាត់សំណងរបស់អង្គការសហប្រជាជាតិ (UNCC) ដែលយោងតាមយុត្តិសាស្ត្រនេះ UNCC "បានជ្រើសរើសវិធីសាស្ត្រថ្មីមួយចំពោះបញ្ហានៃភស្តុតាង ដែលតម្រូវឲ្យមាន នូវ "ឯកសារធម្មតា" ឬ "កម្រិតអប្បបរមាសមហេតុផល" ពីអ្នកទាមទារតាមវិធីនៃការបង្ហាញភស្តុតាង។ ប្រការនេះ មិនកែប្រែបទដ្ឋាននៃភស្តុតាងអំពី "តុល្យភាពនៃភវនីយភាព" ឡើយ ប៉ុន្តែជួយដល់អ្នកទាមទារនៅក្នុងការទទួលបានបទដ្ឋាននេះ")។

មិនចងកាតព្វកិច្ចដោយវិធានរបស់ជាតិទេ ហើយបានពឹងផ្អែកតែលើចរិតលក្ខណៈនៃការរំលោភបំពាន និងបញ្ហានានាក្នុងវិវាទរបស់ភាគី[1097]។ ហេតុនេះ ភាពខុសគ្នាជាមួយ អ.វ.ត.ក មានជាប់ពាក់ព័ន្ធនឹងបញ្ហាពីរ គឺបញ្ហានៃការបង្ហាញភស្តុតាងដែលសំដៅដល់ការរំលោភសិទ្ធិដែលជាលទ្ធផលបង្កើតឱ្យមានទូវឋានៈជាជនរងគ្រោះ[1098] និងបទដ្ឋាននៃការបង្ហាញភស្តុតាងដែលអាស្រ័យទៅលើការពិតដែលថា រដ្ឋហត្ថលេខីមានកាតព្វកិច្ចសហការជាមួយនឹងស្ថាប័នដែលបង្កើតឡើងដោយអនុសញ្ញា ក្នុងការបង្ហាញការពិត[1099]។

---

[1097] *សូមមើលឧទា. រឿងក្តី* *Nachova and Others* *ទល់នឹង ប្រទេសប៊ុលហ្គារី*, សាលក្រមប្រណិតរបស់តុលាការ ECtHR, បណ្តឹងលេខ ៤៣៥៧៧/៩៨ និង ៤៣៥៧៩/៩៨ ចុះថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៥, កថាខណ្ឌ ១៤៧ (ដោយលើកឡើងម្តងទៀតថា "នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ ពុំមានឧបសគ្គផ្នែកនីតិវិធីចំពោះការទទួលយកភស្តុតាង ឬរូបមន្តមុនពេលសម្រេចសម្រាប់ការវាយតម្លៃឡើយ។ តុលាការបានអនុម័តសេចក្តីសន្និដ្ឋាននានាដែលតាមការយល់ឃើញរបស់ខ្លួន ត្រូវបានគាំទ្រដោយការវាយតម្លៃដោយសេរីលើ រាល់ភស្តុតាងទាំងអស់ រួមទាំងការសន្និដ្ឋានបែបនេះដែលអាចកើតចេញមកពីអង្គហេតុនានា និងសេចក្តីសន្និដ្ឋានរបស់ភាគីនានា")។ *រឿងក្តីរបស់ឡានពណ៌ស (white van )*"សេចក្តីសម្រេច (សំណង និងសោហ៊ុយ)", កថាខណ្ឌ ៥១។

[1098] *រឿងក្តី* Contreras *និងជនដទៃទៀត ទល់នឹង* El Salvador, តុលាការ IACtHR, សាលក្រម (អង្គសេចក្តី សំណង និងសោហ៊ុយ) ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១, កថាខណ្ឌ ១៨១។ *រឿងក្តី Vera Vera ទល់នឹង ប្រទេសអេក្វាឌ័រ* តុលាការ IACtHR, សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ) ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ១០៩។ *រឿងក្តី Abrill Alosilla និងជនដទៃទៀត ទល់នឹង ប្រទេសប៉េរូ*, តុលាការ IACtHR, សេចក្តីសម្រេច (អង្គសេចក្តី សំណង នឹងសោហ៊ុយ) ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១១, កថាខណ្ឌ ៨៩ ដល់ ៩០។ *រឿងក្តី Cabrera Garcia និង Montiel Flores ទល់នឹង ប្រទេសម៉ិចស៊ិចកូ*, តុលាការ IACtHR, សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយតាមផ្លូវច្បាប់) ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ២១១ ដល់ ២១២។ *រឿងក្តី Usón Ramírez ទល់នឹង ប្រទេសវ៉េណេហ្ស៊ុយអេឡា*, តុលាការ IACtHR, សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ) ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ២០៦ ដល់ ២០៨។ *រឿងក្តី Acevedo Buendia និងជនដទៃទៀត ទល់នឹង ប្រទេសប៉េរូ* ("*និយោជិកអ្នកជម្រះបញ្ជីដែលត្រូវបានបណ្តេញចេញ និងចូលនិវត្តន៍*"), តុលាការ IACtHR, សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ) ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩, កថាខណ្ឌ ១១១ ដល់ ១១៤។

[1099] អនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៣៨(១)(ក) (អតីតមាត្រា ២៨(១)(ក))។ *រឿងក្តី ប្រទេសអៀរឡង់ ទល់នឹង ចក្រភពអង់គ្លេស*, អនុសញ្ញា ACHR, មាត្រា ៤៨(១)(ឃ)។

៥១៧. នៅក្នុងការអនុវត្ត ជាក់ស្តែង អនុលោមតាមតុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស (IACtCH) តុលាការបានអនុវត្តវិធីសាស្ត្រតាមករណីជាក់ស្តែង ចំពោះបទដ្ឋាននៃការ បង្ហាញភស្តុតាងដើម្បីកំណត់ពីឋានៈជាជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំ ដោយពិចារណាថា ចរិតលក្ខណៈនៃឧក្រិដ្ឋកម្មបង្កឱ្យមានផលប៉ះពាល់ ដោយផ្ទាល់ទៅលើលទ្ធភាពរបស់ជនរងគ្រោះក្នុងការប្រមូលភស្តុតាងទាំងនេះនៅដំណាក់បន្ទាប់មក។ តុលាការអន្តរអាមេរិកបានរក ឃើញថា ក្នុងលក្ខខណ្ឌដែលពួកគេបានដាក់ពាក្យសុំជាបុគ្គល[1100]ទាំងជនរងគ្រោះផ្ទាល់ និងសាច់ញាតិរបស់ជនរងគ្រោះផ្ទាល់ ដែលមិនអាចកំណត់អត្តសញ្ញាណបាននៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះក៏ដោយ ក៏អាចក្លាយជាភាគីរងគ្រោះបានដែរ (ដែលត្រូវបានហៅថា អត្ថគាហកនៃសំណង)។ ដើម្បីទទួលបាននូវសំណងសម្រាប់ការខូចខាតដែលមិនមែនជាប្រាក់កាស សាច់ញាតិរបស់ជនរងគ្រោះផ្ទាល់ដែលត្រូវបានកំណត់អត្តសញ្ញាណ[1101] បន្ទាប់ពីមានការជូនដំណឹងអំពីសាលក្រម ដែលសម្រេចអំពីសំណង ត្រូវធ្វើការបង្ហាញភស្តុតាង ក្នុងអំឡុងពេលជាក់លាក់មួយអំពីទំនាក់ទំនងជាមួយនឹងជនរងគ្រោះផ្ទាល់តាមការបង្ហាញពី"ចំណងញាតិលោហិត" ឬឯកសារផ្លូវការដែលចេញដោយរដ្ឋ មានដូចជា សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ សំបុត្របញ្ជាក់កំណើត និងសំបុត្របញ្ជាក់មរណភាព ឬ"លិខិត

---

[1100] *រឿងក្តី Moiwana Community ទល់នឹង Suriname*, តុលាការ IACtHR, សាលក្រម (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ)" ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥, កថាខណ្ឌ ១៧៧ ដល់ ១៧៨។

[1101] *រឿងក្តី Mapiripan Massacre ទល់នឹង ប្រទេសកូឡុំប៊ី*, តុលាការ IACtHR, សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ)" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៥ កថាខណ្ឌ ២៤៧ ("នៅពេលជនរងគ្រោះប្រហែល ៤៩ នាក់ ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋ ក៏ដូចជាសាច់ញាតិរបស់ពួកគាត់ នឹងជាអ្នកដែលទទួលផលប្រយោជន៍ពីទម្រង់បែបបទស្នើសុំសំណងផ្សេងទៀត និង/ឬ សំណងដែលបានរៀបចំសម្រាប់ការខូចខាត ដែលមិនមែនជាប្រាក់កាស នៅពេលដែលគ្មានព័ត៌មាន តុលាការមិនព្រមបង្គាប់ឱ្យសងសំណងសម្រាប់ការខូចខាតជាប្រាក់កាសជាប្រយោជន៍ ដល់ជនរងគ្រោះទាំងអស់នោះ និងសាច់ញាតិរបស់ពួកគាត់ដែលមិនទាន់ត្រូវបានកំណត់អត្តសញ្ញាណម្នាក់ៗនៅក្នុង កិច្ចដំណើរការនីតិវិធីនេះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការលើកឡើងថា ការសម្រេចសំណងនៅតុលាការ អន្តរជាតិនេះមិនបង្កជាឧបសគ្គ ក៏មិនរារាំងដល់លទ្ធភាពរបស់សាច់ញាតិរបស់ជនរងគ្រោះ ដែលមិនត្រូវបានបង្ហាញអត្តសញ្ញាណដែលបានដាក់ពាក្យបណ្តឹងត្រឹមត្រូវនៅចំពោះមុខអាជ្ញាធរជាតិនោះដែរ នៅពេលដែលពួកគាត់ បានចូលខ្លួនមកបង្ហាញអត្តសញ្ញាណ រួមទាំងមធ្យោបាយទាំងឡាយដែលត្រូវបានបង្គាប់នៅក្នុងសេចក្តីសម្រេចនេះ (...)")។

បញ្ជាក់ជាគ្រីស្តសាសនិក ឯកសារបញ្ជាក់ពីមរណភាព ឬអត្តសញ្ញាណប័ណ្ណ ឬការទទួលស្គាល់អំពីទំនាក់ទំនងនេះតាមនីតិវិធីជាតិ”[1102]។ នៅពេលដែលគ្មានឯកសារផ្លូវការបញ្ជាក់នោះ មធ្យោបាយផ្សេងទៀតនៃការបង្ហាញអត្តសញ្ញាណដែលបានទទួលស្គាល់ មានដូចជា “សាក្សីពីររូបដែលបានស្បថ”[1103] ឬសេចក្តីថ្លែងការណ៍នៅចំពោះមុខមន្ត្រីរដ្ឋការដែលមានសមត្ថកិច្ចដែលជាអ្នកដឹកនាំមានការទទួលស្គាល់ពីសហគមន៍ ក៏ដូចជា សេចក្តីប្រកាសរបស់បុគ្គលពីររូបដែលពួកគេពិតជាបានដឹងច្បាស់អំពីអត្តសញ្ញាណរបស់បុគ្គលនោះ[1104]។

៥១៨. ដោយសារតែមានលក្ខខណ្ឌតម្រូវឱ្យមានកិច្ចខិតខំឲ្យអស់ពីលទ្ធភាព ក្នុងការដោះស្រាយនៅថ្នាក់ជាតិមុននឹងដាក់ពាក្យសុំទៅតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ដែលនេះឆ្លុះបញ្ចាំងអំពីគោលការណ៍ស្តីពីបុត្រសម្ពន្ធ)[1105] ដោយអនុលោមតាមអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ដូច្នេះហើយ អង្គហេតុសំខាន់ៗនៅក្នុងរឿងក្តីភាគច្រើន មិនមានវិវាទគ្នានោះទេ[1106]។ តុលាការអនុវត្តនូវវិធីសាស្ត្រដាច់ដោយឡែកពីគ្នាចំពោះបន្ទុកនៃការបង្ហាញភស្តុតាង ពាក់ព័ន្ធទៅនឹងបញ្ហានានានៃភាពអាចទទួលយកបាន និងអង្គហេតុ[1107]។ នៅក្នុងរឿងក្តី *ប្រទេសអៀឡង់ ទល់នឹង ចក្រភពអង់គ្លេស* តុលាការបានសម្រេចបដិសេធការទទួលស្គាល់ថា បន្ទុកនៃការបង្ហាញភស្តុតាង គឺជាកាតព្វកិច្ចរបស់រដ្ឋភាគីនោះឡើយ ហើយបានចង្អុលបង្ហាញថា តុលាការត្រូវធ្វើ

---

[1102] *រឿងក្តី Ituango Massacres ទល់នឹង ប្រទេសកូឡុំប៊ី* សេចក្តីសម្រេច, (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ), កថាខណ្ឌ ៣៥៦។

[1103] *សូមមើល ឧទា. រឿងក្តី Mapiripan Massacre ទល់នឹង ប្រទេសកូឡុំប៊ី,* តុលាការ IACtHR, សេចក្តីសម្រេច (អង្គសេចក្តី សំណង និងសោហ៊ុយ) ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៥ កថាខណ្ឌ ២៥២, ២៥៧(ខ), ២៨៩, ៣០៩ និង ៣១១(៣)។

[1104] *រឿងក្តី Moiwana Community ទល់នឹង Suriname*, កថាខណ្ឌ ១៧៨។

[1105] មាត្រា ៣៥(១) នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប។

[1106] *Philip Leach និងអ្នកនិពន្ធដទៃទៀត*, “សំអាងហេតុស្តីពីសិទ្ធិមនុស្ស។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សនៅចំណុចខ្វែងគ្នា” បោះពុម្ពដោយព្រឹត្តប័ត្រចេញបួនដងក្នុងមួយឆ្នាំរបស់ប្រទេសហូឡង់ស្តីពីសិទ្ធិមនុស្ស (*Netherlands Quarterly of Human Rights)*, វ៉ុល ២៨:១ (ឆ្នាំ ២០១០), ទំព័រ ៤១។

[1107] ព្រឹត្តប័ត្រនិពន្ធដោយ David Harris *និងអ្នកនិពន្ធដទៃទៀត, ច្បាប់នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស*, ចេញផ្សាយដោយសាកលវិទ្យាល័យ Oxford, បោះពុម្ពផ្សាយលើកទី ២, ឆ្នាំ ២០០៩ ទំព័រ ៨៤៩ ដល់ ៨៥១។

ការពិនិត្យលើភស្តុតាងទាំងអស់ ដែលមាននៅចំពោះមុខខ្លួន ដោយមិនចាំបាច់គិតថា ភស្តុតាងនោះបានមកពីគណៈកម្មការ ពីភាគី ឬពីប្រភពផ្សេងទៀតនោះឡើយ ហើយក្នុងករណីចាំបាច់ តុលាការអាចទទួលយកភស្តុតាង*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*[1108]។ នៅក្នុងរឿងក្តីមួយចំនួនទៀតបន្ទាប់ពីរឿងក្តី *ប្រទេសអៀឡង់ ទល់នឹង ចក្រភពអង់គ្លេស* យុត្តិសាស្ត្ររបស់តុលាការបង្ហាញឱ្យឃើញថា អ្នកដាក់ពាក្យសុំត្រូវធ្វើការបង្ហាញពីករណីរបស់ខ្លួន *ដោយផ្អែកលើសេចក្តីបញ្ជាក់ដំបូង* អំពីការជ្រៀតជ្រែកលើសិទ្ធិដែលទទួលបានការការពារ[1109]។ បើត្រឹមតែការអះអាង គឺមិនទាន់គ្រប់គ្រាន់នោះទេ នៅពេលដែលបញ្ហានៃអង្គហេតុជាក់ស្តែងត្រូវបានជំទាស់ដោយរដ្ឋាភិបាល[1110] លើកលែងតែមានកាលៈទេសៈរំលោភបំពានដែលតុលាការសម្រេចអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំរួចផុតពីបន្ទុកនៃការបង្ហាញភស្តុតាង[1111]។ នៅដំណាក់កាលនៃអង្គសេចក្តី "កម្រិតភាពជឿជាក់ដែលចាំបាច់ សម្រាប់ឈានទៅធ្វើសេចក្តីសន្និដ្ឋានពិសេសមួយ (...) (គឺពិតជា) មានទំនាក់ទំនងទៅនឹងកាលៈទេសៈជាក់លាក់នៃរឿងក្តី ចរិតលក្ខណៈនៃការចោទឡើង និងសិទ្ធិតាមអនុសញ្ញាដែលរងការបំពាន"[1112]។ នៅក្នុងរឿងក្តីទាំងឡាយដែលអនុលោមតាមមាត្រា ២ និង ៣ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស តុលាការបានសម្រេច

---

[1108] *រឿងក្តី ប្រទេសអៀឡង់ ទល់នឹង ចក្រភពអង់គ្លេស*, កថាខណ្ឌ ១៦០។

[1109] *រឿងក្តី Artico ទល់នឹង ប្រទេសអ៊ីតាលី*, តុលាការ ECtHR, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ, ពាក្យបណ្តឹងលេខ ៦៦៩៤/៧៤ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៨០, កថាខណ្ឌ ៣០។

[1110] *រឿងក្តី Goddi ទល់នឹង ប្រទេសអ៊ីតាលី*, តុលាការ ECtHR, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ, ពាក្យបណ្តឹងលេខ ៨៩៦៦/៨០ ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ១៩៨៤, កថាខណ្ឌ ២៩។

[1111] *រឿងក្តី Ribitsch ទល់នឹង ប្រទេសអូទ្រីស*, តុលាការ ECtHR, សេចក្តីសម្រេច, ពាក្យបណ្តឹងលេខ ១៨៨៩៦/៩១ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៩៥, កថាខណ្ឌ ៣៤។ *រឿងក្តីប្រទេសអៀឡង់ ទល់នឹង ចក្រភពអង់គ្លេស* សាលក្រមពេញលេញ, កថាខណ្ឌ ១៦១ (ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការធ្វើទារុណកម្ម និងការប្រព្រឹត្តអមនុស្សធម៌នៅពេល ជាប់ឃុំឃាំង)។ និង*រឿងក្តី Çiçek ទល់នឹង ប្រទេសទួគី*, តុលាការ ECtHR, សេចក្តីសម្រេច, ពាក្យបណ្តឹងលេខ ២៥៧០៤/៩៤ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ១៤៧ (ពាក់ព័ន្ធនឹងការបាត់ខ្លួនដោយបង្ខំ)។

[1112] *រឿងក្តី Nachova and Others ទល់នឹង ប្រទេសប៊ុលហ្គារី*, សាលក្រមប្រណិតបំផុតរបស់អង្គជំនុំជម្រះ, កថាខណ្ឌ ១៤៧។ *សូមមើលផងដែរ* David Harris *និងអ្នកនិពន្ធដទៃទៀត*, *ច្បាប់ស្តីពីអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប*, បោះពុម្ពផ្សាយលើកទី ២, ទំព័រ ៨៤៩។

ថា អង្គហេតុនានាត្រូវតែធ្វើការបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់ មានកម្រិតហួសពីវិមតិសង្ស័យ[1113]។ ពុំមានឧបសគ្គផ្នែកនីតិវិធីចំពោះការទទួលយកភស្តុតាងនោះឡើយ[1114]។ តាមទម្លាប់ តុលាការបានស្តាប់សក្ខីកម្មរបស់សាក្សី តែក្នុងករណីពិសេសប៉ុណ្ណោះ[1115] ហើយភាគច្រើនតុលាការបានដាក់ជំនឿទៅលើភស្តុតាងជាឯកសារ។

៥១៩. ការលើកឡើងខាងលើបង្ហាញច្បាស់ថា ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិបានចែង អំពីគោលការណ៍ណែនាំមានកម្រិតចំពោះ អ.វ.ត.ក ស្តីពីបទដ្ឋាននៃការបង្ហាញភស្តុតាងណាដែលត្រូវយកមកអនុវត្ត សម្រាប់សម្រេចនូវភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលសម្រេចពីសំណង។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សំអាងហេតុចុងក្រោយស្តីពីសិទ្ធិទទួលបានសំណងរបស់អ្នកដាក់ពាក្យសុំទាមទារសំណង ត្រូវបានបង្កើតឡើងក្នុងកម្រិតមួយដែលខ្ពស់ជាងភស្តុតាង *ជាសេចក្តីបញ្ជាក់ដំបូង*។

---

[1113] *រឿងក្តី ប្រទេសអៀរឡង់ ទល់នឹង ចក្រភពអង់គ្លេស*, សេចក្តីសម្រេចកិច្ចប្រជុំពេញអង្គ, កថាខណ្ឌ ១៦១ (ដោយលើកឡើងថា ការបង្ហាញភស្តុតាងដែលហួសពីមន្ទិលសង្ស័យសមស្រប “អាចកើតឡើងដោយសារសហាត្ថិភាពនៃការសន្និដ្ឋានរឹងមាំ ច្បាស់លាស់ និងស្របគ្នាគ្រប់គ្រាន់ ឬសហាត្ថិភាពនៃសច្ចធារណ៍នៃអង្គហេតុដែលមិនត្រូវបាន ជំទាស់ប្រហាក់ប្រហែលគ្នា”)។ *រឿងក្តី* Aydin *ទល់នឹង ប្រទេសទួគី*, តុលាការ ECtHR, សាលក្រមប្រណិតបំផុតរបស់អង្គជំនុំជម្រះ, ពាក្យបណ្តឹងលេខ ២៣១៧៨/៩៤ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៧២ ដល់ ៧៣។ *រឿងក្តី* Mentes *និងជនដទៃទៀត ទល់នឹង ប្រទេសទួគី*, តុលាការ ECtHR, សាលក្រមប្រណិតរបស់អង្គជំនុំជម្រះ, ពាក្យបណ្តឹងលេខ ២៣១៨៦/៩៤ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦៦។ *រឿងក្តី* Anguelova *ទល់នឹង ប្រទេសប៊ុលហ្គារី*, តុលាការ ECtHR, សាលក្រមប្រណិតរបស់អង្គជំនុំជម្រះ, ពាក្យបណ្តឹងលេខ ៣៨៣៦១/៩៧ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២, កថាខណ្ឌ ១១១។

[1114] *រឿងក្តី* Nachova and Others *ទល់នឹង ប្រទេសប៊ុលហ្គារី*, សាលក្រមប្រណិតបំផុតអង្គជំនុំជម្រះ, កថាខណ្ឌ ១៤៧។

[1115] David Harris *និងអ្នកនិពន្ធដទៃទៀត*, *ច្បាប់ស្តីពីអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប*, ចេញផ្សាយដោយសាកលវិទ្យាល័យ Oxford, បោះពុម្ពផ្សាយលើកទី ២, ទំព័រ ៨៤៦ ដល់ ៨៤៨។ Philip Leach *និងអ្នកនិពន្ធដទៃទៀត*, “សំអាងហេតុស្តីពីសិទ្ធិមនុស្ស។ តុលាការសិទ្ធិមនុស្សអឺរ៉ុប នៅចំណុចខ្វែងគ្នា” ទំព័រ ៤២, ៧៧ (ដោយសង្កេតពីកម្រិតខ្ពស់បំផុតនៅក្នុងបេសកកម្មសំអាងហេតុរបស់តុលាការ សិទ្ធិមនុស្សអឺរ៉ុបចាប់ពីឆ្នាំ ១៩៩០ ប៉ុន្តែ មានចំនួនថយចុះគួរឱ្យកត់សម្គាល់ចាប់តាំងពីមានការផ្លាស់ប្តូរប្រព័ន្ធ Strasbourg នៅឆ្នាំ ១៩៩៨)។

### ៦.គ.៣.ក.៣.កម្មវិធីទាមទារសំណង

៥២០. តុលាការកំពូលពិចារណាឃើញថា ខ្លួនអាចនឹងដាក់ឱ្យមានការពិភាក្សាអំពីបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលបានអនុវត្តនៅក្នុងកម្មវិធីទាមទារសំណង ដែលអនុវត្តកន្លងមក។ ស្រដៀងគ្នាទៅនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ដែរ ជាញឹកញាប់ អ្នកទាមទារសំណងមានបញ្ហាប្រឈមនៅចំពោះមុខកម្មវិធីទាមទារសំណងក្នុងការបង្ហាញភស្តុតាងអំពីសិទ្ធិទទួលបានសំណងរបស់ពួកគេ អាស្រ័យដោយគ្មានភស្តុតាងបញ្ជាក់អំពីភាព"មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងកាលៈទេសៈទាំងឡាយ ដែលនាំឱ្យមានការបាត់បង់ និងការរំលោភបំពាននានាដែលបន្តនិរន្តរភាព និងដែលត្រូវដោះស្រាយឡើងវិញតាមរយៈកម្មវិធីផ្តល់*សំណង*នេះ"[1116]។ យោងតាមឯកសាររបស់ Niebergall បញ្ជាក់ថា "ភាគច្រើន" នៃកម្មវិធីទាមទារសំណងដែលកើតមាននាពេលថ្មីៗនេះ "បានបង្កើតឡើង និងបានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងដែលមានភាពងាយស្រួល ដើម្បីជួយសម្រួលដល់បន្ទុករបស់អ្នកប្តឹងទាមទារ ក្នុងការបង្ហាញភស្តុតាងអំពីសំណើរបស់ពួកគេ"[1117]។ បទដ្ឋាននៃការបង្ហាញភស្តុតាងដែលបានអនុវត្តតាមនីតិវិធីដែលមានបណ្តឹងទាមទារច្រើន ត្រូវបានបង្ហាញនៅក្នុងលក្ខខណ្ឌដែលមានដូចជា: ភាពសមល្មម ភាពអាចជឿជាក់បាន ការបង្ហាញពីភាពសមហេតុផល ការផ្តល់ឯកសារធម្មតា លក្ខខណ្ឌតម្រូវអប្បបរមាដែលសមហេតុផល និងតុល្យភាពនៃភវនីយភាព[1118]។

---

[1116] Heike Niebergall "ភាពទន់ខ្សោយនៃភស្តុតាងដែលឈ្នះនៅក្នុងកម្មវិធីស្នើសុំសំណង", បោះពុម្ពផ្សាយដោយនិពន្ធនាយកឈ្មោះ *Ferstman និងនិពន្ធនាយកដទៃទៀត, សំណងសម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹង មនុស្សជាតិ* Brill, ឆ្នាំ ២០០៩, ទំព័រ ១៥០។ *សូមមើលផងដែរ* ស្ថានភាពនៅប្រទេសអ៊ូហ្គង់ដា "សេចក្តីសម្រេចលើពាក្យសុំចូលរួមរបស់ជនរងគ្រោះ a/0010/06, a/0064/06 ដល់ a/0070/06, a/0081/06 ដល់ a/0104/06 និង a/0111/06 ដល់ a/0127/06", កថាខណ្ឌ ១៥ ("មានការរំពឹងដោយសមស្របថា ជនរងគ្រោះនឹងមិនចាំបាច់ ឬតែងតែមានតួនាទីត្រូវបង្ហាញភស្តុតាងឱ្យបានពេញលេញអំពីការស្នើសុំរបស់ខ្លួនឡើយ)។

[1117] Niebergall, "ចំណុចខ្សោយនៃភស្តុតាងដែលឈ្នះនៅក្នុងកម្មវិធីស្នើសុំសំណង", ទំព័រ ១៥៥។ នៅក្នុងជើងទំព័រ លេខ ៣៥, Niebergall បានផ្តល់នូវឧទាហរណ៍នៃកម្មវិធីស្នើសុំសំណងចំនួនពីរដែលមិនបានបញ្ចូលនៅក្នុងវិធានរបស់ខ្លួន"ភាពធូរស្រាលនៃបទដ្ឋាននៃភស្តុតាង"។

[1118] Niebergall, "ចំណុចទន់ខ្សោយនៃភស្តុតាងដែលឈ្នះនៅក្នុងកម្មវិធីស្នើសុំសំណង", ទំព័រ ១៥៦ ដល់ ១៥៩។

៥២១. នៅក្នុងន័យនៃការអនុវត្តជាក់ស្តែង តុលាការសម្រាប់ដោះស្រាយបណ្តឹងទាមទារចំពោះគណនីអសកម្មនៅហ្សូរីស ប្រទេសស្វីស (CRT I និង CRT II) ដែលមានកំណត់បទដ្ឋានស្តីពីភាពសមហេតុផល នៅក្នុងឯកសារសំខាន់ៗ ហើយដែលភាពសមហេតុផលនេះ ត្រូវអនុលោមតាមលក្ខណៈវិនិច្ឆ័យចំនួនបី គឺ ១) ការបង្កើតរាល់ឯកសារ និងព័ត៌មានទាំងអស់ ដែលគេរំពឹងដោយសមហេតុផលថា អាចបង្កើតបានក្នុងទិដ្ឋភាពនៃកាលៈទេសៈពិសេសណាមួយ ២) មិនមានមូលដ្ឋានសមហេតុផលដែលអាចសន្និដ្ឋានថា មានអំពើឆបោក ឬក្លែងបន្លំដែលធ្វើឲ្យប៉ះពាល់ដល់ការទាមទារនោះទេ ឬ ៣) មិនមានមូលដ្ឋានសមហេតុផលដែលអាចសន្និដ្ឋានបានថា បុគ្គលផ្សេងទៀតអាចមានការទាមទារដែលមានស្ថានភាពប្រសើរជាងនេះ ឬក៏ដូចគ្នានោះទេ[1119]។ ផ្អែកតាមលក្ខណៈវិនិច្ឆ័យទាំងនេះ ប្រភេទនៃព័ត៌មានដែលត្រូវបានទទួលយកជាភស្តុតាងបញ្ជាក់អំពីស្ថានភាពផ្ទាល់ខ្លួន មានវិសាលភាពកាន់តែទូលំទូលាយ ដើម្បីជួយដល់អ្នកប្តឹងទាមទារសំណង។ ជំនួសឲ្យឯកសារផ្លូវការឯកសារឯកជនក៏ត្រូវបានទទួលយកផងដែរ ដែលរួមមានទាំង រូបថត លិខិត និងប័ណ្ណប្រៃសណីយ៍។ សូម្បីតែសេចក្តីស្រង់នៃអត្ថបទការសែត ក៏អាចត្រូវបានចាត់ទុកថា ជាព័ត៌មានគ្រប់គ្រាន់សម្រាប់បង្ហាញពីអត្ថិភាពនៃសមាជិកគ្រួសារបានផងដែរ ប្រសិនបើ ការដកស្រង់នោះ មានភាពស៊ីសង្វាក់គ្នា ឬយ៉ាងហោចណាស់ មិនផ្ទុយគ្នាទៅនឹងកំណត់ត្រាធនាគារ[1120]។ គណៈកម្មាធិការអន្តរជាតិសម្រាប់ដោះស្រាយបណ្តឹងទាមទារកិច្ចធានារ៉ាប់រង នាសម័យកាលមហាវិនាសកម្ម (Holocaust Era Insurance Claim) បានសម្រេចថា ការទាមទារត្រូវតែ មានភាពសមហេតុផល "ដោយផ្អែកលើរាល់កាលៈទេសៈពិសេសដែលពាក់ព័ន្ធ ដោយរួមបញ្ចូលទាំងការបំផ្លិចបំផ្លាញដែលបង្កឡើងដោយសង្គ្រាមលោកលើក ទី II មហាវិនាសកម្ម និងពេលវេលាដែលបានកន្លងហួសជា

[1119]ដំណោះស្រាយទាមទារសំណងលើកទី ១ របស់តុលាការសម្រាប់គណនីយអសកម្មនៅទីក្រុង Zurich, វិធាននីតិវិធីប្រទេសស្វីស មាត្រា ២២ ដែលអាចមើលបាននៅគេហទំព័រ www.crt-ii.org/_crt-i/frame.html។

[1120]Niebergall, "ចំណុចខ្សោយនៃភស្តុតាងដែលឈ្នះនៅក្នុងកម្មវិធីទាមទារសំណង", ទំព័រ ១៥៧។

យូរមកហើយ ប៉ុន្តែ មិនកម្រិតត្រឹមតែបញ្ហាទាំងអស់ខាងដើមនោះទេ”[1121]។ អ្នកប្តឹងទាមទារអាចដាក់ជូននូវឯកសារមានលក្ខណៈឯកជនបាន ដូចជាលិខិតបញ្ជាក់របស់តតីយជន ឬលិខិតផ្សេងៗទៀត។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលអ្នកប្តឹងទាមទារ“មិនអាចដាក់ភស្តុតាងជាឯកសារ ដើម្បីគាំទ្រការទាមទារបាន នោះការអះអាងរបស់ជននេះ ត្រូវតែមានកម្រិតចាំបាច់នៃលក្ខណៈពិសេស និងយថាភាព ដើម្បីធ្វើឲ្យមានការជឿជាក់ចំពោះកាលៈទេសៈនៅក្នុងរឿងក្តី”[1122]។ កម្មវិធីផ្តល់សំណងពលកម្មដោយបង្ខំរបស់ប្រទេសអាល្លឺម៉ង់ (German Forced Labour Compensation Program) បានលើកឡើងថា “សិទ្ធិទទួលបានសំណងត្រូវតែបង្ហាញតាមរយៈការដាក់ឯកសារ”។ យ៉ាងណាក៏ដោយ “ប្រសិនបើមិនអាចរកបាននូវភស្តុតាងពាក់ព័ន្ធនោះទេ នោះសិទ្ធិទទួលបានសំណងអ្នកប្តឹងទាមទារ អាចត្រូវបានធ្វើឲ្យមានភាពជឿជាក់តាមវិធីផ្សេងទៀតបាន”[1123]។ អាស្រ័យលើតម្លៃនៃការទាមទារសំណង គណៈកម្មាធិការផ្តល់សំណងអង្គការសហប្រជាជាតិ (UNCC) បានតម្រូវឲ្យអ្នកប្តឹងទាមទារសំណងបង្ហាញភស្តុតាង ដូចជាៈ “ការផ្តល់ឯកសារធម្មតា” “កម្រិតអប្បបរមាសមហេតុផល ដែលសមស្របតាមស្ថានភាពពិសេស”[1124] ឬក៏“ភស្តុតាងជាឯកសារ ឬភស្តុតាងសមស្របផ្សេងទៀតដែលមាន ភាពគ្រប់គ្រាន់សម្រាប់បង្ហាញ

---

[1121]វិធាន ក (១) នៃបទដ្ឋានធូរស្រាលនៃគោលការណ៍ណែនាំអំពីការបង្ហាញភស្តុតាងរបស់គណៈកម្មាធិការអន្តរជាតិសម្រាប់ដោះស្រាយបណ្តឹងទាមទារកិច្ចធានារ៉ាប់រងនាសម័យកាលមហាវិនាសកម្ម (ICHEIC) ដែលអាចមើលបាននៅ www.icheic.org/docs-documents.html ។

[1122]ក្រុមប្រឹក្សាជំនុំជម្រះបណ្តឹងសាទុក្ខរបស់គណៈកម្មាធិការអន្តរជាតិសម្រាប់ដោះស្រាយបណ្តឹងទាមទារកិច្ចធានារ៉ាប់រងនាសម័យកាលមហាវិនាសកម្ម (ICHEIC) សាលដីកាកោសល្យុប លេខ ២០, កថាខណ្ឌ ១៩ ដែលអាចមើលបាននៅគេហទំព័រ www.icheic.org/docs-appealspanel.htm។

[1123]មាត្រា ១១(២) នៃច្បាប់ស្តីពីការបង្កើតមូលដ្ឋាន “ការចងចាំ ការទទួលខុសត្រូវ និងអនាគត” ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០០ ដែលអាចមើលបាននៅគេហទំព័រ www.stiftung-evz.de/eng/ ។

[1124]សេចក្តីសម្រេចលេខ ១០ របស់ក្រុមប្រឹក្សាយគ្រប់គ្រងនៃគណៈកម្មាធិការផ្តល់សំណងអង្គការសហប្រជាជាតិ (UNCC) ដែលបានអនុម័តវិធានបណ្តោះអាសន្នសម្រាប់នីតិវិធីទាមទារសំណង, ឯកសារអង្គការសហប្រជាជាតិលេខ S/AC.26/1992/10 (ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩២), (“វិធានរបស់ UNCC”), មាត្រា ៣៥(២)(ក)-(គ) ដែលអាចមើលបាននៅគេហទំព័រ www.uncc.ch/decision.htm។

អំពីកាលៈទេសៈ និងទំហំនៃការខូចខាត ដែលបានប្តឹងទាមទារ"[1125]។ ទាក់ទងនឹងប្រភេទចុងក្រោយនេះ គណៈវិនិច្ឆ័យបានសម្រេចថា អ្នកប្តឹងទាមទារសំណងជាច្រើនមិនអាចត្រូវបានគេរំពឹងឲ្យដាក់ឯកសារគ្រប់ចំណុចទាំងអស់នៃការទាមទារនោះទេ ហើយគណៈវិនិច្ឆ័យបន្តបង្កើតនូវ "លក្ខណៈវិនិច្ឆ័យស្តីពីតុល្យភាពនៃភវនីយភាព" ដោយពិនិត្យលើស្ថានភាពដែលកើតមាន នៅពេលឈ្លានពាន និងការខូចខាត[1126]។

## ៦.គ.៤.ការពិចារណា

៥២២. ដើម្បីផ្តល់បរិបទសម្រាប់ជាជំនួយដល់ការពិភាក្សា អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូង ពិនិត្យមើលភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម បន្ទាប់ពីអង្គជំនុំជម្រះបានសម្រេចលើការទទួលខុសត្រូវបទឧក្រិដ្ឋរបស់ កាំង ហ្គេកអ៊ាវ និងនៅក្នុងបរិបទនៃការសម្រេចលើសំណើទាមទារសំណង[1127]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តដោយត្រឹមត្រូវក្នុងការដែលខ្លួនតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណី "ត្រូវតែបង្ហាញដល់អង្គជំនុំជម្រះអំពីទំនាក់ទំនងដោយផ្ទាល់រវាងកំហុសរបស់ជនជាប់ចោទ និងព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងដោយផ្ទាល់"[1128] នៅពេលដែលខ្លួនដាក់សំណើទាមទារសំណង។ បញ្ហានាពេលបច្ចុប្បន្នក្នុងបណ្តឹងសាទុក្ខ គឺការកំណត់បទដ្ឋាននៃការបង្ហាញភស្តុតាងត្រឹមត្រូវ ដែលត្រូវអនុវត្តនៅដំណាក់កាលនៃការផ្តល់ សំណង ដើម្បីសម្រេចអំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី និងដើម្បីកំណត់ ថាតើអង្គជំនុំជម្រះសាលាដំបូង ពិតជាបានអនុវត្តនូវបទដ្ឋាននៃ

---

[1125]មាត្រា ៣៥(៣) នៃវិធានរបស់គណៈកម្មាធិការផ្តល់សំណងអង្គការសហប្រជាជាតិ (UNCC)។

[1126]របាយការណ៍របស់ UNCC និងអនុសាសន៍ដែលធ្វើឡើងដោយគណៈវិនិច្ឆ័យនៃស្នងការទាក់ទិននឹងផ្នែក ១ នៃសងវល្លិសលើកដំបូងនៃការទាមទារសំណងចំពោះការខូចខាតរបស់បុគ្គលម្នាក់ៗ ដែលមានតម្លៃលើសពី ១០០.០០០ ដុល្លាអាមេរិក (ការទាមទារប្រភេទ "ឃ") ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨, ឯកសារអង្គការសហប្រជាជាតិលេខ S/AC.26/1998/1, កថាខណ្ឌ ៧២ ដែលអាចមើលបាននៅគេហទំព័រ www.uncc.ch/reports.htm ។

[1127]អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៦៧ ដល់ ៥៦៨, ៦៣៩ ដល់ ៦៧៥។

[1128]អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៣៩ (គូសបញ្ជាក់បន្ថែម)។

ការបង្ហាញភស្តុតាងបែបនោះចំពោះម្ចាស់បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗដែរ ឬយ៉ាងណា។

៥២៣. បទដ្ឋាននៃការបង្ហាញភស្តុតាង*ជាសេចក្តីបញ្ជាក់ដំបូង* ដែលអង្គជំនុំជម្រះសាលាដំបូងអនុវត្តនៅមុនពេលចាប់ផ្តើមការជំនុំជម្រះ មិនស្ថិតនៅក្នុងបណ្តឹងសាទុក្ខនោះទេ ហើយនៅគ្រប់ពេលវេលា បទដ្ឋាននេះត្រូវបានគេទទួលយកយ៉ាងទូលំទូលាយនៅកម្រិតអន្តរជាតិថា ជាបទដ្ឋានសម្រាប់ប្រើប្រាស់ នៅពេលវាយតម្លៃបឋមលើឋានៈរបស់ជនរងគ្រោះ[1129]។ ទាក់ទងនឹងបទដ្ឋាននៅដំណាក់កាលផ្តល់សំណង អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងថា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៥) "បានកំណត់យ៉ាងច្បាស់"[1130] អំពីបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលត្រូវយកមកអនុវត្តនៅដំណាក់កាលផ្តល់សំណង ដើម្បីកំណត់អំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី។ ចរិតលក្ខណៈនៃការកំណត់ច្បាស់លាស់នេះ គឺថា កិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក បានទទួលស្គាល់យ៉ាងច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៥) នូវបទដ្ឋានដែលមិនមានភាពច្បាស់លាស់នៅក្នុងវិសោធនកម្មលើកទី ៣ នៃវិធានផ្ទៃក្នុង និងនៅក្នុងអំឡុងពេលជំនុំជម្រះសំណុំរឿង ០០១។ អង្គជំនុំជម្រះតុលាការកំពូលក៏យល់ស្របផងដែរជាមួយដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២[1131] ដែលថា ពាក្យថា "អាចជាការពិត"ត្រូវបានប្រើប្រាស់ដើម្បីរៀបរាប់អំពីបទដ្ឋាននៃការបង្ហាញភស្តុតាងដែលត្រូវបានគេហៅថា "ឧត្តមានុភាពនៃភស្តុតាង"[1132] និង"តុល្យភាពនៃ

---

[1129] *សូមមើល ឧទា.* សេចក្តីសង្ខេបខាងលើរបស់តុលាការ ICC, តុលាការ STL និងតុលាការ ECHR។

[1130] អង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៧២។

[1131] បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៥៣។

[1132] នៅក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណីនៅតុលាការថ្នាក់ជាតិ *សូមមើល ឧទា. រឿងក្តីក្រុមហ៊ុន Tolland Enterprises ទល់នឹងក្រុមហ៊ុន Scan-Code, Inc.*, ឆ្នាំ ១៩៩៥ រដ្ឋខនិកធីខាត (Conn.) តុលាការជាន់ខ្ពស់ (Super.) លេខទិន្នន័យ (LEXIS 2882), ទំព័រ ៦ តុលាការជាន់ខ្ពស់នៃរដ្ឋខនិកធីខាត (Superior Ct. Conn.) (ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥) ("នៅក្នុងរឿងក្តីរដ្ឋប្បវេណីធម្មតា ភាគីត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវនៃបន្ទុកភស្តុតាង ប្រសិនបើភស្តុតាងដែលបានបង្ហាញ បង្កើតជាបញ្ហាដែលជាគុណប្រយោជន៍ដល់សាក្សីនោះ ដោយ"ឧត្តមានុភាពនៃភស្តុតាងដែលត្រឹមត្រូវ" មួយ... "ឧត្តមានុភាពដែលត្រឹមត្រូវ" មានន័យថា ជាភស្តុតាងដែលមានភាពប្រសើរជាង ឬមានទម្ងន់ជាង ហើយភាគីមួយ

ភវនីយភាព"[1133]។ ហេតុដូចនេះ បទដ្ឋាននៃការបង្ហាញភស្តុតាងនេះ ស៊ីសង្វាក់គ្នាទៅនឹងបទដ្ឋាននៃការង្ហាញភស្តុតាងដែលមានលក្ខណៈដាច់ខាត នៅក្នុងរឿងក្តីរដ្ឋប្បវេណី។

---

ពុំតម្រូវឲ្យបង្ហាញអង្គហេតុដែលជាក់លាក់ដាច់ខាតនោះទេ តែគេគ្រាន់តែបង្ហាញថា អង្គហេតុមួយ *ទំនងជាពិត* ...។ ឧត្តមានុភាពបែបនេះមិនត្រូវបានវិនិច្ឆ័យទៅតាមចំនួនសាក្សីទេ ប៉ុន្តែវិនិច្ឆ័យអាស្រ័យទៅតាមគុណភាពសាក្សីដែលមកផ្តល់សក្ខីកម្មវិញ") (សេចក្តីបញ្ជាក់បន្ថែម។ លុបអត្ថបទដកស្រង់) បដិសេធចោលបណ្តឹងសាទុក្ខមួយផ្នែក ដោយផ្អែកលើមូលដ្ឋានផ្សេងទៀត, វ៉ុល ២៣៩ រដ្ឋខនិកធីខាត ទំព័រ ៣២៦ តុលាការកំពូលនៃរដ្ឋខនិកធីខាត (Supreme Ct. Conn.) (ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦)។ នៅក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណីនៅតុលាការថ្នាក់ជាតិ *សូមមើល ឧទា. រឿងក្តី ប្រជាជន ទល់នឹង Wilhoite*, វ៉ុល២២៨ អ៊ីលីណយ (Ill.) តុលាការកំពូល 3d ទំព័រ ១២, ២០ តុលាការកំពូលនៃរដ្ឋអ៊ីលីណយ (Ill. App. Ct.) (ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១) ("ឧត្តមានុភាពនៃភស្តុតាងមានន័យថា ចុងចោទត្រូវតែបង្ហាញថា "គាត់ *ទំនងជាមាន*ជំងឺវិកលចរិតនៅពេលដែលគាត់ប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់នោះ...។" *សូមមើលផងដែរ* P. Robinson, ចំណងជើងថា ការការពារក្តីច្បាប់ព្រហ្មទណ្ឌ ១ (1 *Criminal Law Defenses),* ផ្នែកទី ៥ (ក) ទំព័រ ៥១ ដល់ ៥២ (ឆ្នាំ ១៩៨៤) ("ការបង្ហាញភស្តុតាងតាមរយៈការបញ្ជាក់ឧត្តមានុភាពនៃភស្តុតាង តម្រូវឲ្យភាគីដែលមានបន្ទុកស្វែងរកធ្វើយ៉ាងណាឲ្យក្រុមប្រឹក្សាវិនិច្ឆ័យលើអង្គហេតុ ជឿជាក់ថា អំណះអំណាងដែលខ្លួនលើកឡើង*ទំនងជាពិត*។ នៅពេលដែលចុងចោទត្រូវតែបង្ហាញការការពារខ្លួនដោយការបញ្ជាក់ឧត្តមានុភាពនៃភស្តុតាងនោះ ក្រុមប្រឹក្សាវិនិច្ឆ័យលើអង្គហេតុត្រូវតែច្រានចោលការការពារខ្លួននោះ នៅពេលគេជឿថា ភស្តុតាង*មិនសមទំនង*សម្រាប់ឲ្យចុងចម្លើយយកធ្វើជាសំអាងសម្រាប់ការពារខ្លួន")។ (សេចក្តីបញ្ជាក់បន្ថែម) បណ្តឹងសាទុក្ខត្រូវបាន បដិសេធចោល, វ៉ុល ១៤៤ រដ្ឋអ៊ីលីណយ. 2d, ទំព័រ ៦៤២, វ៉ុល ៥៩១ N.E.2d ទំព័រ ៣០, វ៉ុល ១៦៩ អ៊ីលីណយ ខែ ធ្នូ, ទំព័រ ១៥០, (ឆ្នាំ ១៩៩២) លេខវិន្ន័យ (LEXIS)។

[1133]នៅក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណីនៅតុលាការអន្តរជាតិ *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Nikola Sainovic និង Dragoljub Ojdanic,* សំណុំរឿង IT-99-37-AR65, "សាលដីកាសម្រេចលើការដោះលែងបណ្តោះអាសន្ន" "មតិយោបល់ដោយឡែករបស់ចៅក្រម Shahabuddeen", អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០២, កថាខណ្ឌ ៣៧៖

> ក. នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ បញ្ហាថា តើជនជាប់ចោទដែលត្រូវបានចោទប្រកាន់ពីការរំលោភធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ នៅចំពោះមុខតុលាការមួយដោយពុំមានស្ថាប័នប្រតិបត្តិបានត្រឹមត្រូវ អាចនឹងចូលរួមក្នុងការជំនុំជម្រះបានឬយ៉ាងណា។ ដើម្បីសម្រេចបញ្ហាស្តីពីតុល្យភាពនៃលក្ខណវិនិច្ឆ័យនៃភវនីយភាព នឹងមានន័យថា អ្វីដែលជនជាប់ចោទត្រូវធ្វើ គឺធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះសាលាដំបូងយល់ថា ខ្លួនមានវត្តមានក្នុងការជំនុំជម្រះសេចក្តីនេះ តាមរយៈការបង្ហាញថា ខ្លួនជា*ពិតជាទំនង*នឹងបង្ហាញខ្លួន ជាជាងមិនបង្ហាញខ្លួន ហើយបើតាមសំដីរបស់ចៅក្រម Posner ដែលជាចៅក្រមប្រធាន គឺ

៥២៤. បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ទោះជាមានពាក្យពេចន៍ខុសៗគ្នាដែលប្រើដើម្បីរៀបរាប់លក្ខខណ្ឌតម្រូវនៃភស្តុតាងក៏ដោយ ក៏កម្មវិធីផ្តល់សំណងនៅតែមិនអាចញែកចេញពីសញ្ញាណនៃតុល្យភាពនៃភវនីយភាពបាននោះទេ។ បទដ្ឋាននៃ"ភាពអាចជឿជាក់បាន" ដែលត្រូវបានអនុវត្តនៅក្នុងកម្មវិធីផ្តល់សំណង ចំពោះការធ្វើពលកម្មដោយបង្ខំត្រូវបានបំពេញ ប្រសិនបើ "អង្គហេតុមូលដ្ឋាននោះ ទំនងជាពិត ដោយផ្អែកលើព័ត៌មានដែលមាន"[1134]។ អត្ថន័យនៃពាក្យ "អង្គហេតុមូលដ្ឋានដែលទំនងជាការពិតជាងមិនពិត" និង "តុល្យភាពនៃភវនីយភាព" គឺមានអត្ថន័យដូចគ្នាបេះបិទនឹងពាក្យ "អាចជាការពិត ផ្អែកតាមវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៥) របស់ អ.វ.ត.ក។ ជាចុងក្រោយ បទដ្ឋាននៃភស្តុតាងក្នុងលក្ខណៈជា"ការផ្តល់ឯកសារធម្មតា" និង"កម្រិតអប្បបរមាសមហេតុផល" ដែលប្រើដោយ UNCC គឺជាវិធីសាស្ត្រថ្មីមួយចំពោះបញ្ហានៃការបង្ហាញភស្តុតាងនេះ ដែលទោះជាយ៉ាងណាក៏ដោយ ក៏"មិនបានធ្វើឲ្យមានការផ្លាស់ប្តូរនូវបទដ្ឋាននៃការបង្ហាញភស្តុតាងជា "តុល្យភាពនៃភវនីភាព"នោះទេ ប៉ុន្តែបទដ្ឋានថ្មីទាំងនេះ គ្រាន់តែជួយដល់អ្នកប្តឹងទាមទារសំណងឲ្យអនុវត្តបានតាមបទដ្ឋាន"[1135]តែប៉ុណ្ណោះ។

៥២៥. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា តាមការអនុវត្តជាក់ស្តែង កម្មវិធីផ្តល់សំណងបានពិចារណាទៅលើមូលដ្ឋានអង្គហេតុដែលនាំឱ្យមានការទាមទារសំណង និងបានពិចារណាទៅលើកង្វះខាតឯកសារផ្លូវការដែលពាក់ព័ន្ធ និងបានឆ្លើយតបតាមរយៈការជួយសម្រួលបន្ទុក

ថាបើគិតជាតួលេខវិញគឺ ៥១ ទល់នឹង ៤៩ ដែលថា ពួកគេនឹងបង្ហាញខ្លួន។ ដូចដែល Lord Diplock បានផ្តល់សេចក្តីសង្កេតរួចមកហើយនៅក្នុងរឿងក្តី *Fernandez* អំពីលក្ខណៈវិនិច្ឆ័យ គឺត្រូវតែបង្ហាញថា ព្រឹត្តិការណ៍ដែលកំពុងពិភាក្សា "ទំនងពិត...ជា... ដែលនេះគឺជាអត្ថន័យនៃពាក្យពេចន៍ "តុល្យភាពនៃភវនីយភាព" (សេចក្តីបញ្ជាក់បន្ថែម)។

[1134]Niebergall, "ចំណុចខ្សោយនៃភស្តុតាងដែលឈ្នះនៅក្នុងកម្មវិធីស្នើសុំសំណង", ទំព័រ ១៥៨។

[1135]Rajesh Singh, "ការស្នើសុំសំណង: បញ្ហាភស្តុតាងនៅក្នុងការទាមទារសំណងរបស់បុគ្គលរៀងខ្លួននៅចំពោះមុខគណៈកម្មការ ដោះស្រាយសំណងរបស់អង្គការសហប្រជាជាតិ" នៅក្នុងការិយាល័យអន្តរជាតិនៃតុលាការអាជ្ញា កណ្តាល អចិន្ត្រៃយ៍ ការជួសជុលភាពអយុត្តិធម៌តាមរយៈនីតិវិធីទាមទារជាច្រើន: *ការឆ្លើយតបកែលម្អទៅនឹងការជំទាស់តែមួយ,* ចេញផ្សាយដោយសាកលវិទ្យាល័យ Oxford, ឆ្នាំ ២០០៦, ទំព័រ ៦២។

ដល់អ្នកប្ដឹងទាមទារសំណង។ ការសម្រួលនេះ បានធ្វើឡើងតាមរយៈការទទួលយកយ៉ាងទូលំទូលាយនូវវិធីសាស្ត្រផ្សេងទៀតក្នុងការបង្ហាញភស្តុតាង ប៉ុន្តែ បានជួយសម្រួលបន្ទុកតិចតួចបំផុតដល់ការបន្ទាបកម្រិតចាំបាច់នៃភវនីយភាព។ ក្នុងន័យនេះ កម្មវិធីផ្ដល់សំណងបានបោះបង់ចោលនូវលក្ខខណ្ឌតម្រូវដែលថា អង្គហេតុសត្យានុម័តមួយចំនួន ដូចជា ចំណងសាច់ញាតិ កម្មសិទ្ធិ និងទំនាក់ទំនងកិច្ចសន្យា ត្រូវបង្ហាញភស្តុតាងតាមរយៈឯកសារផ្លូវការ ឬឯកសារដែលត្រូវបានបញ្ជាក់ជាផ្លូវការ ហើយបានទទួលយកបណ្ដុំឯកសារឯកជនដែលគាំទ្រដោយផ្ទាល់ ឬដោយប្រយោលចំពោះការទាមទារសំណង នៅពេលដែលពុំមានឯកសារផ្លូវការ ឬឯកសារដែលបញ្ជាក់ជាផ្លូវការនោះ។ ដោយមានវិធីសាស្ត្របែបនេះ ភាពជឿជាក់ដែលអាចមានចំពោះការអះអាងបញ្ជាក់របស់អ្នកដាក់ពាក្យសុំ គឺមានសារៈសំខាន់ជាចម្បង។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា កម្មវិធីទាមទារសំណងចំនួនពីរដែល"ភាពសមហេតុផល"នៃបទដ្ឋាននៃការបង្ហាញភស្តុតាង មានចែងនៅក្នុងឯកសារច្បាប់សំខាន់ៗ[1136]បានទទួលយកការអនុវត្តជាក់ស្ដែងដូចៗគ្នានេះដែរ។

៥២៦. ចំពោះវិធីសាស្ត្រជាក់ស្ដែងរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងបញ្ហាស្ដីពីភាពគ្រប់គ្រាន់នៃការបង្ហាញភស្តុតាង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់មធ្យោបាយនៃការបង្ហាញភស្តុតាងយ៉ាងទូលំទូលាយ។ ដើម្បីបង្ហាញនូវអត្ថិភាពជាជនរងគ្រោះផ្ទាល់ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកកំណត់ហេតុផ្លូវការពីមន្ទីរ ស ២១ និងមន្ទីរ ស ២៤ រួមទាំង សៀវភៅចុះបញ្ជី បញ្ជីឈ្មោះអ្នកជាប់ឃុំឃាំង រូបថត កំណត់ហេតុសារភាព និងជីវប្រវត្តិនៅក្នុងផ្នែកបឋមដែលផ្នែកនេះបានកត់ត្រានូវអត្តសញ្ញាណរបស់អ្នកជាប់ឃុំឃាំង និងដែលមិនអាចត្រូវបានសន្មត ដោយសមហេតុផលថា បានទទួលព័ត៌មានទាំងនេះ ដោយការធ្វើទារុណកម្មនោះទេ[1137]។ ដើម្បីបង្ហាញចំណងសាច់ញាតិ អង្គជំនុំ

[1136] Niebergall, "ចំណុចខ្សោយនៃភស្តុតាងដែលឈ្នះនៅក្នុងកម្មវិធីស្នើសុំសំណង" ទំព័រ ១៥៦ ដល់ ១៥៨ (យោងលើបទដ្ឋាននៃភាពសមទំនងដែលត្រូវបានចែងនៅក្នុង វិធាន CRT I និង II)។

[1137] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៧៩, ១១២២, ១១២៥ ដល់ ១១២៧, ១១២៩ ដល់ ១១៣២។

ជម្រះសាលាដំបូងបានទទួលយកសំបុត្រកំណើត និងអត្តសញ្ញាណប័ណ្ណ[1138] លិខិតបញ្ជាក់ពីមេឃុំ[1139] ប័ណ្ណបោះឆ្នោត និងទម្រង់បែបបទអ្នកចុះឈ្មោះបោះឆ្នោត[1140] និងរូបថតដែលភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ពីតតិយជន[1141]។ ភាពពេញលេញ និងភាពស៊ីសង្វាក់គ្នានៃការអះអាងបញ្ជាក់របស់អ្នកដាក់ពាក្យសុំ ត្រូវបានយកមកវាយតម្លៃជាមួយនឹងឯកសារ។ ព្យសនកម្មដែលកើតមានចំពោះជនរងគ្រោះមិនផ្ទាល់ ត្រូវបានសន្មតថាមានដោយទំនាក់ទំនងជាមួយនឹងគ្រួសារជិតស្និទ្ធ[1142]។

៥២៧. ដោយផ្អែកទៅលើសេចក្តីបញ្ជាក់ពីខាងលើ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនូវបទដ្ឋាននៃការបង្ហាញភស្តុតាង ដែល“អាចជាការពិត” ចំពោះភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលផ្តល់សំណង។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញនូវភាពបត់បែន និងបានទទួលយកយ៉ាងទូលំទូលាយនូវរាល់ភស្តុតាងជាឯកសារ ដែលអាចគាំទ្រដល់ការទាមទារសំណងដោយផ្ទាល់ ឬដោយប្រយោល ដែលទំនងជាទទួលស្គាល់ការលំបាកជាសត្យានុម័តនៅក្នុងការផ្តល់ឯកសារផ្លូវការ។

៥២៨. ដោយពិចារណាលើទឡ្ហីករណ៍បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងគួរតែបានសម្រេចដោយឈរតែលើមូលដ្ឋាននៃការបញ្ជាក់អះអាងរបស់អ្នកដាក់ពាក្យសុំប៉ុណ្ណោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការលើកឡើងបែបនេះមិនត្រូវបានគាំទ្រដោយការអនុវត្តនៅកម្រិតអន្តរជាតិឡើយ។ នៅពេលពិចារណា ថាតើ អ.វ.ត.ក គប្បីបង្កើតនូវបទដ្ឋានបែបនេះ ដើម្បីធ្វើឲ្យមានតុល្យភាពនៃផលប្រយោជន៍នៅក្នុងកិច្ចដំណើរការនីតិវិធី ដែរ ឬយ៉ាង

[1138]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១១២៥,១១២៧, ១១៣០។

[1139]សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១១២៦, ១១៣០ ដល់ ១១៣២។

[1140]សេចក្តីសម្រេចលើឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ, ឯកសារលេខ E2/36, E2/51 និង E2/69 ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៩, ឯកសារលេខ E2/94/2។

[1141]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១១២៦, ១១២៧។

[1142]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ៦៤៣។

ណានោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា កម្មវិធីទាមទារសំណង ហើយស្ថិតក្នុងកម្រិតជាក់លាក់ យន្តការសិទ្ធិស្ដីពីមនុស្សមានចរិតលក្ខណៈពិសេសមួយចំនួន ដែលអនុញ្ញាតឱ្យអ្នកប្ដឹងទាមទារសំណង អាចបំពេញបានតាមបទដ្ឋាននៃការបង្ហាញភស្តុតាង ដោយពុំចាំបាច់មានតួនាទីសកម្មច្រើននោះទេ។ ចរិតលក្ខណៈពិសេសទាំងនេះ ពុំមាននៅ អ.វ.ត.ក ឡើយ៖

- "លេខាធិការដ្ឋាននៃយន្តការទាមទារសំណងភាគច្រើន បានចូលរួមយ៉ាងសកម្មដោយខ្លួនឯងក្នុងការប្រមូលភស្តុតាង"[1143]។ គណៈកម្មការអន្តរអាមេរិស្ដីពីសិទ្ធិមនុស្ស និងអតីតគណៈកម្មការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស ក៏បានដើរតួនាទីប្រហាក់ប្រហែលគ្នានេះដែរ។

- យ៉ាងហោចណាស់នៅក្នុងកម្មវិធីទាមទារសំណងមួយ "អ្នកប្ដឹងទាមទារសំណងភាគច្រើន (...) ពុំមានមេធាវីតំណាងផ្លូវច្បាប់ឡើយ"[1144]។ ស្រដៀងគ្នានេះដែរ យន្តការស្ដីពីសិទ្ធិមនុស្ស ពុំតម្រូវឱ្យមានមេធាវីតំណាងផ្លូវច្បាប់ដែរ[1145]។

- កម្មវិធី និងយន្តការទាំងនេះជួយសម្រួលដល់បន្ទុកក្នុងការបង្ហាញភស្តុតាងចំពោះអ្នកប្ដឹងទាមទារ បានមួយផ្នែក"ដោយចែងនូវកាតព្វកិច្ចដាក់ទៅលើភាគីដទៃទៀត ដែលបានចូលរួមដោយផ្ទាល់ ឬដោយប្រយោល នៅក្នុងដំណើរការដោះស្រាយបណ្ដឹងទាមទារសំណង ក្នុងការសហការប្រមូលភស្តុតាង"[1146]។

៥២៩. ផ្ទុយទៅនឹងចរិតលក្ខណៈពិសេសទាំងនេះ នៅក្នុងសំណុំរឿង ០០១ នៅ អ.វ.ត.ក៖

- អង្គជំនុំជម្រះសាលាដំបូងពុំមានកាតព្វកិច្ច ឬឆន្ទានុសិទ្ធិក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងការប្រមូលភស្តុតាង ដើម្បីជួយគាំទ្រដល់ពាក្យសុំរបស់ដើមបណ្ដឹង

---

[1143] Niebergall, "ចំណុចខ្សោយនៃភស្តុតាងដែលឈ្នះនៅក្នុងកម្មវិធីស្នើសុំសំណង", ទំព័រ ១៥៣។

[1144] Niebergall, "ចំណុចខ្សោយនៃភស្តុតាងដែលឈ្នះនៅក្នុងកម្មវិធីស្នើសុំសំណង", ទំព័រ ១៥៣, ជើងទំព័រ ២៩ (យោងលើតុលាការដោះស្រាយបណ្ដឹងលើកទីមួយ សម្រាប់រឿងរ៉ាវអសកម្មនៅក្នុង Zurich ប្រទេសស្វីស)។

[1145] *សូមមើល ឧទា.* វិធានតុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១១) វិធាន ៣៦។

[1146] Niebergall "ចំណុចខ្សោយនៃភស្តុតាងដែលឈ្នះនៅក្នុងកម្មវិធីស្នើសុំសំណង", ទំព័រ ១៥១។

00798752



រដ្ឋប្បវេណី ក្រៅពីឆន្ទានុសិទ្ធតាមផ្លូវច្បាប់ តាមគំនិតផ្តួចផ្តើមរបស់ខ្លួនក្នុងការ“កោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មីដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត”[1147] និងស៊ីសង្វាក់គ្នាជាមួយនឹងគោលការណ៍ជាសារវន្តនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង។

- ស្របគ្នាជាមួយកិច្ចដំណើរការនីតិវិធីដែលមានចរិតលក្ខណៈតទល់ ពុំមានការដាក់កាតព្វកិច្ចទៅលើ ឌុច ឬតតិយជនក្នុងការសហការ ឬជួយប្រមូលភស្តុតាងដើម្បីគាំទ្រដល់ការដាក់ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

- រាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានតំណាងដោយមេធាវីជាតិ និងមេធាវីអន្តរជាតិ។ មេធាវីអន្តរជាតិតម្រូវឱ្យមាន“បទពិសោធន៍ការងារចៅក្រម ឬព្រះរាជអាជ្ញា ឬក្នុងមុខងារផ្សេងទៀតយ៉ាងតិច ១០(ដប់)ឆ្នាំ ក្នុងរឿងក្តីព្រហ្មទណ្ឌ” និង“មានសមត្ថភាពខាងផ្នែកនីតិវិធី និងច្បាប់ព្រហ្មទណ្ឌជាតិ ឬអន្តរជាតិ”[1148]។ ដោយឡែកមេធាវីជាតិតម្រូវឱ្យមាន“សមត្ថភាពខាងផ្នែកនីតិវិធី និងច្បាប់ព្រហ្មទណ្ឌជាតិ ឬអន្តរជាតិ”[1149]។

៥៣០. ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពរបស់ជនរងគ្រោះទាំងឡាយនៅក្នុងសំណុំរឿង ០០១ នៅ អ.វ.ត.ក មានលក្ខណៈប្រហាក់ប្រហែលគ្នាទាំងស្រុងទៅនឹងកម្មវិធីទាមទារសំណងទាំងអស់នេះ។ ជាគោលការណ៍ទូទៅ គប្បីកត់សម្គាល់ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនទទួលបន្ទុកក្នុងការបង្ហាញភស្តុតាងពីអំពើល្មើសរបស់ កាំង ហ្កេកអ៊ាវ ឡើយ។ ពាក់ព័ន្ធទៅនឹងធាតុផ្សំដែលនៅសេសសល់សំខាន់សម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣) របស់ អ.វ.ត.ក មាន“អង្គភាពជនរងគ្រោះ” មួយដែលមានអាណត្តិក្នុងការជួយសម្រួលដល់ជនរងគ្រោះ ក្នុងការដាក់ពាក្យសុំតាំង

[1147] វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ។

[1148] វិធាន ១១(៤)(គ)(៣) ដល់ (៤) នៃវិធានផ្ទៃក្នុង។

[1149] វិធាន ១១(៤)(ឃ)(២) នៃវិធានផ្ទៃក្នុង។

ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងជួយសម្របសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះ[1150]។ ទាំងនេះមានន័យថា មុននឹងបញ្ជូនពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង កាតព្វកិច្ចរបស់អង្គភាពជនរងគ្រោះ "ក្នុងការពិនិត្យផ្ទៀងផ្ទាត់លើទម្រង់"[1151]នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានលើសពីការពិនិត្យផ្ទៀងផ្ទាត់លើទម្រង់នេះទៅទៀត ជាឧទាហរណ៍ ការពិនិត្យផ្ទៀងផ្ទាត់ ថាតើព័ត៌មានពាក់ព័ន្ធត្រូវបានបំពេញពេញលេញដែរ ឬយ៉ាងណា។ ផ្នែក (គ) នៃទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ បានចែងថា "សម្រាប់ព័ត៌មានស្តីពីទំនាក់ទំនងរវាងព្យសនកម្មនេះ និងឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតក្រោមកិច្ចស៊ើបសួរ របស់ អ.វ.ត.ក ដែលត្រូវធ្វើការបង្ហាញ*សូមធ្វើការទាក់ទងអង្គភាពជនរងគ្រោះ*"[1152]។ ការណែនាំចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (និងមេធាវីរបស់ពួកគាត់) យ៉ាងហោចណាស់ ក៏សន្មតទុកជាមុនជាអប្បបរមាថា អង្គភាពជនរងគ្រោះខ្លួនឯងផ្ទាល់អាចផ្តល់នូវ"ព័ត៌មានស្តីពីទំនាក់ទំនង (...)" និង/ឬ ថា អង្គភាពជនរងគ្រោះ អាចប្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (និងមេធាវី របស់ពួកគាត់) អំពីប្រភពនានានៃ "ព័ត៌មានស្តីពីទំនាក់ទំនង (...)"។ ទោះបីក្នុងករណីណាក៏ដោយ វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ បានចែងច្បាស់ថា ជំនួយដែលបានផ្តល់ឲ្យដោយអង្គភាពជនរងគ្រោះរបស់ អ.វ.ត.ក ដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងជំនួយដែលបានផ្តល់ឲ្យអ្នកទាមទារជាជនរងគ្រោះ ដោយលេខាធិការដ្ឋានដែលស្ថិតនៅក្នុងកម្មវិធីទាមទារសំណងមួយចំនួនខាងលើ។

---

[1150]វិធាន ១២(២)(ឃ), (ឆ) នៃវិធានផ្ទៃក្នុង ។ *សូមមើលផងដែរ* សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ ជនរងគ្រោះ ០២/២០០៧/ វិសោធនកម្មលើកទី១ (ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨) កថាខណ្ឌ ៣.៤ ("អង្គភាពជនរងគ្រោះត្រូវជួយសម្រួលដល់អ្នកដាក់ពាក្យសុំនៅក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (...)")។

[1151]វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង ។

[1152]សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ឧបសម្ព័ន្ធ ក ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ទំព័រ ៣ (សេចក្តីបញ្ជាក់បន្ថែម)។

៥៣១. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា បទដ្ឋាននៃការបង្ហាញភស្តុតាង ដែលអង្គជំនុំជម្រះសាលាដំបូងបានអនុវត្ត ដែលជា"បទដ្ឋានអាចជាការពិត" ឬដែលជា "ឧត្តមានុភាពនៃភស្តុតាង"នោះ មានលក្ខណៈស្របតាមច្បាប់។ បទដ្ឋាននេះ គឺជាបទដ្ឋានរួម ចំពោះការទាមទារសំណងរដ្ឋប្បវេណីនៅទូទាំងពិភពលោក។ លើសពីនេះទៀត ពុំមានមូល ដ្ឋានណាមួយ ក្នុងការទាមទារឲ្យមានការបន្ធូរបន្ថយនៃការអនុវត្តបទដ្ឋាននេះ ទោះជាក្នុងការ អនុវត្តនៅកម្រិតអន្តរជាតិក្តី ឬដោយសារការព្រួយបារម្ភអំពីតុល្យភាពសមស្របនៃផល ប្រយោជន៍ក៏ដោយ។

៥៣២. ពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងដោះស្រាយសារណារបស់ម្ចាស់បណ្តឹងសាទុក្ខជា ដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើការជូន ដំណឹងឲ្យបានត្រឹមត្រូវដល់ពួកគាត់ អំពីបទដ្ឋាននៃការបង្ហាញភស្តុតាងដែលនឹងត្រូវអនុវត្ត នៅក្នុងដំណាក់កាលទូទាត់សំណង។

៥៣៣. បន្ទាប់ពី អង្គជំនុំជម្រះសាលាដំបូង បានធ្វើការវាយតម្លៃលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណីស្តីពីបទដ្ឋាននៃការបង្ហាញភស្តុតាង*ជាសេចក្តីបញ្ជាក់ដំបូង* មុនពេលចាប់ផ្តើមជំនុំ ជម្រះ ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ បានលើកឡើងថា:

> ដោយមិនបានផ្តល់ការជូនដំណឹងជាមុនដល់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ សាលាដំបូង ក្រោយមក បានយកបទដ្ឋានដ៏មានលក្ខណៈខ្ពស់ជាងមុន និងមិនមានចែង នៅក្នុងច្បាប់យកមកអនុវត្ត ហើយធ្វើការវាយតម្លៃសាជាថ្មីលើពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមរបស់ខ្លួន។ ក្រោយពីបានថ្លឹងថ្លែងរវាងពាក្យ សុំទាំងនេះ ជាមួយនឹងបទដ្ឋាននៃការពិនិត្យឡើងវិញដ៏ថ្មីសន្លាងនេះ ហើយក្រោយពី បានបង្កើនលក្ខខណ្ឌទាមទារឲ្យបង្ហាញភស្តុតាងអំពីអត្តសញ្ញាណបណ្ណ អង្គជំនុំជម្រះ សាលាដំបូងបានសន្និដ្ឋានថា ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០ នាក់ ដែលក្នុងនោះមាន ០៩ នាក់ ជាម្ចាស់បណ្តឹងសាទុក្ខនាពេលនេះមិនបានបំពេញតាម"លក្ខខណ្ឌតម្រូវ" នោះទេ[1153]។

[1153]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១, កថាខណ្ឌ ៦៨។

៥៣៤. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ចៅក្រម Lavergne បានលើកឡើងយ៉ាងច្បាស់លាស់ក្នុងអំឡុងពេលសវនាការបឋមថា ការវាយតម្លៃ*ជាសេចក្តីបញ្ជាក់ដំបូង*លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីខុសគ្នាស្រឡះ ពីការសម្រេចលើអង្គសេចក្តីនៃពាក្យសុំទាំងនេះ[1154]។ ការវាយតម្លៃនេះ គួរតែត្រូវបានជូនដំណឹងដល់មេធាវីដែលមានសមត្ថកិច្ចថា បទដ្ឋាននៃការបង្ហាញភស្តុតាង ដែលតឹងតែងជាងនឹងត្រូវអនុវត្តដើម្បីសម្រេចចុងក្រោយអំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី។ ទោះបីជាយ៉ាងណាក្តី ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់រួចហើយ នៅក្នុងពេលពិចារណាអំពីភាពស្របច្បាប់នៃបទដ្ឋាននៃការពិនិត្យឡើងវិញជាពីរដំណាក់កាលរបស់អង្គជំនុំជម្រះសាលាដំបូង ដើមបណ្តឹងរដ្ឋប្បវេណីមានការភាន់ច្រឡំដែលបង្កឡើងដោយសារការផ្តល់ព័ត៌មានជាច្រើនដង ពាក់ព័ន្ធទៅនឹងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ដែលថា អង្គជំនុំជម្រះសាលាដំបូងមិនបានជូនដំណឹងឱ្យបានច្បាស់លាស់អំពីបទដ្ឋាននៃការបង្ហាញភស្តុតាងជាក់លាក់ ដែលខ្លួននឹងអនុវត្តនៅដំណាក់កាលទូទាត់សំណង ដល់ដើមបណ្តឹងរដ្ឋប្បវេណីមុនពេលចេញសាលក្រមឡើយ។ មិនមានលក្ខណៈគ្រប់គ្រាន់ឡើយដែលអង្គជំនុំជម្រះសាលាដំបូងគ្រាន់តែលើកឡើង នៅក្នុងជើងទំព័រនៃសាលក្រម ដែលថា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៥) "បានគូសបញ្ជាក់"អំពីបទដ្ឋាននៃការបង្ហាញភស្តុតាងនោះ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានទទួលស្គាល់ផងដែរថា បន្ទាប់ពីសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងបានបង្កឱ្យមានភាពមិនច្បាស់លាស់អំពី ថាតើបទដ្ឋាននៃការបង្ហាញភស្តុតាងច្បាស់លាស់ណាមួយ ដែលខ្លួននឹងយកមកអនុវត្តនៅដំណាក់កាលទូទាត់សំណងនោះ ហើយភាពមិនច្បាស់លាស់ទាំងនោះបានបង្កឱ្យមានការភ័ន្តច្រឡំ និងខកចិត្តយ៉ាងខ្លាំងដល់ដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពីពិនិត្យលើសាលក្រមឡើងវិញ[1155]។ ទោះ

[1154] ប្រតិចារិក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩, ឯកសារ E1/1.1, ទំព័រ ៦៤ (បន្ទាត់ ៣) ដល់ ទំព័រ ៦៥ (បន្ទាត់ ១)។ ប្រតិចារិក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារ E1/3.1 ទំព័រ ៣៤ (បន្ទាត់ ៣ ដល់ ៨) និងទំព័រ ៣៦ (បន្ទាត់ ២៤) ដល់ទំព័រ ៣៧ (បន្ទាត់ ៧)។

[1155] *សូមមើលទូទៅព្រឹត្តប័ត្ររបស់* Pham, Phuong *និងអ្នកនិពន្ធដទៃទៀត, ការចូលរួមរបស់ជនរងគ្រោះ និងសវនាការសំណុំរឿង ឌុច នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ទំព័រ ២៦៤ ដល់ ២៨៧។ ព្រឹត្តប័ត្រនិពន្ធដោយ Eric Stover

បើជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូល ក៏បានយល់ឃើញផងដែរថា ព្យសនកម្មដែលទទួលរងដោយម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានស្តារឡើងវិញ ដោយពួកគាត់មានឱកាសនៅដំណាក់កាលបណ្តឹងសាទុក្ខ ក្នុងការដាក់ភស្តុតាងបន្ថែមដើម្បីធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ខ្លួនពិតជាដើមបណ្តឹងរដ្ឋប្បវេណីស្របតាមវិធានផ្ទៃក្នុងប្រាកដមែន។ ពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាលក្ខណៈបុគ្គលដូចខាងក្រោម។

## ៦.ឃ.ការទទួលយកពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី

៥៣៥. អង្គជំនុំជម្រះសាលាដំបូង បានបដិសេធពាក្យសុំរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ២២ នាក់[1156] ដោយបានយល់ឃើញថា អ្នកដាក់ពាក្យសុំទាំងនេះ ខកខានពុំបានបង្ហាញអំពីការទទួលរងព្យសនកម្ម ដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ត្រូវបានសម្រេចដាក់ពិរុទ្ធភាព។ ការយល់ឃើញនេះ បានផ្អែកទៅលើសំអាងហេតុមួយ ឬច្រើនក្នុងចំណោមសំអាងហេតុ ខាងក្រោម៖

១. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គហេតុមិនបានបង្ហាញតាមបទដ្ឋានតម្រូវដែលថា ដើមបណ្តឹងរដ្ឋប្បវេណី គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តឡើងដោយ កាំង ហ្គេកអ៊ាវ នៅមន្ទីរ ស ២១ ឬមន្ទីរ ស ២៤[1157]។

---

*និងអ្នកនិពន្ធ ដទៃទៀត*, "ប្រឈមនឹងរឿងក្តី ឌុចៈ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ នៅអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា" ទំព័រ ៣៨ ដល់ ៤៤។

[1156]មានម្ចាស់បណ្តឹងសាទុក្ខសរុបចំនួន ៤១ នាក់។ ៩ នាក់ បានធ្វើបណ្តឹងសាទុក្ខស្តីពីឋានៈ និង ១៩ នាក់ទៀតប្តឹងអំពីសំណង។ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ ស៊ីរ៉ាត (D25/6) ធ្វើបណ្តឹងសាទុក្ខនៅនឹងការខកខានដាក់ឈ្មោះបងថ្លៃស្រីរបស់គាត់ និងកូន នៅក្នុងសាលក្រម។ ហើយចំនួន ១៣ នាក់ទៀត ប្តឹងលើឋានៈ និងសំណង។ ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន ហ្វិត (E2/37) មិនបានប្តឹងសាទុក្ខនៅនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម, កថាខណ្ឌ ២២៨។

[1157]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៧។

00798757



២. ដើមបណ្តឹងរដ្ឋប្បវេណីដែលអះអាងថា ជាជនរងគ្រោះដោយសារតែការបាត់បង់សាច់ញាតិជិតស្និទ្ធនៅមន្ទីរ ស ២១ និងមន្ទីរ ស ២៤ មិនមានលទ្ធភាពបង្ហាញនូវអត្តិភាពនៃជនរងគ្រោះថាជាសាច់ញាតិជិតស្និទ្ធតាមបទដ្ឋានតម្រូវនោះឡើយ[1158]។

៣. ដើមបណ្តឹងរដ្ឋប្បវេណីដែលអះអាងថា ជាជនរងគ្រោះដោយសារតែការបាត់បង់សាច់ញាតិជិតស្និទ្ធ នៅមន្ទីរ ស ២១ និងមន្ទីរ ស ២៤ មិនបានផ្តល់ភស្តុតាងអំពីភាពជាសាច់ញាតិ ឬចំណងពិសេសនៃក្តីស្រលាញ់ ឬការនៅក្នុងបន្ទុករបស់ជនរងគ្រោះផ្ទាល់នៃមន្ទីរ ស ២១ ឬ ស ២៤ ទេ[1159]។

៥៣៦. អង្គជំនុំជម្រះតុលាការកំពូល វាយតម្លៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីខាងក្រោម ដោយផ្អែកតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ ដែលអាចយកមកអនុវត្តបាននៅអង្គជំនុំជម្រះនេះ។ ហេតុដូច្នេះ ផ្អែកតាមបញ្ហាអង្គហេតុ អង្គជំនុំជម្រះតុលាការកំពូលមានភារកិច្ចក្នុងការកំណត់ ថាតើការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងអំពីបទដ្ឋានក្នុងការបង្ហាញភស្តុតាង ដែល"ទំនងជាមានភាពពិតប្រាកដ" ពិតជាពុំមានលក្ខណៈសមហេតុផលដែរ ឬយ៉ាងណា។ នៅក្នុងការវាយតម្លៃរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថាតើសេចក្តីបញ្ជាក់របស់ម្ចាស់បណ្តឹងសាទុក្ខបង្ហាញពីកម្រិតដែលមានលក្ខណៈពិសេស និងយថាភូត ដើម្បីអាចឱ្យអង្គជំនុំជម្រះតុលាការកំពូលជឿជាក់បាននៅក្នុងកាលៈទេសៈនៃរឿងក្តីនេះ ដែរ ឬយ៉ាងណា។ ដោយសារតែកង្វះខាតនៃផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុសម្រាប់ឱ្យជនរងគ្រោះ ធ្វើការទាមទារសំណងជាលក្ខណៈបុគ្គលបាននោះ អង្គជំនុំជម្រះតុលាការកំពូលមានការជឿជាក់ខ្ពស់ទៅលើសេចក្តីបញ្ជាក់របស់ជនរងគ្រោះ ដរាបណាសេចក្តីបញ្ជាក់ទាំងនេះមានភាពស៊ីសង្វាក់គ្នា និងពេញលេញ។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពអាចជឿជាក់បាន ដោយហេតុថា នៅក្នុងពេលសវនាការ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ភាគីដោយផ្ទាល់។ បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលបានវាយតម្លៃលើសេចក្តីបញ្ជាក់របស់ម្ចាស់បណ្តឹងសាទុក្ខ

[1158]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។

[1159]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៩។

ដោយបានប្រៀបធៀបជាមួយនឹង ឯកសារផ្លូវការ ឬឯកជន (ក្រៅផ្លូវការ)[1160] ដែលមាននៅក្នុងសំណុំរឿង ព្រមទាំងឯកសារទាំងឡាយ ដែលភាគីនានាបានដាក់នៅក្នុងសវនាការបណ្តឹងសាទុក្ខ។

**៦.ឃ.១.ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ (E2/61, E2/62, E2/69, E2/73, E2/74, E2/75, E2/86, E2/88, D25/15)**

***ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ លី ហ៊ី ហៅ អ៊ា ហ៊ីវ* (E2/61)**

៥៣៧. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គាត់ត្រូវបានឃុំខ្លួន និងធ្វើទារុណកម្មនៅមន្ទីរ ស ២១ ហើយក្រោយមកត្រូវបានគេផ្ទេរទៅមន្ទីរ ស ២៤ ដែលជាទីកន្លែងដែលគាត់បានរត់គេចខ្លួន។ ជាលទ្ធផលនៃព្រឹត្តិការណ៍ទាំងនេះ គាត់បានអះអាងថា បានទទួលរងនូវព្យសនកម្មជាអចិន្ត្រៃយ៍លើដៃឆ្វេង និងកជើងទាំងពីររបស់គាត់[1161]។

៥៣៨. អង្គជំនុំជម្រះសាលាដំបូងបានបដិសេធម្ចាស់បណ្តឹងសាទុក្ខ ដែលជាជនរងគ្រោះ ដោយសំអាងហេតុដូចខាងក្រោមនេះ៖

> លី ហ៊ី (E2/61) បានអះអាងថា ដំបូងគាត់ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១ (ទួលស្លែង) និងក្រោយមកគាត់ត្រូវបានគេបញ្ជូនទៅ ស ២៤ ដែលជាកន្លែងដែលគាត់បានរត់គេចខ្លួន។ ទោះបីជាមានអ្នកជាប់ឃុំមួយរូបឈ្មោះ អ៊ា ហ៊ីវ នៅមន្ទីរ ស ២១ ដោយយោងតាមឯកសារ និងការរៀបរាប់ ក៏វានៅតែមានចម្ងល់ ថាតើអ្នកជាប់ឃុំរូបនេះ គឺជាដើមបណ្តឹងរដ្ឋប្បវេណី ដែរ ឬយ៉ាងណា[1162]។ បន្ថែមពីលើនេះ នៅក្នុងបណ្ណសារមន្ទីរ ស

[1160]មាត្រា ១៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៦។

[1161]របាយការណ៍នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/61/1។

[1162]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៧, ជើងទំព័រ ១០៨១ ("អង្គជំនុំជម្រះមិនច្បាស់ទេថា លី ហ៊ី ត្រូវបានស្គាល់ថាជា អ៊ា ហ៊ីវ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ *ប្រៀបធៀប* "ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ - សំណើសុំបញ្ចូលស្ថានភាពរបស់លោក លី ហ៊ី *[លី ហ៊ី]* ជាអ្នកនៅរស់រានមានជីវិតពីមន្ទីរ ស ២១ និងយថាភាពនៃ ឯកសារនានាជាផ្នែកនៃកំណត់ហេតុ", ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៩, ឯកសារលេខ E137")។

២១ មិនបានបង្ហាញអំពីការបញ្ជូនអ្នកជាប់ឃុំរូបនេះពីមន្ទីរ ស ២១ ទៅ ស ២៤ ឡើយ ហើយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនបានរៀបរាប់អំពីការដឹកជញ្ជូនដែលខ្លួនបានអះអាងនោះទេ ដែលវាផ្ទុយទៅនឹងប្រតិបត្តិការរបស់មន្ទីរ ស ២១[1163]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ហ៊ា មិនបានបង្ហាញតាមបទដ្ឋានតម្រូវនោះទេ[1164]។

៥៣៩. ដោយសារតែបញ្ហាអំពីសច្ចៈភាពនៃការអះអាងរបស់គាត់ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់*សំណើសុំបញ្ចូលស្ថានភាពរបស់លោក លី ហ៊ា ជាអ្នកនៅរស់រានមានជីវិតពីមន្ទីរ ស ២១ និងយថាភាពនៃឯកសារនានាជាផ្នែកនៃកំណត់ហេតុ* នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០០៩។ ឯកសារ ភ្ជាប់ជាមួយនឹងសំណើនោះ គឺមានសេចក្តីប្រកាសរបស់លោក គេ សុបណ្ណការ ដែលជាប្រធានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដោយបានបញ្ជាក់ថា គាត់បានរកឃើញច្បាប់ដើមនៃឯកសារ ដែលបានដាក់ដើម្បីគាំទ្រដល់ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីឱ្យទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិភាក្សាសម្រេចលើភស្តុតាងបន្ថែមដែលបានដាក់ជូនឡើយ[1165]។

៥៤០. អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់យល់ដឹងឱ្យបានប្រាកដថា "លី ហ៊ា ត្រូវបានស្គាល់ថា ជា អ៊ា ហ៊ីរ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ"[1166] នោះទេ។ អ្វីដែលសំខាន់នោះគឺថា អ្នកដាក់

---

[1163]សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៨, ជើងទំព័រ ១០៩២ ៖ "ទោះបីជាមានចំណារជាលាយលក្ខណ៍អក្សរលើជីវប្រវត្តិនៃអ្នកជាប់ឃុំឈ្មោះ អ៊ា ហ៊ីរ បង្ហាញថា គាត់ត្រូវគេ "ដោះលែងនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦" ("ជីវប្រវត្តិរបស់ អ៊ា ហ៊ីរ" E2/61.2 ERN 00368571) កាំង ហ្គេកអ៊ាវ និងសាក្សីជាច្រើន ដែលរួមបញ្ចូលទាំងអតីតសមាជិកមន្ទីរ ស ២១ បានផ្តល់សក្ខីកម្មថា លើកលែងតែករណីមួយចំនួនតិចតួចដែលមិនមានពាក់ព័ន្ធនឹងអ្នកទោសធម្មតា អ្នកជាប់ឃុំមន្ទីរ ស ២១ទាំងអស់ត្រូវបានសម្លាប់ចោល (*សូមមើល ឧទា.* ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩ (ស្ទួស ធី) ឯកសារលេខ E1/54.1, ទំព័រ ៨៧ ដល់៨៨)។

[1164]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៧, ទំព័រ ២២៤ ដល់ ២២៥។

[1165]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, កថាខណ្ឌ ៦១។

[1166]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៩១។

ពាក្យសុំដែលនៅពេលបច្ចុប្បន្នប្រើឈ្មោះ លី ហ៊ា ជាបុគ្គលតែមួយដែលជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ជាឈ្មោះ អ៊ា ហ៊ីរ។ នៅពេលសវនាការលើបណ្តឹងសាទុក្ខ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ភស្តុតាងបន្ថែមដែលបង្ហាញថា ឈ្មោះឪពុកម្តាយរបស់គាត់ត្រូវគ្នាជាមួយនឹងឈ្មោះឪពុកម្តាយរបស់ អ៊ា ហ៊ីរ[1167] និងបានផ្តល់នូវស្នាមមេដៃរបស់គាត់ដែលត្រូវគ្នាជាមួយនឹងស្នាមមេដៃនៅលើចម្លើយសារភាពរបស់គាត់ នៅមន្ទីរ ស ២១[1168]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់អត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំថាជាជនរងគ្រោះនៅមន្ទីរ ស ២១ និង ស ២៤ ហើយសម្រេចបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងទទួលយកពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហ៊ឹម មុំ* **(E2/62)**

៥៤១. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ក្នុងឆ្នាំ ១៩៧៧ បងប្រុសពីរនាក់របស់គាត់ត្រូវបានចាប់ខ្លួននៅខេត្តតាកែវ ដោយឈ្លបខ្មែរក្រហមចំនួនបួននាក់។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវបានចាប់ខ្លួនផងដែរក្នុងឆ្នាំ ១៩៧៨ ប៉ុន្តែគាត់បានរត់គេចខ្លួន។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គាត់បានឃើញរូបថតបងប្រុសពីរនាក់របស់គាត់នៅសារមន្ទីរទួលស្លែង។ ដោយសារតែលទ្ធផលនៃព្រឹត្តិការណ៍ទាំងនេះ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី បានទទួលរងនូវព្យសនកម្មខាងផ្លូវចិត្ត[1169]។

៥៤២. អង្គជំនុំជម្រះសាលាដំបូងបានយកសំអាងហេតុទីពីរ និងទីបីរបស់ខ្លួនមកអនុវត្ត ដើម្បីបដិសេធឋានៈរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី៖

---

[1167]លិខិតបញ្ជាក់របស់អនុសេនីយទោ អោម សុផៃ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/6.1។

[1168]សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ សុំដាក់ភស្តុតាងបន្ថែម ដើម្បីគាំទ្របណ្តឹងសាទុក្ខប្រឆាំង នឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/3, កថាខណ្ឌ ៧។ ឯកសារភ្ជាប់លេខ F2/3.2.3, ERN 00651493 (ស្នាមផ្តិតមេដៃពេលបច្ចុប្បន្ន); ឧបសម្ព័ន្ធ, ឯកសារលេខ E2/61.2, ERN 00279930 (ស្នាមផ្តិតមេដៃនៅមន្ទីរ ស ២១)។

[1169]របាយការណ៍ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/62/1។

ដើមបណ្តឹងរដ្ឋប្បវេណី E2/62 អះអាងថា បងប្រុសរបស់គាត់[1170]ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរ ស ២១។ ក្នុងការគាំទ្រចំពោះអំណះអំណាងនេះ គាត់បានបង្ហាញរូបថតដែលយកមកពីបណ្ណសាររបស់សារមន្ទីរទួលស្លែង។ ប៉ុន្តែរូបថតនេះមិនអាចកំណត់អត្តសញ្ញាណបានទេ ដូច្នេះមិនអាចកំណត់បានថា រូបថតនោះជារូបនរណានោះទេ។ ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលស្គាល់ហើយថា មិនមានឯកសារបង្ហាញអំពីទំនាក់ទំនងសាច់ញាតិជាមួយជនរងគ្រោះនៃមន្ទីរ ស២១ នោះទេ[1171]។

៥៤៣. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី បានដាក់លិខិតបញ្ជាក់របស់សាក្សីពីរបន្ថែមទៀត៖ លិខិតបញ្ជាក់មួយមកពីបងស្រីរបស់ម្ចាស់បណ្តឹងសាទុក្ខដែលបានកំណត់អត្តសញ្ញាណបុគ្គលនៅក្នុងរូបថតនោះថា ជាបងប្រុសរបស់ម្ចាស់បណ្តឹងសាទុក្ខ[1172] និងលិខិតបញ្ជាក់មួយទៀតមកពីប្រធានភូមិម្នាក់ដែលបញ្ជាក់អះអាងអំពីអត្តសញ្ញាណនៃបុគ្គលក្នុងរូបថតនោះ[1173]។

៥៤៤. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា លិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរ ពុំមានលក្ខណៈសម្បត្តិជាសក្ខីកម្មរបស់សាក្សីឡើយ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលអាចទទួលយកលិខិតបញ្ជាក់ទាំងនេះក្នុងនាមជាឯកសារក្រៅផ្លូវការ។ យថាភាពនៃឯកសារទាំងនេះមិនត្រូវបានជំទាស់តវ៉ាឡើយ។ ឯកសារទាំងនេះគាំទ្រយ៉ាងគ្រប់គ្រាន់ទៅលើសេចក្តីបញ្ជាក់របស់ភាគីដែលទទួលរងព្យសនកម្ម។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មានមូល

---

[1170]ជាក់ស្តែង ម្ចាស់បណ្តឹងសាទុក្ខ បានអះអាងថា បងប្រុសពីរនាក់របស់គាត់ត្រូវបានជាប់ឃុំឃាំងនៅមន្ទីរ ស ២១។ ឧបសម្ព័ន្ធ ១៖ លិខិតបញ្ជាក់, ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/62.1, ERN 00279966-00279968។ ឧបសម្ព័ន្ធ ២៖ ព័ត៌មានបន្ថែម ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/62.2, ERN 00279969។ ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខ ដាក់រូបថតតែមួយសន្លឹករបស់បងប្រុសខ្លួនទៅអង្គជំនុំជម្រះសាលាដំបូង។ ប្រតិចារិកថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារលេខ E1/78.1, ទំព័រ ២០។ រូបថតនៅមន្ទីរ ស ២១, ឯកសារលេខ E165/1/1.2។ ឧបសម្ព័ន្ធ ៤៖ រូបថតនៅមន្ទីរ ស ២១, ឯកសារលេខ E2/62.4។

[1171]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។

[1172]លិខិតបញ្ជាក់របស់ សាំង ណោង ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/3.2.1។

[1173]លិខិតបញ្ជាក់របស់ គង់ ងឿន ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ F2/3.2.2។ *សូមមើលផងដែរ* លិខិតបញ្ជាក់របស់អនុប្រធានការិយាល័យបណ្ណសារ ទួលស្លែង ចុះថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០០៩, ឯកសារលេខ E165/1/1.3។

ដ្ឋានក្នុងការបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងក្នុងការទទួលយកពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

***ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ លឹម យ៉ុន* (E2/69)**

៥៤៥. ម្ចាស់បណ្តឹងសាទុក្ខដើមជាបណ្តឹងរដ្ឋប្បវេណីអះអាងថា ក្នុងខណៈដែលគាត់ត្រូវបានឃុំឃាំងធ្វើទារុណកម្ម និងសួរចម្លើយនៅទីកន្លែងមួយខាងក្រៅមន្ទីរ ស ២១[1174] ប្រធានមន្ទីរសន្តិសុខបានប្រាប់គាត់ថា បងប្រុសរបស់គាត់ជាប់គុកនៅមន្ទីរ ស ២១។

៥៤៦. អង្គជំនុំជម្រះសាលាដំបូងបានយកសំអាងហេតុទីពីររបស់ខ្លួនមកអនុវត្តដើម្បីបដិសេធឋានៈ៖

> លឹម យ៉ុន (E2/69) បានអះអាងថា បងប្រុសរបស់គាត់ម្នាក់ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១ ជាការបន្ថែមលើអំណះអំណាងនៃការចាប់ខ្លួន និងការសម្លាប់សាច់ញាតិមួយចំនួនរបស់គាត់នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ទោះបីជាយ៉ាងណាក៏ដោយមិនមានភស្តុតាងគាំទ្រចំពោះអំណះអំណាងនេះទេ[1175]។

៥៤៧. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី ពុំបានផ្តល់ភស្តុតាងបន្ថែមជូនអង្គជំនុំជម្រះតុលាការកំពូល ឡើយ។ ឈ្មោះបងប្រុសរបស់ម្ចាស់បណ្តឹងសាទុក្ខ មិនឃើញមាននៅក្នុងបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ឡើយ។ ដោយពុំមានមន្ទិលទៅលើសច្ចភាពជាអត្តនោម័តនៅលើផ្នែកនៃដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថាសេចក្តីបញ្ជាក់របស់ភាគីផ្អែកទៅលើពាក្យចចាមអារ៉ាមចេញពីប្រភពមួយ ដែលធ្វើឱ្យមានភាពមន្ទិលសង្ស័យយ៉ាងខ្លាំង[1176]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាពុំមានមូល

---

[1174]លិខិតបញ្ជាក់របស់ លឹម យ៉ុន ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ E2/69.1 (“គ្រួសាររបស់ខ្ញុំជាប់គុកវត្តបារាយណ៍សណ្តែក នៅភូមិកំពង់ថ្ម ឃុំបល្ល័ង្ក រយៈពេល ១០ថ្ងៃ”)។

[1175]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។

[1176]ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ (សម្ងាត់), ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E2/69, ឧបសម្ព័ន្ធ ១, ឯកសារលេខ E2/69.1, ERN 00364915 (“ពេលដែលកំពុងធ្វើទារុណកម្ម ប្រធានសន្តិសុខ សែន ប្រាប់ខ្ញុំថា៖ បងប្រុសខ្ញុំឈ្មោះ ម៉ា យិទ្ធ កាលនោះ អាយុ ៣៥ ឆ្នាំ បានជាប់គុកនៅទួលស្លែង‘ចុះហេតុអ្វីហងឯង ថាមិនដឹង បងឯងក្បត់ ត្រូវគេ

00798763



ដ្ឋានណាមួយឡើយ ក្នុងការបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ម្ចាស់បណ្តឹងសាទុក្ខនេះពុំបានបង្ហាញឋានៈជាជនរងគ្រោះ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលជាប់ទាក់ទិនជាមួយនឹង កាំង ហ្កេកអ៊ាវ ។

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ នង សាវ៉ាត (E2/73) ហៅ ពណ៌*

៥៥៨. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា បងជីដូនមួយ និងពូរបស់គាត់ត្រូវបានឃុំខ្លួន និងសម្លាប់នៅទួលស្លែង។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ជាលទ្ធផលនៃព្រឹត្តការណ៍ទាំងនេះ គាត់បានទទួលរងព្យសនកម្មខាងផ្លូវចិត្ត។

៥៥៩. អង្គជំនុំជម្រះសាលាដំបូងបានយកសំអាងហេតុទីពីរ និងទីបីរបស់ខ្លួនមកអនុវត្ត ដើម្បីបដិសេធឋានៈរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ៖

> នង សាវ៉ាត ហៅ ពណ៌ (E2/73) បានអះអាងថា បងជីដូនមួយរបស់គាត់ឈ្មោះ នង សារួត និងពូរបស់គាត់ឈ្មោះ នង សង ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរ ស ២១។ ប៉ុន្តែអ្នកដាក់ពាក្យសុំមិនបានផ្តល់ភស្តុតាងជាឯកសារទាក់ទងនឹងការឃុំខ្លួន ឬបញ្ជាក់អំពីភាពជាសាច់ញាតិនោះទេ (...) [1177]។

៥៥០. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់លិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរបន្ថែមចំនួនពីរដល់អង្គជំនុំជម្រះតុលាការកំពូល[1178]។ លិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរទីមួយ ដែលមកពីម្តាយមីងរបស់ម្ចាស់បណ្តឹងសាទុក្ខ បង្ហាញអំពីភាពជាសាច់ញាតិរវាងម្ចាស់បណ្តឹងសាទុក្ខ និងពូរបស់ខ្លួន ប៉ុន្តែ លិខិតបញ្ជាក់នេះមិនបានបញ្ជាក់ថា ពូរបស់ខ្លួនត្រូវបាន

---

ចាប់ទៅដាក់ក្នុងទួលស្លែង ព្រោះធ្វើការជាអ្នកក្តោបក្តាប់ខាងទន្លេសាប។ ចំណែកហាងឯង ក៏ចាប់គុកដោយលួចបញ្ចេញស្បៀងឱ្យខ្មាំង')។

[1177]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។

[1178]សេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ នង និត ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/5.2.1។ សេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ ស សារ៉េន ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/5.2.2។

00798764



ជាប់ឃុំនៅមន្ទីរ ស ២១ ឡើយ។ ម្តាយមីងរបស់ម្ចាស់បណ្តឹងសាទុក្ខបញ្ជាក់ថា សហការីរបស់ម្ចាស់បណ្តឹងសាទុក្ខបានប្រាប់គាត់ថា ពូរបស់ម្ចាស់បណ្តឹងសាទុក្ខត្រូវបានចាប់ខ្លួន ប៉ុន្តែបន្ទាប់មកម្តាយមីងរូបនេះក៏បញ្ជាក់ថា "ខ្ញុំមិនដឹងថានរណាជាអ្នកចាប់ខ្លួនគាត់ [ពូរូបនេះ]ទេ ហើយគ្រួសាររបស់គាត់ ហើយខ្ញុំពុំបានដឹងថា គេយកពួកគាត់ទៅណាដែរ"[1179]។ ស្រដៀងគ្នានេះដែរ លិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរទីពីរ ដែលមកពីបងជីដូនមួយរបស់ម្ចាស់បណ្តឹងសាទុក្ខ បញ្ជាក់ថា ៖

> នៅពេលគេយក នង សង និង នង សារួត ទៅ ខ្ញុំមិនដឹងថា គេយកពួកគាត់ទៅណាទេ។ ប៉ុន្តែ ដោយសារពួកគាត់មានតំណែងធំ កាលពីសម័យខ្មែរក្រហម ខ្ញុំគិតថាគាត់ប្រហែលជាត្រូវគេយកទៅទួលស្លែង[1180]។

៥៥១. ទោះបីជា អង្គជំនុំជម្រះតុលាការកំពូលពុំមានហេតុផលក្នុងការដាក់ការមន្ទិលទៅលើភាពស្មោះត្រង់របស់បុគ្គលដែលបានបញ្ចេញនូវសេចក្តីអះអាងទាំងនេះ ជាពិសេសបងជីដូនមួយរបស់ម្ចាស់បណ្តឹងសាទុក្ខដែលបានពង្រាងលិខិតបញ្ជាក់ទីពីរនេះ យ៉ាងណាក៏ដោយ ក៏មានការច្បាស់ណាស់ថា បងជីដូនមួយរបស់ម្ចាស់បណ្តឹងសាទុក្ខមិនបានដឹងដោយខ្លួនឯងផ្ទាល់អំពី ថាតើ នង សង និង នង សារួត ត្រូវបានជាប់ឃុំនៅមន្ទីរ ស ២១ ដែរ ឬយ៉ាងណា នោះឡើយ។ លើសពីនេះទៀត ឈ្មោះរបស់ជនរងគ្រោះដែលបានលើកឡើងមាន នង សង និង នង សារួត មិនឃើញមាននៅក្នុងបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ឡើយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានណាមួយឡើយក្នុងការបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ម្ចាស់បណ្តឹងសាទុក្ខនេះពុំបានបង្ហាញឋានៈជាជនរងគ្រោះពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលជាប់ទាក់ទិនជាមួយនឹង កាំង ហ្គេកអ៊ាវ។

---

[1179] សេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ នង និត។

[1180] "សេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ ស សារ៉េន។

00798765



*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ង៉ែត អ៊ុយ* **(E2/74)**

៥៥២. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ប្តីរបស់គាត់ឈ្មោះ ប្រាក់ ប៉ាត ត្រូវបានឃុំខ្លួនធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរ ស ២១។

៥៥៣. អង្គជំនុំជម្រះសាលាដំបូងបានយកសំអាងហេតុទីពីរ និងទីបីរបស់ខ្លួនមកអនុវត្តដើម្បីបដិសេធឋានៈរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ៖

> ង៉ែត អ៊ុយ (E2/74) បានអះអាងថា ប្តីរបស់គាត់ឈ្មោះ ប្រាក់ ប៉ាត ដែលជាអតីតកម្មាភិបាលកងទ័ពខ្មែរក្រហមត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរ ស ២១។ ដើម្បីគាំទ្រអំណះអំណាងនេះ គាត់បានយោងលើសក្ខីកម្មរបស់ក្មួយខាងប្តីគាត់ ដែលធ្លាប់ធ្វើការនៅមន្ទីរ ស ២១[1181]។ ទោះបីជាយ៉ាងណាក៏ដោយ អត្តសញ្ញាណជាក់លាក់នៃសាក្សីសំខាន់នេះមិនត្រូវបានបង្ហាញនោះទេ។ បន្ថែមពីលើនេះ មិនមានការបញ្ជាក់ ឬឯកសារគាំទ្រចំពោះអំណះអំណាងនេះ ឬចំណងសហព័ទ្ធនោះទេ[1182]។

៥៥៤. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី ពុំបានផ្តល់នូវភស្តុតាងណាមួយនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលឡើយ។ ឈ្មោះប្តីរបស់ម្ចាស់បណ្តឹងសាទុក្ខដែលបានអះអាងនោះមិនឃើញមាននៅក្នុងបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានណាមួយឡើយក្នុងការបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ម្ចាស់បណ្តឹងសាទុក្ខនេះពុំបានបង្ហាញឋានៈជាជនរងគ្រោះនៅក្នុងរឿងក្តីនេះឡើយ។

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឃៀវ នាប ហៅ ខៀវ នាប* **(E2/75)**

៥៥៥. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ប្តីរបស់គាត់ត្រូវបានជាប់ឃុំឃាំង និងសម្លាប់នៅមន្ទីរ ស ២១។

---

[1181] "លិខិតបញ្ជាក់របស់ ង៉ែត អ៊ុយ", ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩, ឯកសារលេខ E2/74.1។

[1182] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។

៥៥៦. អង្គជំនុំជម្រះសាលាដំបូងបានយកសំអាងហេតុទីពីរ និងទីបីរបស់ខ្លួនមកអនុវត្តដើម្បីបដិសេធឋានៈរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ៖

> ផៀវ នាប *ហៅ* ខៀវ នាប (E2/75) បានអះអាងថា ប្តីរបស់គាត់ឈ្មោះ ហេង ជឿន ហៅ ជឿន ត្រូវបានចាប់ខ្លួននៅចុងឆ្នាំ១៩៧៨ ខណៈពេលដែលប្តីរបស់គាត់ គឺជាកម្មាភិបាលនៅមន្ទីរ ៨៧០ និងត្រូវបានបញ្ជូនទៅព្រៃស ( ស ២៤ )។ គាត់បានអះអាងថា បានឃើញការចាប់ខ្លួនប្តីគាត់ និងអះអាងបន្ថែមថា យោធាមួយរូបឈ្មោះ វ៉េត បានប្រាប់គាត់អំពីមរណភាពរបស់ប្តីគាត់នៅ ស ២៤ ។ ទោះបីជាយ៉ាងណាក៏ដោយ អត្តសញ្ញាណពិតប្រាកដនៃសាក្សីនេះមិនត្រូវបានគេស្គាល់នោះទេ និងមិនមានការបញ្ជាក់ ឬឯកសារណាមួយគាំទ្រចំពោះអំណះអំណាងរបស់គាត់ទេ។ លើសពីនេះមិនមានភស្តុតាងបង្ហាញអំពីភាពជាសាច់ញាតិឡើយ[1183]។

៥៥៧. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី ពុំបានផ្តល់ភស្តុតាងបន្ថែមណាមួយដល់អង្គជំនុំជម្រះតុលាការកំពូលឡើយ។ ពាក្យចចាមអារ៉ាមពីប្រភពមួយ ដែលមិនបានកំណត់អត្តសញ្ញាណច្បាស់លាស់នោះ[1184] មិនគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការលើកឡើងទាំងនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានណាមួយក្នុងការបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ម្ចាស់បណ្តឹងសាទុក្ខនេះ ពុំបានបង្ហាញឋានៈជាជនរងគ្រោះនៅក្នុងរឿងក្តីនេះឡើយ។

---

[1183]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។

[1184]ទម្រង់បែបបទអំពីព័ត៌មានជនរងគ្រោះ, ភាសាខ្មែរដាក់នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារបកប្រែភាសាអង់គ្លេសបានដាក់នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៩, លេខឯកសារ E2/75, ឧបសម្ព័ន្ធ ១, ព័ត៌មានទាក់ទងទៅនឹងឧក្រិដ្ឋដែលត្រូវបានចោទប្រកាន, ឯកសារលេខ E2/75.1, ERN 00365580 ("រហូតដល់ឆ្នាំ ១៩៨១ នៅពេលដែលខ្ញុំបានទៅរកស្រូវនៅខេត្តសៀមរាប ខ្ញុំបានជួបជាមួយ វ៉េត ជាអតីតយោធាខ្មែរក្រហម ដែលធ្វើការជាមួយប្តីរបស់ខ្ញុំ ហើយដែលក្រោយមកត្រូវបានអង្គការផ្លាស់ប្តូរចេញពីយោធា។ វ៉េត និយាយប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំបានស្លាប់ហើយ ព្រោះអង្គការបានបញ្ជូនគាត់ទៅកាន់គុកព្រៃស ដោយសារគាត់បានក្បត់នឹង*អង្គការ*")។

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ* **Jeffery JAMES, Joshua ROTHSCHILD (E2/86 និង E2/88)**

៥៥៨. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបនេះអះអាងថា ទទួលរងនូវព្យសនកម្មផ្លូវចិត្ត ដោយសារតែការឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ឪពុកមារបស់ពួកគាត់ James W. CLARK។ Joshua Rothschild អះអាងថា ដោយសារតែមានការអះអាងថា សាកសពរបស់ឪពុកមារបស់គាត់ត្រូវបានគេដុតកម្ទេចនោះ ទើបគាត់ និងគ្រួសាររបស់គាត់មិនអាចបំភ្លេចរឿងទាំងនោះបានទេ[1185]។

៥៥៩. អង្គជំនុំជម្រះសាលាដំបូងបានយកសំអាងហេតុទីបីរបស់ខ្លួនមកអនុវត្ត ដើម្បីបដិសេធឋានៈរបស់អ្នកដាក់ពាក្យសុំទាំងនេះ៖

> Jeffrey JAMES (E2/86) និង Joshua ROTHSCHILD (E2/88) បានអះអាងថា ឪពុកមារបស់ពួកគាត់ឈ្មោះ James W. CLARK ត្រូវបានឃុំខ្លួននៅមន្ទីរ ស២១។ ការឃុំខ្លួនរូបលោក James W. CLARK គឺជាការពិត។ ប៉ុន្តែភាពជាសាច់ញាតិរបស់អ្នកដាក់ពាក្យសុំជាមួយនឹងជនរងគ្រោះ មិនមានភស្តុតាងបង្ហាញដល់កម្រិតបទដ្ឋានតម្រូវនោះទេ។ ទោះបី ជាបានរៀបរាប់ពីការឈឺចាប់របស់ខ្លួន នៅពេលដែលបានដឹងពីជោគវាសនារបស់ជនរងគ្រោះ ក៏ដោយ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែលមានអាយុ ទើបតែប្រាំឆ្នាំ និងប្រាំបីឆ្នាំ នៅពេលដែល James W. CLARK ត្រូវបានចាប់ខ្លួននោះ មិនមានភស្តុតាងបញ្ជាក់អំពីចំណងពិសេសនៃក្តីស្រលាញ់ជាមួយនឹងជនរងគ្រោះនោះទេ[1186]។

៥៦០. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យមានបទដ្ឋាននៃការបង្ហាញភស្តុតាងមិនសមរម្យ ដើម្បីបញ្ជាក់អំពី“ចំណងពិសេសនៃក្តីស្រលាញ់” ជាមួយនឹងសមាជិកគ្រួសារសាច់ឆ្ងាយ។ សហមេធាវីអះអាងថា អង្គជំនុំជម្រះ

---

[1185]លិខិតបញ្ជាក់របស់ Joshua Rothschild, ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E2/88.2។

[1186]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៩។

សាលាដំបូងបានយកសក្ខីកម្មរបស់អ្នកជំនាញ ឈឹម សុធារ៉ា ដែលបានពន្យល់អំពីនិន្នាការប្រវត្តិសាស្ត្រនៃគ្រួសារកម្ពុជាដែលរួមរស់នៅជាមួយគ្នា មកអនុវត្តដោយមិនត្រឹមត្រូវចំពោះអ្នកដាក់ពាក្យសុំទាំងអស់ ដោយមិនគិតអំពីសញ្ជាតិ ឬសាវតារប្បធម៌របស់ពួកគេឡើយ។ សហមេធាវីអះអាងថា JAMES និង ROTHSCHILD រួមជាមួយនឹងម្តាយរបស់ពួកគាត់ គឺជាសាច់ញាតិដែលនៅរស់របស់ឪពុកមារបស់ពួកគាត់។ លើសពីនេះទៀត នៅលើពាក្យសុំរបស់ JAMES គាត់បញ្ជាក់ថា គាត់ និងឪពុកមារបស់គាត់“មានចំណងជិតស្និទ្ធនឹងគ្នាណាស់”។ សហមេធាវីអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានពុំបានពិចារណាលើកាលៈទេសៈជាក់លាក់របស់ម្ចាស់បណ្តឹងសាទុក្ខ ទាំងនេះទេ។

៥៦១. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា “ភាពជាសាច់ញាតិរបស់អ្នកដាក់ពាក្យសុំជាមួយនឹងជនរងគ្រោះមិនត្រូវបានបង្ហាញតាមបទដ្ឋានដែលបានតម្រូវនោះឡើយ”[1187]។ នៅជើងទំព័រ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អ្នកដាក់ពាក្យសុំមិនបានបញ្ជាក់ថា ម្តាយរបស់ពួកគេ Sherry Alice Clark គឺជាបង/ប្អូនស្រីរបស់ James W. Clark ទេ[1188]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បទដ្ឋាននៃការបង្ហាញភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងយកមកអនុវត្តនោះ គឺមានលក្ខណៈតឹងរ៉ឹងមែនទែនចំពោះបញ្ហានៃភាពជាសាច់ញាតិទាក់ទិននឹងម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ។ ពិតណាស់ នៅពេលមើលពីអតីតកាលវិញជាការប្រសើរណាស់ ប្រសិនបើ ម្ចាស់បណ្តឹងសាទុក្ខបានផ្តល់នូវសំបុត្រកំណើតដែលបញ្ជាក់ការពិតដែលថា ម្តាយរបស់ពួកគេ និង James W. Clark កើតចេញពីឪពុកម្តាយតែមួយ ឬក៏នៅកម្រិតអប្បបរមា ប្រសិនបើពួកគេបានផ្តល់នូវលិខិតឆ្លងដែន ឬលិខិតភស្តុតាងពីម្តាយរបស់ពួកគេដែលបញ្ជាក់ថា មានឪពុកម្តាយតែមួយ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារ JAMES បានផ្តល់នូវឯកសារជាក់លាក់ទៅតាមការតម្រូវរបស់តុលាការដូច្នេះ[1189]

---

[1187]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៩។

[1188]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១១២១។

[1189]ដូចដែលបានប្រកាសនៅក្នុងឯកសារបន្ថែមរបស់ Jeffery James ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/86.2, ទំព័រ ២។

ហើយម្តាយរបស់ម្ចាស់បណ្តឹងសាទុក្ខ និងជនរងគ្រោះដោយផ្ទាល់មាននាមត្រកូលដូចគ្នានោះ ហើយជាការពិបាកមួយក្នុងការពន្យល់ថា ហេតុអ្វីបានជាម្ចាស់បណ្តឹងសាទុក្ខទាំងនេះចាំបាច់ខ្វាយខ្វល់ក្នុងការដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ប្រសិនបើ ឪពុកមារបស់ពួកគាត់មិនមែនជាជនរងគ្រោះដោយផ្ទាល់នោះ។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ជីវប្រវត្តិរបស់ James. W. Clark នៅមន្ទីរ ស ២១[1190] មានការបញ្ជាក់ថា គាត់មានបងស្រីម្នាក់។ ជាសរុប អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ចំពោះអត្ថិភាពនៃភាពជាសាច់ញាតិរវាងម្ចាស់បណ្តឹងសាទុក្ខ និងជនរងគ្រោះផ្ទាល់។

៥៦២. ដូចដែលបានយល់ឃើញនៅខាងលើ ជាការត្រឹមត្រូវសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការបញ្ជាក់អំពីលក្ខខណ្ឌតម្រូវនៃចំណងពិសេសនៃក្តីស្រលាញ់ ឬភាពនៅក្នុងបន្ទុករវាងជនរងគ្រោះដោយផ្ទាល់ និងអ្នកដែលអះអាងថា ជាជនរងគ្រោះមិនផ្ទាល់។ អង្គជំនុំជម្រះនេះយល់ឃើញទៀតថា សមាជិកគ្រួសារជិតស្និទ្ធអាចត្រូវបានសន្និដ្ឋានថា មានចំណងបែបនេះ។ ចំពោះអ្វីដែលបង្កើតបានជាគ្រួសារជិតស្និទ្ធ គឺអាស្រ័យលើបរិបទ។ នៅក្នុងបរិបទកម្ពុជា គ្រួសារដែលមានសមាជិកច្រើនរស់នៅជាមួយគ្នា និងបង្កើតចំណងដែលភ្ជាប់សមាជិកគ្រួសារជិតស្និទ្ធ និងសមាជិកគ្រួសារសាច់ឆ្ងាយ។ តាមបទដ្ឋានបស្ចឹមប្រទេស សមាជិកគ្រួសារដែលពេញវ័យជាធម្មតាមិនរស់នៅជាមួយឪពុកម្តាយ ឬបងប្អូនរបស់ពួកគេទេ។ គ្រួសារត្រូវបានបំបែកជាក្រុមគ្រួសារតូចៗ និងមានស្វ័យភាពផ្នែកសេដ្ឋកិច្ច។ ប៉ុន្តែ ការដែលមិនរួមរស់នៅជាមួយគ្នាពុំលុបបំបាត់ចំណងពិសេសនៃក្តីស្រលាញ់នោះឡើយ ជាពិសេសនៅក្នុងគ្រួសារតូចៗ ការដែលពុំមាននូវចំណងទាំងនេះអាចធ្វើឱ្យពួកគេមានភាពរឹងមាំដោយខ្លួនឯង។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា យោងទៅលើជីវប្រវត្តិជនរងគ្រោះផ្ទាល់ គ្រួសាររបស់គាត់ជាគ្រួសារតូច ហើយបន្ទាប់ពីឪពុកម្តាយរបស់គាត់បានលែងលះគ្នាមក គាត់បានរស់នៅជាមួយម្តាយ និងបងស្រីរបស់គាត់។ ផ្ទុយទៅនឹងសារតានេះ សេចក្តីបញ្ជាក់របស់ JAMES អំពី

[1190] សេចក្តីប្រកាសរបស់ James William Clark, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៧៨, ឯកសារលេខ E2/86.5, ទំព័រ ១។

"ការទៅសួរសុខទុក្ខនៅផ្ទះគ្រួសាររបស់អ្នកដាក់ពាក្យសុំ ជាញឹកញាប់របស់ឪពុកមាររបស់ពួកគាត់ក្នុងពេលដែលពួកគាត់កំពុងធំពេញវ័យ"[1191] គឺគួរឱ្យជឿជាក់បាន។

៥៦៣. ដូចដែលបានចង្អុលបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង ម្ចាស់បណ្តឹងសាទុក្ខទាំងពីរនាក់មានអាយុ ៥ ឆ្នាំ និង ៨ ឆ្នាំ នៅពេលដែលឪពុកមាររបស់ពួកគាត់ត្រូវបានពួកខ្មែរក្រហមចាប់ខ្លួន។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលពុំមានព័ត៌មានច្រើនទាក់ទិននឹងប្រភេទគ្រួសាររបស់ពួកគាត់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលនៅតែពុំមានហេតុផលក្នុងការដាក់មន្ទិលទៅលើសុចរិតភាពនៃសេចក្តីបញ្ជាក់របស់ JAMES ដែលថា គាត់ និង ROTHSCHILD "មានចំណងជិតស្និទ្ធនឹងគ្នាណាស់" ជាមួយឪពុកមាររបស់គាត់ ហើយ"មានការគោរពកោតសរសើរគាត់"[1192]។ ដូច្នេះ គួរឱ្យជឿជាក់បានថា Jeffery JAMES នៅត្រឹមអាយុ ១០ ឆ្នាំ និង ROTHSCHILD នៅត្រឹមអាយុ ៨ ឆ្នាំបានទទួលរងការប៉ះទង្គិចផ្លូវចិត្ត ដោយសារតែរឿងរ៉ាវនៅក្នុងទស្សនាវដ្តី ដែលរៀបរ៉ាប់អំពីជោគវាសនារបស់ឪពុកមាររបស់ពួកគាត់[1193]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា មានមូលដ្ឋានគ្រប់គ្រាន់ក្នុងការបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងទទួលយកឋានៈជាជនរងគ្រោះរបស់ម្ចាស់បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបនេះ។

---

[1191]សារណាបណ្តឹងសាទុក្ខរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១, កថាខណ្ឌ ៧៨។ *សូមមើលផងដែរ* សេចក្តីបញ្ជាក់របស់ Jeffrey James, ទំព័រ ១។

[1192]*សូមមើលផងដែរ* ប្រតិចារិកថ្ងៃទី៣០ ខែ មីនា ឆ្នាំ២០១១, ឯកសារលេខ F1/4.1 ទំព័រ ៦១ (បន្ទាត់ ២២ ដល់ ២៥) (លោក កាន)។

[1193]ឯកសារបន្ថែមរបស់ Jeffrey James, ទំព័រ ១ ("ទស្សនាវដ្តីឈ្មោះ Life Magazine (ខែ មីនា ឆ្នាំ ១៩៨០) និពន្ធដោយ Steve Robinson")។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់ Joshua Rothschild, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E2/88, ទំព័រ ៣ (លើកឡើងអំពីជម្ងឺប៉ះទង្គិចផ្លូវចិត្ត និងភាពតានតឹងក្នុងចិត្ត)។

***ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស្ងួន សៀង* (D25/15)**

៥៦៤. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ប្អូនប្រុសរបស់គាត់បីនាក់ និងជីដូនមួយមួយនាក់ ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរ ស ២១។

៥៦៥. អង្គជំនុំជម្រះសាលាដំបូង បានយកសំអាងហេតុទីពីរ និងទីបីរបស់ខ្លួនមកអនុវត្តដើម្បីបដិសេធឋានៈរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

> ស្ងួន សៀង (D25/15) បានទទួលព័ត៌មានពីមិត្តភក្តិរបស់គាត់ថា ប្អូនប្រុសរបស់គាត់បីនាក់ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១។ ប៉ុន្តែ មិនមានភស្តុតាងបង្ហាញអំពីការឃុំខ្លួនរបស់ពួកគេនោះទេ។ គាត់បានអះអាងបន្ថែមទៀតថា បងប្អូនជីដូនមួយរបស់គាត់ឈ្មោះ ប៉ែន អ៊ុំ *ហៅ* រិទ្ធ ក៏ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរ ស ២១ ដែរ[1194]។ ទោះបីជា ការឃុំខ្លួនឈ្មោះ ប៉ែន អ៊ុំ នៅមន្ទីរ ស ២១ ត្រូវបានបញ្ជាក់ក្តី ក៏ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនមានភស្តុតាងបញ្ជាក់អំពីភាពជាសាច់ញាតិជាមួយជនរងគ្រោះនេះទេ[1195]។

៥៦៦. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី ពុំបានផ្តល់ភស្តុតាងបន្ថែមណាមួយដល់អង្គជំនុំជម្រះតុលាការកំពូលឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានណាមួយក្នុងការបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ម្ចាស់បណ្តឹងសាទុក្ខនេះពុំបានបង្ហាញឋានៈជាជនរងគ្រោះនៅក្នុងរឿងក្តីនេះឡើយ។

[1194] ប្រតិចារិកថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩, ឯកសារលេខ E1/69.1, ទំព័រ ១៩ (បន្ទាត់ ១៥) ដល់ទំព័រ ២២ (បន្ទាត់ ១៨)។

[1195] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៩។

**៦.ឃ.២.ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ (E2/32, E2/35, E2/83, E2/22, E2/64)**

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឈឹម ស៊ីថា* ( E2/22)

៥៦៧. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ក្មួយប្រុសរបស់គាត់ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរ ស ២១ ។ ជាលទ្ធផល ម្ចាស់បណ្តឹងសាទុក្ខបានទទួលរងនូវព្យសនកម្មផ្លូវចិត្ត និងលើរូបរាងកាយ។

៥៦៨. អង្គជំនុំជម្រះសាលាដំបូង បានបដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខដោយសារហេតុផលដូចខាងក្រោម:

> ឈឹម ស៊ីថា (E2/22) បានរៀបរាប់ពីការចាប់ខ្លួន ការធ្វើបាប និងការសម្លាប់យោធាមកពីកងពលធំលេខ៣១០ ដែលរូបគាត់ជាសមាជិក។ ទោះបីជាមានយោធាជាច្រើននៅក្នុងកងពលនេះត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១ក៏ដោយ ក៏មិនមានជនរងគ្រោះផ្ទាល់ណាមួយ ក្នុងចំណោមជនរងគ្រោះទាំងនេះ ត្រូវបានបញ្ជាក់អត្តសញ្ញាណថាជា កូវ ផល្លា នោះទេ។ លិខិតបញ្ជាក់ពីប្រធានភូមិ និងមេឃុំរបស់គាត់បង្ហាញថា ឈឹម ស៊ីថា គឺជាឪពុកមារបស់ កូវ ផល្លា។ ប៉ុន្តែ មិនមានភស្តុតាងបញ្ជាក់អំពីចំណងពិសេសនៃក្តីស្រលាញ់ណាមួយនោះទេ[1196]។

៥៦៩. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់នូវលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរមួយជាភស្តុតាងបន្ថែមនៅក្នុងបណ្តឹងសាទុក្ខ។ លិខិតបញ្ជាក់ដែលសរសេរដោយបងស្រីរបស់ម្ចាស់បណ្តឹងសាទុក្ខ និងជាម្តាយក្មួយប្រុសរបស់ម្ចាស់បណ្តឹងសាទុក្ខបញ្ជាក់ថា ៖

> ខ្ញុំបញ្ជាក់ថា កូនប្រុស កូវ ផល្លា និងប្អូនប្រុស ឈឹម ស៊ីថា ធំឡើងជាមួយគ្នាក្នុងភូមិជាមួយគ្នា គឺភូមិកំពង់គរ ឃុំកំពង់គរ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ ពួកគេទាំងពីរ

[1196]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។

នាក់មានអាយុដូចគ្នា បន្ទាប់ពីធ្វើការពិភាក្សាគ្នារួច គេសម្រេចចិត្តទៅធ្វើទាហាននៅកងពល ៣១០។ ពួកគេមានទំនាក់ទំនងគ្នាជិតស្និទ្ធ[1197]។

៥៧០. អង្គជំនុំជម្រះតុលាការកំពូលពុំមានមន្ទិលថា ម្ចាស់បណ្តឹងសាទុក្ខ"បានធំឡើង" និងមាន "ទំនាក់ទំនងជិតស្និទ្ធបំផុត"ជាមួយក្មួយប្រុសរបស់គាត់។ អង្គជំនុំជម្រះតុលាការកំពូល ក៏រំលឹកផងដែរថា សញ្ញាណនៃក្រុមគ្រួសារនៅក្នុងបរិបទនៃប្រទេសកម្ពុជា គឺមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់ ដើម្បីរួមបញ្ចូលទំនាក់ទំនងរវាងឳពុកមាគាត់ជាមួយនឹងក្មួយប្រុសគាត់[1198]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោល សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងទទួលយកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងសាទុក្ខនេះ ។

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ណាំ ម៉ុន* **(E2/32)**

៥៧១. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ម្តាយរបស់គាត់ឈ្មោះ ឃិន តុ ឪពុករបស់គាត់ឈ្មោះ យៀក យ៉ន និងបង/ប្អូនប្រុសរបស់គាត់ឈ្មោះ យ៉ន វឿន, យ៉ន ធឿន, យ៉ន យ៉ុន, យ៉ន សុខហេង និង យ៉ន រុន និងរូបគាត់ផ្ទាល់ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១ នៅចុងឆ្នាំ ១៩៧៧។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា បង/ប្អូនប្រុសរបស់គាត់ត្រូវបានបង្ខំឱ្យសម្លាប់ឪពុកម្តាយរបស់ពួកគេ ហើយក្រោយមក បង/ប្អូនប្រុសរបស់គាត់ក៏ត្រូវបានគេសម្លាប់ចោលដែរ។ គាត់អះអាងបន្ថែមទៀតថា រូបគាត់ និងប្អូនប្រុសរបស់គាត់ដែលនៅរស់សព្វថ្ងៃឈ្មោះ យ៉ន រុន ត្រូវបានគេបញ្ជូនទៅគុកព្រៃឈរដើម្បីសម្លាប់ចោល ប៉ុន្តែពួកគេក៏បានរួចខ្លួនពីសេចក្តីស្លាប់ដោយសារការចូលមកដល់របស់កងទ័ពវៀតណាម។

៥៧២. អង្គជំនុំជម្រះសាលាដំបូង បានបដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខដោយសារហេតុផលដូចខាងក្រោមៈ

---

[1197]សេចក្តីបញ្ជាក់របស់ ឈឹម ភុំ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ F11.2 ។

[1198]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៧៧។

ណាំ ម៉ុន (E2/32) បានលើកឡើងថា ដំបូងគាត់ជាបុគ្គលិកពេទ្យម្នាក់នៅមន្ទីរ ស ២១ និងក្រោយមក គាត់ត្រូវបានឃុំខ្លួននៅទីនោះ ក្រោយពេលចាប់ខ្លួនបងប្រុសគាត់មួយចំនួន ដែលពួកគាត់ជាអ្នកយាមនៅមន្ទីរ ស ២១។ គាត់ត្រូវបានបញ្ជូនពីមន្ទីរ ស ២១ ទៅ ស ២៤ និងក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងផ្សេងទៀត។ ព័ត៌មានដែលបានរៀបរាប់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ មិនស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយដែលគាត់បានឆ្លើយនៅពេលសវនាការ ព្រមទាំងសារណាដែលបានដាក់ជាបន្តបន្ទាប់របស់គាត់នោះទេ[1199]។ គាត់មិនអាចផ្តល់ព័ត៌មានជាក់លាក់ណាមួយទាក់ទងនឹងមន្ទីរ ស ២១ ឬ ស ២៤ ហើយភស្តុតាងដែលគាត់ផ្តល់ឱ្យដើម្បីគាំទ្រអំពីទំនាក់ទំនងសាច់ញាតិទៅនឹងបុគ្គលនៅក្នុងរូបថត ដែលត្រូវបានសម្លាប់នៅមន្ទីរ ស ២១ មិនបានបង្ហាញច្បាស់ថា អ្នកទាំងនោះគឺជាសាច់ញាតិរបស់គាត់ទេ។ ទោះបីជាមានផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត និងការកន្លងផុតនៃពេលវេលាក្តី ក៏អង្គជំនុំជម្រះសន្និដ្ឋានបានថា ណាំ ម៉ុន (E2/32) មិនត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១ (ទួលស្លែង) ឬ ស ២៤ ទេ។ ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់អំពីការរងទុក្ខរបស់គាត់យ៉ាងច្រើនក្តី ក៏ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ត្រូវបដិសេធចោលដែរ[1200]។

---

[1199]អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៧។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មានកង្វះខាតក្នុងពាក្យសុំរបស់គាត់ ដែលគាត់មិនបានកែតម្រូវកង្វះខាតនេះក្នុងបណ្តឹងសាទុក្ខនោះទេ។ ឧទាហរណ៍ ឆ្នាំកំណើតរបស់អ្នកដាក់ពាក្យសុំដូចដែលបានបង្ហាញនៅក្នុងអត្តសញ្ញាណប័ណ្ណខ្មែរ និងពាក្យសុំ (ឆ្នាំ ១៩៦៨) ខុសគ្នាពីការផ្តល់សក្ខីកម្មរបស់គាត់ (ឆ្នាំ ១៩៦០)។ ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារលេខ E1/47.1, ទំព័រ ២ (បន្ទាត់ ៤ ដល់ ១៨) និងទំព័រ ៣ (បន្ទាត់ ១៣ ដល់ ២២)។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់ ណាំ ម៉ុន ភាសាខ្មែរដាក់នៅថ្ងៃទី ២០ មករា ឆ្នាំ ២០០៩, ភាសាអង់គ្លេសដាក់ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩, ឯកសារលេខ E2/32។ ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារលេខ E1/46.1 ទំព័រ ៤៥ (បន្ទាត់ ១៥) ដល់ទំព័រ ៥៤ (បន្ទាត់ ២២)។ អ្នកដាក់ពាក្យសុំបានរៀបរាប់អំពីការខុសគ្នាឆ្នាំកំណើតរបស់គាត់ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងទំនងជាមិនជឿជាក់លើការរៀបរាប់របស់អ្នកដាក់ពាក្យសុំនោះទេ។ ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារ E1/47.1 ទំព័រ ២ (បន្ទាត់ ៤ ដល់ ១៨) និងទំព័រ ៣ (បន្ទាត់ ១៣ ដល់ ២២)។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៨៣។

[1200]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៧ ។

៥៧៣. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អំពើអកម្មរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការ គឺអាចយល់បានដោយផ្អែកលើអង្គហេតុ ដែលថាគាត់មិនប៉ានបង្ហាញឱ្យដឹងថា គាត់ និងបង/ប្អូនប្រុស របស់គាត់ធ្លាប់ធ្វើការនៅមន្ទីរ ស ២១ ដោយខ្លាចមានការសងសឹក។ លើសពីនេះទៀត សហមេធាវីបានអះអាងបន្ថែមទៀតថា វាក៏អាចយល់បានផងដែរថា ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីពីដំបូង មិនបានដាក់បញ្ចូលអង្គហេតុដែលថា គាត់ត្រូវបានគេរំលោភលើផ្លូវភេទ ដោយសារគាត់មានភាពអាម៉ាស់ និងមានការប៉ះទង្គិចផ្លូវចិត្ត[1201]។

៥៧៤. នៅក្នុងបណ្តឹងសាទុក្ខ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា លិខិតបញ្ជាក់ពីមេឃុំឈ្មោះ យឹម សារុន (YIM Saron) ហៅ ហេង[1202] ដែលបានបញ្ជាក់ថា ឪពុករបស់ម្ចាស់បណ្តឹងសាទុក្ខពិតជានៅក្នុងរូបថតមួយរបស់អ្នកជាប់ឃុំខ្លួននៅមន្ទីរ ស ២១ ប្រាកដមែន[1203]។ មេឃុំក៏បានអះអាងផងដែរថា ម្ចាស់បណ្តឹងសាទុក្ខ គឺជាពេទ្យនៅមន្ទីរ ស ២១ ដោយបញ្ជាក់ថា ៖

> ឯចំណែកឈ្មោះ ម៉ុន គឺខ្ញុំស្គាល់ពីប្រវត្តិរបស់គាត់ខ្លះៗដែរ។ រូបគាត់បានចូលធ្វើបដិវត្តតាំងពីរូបគាត់នៅតូច ទៅរស់នៅទីក្រុងភ្នំពេញជាមួយឪពុកមារបស់គាត់ឈ្មោះ អឿន ជាប្រធានកងពល ៣១០។ ឈ្មោះនេះក៏ត្រូវស្លាប់នៅមន្ទីរ ស ២១ ទួលស្លែង ក្រោយមកទៀតឈ្មោះ ម៉ុន ក៏បានធ្វើជាពេទ្យនៅមន្ទីរ ស ២១។ ពេលក្រោយមកទៀតខ្ញុំក៏ពុំបានដឹងច្បាស់ គឺរូបខ្ញុំសូមបញ្ជាក់ជូនដោយសង្ខេបខ្លី[1204]។

---

[1201]បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៨៥។

[1202]បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៨៦។

[1203]សេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ យឹម សារុន ហៅ ហេង និងរូបថតរបស់ តា ប្រាក់ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ F11.3។

[1204]សេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ យឹម សារុន ហៅ ហេង និងរូបថតរបស់ តា ប្រាក់។ ឯកសារបកប្រែលេខ F11.3 ជាភាសាអង់គ្លេស បានរៀបរាប់ខុសអំពីម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីជាមនុស្សប្រុស។

៥៧៥. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សេចក្តីបញ្ជាក់ទាំងពីរនេះពីមេឃុំធ្វើឱ្យអង្គជំនុំជម្រះជឿជាក់បានថា ឪពុករបស់ម្ចាស់បណ្តឹងសាទុក្ខ គឺជាជនរងគ្រោះផ្ទាល់។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល សម្រេចបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងទទួលស្គាល់ឋានៈជនរងគ្រោះនៃម្ចាស់បណ្តឹងសាទុក្ខរូបនេះជាជនរងគ្រោះមិនផ្ទាល់ ដោយសារតែការបាត់បង់ឪពុករបស់គាត់នៅក្នុងមន្ទីរ ស ២១។

៥៧៦. ទោះបីជាយ៉ាងណាក៏ដោយ ការលើកឡើងផ្សេងៗទៀតនៅតែមិនមានភស្តុតាងបញ្ជាក់ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការពន្យល់របស់មេធាវីទាក់ទងទៅនឹងភាពមិនស៊ីសង្វាក់គ្នានៅក្នុងការបញ្ជាក់ដែលអ្នកដាក់ពាក្យសុំផ្តល់ឱ្យនៅក្នុងតុលាការនោះ មិនអាចយកមកជំនួសភស្តុតាងដើម្បីធ្វើឱ្យតុលាការជឿជាក់បានឡើយ។ ទោះបីជាយកបទដ្ឋានអ្វីមកបង្ហាញថា ភាពមិនស្មោះត្រង់របស់ម្ចាស់បណ្តឹងសាទុក្ខទៅលើអង្គជំនុំជម្រះសាលាដំបូង សមស្របក៏ដោយ ក៏មិនអាចសម្រាលដល់ការពិតដែលថា គាត់បានផ្តល់ការបញ្ជាក់អំពីអង្គហេតុដែលមានភាពមិនស៊ីសង្វាក់គ្នា ចំពោះអំណះអំណាងរបស់គាត់ ព្រមទាំង អង្គហេតុដែលគ្មានប្រសិទ្ធភាព ដូចជា ថ្ងៃខែឆ្នាំកំណើតរបស់គាត់ ហើយលើសពីនេះទៀត គាត់មិនអាចផ្តល់នូវចំណុចពិសេសៗអំពីមន្ទីរ ស ២១ ដែលជាទីកន្លែងគាត់ធ្លាប់ធ្វើការ មុនពេលដែលគាត់ក្លាយជាជនរងគ្រោះ ឡើយ។ ជាសរុប អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានហេតុផលក្នុងការចូលធ្វើអន្តរាគមន៍ នៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពគួរឱ្យជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី រូបនេះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចតម្កល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញភស្តុតាង ថាបានជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ឬ ស ២៤ ឡើយ។

### *ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឆាយ កន ហៅ លៀង កន* **(E2/35)**

៥៧៧. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គាត់បានបាត់បង់សាច់ញាតិបួននាក់ក្នុងរបបខ្មែរក្រហម រួមទាំងក្មួយរបស់គាត់ដែលត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១។ ជាលទ្ធផល

នៃព្រឹត្តិការណ៍នេះ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គាត់បានទទួលរងនូវព្យសនកម្មផ្លូវចិត្ត។

៥៧៨. អង្គជំនុំជម្រះសាលាដំបូង បានបដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខដោយសារហេតុផលដូចខាងក្រោមៈ

> ឆាយ កន *ហៅ* លៀង កន (E2/35) បានអះអាងថា ក្មួយរបស់គាត់ម្នាក់ ឈ្មោះ ញ៉ែម ឆឹយ ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១។ គាត់បានឃើញរូបថតក្មួយគាត់នៅពេលគាត់ទៅទស្សនាគុកទួលស្លែង។ ទោះបីជា លៀង កន បានបង្ហាញថា ក្មួយរបស់គាត់ដែលជាកូនកំព្រាកាលពីនៅក្មេងបានរស់នៅជាមួយគាត់ក៏ដោយ ក៏មិនមានឯកសារណាមួយគាំទ្រចំពោះអំណះអំណាងរបស់គាត់ដែរ។ មិនមានភស្តុតាងបង្ហាញថា រូបថតរបស់អ្នកជាប់ឃុំឃាំងដែលជាមូលដ្ឋានគាំទ្រអំណះអំណាងរបស់គាត់ គឺពិតជា ញ៉ែម ឆឹយ ឡើយ[1205]។

៥៧៩. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីដែលថា គាត់ពិតជាស្គាល់រូបថតក្មួយប្រុសរបស់គាត់នៅមន្ទីរ ស ២១ មានភាពប្រាកដប្រជា និងស៊ីសង្វាក់គ្នាឥតលម្អៀង និងបំពេញទៅតាមបទដ្ឋានចាំបាច់បំផុត[1206]។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានដាក់លិខិតបញ្ជាក់បន្ថែមរបស់បងស្រីរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលបានអះអាងថា បុគ្គលនៅក្នុងរូបថតនោះ[1207] គឺជាក្មួយប្រុសរបស់ម្ចាស់បណ្តឹងសាទុក្ខដែលមានឈ្មោះ ញ៉ែម ឆឹយ ប្រាកដមែន[1208]។

៥៨០. អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ទៅលើសេចក្តីអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមាន ឯកសារបញ្ជាក់ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំ

---

[1205]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។

[1206]បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៧៥។

[1207]រូបថតរបស់ លៀង កន ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/35.2។

[1208]សេចក្តីបញ្ជាក់របស់ ឆាយ គៀន ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ F11.4។

ជម្រះតុលាការកំពូល។ ដូច្នេះ មានមូលដ្ឋានជាក់លាក់ក្នុងការបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយទទួលស្គាល់ឋានៈជាជនរងគ្រោះនៃម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ញ៉ិប គឹមស្រ៊ា* **(E2/64)**

៥៨១. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា សមាជិកចំនួន ៧ នាក់ ពោលគឺម្តាយមីង ឪពុកមា និងប្អូនជីដូនមួយរបស់គាត់ចំនួន ៥នាក់ ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរ ស ២១។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គាត់កើតទុក្ខមិនសុខចិត្តឡើយ[1209]។

៥៨២. អង្គជំនុំជម្រះសាលាដំបូង បានបដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខដោយសារហេតុផលដូចខាងក្រោមៈ

> ញ៉ិប គឹមស្រ៊ា (E2/64) បានអះអាងថា ឪពុកមារបស់គាត់ឈ្មោះ ជាប បារ៉ូ *ហៅ* ប៉ែន ប្រពន្ធរបស់គាត់ឈ្មោះ ឃុត ផន និងប្អូនជីដូនមួយរបស់គាត់ចំនួន ៥ នាក់ ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១។ មានភស្តុតាងបង្ហាញថាឈ្មោះ ជាប បារ៉ូ *ហៅ* ប៉ែន ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១។ ទោះជាយ៉ាងនេះក្តី អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលបានកើតនៅឆ្នាំ១៩៧៨ បានទទួលស្គាល់ថា ខ្លួនមិនបានស្គាល់ឪពុកមា ម្តាយមីង និងប្អូនជីដូនមួយរបស់គាត់ទេ។ ហេតុដូច្នេះ មិនមានចំណងពិសេសនៃក្តីស្រលាញ់រវាងអ្នកដាក់ពាក្យសុំ និងសាច់ញាតិទាំងនោះទេ[1210]។

៥៨៣. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីគប្បីត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះគាត់បានទទួលរងនូវព្យសនកម្ម ជាលទ្ធផលនៃការស្លាប់របស់ជនរងគ្រោះផ្ទាល់។ ការឈឺចាប់របស់ឪពុកម្តាយរបស់គាត់ បានកើតមានចំពោះគាត់ពេញមួយជីវិតរបស់គាត់។ នៅក្នុងបណ្តឹងសាទុក្ខ ម្ចាស់

[1209]លិខិតបញ្ជាក់របស់ ញ៉ិប គឹមស្រ៊ា ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩, ឯកសារលេខ E2/64.1, ទំព័រ ១។

[1210]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៩។

បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី បានដាក់លិខិតបញ្ជាក់បន្ថែមមួយពីឪពុករបស់គាត់ ដែលពណ៌នាអំពីទំនាក់ទំនងរវាងគ្រួសារគាត់ និងគ្រួសាររបស់អ្នកស្លាប់។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គាត់ គឺជាសមាជិកគ្រួសារតែម្នាក់គត់ដែលអាចតំណាងឱ្យគ្រួសារគាត់បាន។

៥៨៤. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីមិនមានចំណងពិសេសនៃសេចក្តីស្រលាញ់ជាមួយនឹងជនរងគ្រោះផ្ទាល់ឡើយ ពីព្រោះគាត់កើតក្រោយការស្លាប់របស់ពួកគេ[1211]។ ដូច្នេះ សេចក្តីអះអាងបន្ថែមជាលាយលក្ខណ៍អក្សរដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ជូននេះ មិនពាក់ព័ន្ធទៅនឹងអ្វីដែល ថាតើចំណងពិសេសនៃក្តីស្រលាញ់មានអត្ថិភាពរវាងម្ចាស់បណ្តឹងសាទុក្ខ និងសាច់ញាតិរបស់គាត់ដែលជាជនរងគ្រោះផ្ទាល់ ដែរ ឬយ៉ាងណា នោះឡើយ[1212]។ សហមេធាវីនេះ ទំនងជាលើកទឡ្ហីករណ៍ថា ម្ចាស់បណ្តឹងសាទុ ក្ខគួរតែទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដោយផ្អែកលើមូលដ្ឋានថា គាត់ គឺជាជនរងគ្រោះមិនផ្ទាល់ "ជំនាន់ទីពីរ"[1213] ដែលមានន័យថា ម្ចាស់បណ្តឹងសាទុក្ខទទួលរងព្យសនកម្ម ជាលទ្ធផលនៃព្យសនកម្មដែលឪពុករបស់គាត់បានទទួលរង ដែលឪពុករបស់គាត់ជាបងប្រុសរបស់ជនរងគ្រោះម្នាក់ ក្នុងចំណោមជនរងគ្រោះផ្ទាល់ទាំងនោះ[1214]។ ដោយសារតែលក្ខខណ្ឌតម្រូវយ៉ាងច្បាស់លាស់ដែលថា ព្យសនកម្មដែលជនរង

[1211]ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/4.1, ទំព័រ ៣២ (បន្ទាត់ ២០ ដល់ ២២), ទំព័រ ៣៨ (បន្ទាត់ ២ ដល់ ១៨) និងទំព័រ ៣៨ (បន្ទាត់ ២០ ដល់ ២១)។

[1212]សេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ ជៀប ញ៉ឹម ចុះខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ F11.5 ។ ឪពុករបស់អ្នកដាក់ពាក្យសុំលើកឡើងថា "ខ្ញុំសូមបញ្ជាក់ថា គ្រួសាររបស់ប្អូនប្រុសខ្ញុំ ជៀប បារូ និងគ្រួសាររបស់វារស់នៅជាមួយគ្រួសារខ្ញុំក្នុងផ្ទះជាមួយគ្នា ហើយយើងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ រហូតដល់គ្រួសាររបស់ប្អូនប្រុសខ្ញុំទៅភ្នំពេញ រួចបែកគ្នារហូត"។

[1213]បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ១០៥។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/4.1, ទំព័រ ៣៨ (បន្ទាត់២ ដល់ ១៨) និងទំព័រ ៣៨ (បន្ទាត់២០ ដល់ ២១)។

[1214]បណ្តឹងសាទុក្ខស្តីពីភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ កថាខណ្ឌ ១០៥ (" ញ៉ិប គឹមស្រ៊ា រស់នៅជាមួយឪពុកចាស់ជរា ដែលជាបងប្រុសរបស់ជនរងគ្រោះដែលបានបាត់បង់ជីវិត។ "លិខិតបញ្ជាក់របស់សាក្សី" បន្ថែម (F11.5) បានពិពណ៌នា ថាតើឪពុកគាត់ និងក្រុមគ្រួសារធ្លាប់រស់នៅបែបណាជាមួយអ្នកបាត់បង់ជីវិត និងគ្រួសារ របស់

គ្រោះបានទទួលរងត្រូវតែជាផលវិបាកដោយផ្ទាល់ពីបទល្មើស[1215] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការកើតទុក្ខមិនសុខចិត្តដែលម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងនោះ មិនស្ថិតនៅក្នុងដែនកំណត់នៃការផ្តល់សំណងរបស់ អ.វ.ត.ក ឡើយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានណាមួយឡើយក្នុងការបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ម្ចាស់បណ្តឹងសាទុក្ខនេះ ពុំបានបង្ហាញឋានៈជាជនរងគ្រោះនៅក្នុងរឿងក្តីនេះឡើយ។

### *ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហុង សាវ៉ាត* (E2/83)

៥៨៥. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ឪពុកមារបស់គាត់ត្រូវបានយកទៅកសាងខ្លួននៅឆ្នាំ ១៩៧៥។ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា លែងបានឃើញគាត់រហូត។ នៅឆ្នាំ ២០០៨ ម្ចាស់បណ្តឹងសាទុក្ខ បានឃើញរូបថតគាត់នៅមន្ទីរ ស ២១។

៥៨៦. អង្គជំនុំជម្រះសាលាដំបូង បានប្រើប្រាស់សំអាងហេតុទីពីរ និងទីបី ដើម្បីបដិសេធឋានៈរបស់ម្ចាស់បណ្តឹងសាទុក្ខនេះ។

> ហុង សាវ៉ាត (E2/83)បានអះអាងថា ឪពុកមារបស់គាត់ឈ្មោះ ឡឹក ស្រេង ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរ ស ២១។ គាត់បានអះអាងថា គាត់បានចំណាំឪពុកមារបស់គាត់តាមរយៈរូបថត នៅពេលដែលគាត់បានប្រទះឃើញរូបថតនោះក្នុងឆ្នាំ២០០៨ នៅពេលគាត់ទស្សនាសារមន្ទីរទួលស្លែង។ ប៉ុន្តែ រូបថតនេះ ឬឯកសារភស្តុតាងផ្សេងៗ មិនបានផ្តល់ជូនដើម្បីគាំទ្រអំពីការឃុំខ្លួនឪពុកមារបស់គាត់នៅមន្ទីរ ស ២១ នោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាយុ១១ឆ្នាំនៅពេលដែលឪពុកមា

---

គាត់។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាមនុស្សតែម្នាក់ដែលអាចតំណាងគ្រួសារនៅអ.វ.ត.ក។ ជារៀងរាល់ថ្ងៃ គាត់ត្រូវប្រឈមមុខនឹងការឈឺចាប់របស់ឪពុកគាត់ ដែលបណ្តាលឲ្យក្លាយទៅជាព្យសនកម្មដោយផ្ទាល់ដល់រូបគាត់ដែរ”)។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/4.1, ទំព័រ ៣៨ (បន្ទាត់ ២ ដល់ ១៦)។

[1215] វិធាន ២៣(២)(ខ) នៃវិធានផ្ទៃក្នុង។

របស់គាត់បានបាត់ខ្លួននោះ ក៏មិនបានផ្តល់ភស្តុតាងអំពីចំណងពិសេសនៃក្តីស្រលាញ់ ឬការនៅក្នុងបន្ទុករបស់ឪពុកមាគាត់ទេ[1216]។

៥៨៧. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋានថា ហុង សាវ៉ាត មិនបានផ្តល់ឯកសារភស្តុតាងផ្សេងទៀត ក្រៅពីអំណះអំណាងរបស់គាត់តែប៉ុណ្ណោះ។ សហមេធាវីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងភ័ន្តច្រឡំអង្គហេតុដោយមើលរំលងលើរូបថត ឡឹក ស្រេង ថតនៅមន្ទីរ ស ២១ ជាឪពុកមាដែលបានស្លាប់របស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី[1217]។

៥៨៨. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មានរូបថតមនុស្សប្រុសម្នាក់ត្រូវបានដាក់ជាមួយនឹងពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខ[1218]។ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា រូបថតនេះគឺជាឪពុកមារបស់គាត់ ដែលជាជនរងគ្រោះផ្ទាល់មួយរូបនៅមន្ទីរ ស ២១។ នៅក្នុងបណ្តឹងសាទុក្ខ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ជូនសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរបន្ថែមទៀតរបស់ឈ្មោះ យូ ហុង ដែលជាបងប្រុសរបស់អ្នកទទួលមរណភាព[1219]។ យូ ហុង អះអាងថា គាត់បានថតរូបបងប្រុសរបស់គាត់ (ពោលគឺ រូបថតឪពុកមារបស់ម្ចាស់បណ្តឹងសាទុក្ខ) នៅមន្ទីរ ស ២១ និងក្រោយមកបានឱ្យរូបថតនេះទៅម្ចាស់បណ្តឹងសាទុក្ខ ដែលបានបញ្ចូលរូបនេះទៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា យូ ហុង មិនបានបញ្ជាក់ថា គាត់បានពិនិត្យមើលរូបថតដែលដាក់ដោយម្ចាស់បណ្តឹងសាទុក្ខនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ និង យូ

---

[1216]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ទំព័រ៦៤៨។

[1217]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ៨៧ ដល់ ៨៩។

[1218]រូបថតរបស់ ឡឹក ស្រេង ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារលេខ E2/83.3។

[1219]សេចក្តីបញ្ជាក់របស់ យូ ហុង ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារលេខ F11.6។

ហុង គឺគ្រប់គ្រាន់សម្រាប់បង្ហាញភាពជាសាច់ញាតិរវាងម្ចាស់បណ្តឹងសាទុក្ខជាមួយនឹងជនរងគ្រោះផ្ទាល់។

៥៨៩. ទាក់ទងនឹងចំណងពិសេសនៃក្តីស្រលាញ់អំណះអំណាងបន្ថែមរបស់ យូ ហុង បានលើកឡើងថា៖

> ខ្ញុំបាទសូមបញ្ជាក់ថា៖ មុនរបបខ្មែរក្រហម (ក្នុងរបប លន់ នល់) ក្រុមគ្រួសារទាំងបីនេះ រួមមានក្រុមគ្រួសាររបស់ ឡឹក ស្រេង ក្រុមគ្រួសាររបស់ ហុង សាវ៉ាត និងខ្ញុំបាទ (ប្តីប្រពន្ធ) បានរួមរស់នៅជាគ្រួសារតែមួយ ក្នុងផ្ទះតែមួយយ៉ាងជិតស្និទ្ធគ្នាបំផុត[1220]។

៥៩០. ភាពជាក់ស្តែងដែលថា ម្ចាស់បណ្តឹងសាទុក្ខមានអាយុត្រឹម ១១ ឆ្នាំ នៅពេលឪពុកមារបស់គាត់បានបាត់ខ្លួន មិនអាចកាត់បន្ថយនូវចំណងពិសេសនៃក្តីស្រលាញ់រវាងឪពុកមា ជាមួយនឹងគាត់នាពេលនោះបានទេ។ យូ ហុង បានបញ្ជាក់ថា គ្រួសាររបស់ម្ចាស់បណ្តឹងសាទុក្ខ និងគ្រួសាររបស់ឪពុកមា "បានរួមរស់នៅជាគ្រួសារតែមួយ ក្នុងផ្ទះតែមួយយ៉ាងជិតស្និទ្ធបំផុត"។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា កូនក្មេងអាយុ ១១ ឆ្នាំ អាចបង្កើតឱ្យមានចំណងពិសេសនៃក្តីស្រឡាញ់ជាមួយឪពុកមា ដែលខ្លួនបានរស់នៅយ៉ាងជិតស្និតជាមួយគ្នានោះ ហើយគាត់មិនមានកូនខ្លួនឯងផង។ ចម្លើយរបស់ យូ ហុង គឺជាព័ត៌មានគ្រប់គ្រាន់ដើម្បីបង្ហាញឱ្យឃើញថា មានចំណងពិសេសនៃក្តីស្រឡាញ់ដែលកើតមានរវាងម្ចាស់បណ្តឹងសាទុក្ខ និងជនរងគ្រោះផ្ទាល់ នៅត្រឹមពេលមរណភាពរបស់ជនរងគ្រោះនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងទទួលស្គាល់ឋានៈជាជនរងគ្រោះរបស់ម្ចាស់បណ្តឹងសាទុក្ខ។

[1220]សេចក្តីបញ្ជាក់របស់ យូ ហុង, ទំព័រ ២។

## ៦.ឃ.៣.ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ (E2/23, E2/33, E2/34, E2/63, E2/70, E2/71, E2/82, D25/11)

### *ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឡាយ ចាន់* (E2/23)

៥៩១. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គាត់ត្រូវបានគេសួរចម្លើយ និងធ្វើទារុណកម្ម នៅពេលដែលគាត់ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គាត់បានទទួលរងព្យសនកម្មរូបរាងកាយ ផ្លូវចិត្ត និងសម្ភារៈ ដោយសារបច្ច័យនៃការប្រព្រឹត្តឧក្រិដ្ឋកម្មលើរូបគាត់។

៥៩២. អង្គជំនុំជម្រះសាលាដំបូង បានប្រើប្រាស់សំអាងហេតុទីមួយដើម្បីបដិសេធចោលឋានៈរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីនេះ។

> ទោះបីជាអង្គជំនុំជម្រះមិនមានការសង្ស័យថា ឡាយ ចាន់ (E2/23) ទទួលរងការខូចខាតយ៉ាងខ្លាំងដោយសារតែការឃុំខ្លួន ការសួរចម្លើយ និងការធ្វើទារុណកម្មក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏មិនមានភស្តុតាងបង្ហាញថា ការខូចខាតនេះកើតឡើងនៅមន្ទីរ ស ២១ ទេ។ ភស្តុតាងជាក់ស្តែងពីការចុះឈ្មោះអ្នកទោសផ្លូវការ រូបថត ឬចម្លើយសារភាព មិនបានបញ្ជាក់អំពីការអះអាងរបស់គាត់ដែលថា គាត់ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១ ឡើយ។ ការរៀបរាប់អំពីស្ថានភាពឃុំខ្លួននេះ មិនស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងជាច្រើន ដែលដាក់ជូនអង្គជំនុំជម្រះទាក់ទងនឹងប្រតិបត្តិការនៅមន្ទីរ ស ២១[1221] ទេ។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មិនមានភស្តុតាងដែលបញ្ជាក់ថា ឡាយ ចាន់ (E2/32) ត្រូវបានជាប់ឃុំឃាំងនៅមន្ទីរ ស ២១ ឬ ស ២៤ ទេ។ ដោយសារតែមិនមានភស្តុតាងគ្រប់គ្រាន់ដែលបង្ហាញអំពីទំនាក់ទំនងហេតុ និង

[1221] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៨១ ("ប្រតិចារឹក ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩ (ឡាយ ចាន់) ទំព័រ ៨, ១១ ដល់ ១២, ១៧ ដល់ ១៩ (បានរៀបរាប់ថា គាត់មិនអាចចាំបានអំពីការចុះឈ្មោះ ឬថតរូបជាផ្លូវការ ឬតម្រូវឲ្យផ្តល់ជីវប្រវត្តិទេ។ គាត់បានរៀបរាប់អំពីបន្ទប់ឃុំឃាំងគាត់ ដែលមិនស៊ីគ្នានឹងអ្នកផ្សេងទៀតដែលរៀបរាប់អំពីបន្ទប់ឃុំឃាំងនៅមន្ទីរ ស ២១ ហើយគាត់បានទាមទារឲ្យដោះលែងគាត់ពីមន្ទីរ ស ២១ ដោយគ្មានការពន្យល់អ្វីសោះ ដែលការលើកឡើងនេះ ផ្ទុយគ្នានឹងគោលនយោបាយដែលមាន។ ក្នុងអំឡុងពេលទស្សនាមន្ទីរ ស ២១ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនអាចចំណាំបានផ្នែកនៃមន្ទីរ ស ២១ ដែលជាកន្លែងដែលគាត់ត្រូវបានឃុំខ្លួននោះទេ")។

ផលរវាងព្រឹត្តិការណ៍ដែលបានរៀបរាប់និងឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច មានពិរុទ្ធភាពនោះ ដូច្នេះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ត្រូវបដិសេធចោល[1222]។

៥៩៣. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី បានដាក់រូបថតបន្ថែមមួយមកកាន់អង្គជំនុំជម្រះតុលាការកំពូល[1223] តាមការសន្មត់ គឺដើម្បីជំទាស់ទៅនឹងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងថា ម្ចាស់បណ្តឹងសាទុក្ខ"បានរៀបរាប់អំពីបន្ទប់ឃុំឃាំងគាត់ដែលមិនស៊ីគ្នានឹងអ្នកផ្សេងទៀតដែលរៀបរាប់ និងបានអះអាងអំពីបន្ទប់ឃុំឃាំងនៅមន្ទីរ ស ២១"[1224]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មានភាពមិនច្បាស់លាស់ ថាតើសហមេធាវីអះអាងថា រូបថតនេះ គឺជារូបបន្ទប់ឃុំឃាំងម្ចាស់បណ្តឹងសាទុក្ខ[1225] ឬក៏គ្រាន់តែរូបជាឧទាហរណ៍អំពីប្រភេទបន្ទប់ឃុំឃាំងដែលម្ចាស់បណ្តឹងសាទុក្ខត្រូវបានឃុំឃាំង ដែរ ឬយ៉ាងណា[1226]។ នៅក្នុងករណីណាក៏ដោយ ទោះបីជារូបថតបន្ថែមនេះបង្ហាញថា ការរៀបរាប់របស់ម្ចាស់បណ្តឹងសាទុក្ខអំពីបន្ទប់ឃុំឃាំងគាត់អាចជឿជាក់បានក៏ដោយ ក៏សហមេធាវីមិនបានបង្ហាញទឡ្ហីករណ៍ ឬភស្តុតាងបន្ថែមណាមួយក្នុងបណ្តឹងសាទុក្ខដើម្បីបំពេញភាពមិនគ្រប់គ្រាន់

---

[1222]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៧។

[1223]សំណើសុំឱ្យទទួលយកនូវសំអាងភស្តុតាងបន្ថែមដើម្បីគាំពារសារណាបណ្តឹងឧទ្ធរណ៍ដាក់ ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, ភាសាខ្មែរដាក់ថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១១, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/1, កថាខណ្ឌ ១៦។ រូបថតបន្ទប់ឃុំឃាំងរបស់ ឡាយ ចាន់ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១១, ឯកសារលេខ F2/1.7។ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/4.1, ទំព័រ ៧ (បន្ទាត់៩ ដល់ ១០)។

[1224]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១០៨១។

[1225]រូបថតបន្ទប់ឃុំឃាំងរបស់ ឡាយ ចាន់ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/1.7។ ពាក្យទាំងនេះត្រូវបានសរសេរនៅខាងលើរូបថត "រូបថត ថតនៅមន្ទីរ ស ២១។ កន្លែងបន្ទប់ឃុំឃាំងរបស់ ឡាយ ចាន់"។

[1226]សំណើសុំឱ្យទទួលយកនូវសំអាងភស្តុតាងបន្ថែមដើម្បីគាំពារសារណាបណ្តឹងឧទ្ធរណ៍ ដាក់ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ កថាខណ្ឌ ១៦។ ("រូបថត "បានបង្ហាញថា ដូចអ្វីដែល ឡាយ ចាន់ បាននិយាយរៀបរាប់ និងអះអាងជាច្រើនលើកច្រើនសារមែន ថាពិតជាមានបន្ទប់ឃុំឃាំងស្ថិតនៅក្រោមជណ្តើរ"។ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ F1/4.1, ទំព័រ ៦៦ (បន្ទាត់ ៨ ដល់ ១០) (ម៉ុច សុវណ្ណារី) ("[រូបថត] បង្ហាញថាមានបន្ទប់ឃុំឃាំងមួយស្ថិតនៅក្រោមជណ្តើរ ហើយរូបថតនោះ បានថតពីសារមន្ទីរទួលស្លែង")។

នានា ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញនៅក្នុងពាក្យសុំរបស់គាត់នោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គ្មានសំអាងហេតុណាមួយក្នុងការអន្តរាគមន៍ចំពោះការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពអាចជឿជាក់បានចំពោះដើមបណ្តឹងរដ្ឋប្បវេណីនេះទេ។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូល សម្រេចតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានបង្ហាញអំពីឋានៈជាជនរងគ្រោះនៅក្នុងករណីនេះទេ។

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភោគ ខន* (E2/33)

៥៩៤. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា នៅឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ ប្រពន្ធរបស់គាត់ឈ្មោះ ទុយ លាភ និងបងជីដូនមួយឈ្មោះ ទិន នេត ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ចោលនៅទួលស្លែង។ បន្ថែមពីលើនេះ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង និងត្រូវបានធ្វើទារុណកម្មនៅទួលស្លែងផងដែរ ប៉ុន្តែគាត់បានលួចរត់គេចខ្លួនមុនពេលគាត់ត្រូវបានគេសម្លាប់ចោល។ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា គាត់បានទទួលរងការខូចខាតខាងផ្លូវចិត្ត ដោយសារតែបច្ច័យនៃការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ កាំង ហ្គេកអ៊ាវ។

៥៩៥. អង្គជំនុំជម្រះសាលាដំបូងបានបដិសេធពាក្យសុំរបស់គាត់ ដោយផ្អែកលើសំអាងហេតុដូចខាងក្រោម៖

> ភោគ ខន (E2/33) បានរៀបរាប់អំពីការធ្វើទារុណកម្ម និងសួរចម្លើយលើរូបគាត់នៅក្នុងគុកក្បែរទីក្រុងភ្នំពេញក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ទោះបីជាអង្គជំនុំជម្រះយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អាចត្រូវបានទាហានខ្មែរក្រហមឃុំខ្លួន និងធ្វើទារុណកម្មក្តី ក៏មិនមានភស្តុតាងពិតប្រាកដបង្ហាញថា ការឃុំខ្លួន និងការធ្វើទារុណកម្មនេះ កើតឡើងនៅមន្ទីរ ស ២១ (ទួលស្លែង)ដែរ។ ការរៀបរាប់អំពីកន្លែងឃុំខ្លួនគាត់ មិនស៊ីសង្វាក់គ្នានឹងកន្លែងឃុំខ្លួននៅមន្ទីរ ស ២១ ហើយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនត្រូវបានគេថតរូប ឬបង្ខំឱ្យផ្តល់ជីវប្រវត្តិដែលផ្ទុយទៅនឹងប្រតិបត្តិការរបស់មន្ទីរ ស ២១។ បន្ថែមពីលើនេះ ការរៀបរាប់អំពីការលួចរត់របស់ដើមបណ្តឹងរដ្ឋប្បវេណីពីកន្លែងប្រហារជីវិត និងការផ្តល់ព័ត៌មានអំពីទីតាំងភូមិសាស្ត្រ មិនស៊ីសង្វាក់គ្នានឹងជើងឯក ដែលជាកន្លែងដែលគាត់បានអះអាងថា គាត់បានរួចផុតពីការស្លាប់។ ភោគ ខន បានអះអាងបន្ថែមថា ប្រពន្ធរបស់គាត់ និងជីដូនមួយគាត់ម្នាក់ក៏ត្រូវបានសម្លាប់នៅមន្ទីរ ស ២១ ដែរ។ ទោះបីជាយ៉ាងណាក៏ដោយ មិនមានភស្តុតាងបង្ហាញថា ប្រពន្ធរបស់គាត់ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១ ទេ។ ទោះបីជាបុគ្គលដែលមានឈ្មោះ ឈឿង ភាំ ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរ ស ២១ ក៏ដោយ ក៏អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទទួលស្គាល់ថា គាត់មិន

អាចផ្តល់ភស្តុតាងបញ្ជាក់អំពីទំនាក់ទំនងរបស់គាត់ជាមួយ ឈឿង ភាំ ទេ។ ដូច្នេះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ត្រូវបដិសេធចោល[1227]។

៥៩៦. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជំទាស់តវ៉ាទៅនឹងការបដិសេធចោលអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ និងបានលើកឡើងថា ការពិតដែលថា កាំង ហ្គេកអ៊ាវ មិនបានជំទាស់នឹងពាក្យសុំនោះ បានជួយគាំទ្រដល់ការបដិសេធចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[1228]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងបន្ថែមថា រូបថតនានាដែលបានផ្តល់ជាភស្តុតាងនៅក្នុងបណ្តឹងសាទុក្ខ បង្ហាញអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[1229]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានលើកឡើងផងដែរថា ម្ចាស់បណ្តឹងសាទុក្ខគប្បីត្រូវបានផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ ដោយសារម្ចាស់បណ្តឹងសាទុក្ខនេះ ត្រូវបានទទួលយកដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២[1230]។

៥៩៧. អង្គជំនុំជម្រះតុលាការកំពូល បដិសេធចោលសារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដោយយល់ឃើញថា ដោយសារតែអំណះអំណាងរបស់អ្នកដាក់ពាក្យសុំមានភាពមិនគ្រប់គ្រាន់ ធ្វើឱ្យមានភាពអយុត្តិធម៌ចំពោះជនជាប់ចោទ ដោយមិនបានជំទាស់ទៅនឹងសំអាងហេតុប្រឆាំងនឹងខ្លួន។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងសាជាថ្មីថា អង្គជំនុំជម្រះមិនបានបដិសេធការដែលថា អំណះអំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែមួយ អាចគ្រប់គ្រាន់ក្នុងការគាំទ្រចំពោះការអះអាងនេះ ជាពិសេសនៅពេលដែលការអះអាងនេះ មានភាពច្បាស់លាស់បំផុត ឬជាភស្តុតាងដែលអាចរកបាននោះទេ។ ប៉ុន្តែ ការយល់ឃើញបែបនេះ តម្រូវឱ្យអំណះអំណាងនេះជឿជាក់បាន ក្នុងលក្ខណៈមួយដែលមានភាពស៊ីសង្វាក់គ្នា មានភាពពេញលេញគ្រប់គ្រាន់ និងមានភាពគួរឱ្យជឿជាក់បាននៅក្នុងបរិបទទាំងមូល។ ភាពមិន

[1227] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៧។

[1228] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៧៤។

[1229] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣ ,កថាខណ្ឌ៧៤ ដល់ ៧៦។

[1230] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៧៥។

ស៊ីសង្វាក់ ឬភាពផ្ទុយគ្នាបន្តិចបន្តួចអាចត្រូវចាត់ទុកថា ជាកំហុសឆ្គងនៃការយល់ដឹង ឬមកពីការចងចាំមិនគ្រប់ជ្រុងជ្រោយរបស់មនុស្ស ជាពិសេសនៅពេលដែលពេលវេលាកន្លងផុតទៅ។ ប៉ុន្តែ នៅតែជាភាពចាំបាច់ដែលថា ភាគីត្រូវរៀបរាប់ព្រឹត្តិការណ៍ឱ្យបានលំអិត ក្នុងកម្រិតដែលអាចទទួលយកបាន។ លក្ខខណ្ឌទាំងនេះមិនបានបង្ហាញនៅក្នុងរឿងក្តីនេះទេ នៅពេលអំណះអំណាងមានភាពមិនគ្រប់គ្រាន់ ពាក់ព័ន្ធនឹងអង្គហេតុជាសត្យានុម័ត ដែលបានដាក់ដើម្បីគាំទ្រពាក្យសុំ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានណាមួយក្នុងការជ្រៀតជ្រែកការវាយតម្លៃភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តីនេះទេ។

៥៩៨. អង្គជំនុំជម្រះតុលាការកំពូលមិនមានយុត្តាធិការលើសារណារបស់ភាគី នៅក្នុងសំណុំរឿង ០០២ នោះទេ ហើយអង្គជំនុំជម្រះនឹងត្រូវពិនិត្យលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងតែប៉ុណ្ណោះ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវបានអញ្ជើញឱ្យដាក់ភស្តុតាងបន្ថែមដោយផ្ទាល់ចំពោះមុខអង្គជំនុំជម្រះ។ គ្រប់ពេលវេលាទាំងអស់ ការពិតដែលថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២ ដោយសហចៅក្រមស៊ើបអង្កេត អនុលោមតាមបទដ្ឋាននៃការបង្ហាញភស្តុតាង[1231] *ជាសេចក្តីបញ្ជាក់ដំបូង* មិនមែនជាការសន្និដ្ឋានថា ជាការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលបញ្ចប់នៃសំណុំរឿង ០០១ នោះទេ។ ក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង្ហាញអំពីឋានៈជាជន រងគ្រោះផ្ទាល់នោះទេ។

៥៩៩. ប៉ុន្តែ នៅក្នុងបណ្តឹងសាទុក្ខ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានដាក់រូបថតមួយចំនួនបន្ថែម ដែលគាត់បានអះអាងថា ជារូបថតប្រពន្ធគាត់ រូបថតឪពុកមាគាត់ និងរូបថត

[1231] *សូមមើល ឧទា.* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ដីកាស្តីពីការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីអ្នកដាក់ពាក្យដែលសព្វថ្ងៃរស់នៅខេត្តកំពង់ធំចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ កថាខណ្ឌ ១០, ២៤។

ប្រពន្ធឪពុកមាគាត់[1232]។ បន្ទាប់ពីគាត់បានទៅទស្សនាមន្ទីរ ស ២១ ទើបគាត់អាចកំណត់អត្តសញ្ញាណរូបថតរបស់ប្រពន្ធរបស់គាត់ ឪពុកមា និងប្រពន្ធឪពុកមារបស់គាត់បាន។ ទោះបីជារូបថតទាំងនេះមិនមានឈ្មោះនៅជាប់ជាមួយក្តី ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការបង្ហាញអត្តសញ្ញាណចំពោះបុគ្គលនៅក្នុងរូបថតដោយម្ចាស់បណ្តឹងសាទុក្ខ មានលក្ខណៈគ្រប់គ្រាន់។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បុគ្គលនៅក្នុងរូបថត គឺជាប្រពន្ធ ឪពុកមា និងម្តាយមីងរបស់គាត់។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងទទួលស្គាល់ឋានៈជាជនរងគ្រោះមិនផ្ទាល់របស់អ្នកដាក់ពាក្យសុំ។

***ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សូ សួង* (E2/34)**

៦០០. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា បងថ្លៃប្រុសរបស់គាត់ត្រូវបានដាក់នៅក្នុងមន្ទីរឃុំឃាំង និងត្រូវបានសម្លាប់នៅមន្ទីរ ស ២១។ ការបាត់ខ្លួនបងថ្លៃប្រុសរបស់គាត់បានធ្វើឱ្យម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីមានអារម្មណ៍ភ័យរន្ធត់[1233]។

៦០១. អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលពាក្យសុំនេះ ដោយសារសំអាងហេតុដូចខាងក្រោម៖

> សូ សួង (E2/34) បានអះអាងថា បងថ្លៃរបស់គាត់ឈ្មោះ មាស ស៊ុន *ហៅ* តេង ស៊ុន ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរ ស ២១។ ដើម្បីគាំទ្រអំណះអំណាងនេះ គាត់បាន

---

[1232]ការស្នើសុំឱ្យទទួលយកនូវសំអាងភស្តុតាងបន្ថែម ដើម្បីគាំពារសារណាបណ្តឹងឧទ្ធរណ៍ដាក់ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ១១។ (លោក ភោគ ខន (E2/33) ក៏បានបញ្ជាក់ផងដែរថា សមាជិកគ្រួសាររបស់គាត់ក៏បានស្លាប់នៅមន្ទីរ ស ២១។ គឺបន្ទាប់ពីការស្វែងរកនៅមន្ទីរសន្តិសុខនេះ ទើបគាត់អាចចំណាំនូវរូបភាពប្រពន្ធគាត់ រូបភាពឪពុកមាគាត់ និងរូបភាពប្រពន្ធឪពុកមាគាត់" (សេចក្តីដកស្រង់ពីរូបថតត្រូវបានលុបចោល)។ រូបថតចំនួនប្រាំមួយមានដូចជា៖ ឯកសារលេខ F2/1.1- F2/1.2 (ប្រពន្ធ), ឯកសារលេខ F2/1.3- F2/1.4 (ឪពុកមា), និង ឯកសារលេខ F2/1.5- F2/1.6 (ម្តាយមីង)។

[1233]ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់ សូ សួង, ឯកសារខ្មែរដាក់នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩, ភាសាអង់គ្លេសដាក់ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៩, ឯកសារលេខ E2/34.1 ទំព័រ ៣។

ផ្តល់រូបថតដែលមាននៅក្នុងបណ្ណសាររបស់សារមន្ទីរទួលស្លែង។ ប៉ុន្តែ រូបថតនោះមិនបានបង្ហាញអំពីការបញ្ជាក់នៃអត្តសញ្ញាណ ហើយរូបថតនោះទៀតសោតមិនបានបង្ហាញថា បុគ្គលនៅក្នុងរូបថត គឺពិតជា មាស ស៊ុន នោះទេ។ បន្ថែមពីលើនេះ មិនមានភស្តុតាងបង្ហាញអំពីភាពនៅក្នុងបន្ទុក ឬទំនាក់ទំនងពិសេសនៃសេចក្តីស្រលាញ់ រវាងដើមបណ្តឹងរដ្ឋប្បវេណី និងបងថ្លៃរបស់គាត់នោះទេ[1234]។

៦០២. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញភស្តុតាងអំពីភាពជាសាច់ញាតិជាមួយ មាស ស៊ុន។ អង្គជំនុំជម្រះសាលាដំបូង មិនបានពិចារណាលើរូបថតរបស់ជនរងគ្រោះផ្ទាល់ដែលបានផ្តល់ជូននោះទេ។ កំហុសរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានបង្ហាញនៅក្នុងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីភាពអាចទទួលយកបាននៅក្នុងសំណុំរឿង ០០២ ដែលម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសម្រេចថា ទទួលរងព្យសនកម្មផ្លូវចិត្ត ដែលជាចំណងទាក់ទងដោយផ្ទាល់ទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរ ស ២១[1235]។

៦០៣. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការបង្ហាញអត្តសញ្ញាណចំពោះបុគ្គលនៅក្នុងរូបថតដោយម្ចាស់បណ្តឹងសាទុក្ខ គឺមានលក្ខណៈគ្រប់គ្រាន់។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បុគ្គលនៅក្នុងរូបថតនោះ គឺពិតជាបងថ្លៃប្រុសរបស់ម្ចាស់បណ្តឹងសាទុក្ខប្រាកដមែន។ ទោះបីជាយ៉ាងណាក៏ដោយ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់ភស្តុតាងណាមួយ ដែលបង្ហាញពីចំណងពិសេសនៃក្តីស្រឡាញ់ ឬភាពនៅក្នុងបន្ទុករបស់បងថ្លៃប្រុសរបស់ម្ចាស់បណ្តឹងសាទុក្ខដែលទទួលមរណភាពនោះទេ។ គ្រាន់តែភាពជាសាច់ញាតិបែបនេះ មិននាំឱ្យមានការសន្មតទុកជាមុនបានថា មានភាពជិតស្និទ្ធ ឬភាពនៅក្នុងបន្ទុកនោះទេ ហើយនៅក្នុងករណីដែលគ្មានឯកសារ ឬភស្តុតាងជាសត្យានុម័តផ្សេងទៀតនោះ ភាពជា

---

[1234]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។ ជើងទំព័រ ១០៨៤ (" ទោះបីជាភាពជាសាច់ញាតិ តាមរយៈអាពាហ៍ពិពាហ៍ត្រូវបានបញ្ជាក់ដោយលិខិតបញ្ជាក់ ("លិខិតបញ្ជាក់" ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ E2/34/5.2 ក៏ដោយ) ក៏ភាពជាសាច់ញាតិតែមួយនេះមិនគ្រប់គ្រាន់ទេ (ផ្នែក៤.២.២)។

[1235]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៩២ ដល់ ៩៤។

សាច់ញាតិនេះតម្រូវឱ្យមានភស្តុតាងដោយផ្តល់ជាសក្ខីកម្មយ៉ាងលម្អិត ហើយភស្តុតាងនេះពុំត្រូវបានផ្តល់ឱ្យអង្គជំនុំជម្រះតុលាការកំពូលឡើយ។ អង្គហេតុដែលថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសហចៅក្រមស៊ើបអង្កេតទទួលយកនៅក្នុងសំណុំរឿង ០០២ ផ្អែកតាមបទដ្ឋាននៃភស្តុតាង*ជាសេចក្តីបញ្ជាក់ដំបូង* មិនមែនជាការសន្និដ្ឋានថា ជាការទទួលយកពាក្យសុំរបស់គាត់នៅក្នុងដំណាក់កាលបញ្ចប់នៃសំណុំរឿង ០០១ នោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានណាមួយដើម្បីបដិសេធចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលលើកឡើងថា ម្ចាស់បណ្តឹងសាទុក្ខនេះ មិនបានបង្ហាញឋានៈជាជនរងគ្រោះនៅក្នុងរឿងក្តីនេះទេ។

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ប៉ាន់ ប៊ុច* (E2/63)

៦០៤. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា នៅឆ្នាំ ១៩៧៨ គាត់បានទទួលរូបថតប្អូនថ្លៃប្រុសរបស់គាត់មួយសន្លឹក។ រូបថតត្រូវបានថតនៅមន្ទីរ ស ២១ និងបានបង្ហាញថា ប្អូនថ្លៃប្រុសរបស់គាត់ជាប់ខ្នោះ និងទទួលរងកាយវិកលកម្ម។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គាត់មានអារម្មណ៍បាក់ស្បាត និងតក់ស្លុតយ៉ាងខ្លាំង។

៦០៥. អង្គជំនុំជម្រះសាលាដំបូង បានបដិសេធចោលពាក្យសុំនេះដោយសារសំអាងហេតុដូចខាងក្រោម៖

> ប៉ាន់ ប៊ុច (E2/63) បានអះអាងថា ប្អូនថ្លៃប្រុសរបស់គាត់ឈ្មោះ ភ្លាំង ហួយ ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរ ស ២១ ប៉ុន្តែ មិនមានភស្តុតាងគាំទ្រចំពោះអំណះអំណាងនេះទេ[1236]។

៦០៦. នៅក្នុងបណ្តឹងសាទុក្ខ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានផ្តល់ភស្តុតាងបន្ថែមណាមួយដើម្បីគាំទ្រដល់ពាក្យសុំនោះទេ។ សហមេធាវីលើកទឡ្ហីករណ៍ថា ដោយហេតុថា

[1236] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១១០១ ("លើសនេះទៀត ភាពជាសាច់ញាតិតាមរយៈអាពាហ៍ពិពាហ៍តែឯងគឺជាមូលដ្ឋានមិនគ្រប់គ្រាន់សម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ (ផ្នែក៤.២.២)")។

"ការអះអាងរបស់ជនរងគ្រោះមានលក្ខណៈស៊ីសង្វាក់គ្នា អង្គហេតុដែលបានលើកឡើងដោយជនរងគ្រោះ មានភាពស្មោះត្រង់ច្បាស់លាស់"[1237]។ សហមេធាវីក៏បានលើកឡើងថាៈ

> តុលាការគប្បីធ្វើការពិចារណាទៅលើការលំបាករបស់ជនរងគ្រោះ ក្នុងការបង្ហាញភស្តុតាងអំពីការឃុំខ្លួនរបស់បងប្រុសរបស់គាត់[1238] នៅឯមន្ទីរ ស ២១ និងបង្ហាញនូវអង្គហេតុដែលឯកសារមួយចំនួនធំនៃមន្ទីរឃុំឃាំង បានបាត់បង់ និងបានបំផ្លិចបំផ្លាញ[1239]។

៦០៧. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជាសន្មតថា មានភស្តុតាងបង្ហាញពីអត្តសញ្ញាណ និងភាពជាសាច់ញាតិជាមួយជនរងគ្រោះផ្ទាល់ក៏ដោយ ក៏ការដែលម្ចាស់បណ្តឹងសាទុក្ខបានផ្អែកអំណះអំណាងរបស់ខ្លួនថា ជនរងគ្រោះផ្ទាល់ត្រូវបានដាក់នៅក្នុងមន្ទីរឃុំឃាំងធ្វើទារុណកម្ម និងប្រហែលជាត្រូវបានសម្លាប់នៅមន្ទីរ ស ២១ នោះ មិនបានផ្អែកលើការយល់ដឹងដោយផ្ទាល់ខ្លួននោះទេ ប៉ុន្តែ ផ្អែកតាមរយៈរូបថតដែលមិនស្គាល់ប្រភព និងមិនមាននៅក្នុងបច្ចុប្បន្ននេះទេ។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលពុំមានហេតុផលក្នុងការសង្ស័យទៅលើភាពពិតជាអត្តនោម័តនៃជំនឿរបស់ម្ចាស់បណ្តឹងសាទុក្ខ នៅក្នុងអង្គហេតុដែលលើកឡើងក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចទទួលយកជំនឿរបស់ម្ចាស់បណ្តឹងសាទុក្ខមកធ្វើជាភស្តុតាងបាននោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងដែលលើកឡើងថា មិនមានភស្តុតាងបង្ហាញថា ប្អូនថ្លៃប្រុសរបស់គាត់ គឺជាអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស ២១ នោះទេ។ ក្រៅពីនេះ អ្នកដាក់ពាក្យសុំមិនបានផ្តល់អង្គហេតុណាមួយដើម្បីគាំទ្រថា ចំណងពិសេសនៃក្តីស្រឡាញ់ ឬភាពនៅក្នុងបន្ទុករបស់ប្អូនថ្លៃ

---

[1237]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៧១។

[1238]ទោះបីជាឯកសារសំណៅដើមជាភាសាបារាំងឯកសារលេខ (F9), កថាខណ្ឌ ៧២ ប្រើពាក្យ "បងប្រុស"ក្តី ក៏របាយការណ៍របស់អង្គភាពជនរងគ្រោះស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩, ឯកសារលេខ E2/63/1 និងឯកសារផ្សេងៗទៀត (សេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ គី សៀនថៃ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៨, ឯកសារលេខ E2/63.1) បានបញ្ជាក់ច្បាស់ថា ជនរងគ្រោះដោយផ្ទាល់គឺជាប្អូនថ្លៃប្រុសរបស់អ្នកដាក់ពាក្យសុំ។

[1239]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៧២។

ប្រុសរបស់គាត់នោះទេ។ ដូចដែលបានកត់សម្គាល់ពីមុន ភាពជាសាច់ញាតិបែបនេះ មិនបាន អនុញ្ញាតឱ្យសន្និតថា មានភាពជិតស្និទ្ធពិសេស ឬភាពនៅក្នុងបន្ទុកនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលរកមិនឃើញសំអាងហេតុ ដើម្បីបដិសេធចោលសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងដែលលើកឡើងថា ម្ចាស់បណ្តឹងសាទុក្ខនេះមិនបានបង្ហាញ ឋានៈជាជនរងគ្រោះនៅក្នុងរឿងក្តីនេះទេ។

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ចាន់ យឿង* **(E2/70)**

៦០៨. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ឪពុកមារបស់គាត់ឈ្មោះ សុខ បុន ដែលអតីតជាប្រធានភូមិត្រូវបានចាប់ខ្លួន និងត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងនៅគុក សាលារៀង និងក្រោយមកត្រូវបានគេបញ្ជូនទៅឃុំឃាំងនៅមន្ទីរ ស ២១ ជាមួយនឹងជនប្រាំមួយនាក់ផ្សេងទៀត។ ក្រោយថ្ងៃរំដោះ ប្រពន្ធរបស់ សុខ បុន ឈ្មោះ នង់ សុខុន បានប្រាប់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីថា ឪពុកមារបស់គាត់ត្រូវបានគេសម្លាប់នៅមន្ទីរ ស ២១។

៦០៩. អង្គជំនុំជម្រះសាលាដំបូង បានបដិសេធចោលពាក្យសុំនេះដោយសារសំអាងហេតុដូចខាងក្រោម៖

> ចាន់ យឿង (E2/70) បានអះអាងថា ឪពុកមារបស់គាត់ឈ្មោះ សុខ ប៊ុន ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរ ស ២១។ ទោះបីជាអាចបញ្ជាក់អំពីភាពជាសាច់ញាតិក្តី អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទទួលស្គាល់ថា មិនមានភស្តុតាងបញ្ជាក់អំពីការឃុំខ្លួនជនរងគ្រោះផ្ទាល់នៅមន្ទីរស ២១ ទេ[1240]។

៦១០. នៅក្នុងសារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សរសហមេធាវី បានលើកឡើងដូចខាងក្រោមថា៖

[1240]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៨។

លោក សុខ ប៊ុន ដែលជាឪពុកមារបស់លោកស្រី[1241] គឺជាអតីតចៅហ្វាយស្រុកដ៏ល្អ នៅរមាសហែក ស្រុករវៀង ខេត្តព្រះវិហារ។ នៅដើមឆ្នាំ ១៩៧៨ មានការស្រាវជ្រាវរកអ្នកមានមុខតំណែងជាមេភូមិ ចៅហ្វាយស្រុក នៅក្នុងភូមិ ឃុំ ស្រុកខាងលើ ហើយត្រូវបានគេចាប់ខ្លួន និងបន្ទាប់មកបញ្ជូនទៅសាលារវៀង មុនពេលដែលបញ្ជូនទៅ ស ២១ នៅរាជធានីភ្នំពេញ។ នៅក្នុងអំឡុងពេលសវនាការ ឌុច បានទទួលស្គាល់ថា មានការបោសសម្អាតផ្ទៃក្នុងកើតឡើងមែន[1242]។

៦១១. នៅក្នុងសវនាការបណ្តឹងសាទុក្ខ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា "គ្មានភស្តុតាងណាបញ្ជាក់ថា បានឃើញរូបថតឪពុកមារបស់គាត់នៅមន្ទីរ ស ២១។ ក៏ប៉ុន្តែ ខ្ញុំសូមជម្រាបជូនថាព័ត៌មានដែលគាត់បានផ្តល់ឱ្យនោះ គឺគួរឱ្យជឿ គឺវាទាក់ទងជាមួយនឹងការបោសសម្អាតផ្ទៃក្នុង"[1243]។

៦១២. អង្គជំនុំជម្រះតុលាការកំពូលមិនអាចសន្និដ្ឋានថា ឪពុកមារបស់ម្ចាស់បណ្តឹងសាទុក្ខត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១ ដោយផ្អែកលើអ្វីដែលបានកើតឡើងចំពោះ "មេភូមិ និងចៅហ្វាយស្រុកមួយចំនួន" នោះទេ។ ការទទួលស្គាល់ជាទូទៅរបស់ជនជាប់ចោទអំពីការបោសសម្អាតផ្ទៃក្នុង[1244] និងជំនឿជឿជាក់របស់ម្ចាស់បណ្តឹងសាទុក្ខ មិនគ្រប់គ្រាន់សម្រាប់ការបង្ហាញអំពីភស្តុតាងនៃអង្គហេតុដែលតម្រូវនោះទេ ទោះបីជាជំនឿនេះមានភាពស្មោះត្រង់ក៏ដោយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានសំអាងហេតុដើម្បីបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចថា ម្ចាស់បណ្តឹងសាទុក្ខមិនមានលក្ខណៈសម្បត្តិជាដើមបណ្តឹងរដ្ឋប្បវេណីផ្អែកតាមវិធានផ្ទៃក្នុងនោះទេ។

---

[1241] ឯកសារបកប្រែភាសាអង់គ្លេសនៃបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៦៧ លើកឡើងខុសថា "ពូរបស់គាត់"។

[1242] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៦៧ ដល់ ៦៨។

[1243] ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/4.1 , ទំព័រ ៦៩ (បន្ទាត់៤ ដល់ ៥) ។

[1244] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៦៨ ("នៅក្នុងអំឡុងពេលសវនាការ ឌុច ទទួលស្គាល់ថា មានការបោះសម្អាតផ្ទៃក្នុងដូចនេះមែន")។

***ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សឹម ពៅ* (E2/71)**

៦១៣. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា បងថ្លៃប្រុសរបស់គាត់ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់នៅទួលស្លែងក្នុងឆ្នាំ ១៩៧៦។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គាត់មានជីវភាពលំបាក ដោយសារតែបច្ច័យនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្ត។

៦១៤. អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលពាក្យសុំនេះ ដោយសារសំអាងហេតុដូចខាងក្រោម៖

> សឹម ពៅ (E2/71) បានអះអាងថា បងថ្លៃប្រុសរបស់គាត់ឈ្មោះ ង៉ុយ ស្រេង ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់ នៅមន្ទីរ ស ២១។ ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន គាត់បានផ្តល់ប្រវត្តិរូបមួយដែលបានមកពីបណ្ណសាររបស់មន្ទីរ ស ២១។ ទោះបីជា ង៉ុយ ស្រេង ត្រូវបានឃុំខ្លួននៅមន្ទីរ ស ២១ ក្តី ក៏ភាពជាសាច់ញាតិតាមរយៈ អាពាហ៍ពិពាហ៍តែមួយនោះ មិនមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបង្ហាញអំពីចំណងនៃក្តីស្រលាញ់ ឬភាពនៅក្នុងបន្ទុកនោះទេ (ផ្នែក ៤.២.២)[1245]។

៦១៥. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់ភស្តុតាងណាមួយដែលបង្ហាញអំពីចំណងពិសេសនៃក្តីស្រឡាញ់ ឬ ភាពនៅក្នុងបន្ទុករបស់ជនរងគ្រោះផ្ទាល់នោះទេ។ ជាពិសេស គាត់មិនបានបង្ហាញថា ការបាត់បង់បងថ្លៃប្រុសរបស់គាត់ បានបង្កឱ្យមានព្យសនកម្មខាងសេដ្ឋកិច្ចចំពោះរូបគាត់នោះទេ។ ព្យសនកម្មបែបនេះមិនអាចត្រូវបានសន្មត ដោយគ្រាន់តែផ្អែកលើទំនាក់ទំនងអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ ប៉ុន្តែ ព្យសនកម្មបែបនេះតម្រូវឱ្យបង្ហាញអំពីអង្គហេតុរឹងមាំ ទាក់ទងនឹងផលប៉ះពាល់នៃមរណភាពរបស់ជនរងគ្រោះទៅលើសិទ្ធិបេតិកភណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខ។ ដោយសារតែមិនមានអង្គហេតុបែបនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានសំអាងហេតុណាមួយដើម្បីបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំ

[1245] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៩។

ជម្រះសាលាដំបូងដែលសម្រេចថា ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញឋានៈជាជនរងគ្រោះនៅក្នុងករណីនេះទេ។

*ពាក្យសុំរបស់ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ម៉ន សុធា* (E2/82)

៦១៦. ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងសាទុក្ខអះអាងថា ម្ដាយរបស់គាត់ដែលជាអតីតអ្នកការទូតត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង និងត្រូវបានសម្លាប់នៅមន្ទីរ ស ២១។ ម្ចាស់បណ្ដឹងសាទុក្ខទទួលរងការភិតភ័យ និងទុក្ខព្រួយ ដោយសារបច្ច័យនៃការប្រព្រឹត្តឧក្រិដ្ឋកម្មលើម្ដាយរបស់គាត់។

៦១៧. អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលពាក្យសុំនេះ ដោយសារសំអាងហេតុដូចខាងក្រោម៖

> ម៉ន សុធា (E2/82) បានអះអាងថា ម្ដាយរបស់គាត់ ដែលជាអតីតអ្នកការទូត និងសមាជិកគ្រួសារជាច្រើននាក់ផ្សេងទៀតរបស់គាត់ បានបាត់ខ្លួនក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញក្នុងខែ មេសា ឆ្នាំ ១៩៧៥។ ទោះបីជាចម្លើយរបស់គាត់ ទំនងជាអាចជឿជាក់បានក៏ដោយ ក៏ចម្លើយនេះមិនមានភស្តុតាងបង្ហាញអំពីការជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានរកឃើញថា មានពិរុទ្ធភាពនោះទេ[1246]។

៦១៨. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំទៅលើអង្គហេតុ ដោយមិនបានពិចារណាលើរូបថតរបស់ជនរងគ្រោះផ្ទាល់ដែលបានឃុំខ្លួននៅមន្ទីរ ស ២១ ដែលរូបថតនេះបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ[1247]។ នៅក្នុងបណ្ដឹងសាទុក្ខ ម្ចាស់បណ្ដឹងសាទុក្ខបានដាក់ភស្តុតាងបន្ថែមចំនួនពីរទៀត។ មីងរបស់ម្ចាស់បណ្ដឹងសាទុក្ខ បានសរសេរលិខិតជាលាយលក្ខណ៍អក្សរមួយច្បាប់ ដែលបញ្ជាក់អំពីភាពជាសាច់ញាតិរវាងម្ចាស់បណ្ដឹងសាទុក្ខ និងម្ដាយរបស់គាត់ឈ្មោះ សែម សុខលីន ដែលជាជនរងគ្រោះផ្ទាល់ និងបានអះអាងថា កាលពីខែ វិច្ឆិកា ឆ្នាំ ២០០៩ គាត់បានឃើញរូបថតរបស់

---

[1246]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៥៨។

[1247]បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៩៥។

សែម សុខលីន នៅមន្ទីរ ស ២១[1248]។ រូបថតនេះគឺជាវត្ថុតាងពីរបន្ថែមទៀតត្រូវបានដាក់នៅក្នុងសំណុំរឿង[1249]។

៦១៩. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភស្តុតាងបន្ថែមនេះ គឺគ្រប់គ្រាន់ដើម្បីបង្ហាញទំនាក់ទំនងរវាងម្ចាស់បណ្តឹងសាទុក្ខ និងឧក្រិដ្ឋកម្មដែល កាំង ហ្កេកអ៊ាវ ដែលជាអ្នកទទួលខុសត្រូវ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយអង្គជំនុំជម្រះទទួលស្គាល់ឋានៈជាជនរងគ្រោះរបស់ម្ចាស់បណ្តឹងសាទុក្ខនេះ។

*ពាក្យសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឃួន សារិន* (D25/11)

៦២០. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ឪពុកមារបស់គាត់ឈ្មោះ ខៀវ សាគួរ ដែលបានធ្វើការងារនៅស្ថានទូតជប៉ុនក្រោមរបប លន់ នល់ ត្រូវបានឃុំនៅមន្ទីរ ស ២១ និងត្រូវបានសម្លាប់នៅឆ្នាំ ១៩៧៦។

៦២១. អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលពាក្យសុំនេះ ដោយសារសំអាងហេតុដូចខាងក្រោមៈ

> ឃួន សារិន (D25/11) ដែលបានអះអាងដោយផ្អែកលើការចាប់ខ្លួន និងការសម្លាប់ឈ្មោះ ខៀវ សាគួរ ដែលគាត់ជាបុគ្គលិកម្នាក់របស់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសជប៉ុន។ ទោះបីជាមានភស្តុតាងដែលបង្ហាញអំពីការឃុំខ្លួន ខៀវ សាគួរ នៅមន្ទីរ ស ២១ ក្តី ក៏មិនមានឯកសារភស្តុតាងណាមួយបង្ហាញអំពីលក្ខណៈនៃភាពជាសាច់ញាតិជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ឬភស្តុតាងបង្ហាញអំពីចំណងពិសេសនៃក្តីស្រលាញ់ណាមួយនោះទេ។ ទោះបីជា កាំង ហ្កេកអ៊ាវ ហៅ ឌុច មិនបានជំទាស់ទៅនឹងពាក្យ

[1248] សេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ សាំង ថៃ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ F2/6.2។

[1249] រូបថត សែម សុខលីន ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១, ឯកសារលេខ F2/6.3។

សុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ក៏ដោយ ក៏អង្គជំនុំជម្រះបដិសេធពាក្យសុំនេះចោលដែរ[1250]។

៦២២. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងថា ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណី គឺជាក្មួយរបស់ជនរងគ្រោះ ហើយជនរងគ្រោះ គឺជាអ្នកដែលបានចិញ្ចឹមបីបាច់ថែរក្សាម្ចាស់បណ្ដឹងសាទុក្ខ ហើយបានចាត់ទុកដូចជាកូនប្រុសរបស់គាត់[1251]។ អំណះអំណាងរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងបណ្ដឹងសាទុក្ខ គឺមិនគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាចំពោះពាក្យសុំដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់នោះទេ។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលមិនតម្រូវជាចាំបាច់ឱ្យផ្ដល់ភស្តុតាងជាឯកសារក្ដីក៏ដោយ ក៏អង្គជំនុំជម្រះនៅតែត្រូវការភស្តុតាងជាសក្ខីកម្មក្នុងកម្រិតអប្បបរមា ដើម្បីបង្ហាញអំពីទំនាក់ទំនងរវាងម្ចាស់បណ្ដឹងសាទុក្ខជាមួយនឹងជនរងគ្រោះផ្ទាល់។ ហេតុដូច្នេះអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានសំអាងហេតុណាមួយដើម្បីបដិសេធសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចថា ម្ចាស់បណ្ដឹងសាទុក្ខនេះមិនបានបង្ហាញអំពីឋានៈជាជនរងគ្រោះនៅក្នុងរឿងក្ដីនេះទេ។

***ពាក្យសុំរបស់ ហៀត តឺជៅ* (E2/38)**

៦២៣. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ៣ បានលើកអំណះអំណាងទាក់ទងទៅនឹងការបដិសេធពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហៀត តឺជៅ (E2/38) នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[1252]។ ប៉ុន្ដែ អង្គជំនុំជម្រះតុលាការកំពូលសម្រេចមិនពិចារណា

---

[1250]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៤៩។

[1251]បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៩១ (ឯកសារដើមជាភាសារបារាំង, លេខ ERN 00613343, លើកឡើងមិនត្រឹមត្រូវថា ម្ចាស់បណ្ដឹងសាទុក្ខគឺជាឪពុកមារបស់ជនរងគ្រោះផ្ទាល់។ ម្ចាស់បណ្ដឹងសាទុក្ខអះអាងថា ជនរងគ្រោះផ្ទាល់ គឺជាឪពុកមារបស់គាត់។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ឯកសារខ្មែរដាក់នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨, ភាសាអង់គ្លេសដាក់នៅ ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសាលេខ D25/11)។

[1252]បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៧៧ ដល់ ៨០។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង ទំព័រ ២២៦។

លើបញ្ហាទាក់ទងនឹងអំណៈអំណាងនេះទេ ពីព្រោះមានវិការៈផ្នែកនីតិវិធីក្នុងបណ្តឹងសាទុក្ខ ដោយហេតុថា ពុំមានលិខិតប្រគល់សិទ្ធិរបស់មេធាវីដែលត្រូវតែភ្ជាប់ជាមួយនឹងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនេះ[1253] ហើយឈ្មោះពិត និងឈ្មោះហៅរបស់អ្នកដាក់ពាក្យសុំ ពុំបានបញ្ចូលនៅក្នុងបញ្ជីរាយនាមជាអ្នកបណ្តឹងសាទុក្ខ នៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខឡើយ[1254]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធអំណះអំណាងទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ហៀត តីដៅ (E2/38) ដោយផ្អែកលើវិធាន ១១១(២) នៃវិធានផ្ទៃក្នុង។

## ៦.ឃ.៤.បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ ស៊ីរ៉ាត

៦២៤. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ បានប្តឹងសាទុក្ខទៅកាន់អង្គជំនុំជម្រះតុលាការកំពូល តាងនាមឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ ស៊ីរ៉ាត ប្រឆាំងនឹងការលុបចោលឈ្មោះប្អូនថ្លៃស្រីរបស់គាត់ឈ្មោះ គីម សុវណ្ណារី និងកូនរបស់គាត់ (មិនស្គាល់ឈ្មោះ) នៅក្នុងសាលក្រម[1255]។

៦២៥. កាលពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងកែតម្រូវសាលក្រម និងស្នើសុំឱ្យបញ្ចូលឈ្មោះ គីម សុវណ្ណារី និងកូនរបស់គាត់នៅទំព័រ ២៣០ របស់សាលក្រមនៅក្នុងសំណៅជាភាសាអង់គ្លេស ខ្មែរ និងបារាំង[1256]។ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានសម្រេចលើសំណើសុំនេះ។

៦២៦. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា "ការខកខានក្នុងការដាក់ឈ្មោះរបស់ប្អូនថ្លៃស្រីរបស់លោក ជុំ ស៊ីរ៉ាត គឺផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំអង្គហេតុដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ និងកំហុសអង្គច្បាប់/វិធានផ្ទៃក្នុង ដោយរំលោភលើវិធាន ២១(១)(ក)

---

[1253] *ប្រៀបធៀប* ឯកសារលេខ E188/4.1 ជាមួយម្ចាស់ប្តឹងសាទុក្ខ D25/11។

[1254] សេចក្តីជូនដំណឹងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣, កថាខណ្ឌ ១ ដល់ ៧។

[1255] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ លើ ជុំ ស៊ីរ៉ាត, កថាខណ្ឌ ១ ដល់ ២។

[1256] សំណើសុំកែតម្រូវរបស់សហមេធាវីការពារក្តី, ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ E188/1។

និង(គ) វិធានផ្ទៃក្នុង ដែលនាំឱ្យសាលក្រមគ្មានសុពលភាព"[1257]។ សហមេធាវីលើកឡើងថា ការលុបឈ្មោះ គីម សុវណ្ណារី និងកូនរបស់គាត់ចេញពីបញ្ជី ប៉ុន្តែ បែរជាបញ្ចូលសមាជិកគ្រួសារមិនផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត គឺជាការផ្តល់ភាពមិនស្មើគ្នាដែលជាការរំលោភបំពានវិធាន ២១(១)(ក) និង (គ) នៃវិធានផ្ទៃក្នុង។

៦២៧. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងសាលក្រមថា៖

> ដោយសារតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ត្រូវបានទទួលយកដោយផ្អែកលើមូលដ្ឋានជាជនរងគ្រោះដែលជាសមាជិកគ្រួសារជិតស្និទ្ធ ក៏ជនរងគ្រោះផ្សេងទៀតដែលជាសមាជិកគ្រួសារសាច់ឆ្ងាយ ត្រូវបានបង្ហាញគ្រាន់តែទុកសម្រាប់ជាព័ត៌មានតែប៉ុណ្ណោះ។ នៅពេលពាក្យសុំផ្អែកទាំងស្រុងលើទំនាក់ទំនងទៅនឹងសមាជិកគ្រួសារសាច់ឆ្ងាយ អង្គជំនុំជម្រះនឹងពិចារណា ថាតើភស្តុតាងដែលមានបានបង្ហាញអំពីអត្ថិភាពនៃចំណងពិសេសនៃក្តីស្រលាញ់ ឬភាពនៅក្នុងបន្ទុក ដែរ ឬយ៉ាងណា[1258]។

៦២៨. ឋានៈដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជុំ ស៊ីវ៉ាត ត្រូវបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង នៅពេលបានបង្ហាញឱ្យឃើញនូវការចាប់ខ្លួន និងការឃុំខ្លួនសមាជិកគ្រួសារផ្ទាល់របស់គាត់នៅមន្ទីរ ស ២១។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មិនចាំបាច់ដើម្បីបង្ហាញភាពជាសាច់ញាតិ និង"ចំណងពិសេសនៃក្តីស្រឡាញ់" ដែលមានរវាងលោក ជុំ ស៊ីវ៉ាត ជាមួយនឹងបងថ្លៃស្រី និងកូនរបស់គាត់នោះទេ។

៦២៩. បណ្តឹងសាទុក្ខប្រឆាំងនឹងកំហុសបច្ចេកទេស (កំហុសសម្ភារៈ) ដែលមិនជាប់ពាក់ព័ន្ធនឹងអង្គច្បាប់ ឬអង្គហេតុ ស្ថិតនៅក្រៅវិសាលភាពនៃបណ្តឹងសាទុក្ខចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[1259] ហេតុដូច្នេះ បណ្តឹងសាទុក្ខនេះ ត្រូវបានបដិសេធថា មិនអាចទទួលយកបាន។ ប៉ុន្តែ

---

[1257] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ លើ ជុំ ស៊ីវ៉ាត, កថាខណ្ឌ ១១ ដល់ ១៤។

[1258] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១១២៣។

[1259] វិធាន ១០៤ នៃវិធានផ្ទៃក្នុង។

00798801



ដោយសារតែអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការលុបឈ្មោះ កឹម សុវណ្ណារី និងកូនរបស់គាត់ចេញពីបញ្ជីជនរងគ្រោះក្នុងសាលក្រម គឺជាកំហុសបច្ចេកទេស(កំហុសសម្ភារៈ) មួយនោះ អង្គជំនុំជម្រះតុលាការកំពូលកែតម្រូវកំហុសបច្ចេកទេស(កំហុសសម្ភារៈ)នេះ ដោយរួមបញ្ចូលឈ្មោះ កឹម សុវណ្ណារី និងកូនរបស់គាត់នៅក្នុងសាលក្រមវិញ។

# ៧.កំហុសដែលបានលើកឡើងទាក់ទងនៅនឹងសំណើទាមទារសំណង (បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និង ៣)

## ៧.ក.សេចក្តីបង្គាប់ដែលស្នើសុំដោយម្ចាស់បណ្តឹងសាទុក្ខ

៦៣០. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ពុំបានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពីសំណងឡើយ ពីព្រោះមានការជឿជាក់ថា ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាសំណងគ្រប់គ្រាន់[1260]។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីដែលទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខស្តីពីសំណង ដែលបានស្នើឡើងដោយម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីក្រុមដទៃទៀតត្រូវបានទទួលយកនោះ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ បានលើកសំណើថា ផលប្រយោជន៍ដែលទទួលបានពីសំណងណាមួយដែលត្រូវបានផ្តល់ដោយអង្គជំនុំជម្រះតុលាការកំពូល គួរតែផ្តល់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ផងដែរ ដែលពាក្យសុំរបស់ពួកគាត់ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងបណ្តឹងសាទុក្ខ[1261]។

៦៣១. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានលើកនូវទឡ្ហីករណ៍យ៉ាងទូលំទូលាយស្តីពីសំណង។ នៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន ព្រមទាំងនៅក្នុងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមស្តីពីសំណង ដើមបណ្តឹងរដ្ឋប្បវេណីក្រុមនេះ បានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យច្រានចោល នូវការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើទាមទារសំណងទាំងប្រាំបួនចំណុចរបស់ខ្លួន ហើយសុំឱ្យផ្តល់សំណងទាំងអស់[1262]នោះវិញ។

---

[1260]សារណាបន្ថែមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ ចំពោះសេចក្តីជូនដំណឹងអំពីគោលបំណង, កថាខណ្ឌ ៤ ដល់ ៥។

[1261]ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារ F1/4.1, ទំព័រ ៨ (បន្ទាត់ ១៣ ដល់ ១៨)។

[1262]សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ២) លើសាលក្រមទាក់ទិននឹងសំណង ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ E188/14, កថាខណ្ឌ ៩។ បណ្តឹងសាទុក្ខស្តីពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៨ និង ១៣០។

៦៣២. ការផ្តោតជាសំខាន់នៃបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ទាក់ទងទៅនឹងភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធ។ ទោះបីជាយ៉ាងណា ក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមនេះ បានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្តល់ឱ្យតាមការទាមទារសំណងពីដំបូងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានបដិសេធនៅក្នុងសាលក្រម[1263]។

## ៧.២.អំណះអំណាងទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី

៦៣៣. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិនិត្យទៅលើអំណះអំណាងទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបញ្ហាចំនួនបីខាងក្រោមនេះ៖

(ក) ថាតើ អ.វ.ត.ក មានអំណាចក្នុងការបង្កើតនូវវិធានការផ្តល់សំណងដែលទាមទារឱ្យមានជំនួយពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអាចឱ្យអនុវត្តទៅបាន ដែរ ឬយ៉ាងណា។

(ខ) ថាតើ ភាពក្រីក្រនៅពេលបច្ចុប្បន្នរបស់ កាំង ហ្គេកអ៊ាវ រារាំង អ.វ.ត.ក មិនឱ្យចេញសេចក្តីបង្គាប់ឱ្យសងសំណង ដែរ ឬយ៉ាងណា ពីព្រោះការអនុវត្តសេចក្តីបង្គាប់បែបនេះ តម្រូវឱ្យ កាំង ហ្គេកអ៊ាវ មានមធ្យោបាយខាងហិរញ្ញវត្ថុ។ និង

(គ) ថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដែរ ឬយ៉ាងណា ការដែលខ្លួនបានដាក់បញ្ចូលជាក្រុមចំពោះសំណើទាមទារសំណង និងសម្រេចបដិសេធសំណើទាំងនោះ ដោយពុំបានពន្យល់ហេតុផលឱ្យបានច្បាស់លាស់ថា សំណើមួយណាដែលត្រូវលើកយកមកដោះស្រាយចំពោះក្រុមណាមួយនោះ។

៦៣៤. បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវលើកយកមកដោះស្រាយនូវសំណើទាមទារសំណងជាក់លាក់របស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដែលត្រូវបានបញ្ជាក់ជាថ្មីនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងបណ្តឹងសាទុក្ខ។

---

[1263] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣ ឯកសារខ្មែរដាក់ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ E188/4, កថាខណ្ឌ ២៦, ២៧។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣៖ កថាខណ្ឌ ១០៧ ដល់ ១០៨។

## ៧.២.១.សារណា

៦៣៥. ជាការសង្កេតទូទៅ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានកត់សម្គាល់ថា ដោយមិនគិតពីការផ្លាស់ប្តូររដ្ឋាភិបាលឡើយ រដ្ឋត្រូវទទួលខុសត្រូវក្នុងការផ្តល់សំណង[1264]។ ដោយហេតុថា ព្រះរាជាណាចក្រកម្ពុជាគឺជា រដ្ឋភាគីរបស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្មរបស់អង្គការសហប្រជាជាតិ[1265]ដែលកតិកាសញ្ញា និងអនុសញ្ញាខាងលើនេះ តម្រូវឱ្យរដ្ឋភាគីនេះធានានូវដំណោះស្រាយប្រកបដោយប្រសិទ្ធិភាពសម្រាប់ជនរងគ្រោះ នៃការរំលោភសន្ធិសញ្ញានីមួយៗនេះ ដូច្នេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចតាមផ្លូវច្បាប់ ក្នុងការឆ្លើយតបចំពោះសិទ្ធិទទួលបានការទូទាត់សំណងដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ[1266]។ ទោះបីជាមានការទទួលស្គាល់ថា វិសាលភាពនៃយុត្តាធិការរបស់ អ.វ.ត.ក ពុំបានបញ្ចូលនូវអំណាចក្នុងការចេញសេចក្តីបង្គាប់ឱ្យសងសំណងដែលដាក់កាតព្វកិច្ចដល់រាជរដ្ឋាភិបាលកម្ពុជាក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ អះអាងថា អ.វ.ត.ក មិនត្រូវបានរារាំងមិនឱ្យចេញសេចក្តីបង្គាប់ឱ្យសងសំណងដែលតម្រូវឱ្យមានការជួយគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងទម្រង់"ការគាំទ្រមិនមែនហិរញ្ញវត្ថុ និងផ្នែករដ្ឋបាល ដែលមិនមែនជាការរួមវិភាគទានហិរញ្ញវត្ថុ"ឡើយ[1267] ដោយសារតែជំនួយបែបនេះគឺជា "ភារកិច្ចទូទៅរបស់រដ្ឋក្នុងការយកចិត្តទុកដាក់អំពីតម្រូវការរបស់ប្រជាជនខ្លួន"។ ទោះបីជាពុំមានការពន្យល់បន្ថែមក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ក៏បានលើកទឡ្ហីករណ៍ផងដែរថា អ.វ.ត.ក អាចធ្វើហួសពីអណត្តិរបស់ខ្លួនទាក់ទិននឹងការផ្តល់នូវសំណង យោងទៅលើ "បទប្បញ្ញត្តិស្តីពីការរឹបអូសទ្រព្យសម្បត្តិមិនស្របច្បាប់ ឬទទួលបានពីការប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ នៅក្នុងច្បាប់ស្តីពីបង្កើត អ.វ.ត.ក"[1268]។

---

[1264]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ២១។

[1265]បណ្តឹងសាទុក្ខស្តីពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ២២ ដល់ ២៣។

[1266]បណ្តឹងសាទុក្ខស្តីពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ២៥។

[1267]បណ្តឹងសាទុក្ខស្តីពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ កថាខណ្ឌ ២៥។

[1268]បណ្តឹងសាទុក្ខស្តីពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៩៨។

៦៣៦. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ អះអាងបន្ថែមទៀតថា ភាពក្រីក្ររបស់ កាំង ហ្គេកអ៊ាវ មិនមែនជាឧបសគ្គរារាំង អ.វ.ត.ក មិនឱ្យចេញសេចក្តីបង្គាប់ឱ្យសងសំណងនោះឡើយ[1269]។ ទោះបីជាការផ្តល់សំណងត្រូវបានធ្វើឡើងប្រឆាំងនឹងទណ្ឌិត និងជាបន្ទុករបស់ទណ្ឌិត”[1270] ក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ លើកឡើងថា សេចក្តីបង្គាប់ឱ្យសងសំណងនេះត្រូវតែធ្វើឡើងដោយពុំគិតអំពីស្ថានភាពហិរញ្ញវត្ថុរបស់ កាំង ហ្គេកអ៊ាវ ឡើយ ហើយសេចក្តីបង្គាប់នេះមិនគួរត្រូវបានបដិសេធ ដោយផ្អែកតែទៅលើមូលដ្ឋាននៃប្រភពហិរញ្ញវត្ថុមិនជាក់លាក់នោះឡើយ[1271]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ កត់សម្គាល់ថា ទាក់ទិននឹងបញ្ហានេះ ទោះបីជា កាំង ហ្គេកអ៊ាវ ទំនងជាពុំមានទ្រព្យសម្បត្តិអ្វីនៅពេលបច្ចុប្បន្នក៏ដោយ ក៏ត្រូវមានការស៊ើបអង្កេតឱ្យបានហ្មត់ចត់ទៅលើស្ថានភាពហិរញ្ញវត្ថុ ដែលអាចរកឃើញនូវទ្រព្យសម្បត្តិ ឬក៏គាត់អាចទទួលបានប្រាក់ចំណូលពីការបោះពុម្ពផ្សាយ ឬពីប្រភពផ្សេងៗទៀត នៅពេលអនាគត[1272]។

៦៣៧. ផ្អែកតាមមូលដ្ឋានជារួម នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងសំណើទាមទារសំណងទាំងអស់ដែលត្រូវបានបដិសេធ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ អះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារតែការសង្ខេប និងបញ្ចូលគ្នានូវសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយពុំបានធ្វើការបញ្ជាក់ឱ្យបានច្បាស់ ថាតើសំណើមួយណាដែលខ្លួនធ្វើការពិចារណានៅត្រង់កថាខណ្ឌណាមួយនោះ ដូច្នេះហើយជាការរំលោភទៅលើសិទ្ធិទទួលបាននូវសេចក្តីសម្រេចដែលមានសំអាងហេតុដូចដែលមានការអនុវត្តជាអន្តរជាតិ និងមានការធានានៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលចំណុចទាំងនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ដោយអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក[1273]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានអះអាងថា ការផ្តល់

---

[1269]ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/4.1, ទំព័រ ៤៣ (បន្ទាត់ ៣ ដល់ ៤)។

[1270]វិធាន ២៣(១១) នៃវិធានផ្ទៃក្នុង។

[1271]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ២៦។

[1272]ប្រតិចារឹកថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារ F1/4.1, ទំព័រ ៤៣ (បន្ទាត់ ៤ ដល់ ៨)។

[1273]បណ្តឹងសាទុក្ខស្តីពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ២៩ ដល់ ៤៤។

សំអាងហេតុដែលមានលក្ខណៈពុំគ្រប់គ្រាន់ និងពេញលេញពីសំណាក់អង្គជំនុំជម្រះសាលាដំបូង មិនត្រឹមតែរំលោភលើសិទ្ធិសារវន្តរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការទទួលបានសេចក្ដីសម្រេចមានសំអាងហេតុប៉ុណ្ណោះទេ ថែមទាំងបានរារាំងដល់ការពិនិត្យឡើងវិញ នៅក្នុងដំណាក់កាលបណ្ដឹងសាទុក្ខប្រកបដោយភាពត្រឹមត្រូវ និងទូលំទូលាយពីសំណាក់អង្គជំនុំជម្រះតុលាការកំពូលទៀតផង[1274]។

## ៧.ខ.២.ការពិចារណា

### *៧.ខ.២.ក.សំណងរដ្ឋប្បវេណីនៅក្នុងក្របខណ្ឌច្បាប់ អ.វ.ត.ក*

៦៣៨. ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីតែងតែផ្អែកទៅលើឯកសារសំអាងផ្លូវច្បាប់អន្តរជាតិផ្សេងៗជាច្រើននៅក្នុងសារណារបស់ខ្លួន នេះជាការសមស្របដែលត្រូវគូសបញ្ជាក់ជាបឋមអំពីក្របខណ្ឌគតិយុត្ត ដែលអាចអនុវត្តបានចំពោះសំណងនៅចំពោះមុខ អ.វ.ត.ក ដើម្បីធ្វើការវាយតម្លៃអំពីវិសាលភាពដែលឯកសារសំអាងផ្លូវច្បាប់ទាំងនេះពាក់ព័ន្ធ។

៦៣៩. ដូចដែលបានកត់សម្គាល់យ៉ាងត្រឹមត្រូវ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[1275] ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក រួមមានសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមជាភាគីនៅក្នុងដំណើរការជំនុំជម្រះ ក្នុងរឿងព្រហ្មទណ្ឌលើជនជាប់ចោទ និងសិទ្ធិក្នុងការដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងផ្លូវចិត្ត និងសម្ភារភាព[1276]។ ចំពោះសិទ្ធិក្នុងការចូលរួម ត្រូវបានបញ្ញត្តិយ៉ាងទូលំទូលាយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ និងនៅក្នុងវិធានផ្ទៃក្នុងចំពោះបញ្ហាសំណងវិញ វិធានផ្ទៃក្នុងគឺជាក្របខណ្ឌគតិយុត្តដែលមានលក្ខណៈច្បាស់លាស់ជាង។ នៅក្នុងបញ្ហានេះ បទប្បញ្ញត្តិជាមូលដ្ឋាន គឺវិធាន ២៣(១១) និង (១២) នៃវិធានផ្ទៃក្នុងដែលចែងថា ៖

---

[1274] បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៣០ ដល់ ៣៥, ៣៩។

[1275] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៦០។

[1276] វិធាន ២៣(១) នៃវិធានផ្ទៃក្នុង។

(១១) យោងទៅលើមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ អង្គជំនុំជម្រះ អាចសម្រេចផ្តល់ឱ្យតែសំណងផ្លូវចិត្ត និងជាសមូហភាពទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ការផ្តល់សំណងនេះត្រូវធ្វើឡើងប្រឆាំងទៅនឹងទណ្ឌិត និងជាបន្ទុករបស់ទណ្ឌិត។

(១២) ការផ្តល់សំណងអាចធ្វើឡើងក្រោមរូបភាពដូចខាងក្រោម ៖

ក-ការបង្គាប់ឱ្យបោះពុម្ពផ្សាយសាលក្រម ឬសាលដីកានៅក្នុងសារព័ត៌មានសមស្របណាមួយ ដែលការចំណាយជាបន្ទុករបស់ទណ្ឌិត។

ខ-ការបង្គាប់ឱ្យផ្តល់មូលនិធិដល់សកម្មភាព ឬ សេវាកម្មមិនរកប្រាក់ចំណេញណាមួយ ដែលមានគោលបំណងផ្តល់ប្រយោជន៍ដល់ជនរងគ្រោះ។ ឬ

គ-ទម្រង់ដទៃទៀតនៃសំណងដែលមានលក្ខណៈសមរម្យ និងប្រហាក់ប្រហែល។

៦៤០. បន្ទាប់ពីការចេញសាលដីកាស្ថាពរ "ការអនុវត្តការជួសជុលសំណង ត្រូវធ្វើតាមគំនិតផ្តួចផ្តើមរបស់ដើមបណ្តឹងរដ្ឋប្បវេណី"[1277]។

៦៤១. ដោយពង្រីកនូវទស្សនឱ្យកាន់តែទូលំទូលាយទៀតនោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សញ្ញាណនៃសំណងនៅចំពោះមុខ អ.វ.ត.ក កើតចេញពីប្រភពពីរ គឺក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់បណ្តឹងរដ្ឋប្បវេណី[1278] និងច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីសំណងដែលថ្មីៗនេះ ត្រូវបានយកមកអនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ[1279]។ ទោះបីជាយ៉ាងណាក៏ដោយ ភាពពាក់ព័ន្ធទៅនឹងបណ្តឹងរដ្ឋប្បវេណី និង

---

[1277] វិធាន ១១៣(១) នៃវិធានផ្ទៃក្នុង។

[1278] មាត្រា ១៣ ដល់ ២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

[1279] *សូមមើល ឧទា.* មាត្រា ៧៥ នៃលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងមាត្រា ២៥ នៃលក្ខន្តិកៈនៃតុលាការពិសេសសម្រាប់លីបង់ ("STL")។

សំណងរបស់ច្បាប់កម្ពុជា និងរបស់គោលការណ៍នានា ដែលបានដកស្រង់ចេញពីលិខិតុបករណ៍ ឬយុត្តិសាស្ត្រអន្តរជាតិ នៅមានកម្រិតនៅឡើយ ពីព្រោះវិធានផ្ទៃក្នុងកំណត់ច្បាស់លាស់អំពីរបបសំណងជាក់លាក់ដែលសមស្របទៅតាមអណត្តិ និងយន្តការ*ពិសេសខុសប្លែកពីគេ*របស់ អ.វ.ត.ក។

៦៤២. ច្បាប់កម្ពុជាបានទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទាមទារសំណងចំពោះព្យសនកម្មដែលខ្លួនបានទទួលរង។ ក្នុងការកំណត់អំពីគោលបំណងទូទៅនៃបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា បណ្តឹងរដ្ឋប្បវេណី មានគោលបំណង"ជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជំងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួលរង"[1280]។ បណ្តឹងរដ្ឋប្បវេណីដែលទាមទារការជួសជុលព្យសនកម្មនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក៏ដូចជាករណីនៅចំពោះមុខ អ.វ.ត.ក ដែរ ត្រូវបានកម្រិតចំពោះតែព្យសនកម្មដែលជា "ផលវិបាកផ្ទាល់នៃបទល្មើស" ជាព្យសនកម្មផ្ទាល់ខ្លួន និង "បានកើតឡើង និងមាននៅក្នុងពេលបច្ចុប្បន្ន"[1281]។

៦៤៣. មានភាពខុសគ្នាជាច្រើនរវាងសំណងជំងឺចិត្តនៅ អ.វ.ត.ក និងការជួសជុលព្យសនកម្មនៅក្នុងច្បាប់ជាតិ។ យោងតាមច្បាប់ជាតិ វិសាលភាពនៃបណ្តឹងរដ្ឋប្បវេណី មានភាពទូលំទូលាយគួរឱ្យកត់សម្គាល់។ ដើមបណ្តឹងរដ្ឋប្បវេណី អាចទាមទារសំណងព្យសនកម្មចំពោះក្រុមជនដែលមានការទទួលខុសត្រូវ ដែលរួមមាន ចារី ប៉ុន្តែមិនកម្រិតត្រឹមតែចារីនេះឡើយ[1282]។

[1280]មាត្រា ២(៣) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ។

[1281]មាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ។

[1282]មាត្រា ២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ (ដែលចែងថាបណ្តឹងរដ្ឋប្បវេណីអាច ធ្វើឡើងប្រឆាំងនឹងជនទាំងអស់ដែលត្រូវជួសជុលព្យសនកម្មបណ្តាលមកពីបទល្មើសរួមមាន៖ ចារីអ្នកផ្តើមគំនិតអ្នកសមគំនិត និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី)។ ជាលទ្ធផលនៅកម្រិតជាតិការជួសជុលព្យសនកម្មក៏អាចត្រូវបានបង្គាប់ ទៅលើអ្នកទទួលខុសត្រូវរដ្ឋប្បវេណីជាជាងជនជាប់ចោទផងដែរ។ មាត្រា ២៨១ (កំណត់និយមន័យអ្នកទទួល ខុសត្រូវរដ្ឋប្បវេណីជា "បុគ្គលគ្រប់រូបដោយអនុវត្តតាមច្បាប់ដែលត្រូវតែជួសជុលព្យសនកម្មដែលបណ្តាលឲ្យមានដល់ជនរងគ្រោះនៃបទល្មើស")

យោងតាមរបបរបស់ អ.វ.ត.ក ការផ្តល់សំណងនេះ ត្រូវធ្វើឡើងប្រឆាំងនឹងទណ្ឌិត[1283]។ តុលាការជាតិមានសមត្ថកិច្ចក្នុងការបង្គាប់ឱ្យជួសជុលសំណងព្យសនកម្មក្នុងលក្ខណៈទូលាយ ដែលមានដូចជា សំណងជំងឺចិត្តដែលធ្ងន់ធ្ងរមទៅនឹងព្យសនកម្មដែលទទួលរង ការសង ទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ និងការធ្វើឱ្យដូចសភាពដើមវិញនូវទ្រព្យ សម្បត្តិដែលគេបំផ្លិចបំផ្លាញ ឬធ្វើឱ្យខូចខាត[1284]។ នៅក្នុងការប្រៀបធៀបរវាងវិធានផ្ទៃក្នុង និងច្បាប់ជាតិឃើញថា វិធានផ្ទៃក្នុងបានកំណត់អំពីសំណងក្នុងលក្ខណៈជាសមូហភាព និងផ្លូវ ចិត្ត ដែលវិធានការទាក់ទងនឹងសំណងប្រភេទនេះពុំមានឡើយនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧[1285]។ ដូច្នេះ បណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក មិនត្រូវបានកម្រិតដោយអាជ្ញា យុកាលដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឡើយ[1286]។ ជាចុងក្រោយ ភាពខុសគ្នាដែលកើត មានរវាងរបបទាំងពីរនេះ គឺពាក់ព័ន្ធនឹងលទ្ធភាពក្នុងការដាក់បណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ តុលាការរដ្ឋប្បវេណី ដែលមានចែងនៅក្នុងច្បាប់ជាតិ[1287]ដែលចំណុចនេះពុំមានឡើយសម្រាប់ ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក។

៦៤៤. ដូច្នេះ ទោះបីជារបបផ្តល់សំណងដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង មានទម្រង់ស្រដៀងគ្នា ទៅនឹងសំណង ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ក៏ដោយ ក៏អង្គ ជំនុំជម្រះសាលាដំបូងយល់ឃើញយ៉ាងត្រឹមត្រូវថា បទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងដើមបណ្តឹង រដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក មានលក្ខណៈខុសគ្នាពីបទបញ្ញត្តិទាំងឡាយនៅក្នុងច្បាប់ ជាតិដែរ ហើយមិនអាចអនុវត្តតាមដោយផ្អែកតាមរយៈភាពស្រដៀងគ្នាបានឡើយ[1288]។ ការ

---

និងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ (ដែលចែងថាពាក្យបណ្តឹងរបស់ដើម បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានសម្រេចប្រឆាំងនឹងជនជាប់ចោទ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី)។

[1283]វិធាន ២៣(១១) នៃវិធានផ្ទៃក្នុង។

[1284]មាត្រា ១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ។

[1285]វិធាន ២៣(១)(ខ) និង ២៣(១១) នៃវិធានផ្ទៃក្នុង។

[1286]មាត្រា ២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

[1287]មាត្រា ២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

[1288]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៦១។

កត់សម្គាល់នេះ គឺមានសុពលភាពជាពិសេសទាក់ទិននឹងរបបផ្តល់សំណងរដ្ឋប្បវេណី ដែលមានលក្ខណៈខុសប្លែកពីវិធានផ្ទៃក្នុងជាច្រើនចំណុច។ ដូចដែលបានកត់សម្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង "ការដកចេញបែបនេះពីច្បាប់ជាតិត្រូវបានចាត់ទុកថាចាំបាច់ ដោយគិតអំពី ចំនួនដ៏ច្រើននៃដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវរំពឹងទុក នៅចំពោះមុខ អ.វ.ត.ក និងផលវិបាកដែលមិនអាចចៀសផុត ក្នុងការកំណត់បរិមាណទៅលើវិសាលភាពទាំងមូលនៃការបាត់បង់ ដែលក្រុមជនរងគ្រោះបានទទួលរង ដោយសារតែក្រុមនេះមានភាពមិនច្បាស់លាស់"[1289]។ លើសពីនេះទៀត ជាការចាំបាច់ ក្នុងការបំពេញអណត្តិរបស់ខ្លួនក្នុងការវិនិច្ឆ័យឧក្រិដ្ឋកម្មអន្តរជាតិ ដែលការចោទប្រកាន់អំពីឧក្រិដ្ឋកម្មទាំងនេះមិនអាចធ្វើទៅបានក្នុងរយៈពេលជាច្រើនឆ្នាំនោះ ដូច្នេះសំណងនៅចំពោះមុខ អ.វ.ត.ក ជាចាំបាច់ត្រូវធ្វើឡើងក្នុងគោលបំណងជានិមិត្តរូប ជាជាងការផ្តល់ជាសំណងជំងឺចិត្ត[1290] ដោយភ្ជាប់ជាមួយនឹងសិទ្ធិទទួលបានដែលត្រូវបានសម្រេចដោយផ្អែកទៅលើមូលដ្ឋានសមធម៌ ជាជាងផ្អែកទៅតាមរូបមន្តផ្តល់សំណងរដ្ឋប្បវេណី។

៦៤៥. ពាក់ព័ន្ធនឹងច្បាប់អន្តរជាតិ សិទ្ធិក្នុងការទទួលបានសំណងត្រូវបានលើកឡើងតាំងពីយូរលុងណាស់មកហើយនៅក្នុងសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍នៅក្នុងរឿងក្តី *Chorzow Factory* ដែលបានសម្រេចថា:

> "គឺជាគោលការណ៍ច្បាប់អន្តរជាតិ ហើយក៏ជាទស្សនទានទូទៅរបស់ច្បាប់ដែលថា ការរំលោភបំពានណាមួយលើកិច្ចសន្យា គឺជាប់កាតព្វកិច្ចក្នុងការសងសំណង"[1291]។

[1289]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១១៤៤។

[1290]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១១៤៤។

[1291]រឿងក្តីពាក់ព័ន្ធនឹង *Factory at Chorzow* (*ប្រទេសអាល្លឺម៉ង់ ទល់នឹង ប្រទេសប៉ូឡូញ*) សាលក្រម (បណ្តឹងទាមទារសំណង) (អង្គសេចក្តី), តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍, ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩២៨, PCIJ ស៊េរី ក, លេខ ១៧, កថាខណ្ឌ ៧៣។

តុលាការអចិន្ត្រៃយ៍បញ្ជាក់បន្ថែមទៀតថាៈ "តាមលទ្ធភាពដែលអាចធ្វើទៅបាន ការសងសំណងត្រូវលុបបំបាត់នូវរាល់ផលវិបាកនៃអំពើខុសច្បាប់ និងស្តារឡើងវិញនូវស្ថានភាពដែលអាចនឹងកើតមាន ប្រសិនបើអំពើនោះមិនត្រូវបានប្រព្រឹត្តឡើងទេនោះ"[1292]។

៦៤៦. យោងតាមសាលក្រមដែលមានលក្ខណៈលេចធ្លោជាងគេនេះ គោលការណ៍អន្តរជាតិត្រូវបានបង្កើតឡើងថា ការរំលោភបំពានណាមួយនឹងត្រូវបានដោះស្រាយ *ទាំងស្រុង* ប្រសិនបើអាចធ្វើទៅបានតាមគោលការណ៍ *restitutio in integrum* ដែលជាការស្តារឡើងវិញនូវស្ថានភាពផ្លូវច្បាប់ដែលមានពីមុន។ ដោយផ្អែកតាមគំនិតយោបល់ថ្មីៗនេះ តុលាការយុត្តិធម៌អន្តរជាតិបានសម្រេចថា គោលការណ៍នេះអាចអនុវត្តបានផងដែរ រវាងរដ្ឋជាមួយនឹងបុគ្គល[1293]។

៦៤៧. គោលការណ៍នេះដែលបានបង្កើតឡើងនៅក្នុងបរិបទនៃការទទួលខុសត្រូវរបស់រដ្ឋ ត្រូវបានពន្លាតការអនុវត្តរបស់ខ្លួនក្នុងច្បាប់ស្តីពីសិទ្ធិមនុស្ស[1294]។ មាត្រា ៨ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស បញ្ជាក់ថា បុគ្គលណាក៏ដោយ ត្រូវមានសិទ្ធិក្នុងការទទួលបានសំណងប្រកបដោយប្រសិទ្ធភាព តាមរយៈតុលាការជាតិដែលមានសមត្ថកិច្ច ចំពោះអំពើរំលោភលើសិទ្ធិសារវន្តរបស់បុគ្គលនោះ។ ដូចគ្នានេះដែរ សន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សជាច្រើន បានរួមបញ្ចូលបទប្បញ្ញត្តិជាក់លាក់នានា ដែលបញ្ជាក់ពីសិទ្ធិក្នុងការទទួលបាននូវសំណងប្រកបដោយប្រសិទ្ធភាព សម្រាប់រាល់បុគ្គលដែលសិទ្ធិរបស់ខ្លួនមានចែងក្នុងសន្ធិសញ្ញានេះ ត្រូវបានរំលោភបំពាន ។ មាត្រា ២(៣) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតម្រូវឱ្យរដ្ឋជាភាគីធ្វើការធានាថា សំណងប្រកបដោយប្រសិទ្ធភាពត្រូវបានផ្តល់ឱ្យបុគ្គលណាដែល

---

[1292] *Chorzow Factory,* សាលក្រម, (បណ្តឹងទាមទារសំណងអង្គសេចក្តី) (អង្គសេចក្តី), កថាខណ្ឌ ១២៥។

[1293] *ផលវិបាកនៃការសាងសង់ជញ្ជាំងនៅក្នុងទឹកដីដែលត្រូវត្រួតត្រាដោយប៉ាឡេស្ទីន* មតិប្រឹក្សា តុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៤, របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិ (២០០៤) កថាខណ្ឌ ១៥២ ដល់ ១៥៣ (សម្រេចថា ប្រទេសអ៊ីស្រាអែលមានកាតព្វកិច្ចធ្វើសំណងចំពោះព្យសនកម្មដែលកើតមានចំពោះនីតិបុគ្គល និងរូបវន្តបុគ្គលទាំងអស់ ដោយប្រគល់មកវិញនូវទ្រព្យសម្បត្តិដែលបានរឹបអូស ឬដោយផ្តល់សំណងជាប្រាក់កាសដល់បុគ្គលដែលទទួលរងព្យសនកម្ម ក្នុងករណីមិនអាចប្រគល់ទ្រព្យសម្បត្តិទាំងនោះមកវិញ)។

[1294] *សូមមើល* ព្រឹត្តប័ត្រនិពន្ធដោយ Dinah Shelton, *សំណងដែលមាននៅក្នុងច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ,* បោះពុម្ពលើកទីពីរ, ចេញផ្សាយដោយសាកលវិទ្យាល័យ Oxford ឆ្នាំ ២០០៦, ទំព័រ ១១៣ *និងទំព័របន្តបន្ទាប់ទៀត*។

សិទ្ធិរបស់ខ្លួនត្រូវបានរំលោភ[1295]។ ប្រហាក់ប្រហែលគ្នានេះដែរ សិទ្ធិក្នុងការទទួលបាននូវសំណង ត្រូវបានបញ្ជាក់នៅក្នុងអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ពណ៌សម្បុរ[1296] អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[1297] ពិធីសារដែលជាជម្រើសចំពោះអនុសញ្ញាស្ដីពីសិទ្ធិរបស់កុមារក្នុងការលក់កុមារធ្វើសញ្ចារកម្ម និងការថតរូបភាពអាសអាភាស[1298] និងអនុសញ្ញាស្ដីពីសិទ្ធិមនុស្សប្រចាំតំបន់ដូចជា តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (ECHR)[1299]និងអនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស (ACHR)[1300]។

---

[1295]មាត្រា២(៣) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ចែងថា "បុគ្គលណាដែលសិទ្ធិ ឬសេរីភាពរបស់ខ្លួនដែលត្រូវបានទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ ត្រូវបានរំលោភបំពាន ត្រូវទទួលបាននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព" និងថា រដ្ឋជាភាគីនីមួយៗ ត្រូវ"បង្កើតលទ្ធភាពនៃដំណោះស្រាយតុលាការ" និង "ធានាថា អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តដំណោះស្រាយនេះនៅពេលទទួលបានការអនុញ្ញាត")។ *សូមមើលផងដែរ* មាត្រា៩(៥) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ដោយចែងថា "បុគ្គលណាដែលជាជនរងគ្រោះនៃការចាប់ខ្លួន ឬការឃុំខ្លួនដោយខុសច្បាប់ត្រូវមានសិទ្ធិទទួលបានសំណងដែលអាចអនុវត្តបាន")។ គណកម្មាធិការសិទ្ធិមនុស្ស មតិយោបល់ទូទៅលេខ ៣១ លក្ខណៈនៃកាតព្វកិច្ចផ្លូវច្បាប់ទូទៅចំពោះរដ្ឋភាគីនៃកតិកាសញ្ញា ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៤, CCPR/C/21/Rev.1/Add. 13, កថាខណ្ឌ ១៥ ("មាត្រា ២ កថាខណ្ឌ ៣ នៃ(កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ) ចែងតម្រូវថា ក្រៅពីការផ្ដល់ការការពារដោយប្រសិទ្ធភាពលើសិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញា រដ្ឋភាគីត្រូវធានាថាជនទាំងឡាយត្រូវមានសិទ្ធិទទួលបានដំណោះស្រាយដោយមានប្រសិទ្ធភាពផងដែរដើម្បីអាចការពារសិទ្ធិទាំងនោះបាន")។

[1296]មាត្រា ៦ នៃ*អនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ពណ៌សម្បុរ* (ដាក់កាតព្វកិច្ចលើរដ្ឋជាភាគីឲ្យ "ធានាដល់បុគ្គលគ្រប់រូបដែលស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួននូវការការពារនិងដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ... ក៏ដូចជាសិទ្ធិក្នុងការស្នើសុំពីតុលាការ(ជាតិដែលមានសមត្ថកិច្ច)នូវសំណង ឬការសងបំណុលដែលត្រឹមត្រូវ និងគ្រប់គ្រាន់")។

[1297]*អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនិងការប្រព្រឹត្ត ឬការដាក់ទណ្ឌកម្មដែលឃោរឃៅអមនុស្សធម៌ឬថោកទាបផ្សេងៗទៀត* មាត្រា១៤(១) (ដែលចែងអំពីសិទ្ធិដែលអាចអនុវត្តបានរបស់ជនរងគ្រោះក្នុងការ"ទទួលបាននូវសំណងត្រឹមត្រូវនិងគ្រប់គ្រាន់រួមទាំងមធ្យោបាយសម្រាប់ស្ដារនីតិសម្បទាឡើងវិញទាំងស្រុងតាមដែលអាចធ្វើបាន")។

[1298]ពិធីសារជ្រើសរើសចំពោះអនុសញ្ញាស្ដីពីសិទ្ធិរបស់កុមារស្ដីពីការលក់កុមារការធ្វើសញ្ចារកម្មលើកុមារ និងការថតរូបភាពអាសអាភាសកុមារ បើកឲ្យចុះហត្ថលេខានៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០០ វ៉ុល ២១៧១ លេខលំដាប់សន្ធិសញ្ញាទំព័រ ២២៧ (2171 UNTS 227) (ចូលជាធរមាននៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២) ("ពិធីសារស្ដីពីការលក់កុមារការធ្វើសញ្ចារកម្មលើកុមារ និងការថតរូបភាពអាសអាភាសកុមារ") មាត្រា៩(៤) (ចែងថា ជនរងគ្រោះ"មានសិទ្ធិអនុវត្តនីតិវិធី

៦៤៨. សិទ្ធិក្នុងការទទួលបានសំណង ក៏ត្រូវបានទទួលស្គាល់នៅក្នុងវិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិផងដែរ។ ជាឧទាហរណ៍ តុលាការ ICTR បានសម្រេចថា សិទ្ធិទទួលបានសំណងប្រកបដោយប្រសិទ្ធភាពគឺ ពិតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[1301] និងថា "ទោះបីជាការរំលោភបំពានបានធ្វើឱ្យប៉ះពាល់ក្នុងកម្រិតណាក៏ដោយ ក៏ការរំលោភបំពាននេះតម្រូវឱ្យមានសំណងមួយដែលមានលក្ខណៈសមាមាត្រ"[1302]។

៦៤៩. គួរមានការកត់សម្គាល់ផងដែរថា ឯកសារទាំងឡាយដែលពុំមានអានុភាពចងកាតព្វកិច្ច បានបង្ហាញអំពីបទដ្ឋានអន្តរជាតិស្តីពីសំណង។ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសំណងបានអះអាងថា រដ្ឋគប្បីព្យាយាមបង្កើតឱ្យមាននូវដំណោះស្រាយដែលមានលក្ខណៈសមស្រប ឆាប់រហ័ស មានប្រសិទ្ធភាព និងគ្រប់គ្រាន់ពេលលេញ រួមទាំងការសង

---

គ្រប់គ្រាន់ក្នុងការស្នើសុំសំណងសម្រាប់ការខូចខាត ដែលកើតចេញមកពីជនទាំងឡាយណាដែលត្រូវទទួលខុសត្រូវតាមច្បាប់ដោយគ្មានការរើសអើង")។

[1299]មាត្រា ១៣ នៃ ECHR (ចែងថា "បុគ្គលគ្រប់រូបដែលសិទ្ធិនិងសេរីភាពរបស់ខ្លួនដែលមានចែងនៅក្នុងអនុសញ្ញានេះត្រូវបានរំលោភបំពានត្រូវមានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពនៅចំពោះមុខអាជ្ញាធរជាតិ...") និងមាត្រា ៤១ (បានផ្តល់អំណាចឱ្យតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ក្រោមកាលៈទេសៈខ្លះ "ឱ្យផ្តល់សំណងសមស្របដល់ភាគី ដែលទទួលរងព្យសនកម្ម")។

[1300]មាត្រា ៦៣(១) នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ផ្តល់អំណាចដល់តុលាការអន្តរអាមេរិកក្នុងការរកឱ្យឃើញថា "មានការរំលោភសិទ្ធិឬសេរីភាពដែលត្រូវបានការពារដោយ[ACHR]" និងក្នុងការសម្រេចនៅពេលសមស្របថា "ការបំពានលើសិទ្ធិ ឬសេរីភាពនេះត្រូវទទួលបាននូវការផ្តល់សំណងសមស្រប ត្រូវផ្តល់ឱ្យភាគីដែលទទួលរងព្យសនកម្ម")។ *សូមមើលផងដែរ* ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិរបស់ប្រជាជន, អនុម័តនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៨១, លេខឯកសារ ឯកសាររបស់អង្គការរួបរួមអាហ្វ្រិក (CAB/LEG/67/3/Rev.5), *បានបោះពុម្ពសារជាថ្មីនៅក្នុងព្រឹត្តប័ត្រផ្សេងៗស្តីពីគតិយុត្តអន្តរជាតិ* វ៉ុល ២១ (ឆ្នាំ ១៩៨២) ទំព័រ ៥៨ (បានចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៨៦) មាត្រា ២១(២)។ ធម្មនុញ្ញអារ៉ាប់ស្តីអំពីសិទ្ធិមនុស្ស, អនុម័តនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៤, ត្រូវបានបោះពុម្ពសារជាថ្មីនៅក្នុងព្រឹត្តប័ត្ររបស់សាកលវិទ្យាល័យបុស្តុនស្តីពីច្បាប់អន្តរជាតិ *(Boston University International Law Journal)* លេខ ២៤ (សរទរដូវ ឆ្នាំ ២០០៦), ទំព័រ ១៤៧ (បានចូលជាធរមាននៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៨) មាត្រា ២៣។

[1301]*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Rwamakuba,* សំណុំរឿងលេខ ICTR-98-44C-T, អង្គជំនុំជម្រះសាលាដំបូង, "សេចក្តីសម្រេចលើសំណងសមរម្យ", ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧, កថាខណ្ឌ ៤០។

[1302]សេចក្តីសម្រេចក្នុង*រឿងក្តី* *Semanza,* កថាខណ្ឌ ១២៥។

សំណង ចំពោះការរំលោភលើបទដ្ឋាននៃច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ដូចដែលបានអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ជាតិនានា[1303]។ គោលការណ៍បានចែងផងដែរថា៖

> រដ្ឋគប្បីខិតខំព្យាយាមបង្កើតកម្មវិធីនានាស្តីពីការសងសំណង និងការជួយជ្រោមជ្រែងនានាដល់ជនរងគ្រោះ នៅក្នុងករណីភាគីណាដែលទទួលខុសត្រូវចំពោះព្យសនកម្ម ពុំមានលទ្ធភាព ឬពុំមានឆន្ទៈក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន[1304]។

៦៥០. ប្រហាក់ប្រហែលគ្នានេះដែរ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ បានលើកឡើងថា៖

> ជនរងគ្រោះគួរទទួលបានក្តីមេត្តាអាណិតអាសូរ និងការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់ខ្លួន។ពួកគេមានសិទ្ធិទទួលបានយន្តការផ្តល់យុត្តិធម៌ និងការជួសជុលជាបន្ទាន់លើព្យសនកម្មដែលខ្លួនបានទទួលរង ដូចមានចែងនៅក្នុងច្បាប់ជាតិ[1305]។

៦៥១. ជាពិសេស សំដៅលើអំពីជនរងគ្រោះដោយសារការរំលោភអំណាច សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះបានចែងថា៖

> រដ្ឋគប្បីពិចារណា (...) ក្នុងការផ្តល់សំណងជូនជនរងគ្រោះនៃការរំលោភបំពានបែបនេះ។ជាពិសេសសំណងបែបនេះគប្បីរួមទាំងបដិទាន និង/ឬសំណងផ្លូវចិត្ត ព្រមទាំងការជួយជ្រោមជ្រែងនិងគាំទ្រជាចាំបាច់ ដូចជា ផ្នែកសម្ភារៈ ផ្នែកវេជ្ជសាស្ត្រ ផ្នែកផ្លូវចិត្ត និងផ្នែកសង្គម[1306]។

---

[1303]មាត្រា I (២)(គ) នៃគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសំណង។

[1304]មាត្រា IX(16) នៃគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសំណង។

[1305]សេចក្តីប្រកាសនៃគោលការណ៍អង្គការសហប្រជាជាតិស្តីពីយុត្តិធម៌សម្រាប់ជនរងគ្រោះ, កថាខណ្ឌ ៤។

[1306]សេចក្តីប្រកាសនៃគោលការណ៍អង្គការសហប្រជាជាតិស្តីពីយុត្តិធម៌សម្រាប់ជនរងគ្រោះ, កថាខណ្ឌ ១៩។ *សូមមើលផងដែរ* សេចក្តីប្រកាសនៃគោលការណ៍ច្បាប់អន្តរជាតិស្តីអំពីសំណងជូនជនរងគ្រោះនៃជម្លោះប្រដាប់អាវុធ (បញ្ហាសំខាន់ ៗ) ដែលបានដាក់ភ្ជាប់នឹងសេចក្តីសម្រេចលេខ ២/២០១០ នៅក្នុងពេលសន្និសីទលើកទី ៧៤ នៃសមាគមច្បាប់អន្តរជាតិ

៦៥២. យុត្តិសាស្ត្ររបស់ស្ថាប័នសិទ្ធិមនុស្សនៅកម្រិតតំបន់នានា ស្តីអំពីការផ្តល់សំណងដល់ជនរងគ្រោះ អាចធ្វើជាឯកសារមូលដ្ឋានគួរឱ្យជឿបានពាក់ព័ន្ធនឹងខ្លឹមសារនៃសិទ្ធិទទួលបានសំណងចំពោះព្យសនកម្មដែលបុគ្គលទាំងឡាយបានទទួលរង រួមទាំងជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់រួចហើយថា យុត្តាធិការរបស់ស្ថាប័នទាំងនេះផ្តោតលើការរំលោភបំពានកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការលើកកម្ពស់សិទ្ធិមនុស្សតែប៉ុណ្ណោះ។ ហេតុដូច្នេះ កិច្ចដំណើរការនីតិវិធីនៅចំពោះមុខស្ថាប័នសិទ្ធិមនុស្សនៅកម្រិតតំបន់ទាំងនេះ មានលក្ខណៈខុសៗគ្នាពីនីតិវិធីជំនុំជម្រះក្នុងរឿងព្រហ្មទណ្ឌនានា ទាក់ទងទៅនឹងគោលនយោបាយ ក្របខណ្ឌបច្ចេកទេសច្បាប់ និងវិធាននៃការបកស្រាយ[1307]។ ដូចគ្នានេះដែរ ទម្រង់នៃសំណងដែលជាការទទួលខុសត្រូវរបស់រដ្ឋមានលក្ខណៈខុសពីទម្រង់នៃសំណង ដែលជាការទទួលខុសត្រូវរបស់ពិរុទ្ធជន។ យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាដោយប្រុងប្រយ័ត្នលើការសំអាងអំពីយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា ដែលមិនមែនជាតុលាការព្រហ្មទណ្ឌពីសំណាក់អ្នកដាក់ពាក្យសុំ ហើយអង្គជំនុំជម្រះតុលាការកំពូលនឹងចាត់ទុកយុត្តិសាស្ត្រទាំងនេះថា មានសក្តានុភាពជាបទដ្ឋានគួរឱ្យជឿជាក់បានតាមករណីជាក់ស្តែងនីមួយៗនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ។ កង្វល់ប្រហាក់ប្រហែលគ្នានេះដែរ មានជាប់ពាក់ព័ន្ធទៅនឹងនីតិវិធីដូចខាងក្រោម ដែលអនុវត្តដោយស្ថាប័នរដ្ឋបាលនានា ដូចជាកម្មវិធីផ្តល់សំណងដែលត្រូវបានបង្កើតក្នុងគោលបំណងធ្វើការសម្រេចអំពីសំណងនានា។

---

ដែលបានរៀបចំឡើងនៅទីក្រុងឡាអេនៃប្រទេសហូឡង់ដ៏ចាប់ពីថ្ងៃទី ១៥ ដល់ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០។ <http://www.ila-hq.org/en/committees/index.cfm/cid/1018> ។

[1307] *សូមមើលរឿងក្តី Velasquez-Rodriguez ទល់នឹង Honduras,* IACtHR, សាលក្រម(លើអង្គសេចក្តី) ចុះថ្ងៃ ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨, កថាខណ្ឌ ១៣៤ ("ការការពារជាអន្តរជាតិលើសិទ្ធិមនុស្ស មិនត្រូវយល់ច្រឡំជាមួយនឹងយុត្តិធម៌ព្រហ្មទណ្ឌឡើយ។ រដ្ឋទាំងឡាយមិនចូលខ្លួននៅចំពោះមុខតុលាការ ក្នុងនាមជនជាប់ចោទនៅក្នុងបណ្តឹងអាជ្ញានោះទេ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិមិនមែនមានគោលបំណងដាក់ទណ្ឌកម្មជនទាំងឡាយណា ដែលមានពិរុទ្ធភាពលើការរំលោភបំពាននោះទេ ក៏ប៉ុន្តែច្បាប់នេះមានគោលបំណងការពារជនរងគ្រោះនិងផ្តល់ជូនពួកគេនូវសំណងចំពោះព្យសនកម្មដែលកើតចេញពីអំពើទាំងឡាយដែលរដ្ឋជាអ្នកទទួលខុសត្រូវ")។

៦៥៣. ព្រះរាជាណាចក្រកម្ពុជា គឺជារដ្ឋភាគីនៃលិខិតុករណ៍អន្តរជាតិមួយចំនួន ដែលមានចែងអំពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងប្រកបដោយប្រសិទ្ធភាព[1308]។ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទាំងឡាយត្រូវបានទទួលស្គាល់ដោយច្បាប់កម្ពុជាដូចមានចែងក្នុង មាត្រា ៣១(១) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា៖

> ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

៦៥៤. ពាក់ព័ន្ធនឹងការពិចារណាខាងលើចំពោះអំណាចរបស់ អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើក្របខណ្ឌគតិយុត្តដែលថា ទោះបីជា អ.វ.ត.ក ជាតុលាការកូនកាត់ក៏ដោយ ក៏តុលាការនេះដើរតួនាទីជាតុលាការជាតិកម្ពុជា ហើយមានកាតព្វកិច្ចគោរពបទដ្ឋានយុត្តិធម៌អន្តរជាតិ ព្រមទាំង គោលការណ៍សិទ្ធិមនុស្សផ្សេងទៀត ដែលត្រូវបានទទួលស្គាល់ជាទូទៅ។ បើជាទោះជាយ៉ាងណាក៏ដោយ ក៏ អ.វ.ត.ក នៅតែមានអំណាចតិចតួច"ក្នុងការកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម (...)"[1309]។ ក្នុងនាមជាតុលាការព្រហ្មទណ្ឌ បើទោះជាមានលក្ខណៈអន្តរជាតូបនីយកម្មក៏ដោយ ក៏ អ.វ.ត.ក ពុំមានអំណាចធ្វើការវាយតម្លៃអំពីការគោរពពីសំណាក់ប្រទេសកម្ពុជាចំពោះកាតព្វកិច្ចអន្តរជាតិទាំងនេះនោះទេ។

---

[1308]ព្រះរាជាណាចក្រកម្ពុជាបានចូលជាភាគីនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ដោយពុំមានការប្រកាសខរក្សាសិទ្ធិឡើយហើយបានចូលជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២។ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារស្តីពីការលក់ដូរកុមារ ពេស្យាចារកុមារ និងរូបថតអាសអាភាសលើកុមារនៅថ្ងៃទី ៣៩ ខែ ឧសភា ឆ្នាំ ២០០២ ដោយពុំមានការប្រកាសខរក្សាសិទ្ធិឡើយ ព្រមទាំងបានផ្តល់សច្ចាប័នលើលក្ខន្តិកៈទីក្រុងរ៉ូមនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០២ និងអនុសញ្ញាស្តីពីការលុបចំបាត់ចោលរាល់ទម្រង់នៃការរើសអើសពូជសាសន៍គ្រប់ប្រភេទនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៨៣។

[1309]មាត្រា ១ នៃកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

៦៥៥. ចំពោះកម្រិតគោលនយោបាយគប្បីធ្វើការគូសបញ្ជាក់ថា កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌរបស់ អ.វ.ត.កគួរត្រូវបានចាត់ទុកថា ជាការចូលរួមចំណែកដល់ដំណើរការនៃការផ្សះផ្សាជាតិដែលអាចជាចំណុចចាប់ផ្តើមសម្រាប់គម្រោងនៃសំណង ហើយពុំមែនជាគម្រោងសំណងចុងក្រោយចំពោះផលវិបាកនៃសោកនាដកម្ម ដែលបានកើតឡើងនៅទូទាំងប្រទេសក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ។ ដូច្នេះ ពុំអាចមានការរំពឹងទុកហួសហេតុពេកថា អ.វ.ត.ក អាចធ្វើហួសពីគោលបំណងក្នុងការទទួលបានយុត្តិធម៌អន្តរកាលនេះបានឡើយ[1310]។ ហេតុដូច្នេះ ទោះបីជា អ.វ.ត.ក ពិតជាមានសមត្ថកិច្ចផ្តល់សំណង"ផ្លូវចិត្ត និងសមូហភាព" ក៏ដោយ ក៏សមត្ថកិច្ចនេះត្រូវតែបកស្រាយទៅតាមគោលបំណង និងអាណត្តិដ៏ចង្អៀតដែរ។

៦៥៦. ផលវិបាកទីមួយដែលកើតចេញពីការបកស្រាយអំពីអាណត្តិរបស់ អ.វ.ត.ក មានចែងយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុងថា សំណង"ត្រូវធ្វើឡើងប្រឆាំងទៅនឹងទណ្ឌិត និងជាបន្ទុករបស់ទណ្ឌិត"[1311]។ វិធាននេះចែងបន្តទៀតថា បណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក អាចធ្វើឡើងប្រឆាំងទៅនឹងជនជាប់ចោទតែប៉ុណ្ណោះ ហើយជនរងគ្រោះមិនមានសិទ្ធិដាក់ពាក្យបណ្តឹងទាមទារនេះនៅ អ.វ.ត.ក ប្រឆាំងនឹងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីផ្សេងពី

[1310] *សូមមើលជាទូទៅលើព្រឹត្តិប័ត្ររបស់* Harvey M. Weinstein "កំណត់សម្គាល់របស់និពន្ធនាយក៖ ភាពមិនពិតនៃការបញ្ចប់, ភាពមិនពិតនៃការសម្របសម្រួលៈ ការផ្តុះបញ្ចាំងចុងក្រោយរយៈពេលប្រាំឆ្នាំ ជាសហប្រធាននិពន្ធនាយក (The Myth of Closure, the Illusion of Reconciliation: Final Thoughts on Five Years as Co-Editor-in-Chief)" នៅក្នុងព្រឹត្តប័ត្រអន្តរជាតិនៃយុត្តិធម៌អន្តរកាល លេខ ៥(១) (ឆ្នាំ ២០១១) (បង្ហាញមន្ទិលសង្ស័យលើសមត្ថភាពនៃសវនាការជំនុំជម្រះគណៈកម្មាការស្វែងរកការពិត និងពិធីរំលឹកដើម្បីទទួលបានក្នុងរយៈពេលខ្លីនូវគោលបំណងនានាដូចជាការផ្សះផ្សាជាតិនិងការបិទទំព័រនៅក្នុងសហគមន៍ដែលទទួលរងការប៉ះពាល់។ អ្នកនិពន្ធលើកឡើងថា សហគមន៍អន្តរជាតិគប្បីបន្ថយនូវគោលបំណងរបស់ខ្លួនដើម្បីជៀសវាង ("ការរំពឹងទុកហួសហេតុនិងការស្រងាកចិត្តនាពេលចុងក្រោយ ពីជនទាំងឡាយដែលបានទទួលរងការឈឺចាប់")។ *សូមមើលផងដែរ* Susana SáCouto, "ការចូលរួមរបស់ជនរងគ្រោះនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាៈ គម្រោងស្តីពីការគាំទ្រស្ត្រី ? ចេញផ្សាយដោយមហាវិទ្យាល័យច្បាប់វ៉ាស៊ីងតោនរបស់មេរិក, ព្រឹត្តប័ត្រស្រាវជ្រាវ លេខ ២០១១-៣០, ទំព័រ ៥៤ ដល់ ៥៦ (ដែលបានលើកឡើងថា ជាការប្រសើរបំផុតនោះ មិនគួរបង្កើតឲ្យមានសេចក្តីសង្ឃឹម ដែលទំនងជាមិនអាចបំពេញបាននោះទេ) តាមរយៈគេហទំព័រ http://ssrn.com/abstract=1934320 ។

[1311] វិធាន២៣(១១) នៃវិធានផ្ទៃក្នុង។

ជនជាប់ចោទឡើយ[1312]។ បើទោះជាបញ្ហាថាតើបណ្តឹងរដ្ឋប្បវេណីអាចធ្វើឡើងនៅចំពោះមុខតុលាការជាតិកម្ពុជា ដែរ ឬយ៉ាងណានោះក៏ដោយ[1313] ក៏ការកម្រិតនេះរារាំងការប្រើប្រាស់ក្របខណ្ឌគតិយុត្តដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ ដើម្បីធ្វើបណ្តឹងប្រឆាំងនឹងរដ្ឋនៅចំពោះមុខ អ.វ.ត.ក។ ចំណុចទីពីរក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក មិនមានចែងអំពីយន្តការក្នុងការអញ្ជើញអ្នកតំណាងរបស់រដ្ឋឡើយ ដែលផ្ទុយពីក្របខណ្ឌជាធរមាននៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ[1314]។ ជាការពិត ការអនុវត្តនេះដើរផ្ទុយពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌ផ្នែកនីតិវិធី ដោយចេញដីកាបង្គាប់ចងកាតព្វកិច្ចប្រឆាំងនឹងរដ្ឋ ឬរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដែលមិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី ឬដែលពុំមានឱកាសក្នុងការដាក់សេចក្តីសង្កេតរបស់ខ្លួន។

៦៥៧. គប្បីធ្វើការកត់សម្គាល់ថា ក្របខណ្ឌគតិយុត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ ដែលតុលាការទាំងពីរនេះដោះស្រាយព្យសនកម្មដែលជនរងគ្រោះបានទទួលរង[1315] ខុសគ្នាពីក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ត្រង់ចំណុចដែលថា

---

[1312]ចំណុចមួយនេះពុំមានការកែប្រែតាមរយៈការធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុងនាពេលក្រោយៗមកទៀតនោះទេ (សូមមើលវិធាន២៣*ស្ទួនបួន*(៣) (វិសោធនកម្មលើកទី ៨)។

[1313]ទោះបីជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក្រៅពីជនជាប់ចោទជាអ្នកទទួលខុសត្រូវលើការសម្រេចអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទក៏ដោយ (ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ត្រង់មាត្រា ២៨១, ៣៥៥) ក៏រដ្ឋមានកាតព្វកិច្ចផ្តល់សំណងដោយពុំចំណុះនៅក្រោមការសម្រេចលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនណាម្នាក់ឡើយ។ នៅពេលពុំមានបទប្បញ្ញត្តិនៅក្នុងច្បាប់ជាតិចែងជាវិជ្ជមានលើសំណង វានឹងចងកាតព្វកិច្ចដល់រដ្ឋក្នុងការសងសំណង នៅពេលរកឃើញថា អតីតមន្ត្រីរបស់ខ្លួនជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌនោះ។ ការប្រើប្រាស់បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ស្តីពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីគឺទំនងជាបញ្ហាចម្រូងចម្រាសមួយ។

[1314]សូមមើលមាត្រា ៧៥(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម និងវិធាន ៩៤(២) និងវិធាន ៩៥(១) នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់តុលាការ ICC (“វិធានស្តីពីនីតិវិធីនិងភស្តុតាង”) (ដែលចែងព្យាករណ៍ទុកថា តុលាការ ICC អាចអញ្ជើញតំណាងរដ្ឋដែលចាប់អារម្មណ៍ ឬអ្នកតំណាងណាម្នាក់ក្នុងនាមរដ្ឋដែលចាប់អារម្មណ៍ដែលទទួលបានការជូនដំណឹងអំពីសំណើទាមទារសំណង)។

[1315]តាមសំណើ ឬឆន្ទានុសិទ្ធិរបស់ខ្លួន តុលាការ ICC អាចសម្រេចលើព្យសនកម្មដែលទទួលរងដោយជនរងគ្រោះ ធ្វើដីកាបង្គាប់ឲ្យសងសំណងលើពិរុទ្ធជន ឬបង្គាប់ថា ការសងសំណងត្រូវធ្វើឡើងតាមរយៈមូលនិធិពិសេស (មាត្រា ៧៥(១)

តុលាការទាំងពីរនេះមានចែងអំពីយន្តការនីតិវិធី សមស្របក្នុងការរារាំងមិនឱ្យមានការពន្យារពេលនៃសំណុំរឿងព្រហ្មទណ្ឌ ដោយសារតែនីតិវិធីនេះមានបន្ទុកធ្ងន់ធ្ងរ និងត្រូវការពេលវេលាច្រើនដែលអាចកើតមានទាក់ទងនឹងសំណង។ មូលនិធិពិសេសសម្រាប់ជនរងគ្រោះដែលបង្កើតឡើង នៅក្នុងប្រព័ន្ធតុលាការព្រហ្មទណ្ឌអន្តរជាតិ មានកាតព្វកិច្ចក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដែលមានសិទ្ធិទទួលសំណង និងគ្រប់គ្រងហិរញ្ញវត្ថុ ឬអនុវត្តការផ្តល់សំណង[1316]។ លើសពីនេះទៅទៀត ដំណើរការនីតិវិធីនៃការផ្តល់សំណងអាចត្រូវបានបង្កើតឡើងនៅដំណាក់កាលក្រោយបន្ទាប់ពីការ សម្រេចដាក់ពិរុទ្ធភាព[1317]។ លក្ខន្តិកៈតុលាការពិសេសសម្រាប់ប្រទេសលីបង់ ដែលចែងអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ បានអនុញ្ញាតឱ្យតុលាការជាតិ ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតធ្វើការដោះស្រាយលើការផ្តល់សំណងដល់ជនរងគ្រោះ[1318]។ ការផ្ទេរសមត្ថ កិច្ចក្នុងរឿងទាមទារសំណងបែបនេះមិនមានចែង នៅក្នុងក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក នោះទេ ដែលយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានកម្រិតដោយការសង្ខេបខ្លឹមសារនៃបណ្តឹងដែលអាចទទួលយកបានប៉ុណ្ណោះ។

៦៥៨. ជាផលវិបាក សំណងនៅ អ.វ.ត.ក ត្រូវបានកម្រិតត្រឹមសំណង"ផ្លូវចិត្ត និងសមូហភាព" ដែលមានចែងនៅក្នុងវិធាន ២៣ (១)(ខ) និងវិធាន ២៣ (១១) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ[1319]។

---

និង(២) នៃលក្ខន្តិកៈតុលាការ ICC)។ តុលាការ STL "អាចកំណត់អត្តសញ្ញាណជនរងគ្រោះដែលទទួលរងការខូចខាតដោយសារតែការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ ដែលត្រូវបានតុលាការផ្តន្ទាទោស"។ (មាត្រា ២៥(១) នៃលក្ខន្តិកៈតុលាការ STL)។

[1316]បទបញ្ជា ៤៣, ៤៤, ៤៥, ៥៤, ៥៨, ៦០, ៦១, ៦៩, ៧០ នៃបទបញ្ជាមូលនិធិពិសេសសម្រាប់ជនរងគ្រោះ ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចលេខ ICC-ASP/4/Res.3, ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៥។

[1317]មាត្រា ៧៦(៣) នៃលក្ខន្តិកៈតុលាការ ICC និងវិធាន ១៤៣ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC។

[1318]មាត្រា ២៥(៣) នៃលក្ខន្តិកៈតុលាការSTL។

[1319]*សូមមើលជាទូទៅលើ*បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ កថាខណ្ឌ ២៧, ២៨, ៩២ ដល់ ១១០ និងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ កថាខណ្ឌ ៩៧ (លើកឡើងក្នុងពាក្យជាទូទៅអំពីបញ្ហានៃអត្ថន័យ "សមូហភាព និងផ្លូវចិត្ត")។

ទោះបីជាពាក្យ“សំណង ផ្លូវចិត្ត” មិនធ្លាប់មានពីមុនមកនៅក្នុងក្របខណ្ឌគតិយុត្តជាតិ ឬអន្តរជាតិក្តី[1320] ក៏ទស្សនទាននៃព្យសនកម្មផ្លូវចិត្តធ្លាប់បានលើកឡើងផងដែរ[1321]។ ទោះបីជាយ៉ាងណាក៏ដោយ វិធានផ្ទៃក្នុងពិតជាបានផ្តល់ការណែនាំមួយចំនួន ដើម្បីបកស្រាយពាក្យពេចន៍តាមរយៈការលើកជាឧទាហរណ៍នូវវិធានការនានា ដែលអាចជាសំណងផ្លូវចិត្ត និងសមូហភាព។ វិធាន ២៣ (១២) នៃវិធានផ្ទៃក្នុងចែងអំពីការបោះពុម្ពផ្សាយសាលក្រម ការផ្តល់មូលនិធិដល់សកម្មភាព ឬសេវាកម្មមិនរកប្រាក់ចំណេញដែលផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះ និង“ទម្រង់ដទៃទៀតនៃសំណងដែលមានលក្ខណៈសមរម្យ និងប្រហាក់ប្រហែល”។ នៅក្នុងបរិបទនេះ ពាក្យពេចន៍“ផ្លូវចិត្ត”បង្ហាញនូវគោលបំណងជួសជុលព្យសនកម្មផ្លូវចិត្ត មិនមែនជួសជុលព្យសនកម្មខាងសម្ភារៈនោះទេ។ ទោះបីជា ចរិតលក្ខណៈនៃវិធានការ“សមូហភាព”បញ្ជាក់ពីភាពមិនផ្តល់សំណងហិរញ្ញវត្ថុជាលក្ខណៈបុគ្គលក្តី ក៏លក្ខខណ្ឌតម្រូវដែលមានចរិតលក្ខណៈសមូហភាព ឬផ្លូវចិត្តមិនបានរារាំងមិនឱ្យមានវិធានការ*ផ្សេងៗទៀត* ដែលជាតម្រូវការហិរញ្ញវត្ថុដើម្បីអាចអនុវត្តបាននោះទេ។ ដរាបណាជនរងគ្រោះត្រូវបានផ្តល់សំណងសមូហភាព ក៏សំណងផ្លូវចិត្តអាចផ្តល់នូវផលប្រយោជន៍សម្រាប់សមាជិកនៃក្រុមសមូហភាពផងដែរ[1322]។

---

[1320] *សូមមើល* បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៩៥។

[1321] *សូមមើល ឧទា. រឿងក្តី* Castillo-Páez *ទល់នឹង ប៉េរូ* “សេចក្តីសម្រេច (សំណង និងសោហ៊ុយ)”, កថាខណ្ឌ ៥៣ (សម្រេចថា “ដូចដែលឈ្មោះបង្កប់ន័យ សំណងមានបំណងលុបបំបាត់ចោលឥទ្ធិពលនៃការរំលោភបំពាន។ ប្រភេទ និងទំហំនៃសំណង ផ្អែកលើព្យសនកម្មដែលបង្កទាំងនៅកម្រិតសម្ភារៈ និងផ្លូវចិត្ត”)។

[1322] មជ្ឈមណ្ឌលសម្រាប់យុត្តិធម៌ និងការទទួលខុសត្រូវ, ការទទួលបានភាពយុត្តិធម៌នៅអាស៊ី និងមជ្ឈមណ្ឌលស្តីពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ, “សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណងៈ ការផ្តល់សំណងប្រកបដោយអត្ថន័យនៅអ.វ.ត.ក”, ទំព័រ ៧ (លើកឡើងថា “សំណងជាសមូហភាព ដែលបានព្យាយាមជួសជុលព្យសនកម្មរួម ឬសមូហភាព អាចផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់សមាជិកនៅក្នុងសហគមន៍នៅក្នុងនាមបុគ្គលម្នាក់ៗ”), គេហទំព័រ www.accessjusticeasia.org/victims-right-to-remedy។

៦៥៩. ពាក្យពេចន៍“សមូហភាព”គឺមានន័យចំៗតែម្តង និងមានចែងនៅក្នុងយុត្តិសាស្ត្រទាក់ទងនឹងសំណង[1323]។ នៅក្នុងបរិបទនៃ អ.វ.ត.ក មិនមានការបញ្ចូលសំណងជាលក្ខណៈបុគ្គលនោះទេ ទោះបីជាប្រភេទហិរញ្ញវត្ថុ ឬមិនមែនក៏ដោយ។ វាហាក់ដូចជាគាំទ្រវិធានការទាំងឡាយដែលផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះជាច្រើនតាមតែអាចធ្វើបាន។ រឿងក្តីបច្ចុប្បន្ននេះពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំដែលប៉ះពាល់ដោយផ្ទាល់ និងមិនផ្ទាល់ចំពោះជនរងគ្រោះក្នុងចំនួនច្រើនដោយផ្អែកតាមប្រភេទឧក្រិដ្ឋកម្មទាំងនេះ ទោះជាការប៉ះពាល់នេះមានកម្រិតផ្សេងៗគ្នាក៏ដោយ។ ទោះបីជាវិធានការទាំងនេះអាចទទួលយកបានក៏ដោយ ក៏ការផ្តល់វិធានការដែលអាចផ្តល់ផលប្រយោជន៍ដល់ក្រុមជនរងគ្រោះមួយចំនួនតូច អាចមិនរួមបញ្ចូលនូវបុគ្គលផ្សេងទៀត ដូចជាជនទាំងឡាយដែលមិនបានដឹងអំពីដំណើរការនីតិវិធីឬជនទាំងឡាយដែលគ្មានឱកាសចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី[1324] ឬបុគ្គលដែលមិនមានលទ្ធភាពខាងហិរញ្ញវត្ថុ មិនមានកាយសម្បទារឹងមាំ មិនមានសម្បទាផ្លូវចិត្ត ឬមិនមានលទ្ធភាពខាងភស្តុភារ ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ឬបុគ្គលដែលមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបំពេញបាននូវលក្ខខណ្ឌតម្រូវនៃភាពអាចទទួលយកបាន ឬបុគ្គលដែលមិនចង់ចូលរួមដោយមូលហេតុផ្សេងៗទៀត។ ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣បានកត់សម្គាល់រឿងក្តីបច្ចុប្បន្ននេះមានដើមបណ្តឹងរដ្ឋប្បវេណីតិចជាងមួយរយនាក់ ខណៈពេលដែលឧក្រិដ្ឋកម្ម

---

[1323] *សូមមើល ឧទា. រឿងក្តី “Street Children”* សាលក្រម (សំណង និងសោហ៊ុយ)”, កថាខណ្ឌ ៨៤។ *សូមមើលផងដែរ* វិធាន ៩៨(៣) វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICC (ចែងអំពីសំណងសមូហភាព)។

[1324] យោងលើការស្ទង់មតិទូទាំងប្រទេសដែលធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់សាកលវិទ្យាល័យ Berkeley, ៣៩ ភាគរយនៃអ្នកត្រូវបានសម្ភាសន៍ មិនបានដឹងអំពី អ.វ.ត.ក ទាល់តែសោះ។ Pham, Phuong *អ្នកនិពន្ធដទៃទៀត*, “ដូច្នេះ យើងនឹងមិនបំភ្លេចឡើយៈ ការស្ទង់មតិលើប្រជាជនស្តីពីលក្ខណៈនៃការស្ថាបនាសង្គមឡើងវិញ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា”, មជ្ឈមណ្ឌលសិទ្ធិមនុស្ស, សាកលវិទ្យាល័យ California, Berkeley, ខែ មករា ឆ្នាំ ២០០៩, ទំព័រ ៣៦, គេហទំព័រ http://www.law.berkeley.edu។

00798822



ពាក់ព័ន្ធនឹងជនរងគ្រោះលើសពី ១២.០០០ (ដប់ពីរពាន់) នាក់[1325]។ លើសពីនេះទៅទៀត ចំនួនជនរងគ្រោះដែលមិនមានការបញ្ជាក់ច្បាស់លាស់មិនអាច និងមិនដែលបានកំណត់អត្តសញ្ញាណពេញលេញនោះទេ។ នៅក្នុងកាលៈទេសៈបច្ចុប្បន្ន អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គួរផ្តល់អាទិភាពដល់វិធានការនៃសំណង ទាំងឡាយដែលមានលក្ខណៈពេញលេញ។

៦៦០. ជាចុងក្រោយ ដោយពិចារណាថា ការខូចខាតសមូហភាពសមនឹងទទួលបានការជួសជុលសមូហភាព នោះអង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់អំពីមុខងាររបស់សំណងក្នុងលក្ខណៈផ្សះផ្សា។ ដូចដែលបានផ្តល់អនុសាសន៍នៅក្នុងរបាយការណ៍របស់គណៈកម្មាធិការស្រាយបំភ្លឺប្រវត្តិសាស្ត្រកាតេម៉ាឡាៈ

> វិធានការសំណងសមូហភាពសម្រាប់អ្នកនៅរស់រានមានជីវិតពីការរំលោភសិទ្ធិមនុស្ស និងអំពើហិង្សាសមូហភាព និងសាច់ញាតិរបស់ជនរងគ្រោះ គួរតែអនុវត្តនៅក្នុងក្របខណ្ឌនៃគម្រោងតាមដែនដីនានាដើម្បីលើកកម្ពស់ការផ្សះផ្សា ដើម្បីដោះស្រាយសំណង ហើយចំណាត់ការនិងផលប្រយោជន៍ផ្សេងទៀតក៏គាំទ្រដល់ប្រជាជនទាំងមូល ដោយមិនមានការបែងចែករវាងជនរង គ្រោះ និងចារីនោះឡើយ[1326]។

---

[1325] ប្រតិចារឹកនៃដំណើរការនីតិវិធីបណ្តឹងសាទុក្ខ, ឯកសារលេខ F1/4.1 ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ទំព័រ ៨៤ (បន្ទាត់ ១៥ ដល់ ២២) (តវ៉ាថា ជនរងគ្រោះមួយផ្នែក មិនបានស្នើសុំជាដើមបណ្តឹងរដ្ឋប្បវេណីដោយសារភិតភ័យ ទោះបីជាមិនមានការគម្រាមកំហែងពិតប្រាកដនាពេលបច្ចុប្បន្ននេះទេ)។

[1326] គណៈកម្មការស្តីពីការបញ្ជាក់ជាប្រវត្តិសាស្ត្រនៃ Guatemalan (Guatemalan Historical Clarification Commission), "Guatemala: ការចងចាំនូវភាពស្ងាត់ជ្រងំ" ផ្នែក III (១០), គេហទំព័រ http://shr.aaas.org/guatemala/ceh/report/english/recs3.html។ *សូមមើលផងដែរ* Friedrich Rosenfeld "សំណងជាសមូហភាពសម្រាប់ជនរងគ្រោះជម្លោះប្រដាប់អាវុធ" ព្រឹត្តប័ត្រស្តីពីការពិនិត្យឡើងវិញជាអន្តរជាតិរបស់កាកបាទក្រហម (*International Review of the Red Cross*) វ៉ុល ៩២:៨៧៩, (ឆ្នាំ ២០១០), ទំព័រ៧៤៥ (បង្ហាញថា សំណងសមូហភាព អាចផ្តល់ឱ្យជនរងគ្រោះគ្រប់គ្នាដែលទទួលរងការខូចខាតក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ ដូចនេះអាចជៀសវាង "ផលប៉ះពាល់ជាអវិជ្ជមានចំពោះ សំណងជាបុគ្គល ដែលជនរងគ្រោះម្នាក់ៗ មិនអាចទទួលបានសំណងណាមួយនោះទេ")។

៦៦១. ដោយទទួលស្គាល់អំពីក្របខណ្ឌដែលមានកម្រិតរបស់ អ.វ.ត.ក ដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជាសំណងផ្លូវចិត្ត និងសមូហភាពមិនអាចផ្តល់សំណងពេញលេញដល់ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្សខាងរូបកាយ ឬខាងសេដ្ឋកិច្ចក្តី ក៏គោលបំណងនៃសំណងទូទៅផ្សេងទៀតត្រូវបានបំពេញនៅចំពោះមុខ អ.វ.ត.ក ក្នុងកម្រិតដែលអាចឆ្លើយតបទៅនឹង"ការរំលោភបំពានខាងចិត្តសាស្ត្រ ផ្លូវចិត្ត និងនិមិត្តរូប"[1327]។ ករណីនេះអាចសម្រេចបានតាមរយៈ៖ "ការផ្ទៀងផ្ទាត់ អង្គហេតុ និងការបង្ហាញការពិតពេញលេញ និងជាសាធារណៈ"[1328] ដូចដែលលើកឡើងដោយសំអាងហេតុរបស់អង្គជំនុំជម្រះនានាតាមរយៈការចូលរួមរបស់ជនរងគ្រោះ ក្នុងកិច្ចដំណើរការនីតិវិធី[1329] និងការទទួលស្គាល់ជាបុគ្គលនៅក្នុងសាលក្រម និងការកំណត់អត្តសញ្ញាណជនរងគ្រោះ[1330]ដែលបង្ហាញនូវការ

---

[1327]ព្រឹត្តប័ត្រនិពន្ធដោយ Alice Riener "សំណង និងបញ្ហាវប្បធម៌ យ៉ែនឌ័រ ជនជាតិភាគតិចអំបូរដើម សេរីភាពក្នុងការបញ្ចេញមតិ៖ 'កុមារ និងសំណង'", "នៅក្នុងពេលសន្និសីទស្តីពីសំណងនៅក្នុងប្រព័ន្ធអន្តរទ្វីបអាមេរិក៖ វិធីសាស្ត្រប្រៀបធៀប", ចេញផ្សាយដោយការពិនិត្យឡើងវិញរបស់សាកលវិទ្យាល័យស្តីពីច្បាប់, វ៉ុល ៥៦:៦, (ឆ្នាំ ២០០៧), ទំព័រ ១៩៩២។

[1328]មាត្រា IX (២២)(ខ) នៃគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសំណង។

[1329]*សូមមើល* មាត្រាVIII នៃគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសំណង។ ព្រឹត្តប័ត្រនិពន្ធដោយ Susana SáCouto, "ការចូលរួមរបស់ជនរងគ្រោះនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៖ គម្រោងស្តីពីការគាំទ្រដល់ស្ត្រី ?, ទំព័រ៣៩ (បង្ហាញថា ការចូលរួមរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាអំពីការចូលរួមរបស់ពួកគេ និងជាពិសេសឱកាសបង្ហាញខ្លួន ប្រាប់រឿងរ៉ាវរបស់ខ្លួន សួរសំណួរឌុច និងបានដឹងលំអិតអំពីអ្នកដែលខ្លួនស្រឡាញ់ ដែលជាសំណងមានតម្លៃបំផុត)។

[1330]*សូមមើល* មាត្រា IX (២២)(គ) នៃគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសំណង។ Pham, Phuong *និងអ្នកនិពន្ធដទៃទៀត* "ដូច្នេះ យើងនឹងមិនបំភ្លេចឡើយ: ការស្ទង់មតិលើប្រជាជនស្តីពីលក្ខណៈនៃការស្ថាបនាសង្គមឡើងវិញ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា", ទំព័រ ២៦៤ ដល់ ២៨៧ (ដោយបង្ហាញថា នៅក្នុងការស្ទង់មតិមួយបានឱ្យដឹងថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៧៥ នៅក្នុងសំណុំរឿង ០០១ បានលើកឡើងអំពីលទ្ធផលវិជ្ជមាននៃការជំនុំជម្រះ ក្នុងនោះរួមមាន ការចូលរួមចំណែករបស់តុលាការនេះនៅក្នុងការបង្ហាញការពិតជាប្រវត្តិសាស្ត្រ ការផ្តល់ឱកាសដល់ពួកគេនៅក្នុងការរៀបរាប់រឿងរ៉ាវ ហើយពួកគេរំពឹងទុកផងដែរថា ការជំនុំជម្រះនឹងផ្តល់យុត្តិធម៌ និងទទួលស្គាល់ជនរងគ្រោះ)។

ទទួលស្គាល់ជាសាធារណៈនូវការឈឺចាប់របស់ពួកគាត់[1331]។ ជាងនេះទៅទៀត ជំនុំជម្រះតុលាការកំពូលពិចារណាថា ការគ្រាន់តែទទួលស្គាល់សំណងដែលស្នើសុំថា ជាវិធានការសំណងសមស្រប មានសក្តានុពលជាទម្រង់គ្រប់គ្រាន់ និងមានប្រសិទ្ធិភាពបង្ហាញអំពីការពេញចិត្ត និងការជួសជុលដែលអាចទាក់ទាញការចាប់អារម្មណ៍កិច្ចខិតខំប្រឹងប្រែង និងធនធាននានាចំពោះការសម្រេចបានពិតប្រាកដ។

***៧.ខ.២.ខ. ថាតើ អ.វ.ត.ក អាចចេញដីកាបង្គាប់ឱ្យសងសំណងដែលការអនុវត្តដីកាបង្គាប់នេះអាចតម្រូវឱ្យមានជំនួយផ្នែករដ្ឋបាលរបស់រដ្ឋាភិបាល ដែរ ឬយ៉ាងណា***

៦៦២. សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណងជាច្រើនតម្រូវឱ្យមានយ៉ាងច្បាស់ ឬដោយតុណ្ហីភាពនូវការ ចូលរួមយ៉ាងសកម្មពីអាជ្ញាធរកម្ពុជា ដើម្បីឱ្យវិធានការទាំងនេះសម្រេចបាន។ បញ្ហានៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺថាតើការតម្រូវនេះរារាំងការចេញនូវសំណងបែបនេះដែរ ឬយ៉ាងណា។

៦៦៣. អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អង្គជំនុំជម្រះមិនមានយុត្តាធិការលើបញ្ហាដែលច្បាប់មិនបានចែង នោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងសាជាថ្មីថា អាណត្តិរបស់ អ.វ.ត.ក មិនបានផ្តល់អំណាចឱ្យអង្គជំនុំជម្រះមានយុត្តាធិការលើរដ្ឋ ឬរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្គាប់ឱ្យគ្រប់គ្រង ផែនការសំណងនោះទេ។ ដូចគ្នានេះដែរ អ.វ.ត.ក មិនអាចចាប់បង្ខំឱ្យរាជរដ្ឋាភិបាលកម្ពុជាក្លាយជាចុងចម្លើយ នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខខ្លួន ហើយអ.វ.ត.ក ក៏មិនអាចអនុវត្តយុត្តាធិការដែលរំលោភលើសមត្ថកិច្ចស្រប

---

[1331] ព្រឹត្តប័ត្រនិពន្ធដោយ Bridget Mayeux, Justin Mirabal, "សំណងសមូហភាព និងសំណងផ្លូវចិត្តនៅក្នុងតុលាការសិទ្ធិមនុស្សអន្តរអាមេរិក" មជ្ឈលសិទ្ធិមនុស្ស សាកលវិទ្យាល័យនៃសាលាច្បាប់តិចសាស ចុះខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤ ("សំណងសមូហភាព និងផ្លូវចិត្ត ចាប់ផ្តើមបង្កើតឡើងនូវសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ តាមរយៈចែករំលែកជាសាធារណៈនូវរឿងរ៉ាវរបស់ពួកគាត់។ ការទទួលស្គាល់ការឈឺចាប់របស់ពួកគាត់ លើកកម្ពស់ជនរងគ្រោះឡើងវិញក្នុងឋានៈជាមនុស្សជាតិ ជាមួយនឹងសិទ្ធិដែលទាមទារឲ្យគោរព។ ព្រលឹងដែលមិនស្គាល់ឈ្មោះ ដែលបាត់សូន្យដោយសារតែការបាត់ខ្លួនដោយកងកម្លាំងគាំទ្រដោយរដ្ឋ បានទទួលមកវិញនូវអត្តសញ្ញាណរបស់ពួកគាត់") គេហទំព័រ www.utexas.edu/law។

តាមច្បាប់របស់អង្គនីតិប្រតិបត្តិនោះដែរ។ ដូចដែលតុលាការសិទ្ធិមនុស្សអឺរ៉ុប បានកត់សម្គាល់ "សំណាងដែលមិនអាចអនុវត្តបាន ឬដែលអាស្រ័យនឹងឆន្ទានុសិទ្ធិរបស់អង្គនីតិប្រតិបត្តិ មិនស្ថិតនៅក្នុងទស្សនទាននៃប្រសិទ្ធភាពនៃសំណងនោះទេ (....)"[1332]។

៦៦៤. ការទាមទារសំណងណាមួយត្រូវបានកំណត់ជាមុនថានឹងទទួលការបដិសេធ ប្រសិនបើសំណងនេះតម្រូវ ជា*ចាំបាច់*ឱ្យមានអន្តរាគមន៍ពីរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងកម្រិតដែលសំណើសុំបែបនេះស្វែងរកទាំង ស្រុងនូវវិធានការមួយដែលស្ថិតនៅក្នុងបុព្វសិទ្ធិរបស់រាជរដ្ឋាភិបាល។ ឧទាហរណ៍ ដូចជាករណីសំណើសុំឱ្យមានការសុំទោសជាផ្លូវការពីរដ្ឋ ការរៀបចំសេវាថែរក្សាសុខភាព ការបង្កើតថ្ងៃរំឭកបុណ្យជាតិ និងការយកឈ្មោះជនរងគ្រោះដាក់ជាឈ្មោះអគារសាធារណៈ។

៦៦៥. ម្យ៉ាងវិញទៀត វាមិនមានការសង្ស័យទេថា តុលាការជាតិត្រូវជាប់កាតព្វកិច្ចផ្តល់អនុភាពដល់ដីកាបង្គាប់ឱ្យសងសំណងរបស់ អ.វ.ត.ក ប្រឆាំងនឹងពិរុទ្ធជនដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងដីកាបង្គាប់ឱ្យសងសំណងផ្សេងទៀត ដែលចេញដោយតុលាការជាតិដែរ[1333]។

### *៧.ខ.២.គ.ថាតើភាពក្រីក្ររបស់ កាំង ហ្កេកអ៊ាវ ប៉ះពាល់ដល់អំណាចរបស់ អ.វ.ត.ក ចំពោះការសងសំណងដែលជាកាតព្វកិច្ចរបស់ កាំង ហ្កេកអ៊ាវ ដែរ ឬយ៉ាងណា*

៦៦៦. ភាពក្រីក្ររបស់ កាំង ហ្កេកអ៊ាវ[1334] ដែលត្រូវបានសន្មតទុកជាមុន មិនបានរារាំង អ.វ.ត.ក ក្នុងការផ្តល់សំណងចំពោះបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានធ្វើឡើងស្របតាមក្រមនីតិវិធី

---

[1332] *ប្រទេសប៉ែលស៊ីក និងឡុចសំបួរ ទល់នឹង ប្រទេសអង់គ្លេស* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ ៣៦៥៣៦/០២ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤ ទំព័រ ៩។

[1333] វិធាន១១៣(១) នៃវិធានផ្ទៃក្នុង និងមាត្រា៤៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧។

[1334] សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ E159/8 កថាខណ្ឌ ៥០ (បង្ហាញថា ជនជាប់ចោទត្រូវបានរកឃើញថាជាអ្នកក្រីក្រនៅពេលបញ្ជូនគាត់មកកាន់អ.វ.ត.ក)។ ការប្រកាសអំពីប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់ជនជាប់ចោទ ឯកសារលេខ E175/1.1 (ដែលចុះហត្ថលេខាដោយជនជាប់ចោទ) នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ (ប្រកាសថា គាត់លែងមានប្រាក់ចំណូល ឬទ្រព្យ

ព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ នោះទេ។ បណ្តឹងរដ្ឋប្បវេណីផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ មានការសន្មតជាមុនថា ទោះបីជាចុងចោទក្នុងបណ្តឹងរដ្ឋប្បវេណីគឺជាជនក្រីក្រក៏ដោយ ក៏ជននេះអាចទទួលបានចំណូលក្នុងពេលអនាគត ឬតតីយជនអាចសងសំណងជំនួសជននេះបានផងដែរ។ ក្រមរដ្ឋប្បវេណីកម្ពុជាចែងយ៉ាងច្បាស់ថា "ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន"[1335] និងចែងអំពីឧបាទេសកម្មនៅក្នុងការអនុវត្តកាតព្វកិច្ច[1336]។ កាតព្វកិច្ចក៏អាចបន្តឱ្យទាយាទរបស់ជនជាប់ចោទ បន្ទាប់ពីការយល់ព្រមទទួលសន្តតិកម្ម[1337]។ ដូច្នេះ ភាពក្រីក្ររបស់អ្នកជាប់កាតព្វកិច្ច មិនបានទាត់ចោលលទ្ធភាពដែលថា កាតព្វកិច្ចរបស់គាត់អាចត្រូវបានអនុវត្តជាចុងក្រោយតាមរយៈការចូលរួមរបស់តតីយជន។

៦៦៧. ផ្អែកតាមការលើកឡើងខាងលើ ដោយពិចារណាលើចរិតលក្ខណៈនៃរបបសំណងរបស់ អ.វ.ត.ក ដែលមាន*លក្ខណៈពិសេស* និងលក្ខណៈទ្វេឯកជន និងសាធារណៈ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា តាមគ្រប់លទ្ធភាព សំណងដែលមិនអាចអនុវត្តបានពោល គឺសំណងដែលមានលក្ខណៈ*ប្រឌិតតាមព្រឹត្តិន័យ*មិនបានបង្ហាញពីគោលបំណងនៃសំណងប្រកប*ដោយប្រសិទ្ធិភាព* និងធ្វើឱ្យភ័ន្តច្រឡំនិងធ្វើឱ្យសោកស្តាយចំពោះជនរងគ្រោះ[1338]។ ខុសគ្នាពី

---

សម្បត្តិផ្ទាល់ខ្លួនណាមួយទេ ឬគាត់មិនសង្ឃឹមថាទទួលបានចំណូលនាពេលអនាគតនោះទេ)។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ចាប់តាំងពីពេលចាប់ខ្លួនជនជាប់ចោទនៅក្នុងឆ្នាំ ១៩៩៩ មក ទ្រព្យសម្បត្តិរបស់ជនជាប់ចោទពុំត្រូវបានរកឃើញ ឬ ពុំត្រូវបានចោទប្រកាន់ឡើយ។

[1335]មាត្រា ៤៣៤(១) (អ្នកសង) ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០២ (គូសបញ្ជាក់បន្ថែម)។ កថាខណ្ឌ(២) និង(៣) នៃមាត្រាដូចគ្នា ចែងថា តតិយជននោះមិនអាចសងបានឡើយ ប្រសិនបើ (ក) ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជនបានទេ ឬ (ខ) ម្ចាស់បំណុល និងកូនបំណុលអាចព្រមព្រៀងគ្នា។

[1336]មាត្រា ៤៥៩ និង*មាត្រាបន្តបន្ទាប់*នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០២។

[1337]*សូមមើល* គន្ថីទី ៨ ("សន្តតិកម្ម") នៃក្រមរដ្ឋប្បវេណីកម្ពុជា។

[1338]*សូមមើល* Phuong Pham *និងអ្នកនិពន្ធដទៃទៀត* "ការចូលរួមរបស់ជនរងគ្រោះ និងការជំនុំជម្រះក្តីខុចនៅអង្គជំនុំវិសាមញ្ញក្នុងតុលាការកម្ពុជា" ទំព័រ ២៦៤ ដល់ ២៨៧ (បង្ហាញថាយោងតាមការស្ទង់មតិមួយ ដើមបណ្តឹងរដ្ឋប្បវេណីទំនងជាមានមតិអវិជ្ជមានជាងប្រជាជនទូទៅដែលរស់នៅក្រោមរបបខ្មែរក្រហម ចំពោះផលប៉ះពាល់នៃការជំនុំជម្រះសំណុំរឿង ០០១ ស្តីអំពីនីតិរដ្ឋ ភាពអត់អោនទោស និងការផ្សះផ្សា)។

បណ្តឹងរដ្ឋប្បវេណីធម្មតា ដែលការស្វែងរកលិខិតអនុវត្តប្រឆាំងនឹងចុងចម្លើយអាស្រ័យនឹងជម្រើស និងផលប្រយោជន៍ឯកជនរបស់ដើមចោទ កិច្ចដំណើរការនីតិវិធីនៃការទាមទារសំណងនៅ អ.វ.ត.ក តម្រូវឱ្យមាន លក្ខខណ្ឌប្រសិទ្ធភាពនៃសំណង ពោលគឺត្រូវមានមូលនិធិដែលអាចរកបាន។ ហេតុដូច្នេះ កម្មវិធីទាមទារសំណងប្រមើលអំពីសំណងនានាដែលជាបន្ទុករបស់រដ្ឋ ក្រុមហ៊ុន ឬមូលនិធិជាក់លាក់[1339]។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ទោះបីជាលក្ខន្តិកៈចែងអំពីការផ្តល់សំណងប្រឆាំងនឹងទណ្ឌិត ដោយមិនគិតពីភាពក្រីក្ររបស់ជននេះក៏ដោយ ក៏ការអនុវត្តសំណងត្រូវបានធានាដោយកម្មវិធីមូលនិធិសំណង[1340]។ នៅតុលាការពិសេសសម្រាប់ប្រទេសលីបង់ ភាពក្រីក្ររបស់ទណ្ឌិតមិនត្រូវយកមកពិចារណាឡើយ ដោយហេតុថា តុលាការដោះស្រាយតែបញ្ហានៃការកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះដែលទទួលរងនូវព្យសនកម្ម ដែលបណ្តាលមកពីឧក្រិដ្ឋកម្មនានា ហើយចំពោះការកំណត់អំពីភាពក្រីក្ររបស់ទណ្ឌិតដែលអាចកើតមាន ជាសមត្ថកិច្ចរបស់តុលាការជាតិ ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត[1341]។

៦៦៨. ដោយពិចារណាថា នៅក្នុងបរិបទរបស់ អ.វ.ត.ក មិនមានយន្តការផ្តល់មូលនិធិពីខាងក្រៅដែលអាចផ្តល់អានុភាពដល់ដីកាបង្គាប់ដែលចេញប្រឆាំងនឹងទណ្ឌិតដែលជាជនក្រីក្រនោះ អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង[1342] ដែលលើកឡើងថា មានភាពសំខាន់បឋមក្នុងការកម្រិតសំណងដែលអាចអនុវត្តបានពិត

---

[1339] *សូមមើល ឧទា.* Heike Niebergall, "ចំណុចខ្សោយនៃភស្តុតាងដែលឈ្នះនៅក្នុងកម្មវិធីស្នើសុំសំណង", ទំព័រ ១៤៥ ដល់ ១៦៦ (ដោយ នៅក្នុងនោះ យោងលើសេចក្តីសម្រេចដំបូងលើបណ្តឹងទាមទារសំណងចំពោះរឿងរ៉ាវ Dormant នៅទីក្រុងហ្សូរីក ប្រទេសស្វីស គណកម្មការផ្តល់សំណងរបស់អង្គការសហប្រជាជាតិ កម្មវិធីផ្តល់សំណងចំពោះពលកម្មដោយបង្ខំនៅប្រទេសអាល្លឺម៉ង់ និងគណកម្មការអន្តរជាតិស្តីពីបណ្តឹងទាមទារសំណងធានារ៉ាប់រងនៅក្នុងយុគសម័យសោដនាដកម្ម)។

[1340] មាត្រា ៧៩ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ។

[1341] មាត្រា ២៥(១) និង(៣) នៃលក្ខន្តិកៈតុលាការពិសេសសម្រាប់ប្រទេសលីបង់ និងមាត្រា ៨៦(ឆ) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់។

[1342] សូមមើលសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៦៤, ៦៦៦។

ប្រាកដ ដោយពិចារណាអំពីស្ថានភាពហិរញ្ញវត្ថុពិតប្រាកដរបស់ពិរុទ្ធជន។ នៅក្នុងន័យអរូបិយ មានលទ្ធភាពអាចប្រមើលបានថា កាំង ហ្គេកអ៊ាវ អាចធ្វើឱ្យខ្លួនឯងមានបាននាពេលអនាគត ឬតតីយជនអាចចូលអន្តរាគមដើម្បីផ្តល់នូវមធ្យោបាយចាំបាច់នានា ដើម្បីផ្តល់មូលនិធិដល់សំណង ដោយជ្រើសរើសធ្វើបែបនេះក្នុងនាម កាំង ហ្គេកអ៊ាវ ជាជាងក្នុងនាមជាតតីយជន។ លទ្ធភាពបែបនេះមានតិចតួចពេកដែលមិនអាចអនុវត្តបាន ហេតុដូច្នេះមិនអាចបង្កើតជាមូលដ្ឋានសម្រាប់បង្គាប់ឱ្យសងសំណងបាននោះទេ។ សំណងដែលសមស្របតាមក្របខណ្ឌសំណងរបស់ អ.វ.ត.ក គឺជា សំណងដែលមានលក្ខណៈសាមញ្ញតែអាចអនុវត្តបាន[1343]។ អង្គជំនុំជម្រះតុលាការកំពូលក៏បញ្ជាក់ផងដែរថា សំណងដែលមានកម្រិតនៅអ.វ.ត.ក មិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះ ដើម្បីស្វែងរក និងទទួលសំណងដែលអាចដោះស្រាយទាំងស្រុងនូវការខូចខាតរបស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធី ដែលអាចមាន សម្រាប់គោលបំណងនេះនាពេលអនាគត[1344]។

[1343] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ត្រង់ចំណុចនេះថា ទោះបីជាវិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មថ្មីៗនេះដើម្បីពង្រីកវិធានការសំណងដែលមាននៅ អ.វ.ត.ក ក៏ដោយ ក៏វិធានទាំងនេះនៅតែមានហេតុផលដូចគ្នា ដោយត្រូវពិចារណាលើលទ្ធភាពនៃមូលនិធិ។ យោងតាមវិធាន ២៣*ក្វាទ្យួន* (វិសោធនកម្មលើកទី ៨) ទម្រង់នៃសំណងជាប្រាក់កាសសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានដាក់បញ្ចូលនោះទេ ហើយសំណងត្រូវតែស្នើឡើងនៅក្នុងសេចក្តីសន្និដ្ឋានរួមតែមួយដែលសេចក្តីសន្និដ្ឋាននេះ ធ្វើការទាមទារសំណងមួយចំនួនមានកំណត់។ គម្រោងសំណងដែលស្នើឡើងត្រូវផ្តល់ហិរញ្ញប្បទានដោយទណ្ឌិត ឬ ដោយម្ចាស់ជំនួយពីខាងក្រៅ។

[1344] *ប្រៀបធៀបសូមមើល* សំណង "សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា" គេហទំព័រ http://www.redress.org/international-criminal-tribunals/international-criminal-tribunal-for-rwanda (កត់សម្គាល់ឃើញថា ក្នុងប្រទេសរ្វ៉ាន់ដា ទោះជាជនជាប់ចោទជាជនក្រីក្រក៏ដោយ ក៏ជនរងគ្រោះបានទាមទារ និងទទួល សំណងជាប្រាក់កាសយ៉ាងច្រើនសន្ធឹកសន្ធាប់ចំពោះការទទួលរងព្យសនកម្ម ក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពិរុទ្ធជន)។ ទោះបីជាយ៉ាងណាក៏ដោយ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលធ្វើការកត់សម្គាល់ថា ធាតុផ្សំមួយចំនួនបង្ហាញថា ការផ្អែកលើស្ថានភាពក្នុងប្រទេសរ្វ៉ាន់ដាមិនសមស្របទៅនឹងសំណុំរឿងរបស់ អ.វ.ត.ក នាពេលបច្ចុប្បន្នឡើយ។ នៅប្រទេសរ្វ៉ាន់ដា សំណងចំពោះព្យសនកម្មត្រូវសម្រេចដោយតុលាការជាតិអនុលោមតាមច្បាប់ជាតិ ដែលបានអនុម័តជាពិសេសសម្រាប់គោលបំណងនេះ ខណៈដែលក្របខណ្ឌច្បាប់ អ.វ.ត.ក មិនមានបទប្បញ្ញត្តិ ចែងព្យាករណ៍ទុកថា សេចក្តីសម្រេចលើ

### ៧.ខ.២.ឃ. ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការដាក់សំណើទាមទារសំណងជាក្រុម ដោយមិនបានបង្ហាញច្បាស់លាស់អំពីសំអាងហេតុផល់ការបដិសេធលើសំណើនីមួយៗ

៦៦៩. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចលើសំណើទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន តាមរយៈដាក់បញ្ចូលសំណើសុំរបស់ពួកគេទៅក្នុងប្រភេទទូទៅដាច់ដោយឡែកចំនួនប្រាំបី ដោយមិនបានបង្ហាញអំពីមូលហេតុចំពោះការទាមទារនីមួយៗ លើកលែងតែការលើកឡើងមួយចំនួនតាមរយៈឧទាហរណ៍ប៉ុណ្ណោះ។ ការធ្វើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានសន្សំសំចៃធនធានដ៏មានតម្លៃរបស់ខ្លួន ប៉ុន្តែ មិនបានផ្តល់ឱ្យអ្នកដាក់ពាក្យសុំពីសំអាងហេតុនៃការបដិសេធចោលសំណើសុំពិតប្រាកដនោះទេ។ បញ្ហានៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺថាតើចំណាត់ការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងនេះបានរំលោភបំពាន លើសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី ពោលគឺសិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុដែរ ឬយ៉ាង ណា។

៦៧០. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ នៅក្នុងសារណារបស់ខ្លួន បានបង្ហាញអំពីកម្រិតអន្តរជាតិដើម្បីអះអាងអំពីសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ ដែលមានជាប់ជាមួយនឹងសេចក្តីសម្រេចលើសំណើសុំសំណង។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មិនចាំបាច់ពឹងផ្អែកលើវិធាននានានៅកម្រិតអន្តរជាតិនោះទេ ដោយហេតុថាសិទ្ធិដែលពាក់ព័ន្ធអាចទាញចេញពីច្បាប់នីតិវិធីកម្ពុជាបាន។ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសេចក្តីសម្រេចមានសំអាងហេតុមានចែងជា ដំបូងនៅក្នុងមាត្រា ១៣៩(៤) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ដោយយោងតាមមាត្រានេះ នៅពេលដែល សហចៅក្រមស៊ើបអង្កេតបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចមួយដោយមាន "សំអាងហេតុ" ក្នុងករណីដែលគាត់សម្រេចមិនស៊ើបអង្កេត ហើយដីកាសម្រេចនេះត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជា

---

សំណងនៅ អ.វ.ត.ក ត្រូវបញ្ជូនឱ្យទៅតុលាការជាតិ ឬ ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត។ លើសពីនេះ នៅពេលដែលសេចក្តីសម្រេចរបស់តុលាការពុំត្រូវបានអនុវត្តទេនោះ វាបញ្ជាក់នូវអប្រសិទ្ធភាពរបស់តុលាការលើបញ្ហានេះ។

ដើមបណ្តឹងរដ្ឋប្បវេណី។ អង្គហេតុដែលថា ដីកានេះអាចប្តឹងឧទ្ធរណ៍បាន[1345]បញ្ជាក់អំពីចំណុចមួយនៃសំអាងហេតុតុលាការ ពោលគឺដើម្បីផ្តល់អត្ថន័យ ពេញលេញដល់សិទ្ធិស្នើសុំពិនិត្យឡើងវិញនៅដំណាក់កាលឧទ្ធរណ៍ ឬសាទុក្ខ។ ពាក់ព័ន្ធដូចគ្នានេះដែរគឺមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ បានចែងថា សេចក្តីសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី គឺជាផ្នែកនៃសាលក្រមដែលបង្កប់ន័យថា តុលាការត្រូវតែផ្តល់សំអាងហេតុគ្រប់គ្រាន់ដើម្បី"ឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី"[1346]។ ករណីនេះអាចឱ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍បាន ចំពោះផលប្រយោជន៍រដ្ឋប្បវេណីនៃរឿងក្តី[1347] ហើយជាយថាហេតុអាចដាក់បណ្តឹងសាទុក្ខ[1348] ដោយផ្អែកលើមូលដ្ឋានថា "គ្មានសំអាងហេតុ"[1349]។

៦៧១. អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ដើមបណ្តឹងរដ្ឋប្បវេណីបានអនុវត្តសិទ្ធិក្នុងការទទួលបានសេចក្តីសម្រេច ដែលមានសំអាងហេតុត្រឹមត្រូវស្តីពីបណ្តឹងទាមទារសំណងរបស់ខ្លួន។ នាពេលបច្ចុប្បន្ន អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេច ថាតើការផ្តល់សំអាងហេតុបែបសំយោគរបស់អង្គជំនុំជម្រះសាលាដំបូងពិតជាបានរំលោភសិទ្ធិនេះមែន ដែរ ឬយ៉ាងណា។ ជាបឋម ក្រៅពីលក្ខខណ្ឌណាមួយដែលច្បាប់បានកំណត់ ចៅក្រម គឺជាអ្នកសម្រេចទៅលើលក្ខណៈនៃការផ្តល់សំអាងហេតុ។ តាមទស្សនៈនេះ វិធីសាស្ត្រនៃការបង្កើតប្រភេទទូទៅនៃសំណើ រួចបន្ទាប់មកធ្វើការដោះស្រាយសំណើទាំងនោះដោយការសំយោគមិនមានកំហុសឡើយ។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ចំណាត់ការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងពិតជាបានរំលោភទៅលើសិទ្ធិ ក្នុងការទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ ត្រង់ចំណុចដែលថា អង្គជំនុំជម្រះសាលាដំបូងពុំអនុញ្ញាតឱ្យម្ចាស់បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណី បានដឹងច្បាស់លាស់អំពីសំអាងហេតុនានាពាក់ព័ន្ធនឹង

---

[1345]មាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧។

[1346]មាត្រា ៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ (គូសបញ្ជាក់បន្ថែម)។

[1347]មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។

[1348]មាត្រា ៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។

[1349]មាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។

សំណើទាមទារសំណងមួយចំនួនរបស់ខ្លួនឡើយ[1350]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា មានការរំលោភសិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការទទួលបានសេចក្ដីសម្រេចដែលមានសំអាងហេតុ ហើយដើម្បីជួសជុលបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូល ត្រូវផ្ដល់សំអាងហេតុរបស់ខ្លួនផ្ទាល់ចំពោះសំណើទាមទារសំណងដែលបានលើកឡើងសាជាថ្មីនៅពេលប្ដឹងសាទុក្ខ។

### *៧.ខ.២.ង.សំណើទាមទារសំណងជាក់លាក់របស់ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណី*

#### *៧.ខ.២.ង.១.ការចងក្រង និងផ្សព្វផ្សាយពាក្យសម្ដីសុំអភ័យទោស និងការចងក្រងមតិយោបល់របស់ដើមបណ្ដឹងរដ្ឋប្បវេណី*

៦៧២. ដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំចងក្រង និងផ្សព្វផ្សាយពាក្យសម្ដីសុំអភ័យទោសដែល កាំង ហ្គេកអ៊ាវ បានលើកកាលពីក្នុងអំឡុងពេលសវនាការ រួមនឹងមតិយោបល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីពាក្យពេចន៍ទាំងអស់នោះ[1351]។ អង្គជំនុំជម្រះសាលាដំបូងបានឯកភាពទៅលើសំណើរសុំចងក្រង និងផ្សព្វផ្សាយពាក្យសម្ដីសុំអភ័យទោសរបស់ជនជាប់ចោទ ប៉ុន្ដែបានបដិសេធមិនដាក់បញ្ចូលមតិយោបល់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយផ្ដល់សំអាងហេតុថាមតិយោបល់ទាំងនេះខុសពីពាក្យសម្ដីសុំអភ័យទោស ហើយខ្លឹមសារនៃមតិយោបល់ទាំងនោះគ្មានភាពច្បាស់លាស់[1352]។

៦៧៣. ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី ២ បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបដិសេធពុំព្រមដាក់មតិយោបល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីទៅក្នុងពាក្យសម្ដីសុំអភ័យទោស

---

[1350]បណ្ដឹងសាទុក្ខស្ដីអំពីសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី ២, កថាខណ្ឌ ៨៥ ដល់ ៨៧ (ដែលបានអះអាងត្រឹមត្រូវថាអង្គជំនុំជម្រះសាលាដំបូង ពុំបានសម្រេចលើសំណើសុំឱ្យបង់ប្រាក់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះការធ្វើទស្សនកិច្ច ទៅកាន់ទីបូជនីយដ្ឋាន) ៥៨, ១២៧ (ដោយកត់សម្គាល់យ៉ាងត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចលើសំណើនេះថា ជនជាប់ចោទត្រូវបានបង្គាប់ឲ្យសរសេរលិខិតចំនួនពីរច្បាប់ជូនទៅរាជរដ្ឋាភិបាលកម្ពុជា)។

[1351]អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៥២, ៦៥៧។

[1352]អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៦៨។

របស់ កាំង ហ្គេកអ៊ាវ ដោយសំអាងថាមតិយោបល់ទាំងនោះពុំមានភាពច្បាស់លាស់ ពីព្រោះ "គេពុំអាចនិយាយថាពាក្យសម្តីសុំអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ មានភាព"ជាក់លាក់" ជាងពាក្យពេចន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ"[1353]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ អះអាងទៀតថា ជាការពិតជាក់ស្តែងដែលថា មតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី "ខុសប្លែក"ពីពាក្យសម្តីសុំអភ័យទោសរបស់ ឌុច ទើបការលើកឡើងនេះពុំមែនជាសំអាងហេតុដែលមានសុពលភាព សម្រាប់បដិសេធសំណើដាក់បញ្ចូលយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងពាក្យសម្តីសុំអភ័យទោសរបស់ ឌុច នោះឡើយ[1354]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានសន្និដ្ឋានដោយនៅរក្សាជំហរថា អង្គជំនុំជម្រះសាលាដំបូងពិតជាមិនបានផ្តល់សំអាងហេតុក្នុងការសម្រេចបដិសេធសំណើនេះ ហើយ ហេតុដូច្នេះ បានរំលោភវិធាន ២១ (១)(ក) និង(គ) នៃវិធានផ្ទៃក្នុង[1355]។

៦៧៤. ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល បានកត់សម្គាល់នូវអំណះអំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ដែលថា ដោយសារការកែប្រែយុទ្ធសាស្ត្ររបស់មេធាវីការពារក្តីដែលធ្វើឱ្យសំណើសុំលើកលែងការចោទប្រកាន់របស់ កាំង ហ្គេកអ៊ាវ មានភាពយឺតយ៉ាវទើបធ្វើឱ្យ "[សំណើសុំចងក្រងពាក្យសម្តីសុំអភ័យទោស]លែងមានសារៈសំខាន់ ហើយកាន់តែលែងមានអត្ថន័យប្រសិនបើ ពុំមានការដាក់មតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីចូលទៅក្នុងការសុំអភ័យទោសទាំងអស់នោះ ដែលបានធ្វើនៅសវនាការនាពេលកន្លងមក"[1356]។ នៅក្នុងសវនាការលើបណ្តឹងសាទុក្ខ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ នៅរក្សាជំហរដដែលនេះ[1357] ហើយដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ បានឯកភាពថាពាក្យសម្តីសុំអភ័យទោសរបស់

---

[1353]ប្រតិចារឹកថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១ ឯកសារ F1/4.1, ទំព័រ ៤៤ (បន្ទាត់១៦ ដល់ ២៣)។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមស្តីពីសំណងដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ៥០ និង ៥១។

[1354]បណ្តឹងសាទុក្ខស្តីអំពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណ ក្រុម ២, កថាខណ្ឌ ៤៩។

[1355]បណ្តឹងសាទុក្ខស្តីអំពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណ ក្រុម ២, កថាខណ្ឌ ៥២ និង ៥៣។

[1356]បណ្តឹងសាទុក្ខស្តីអំពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណក្រុម ២, កថាខណ្ឌ ៤៦។

[1357]ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១ ឯកសារ F1/4.1 ទំព័រ ៤១ (បន្ទាត់ ១២ ដល់ ១៦)។

កាំង ហ្គេកអ៊ាវ ពុំអាចត្រូវបានចាត់ទុកជាសំណងប្រកបដោយអត្ថន័យបានឡើយ ដរាបណាជនរងគ្រោះយល់ថា ជាពាក្យភូតកុហក[1358]។

៦៧៥. ថ្វីត្បិតការចងក្រង និងការផ្សព្វផ្សាយពាក្យសម្តីសុំអភ័យទោសទាំងអស់នេះ ពុំមែនជាការបង្គាប់ដល់ កាំង ហ្គេកអ៊ាវ ក្តី ក៏អង្គជំនុំជម្រះសាលាដំបូង បានឯកភាពទៅនឹងសំណើនេះដោយសំអាងថា "ការទទួលស្គាល់ទូទៅនៃវិធានការស្រដៀងគ្នា គឺជាសំណង"[1359]។ គោលការណ៍មូលដ្ឋានអង្គការសហប្រជាជាតិ ស្តីពីសំណងក៏មានចែងថា[1360]សំណងរួមបញ្ចូលនូវវិធានការបំពេញចិត្តនានាដូចជា ការសុំអភ័យទោសជាសាធារណៈ ក្នុងនោះរួមមានការទទួលស្គាល់ការពិត និងការទទួលខុសត្រូវ។ គួរកត់សម្គាល់ថា ក្នុងក្របខណ្ឌអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ACHR) ការសុំអភ័យទោសពាក់ព័ន្ធជាចម្បងទៅនឹង*រដ្ឋភាគី* ដែលសុំអភ័យទោសចំពោះការរំលោភបំពានធ្ងន់ធ្ងរទៅលើសិទ្ធិជនរងគ្រោះ ដែលមានចែងក្នុងអនុសញ្ញានេះ ហើយការសុំអភ័យទោសធ្វើឡើង ដើម្បី"ជាវិធានការមួយសម្រាប់ជាសំណងដល់ជនរងគ្រោះ និងជាវិធានការទប់ស្កាត់មិនឱ្យកើតមានជាថ្មីម្តងទៀតនូវអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ"[1361]។

៦៧៦. ការសុំអភ័យទោសក្នុងលក្ខណៈជាសំណងពុំរំពឹងថា មានការចូលរួមរបស់ជនរងគ្រោះជាមតិយោបល់ពាក់ព័ន្ធនឹងពាក្យសម្តីសុំអភ័យទោសទាំងនោះឡើយ។ ប៉ុន្តែ ជាទម្លាប់នៃការអនុវត្តទូទៅ ការសុំអភ័យទោសក្នុងប្រភេទជាសំណងនេះ គឺស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ

---

[1358]ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១ ឯកសារ F1/4.1 ទំព័រ ៧១ (បន្ទាត់ ១០ ដល់ ១៨)។ *សូមមើលផងដែរ* ប្រតិចារឹកថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារ F1/4.1, ទំព័រ ទំព័រ ៧៥ (បន្ទាត់ ២៤) ដល់ទំព័រ ៧៦ (បន្ទាត់ ២០) ដែលបញ្ជាក់ថា ពួកគាត់មិនពេញចិត្តដូចគ្នាចំពោះអាកប្បកិរិយាសូមទោសរបស់ជនជាប់ចោទនៅពេលសវនាការលើបណ្តឹងសាទុក្ខ)។

[1359]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ជើងទំព័រ ១១៥៣។

[1360]មាត្រា IX(22)(e) នៃគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសំណង។

[1361]*រឿងក្តី Ituango Massacres ទល់នឹង ប្រទេសកូឡុំប៊ី*, "សាលក្រម (អញ្ញត្រកម្ម, អង្គសេចក្តី, សំណង និងការចំណាយ)", កថាខណ្ឌ ៤០៦។

ដើម្បីធានាថាការសុំអភ័យទោសធ្វើឡើងប្រកបដោយសេចក្តីថ្លៃថ្នូរ[1362]។ នៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ន ទោះបីពាក្យសម្តីសុំអភ័យទោសពុំត្រូវបានចងក្រងដោយ កាំង ហ្កេកអ៊ាវ ក៏ដោយ ក៏ពាក្យពេចន៍ទាំងនោះពិតជាផុសចេញពីចិត្តរបស់គាត់ និងឆ្លុះបញ្ចាំងការពិតជាក់ស្តែងនៃកិច្ចដំណើរការនីតិវិធីថែមទៀតផង។ អង្គជំនុំជម្រះតុលាការកំពូលយល់ថាចំណុចនេះ ជាគុណសម្បត្តិមួយទៀត បើប្រៀបធៀបជាមួយនឹងការសុំអភ័យទោសដែលរៀបចំឡើងតាមការកំហិតរបស់តុលាការ ហើយម្យ៉ាងទៀតក៏ដកចេញនូវរាល់បញ្ហានានាទាក់ទងនឹងការអនុវត្តដូចដែលនឹងលើកយកមកពិភាក្សាខាងក្រោម។ ផ្ទុយទៅវិញ ការសុំអភ័យទោសដែលរួមបញ្ចូលនូវការរិះគន់របស់អ្នកអាន ឬដែលរួមបញ្ចូលនូវខ្លឹមសារនានាដែលបន្ទាបបន្ថោកពិរុទ្ធជន នឹងធ្វើឱ្យពាក្យសម្តីសុំអភ័យទោសនេះឯងបន្ថយតម្លៃរបស់ខ្លួន ហើយក៏មិនបម្រើគោលបំណងនៃការបំពេញចិត្តផងដែរ។

---

[1362] ការពិនិត្យឡើងវិញទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស (“IACtHR”) ដែលទាក់ទិនទៅនឹងសំណងបញ្ជាក់ថា ខណៈដែលតុលាការ IACtHR បានបង្កើតវិធីសាស្ត្រមួយបែបសេរី ច្នៃប្រឌិត និងមានក្រឹត្យក្រមចំពោះសំណងដល់ជនរងគ្រោះ (ដោយរួមមាន ការប្រើប្រាស់ការទទួលយករបស់សាធារណជនចំពោះការទទួលខុសត្រូវ និងការសូមអភ័យទោស) វិធីសាស្ត្រនេះមិនបានលាតសន្ធឹងដោយរួមបញ្ចូលទាំងយោបល់របស់ជនរងគ្រោះស្តីពីការសុំអភ័យទោសជាសាធារណៈនោះទេ។ *សូមមើល ឧទា. រឿងក្តី Plan de Sánchez Massacre ទល់នឹង ប្រទេសហ្គាតេម៉ាឡា* “សាលក្រម (សំណង)” តុលាការ IACtHR ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ ១០០ (ដោយចេញដីកាបង្គាប់មួយយ៉ាងពិស្តារដែលថា រដ្ឋភាគីចុងចោទត្រូវសុំអភ័យទោសជាសាធារណៈដល់សហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារឧក្រិដ្ឋកម្ម និងត្រូវផ្សព្វផ្សាយការសុំអភ័យទោសនោះនៅតាមបណ្តាញសារព័ត៌មាន)។ *រឿងក្តី Ituango Massacres ទល់នឹង ប្រទេសកូឡុំប៊ី* “សាលក្រម (អញ្ញត្រកម្ម, អង្គសេចក្តី, សំណង និងការចំណាយ)” កថាខណ្ឌ ៤០៦ (ដែលបង្គាប់ឱ្យរដ្ឋជាភាគីចុងចោទត្រូវទទួលស្គាល់ជាសាធារណៈ ដោយមានវត្តមានអាជ្ញាធរជាន់ខ្ពស់ អំពីការទទួលខុសត្រូវជាអន្តរជាតិរបស់ខ្លួនចំពោះការសម្លាប់រង្គាល និងការសុំអភ័យទោសចំពោះសាច់សារលោហិតរបស់ជនរងគ្រោះ) *រឿងក្តី Zambrano-Vélez និងជនដទៃទៀត ទល់នឹង ប្រទេសអេក្វាឌ័រ* “សាលក្រម (អង្គសេចក្តី, សំណង និងការចំណាយ)” តុលាការ IACtHR ចុះថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០០៧ ត្រង់កថាខណ្ឌ ១៥០ (ដោយបង្គាប់ឱ្យរដ្ឋជាភាគីចុងចោទរៀបចំសកម្មភាពជាសាធារណៈទទួលស្គាល់ពីការទទួលខុសត្រូវរបស់ខ្លួនចំពោះការរំលោភបំពាន នៅចំពោះមុខសមាជិកគ្រួសារជនរងគ្រោះ ដោយមានការចូលរួមពីអាជ្ញាធរជាន់ខ្ពស់របស់រដ្ឋផងដែរ)។

00798835



៦៧៧. ជាការឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ដែលសម្តែងនូវការសង្ស័យ ទាក់ទងទៅនឹងភាពស្មោះត្រង់នៃពាក្យសម្តីសុំអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា អ្នកអាន និងអ្នកស្តាប់ពាក្យសម្តីសុំអភ័យទោសនេះ មានបំណងប្រាថ្នាចង់ឱ្យពាក្យសម្តីសុំអភ័យទោសនេះជាការសម្តែងនូវវិប្បដិសារីដ៏ស្មោះត្រង់មួយ។ ទោះបីជាយ៉ាងណាក៏ដោយភាពស្មោះត្រង់ពុំអាចចាប់បង្ខំបានឡើយ ហើយការដាក់បញ្ចូលនូវមតិយោបល់ទៅ ក្នុងពាក្យសម្តីសុំអភ័យទោសរបស់ ឌុច ក៏មិនបានធ្វើឱ្យពាក្យសម្តីសុំអភ័យទោសរបស់ ឌុច កាន់តែមាន ភាពស្មោះត្រង់នោះដែរ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជាជនរងគ្រោះមួយ ចំនួនមិនទទួលស្គាល់ភាពស្មោះត្រង់នៃពាក្យសម្តីសុំអភ័យទោសនេះក៏ដោយ ក៏តម្លៃនៃការសុំអភ័យទោស នេះនៅតែរក្សាបានតាមរយៈការបោះពុម្ព និងការរំឭកអំពីព្យសនកម្ម និងការសុំអភ័យទោស។ ការសុំអភ័យទោសមិនរលត់ផុតទៅតាមពេលវេលា និងមានតម្លៃជាងរូបភាពបន្ទប់សវនាការទៅទៀត[1363] ហើយក្នុងន័យនេះ ការសុំអភ័យទោសរួមចំណែកឱ្យមានសំណងប្រកបដោយយុត្តិធម៌នៅពេលអនាគត និងសម្រាប់មនុស្សជំនាន់ក្រោយដោយទុកឱ្យជនរងគ្រោះនូវជម្រើសក្នុងការទទួលយកការសុំអភ័យទោសនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុស ក្នុងការសម្រេចពុំដាក់បញ្ចូលមតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនឡើយ។ ជាងនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើចំណុចនេះ ពុំបានហាម

[1363]អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា តុលាការ IACtHR ពិតជាបានឆ្លើយតបទៅនឹងរឿងក្តីនានាដែលការអភ័យទោសរបស់រដ្ឋត្រូវបានយកមកពិចារណាតែមួយផ្នែកប៉ុណ្ណោះ ហើយបានសម្រេចថា ការសុំអភ័យទោសនេះតំណាងឱ្យ "ការចូលរមចំណែកជាវិជ្ជមាន" និង "ការចូលរួមចំណែកដ៏មានតម្លៃ" ចំពោះវឌ្ឍនភាពនៃកិច្ចដំណើរការនីតិវិធី និងការអនុវត្តសិទ្ធិមនុស្ស។ *រឿងក្តី Molina-Theissen ទល់នឹង ប្រទេសហ្គាតេម៉ាឡា*, "សាលក្រម (អង្គសេចក្តី)" តុលាការ IACtHR, ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០០៤ ត្រង់កថាខណ្ឌ ៤៦ *រឿងក្តី Ticona Estrada និងជនដទៃទៀត ទល់នឹង ប្រទេសបូលីវី* "សាលក្រម (អង្គសេចក្តី សំណង់ និងសោហ៊ុយ" ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ត្រង់កថាខណ្ឌ ២៦។ ទោះក្នុងករណីណាក៏ដោយ ទោះបីជាភាពលម្អៀងនៃការអភ័យទោសជួនកាលនាំឱ្យតុលាការ IACtHR បង្គាប់ឱ្យរដ្ឋជាភាគីចុងចម្លើយចាត់វិធានការបន្ថែមលើសំណង ក៏រដ្ឋទាំងនេះពុំបានបញ្ចូលយោបល់របស់ជនរងគ្រោះស្តីអំពីការសុំអភ័យទោសបែបនេះទេ។

ឃាត់ដើមបណ្ដឹងរដ្ឋប្បវេណី មិនឱ្យបញ្ចេញមតិយោបល់អំពីពាក្យសម្ដីសុំអភ័យទោសរបស់ ឌុច នៅក្រៅក្របខណ្ឌនៃសាលដីកាស្ដាពរឡើយ។

### ៧.ខ.២.ឃ.២.លិខិតសុំការអភ័យទោសពីរដ្ឋាភិបាល

៦៧៨. ដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើសុំទាមទារឱ្យ កាំង ហ្គេកអ៊ាវ សរសេរលិខិតចំហមួយច្បាប់ ផ្ញើជូនរាជរដ្ឋាភិបាលកម្ពុជាដើម្បីសុំការអភ័យទោសដោយស្មោះត្រង់ ឥតបន្ទំ និងប្រកបដោយសច្ចៈភាពពីរដ្ឋ[1364]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ ដោយសំអាងថា សំណើនេះពុំស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ឡើយ ហើយមានតែរាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះ ដែលមានបុព្វសិទ្ធិសម្រេចលើការចេញសេចក្ដីថ្លែងសុំអភ័យទោសនេះ[1365]។ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ២ បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុចំពោះការបកស្រាយខ្លឹមសារនៃសំណើនេះពុំបានត្រឹមត្រូវជាក់ស្ដែងនៅត្រង់ការដាក់បញ្ចូលសំណើនេះទៅក្នុងសាលក្រម ក្រោមចំណងជើងថា "សំណើសុំវិធានការពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា[1366]។ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ២ បានអះអាងថា ខ្លឹមសារជាក់ស្ដែងនៃសំណើរបស់ខ្លួន គឺគ្រាន់តែជាការបង្គាប់ឱ្យ កាំង ហ្គេកអ៊ាវ សរសេរលិខិតមួយច្បាប់ប៉ុណ្ណោះ ពុំមែនបង្គាប់ឱ្យរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការណាមួយឡើយ[1367]។ ម្យ៉ាងទៀត ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ២ អះអាងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភវិធាន ១០០(១) នៃវិធានផ្ទៃក្នុង ដោយពុំបានចេញសេចក្ដីសម្រេចជាក់លាក់តាមការស្នើសុំនេះ[1368]។

---

[1364]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៥៦។

[1365]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧១។

[1366]បណ្ដឹងសាទុក្ខស្ដីអំពីសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ២ កថាខណ្ឌ ៥៦ (ដោយយោងសាលក្រម ត្រង់ចំណងជើង ៤.៤.៣.៥ ពាក់ព័ន្ធនឹងកថាខណ្ឌ ៦៧១)។

[1367]បណ្ដឹងសាទុក្ខស្ដីអំពីសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ២ កថាខណ្ឌ ៥៧។ ប្រតិចារឹកថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/4.1, ទំព័រ ៤៥ (បន្ទាត់ ១១ ដល់១៤) ។

[1368]បណ្ដឹងសាទុក្ខស្ដីអំពីសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ២ កថាខណ្ឌ ៥៥ និង ៦០។

៦៧៩. បន្ទាប់ពីបានពិនិត្យមើលសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ទៅអង្គជំនុំជម្រះសាលាដំបូងផ្តោតទៅលើ "ការសុំអភ័យទោសពីសំណាក់រាជរដ្ឋាភិបាល"[1369]ដើម្បីទទួលបានការអភ័យទោស "ស្មោះត្រង់ពិតប្រាកដ និងត្រឹមត្រូវ" ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាដែលជាអ្នកបន្តវេនពីរបបកម្ពុជាប្រជាធិបតេយ្យ នូវរាល់បទឧក្រិដ្ឋទាំងប៉ុន្មានដែលរបបកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្ត។ បើតាមទស្សនៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ លិខិតជាចំហមួយរបស់ កាំង ហ្គេកអ៊ាវ ផ្ញើជូនរាជរដ្ឋាភិបាលកម្ពុជានឹងជួយ "រួមចំណែកដល់ដំណើរការ"ផ្សះផ្សា[1370]។ អង្គជំនុំជម្រះតុលាការកំពូល ឯកភាពតាមទស្សនៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សំណើនេះមានចេតនាចង់ឱ្យរដ្ឋផ្តល់សំណង[1371]។ ម្យ៉ាងទៀត តាមរយៈការបកស្រាយក្នុងបណ្តឹងសាទុក្ខ សំណើនេះមានគោលបំណងប្រើប្រាស់ កាំង ហ្គេកអ៊ាវ ជាមធ្យោបាយក្នុងការបញ្ជូនសារ ប៉ុន្តែសំណើនេះនៅតែសំដៅទៅរាជរដ្ឋាភិបាលកម្ពុជា ថ្វីបើពុំពាក់ព័ន្ធនឹង កាំង ហ្គេកអ៊ាវ ក៏ដោយ[1372]។ ទោះបីជាការសុំអភ័យទោសពីសំណាក់រដ្ឋាភិបាល ឬការទទួលស្គាល់នូវការទទួលខុសត្រូវជាទម្រង់នៃសំណងដែលត្រូវបាន អនុវត្តជាអន្តរជាតិក៏

---

[1369]សារណាចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ២), កថាខណ្ឌ ៩ ដល់ ១៤។

[1370]សារណាចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ២), កថាខណ្ឌ ១៤។

[1371]សារណាចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ២), កថាខណ្ឌ ១៣ (ដោយលើកឡើងថា "ចំពោះហេតុផលដែលបានលើកឡើងរួចមកហើយនេះ [ទាក់ទងនឹងការសុំអភ័យទោសរបស់រដ្ឋ] ដើមបណ្តឹងរដ្ឋប្បវេណីជឿជាក់ថា វាដល់ពេលវាលា*សម្រាប់រដ្ឋាភិបាលកម្ពុជា*ធ្វើការសុំអភ័យទោសដោយស្មោះត្រង់ ឥតក្លែងបន្លំ និងសច្ចៈ ចំពោះឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នង ដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ") (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សារណារួមគ្នារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ E159/3 ("សារណារួមគ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណី") ជើងទំព័រលេខ ៦ (ដោយលើកឡើងថា "ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានស្នើបន្ថែមទៀតថា តុលាការមានអំណាចស្នើឱ្យមានការទទួលស្គាល់ជាផ្លូវការ និងការសុំអភ័យទោស*ពីរដ្ឋាភិបាលកម្ពុជា*") (គូសបញ្ជាក់បន្ថែម)។

[1372]បញ្ហានេះត្រូវបានបញ្ជាក់កាន់តែច្បាស់ ដោយសារម្ចាស់បណ្តឹងឧទ្ធរណ៍ពុំមានការជឿជាក់ ចំពោះភាពស្មោះត្រង់របស់ កាំង ហ្គេកអ៊ាវ។

ដោយ[1373] ក៏ការសម្រេចបែបនេះមិនអាចធ្វើទៅបានឡើយ នៅក្នុងក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសណាមួយឡើយ ក្នុងការបដិសេធសំណើនេះ។

៦៨០. លើសពីនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដីកាសម្រេចប្រភេទនេះ ពុំអាចអនុវត្តប្រឆាំងនឹង កាំង ហ្កេកអ៊ាវ បានឡើយ ដោយហេតុថាគោលការណ៍ច្បាប់មានការវិវត្តន៍ប្រែប្រួលដែលពុំអាចចាប់បង្ខំជនណាម្នាក់ឱ្យបំពេញកាតព្វកិច្ច ក្នុងការអនុវត្ត*តាមការកំណត់*ដែលជាកាតព្វកិច្ចផ្ទាល់ខ្លួនបានឡើយ[1374]។ ប្រសិនបើតាមការអះអាងថាតុលាការជាអ្នក

---

[1373] *សូមមើល ឧទា. រឿងក្តី Ituango Massacres ទល់នឹង ប្រទេសកូឡុំប៊ី*, សាលក្រម (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងការចំណាយ), កថាខណ្ឌ ៤០៦។

[1374]ច្បាប់ពាក់ព័ន្ធនឹងកាតព្វកិច្ច*ត្រូវបំពេញ* មានចែងច្បាស់នៅក្នុងប្រពន្ធ័ច្បាប់អង់គ្លូសាក់សុង និងប្រពន្ធ័ច្បាប់ស៊ីវិល ជាពិសេសក្នុងបរិបទនៃសំណងចំពោះការរំលោភកិច្ចសន្យា។ *សូមមើលជាទូទៅព្រឹត្តប័ត្ររបស់* G. H. Treitel 'សំណងចំពោះការរំលោភកិច្ចសន្យា', *នៅក្នុងសព្វវចនធិប្បាយអន្តរជាតិស្តីពីច្បាប់ដែលមានលក្ខណៈប្រហាក់ប្រហែល* លេខ ៧ J CB Mohr ឆ្នាំ ១៩៧៦ ត្រង់ទំព័រ ១៣។ Randy Barnett 'សំណងចំពោះកិច្ចសន្យា និងសិទ្ធិដែលមិនផ្តាច់ចេញបាន', *ចេញផ្សាយនៅក្នុងទស្សនៈវិទ្យា និងគោលនយោបាយស្តីពីសង្គម*, វ៉ុល ៤:១ (ឆ្នាំ ១៩៨៦) ទំព័រ ១៧៩ ដល់ ២០២។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ជាឧទាហរណ៍ ក្រោមច្បាប់កិច្ចសន្យា បារាំង អាល្លឺម៉ង់ និងស្វីស សំណងសមស្របចំពោះការរំលោភកាតព្វកិច្ច*ត្រូវបំពេញ*របស់រូបវន្តបុគ្គល គឺជាការបង្គាប់ឱ្យផ្តល់សំណងជាប្រាក់កាសចំពោះការពុំបានធ្វើតាមសន្យាដែលរងការខកចិត្ត។ ផ្ទុយមកវិញ ការបង្គាប់តាមរយៈវិធានការចាប់បង្ខំផ្សេងៗឱ្យបំពេញកាតព្វកិច្ចជាក់លាក់នឹងបង្កើតជាការជ្រៀតជ្រែកមកលើសេរីភាពរបស់បុគ្គល។ Charles Szladits, 'ទស្សនៈនៃការអនុវត្តនៅក្នុងប្រពន្ធ័ច្បាប់ស៊ីវិល' *ចេញផ្សាយដោយព្រឹត្តប័ត្រស្តីពីច្បាប់ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា*, វ៉ុល ៤:២ (ឆ្នាំ ១៩៩៥), ទំព័រ ២១៦, ២២៦, ២៣០ ជើងទំព័រ ៣១។ *សូមមើលផងដែរ* Louis J. Romero, 'ការបំពេញកាតព្វកិច្ចជាក់លាក់លើកិច្ចសន្យាក្នុងច្បាប់ដែលមានលក្ខណៈប្រហាក់ប្រហែលៈ ការសង្កេតជាបឋម', ចេញផ្សាយនៅក្នុង *Les Cahiers de Droit* វ៉ុល ២៧ (ឆ្នាំ ១៩៨៦), ទំព័រ ៨០៥ ដល់ ៨០៦។ Alan Schwartz 'រឿងក្តីសម្រាប់ការបំពេញកាតព្វកិច្ចជាក់លាក់' *ចេញផ្សាយនៅក្នុងព្រឹត្តប័ត្រច្បាប់សាលកវិទ្យាល័យយ៉េល* វ៉ុល ៨៩:២ (ឆ្នាំ ១៩៧៩), ទំព័រ ២៩៧។ Lando H., Rose C., "ការពង្រឹងការបំពេញកាតព្វកិច្ចជាក់លាក់នៅក្នុងប្រទេស ដែលអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល, ការពិនិត្យជាអន្តរជាតិទៅលើច្បាប់សេដ្ឋកិច្ច" លេខ ២៤ (ឆ្នាំ ២០០៤) ទំព័រ ៤៣៧ ដល់ ៤៨៧ (ដោយបានធ្វើការកត់សម្គាល់ថា ការបំពេញកាតព្វកិច្ចជាក់លាក់ណាមួយជាសំណងដ៏កម្រមួយនៅដេណឺម៉ាក,អាល្លឺម៉ង់ និងបារាំង ដោយហេតុថា វាមានលក្ខណៈចាប់បង្ខំពុំចាំបាច់ និងវិសមាមាត្រនឹងចំណាយរដ្ឋបាល)។ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ក៏បានទទួលស្គាល់ហេតុផលស្រដៀងគ្នានេះ

បង្គាប់ក៏ដោយ ក៏ការបំពេញកាតព្វកិច្ចនេះវាអាស្រ័យទៅលើឆន្ទៈរបស់ កាំង ហ្កេកអ៊ាវ។ ដូច ដែលយើងបានពិភាក្សាខាងលើ ដោយសារ កាំង ហ្កេកអ៊ាវ ជាជនក្រីក្រ ទើបការដាក់ទណ្ឌកម្ម ហិរញ្ញវត្ថុចំពោះការពុំបានអនុវត្តតាមការបង្គាប់ ពុំធានាថា កាតព្វកិច្ចនេះត្រូវបានបំពេញ ឡើយ។ ប្រហាក់ប្រហែលគ្នានេះ ថ្វីត្បិតការឃុំខ្លួនដែលជាទណ្ឌកម្មក្នុងករណីដែលពុំបាន អនុវត្តសំណងតាមការបង្គាប់ដូចមានចែងនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ក៏ ដោយ[1375] ក៏ទំនងជាពុំមានប្រសិទ្ធភាពមកលើ កាំង ហ្កេកអ៊ាវ ឡើយ ដោយហេតុថា កាំង ហ្កេកអ៊ាវ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតរួចទៅហើយ។ ហេតុដូច្នេះ ការ ចេញវិធានការណាមួយដែល មិនអាចយកទៅអនុវត្តបាន នឹងធ្វើឱ្យបាត់បង់តម្លៃនៃសេចក្តី សម្រេចរបស់តុលាការ និងធ្វើឱ្យជនរងគ្រោះខកចិត្ត។

### *៧.ខ.២.ឃ.៣.ការសាងសង់បូជនីយដ្ឋាននៅទួលស្លែង និងជើងឯក និងការប្រែក្លាយព្រៃស ឱ្យទៅជាកន្លែងបូជនីយដ្ឋាន*

៦៨១. ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំសំណងមួយចំនួនដែល ក្នុងគោលបំណងថែរក្សា និងស្តារ នូវការចងចាំជាសាធារណៈអំពីព្រឹត្តការណ៍កាលពីអតីតកាល[1376]។ សំណើទាមទារសំណង ទាំងនេះរួមមាន ការសាងសង់បូជនីយដ្ឋាននៅក្នុងបរិវេណទួលស្លែង (មន្ទីរ ស ២១) និងនៅ ផ្នែកទាំងសងខាងនៃចេតិយនៅជើងឯក ព្រមទាំងការប្រែក្លាយព្រៃស (មន្ទីរ ស ២៤) ឱ្យទៅ ជាកន្លែងបូជនីយដ្ឋាន។ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធសំណើរបស់ដើមបណ្តឹង រដ្ឋប្បវេណីស្នើសុំវត្តអារ៉ាម និងបូជនីយដ្ឋានដទៃទៀត ដោយផ្អែកលើមូលដ្ឋានថា សំណើទាំង

---

ដែរចំពោះការដកចេញនូវការបំពេញកាតព្វកិច្ចជាក់លាក់មួយចំនួនចំពោះរូបវន្តបុគ្គល។ *សូមមើល ឧទា.* Lumley *ទល់នឹង* *Wagner* លេខ ៤២ (ឆ្នាំ ១៨៥២) ទំព័រ ៦៨៧ *និងទំព័របន្តបន្ទាប់ទៀត* (ដោយទទួលស្គាល់ដោយផ្អែកផងដែរលើ យុត្តិសាស្ត្រមុនៗថា ការបំពេញកាតព្វកិច្ចជាក់លាក់ដោយការច្រៀងនៅសាលមហោស្រព ពុំអាចត្រូវបានបង្គាប់ឡើយ)។ Alan Schwartz "រឿងក្តីសម្រាប់ការបំពេញកាតព្វកិច្ចជាក់លាក់" ចេញផ្សាយដោយព្រឹត្តិប័ត្រច្បាប់សាលកវិទ្យាល័យយ៉ែល វ៉ុល ៨៩:២ (ឆ្នាំ ១៩៧៩), ទំព័រ ២៩៧ (ពាក់ព័ន្ធនឹងការបំពេញកាតព្វកិច្ចជាក់លាក់ក្នុងការផ្តល់សេវាផ្ទាល់ខ្លួន)។

[1375]មាត្រា ៥២៣ និងមាត្រា ៥៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ដែលចែងអំពីការដាក់ពន្ធនាគារជំនួសឱ្យការបង់ ប្រាក់ក្នុងករណីដែលទណ្ឌិតពុំបានផ្តល់សំណងទូទាត់ការខូចខាត និងព្យសនកម្ម ជូនដើមបណ្តឹងរដ្ឋប្បវេណី)។

[1376]សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥២, ៦៥៤, ៦៥៦ និង ៦៥៧។

នោះពុំមានភាពច្បាស់លាស់ពាក់ព័ន្ធទៅនឹងចំនួន លក្ខណៈទីតាំង និងតម្លៃពិតប្រាកដរបស់បូជនីយដ្ឋាននោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានសង្កត់ធ្ងន់ថា "មិនមានការផ្តល់នូវព័ត៌មានទាក់ទងទៅនឹងអត្តសញ្ញាណនៃម្ចាស់ទីតាំងដែលបានស្នើសុំទាំងនោះ តើពួកគេយល់ព្រមឱ្យសាងសង់បូជនីយដ្ឋានដែលបានស្នើសុំនីមួយៗនោះដែរឬទេ ឬថាតើលិខិតអនុញ្ញាតបន្ថែម ដូចជា លិខិតអនុញ្ញាតឱ្យសាងសង់ ដែលចាំបាច់ដើម្បីធ្វើឱ្យវិធានការនីមួយៗមានប្រសិទ្ធភាព ដែរ ឬទេ"[1377]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អង្គជំនុំជម្រះមិនមានតួនាទីចេញដីកាបង្គាប់ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ឱ្យបង់"ថ្លៃជាសំណងជាក់លាក់" ដើម្បីផ្តល់មូលនិធិដល់ការសាងសង់ដែលបានស្នើសុំទាំងនោះឡើយ[1378]។

៦៨២. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ អះអាងថា វិធានផ្ទៃក្នុងពុំមានចែងនូវមូលដ្ឋានផ្នែកច្បាប់ដើម្បីដាក់ចេញនូវបទដ្ឋានកម្រិតខ្ពស់នៃភាពច្បាស់លាស់ឡើយ ហើយនៅក្នុងគ្រប់ករណីទាំងអស់សំណើរបស់ពួកគាត់មានលក្ខណៈពិស្តារ និងច្បាស់លាស់គ្រប់គ្រាន់[1379]។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ អះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ដោយបានមើលរំលងនូវព័ត៌មានលម្អិតនៅក្នុងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលទាក់ទិននឹងសំណើសុំបូជនីយដ្ឋាន[1380]។ ទីពីរ ដោយតម្រូវឱ្យមានលក្ខណៈលម្អិតទៀតជាងអ្វីដែលបានដាក់ជូនរួចហើយនោះ អង្គជំនុំជម្រះសាលាដំបូងបានដាក់នូវលក្ខខណ្ឌតម្រូវតឹងរ៉ឹងហួសហេតុ ដូច្នេះធ្វើឱ្យសំណើទាមទារសំណងមិនអាចធ្វើទៅរួច និងរំលោភសិទ្ធិរបស់ជនរងគ្រោះដែលត្រូវបានធានានៅក្នុងវិធានផ្ទៃក្នុង ២១(ក) និង (គ)[1381]។ ទោះបីជាទទួលស្គាល់ថា យន្តការរបស់ អ.វ.ត.ក គឺកើតចេញពី "អ្នកដាក់ពាក្យបណ្តឹង" ក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ អះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវបានគេរំពឹងថា ផ្តល់នូវសេចក្តីលម្អិតផ្នែក

---

[1377]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧២។

[1378]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧២។

[1379]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៦៦។

[1380]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៦៦, ៨៣ និង ៨៤។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៩៩។

[1381]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៦៧ និង ៨០។

បច្ចេកទេសបានឡើយ ដូចជា អត្តសញ្ញាណរបស់កម្មសិទ្ធិករនៃទីកន្លែង ការឯកភាពពីកម្មសិទ្ធិករទាំងនេះ ចំពោះការសាងសង់បូជនីយដ្ឋាន ឬការសុំការអនុញ្ញាតពីអាជ្ញាធររដ្ឋបាល[1382]។ ប៉ុន្តែ អ.វ.ត.ក គួរតែបង្កើតនូវវិធីសាស្ត្រជាក់ស្តែង ដែលអាចបត់បែនបានគួរឱ្យកត់សម្គាល់ទាក់ទិននឹងសំណងទាមទារនូវការបំពេញចិត្ត ដូចជាសំណើសុំទាំងឡាយដែលបានស្នើឡើង ដែលផ្តល់នូវផលវិបាកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការផ្តល់នូវសេចក្តីលម្អិត ទាំងអស់អំពីគម្រោង ដោយគ្មានធនធាន និងអ្នកជំនាញគ្រប់គ្រាន់នោះ។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អង្គជំនុំជម្រះតុលាការកំពូលគួរតែអនុវត្តតាមគោលការណ៍សមធម៌ ដែលទាញចេញមកពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងទទួលយកនូវលក្ខខណ្ឌតម្រូវទាបអំពីភាពច្បាស់លាស់ដែលថា តុលាការនឹងបំពេញបន្ថែមតាមរយៈការប្រើប្រាស់អំណាចរបស់ខ្លួន ក្នុងការអនុវត្ត*តាមការផ្តួចផ្តើមរបស់ខ្លួន*[1383]។ ចុងបញ្ចប់ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ អះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីជាមុនអំពីកម្រិតនៃភាពច្បាស់លាស់ ដែលតម្រូវឱ្យមាននោះឡើយ[1384]។

៦៨៣. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង នៅក្នុងការគាំទ្រចំពោះសំណើសុំទាំងនេះ និងយល់ឃើញថា សំណើសុំទាំងនេះពិតជាស្ថិតនៅក្នុងអត្ថន័យនៃ “សំណងផ្លូវចិត្ត និង សមូហភាព” ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ២៣(១)(ខ)។ លក្ខខណ្ឌតម្រូវ “ផ្លូវចិត្ត” អាចទទួលយកបានតាមរយៈអង្គហេតុដែលថា បូជនីយដ្ឋានទាំងនេះនឹងស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ តំណាងឱ្យការទទួលស្គាល់ជាសាធារណៈនូវឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត និងព្យសនកម្មដែលជនរងគ្រោះបានទទួលរង និងជានិមិត្តរូបដ៏សំខាន់ និងចិតថេរយូរអង្វែង ជួយព្យាបាលរបួសជនរងគ្រោះជាសមូហភាព ដោយរួម

[1382] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៧១, ៨១ និង ៨២។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ៩៩ និង ១០០ (ដែលគាំទ្រថា សំណើសុំសាងសង់បូជនីយដ្ឋានមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់សម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់សំណង ហើយវាមិនមែនជាសមត្ថកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការកំណត់លើចំនួនទឹកប្រាក់នោះទេ)។

[1383] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ៧១ ដល់ ៧៩។

[1384] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ៦៧។

ទាំងបុគ្គលនានា ដែលត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីទៅទៀត។ លើសពីនេះទៀត បូជនីយដ្ឋាននឹងរួមចំណែកដល់ការផ្សះផ្សាជាតិ ដោយពង្រឹងនូវការយល់ដឹងជាសាធារណៈអំពីឧក្រិដ្ឋកម្មកាលពីអតីតកាល ជំរុញនូវវប្បធម៌សន្តិភាពក្នុងចំណោមមនុស្សជំនាន់បច្ចុប្បន្ន និងនៅក្នុងពេលអនាគត និងរួមចំណែកក្នុងការផ្សព្វផ្សាយព័ត៌មានអំពីភាពស្រុះស្រួលគ្នា ជាសាកលទៅដល់អ្នកទស្សនាសំខាន់ៗទាំងអស់[1385]។

៦៨៤. ដូចដែលបានយល់ឃើញពីមុននៅក្នុងសាលដីកានេះ មានឧបសគ្គសំខាន់ពីរនៅក្នុងការទទួលយកការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ទីមួយ គឺភាពក្រីក្ររបស់ កាំង ហ្គេកអ៊ាវ ដែលជាឧបសគ្គមិនអាចឱ្យ មានការចេញដីកាសម្រេចប្រឆាំងនឹងរូបគាត់ ដូច្នេះហើយនាំឱ្យ

---

[1385] *រឿងក្តី Plan de Sánchez Massacre ទល់នឹង ហ្គាទ់តេម៉ាឡា* សាលក្រម (សំណង និងសោហ៊ុយ) កថាខណ្ឌ ១០4 (ដែលបង្គាប់ឲ្យរដ្ឋជាភាគីចុងចម្លើយផ្តល់ហិរញ្ញវត្ថុដើម្បីថែរក្សា និងកែលម្អចេតិយដែលគេអាចគោរពវិញ្ញាណក្ខ័ន្ធជនរងគ្រោះ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងថែរក្សាការចងចាំដល់អ្នកដែលបានស្លាប់ ក្នុងគោលបំណងកុំឲ្យមានការកើតឡើងឧក្រិដ្ឋកម្មស្រដៀងគ្នានេះសាជាថ្មីទៀត។ រឿងក្តី *La Cantuta ទល់នឹង ប៉េរូ* សាលក្រម (អង្គសេចក្តី សំណង និងសោហ៊ុយ) កថាខណ្ឌ ២៣៦ (លើកឡើងថា ដើម្បីឲ្យការរំលឹកការចងចាំក្លាយជាវិធានការសំណងមួយដ៏សមស្រប ស្លាកដែលមានឈ្មោះបុគ្គលចំនួន ១០ នាក់ ដែលត្រូវបានគេសម្លាប់ចោល ឬ ធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ត្រូវរួមបញ្ចូលផងដែរក្នុងករណីបងប្អូនសាច់ញាតិរបស់គេចង់បាននោះ)។ រឿងក្តី *Goiburu និងជនដទៃទៀត ទល់នឹង ប៉ារ៉ាហ្គាយ* សាលក្រម (អង្គសេចក្តី សំណង និងសោហ៊ុយ) កថាខណ្ឌ ១៧៧ (បង្គាប់ឲ្យរដ្ឋភាគីចុងចម្លើយកសាងស្តូបដែលមានស្លាកឈ្មោះជនរងគ្រោះ និងរៀបរាប់អំពីហេតុការណ៍ដែលឧក្រិដ្ឋកម្មបានកើតឡើង)។ ស្តូបទាំងនេះត្រូវបានបង្គាប់ដោយតុលាការ IACtHR នៅក្នុងប្រភេទនៃ "ទម្រង់សំណងផ្សេងទៀត" ដែលក្នុងចំណោមនោះ មានវិធានការបំពេញចិត្ត ដែលមានវិសាលភាពជាសាធារណៈ ឬ លទ្ធផល ហើយដែលមានគោលបំណង "ចង់ឲ្យចងចាំដល់ជនរងគ្រោះ ទទួលស្គាល់សេចក្តីថ្លៃថ្នូររបស់ពួកគេ ការលួងលោមដល់សាច់ញាតិក្រោយរបស់ជនរងគ្រោះ ឬធ្វើសារចំពោះការដាក់ទោសជាផ្លូវការលើការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធ ព្រមទាំងដើម្បីជៀសវាងកុំឲ្យការរំលោភបំពាន[ស្រដៀងគ្នា]ទាំងនេះកើតឡើងសារជាថ្មី"។ *រឿងក្តី Gomez-Paquiyauri ទល់នឹង ប៉េរូ* តុលាការ IACtHR សាលក្រម (អង្គសេចក្តី សំណង និងសោហ៊ុយ) ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ២២៣។ *សូមមើលផងដែរ* Bridget Mayeux, Justin Mirabal "សំណងផ្លូវចិត្ត សមូហភាពនៅក្នុងតុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស", ទំព័រ ៣៣ (ដោយកត់សម្គាល់ថា "ការរំលឹកការចងចាំ និងបូជនីយដ្ឋាន សម្រាប់ការទទួលស្គាល់យ៉ាងសំខាន់លើការខូចខាតដែលកើតឡើងលើប្រជាជន។ វាពុំត្រឹមតែជាការគោរពឲ្យតម្លៃលើជនរងគ្រោះនៃការរំលោភបំពានដ៏សំខាន់បំផុតនោះទេ ប៉ុន្តែ វាជាការស្តារសម្បទាចំពោះអ្នករស់រានមានជីវិតផងដែរ")។

មានការច្រានចោលជាមុននូវ "សំណង ប្រកបដោយប្រសិទ្ធភាព"។ ឧបសគ្គមួយទៀត គឺការកម្រិតយុត្តាធិការ ដែលរារាំងមិនឱ្យមានការដាក់កាតព្វកិច្ចទៅលើរាជរដ្ឋាភិបាលកម្ពុជា ឬភាគីទីបីដទៃទៀត ដូច្នេះហើយ នាំឱ្យមានការច្រានចោលជាមុននូវការផ្តល់សំណងដែលតាមលក្ខណៈនេះ តម្រូវឱ្យមានកាតព្វកិច្ចបែបនេះ។ ឧបសគ្គទាំងនេះ រារាំងមិនឱ្យមានការទទួលយកសំណើទាមទារសំណងទាំងនេះ។

៦៨៥. ជាបញ្ហាដែលពាក់ព័ន្ធ អង្គជំនុំជម្រះតុលាការកំពូលត្រង់ចំណុចនេះ យោងទៅលើសារណារបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីដែលថា ក្នុងការបដិសេធការទាមទាររបស់ពួកគាត់ដោយសារតែកង្វះខាតនូវភាពច្បាស់លាស់នោះ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតនូវបទដ្ឋានតម្រូវហួសហេតុ បើប្រៀបធៀបទៅនឹងការអនុវត្តនានានៃស្ថាប័នសិទ្ធិមនុស្សអន្តរជាតិ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការពុំមានភាពច្បាស់លាស់ គឺពុំមែនជាវិការៈធ្ងន់ធ្ងរឡើយនៅក្នុងសំណើទាមទារសំណង ប្រសិនបើ សំណើបង្ហាញថា ការផ្តល់សំណងដែលបានទាមទារនោះមានលក្ខណៈសមស្រប និងអនុវត្តប្រឆាំងនឹង កាំង ហ្គេកអ៊ាវ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពច្បាស់លាស់នៃការសងសំណងគួរតែកំណត់នៅក្នុងសំណើរបស់ភាគី បើពុំដូច្នោះទេ ភាពច្បាស់លាស់ទាំងនោះអាចត្រូវតុលាការទទួលបាន តាមរយៈការប្រើប្រាស់អំណាចផ្ទាល់របស់ខ្លួន[1386]។ ទោះបីជាយ៉ាងណាក៏ដោយ តម្រូវការក្នុងការវិនិច្ឆ័យរឿងក្តីព្រហ្មទណ្ឌនៅក្នុងពេលវេលាមួយដ៏សមស្រប ពុំអនុញ្ញាតឱ្យ អ.វ.ត.ក គ្រាន់តែអនុវត្តតាមគោលការណ៍អនុវត្តរបស់អនុសញ្ញាអាមេរិកស្តីពីសំណងនោះឡើយ ដែលយោងទៅតាមគោលការណ៍នោះ តុលាការអន្តរទ្វីបអាមេរិកមានភារកិច្ចចុងក្រោយក្នុងការកំណត់សំណងប្រកបដោយសមធម៌ និងត្រឹមត្រូវសម្រាប់ភាគីដែលទទួលរងព្យសនកម្ម"[1387] និង "កំណត់នូវសំណងដែលសមស្រប ហើយមិនចងកាតព្វកិច្ចខ្លួនឯង ទៅតាមសំណើសុំរបស់

[1386]វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ មាត្រា ១២៤(២) នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ (ពាក់ព័ន្ធនឹងអំណាចរបស់តុលាការនៅក្នុងការទទួលយកភស្តុតាងតាមគំនិតផ្តួចផ្តើមរបស់ខ្លួន។

[1387]បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ៧២។

ជនរងគ្រោះឡើយ"[1388]។ អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចផ្តល់អាទិភាពទៅលើការកំណត់បញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយអាចបន្តសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីនៅក្នុង សវនាការដោយឡែកមួយទៀតបាន[1389]។ ផ្ទុយទៅវិញ អណត្តិរបស់ អ.វ.ត.ក និងក្របខណ្ឌគតិយុត្ត ដែលរក្សាលក្ខណៈពិសេសរបស់បណ្តឹងរដ្ឋប្បវេណីតម្រូវថា កិច្ចដំណើរការនីតិវិធីពិនិត្យលើភស្តុតាង ស្តីពីសំណងនៅតែជាបន្ទុករបស់ដើមចោទដដែល។

៦៨៦. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ អ.វ.ត.ក "មានកាតព្វកិច្ចជួយសម្រួល និងជួយជ្រោមជ្រែងដល់ជនរងគ្រោះនៅក្នុងការទទួលបានសំណង" ហើយថា ប្រការនេះគួរតែត្រូវបានធ្វើឡើងតាមរយៈការបន្ធូរបន្ថយបន្ទុកផ្នែកនីតិវិធីទៅលើជនរងគ្រោះ[1390]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា លិខិតុបករណ៍ជាច្រើននៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលទាក់ទិននឹងសំណងជាប់ពាក់ព័ន្ធជាមួយនឹងកាតព្វកិច្ចទូទៅរបស់រដ្ឋ ក្នុងការផ្តល់ដល់ជនរងគ្រោះនូវសិទ្ធិទទួលបានយុត្តិធម៌[1391]។ អ.វ.ត.ក និងអង្គការសហប្រជាជាតិ បំពេញនូវកាតព្វកិច្ចនេះតាមវិធីជាច្រើនក្នុងចំណោមប្រការផ្សេងទៀតដោយ មានជាអាទិ៍ ការរៀបចំ និងការផ្តល់មូលនិធិដល់តំណាងវិជ្ជាជីវៈផ្នែកច្បាប់សម្រាប់ជនរងគ្រោះ[1392] ការផ្សព្វផ្សាយព័ត៌មាន ការអប់រំផ្សព្វផ្សាយ និងការគាំទ្រដល់សកម្មភាព នានាតាមរយៈផ្នែកគាំពារជនរងគ្រោះ[1393] និងសហការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលនានា[1394] ដែលទាំងអស់នេះ អាចផ្តល់នូវព័ត៌មាន យោបល់ និងជំនួយដល់ជនរង

---

[1388]បណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ៧៣។

[1389]វិធាន ១០០ នៃវិធានផ្ទៃក្នុង។

[1390]សារណាបណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ កថាខណ្ឌ ៧២ (សេចក្តីដកស្រង់ត្រូវបានលុបចោល)។

[1391]*សូមមើល ឧទា.* គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសំណង មាត្រា VIII(12)c និង (១៣)។

[1392]វិធាន ១២ នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៣)។ វិធាន ១២ វិធាន ១២ *ស្ទួន* និងវិធាន ១២ *ស្ទួនពីរ* (វិសោធនកម្មទី ៨)។

[1393]វិធាន ១២ នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៣)។ វិធាន ១២*ស្ទួន* (១) (វិសោធនកម្មទី ៨)(ដែលបញ្ជាក់ផងដែរថា សកម្មភាពផ្សព្វផ្សាយដល់មូលដ្ឋានពាក់ព័ន្ធនឹងជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី គួរត្រូវធ្វើឡើង នៅក្នុងករណីសមស្រប ដោយត្រូវពិគ្រោះយោបល់ជាមួយនឹងផ្នែកកិច្ចការសាធារណៈ។

[1394]វិធាន ១២ *ស្ទួន* (២) និង (៣)។

គ្រោះក្នុងចំណោមប្រការផ្សេងទៀត ដែលទាក់ទងទៅនឹងកាតព្វកិច្ចផ្នែកនីតិវិធី។ ទោះបីជាយ៉ាងណាក៏ដោយ តួនាទីរបស់តុលាការដែលវិនិច្ឆ័យរឿងក្តីព្រហ្មទណ្ឌនៅក្នុងការជួយភាគីមួយចំពោះកិច្ចដំណើរការនីតិវិធី ត្រូវតែមានកម្រិត និងមិនផ្លាស់ប្តូរទៅជា"កាតព្វកិច្ចចុងក្រោយរបស់តុលាការក្នុងការកំណត់នូវសំណងប្រកបដោយសមធម៌ និងត្រឹមត្រូវសម្រាប់ភាគីដែលទទួលរងព្យសនកម្ម"ឡើយ។

៦៨៧. សរុបសេចក្តីមក សំណើទាមទារសំណងត្រូវតែផ្តល់នូវកម្រិតមួយដ៏សមហេតុផលនៃសេចក្តីលម្អិត ដោយផ្អែកទៅលើលក្ខណៈនៃសំណើ។ ដើម្បីឱ្យតុលាការមានតួនាទីចេញនូវការផ្តល់សំណងតម្រូវឱ្យតុលាការមានភាពច្បាស់លាស់គ្រប់គ្រាន់ ដែលអាចឱ្យតុលាការផ្តល់ទៅតាមសំណើ តាមរយៈផ្នែកសម្រេចសេចក្តីដែលអាចអនុវត្តបាន។

៦៨៨. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតថា កម្រិតនៃភាពជាក់លាក់សម្រាប់សំណើទាមទារសំណង និងបុព្វសិទ្ធិរបស់រដ្ឋាភិបាល គឺជាបញ្ហាដែលក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក មិនអនុញ្ញាតឱ្យតុលាការ យកតាមយន្តការសិទ្ធិមនុស្សក្នុងតំបន់ ជាពិសេស តុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស ដែលអនុវត្តនូវបទដ្ឋាននៃភាពជាក់លាក់កម្រិតទាប"ដោយដាក់បន្ទុកមួយចំនួនដល់រដ្ឋនៅក្នុងការអនុវត្តការបង្គាប់សំណងវិញ"[1395] ហើយ"ផ្តល់ជម្រើសដល់រដ្ឋនូវវិធីសាស្ត្រនៅក្នុងការអនុវត្តដីកាបង្គាប់"[1396]។ ដូចដែលបានលើកឡើងរួចហើយ អ.វ.ត.ក មិនមានយុត្តាធិការទៅលើរដ្ឋ ឬអង្គនីតិប្រតិបត្តិរបស់រដ្ឋនោះទេ និងមិនមានអំណាចក្នុងការឃ្លាំមើលឡើយ។ ហេតុដូច្នេះ អ.វ.ត.ក មិនអាចទទួលផលប្រយោជន៍ពីកិច្ចសហការគ្នាទៅវិញទៅមកជាមួយអង្គនីតិប្រតិបត្តិរបស់រដ្ឋនោះបានទេ ដែលនេះជាសមាសធាតុសំខាន់នៅក្នុងសំណងដែលមិនសូវមានភាពច្បាស់លាស់ និងដែលកំពុងដំណើរការដែលត្រូវផ្តល់ឱ្យស្របតាមអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស។ ផ្ទុយទៅវិញ ដីកានានារបស់ អ.វ.ត.ក ត្រូវយកទៅអនុវត្តនៅក្នុងប្រព័ន្ធតុលាការ ដូចជា *តាមរយៈអាជ្ញាសាលា*[1397]។ ដូចនេះ ដោយមិនគិត

---

[1395]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៧៤។

[1396]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៧៥។

[1397]មាត្រា ៣៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ (ស្ថាប័នអនុវត្ត)។

អំពីបញ្ហា ថាតើភាពច្បាស់លាស់ត្រូវបានសម្រេចតាមរយៈគំនិតផ្តួចផ្តើមរបស់ភាគីផ្ទាល់ ឬ តាមរយៈអំណាចរបស់តុលាការដែរ ឬយ៉ាងណានោះ ការផ្តល់សំណាងត្រូវតែមានអានុភាពអនុវត្តខ្លួនឯង។ នេះមានន័យថា ដីកាស្តីពីការផ្តល់សំណងត្រូវមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យមានការអនុវត្តដោយមិនតម្រូវឱ្យមាន សេចក្តីសម្រេចផ្នែករដ្ឋបាល និង ឆន្ទានុសិទ្ធិផ្នែករដ្ឋបាលសម្រាប់ការអនុវត្តដីកានោះ នៅពេលក្រោយទៀតឡើយ។ ការចេញដីកាដោយផ្ទាល់ ឬដោយប្រយោល ដែលចងកាតព្វកិច្ចអង្គនីតិប្រតិបត្តិឱ្យអនុវត្តគម្រោង និង កម្មវិធីនានា មិនថាមានតម្លៃកម្រិតណាទេ នឹងមិនត្រឹមតែហួសពីយុត្តាធិការរបស់ អ.វ.ត.ក ប៉ុណ្ណោះទេ បើគិតអំពីសេចក្តីត្រូវការនៃយន្តការស្តីពីការអនុវត្ត ថែមទាំងមិនស្របទៅនឹង សញ្ញាណនៃសំណងប្រកប ដោយប្រសិទ្ធភាពទៀតផង។ ហេតុដូច្នេះ អ.វ.ត.ក គ្រាន់តែអាចគាំទ្រសំណើទាមទារសំណងដោយគ្រាន់តែបញ្ជាក់ថា ទម្រង់នៃសំណង គឺសមស្របតែប៉ុណ្ណោះ។

៦៨៩. ទោះបីជាយ៉ាងណាក៏ដោយ ភាពច្បាស់លាស់នៃសំណើ គឺជាបញ្ហាមួយបន្ទាប់ពីបញ្ហានៃការជ្រៀតជ្រែកសិទ្ធិរបស់ភាគីទីបី និងបុព្វសិទ្ធិរបស់រដ្ឋាភិបាល។ មិនចាំបាច់មានការបញ្ជាក់ច្បាស់លាស់ផ្នែកបច្ចេកទេស អំពីសំណើដែលបានដាក់ ដើម្បីឱ្យដឹងថា ការសាងសង់វិមាន ប្រសិនបើមិនស្ថិតនៅលើដីដែលជាកម្មសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ពិតជាអាចសន្និដ្ឋានបានថា មានការទន្ទ្រានទៅលើផ្នែកនៃកម្មសិទ្ធិ (ឯកជន ឬសាធារណៈ) និងរដ្ឋបាលដីធ្លី និងផ្នែករដ្ឋបាលនៃលិខិតអនុញ្ញាតសាងសង់។ ដូច្នេះ សំណើមិនអាចអនុញ្ញាតឱ្យជាដីកាបង្គាប់ឡើយ លើកលែងតែបញ្ហានៃកម្មសិទ្ធិ និងលិខិតអនុញ្ញាតផ្នែករដ្ឋបាល ដែលតម្រូវឱ្យមាននៅក្នុងច្បាប់ត្រូវបានដោះស្រាយរួចរាល់ មុនការដាក់សំណើនៅចំពោះមុខតុលាការព្រហ្មទណ្ឌ។ នៅក្នុងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "មិនមានការផ្តល់នូវព័ត៌មានទាក់ទងទៅនឹងអត្តសញ្ញាណនៃម្ចាស់ទីតាំងដែលបានស្នើសុំទាំងនោះ ថាតើពួកគេយល់ព្រមឱ្យសាងសង់បូជនីយដ្ឋានដែលបានស្នើសុំនីមួយៗនោះដែរ ឬយ៉ាងណា ឬ ថាតើលិខិតអនុញ្ញាតបន្ថែម ដូចជា លិខិតអនុញ្ញាតឱ្យសាងសង់ដែល

ចាំបាច់ ដើម្បីធ្វើឱ្យវិធានការនីមួយៗមានប្រសិទ្ធភាពដែរ ឬយ៉ាងណា"[1398]នោះទេ។ សេចក្តីបញ្ជាក់នេះ *ជាក់ស្តែង*អះអាងថា ទម្រង់ទាំងអស់នៃសំណងដែលបានស្នើសុំនៅក្រោមចំណងជើង "បូជនីយដ្ឋាន" ពិតជាជ្រៀតជ្រែកសិទ្ធិរបស់ភាគីទីបី និងបុព្វសិទ្ធិរបស់អង្គនីតិប្រតិបត្តិ។ ការជ្រៀតជ្រែកនេះ គឺជាមូលដ្ឋាននៃការបដិសេធសំណើទាំងនេះ ពោល គឺមិនមែនដោយសារកង្វះខាតទូទៅនៃភាពច្បាស់លាស់ឡើយ។

៦៩០. ក្នុងចំណោមសំណើដែលបានជម្រុញឱ្យសង់បូជនីយដ្ឋាននានា សំណង់បូជនីយដ្ឋានរបស់ជនរងគ្រោះមន្ទីរ ស ២១ ដែលបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ក្នុងនាមសមាគមជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ "ក្បៀមក្សាន្ត"[1399]ដែលរួមបញ្ចូលនូវជនរងគ្រោះភាគច្រើននៅក្នុងសំណុំរឿង ០០១[1400] មានភាពលេចធ្លោគួរឱ្យចាប់អារម្មណ៍ដោយសារភាពច្បាស់លាស់ដែលបានផ្តល់ឱ្យ។ ការសាងសង់បូជនីយដ្ឋានដែលបានស្នើឡើង ត្រូវបានគ្រោងទុកនៅក្នុងធាតុផ្សំដែលបានពណ៌នាសំខាន់នានា រួមមាន ទីតាំងដែលត្រូវការដែល

---

[1398]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧២។

[1399]ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខឯកសារ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/4.1, ទំព័រ ៧០ (បន្ទាត់ ២៥) ដល់ទំព័រ ៧៣ (បន្ទាត់ ២៤)។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ១: សំណើធ្វើឡើងដោយសមាគមជនរងគ្រោះក្បៀមក្សាន្តសុំសាងសង់បូជនីយដ្ឋានជនរងគ្រោះមន្ទីរ ស ២១ នៅសារមន្ទីរ ទួលស្លែង ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F25.1 (សំណើរបស់សមាគមក្បៀមក្សាន្ត)។ បច្ចុប្បន្ន សមាគមន៍នេះមានជនរងគ្រោះចំនួន ៤៨៦ នាក់ បានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងបានរួមបញ្ចូលនៅក្នុងបញ្ជីសមាគមដែលត្រូវបានទទួលស្គាល់ ដោយផ្នែកគាំពារជនរងគ្រោះនៃ អ.វ.ត.ក ផងដែរ។

[1400]អង្គជំនុំជម្រះតុលាការកំពូលបានឱ្យតម្លៃជាពិសេសថា សំណើសុំសាងសង់បូជនីយដ្ឋាននេះត្រូវបានបង្កើតឡើង និងត្រូវបានសម្រេចចុងក្រោយដោយសមាគមមួយដែលតំណាងឱ្យជនរងគ្រោះភាគច្រើននៅក្នុងសំណុំរឿងនេះ។ *សូមមើល* Brandon Hamber, "ការបង្រួមនូវផ្នែក Micro និង Macro: ទស្សនវិស័យលើចិត្តសាស្ត្រស្តីពីសំណងនៅក្នុងសង្គមដែលស្ថិតក្នុងអន្តរកាល", *កូនសៀវភៅស្តីពីសំណង*, ចេញដោយសាលកវិទ្យាល័យ Oxford, ឆ្នាំ ២០០៦, ទំព័រ ៥៧៦ ("សហគមនានាគួរតែមានការបញ្ចេញមតិនៅក្នុងដំណើរការស្តីពីសំណងសហគមន៍ត្រូវបានគិតបែបណា និងត្រូវបានបញ្ជូនឱ្យតាមវិធីណា។ នៅក្នុងការធ្វើដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់នូវអំពីផលប៉ះពាល់ជាបុគ្គល និងជាសមូហភាពលើការប៉ះទង្គិចខ្លាំងនៃសម្ពាធនយោបាយ និងអំពើហឹង្សា ក៏ដូចជាសារៈសំខាន់នៃដំណើរការ និងពាក់ព័ន្ធនឹងបញ្ហានោះ អង្គជំនុំជម្រះតុលាការកំពូលគួរចង្អុលបង្ហាញអំពីវិធីមួយចំនួនដែលត្រូវធ្វើ")។

ស្ថិតនៅក្នុងបរិវេណមន្ទីរ ស ២១ ផលប៉ះពាល់លើទីកន្លែងដែលត្រូវបានទទួលស្គាល់ដោយអង្គការយូណេស្កូ និងភាពច្បាស់លាស់ផ្នែកបច្ចេកទេសស្តីពីការសាងសង់ ការគ្រប់គ្រង ការថែរក្សា និងថ្លៃចំណាយដែលត្រូវបានប៉ាន់ស្មានថា អស់ ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក[1401]។ សំណង់ដែលមាន ទទឹងប្រវែង ១៣ម៉ែត្រ ត្រូវបានគ្រោងធ្វើឡើងនៅក្នុងទីធ្លាដែលនៅជុំវិញអាគារ ក ខ និង ង ដែលស្ថិតនៅក្នុងបរិវេណមន្ទីរ ស ២១។ កត្តាទាំងអស់រួមទាំងផ្ទាំងផ្លាកឈ្មោះជនរងគ្រោះ នឹងត្រូវបានតម្កើងដូចដែលបានគ្រោងទុកនៅក្នុងគម្រោងដែលបានដាក់ដោយសមាគមក្សេមក្សាន្ត។ វានឹងមិនប៉ះពាល់ដល់ទីកន្លែងទួលស្លែងដែលត្រូវបានទទួលស្គាល់ដោយអង្គការយូណេស្កូនោះទេ ហើយប្រសិនបើចាំបាច់ នឹងត្រូវបានកែប្រែឱ្យស្របតាមការណែនាំរបស់អង្គការយូណេស្កូ។

៦៩១. ដោយបានពិចារណាអំពីភាពច្បាស់លាស់ដែលមានកម្រិតខ្ពស់ និងការគាំទ្រដែលគួរឱ្យកត់សម្គាល់របស់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់បូជនីយដ្ឋានរបស់ជនរងគ្រោះមន្ទីរ ស ២១ ថាជាទម្រង់សមស្រប នៃការស្នើសុំសំណង ស្របតាមអត្ថន័យដែលមានចែងនៅក្នុងវិធាន ២៣(១)(ខ) នៃវិធានផ្ទៃក្នុង ដោយមិនមានបុរេវិនិច្ឆ័យ អំពីការបញ្ជាក់ច្បាស់លាស់ផ្នែកបច្ចេកទេសដែលល្អវិសេសវិសាលនោះទេ។ ដូចដែលបានបញ្ជាក់ដោយ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ការទទួលស្គាល់ជាផ្លូវការ និងជាឧឡារិករបស់ អ.វ.ត.ក អំពីភាពសម ស្របនៃសំណើសុំសំណងពេលនេះ បង្កើតបាននៅក្នុង និងដោយខ្លួនឯងនូវទម្រង់នៃសំណង ដោយមិនគិតអំពីការអនុវត្ត នាថ្ងៃអនាគត ឡើយ[1402]។

៦៩២. ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដោយសារភាពក្រីក្ររបស់ កាំង ហ្គេកអ៊ាវ សំណើនេះមិនអាចទទួលយកបានឡើយ។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា គំនិតផ្តួចផ្តើមស្នើសុំមូលនិធិដែលអាចទាក់ទាញការចាប់អារម្មណ៍របស់

[1401]ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ចុះថ្ងៃទី ៣០ ខែ មីនាឆ្នាំ ២០១១, ឯកសារលេខ F1/4.1, ទំព័រ ៧៣ (បន្ទាត់ ៩ ដល់ ២៤)។ សំណើសុំរបស់សមាគមក្សេមក្សាន្ត។

[1402]សារណាបន្ថែមស្តីពីសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌចុងក្រោយ ទំព័រ ៣។

អ្នកផ្តល់ជំនួយដែលអាចមាន គឺពិតជា ត្រូវបានគិតទុកជាមុនដោយសមាគមក្សេមក្សាន្ត[1403]។ ដោយចងចាំថាសំណង់បូជនីយដ្ឋានដែលស្ថិតនៅ ក្នុងបរិវេណមន្ទីរ ស ២១ គឺជាដំណើរការស្មុគស្មាញមួយដែលចាំបាច់ត្រូវមានការចូលរួមប្រកបដោយន័យស្ថាបនា និងការសម្របសម្រួលរបស់ស្ថាប័នជាច្រើន ព្រមទាំងអង្គភាពរដ្ឋបាលនានាផងដែរ អង្គជំនុំជម្រះតុលាការកំពូលណែនាំ និងលើកទឹកចិត្តដល់ស្ថាប័នជាតិ និងអន្តរជាតិដែលមានសមត្ថកិច្ចក្នុងការជួយសម្រួលដល់ការអនុវត្តវិធានការគ្រប់បែបយ៉ាង ដែលចាំបាច់សំដៅធ្វើឱ្យការសាងសង់អាចប្រព្រឹត្តទៅបានដោយជោគជ័យ។

### *៧.ខ.២.ឃ.៤.ការផ្តល់សោហ៊ុយដល់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការធ្វើទស្សនកិច្ចទៅបូជនីយដ្ឋាននានា*

៦៩៣. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំសំណង នៅក្នុងទម្រង់នៃការផ្តល់សោហ៊ុយសម្រាប់ការធ្វើទស្សនកិច្ចនៅកន្លែងបូជនីយដ្ឋាននានា ចំនួនបីដងក្នុងមួយឆ្នាំ និងដោយការធ្វើទស្សនកិច្ចម្តងៗ មានរយៈពេល ០៤ ថ្ងៃ[1404]។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងមិនបានលើកឡើងអំពី សំណើសុំនេះឱ្យបានច្បាស់លាស់ឡើយ។ ហេតុនេះដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើវិធាន ១០០(១) នៃវិធានផ្ទៃក្នុង ដែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីទាំងអស់ ហើយអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដែលនាំឱ្យមានភាពមិនយុត្តិធម៌[1405]។

៦៩៤. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការអនុវត្តសំណើសុំនេះនឹងនាំឱ្យមានជំនួយហិរញ្ញវត្ថុ និងការរៀបចំផ្នែករដ្ឋបាល និងសម្ភារៈដែលគួរឱ្យកត់សម្គាល់។ នៅពេលដែល អ.វ.ត.ក មិនអាចចេញដីកាដែលអាចអនុវត្តបានប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ភាពមិនច្បាស់

[1403]សំណើសុំរបស់សមាគមក្សេមក្សាន្ត ទំព័រ ១១។

[1404]សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៦។

[1405]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ កថាខណ្ឌ ៨៦ និង ៨៧។

លាស់នៃសំណើមិនមានផលប៉ះពាល់ដល់ការបដិសេធលើសំណើសុំនេះទេ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះនេះកត់សម្គាល់ឃើញថា សំណើសុំមិនមានទិន្នន័យបច្ចេកទេសជាមូលដ្ឋាននោះទេ ដូចជាចំនួន និងវិសាលភាព ដែលបុគ្គលទាំងឡាយមានចេតនាចូលរួមដោយប្រសិទ្ធភាព តើការធ្វើទស្សនកិច្ចទៀងទាត់ពេលវេលាទាំងនេះនឹងបន្តធ្វើប៉ុន្មានឆ្នាំ ទីកន្លែងរស់នៅ នៅក្នុងប្រទេសកម្ពុជារបស់អ្នកធ្វើទស្សនកិច្ច និងភាពច្បាស់លាស់ផ្សេងទៀតដែលនឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូល ធ្វើការវាយតម្លៃអំពីភាពសមស្របនៃសំណើសុំនេះ និងវាយតម្លៃ ពីការចំណាយដែលពាក់ព័ន្ធ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលមិនយល់ស្របទៅតាមសំណើ ដែលជាអនុសាសន៍មិនចងកាតព្វកិច្ច ពាក់ព័ន្ធទៅនឹងទម្រង់សមស្របនៃផ្តល់សំណងនេះទេ។

*៧.ខ.២.ឃ.៥.ការផ្តល់នូវការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងសេវាចិត្តសាស្ត្រដល់ដើមបណ្តឹងរដ្ឋប្បវេណី*

៦៩៥. ដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំទទួលបាននូវការព្យាបាលផ្នែកវេជ្ជសាស្ត្រដោយឥតគិតថ្លៃ រួមទាំងការព្យាបាលរូបរាងកាយ និងផ្លូវចិត្តផងដែរដោយរួមទាំងថ្លៃចំណាយលើការធ្វើដំណើរទៅមកមណ្ឌលសុខភាពសមស្របផងដែរ[1406]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំទាំងអស់នេះ ដោយហេតុ ថា: (ក) ដោយសារតែសំណើសុំព្យាបាលផ្នែកវេជ្ជសាស្ត្រទាំងអស់នេះមិនមែនជាសំណងនិមិត្តរូបទេ ប៉ុន្តែ ជាការផ្តល់សេវាសុខភាពដល់ជនរងគ្រោះច្រើននាក់ ដែលសំណើសុំទាំងនេះអាចជាការដាក់កាតព្វកិច្ចដល់អាជ្ញាធរជាតិ និងដែលការស្នើសុំនេះហួសពីសមត្ថកិច្ចរបស់ អ.វ.ត.ក។ (ខ) ពុំមានទំនាក់ទំនង នៃវិធានការដែលអ្នកដាក់ពាក្យសុំបានស្នើសុំ និងឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ត្រូវបានកាត់ឱ្យជាប់ទោសឡើយ។ និង (គ) សំណើសុំទាំងអស់នេះមិនបានបំពេញលក្ខខណ្ឌតម្រូវឱ្យមានការបញ្ជាក់ច្បាស់លាស់នោះទេ ដោយគ្មានធាតុផ្សំសំខាន់ដូចជា ចំនួន និងអត្តសញ្ញាណរបស់អ្នកដែលត្រូវទទួលបានផលប្រយោជន៍ពីសំណើទាំងនេះ និងលក្ខណៈ ព្រមទាំងថ្លៃចំណាយលើវិធានការដែលបានស្នើសុំ[1407]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "សំណើដែលមានក្នុងទម្រង់នេះមិន

[1406]សាលក្រមរបស់អង្គបុរេជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥២, ៦៥៤, ៦៥៦ និង ៦៥៧។

[1407]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧៤។

អាចផ្តល់នូវមូលដ្ឋានសម្រាប់ចេញដីកាបង្គាប់ដែលអាចអនុវត្តបានចំពោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច នោះទេ”[1408]។

៦៩៦. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ខុសអំពីអត្ថន័យនៃសំណើសុំនេះ ដោយសារតែសំណើគ្រាន់តែសុំឱ្យផ្តល់ការព្យាបាលវេជ្ជសាស្ត្រដល់ជនរងគ្រោះ ចំនួន ១៧ នាក់ប៉ុណ្ណោះ មិនមែនជនរងគ្រោះច្រើននាក់ទេ[1409]។ សំណើសុំត្រូវបានលើកឡើងថាមានការបកស្រាយខុសផងដែរ ពីព្រោះដោយបដិសេធសំណើសុំដោយហេតុថា សំណើសុំស្នើឱ្យដាក់កាតព្វកិច្ចទៅលើអាជ្ញាធរជាតិ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានឱ្យតម្លៃដល់អត្ថន័យ “ច្បាស់លាស់ និងជាក់លាក់”របស់សំណើសុំទេ ដែលបានលើកឡើងថា កាំង ហ្កេកអ៊ាវ ត្រូវទទួលបន្ទុកថ្លៃចំណាយក្នុងការព្យាបាលរូបរាងកាយ និងផ្លូវចិត្តនេះ និងថា មិនមែនមានន័យថា សេវាទាំងអស់នេះត្រូវតែធ្វើឡើងដោយអាជ្ញាធរសុខាភិបាលជាតិជាចាំបាច់នោះទេ[1410]។

៦៩៧. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និង ក្រុម ៣ លើកឡើងថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានចេញ សេចក្តីសម្រេចដោយផ្អែកលើការបកស្រាយភ័ន្តច្រឡំអំពីអត្ថន័យនៃ “សំណងសមូហភាព និងសំណងផ្លូវចិត្ត”ដែលមានចែងនៅក្នុងវិធាន ២៣(១)(ខ) នៃវិធានផ្ទៃក្នុង[1411]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ នៅតែលើកឡើងថា ការបកស្រាយដែលមានលក្ខណៈទូលំទូលាយនៃ“សំណងសមូហភាព និងសំណងផ្លូវចិត្ត” គួរតែត្រូវបានអនុម័ត យោងតាមបទដ្ឋានគតិយុត្តអន្តរជាតិដូចបានបង្កើតឡើង ឧទាហរណ៍ យោងតាមអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្សជាដើម[1412]។ ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ លើកឡើងថា សំណង

---

[1408]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧៥។

[1409]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៩០។

[1410]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៨៨, ៩១ និង ១០៥។

[1411]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៩២ និង ១១០។ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣ កថាខណ្ឌ ៩៧។

[1412]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ កថាខណ្ឌ ៩២, ៩៣, ៩៧ និង ១០៧។

សមូហភាព និងសំណងផ្លូវចិត្តៈ (ក) រួមបញ្ចូលនូវ"អ្វីក៏ដោយដែលលើសពីសំណងហិរញ្ញវត្ថុជាបុគ្គល"[1413]។ (ខ) អាចនៅមានការពាក់ព័ន្ធនឹងថ្លៃចំណាយលើការអនុវត្តមួយចំនួន។ និង (គ) ខុសគ្នាដាច់ស្រឡះពីការកម្រិត ចំពោះវិធានការនានាដែលថាត្រូវផ្តល់ផលប្រយោជន៍ឱ្យដល់សមូហភាពរួមតែប៉ុណ្ណោះនោះ សំណងសមូហភាព និងសំណងផ្លូវចិត្ត អាចតម្រូវឱ្យមានផលប្រយោជន៍បុគ្គលសម្រាប់ជនរងគ្រោះ[1414]ផងដែរ។ សំណើសុំផ្តល់ការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត គឺជាសំណើទាមទារសំណងផ្លូវចិត្ត ដោយសារតែមិនមានលក្ខណៈជាសំណងសុំឱ្យផ្តល់សំណងហិរញ្ញវត្ថុទេ ហើយសំណើសុំសមូហភាពដោយហេតុថា សំណើសុំនេះសង្កត់ធ្ងន់ទៅលើការផ្តល់ផលប្រយោជន៍ទៅឱ្យក្រុមប្រជាពលរដ្ឋ ដែលរងគ្រោះពីការបំពានសិទ្ធិមនុស្ស[1415]។

៦៩៨. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីប្រឈមនឹងបញ្ហា ថាតើទំនាក់ទំនងហេតុ និងបច្ច័យរវាងសំណងដែលបានស្នើសុំ និងឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ត្រូវបានរកឃើញថាត្រូវទទួលខុសត្រូវត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា[1416]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ សង្កត់ធ្ងន់ថា ដោយបានស្នើសុំឱ្យ បង្ហាញភស្តុតាងអំពីទំនាក់ទំនងនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដែលបានបំពានលើសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានសំណងដែលមានចែងនៅក្នុងវិធាន ២៣ នៃវិធានផ្ទៃក្នុង ដោយហេតុថា ទាំងនៅក្នុងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ឬច្បាប់អន្តរជាតិ មិនបានចែងអំពីមូលដ្ឋានច្បាប់ណាមួយដែលតម្រូវឱ្យបង្ហាញអំពីទំនាក់ទំនងនេះឡើយ[1417]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ក៏បានលើកឡើងអំពីកំហុស ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនៅក្នុងករណីនេះ[1418]ផងដែរ។ ទោះបីជាមានការទទួលស្គាល់យ៉ាងច្បាស់នូវចំណងហេតុនិង

---

[1413]ប្រតិចារឹកថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/4.1, ទំព័រ ៤៨ (បន្ទាត់ ១៦ ដល់ ១៧)។

[1414]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ៩៧។

[1415]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ១០៨ និង ១០៩។

[1416]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ១១២។

[1417]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២, កថាខណ្ឌ ១១២។

[1418]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣, កថាខណ្ឌ ១០២។

បច្ច័យថា ជាបុរេលក្ខខណ្ឌមួយសម្រាប់ផ្តល់សំណងក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ តវ៉ាថា ចំណងហេតុ និងបច្ច័យ គឺពិតជា"ជាក់ស្តែង"ចំពោះសំណើសុំពាក់ព័ន្ធការថែទាំសុខភាព[1419]។

៦៤៩. អង្គជំនុំជម្រះតុលាការកំពូល ជាដំបូងត្រូវពិភាក្សាលក្ខខណ្ឌតម្រូវនៃចំណងហេតុនិងបច្ច័យរវាងវិធានការសងសំណង ដែលស្នើសុំដោយម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ និងព្យសនកម្មដែលកើតចេញពីឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ត្រូវបានរកឃើញថាបានទទួលខុសត្រូវ។ ដំបូង អង្គជំនុំជម្រះតុលាការកំពូលមានបំណងកត់សម្គាល់ថា ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ លើកឡើងមិនត្រឹមត្រូវអំពីចរិតលក្ខណៈដែលមិនធ្លាប់មានពីមុនមកនៃលក្ខខណ្ឌតម្រូវដែលបង្ហាញអំពីចំណងហេតុ និងបច្ច័យរវាងឧក្រិដ្ឋកម្មជាមួយនឹងទម្រង់នៃសំណងដែលស្នើសុំ។ ការបង្ហាញនៃចំណងចាំបាច់រវាងអំពើហាមឃាត់ដែលនាំឱ្យសងសំណងជាមួយនឹងទម្រង់នៃការស្នើសុំសំណងត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងតុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស ហើយទោះបីជាមិនច្បាស់ទាំងស្រុងក្តី ក៏ប៉ុន្តែការបង្ហាញនៃចំណងនេះ មានភាពងាយស្រួលក្នុងការបកស្រាយ[1420]។ នៅក្នុងបរិបទរបស់ អ.វ.ត.ក ដូចដែលបានពិភាក្សាខាងលើ ចំណងហេតុនិងបច្ច័យដែលត្រូវបង្ហាញ ដើម្បីអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការបង្ហាញឱ្យឃើញមានព្យសនកម្មដែលទទួលរង ដោយសារតែផល

[1419] បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣, កថាខណ្ឌ ១០២។

[1420] *សូមមើល ឧទា. រឿងក្តី Contreras និងជនដទៃទៀត ទល់នឹង El Salvador* (អង្គសេចក្តី សំណង និងសោហ៊ុយ) កថាខណ្ឌ ១៣៩ ("សំណងត្រូវតែមានទំនាក់ទំនងហេតុនិងបច្ច័យទៅនឹងអង្គហេតុនៃរឿងក្តីការបង្ហាញអំពីការរំលោភបំពាន និងព្យសនកម្ម និងការស្នើសុំវិធានការជួសជុលការខូចខាត។ ហេតុដូច្នេះ តុលាការត្រូវតែផ្ទៀងផ្ទាត់អំពីការយល់ស្របគ្នានៃធាតុផ្សំទាំងនេះ ដើម្បីសម្រេចឱ្យស្របតាមច្បាប់")។ *រឿងក្តី Mai Engineering Ood និងជនដទៃទៀត ទល់នឹង បុលហ្គារី* តុលាការ ECtHR សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ ១៣៨៥៤/០៤ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ១០១ ("លក្ខណៈ និងវិសាលភាពនៃការបំពេញចិត្តដែលបង្គាប់ដោយតុលាការតាមមាត្រា ៤១ នៃអនុសញ្ញាផ្អែកដោយផ្ទាល់លើលក្ខណៈនៃការរំលោភបំពាន។ លើសពីនេះ ចំណងហេតុ និងបច្ច័យរវាងព្យសនកម្មដែលទាមទារដោយអ្នកដាក់ពាក្យសុំ និងការរំលោភបំពាន ត្រូវតែបញ្ជាក់ឱ្យបានច្បាស់") (ការដកស្រង់ត្រូវបានលុបចោល)។

វិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្ម[1421]។ ការបង្ហាញឱ្យឃើញថា មានព្យសនកម្ម គឺបង្ហាញឱ្យឃើញនូវសិទ្ធិស្នើសុំសំណង។ អាស្រ័យហេតុនេះ នៅពេលអង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា មានព្យសនកម្ម និងទទួលស្គាល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងសាទុក្ខ ដូច្នេះភាពអាចទទួលបានសំណងត្រូវមានភស្តុតាងបង្ហាញ។ ដូចដែលពាក់ព័ន្ធនឹងទម្រង់នៃការសងសំណង អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ពាក់ព័ន្ធនឹងព្យសនកម្មដែលមាននៅក្នុងទម្រង់នៃសំណងដែលចង់បាន និងសមស្រប បានលុបចោលនូវផលវិបាកនៃអំពើល្មើស ព្រមទាំងស្តារឡើងវិញតាមអាចធ្វើបាននូវឋានៈស្របច្បាប់ពីមុន។ ដោយពិចារណាថា ព្យសន កម្មដែលកើតមានចំពោះជនរងគ្រោះ គឺជាព្យសនកម្មចំពោះសុខភាពរូបរាងកាយ និង/ឬចិត្តសាស្ត្ររបស់ពួកគេ ការផ្តល់នូវការព្យាបាលលើរូបរាងកាយ និងចិត្តសាស្ត្រនៃព្យសនកម្មនេះ គឺជាទម្រង់សមស្របនៃសំណងផ្អែកតាមលក្ខខណ្ឌនេះ។

៧០០. បញ្ហាបន្ទាប់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺថាតើវិធានការដែលស្នើសុំមានលក្ខណៈសម្បត្តិជា "សមូហភាព និងផ្លូវចិត្ត" ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ជាការពិតនៅក្នុងករណីជាច្រើន តុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្សបានផ្តល់ឱ្យភាគីដែលរងព្យសនកម្មអាចទទួល ការព្យាបាលវេជ្ជសាស្ត្រ និងផ្លូវចិត្តដោយឥតគិតថ្លៃ ដែលជាទម្រង់សមស្របនៃការសងសំណង។ ក្នុងរឿងក្តី *Plan de Sánchez Massacre ទល់នឹង កាតេម៉ាឡា* ដែលទាក់ទងនឹងការធ្វើទារុណកម្ម និងការសម្លាប់រង្គាលប្រជាជនជាបន្តបន្ទាប់លើសពី ២៥០ នាក់ រដ្ឋភាគីត្រូវបានបញ្ជាឱ្យបង្កើតមណ្ឌលសុខភាពនៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ដោយឧក្រិដ្ឋកម្ម ដូច្នេះជនរងគ្រោះ និងញាតិសន្តានរបស់ពួកគេ អាចទទួលបានការព្យាបាលវេជ្ជសាស្ត្រ និងចិត្តសាស្ត្រគ្រប់គ្រាន់តាមរយៈស្ថាប័នជំនាញសុខាភិបាលរបស់រដ្ឋភាគី[1422]។ នៅក្នុងករណីនេះ តុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្សមិនអាចកំណត់បានច្បាស់អំពីចំនួនសរុបនៃជនរងគ្រោះ និងអ្នកត្រូវទទួលសំណងនោះទេ។ ជាចុងក្រោយ អលទ្ធភាពនេះត្រូវបានចាត់ទុកជាសំអាងហេតុមួយ ដើម្បីបដិសេធ

---

[1421] មាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ ។ វិធាន ២៣*ស្ទួន*(២) នៃវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៨)។

[1422] *រឿងក្តី Plan de Sánchez Massacre ទល់នឹង ហ្គាន់តេម៉ាឡា*, សាលក្រម (សំណង និងសោហ៊ុយ), កថាខណ្ឌ ១០៧។

ចោលសំណងជាហិរញ្ញវត្ថុសម្រាប់ជនទាំងឡាយដែលមិនត្រូវបានកំណត់អត្តសញ្ញាណ នៅពេលចេញសាលក្រមរបស់តុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស និងដើម្បីកំណត់យក "ទម្រង់ផ្សេងទៀតនៃសំណង" ដែលអាចផ្តល់ផលប្រយោជន៍ដល់"សមាជិកនៃសហគមន៍ទាំងអស់ដែលទទួលរងផលប៉ះពាល់ដោយអង្គហេតុនៃរឿងក្តី"[1423]។ នៅក្នុងចំណោមទម្រង់ផ្សេងទៀតនៃសំណងដែលបានបង្គាប់ ការផ្តល់សេវាផ្នែកវេជ្ជសាស្ត្រដោយមិនគិតថ្លៃគឺ ជាសំណងពាក់ព័ន្ធសម្រាប់រឿងក្តីនេះ។ ជាពិសេស ក្នុងរឿងក្តី *Plan de Sánchez Massacre ទល់នឹង ការតេម៉ាឡា* ទម្រង់នៃការសងសំណងនេះត្រូវបានស្នើសុំយ៉ាងច្បាស់ដោយរដ្ឋភាគី ដែលបានលើកឡើងថាៈ

> ដោយពិចារណាពីភាពលំបាកនៃការកំណត់ជនរងគ្រោះនីមួយៗ ដែលបានស្លាប់នៅក្នុងការសម្លាប់រង្គាល ព្រមទាំងញាតិសន្តាន និងអ្នកទទួលសំណង វិធានការសងសំណងត្រូវបានបង្គាប់ថាអ្នកនៅរស់រានមានជីវិតដែលជាញាតិសន្តាន និងជាជនរងគ្រោះ ត្រូវតែធ្វើឱ្យមានកិត្តិយសនិងឱ្យមាននីតិសម្បទា ជាជាងគ្រាន់តែផ្តល់ជូននូវសំណងជាហិរញ្ញវត្ថុដល់បុគ្គលម្នាក់ៗ[1424]។

៧០១. សេចក្តីសម្រេចនេះ និងសេចក្តីសម្រេចផ្សេងទៀតរបស់តុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្សបញ្ជាក់ថា ការផ្តល់ការព្យាបាលវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ គឺត្រូវបានទទួលស្គាល់ជាអន្តរជាតិថា ជាទម្រង់នៃការសងសំណងសមស្រប។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សំណើសុំដែលដាក់ដោយម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ គឺស្ថិតនៅក្នុងពាក្យពេចន៍នៃសំណង"សមូហភាព និងផ្លូវចិត្ត" ដែលមានចែងនៅក្នុងវិធាន ២៣(១)(ខ) នៃវិធានផ្ទៃក្នុង ហេតុដូច្នេះ ស្ថិតនៅក្នុងវិធានការដែលតុលាការនេះត្រូវបានផ្តល់អំណាចឱ្យបង្គាប់។

---

[1423] *រឿងក្តី Plan de Sánchez Massacre ទល់នឹង ហ្គាន់តេម៉ាឡា*, សាលក្រម (សំណង និងសោហ៊ុយ), កថាខណ្ឌ ៦២។

[1424] *រឿងក្តី Plan de Sánchez Massacre ទល់នឹង ហ្គាន់តេម៉ាឡា*, សាលក្រម (សំណង និងសោហ៊ុយ), កថាខណ្ឌ ៩២។

៧០២. បញ្ហាដែលនៅសេសសល់ គឺភាពអាចអនុវត្តបាន។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅក្នុងរឿងក្តី *Plan deSánchez Massacre ទល់នឹង ការតេម៉ាឡា* ការណែនាំលម្អិត ត្រូវបានផ្តល់ដោយតុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស (IACtHR) ដែលទាក់ទងនឹង គណៈកម្មាធិការដែលថា តុលាការសម្រេចបង្គាប់ឱ្យបង្កើតឡើង ដើម្បីធ្វើការវាយតម្លៃអំពីតម្រូវ ការរបស់ជនរងគ្រោះម្នាក់ៗ ដោយមានការជួយជ្រោមជ្រែងពីអង្គការមិនមែនរដ្ឋាភិបាល[1425]។ ជាការគួរឱ្យចាប់អារម្មណ៍ផងដែរ តុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស(IACtHR) បានសម្រេចបង្គាប់បន្ថែមឱ្យបង្កើតយន្តការមួយ ដែលរួមបញ្ចូលនូវការប្រកាសតាមសាព័ត៌មាន វិទ្យុ និងទូរទស្សន៍ អំពីទីកន្លែងសាច់ញាតិរបស់ជនរងគ្រោះ ដែលតុលាការមិនបានកំណត់នូវអត្តសញ្ញាណ ប៉ុន្តែ ត្រូវបានទទួលស្គាល់ថា មានសិទ្ធិទទួលបានសំណង[1426]។

៧០៣. រឿងក្តីនានាក្នុងក្របខណ្ឌអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ACHR) ដែលបានពិភាក្សាខាងលើ បង្ហាញយ៉ាងច្បាស់ថា ប្រភេទនៃវិធានការទាំងនេះតម្រូវឱ្យមានរចនាសម្ព័ន្ធរដ្ឋបាល

---

[1425] *រឿងក្តី Plan de Sánchez Massacre ទល់នឹង ហ្គាន់តេម៉ាឡា*, សាលក្រម (សំណង និងសោហ៊ុយ), កថាខណ្ឌ ១០៨។ *រឿងក្តីស្ថាប័ន "Juvenile Reeducation Institute" ទល់នឹង ប៉ារ៉ាហ្គាយ*, តុលាការ IACtHR, សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ), ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០០៤, កថាខណ្ឌ ៣១៨ ដល់ ៣២០។ *សូមមើលផងដែរ រឿងក្តី Serrano-Cruz Sisters ទល់នឹង El Salvador,* តុលាការ IACtHR, សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ) ចុះថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៥ កថាខណ្ឌ ១៩៨ (ដោយសម្រេចថា ស្ថាប័នមិនមែនរដ្ឋាភិបាល គួរចូលរួមនៅក្នុងការអនុវត្តការព្យាបាលវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ)។ ចំពោះការព្យាបាលវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ ដែលជាទម្រង់នៃសំណង, *សូមមើលជាទូទៅ រឿងក្តីពាណិជ្ជករ១៩ នាក់ (19 Merchants) ទល់នឹង កូឡុំប៊ី,* តុលាការ IACtHR, សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោយហ៊ុយ) ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ២៧៨។ *សូមមើល រឿងក្តី Huilca-Tecse ទល់នឹង ប៉េរូ* តុលាការ IACtHR សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ), ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៥, កថាខណ្ឌ ១០៣[៧], ១១៦។ *រឿងក្តី De La Cruz-Flores ទល់នឹង ប៉េរូ,* តុលាការ IACtHR, សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ), ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤, កថាខណ្ឌ ១៦៨។

[1426] *រឿងក្តីពាណិជ្ជករ ១៩ នាក់ ទល់នឹង កូឡុំប៊ី,* តុលាការ IACtHR , សេចក្តីសម្រេច (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងសោហ៊ុយ), កថាខណ្ឌ ២៣៣ ដល់ ២៣៤។

ស្មុគស្មាញមួយ ដើម្បីអាចអនុវត្តបាន។ យោងតាមអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ប្រភេទនៃវិធានការទាំងនេះត្រូវអនុវត្តដោយស្ថាប័នរបស់រដ្ឋភាគី តាមរយៈស្ថាប័នសុខភាពជំនាញរបស់ខ្លួន និងនៅក្នុងក្របខណ្ឌដែលតុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្សនៅតែរក្សាតួនាទីគ្រប់គ្រងដដែល។ ក្នុងគោលបំណងនេះ គណៈកម្មាធិការនានាត្រូវបានបង្គាប់ឱ្យបង្កើតឡើង ស្ថាប័នខាងក្រៅត្រូវតែមានការពាក់ព័ន្ធ ហើយដំណាក់កាលអនុវត្តត្រូវបានគ្រប់គ្រងមួយផ្នែកដោយតុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្សខ្លួនឯង។ យន្តការនៃការអនុវត្តបែបនេះ គឺមានសារសំខាន់ ដើម្បីជួយដល់សេចក្តីបង្គាប់របស់តុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស អាចអនុវត្តបានពិតប្រាកដ ជាឧទាហរណ៍ ដោយជួយកំណត់អត្តសញ្ញាណអ្នកសងសំណង និងជួយវាយតម្លៃលើតម្រូវការរបស់ពួកគេ។ ផ្ទុយមកវិញ អ.វ.ត.ក មិនត្រូវបានផ្តល់អំណាចឱ្យចេញដីកាបង្គាប់ចងកាតព្វកិច្ចប្រឆាំងនឹងរដ្ឋ ឬអង្គនីតិប្រតិបត្តិរបស់រដ្ឋ ឬ អ.វ.ត.ក មិនត្រូវបានបង្ហាញឱ្យឃើញថា រដ្ឋស្ម័គ្រចិត្ត ឬមានលទ្ធភាពជួយកំណត់អត្តសញ្ញាណរបស់ប្រភេទនៃអត្តគាហក ដែលមានចំនួនច្រើន និងមិនមានអត្តសញ្ញាណច្បាស់លាស់នោះទេ[1427]។ នៅក្នុងបរិបទរបស់ អ.វ.ត.ក ដីកាបង្គាប់អាចចងជាប់កាតព្វកិច្ចចំពោះតែពិរុទ្ធជន ប៉ុណ្ណោះ[1428]។ ដោយពិចារណាអំពីភាពក្រីក្ររបស់ កាំង ហ្កេកអ៊ាវ និងការគ្មានអំណាចទូលំទូលាយដើម្បីវិនិច្ឆ័យ និងអនុវត្តវិធានការដោយមានការគាំទ្រពីស្ថាប័នរដ្ឋ អង្គជំនុំជម្រះតុលាការកំពូល មិនអាចទទួលយកសំណើសុំរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ។

៧០៤. នៅដំណាក់កាលនេះ ដោយសារតែអង្គជំនុំជម្រះតុលាការកំពូលមិនមានលទ្ធភាពបង្កើតទិន្នន័យសំខាន់ៗនៃដីកាបង្គាប់ស្តីពីសំណងដែលស្នើសុំ ដោយរួមបញ្ចូលទាំងតម្លៃនៃសំណង ចំនួន និងអត្តសញ្ញាណនៃអ្នកទទួលសំណង ព្រមទាំងប្រភេទ អំឡុងពេល និងរបៀបនៃ

---

[1427] *ប្រៀបធៀបរឿងក្តី Plan de Sánchez Massacre ទល់នឹង Guatemala*, សេចក្តីសម្រេច (សំណង និងសោហ៊ុយ)", កថាខណ្ឌ ៩២ (ដោយពិចារណាអំពីការលំបាកនៃការកំណត់អត្តសញ្ញាណចំនួនសរុបនៃអ្នកទទួលសំណង រដ្ឋជាចុងបណ្តឹងសាទុក្ខខ្លួនឯង ដែលត្រូវស្នើសុំវិធានការ ដែលអាចលើកកម្ពស់សេចក្តីថ្លៃថ្នូរ និងធ្វើឱ្យមាននីតិសម្បទាជនរងគ្រោះ ដូចជាការព្យាបាលវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ ព្រមទាំងសេវាសង្គម និងអប់រំសម្រាប់សហគមន៍ដែលទទួលរងផលប៉ះពាល់)។

[1428] វិធាន ២៣(១១) នៃវិធានផ្ទៃក្នុង។

ការព្យាបាលដែលត្រូវការ[1429] សំណើទាមទារសំណងនេះមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចទទួលយកសំណើនីមួយៗបានឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការផ្តល់សេវាសុខភាព ជាទូទៅ គឺជាទម្រង់នៃសំណង ដែលសមស្របមួយ[1430]។

---

[1429]ទោះបីជា នៅក្នុងបណ្តឹងសាទុក្ខដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ បញ្ជាក់ថា សំណើសុំនេះពាក់ព័ន្ធតែមនុស្ស ១៧នាក់ប៉ុណ្ណោះក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណីនានាមានជំហរខុសៗគ្នានៅអង្គជំនុំជម្រះសាលាដំបូង។ ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ បានសំដៅលើការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ សម្រាប់អ្នកនៅរស់រានមានជីវិតដោយផ្ទាល់ពីមន្ទីរ ស ២១ និងមន្ទីរ ស ២៤ និងសម្រាប់ជនរងគ្រោះដោយប្រយោល ដែលអាចបង្ហាញអំពីទំនាក់ទំនងហេតុ និងបច្ច័យរវាងការឈឺចាប់របស់ខ្លួន ជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ សារណាចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២, កថាខណ្ឌ ១៨។ ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ បានដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូងសុំឱ្យព្យាបាលវេជ្ជសាស្ត្រដល់ជនរងគ្រោះជាទូទៅ នោងជាពិសេសដល់ជនរងគ្រោះនៅមន្ទីរ ស ២១។ ដូចគ្នាដែរ ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ៣ បានស្នើសុំព្យាបាលវេជ្ជសាស្ត្រដោយឥតគិតថ្លៃចំពោះអ្នកនៅរស់រានមានជីវិតពីមន្ទីរ ស ២១ និងមន្ទីរ ស ២៤ ព្រមទាំងព្យាបាលជម្ងឺបាក់ស្បាតដែលជនរងគ្រោះដោយផ្ទាល់ និងជនរងគ្រោះដោយប្រយោលទទួលរង។ សារណាចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣, ឯកសារ E159/5 ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩, កថាខណ្ឌ ១៥៧ ដល់ ១៥៨។ សារណារួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការព្យាបាលផ្នែករូបរាងកាយ និងចិត្តសាស្ត្រ ដោយរួមបញ្ចូលទាំងការដឹកជញ្ជូនទៅមណ្ឌលសុខភាពចំពោះដើមបណ្តឹងរដ្ឋប្បវេណីជាទូទៅ។ សារណារួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១៧ ដល់ ២២។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ត្រឹមត្រូវក្នុងការសម្រេចថា សិទ្ធិវន្តដែលទទួលសំណង មិនត្រូវបានកំណត់អត្តសញ្ញាណច្បាស់លាស់នោះទេ។ ទាក់ទងនឹងការទាមទារឲ្យព្យាបាលផ្នែកវេជ្ជសាស្ត្រដោយឥតគិតថ្លៃ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការទាក់ទងរបស់ពួកគេទៅនឹងឧក្រិដ្ឋកម្មដែល ឌុច ត្រូវបានរកឃើញថាទទួលខុសត្រូវ គឺមិនច្បាស់ដូចដែលការទាមទារទាំងនោះ ដែលទាក់ទងនឹងការព្យាបាលចិត្តសាស្ត្រ ដែលមានបំណងព្យាបាលជំងឺបាក់ស្បាត។ អាស្រ័យហេតុនេះ សំណើសុំ ត្រូវការឲ្យបញ្ជាក់ថាតើស្នើសុំការព្យាបាលផ្នែកវេជ្ជសាស្ត្រទាំងមូល ឬកំណត់ត្រឹមស្ថានភាពផ្នែករូបរាងកាយ ដែលកើតឡើងដោយសារព្យសនកម្ម ដែលទទួលរងដោយសារតែឧក្រិដ្ឋកម្ម។ នៅក្នុងករណីក្រោយៗ យន្តការសម្រាប់បង្ហាញការទទួលស្គាល់សិទ្ធិវន្ត តម្រូវឲ្យផ្តល់អនុភាពដល់សំណង។

[1430]សម្រាប់គោលបំណងនេះ ដំណោះស្រាយដែលអាចធ្វើទៅបានមួយ អាចជាការបង្កើតមូលនិធិស្ម័គ្រចិត្ត ដែលផ្តល់មូលនិធិពីខាងក្រៅ ដែលរចនាសម្ព័ន្ធរបស់វា នឹងទទួលភារៈអនុវត្តវិធានការដែលបានស្នើសុំ។ វិសោធនកម្មថ្មីៗលើវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់អំពីយន្តការថ្មីមួយ ដែល អ.វ.ត.ក អាចទទួលស្គាល់លើគម្រោងសំណងដែលរៀបចំឡើង និងបង្កើតឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយមានការសហការជាមួយនឹងផ្នែកគាំពារជនរងគ្រោះ។ អង្គជំនុំ

### *៧.ខ.២.ឃ.៦.ការបង្កើត និងចែកចាយសម្ភារៈសោតទស្សន៍ស្ដីពីសំណុំរឿង ០០១*

៧០៥. ដើមបណ្ដឹងរដ្ឋប្បវេណីលើកសំណើមួយចំនួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលជាទូទៅ ពាក់ព័ន្ធនឹងការចែកចាយសាលក្រម និងសកម្មភាពផ្សព្វផ្សាយព័ត៌មានដទៃផ្សេងទៀត ដោយរួមមានការផលិត សម្ភារៈសោតទស្សន៍ដែលមានរយៈពេលយ៉ាងហោចណាស់ ១០០ (មួយរយ) ម៉ោង ស្ដីអំពីកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះ[1431]។ សំណើសុំទាំងនេះរួមមានការចែកចាយសម្ភារៈទាំងនេះទៅតាមបណ្ដាខេត្ត និងឃុំ/សង្កាត់ ដូចជាឯកសារជាសម្លេង និងជាលាយលក្ខណ៍អក្សរ សង្ខេប និងពន្យល់អំពីសាលក្រម ឬសាលដីកាស្ដាពរ សេចក្ដីជូនដំណឹងអំពីសាលក្រមតាមរយៈការបោះពុម្ពផ្សាយជាផ្លូវការ និងតាមរយៈសារព័ត៌មានជាតិផ្សេងៗទៀត ហើយនិងការផ្សព្វផ្សាយនូវសាលក្រមតាមបណ្ដាវិទ្យុ និងទូរទស្សន៍នានាផងដែរ[1432]។

៧០៦. បើទោះបីជា អង្គជំនុំជម្រះសាលាដំបូងមិនបានដោះស្រាយដោយផ្ទាល់លើសំណើសុំឱ្យចែកចាយសម្ភារៈ និងឯកសារសោតទស្សន៍ស្ដីអំពីសវនាការក៏ដោយ ក៏អាចមានការសន្និដ្ឋានបានដោយត្រឹមត្រូវដែរថា សំណើសុំទាំងនេះត្រូវបានសម្រេចនៅក្នុងត្រង់ចំណុចដែលមានចំណាង

---

ជម្រះតុលាការកំពូលស្វាគមន៍នូវក្របខណ្ឌគតិយុត្តថ្មីមួយនេះ ប៉ុន្តែ នៅពេលជាមួយគ្នានោះ កត់សម្គាល់ថា ពុំអនុវត្តចំពោះរឿងក្ដីបច្ចុប្បន្ននោះទេ។ វិធាន ១១៤(៣) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨)។ សាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៧០ (បានច្រានចោលយ៉ាងត្រឹមត្រូវលើសំណើសុំបង្កើតមូលនិធិសង្គ្រោះចិត្ត ដោយហេតុថា ស្ថិតនៅក្រៅវិសាលភាពនៃសំណងដែលផ្ដល់ជូននៅចំពោះមុខ អ.វ.ត.ក)។ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣ បានអះអាងដោយគ្មានមូលដ្ឋានថា“អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ ដោយសារពុំបានសម្រេចលើបញ្ហានៃការបង្កើតមូលនិធិសង្គ្រោះចិត្ត” គឺពុំត្រឹមត្រូវឡើយ។ បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ៣, កថាខណ្ឌ ១០១។ នៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះតុលាការកំពូលអាចត្រឹមតែលើកទឹកចិត្តឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ ដែលភាគច្រើនក៏បានចូលរួមនៅក្នុងសំណុំរឿង ០០២ ផងដែរនោះ (ក្នុងចំណោម ៩៤ នាក់ មានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចំនួន ៦៩ នាក់នៅក្នុងសំណើរឿង ០០១ ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២) បានស្នើសុំទម្រង់នៃសំណងមួយប្រភេទនេះតាមរយៈប្រព័ន្ធដែលបានធ្វើវិសោធនកម្ម។

[1431]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៥៤, ៦៥៦, ៦៥៧។

[1432]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៥៤, ៦៥៦, ៦៥៧។

ដើងថា "សំណើទាក់ទងនឹងការបោះពុម្ពផ្សាយសាលក្រម និងការផ្សព្វផ្សាយ"[1433]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំទាំងនេះនៅត្រង់ផ្នែកនេះ ដោយសារតែសំណើសុំ ខ្វះភាពជាក់លាក់ ពីព្រោះថា "លក្ខណៈពិតប្រាកដនៃវិធានការដែលបានស្នើសុំ និងសោហ៊ុយជំងឺចិត្តមានភាពមិនច្បាស់លាស់ និងមិនអាចកំណត់បានឡើយ"[1434]។ ទោះជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា (ក) សាលក្រមនឹងអាចរកបាននៅក្នុងប្រព័ន្ធសារព័ត៌មាន តាមរយៈគេហទំព័ររបស់ អ.វ.ត.ក និង (ខ) ការផ្សព្វផ្សាយព័ត៌មានស្តីពីសាលក្រម នឹងប្រព្រឹត្តទៅជាផ្នែកមួយនៃកម្មវិធីអប់រំផ្សព្វផ្សាយរបស់ផ្នែកកិច្ចការសាធារណៈ[1435]។

៧០៧. ចំពោះទឡ្ហីករណ៍នានា ដែលបានលើកឡើងដើម្បីគាំទ្រដល់សំណើសុំឱ្យមានការរំពូកដល់ជនរងគ្រោះនោះ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងកំណត់លក្ខខណ្ឌវិនិច្ឆ័យខ្ពស់ហួសហេតុពេក ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃភាពជាក់លាក់សម្រាប់សំណើសុំទាំងនេះ ដែលជាលទ្ធផល បានរំលោភបំពានលើវិធាន ២១ (ក) និង (គ) និងវិធាន ២៣ នៃវិធានផ្ទៃក្នុង[1436]។ ដោយតម្រូវឱ្យបង្ហាញនូវកម្រិតខ្ពស់នៃភាពជាក់លាក់បែបនេះដោយគ្មានមូលដ្ឋានអង្គច្បាប់នោះ អង្គជំនុំជម្រះសាលាដបូងបានដាក់បន្ទុកធ្ងន់ហួសហេតុដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយបានរំលោភបំពានលើវិធាន ២១ (១) (ក) នៃវិធានផ្ទៃក្នុងស្តីអំពីគោលការណ៍នៃភាពយុត្តិធម៌នៅក្នុងកិច្ចដំណើរការនីតិវិធី និងសិទ្ធិរបស់ជនរងគ្រោះ[1437]។ បន្ថែមលើនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ក៏បានលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ដោយបានមើលរំលងនូវព័ត៌មានជាក់លាក់ដែលបានផ្តល់ឱ្យសម្រាប់សំណើសុំទាំងនោះ[1438]។

---

[1433]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ចំណងជើង ៤.៤.៣.៣ ទាក់ទងនឹងកថាខណ្ឌ ៦៦៩។

[1434]សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៩។

[1435]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៦៩។

[1436]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ, កថាខណ្ឌ ១១៦។

[1437]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ, កថាខណ្ឌ ១១៧ ដល់ ១១៨។

[1438]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ, កថាខណ្ឌ ១១៩។

៧០៨. អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា ការចែកចាយឱ្យបានទូលំទូលាយនូវសម្ភារៈពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ និងរាល់សេចក្ដីសម្រេចរបស់ខ្លួនលើអង្គហេតុ និងអង្គច្បាប់គឺស្របទៅនឹងអាណត្តិរបស់ អ.វ.ត.ក ដែលរួមមានទាំងការចូលរួមចំណែកនៅក្នុងការផ្សះផ្សាជាតិ និងការផ្ដល់ឱ្យនូវឯកសារ ដើម្បីគាំទ្រដល់ការស្វែងរកការពិតខាងផ្នែកប្រវត្តិសាស្ត្រដ៏យូរអង្វែងមកហើយ។ ការយល់ដឹងរបស់សាធារណជន និងការពិភាក្សាវែកញែកអំពីទំព័រប្រវត្តិសាស្ត្រកម្ពុជាដ៏សោកនាដកម្មទាំងនេះ គឺជាផ្នែកមួយនៃកិច្ចប្រឹងប្រែងដើម្បីស្វែងរកជ័យជំនះឱ្យប្រជាជនកម្ពុជា[1439]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការចែកចាយឱ្យទូលំទូលាយនូវសេចក្ដីសម្រេចរបស់ខ្លួន អាចចូលរួមចំណែកនៅក្នុងគោលបំណងនៃការផ្សះផ្សាជាតិ តាមរយៈការជំរុញឱ្យមានកិច្ចពិភាក្សាលើអតីតកាលជាពិសេស និងជាសាធារណៈ ដោយផ្អែកលើមូលដ្ឋានដ៏រឹងមាំមួយដែលជាលទ្ធផលអាចកាត់បន្ថយនូវទស្សនៈនៃការមិនទទួលស្គាល់ការបំផ្លើអង្គហេតុ និងភាពពិតដែលមានតែមួយផ្នែកនោះបាន។

៧០៩. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ការចែកចាយសម្ភារៈស្ដីពីកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក គឺជាទម្រង់នៃសំណងដ៏សមស្របមួយ។ ក្នុងន័យនេះ ជាការចាំបាច់ត្រូវបញ្ជាក់ជាថ្មីម្ដងទៀតថា រាល់ដីកាសម្រេចលើសំណងបែបនេះ មិនអាចអនុវត្តបានទេ

[1439] *សូមមើល រឿងក្ដី* *Lehideux និង Isorniv ទល់នឹង ប្រទេសបារាំង*, តុលាការ ECtHR, សាលក្រមដ៏ប្រណិតរបស់អង្គជំនុំជម្រះ សំណុំរឿងលេខ ២៤៦៦២/៩៤ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៥ (ដែលបានយល់ឃើញថា ទាក់ទងនឹងទំព័រប្រវត្តិសាស្ត្រដ៏ឈឺចាប់របស់ប្រទេសបារាំង ដូចជាគោលនយោបាយដ៏ចម្រូងចម្រាស់នៃការសហការណ៍គ្នាជាមួយនឹងពួកណាហ្ស៊ី (Nazi) នៃប្រទេសអាល្លឺម៉ង់ ក្នុងការសម្លាប់រង្គាល់នូវជនជាតិជ្វីហ្វ (Jews) វាមិនមែនជាភាពសមស្របនោះទេ ដែលរដ្ឋអាជ្ញាត្រូវកំហិតការពិភាក្សាជាសាធារណៈលើប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួននោះ បើទោះជាយថាហេតុនៃការពិភាក្សានោះនឹងបើកកកាយសារឡើងវិញនូវភាពចម្រូងចម្រាស់ និងរំឭកនូវការចងចាំដ៏ឈឺផ្សាអំពីអតីតកាលក៏ដោយ)។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា "ទាំងនេះគឺជាតម្រូវការឱ្យមានពហុបក្សនិយម ការអធ្យាស្រ័យគ្នា និងគំនិតទូលំទូលាយ ដែលអវត្តមាននៃតម្រូវការទាំងនេះ នឹងមិននាំឱ្យយើងទទួលបាននូវ "សង្គមប្រជាធិបតេយ្យ" មួយបានឡើយ"។ *រឿងក្ដី Lehideux និង Isorniv ទល់នឹង ប្រទេសបារាំង* , សាលក្រមប្រណិតរបស់អង្គជំនុំជម្រះ, កថាខណ្ឌ ៥៥។

ដោយហេតុថា កាំង ហ្កេកអ៊ាវ គឺជាជនក្រីក្រ។ ទោះជាយ៉ាងដូច្នេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលជាម្ចាស់បណ្តឹងសាទុក្ខ គឺស្ថិតនៅក្នុងក្របខណ្ឌការងាររបស់ផ្នែកកិច្ចការសាធារណៈ និងផ្នែកគាំពារជនរងគ្រោះ ដែលអាណត្តិរបស់អង្គភាពទាំងពីរនេះ រួមមានការសកម្មភាពផ្សព្វផ្សាយទាក់ទងទៅនឹងជនរងគ្រោះ[1440] និងការផ្សព្វផ្សាយព័ត៌មានស្តីអំពី អ.វ.ត.ក[1441]។ អង្គជំនុំជម្រះតុលាការកំពូលស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងដែលធ្វើឡើងមកទល់ពេលនេះ ក្នុងការធានានូវការចែកចាយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងខិត្តប័ណ្ណ និងសម្ភារៈសោតទស្សន៍នានាដែលសង្ខេបលើសេចក្តីសម្រេចសំខាន់ៗទៅតាមបណ្តាឃុំ/សង្កាត់ និងមន្ទីរខេត្តភាគច្រើន និងទៅតាមបណ្តាសារព័ត៌មាននានា តាមសំណើសុំ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ដល់ផ្នែកកិច្ចការសាធារណៈ និងផ្នែកគាំពារជនរងគ្រោះឱ្យរៀបចំកម្មវិធីផ្សព្វផ្សាយព័ត៌មាននានា ដោយរួមមានការចែកចាយព័ត៌មានស្តីអំពីសាលដីកាលើបណ្តឹងសាទុក្ខ ដោយមានភ្ជាប់ជាមួយផងដែរនូវសេចក្តីពិចារណាដ៏ត្រឹមត្រូវលើសំណើទាមទារសំណងនានារបស់ដើមបណ្តឹងរដ្ឋប្បវេណីជាម្ចាស់បណ្តឹងសាទុក្ខ។

### *៧.ខ.២.ឃ.៧.ការយកឈ្មោះរបស់ជនរងគ្រោះចំនួន ១៧ រូប ដាក់ជាឈ្មោះអគារសាធារណៈ និងការប្រារព្ធពិធីបុណ្យផ្សេងៗដល់ជនរងគ្រោះ*

៧១០. ដើមបណ្តឹងរដ្ឋប្បវេណីដែលជាម្ចាស់បណ្តឹងសាទុក្ខ បានស្នើសុំឱ្យប្រកាសថ្ងៃចងចាំថ្នាក់ជាតិមួយ ដើម្បីរំឭកដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ការផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗនូវសិទ្ធិក្នុងការដាក់ឈ្មោះអគារសាធារណៈណាមួយដែលគាត់ជ្រើសរើស ទៅតាមឈ្មោះរបស់ជនរងគ្រោះដែលគាត់ធ្វើជាតំណាង ការប្រារព្ធពិធីជាផ្លូវការនានា និងការកសាងនូវផ្ទាំង

---

[1440] វិធាន ១២(២)(ជ) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣)។ វិធាន ១២*ស្ទួន*(១)(ជ) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨)។

[1441] វិធាន ៩(៤) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣ និងលើកទី ៨)។ វិធាន ១២*ស្ទួន*(១)(ង) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨)។

00798863



សិលាជាព័ត៌មាន និងជាការរំឭក[1442]។ អង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចជាក់លាក់ចំពោះសំណើសុំទាំងនេះនោះទេ ប៉ុន្តែអាចមានការសន្និតបានថា សេចក្តីសម្រេចលើសំណើសុំទាំងនេះមាននៅក្នុងផ្នែកដែលមានចំណងជើងថា "សំណើសុំនូវវិធានការមួយចំនួនពីរាជរដ្ឋាភិបាលកម្ពុជា"[1443]។ ក្នុងន័យនេះ សំណើសុំទាំងនេះត្រូវបានច្រានចោលដោយអង្គជំនុំជម្រះសាលាដំបូង ដោយហេតុថាសំណើសុំមិនស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ ពីព្រោះ អ.វ.ត.ក មិនមានសមត្ថកិច្ចក្នុងការចាប់បង្ខំអាជ្ញាធរជាតិឡើយ[1444]។

៧១១. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ លើកឡើងថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចលើសំណើសុំឱ្យដាក់ឈ្មោះអគារសាធារណៈនេះ បង្កើតបានជាកំហុសអង្គហេតុមួយ និងជាការរំលោភបំពានលើវិធាន ១០០ (១) នៃវិធានផ្ទៃក្នុង[1445]។ បន្ថែមលើនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ នេះ ក៏បានលើកឡើងករណីផងដែរថា អង្គជំនុំជម្រះសាលាដំបូងមិនគួរត្រូវបានរារាំងក្នុងការសម្រេចលើសំណើទាមទារសំណង ដែលមិនតម្រូវឱ្យមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងមិនពាក់ព័ន្ធដល់ថវិការបស់រាជរដ្ឋាភិបាលកម្ពុជានោះទេ[1446]។

៧១២. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការចាប់ផ្តើមអនុវត្តនូវវិធានការបែបនេះគឺជា បុព្វសិទ្ធិរបស់អាជ្ញាធររដ្ឋបាលពាក់ព័ន្ធ ឬសម្ហូហភាពដែនដី។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់បន្ថែមទៀតថា អ.វ.ត.ក មិនមានអំណាចក្នុងការចេញដីកា ដែលចងកាតព្វកិច្ចដល់តតីយជន ឬចេញដីកា ដែលបង្កើតឱ្យមានកាតព្វកិច្ចដល់ភាគី ឬស្ថាប័នណាមួយដែលមិនមែនជា កាំង ហ្គេកអ៊ាវ នោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វិសាលភាពរួមនៃសំណើសុំទាំងនេះស្ថិតនៅក្រៅសមត្ថកិច្ចរបស់ អ.វ.ត.ក។ ហើយដូច្នេះ សំណើសុំទាំងនេះត្រូវបានបដិសេធចោលយ៉ាងត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូង។

---

[1442]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៥៤, ៦៥៦ ដល់ ៦៥៧។

[1443]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ផ្នែក ៤.៤.៣.៥ ទាក់ទងនឹងកថាខណ្ឌ ៦៧១។

[1444]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៧១។

[1445]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ, កថាខណ្ឌ ១២១, ១២៣។

[1446]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ, កថាខណ្ឌ ១២២។

៧១៣. ក្នុងពេលជាមួយគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ការកំណត់ថ្ងៃរំលឹកវិញ្ញាណក្ខន្ធជាតិ ការប្រារព្ធពិធីផ្លូវការនានា និងការកសាងនូវផ្ទាំងសិលាជាព័ត៌មាននិងជាការរំឭកនោះ គឺជាវិធានការសមស្របនៃសំណងនៅក្នុងកាលៈទេសៈនៃសំណុំរឿងនាពេលបច្ចុប្បន្ននេះ។

### *៧.ខ.២.ឃ.៨.ការសរសេរលិខិតជាចំហទៅកាន់រដ្ឋាភិបាល ដោយស្នើសុំថវិកាមួយផ្នែកដែលបានមកពីការចូលទស្សនាសារៈមន្ទីរត្រូវយកមកប្រើប្រាស់ជាការផ្តល់សំណង*

៧១៤. ដើមបណ្តឹងរដ្ឋប្បវេណីដែលជាម្ចាស់បណ្តឹងសាទុក្ខ បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចបង្គាប់ឱ្យ កាំង ហ្គេកអ៊ាវ សរសេរលិខិតចំហមួយផ្ញើទៅកាន់រាជរដ្ឋាភិបាល ដោយស្នើសុំថា ថវិកាបានមកពីការចូលទស្សនាសារៈមន្ទីរទួលស្លែង និងជើងឯក ចំនួនមួយភាគបីត្រូវយកមកប្រើប្រាស់សម្រាប់គាំទ្រដល់សំណើទាមទារសំណងរបស់ពួកគេ ហើយថវិកាដែលនៅសេសសល់ត្រូវផ្តល់ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីជាសំណងជំងឺចិត្ត[1447]។ អង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចលើសំណើសុំនេះឱ្យបានច្បាស់លាស់ នោះទេ។

៧១៥. ទីមួយ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើវិធាន ១០០ (១) នៃវិធានផ្ទៃក្នុង ដោយមិនសម្រេចលើសំណើសុំនេះឱ្យបានច្បាស់លាស់។ ទីពីរ ដោយសន្មតថា សំណើសុំនេះប្រហែលជាត្រូវបញ្ចូលនៅក្នុងផ្នែកដែលមានចំណងជើងថា "សំណើទាមទារសំណងជាប្រាក់ជាលក្ខណៈបុគ្គលសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ឬការបង្កើតនូវមូលនិធិមួយ" ឬនៅក្នុងផ្នែក"សំណើសុំនូវវិធានការពីរាជរដ្ឋាភិបាលកម្ពុជា" អង្គជំនុំជម្រះសាលាដំបូងត្រូវបានចោទប្រកាន់ថា មានកំហុសអង្គហេតុ ដោយបកស្រាយខុសទៅលើសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងដោយបានមើលរំលងនូវអត្ថន័យដ៏ច្បាស់លាស់របស់សំណើសុំនោះ[1448]។

[1447]សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦៥៦។

[1448]បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុមពីរ, កថាខណ្ឌ ១២៦ ដល់ កថាខណ្ឌ ១២៩។

៧១៦. អង្គជំនុំជម្រះតុលាការកំពូលរំលឹកឡើងវិញនូវសំអាងហេតុរបស់ខ្លួនពីខាងលើ ពាក់ព័ន្ធនឹងសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាម្ចាស់បណ្តឹងសាទុក្ខ ដែលស្នើសុំឱ្យ កាំង ហ្គេកអ៊ាវ សរសេរលិខិតទាមទារការសុំអភ័យទោសពីរាជរដ្ឋាភិបាលកម្ពុជា[1449] ហើយអង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ជាថ្មីម្តងទៀតថា អ.វ.ត.ក មិនមានអំណាច នៅក្នុងការចេញដីកាដែលចងកាតព្វកិច្ចដល់រាជរដ្ឋាភិបាលកម្ពុជាឡើយ។ ហេតុដូច្នេះ ការសម្រេចច្រានចោលដោយអង្គជំនុំសាលាដំបូងចំពោះសំណើសុំមួយនេះ គឺជាការសម្រេចដោយត្រឹមត្រូវ។

## ៧.ខ.៣.សេចក្តីសន្និដ្ឋាន

៧១៧. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ការឈឺចាប់របស់ជនរងគ្រោះ ក៏ដូចជាសិទ្ធិទទួលបានទម្រង់នៃសំណង ប្រកបដោយប្រសិទ្ធភាពយោងតាមបទដ្ឋានអន្តរជាតិ។ អង្គជំនុំជម្រះតុលាការកំពូលកត់ សម្គាល់បន្ថែមទៀតថា ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី និងជាពិសេស ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានលើកឡើងនូវសំណើជាច្រើន ដែលជាទូទៅមានទម្រង់ជាសំណងសមស្របចំពោះ ព្យសនកម្មដែលទទួលរង មានដូចជា ការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងសេវាចិត្តសាស្ត្រសម្រាប់ជនរងគ្រោះផ្ទាល់ និងមិនផ្ទាល់ ការយកឈ្មោះរបស់ជនរងគ្រោះធ្វើជាឈ្មោះរបស់អគារសាធារណៈ ការប្រារព្ធពិធីជាផ្លូវការនានា និងការកសាងនូវផ្ទាំងសិលាជាព័ត៌មាន និងជាការរំឭក ការកំណត់ថ្ងៃរំលឹកវិញ្ញាណក្ខន្ធជាតិ ការសាងសង់បូជនីយដ្ឋាននានា ដូចជា វត្តអារាម របងវត្ត និងវិមាននានា។ ក៏ប៉ុន្តែ ដោយមានការកម្រិតដែលមានចែងនៅក្នុងក្របខណ្ឌសំណងរបស់ អ.វ.ត.ក. ដូចបានគូសបញ្ជាក់ខាងលើ សំណើទាមទារសំណងជាក់លាក់ទាំងនេះ មិនអាចទទួលយកបានទេ។ ដោយពិចារណាថា សំណើជាច្រើនត្រូវបានបដិសេធផងដែរ ដោយសារភាពក្រីក្ររបស់ កាំង ហ្គេកអ៊ាវ និងដោយវាយតម្លៃថា សំណើមួយចំនួនមានភាពច្បាស់លាស់គ្រប់គ្រាន់ អង្គជំនុំជម្រះតុលាការកំពូលលើកទឹកចិត្តដល់អាជ្ញាធរជាតិ សហគមន៍អន្តរជាតិ ឬអ្នកដែលអាចនឹងជួយផ្តល់ជំនួយបង្ហាញសាមគ្គីភាពជាមួយជនរងគ្រោះតាមរយៈការផ្តល់ជំនួយ ការគាំទ្រជា

[1449] សូមមើលចំណុចខាងលើផ្នែក ខ "លិខិតស្នើសុំការអភ័យទោសពីរដ្ឋាភិបាល"។

ហិរញ្ញវត្ថុ ឬជំនួយតាមរូបភាពផ្សេងទៀតដែលអាចជួយរៀបចំ និងអនុវត្តទម្រង់នៃសំណង ដែលសមស្របទាំងនេះ។

## ៨.ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល៖**

**ដោយអនុលោមតាម** មាត្រា ១៤ថ្មី (១)(ខ) និង មាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៤(១)(ខ) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ឆ្នាំ ២០០៣ និងវិធាន ១១១ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨)

**បានឃើញ** សារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សររបស់ភាគីនីមួយៗ និងអំណះអំណាងដែលភាគីបានលើកឡើងនៅក្នុងសវនាការបណ្តឹងសាទុក្ខ ចាប់ពីថ្ងៃទី ២៨ ដល់ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១។

<u>ចំពោះបណ្តឹងសាទុក្ខរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច”</u>

**សម្រេចបដិសេធ** បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។

<u>ចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា</u>

**សម្រេចទទួលយក** ផ្នែកខ្លះនៃទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និង**សម្រេចបដិសេធ** ផ្នែកខ្លះនៃទឡ្ហីករណ៍នេះ។

> **សម្រេចបដិសេធ** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រង់ចំណុចស្រូបបញ្ចូលបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងបទធ្វើទុក្ខបុកម្នេញ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា **កាំង ហ្គេកអ៊ាវ** ជាអ្នកទទួលខុសត្រូវ។
>
> **សម្រេចតម្កល់ការដាក់ពិរុទ្ធភាពលើ កាំង ហ្គេកអ៊ាវ** ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F28

**សម្រេចដាក់ពិរុទ្ធភាពបន្ថែម** លើ **កាំង ហ្កេកអ៊ាវ** ពីបទសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) បទធ្វើឲ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

**សម្រេចទទួលយក** ទឡ្ហីករណ៍ទី ១ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

**សម្រេចបដិសេធ** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចសម្រេចផ្តន្ទាទោសលើ **កាំង ហ្កេកអ៊ាវ** ដាក់ពន្ធនាគាររយៈពេល ៣៥ ឆ្នាំ ។

**សម្រេចបដិសេធ** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចសម្រេចផ្តល់សំណង ចំពោះការរំលោភសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ដែលបណ្តាលមកពីការឃុំខ្លួនខុសច្បាប់នីតិវិធី របស់តុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ ដល់ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧។ និង

**សម្រេចផ្តន្ទាទោស** លើ **កាំង ហ្កេកអ៊ាវ** ដាក់ពន្ធនាគារអស់មួយជីវិត ដោយចាប់គិតពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ តទៅ ដែលគិតមកទល់ពេលនេះ **កាំង ហ្កេកអ៊ាវ** បានទទួលរងទោសអស់រយៈពេល ១២ ឆ្នាំ និង ២៦៩ ថ្ងៃរួចហើយ។

**សម្រេចបដិសេធ** ទឡ្ហីករណ៍ទី ៣ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

<u>ចំពោះបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ក្រុម ២ និង ក្រុម ៣</u>

**សម្រេចទទួលយក** ផ្នែកខ្លះនៃទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង**បដិសេធ** ផ្នែកខ្លះនៃទឡ្ហីករណ៍ទាំងនេះ។

**សម្រេចទទួលស្គាល់** ជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានភស្តុតាងបង្ហាញនៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខថាពិតជាបានទទួលរងព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែល **កាំង**

**ហ្គេកអ៊ាវ** ត្រូវបានសម្រេចដាក់ពិរុទ្ធភាព បន្ថែមលើដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងកថាខណ្ឌ ៦៨២ នៃសាលក្រម ដូចមានរាយនាមខាងក្រោម:

- លី ហ៊ំ ហៅ អ៊ា ហ៊ំរ (E2/61)
- ហ៊ឹម មុំ (E2/62)
- JAMES Jeffrey, ROTHSCHILD Joshua (E2/86 និង E2/88)
- ឆាយ កន ហៅ លៀង កន (E2/35)
- ហុង សាវ៉ាត (E2/83)
- ភោគ ខន (E2/33)
- ម៉ន សុធា (E2/82)
- ឈឹម ស៊ីថា (E2/22)
- ណាំ ម៉ុន (E2/32)[1450]។

**សម្រេចបដិសេធ** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត។

**សម្រេចបដិសេធ** ទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង។

**សម្រេចតម្កល់** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចស្តីពីការចងក្រង និងផ្សព្វផ្សាយនៅក្នុងគេហទំព័រជាផ្លូវការរបស់ អ.វ.ត.ក នូវសេចក្តីថ្លែងសុំអភ័យទោស និងការទទួលស្គាល់នូវការទទួលខុសត្រូវដែលបានធ្វើឡើងដោយ **កាំង ហ្គេកអ៊ាវ** ក្នុងអំឡុងពេលជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង ព្រមទាំងនៅអង្គជំនុំជម្រះតុលាការកំពូល[1451]។

---

[1450]ការចងក្រងការសុំអភ័យទោស ត្រូវបានដាក់ភ្ជាប់ទៅនឹងសាលដីកា, ឯកសារលេខ F28.1។

[1451]សេចក្តីចងក្រងនេះបានភ្ជាប់ទៅនឹងសាលដីកដែលមានលេខឯកសារលេខ F28.1, ដាក់ក្នុងសំណុំរឿងនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ហើយបានកែសម្រួលនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២។

**សម្រេចតម្កល់** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចបដិសេធសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

**ដោយអនុលោមតាម** វិធាន ១១១ (៥) និង ១១៣(១)-(៣) នៃវិធានផ្ទៃក្នុង

**បង្គាប់ថា កាំង ហ្កេកអ៊ាវ** ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតដល់ពេលបញ្ចប់នៃកិច្ចរៀបចំនានាក្នុងការផ្ទេរ **កាំង ហ្កេកអ៊ាវ** ទៅកាន់ពន្ធនាគារដែលខ្លួនត្រូវអនុវត្តទោស ដោយអនុលោមតាមច្បាប់ជាធរមាន។

ធ្វើជាភាសាខ្មែរ ភាសាអង់គ្លេស ។

រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២

**ក្រឡាបញ្ជី**

**ស៊ា ម៉ៅ** **Christopher RYAN** **ផន ធឿន** Paolo LOBBA

ចៅក្រម **គង់ ស្រ៊ឹម** ប្រធាន

ចៅក្រម **Motoo NOGUCHI**

ចៅក្រម **សោម សិរិវឌ្ឍ**

ចៅក្រម **Agnieszka KLONOWIECKA-MILART**

ចៅក្រម **ស៊ិន រិទ្ធ**

ចៅក្រម **Chandra Nihal JAYASINGHE**

ចៅក្រម **យ៉ា ណារិន**

ចៅក្រម Klonowiecka-**Milart** និងចៅក្រម **Chandra Nihal Jayasinghe** ភ្ជាប់មតិជំទាស់រួមគ្នាលើផ្នែកខ្លះ។

## ៩.មតិជំទាស់រួមគ្នាលើផ្នែកខ្លះរបស់ចៅក្រម AGNIESKA KLONOWIECKA-MILART និង ចៅក្រម CHANDRA NIHAL JAYASINGE

១. ដោយផ្អែកទៅនឹងមតិរបស់អង្គជំនុំជម្រះសាលាដំបូង និងលើសពីសំណើររបស់សហព្រះរាជអាជ្ញា ចៅក្រមភាគច្រើននៃអង្គជំនុំជម្រះតុលាការកំពូល បានសម្រេចប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត[1452]។ ដោយផ្អែកទៅលើការវាយតម្លៃរបស់យើងលើស្ថានទម្ងន់នៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ កាលៈទេសៈបុគ្គលរបស់ជនជាប់ចោទ ព្រមទាំងកត្តាស្ថានទម្ងន់ទោសដែលពាក់ព័ន្ធ យើងយល់ស្របថា តម្រូវឲ្យមានការដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិត។ ប៉ុន្តែ យើងមិនអាចយល់ស្របតាមចៅក្រមភាគច្រើន ដែលបដិសេធការទូទាត់សងចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិជាសារវន្តរបស់ កាំង ហ្គេកអ៊ាវ ដោយសារតែការឃុំខ្លួនគាត់ជាបណ្តោះអាសន្នអស់រយៈពេលយ៉ាងយូរ[1453]។

២. អង្គជំនុះជម្រះសាលាដំបូងបានយល់ឃើញថា ការឃុំខ្លួន កាំង ហ្គេកអ៊ាវ រយៈពេល ៨ (ប្រាំបី) ឆ្នាំ ដោយតុលាការយោធាជាតិ គឺលើសពីរយៈពេលកំណត់ ៣ (បី) ឆ្នាំ តាមច្បាប់ជាធរមាន ហើយលើសពីនេះទៅទៀត បើទោះបីជាការពន្យារពេលជាបន្តបន្ទាប់ក្នុងការឃុំខ្លួន កាំង ហ្គេកអ៊ាវ ត្រូវបានពន្យល់ថាដោយសារតែតម្រូវការចាំបាច់សម្រាប់ការស៊ើបអង្កេតដែលកំពុងតែដំណើរការក៏ដោយ ក៏មិនមានភស្តុតាងដែលថាមានការស៊ើបអង្កេតជាសំខាន់ និងជាប្រព័ន្ធនោះឡើយ។ ក្នុងករណីខ្លះ ការពន្យារពេលនៃការឃុំខ្លួនជនជាប់ចោទ ត្រូវបានបង្គាប់ឡើងដោយព្រះរាជអាជ្ញា មិនមែនដោយអង្គភាពតុលាការដែលមានសមត្ថកិច្ចឡើយ[1454]។ ការយល់ឃើញបែបនេះមិនត្រូវបានជំទាស់ដោយភាគីណាមួយ ឬដោយចៅក្រមភាគច្រើនរបស់អង្គជំនុំជម្រះតុលាការកំពូលនោះឡើយ។ លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាបានទទួលស្គាល់យ៉ាងច្បាស់នូវការចាំបាច់ក្នុងការកាត់បន្ថយទោស ទៅជាការដាក់ពន្ធនាគារដោយមាន

[1452]សាលដីកា, ផ្នែកទី ៨ នៃផ្នែកសម្រេចសេចក្តី។

[1453]សាលដីកា, កថាខណ្ឌ ៣៣៧ ដល់ ៤០៥ (“មតិភាគច្រើនស្តីពីការប្រកាសទោស”) កថាខណ្ឌ ៣៨៩ ដល់ ៣៩៩។

[1454]សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ១៩ ដល់ ២០។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៦២៤, ៦២៦។

រយៈពេលកំណត់ ដើម្បីជាការទូទាត់សងចំពោះការឃុំខ្លួនខុសនីតិវិធីច្បាប់[1455]។ យើងកត់សម្គាល់បន្ថែមទៀតថា ការឃុំខ្លួន កាំង ហ្គេកអ៊ាវ បណ្តោះអាសន្នលើសរយៈពេលកំណត់ដែលមានចែងក្នុងច្បាប់ ហើយដែលបានបន្តមករយៈពេល ១០ (ដប់) ឆ្នាំនោះ គឺមិនស្របជាមួយនឹងបទដ្ឋានដែលបង្កើតឡើងដោយមាត្រា ៩(១), (៣) និង មាត្រា ១៤(៣)(គ) នៃកតិកាសញ្ញា ICCPR ដែលប្រទេសកម្ពុជាគឺជាភាគីមួយនៃកតិកាសញ្ញានេះទេ ហើយកតិកាសញ្ញានេះគឺជាច្បាប់ដែលចងកាតព្វកិច្ចនៅចំពោះមុខ អ.វ.ត.ក[1456]។ ដូច្នេះ យើងនឹងកម្រិតការវិភាគរបស់យើងតែត្រឹមបញ្ហាថាតើការដកហូតសេរីភាពរបស់ កាំង ហ្គេកអ៊ាវ មានជាប់ពាក់ព័ន្ធទៅនឹង អ.វ.ត.ក ដែរឬយ៉ាងណា ហើយប្រសិនបើជាប់ពាក់ព័ន្ធមែន តើគាត់គួរតែទទួលបាននូវការទូទាត់សងបែបណា។

៣. មតិចៅក្រមភាគច្រើនរបស់អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ដោយយោងទៅលើយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ ពិរុទ្ធជនអាចទទួលបានការទូទាត់សងចំពោះការ

[1455] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣១ ("ក្រៅពីការផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិតអង្គជំនុំជម្រះសាលាដំបូងគួរតែកាត់បន្ថយកម្រិតទោសមកត្រឹមជាប់ពន្ធនាគារ ៤៥ ឆ្នាំបាន ដើម្បីជាការជួសជុលដល់ការជាប់ឃុំឃាំងដោយខុសច្បាប់របស់ចុងបណ្តឹងឧទ្ធរណ៍")។

[1456] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ៩ ("១. (...) គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយលើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។ (...) ៣. បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌនឹងត្រូវបាន ... ក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។")។ *សូមមើលផងដែរ* គណៈកម្មាធិការសិទ្ធិមនុស្ស, យោបល់ទូទៅលេខ ៨ - មាត្រា ៩៖ សិទ្ធិមានសេរីភាព និងសន្តិសុខរបស់បុគ្គល, ឯកសារ អ.ស.ប លេខ HRI/GEN/1/Rev.6 ត្រង់ 130 (ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៨២) ("យោបល់ទូទៅលេខ ៨"), កថាខណ្ឌ ៨ ("ការឃុំខ្លួនមុនសវនាការគួរតែជាករណីលើកលែង និងក្នុងរយៈពេលខ្លីតាមតែអាចធ្វើបាន")។ គណៈកម្មាធិការសិទ្ធិមនុស្ស, យោបល់ទូទៅលេខ ៣២ - មាត្រា ១៤៖ សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានសវនាការប្រកបដោយយុត្តិធម៌, ឯកសារ អ.ស.ប លេខ CCPR/C/GC/32 (ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧), កថាខណ្ឌ ៣៥ (ដែលតម្រូវថា ការដកហូតសិទ្ធិមិនត្រូវឲ្យហួសពីការចាំបាច់ ក្រោមកាលៈទេសៈដែលរាប់បញ្ចូលទាំងភាពស្មុគស្មាញនៃរឿងក្តី ការប្រព្រឹត្តរបស់ជនជាប់ចោទ និងឥរិយាបថនៃការឆ្លើយតបរបស់អាជ្ញាធរ), ជើងទំព័រលេខ ៧២ (ពិនិត្យឡើងវិញពីយុត្តិសាស្ត្ររបស់គណៈកម្មាធិការ ដែលមានឧទាហរណ៍ជាច្រើនដែលបង្ហាញថា ការឃុំខ្លួនមុនសវនាការមានរយៈពេលតិចជាង ១០ ឆ្នាំ ដូចក្នុងករណីនេះត្រូវបានចាត់ទុកថារំលោភដល់មាត្រា ១៤(៣)(គ))។

រំលោភទៅលើសិទ្ធិរបស់គាត់ តែក្នុងករណីដែល "យ៉ាងហោចណាស់ក៏មានការទទួលខុសត្រូវមួយចំនួន" ចំពោះការរំលោភបំពានសិទ្ធិ ដោយតុលាការនោះ[1457]។ ដោយដកស្រង់សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា អ.វ.ត.ក គឺជា "តុលាការដែលមានចរិតលក្ខណៈអន្តរជាតិ ឯករាជ្យ និងដាច់ដោយឡែក" នោះ ចៅក្រមភាគច្រើនបានសន្និដ្ឋានថា អ.វ.ត.ក មិនមានការទទួលខុសត្រូវចំពោះការរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទដែលបង្កឡើងដោយអាជ្ញាធរកម្ពុជា ពាក់ព័ន្ធទៅនឹងដំណើរការនីតិវិធីព្រហ្មទណ្ឌ មុនពេលបង្កើត អ.វ.ត.ក នោះឡើយ[1458]។ ដើម្បីគាំទ្រដល់ការសន្និដ្ឋានបែបនេះ ចៅក្រម ភាគច្រើនបានពឹងផ្អែកទាំងស្រុងទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY និង តុលាការ ICTR ដែលតុលាការទាំងនោះជាធម្មតាបានទទួលស្គាល់ការទទួលខុសត្រូវចំពោះការរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទ ក្នុងអំឡុងពេលឃុំខ្លួនបណ្ដោះអាសន្ន ដោយចៅក្រមភាគច្រើនផ្ដោតតែទៅលើចំណុចដែលរដ្ឋអាជ្ញាអន្តរជាតិ បានដាក់សំណើឃុំខ្លួនបណ្ដោះអាសន្នទៅអាជ្ញាធរជាតិ ផ្អែកតាមវិធាន ៤០ នៃ វិធានស្ដីពីនីតិវិធី និងភស្តុតាង របស់តុលាការ ICTY និង តុលាការ ICTR ប៉ុណ្ណោះ[1459]។ មតិភាគច្រើនរបស់ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល មានភាព

[1457] មតិចៅក្រមភាគច្រើនស្ដីពីការប្រកាសទោស, កថាខណ្ឌ ៣៩២។

[1458] មតិចៅក្រមភាគច្រើនស្ដីពីការប្រកាសទោស, កថាខណ្ឌ ៣៩៣។ ការសន្និដ្ឋានរបស់ចៅក្រមភាគច្រើនក៏ផ្អែកទៅលើការសម្រេចពីរចំណុចដែរគឺថា៖ ការឃុំខ្លួននៅតុលាការយោធាពុំបណ្ដាលឱ្យមានការរំលោភបំពានដល់ដំណើរការទេ និងថាពុំមានភស្តុតាងពី "សកម្មភាពរួមគ្នា" រវាងអាជ្ញាធរថ្នាក់ជាតិ និង អ.វ.ត.ក ទេ។ *សូមមើល* មតិចៅក្រមភាគច្រើនស្ដីពីការប្រកាសទោស, កថាខណ្ឌ ៣៩២ ដល់ ៣៩៤។ យើងសូមលើកឡើងថា ពុំមានការរំលោភបំពានដល់ដំណើរការនេះទេដោយសារការវិភាគរបស់យើងគឺផ្អែកទាំងស្រុងទៅលើសេចក្ដីសេចក្ដីសន្និដ្ឋានរបស់យើងដែលថា ការប្រព្រឹត្តរបស់អាជ្ញាធរថ្នាក់ជាតិដែលមានជាប់ព័ន្ធនឹង អ.វ.ត.ក។ ចំពោះសកម្មភាពរួមគ្នា ចំពោះសំអាងហេតុដែលយើងមានក្នុងទស្សនៈរបស់យើងគឺថា ការពុំមានសកម្មភាពរួមគ្នាជាក់លាក់ មិនមែនជាការចប់សព្វគ្រប់ក្រោមកាលៈទេសៈនេះទេ។

[1459] មតិចៅក្រមភាគច្រើនស្ដីពីការប្រកាសទោស, កថាខណ្ឌ ៣៩៧ ដោយដកស្រង់ចេញពីសេចក្ដីសម្រេចក្នុង*រឿងក្ដី Semanza*, កថាខណ្ឌ ៤, ៥, ៧៩។ សាលដីកាក្នុង*រឿងក្ដី Kajelijeli*, កថាខណ្ឌ ២២៧, ៣២៣ និង ៣២៤។ សេចក្ដីលើការចាប់ខ្លួន និងការឃុំខ្លួនដោយខុសច្បាប់ក្នុង*រឿងក្ដី Rwamakuba*, កថាខណ្ឌ ២៧ និង៣០។ ចៅក្រមភាគច្រើនក៏បានបែងចែកដាច់ពីគ្នាផងដែរនៃសេចក្ដីសម្រេចក្នុង*រឿងក្ដី Barayagwiza* ដោយផ្អែកលើការសន្និដ្ឋានរបស់ខ្លួនដែលថា ការដកហូតសិទ្ធិរបស់ជនជាប់ចោទ បណ្ដាលឱ្យមានការរំលោភបំពានដំណើរការ ជាចំណុចដែលយើងមិនអាចឆ្លើយតបក្នុងទស្សនៈនេះបាន។ *សូមមើល* មតិចៅក្រមភាគច្រើនស្ដីពីការប្រកាសទោស, កថាខណ្ឌ ៣៩៦។

ខុសពីមតិរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានសម្រេចជាស្ពាពរថា តុលាការអន្តរជាតិត្រូវតែពិចារណាពីនិត្យានុកូលភាពនៃការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នពីពេលមុន បើទោះបីជាការឃុំខ្លួនបណ្តោះអាសន្ននោះ មិនមែនដោយសារតែតុលាការនោះក៏ដោយ[1460]។

៤. យើងយល់ស្របជាមួយការលើកឡើងរបស់ចៅក្រមភាគច្រើនតែត្រង់ចំណុចដែលថា ក្នុងយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ តម្រូវឱ្យមានទំនាក់ទំនងមួយចំនួនរវាងតុលាការដែលជំនុំជម្រះក្តី ជាមួយនិងភាពខុសច្បាប់ក្នុងការឃុំខ្លួន មុនពេលដែលការទូទាត់សងអាចត្រូវបានផ្តល់ឱ្យ។ ប៉ុន្តែយើងមិនយល់ស្របជាមួយចៅក្រមភាគច្រើន ដែលអនុវត្តជាស្វ័យប្រវត្តិនូវវិធីសាស្ត្ររបស់តុលាការ ICTY និង តុលាការ ICTR ទៅលើអង្គហេតុនៃរឿងក្តីនេះ។ យើងយល់ឃើញថា ការអនុម័តិយកវិធីសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ គឺជាការមិនសមស្របនោះទេ ដោយផ្អែកទៅលើភាគខុសគ្នាយ៉ាងច្បាស់ ពាក់ព័ន្ធទៅនឹងគោលជំហររបស់ អ.វ.ត.ក ធៀបជាមួយនឹងគោលជំហររបស់តុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍ និងប្រព័ន្ធតុលាការជាតិ ដែលបង្កឱ្យមានការរំលោភបំពានទាំងនេះ។

៥. តុលាការ ICTY និង តុលាការ ICTR ជាតុលាការអន្តរជាតិ ដែលបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដោយអនុលោមតាមជំពូកប្រាំពីរនៃធម្មនុញ្ញអង្គការសហប្រជា ជាតិ[1461]។ ឯកសារផ្លូវការបង្កើតតុលាការនេះ ព្រមទាំងសេចក្តីសម្រេចដែលពាក់ព័ន្ធរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងលក្ខន្តិកនានារបស់តុលាការនេះ ត្រូវ

---

[1460]សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ១៦។

[1461]*ការបង្កើតតុលាការអន្តរជាតិ និងការអនុម័តលក្ខន្តិកៈរបស់តុលាការនោះ,* សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ 955, របាយការណ៍ផ្លូវការរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ, កិច្ចប្រជុំលើកទី ៣៤៥៤, ឯកសារ អ.ស.ប លេខ S/RES/955 (ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤) ("S.C. Res 955"); *តុលាការ (អតីតប្រទេសយូហ្គោស្លាវី),* សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ 808, UN SCOR, កិច្ចប្រជុំលើកទី ៣១៧៥, ឯកសារ អ.ស.ប លេខ S/RES/808 (ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៣) ("S.C. Res 808"); *តុលាការ (អតីតប្រទេសយូហ្គោស្លាវី),* សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ 827, របាយការណ៍ផ្លូវការរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ, សម័យប្រជុំលើកទី ៣២១៧, ឯកសារ អ.ស.ប លេខ S/RES/827 (ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣) ("S.C. Res 827")។

00798876



បានប្រកាសក្នុងលក្ខណៈប្រហាក់ប្រហែលគ្នា ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលធ្វើឡើងតាមអំណាចដែលមានចែងក្នុងជំពូកប្រាំពីរ[1462]។ ការបង្កើតតុលាការទាំងនេះមិនពឹងផ្អែកទៅលើកិច្ចព្រមព្រៀងណាមួយជាមួយរដ្ឋាភិបាលប្រទេសរវ៉ាន់ដា ឬប្រទេសយូហ្គោស្លាវីនោះឡើយ ហើយក៏មិនមានបញ្ញត្តិច្បាប់ណាមួយត្រូវបានបង្កើតឡើងក្នុងប្រព័ន្ធនីតិបញ្ញត្តិរបស់ប្រទេសរវ៉ាន់ដា ឬប្រទេសយូហ្គោស្លាវីនោះដែរ។ វិធានថ្នាក់ជាតិ របស់ច្បាប់ និងនីតិវិធីព្រហ្មទណ្ឌ មិនអាចអនុវត្តនៅតុលាការទាំងនេះបានឡើយ[1463]។

៦. លក្ខណៈរបស់ អ.វ.ត.ក ដែលជាតុលាការមានចរិតលក្ខណៈជាតុលាការអន្តរជាតិនោះ គឺខុសប្លែកពីនេះ។ យើងពិតជាទទួលស្គាល់ថា អ.វ.ត.ក មានចរិតលក្ខណៈអន្តរជាតិមួយចំនួនដែរ ដោយរួមមានអង្គហេតុដែលថា (១) កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយអង្គការសហប្រជាជាតិ គឺជាឯកសារផ្លូវការបង្កើតតុលាការមួយ ក្នុងចំណោមឯកសារផ្លូវការនានា (២) អ.វ.ត.ក មានចៅក្រមអន្តរជាតិ និង (៣) អ.វ.ត.ក អនុវត្តច្បាប់អន្តរជាតិសម្រាប់គោលដៅមួយចំនួន[1464]។ ទោះបីជាយ៉ាងណាក៏ដោយ អ.វ.ត.ក នៅតែជាតុលាការជាតិ ក្នុងផ្នែកគន្លឹះមួយចំនួន (ដែលយើងនឹងពិភាក្សានៅផ្នែកខាងក្រោម)[1465]។

---

[1462] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ 955, កថាខណ្ឌ ១; របាយការណ៍របស់អគ្គលេខាធិការអនុលោមតាមកថាខណ្ឌ ២ នៃ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ 808 (ឆ្នាំ ១៩៩៣), ឯកសារ អ.ស.ប លេខ S/25704, (ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៩៣)។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ 827, កថាខណ្ឌ ២។

[1463] សម្រាប់ករណីលើកលែង *សូមមើល* លក្ខន្តិកៈតុលាការ ICTR Statute, មាត្រា ២៣ (ដែលកត់សម្គាល់ឃើញថា តុលាការត្រូវ "មានជម្រើសក្នុងការជ្រើសរើសទម្លាប់អនុវត្តន៍ជាសាធារណៈពាក់ព័ន្ធនឹងការផ្តន្ទាទោសដាក់ពន្ធនាគារ" ក្នុងការផ្តន្ទាទោស); ICTR RPE, វិធាន ១០១(ខ)(iii) (ដូចគ្នា); លក្ខន្តិកៈតុលាការ ICTY, មាត្រា ២៤ (ដូចគ្នា); ICTY RPE, វិធាន ១០១(ខ) (iii) (ដូចគ្នា)។

[1464] *សូមមើល ឧទាហរណ៍*, កិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាល, មាត្រា១២(១); ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៤, ៥, ៣៣ថ្មី។

[1465] ពាក់ព័ន្ធនឹងលក្ខណៈសម្បត្តិដទៃទៀតដែលយកមកអនុវត្តដោយចៅក្រមភាគច្រើន យើងគូសបញ្ជាក់ថា ការដែលថា អ.វ.ត.ក ត្រូវបាន "បង្កើតឡើងដោយឡែក" គឺគ្រាន់តែបង្ហាញពីភាពដោយឡែកនៃការរចនាសម្ព័ន្ធការងារប៉ុណ្ណោះ ចំណែកឯ "ឯករាជភាព" ជា លក្ខខណ្ឌតម្រូវរបស់តុលាការដែលស្ថិតក្រោមបទដ្ឋានអន្តរជាតិ និងជាលក្ខខណ្ឌតម្រូវក្នុងរដ្ឋធម្មនុញ្ញ

៧. ដោយសារតែរចនាសម្ព័ន្ធដែលមានលក្ខណៈចម្រុះគ្នា (hybrid) ជាពិសេស របស់ អ.វ.ត.ក បែបនេះហើយ ទើបការកត់សម្គាល់របស់ចៅក្រមភាគច្រើន ដែលថា តុលាការ ICTY និង តុលាការ ICTR បានផ្តល់ការទូទាត់សងតែចំពោះការរំលោភបំពានណាដែលកើតឡើងក្រោយពេលរដ្ឋអាជ្ញាអន្តរជាតិ បានស្នើសុំឱ្យមានការឃុំខ្លួនបណ្តោះអាសន្ន ផ្អែកតាមវិធាន ៤០ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង របស់ តុលាការ ICTY និង តុលាការ ICTR នោះមានលក្ខណៈមិនគួរឱ្យជឿជាក់បាន។ តុលាការ ICTY និង តុលាការ ICTR បានបដិសេធមិនទទួលខុសត្រូវចំពោះការរំលោភបំពានណា ដោយសារតែអាជ្ញាធររបស់រដ្ឋដែលមានអធិបតេយ្យ និងមានយុត្តាធិការដោយឡែក ដែលតុលាការអន្តរជាតិមិនអាចគ្រប់គ្រងបាន[1466]។ វិធីសាស្ត្រនេះគឺស្របជាមួយនឹងគោលការណ៍ជាទូទៅនៃច្បាប់អន្តរជាតិ ដែលតាម គោលការណ៍នេះ ការអនុវត្តតាមផ្លូវច្បាប់ស្តីសិទ្ធិមនុស្ស និងការការពារជាក់លាក់ចំពោះបុគ្គលមិនឱ្យទទួលការរំលោភបំពានទៅលើសិទ្ធិទាំងនោះ គឺជាបញ្ហាក្នុងប្រទេស[1467]។ ទោះបីជាការទទួលខុសត្រូវ

---

របស់តុលាការជាតិទាំងអស់តែប៉ុណ្ណោះ។ *សូមមើល* រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១០៩។ ហេតុនេះលក្ខខណ្ឌទាំងនេះមិនបានផ្តល់នូវស្វ័យភាពដាច់ចេញពីប្រព័ន្ធតុលាការថ្នាក់ជាតិនៅកម្ពុជាឡើយ។

[1466] សេចក្តីសម្រេចលើការជួសជុលដល់ការរំលោភសិទ្ធិពាក់ព័ន្ធនឹងការចាប់ខ្លួនក្នុង*រឿងក្តី Karadžić*, កថាខណ្ឌ ២៦ (នៅពេលអាជ្ញាធរស៊ែបចាប់ខ្លួនគាត់ជាលើកដំបូង ជនជាប់ចោទត្រូវបានឃុំខ្លួន*ដោយពុំឱ្យមានទំនាក់ទំនងជាមួយអ្នកខាងក្រៅ (incommunicado)* រយៈពេល ៤ ថ្ងៃ មុនពេលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខចៅក្រមមួយរូបនៃតុលាការជាតិ); សេចក្តីសម្រេចក្នុង*រឿងក្តី Semanza*, កថាខណ្ឌ ៤ ដល់ ១២, ៧៩ (តុលាការនេះខកខានមិនបានទាក់ទងតុលាការ ICTR ក្នុងពេលឃុំខ្លួនរយៈពេល ១៩ ថ្ងៃ មុននឹងរដ្ឋអាជ្ញានៃតុលាការ ICTR ស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្ន រួមទាំងរយៈពេលឃុំខ្លួនបន្តបន្ទាប់ពីមានសេចក្តីសម្រេចរបស់រដ្ឋអាជ្ញាក្នុងការច្រានចោលការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ); សេចក្តីសម្រេចលើការចាប់ខ្លួន និងការឃុំខ្លួនដោយខុសច្បាប់លើរឿងក្តី *Rwamakuba*, កថាខណ្ឌ ៣០ និង៣៤ (តុលាការ ICTR សម្រេចថា រដ្ឋអាជ្ញាមិនទាំងបាន*ដឹង*ពីការឃុំខ្លួនជនជាប់ចោទក្នុងរយៈពេល ៥ ខែដំបូងក្នុងរយៈពេលឃុំខ្លួន ៦ ខែនោះទេ ហើយថា ខ្លួនបានជូនដំណឹងទៅអាជ្ញាធរជាតិក្នុងរយៈពេល ២៧ ថ្ងៃ បន្ទាប់ពីបានដឹងពីការឃុំខ្លួននេះថា ពុំមានភស្តុតាងគ្រប់គ្រាន់សម្រាប់បន្តការឃុំខ្លួននោះឡើយ)។ សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើរឿងក្តី *Kajelijeli*, កថាខណ្ឌ ២២៧, ៣២៣, ៣២៤ (តុលាការសម្រេចថា ការចាប់ខ្លួនដោយអាជ្ញាធរជាតិបានធ្វើឡើងបន្ទាប់ពីមានសំណើសុំពីរដ្ឋអាជ្ញា និងមានការផ្តល់នូវការជួសជុលពេញលេញជាលក្ខណៈនៃការកាត់បន្ថយការផ្តន្ទាទោសវិញ)។

[1467] Manfred Nowak, *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ អ.ស.ប៖ សេចក្តីអធិប្បាយចំពោះកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*, 2nd rev. ed., N.P. Engel, ឆ្នាំ ២០០៥, ទំព័រ ៥៧ ("[មាត្រា

00798878



របស់តុលាការអន្តរជាតិ ទៅលើការប្រព្រឹត្តិក្នុងប្រទេស អាចត្រូវបានកម្រិតតែត្រឹម "សកម្មភាពរួមគ្នា" ជាក់ច្បាស់ក៏ដោយ[1468] ក៏តម្រូវឱ្យមានការវិភាគផ្សេងគ្នាមួយទៀតសម្រាប់ "តុលាការដែលមានចរិតលក្ខណៈអន្តរជាតិ" ដែលត្រូវបានបង្កើតឡើងដោយរដ្ឋដែលបានស្នើសុំ។ យើងស្នើថា នេះជាគោលការណ៍ដ៏ទូលាយមួយក្នុងការទទួលខុសត្រូវរួមគ្នា ដែលគ្រប់គ្រងទៅលើបញ្ហាថាតើតុលាការចម្រុះមួយ គួរតែត្រូវទទួលខុសត្រូវចំពោះអំពើនានារបស់ប្រព័ន្ធតុលាការជាតិ ដែរឬយ៉ាងណា។ កម្រិតនៃ "ការទទួលខុសត្រូវរួមគ្នា" របស់តុលាការចាំបាច់ត្រូវតែសម្រេចដោយផ្អែកលើភាពយុត្តិធម៌ ដោយត្រូវពិចារណាដល់កាលៈទេសៈទាំងមូលផងដែរ។

៨. ជាពិសេស យើងជឿជាក់ថា ការពិចារណាដូចតទៅនេះ គឺពិតជាមានការពាក់ព័ន្ធ៖ (១) កម្រិតនៃការ បញ្ចូលតុលាការដែលធ្វើការជំនុំជម្រះ ទៅក្នុងប្រព័ន្ធថ្នាក់ជាតិ (២) ទំនាក់ទំនងរវាងការរំលោភបំពាន ជាមួយនឹងដំណើរការនីតិវិធី នៅចំពោះមុខតុលាការដែលធ្វើការជំនុំជម្រះ (៣) ស្ថានទម្ងន់នៃការរំលោភបំពាន ដែលត្រូវឈានទៅដល់កម្រិតរំលោភបំពានទៅលើសិទ្ធិជាសារវន្ត (៤) ថាតើការទូទាត់សងដ៏សមរម្យមួយ ស្ថិតនៅក្នុងយុត្តាធិការនៃតុលាការដែលធ្វើការជំនុំជម្រះដែរ ឬយ៉ាងណា និង (៥) ថាតើការផ្តល់ការទូទាត់សង នឹងបង្កឱ្យមានការប៉ះពាល់ដល់អាណត្តិរបស់តុលាការដែលធ្វើការជំនុំជម្រះដែរឬយ៉ាងណា (ជាឧទាហរណ៍ ដោយតម្រូវឱ្យមានការដោះលែងជនជាប់ចោទជាបន្ទាន់)។ ដោយផ្អែកទៅលើការវិភាគរបស់យើងទៅលើកត្តាទាំងអស់នៅក្នុងរឿងក្តីនេះ យើងសន្និដ្ឋានថា អ.វ.ត.ក មានកាតព្វកិច្ចក្នុងការពិចារណាពីការទទួលខុសត្រូវរបស់ខ្លួនចំពោះការឃុំខ្លួន កាំង ហ្កេកអ៊ាវ ដោយតុលាការយោធា មុនពេលដែលគាត់ត្រូវបានផ្ទេរមកឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ អ.វ.ត.ក។

---

២ កថាខណ្ឌ ៣] តំណាងឱ្យគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិដែលមិនត្រឹមតែជាការអនុវត្តទៅតាមក្របខណ្ឌច្បាប់ និងបង្កើតជាបទដ្ឋានអន្តរជាតិនៃសិទ្ធិប៉ុណ្ណោះទេ ការការពារជាក់លាក់ចំពោះបុគ្គលប្រឆាំងនឹងការរំលោភសិទ្ធិទាំងនេះក៏ជាបញ្ហាចម្បងរបស់តុលាការថ្នាក់ជាតិដែរ")។

[1468]មតិទៅក្រុមភាគច្រើនស្តីពីការប្រកាស, កថាខណ្ឌ ៣៩២ និង ៣៩៧។

00798879



៩. ជាបឋម និងសំខាន់បំផុតនៅក្នុងរឿងក្ដីនេះ អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយប្រព័ន្ធច្បាប់ជាតិ ហើយស្ថិតក្រោមប្រព័ន្ធច្បាប់ជាតិ។ ចំណុចត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈ (១) បុព្វកថានៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក បញ្ជាក់យ៉ាងច្បាស់ថា អ.វ.ត.ក ត្រូវបានបង្កើតឡើង "នៅក្នុងរចនាសម្ពន្ធ័តុលាការកម្ពុជាដែលមានស្រាប់"[1469] (២) អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ជាច្បាប់ជាតិមួយ ដែលបានបង្កើតឡើងដោយស្ថាប័ននីតិបញ្ញត្តិកម្ពុជា ដូចដែលបានពិចារណាក្នុងកិច្ចព្រមព្រៀងរវាង អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[1470] (៣) ពាក្យពេចន៍ "ក្នុងតុលាការកម្ពុជា" មាននៅក្នុងចំណងជើងនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ហើយច្បាប់នេះបានលើកឡើងយ៉ាងច្បាស់ថា អ.វ.ត.ក "ត្រូវបានបង្កើតនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់"[1471] (៤) ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ក្នុងសំណៅចាស់ បានចម្លងតាមឋានានុក្រមនៃប្រព័ន្ធយុត្តិធម៌កម្ពុជា[1472] (៥) ចៅក្រមអន្តរជាតិ ត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នរបស់កម្ពុជា[1473] ហើយ (៦) អ.វ.ត.ក បានអនុវត្តច្បាប់សារធាតុជាតិ រហូតដល់កម្រិតមួយ គឺចែងនៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងនៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[1474]។ លើសពីនេះទៅទៀត លក្ខណៈជាតុលាការជាតិនេះ គឺជាចំណុចចរចាយ៉ាងស្រួចស្រាវរបស់ក្រុមអ្នកតាក់តែង នៅពេលដែលច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានបង្កើតឡើង។ ជាការពិត រាជរដ្ឋាភិបាលកម្ពុជា ប្រកាន់ជំហររបស់ខ្លួន

---

[1469]កិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាល, បុព្វកថា។

[1470]កិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាល, មាត្រា ២(២)។

[1471]ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ២ថ្មី។

[1472]ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ឆ្នាំ ២០១១, មាត្រា ២, ៩ (ដែលបង្កើតប្រព័ន្ធតុលាការដែលមានបីថ្នាក់គឺៈ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល)។

[1473]ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ១១ថ្មី។

[1474]កិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាល, មាត្រា ៩; ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ៣ ថ្មី។

យ៉ាងម៉ឺងម៉ាត់ទាមទារឲ្យខានតែបាននូវតុលាការជាតិមួយដោយមានជំនួយពីអន្តរជាតិ ដែលស្ទើរតែធ្វើឲ្យមានការបែកបាក់ [1475]។

១០. លើសពីនេះទៅទៀត អ្នកតាក់តែងរបបគតិយុត្តិសម្រាប់ អ.វ.ត.ក មានចេតនាប្រើប្រាស់នីតិវិធីរបស់កម្ពុជា ធ្វើជាប្រភពចម្បងសម្រាប់ច្បាប់នីតិវិធីនៅ អ.វ.ត.ក។ ចំណុចនេះបង្ហាញយ៉ាងច្បាស់ក្នុងអត្ថបទច្បាប់៖ (១) ក្រុមអ្នកតាក់តែងច្បាប់បានដាក់បញ្ចូលពាក្យពេចន៍ "នៅក្រោមច្បាប់កម្ពុជា" ទៅក្នុងចំណងជើងនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក (២) ពាក្យពេចន៍ "ច្បាប់កម្ពុជា" គឺជាប្រភពនៃច្បាប់ដែលបានរៀបរាប់ដំបូងគេនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក[1476] និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[1477] ទាំងមូល (៣) "ច្បាប់កម្ពុជា" ត្រូវបានទទួលស្គាល់យ៉ាងជាក់ច្បាស់ថាជាប្រភពចម្បងនៃដំណើរការនីតិវិធី ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក[1478] ហើយ ពាក្យ "នីតិវិធីដែលនៅជាធរមាន" ត្រូវបានទទួលស្គាល់យ៉ាងច្បាស់ដោយ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[1479] ហើយ (៤) តុលាការមានសិទ្ធិអំណាចក្នុងការស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ តែក្នុងករណីដែលច្បាប់កម្ពុជាពុំមានចែង មានភាពមិនច្បាស់លាស់ ឬមិនស្របទៅនឹងបទដ្ឋានអន្តរជាតិតែប៉ុណ្ណោះ[1480]។

១១. លក្ខណៈជាតុលាការជាតិរបស់ អ.វ.ត.ក នេះ ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងការអនុវត្តទោស។ សម្រាប់តុលាការដែលមានលក្ខណៈអន្តរជាតិទាំងអស់ ដែលមានគោលដៅធ្វើការជំនុំ

---

[1475] David Scheffer, "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា", និពន្ធនាយក M. Cherif Bassiouni (ed.), *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, បោះពុម្ពផ្សាយលើកទី បី, ចេញផ្សាយដោយ Koninklijke Brill NV, ឆ្នាំ ២០០៨, ទំព័រ ២២៤ ដល់ ២៣៩។

[1476] កិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាល, មាត្រា ១, ៥(៣), ៦(៣)។

[1477] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ១។

[1478] កិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាល, មាត្រា ១២(១)។

[1479] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ២៣ថ្មី, ២៥, ៣៣ថ្មី, ៣៤ថ្មី។

[1480] កិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាល, មាត្រា ១២(១)។

ជម្រះក្តីនោះ ពិរុទ្ធជនត្រូវឃុំឃាំង និងគ្រប់គ្រងដោយអាជ្ញាធរពន្ធនាគារទូទៅ[1481]។ តាមទស្សនៈរបស់យើង លក្ខណៈអន្តរជាតិរបស់តុលាការបែបនេះ មិនសូវជាពាក់ព័ន្ធទៅលើបញ្ហាមួយចំនួន ដូចជា ការឃុំឃាំងនោះទេ ដែលបញ្ហានេះត្រូវអនុវត្តតាមច្បាប់ និងនីតិវិធីជាតិ ដោយមិនដូចទៅនឹងបញ្ហា ដូចជា ការកំណត់ច្បាប់ដែលត្រូវអនុវត្តសម្រាប់ដំណើរការនីតិវិធី នៅចំពោះមុខតុលាការទេ។

១២. ចំណុចទីពីរ គឺប្រវត្តិនៃការឃុំខ្លួន កាំង ហ្កេកអ៊ាវ ដោយតុលាការយោធា បានបង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងរយៈពេលនៃការឃុំខ្លួន ជាមួយនឹងសំណុំរឿងប្រឆាំង កាំង ហ្កេកអ៊ាវ នៅ អ.វ.ត.ក។ កាំង ហ្កេកអ៊ាវត្រូវបានឃុំឃាំងជាលើកដំបូងនៅក្នុងឆ្នាំ ១៩៩៩ គឺប្រហែលជាពីរឆ្នាំបន្ទាប់ពីសំណើសុំជាលើកដំបូងរបស់រាជរដ្ឋាភិបាលកម្ពុជា ឲ្យមានជំនួយក្នុងការជំនុំជម្រះលើអតីតសមាជិកខ្មែរក្រហមមួយចំនួន ត្រូវបានបញ្ជូនទៅកាន់អង្គការសហប្រជាជាតិ[1482]។ កាំង ហ្កេកអ៊ាវ ត្រូវបានឃុំខ្លួនក្នុងពេលចរចាដ៏យូរ ដែលលទ្ធផលនៃការចរចានេះនាំដល់ការបង្កើតកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងឆ្នាំ ២០០៣ ព្រមទាំងការអនុម័តទៅលើច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ជាស្ថាពរ នៅ

[1481] *សូមមើល* កិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាល, ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, និងវិធានផ្ទៃក្នុងដែលពុំមានចែងពីការដាក់ក្នុងពន្ធនាគារបន្ទាប់ពីបានផ្តន្ទាទោសហើយនោះទេ ដោយមានករណីលើកលែងនៅក្នុងវិធាន ១១៣ នៃវិធានផ្ទៃក្នុងដែលចែងថា, ការអនុវត្តទោសត្រូវធ្វើតាម"ការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញា" ដែលសហព្រះរាជអាជ្ញា "អាចសុំជំនួយពីអាជ្ញាធរអនុវត្តច្បាប់"។ ផ្ទុយទៅវិញ វិធាននិងលក្ខន្តិកៈរបស់តុលាការ ICTR និង ICTY មានចែងយ៉ាងច្បាស់៖ *សូមមើល* លក្ខន្តិកៈតុលាការ ICTR, មាត្រា ២៦ (ការផ្តន្ទាទោសដាក់ពន្ធនាគារត្រូវបានជ្រើសរើសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតម្រូវឱ្យធ្វើការត្រួតពិនិត្យតាមផ្លូវតុលាការ) និង ២៧ (ការលើកលែងទោសដែលជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ)។ វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICTR, ពីវិធាន ១០២ ដល់ ១០៤ (ការផ្តន្ទាទោសដាក់ពន្ធនាគារត្រូវបានជ្រើសរើសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតម្រូវឱ្យធ្វើការត្រួតពិនិត្យតាមផ្លូវតុលាការ)។ លក្ខន្តិកៈតុលាការ ICTY, មាត្រា ២៧ និង ២៨ (ប្រហាក់ប្រហែលគ្នា) ។ វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICTY, ពីវិធាន ១០២ ដល់ ១០៤(ប្រហាក់ប្រហែលគ្នា)។

[1482] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, អយ្យការយោធា (តុលាការយោធាលេខ 012/99), ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩, ឯកសារ E52/4.3; ដីកាសម្រេចឃុំខ្លួន, ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា (តុលាការយោធាលេខ142/99), ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩, ឯកសារលេខ E52/4.8។

ក្នុងឆ្នាំ ២០០៤។ នៅក្នុងពេលចរចាគ្នានោះ មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា បានធ្វើសេចក្តីប្រកាសជាច្រើនដង បង្ហាញពីការរំពឹងទុកដែលថា កាំង ហ្កេកអ៊ាវ ប្រហែលជាជនមួយរូបដែលត្រូវទទួលការជំនុំជម្រះដោយតុលាការមួយ ដែលមិនទាន់លេចចេញជារូបរាងនៅឡើយនោះ[1483]។ ក្រោយពី អ.វ.ត.ក ចាប់ផ្តើមដំណើរការបានបន្តិច សហព្រះរាជអាជ្ញាបានបើកកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការប្រឆាំងនឹងរូបគាត់[1484] ហើយពីរសប្តាហ៍ក្រោយមក កាំង ហ្កេកអ៊ាវត្រូវបានបញ្ជូនមកឃុំឃាំងនៅ អ.វ.ត.ក វិញ[1485]។ ជាលទ្ធផល តុលាការយោធាបានសម្រេចបញ្ចប់យុត្តាធិការរបស់ខ្លួនទៅលើជនជាប់ចោទ ដោយទុកឲ្យសំណុំរឿងនេះស្ថិតក្នុងចំណាត់ការរបស់ អ.វ.ត.ក វិញ[1486] ហើយអង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា មិនមានកិច្ចស៊ើបអង្កេតជាប្រព័ន្ធ និងជាសំខាន់ ត្រូវបានធ្វើឡើងក្នុងអំឡុងពេលនោះឡើយ[1487]។ ក្នុងកាលៈទេសៈទាំងនេះ ប្រាកដណាស់ថា សំណុំរឿងប្រឆាំង កាំង ហ្កេកអ៊ាវ នៅ អ.វ.ត.ក គឺពិតជាការបន្តបទចោទដែលធ្វើឡើងជាដំបូងដោយតុលាការយោធានៅក្នុងឆ្នាំ ១៩៩៩ មែន។

១៣. អង្គហេតុទាំងនេះបានបង្ហាញនូវភាពខុសគ្នាយ៉ាងច្បាស់ ធៀបជាមួយអង្គហេតុនានាដែលស្ថិតនៅក្នុងយុត្តាធិការតុលាការមិនអចិន្ត្រៃយ៍នានា ដែលចៅក្រមភាគច្រើនបានពឹងផ្អែកទៅលើ។ សំណុំរឿងទាំងនោះពាក់ព័ន្ធជាមួយនឹងការឃុំខ្លួនរយៈខ្លីដោយអាជ្ញាធរ ដែលមានយុត្តាធិការខុសគ្នា ហើយករណីដែលតុលាការមិនអចិន្ត្រៃយ៍ទាំងនោះបានបដិសេធទៅលើសំណើទូទាត់សង មិនមានការបង្ហាញពីទំនាក់ទំនងហេតុ និងផល រវាងដំណើរការនីតិវិធីនៅចំពោះមុខ

[1483] *សូមមើល* David Scheffer, "ប្រវត្តិនៃកិច្ចចចារអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក" ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ៤ គេហទំព័រ <http://www.cambodiatribunal.org/>; Steve Heder, "ការពិនិត្យមើលឡើងវិញទៅលើការចរចា ដែលនាំទៅដល់ការបង្កើតឡើងនូវយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០១១, កថាខណ្ឌ ៣១,៣៧,៣៩,៤១ គេហទំព័រ http://www.cambodiatribunal.org/blog។

[1484] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា, ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៧, ឯកសារលេខ D3។

[1485] ដីកាបង្គាប់ឲ្យនាំខ្លួន, ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧, ឯកសារ C1។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការប្រគល់ខ្លួនជនល្មើស, ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧, ឯកសារលេខ E52/4.65។

[1486] ដីកា, ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា, ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៨, ឯកសារលេខ E52/4.66។

[1487] សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌ ២០ ។

តុលាការអន្តរជាតិ ជាមួយនឹងការឃុំខ្លួនជាបន្តដោយអាជ្ញាធរជាតិនោះទេ[1488]។ ផ្ទុយទៅវិញ រដ្ឋកម្ពុជាបានឃុំឃាំង កាំង ហ្កេកអ៊ាវ អស់រយៈពេល ៨ (ប្រាំបី) ឆ្នាំ ដោយមិនមានកិច្ច ដំណើរការនីតិវិធីលើអង្គសេចក្តីណាមួយ ហើយក្នុងពេលជាមួយគ្នានោះ ខ្លួនបានធ្វើការចរចា ដើម្បីបង្កើត អ.វ.ត.ក ហើយបន្ទាប់មកបានបញ្ជូន កាំង ហ្កេកអ៊ាវ ទៅតុលាការមួយដែលបាន បង្កើតដោយខ្លួនឯង ដើម្បីធ្វើការស៊ើបអង្កេតទៅលើបទចោទដែល "ប្រហាក់ប្រហែលគ្នាយ៉ាង ខ្លាំង"[1489]។ តាមទស្សនៈរបស់យើង ករណីនេះពិតជាមានទំនាក់ទំនងរវាងការឃុំខ្លួននៅតុលា ការយោធា ជាមួយនឹងសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក។

១៤. ចំណុចទីបី រាល់ការដកហូតសេរីភាពដោយមិនមានមូលដ្ឋានគ្រប់គ្រាន់ គឺជាការរំលោភទៅ លើសិទ្ធិជាសារវន្ត ចំណែកការរំលោភទៅលើសេរីភាពរបស់ កាំង ហ្កេកអ៊ាវ គឺមានលក្ខណៈ ធ្ងន់ធ្ងរយ៉ាងខ្លាំង។ គណៈកម្មាការសិទ្ធិមនុស្ស និងតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស បាន កំណត់រយៈពេលឃុំខ្លួនដ៏ខ្លីជាង នេះឆ្ងាយណាស់ ថាជាការខុសច្បាប់ បើផ្អែកតាមបទដ្ឋានសិទ្ធិ មនុស្សអន្តរជាតិដែលនៅជាធរមាន[1490]។ ដោយផ្អែកតាមដែនកំណត់ដែលមានចែងក្នុងច្បាប់ បើទោះបីជាភាពស្មុគស្មាញនៃរឿងក្តីអាចធ្វើជាយុត្តិកម្មសម្រាប់ការឃុំខ្លួន ដែលមានរយៈ ពេលវែងក៏ដោយ ក៏នៅក្នុងរឿងក្តីមួយនេះ អាជ្ញាធរបានឃុំខ្លួនលើសពីរយៈពេលកំណត់អតិ

[1488]*សូមមើល* សំណុំរឿងនានាដែលបានលើកនៅត្រង់ជើងទំព័រ ១៤៦៦, *ខាងលើ* ។

[1489]មតិទៅក្រុមភាគច្រើនស្តីពីការប្រកាសទោស, កថាខណ្ឌ ៤០៣ និង ជើងទំព័រ ៨៥១ ។

[1490]*សូមមើលរឿងក្តី Sextus ទល់នឹង Trinidad and Tobago*, គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, ទស្សនៈ, ឯកសារ អ.ស.ប លេខ CCPR/C/72/D/818/1998 (ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០១) ("សំណុំរឿង Sextus *ទល់នឹង* Trinidad និង Tobago"), កថាខណ្ឌ ៧.២ (ការឃុំខ្លួនចំនួន ២២ ខែ មុនពេលជំនុំជម្រះ ផ្ទុយទៅនឹងមាត្រា៩(៣) និង ១៤(៣)(គ))។ *រឿងក្តី Siewpersaud និងជនដទៃទៀត ទល់នឹង Trinidad និង Tobago*, គណៈកម្មាធិការសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ, ទស្សនៈ, ឯកសារ អ.ស.ប លេខ CCPR/C/81/D/938/2000 (ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤) ("សំណុំរឿង Siewpersaud *និងជនដទៃទៀត ទល់នឹង* Trinidad និង Tobago"), កថាខណ្ឌ ៦.១, (ការឃុំខ្លួនចំនួន ៣៤ ខែមុនពេលជំនុំជម្រះ ផ្ទុយទៅនឹងមាត្រា ៩(៣)); សំណុំរឿង *Dzelili ទល់នឹង Germany*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សាលក្រមរបស់អង្គជំនុំជម្រះ, បណ្តឹងលេខ 65745/01, ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ("សាលក្រម *Dzelili*"), កថាខណ្ឌ ៦៨, ៨១ (ការឃុំខ្លួននៅដំណាក់កាលមុនជំនុំជម្រះចំនួន ៤ ឆ្នាំ, ៨ ឆ្នាំ ដែលពុំស្របទៅនឹងមាត្រា ៥(៣) នៃតុលា ការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។

បរមាដូចមានចែងក្នុងច្បាប់ ហើយមិនបានដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស ក្នុងរយៈពេល ៨ (ប្រាំបី) ឆ្នាំ[1491]។

១៥. ជាចុងក្រោយ ដូចដែលបានបង្ហាញនៅផ្នែកខាងក្រោម អ.វ.ត.ក មានតួនាទីជាពិសេសក្នុងការផ្តល់នូវការទូទាត់សងប្រកបដោយប្រសិទ្ធភាព ដោយមិនធ្វើឲ្យប៉ះពាល់ដល់អាណត្តិរបស់តុលាការនោះឡើយ។

១៦. សាលដីកានេះ បានពិនិត្យជាលម្អិតទៅលើច្បាប់អន្តរជាតិស្តីពីសិទ្ធិទទួលបានការទូទាត់សងនៅក្នុងបរិបទនៃការវិភាគអំពីការទូទាត់សងចំពោះដើមបណ្តឹងរដ្ឋប្បវេណី[1492]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានដូច្នោះដែរ សិទ្ធិរបស់បុគ្គលក្នុងការទទួលបានការទូទាត់សងចំពោះការរំលោភបំពានទៅលើបទដ្ឋានសិទ្ធិមនុស្សជាសារវន្តនោះ គឺមានកំណត់យ៉ាងច្បាស់លាស់នៅក្នុងលិខិតុបករណ៍អន្តរជាតិជាច្រើន ដែលភាគច្រើននៃលិខិតុបករណ៍ទាំងនេះ បានចងកាតព្វកិច្ចកម្ពុជា ផ្អែកតាមច្បាប់អន្តរជាតិ ហើយត្រូវបានទទួលស្គាល់ដោយកម្ពុជា ដោយផ្អែកតាមមាត្រា ៣១(១)នៃរដ្ឋធម្មនុញ្ញ[1493]។ ក្នុងចំណោមមាត្រាទាំងនេះ មាត្រា ២(៣)(ក) នៃកតិកាសញ្ញា ICCPR បានចែងពីសិទ្ធិទទួលបាន "ការទូទាត់សងប្រកបដោយប្រសិទ្ធភាព" សម្រាប់ការរំលោភបំពានទៅលើសិទ្ធិណាមួយ ដែលត្រូវបានធានាដោយកតិកាសញ្ញាមួយនេះ។ តុលាការ ICTR បានបញ្ជាក់បន្ថែមទៀតថា ការរំលោភបំពានទៅលើសិទ្ធិជាសារវន្តរបស់ជនជាប់ចោទ តម្រូវឲ្យមានការទូទាត់សងឲ្យបានសមស្របមួយ[1494]។

---

[1491] *សូមមើល*យោបល់ទូទៅ ៣២ កថាខណ្ឌ ៣៥ (ភាពសមហេតុផលនៃការឃុំខ្លួនមុនពេលជំនុំជម្រះអាស្រ័យទៅលើ "ភាពស្មុគស្មាញនៃសំណុំរឿង ទង្វើរបស់ជនជាប់ចោទ និងវិធីនៃចំណាត់ការនានារបស់ផ្នែករដ្ឋបាល និងផ្នែកតុលាការទៅលើបញ្ហានេះ")។ សេចក្តីសម្រេចលើរឿងក្តី *Barayagwiza*, កថាខណ្ឌ ២, ៨១ ដល់ ១០១ (រិះគន់កង្វះការយកចិត្តទុកដាក់របស់ភាគីអយ្យការចំពោះកិច្ចស៊ើបសួរអស់រយៈពេល ១៨ ខែ មុនពេលនៃការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។

[1492] សាលដីកា, កថាខណ្ឌ ៦៤៥ ដល់ ៦៥២។

[1493] សាលដីកា, កថាខណ្ឌ ៦៥៣។

[1494] សេចក្តីសម្រេចក្នុង *រឿងក្តី Semanza*, កថាខណ្ឌ ១២៥។

១៧. សិទ្ធិទទួលបានការទូទាត់សង ត្រូវបានសង្កត់ធ្ងន់ជាពិសេសពាក់ព័ន្ធទៅនឹងការឃុំខ្លួនដោយខុសនីតិវិធីច្បាប់។ ទោះបីជាច្បាប់កម្ពុជាមិនបានចែងពីផលវិបាកនៃការឃុំខ្លួនបណ្ដោះអាសន្នខុសនីតិវិធីច្បាប់ក៏ដោយ ក៏រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានការពារយ៉ាងខ្លាំងក្លាទៅលើសិទ្ធិទទួលបានសេរីភាព[1495]។ វិធានដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិបានបញ្ជាក់ថា រដ្ឋមួយដែលបានកម្រិតដោយខុសច្បាប់ទៅលើសេរីភាពផ្នែករូបរាងកាយរបស់បុគ្គល ត្រូវមានកាតព្វកិច្ចផ្ដល់ការទូទាត់សងដោយសមស្រប។ មាត្រា ៩ នៃកតិកាសញ្ញា ICCPR ដែលធានាការការពារពីការចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តនោះ បានចែងនៅក្នុងអនុកថាខណ្ឌ ៤ ថា ជនណាដែលត្រូវបានដកហូតមិនឱ្យទទួលបាននូវការការពារបែបនេះ អាចដាក់សំណើទៅតុលាការសុំឱ្យដោះលែង។ កថាខណ្ឌ ៥ ក៏បានចែងប្រហាក់ប្រហែលគ្នានេះដែរអំពីសិទ្ធិទទួលបានសំណង។ ដោយធ្វើការបកស្រាយមាត្រា ៩ គណៈកម្មាការសិទ្ធិមនុស្ស បានកត់សម្គាល់ពីកាតព្វកិច្ចក្នុងការផ្ដល់ការទូទាត់សងប្រកបដោយប្រសិទ្ធភាព សម្រាប់ការដកហូតសេរីភាពដោយរំលោភទៅលើកតិកាសញ្ញា[1496]។

១៨. គោលបំណងនៃការទូទាត់សងចំពោះការរំលោភបំពានទៅលើសិទ្ធិ ដែលត្រូវបានធានាដោយច្បាប់អន្តរជាតិនោះ គឺត្រូវដោះស្រាយទាំងស្រុងចំពោះម្ចាស់បណ្ដឹង[1497]។ ដូចដែលបានបញ្ជាក់ដោយតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ នៅក្នុងរឿងក្ដី *Chorzow Factory* "ការទូទាត់សំណង ត្រូវតែធ្វើឡើងដល់កម្រិតខ្ពស់បំផុត ដើម្បីលុបបំបាត់រាល់ផលវិបាកនៃអំពើខុសច្បាប់ និងដើម្បីបង្កើតឡើងវិញនូវស្ថានភាពដែលគួរតែកើតមានក្នុងករណីដែលអំពើខុសច្បាប់

---

[1495] *សូមមើល* រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៣១, ៣២ និង ៣៨។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ៥០៧ ("គ្រប់ចៅក្រមទាំងអស់ដែលបានទទួលបណ្ដឹងស្ដីពីការឃុំខ្លួនបុគ្គលណាម្នាក់ដោយខុសច្បាប់ត្រូវធ្វើការផ្ទៀងផ្ទាត់ជាចាំបាច់ភ្លាម")។

[1496] យោបល់ទូទៅ ៨ កថាខណ្ឌ ១។

[1497] *សូមមើល* សាលដីកា, កថាខណ្ឌ ៦៤៥ ដល់ ៦៤៦។ *សូមមើលផងដែរសំណុំរឿង Paniagua-Morales និងជនដទៃទៀត ទល់នឹង Guatemala ("សំណុំរឿងរថយន្តពណ៌ស")*, តុលាការសិទ្ធិមនុស្សអន្តរអាមេរិក, សាលក្រម (សំណង និងសោហ៊ុយ), ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១, កថាខណ្ឌ ៧៦, ៧៩ (សំណងតម្រូវឱ្យមាន "ការសងទាំងស្រុង (...) ដែលជាផ្នែកមួយនៅក្នុងការបង្កើតឡើងវិញនូវស្ថានភាពមុន")។

នោះមិនត្រូវបានប្រព្រឹត្តិឡើង"[1498]។ ក្នុងបញ្ហានេះ "ត្រឹមតែលទ្ធភាព" នៃការទទួលបានការទូទាត់សំណង គឺមិនមានលក្ខណៈគ្រប់គ្រាន់នោះទេ[1499]។ ការទូទាត់សងដែលផ្តល់ឲ្យ គួរតែ "មានលទ្ធភាពផ្តល់នូវការទូទាត់សង" ជាក់ស្តែង[1500]។

១៩. នៅក្នុងបរិបទនៃឧក្រិដ្ឋកម្ម ដូច្នេះតុលាការអន្តរជាតិធ្វើការទូទាត់សងចំពោះការឃុំខ្លួនដោយខុសនីតិវិធីច្បាប់ ដោយស្តារឡើងវិញនូវសេរីភាពរបស់ជនជាប់ចោទ ដែលត្រូវបានដកហូត។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បានសម្រេចនៅក្នុងបរិបទនៃការឃុំខ្លួនដោយខុសច្បាប់ ថា រដ្ឋតម្រូវឲ្យ "បញ្ចប់នូវការរំលោភបំពានដែលរកឃើញដោយតុលាការ ហើយត្រូវផ្តល់នូវការទូទាត់សងតាមគ្រប់លទ្ធភាពចំពោះផលវិបាកដែលបណ្តាលមកពីការរំលោភបំពាននេះ ដើម្បីស្តារឡើងវិញតាមគ្រប់លទ្ធភាពនូវស្ថានភាពដែលកើតមាន នៅមុនពេលមានការរំលោភបំពាន"[1501]។ ហេតុដូច្នេះ យុត្តិសាស្ត្រដែលបានដកស្រង់ចេញពីតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស

---

[1498] *រឿងក្តី Chorzow Factory*, សាលក្រម (ការទាមទារសំណង) (អង្គសេចក្តី), ទំព័រ ៤៧។ បទដ្ឋានទាំងនេះត្រូវបានអង្គជំនុំជម្រះ យកមកអនុវត្តនៅក្នុងការពិភាក្សារបស់ខ្លួនស្តីពីសំណង៖ សាលដីកា, កថាខណ្ឌ ៦៤៥ ដល់ ៦៤៦។

[1499] *រឿងក្តី Agudo ទល់នឹង Spain*, គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, ទស្សនៈ, ឯកសារ អ.ស.ប CCPR/C/76/D/890/1999 (ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២),កថាខណ្ឌ ៩.១។

[1500] *រឿងក្តី Menesheva ទល់នឹង Russia*,តុលាការសិទ្ធិមនុស្សអឺរ៉ុប, សាលក្រមអង្គជំនុំជម្រះ, សាលក្រមលេខ 59261/00, ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦, កថាខណ្ឌ ៧៦ (ដំណោះស្រាយមួយដែលទំនងជាពុំអាចលេចចេញជាសំណងជាក់ស្តែង គឺជាសំណងដែលផ្អែកតែទៅលើ "ទ្រឹស្តី និងពុំមានភាពជាក់ស្តែង" ហើយដូច្នេះពុំបានបំពេញលក្ខខណ្ឌតម្រូវនៃអនុសញ្ញានេះបានឡើយ)។ *រឿងក្តី Vernillo ទល់នឹង France*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សាលក្រមអង្គជំនុំជម្រះ, ឯកសារលេខ 11889/85, ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩១, កថាខណ្ឌ ២៧ ("សំណងនានាត្រូវមានភាព ជាក់លាក់គ្រប់គ្រាន់ទាំងក្នុងទ្រឹស្តី និងការអនុវត្ត"); រឿងក្តី *Selmouni ទល់នឹង France*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សាលដីកាអង្គជំនុំជម្រះកំពូល, ឯកសារលេខ 25803/94, ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៧៦ (សំណងត្រូវតែ "មានប្រសិទ្ធភាពដែលមានទាំងក្នុងទ្រឹស្តីនិងក្នុងការអនុវត្តនៅពេលពាក់ព័ន្ធ ពោលគឺសំណងត្រូវតែអាចទទួលយកបានហើយដែលអាចផ្តល់ជំនឹចិត្តពាក់ព័ន្ធនឹងការតវ៉ារបស់ម្ចាស់បណ្តឹង និងផ្តល់លទ្ធភាពនៃជោគជ័យដោយមានហេតុផលត្រឹមត្រូវ")។

[1501] *រឿងក្តី Assanidze ទល់នឹង Georgia*, តុលាការសិទ្ធិមនុស្សអឺរ៉ុប,សាលដីកាអង្គជំនុំជម្រះតុលាការកំពូល, ឯកសារលេខ 71503/01, ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៤, កថាខណ្ឌ ១៩៨ ។ *សូមមើលផងដែរនូវឯកសារយោងខាងលើកថាខណ្ឌ ២០២* (ដែលបានសម្រេចថា សំណងតែមួយគត់ដែលអាចធ្វើទៅបាន សម្រាប់ការឃុំខ្លួនម្ចាស់បណ្តឹងដោយខុសច្បាប់ គឺការដោះលែងជាបន្ទាន់ ក្រោមកាលៈទេសៈទាំងនេះ ។

បានបញ្ជាក់ថា ការកាត់បន្ថយទោស គឺជាការទូទាត់សងដ៏សមស្របសម្រាប់ការឃុំខ្លួនដោយខុសច្បាប់ ឬដោយហួសរយៈពេលកំណត់[1502] ហើយការកាត់បន្ថយទោសបែបនេះ ត្រូវតែជា "ការទូទាត់សងដោយសមស្រប" សម្រាប់ការរំលោភបំពានដែលបានចោទប្រកាន់ឡើង[1503]។ ជារួម តុលាការមិនអចិន្ត្រៃយ៍នានាបានផ្តល់នូវការកាត់បន្ថយទោស បន្ថែមពីលើការគិតបញ្ចូលថិរវេលាជាប់ឃុំ ថាជាការទូទាត់សំណងសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នខុសនីតិវិធីច្បាប់[1504]។

២០. អនុលោមតាមការវិភាគនេះ កាំង ហ្កេកអ៊ាវមានសិទ្ធិទទួលបានការទូទាត់សងសម្រាប់ការរំលោភបំពានលើសិទ្ធិទទួលបានសេរីភាពរបស់គាត់។ ការទូទាត់សងនេះត្រូវរួមបញ្ចូលទាំងការទទួលស្គាល់ដោយចៅក្រម តាមរយៈទស្សនៈនេះ អំពីការរំលោភបំពានសិទ្ធិរបស់គាត់ ព្រមទាំងការទូទាត់សងជាទម្រង់នៃការកាត់បន្ថយទោស។ ដោយសារតែអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចជាឯកច្ឆន្ទថាស្ថានទម្ងន់នៃបទឧក្រិដ្ឋរបស់ កាំង ហ្កេកអ៊ាវ តម្រូវឱ្យប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត ទើបការផ្តល់សំណងនេះអាចធ្វើឡើងទៅបានតែតាមរយៈការកែប្រែការប្រកាសទោសមកជាការដាក់ពន្ធនាគារដោយមានពេលវេលាកំណត់

---

[1502] *រឿងក្តី* Chraidi *ទល់នឹង* Germany, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សាលក្រមអង្គជំនុំជម្រះ, ឯកសារលេខ 65655/01, ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ("សាលក្រមក្នុង *រឿងក្តី* Chraidi"), កថាខណ្ឌ ២៤-២៥; សាលក្រមក្នុង *រឿងក្តី* Dzelili, កថាខណ្ឌ ៨៣ ដល់ ៨៥។ *សូមមើលផងដែរ* របាយការណ៍ស្តីពីប្រសិទ្ធភាពនៃសំណងជាលក្ខណៈជាតិពាក់ព័ន្ធនឹងរយៈពេលលើសលប់នៃកិច្ចដំណើរការនីតិវិធី, ឯកសារសិក្សាលេខ 316/2004, ដែលគណៈកម្មការអឺរ៉ុបសម្រាប់លទ្ធិប្រជាធិបតេយ្យតាមរយៈច្បាប់ បានអនុម័ត នៅក្នុងសម័យប្រជុំពេញអង្គលើកទី ៦៩, ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៧, កថាខណ្ឌ ២២៨ ("ការពិចារណាអំពីការពន្យារពេល នៅក្នុងការវាយតម្លៃអំពីការផ្តន្ទាទោសត្រូវចាត់ទុកជាទម្រង់សមស្របមួយនៃសំណងនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ")។

[1503] *សាលក្រមក្នុងរឿងក្តី* Chraidi, កថាខណ្ឌ ២៤។

[1504] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង* Barayagwiza *និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ ICTR-99-52-T, សាលក្រម និងការផ្តន្ទាទោស, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៣ ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង Barayagwiza"), កថាខណ្ឌ ១១០៦ ដល់ ១១០៧។ សាលដីកាសាលាឧទ្ធរណ៍ក្នុង *រឿងក្តី* Semanza, កថាខណ្ឌ ៣២៣ ដល់ ៣២៨ ។ សាលដីកាសាលាឧទ្ធរណ៍ក្នុង *រឿងក្តី* Kajelijeli, កថាខណ្ឌ ៣២៤។

តែប៉ុណ្ណោះ។ វិធីសាស្ត្របែបនេះត្រូវបានគាំទ្រដោយការអនុវត្តនៅបណ្តាតុលាការមិនអចិន្ត្រៃយ៍នានា[1505]។

២១. ឥឡូវនេះយើងងាកទៅពិចារណាអំពីរយៈពេលនៃការផ្តន្ទាទោសដាក់ពន្ធនាគារ ដោយមានរយៈពេលកំណត់។ មាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប្រមើលមើលអំពីទោសជាប់ ពន្ធនាគារ ដែលមានរយៈពេលកំណត់ពី ៥ ឆ្នាំ រហូតដល់មួយជីវិតចំពោះបទឧក្រិដ្ឋនានាដែល ស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ។ មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ អនុញ្ញាតឲ្យ ផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬដាក់ពន្ធនាគារក្នុងរយៈពេលកំណត់ រហូតដល់ ៣០ ឆ្នាំ។ ចៅក្រមភាគច្រើនយល់ឃើញ ដោយសំអាងទៅលើមាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជាច្បាប់ពិសេស (*lexspecialis*) បើប្រៀបធៀបទៅនឹងច្បាប់ទូទៅ (*legegeneralis*) នៃគន្ថី I នៃក្រម ព្រហ្មទណ្ឌឆ្នាំ ២០០៩ ដូច្នេះហើយត្រូវដាក់ជំនួសគន្ថី ១ នៃក្រម ព្រហ្មទណ្ឌឆ្នាំ ២០០៩ នៅពេលដែលមានវិវាទ កើតឡើង។ ដូច្នេះ ចៅក្រមភាគច្រើនយល់ឃើញថា មាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មានអធិកភាពទៅលើមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ទាក់ទិននឹងឆន្ទានុសិទ្ធិស្របច្បាប់ របស់តុលាការក្នុងការផ្តន្ទាទោស[1506]។ យើងពុំយល់ស្របទៅនឹងការផ្អែកទៅលើគោលការណ៍នៃច្បាប់ ពិសេសរបស់ចៅក្រមភាគច្រើនឡើយ ដោយនៅក្នុងទស្សនៈរបស់យើង គោលការណ៍នេះមិនអាចយកមកអនុវត្តបានទេចំពោះករណីនេះ។

២២. នៅក្រោមគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ ឃ្លា*ច្បាប់ពិសេសបដិញ្ញត្តិច្បាប់ទូទៅ* (*lex specialis derogat lege generali*) អាចយកមកអនុវត្តបានតែក្នុងករណីដែលមានភាពស្មើគ្នានៃនិយាមមួយចំនួនដែលត្រូវយកមកប្រៀបផ្ទឹមគ្នាប៉ុណ្ណោះ មានន័យថា *យុត្តាធិការនៃរឿងក្តី* (*ratione materiae*) នៃនិយាមទាំងពីរ មានលក្ខណៈស្រដៀងគ្នាមែនទែន ទាំងខ្លឹមសារ

[1505]សាលក្រមជំនុំជម្រះក្នុង*រឿងក្តី Barayagwiza*, កថាខណ្ឌ ១១០៦ ដល់ ១១០៧។ សាលដីកាក្នុងរឿងក្តី *Kajelijeli*, កថាខណ្ឌ ៣២៤។

[1506]មតិចៅក្រមភាគច្រើនស្តីពីការប្រកាសទោស, កថាខណ្ឌ ៣៤៨ ដល់ ៣៥១។

និងមុខងារ របស់និយាមទាំងនោះ[1507]។ សម្រាប់គោលបំណងនៃការផ្តន្ទាទោស បទបញ្ញត្តិមួយ ដូចជា មាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលកំណត់នូវកម្រិតទោស អាចបង្កើតបានជាច្បាប់ពិសេស ទាក់ទិនទៅនឹងបទបញ្ញត្តិមួយទៀតបាន លុះត្រាតែវិធានទាំងពីរនេះសុទ្ធតែមានគោលបំណងដាក់ ទណ្ឌកម្មដល់បទឧក្រិដ្ឋស្រដៀងគ្នា។

២៣. បញ្ហាជាក់លាក់នៅក្នុងរឿងក្តីនេះ គឺថាតើនិយាមដែល កាំង ហ្គេកអ៊ាវ ត្រូវបានចោទប្រកាន់នៅក្រោមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) ស្ថិត នៅក្នុងទំនាក់ទំនងរវាង*ច្បាប់ពិសេស និងច្បាប់ទូទៅ* ជាមួយនឹងបទឧក្រិដ្ឋស្រដៀងគ្នាដូចដែលមាន ចែងនៅក្នុងមាត្រា ១៨៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ឬយ៉ាងណា។ ដូចដែលបានកត់សម្គាល់នៅ ក្នុងសាលដីការបស់យើង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពុំបាន*កំណត់និយមន័យ* នៃបទឧក្រិដ្ឋឡើយ ដោយគ្រាន់តែចែងអំពីយុត្តាធិការរបស់ អ.វ.ត.ក ទៅលើបទឧក្រិដ្ឋអន្តរជាតិ ដែលបានកើតមាននៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ នៅក្រោមច្បាប់អន្តរជាតិ។ ផ្ទុយទៅវិញ ក្រមព្រហ្មទណ្ឌ គឺជាប្រភពនៃការចាត់ទុកទម្រង់នៃអំពើមួយចំនួនថាជាបទល្មើសនៅក្រោមច្បាប់ជាតិ ដោយមានអានុភាពសម្រាប់ពេលអនាគត។ នៅក្នុងទស្សនៈរបស់យើង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ (ជាពិសេសទំនៀមទម្លាប់) និងមាត្រា ១៨៨ នៃក្រមព្រហ្មទណ្ឌ តាមលក្ខណៈបច្ចេកទេស ចែងអំពីប្រភេទផ្សេងៗគ្នានៃបទល្មើស ដូច្នេះហើយយើងមិនអាចអនុវត្តគោលការណ៍នៃការប្រៀបធៀបរវាង*ច្បាប់ពិសេស ច្បាប់ទូទៅ* ឡើយ។ ដូច្នេះ ការដាក់ទោសទណ្ឌ ដែលត្រូវប្រមើលមើលនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នឹងមានលក្ខណៈចងកាតព្វកិច្ច ទាក់ទិននឹងបទឧក្រិដ្ឋនានាដែលត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់អន្តរជាតិ ដោយផ្អែកតែទៅលើមូលដ្ឋាននៃច្បាប់ជាក់លាក់ពីរដ្ឋសភាប៉ុណ្ណោះ។ ច្បាប់បែបនេះមិនឃើញមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ

---

[1507] *បំបែកនៃច្បាប់អន្តរជាតិៈ ការលំបាកដែលចេញពីផ្នែកផ្សេងៗ និងវិសាលភាពនៃច្បាប់អន្តរជាតិ*របាយការណ៍របស់ក្រុមសិក្សាស្រាវជ្រាវអំពីគណៈកម្មការច្បាប់អន្តរជាតិ សេចក្តីសន្និដ្ឋានពង្រាងនៃកិច្ចការរបស់ក្រុមសិក្សាស្រាវជ្រាវ ដែលរៀបចំបញ្ចប់ដោយ MarttiKoskenniemi, ឯកសារអង្គការសហប្រជាជាតិលេខ A/CN.4/L.682/Add.1 (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០០៦), កថាខណ្ឌ ៥, (ដែលបញ្ជាក់អំពីទ្រឹស្តីដែលអនុវត្តបាន (និងជាចម្បង) នៅក្នុងកម្រិតជាតិ)។

២០០៩ ឡើយ ដែលប្រការនេះទំនងជាកម្រិតនូវការអនុវត្តគន្លី I ត្រឹមតែចំពោះបទឧក្រិដ្ឋនានាដែលកំណត់ ដោយលក្ខន្តិកៈ[1508]។ សេចក្តីសន្និដ្ឋានដែលមានលក្ខណៈប្រសើរជាងនោះគឺថា ការផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មិនអាចយកមកអនុវត្តបានទេនៅចំពោះមុខ អ.វ.ត.ក ទាក់ទិននឹងបទឧក្រិដ្ឋអន្តរជាតិ[1509]។

២៤. ទោះបីជាយ៉ាងណាក៏ដោយ ដោយសារហេតុផលជាច្រើន យើងបានសន្និដ្ឋានថា តុលាការនេះគួរតែផ្តល់ទម្ងន់ឲ្យបានច្រើនទៅឲ្យការអនុវត្តការផ្តន្ទាទោសតាមច្បាប់ជាតិ ដែលរួមបញ្ចូលទាំងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ។

២៥. ទីមួយ ដែនកំណត់នៃការផ្តន្ទាទោសដែលប្រមើលមើលនៅក្នុងមាត្រា ៣៩ នៃច្បាប់ស្តីពី ការបង្កើត អ.វ.ត.ក គឺមានលក្ខណៈទូលំទូលាយយ៉ាងខ្លាំង និងមានគោលការណ៍ណែនាំតិចតួចស្តីពីការផ្តន្ទាទោសនៅក្នុងមាត្រាផ្សេងទៀតក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[1510]។

២៦. ទីពី គោលការណ៍ផ្តន្ទាទោសនៅកម្រិតអន្តរជាតិ មានកម្រិត កំណត់។ មុនពេលកើតមានតុលាការមិនអចិន្ត្រៃយ៍ ជាក់ស្តែង “ពុំមានវិធានច្បាប់ឡើយ” នៅក្នុងការផ្តន្ទាទោសចំពោះ

---

[1508]*សូមមើលខទា.* មាត្រា ១, ២ និង ៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

[1509]មិនដូចជាបទឧក្រិដ្ឋនានាដែលមានចែងនៅក្នុងច្បាប់ជាតិដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក (*សូមមើល* មាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក)។ ទាក់ទិននឹងបទឧក្រិដ្ឋទាំងនេះ ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ អាចយកមកអនុវត្តបាន ជាអប្បបរមា ក្នុងវិសាលភាពដែលក្រមនេះមានអានុភាព*ដែលចែងអំពីទោសដែលស្រាល*។ សូមមើល កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១២(១) កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១២(២) និងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មាត្រា ១០។

[1510]Mark D. Kielsgard, “The Legality Principle in Sentencing at the ECCC: Making Up Law as It Goes Along?”, *Asian Journal of International Law* វ៉ុល ២ (ឆ្នាំ ២០១២) ទំព័រ ១១៩ ដល់ ១២០(“ឯកសារច្បាប់នៅ អ.វ.ត.ក មិនបានចែងនូវការណែនាំគ្រប់គ្រាន់ឡើយ។ ជាការពិត សេចក្តីព្រាងនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ដូចដែលបានប្រកាសឱ្យប្រើពីដំបូង និងថ្មីនេះក្នុងឆ្នាំ ២០០៤) ស្តីពីការប្រកាសទោស មានលក្ខណៈគ្រួសៗ មិនច្បាស់លាស់ ធ្វើឱ្យភាន់ច្រឡំ។ ការប្រកាសទោសដែលចែងនៅក្នុង អ.វ.ត.ក មានការប៉ះពាល់យ៉ាងដល់គោលការណ៍នីត្យានុកូលភាព (...)”)។

បទឧក្រិដ្ឋអន្តរជាតិធ្ងន់ធ្ងរ[1511]។ នៅក្នុងឆ្នាំ ២០០០ អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY នៅក្នុងរឿងក្តី *Furundžija* បានសម្រេចថា វានៅតែជា "ការឆាប់រហ័សពេកក្នុងការនិយាយអំពីអត្ថិភាពនៃរបបព្រហ្មទណ្ឌ" នៅកម្រិតអន្តរជាតិ[1512]។ទោះបីជាតុលាការមិនអចិន្ត្រៃយ៍ នានាបានបន្តបង្កើតវិធានច្បាប់ស្តីពីការផ្តន្ទាទោសក៏ដោយ ក៏ការប្រមូលផ្តុំជាក្រុមនៃគោលការណ៍ ណែនាំទាំងនោះនៅមានកម្រិតរហូតដល់មានការអនុម័តវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC[1513]។ ទោះបីជា យ៉ាងណាក៏ដោយ គោលការណ៍ណែនាំទាំងនេះពិពណ៌នាតែអំពីកត្តានានាពាក់ព័ន្ធទៅនឹងការផ្តន្ទា ទោសតែប៉ុណ្ណោះ ប៉ុន្តែពុំបានបកស្រាយកត្តាទាំងនោះ ជាការកំណត់ជាក់ស្តែងពីកម្រិតទោសសម្រាប់បទល្មើសនានាឡើយ។ លើសពីនេះទៀត ដោយសារតែគោលការណ៍ណែនាំទាំងនោះ មានអត្ថិភាព តែត្រូវបានបង្កើតឡើងក្នុងរយៈពេលជាយូរបន្ទាប់ពីកើតមានបទឧក្រិដ្ឋនានានៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក តុលាការនេះអាចនឹងរំលោភទៅលើគោលការណ៍នីត្យានុកូលភាព តាមរយៈការផ្អែកទាំងស្រុង

[1511]Mirko Bagaric and John Morss, "International Sentencing Law: In Search of a Justification and Coherent Framework", វិវេចនាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ វ៉ុល ៦ (ឆ្នាំ ២០០៦) ទំព័រ ១៩២ ដកស្រង់ចេញពី William A. Schabas, "Sentencing by International Tribunals: A Human Rights Approach", *Duke Journal of Comparative & International Law* វ៉ុល ៧ (ឆ្នាំ ១៩៩៩) ទំព័រ ៤៦១ ដល់ ៤៦២។ Barbara Hola et al., "International Sentencing Facts and Figures: Sentencing Practice at the ICTY and ICTR", *Journal of International Criminal Justice* វ៉ុល ៩ (ឆ្នាំ ២០១១) ទំព័រ ៤១១ (កត់សម្គាល់ថា តុលាការមិនអចិន្ត្រៃយ៍នានាបាន "នាំមុខគេ" ក្នុងការអភិវឌ្ឍគោលការណ៍កំណត់ទោស ដំបូងមួយចំនួន") ទំព័រ ៤១២ (ការលើកទឡ្ហីករណ៍អំពីការផ្តន្ទាទោសនៅតុលាការ Nuremberg និង Tokyo គឺមាន "លក្ខណៈជាមូលដ្ឋានបំផុត")។

[1512]សាលដីកាលើរឿងក្តី *Furundžija កថាខណ្ឌ ២៣៧*។

[1513]*សូមមើល* វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC វិធាន ១៤៥ (ចែងអំពីស្ថានសម្រាលទោស និងស្ថានទម្ងន់ ទោសដែលពាក់ព័ន្ធ)។ ប្រៀបធៀប លក្ខន្តិកៈតុលាការ ICTY មាត្រា ២៤(២) និងវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY វិធាន ១០១ (គ្រាន់តែចែងថា តុលាការគួរតែពិចារណាទៅលើភាពធ្ងន់ធ្ងរនៃបទល្មើស ស្ថានភាពបុគ្គលរបស់ជនជាប់ចោទ ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស រួមទាំងកិច្ចសហប្រតិបត្តិការជាមួយនឹងរដ្ឋអាជ្ញា និងការអនុវត្តទូទៅនៃទោសជាប់ពន្ធនាគារនៅក្នុងប្រទេសយូហ្គោស្លាវី)។

ឬជាសំខាន់ទៅលើយុត្តិសាស្ត្ររបស់តុលាការទាំងនោះ[1514]។ សម្រាប់ហេតុផលទាំងនេះ ទាំងវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និងវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR ណែនាំឲ្យតុលាការធ្វើការពិចារណាអំពី"ការអនុវត្តជាទូទៅទាក់ទិននឹងទោសដាក់ពន្ធនាគារ" នៅក្នុងតុលាការក្នុងប្រទេស[1515]។

២៧. ទីបី សនិទានភាពក្នុងការអនុវត្តតាមរបបនៃការផ្តន្ទាទោសនៅកម្រិតថ្នាក់ជាតិ យ៉ាងហោចណាស់ក៏ត្រឹមត្រូវ ចំពោះបរិបទរបស់អង្គជំនុំជម្រះ ដូចជា អ.វ.ត.ក នេះ ដែលត្រូវបានបង្កើតឡើងនៅក្នុង "វចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់"នោះ[1516]។ ជាភស្តុតាងបង្ហាញអំពីភាពអាចអនុវត្តបាននៃ វិធីសាស្ត្រនេះ យើងកត់សម្គាល់ថា សាលក្រម និងសាលដីការបស់អង្គជំនុំជម្រះនេះបានប្រើប្រាស់ ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ សម្រាប់បញ្ហានានាទាក់ទិននឹងឧទាហរណ៍ ការដាក់ទោសតែមួយចំពោះការផ្តន្ទាទោសច្រើនបទចំពោះបទឧក្រិដ្ឋអន្តរជាតិ[1517]។ ហេតុដូច្នេះ យើងសូមស្នើថា ក្នុងស្ថានភាពដែលពុំមានបទដ្ឋានអន្តរជាតិបែបនេះ អ.វ.ត.ក គួរតែកុំអនុវត្តតាមរបបប្រកាសទោសនៅតុលាការកម្ពុជា តែនៅពេលដែលមាន

---

[1514] អ្នកនិពន្ធ Shahram Dana, "ហួសពីប្រតិសកម្មឈានទៅដល់ការទទួលបានយុត្តិធម៌: ទ្រឹស្តីស្តីពីគោលការណ៍នីត្យានុកូលភាពនៅក្នុងការប្រកាសតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ", ព្រឹត្តប័ត្រស្តីពីច្បាប់អន្តរជាតិ និងឧក្រិដ្ឋវិទ្យា វ៉ុល ៩៩:៤ (ឆ្នាំ ២០០៩) ទំព័រ ៨៨៧ ដល់ ៩០៥។

[1515] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY វិធាន ១០១(ខ) (iii)។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR វិធាន ១០១(ខ)(iii)។ *សូមមើលផងដែរ* Shahram Dana, ហួសពីប្រតិសកម្មឈានទៅដល់ការទទួលបានយុត្តិធម៌: ទ្រឹស្តីស្តីពីគោលការណ៍នីត្យានុកូលភាពនៅក្នុងការប្រកាសតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ", ទំព័រ ៨៨៧ ដល់ ៩០៥។

[1516] លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេស Serra Leone ណែនាំឲ្យអង្គជំនុំជម្រះសាលាដំបូងមានដំណោះស្រាយ ចំពោះការផ្តន្ទាទោសរបស់តុលាការជាតិ Serra Leone និងតុលាការ ICTR ប៉ុន្តែលុបចោលការអនុវត្តនៅ ICTY។ ការអនុវត្តបែបនេះឆ្លុះបញ្ចាំងអំពីវិធីសាស្ត្រផ្តន្ទាទោសជាលក្ខណៈជាតិ ឬតំបន់ ប៉ុន្តែមិនមែនជាលក្ខណៈអន្តរជាតិនោះទេ។ *សូមមើល* មាត្រា ១៩(១) នៃលក្ខន្តិកៈរបស់តុលាការSCSL។

[1517] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៩។ សាលដីកា កថាខណ្ឌ ៣២៨។ *សូមមើល*សាលក្រម អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ៥៨៥ (ដកស្រង់ចេញពីក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ទាក់ទងទៅនឹងស្ថានសម្រាលទោស)។

មូលហេតុត្រឹមត្រូវផ្អែកតាមកាលៈទេសៈមួយចំនួនប៉ុណ្ណោះ[1518]។ ឧទាហរណ៍ មូលហេតុបែបនោះ អាចរួមមាន ករណីដែលប្រព័ន្ធច្បាប់ជាតិ មិនបានកំណត់បទព្រហ្មទណ្ឌចំពោះអំពើពាក់ព័ន្ធនោះ ឬនៅពេលដែលច្បាប់កម្ពុជា ពិចារណាអំពីការផ្តន្ទាទោស ដែលពិតជាមានលក្ខណៈមិនគ្រប់គ្រាន់ បើប្រៀបធៀបនឹងការអនុវត្តអន្តរជាតិ ដោយការផ្តន្ទាទោសនោះមានកម្រិតធ្ងន់ធ្ងរពេក[1519] ឬស្រាលពេក។

២៨. នៅក្នុងករណីនេះ មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ចែងថា ការផ្តន្ទាទោសកម្រិតអតិបរមា ដែលស្ថិតនៅក្រោមការដាក់ទោសពន្ធនាគារអស់មួយជីវិត គឺត្រឹមរយៈពេលកំណត់សាមសិប(៣០)ឆ្នាំ។ តាមរយៈការអនុម័តនូវការកម្រិតបែបនេះ អង្គនីតិបញ្ញត្តិនៃប្រទេសកម្ពុជា បានសម្រេចអំពីគោលនយោបាយព្រហ្មទណ្ឌ ដែលស្របគ្នាទៅនឹងការអនុវត្តប្រព័ន្ធច្បាប់ប្រទេសអឺរ៉ុប ថា ទោសដាក់ពន្ធនាគារដែលមានរយៈពេលកំណត់ គឺជារយៈពេលដែលអាចថាជនល្មើសអាចជាប់ពន្ធនាគារអស់មួយជីវិត។ ទាំងគោលនយោបាយនោះ និងទោសជាប់ពន្ធនាគារដែលមានរយៈពេល កំណត់សាមសិប (៣០)ឆ្នាំ ដែលត្រូវការសម្រាប់ករណីនេះ មិនមែនមិនស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិឡើយ។ ជាការពិត មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ចម្លងតាមរបបនៃការផ្តន្ទាទោសនៅតុលាការ ICC ដែលកំណត់ការផ្តន្ទាទោសស្រដៀងគ្នាដែរ គឺត្រឹមកម្រិតអតិបរមាសាមសិបឆ្នាំ[1520]។ ការស្ទង់មតិប្រព័ន្ធច្បាប់ជាតិចំនួនម្ភៃបី ដែលធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY នៅក្នុងរឿងក្តី *Nikolić* បានរកឃើញថា រដ្ឋចំនួនដប់ប្រាំបួន លើកលែងតែរដ្ឋប្រើប្រាស់យុត្តាធិការ ច្បាប់

---

[1518]ទោះបីជានៅតុលាការ ICTY អង្គជំនុំជម្រះតុលាការកំពូល បានរៀបរាប់ថា "អង្គជំនុំជម្រះសាលាដំបូង ត្រូវតែពិចារណាអំពីការអនុវត្តការផ្តន្ទាទោសនៅអតីតប្រទេសយូហ្គោស្លាវី ហើយប្រសិនបើអង្គជំនុំជម្រះមិនបានអនុវត្តតាមការកំណត់សម្រាប់ការផ្តន្ទាទោសដែលមាននៅក្នុងការអនុវត្តទាំងនោះទេ *អង្គជំនុំជម្រះត្រូវតែផ្តល់សំអាងហេតុសម្រាប់ការមិនអនុវត្តនោះ*"។ សាលដីកាលើ *រឿងក្តី* Nikolić កថាខណ្ឌ ៦៩ (សេចក្តីបញ្ជាក់បន្ថែម)។

[1519]*រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Fofana និង Kondewa, សំណុំរឿងលេខ SCSL-04-14-T, "សាលក្រមស្តីពីការផ្តន្ទាទោស Moinina Fofana និង Allieu Kondewa", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៧ ("*សាលក្រមផ្តន្ទាទោស Fofana and Kondewa*"), កថាខណ្ឌ ៤៣។

[1520]មាត្រា ៧៧(១)(ក) នៃលក្ខន្តិកៈរបស់តុលាការ ICC។

ស៊ីវិលមួយប៉ុណ្ណោះ បានពិចារណាអំពីការផ្តន្ទាទោសអតិបរមាសាមសិបឆ្នាំ ឬតិចជាងនេះ[1521]។ នៅតុលាការមិនអចិន្ត្រៃយ៍ មានតែចុងចោទចំនួនដប់ពីររូបប៉ុណ្ណោះ (លើកលែងការផ្តន្ទាទោសត្រូវបានបន្ធូរបន្ថយនៅតុលាការកំពូល) បានទទួលការផ្តន្ទាទោសដាក់ពន្ធនាគារលើសពី៣០ឆ្នាំ[1522] ហើយមានតែចុងចោទបីរូបប៉ុណ្ណោះ ទទួលការផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៣៥ ឆ្នាំ[1523] ទោះបីជាតុលាការទាំងនោះ មិនត្រូវបានរាំងដោយការកំណត់ទោសលើសដែលមានចែងនៅក្នុងច្បាប់រវ៉ាន់ដា ឬច្បាប់យូហ្គោស្លាវីនោះទេ។ បន្ថែមពីលើនេះ ការផ្តន្ទាទោសក្នុងរឿងក្តីចំនួនពីរនៃរឿងក្តីទាំងនេះប៉ុណ្ណោះ បានរួមបញ្ចូលសំណងចំពោះការឃុំខ្លួនបណ្តោះអាសន្នលើសកំណត់។ ករណីបែបនោះមានចំនួនតិចតួចណាស់ និងពាក់ព័ន្ធលក្ខណៈខុសៗគ្នាជាច្រើន (រួមទាំងរយៈពេលតិចតួចនៃការឃុំខ្លួន និងប្រភេទនៃការចោទប្រកាន់បទឧក្រិដ្ឋខុសគ្នា និងមិនអាចប្រៀបធៀបគ្នាយ៉ាងងាយនោះទេ) ដែលយើងមិនអាចបង្កើតជានិន្នាការ ឬលំនាំនៃសំអាងផ្លូវច្បាប់ដែលអាចអនុវត្តបានចំពោះរឿងក្តីនេះទេ[1524]។

---

[1521] Dr. Ulrich Sieber, "របាយការណ៍អ្នកជំនាញ ៖ *ការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ៖ ការវិភាគច្បាប់ និងការអនុវត្តការផ្តន្ទាទោសដោយប្រៀបធៀប* Version 2.0/10 ខែវិច្ឆិកា ឆ្នាំ ២០០៣", IT-94-2-S (ទំព័រ 5863 - ទំព័រ 5724) ទំព័រ៧៤-៧៥។ យោងតាមរបាយការណ៍នេះ ប្រទេសម៉ិចស៊ិក ដែលមានតែយុត្តាធិការច្បាប់ស៊ីវិល អនុញ្ញាតឲ្យមានការផ្តន្ទាទោសលើសពីរយៈពេល ៣០ ឆ្នាំ ប៉ុន្តែកម្រិតការផ្តន្ទាទោសអតិបរមាត្រឹម៦០ឆ្នាំ។ *ដូចខាងលើដែរ*។

[1522] នៅតុលាការ ICTY ទាំងនេះរួមបញ្ចូល Drago Nikolić, Milan Martić, Milomir Stakić, Radislav Krstić និង Goran Jelisić។ *សូមមើល* បញ្ជីរាយឈ្មោះសេចក្តីសម្រេច <http://www.icty.org/sid/10095>។ នៅតុលាការ ICTR ទាំងនេះរួមបញ្ចូល Hassan Ngeze, Joseph Kanyabashi, Theoneste Bagosara, Jean-Bosco Barayagwiza,Laurent Semanza, Juvénal Kajelijeli និង Siméon Nchamihigo។

[1523] នៅតុលាការ ICTY ទាំងនេះរួមបញ្ចូល Milomir StakićandGoran Jelisić។ *សូមមើល* បញ្ជីរាយឈ្មោះសេចក្តីសម្រេច នៅគេហទំព័រ <http://www.icty.org/sid/10095>។ នៅតុលាការ ICTR នេះរួមបញ្ចូល Juvénal Kajelijeli។

[1524] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ F1/3.1 ទំព័រ ៦៤ ដល់ ៦៥ (ភាសាអង់គ្លេស) (សហព្រះរាជអាជ្ញាអន្តរជាតិ កត់សម្គាល់ថា ការបំពារបំពានលើសិទ្ធិរបស់ជនជាប់ចោទនៅក្នុងរឿងក្តីមួយចំនួននៅតុលាការ ICTR គឺ "មិនសូវធ្ងន់ធ្ងរដូចនៅក្នុងរឿងក្តីនេះទេ")។ *សូមមើល ឧទា.* សាលដីកាលើ*រឿងក្តី Kajelijeli* កថាខណ្ឌ ៣២៣ ដល់ ៣២៤ (បន្ធូរបន្ថយទោសពីការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលពីរជីវិត និងការដាក់ទោសជាប់ពន្ធនាគាររយៈពេល ១៥ឆ្នាំ ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការញុះញង់ជាសាធារណៈឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការ

00798895



២៩. បើផ្អែកតាមការពិចារណាទាំងនេះ ការអនុវត្តការផ្តន្ទាទោសពិតប្រាកដនៅតុលាការ *មិនអចិន្ត្រៃយ៍* គឺមិនច្បាស់លាស់គ្រប់គ្រាន់ ឬសមស្របគ្រប់គ្រាន់ដើម្បីចោទជាសំណួរចំពោះការកំណត់ទោសរយៈពេលត្រឹមសាមសិបឆ្នាំ ដែលកំណត់ដោយច្បាប់កម្ពុជាបាននោះទេ[1525]។ ទាក់ទិននឹងបញ្ហានេះ យើងកត់សម្គាល់នូវភាពស្ទាក់ស្ទើរក្នុងកម្រិតមួយនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជ អាជ្ញានៅក្នុងការបញ្ជាក់អំពីមូលដ្ឋានស្នើឲ្យមានការបន្ថែមទោសពីសាមសិបប្រាំឆ្នាំ (ជាធរមាន សាមសិបឆ្នាំ) ដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង រហូតទៅដល់សែសិបប្រាំឆ្នាំ[1526]។ យើងកត់សម្គាល់ឃើញថា វាហាក់ដូចជាមិនមានការគាំទ្រឡើយនៅក្នុងយុត្តិសាស្ត្រអន្តរជាតិ ចំពោះ តួលេខជាក់លាក់នៃការផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលសែសិបប្រាំឆ្នាំ។ ជាការពិត សហព្រះរាជអាជ្ញា បានទទួលស្គាល់

---

សម្លាប់រង្គាល ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឲ្យមកត្រឹមតែការដាក់ពន្ធនាគាររយៈពេល ៤៥ ឆ្នាំ ដោយសារតែបច្ច័យនៃការឃុំខ្លួនរយៈពេល ៣០៦ ថ្ងៃ ដោយមិនបានជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងលើរូបគាត់ ឬមិនបានផ្តល់ឲ្យបង្ហាញខ្លួនចំពោះមុខចៅក្រម)។ សាលក្រមក្នុង *រឿងក្តី* *Barayagwiza* កថាខណ្ឌ ១១០៦-១១០៧ (បន្ធូរបន្ថយទោសពីការដាក់ពន្ធនាគារអស់មួយជីវិត ដែលដាក់ចំពោះពិរុទ្ធភាពពីបទការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ការញុះញង់ដោយផ្ទាល់និងជាសាធារណៈឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់រង្គាល ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មកត្រឹមការដាក់ពន្ធនាគាររយៈពេល៣៥ឆ្នាំ ដោយសារតែការឃុំខ្លួន១៨ខែ ចំពោះការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ *សូមមើលផងដែរ* សេចក្តីសម្រេចលើ *រឿងក្តី* *Barayagwiza* *កថាខណ្ឌ ៩១ ដល់ ៩៩*។

[1525] *សូមមើល*Barbar Hola *និងអ្នកនិពន្ធដទៃទៀត,* "អង្គហេតុ និងទូរលេខនៃការផ្តន្ទាទោសអន្តរជាតិ៖ ការផ្តន្ទាទោសនៅតុលាការ ICTY និង ICTR", ការវិភាគទៅលើរបបនៃការប្រកាសទោសនៅ តុលាការ ICTY និង ICTR។

[1526] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១ ឯកសារ F1/3.2 ទំព័រ ៥១ (បន្ទាត់ ២ ដល់ ២០)(សហចៅក្រមអន្តរជាតិដកស្រង់រឿងក្តីពីរដើម្បីគាំទ្រដល់សំណើដាក់ពន្ធនាគាររយៈពេល ៤៥ ឆ្នាំ ដែលរឿងក្តី មួយក្នុងចំណោមរឿងក្តីទាំងពីរនោះមានការផ្តន្ទាទោសរយៈពេល ៣៥ ឆ្នាំ) ទំព័រ ៥២ (បន្ទាត់ ១៧) ដល់ ទំព័រ ៥៣ (បន្ទាត់ ១១) (សហព្រះរាជអាជ្ញា មិនជំទាស់ឡើយប្រសិនបើអង្គជំនុំជម្រះត្រូវសម្រេចចេញជាតួលេខផ្សេង (...) ដរាបណាមានការ បន្ថែមទោសទៅលើរយៈពេល ៣៥ ឆ្នាំ") (បន្ថែមលើសំណើសុំការដាក់ពន្ធនាគារ ៤៥ ឆ្នាំ ដែលថា ប្រសិនបើយកមកពិចារណា ស្ថានសម្រាល់ទោសអាចកាត់បន្ថយចំនួនប្រាំឆ្នាំទៀត)។

00798896



បញ្ហានេះនៅក្នុងដីកាសន្និដ្ឋានបញ្ចប់សវនាការដេញដោល[1527] ហើយបានជ្រើសរើស "គោរពតាមឧត្តមគតិរបស់អង្គជំនុំជម្រះ" ទាក់ទងទៅនឹងការកាត់បន្ថយទោសដ៏ច្រើននេះ[1528] ម៉្យាងវិញទៀត វានឹងមានលទ្ធផលជាក់ស្តែងយ៉ាងច្បាស់លាស់បំផុតអំពីការបន្ថែមទោសបែបនេះ៖ ដែលថា ជនជាប់ចោទមានអាយុហុកសិបប្រាំពីរ (៦៧) ឆ្នាំ នៅត្រឹមកាលបរិច្ឆេទនៃការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង នឹងមិនទំនងជាទទួលបាននូវផលប្រយោជន៍ពីដំណោះស្រាយដែលបានផ្តល់ឲ្យឡើយ។ ដូច្នេះ ដំណោះស្រាយនឹងគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ[1529]។ ដោយយោងទៅលើហេតុផលទាំងនេះ យើងពិចារណាឃើញថា របបផ្តន្ទាទោសតាមច្បាប់ជាតិផ្តល់នូវគោលការណ៍ណែនាំដ៏មានតម្លៃទៅដល់ ក្របខណ្ឌនៃការផ្តន្ទាទោសរបស់ អ.វ.ត.ក និងកាត់បន្ថយការព្រួយបារម្ភអំពីការសម្រេចតាមតែទំនើងចិត្ត។

៣០. ចុងក្រោយ ដំណោះស្រាយដែលយើងចង់បាន មិនបានរារាំងអណត្តិរបស់តុលាការនេះ ដែលមានគោលបំណងកាត់សេចក្តីចំពោះមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណា ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងពេលរបបនោះទេ[1530]។ ដំណោះស្រាយរបស់យើង គឺដើម្បីធានាថា ឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយ កាំង ហ្កេកអ៊ាវ ត្រូវបានថ្កោល

[1527]ដីកាសន្និដ្ឋានបញ្ចប់សវនាដេញដោល ឧបសម្ព័ន្ធ ១ ដល់ ៥ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារលេខ E159/9, កថាខណ្ឌ ៤៦៩ ("យុត្តិសាស្ត្រពាក់ព័ន្ធ មិនបានលើកឡើងនូវការណែនាំច្បាស់លាស់ទាក់ទងទៅនឹងការកំណត់អំពីសំណងក្នុងករណីនេះឡើយ")។

[1528]ដីកាសន្និដ្ឋានបញ្ចប់សវនាដេញដោល ឧបសម្ព័ន្ធ ១ ដល់ ៥, កថាខណ្ឌ ៤៧២។

[1529]*សូមមើល*ជើងទំព័រ ១៥០០ ដូចខាងលើ ដកស្រង់ក្នុងចំណោមរឿងក្តីផ្សេងៗ *រឿងក្តី Menesheva* ទល់នឹងប្រទេសរុស្ស៊ី, កថាខណ្ឌ ៧៦ (ដំណោះស្រាយប្រាកដជាអាចជាការផ្តល់នូវសំណង"។ ដំណោះស្រាយដែលទំនងជាមិនស្តែងឲ្យចេញជាសំណងជាក់ស្តែងនោះ គឺ "មានលក្ខណៈជាទ្រឹស្តី និងជាការបំភាន់បញ្ឆោត" និងមិនបំពេញលក្ខខណ្ឌតម្រូវរបស់អនុសញ្ញា ឡើយ)។

[1530]មាត្រា ១ នៃកិច្ចព្រមព្រៀងរវាង អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ ដូចដែលសហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ ការបំពារបំពានលើសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ទោះបីជាការបំពារបំពានធ្ងន់ក៏ដោយ ក៏មិនអាចធ្វើជាយុត្តិកម្មសម្រាប់ដោះលែង បើពិចារណាអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលផ្តន្ទាទោសចំពោះជនជាប់ចោទ។ *សូមមើល* ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧, ឯកសារ C3, កថាខណ្ឌ ២១។

ទោសយ៉ាងខ្លាំង និងផ្តន្ទាទោសជាដាច់ខាត។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវធានាថា ការផ្តន្ទាទោសចំពោះគាត់ ស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានយុត្តិធម៌ដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ និងធានាថា តុលាការនេះ បន្តធ្វើជាគំរូមួយសម្រាប់ការជំនុំជម្រះដោយយុត្តិធម៌ ដោយគោរពយ៉ាងត្រឹមត្រូវចំពោះសិទ្ធិរបស់ជនជាប់ចោទ។

៣១. យើងសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំពោះ កាំង ហ្កេក អ៊ាវ ដោយបន្ធូរបន្ថយមកត្រឹមរយៈពេលសាមសិបឆ្នាំ ដែលជាការទូទាត់ចំពោះការរំលោភបំពានដោយអាជ្ញាធរក្នុងស្រុកដល់សិទ្ធិសារវន្តរបស់គាត់។ ជាការកត់សម្គាល់ផ្នែកបច្ចេកទេស យើងមានបំណងលើកឡើងបន្ថែមលើនេះថា យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ការកាត់បន្ថយទោសរបស់តុលាការជំនុំជម្រះក្តី មិនបានធ្វើយុត្តិកម្មដល់ការដាក់ទោសពីរដាច់ដោយឡែកពីគ្នាគឺ ទណ្ឌកម្មដំបូង និងទណ្ឌកម្មដែលត្រូវកាត់បន្ថយ[1531]។ ទណ្ឌិតទទួលទណ្ឌកម្មតែមួយ។ ការពិចារណាដែលនាំទៅដល់ការសម្រេចទោសបែបនេះ ដែលរួមទាំងការផ្តន្ទាទោសនៅក្នុងលក្ខណៈអរូបិយ និងការកាត់បន្ថយដែលត្រូវផ្តល់បន្តបន្ទាប់នេះ បានបង្ហាញនៅក្នុងផ្នែកសំអាងហេតុ។

---

[1531] *សូមមើល* មាត្រា ៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ("តុលាការត្រូវពិនិត្យ [...] ទណ្ឌកម្ម") (គូសបញ្ជាក់បន្ថែម)។ របាយការណ៍គណៈកម្មការ Venice, កថាខណ្ឌ ២៤០ ("នៅក្នុងមូលហេតុដែលចៅក្រមប្រើ ពេលធ្វើការវាយតម្លៃពីរយៈពេលនៃកិច្ចដំណើរការនីតិវិធី ទំនាក់ទំនងរវាងរយៈពេលនៃកិច្ចដំណើការនីតិវិធី និងការវាយតម្លៃលើទណ្ឌកម្ម គប្បីធ្វើឡើងឱ្យបានច្បាស់លាស់ ហើយសមស្របដោយបង្ហាញ តើទណ្ឌកម្មអ្វីត្រូវបានដាក់នោះ ប្រសិនបើយល់ឃើញថា រយៈពេលនោះមានលក្ខណៈសមហេតុផលនោះ)។

# ១០.ឧបសម្ព័ន្ធ I: សាវតានីតិវិធីលើបណ្ដឹងសាទុក្ខ[1532]

## ក.បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

១. នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញា បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ[1533] ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយស្នើសុំឱ្យកែតម្រូវការភ័ន្តច្រឡំលើអង្គ ច្បាប់ និងបង្កើនការផ្ដន្ទាទោសបន្ថែមទៀត។ នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ អង្គជំនុំជម្រះតុលាការកំពូល ទទួលយកសំណើរបស់សហព្រះរាជអាជ្ញា[1534]សុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន[1535]។ នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញា បានដាក់ សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន[1536]។ មិនមានសារណាតបណាមួយ ត្រូវបានធ្វើឡើងប្រឆាំងនឹង សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាឡើយ។

---

[1532]សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ឧបសម្ព័ន្ធទី I លើកឡើងសាវតានីតិវិធីលម្អិតចាប់តាំងពីពេលចាប់ខ្លួន ការផ្ទេរ និងការឃុំខ្លួន កាំង ហ្គេកអ៊ាវ តាមរយៈ និងរួមបញ្ចូលក្នុងការចេញសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

[1533]សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងករណីរឿង កាំង ហ្គេកអ៊ាវ *ហៅ*ឌុច, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២ ០១០, ឯកសារលេខ E188/2។

[1534]សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រសម្រាប់សេចកក្ដីសន្និដ្ឋានបណ្ដឹងសាទុក្ខរបស់ខ្លួន ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ F5។ សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រ ដើម្បីដាក់សេចក្ដីសន្និដ្ឋានបណ្ដឹងសាទុក្ខរបស់ខ្លួន ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ F5/1។

[1535]សេចក្ដីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រ សម្រាប់ការដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ F5/2។

[1536]បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្ដីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ F10។

00798899



## ខ.បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ

២. នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០ សហមេធាវីការពារក្តីជនជាប់ចោទ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[1537] ដោយស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលដោះលែងជនជាប់ចោទ ចាត់ទុកជនជាប់ចោទជាសាក្សីនៃរបបកម្ពុជាប្រជាធិបតេយ្យ និងចាត់ទុករយៈពេលឃុំខ្លួនថាជា "ការថែរក្សាការពារសាក្សី ទៅវិញ"។

៣. នៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១០ សហមេធាវីការពារក្តីជនជាប់ចោទបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលពន្យាពេលដាក់សារណាបណ្តឹងសាទុក្ខចំនួន ៣០ ថ្ងៃ បន្ថែមទៀត[1538]។ នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ អង្គជំនុំជម្រះតុលាការកំពូលអនុញ្ញាតតាមសំណើសុំពន្យាកាលបរិច្ឆេទសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខ និងបានយល់ឃើញថា សារណាតបរបស់សហព្រះរាជអាជ្ញា[1539]មានភាពយឺតយ៉ាវជាងការកំណត់ ដូច្នេះសារណាតបនេះ មិនអាចទទួលយកបានថាត្រឹមត្រូវតាមច្បាប់នោះទេ[1540]។

---

[1537]សេចក្តីជូនដំណឹងរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ E188/8។

[1538]សំណើរបស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" សុំពន្យារពេលកំណត់សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ F6។

[1539]សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច សុំបន្ថែមពេលវេលាដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ F6/1។

[1540]សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ *ហៅ* ឌុច សុំពន្យារកាលបរិច្ឆេទសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ F6/2។

៤. នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហមេធាវីការពារក្តីជនជាប់ចោទបានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[1541]។ ការកែតម្រូវចំនួនពីរជាបន្តបន្ទាប់លើសំណៅបកប្រែជាភាសាអង់គ្លេសត្រូវបានដាក់នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០ និងថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១១[1542]។

៥. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានស្នើសុំ[1543]អង្គជំនុំជម្រះតុលាការកំពូលផ្តល់ការអនុញ្ញាតពន្យារយៈពេល ១៥ ថ្ងៃទៀត ដើម្បីដាក់សារណាតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតតាមសំណើសុំនៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១០[1544]។

៦. នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ បានដាក់សារណាតបរបស់ខ្លួនទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ[1545]។

---

[1541] សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារលេខ F14។ បណ្តឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្តីត្រូវបានដាក់ជាភាសាខ្មែរនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០ ហើយបណ្តឹងសាទុក្ខនេះជាភាសាអង់គ្លេសដែលត្រូវបានកែប្រែចុងក្រោយ ត្រូវបានដាក់នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១១។

[1542] សំណើសុំកែសម្រួលលើសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ F14/Corr-1 ។ សំណើសុំកែសម្រួលលើសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១១ F14/Corr-2។

[1543] ពាក្យសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់ចម្លើយតបរបស់ខ្លួនចំពោះសារណាបណ្តឹងឧទ្ធរណ៍របស់សហមេធាវីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារលេខ F14/1។

[1544] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារលេខ F14/3។

[1545] សារណាតបរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី ឌុច ប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ភាសាខ្មែរដាក់នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១០, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ F14/2។

៧. នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានដាក់សារណាតបរបស់ខ្លួនទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ[1546]។

៨. អង្គជំនុំជម្រះតុលាការកំពូល បានអនុញ្ញាតឱ្យសហមេធាវីការពារក្ដីជនជាប់ចោទដាក់ការឆ្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមមាត្រា ៨(៤)នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខអ.វ.ត.ក (វិសោធនកម្មលើកទី ៥) នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០[1547]។ នៅថ្ងៃ ទី ១៤ ខែ មករា ឆ្នាំ ២០១១ សហមេធាវីការពារក្ដីជនជាប់ចោទបានដាក់ការឆ្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា[1548]។

៩. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់សេចក្ដីអង្កេតទៅលើសារណាបណ្ដឹងសាទុក្ខជាភាសាអង់គ្លេសរបស់ជនជាប់ចោទដែលបានធ្វើការកែតម្រូវ[1549]។

## គ. បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១

១០. នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ បានដាក់ "បណ្ដឹងសាទុក្ខភ្លាមៗ"ទាក់ទងនឹងការបដិសេធនូវឋានៈដើមបណ្ដឹងរដ្ឋប្បវេណី[1550]។ អង្គជំនុំជម្រះតុលាការ

---

[1546]សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារក្ដីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ភាសខ្មែរដាក់នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១០, ភាសាអង់គ្លេសដាក់ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១០, ឯកសារលេខ F14/4។

[1547]សេចក្ដីសម្រេចផ្ដល់ឱកាសឲ្យសហមេធាវីការពារក្ដីជនជាប់ចោទធ្វើការឆ្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារលេខ F14/4/1។

[1548]ការឆ្លើយតបរបស់សហមេធាវីការពារក្ដីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១០, ភាសាខ្មែរដាក់ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ F14/4/2។

[1549]សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញាទៅលើសារណាបណ្ដឹងសាទុក្ខច្បាប់កែសម្រួលជាភាសាអង់គ្លេស ធ្វើឡើងដោយសហមេធាវីការពារក្ដី កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F14/5។

កំពូលបានសម្រេចកំណត់ចរិតលក្ខណៈនៃបណ្ដឹងសាទុក្ខភ្លាមៗនេះ ថាជាសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងជាសារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១០[1551]។

១១. យោងតាមការអញ្ជើញរបស់អង្គជំនុំជម្រះតុលាការកំពូល[1552]នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ បានជូនដំណឹងដល់អង្គជំនុំជម្រះតុលាការកំពូលថា ពួកគាត់មិនមានបំណងដាក់សារណាបន្ថែម ឬពង្រីកបញ្ហាដែលបានលើកឡើងបន្ថែមលើបញ្ហាសំណងនោះទេ[1553]។

១២. នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ បានដាក់សំណើសុំដកវិធានការការពារខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី E2/62[1554] ដែលសំណើនេះ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលយល់ព្រមតាមកាលពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១[1555]។

---

[1550]បណ្ដឹងសាទុក្ខភ្លាមៗរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ១ ចំពោះការសម្រេចដកឋានៈរបស់ ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ F8។ ទោះបីជាបណ្ដឹងសាទុក្ខរបស់ ក្រុម ១ នេះ បានដាក់ពីដំបូង នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០ បណ្ដឹងនេះបានដាក់សារជាថ្មីនៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ដោយដាក់បញ្ចូលលិខិតប្រគល់ ដែលចុះហត្ថលេខាដោយដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៩ នាក់ នៅក្នុង ក្រុម ១។

[1551]សេចក្ដីសម្រេចស្ដីពីការកំណត់ចរិតលក្ខណៈនៃបណ្ដឹងសាទុក្ខភ្លាមៗរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ ចំពោះការសម្រេចពីឋានៈនៃដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ F8/1។

[1552]សេចក្ដីសម្រេចស្ដីពីការកំណត់ចរិតលក្ខណៈបណ្ដឹងសាទុក្ខភ្លាមៗរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ ចំពោះការសម្រេចពីឋានៈនៃដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ F8/1, កថាខណ្ឌ ៦។

[1553]សារណាបន្ថែមរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ ចំពោះសេចក្ដីជូនដំណឹងអំពីគោលបំណង, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ F12។

[1554]សំណើរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ ស្នើសុំដកវិធានការការពារ, ឯកសារលេខ E2/62 ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F23។

## ឃ.បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២

១៣. នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បាន ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខលើកទីមួយរបស់ខ្លួន[1556] ទាក់ទងនឹងការទទួលយក ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០ មេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ដែលកំណត់ ត្រឹមតែការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥ រូប ប៉ុណ្ណោះ[1557]។

១៤. នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បាន ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខលើកទីពីរ[1558] ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គ ជំនុំជម្រះតុលាការដំបូង ដែលបានបដិសេធចោលសំណើសុំសំណងភាគច្រើនរបស់ពួកគាត់។ សារណាបណ្តឹងសាទុក្ខលើកទីពីរប្រឆាំងនឹងសាលក្រមទាក់ទងនឹងសំណងនេះ[1559] ត្រូវបាន ដាក់កាលពីថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១០។

១៥. នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បាន ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខលើកទីបី តាងនាមឱ្យដើមបណ្តឹងរដ្ឋប្បវេណីលោក ជុំ

---

[1555]សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី ១ ស្នើសុំលុបចោលវិធានការការពារ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F23/1។

[1556]សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ E188/6។

[1557]បណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម-សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ F11។

[1558]សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ លើសាលក្រមទាក់ ទិន នឹងសំណង ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ E188/14។

[1559]បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមស្តីពីសំណង ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារលេខ F13។

ស៊ីវ៉ាត ចំពោះការខកខានក្នុងការបញ្ចូលឈ្មោះប្អូនស្រីថ្លៃ និងឈ្មោះកូនរបស់គាត់ទៅក្នុងសាលក្រម[1560]។

## ខ.បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣

១៦. នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ទាក់ទងនឹងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការទាមទារសំណង[1561]។ នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១០ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ បានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[1562]។

១៧. នៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣បានដាក់សារណាបន្ថែមស្តីពីសំណង[1563]។

## ច.ភស្តុតាងបន្ថែម

១៨. មេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ក្រុម ២ និងក្រុម ៣ បានដាក់សំណើសុំដាក់ភស្តុតាងបន្ថែម[1564] មកកាន់អង្គជំនុំជម្រះតុលាការកំពូល។ នៅថ្ងៃទី ២៥ និងថ្ងៃទី ២៩

---

[1560]សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ E188/12។ សេចក្តីជូនដំណឹងនេះត្រូវបានបញ្ជាក់ដោយអ៊ីមែលថា ជាបណ្តឹងសាទុក្ខលើអង្គសេចក្តី។

[1561]សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣, ភាសាខ្មែរដាក់ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ E188/4។

[1562]សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣៖ សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមចេញថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ភាសាខ្មែរដាក់ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារលេខ F9។

[1563]សារណាបន្ថែមស្តីពីសំណង, ភាសាខ្មែរដាក់ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ៣០ ខែ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F25។

[1564]សំណើសុំរបស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ *ហៅ* ឌុច សុំឲ្យទទួលស្គាល់ភស្តុតាងថ្មី ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ F2/2។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំរបស់សហមេធាវីការពារក្តី កាំង

ខែ មីនា ឆ្នាំ២០១១ និងថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១ អង្គជំនុំជម្រះតុលាការកំពូលបាន ចេញសេចក្តីសម្រេចទទួលយកភស្តុតាងបន្ថែម ដែលបានស្នើសុំដោយម្ចាស់បណ្តឹងសាទុក្ខ ទាំងនេះ[1565]។

## ឆ.សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី

១៩. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០ ផ្នែកគាំពារការការពារក្តីបានដាក់សំណើសុំ[1566]ដាក់ *សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*។ សហព្រះរាជអាជ្ញាបានឆ្លើយតប[1567] នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០។

---

ហុកអ៊ាវ *ប៉ោ* ឌុច សុំឲ្យទទួលស្គាល់ភស្តុតាងថ្មី និងឧបសម្ព័ន្ធ ក ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ F2/2/1។ សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ពាក់ព័ន្ធនឹង សំណើសុំរបស់សហព្រះរាជអាជ្ញាសុំដាក់ភស្តុតាងបន្ថែម ដែលគាំទ្រលើបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រម ចុះ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ F2/3។ បណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធរបស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១១ ឯកសារ (ស្នើ សុំឲ្យទទួលយកភស្តុតាងបន្ថែមនៅក្នុងកថាខណ្ឌ ៧១ ដល់ ៨៦ កថាខណ្ឌ ១០៥ កថាខណ្ឌ ១០៧ ដល់ ១០៨)។ សំណើសុំ ដាក់ភស្តុតាងបន្ថែមដើម្បីគាំទ្រសារណាបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣, ភាសាខ្មែរដាក់នៅ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១, ភាសាអង់គ្លេសដាក់នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/1។ សំណើរបស់ដើមបណ្តឹងរដ្ឋ ប្បវេណីក្រុម ១ សុំដាក់ភស្តុតាងបន្ថែមដើម្បីគាំទ្របណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/5។ ប្រតិចារឹកសវនាការលើបណ្តឹងសាទុក្ខចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ F1/4.1 ទំព័រ ៩៥ ដល់ ៩៨ (ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១) ទំព័រ ៦៩, ៩០ (ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣)។

[1565]សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ ក្រុម ២ និង ក្រុម ៣ ដើម្បីសុំឲ្យទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/4។ សេចក្តីសម្រេចលើ សំណើសុំបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ សុំឲ្យទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F2/5/1។ សេចក្តីសម្រេចដាក់ភស្តុតាងបន្ថែមដោយទទួលយកតាមរយៈសេចក្តីសម្រេចដោយផ្ទាល់មាត់របស់ អង្គជំនុំជម្រះនៅក្នុងពេលសវនាការលើបណ្តឹងសាទុក្ខ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១, ឯកសារ លេខ F2/6។ ប្រតិចារឹក សវនាការលើបណ្តឹងសាទុក្ខចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារ F1/4.1 ទំព័រ ២៨ ដល់ ៣០ (ពាក់ព័ន្ធនឹងដើមបណ្តឹង រដ្ឋប្បវេណីក្រុម ១, ទំព័រ ៦៩ ដល់ ៧២ (ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣) (ភាសាអង់គ្លេស)។

[1566]សំណើរបស់អង្គភាពគាំពារការការពារក្តីសុំដាក់*សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* នៅអង្គជំនុំជម្រះតុលា ការកំពូល, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ F7។

២០. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្ដីសម្រេចរបស់ខ្លួន[1568]លើសំណើសុំដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី ដោយយល់ឃើញថា *សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* ត្រូវតែមិនជាប់ពាក់ព័ន្ធនឹងតុលាការ ឬការិយាល័យណាមួយរបស់ តុលាការឡើយ។ អង្គជំនុំជម្រះយល់ឃើញថា ដោយសារជនជាប់ចោទត្រូវបានតំណាងដោយសហមេធាវីជាតិពីររូប លទ្ធភាពសមស្របតែមួយគត់ដែលផ្នែកគាំពារការការពារក្ដី អាចបំពេញអណត្តិរបស់ខ្លួន គឺការផ្ដល់ជំនួយ និងការគាំទ្រផ្នែកច្បាប់ ដល់កាំង ហ្គេកអ៊ាវ និងសហមេធាវីការពារក្ដី ដោយអនុលោមតាមវិធាន ១១(២)(ញ) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ សំណើសុំនេះ ត្រូវបានបដិសេធចោល។

២១. នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ផ្នែកគាំពារការការពារក្ដី បានដាក់សំណើសុំដាក់*សារណារបស់អ្នកដែលមិនមែនជាគូភាគីនៃរឿងក្ដី*ជាលើកទីពីរ[1569] ដោយស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យអញ្ជើញ ការដាក់*សារណាមួយ ឬច្រើនរបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដី*ពីសំណាក់ភាគីទីបីដែល ឯករាជ្យ ដើម្បីធានាពី“ការបង្ហាញពេញលេញនូវអំណះអំណាងផ្នែកច្បាប់ទាក់ទងនឹងបញ្ហានានា...”[1570]។ សហព្រះរាជអាជ្ញាបានឆ្លើយតប[1571]នៅថ្ងៃទី ០៣ ខែ

---

[1567]សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំរបស់អង្គភាពគាំពារការការពារក្ដី ដើម្បីដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដីទៅអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ F7/1។

[1568]សេចក្ដីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្ដី សុំដាក់សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្ដីមកកាន់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារលេខ F7/2។

[1569]អង្គភាពគាំពារការការពារក្ដី ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលអនុវត្តអំណាចរបស់ខ្លួន ក្រោមវិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ F16។

[1570]សំណើរបស់អង្គភាពគាំពារការការពារក្ដីសុំអង្គជំនុំជម្រះតុលាការកំពូលអនុវត្តអំណាចរបស់ខ្លួន ក្រោមវិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ F16, កថាខណ្ឌ ១៦។

[1571]សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គភាពគាំពារការការពារក្ដី សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលអញ្ជើញឱ្យដាក់*សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដី* ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ F16/1។

កុម្ភៈ ឆ្នាំ ២០១១ ហើយផ្នែកគាំពារការការពារក្តី បានដាក់ការឆ្លើយតបរបស់ខ្លួននៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០១១[1572]។

២២. អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសម្រេចរបស់ខ្លួនលើសំណើលើកទីពីរសុំដាក់ *សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១១ ដោយយល់ឃើញថា វាមិនសមស្របក្នុងការអញ្ជើញឱ្យដាក់*សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* ផ្អែកតាមវិធាន ៣៣(១) នៃវិធានផ្ទៃក្នុងនោះ[1573]។

២៣. នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១១ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសម្រេចរបស់ខ្លួនបដិសេធសំណើរបស់ លោក Wayne Jordash សុំការអនុញ្ញាតដាក់សារណារបស់*អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី*[1574]។

## ៥.សវនាការបណ្តឹងសាទុក្ខ

២៤. កិច្ចប្រជុំរៀបចំសវនាការលើបណ្តឹងសាទុក្ខបានធ្វើឡើងនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១[1575] ហើយសវនាការលើអង្គសេចក្តីបានធ្វើឡើងរយៈពេលបីថ្ងៃ ចាប់តាំងពីថ្ងៃទី ២៨ ដល់ថ្ងៃទី

---

[1572] ការឆ្លើយតបរបស់អង្គភាពគាំពារការការពារក្តីចំពោះសារណាតបរបស់សហព្រះរាជអាជ្ញា ដែលធ្វើឡើងតបទៅនឹងសំណើរបស់អង្គភាពគាំពារការការពារក្តីសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តអំណាចរបស់ខ្លួន តាមវិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ F16/2។

[1573] សេចក្តីសម្រេចស្តីពីសំណើរបស់អង្គភាពគាំពារការការពារក្តីសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលអញ្ជើញភាគីទីបី ដែលឯករាជ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F16/3។

[1574] សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចលើពាក្យសុំដាក់*សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១១ ដាក់នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារលេខ F27។ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជូនឯកសារនេះតាមរយៈអ៊ីមែលជូនទៅលោក Jordan នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១១ នៅវេលាម៉ោង ៩:៤០ នាទីព្រឹក (ម៉ោងក្នុងស្រុក)។

[1575] ដីកាកំណត់កាលបរិច្ឆេទរៀបចំកិច្ចសវនាការលើបណ្តឹងសាទុក្ខ, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F19។ ប្រតិចារិកតំណើរការនីតិវិធីបណ្តឹងសាទុក្ខ កិច្ចប្រជុំរៀបចំសវនាការរឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ជាសម្ងាត់ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/1.1។

៣០ ខែ មីនា ឆ្នាំ ២០១១។ អនុលោមតាម"ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ"[1576] របស់អង្គជំនុំជម្រះតុលាការកំពូល សវនាការបណ្តឹងសាទុក្ខត្រូវបានចែកចេញជាបញ្ហាផ្លូវច្បាប់ចំនួនបួនដូចខាងក្រោម៖

១) យុត្តាធិការបុគ្គល (ថ្ងៃទី ១)

២) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ថ្ងៃទី ២ ពេលព្រឹក)

៣) ការកំណត់ទោស (ថ្ងៃទី ២ ពេលរសៀល) និង

៤) ដើមបណ្តឹងរដ្ឋប្បវេណី (ថ្ងៃទី ៣)។

២៥. កាំង ហ្កេកអ៊ាវ បានផ្តល់ចម្លើយផ្ទាល់ខ្លួននៅពេលដំបូងនៃថ្ងៃទី ១ និងនៅពេលបញ្ចប់នៃថ្ងៃទី ៣។ សហមេធាវីការពារក្តី កាំង ហ្កេកអ៊ាវ និងសហព្រះរាជអាជ្ញាបានលើកឡើង សេចក្តីសន្និដ្ឋានផ្ទាល់មាត់លើបញ្ហាសំខាន់ៗទាំងបួន។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីក្រុម បានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់លើបញ្ហា នៃភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសំណង។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី ៣ ក៏បានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់លើបញ្ហាយុត្តាធិការបុគ្គលដែរ[1577]។

[1576]ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ F20។ *សូមមើលផងដែរ* ដីកាចាត់តាំងចៅក្រមរបាយការណ៍ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F21។ សំណើរបស់សហព្រះរាជអាជ្ញាសុំធ្វើវិសោធនកម្មលើវិធីសាស្ត្រជាក់ស្តែងរបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីវិសាលភាពនៃការពិនិត្យលើបណ្តឹងសាទុក្ខនៅ អ.វ.ត.ក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F24។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំធ្វើ វិសោធនកម្មលើវិធីសាស្ត្រជាក់ស្តែង របស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីវិសាលភាពនៃការពិនិត្យលើបណ្តឹងសាទុក្ខនៅ អ.វ.ត.ក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ ដាក់ក្នុងសំណុំរឿង ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២, ឯកសារលេខ F24/1(តាមរយៈអ៊ីម៉ែលទៅកាន់ម្ចាស់បណ្តឹងសាទុក្ខ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ នៅម៉ោង ៥ និង ២០នាទីល្ងាច ម៉ោងក្នុងស្រុក)។

[1577]ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ថ្ងៃទី ២៨ ដល់ ៣០ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ F1/2.1, F1/3.2, F1/4.1។

សំណុំរឿងលេខៈ ០០១/១៨ កក្កដា ២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F28

## ឈ. ការប្រកាស និងការចេញសាលដីកា

២៦. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះតុលាការកំពូល បានចេញដីកាកំណត់កាលបរិច្ឆេទស្តីពីសវនាការជាសាធារណៈសម្រាប់ប្រកាសសាលដីការបស់ខ្លួន ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២[1578]។ នៅក្នុងសវនាការជាសាធារណៈដែលចុះនៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានអាននូវសាលដីកាសង្ខេប និងផ្នែកសម្រេចសេចក្តីដែលចូលស្ពាតរនៃសាលដីកានេះ[1579]។ សាលដីកាសង្ខេប និងផ្នែកសម្រេចសេចក្តីនៃសាលដីកានេះបានចម្លងជូនសាធារណៈជនផងដែរ។

២៧. អង្គជំនុំជម្រះតុលាការកំពូល បានចេញសាលដីកាទាំងមូលជាលាយលក្ខណ៍អក្សរនៅក្នុងថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ជាភាសាខ្មែរ និងភាសាអង់គ្លេស។ ចំពោះការបកប្រែជាភាសាបារាំង នឹងចេញក្នុងពេលឆាប់ខាងមុខ។

---

[1578]ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលដីកាបណ្តឹងសាទុក្ខ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ F26។

[1579]ប្រតិចារិកនៃការប្រកាសសាលដីកាចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារលេខ F1/5.1។

# ១១.ឧបសម្ព័ន្ធ II: សន្ទានុក្រម និងតារាងអក្សរកាត់

| | |
|---|---|
| **គោលការណ៍ Nuremberg ឆ្នាំ ១៩៥០** | គោលការណ៍ច្បាប់អន្តរជាតិដែលទទួលស្គាល់នៅក្នុងធម្មនុញ្ញនៃតុលាការព្រហ្មទណ្ឌ Nürnberg និងនៅក្នុងសាលក្រម។ |
| **ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦** | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ១៩៥៦) ដែលត្រូវបានឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើប្រាស់ នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៥៥ ដោយព្រះមហាក្សត្រ (ព្រះរាជក្រមលេខ ៩៣៣ នស) ព្រះរាជាណាចក្រកម្ពុជា, កម្រងឯកសារច្បាប់, ការបោះពុម្ពផ្សាយពិសេស, ឆ្នាំ ១៩៥៦, ទំព័រ ១១ ដល់ ៤០៣។ |
| **សេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីអំពើធ្វើទារុណកម្ម** | សេចក្តីប្រកាសស្តីពីការការពារជនទាំងឡាយ ដែលទទួលរងការធ្វើ ទារុណកម្ម និងអំពើដទៃទៀត ឬការដាក់ទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬមានលក្ខណៈបន្ទាបបន្ថោក, សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៣៤៥២ (XXX) ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៧៥។ |
| **អនុសញ្ញាឆ្នាំ ១៩៨៤ ប្រឆាំងនឹងអំពើធ្វើទារុណកម្ម** | អនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម និង អំពើដទៃទៀត ឬការដាក់ទណ្ឌកម្ម ដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬមានលក្ខណៈបន្ទាបបន្ថោក។ |
| **ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧** | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើប្រាស់ដោយព្រះមហាក្សត្រ នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។ |
| **ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩** | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើប្រាស់ដោយព្រះមហាក្សត្រ នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ (កន្លឹទី ១ ចូលជាធរមានអនុវត្តតែម្តង ចំណែកឯបទប្បញ្ញត្តិដទៃទៀតនៃក្រមនេះនឹងចូលជាធរមាន ១ ឆ្នាំ បន្ទាប់ពីថ្ងៃឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើប្រាស់)។ |

| | |
|---|---|
| **ជនជាប់ចោទ** | កាំង ហ្កេកអ៊ាវ *ហៅ* ឌុច។ |
| **ACHR** | អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស។ |
| **ពិធីសារបន្ថែម I** | ពិធិសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងពាក់ព័ន្ធទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលត្រូវបានអនុម័តនៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧ វ៉ុល ១១២៥ លេខលំដាប់សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ទំព័រ៤ ៣ (ចូលជាធរមាននៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៧៨)។ |
| **ពិធីសារបន្ថែម II** | ធិសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងពាក់ព័ន្ធទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលត្រូវបានអនុម័តនៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧ វ៉ុល ១១២៥ លេខលំដាប់សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ទំព័រ (ចូលជាធរមាននៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៧៨)។ |
| **ដីកាដំណោះស្រាយ ដែលត្រូវបានកែប្រែ** | ដីកានេះចេញដោយសហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿងលេខ ០០១ ដែលត្រូវបានកែប្រែដោយសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែលចោទប្រកាន់ កាំង ហ្កេក អ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨ D99/3/42។ ដីកាដំណោះស្រាយដែលត្រូវបានកែប្រែនេះ បង្ហាញពី អង្គហេតុចោទប្រកាន់សម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេច ក្នុងពេលជំនុំជម្រះក្តី។ |
| **ស.ច.ស** | សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ |
| **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣** | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ១៩៩៣) ត្រូវបានអនុម័តដោយសភាធម្មនុញ្ញ និងចុះហត្ថលេខាដោយប្រធានសភា |

| | |
|---|---|
| | ធម្មនុញ្ញ នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣។ |
| **ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង** | ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងសម្ព័ន្ធមិត្តៈ ការផ្តន្ទាទោសទៅលើបុគ្គលទាំងឡាយណា ដែលមានពិរុទ្ធពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ដែលត្រូវបានចុះហត្ថលេខានៅទីក្រុងប៊ែរឡាំង ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ ត្រូវបានបោះពុម្ពផ្សាយនៅ (ឆ្នាំ ១៩៤៦) ក្នុងព្រឹត្តិប័ត្រផ្លូវការលេខ ៣ របស់ក្រុមប្រឹក្សាគ្រប់គ្រងអាល្លឺម៉ង់ ទំព័រ ៥០ ដល់ ៥៥។ |
| **ក្រុមដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ ក្រុម ២ ក្រុម ៣** | ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៣ នាក់ បានរួមគ្នាបង្កើតជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ ក្រុម។ |
| **ដីកាដំណោះស្រាយ** | ដីកាដំណោះស្រាយចោទប្រកាន់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨, ឯកសារលេខ D99/3/42។ |
| **ប.ក.ក** | បក្សកុម្មុយនីស្តកម្ពុជា។ |
| **DC-Cam** | មជ្ឈមណ្ឌលឯកសារកម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជា |
| **មេធាវីការពារក្តី** | មេធាវីការពារក្តីជនជាប់ចោទ |
| **ក.ប (DK)** | កម្ពុជាប្រជាធិបតេយ្យ |
| **អ.វ.ត.ក** | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| **ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក** | ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដោយមានការធ្វើវិសោធនកម្មដែលប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦)។ |
| **ECHR** | អនុសញ្ញាការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលអនុម័តនៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០, វ៉ុល ២១៣ លេខលំដាប់សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ទំព័រ ២២១, (ចូលជាធរមាន នៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៥៣) |

| | |
|---|---|
| | ត្រូវបានវិសោធនកម្មដោយ ពិធីសារបន្ថែម លេខ ១១ និង ១៤។ |
| **ECtHR** | តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ |
| **e.g.** | ឧទា. (ឧទាហរណ៍)។ |
| **f.n** |ជើងទំព័រ។ |
| **Geneva Convention IV** | អនុសញ្ញាទីក្រុងហ្សឺណែវទី ៤។ |
| **IACtHR** | តុលាការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស។ |
| **ICC** | តុលាការព្រហ្មទណ្ឌអន្តរជាតិ។ |
| **ICCPR** | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលអនុម័ត នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦, វ៉ុល ៩៩៩ លេខលំដាប នៃសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ទំព័រ ១៧១, ចូលជាធរមាននៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦។ |
| **ICC Statute** | លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិអនុម័តនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨, វ៉ុល ២១៨៧ លេខលំដាបនៃសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ទំព័រ ៣ (ចូលធរមាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២)។ |
| **ICJ** | តុលាការយុត្តិធម៌អន្តរជាតិ។ |
| **ICJC** | គណៈកម្មការកាកបាទក្រហមអន្តរជាតិ។ |
| **ICTR** | តុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីកាត់សេចក្តីបុគ្គល ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តនៅលើទឹកដីរវ៉ាន់ដា និងដើម្បីកាត់ទោសប្រជាជនរវ៉ាន់ដាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរផ្សេងៗទៀត ដែលបានប្រព្រឹត្តនៅលើទឹកដីប្រទេសជិតខាង ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤។ |

| | |
|---|---|
| **ICTY** | តុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីកាត់សេចក្ដីបុគ្គល ដែលទទួលខុសត្រូវចំពោះការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តនៅក្នុងទឹកដីអតីតយូហ្គោស្លាវីពីឆ្នាំ ១៩៩១។ |
| **ILC** | គណៈកម្មការនីតិអន្តរជាតិ។ |
| **IMT** | តុលាការយោធាអន្តរជាតិ។ |
| **ធម្មនុញ្ញ IMT** | ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ សម្រាប់ការកាត់សេចក្ដីឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងទីក្រុងឡុងដ៍ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ *សម្រាប់ការកាត់សេចក្ដី និងផ្ដន្ទាទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៅចំពោះមុខតុលាការយោធាអន្តរជាតិ* ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ វ៉ុល I ទំព័រ ១០ ដល់ ១៨។ |
| **IMTFE** | តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ាឆ្នាំ ១៩៤៦។ |
| **ធម្មនុញ្ញ IMTFE** | ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៦៤, បោះពុម្ពផ្សាយឡើងវិញដោយនាយកនិពន្ធ Neil Boister និង Robert Cryer ឯកសារស្ដីពីតុលាការយោធាអន្តរជាតិតូក្យូៈ *ធម្មនុញ្ញ ការចោទប្រកាន់ និងការកាត់សេចក្ដី* ចេញផ្សាយក្នុងសារព័ត៌មានរបស់សាលកវិទ្យាល័យ Oxford ឆ្នាំ ២០០៨។ |
| **វិធានផ្ទៃក្នុង** | វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ |
| **ម ១៣** | មន្ទីរសន្តិសុខក្នុងខេត្ត កំពង់ ស្ពឺ។ |
| **NMT** | តុលាការយោធា Nuremberg។ |
| **no.** | លេខ។ |
| **p.,pp.** | ទំព័រ។ |
| **para.,paras** | កថាខណ្ឌ។ |

| | |
|---|---|
| **អ.ប.ជ** | អង្គបុរេជំនុំជម្រះ។ |
| **រ.រ.ក** | រាជរដ្ឋាភិបាលកម្ពុជា។ |
| **RPE** | វិធានស្តីពីនីតិវិធី និងភស្តុតាង។ |
| **ស ២១** | បរិវេណនៃមន្ទីរ ស ២១ នៅទីក្រុងភ្នំពេញ រួមមាន (លើកលែងក្នុងករណីដែលបរិបទតម្រូវផ្សេងពីនេះ) ទាំងអគារនានាក្នុងមន្ទីរ ស ២១ ដែលបច្ចុប្បន្នជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង រួមទាំងទីតាំងបន្ទាប់បន្សំនៅបឹងជើងឯក និងមន្ទីរ ស ២៤។ |
| **ស ២៤** | ជំរំអប់រំកែប្រែព្រៃស។ |
| **អ.ជ.ត.ក** | អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ |
| **SCSL** | តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន។ |
| **អនុសញ្ញាស្តីពីទាសភាព** | អនុសញ្ញាទប់ស្កាត់ការធ្វើជំនួញទាសករ និងទាសភាពដែលបានអនុម័តនៅ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩២៦ វ៉ុល ៦០ លេខលំដាប់សម្ព័ន្ធសន្ធិសញ្ញាប្រជាជាតិ ទំព័រ ២៥៤ (ចូលជាធរមាននៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩២៧)។ |
| **អនុសញ្ញាបន្ថែមស្តីពីទាសភាព** | អនុសញ្ញាបន្ថែមស្តីពីការលប់បំបាត់ទាសភាព ការធ្វើជំនួញទាសករ និង ការរៀបចំនិងទម្លាប់អនុវត្តន៍ប្រហាក់ប្រហែលគ្នាចំពោះទាសភាព។ |
| **STL** | តុលាការពិសេសសម្រាប់ប្រទេសលីបង់។ |
| **អនុសញ្ញាបន្ថែមស្តីពីទាសភាព** | អនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ទាសភាព និងការជួញដូរទាសការ និងស្ថាប័ន និងការអនុវត្តដែលមានលក្ខណៈប្រហែលទៅនឹងទាសភាព ដេលចុះហត្ថលេខានៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៥៦ វ៉ុល ២២៦ លេខលំដាប់សិន្ធិសញ្ញារបស់អង្គការសហប្រជាតិ ទំព័រ ២៥៤ (ចូលជាធរមាននៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩២៧)។ |

| | |
|---|---|
| ***Sui Generis Institution*** | ស្ថាប័នពិសេសមួយសម្រាប់ប្រភេទរឿងដូចគ្នា។ |
| ***Principle of Subsidiarity*** | ដែលនេះឆ្លុះបញ្ចាំងអំពីគោលការណ៍ស្តីពីបុត្រសម្ពន្ធ។ |
| **កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក** | កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជា ចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចុះហត្ថលេខា នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ (ចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥)។ |
| **UNAKRT** | ជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម។ |
| **UNCC** | គណៈកម្មការផ្តល់សំណងរបស់អង្គការសហប្រជាជាតិ។ |
| **UNESCO** | អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌។ |
| **UNWCC** | គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ។ |
| **សេចក្តីប្រកាសស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ** | សេចក្តីប្រកាសស្តីពីរបស់អង្គការសហប្រជាជាតិ ស្តីពីគោលការណ៍ មូលដ្ឋាននៃយុត្តិធម៌ សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច។ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៤០/៣៤ សម័យប្រជុំលើកទី ៤០ ឯកសារអង្គការសហប្រជាជាតិលេខ A/RES/40/34 (ថ្ងៃទី ២៩ ខែ វិច្ឆកា ឆ្នាំ ១៩៨៥)។ |
| **គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសំណង** | គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ និងសេចក្តីណែនាំស្តីពីសិទ្ធិមនុស្សក្នុងទទួលបានដំណោះស្រាយ និងសំណងសម្រាប់ ជនរងគ្រោះដោយសារអំពើរំលោភដោយ កម្រោលលើច្បាប់ស្តីពីសិទ្ធិមនុស្ស និងការរំលោភយ៉ាងធ្ងន់ធ្ងរលើ លើច្បាប់មនុស្សជាតិអន្តរជាតិ។ សេចក្តីសម្រេចរបស់មហាសន្និបាត |

| | |
|---|---|
| | លេខ ៦០/១៤៧, កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី ៦០ ឯកសារអង្គការសហប្រជាជាតិលេខ A/RES/60/147 (ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥)។ |